# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
# ព្រះអដ្ឋកថា

## ភាគ៣

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# វិនយបិដក

## និង

# សមន្តប្បាសាទិកា អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## មហាវិភង្គ

## អនិយតកណ្ឌ

## និស្សគ្គិយកណ្ឌ និង បាចិត្តិយកណ្ឌ

## ៣

## បាលីប្រែ ២-៣-៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣

## សូមនមស្ការចំពោះ

## ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ

## អនិយតកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ

អាបត្តិទាំងឡាយពីរ ឈ្មោះអនិយតនេះ មកកាន់ឧទ្ទេស ។

## អនិយតទី ១

[ ៣៣១ ] សម័យនោះ ព្រះពុទ្ធដ៏មានបុញ្ញសិរីគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលណោះ ឧទាយិដ៏មានអាយុ ជាកុលូបកភិក្ខុចូលទៅរកត្រកូល តែងចូលទៅរកត្រកូលទាំងឡាយជាច្រើនក្នុងក្រុងសាវត្ថី ។ សម័យនោះ កុមារិកានៃត្រកូលជាឧបដ្ឋាកលោកឧទាយិដ៏មានអាយុ មាតាបិតាបានផ្សំឲ្យដល់កុមារម្នាក់នៃត្រកូល ។ គ្រាក្រោយ ឧទាយិដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រចីវរ ក្នុងពេលព្រឹកព្រហាម ហើយចូលទៅរកត្រកូលនោះ លុះចូលទៅហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះទៅណាហើយ ។ មនុស្សអម្បាលនោះ បាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន កុមារិកានោះ យើងខ្ញុំឲ្យទៅកុមារនៃត្រកូលឯណោះហើយ ។ ឯត្រកូលនោះឯង ក៏ជាឧបដ្ឋាកឧទាយិដ៏មានអាយុដែរ ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ចូលទៅរកត្រកូលនោះ លុះចូលទៅដល់

ហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះ នៅឯណា ។ មនុស្សទាំងឡាយឆ្លើយថា លោកម្ចាស់ចូររកមើលចុះ កុមារិកានោះ នៅក្នុងបន្ទប់តូច ។ ទើបឧទាយិដ៏មានអាយុ តែម្នាក់ឯងចូលទៅរកកុមារិកានោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងកុមារិកាតែម្នាក់ឯងនោះ ហើយនិយាយគ្នាអស់កាលដ៏គួរ[១] និងនិយាយធម៌អស់កាលដ៏គួរ[២] ។

[ ៣៣២ ] សម័យនោះឯង នាងវិសាខា ជាម្តាយនៃមិគារសេដ្ឋី នាងមានកូនច្រើន មានចៅច្រើន ទាំងកូនក៏មិនសូវមានរោគ ចៅក៏មិនសូវមានរោគ ជាស្រីមានមង្គលដ៏ប្រសើរ ។ មនុស្សទាំងឡាយកាលបើមានធ្វើទានធំ កាលបើមានអាវាហៈ និងវិវាហមង្គលជាដើម កាលបើមានមហោស្រព មានថ្ងៃចូលវស្សានិងចេញវស្សាជាដើម តែងឲ្យនាងវិសាខា ជាម្តាយនៃមិគារសេដ្ឋី បរិភោគមុនគេជាដំបូង ។ គ្រានោះឯង នាងវិសាខា ជាមិគារមាតា គេបានអញ្ជើញឲ្យទៅកាន់ត្រកូល ជាឧបដ្ឋាកនៃឧទាយិនោះ ។ ឯនាងវិសាខា ជាមិគារមាតា បានឃើញឧទាយិដ៏មានអាយុតែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំងល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងកុមារិកាតែម្នាក់ឯងនោះ

---

១- ភិក្ខុអង្គុយជាមួយនឹងស្រីអស់ពេលដែលគ្មានអ្នកណាទៅមក ហើយនិយាយពាក្យស្និទ្ធស្នាលនឹងគ្នាថា សព្វថ្ងៃនាងឯងមិនអផ្សុកទេឬ នាងឯងមិនលំបាកចិត្តទេឬ នាងឯងមិនស្រេកឃ្លានទេឬ ដូច្នេះជាដើម ។ ២- ភិក្ខុអង្គុយជាមួយនឹងស្រីអស់ពេលដែលគ្មានអ្នកណាទៅមក ហើយនិយាយធម៌ប្រាប់ស្រីនោះថា នាងឯងត្រូវរក្សាឧបោសថសីល នាងឯងត្រូវឲ្យសលាកភត្តដូច្នេះជាដើម ។

លុះឃើញហើយបាននិយាយពាក្យនេះនឹងឧទាយិដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ការនេះ មិនមែនជាការស្វាត់កំបាំងទេ មិនសមគួរទេ លោកម្ចាស់តែមួយអង្គ មកអង្គុយលើអាសនៈដ៏ស្វាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បានជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនត្រូវការដោយធម៌នោះក៏ពិតមែនហើយ តែថា មនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ ។ ចំណែកឧទាយិដ៏មានអាយុ ទុកជានាងវិសាខា ជាមិគារមាតាថាឲ្យយ៉ាងនេះ ក៏នៅមិនអើពើសោះ ។ ទើបនាងវិសាខាជាមិគារមាតាចេញទៅ ហើយពិតរឿងនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច មានសេចក្ដីសន្ដោស ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្ទុះបន្ទាប់ថា ហេតុដូចម្ដេច ក៏ឧទាយិដ៏មានអាយុម្នាក់ឯងអង្គុយលើអាសនៈដ៏ស្វាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ។ លំដាប់នោះឯង ភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ឮថា អ្នកឯងតែម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្វាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ ។ ឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុញ្ញសិរី ទ្រង់តិះដៀលថា ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិនស្រួល មិនទំនង ។បេ។ ម្នាលមោឃបុរស ហេតុដូចម្ដេច ក៏អ្នកឯងតែម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្វាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាម

តែម្នាក់ឯង ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ តែម្នាក់នឹងម្នាក់អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបានឃើញភិក្ខុនោះ ហើយគប្បីចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ ( នោះមែន ) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាងចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកានោះមានវាចាគួរជឿបាន ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ អាបត្តិនេះ ឈ្មោះថា អនិយត ( មិនទៀង ) ។

[ ៣៣៣ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ រួចហើយ ។ មនុស្សស្រី ហៅថា មាតុគ្រាម យក្សស្រីប្រេតស្រី តិរច្ឆានញី មិនឈ្មោះថា មាតុគ្រាមទេ ដោយហោចទៅ សូម្បីទារិកាកើតក្នុងថ្ងៃនោះ ក៏ហៅថា មាតុគ្រាមដែរ មិនបាច់ពោលដល់ស្រីធំទេ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺភិក្ខុម្នាក់មាតុគ្រាមម្នាក់ ។ កំបាំងភ្នែក ស្ងាត់ត្រចៀក ហៅថា ស្ងាត់ ។ ដែលហៅថា ទីកំបាំងភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលមិនអាចនឹងឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺបុគ្គលមិនអាច

ស្តាប់ពាក្យជាប្រក្រតីបាន ។ ដែលហៅថា អាសនៈកំបាំង គឺអាសនៈដែលបិទបាំង ដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលក្តី ដោយការព័ន្ធព័ទ្ធដោយវាំងននក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ដោយវត្ថុឯណានីមួយក្តី ។ ពាក្យថា ល្មមធ្វើ ( សេវនកិច្ច ) បាន គឺភិក្ខុអាចសេពមេថុនធម្មបាន ។ ពាក្យថា អង្គុយ គឺកាលបើមាតុគ្រាមអង្គុយហើយ ភិក្ខុទៅអង្គុយជិតក្តី ដេកជិតក្តី កាលបើភិក្ខុអង្គុយហើយ មាតុគ្រាមទៅអង្គុយជិតក្តី ដេកជិតក្តី អ្នកទាំងពីរអង្គុយក្តី អ្នកទាំងពីរដេកក្តី ។

[ ៣៣៤ ] ស្រីដែលមានផលមកហើយ ( សម្រេចសោតាបត្តិផល ) ត្រាស់ដឹងសច្ចៈបួន ស្គាល់សាសនាច្បាស់ ហៅថា មានវាចាគួរជឿបាន ។ ស្រីដែលដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក ហៅថា ឧបាសិកា ។ ពាក្យថា ឃើញ គឺមើលឃើញ ។

[ ៣៣៥ ] ឧបាសិកានោះ ចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី កាលភិក្ខុទទួលប្តេជ្ញាការអង្គុយ ( នោះមែន ) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកាមានវាចាគួរជឿបាននោះ គប្បីចោទដោយអាបត្តិណា ភិក្ខុនោះ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ។

[ ៣៣៦ ] បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ហើយ លោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ។ ឯភិក្ខុនោះទទួល

ប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ( ដល់ភិក្ខុនោះ ) ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាមហើយ ឯភិក្ខុនោះ ពោលយ៉ាងនេះថា អាត្មាអង្គុយមែន តែមិនសេពមេថុនធម្មទេ វិនយធរត្រូវវិនិច្ឆ័យអាបត្តិដោយការអង្គុយ ។ បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ តែថាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យអាបត្តិដោយការដេក ។ បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ អាត្មាគ្រាន់តែឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៣៧ ] បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ បើឧបាសិកាចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាដេកមែន តែអាត្មាមិនសេពមេថុនធម្មទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។ បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោស ដោយការអង្គុយ ។ បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹង

មាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៣៨ ] បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះ ទទួលប្តេជ្ញានូវការចាប់នោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាអង្គុយមែន តែអាត្មាមិនបានចាប់ពាល់រាងកាយមាតុគ្រាមទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។បេ។ អាត្មាមិនមែនអង្គុយទេ តែថាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។បេ។ អាត្មាមិនមែនអង្គុយទេ តែថា អាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៣៩ ] បើឧបាសិកានោះចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ បើឧបាសិកាចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះ ពោលយ៉ាងនេះថា អាត្មាដេកមែន តែអាត្មាមិនចាប់ពាល់រាងកាយមាតុគ្រាមទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។បេ។ ភិក្ខុពោលថា អាត្មាមិនមែនដេកទេ តែថាអាត្មាអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។បេ។ អាត្មាមិនមែនដេកទេ តែថា អាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៤០ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់

ម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។បេ។ អាត្មាមិនមែនអង្គុយទេ តែថាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។បេ។ ថា អាត្មា មិនមែនអង្គុយទេ តែថា អាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៤១ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង ដេកលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ឯភិក្ខុនោះទទួលប្តេជ្ញាការដេកនោះ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។បេ។ អាត្មាមិនមែនដេកទេ តែថាអាត្មាអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។បេ។ អាត្មាមិនមែនដេកទេ តែថា អាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[ ៣៤២ ] ពាក្យថា អនិយត គឺមិនប្រាកដជាអាបត្តិបារាជិក ឬសង្ឃាទិសេស ឬបាចិត្តិយ ។

[ ៣៤៣ ] ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ ប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ ប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសដោយកិរិយាអង្គុយ ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរមិនត្រូវ

វិនិច្ឆ័យឡើយ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ តែប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមការអង្គុយ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

អនិយតទី ១ ចប់

# អដ្ឋកថា
# អនិយតកណ្ឌវណ្ណនា
# អលំកម្មនិយសិក្ខាបទ

*លោកដ៏មានអាយុទាំងឡាយ ម្យ៉ាងទៀត ធម៌ គឺអនិយត ២ សិក្ខាបទនេះឯង រមែងមកកាន់ឧទ្ទេស ។*

*អនិយតសិក្ខាបទទី ១ បទថា* **តេន សមយេន ពុទ្ធោ ភគវា** *ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងអនិយតសិក្ខាទបទី ១ មានវិនិច្ឆ័យដូចតទៅនេះ*

*បទថា* **កាលយុត្តំ សមុល្លបន្តោ** *សេចក្តីថា កំណត់កាលហើយពោលវាចាទាក់ទងដោយរឿងអ្នកស្រុក ក្នុងវេលាដែលបុគ្គលណាមួយ មិនបានដើរច្នេងទៅ ឬដើរច្នេងទៅមកជិតៗ គឺតាមដែលសមគួរដល់វេលាដូច្នោះជាដើមថា នាងមិនព្រួយចិត្ត មិនលំបាកចិត្ត មិនអត់ឃ្លានទេឬ ។*

*បទថា* **កាលយុត្តំ ធម្មំ ភណន្តោ** *សេចក្តីថា កំណត់កាលហើយពោលធម្មកថា ក្នុងវេលាដែលអ្នកដទៃណាមួយដើរច្នេងមក ឬដើរច្នេងទៅ គឺតាមដែលសមគួរដល់វេលាដូច្នេះ មានជាដើមថា នាងគួររក្សាឧបោសថ នាងគួរថ្វាយសលាកភត្ត ដូច្នេះ ។*

*[ ៣៣២ ] នាងវិសាខានោះ ឈ្មោះថា មានកូនច្រើន ព្រោះនាងមានកូនស្រី និងកូនប្រុសច្រើន ។ បានឮថា នាងមានកូនប្រុស ១០ និងកូនស្រី ១០ ឈ្មោះថា* **ពហុនត្តា** *ព្រោះនាងមានចៅច្រើន ។ នាងវិសាខានោះ មានកូនប្រុសស្រី ២០ នាក់ យ៉ាងណា សូម្បីកូនប្រុសស្រីរបស់នាង ក៏មានកូន*

ម្នាក់ ២០ ដូច្នោះ ។ ទើបនាងបានឈ្មោះថា មានកូន និងចៅជាបរិវារ ៤២០ នាក់ ដោយប្រការយ៉ាងនេះ ។

បទថា **អភិមង្គលសម្មតា** គឺដែលអ្នកស្រុកសន្មតថា ជាឧត្តមមង្គល ។

បទថា **យញ្ញេសុ** គឺទានតូច និងទានធំ ។ បទថា **ឆណេសុ** គឺក្នុងការងារមហោស្រព ដែលប្រព្រឹត្តទៅម្តងម្កាល មានអាវាហមង្គល និងវិវាហមង្គលជាដើម ។ បទថា **ឧស្សវេសុ** បានដល់ ក្នុងការធ្វើមហោស្រព ( សម្ពោធ ) មានអាសាឡ្ហនក្ខត្តឫក្ស និងបវារណានក្ខត្តឫក្សជាដើម ( ការធ្វើនក្ខត្តឫក្សថ្ងៃចូលវស្សា និងថ្ងៃចេញវស្សា ) ។

បទថា **បឋមំ ភោជេន្តិ** សេចក្តីថា ជនទាំងឡាយអញ្ជើញឲ្យបរិភោគមុន ញាតិសូមពរថា ក្មេងទាំងនេះ ចូរជាអ្នកមិនមានរោគ មានអាយុវែងដូចលោកយាយចុះ ដូច្នេះ ។ សូម្បីជនពួកណា ជាអ្នកមានសទ្ធាជ្រះថ្លា ជនទាំងនោះ ឲ្យភិក្ខុទាំងឡាយឆាន់ហើយ ទើបអញ្ជើញនាងវិសាខានោះឯង ឲ្យបរិភោគមុនគេបង្អស់ បន្ទាប់អំពីភិក្ខុឆាន់ហើយនោះ ។

បទថា **ន អាទិយិ** សេចក្តីថា ព្រះឧទាយិត្ថេរមិនស្តាប់ពាក្យសម្តីរបស់នាង ។ ម្យ៉ាងទៀត សេចក្តីថា មិនធ្វើការអើពើ ។

បទថា **អលំកម្មនិយេ** មានវិគ្គហៈថា ទីអន្ធយ ឈ្មោះថា **កម្មនិយ** ព្រោះអត្ថថា គួរដល់កម្ម គឺសមគួរដល់កម្ម ។ ដែលឈ្មោះថា **អលំកម្មនិយ** ព្រោះអត្ថថា អាច ដើម្បីធ្វើកម្មបាន ក្នុងអាសនៈកំបាំងដែលល្មមនឹងធ្វើកម្មបាននោះ សេចក្តីថា ក្នុងទីដែលជនទាំងឡាយ កាលនឹងធ្វើអជ្ឈាចារ អាចធ្វើ

កម្មនោះបាន ។ ដោយហេតុនោះឯង ទើបក្នុងការចែកបទនៃបទថា **អលំ-កម្មនិយេ** នោះ លោកពោលថា អាចនឹងសេពមេថុនធម្មបាន មានពាក្យអធិប្បាយថា ក្នុងទីដែលអាចសេពមេថុនធម្មបាន ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃអលំកម្មនិយសិក្ខាបទ

[ ៣៣៣ ] ពីរបទថា **និសជ្ជំ កប្បេយ្យ** បានដល់ គប្បីធ្វើការអង្គុយ អធិប្បាយថា គប្បីអង្គុយ ។ ក៏ព្រោះបុគ្គលអង្គុយមុន ហើយទើបដេក ដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ការអង្គុយ និងការដេកទាំងពីរទុកក្នុងបទភាជនៈនៃបទថា **និសជ្ជំ កប្បេយ្យ** នោះ ។

បណ្ដាបទទាំងនោះ បទថា **ឧបនិសិន្នោ** សេចក្ដីថា បុគ្គលចូលទៅអង្គុយជិតៗ នោះឯង អ្នកសិក្សាគប្បីជ្រាបថា ដេកជិត ។

ពីរបទថា **ភិក្ខុ និសិន្នេ** សេចក្ដីថា កាលភិក្ខុអង្គុយហើយ ។ ពីរបទថា **ឧភោ វា និសិន្នា** សេចក្ដីថា សូម្បីមនុស្សពីរនាក់ អង្គុយមិនមុនមិនក្រោយ ( អង្គុយព្រមគ្នា ) ។

ក្នុងសិក្ខាបទទី ១ នេះ ពាក្យថា ទីកំបាំងត្រចៀក មិនបានមកក្នុងព្រះបាលីក៏ពិត តែគប្បីជ្រាបការកំណត់ ( អាបត្តិ ) ដោយទីកំបាំងភ្នែកប៉ុណ្ណោះ ។ បើមានបុរសដឹងក្ដីអង្គុយនៅជិតមាត់ទ្វារដែលបិទក៏រក្សាអាបត្តិមិនបានឡើយ ។ តែបើអង្គុយជិតទ្វារដែលមិនបានបិទ រក្សាអាបត្តិបាន ។ ហើយមិនមែនតែទីជិតទ្វារតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីអង្គុយក្នុងឱកាសខាងក្នុងទី ១២ ហត្ថ បើ

បុគ្គលក្អែកល្អ មានចិត្តរាយមាយក្តី ផក់ទៅក្តី រក្សាអាបត្តិបាន ។ មនុស្ស ក្អែកខ្វាក់ សូម្បីនៅឈរក្នុងទីជិត ក៏រក្សាអាបត្តិមិនបាន ។ សូម្បីមនុស្សក្អែក ល្អដែលដេកលក់ ក៏គ្រប់គ្រងអាបត្តិមិនបាន ។ ចំណែកស្ត្រី សូម្បីរាប់រយ នាក់ ក៏រក្សាអាបត្តិមិនបានឡើយ ។

[ ៣៣៤ ] បទថា **សទ្ធេយ្យវចសា** ប្រែថា មានវាចាគួរជឿបាន ។ ព្រោះឧបាសិកានោះ ជាអរិយសាវិកា ដោយហេតុនោះឯង ទើបព្រះមានព្រះ ភាគត្រាស់ថា **អាគតផលា** ជាដើមទុកក្នុងបទភាជនីយ៍នៃបទថា **សទ្ធេយ្យ-វចសា** នោះ ។

ក្នុងបទថា **អាគតផលា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ឧបាសិកា នោះ ឈ្មោះថា **អាគតផលា** ព្រោះថា មានផលបានមកហើយ ។ អធិប្បាយថា អ្នកបានសោតាបត្តិផលហើយ ។

បទថា **អភិសមេតាវិនី** គឺអ្នកបានត្រាស់ដឹងសច្ចៈ ៤ ។ ឧបាសិកា នេះដឹងក្នុងសាសនា គឺត្រៃសិក្ខាល្អ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកដឹងក្នុង សាសនាល្អ ។

[ ៣៣៥ ] បទថា **និសជ្ជំ ភិក្ខុ បដិជានមានោ** សេចក្តីថា ឧបាសិកា ដូច្នេះឃើញហើយ ទើបនិយាយក៏ពិត តែភិក្ខុប្តេជ្ញាការអង្គុយតែម្យ៉ាង ព្រះ វិនយធរគប្បីកាត់អាបត្តិដោយធម៌ ៣ យ៉ាងណាមួយ កាលលោកមិនប្តេជ្ញា មិនគប្បីកាត់ ។

បទថា **យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ តេន សោ**

**ភិក្ខុ អាការេនេវ** ប្រែថា ម្យ៉ាងទៀត ឧបាសិកាមានវាចាគួរជឿបាននោះចោទដោយអាបត្តិណា ភិក្ខុនោះ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ សេចក្តីថា ឧបាសិកានោះ លើករឿងមេថុនធម្មជាដើមឡើង ព្រមដោយអាការ មានការអង្គុយជាដើម អាការឯណានីមួយ ភិក្ខុនោះក៏ប្តេជ្ញា គប្បីកាត់អាបត្តិដោយអាការយ៉ាងនោះ អធិប្បាយថា មិនគប្បីកាត់ដោយអាការត្រឹមតែពាក្យសម្តីរបស់ឧបាសិកាបែបនេះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះធម្មតា រឿងដែលឃើញយ៉ាងនោះក៏មាន ជាយ៉ាងដទៃក៏មាន ដើម្បីប្រកាសអត្ថនោះ ទើបអាចារ្យទាំងឡាយនាំរឿងមកជាឧទាហរណ៍ដូចតទៅនេះ

បានឮថា ក្នុងមល្លារាមវិហារ ព្រះថេរៈជាព្រះខីណាស្រពមួយអង្គ ទៅកាន់ត្រកូលឧបដ្ឋាក ក្នុងថ្ងៃមួយ អង្គុយហើយ នាចំណែកក្នុងផ្ទះ ។ ចំណែកឧបាសិកា ក៏ឈរផ្អែកបល្ល័ង្កសម្រាប់ដេក ។ លំដាប់នោះ ភិក្ខុកាន់បិណ្ឌបាតជាវត្តមួយអង្គ ឈរក្នុងទីជិតទ្វារ ឃើញព្រះថេរៈ មានការសម្គាល់ថា ព្រះថេរៈអង្គុយលើអាសនៈតែមួយជាមួយនឹងឧបាសិកា ទើបសម្លឹងមើលរឿយៗ ។ សូម្បីព្រះថេរៈក៏កំណត់ដឹងថា ភិក្ខុអង្គនេះ កើតមានការយល់ក្នុងអាត្មាអញថា មិនបរិសុទ្ធ ធ្វើភត្តកិច្ចហើយ ទៅកាន់វិហារ ចូលទៅកាន់លំនៅរបស់ខ្លួនហើយ នៅអង្គុយខាងក្នុងនោះឯង ភិក្ខុអង្គនោះមកហើយ ដោយតាំងចិត្តថា អញនឹងចោទព្រះថេរៈ គ្រហែម ហើយបើកទ្វារ ។ ព្រះថេរៈជ្រាបចិត្តរបស់លោក ទើបហោះឡើងលើអាកាស អង្គុយពត់ភ្នែន ផ្អែកជញ្ជាំងផ្ទះកំពូល ។

*សូម្បីភិក្ខុនោះចូលទៅខាងក្នុង ពិនិត្យមើលគ្រែ និងខាងក្រោមគ្រែ មិនឃើញព្រះថេរៈ ទើបងើយមើលខាងលើ ។ លំដាប់នោះ លោកឃើញព្រះថេរៈអង្គុយលើអាកាស ទើបពោលថា បពិត្រលោកម្ចាស់ លោកឈ្មោះថា មានឫទ្ធិច្រើនយ៉ាងនេះ សូមប្រាប់ការដែលលោកអង្គុយលើអាសនៈជាមួយមាតុគ្រាមមកសិនចុះ ទើបព្រះថេរៈពោលថា លោកដ៏មានអាយុ នេះជាទោសរបស់ចន្លោះស្រុក តែខ្ញុំមិនអាចឲ្យលោកជឿបាន ទើបធ្វើយ៉ាងនេះ លោកគួរជួយរក្សាខ្ញុំផងចុះ ព្រះថេរៈពោលយ៉ាងនេះហើយ ក៏ចុះមក ។*

*[ ៣៣៦ ] បន្ទាប់អំពីនេះទៅ បទថា* **សា ចេ ឯវំ វទេយ្យ** *ជាដើមទាំងអស់ ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងអាការនៃហេតុរបស់ការប្ដេជ្ញា ។*

*បណ្ដាបទទាំងនោះ ច្រើនបទថា* **មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោ** *សេចក្ដីថា អ្នកសេពមេថុនធម្មក្នុងមគ្គរបស់មាតុគ្រាម ។*

*បទថា* **និសជ្ជាយ ការេតព្វោ** *សេចក្ដីថា ភិក្ខុប្ដេជ្ញាការអង្គុយហើយ មិនប្ដេជ្ញាការសេពមេថុនធម្ម កុំកាត់អាបត្តិដោយមេថុនធម្មបារាជិក គប្បីកាត់ដោយអាបត្តិដែលត្រូវដោយហេតុត្រឹមតែអង្គុយ ។ អធិប្បាយថា គប្បីកាត់ដោយអាបត្តិបាចិត្តិយ គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទាំងអស់ដោយន័យនេះ ។*

*សិក្ខាបទវិភង្គនៃអលំកម្មនិយសិក្ខាបទ ចប់*

# អធិប្បាយ
# បទភាជនីយ៍នៃអលំកម្មនិយសិក្ខាបទ

[ ៣៤៣ ] បណ្តាបទ មានបទថា **គមនំ បដិជានាតិ** ជាដើមដែលត្រាស់ទុកដើម្បីទ្រង់សម្តែងការកំណត់អាបត្តិ និងអនាបត្តិ ក្នុងទីបំផុតនៃសិក្ខា-បទ ។ ពីរបទថា **គមនំ បដិជានាតិ** សេចក្តីថា រមែងប្តេជ្ញាការដើរយ៉ាងនេះថា ខ្ញុំជាអ្នកដើរទៅដើម្បីត្រេកអរចំពោះការអង្គុយក្នុងទីកំបាំង ។ បទថា **និសជ្ជំ** សេចក្តីថា រមែងប្តេជ្ញានូវការអង្គុយ ដោយសេចក្តីត្រេកអរក្នុងការអង្គុយប៉ុណ្ណោះ ។ បទថា **អាបត្តឹ** បានដល់ បណ្តាអាបត្តិទាំង ៣ អាបត្តិណាមួយ ។ ពីរបទថា **អាបត្តិយា ការេតព្វោ** សេចក្តីថា បណ្តាអាបត្តិទាំង ៣ គប្បីកាត់ដោយអាបត្តិដែលភិក្ខុប្តេជ្ញា ។

ពាក្យដ៏សេសក្នុងចតុក្កៈ ក្នុងសិក្ខាបទនេះ មានអធិប្បាយរាក់ទាំងអស់ហើយ ។

ឯក្នុងទុតិយចតុក្កៈមានវិនិច្ឆ័យដូច្នេះថា ពីរបទថា **គមនំ ន បដិជានាតិ** សេចក្តីថា រមែងមិនប្តេជ្ញាដោយអំណាចនៃសេចក្តីត្រេកអរ ចំពោះការអង្គុយក្នុងទីកំបាំង រមែងពោលថា ខ្ញុំទៅដោយការងារផ្ទាល់ខ្លួន មានសលាកភត្តជាដើម ឯឧបាសិកានោះ មកកាន់ទីកន្លែងដែលខ្ញុំអង្គុយឯង បទដ៏សេសសូម្បីក្នុងទុតិយចតុក្កៈនេះ ក៏មានអធិប្បាយរាក់ហើយដូចគ្នា ។

តែបណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទាំងពួង ដូចតទៅនេះថា កិលេសដែលអាស្រ័យមេថុនធម្ម ទ្រង់ត្រាស់ថា **រហោ និសជ្ជស្សាទោ** សេចក្តីត្រេកអរចំពោះការអង្គុយក្នុងទីកំបាំង ។ ភិក្ខុណា ប្រាថ្នាទៅកាន់សម្នាក់នៃ

មាតុគ្រាម ដោយការត្រេកអរនោះ បន្ទក់ភ្នែក ត្រូវអាបត្តិទុក្កដ ស្លៀកសំពត់ ចងវត្ថពន្ធចង្កេះ ដណ្តប់ចីវរ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ក្នុងចតុក្កៈទាំងពួង ។ កាលដើរទៅ ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។ ដើរទៅហើយ អង្គុយ ត្រូវអាបត្តិទុក្កដតែម្យ៉ាង កាលមាតុគ្រាមមកអង្គុយ ត្រូវអាបត្តិបាចិត្តិយ ។ បើស្រីនោះ ម្តងក្រោកឈរ ម្តងអង្គុយ ដោយករណីយកិច្ចឯណាមួយ ត្រូវអាបត្តិបាចិត្តិយ ក្នុងការអង្គុយ គ្រប់ៗ វារៈ ។ ភិក្ខុបំណងទៅរកស្រីណា មិនជួបស្រីនោះ ស្រីដទៃមកអង្គុយ កាលកើតសេចក្តីត្រេកអរ ក៏ត្រូវអាបត្តិបាចិត្តិយ ។ តែក្នុងមហាបច្ចរីពោលថា ព្រោះមានចិត្តមិនបរិសុទ្ធ តាំងអំពីពេលមក ជាអាបត្តិដូចគ្នា ។ បើស្រីច្រើនមកអង្គុយជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ តាមចំនួនមនុស្សស្រី ។ បើពួកស្រីទាំងនោះក្រោកចុះ ក្រោកឡើងរឿយៗ ត្រូវអាបត្តិបាចិត្តិយច្រើន តាមចំនួន និងកិរិយាដែលអង្គុយ ។ តែកាលភិក្ខុមិនកំណត់ទុក ទៅអង្គុយ ដោយតាំងចិត្តថា អញនឹងសម្រេចការត្រេកអរក្នុងទីកំបាំងជាមួយស្រីដែលអញជួបហើយ ដូច្នោះ ។ បណ្ឌិតគប្បីជ្រាបអាបត្តិច្រើន ដោយអំណាចនៃស្រីទាំងឡាយ ដែលមកហើយមកទៀត និងដោយអំណាចការអង្គុយរឿយៗ ច្រើនដង ដោយន័យដូចពោលហើយនោះឯង ។ បើភិក្ខុទៅអង្គុយដោយចិត្តបរិសុទ្ធ កើតការត្រេកអរក្នុងទីកំបាំងជាមួយស្រីដែលមកកាន់សម្នាក់ ហើយអង្គុយ មិនត្រូវអាបត្តិឡើយ ។ សមុដ្ឋានជាដើម ដូចគ្នានឹងបឋមបារាជិក សិក្ខាបទនោះឯង ។

អលំកម្មនិយសិក្ខាបទ ចប់

# វិនយបិដក

## អនិយតទី ២

[ ៣៨៤ ] សម័យនោះ ព្រះពុទ្ធដ៏មានបុណ្យសិរី គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិដ៏មានអាយុគិតថា កាលដែលភិក្ខុម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំងល្មមធ្វើ ( សេវនកិច្ច ) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ( ក៏ខ្ញុំឧទាយិនោះ ) តែម្នាក់ឯងទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងកុមារិកាតែម្នាក់ឯងដដែលនោះ និយាយសមគួរតាមកាល និយាយធម៌សមគួរតាមកាល ។ នាងវិសាខាជាមិគារមាតា គេបានអញ្ជើញទៅកាន់ត្រកូលនោះ អស់វារៈជាគម្រប់ពីរដងទៀត ។ នាងវិសាខាជាមិគារមាតា បានឃើញឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងកុមារិកា ម្នាក់ឯងដដែលនោះ លុះឃើញឧទាយិដ៏មានអាយុហើយ បានពោលពាក្យនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កម្មដែលលោកធ្វើនេះ មិនមែនជាកម្មស្ងាត់កំបាំងទេ មិនសមគួរទេ លោកម្ចាស់ម្នាក់ឯង ទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនត្រូវការដោយ ( មេថុន ) ធម៌នោះក៏ពិតមែន តែថាមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ ។ ឧទាយិដ៏មានអាយុទុកជានាងវិសាខាជាមិគារមាតា ស្តីឲ្យយ៉ាងនេះក៏ដោយ ក៏នៅតែមិនអើពើឡើយ ។ គ្រានោះឯង នាងវិសាខាជាមិគារមាតា ចេញទៅហើយ ពិតដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស

តិះដៀល បន្ទះបន្ទាប់ថា មិនគួរសោះ ឧទាយិដ៏មានអាយុម្នាក់ឯង នឹងទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ។ ទើបភិក្ខុទាំងឡាយនោះក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧទាយិ ឮថា អ្នកឯងតែម្នាក់ឯង ទៅអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុញ្ញសិរីទ្រង់តិះដៀលថា ។បេ។ នែមោឃបុរស អ្នកតែម្នាក់ឯង មិនសមបើនឹងទៅអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯងសោះ នែមោឃបុរស កម្មដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អាសនៈដែលគេមិនបានបិទបាំងមែន មិនល្មមធ្វើ ( សេវនកិច្ច ) បានមែន តែថា គួរអាចនឹងនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់បាន ។ ភិក្ខុណាមួយ តែម្នាក់នឹងម្នាក់ អង្គុយក្នុងទីកំបាំង លើអាសនៈមានសភាពយ៉ាងនោះជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះហើយ ចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ ( នោះ ) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេស ឬបាចិត្តិយ ម្យ៉ាងទៀត ឧបាសិកាដែលមានសំដីគួរជឿបាននោះ ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ សូម្បីធម៌នេះ ក៏ឈ្មោះថា អនិយតដែរ ។

[ ៣៨៥ ] ត្រង់ពាក្យថា អាសនៈដែលគេមិនបានបិទបាំងមែន សេចក្តីថា អាសនៈដែលមិនបិទបាំង ដោយជញ្ជាំងក្តី សន្ទះទ្វារក្តី កន្ទេលផែងក្តី ព័ទ្ធព័ទ្ធដោយរាំងននក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ឬអាសនៈមិនបានបិទបាំងដោយរបស់ណាមួយ ។ ពាក្យថា មិនល្មមធ្វើ ( សេវនកិច្ច ) បាន គឺភិក្ខុមិនអាចនឹងសេពមេថុនធម្មបាន ។ ពាក្យថា តែថាល្មមនិយាយបែចចង់មាតុគ្រាមដោយវាចាអាក្រក់បាន គឺភិក្ខុអាចនិយាយបែចចង់មាតុគ្រាមដោយវាចាអាក្រក់បាន ។

[ ៣៨៦ ] ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយរួចហើយក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ ។ ពាក្យថា លើអាសនៈមានសភាពយ៉ាងនោះ គឺលើអាសនៈបែបយ៉ាងនោះ ។ មនុស្សស្រីហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ គឺស្រីដែលដឹងក្តី អង់អាច យល់ពាក្យជាសុភាសិត និងទុព្ភាសិត ពាក្យអាក្រក់ និងពាក្យល្អបាន ហៅថា មាតុ-គ្រាមក្នុងទីនេះ ។ ពាក្យថា ជាមួយគ្នា គឺក្នុងទីជាមួយ ។ ពាក្យថា តែម្នាក់និងម្នាក់ គឺមានតែភិក្ខុ និងមាតុគ្រាមប៉ុណ្ណោះ ។ ទីកំបាំងភ្នែក ទីស្ងាត់ត្រចៀកឈ្មោះថា ទីកំបាំង ។ បុគ្គលមិនអាចនឹងឃើញជនទាំងឡាយ កាលមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ក្នុងទីណា ទីនោះ ហៅថា កំបាំងភ្នែក ។ ទីដែលបុគ្គលមិនអាចឮសម្តីជាប្រក្រតីបាន ហៅថា ទីស្ងាត់ត្រចៀក ។ ពាក្យថា ទៅអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិតក្តី ដេកជិតក្តី ឬថាកាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិតក្តី ដេកជិតក្តី ឬថាអង្គុយទាំងពីរនាក់

ក្តី ដេកទាំងពីរនាក់ក្តី ។

[ ៣៨៧ ] ឧបាសិកាដែលមានផលមកហើយ ( សម្រេចសោតាបត្តិផល ) ត្រាស់ដឹងសច្ចៈបួន ស្គាល់សាសនាច្បាស់ ហៅថា ឧបាសិកាមានសម្តីគួរជឿបាន ។ ស្រីដែលដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង ហៅថា ឧបាសិកា ។ ពាក្យថា ឃើញ គឺបានប្រទះឃើញ ។

[ ៣៨៨ ] ឧបាសិកាចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុក៏ទទួលប្តេជ្ញាការអង្គុយ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកាមានសំដីគួរជឿបាននោះ ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។

[ ៣៨៩ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម ឯភិក្ខុនោះប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនប៉ះពាល់កាយទេ វិនយធរត្រូវវិនិច្ឆ័យចំពោះតែការអង្គុយ ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យចំពោះការដេក ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោក

ម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះ ឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំឈរ វិនយធរមិនគួរនឹងកាត់ ( ឲ្យត្រូវអាបត្តិអ្វីឡើយ ) ។

[ ៣៥០ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកប៉ះពាល់មាតុគ្រាម បើភិក្ខុនោះប្តេជ្ញាការដេកនោះ វិនយធរត្រូវកាត់ទោសតាមអាបត្តិ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំបានដេកមែន តែថាខ្ញុំមិនបានប៉ះពាល់កាយមាតុគ្រាមទេ វិនយធរត្រូវវិនិច្ឆ័យចំពោះការដេក ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ វិនយធរត្រូវកាត់ទោសចំពោះការអង្គុយ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិនយធរមិនគួរកាត់ ( អាបត្តិអ្វីឡើយ ) ។

[ ៣៥១ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយនិយាយបែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះប្តេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយនិយាយបែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនបាននិយាយបែចង់មាតុគ្រាមដោយវាចាអាក្រក់ទេ នោះវិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ ។បេ។ បើភិក្ខុឆ្លើយថាខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យតាមការដេក ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំឈរ វិនយធរមិនគួរវិនិច្ឆ័យ ( ឲ្យត្រូវអាបត្តិអ្វីឡើយ ) ។

[ ៣៥២ ] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោក

ម្ចាស់ដេកនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះ ប្ដេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំដេកមែន តែថា ខ្ញុំមិនបាននិយាយចែចង់ ( មាតុគ្រាម ) ដោយវាចាអាក្រក់ទេ វិនយធរត្រូវវិនិច្ឆ័យតាមការដេក ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថា ខ្ញុំអង្គុយ វិនយធរត្រូវវិនិច្ឆ័យតាមការអង្គុយ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ វិនយធរមិនគួរវិនិច្ឆ័យ ( ឲ្យត្រូវអាបត្តិអ្វីឡើយ ) ។

[ ៣៥៣ ] បើឧបាសិកានោះឆ្លើយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម គឺស្រីតែម្នាក់ បើភិក្ខុប្ដេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវកាត់អាបត្តិ ចំពោះការអង្គុយ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យតាមការដេក ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំឈរ វិនយធរមិនគួរ កាត់ ( ឲ្យត្រូវអាបត្តិអ្វីឡើយ ) ។

[ ៣៥៤ ] បើឧបាសិកានោះឆ្លើយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង ដេកក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាម គឺស្រីតែម្នាក់ បើភិក្ខុនោះប្ដេជ្ញាការដេកនោះ វិនយធរត្រូវវិនិច្ឆ័យដោយការដេក ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ វិនយធរត្រូវកាត់អាបត្តិតាមការអង្គុយ ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ វិនយធរមិនគួរកាត់ ( ឲ្យត្រូវអាបត្តិអ្វីឡើយ ) ។

[ ៣៥៥ ] ត្រង់ពាក្យថា សូម្បីធម៌ គឺតថាគតពោលប្រៀបធៀបនឹងសិក្ខាបទមុន ។ ត្រង់ពាក្យថា អនិយត គឺមិនប្រាកដជាអាបត្តិសង្ឃាទិសេស

ឬបាចិត្តិយ ។

[ ៣៥៦ ] ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ។ ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរមិនគួរវិនិច្ឆ័យអ្វីឡើយ ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិនោះ វិនយធរមិនគួរ វិនិច្ឆ័យ ( អ្វីឡើយ ) ។

**អនិយតទី ២ ចប់**

[ ៣៥៧ ] លោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះអនិយតពីរ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈពីរដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈបីដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ លោកម្ចាស់បរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះបានជាលោកម្ចាស់ស្ងៀមនៅ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

អនិយតកណ្ឌ ចប់

## ឧទ្ទាននៃអនិយតកណ្ឌនោះ

*អនិយតាបត្តិ ( ពីរ ) គឺអលំកម្មនិយ ១ នាលំកម្មនិយ ១ ដែលព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ មានព្រះគុណធម៌មាំមួន ទ្រង់បញ្ញត្តទុកល្អហើយ ។*

## អដ្ឋកថា
## ឆាលំកម្មនិយសិក្ខាបទ

[ ៣៨៤ ] អនិយតសិក្ខាបទទី ២ បទថា **នេវ សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងអនិយតសិក្ខាបទទី ២ នោះ មានវិនិច្ឆ័យ ដូចតទៅនេះថា ក្នុងបទថា **ភគវតា បដិក្ខិត្តំ** ជាដើម អ្នកសិក្សាគប្បីជ្រាបសម្ពន្ធយ៉ាងនេះថា ភិក្ខុមួយរូប គប្បីសម្រេចការអន្ធយណា ក្នុងទីកំបាំង គឺអាសនៈកំបាំង ល្មមធ្វើកម្មបានជាមួយមាតុគ្រាមម្នាក់ ព្រះមានព្រះភាគទ្រង់ហាមការសម្រេចកិរិយាអន្ធយនោះ ។ ពិតហើយ កាលនឹងកាន់យកអត្ថដោយប្រការដទៃ គួរនឹងត្រាស់ថា **ឯកស្ស ឯកាយ** ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកពោលពាក្យថា ទ្រង់ហាមហើយ ។ មួយទៀត បទថា **ឯកោ** នេះ គប្បីជ្រាបថា ជាបឋមាវិភត្តិចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

## អធិប្បាយ
## សិក្ខាបទវិភង្គនៃឆាលំកម្មនិយសិក្ខាបទ

[ ៣៨៥ ] ក្នុងបទថា **ន ហេវ ខោ បន បដិច្ឆន្នំ** នេះ សូម្បីទីបិទបាំងខាងក្រៅ ខាងក្នុងស្រឡះ មានបរិវេណទីធ្លាជាដើម ក៏គប្បីជ្រាបថា សង្គ្រោះចូលចំណែកខាងក្នុង ( ទីមិនកំបាំង ) ។ លោកពោលទុកក្នុងមហាបច្ចរីថា ទីកន្លែងសូម្បីដូច្នេះ រាប់ចូលក្នុងទីមិនកំបាំងនោះឯង ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យនៃអលំកម្មនិយសិក្ខាបទនោះឯង ។ ក្នុងសិក្ខាបទនេះ មាន

សេចក្ដីប្លែកគ្នាតែម្យ៉ាងប៉ុណ្ណោះថា មនុស្សដើងក្ដីម្នាក់ណាមួយជាស្រីក្ដី ប្រុសក្ដី មិនជាមនុស្សខ្វាក់ និងថ្លង់ ឈរ ឬអង្គុយក្នុងឱកាស ១២ ហត្ថ មានចិត្តរាយមាយក្ដី ងោកងក់ក្ដី ក៏រក្សាអាបត្តិបាន ។ ចំណែកមនុស្សថ្លង់ សូម្បីមានភ្នែកល្អ ឬមនុស្សខ្វាក់ សូម្បីត្រចៀកមិនថ្លង់ ក៏រក្សាមិនបាន ។ ព្រះមានព្រះភាគ ទ្រង់បន្ថយអាបត្តិបារាជិកចុះមក កាត់អាបត្តិព្រោះទុដ្ឋុល្លវាចា ។ ពាក្យដ៏សេសដូចគ្នានឹងសិក្ខាបទមុននោះឯង ។ សូម្បីក្នុងសិក្ខាបទទាំងពីរ ក៏មិនត្រូវអាបត្តិដល់ភិក្ខុនី និងភិក្ខុដើមបញ្ញត្តិ ។

ក្នុងសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតអំពីកាយនិងចិត្ត វាចា និងចិត្ត កាយវាចា និងចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត មានវេទនា ២ ជាសុខវេទនា និងឧបេក្ខាវេទនា ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

អនិយតវណ្ណនា

ក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះ សមន្តប្បាសាទិកា ចប់

បឋមសមន្តប្បាសាទិកាវិនយវណ្ណនា ចប់

# និស្សគ្គិយកណ្ឌ

*បពិត្រលោកដ៏មានអាយុទាំងឡាយ*

*អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ នេះឯង មកកាន់ឧទ្ទេស*

*( គឺព្រះបាតិមោក្ខដែលសង្ឃត្រូវសំដែងរាល់កន្លះខែ ) ។*

## ចីវរវគ្គ សិក្ខាបទទី ១

[ ១ ] *សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងគោតមចេតិយ ទៀបក្រុងវេសាលី ។ វេលានោះឯង ត្រៃចីវរដែលព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយ រួចស្រេចហើយ ។ ពួកឆព្វគ្គិយ-ភិក្ខុ ( ភិក្ខុមានពួក ៦ ) បានដឹងថា ត្រៃចីវរព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ( ក៏ប្រើប្រាស់ចីវរហួសពុទ្ធានុញ្ញាត គឺប្រើប្រាស់ចីវរ ៣ ត្រៃ ) ចូលទៅកាន់ស្រុក ( ស្លៀកដណ្ដប់ ) ចីវរមួយត្រៃ នៅក្នុងអារាម ( ស្លៀកដណ្ដប់ ) ចីវរមួយត្រៃ ចុះកាន់កំពង់ងូតទឹក ( ស្លៀកដណ្ដប់ )ចីវរមួយត្រៃ ។ ភិក្ខុទាំង-ឡាយណា ដែលជាអ្នកប្រាថ្នាតិច ជាអ្នកសន្ដោស ជាអ្នកមានសេចក្ដីអៀនខ្មាស ជាអ្នកក្ដៅក្រហាយនឹងបាប ជាអ្នកពេញចិត្តខាងការរៀនសូត្រ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបីបើនឹងប្រើប្រាស់អតិរេកចីវរ ( ចីវរច្រើន ) លើសកំណត់ ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ រួចត្រាស់សួរបញ្ជាក់ទៅពួកឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានប្រើប្រាស់អតិរេកចីវរមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏*

មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ មិនទំនង មិនសមបែប មិនសមគួរ មិនមែនជារបស់សមណៈ ជាការមិនគប្បី មិនគួរបើនឹងធ្វើសោះ ម្នាលមោឃបុរសទាំងឡាយ គួរបើដែរ អ្នកឯងរាល់គ្នា នឹងប្រើប្រាស់អតិរេកចីវរ ( យ៉ាងនេះ ) ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀត ( នោះ ) ក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយប្រើប្រាស់អតិរេកចីវរ ( ភិក្ខុនោះ ) ត្រូវនិស្សគ្គិយបាចិត្តិយ[១] ។ ឯសិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[ ២ ] គ្រានោះ អតិរេកចីវរកើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុចង់ប្រគេនចីវរនោះ ទៅព្រះសារីបុត្តដ៏មានអាយុ ។ តែព្រះ-សារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត ( មិនទាន់និមន្តមកដល់ ) ។ វេលានោះ ព្រះអានន្ទដ៏មានអាយុត្រិះរិះគិតថា ព្រះដ៏មានព្រះភាគ បានបញ្ញត្តសិក្ខាបទថា ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរឡើយ ឥឡូវអតិរេកចីវរកើតឡើងដល់អញហើយ អញមានបំណងនឹងប្រគេនចីវរនេះទៅព្រះសារីបុត្តដ៏មានអាយុ តែព្រះសារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត តើអញត្រូវប្រតិបត្តិដូចម្តេចអេះ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏

---

១- គឺអតិរេកចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀតនឹងមកដល់ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ប្រហែលជា ៩ ថ្ងៃ ឬ ១០ ថ្ងៃទៀត ( ទើបលោកនឹងនិមន្តមកដល់ ) ។ គ្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នករាល់គ្នាទុកអតិរេកចីវរ កំណត់ត្រឹម ១០ ថ្ងៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវរសម្រេចហើយ ( ក្តី ) កឋិនដោះហើយ ( ក្តី ) ភិក្ខុត្រូវទុកអតិរេកចីវរបានតែត្រឹម ១០ ថ្ងៃ បើឲ្យកន្លងហួសពី ១០ ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៣ ] ត្រង់ពាក្យថា ចីវរសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចហើយក្តី ចីវរដែលបាត់ដោយចោរជាដើមលួចយកទៅក្តី ចីវរវិនាសដោយសត្វកណ្តៀរជាដើមកាត់ក្តី ចីវរដែលភ្លើងឆេះក្តី សេចក្តីប្រាថ្នាក្នុងចីវរ ( របស់ភិក្ខុនោះ ) ដាច់ស្រឡះក្តី ។ ពាក្យថា កឋិនដោះហើយ គឺកឋិនដែលដោះដោយបណ្តាមាតិកា ៨ យ៉ាង មាតិកាណាមួយ ឬសង្ឃបានប្រជុំគ្នាសូត្រដោះក្នុងកាលជាចន្លោះ ។ ពាក្យថា កំណត់ត្រឹម ១០ ថ្ងៃ គឺភិក្ខុត្រូវទុក ( អតិរេកចីវរ ) កំណត់យ៉ាងយូរបានត្រឹមតែ ១០ ថ្ងៃ ។ ចីវរដែលភិក្ខុមិនបានអធិដ្ឋាន មិនបានវិកប្ប ឈ្មោះថា អតិរេកចីវរ ។ បណ្តាចីវរទាំង ៦ ចីវរណាមួយដែលតូចបំផុតគួរល្មមភិក្ខុវិកប្បបាន ឈ្មោះថា ចីវរ ។ ពាក្យថា បើទុកឲ្យកន្លងហួសពី ១០ ថ្ងៃនោះទៅត្រូវនិស្សគ្គិយ អធិប្បាយថា ចីវរ កាលបើអរុណរះឡើងក្នុងថ្ងៃទី ១១

( ឡើងទៅ ) ភិក្ខុត្រូវលះចេញ គឺត្រូវលះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះ ( ចីវរដល់ជំនុំសង្ឃ ) បែបយ៉ាងនេះ ។

[ ៤ ] ភិក្ខុនោះឯងត្រូវ ( យកចីវរដែលជានិស្សគ្គិយនោះ ) ចូលទៅរកជំនុំសង្ឃ ហើយធ្វើឧត្តរាសង្គ ( ចីវរ ) ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលីឡើង ពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន នេះចីវររបស់ខ្ញុំកន្លង ១០ ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវ ខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ ។ លុះ ( ភិក្ខុនោះ ) លះរួចហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវទទួលអាបត្តិ ត្រូវប្រគល់ចីវរដែលលះបង់ឲ្យដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ[១] បានលះចីវរនេះ ដែលត្រូវនិស្សគ្គិយដល់ជំនុំសង្ឃហើយ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវប្រគល់ចីវរនេះ ឲ្យទៅភិក្ខុឈ្មោះនេះ[២] វិញចុះ ។

[ ៥ ] ( បើលះចីវរដល់គណៈ ) ភិក្ខុនោះត្រូវចូលទៅរកភិក្ខុច្រើនអង្គ ( គឺភិក្ខុ ៣ រូប ឬ ២ រូប ) ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង សំពះទៀបបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងប្រណម្យអញ្ជលីឡើង ពោលនឹងភិក្ខុទាំងនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន នេះចីវររបស់ខ្ញុំកន្លង ១០ ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវខ្ញុំសូមលះចីវរនេះដល់លោកដ៏មានអាយុទាំងឡាយ។ ភិក្ខុនោះលះរួចហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុអ្នកឈ្លាសអង់អាចត្រូវ

---

១-២ ត្រង់នេះត្រូវដាក់ឈ្មោះបញ្ចូលមក គឺបើភិក្ខុនោះឈ្មោះអ្វី ត្រូវចេញឈ្មោះនោះ ដូចឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិតជាដើម ។

ទទួលអាបត្តិ រួចត្រូវឲ្យចីវរដែលភិក្ខុលះនោះដោយពាក្យថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ពាក្យខ្ញុំ ចីវរនេះរបស់ភិក្ខុឈ្មោះនេះជានិស្សគ្គិយ លោកបានលះបង់ដល់លោកដ៏មានអាយុទាំងឡាយហើយ ។ បើកម្មមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយហើយ អស់លោកដ៏មានអាយុត្រូវប្រគល់ចីវរនេះឲ្យទៅភិក្ខុឈ្មោះនេះវិញចុះ ។

[ ៦ ] ( បើលះដល់បុគ្គល ) ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុមួយរូបហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចអង្គុយច្រហោងប្រណម្យអញ្ជលីឡើងហើយពោលនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ នេះចីវររបស់ខ្ញុំកន្លង ១០ ថ្ងៃហើយ ត្រូវតែលះបង់ ឥឡូវខ្ញុំសូមលះចីវរនេះដល់លោកដ៏មានអាយុ ។ ភិក្ខុនោះ លុះលះរួចហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុត្រូវទទួលអាបត្តិ ហើយត្រូវប្រគល់ចីវរដែលលះបង់ដោយពាក្យថា ខ្ញុំឲ្យចីវរនេះដល់លោកដ៏មានអាយុវិញ ។

[ ៧ ] ( កាលបើចីវរ ) កន្លងហួស ១០ ថ្ងៃហើយ ភិក្ខុដឹងច្បាស់ថាកន្លង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) កន្លងហួស ១០ ថ្ងៃហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) ដែលកន្លងហួស ១០ ថ្ងៃហើយ ភិក្ខុសម្គាល់ថាមិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) ដែលមិនទាន់បានអធិដ្ឋាន ហើយភិក្ខុសម្គាល់ថាបានអធិដ្ឋានហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) ដែលភិក្ខុមិនទាន់បានវិកប្ប ហើយភិក្ខុសម្គាល់ថា បានវិកប្ប ត្រូវនិស្សគ្គិយបាចិត្តិយ ។

( កាលបើចីវរ ) ដែលភិក្ខុមិនទាន់បានលះ ហើយភិក្ខុដឹងច្បាស់ថាបានលះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) មិនបាត់ទេ ហើយភិក្ខុសម្គាល់ថាបាត់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) មិនខូចទេ ហើយភិក្ខុសម្គាល់ថាខូច ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) ភ្លើងមិនឆេះទេ ហើយភិក្ខុសម្គាល់ថាភ្លើងឆេះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ( កាលបើចីវរ ) ចោរឥតបានប្លន់យកទេ តែភិក្ខុសម្គាល់ថា ចោរប្លន់យក ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមិនបានលះចីវរដែលត្រូវនិស្សគ្គិយ ហើយយកមកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ( កាលបើចីវរ ) មិនទាន់កន្លងហួស ១០ ថ្ងៃទេ ភិក្ខុសម្គាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ ។ ( កាលបើចីវរ ) មិនទាន់កន្លងហួស ១០ ថ្ងៃទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ( កាលបើចីវរ ) មិនទាន់កន្លងហួស ១០ ថ្ងៃ ហើយភិក្ខុក៏សម្គាល់ថា មិនទាន់កន្លងទេ មិនត្រូវអាបត្តិឡើយ ។

[ ៨ ] វារៈដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុបានអធិដ្ឋាន បានវិកប្ប ក្នុងខាងក្នុង ១០ ថ្ងៃ ១ ភិក្ខុបានលះ ១ ចីវរបាត់ ១ ចីវរខូច ១ ចីវរភ្លើងឆេះ ១ ចីវរចោរដណ្តើមយក ១ ចីវរដែលភិក្ខុយកដោយសេចក្តីស្និទ្ធស្នាល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[ ៩ ] ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រគល់ចីវរដែលលះឲ្យទៅភិក្ខុ ( ម្ចាស់ចីវរ ) នោះវិញ ។ ភិក្ខុទាំងឡាយណា ដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្ទោសថា គួរ

បើដែរ ពួកឆព្វគ្គិយភិក្ខុមិនឲ្យចីវរដែលលះ ( ទៅម្ចាស់ចីវរ ) វិញ ។ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៅពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ មិនបានឲ្យចីវរដែលលះ ( ទៅភិក្ខុម្ចាស់ចីវរ ) វិញមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា មែន ព្រះអង្គ ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោស ។បេ។ លុះទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនឲ្យចីវរដែលលះ ( ទៅភិក្ខុម្ចាស់ចីវរ ) វិញ ភិក្ខុណាមិនឲ្យ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

សិក្ខាបទទី ១ ចប់

# អដ្ឋកថា

# ទុតិយសមន្តបាសាទិកា វិនយវណ្ណនា

# តឹសកកណ្ឌវណ្ណនា

ធម៌ ៣០ ពួកណា ឈ្មោះនិស្សគ្គិយ ដែលព្រះសម្មាសម្ពុទ្ធ ជាអ្នកស្ងប់ ទ្រង់សម្ដែងហើយ ឥឡូវនេះ ខ្ញុំនឹងធ្វើការពណ៌នាបទដែលមិនធ្លាប់មានមកពីមុននៃធម៌ទាំងនោះ ។

## និស្សគ្គិយបាចិត្តិយ ចីវរវគ្គទី ១

## សិក្ខាបទទី ១ បឋមកឋិនសិក្ខាបទ

[ ១ ] ក្នុងនិទានថា ដោយសម័យនោះឯង ព្រះមានព្រះភាគសម្មាសម្ពុទ្ធ គង់នៅនាគោតមកចេតិយ ជិតក្រុងវេសាលី សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ដូច្នេះជាដើមថា ដែលឈ្មោះថា ត្រៃចីវរនោះ បានដល់ ចីវរ ៣ ផ្ទាំង គឺអន្តរវាសក: ១ ឧត្តរាសង្គ: ១ សង្ឃាដី ១ គឺព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ដើម្បីប្រើប្រាស់ ។ ឯចីវរ ៣ ផ្ទាំងនេះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតក្នុងទីណា ទ្រង់អនុញ្ញាតក្នុងកាលណា និងទ្រង់អនុញ្ញាតព្រោះហេតុអ្វី ពាក្យទាំងអស់មកហើយក្នុងរឿងពេទ្យជីវកក្នុងចីវរក្ខន្ធក:នោះឯង ។

ពាក្យថា **អញ្ញេនេវ តិចីវរេន គាមំ បវិសន្តិ** សេចក្ដីថា ពួកឆព្វគ្គិយភិក្ខុគ្រង់ត្រៃចីវរ ចូលស្រុកមួយសម្រាប់ មួយសម្រាប់ទៀត ប្រើគ្រង់នៅក្នុងវត្ត និងមួយសម្រាប់ប្រើគ្រង់ស្រង់ទឹក ប្រើចីវរមួយថ្ងៃ ៩ ផ្ទាំង រាល់ថ្ងៃ

ដោយអាការយ៉ាងនេះ ។

[ ២ ] ពីរបទថា **ឧប្បន្នំ ហោតិ** សេចក្តីថា អតិរេកចីវរនេះកើតឡើងឲ្យឱកាសដល់អនុប្បញ្ញត្តិ ដោយអំណាចការបាន មិនមែនដោយអំណាចការសម្រេច ។

ពាក្យថា **អាយស្មតោ សារីបុត្តស្ស ធាតុកាមោ ហោតិ** សេចក្តីថា បានឮថា ព្រះអានន្ទរមែងស្រឡាញ់រាប់អានព្រះសារីបុត្រ ដោយរាប់អានការមានគុណច្រើនរបស់ព្រះសារីបុត្រថា វៀរព្រះមានព្រះភាគ បុគ្គលដទៃមានគុណវិសេស មានសភាពបែបនេះ មិនមានឡើយ ។ លោកបានចីវរដែលពេញចិត្ត បោកគក់ហើយ ធ្វើពិន្ទុកប្បៈ ហើយប្រគេនដល់ព្រះថេរៈនោះឯង គ្រប់ៗដង ។ ក្នុងវេលាមុនឆាន់ បានបបរ និងរបស់ទំពា ឬបិណ្ឌបាតប្រណីតហើយ រមែងប្រគេនដល់ព្រះថេរៈដូចគ្នា ។ ក្នុងវេលាក្រោយឆាន់ បានភេសជ្ជៈ មានទឹកឃ្មុំ និងទឹកអំពៅជាដើមក៏ប្រគេនដល់ព្រះថេរៈនោះឯង ។ នាំកុមារទាំងឡាយចេញអំពីត្រកូលឧបដ្ឋាកឲ្យបព្វជ្ជា ឲ្យកាន់យកឧបជ្ឈាយ៍ ក្នុងសម្នាក់ព្រះថេរៈហើយ ធ្វើអនុសាវនាកម្មឯង ។

ចំណែកព្រះសារីបុត្រ ក៏រាប់អានព្រះអានន្ទពន់ពេក ដោយធ្វើទុកក្នុងចិត្តថា ធម្មតាកិច្ចដែលបុត្រគប្បីធ្វើដល់បិតា ជាភារៈរបស់បុត្រច្បង ព្រោះដូច្នោះ កិច្ចណាដែលអញគប្បីធ្វើដល់ព្រះមានព្រះភាគ កិច្ចទាំងអស់នោះ ព្រះអានន្ទជាអ្នកធ្វើ អាត្មាអញអាស្រ័យព្រះអានន្ទ ទើបបានជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ។ ពាក្យទាំងអស់ថា សូម្បីព្រះថេរៈបានចីវរដែលពេញចិត្តហើយ

ក៏ប្រគេនព្រះអានន្ទដូចគ្នាជាដើម ដូចគ្នានឹងពាក្យមុននោះឯង ។ ព្រះអានន្ទរាប់អានដោយការរាប់គុណច្រើនយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រមែងជាអ្នកមានបំណងនឹងប្រគេនចីវរ ដែលកើតឡើងក្នុងគ្រានោះដល់ព្រះសារីបុត្រ ។

ក្នុងពាក្យថា **នវមំ វា ភគវា ទិវសំ ទសមំ វា** នេះ បើបុគ្គលណាម្នាក់ គប្បីមានសេចក្ដីសង្ស័យថា ព្រះថេរៈជ្រាបបានដូចម្ដេច ឆ្លើយថា ព្រះថេរៈជ្រាបដោយហេតុច្រើនយ៉ាង ។

## ហេតុដែលព្រះអានន្ទជ្រាបការមករបស់ព្រះសារីបុត្រថាន

បានឮថា ព្រះសារីបុត្តត្ថេរ កាលចៀសចារិកទៅក្នុងជនបទ រមែងពោលលាព្រះអានន្ទមុនថា ខ្ញុំនឹងមកដោយកាលមានប្រមាណប៉ុណ្ណេះ ក្នុងរវាងនេះ លោកកុំលះបង់ព្រះមានព្រះភាគឡើយ ទើបចៀសចេញទៅ ដូច្នេះ ។ ទោះលោកមិនពោលលាក្នុងទីចំពោះមុខ ក៏ត្រូវបញ្ជូនភិក្ខុទៅលាសិន ទើបទៅ ។ បើលោកនៅចាំវស្សាក្នុងអាវាសដទៃ បើភិក្ខុណាមកមុន លោកក៏បញ្ជូនភិក្ខុទៅយ៉ាងនេះថា ពួកលោកចូរថ្វាយបង្គំព្រះយុគលបាទ របស់ព្រះមានព្រះភាគដោយសិរសា គឺត្បូងតាមពាក្យរបស់ខ្ញុំ ហើយសូមសាកសួរដល់ការមិនមានរោគរបស់ព្រះអានន្ទ ហើយប្រាប់ថា ខ្ញុំនឹងមកក្នុងថ្ងៃឈ្មោះនោះ ហើយព្រះថេរៈរមែងមកក្នុងថ្ងៃតាមដែលលោកកំណត់ទុក ហើយនោះឯងជានិច្ច ។

ម្យ៉ាងទៀត ព្រះអានន្ទ រមែងជ្រាបបានដោយការប៉ាន់ស្មានខ្លះ ដោយន័យនេះថា ព្រះសារីបុត្រ កាលអត់សង្កត់ការវិយោគ ( គឺការព្រាត់ប្រាស )

អំពីព្រះមានព្រះភាគអស់ថ្ងៃ មានប្រមាណប៉ុណ្ណេះ ឥឡូវនេះ រាប់អំពីថ្ងៃនេះទៅ នឹងមិនហួសថ្ងៃឈ្មោះនោះ លោកនឹងមកដោយពិត ពិតហើយ ជនទាំងឡាយដែលជាអ្នកមានបញ្ញាច្រើន រមែងមានការស្រឡាញ់ និងការគោរពក្នុងព្រះមានព្រះភាគច្រើន ដូច្នេះ ។ ព្រះថេរៈរមែងជ្រាបបានដោយហេតុច្រើនយ៉ាង ដោយប្រការយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបលោកក្រាបទូលថា នឹងមកក្នុងថ្ងៃទី ៩ ឬថ្ងៃទី ១០ ដូច្នេះ កាលព្រះអានន្ទក្រាបទូលដូច្នេះហើយ ព្រោះសិក្ខាបទនេះជាបណ្ណត្តិវជ្ជៈ មិនមែនជាលោកវជ្ជៈ ព្រោះហេតុនោះ គ្រានោះឯង កាលព្រះមានព្រះភាគទ្រង់ធ្វើថ្ងៃ ដែលព្រះអានន្ទក្រាបទូលនោះឯងឲ្យជាកំណត់ ទើបទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នករាល់គ្នា ទុកអតិរេកចីវរកំណត់ត្រឹម ១០ ថ្ងៃ ដូច្នេះ ។ បើព្រះថេរៈនេះគប្បីទូលសម្តែងឡើងដល់កន្លះខែ ឬមួយខែ សូម្បីកន្លះខែ ឬមួយខែនោះ ព្រះមានព្រះភាគក៏ទ្រង់អនុញ្ញាត ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃបឋមកឋិនសិក្ខាបទ

[ ៣ ] បទថា **និដ្ឋិតចីវរស្មឹ** បានដល់ កាលចីវរសម្រេចហើយ ដោយការសម្រេច ឯណានីមួយ ។ ព្រោះចីវរនោះ រមែងសម្រេចហើយដោយការធ្វើខ្លះ ដោយហេតុមានការបាត់ជាដើមខ្លះ ដូច្នោះ ដើម្បីទ្រង់សម្តែងត្រឹមតែអត្ថប៉ុណ្ណោះ ក្នុងបទភាជនីយ៍នៃបទថា **និដ្ឋិតចីវរស្មឹ** នោះទើបព្រះមានព្រះភាគ ត្រាស់ពាក្យជាដើមថា **ភិក្ខុនោ ចីវរំ កតំ វា ហោតិ** ដូច្នេះ ។

និស្សគ្គិយបាចិត្តិយ ចីវរវគ្គ សិក្ខាបទទី ១ ៤០

បណ្ដាបទទាំងនោះ បទថា **កតំ** គឺដែលភិក្ខុធ្វើហើយដោយកម្ម មានសូចិកម្មជាទីបំផុត ។ ដែលឈ្មោះថា កម្ម មានសូចិកម្មជាទីបំផុត បានដល់ការធ្វើកម្មដែលគួរធ្វើដោយម្ជុលឯណានីមួយ មានការភ្ជាប់អន្ទាក់ និងក្ដុំជាទីបំផុត ហើយក៏រក្សាម្ជុលទុក ( ក្នុងបំពង់ម្ជុល ) ។

បទថា **ឆន្នំ** គឺត្រូវពួកចោរជាដើមលួចយកទៅ ពិតហើយ សូម្បីចីវរនោះ លោកហៅថា សម្រេចហើយ ព្រោះការកន្លល់ដោយការធ្វើនោះឯងសម្រេចហើយ ។

បទថា **វិនដ្ឋំ** គឺត្រូវពួកសត្វ មានកណ្ដៀរជាដើមកាត់ហើយ ។

បទថា **ឧឌ្ឍំ** គឺត្រូវភ្លើងឆេះ ។

ពីរបទថា **ចីវរាសា វា ឧបច្ឆិន្នា** សេចក្ដីថា អស់ការសង្ឃឹមក្នុងចីវរដែលកើតឡើងថា អញនឹងបានចីវរក្នុងត្រកូលឈ្មោះនោះក្ដី ។ សេចក្ដីពិតគួរជ្រាបភាពដែលចីវរទាំងនេះសម្រេចហើយ ព្រោះការកន្លល់ដោយការធ្វើនោះឯង សម្រេចហើយ ។

ពីរបទថា **ឧព្ភតស្មឹ កឋិនេ** គឺ ( កាលចីវរសម្រេចហើយ ) កាលកឋិនដោះហើយ ។ ដោយបទថា **ឧព្ភតស្មឹ កឋិនេ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងការមិនមាននៃបលិពោធទី ២ ឯកឋិននោះ ដែលភិក្ខុទាំងឡាយដោះដោយមាតិកាឯណាមួយ ក្នុងបណ្ដាមាតិកា ៨ ឬដោយការដោះក្នុងចន្លោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **អដ្ឋន្នំ មាតិកានំ** ជាដើម ក្នុងនិទ្ទេសនៃបទថា **ឧព្ភតស្មឹ កឋិនេ** នោះ ។

បណ្ដាមាតិកា និងការដោះក្នុងចន្លោះនោះ មាតិកា ៨ មកហើយក្នុងកឋិនក្ខន្ធកៈ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មាតិកានៃការដោះកឋិនទាំង ៨ នេះ គឺ **បក្កមនន្តិកា និដ្ឋានន្តិកា សន្និដ្ឋានន្តិកា នាសនន្តិកា សវនន្តិកា អាសាវច្ឆេទិកា សីមាតិក្កន្តិកា សហុព្ភារា ។**

សូម្បីការដោះកឋិនក្នុងចន្លោះ ក៏មកក្នុងភិក្ខុនីវិភង្គ យ៉ាងនេះថា **សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧទ្ធតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។** បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើការដោះកឋិននេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវដកនូវកឋិន។ នេះជាវាចាដែលប្រកាសឲ្យសង្ឃដឹង។ បពិត្រព្រះសង្ឃដ៏ចម្រើនសូមព្រះសង្ឃស្ដាប់ខ្ញុំ ឥឡូវនេះសង្ឃដកកឋិនចេញ ។ ការដកកឋិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះពោលឡើង ។ កឋិនសង្ឃបានដកហើយ ។ ការដកកឋិនសមគួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ ខ្ញុំសូមចាំទុកនូវកម្មនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

ខ្ញុំនឹងពណ៌នាពាក្យដែលគួរពោលក្នុងមាតិកា និងអន្តរុព្ភារទាំងអស់នោះក្នុងអាគតដ្ឋាននោះឯង តែកាលនឹងពោលក្នុងទីនេះ បាលីដែលគួរនាំមកក្ដី

អត្ថដែលគួរនឹងពោលក្តី សូម្បីពោលហើយ តែក៏ជារឿងដែលដឹងបានលំបាក ព្រោះពោលទុកក្នុងឋានៈដែលមិនគួរ ។

បទថា **ទសាហបរមំ** មានវិគ្គហៈថា ១០ ថ្ងៃ ជាកំណត់យ៉ាងក្រៃលែង នៃកាលនោះ ព្រោះហេតុនោះ ទើបកាលនោះ ឈ្មោះថា មាន ១០ ថ្ងៃយ៉ាងយូរ អធិប្បាយថា ចីវរនោះដែលភិក្ខុគប្បីទុកអស់កាល ១០ ថ្ងៃ យ៉ាងក្រៃលែង ។ តែកាលទ្រង់សម្តែងអត្ថប៉ុណ្ណោះ ក្នុងបទភាជនីយ៍ ទើបព្រះមានព្រះភាគត្រាស់ថា គប្បីទុកបាន ១០ ថ្ងៃយ៉ាងយូរ ពិតហើយ មានពាក្យអធិប្បាយថា ភាពជាកាល ១០ ថ្ងៃយ៉ាងក្រៃលែង ដែលត្រាស់ទុកក្នុងបទថា **ទសហបរមំ** នេះ ភាវៈនៃកាលមាន ១០ ថ្ងៃយ៉ាងក្រៃលែងនោះ មានអត្ថដូច្នេះថា គប្បីទុកបានអស់កាលប្រមាណប៉ុណ្ណោះ ដែលមិនទាន់កន្លងទៅ ។ ចីវរដែលឈ្មោះថា **អតិរេក** ព្រោះមិនរាប់ចូលក្នុងពួកចីវរដែលអធិដ្ឋាន និងវិកប្បទុក ព្រោះហេតុនោះ ទើបឈ្មោះថា អតិរេកចីវរ ។ ដោយហេតុនោះ ក្នុងបទភាជនីយ៍នៃបទថា **អតិរេកចីវរំ** នោះ ទើបត្រាស់ថា ចីវរដែលមិនបានអធិដ្ឋាន និងមិនបានវិកប្ប ។

## អធិប្បាយ កំណើតចីវរ ៦ ប្រភេទ

ពាក្យថា **ឆន្នំ ចីវរានំ អញ្ញតរំ** សេចក្តីថា បណ្តាចីវរ ៦ ប្រភេទនេះ គឺចីវរដែលធ្វើដោយសម្បកឈើ ១ ចីវរដែលធ្វើដោយកប្បាស ១ ចីវរដែលធ្វើដោយសូត្រ ១ ចីវរដែលធ្វើដោយរោមសត្វ ( វៀរលែងតែសក់ ឬរោមមនុស្សចេញ ) ១ ចីវរដែលធ្វើដោយសម្បកធ្មៃ ១ សំពត់ដែលធ្វើលាយ

ដោយវត្ថុ ៥ យ៉ាងខាងដើម ១ ចីវរណាមួយ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសមុដ្ឋានចីវរ ដោយពាក្យថា **ឆន្នំ** ជាដើមនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងខ្នាត ទើបត្រាស់ថា ចីវរយ៉ាងតូច គួរវិកប្បបានដូច្នេះ ទំហំចីវរនោះបណ្ដោយ ២ ចំអាម ទទឹង ១ ចំអាម ។ ទំហំនៃចីវរនោះ មានព្រះបាលីដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុវិកប្បចីវរយ៉ាងតូចបំផុត បណ្ដោយ ត្រឹម ៨ ធ្នាប់ ទទឹងត្រឹម ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត ។

បទថា **តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ** សេចក្ដីថា កាលភិក្ខុញ៉ាំងចីវរមានសមុដ្ឋាន និងប្រមាណតាមដែលពោលហើយនោះ ឲ្យកន្លងកាល ១០ ថ្ងៃយ៉ាងក្រៃលែង គឺកាលនឹងធ្វើដោយវិធីដែលមិនជាអតិរេកចីវរចេញ ក្នុងរវាងកាល ១០ ថ្ងៃយ៉ាងក្រៃលែងនេះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ អធិប្បាយថា ចីវរនោះ ជានិស្សគ្គិយផង ជាអាបត្តិបាចិត្តិយ ដល់ភិក្ខុនោះផង ។ម្យ៉ាងទៀត ការលះបង់ ឈ្មោះថា និស្សគ្គិយ ។ ពាក្យថា និស្សគ្គិយនោះជាឈ្មោះរបស់វិនយកម្មដែលភិក្ខុគប្បីធ្វើក្នុងកាលជាខាងដើម ការលះបង់មានដល់ធម្មជាតិនោះ ហេតុនោះ ទើបធម្មជាតិនោះ ឈ្មោះថា និស្សគ្គិយដូច្នេះឯង ។ និស្សគ្គិយនោះ គឺអ្វី គឺបាចិត្តិយ ។ ក្នុងបទថា **តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ** នេះ មានអត្ថដូច្នេះថា ត្រូវអាបត្តិបាចិត្តិយមានការលះបង់ជាវិនយកម្មដល់ភិក្ខុ ដែលទុកឲ្យកន្លងកាលនោះទៅ ។

តែក្នុងបទភាជនីយ៍ ដើម្បីសម្ដែងអត្ថវិកប្បជំបូងមុន ទើបព្រះមានព្រះ-

ភាគតាំងមាតិកាថា កាលភិក្ខុទុកឲ្យកន្លងកាលនោះទៅ ជានិស្សគ្គិយ ហើយត្រាស់ពាក្យថា ក្នុងកាលអរុណថ្ងៃទី ១១ រះឡើងជានិស្សគ្គិយ គឺដែលភិក្ខុគប្បីលះបង់ដូច្នេះ ។ ចីវរនោះ ភិក្ខុគប្បីលះបង់ដល់បុគ្គលណា គប្បីលះបង់ដោយវិធីដូចម្តេច ដើម្បីសម្តែងបុគ្គល និងវិធីលះបង់នោះទៀត ទើបទ្រង់ត្រាស់ពាក្យជាដើមថា **សង្ឃស្ស វា** ដូច្នេះ ។

បណ្តាបទទាំងនោះ ក្នុងបទថា **ឯកាទសេ អរុណុគ្គមនេ** នេះ អ្នកសិក្សាគប្បីជ្រាបថា ចីវរកើតឡើងក្នុងថ្ងៃណា អរុណនៃថ្ងៃនោះ អាស្រ័យថ្ងៃដែលចីវរកើតឡើង ព្រោះហេតុនោះ ទើបជានិស្សគ្គិយ ក្នុងកាលអរុណថ្ងៃទី ១១ រះឡើង រួមជាមួយថ្ងៃដែលចីវរកើត បើចីវរជាច្រើនចង ឬតម្រួតរួមគ្នា ក៏ជាអាបត្តិ ១ ប៉ុណ្ណោះ ក្នុងចីវរដែលបត់ទុកមិនរួមគ្នា ជាអាបត្តិច្រើន តាមចំនួននៃវត្ថុ ។

[ ៤ ] បទថា **និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា** សេចក្តីថា សួរថា គប្បីសម្តែងអាបត្តិដូចម្តេច ឆ្លើយថា គប្បីសម្តែងដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងខន្ធកៈ ។

សួរថា ត្រាស់ទុកក្នុងខន្ធកៈនោះដូចម្តេច ឆ្លើយថា ត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ អង្គុយច្រហោងផ្គងអញ្ជលី ពោលនឹងសង្ឃយ៉ាងនេះថា **អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ** បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំត្រូវអាបត្តិឈ្មោះនេះ

ហើយ សូមសម្ដែងនូវអាបត្តិនោះចេញ ។

ក្នុងអធិការនេះ បើចីវរមានមួយផ្ទាំង គប្បីពោលថា **ឯកំ និស្សគ្គិយំ បាចិត្តិយំ ...** ( ត្រូវហើយ ) នូវនិស្សគ្គិយបាចិត្តិយ ១ ។ បើចីវរ ២ ផ្ទាំង គប្បីពោលថា **ទ្វេ ...** នូវអាបត្តិ ២ ។ បើចីវរច្រើនផ្ទាំង គប្បីពោលថា **សម្ពហុលា ...** នូវអាបត្តិច្រើន ។ សូម្បីក្នុងការលះបង់ បើចីវរមួយផ្ទាំង គប្បីពោលតាមសមគួរដល់បាលីនោះឯងថា **ឥទំ មេ ភន្តេ ចីវរំ** បពិត្រលោកម្ចាស់ទាំងឡាយ ចីវររបស់ខ្ញុំមួយផ្ទាំងនេះជាដើម ។ បើចីវរ ២ ផ្ទាំង ឬច្រើនផ្ទាំង គប្បីពោលថា **ឥមានិ មេ ភន្តេ ចីវរានិ ទសាហាតិក្កន្តានិ និស្សគ្គិយានិ ឥមានាហំ សង្ឃស្ស និស្សជ្ជាមិ** ( បពិត្រលោកម្ចាស់ទាំង-ឡាយ ចីវររបស់ខ្ញុំទាំងនេះ កន្លង ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរទាំងនេះដល់សង្ឃ ) ។ កាលមិនអាចនឹងពោលបាលីបាន គប្បីពោលដោយភាសាដទៃក៏បាន ។ ភិក្ខុគប្បីទទួលអាបត្តិ ដោយន័យដូចពោលទុកក្នុងខន្ធកៈនោះឯងថា ភិក្ខុអ្នកឈ្លាសប្រតិពល គប្បីទទួលអាបត្តិ ។ សមដូចព្រះតម្រាស់ត្រាស់ទុកក្នុងខន្ធកៈយ៉ាងនេះថា ភិក្ខុអ្នកឈ្លាសប្រតិពល គប្បីផ្ទៀងសង្ឃថា លោកមានអាយុទាំងឡាយ ចូរស្ដាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នឹកឃើញអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សម្ដែងអាបត្តិ ។ បើកម្មមានកាលដ៏សមគួរដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុឈ្មោះនេះ ។

ភិក្ខុអ្នកនោះត្រូវពោលថា **បស្សសិ** លោកឃើញឬទេ ។ អ្នកសម្ដែង

ត្រូវពោលថា **អាម ភន្តេ បស្សាមិ** ខ្ញុំឃើញលោកម្ចាស់ អ្នកទទួលប្រាប់ថា **អាយតឹ សំវរេយ្យាសិ** លោកគប្បីសង្រួមតទៅ អ្នកសម្តែងទទួលថា **សាធុ សុដ្ឋុ សំវរិស្សាមិ** សាធុ ខ្ញុំនឹងសង្រួមឲ្យល្អ ។

ក្នុងអាបត្តិ ២ ឬអាបត្តិច្រើន អ្នកសិក្សាគប្បីជ្រាបការផ្សេងគ្នានៃវចនៈដោយន័យមុននោះឯង សូម្បីក្នុងការឲ្យចីវរ ( ប្រគល់ឲ្យវិញ ) ក៏គប្បីជ្រាបសេចក្តីប្លែកគ្នានៃវចនៈ ដោយអំណាចនៃវត្ថុ គឺ **សង្ឃោ ឥមំ ចីវរំ ឥមានិ ចីវរានិ ...** សង្ឃគប្បីឲ្យចីវរមួយផ្ទាំងនេះ ... គប្បីឲ្យចីវរទាំងឡាយនេះ ... សូម្បីក្នុងការលះបង់ដល់គណៈ និងដល់បុគ្គល ក៏មានន័យយ៉ាងនេះដូចគ្នា ។

[ ៥-៦ ] ក្នុងការសម្តែង និងការទទួលអាបត្តិ ក្នុងអធិការនេះ មានបាលី ដូចតទៅនេះថា **តេន ភិក្ខវេ ភិក្ខុនា ។បេ។ ឯវមស្ស វចនីយោ អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុច្រើនរូប ហើយធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ក្រាបសំពះ បាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី គប្បីពោលយ៉ាងនេះ នឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណា ត្រូវអាបត្តិឈ្មោះនេះហើយ សូមសម្តែងអាបត្តិនោះចេញ ។

ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្ទៀងភិក្ខុទាំងនោះឲ្យជ្រាបថា **សុណន្តុ មេ ភន្តេ អាយស្មន្តា អយំ ឥត្ថន្នាមោ ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តានីករោតិ ទេសេតិ ។ យទា យស្មន្តានំ បត្តកល្លំ អហំ ឥត្ថន្នាមស្ស ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យំ** លោកមានអាយុទាំងឡាយ ចូរស្តាប់ខ្ញុំ ភិក្ខុឈ្មោះ

នេះ នឹកឃើញអាបត្តិ បង្កើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សម្តែងអាបត្តិ ។ បើកម្មមានកាលដ៏សមគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុឈ្មោះនេះ ។

ភិក្ខុអ្នកទទួលអាបត្តិនោះ ត្រូវពោលថា **បស្សសិ** លោកឃើញឬទេ ។ ភិក្ខុអ្នកសម្តែងពោលថា **អាម បស្សាមិ** ករុណា ខ្ញុំឃើញ ។ ភិក្ខុអ្នកទទួលត្រូវប្រាប់ថា **អាយតឹ សំវរេយ្យាសិ** លោកត្រូវសង្រួមតទៅទៀត ។

ភិក្ខុនោះគប្បីចូលទៅរកភិក្ខុមួយអង្គ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាងហើយ អង្គុយច្រហោង ផ្គងអញ្ជលី ហើយពោលយ៉ាងនេះថា លោកដ៏មានអាយុ ខ្ញុំត្រូវអាបត្តិមានឈ្មោះនេះហើយ ។ ភិក្ខុអ្នកទទួលអាបត្តិនោះ គប្បីពោលថា លោកឃើញឬ អ្នកសម្តែងគប្បីពោលថា **អាម បស្សាមិ** ខ្ញុំឃើញ អ្នកទទួលប្រាប់ថា **អាយតឹ សំវរេយ្យាសិ** លោកគប្បីសង្រួមតទៅ ។

ក្នុងវិស័យនៃការសម្តែង និងទទួលអាបត្តិនោះ អ្នកសិក្សាគប្បីជ្រាបការប្រាព្ធឈ្មោះអាបត្តិ និងការផ្សេងគ្នានៃវចនៈដោយន័យមុននោះឯង ។ គប្បីជ្រាបបាលីក្នុងការលះបង់ដល់ភិក្ខុ ២ រូប ដូចក្នុងការលះដល់គណៈដូច្នោះ ។ បើគប្បីមានការប្លែកគ្នាសោត ព្រះមានព្រះភាគ គប្បីត្រាស់បាលីមួយផ្នែកក្នុងការលះដល់ភិក្ខុ ២ រូបនេះ ដូចដែលទ្រង់ត្រាស់បារិសុទ្ធិឧបោសថដល់ភិក្ខុ ៣ រូប ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ៣ រូប ធ្វើបារិសុទ្ធិឧបោសថដល់គ្នានឹងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបារិសុទ្ធិឧបោសថនោះ ត្រូវភិក្ខុធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុដែលឈ្លាសប្រតិពល ឲ្យភិក្ខុ

ទាំងឡាយនោះដឹង ... ហើយត្រាស់បារិសុទ្ធិឧបោសថដល់ភិក្ខុ ២ រូបមួយផ្នែកទៀតដោយឡែក ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភិក្ខុ ២ រូប ធ្វើបារិសុទ្ធិឧបោសថបាន ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបោសថនោះ ត្រូវភិក្ខុទាំងឡាយធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុថេរៈធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ... ដូច្នេះ ។ ព្រោះមិនមានការប្លែកគ្នា ដូច្នោះ ទើបព្រះមានព្រះភាគមិនបានត្រាស់ទុក ទ្រង់រំលងទៅ ព្រោះដូច្នោះ បាលីក្នុងការលះបង់ដល់ភិក្ខុ ២ រូបនេះ ជាបាលីដែលត្រាស់ទុកដល់គណៈដូចគ្នា ។

ចំណែកក្នុងការទទួលអាបត្តិ មានការប្លែកគ្នាដូច្នេះថា បណ្តាភិក្ខុ ២ រូប ភិក្ខុរូបណាមួយ កុំតាំងញត្តិដូចភិក្ខុដែលទទួលអាបត្តិតាំងញត្តិ ក្នុងកាលភិក្ខុត្រូវអាបត្តិលះបង់ដល់គណៈ ហើយសម្តែងអាបត្តិ គប្បីទទួលអាបត្តិ ដូចបុគ្គលម្នាក់ទទួល ដូច្នោះ ។ ពិតហើយ ឈ្មោះថា ការតាំងញត្តិសម្រាប់ភិក្ខុ ២ រូបរមែងមិនមាន ។ បើមាន ព្រះមានព្រះភាគមិនគប្បីត្រាស់បារិសុទ្ធិ-ឧបោសថទុកមួយផ្នែក សម្រាប់ភិក្ខុ ២ រូប សូម្បីក្នុងការឲ្យចីវរដែលលះបង់ហើយទៅវិញ និងពោលថា **ឥមំ ចីវរំ អាយស្មតោ ទេម** ពួកខ្ញុំឲ្យចីវរមួយនេះដល់លោក ដូចភិក្ខុមួយរូបពោលថា **ឥមំ ចីវរំ អាយស្មតោ ទម្មិ** ខ្ញុំឲ្យចីវរទាំងនេះដល់លោក ដូច្នេះក៏គួរ ។ ពិតហើយ សូម្បីញត្តិទុតិយកម្មដែលធ្ងន់ជាងនេះ ត្រាស់ថា គួរអបលោកធ្វើក៏មាន ។ វិនយកម្មមានការលះនេះ សមគួរដល់ញត្តិទុតិយកម្មទាំងនោះ ។ ចីវរដែលលះបង់ហើយ គួរឲ្យមកវិញ នឹងមិនឲ្យមិនបាន ។ ឯការឲ្យត្រឡប់មកវិញ នូវចីវរដែលលះបង់

ហើយនេះ ជាវិនយកម្ម ។ ចីវរនោះ ទោះជាភិក្ខុនោះឲ្យដល់សង្ឃក្តី គណៈក្តី បុគ្គលក្តី មិនបានទាំងអស់នោះឯង ។

# អធិប្បាយ

# បទភាជនីយ៍នៃបឋមកឋិនសិក្ខាបទ

បទថា **ទសាហាតិក្កន្តេ អតិក្កន្តសញ្ញី** បានដល់ បុគ្គលមានសេចក្តីសម្គាល់ក្នុងចីវរដែលកន្លង ១០ ថ្ងៃហើយ យ៉ាងនេះថា ចីវរនេះកន្លង ( ១០ ថ្ងៃ ) ហើយ ។ ម្យ៉ាងទៀត សេចក្តីថា កាល ១០ ថ្ងៃកន្លងហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា ១០ ថ្ងៃកន្លងទៅហើយ ។

បទថា **និស្សគ្គិយំ ធាចិត្តិយំ** សេចក្តីថា ការសម្គាល់ដែលពោលទុកក្នុងបទថា **អតិក្កន្តសញ្ញី** នេះ រក្សាអាបត្តិមិនបាន សូម្បីភិក្ខុណា ទោះមានសេចក្តីសម្គាល់យ៉ាងនេះ ចីវរនោះរបស់ភិក្ខុនោះ ក៏ជានិស្សគ្គិយ ហើយភិក្ខុនោះក៏ត្រូវអាបត្តិបាចិត្តិយផងដែរ ឬជាបាចិត្តិយ មានការលះបង់ជាវិនយ-កម្ម ព្រោះដូច្នោះ អត្ថវិកប្បទាំង ២ រមែងត្រឹមត្រូវ ។ គ្រប់ៗ បទក៏មានន័យដូច្នេះ ។

បទថា **អវិស្សដ្ឋេ វិស្សដ្ឋសញ្ញី** បានដល់ ដែលមានសេចក្តីសម្គាល់ក្នុងចីវរដែលខ្លួនមិនបានឲ្យ គឺមិនបានលះបង់ឲ្យដល់បុគ្គលណាមួយយ៉ាងនេះថា អញលះបង់ហើយ ។

បទថា **អនដ្ឋេ នដ្ឋសញ្ញី** សេចក្តីថា ចោរទាំងឡាយរមែងលួចយកចីវរដ៏ច្រើនរបស់ភិក្ខុពួកដទៃ ដែលរក្សាទុកជាមួយចីវររបស់ខ្លួន បណ្តាភិក្ខុ

ទាំងនោះ ភិក្ខុរូបនេះ ជាអ្នកមានការសម្គាល់ក្នុងចីវររបស់ខ្លួន ដែលមិនបាន បាត់ទៅ ថាបាត់ហើយ ។ សូម្បីក្នុងចីវរដែលមិនបានវិនាសជាដើម ក៏មាន ន័យដូច្នេះ ។

ក្នុងបទថា **អវិលុត្តេ** នេះ គប្បីជ្រាបសន្និដ្ឋានថា ក្នុងចីវរដែលចោរ មិនបានដណ្តើមយកទៅ ដោយអំណាចការទម្លាយជញ្ជាំង ហើយគំរាមកំហែងប្លន់យកទៅ ។

បទថា **អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស** សេចក្តីថា ភិក្ខុ មិនដោះចីវរដែលស្លៀកម្តង ឬដណ្តប់ម្តង ចេញអំពីកាយ ហើយត្រាច់ទៅ សូម្បីអស់ថ្ងៃ ជាអាបត្តិ ១ ប៉ុណ្ណោះ ។ ភិក្ខុដោះចេញហើយ ស្លៀក ឬ ដណ្តប់ចីវរដែលមិនទាន់លះបង់នោះ ត្រូវអាបត្តិទុក្កដគ្រប់ៗប្រយោគ ។ រៀបចំចីវរដែលស្លៀកដណ្តប់មិនរៀបរយ ឬដណ្តប់មិនរៀបរយ ឲ្យរៀបរយ មិនត្រូវអាបត្តិ ។ មិនជាអាបត្តិដល់ភិក្ខុដែលប្រើប្រាស់របស់ភិក្ខុដទៃ ឯពាក្យ ជាដើមថា ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយប្រើប្រាស់ ដូច្នេះ ជាគ្រឿង សាធកៈ ក្នុងការមិនត្រូវអាបត្តិនោះ ។ ទ្រង់សំដៅយកការប្រើប្រាស់ កាត់ អាបត្តិទុក្កដដល់ភិក្ខុ ដែលមានការសម្គាល់ក្នុងចីវរដែលមិនទាន់កន្លង ( ១០ ថ្ងៃ ) ថាកន្លងហើយ និងភិក្ខុដែលមានសេចក្តីសង្ស័យ ។

## អនាបត្តិក្នុងបឋមកឋិនសិក្ខាបទ

[ ៨ ] ក្នុងបទថា **អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ** នេះ អ្នកសិក្សាគប្បីជ្រាបចីវរដែលគួរអធិដ្ឋាន និងដែលគួរវិកប្ប ។ ក្នុងចីវរដែល

គួរអធិដ្ឋាន និងវិកប្បនោះ មានព្រះបាលីដូចតទៅនេះថា គ្រានោះឯង ភិក្ខុទាំងឡាយ មានសេចក្តីរំពឹងយ៉ាងនេះថា ចីវរទាំងឡាយ ដែលព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតទុក គឺចីវរ ៣ ក្តី វស្សិកសាដកក្តី និសីទនៈក្តី បច្ចត្ថរណៈក្តី កណ្ឌុបដិច្ឆាទិក្តី មុខបុញ្ឆនចោឡក្តី បរិក្ខារចោឡក្តី គួរអធិដ្ឋានទាំងអស់ ឬគួរវិកប្បឬហ្ន៎ ។ ភិក្ខុទាំងឡាយបានក្រាបទូលរឿងនេះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ អធិដ្ឋានត្រៃចីវរ មិនអនុញ្ញាតឲ្យវិកប្ប ឲ្យអធិដ្ឋានវស្សិកសាដកអស់កាល ៤ ខែនៃរដូវភ្លៀង ផុតអំពី ៤ ខែរដូវភ្លៀងនោះ អនុញ្ញាតឲ្យវិកប្បទុក អនុញ្ញាតឲ្យអធិដ្ឋាននិសីទនៈ មិនឲ្យវិកប្បៈ អនុញ្ញាតឲ្យអធិដ្ឋានសំពត់ក្រាល មិនឲ្យវិកប្បៈ អនុញ្ញាតឲ្យអធិដ្ឋានកណ្ឌុបដិច្ឆាទិ ( សំពត់រុំដំបៅ ) ក្នុងរយៈពេលអាពាធ ផុតអំពីអាពាធនោះ អនុញ្ញាតឲ្យវិកប្បៈ អនុញ្ញាតឲ្យអធិដ្ឋានមុខបុញ្ឆនចោឡ ( សំពត់ជូតមុខ ) មិនអនុញ្ញាតឲ្យវិកប្បៈ អនុញ្ញាតឲ្យអធិដ្ឋានបរិក្ខារចោឡ មិនអនុញ្ញាតឲ្យវិកប្បៈ ដូច្នេះ ។

## ការអធិដ្ឋានត្រៃចីវរជាដើម

បណ្តាចីវរជាដើមនោះ ភិក្ខុកាលអធិដ្ឋានត្រៃចីវរ ជ្រលក់ហើយ ធ្វើកប្បពិន្ទុ គប្បីអធិដ្ឋានចីវរដែលបានប្រមាណប៉ុណ្ណោះ ប្រមាណនៃចីវរនោះដោយកំណត់យ៉ាងធំបំផុត តូចជាងសុគតចីវរ ទើបគួរ ។ និងដោយកំណត់យ៉ាងតូចប្រមាណនៃសង្ឃាដី និងឧត្តរាសង្គ បណ្តោយ ៥ ហត្ថក្តាប់ ទទឹង ៣ ហត្ថក្តាប់ ទើបគួរ ។ អន្តរវាសក(ស្បង់) បណ្តោយ ៥ ហត្ថក្តាប់ ទទឹង

២ ហត្ថក៏គួរ ព្រោះអាចដើម្បីបិទបាំងមណ្ឌលផ្ចិត ដោយសំពត់ស្លៀកខ្លះ សំពត់ដណ្ដប់ខ្លះ ដូច្នេះ ។ ឯចីវរដែលធំ និងតូចជាងប្រមាណ ដូចពោល ហើយ គប្បីអធិដ្ឋានថា បរិក្ខារចោឡ ។

ក្នុងវិស័យនៃការអធិដ្ឋានចីវរនោះ លោកពោលទុកថា ការអធិដ្ឋានចីវរ មាន ២ យ៉ាង គឺអធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ដូច្នោះ ភិក្ខុ គប្បីដកសង្ឃាដីចាស់ចោលថា **ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** អញដកសង្ឃាដី មួយនេះ ហើយយកដៃចាប់សង្ឃាដីថ្មី ឬពាក់លើចំណែកនៃរាងកាយ ធ្វើការ ផ្ដោតចិត្តថា **ឥមំ សង្ឃាដឹ អធិដ្ឋាមិ** អញអធិដ្ឋានសង្ឃាដីនេះ ហើយគប្បី ធ្វើកាយវិការ អធិដ្ឋានដោយកាយនេះ ឈ្មោះថា ការអធិដ្ឋានដោយកាយ ។ កាលមិនពាល់ត្រូវចីវរនោះ ដោយចំណែកនៃរាងកាយណាមួយ ការអធិដ្ឋាន នោះ មិនគួរ ។

ចំណែកការអធិដ្ឋានដោយវាចា គប្បីបន្លឺវាចា ហើយអធិដ្ឋានដោយ វាចា ។ ក្នុងការអធិដ្ឋានដោយវាចានោះ មានការអធិដ្ឋាន ២ វិធី ។ បើ សំពត់សង្ឃាដីនៅក្នុងហត្ថបាស គប្បីបន្លឺវាចាថា អញអធិដ្ឋានសង្ឃាដីមួយ នេះ ។ បើនៅខាងក្នុងបន្ទប់ក្នុងប្រាសាទជាន់លើ ឬក្នុងវត្តក្បែរៗ នោះ គប្បី កំណត់ទីដែលទុកសង្ឃាដីនោះ ហើយបន្លឺវាចាថា **ឯតំ សង្ឃាដឹ អធិដ្ឋាមិ** អញអធិដ្ឋានសង្ឃាដីនោះ ។ ក្នុងឧត្តរាសង្គ( ចីវរ ) និងអន្តរវាសក ក៏មាន ន័យយ៉ាងនេះ ។ ពិតហើយ ត្រឹមតែឈ្មោះប៉ុណ្ណោះដែលប្លែកគ្នា ។ ព្រោះ ដូច្នោះ គប្បីអធិដ្ឋានចីវរទាំងអស់ដោយឈ្មោះរបស់ខ្លួនប៉ុណ្ណោះ យ៉ាងនេះថា

**សង្ឃាដី ឧត្តរាសង្គំ អន្តរវាសកំ** ដូច្នេះ ។

បើភិក្ខុធ្វើចីវរ មានសង្ឃាដីជាដើម ដោយសំពត់ដែលអធិដ្ឋានរក្សាទុកកាលជ្រលក់ និងវិកប្បស្រេចហើយ គប្បីដកថា **ឥមំ បច្ចុទ្ធរាមិ** អញដកសំពត់នេះ ហើយអធិដ្ឋានជាថ្មី ។ តែកាលដេរសំពត់ផ្ទាំងថ្មី ឬខណ្ឌថ្មី ចំពោះដែលធំជាងចីវរដែលអធិដ្ឋានហើយ គួរអធិដ្ឋានជាថ្មី ។ ក្នុងផ្ទាំងសំពត់ដែលប៉ុនគ្នា ឬតូចជាង មិនមានកិច្ចដោយការអធិដ្ឋានថ្មីឡើយ ។

សួរថា ត្រៃចីវរនឹងអធិដ្ឋានជាបរិក្ខារចោឡ គួរ ឬមិនគួរ ឆ្លើយថា បានឮថា ព្រះមហាបទុមត្ថេរពោលថា ត្រៃចីវរ គប្បីអធិដ្ឋានជាត្រៃចីវរតែម្យ៉ាង បើអធិដ្ឋានជាបរិក្ខារចោឡបាន ការរក្សាដែលត្រាស់ទុកក្នុងឧទ្ទោសិតសិក្ខាបទ ក៏ឥតប្រយោជន៍ទៅ បានឮថា កាលព្រះមហាបទុមត្ថេរ ពោលយ៉ាងនេះ ពួកភិក្ខុដ៏សេសពោលថា សូម្បីបរិក្ខារចោឡ ព្រះមានព្រះភាគក៏ត្រាស់ថា គប្បីអធិដ្ឋាន ព្រោះហេតុនោះ ការអធិដ្ឋានត្រៃចីវរឲ្យជាបរិក្ខារចោឡ រមែងសមគួរ ។

សូម្បីក្នុងមហាបច្ចរីក៏ពោលថា ឈ្មោះថា បរិក្ខារចោឡនេះ ជាហេតុនៃការរក្សាទុក ( ដោយភាពមិនជានិស្សគ្គិយ ) ទុកមួយផ្នែក ។ ទោះអធិដ្ឋានត្រៃចីវរថា **បរិក្ខារចោឡ** ហើយប្រើប្រាស់ គួរ ។ ឯក្នុងឧទ្ទោសិតសិក្ខាបទ ត្រាស់ការរក្សាទុកសម្រាប់ភិក្ខុដែលអធិដ្ឋានត្រៃចីវរ ហើយរក្សា ។

បានឮថា ព្រះមហាតិស្សត្ថេរអ្នកពោលឧកតោវិភង្គ ដែលនៅត្រង់បុណ្ណវាលិការាម បានពោលថា ក្នុងកាលមុន ពួកយើងបានស្តាប់អំពីព្រះ

មហាថេរៈថា ពួកភិក្ខុដែលពេញចិត្តនៅក្នុងព្រៃ រក្សាចីវរទុកក្នុងព្រង់ឈើជាដើម ទៅដើម្បីបំពេញសេចក្តីព្យាយាម កាលភិក្ខុទាំងនោះទៅ ដើម្បីបំណងស្តាប់ធម៌ក្នុងវិហារជិតនោះ កាលព្រះអាទិត្យរះឡើងហើយ ពួកសាមណេរឬពួកភិក្ខុកំលោះ ទើបកាន់បាត្រចីវរមកឲ្យ ព្រោះដូច្នោះ ការអធិដ្ឋានត្រៃចីវរជាបរិក្ខារចោឡ ដើម្បីប្រើប្រាស់ងាយស្រួល គួរ ។

សូម្បីក្នុងមហាបច្ចរីក៏ពោលថា ក្នុងកាលមុន ពួកភិក្ខុដែលនៅព្រៃ បានអធិដ្ឋានត្រៃចីវរជាបរិក្ខារចោឡនោះឯង ហើយប្រើប្រាស់ ដោយតាំងចិត្តថាក្នុងដែនដែលមិនបានចងសីមា រក្សាបានលំបាក ។

វស្សិកសាដកដែលមិនធំហួសប្រមាណ ភិក្ខុគប្បីប្រារព្ធឈ្មោះ ហើយអធិដ្ឋានអស់ ៤ ខែ ក្នុងរដូវភ្លៀង ដោយន័យដូចពោលហើយនោះឯង បន្ទាប់អំពីនោះ គប្បីដកអធិដ្ឋាន ហើយវិកប្បៈទុក ។ ឯវស្សិកសាដកនេះ សូម្បីជ្រលក់ល្មមធ្វើឲ្យខូចពណ៌ក៏គួរ តែពីរផ្ទាំងមិនគួរ ។

សំពត់និសីទនៈ គប្បីអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ។ ឯសំពត់និសីទនៈនោះ ដែលត្រូវប្រមាណ គប្បីមានត្រឹមមួយផ្ទាំងប៉ុណ្ណោះ ប្រើ ២ ផ្ទាំងមិនគួរ ។

សំពត់ក្រាលដេក ក៏គួរអធិដ្ឋានដូចគ្នា ។ សំពត់ក្រាលដេកនោះ សូម្បីធំក៏គួរ មួយផ្ទាំងក៏គួរ សូម្បីច្រើនផ្ទាំងក៏គួរ មានលក្ខណៈពណ៌ខៀវក្តី លឿងក្តី មានជាយក្តី មានជាយជារូបផ្កាក្តីជាដើម រមែងគួរគ្រប់ប្រការ ។ ភិក្ខុអធិដ្ឋានម្តង ឈ្មោះថា អធិដ្ឋានហើយស្រេច ។

សំពត់គ្របបូស ដែលត្រូវខាត គប្បីអធិដ្ឋានមួយរយៈពេលដែលនៅមានអាពាធ បើអាពាធជាហើយ គប្បីបច្ចុទ្ធរណៈ វិកប្បៈទុក ។ សំពត់មួយផ្ទាំងប៉ុណ្ណោះ ទើបគួរ ។

សំពត់ជូតមុខ គប្បីអធិដ្ឋានដូចគ្នា ។ ភិក្ខុចាំបាច់ប្រើសំពត់ដទៃដើម្បីប្រើប្រាស់នៅពេលដែលសំពត់មួយផ្ទាំងទៀត ត្រូវបោកគក់ ព្រោះដូច្នោះ ២ ផ្ទាំង ក៏គួរ ។ តែព្រះថេរៈមួយពួកទៀតពោលថា ការអធិដ្ឋានសំពត់ជូតមុខនោះ សំដៅយកការរក្សាទុកជាសំខាន់ ។ សូម្បីច្រើនផ្ទាំង ក៏គួរ ។

ក្នុងបរិក្ខារចោឡ ឈ្មោះថា ការរាប់ចំនួនមិនមាន គប្បីអធិដ្ឋានបានតាមចំនួនដែលត្រូវការនោះឯង ។ ថង់យាមក្តី សំពត់តម្រងទឹកក្តី មានប្រមាណប៉ុនចីវរដែលគួរវិកប្បយ៉ាងតូច គប្បីអធិដ្ឋានជា បរិក្ខារចោឡដូចគ្នា សូម្បីប្រមូលចីវរច្រើនផ្ទាំងចូលគ្នា អធិដ្ឋានថា **ឥមានិ ចីវរានិ បរិក្ខារ-ចោឡានិ អធិដ្ឋាមិ** អញអធិដ្ឋានចីវរទាំងនេះជា បរិក្ខារចោឡ ដូច្នេះក៏គួរដូចគ្នា ។ សូម្បីភិក្ខុរក្សាទុកដើម្បីប្រយោជន៍ដល់កេសដ្ឋៈ នវកម្ម និងមាតាបិតាជាដើម ក៏ចាំបាច់អធិដ្ឋានពិត ។ តែក្នុងមហាបច្ចរីពោលថា មិនត្រូវអាបត្តិ ។

ឯក្នុងសេនាសនបរិក្ខារទាំងនេះ គឺពូកគ្រែ ១ ពូកតាំង ១ ខ្នើយ ១ សំពត់បាវារ ១ សំពត់កោជវៈ ( ព្រំ ) ១ និងក្នុងគ្រឿងកម្រាលដែលគេប្រគេនដើម្បីប្រយោជន៍ដល់សេនាសនបរិក្ខារ មិនមានកិច្ចដែលត្រូវអធិដ្ឋានឡើយ ។

# ហេតុឱ្យដាច់អធិដ្ឋាន

សួរថា ចីវរដែលអធិដ្ឋានហើយ កាលភិក្ខុប្រើប្រាស់ នឹងដាច់អធិដ្ឋានទៅ ដោយហេតុដូចម្ដេច ឆ្លើយថា រមែងដាច់ដោយហេតុ ៩ យ៉ាង គឺឲ្យទៅបុគ្គលដទៃ ១ ត្រូវចោរដណ្ដើមយកទៅ ១ អ្នកដទៃកាន់យកដោយវិស្សាសៈ ១ ត្រឡប់ទៅជាហីនភេទ ១ ដោយលាសិក្ខា ១ ដោយមរណកាល ១ ដោយភេទត្រឡប់ ១ ដោយដកអធិដ្ឋាន ១ ដោយដាច់ធ្លុះ ១ ។

បណ្ដាហេតុ ៩ យ៉ាងនោះ ចីវរគ្រប់ប្រភេទ រមែងដាច់អធិដ្ឋានដោយហេតុ ៨ យ៉ាងខាងដើម ។ តែចំពោះត្រៃចីវរដាច់អធិដ្ឋានដោយការដាច់ធ្លុះ លោកពោលទុកក្នុងអដ្ឋកថាគ្រប់អន្លើ ។ ហើយការដាច់អធិដ្ឋាននោះ លោកពោលទុកដោយប្រហោងធ្លុះប្រមាណប៉ុនខ្នងក្រចក ។ ក្នុងប្រហោងធ្លុះប្រមាណប៉ុនខ្នងក្រចកនោះ អ្នកសិក្សាគប្បីជ្រាបទំហំប៉ុនខ្នងក្រចក ដោយអំណាចនៃក្រចកកូនដៃ និងប្រហោងធ្លុះជាប្រហោងនោះឯង ។ សូម្បីខាងក្នុងប្រហោងធ្លុះមានសរសៃអំបោះមួយសរសៃមិនទាន់ដាច់ គង់រក្សានៅឡើយ ។

បណ្ដាត្រៃចីវរនោះ សម្រាប់សង្ឃាដី និងឧត្តរាសង្គ ប្រហោងធ្លុះអំពីផ្នែកខាងក្នុងនៃសាច់ដែលមានប្រមាណត្រឹម ១ ចំអាមអំពីជាយផ្នែកបណ្ដោយមានប្រមាណ ៨ ធ្នាប់ អំពីជាយខាងទទឹង រមែងធ្វើឲ្យដាច់អធិដ្ឋាន ។ តែសម្រាប់អន្តរវាសក ប្រហោងធ្លុះអំពីផ្នែកខាងក្នុងនៃសាច់ ដែលមានប្រមាណ ១ ចំអាមអំពីជាយបណ្ដោយ មានប្រមាណ ៤ ធ្នាប់ អំពីជាយទទឹង រមែងដាច់អធិដ្ឋាន ។ ប្រហោងធ្លុះតូចចុះមក មិនធ្វើឲ្យដាច់អធិដ្ឋានឡើយ ។ ព្រោះដូច្នោះ កាលកើតជាប្រហោងធ្លុះ ចីវរនោះរមែងតាំងនៅក្នុងឋានៈនៃអតិរេក-

ចីវរ គួរធ្វើសូចិកម្ម ហើយអធិដ្ឋានជាថ្មី ។

តែព្រះមហាសុមត្ថេរពោលថា សម្រាប់ចីវរដែលបានប្រមាណ មានប្រហោងធ្លុះកន្លែងណាមួយ រមែងធ្វើឲ្យដាច់អធិដ្ឋាន តែសម្រាប់ចីវរដែលធំ ប្រហោងធ្លុះខាងក្រៅអំពីប្រមាណ មិនធ្វើឲ្យដាច់អធិដ្ឋានឡើយ ប្រហោងធ្លុះដែលកើតខាងក្នុង ទើបធ្វើឲ្យដាច់អធិដ្ឋាន ដូច្នេះ ។

ព្រះករវិយតិស្សត្ថេរពោលថា ចីវរតូច-ធំ មិនជាប្រមាណ ប្រហោងធ្លុះក្នុងទីដែលកិក្ខុ កាលគ្រងចីវរត្រួតគ្នាពីរជាន់ មូរមកពាក់ទុកលើដើមដៃខាងឆ្វេង មិនទាន់ធ្វើឲ្យដាច់អធិដ្ឋាន ប្រហោងធ្លុះចំណែកខាងក្នុង រមែងធ្វើឲ្យដាច់អធិដ្ឋាន សម្រាប់អន្តរវាសក ប្រហោងធ្លុះក្នុងទីនៃចីវរដែលកិក្ខុមូរឲ្យជាវប្ុម រមែងមិនធ្វើឲ្យដាច់អធិដ្ឋាន ប្រហោងធ្លុះដែលក្រោមចុះអំពីវប្ុំនោះរមែងធ្វើឲ្យដាច់អធិដ្ឋាន ។

ក្នុងអន្ធកអដ្ឋកថា លោកធ្វើវាទៈរបស់ព្រះមហាសុមត្ថេរឲ្យជាគោលក្នុងត្រៃចីវរ ហើយពោលថា ចីវរប្រមាណយ៉ាងតូចរមែងរក្សាអធិដ្ឋានទុកបាន ទើបពោលពាក្យនេះបន្ថែមទុកថា ក្នុងបរិក្ខារចោឡផ្នែកបណ្តោយ ៨ ធ្នាប់ ផ្នែកទទឹង ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត ជាប្រហោងធ្លុះក្នុងចំណែកណាមួយ រមែងដាច់អធិដ្ឋានទៅក្នុងបរិក្ខារចោឡផ្ទាំងធំ ប្រហោងធ្លុះដែលទាបជាង ៨ ធ្នាប់ និង ៤ ធ្នាប់នោះ មិនទាន់អធិដ្ឋានឡើយ ក្នុងចីវរដែលគួរអធិដ្ឋានទាំងអស់ ក៏មានន័យដូច្នេះ ។

បណ្តាវាទៈទាំង ៤ នោះ ដែលបានឈ្មោះថា ប្រមាណយ៉ាងតូច គឺ

ប្រមាណតូចបំផុតជាង នៃចីវរដែលគួរវិកប្បរបស់ចីវរដែលគប្បីអធិដ្ឋានទាំង អស់ រមែងមិនមាន ។ ព្រោះថា ប្រមាណនៃសំពត់និសីទនៈ សំពត់បិទដំបៅ និងសំពត់ងូតទឹកភ្លៀង ដែលលោកពោលទុកនោះ ជាប្រមាណយ៉ាងធំ ព្រោះប្រមាណដែលក្រៃលែងជាងប្រមាណយ៉ាងធំនោះ សម្រេចហើយ ( ប្រើបាន ) មិនមែនជាប្រមាណយ៉ាងតូចឡើយ ព្រោះប្រមាណយ៉ាងតូចចុះមក អំពីប្រមាណយ៉ាងធំនោះ មិនសម្រេច ( ប្រើមិនបាន ) ។ ត្រៃចីវរដែលតូចជាងប្រមាណនៃសុគតចីវរ ចាត់ជាប្រមាណយ៉ាងធំដូចគ្នា ។ តែប្រមាណយ៉ាងតូច ដែលលោកចែកពោលទុកក្នុងព្រះសូត្រមិនមាន ។

ការកំណត់ខ្នាតធំនៃសំពត់ជូតមុខ កម្រាលដេក និងបរិក្ខារចោឡ មិនមានដូចគ្នា ។ តែលោកពោលកំណត់ទុកដោយប្រមាណយ៉ាងតូច ប៉ុនទំហំចីវរដែលគួរវិកប្ប ។ ព្រោះដូច្នោះ ពាក្យណាដែលលោកពោលទុកមុន ក្នុងអដ្ឋកថាអន្ធកៈថា ប្រមាណយ៉ាងតូច រមែងរក្សាការអធិដ្ឋានទុកបាន ហើយសម្ដែងប្រមាណយ៉ាងតូច ៨ ធ្នាប់ និង ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគតនៃបរិក្ខារចោឡ ក្នុងបណ្ដាត្រៃចីវរ និងបរិក្ខារចោឡជាដើមនោះ និងសំដៅយកប្រមាណយ៉ាងតូចនៃត្រៃចីវរជាដើមក្រៅអំពីនេះ ដែលមានប្រភេទ ៥ ហត្ថក្តាប់ជាដើម ទើបពោលថា ក្នុងចីវរដែលគួរអធិដ្ឋានទាំងអស់ ក៏ន័យនេះ ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាអន្ធកៈនោះ រមែងមិនសមគ្នា ។ សូម្បីក្នុងវាទៈរបស់ព្រះករវិយតិស្សត្ថេរ លោកក៏សម្ដែងប្រហោងធ្លុះអំពីជាយផ្នែកបណ្ដោយប៉ុណ្ណោះ ជាយផ្នែកទទឹងមិនបានសម្ដែងឡើយ ព្រោះដូច្នោះ វាទៈ

របស់ព្រះករវិយតិស្សត្ថេរនោះ ក៏មិនបានកំណត់ទុក ។

ក្នុងវាទៈរបស់ព្រះមហាសុមត្ថេរ ពោលទុកថា ប្រហោងធ្លុះក្នុងទីណាមួយនៃចីវរដែលបានប្រមាណ រមែងធ្វើឲ្យដាច់អធិដ្ឋាន ប្រហោងធ្លុះខាងក្រៅអំពីប្រមាណនៃចីវរខ្នាតធំ តែលោកក៏មិនបានពោលថា ចីវរឈ្មោះនេះ ចាត់ជាចីវរដែលបានប្រមាណ ចីវរដែលធំជាងប្រមាណនេះចាត់ជាចីវរធំ ។

ម្យ៉ាងទៀត ក្នុងវិស័យនៃត្រៃចីវរជាដើមនេះ អាចារ្យទាំងឡាយ បំណងយកពាក្យថា ទំហំដែលផ្សេងគ្នា មាន ៥ ហត្ថជាដើម ជាប្រមាណយ៉ាងតូចនៃត្រៃចីវរជាដើម បើក្នុងចីវរធំនោះ ប្រហោងធ្លុះខាងក្រៅអំពីប្រមាណយ៉ាងតូច មិនគប្បីធ្វើឲ្យដាច់អធិដ្ឋានសោត ប្រហោងធ្លុះអំពីខាងក្រៅប្រមាណយ៉ាងតូចសូម្បីនៃបាត្រខ្នាតធំ ឬនៃបាត្រខ្នាតកណ្ដាល ក៏មិនគប្បីធ្វើឲ្យដាច់អធិដ្ឋានតែ ( ប្រហោងធ្លុះខាងក្រៅអំពីប្រមាណយ៉ាងតូច ) នឹងមិនធ្វើឲ្យដាច់អធិដ្ឋានក៏ទេ ព្រោះដូច្នោះ វាទៈនេះក៏មិនបានកំណត់ខ្នាតទុក ។

តែអដ្ឋកថាវាទៈដំបូងបង្អស់នេះជាប្រមាណ ក្នុងអធិការវិនិច្ឆ័យត្រៃចីវរជាដើមនេះ ។ ព្រោះហេតុអ្វី ព្រោះមានកំណត់ ។ ពិតហើយ ប្រមាណយ៉ាងតូចនៃត្រៃចីវរ ប្រមាណប្រហោងធ្លុះ និងប្រមាណនៃចំណែកដែលជាប្រហោងធ្លុះ លោកកំណត់ពោលទុកហើយ គ្រប់ៗ អដ្ឋកថាដូចគ្នា ។ ព្រោះដូច្នោះ វាទៈនោះឯងជាប្រមាណ ។ ព្រោះថា អដ្ឋកថាវាទនោះ លោកពោលអនុលោមតាមព្រះបំណងរបស់ព្រះមានព្រះភាគដោយពិត ។ ឯក្នុង ៣ វាទៈក្រៅអំពីនេះ មិនមានកំណត់ឡើយ ។ ពាក្យមុន និងពាក្យក្រោយ មិនសមគ្នា

ដូច្នេះឯង ។

ភិក្ខុណា ប៉ះសំពត់ថ្មីចុះក្នុងទីទ្រុឌទ្រោមជាមុនហើយ កាត់ ឬរុះទីដែលទ្រុឌទ្រោមចេញក្នុងកាលជាក្រោយ ការអធិដ្ឋានរបស់ភិក្ខុនោះ មិនដាច់ឡើយ សូម្បីក្នុងការផ្លាស់ប្តូរខ្នង់ ( ចីវរ ) ក៏មានន័យយ៉ាងនេះដូចគ្នា ។ សម្រាប់ចីវរពីរជាន់ កាលចីវរមួយជាន់ប្រហោងធ្លុះ ឬរសាត់ទៅ អធិដ្ឋានមិនដាច់ឡើយ ។ ភិក្ខុធ្វើចីវរផ្ទាំងតូចឲ្យជាផ្ទាំងធំ ឬធ្វើផ្ទាំងធំឲ្យជាផ្ទាំងតូច អធិដ្ឋានមិនដាច់ឡើយ ។ តែកាលតជាយសងខាងចូលត្រង់កណ្តាល បើកាត់ចេញមុន ហើយដេរជាក្រោយភ្ជាប់គ្នា អធិដ្ឋានរមែងដាច់ ។ បើដេរភ្ជាប់គ្នាហើយទើបកាត់ជាក្រោយ មិនដាច់អធិដ្ឋានឡើយ ។ សូម្បីប្រើពួកជាងជ្រលក់ជាសំពត់ស អធិដ្ឋានក៏នៅជាអធិដ្ឋានដដែល ។

វិនិច្ឆ័យក្នុងការអធិដ្ឋាន ក្នុងពាក្យថា **អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ** នេះ មានប្រមាណប៉ុណ្ណេះ ។

## អធិប្បាយ ការវិកប្បចីវរ

ចំណែកក្នុងការវិកប្ប មានវិនិច្ឆ័យដូចតទៅនេះថា វិកប្បមាន ២ យ៉ាង គឺ វិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។

សួរថា វិកប្បចំពោះមុខដូចម្តេច ឆ្លើយថា ភិក្ខុគប្បីជ្រាបថា ចីវរមួយផ្ទាំង ឬច្រើនផ្ទាំង បើចីវរដាក់ជិត ឬមិនបានដាក់ជិត ( នៅក្នុងហត្ថបាស ឬក្រៅហត្ថបាស ) ត្រូវពោលថា **ឥមំ ចីវរំ** ចីវរមួយផ្ទាំងនេះក្តី **ឥមានិ ចីវរានិ** ចីវរទាំងនេះក្តី **ឯតំ ចីវរំ** ចីវរនោះក្តី **ឯតានិ ចីវរានិ** ចីវរទាំងនោះក្តី ហើយ

*គប្បីពោលថា* **តុយ្ហំ វិកប្បេមិ** *ខ្ញុំវិកប្បដល់លោក ដូច្នេះ ។ វិកប្បចំពោះមុខនេះ មានតែម្យ៉ាង ។ ដោយការវិកប្បត្រឹមប៉ុណ្ណេះ នឹងរក្សាទុកសមគួរ ។ បើប្រើប្រាស់ក្តី លះបង់ក្តី អធិដ្ឋានក្តី មិនគួរ ។ តែកាលភិក្ខុនោះ ( ភិក្ខុដែលទទួលវិកប្ប ) ពោលពាក្យថា* **មយ្ហំ សន្តកំ មយ្ហំ សន្តកានិ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** *ចីវរនេះ ឬចីវរទាំងនេះជារបស់ខ្ញុំ លោកចូរប្រើប្រាស់ ចូរចំណាយ ចូរធ្វើតាមសមគួរដល់បច្ច័យចុះ ដូច្នេះ ឈ្មោះថា បច្ចុទ្ធរណៈ ( ដកវិកប្ប ) ចាប់តាំងអំពីពេលនោះ សូម្បីការបរិភោគជាដើម រមែងសមគួរ ។*

*ន័យម្យ៉ាងទៀត ភិក្ខុគប្បីដឹងថា ចីវរមួយផ្ទាំង ឬច្រើនផ្ទាំងដាក់ជិត ឬមិនបានដាក់ជិត យ៉ាងនោះឯង ហើយពោលថា* **ឥមំ ចីវរំ** *ក្តី* **ឥមានិ ចីវរានិ** *ដូច្នេះក្តី* **ឯតំ ចីវរំ** *ក្តី* **ឯតានិ ចីវរានិ** *ដូច្នេះក្តី ក្នុងសម្នាក់របស់ភិក្ខុនោះឯង ប្រាវព្ធឈ្មោះសហធម្មិក ៥ រូបណានីមួយ គឺបុគ្គលណាមួយ ដែលខ្វីនពេញចិត្ត ហើយគប្បីពោលថា* **តិស្សស្ស ភិក្ខុនោ វិកប្បេមិ** *ខ្ញុំ វិកប្ប ... ដល់ភិក្ខុតិស្សៈក្តី* **តិស្សាយ ភិក្ខុនិយា, តិស្សាយ សិក្ខមានាយ, តិស្សស្ស សាមណេរស្ស, តិស្សាយ សាមណេរិយា វិកប្បេមិ** *ខ្ញុំវិកប្ប ... ដល់តិស្សាភិក្ខុនី ដល់តិស្សាសិក្ខមានា ដល់តិស្សសាមណេរ ដល់តិស្សាសាមណេរី ដូច្នេះ ។ នេះជាវិកប្បចំពោះមុខមួយបែប ។ ដោយការវិកប្បប្រមាណប៉ុណ្ណេះ នឹងរក្សាទុក គួរ ។ តែក្នុងការប្រើប្រាស់ជាដើម ឬកិច្ចឯណាមួយ រមែងមិនគួរ ។ តែកាលភិក្ខុនោះពោលពាក្យថា ចីវរនេះរបស់ភិក្ខុ ឈ្មោះតិស្សៈ ។បេ។*

របស់សាមណេរីឈ្មោះតិស្សា លោកចូរបរិភោគក្តី លោកចូរចំណាយក្តី ចូរធ្វើតាមសមគួរដល់បច្ច័យក្តី ដូច្នេះ ឈ្មោះថា ជាការដក ចាប់ផ្តើមអំពីនោះ សូម្បីការប្រើប្រាស់ជាដើម ក៏សមគួរ ។

សួរថា ការវិកប្បកំបាំងមុខដូចម្តេច ឆ្លើយថា ភិក្ខុគប្បីជ្រាបថា ចីវរមួយផ្ទាំង ឬច្រើនផ្ទាំង និងចីវរដែលទុកជិតខ្លួន ឬមិនបានទុកជិតយ៉ាងនោះហើយ ពោលថា **ឥមំ ចីវរំ** នូវចីវរនេះក្តី **ឥមានិ ចីវរានិ** នូវចីវរទាំង-ឡាយនេះក្តី **ឯតំ ចីវរំ** នូវចីវរនោះក្តី **ឯតានិ ចីវរានិ** នូវចីវរទាំងឡាយនោះក្តី ដូច្នេះ ហើយពោលថា **តុយ្ហំ វិកប្បនត្ថាយ ទម្មិ** ខ្ញុំឲ្យដល់លោកដើម្បីប្រយោជន៍ដល់ការវិកប្ប ។ ភិក្ខុអ្នកវិកប្ប ដែលភិក្ខុអ្នកទទួលវិកប្បនោះគប្បីពោលថា នរណាជាមិត្រ ឬជាសម្លាញ់ធ្លាប់ឃើញក្តី សម្លាញ់ស្និទ្ធស្នាលរបស់លោកក្តី លំដាប់នោះ ភិក្ខុអ្នកវិកប្បគប្បីពោលថា ភិក្ខុឈ្មោះតិស្សៈក្តី ។បេ។ សាមណេរីឈ្មោះតិស្សាក្តី ដោយន័យមុននោះឯង ។ ភិក្ខុនោះគប្បីពោលពាក្យថា **អហំ តិស្សស្ស ភិក្ខុនោ ទម្មិ** ខ្ញុំឲ្យដល់ភិក្ខុឈ្មោះតិស្សៈ ។បេ។ ក្តី **អហំ តិស្សាយ សាមណេរិយា ទម្មិ** ខ្ញុំឲ្យដល់សាមណេរី ឈ្មោះតិស្សា ដូច្នេះ ។ យ៉ាងនេះ ឈ្មោះថា វិកប្បកំបាំងមុខ ។ ដោយការវិកប្បមានប្រមាណប៉ុណ្ណោះ ការរក្សាទុក គួរ ។ ឯការប្រើប្រាស់ជាដើម កិច្ចសូម្បីតែម្យ៉ាង ក៏មិនគួរ ។ តែកាលភិក្ខុនោះពោលពាក្យថា **ឥត្ថ-ន្នាមស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** ( ចីវរ ) នៃភិក្ខុឈ្មោះនេះ លោកចូរប្រើប្រាស់ក៏បាន ចំណាយក៏បាន

ធ្វើតាមសមគួរដល់បច្ច័យក៏បាន ដោយន័យដូចពោលហើយ ក្នុងវិកប្បចំពោះមុខបែបទី ២ នោះឯង ឈ្មោះថា ជាការដក ។ ចាប់តាំងអំពីដកហើយនោះ សូម្បីកិច្ចទាំងឡាយ មានការប្រើប្រាស់ជាដើម គួរ ។

សួរថា ការវិកប្បទាំង ២ យ៉ាងផ្សេងគ្នាដូចម្ដេច ឆ្លើយថា ក្នុងការវិកប្បចំពោះមុខ ភិក្ខុវិកប្បឯង ហើយឲ្យអ្នកដទៃដកបាន ក្នុងវិកប្បកំបាំងមុខ ភិក្ខុឲ្យអ្នកដទៃវិកប្បហើយ ឲ្យអ្នកដទៃនោះឯងដក នេះជាការផ្សេងគ្នាក្នុងរឿងវិកប្បទាំងពីរនេះ ។ បើវិកប្បដល់បុគ្គលណា បុគ្គលនោះមិនឈ្លាសក្នុងសិក្ខាបទបញ្ញត្តិ មិនចេះដក គប្បីកាន់ចីវរនោះ ទៅកាន់សម្នាក់សហធម្មិកដែលជាអ្នកឈ្លាស វិកប្បជាថ្មីហើយគប្បីឲ្យដក ។ នេះឈ្មោះថា ការវិកប្បបរិក្ខារដែលវិកប្បហើយ គួរ ។

ក្នុងបទថា **វិកប្បេតិ** នេះ មានវិនិច្ឆ័យដូចតទៅថា ព្រះមានព្រះភាគត្រាស់ដោយមិនប្លែកគ្នាថា **វិកប្បេតិ** នេះ មើលទៅហាក់ដូចជាខុសពីព្រះបាលីជាដើមថា **អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអធិដ្ឋានត្រៃចីវរ មិនមែនឲ្យវិកប្បដូច្នេះ តែព្រះតថាគតទាំងឡាយ រមែងមិនត្រាស់ពាក្យដែលខុស ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបអត្ថនៃពាក្យថា **អនុជានាមិ ភិក្ខវេ តិចីវរំ** ជាដើមនោះ ដោយន័យយ៉ាងនេះថា តថាគតអនុញ្ញាតឲ្យអធិដ្ឋានសម្រាប់ភិក្ខុដែលរក្សាត្រៃចីវរ ដោយសន្មេបថា ត្រៃចីវរប៉ុណ្ណោះមិនមែនឲ្យវិកប្ប តែសំពត់ងូតទឹកភ្លៀង អនុញ្ញាតឲ្យវិកប្បតែម្យ៉ាង បន្ទាប់អំពី ៤ ខែ ( រដូវភ្លៀង ) មិន

មែនអធិដ្ឋាន កាលមានអត្ថយ៉ាងនេះ ភិក្ខុអង្គណាប្រាថ្នានៅប្រាសចាកត្រៃចីវរផ្ទាំងណានីមួយ ដែលទ្រង់ប្រទានឱកាសដល់ភិក្ខុនោះ ដើម្បីដកចីវរអធិដ្ឋាន ហើយវិកប្ប ដើម្បីងាយស្រួលក្នុងការនៅប្រាស ( ត្រៃចីវរ ) មិនត្រូវអាបត្តិក្នុងកាលកន្លង ១០ ថ្ងៃ ដោយឧបាយនេះ បណ្ឌិតគប្បីជ្រាបការវិកប្ប មិនសម្រេចក្នុងចីវរជាដើមទាំងអស់ ដូច្នេះឯង ។

បទថា **វិកប្បេត្វា** មានវិនិច្ឆ័យថា ភិក្ខុឲ្យចីវរដល់អ្នកដទៃដូចម្ដេចឈ្មោះថា ឲ្យហើយ ដូចម្ដេច ឈ្មោះថា កាន់យកហើយ ភិក្ខុដែលលះបង់ឲ្យពោលថា **ឥមំ តុយ្ហំ ទេមិ ទទាមិ ទជ្ជាមិ ឱណោជេមិ បរិច្ចជាមិ វិស្សជ្ជាមិ** ខ្ញុំឲ្យ លើកឲ្យ ប្រគល់ឲ្យ បង្អោនឲ្យ លះបង់ឲ្យ ចំណាយចីវរមួយផ្ទាំងនេះដល់លោកក្ដី **ឥត្ថន្នាមស្ស ទេមិ ។បេ។ និស្សជ្ជាមិ** ខ្ញុំឲ្យ ។បេ។ លះបង់ឲ្យដល់លោក ដែលមានឈ្មោះនេះ ដូច្នេះ ឈ្មោះថា ឲ្យ ទាំងចំពោះមុខ និងកំបាំងមុខនោះឯង កាលបុគ្គលលះបង់ឲ្យ ហើយពោលថា **តុយ្ហំ គណ្ហាហិ** លោកចូរកាន់យករបស់លោកចុះ ដូច្នេះ ភិក្ខុអ្នកទទួលពោលថា **មយ្ហំ គណ្ហាមិ** ខ្ញុំកាន់យករបស់ខ្ញុំ ជាការឲ្យត្រូវ និងកាន់យកត្រូវ កាលអ្នកលះបង់ឲ្យ ពោលថា **តវ សន្តកំ ករោហិ តវ សន្តកំ ហោតុ តវ សន្តកំ ករិស្សសិ** លោកចូរធ្វើឲ្យជារបស់លោក ចូរជារបស់លោក លោកនឹងធ្វើឲ្យជារបស់លោក ដូច្នេះ ។ ភិក្ខុអ្នកទទួលពោលថា **មម សន្តកំ ករោមិ** ខ្ញុំនឹងធ្វើឲ្យជារបស់ខ្ញុំ **មម សន្តកំ ហោតុ** ចូរជារបស់ខ្ញុំ **មម សន្តកំ ករិស្សាមិ** ខ្ញុំនឹងធ្វើឲ្យជារបស់ខ្ញុំ ដូច្នេះ ជាការឲ្យមិនត្រូវ និងជាការកាន់យកមិនត្រូវ ។

ភិក្ខុអ្នកលះបង់ឲ្យមិនដឹង ដើម្បីនឹងឲ្យ ( មិនដឹងវិធីលះបង់ឲ្យ ) ឡើយ ឯអ្នកទទួល ក៏ពុំចេះដើម្បីនឹងទទួល ( មិនដឹងវិធីទទួល ) ។ កាលភិក្ខុដែលលះបង់ឲ្យពោលថា សូមលោកធ្វើឲ្យជារបស់លោក ភិក្ខុអ្នកទទួលពោលថា សាធុ លោកម្ចាស់ ខ្ញុំនឹងទទួលយក ហើយកាន់យក ជាការដែលឲ្យមិនត្រឹមត្រូវ តែជាការទទួលយកត្រឹមត្រូវ ។ បើមួយអង្គពោលថា លោកនឹងកាន់យកចុះ មួយអង្គទៀត ( គឺអ្នកទទួល ) ពោលថា ខ្ញុំមិនយក អ្នកលះបង់ឲ្យនោះពោលទៀតថា លោកចូរកាន់យករបស់ដែលខ្ញុំឲ្យហើយ ដើម្បីលោក ឯភិក្ខុនោះពោលថា ខ្ញុំមិនត្រូវការដោយទ្រព្យនេះ ក្រោយអំពីនោះ សូម្បីភិក្ខុអង្គមុន ក៏ឲ្យកន្លង ១០ ថ្ងៃទៅ ដោយយល់ថា អញឲ្យហើយ ឯភិក្ខុអង្គក្រោយក៏ឲ្យកន្លង ១០ ថ្ងៃទៅ ដោយយល់ថា អញបានបដិសេធហើយ ត្រូវអាបត្តិដល់បុគ្គលណា មិនត្រូវអាបត្តិដល់បុគ្គលណា មិនត្រូវអាបត្តិដល់បុគ្គលណាឡើយ បើភិក្ខុណាពេញចិត្ត ភិក្ខុអង្គនោះ គប្បីអធិដ្ឋានប្រើចុះ ។

ចំណែកភិក្ខុដែលមានសេចក្តីសង្ស័យក្នុងការអធិដ្ឋាន គប្បីធ្វើដូចម្តេច គប្បីប្រាប់ការសង្ស័យ ហើយពោលថា បើចីវរមិនបានអធិដ្ឋាន កាលបើដូច្នោះ ចីវរជារបស់គួរដល់ខ្ញុំ ហើយគប្បីលះបង់ដោយន័យដូចពោលហើយនោះឯង ។ ព្រោះថា កាលភិក្ខុឲ្យដឹងយ៉ាងនេះហើយ ធ្វើវិនយកម្ម មិនជាមុសាវាទឡើយ តែអាចារ្យពួកខ្លះពោលថា ចីវរនោះ ភិក្ខុមួយអង្គកាន់យកជាវិស្សាសៈហើយ សងវិញក៏គួរ ។ ពាក្យរបស់អាចារ្យពួកខ្លះនោះមិនត្រឹមត្រូវ ។ ព្រោះដូច្នោះ មិនមែនជាវិនយកម្មរបស់ភិក្ខុដែលមានសេចក្តីសង្ស័យ

នោះ ៗ ទាំងសំពត់នោះ ក៏មិនជាវត្ថុដទៃ ដោយហេតុគ្រាន់តែកាន់យកហើយសងវិញនេះទេ ។

បទថា **ឆស្សតិ** ជាដើម មានអត្ថពាក់ទាំងអស់ហើយ ។

[ ៩ ] ក្នុងបទថា **យោ ច ទទេយ្យ អាបត្តិ ទុក្កដស្ស** នេះ មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលមិនឲ្យវិញ ដោយការសម្គាល់យ៉ាងនេះថា ភិក្ខុនេះឲ្យហើយដល់អញ ។ តែភិក្ខុដែលដឹងថា ជារបស់ភិក្ខុនោះ ហើយដណ្តើមយកដោយលេស វិនយធរគប្បីវាយតម្លៃទ្រព្យ កាត់អាបត្តិដូច្នេះឯង ។

ក្នុងសមុដ្ឋានជាដើម សិក្ខាបទនេះ ឈ្មោះថា កឋិនសមុដ្ឋាន រមែងកើតតាមកាយ និងវាចា និងតាមកាយ វាចា និងចិត្ត ជាអកិរិយា ព្រោះត្រូវដោយការមិនអធិដ្ឋាន និងមិនវិកប្ប ជានោសញ្ញាវិមោក្ខ ព្រោះមិនរួចផុតដោយសញ្ញា សូម្បីមិនដឹងក៏ត្រូវ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមកឋិនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[ ១០ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុច្រើនរូបបានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ ( រួចស្លៀកដណ្ដប់ ) តែស្បង់ និងចីវរចេញទៅកាន់ជនបទចារិកទៅ ។ ឯចីវរដែលផ្ញើទុកនោះ យូរពេកក៏ជាមច្ចុកជាំអស់ ។ ភិក្ខុទាំងឡាយក៏យកចីវរទាំងអម្បាលនោះទៅហាលសំដិល ។ ព្រះអានន្ទដ៏មានអាយុបាននិមន្តទៅកាន់សេនាសនៈចារិក ក្រឡេកទៅឃើញភិក្ខុទាំងនោះកំពុងហាលសំដិលចីវរទាំងនោះ ក៏ដើរចូលទៅជិតភិក្ខុទាំងឡាយនោះ លុះចូលទៅជិតហើយ សួរទៅភិក្ខុទាំងនោះថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះជាមច្ចុកជាំអស់ តើជារបស់លោកណា ។ គ្រានោះឯង ភិក្ខុទាំងអម្បាលនោះក៏បានប្រាប់សេចក្ដីនុ៎ះដល់ព្រះអានន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុក៏លើកទោស តិះដៀល បន្ទោសថា ភិក្ខុទាំងឡាយមិនគួរបើនឹងផ្ញើចីវរទុកដាក់ដៃរបស់ភិក្ខុទាំងឡាយហើយ ( ស្លៀកដណ្ដប់ ) តែស្បង់ និងចីវរចេញដើរទៅកាន់ជនបទចារិកសោះ ។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរតបទៅពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុទាំងឡាយបានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយហើយ ( ស្លៀកដណ្ដប់ ) តែស្បង់ និងចីពរចេញដើរទៅកាន់ជនបទចារិកមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ ព្រះមេត្តាប្រោស ហេតុនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោស

ថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ មោឃបុរសទាំងនោះ ហ៊ានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ ( ហើយស្លៀកដណ្តប់ ) តែស្បង់ និងចីពរចេញដើរទៅកាន់ជនបទចារិក ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបាននាំ មនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ( នោះ ) ក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងនូវសិក្ខាបទនេះ យ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយកឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែ ១ យប់ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះហើយ ។

[ ១១ ] គ្រានោះឯង ក្នុងក្រុងកោសម្ពីមានភិក្ខុមួយរូបមានជំងឺ ។ ពួកជនជាញាតិ ក៏បានចាត់ប្រើបម្រើទៅក្នុងសម្នាក់ភិក្ខុនោះថា សូមឲ្យលោកម្ចាស់និមន្តមក យើងនឹងផ្គត់ផ្គង់បម្រើ ។ ទាំងភិក្ខុទាំងឡាយក៏ជួយនិយាយថា ម្នាលអាវុសោ លោកចូរនិមន្តទៅចុះ ពួកញាតិគេនឹងបានផ្គត់ផ្គង់បម្រើលោក ។ ភិក្ខុនោះនិយាយតបយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយរួចហើយថា ភិក្ខុមិនត្រូវនៅប្រាសចាកត្រៃចីវរទេ ក៏ឥឡូវខ្លួនខ្ញុំមានជំងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានឡើយខ្ញុំនឹងទៅមិនកើតទេ ។ ភិក្ខុទាំងឡាយក៏បានទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ក៏ធ្វើធម្មីកថាក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាតឲ្យជុំនុំសង្ឃឲ្យនូវសម្មតិ ដើម្បីឲ្យនៅប្រាសចាកត្រៃចីវរដល់ភិក្ខុដែល មានជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ( សង្ឃ ) ត្រូវឲ្យសម្មតិយ៉ាងនេះ ។ ភិក្ខុ ដែលមានជំងឺនោះត្រូវចូលទៅកាន់ជុំនុំសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួច សំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលនឹង សង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ឥឡូវខ្ញុំមានជំងឺ មិនអាចនឹងយក ត្រៃចីវរចេញដើរទៅបានទេ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំនោះសូមសម្មតិ ដើម្បី នៅប្រាសចាកត្រៃចីវរនឹងសង្ឃ ។ ភិក្ខុត្រូវសូមគម្រប់ ២ ដងផង ត្រូវសូម គម្រប់ ៣ ដងផង ។ ភិក្ខុអ្នកឆ្លាតអង់អាច ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រ ព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ( ដ្បិត )ភិក្ខុនេះ ឈ្មោះនេះ មានជំងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានទេ ។ ភិក្ខុនោះមកសូមសម្មតិ ដើម្បីនៅប្រាសចាកត្រៃចីវរនឹងជុំនុំសង្ឃ ។ បើកម្មមានកាលល្មមសមគួរ ដល់ សង្ឃហើយ សង្ឃត្រូវឲ្យសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ ចុះ ។ វាចានេះ ( ជាពាក្យផ្ដើម ) ញុំាងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃ ដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចនឹង យកត្រៃចីវរចេញដើរទៅបាន ។ ភិក្ខុនោះសូមសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរ នឹងសង្ឃ ។ សង្ឃឲ្យនូវសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យនូវសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏ មានអាយុអង្គណា សូមឲ្យលោកដ៏មានអាយុអង្គនោះស្ងៀម ( បើ ) មិនគួរដល់ លោកដ៏មានអាយុអង្គណា សូមឲ្យលោកដ៏មានអាយុអង្គនោះនិយាយឡើង ។

ការសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរ សង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះហើយ ។ ការឲ្យសម្មតិគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវហេតុនេះដោយកិរិយាស្ងៀមយ៉ាងនេះ ( ទុកជាការស្រេច ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះ យ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។

[ ១២ ] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចជាស្រេចហើយក្តី ចីវរបាត់ក្តី ចីវរដែលខូចក្តី ចីវរភ្លើងឆេះក្តី បំណងក្នុងចីវរដាច់ស្រឡះក្តី ។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដោះហើយ បណ្តាមាតិកាទាំង ៨ យ៉ាង ដោយមាតិកាណាមួយ ម្យ៉ាងទៀត កឋិនដែលសង្ឃបានដោះក្នុងចន្លោះ ។ ពាក្យថា បើភិក្ខុនៅប្រាសចាកត្រៃចីវរសូម្បីតែមួយយប់ អធិប្បាយថា បើភិក្ខុនៅប្រាសចាកសង្ឃាដិក្តី ឧត្តរាសង្គក្តី ស្បង់ក្តី សូម្បីតែមួយយប់ ។ ពាក្យថា វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ អធិប្បាយថា លើកលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។ ពាក្យថា និស្សគ្គិយអធិប្បាយថា ចីវរជានិស្សគ្គិយ ដំណាលនឹងពេលដែលអរុណរះឡើង ភិក្ខុនោះឯង ត្រូវលះ ( ចីវរនោះ ) ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុត្រូវលះបង់ យ៉ាងនេះ ។ ភិក្ខុនោះត្រូវចូលទៅកាន់ជំនុំសង្ឃ ។បេ។ ហើយពោលនឹងសង្ឃ យ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះខ្ញុំនៅប្រាស

ឃ្លាតមួយរាត្រីហើយ ជានិស្សគ្គិយ ព្រោះឥតមានភិក្ខុសម្មតិទេ ខ្ញុំសូមលះចីវរនេះ ដល់សង្ឃ ។បេ។

(ត្រង់បេយ្យាល ទាំង ៣ មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ ) ។

[ ១៣ ] ស្រុកមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ផ្ទះមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ឃ្លាំងមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា បញ្ចាមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា រោងមានជ្រុង ៤ មានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ប្រាសាទមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ប្រាសាទមានដំបូលត្រឹងិលមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា នាវាមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ពួកឈ្មួញរទេះមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ស្រែមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា លានស្រូវមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា សួនច្បារមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា វិហារមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ទីជិតដើមឈើមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ទីវាលមានឧបចារៈតែមួយ មានឧបចារៈផ្សេងគ្នា ។

[ ១៤ ] ស្រុកដែលមានឈ្មោះថា មានឧបចារៈតែមួយ (នោះសំដៅយក ) ស្រុករបស់ត្រកូលតែមួយ ដែលគេរាំងព័ទ្ធ ( របង ) ជុំវិញ ភិក្ខុត្រូវទុកចីវរក្នុងខាងក្នុងស្រុក ហើយនៅក្នុងខាងក្នុងស្រុក ។ ស្រុកដែលគេមិនបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ម្យ៉ាងទៀត មិនត្រូវលះហត្ថបាស

ឡើយ ។ ស្រុកដែលឈ្មោះថា មានឧបចារៈផ្សេងគ្នា គឺ ស្រុករបស់ត្រកូលផ្សេងគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ឬនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ កាលបើភិក្ខុទៅក្នុងរោងជាទីប្រជុំ ត្រូវទុកចីវរ ក្នុងហត្ថបាស ហើយនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ បើភិក្ខុទុកចីវរក្នុងរោងជាទីប្រជុំ ត្រូវឲ្យនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ បើស្រុកដែលគេមិនបានរាំងព័ទ្ធទេ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ១៥ ] បើផ្ទះរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុត្រូវទុកចីវរខាងក្នុងផ្ទះ ហើយត្រូវនៅខាងក្នុងផ្ទះ ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ( ភិក្ខុ ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។ម្យ៉ាងទៀត ផ្ទះរបស់ត្រកូលផ្សេងៗ គ្នា ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗ គ្នា មានបន្ទប់ផ្សេងគ្នា ( ភិក្ខុ ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ១៦ ] ឃ្លាំងរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ( ភិក្ខុ ) ត្រូវទុកចីវរខាងក្នុងឃ្លាំង

ហើយត្រូវនៅខាងក្នុងឃ្លាំង ។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ( ភិក្ខុ ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាស ឡើយ ។ ម្យ៉ាងទៀត ឃ្លាំងរបស់ត្រកូលផ្សេងៗគ្នា ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ( ភិក្ខុ ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ១៧ ] បញ្ចារបស់ត្រកូលតែ ១ ភិក្ខុទុកចីវរខាងក្នុងបញ្ចាហើយ ត្រូវនៅខាងក្នុងបញ្ចា ។ បញ្ចារបស់ត្រកូលផ្សេងៗគ្នា មានល្វែងក៏ផ្សេងៗគ្នា មានបន្ទប់ក៏ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ១៨ ] ប្រាសាទមានជ្រុង ៤ របស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទមានជ្រុង ៤ ហើយត្រូវនៅខាងក្នុងនៃប្រាសាទមានជ្រុង ៤ ។ ប្រាសាទមានជ្រុង ៤ របស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារមួយទៀត មិនត្រូវលះហត្ថបាសឡើយ ។

[ ១៩ ] ប្រាសាទវែងរបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទវែង ហើយត្រូវនៅខាងក្នុងប្រាសាទវែង ។ ប្រាសាទវែងរបស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅ

ក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ២០ ] ប្រាសាទមានដំបូលត្រងិលរបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទត្រងិល ហើយត្រូវនៅខាងក្នុងប្រាសាទត្រងិល ។ ប្រាសាទមានដំបូលត្រងិលរបស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ២១ ] នាវារបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងនាវា ហើយត្រូវនៅខាងក្នុងនាវា ។ នាវារបស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងបន្ទប់ណា ត្រូវនៅក្នុងបន្ទប់នោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ២២ ] ពួកឈ្មួញរទេះរបស់ត្រកូលតែមួយ ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះ ( នោះ ) ទោះបីដើរខាងមុខរទេះក្តី ខាងក្រោយរទេះក្តី មិនត្រូវលះបង់ចម្ងាយ ៧ អព្ភន្តរ[១] ឡើយ ( ដើរឲ្យល្មមតែ ) ក្រឡេកមើលទៅឃើញ ( រទេះ ) ទើបមិនត្រូវលះបង់អព្ភន្តរ ។ ពួកឈ្មួញរទេះរបស់ត្រកូលផ្សេងៗគ្នា ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះហើយ មិនត្រូវលះហត្ថបាសឡើយ ។

[ ២៣ ] ស្រែរបស់ត្រកូលតែមួយ គេបានបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ ( នោះ ) ត្រូវនៅក្នុងខាងក្នុងនៃស្រែ ( នោះ ) ។ ( បើស្រែ ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។ បើស្រែរបស់

---

១- អដ្ឋកថា ពន្យល់សេចក្តីថា ២៨ ហត្ថ ហៅថា មួយអព្ភន្តរ ( ចម្ងាយ ៧ អព្ភន្តរត្រូវជា ១៩៦ ហត្ថ ) ។

ត្រកូលផ្សេងៗគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ ( នោះ ) ហើយត្រូវនៅក្នុងខាងក្នុងនៃស្រែ ( នោះ ) ឬ ( ត្រូវនៅ ) ទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ ( បើស្រែ ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[ ២៤ ] លានស្រូវរបស់ត្រកូលតែមួយ គេរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅក្នុងខាងក្នុងនៃលាន ( នោះ ) ។ ( បើលានស្រូវ ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។ លានស្រូវរបស់ត្រកូលផ្សេងៗគ្នា គេបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ ( បើលានស្រូវ ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[ ២៥ ] សួនច្បាររបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរខាងក្នុងសួនច្បារហើយ ត្រូវនៅខាងក្នុងនៃសួនច្បារ ។ សួនច្បារគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។ សួនច្បាររបស់ ត្រកូលផ្សេងៗគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃសួនច្បារ ហើយត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ សួនច្បារ គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[ ២៦ ] លំនៅរបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងលំនៅហើយ ត្រូវនៅខាងក្នុងលំនៅ ។ លំនៅដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ហើយមិន

ត្រូវលះហត្ថបាសឡើយ ។ លំនៅរបស់ត្រកូលផ្សេងៗគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ លំនៅដែលគេមិនបានរាំងព័ទ្ធ ជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[ ២៧ ] ម្លប់ឈើរបស់ត្រកូលតែមួយ ក្នុងពេលថ្ងៃត្រង់ ម្លប់ឈើនោះផ្សាយទៅជុំវិញត្រឹមណា ភិក្ខុទុកចីវរ ក្នុងខាងក្នុងម្លប់ ហើយត្រូវនៅត្រឹមតែខាងក្នុងម្លប់ ( នោះ ) ។ ម្លប់ឈើរបស់ត្រកូលផ្សេងៗគ្នា ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[ ២៨ ] ដែលហៅថាទីវាល មានឧបចារៈតែមួយ មានឧបចារៈផ្សេងៗគ្នា គឺទីក្នុងព្រៃដែលឥតមានស្រុក ចំនួន ៧ អព្ភន្តរដោយជុំវិញ ( ទីវាលនោះ ) ហៅថាមានឧបចារៈតែមួយ លំដាប់តអំពីអព្ភន្តរនោះទៅ ហៅថា មានឧបចារៈផ្សេងៗគ្នា ។

[ ២៩ ] ភិក្ខុមានសេចក្តីដឹងច្បាស់ថាចីវរដែលខ្លួននៅប្រាស ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុមានសេចក្តីសង្ស័យ ត្រង់ចីវរដែលខ្លួននៅប្រាស ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរ គឺខ្លួនមិនបាននៅប្រាសទេ ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរ គឺខ្លួនបានដកអធិដ្ឋានហើយ ត្រង់ចីវរដែល

ខ្លួនមិនបានដកអធិដ្ឋានទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរ គឺខ្លួនបានលះបង់ហើយ ត្រង់ចីវរដែលខ្លួនមិនទាន់បានលះបង់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរបាត់ ត្រង់ចីវរដែលមិនមែនបាត់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរវិនាស ត្រង់ចីវរដែលមិនមែនវិនាសទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរភ្លើងឆេះ ត្រង់ចីវរដែលភ្លើងមិនមែនឆេះទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសម្គាល់ថា ចីវរចោរប្លន់យក ត្រង់ចីវរដែលចោរមិនមែនប្លន់យកទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។

[ ៣០ ] ភិក្ខុមិនបានលះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ថា ចីវរ គឺខ្លួននៅប្រាសហើយ ត្រង់ចីវរដែលខ្លួនមិនមែននៅប្រាសទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែលមិនបាននៅប្រាស ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ថា ចីវរ គឺខ្លួនមិនមែននៅប្រាសទេ ត្រង់ចីវរដែលខ្លួនមិនមែននៅប្រាសពិត មិនត្រូវអាបត្តិឡើយ ។

[ ៣១ ] ហេតុដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុបានដកអធិដ្ឋាន ក្នុងខាងក្នុងនៃអរុណ ១ ភិក្ខុបានលះចីវរ ១ ចីវរបាត់ ១ ចីវរវិនាស ១ ចីវរភ្លើងឆេះ ១ ចីវរចោរដណ្តើមយក ១ អ្នកដទៃយកដោយសេចក្តីស្និទ្ធស្នាល ១ ភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា
# ចីវរវគ្គទី ១ សិក្ខាបទទី ២
# ឧទ្ទោសិតសិក្ខាបទ

[ ១០ ] ឧទ្ទោសិតសិក្ខាបទ ត្រង់ពាក្យថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងវិនិច្ឆ័យឧទ្ទោសិតសិក្ខាបទនោះ គប្បីជ្រាបដូចតទៅនេះ

បទថា **សន្តរុត្តរេន** សេចក្តីថា អន្តរវាសក ត្រាស់ហៅថា **អន្តរ** ។ ឧត្តរាសង្គ ត្រាស់ហៅថា **ឧត្តរ** ។ សំពត់ដណ្តប់ និងសំពត់ស្លៀក ឈ្មោះថា **សន្តរុត្តរ** ។ មានតែសំពត់ដណ្តប់ និងសំពត់ស្លៀកនោះ អធិប្បាយថា មួយអន្លើដោយសំពត់ឧត្តរាសង្គ និងសំពត់អន្តរវាសក ។

បទថា **កណ្ណកិតានិ** បានដល់ កើតជាចំណុចខ្មៅៗ សៗ ក្នុងទីដែលញើសពាល់ត្រូវ ។

បទថា **អទ្ទសា ខោ អាយស្មា អានន្ទោ សេនាសនចារិកំ អាហិណ្ឌន្តោ** សេចក្តីថា បានឮថា ព្រះថេរៈ កាលព្រះមានព្រះភាគយាងចូលកាន់ព្រះគន្ធកុដិ ដើម្បីទ្រង់បំណាងនឹងសម្រាកក្នុងពេលថ្ងៃ បានឱកាសនោះហើយ ព្រះអានន្ទរក្សាកណ្តុះឈើ និងកណ្តុះដីដែលទុកដាក់មិនល្អ បោសសម្អាតទីដែលមិនទាន់បោស ធ្វើបដិសណ្ឋារៈជាមួយពួកភិក្ខុអាពាធ ទៅដល់សេនាសនដ្ឋាននៃភិក្ខុទាំងនោះ បានឃើញហើយ ។ ព្រោះហេតុនោះ ទើបព្រះសង្គាហកាចារ្យពោលថា ព្រះអានន្ទត្រាច់ទៅកាន់សេនាសនចារិក បាន

ឃើញហើយ ដូច្នេះ ។

## អនុប្បញ្ញត្តិឧទ្ទោសិតសិក្ខាបទ

[ ១១ ] បទថា **អវិប្បវាសសម្មតឹ ទាតុំ** សេចក្ដីថា សម្មតិក្នុងការមិននៅប្រាស ( ត្រៃចីវរ ) ឈ្មោះអវិប្បវាសសម្មតិ ។ម្យ៉ាងទៀត សម្មតិដើម្បីការមិននៅប្រាស ( ត្រៃចីវរ ) ឈ្មោះអវិប្បវាសសម្មតិ ។ ក្នុងអវិប្បវាសសម្មតិនេះ មានអានិសង្សដូចម្ដេច ភិក្ខុនៅប្រាសចាកចីវរផ្ទាំងណា ចីវរផ្ទាំងនោះមិនជានិស្សគ្គិយ ហើយភិក្ខុដែលនៅប្រាសចាក មិនត្រូវអាបត្តិ ។ នៅប្រាសចាកបានអស់រយៈប៉ុនណា ព្រះមហាសមត្ថេរពោលទុកមុនថា មួយរយៈដែលរោគមិនទាន់ស្ងប់ តែកាលរោគស្ងប់ហើយ ភិក្ខុគប្បីប្រញាប់ត្រឡប់មក ទីកន្លែងដែលទុកចីវរ ដូច្នេះ ។ ព្រះមហាបទុមត្ថេរពោលថា កាលភិក្ខុនោះប្រញាប់ប្រញាល់ត្រឡប់មក រោគគប្បីរើឡើង ព្រោះដូច្នោះ គួរនឹងមកសន្សឹមៗ ភិក្ខុគួរស្វែងរកពួករទេះ ឬធ្វើការចងចិត្តថា អញនឹងទៅ ចាប់តាំងអំពីកាលណានឹងនៅប្រាសចាកចាប់ផ្ដើមអំពីនោះទៅ ក៏គួរ តែកាលភិក្ខុធ្វើការដាក់ធុរៈយ៉ាងនេះថា អញនឹងមិនទៅក្នុងវេលានេះ គប្បីដក ត្រៃចីវរដែលដកហើយ នឹងតាំងនៅក្នុងឋានៈជាអតិរេកចីវរ ដូច្នេះ ។

សួរថា បើរោគរបស់លោករើឡើង លោកគប្បីធ្វើដូចម្ដេច ឆ្លើយថា ព្រះបុស្សទេវត្ថេរពោលទុកមុនថា បើរោគនោះឯងត្រឡប់កើតឡើង អវិប្បវាសសម្មតិនោះឯង គង់នៅជាសម្មតិដដែលមិនមានកិច្ចដែលនឹងត្រូវសម្មតិជាថ្មី បើរោគដទៃកើតឡើង គប្បីឲ្យសម្មតិជាថ្មី ដូច្នេះ ។ ព្រះឧបតិស្សត្ថេរ

ពោលថា ភេគនោះក្តី ភេគដទៃក្តី លើកទុកដោយឡែក មិនមានកិច្ចដែលត្រូវឲ្យសម្មតិជាថ្មីឡើយ ដូច្នេះ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃទុតិយកឋិនសិក្ខាបទ

[ ១២ ] ឯក្នុងបទថា **និដ្ឋិត ចីវរស្មឹ ភិក្ខុនា** នេះ បណ្ឌិតកុំយល់អត្ថដូចក្នុងសិក្ខាបទមុន គប្បីជ្រាបអត្ថនៃតតិយាវិភត្តិ ដោយអំណាចនៃឆដ្ឋីវិភត្តិយ៉ាងនេះថា **និដ្ឋិតេ ចីវរស្មឹ ភិក្ខុនោ** កាលចីវររបស់ភិក្ខុសម្រេចហើយ ដូច្នេះ ។ ព្រោះអត្ថដោយអំណាចនៃតតិយាវិភត្តិថា កិច្ចឈ្មោះនេះ ដែលភិក្ខុគប្បីធ្វើដូច្នេះមិនមាន តែអត្ថដោយអំណាចនៃឆដ្ឋីវិភត្តិយ៉ាងនេះថា កាលចីវរសម្រេចហើយ និងកាលកឋិនដោះហើយ បើភិក្ខុមានបលិពោធដាច់ហើយយ៉ាងនេះ គប្បីនៅប្រាសចាកត្រៃចីវរ សូម្បីអស់រាត្រីមួយ ដូច្នេះ រមែងសមគួរ ( ព្រោះហេតុណា ព្រោះហេតុនោះ គប្បីជ្រាបអត្ថនៃតតិយាវិភត្តិ ដោយអំណាចឆដ្ឋីវិភត្តិ ) ។

បណ្តាបទទាំងនោះ បទថា **តិចីវរេន** បានដល់ អំពីបណ្តាត្រៃចីវរដែលអធិដ្ឋានហើយ ចីវរផ្ទាំងណាមួយ ។ ពិតហើយ ភិក្ខុសូម្បីនៅប្រាសចាកចីវរមួយផ្ទាំង ក៏រាប់ថា ជាអ្នកនៅប្រាសចាកត្រៃចីវរ ព្រោះជាអ្នកនៅប្រាសចាក ( ចីវរមួយផ្ទាំង ) ដែលជាប់ទាក់ទងក្នុងការសម្រេចជាត្រៃចីវរ ព្រោះហេតុនោះឯង ក្នុងបទភាជនីយ៍នៃបទថា **តិចីវរេន** នោះ ទើបទ្រង់ត្រាស់ពាក្យថា **សង្ឃាដិយា** ជាដើម ។

*បទថា* **វិប្បវសេយ្យ** *គឺគប្បីជាអ្នកនៅប្រាស ។*

## អធិប្បាយ

## បទភាជនីយនៃឧទ្ទោសិតសិក្ខាបទ

[ ១៣ ] *បទថា* **គាមោ ឯកូបចារោ** *ជាដើម ទ្រង់ត្រាស់ទុកដើម្បីឲ្យកំណត់លក្ខណៈនៃការមិននៅប្រាសចាក ( ត្រៃចីវរ ) ។ បន្ទាប់អំពីពាក្យថា* **គាមោ ឯកូបចារោ** *ជាដើមនេះទៅ ព្រះមានព្រះភាគ កាលទ្រង់ពង្រីកបទមាតិកាទាំង ១៥ បទនោះឯង ឲ្យពិស្តារតាមលំដាប់ ទើបត្រាស់ថា* **គាមោ ឯកូបចារោ នាម** *ជាដើម ។*

[ ១៤ ] *ក្នុងបទថា* **គាមោ ឯកូបចារោ** *នោះ មានវិនិច្ឆ័យដូច្នេះថា ព្រះរាជវាំងរបស់ព្រះរាជាមួយអង្គ ឬស្រុករបស់មេស្រុកម្នាក់ ឈ្មោះថាស្រុករបស់ត្រកូលមួយ ។ បទថា* **បរិក្ខិត្តោ** *សេចក្តីថា ព័ទ្ធដោយកំពែងដោយរបង ឬដោយគូទឹកឯណាមួយ ។*

*លោកសម្តែងភាពដែលស្រុករបស់ត្រកូលមួយ មានឧបចារៈមួយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។*

*ពីរបទថា* **អន្តោគាមេ វត្ថព្វំ** *សេចក្តីថា ភិក្ខុនឹងទុកចីវរក្នុងស្រុក ដូច្នេះហើយ ឲ្យអរុណរះក្នុងទីដែលខ្លួនពេញចិត្ត ក្នុងលំនៅស្រុក រមែងគួរ ។*

*ដោយបទថា* **អបរិក្ខិត្តោ** *នេះ លោកសម្តែងភាពដែលស្រុកនោះឯងមានឧបចារៈផ្សេងៗគ្នា ។*

*បទថា* **តស្មឹ ឃរេ វត្ថព្វំ** *សេចក្តីថា គប្បីនៅក្នុងផ្ទះដែលខ្លួនទុកចីវរ*

ក្នុងស្រុកបែបនោះ ។

ត្រើនបទថា **ហត្ថបាសា វា ន វិជហិតព្វំ** សេចក្តីថា មួ៉ាងទៀត គប្បីលះផ្ទះនោះអំពីហត្ថបាសដោយជុំវិញ ។ មានពាក្យអធិប្បាយថា មិនគប្បីលះឲ្យឆ្ងាយអំពីប្រទេសប្រមាណ ២ ហត្ថ ១ ចំអាម ។ ឯការនៅខាងក្នុង ២ ហត្ថ ១ ចំអាម រមែងសមគួរ ។ កន្លងប្រមាណនោះទៅ សូម្បីភិក្ខុដែលមានឫទ្ធិ ញុំាងអរុណឲ្យតាំងឡើងក្នុងអាកាស ក៏ជានិស្សគ្គិយដូចគ្នា ។

បណ្ឌិតគប្បីជ្រាបការកំណត់ផ្ទះក្នុងបទថា **យស្មឹ ឃរេ** ក្នុងវិស័យថា ស្រុករបស់ត្រកូលមួយនេះ ដោយលក្ខណៈជាដើមថា ជាផ្ទះរបស់ត្រកូលមួយ ដូច្នេះ ។

បទថា **នានាកុលស្ស គាមោ** បានដល់ ដំណាក់នៃព្រះរាជាផ្សេងអង្គគ្នា ឬស្រុករបស់មេស្រុកផ្សេងៗ ដូចក្រុងវេសាលី និងក្រុងកុសិនារាជាដើម ។

ដោយបទថា **បរិក្ខិត្តោ** នេះ លោកសម្តែងភាពដែលស្រុករបស់ត្រកូលផ្សេងគ្នា មានឧបចារៈតែមួយ ។

លោកពោលសភាដោយលិង្គផ្ទុយ ក្នុងបទថា **សភាយេ វា ទ្វារមូលេ វា** នេះថា **សភាយំ**។

បទថា **ទ្វារមូលេ** បានដល់ ទីជិតទ្វារក្រុង មានពាក្យអធិប្បាយថា ឬគប្បីនៅក្នុងផ្ទះដែលខ្លួនរក្សាចីវរទុកក្នុងផ្ទះបែបនោះ ។ កាលភិក្ខុមិនអាចនឹងនៅក្នុងផ្ទះនោះ ព្រោះសំឡេងអឺងកង ឬព្រោះមនុស្សកុះករ គប្បីនៅក្នុងសភា

ឬទីជិតទ្វារក្រុង ។ បើមិនអាចនៅក្នុងសភា ឬក្នុងទីជិតទ្វារក្រុងនោះ គប្បីនៅក្នុងទីផាសុកណាមួយ ហើយមកខាងក្នុងពេលអរុណរះ មិនគប្បីលះហត្ថបាសនៃសភា និងទីជិតទ្វារក្រុងនោះឡើយ ។ ឯកិច្ចដែលភិក្ខុគប្បីនៅក្នុងហត្ថបាសនៃផ្ទះ ឬនៃចីវរ មិនមានឡើយ ។

បទថា **សភាយំ គច្ឆន្តេន ហត្ថបាសេ ចីវរំ និក្ខិបិត្វា** សេចក្តីថា បើភិក្ខុមិនរក្សាទុកក្នុងផ្ទះ ទៅកាន់សភាដោយកំណត់ក្នុងចិត្តថា អញនឹងទុកត្រង់សភា កាលភិក្ខុនោះទៅកាន់សភា គប្បីលាដៃចេញទៅក្នុងហត្ថបាស ទុកចីវរត្រង់រានផ្សារណាមួយ ដែលជាផ្លូវនៃការរក្សាទុក គឺនៅក្នុងហត្ថបាសយ៉ាងនេះថា ណ្ហើយចុះ អញនឹងរក្សាចីវរនេះទុក ហើយគប្បីនៅត្រង់សភាក្តី ទីជិតទ្វារក្តី មិនគប្បីលះ ( ចីវរ ) អំពីហត្ថបាសដោយន័យមុននោះឯង ។

ក្នុងវិស័យថា **សភាយេ វា ទ្វារមូលេ វា** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះបុស្សទេវត្ថេរពោលទុកមុនថា មិនមានកិច្ចចាំបាច់នៅក្នុងហត្ថបាសនៃចីវរ ទោះនៅក្នុងទីណាមួយ ជាហត្ថបាសថ្នល់ក្តី ហត្ថបាសសភាក្តី ហត្ថបាសទ្វារក្តី រមែងសមគួរទាំងអស់ ដូច្នេះ ។

ចំណែកព្រះឧបតិស្សត្ថេរពោលថា ក្រុងមានទ្វារច្រើនក៏មាន មានសភាច្រើនក៏មាន ព្រោះដូច្នោះ នៅក្នុងទីទូទៅ មិនសមគួរ តែមិនគប្បីលះហត្ថបាសនៃសភា និងទ្វារ ដែលមាននៅក្នុងទីចំពោះមុខនៃថ្នល់ដែលខ្លួនទុកដាក់ចីវរ ពិតហើយ បើដូច្នេះ អាចជ្រាបការប្រព្រឹត្តទៅនៃចីវរបាន ដូច្នេះ ។

តែកាលភិក្ខុទៅកាន់សភា ទុកចីវរក្នុងដៃរបស់អ្នកលក់ដូរណាមួយ បើ

អ្នកលក់ដូរនោះ ប្រទ្បំនាំចីវរនោះទៅទុកឯផ្ទះ ហត្ថបាសថ្នល់រក្សាមិនបានទេ ភិក្ខុត្រូវនៅក្នុងហត្ថបាសនៃផ្ទះប៉ុណ្ណោះ បើផ្ទះធំ ផ្សាយគ្រប់ជណ្តប់ទៅរហូតថ្នល់ ២ ភិក្ខុគប្បីឲ្យអរុណតាំងឡើងចំពោះក្នុងហត្ថបាស ផ្លូវខាងមុខ ឬផ្លូវខាងក្រោយ ( នៃផ្ទះនោះ ) ។ តែភិក្ខុរក្សា ( ចីវរ ) ផ្ញើទុកក្នុងសភា គប្បីឲ្យអរុណរះក្នុងសភា ឬទីជិតទ្វារក្រុង ត្រង់មុខសភានោះ ឬក្នុងហត្ថបាសនៃសភា ឬទីជិតទ្វារក្រុងនោះឯង ។

ដោយបទថា **អបរិក្ខិត្តោ** នេះ លោកសម្តែងភាពដែលស្រុកនោះឯងមានឧបចារៈផ្សេងគ្នា ។ គប្បីជ្រាបការមានឧបចារៈតែមួយ និងឧបចារៈផ្សេងគ្នាក្នុងបទទាំងពួង ដោយឧបាយយ៉ាងនេះដូចគ្នា ។ តែក្នុងព្រះបាលី ព្រះមានព្រះភាគទ្រង់លើកបទមាតិកាឡើងត្រឹមមួយបទ ដែលមាននៅក្នុងបទដើម យ៉ាងនេះថា ស្រុក ឈ្មោះថា មានឧបចារៈមួយ និងដែលតាំងនៅក្នុងទីបំផុតយ៉ាងនេះថា ទីវាល ឈ្មោះថា មានឧបចារៈមួយ ហើយពង្រីកបទភាជនៈឲ្យពិស្តារ ។ ព្រោះដូច្នោះ គ្រប់បទទាំងអស់ គប្បីជ្រាបការមានឧបចារៈតែមួយដោយអំណាចនៃទី មានរបងជាដើម និងឧបចារៈផ្សេងគ្នា ដោយអំណាចទីដែលមិនមានរបងជាដើម ដោយទំនងនៃបទនោះឯង ។

[ ១៥ ] ក្នុងនិវេសន៍ ( ផ្ទះសម្នាក់ ) ជាដើម មានវិនិច្ឆ័យដូច្នេះថា បទថា **ឱវរកា** នេះ ជាពាក្យហៅបន្ទប់ទាំងឡាយនោះ ។

បទថា **ហត្ថបាសា វា** បានដល់ អំពីហត្ថបាសនៃបន្ទប់ ឬនៃផ្ទះ ។

បទថា **ទ្វារមូលេ** បានដល់ ក្នុងទីជិតទ្វារផ្ទះដែលជាសាធារណៈដល់

ជនទាំងពួងក្តី ។

បទថា **ហត្ថបាសា វា** បានដល់ ចាកហត្ថបាសនៃបន្ទប់ក្តី នៃផ្ទះក្តី នៃទីជិតទ្វារផ្ទះក្តី ។

[ ១៦ ] ដែលឈ្មោះថា រោងទុកទ្រព្យនោះ មានរោងទុកទ្រព្យ មានយានជាដើម ។ ចាប់ពីរោងទុកទ្រព្យរបស់នេះទៅ គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលហើយក្នុងនិវេសន៍ គឺផ្ទះសម្នាក់ ។

[ ១៧ ] ដែលឈ្មោះថា បញ្ជានោះ បានដល់ ទីអាស្រ័យពិសេស ដែលគេធ្វើដោយឥដ្ឋដើម្បីការពារព្រះរាជាជាសត្រូវជាដើម មានជញ្ជាំងក្រាស់ មានជាន់ ៤-៥ ជាន់ ។

[ ១៨ ] ប្រាសាទ ៤ ជ្រុង ដែលសង្គ្រោះចូលដោយកំពូលតែមួយ ឈ្មោះថា ផ្ទះកំពូល ១ ។

[ ១៩ ] ប្រាសាទវែង ឈ្មោះថា ប្រាសាទ ។

[ ២០ ] ប្រាសាទមានដំបូលកាត់ ( ប្រាសាទត្រងិល ) ឈ្មោះថា ហម្មិយ ។

[ ២២ ] អព្ភន្តរនោះ លោកពោលទុកក្នុងពាក្យថា ៧ អព្ភន្តរនេះ គឺ ១ អព្ភន្តរ មានប្រមាណ ២៨ ហត្ថ ។

បទថា **សន្តោ** សេចក្តីថា បើក្រុមរទេះទៅឈប់សម្រាកក្បែរភូមិ ឬស៊ីងជាប់ជាមួយគ្នានឹងក្រុមរទេះ ដែលចូលទៅខាងក្នុង រាត់រាយនៅរហូតពាសពេញប្រាំងនាយ និងប្រាំងអាយ រមែងបានបរិហារថា ក្រុមរទេះពិត ។

បើក្រុមរទេះនៅជាប់គ្នាត្រង់ស្រុក ឬត្រង់ស៊ីង ក្រុមរទេះដែលចូលទៅខាងក្នុងហើយ រមែងបានបរិហារថា ស្រុក និងបរិហារថា ស៊ីង ។ បើក្រុមរទេះឈប់ស្នាក់នៅហួសវិហារសីមាទៅ ចីវរខាងក្នុងសីមា គប្បីទៅកាន់វិហារហើយខាងក្នុងសីមានោះ បើចីវរនៅខាងក្រៅសីមា គប្បីនៅក្នុងទីជិតក្រុមរទេះនោះឯង ។ បើក្រុមរទេះកំពុងធ្វើដំណើរ បើរទេះបាក់ ឬគោបាត់ រមែងជាប់គ្នាក្នុងចន្លោះ ចីវរដែលទុកក្នុងចំណែកណា គប្បីនៅក្នុងចំណែកនោះ ។

[ ២៣ ] ហត្ថបាសនៃចីវរនោះឯង ឈ្មោះថា ហត្ថបាសក្នុងស្រែចម្ការរបស់ត្រកូល ១ ហត្ថបាសនៃទ្វារស្រែចម្ការ ឈ្មោះថា ហត្ថបាសក្នុងស្រែចម្ការរបស់ត្រកូលផ្សេងគ្នា ហត្ថបាសនៃចីវរប៉ុណ្ណោះ ឈ្មោះថា ហត្ថបាសក្នុងស្រែចម្ការដែលឥតរបង ។

[ ២៤ ] លានស្រូវ លោកហៅថា ធញ្ញករណៈ ។

[ ២៥ ] សួនផ្កា ឬសួនផ្លែឈើ លោកហៅថា អារាម ។ ក្នុងលានបោកបែនស្រូវ និងអារាម ទាំង ២ មានវិនិច្ឆ័យដូចដែលពោលហើយ ក្នុងស្រែចម្ការនោះឯង ។

[ ២៦ ] ក្នុងបទថា **វិហារ** ( លំនៅ ) ក៏មានវិនិច្ឆ័យដូចគ្នានឹងនិវេសន៍ ( ផ្ទះសម្នាក់ ) នោះឯង ។

[ ២៧ ] ក្នុងរុក្ខមូល គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **អន្តោឆាយាយ** គឺចំពោះខាងក្នុងឱកាស ដែលម្លប់ផ្សាយទៅដល់ ។ តែចីវរដែលភិក្ខុទុកក្នុងឱកាសដែលកម្តៅថ្ងៃពាល់ត្រូវនៃដើមឈើដែលស្រឡះ ជានិស្សគ្គិយ ដោយ

ពិត ។ ព្រោះដូច្នោះ ភិក្ខុគប្បីទុកចីវរត្រង់មួប់នៃមែកឈើ ឬស្រមោលនៃដើមរបស់ឈើ ដូច្នោះ ។ បើទុកលើមែកឈើ ឬលើប្រគាប គប្បីទុកក្នុងឱកាសដែលស្រមោលនៃមែកឈើខាងលើផ្សាយទៅដល់ប៉ុណ្ណោះ ។ ស្រមោលរបស់ដើមឈើទាប រមែងផ្សាយទៅឆ្ងាយ គប្បីទុកក្នុងឱកាសដែលស្រមោលផ្សាយទៅត្រូវ ។ គួរនឹងរក្សាទុកក្នុងទីស្រមោលដែលក្រាស់ប៉ុណ្ណោះ ។ **ហត្ថបាស** ក្នុងអធិការនៃគល់ឈើនេះ គឺហត្ថបាសនៃចីវរនោះឯង ។

[ ២៨ ] បទថា **អគាមកេ អរញ្ញេ** សេចក្ដីថា ព្រៃដែលឈ្មោះថាមិនមែនជាស្រុក រមែងបានក្នុងព្រៃ មានព្រៃជ្រៅជាដើម ឬលើកោះ ដែលមិនជាផ្លូវ ត្រាច់ទៅរបស់ពួកអ្នកប្រមង់ ក្នុងកណ្ដាលសមុទ្រ ។

បទថា **សមន្តា សត្តព្ភន្តរា** សេចក្ដីថា ៧ អព្ភន្តរក្នុងទិសទាំងពួង នៃបុគ្គលដែលឈរត្រង់កណ្ដាល រួមជា ១៤ អព្ភន្តរដោយសងខាង ។ ភិក្ខុអង្គុយត្រង់កណ្ដាល រមែងរក្សាចីវរដែលទុកក្នុងទីបំផុតដោយជុំវិញនៃទិសខាងកើត ឬខាងលិច ។ បើភិក្ខុដើរទៅកាន់ទិសខាងកើត ត្រឹមមួយចម្រៀកសក់ ក្នុងវេលាអរុណរះ ចីវរក្នុងទិសខាងលិចជានិស្សគ្គិយ ក្នុងចីវរក្រៅអំពីនេះ ក៏មានន័យដូច្នេះ ។ ឯក្នុងការធ្វើឧបោសថ គប្បីជម្រះសត្តព្ភន្តរសីមាឲ្យបរិសុទ្ធ តាំងពីភិក្ខុដែលអង្គុយក្នុងទីបំផុតនៃបរិស័ទ ។ ភិក្ខុសង្ឃពង្រីកទៅអស់ទីប្រមាណប៉ុនណា សីមាក៏រីកចេញទៅអស់ទីប្រមាណប៉ុណ្ណោះ ។

[ ៣០ ] ក្នុងបទថា **អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស** នេះ អាចារ្យពួកខ្លះពោលថា បើភិក្ខុដែលប្រកបព្យាយាម បំពេញព្យាយាមអស់

រាត្រីរហូតភ្លឺ ដាក់ចិត្តថា អញនឹងងូតទឹកក្នុងវេលាជិតភ្លឺ សឹមចេញទៅ ដាក់ចីវរទាំង ៣ ផ្ទាំង ត្រង់មាត់ច្រាំង ចុះកាន់ស្ទឹង កាលលោកកំពុងងូតនោះឯង អរុណរះឡើង លោកគប្បីធ្វើដូចម្តេច ព្រោះថា បើលោកឡើងមកហើយ ដណ្តប់ចីវរ រមែងត្រូវអាបត្តិទុក្កដ ព្រោះមិនទាន់លះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ជាបច្ច័យ បើលោកអាក្រាតកាយទៅ ដោយការអាក្រាតទៅយ៉ាងនោះ ក៏ត្រូវអាបត្តិទុក្កដ ឆ្លើយថា លោកមិនត្រូវអាបត្តិឡើយ ព្រោះលោកតាំងនៅក្នុងឋានៈនៃភិក្ខុដែលមានចីវរបាត់ ព្រោះចីវរទាំងនោះ ជារបស់មិនគួរបរិភោគ ដរាបណាមិនទាន់ជួបភិក្ខុដទៃ ហើយធ្វើវិនយកម្ម ឈ្មោះថារបស់ដែលមិនគួរដល់ភិក្ខុដែលមានចីវរបាត់ មិនមាន ព្រោះដូច្នោះ លោកគប្បីស្លៀកមួយផ្ទាំង យកដៃកាន់ ២ ផ្ទាំងទៅកាន់វិហារ ហើយធ្វើវិនយកម្ម ។ បើវិហារនៅឆ្ងាយ ក្នុងរវាងផ្លូវ មានពួកអ្នកស្រុកសញ្ចរទៅមក លោកជួបពួកអ្នកស្រុកទាំងនោះ គប្បីស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ដាក់មួយផ្ទាំងលើចង្កួយស្មា ហើយគប្បីដើរទៅ ។ បើមិនជួបភិក្ខុដែលពេញចិត្តគ្នាក្នុងវិហារ ហើយភិក្ខុទាំងឡាយត្រាច់ទៅបិណ្ឌបាតអស់ លោកគប្បីដាក់សំពត់សង្ឃាដីទុកខាងក្រៅស្រុក ទៅកាន់រោងឆាន់ ដោយសំពត់ឧត្តរាសង្គ និងអន្តរវាសក ហើយធ្វើវិនយកម្ម ។ បើខាងក្រៅស្រុក មានចោរភ័យ គប្បីដណ្តប់សង្ឃាដីទៅផង បើរោងឆាន់ចង្អៀត មានមនុស្សពពាក់ពពូន លោកមិនអាចដោះចីវរចេញ ធ្វើវិនយកម្មក្នុងផ្ទះមួយបាន គប្បីនាំភិក្ខុមួយរូបទៅខាងក្រៅស្រុក ធ្វើវិនយកម្ម ហើយប្រើប្រាស់ចីវរទាំងឡាយចុះ ។

បើភិក្ខុទាំងឡាយ ឲ្យបាត្រ និងចីវរ ទុកក្នុងដៃនៃភិក្ខុកំលោះទាំងឡាយ កំពុងធ្វើដំណើរទៅ មានបំណងនឹងសម្រាកដេក ក្នុងបច្ឆិមយាម គប្បីធ្វើចីវរ រៀងៗខ្លួន ទុកក្នុងហត្ថបាសជាមុនហើយសឹមដេក ។ បើពួកភិក្ខុកំលោះ មកមិនទាន់ថ្ងៃរះ ព្រះថេរៈទាំងឡាយដែលកំពុងដើរទៅនោះឯង ចីវរ ទាំងឡាយរមែងជានិស្សគ្គិយ ។ ចំណែកនិស្ស័យមិនរម្ងាប់ទេ ។ បើពួកភិក្ខុ កំលោះដើរហួសទៅមុនក្តី ព្រះថេរៈទាំងឡាយដើរតាមមិនទាន់ក្តី មានន័យ យ៉ាងនេះដូចគ្នា ។ បើភិក្ខុទាំងឡាយបែកផ្លូវគ្នា មិនឃើញគ្នានិងគ្នាក្នុងព្រៃ ក៏មានន័យយ៉ាងនេះដូចគ្នា ។ បើពួកភិក្ខុកំលោះប្រាប់ថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងដេកមួយស្របក់ ហើយនឹងតាមទៅទាន់ពួកលោកម្ចាស់ក្នុងឱកាស ឈ្មោះនោះ ដូច្នេះហើយ ដេករហូតថ្ងៃរះ ចីវរជានិស្សគ្គិយផង និស្ស័យក៏ រម្ងាប់ផង ។ កាលព្រះថេរៈទាំងឡាយបញ្ជូនពួកភិក្ខុកំលោះទៅមុន ហើយ ដេក ក៏មានន័យយ៉ាងនេះដូចគ្នា ។ ជួបផ្លូវបែកជា ២ ព្រះថេរៈទាំងឡាយ ប្រាប់ថា ផ្លូវនេះ ពួកភិក្ខុកំលោះប្រាប់ថា ផ្លូវនេះ មិនជឿពាក្យគ្នានិងគ្នា ហើយ ទៅ ( បែកផ្លូវគ្នា ) អរុណរះឡើង ចីវរទាំងឡាយ ជានិស្សគ្គិយ និស្ស័យ ទាំងឡាយ រមែងរម្ងាប់ ។

បើពួកភិក្ខុកំលោះចៀសចេញអំពីផ្លូវពោលថា ពួកខ្ញុំនឹងត្រឡប់មកឲ្យ ទាន់ខាងក្នុងអរុណនោះឯង ហើយចូលទៅកាន់ស្រុក ដើម្បីភេសជ្ជៈ កំពុងដើរមក អរុណរះ ពួកលោកដែលត្រឡប់មកមិនទាន់ដល់នោះឯង ចីវរ ទាំងឡាយជានិស្សគ្គិយ តែនិស្ស័យមិនរម្ងាប់ ។ បើពួកលោកពោលថា ពួក

ខ្ញុំឈរមួយស្របក់ ហើយនឹងទៅ ឈរក្តី អង្គុយក្តី ព្រោះខ្លាចមេគោទឹកដោះ ( មេគោកូនខ្ចី ) ឬព្រោះខ្លាចឆ្កែ ហើយទើបដើរទៅ កាលថ្ងៃរះក្នុងរវាងផ្លូវ ចីវរទាំងឡាយជានិស្សគ្គិយផង និស្សយ័ក៏រម្ងាប់ផង ។ បើភិក្ខុទាំងឡាយ ( កាលអាចារ្យ និងអន្តេវាសិក ) ចូលទៅកាន់ស្រុកខាងក្នុងសីមា ដោយតាំងចិត្តថា អញនឹងមកខាងក្នុងអរុណរះនោះឯង អរុណរះក្នុងចន្លោះ ចីវរទាំងឡាយមិនជានិស្សគ្គិយ និស្សយ័ក៏មិនរម្ងាប់ ។ បើភិក្ខុទាំងឡាយអង្គុយនៅ ដោយមិនតាំងចិត្តថា រាត្រីចូរភ្លឺក្តី មិនភ្លឺក្តី បើអរុណរះឡើងហើយ ចីវរមិនជានិស្សគ្គិយ តែនិស្សយ័រមែងរម្ងាប់ ។

ភិក្ខុពួកណា ចូលទៅកាន់រោងខាងក្រៅឧបចារសីមា ដោយមានឧស្សាហ៍ថា អញនឹងមកឲ្យទាន់អរុណនោះឯង ដើម្បីប្រយោជន៍ដល់កម្ម មានឧបសម្បទាកម្មជាដើម អរុណរះត្រង់រោងនោះដល់ពួកលោក ចីវរជានិស្សគ្គិយ តែនិស្សយ័មិនរម្ងាប់ ។ ភិក្ខុទាំងឡាយចូលទៅកាន់រោងនោះឯង ខាងក្នុងឧបចារសីមា កាលអរុណតាំងឡើង ចីវរមិនជានិស្សគ្គិយ និស្សយ័ក៏មិនរម្ងាប់ ។ តែភិក្ខុពួកណា នៅមានឧស្សាហ៍ ទៅកាន់វិហារជិតខាងដើម្បីប្រយោជន៍នឹងស្តាប់ធម៌ តាំងចិត្តថា នឹងមកឲ្យទាន់ខាងក្នុងអរុណ តែអរុណរះឡើងដល់ពួកលោក ក្នុងចន្លោះផ្លូវនោះឯង ចីវរទាំងឡាយជានិស្សគ្គិយ តែនិស្សយ័មិនរម្ងាប់ ។ បើពួកលោកនៅអង្គុយ ដោយគោរពក្នុងធម៌ថា ពួកយើងស្តាប់រហូតចប់ ហើយនឹងទៅ អរុណក៏រះឡើង សូម្បីចីវរទាំងឡាយក៏ជានិស្សគ្គិយ និស្សយ័ក៏រម្ងាប់ ។

ព្រះថេរៈ កាលបញ្ជូនភិក្ខុកំលោះទៅកាន់លំនៅស្រុក ដើម្បីបោកចីវរ គប្បីបច្ចុទ្ធរចីវររបស់ខ្លួនមុនហើយ សឹមឲ្យ ។ សូម្បីចីវររបស់ ភិក្ខុកំលោះ ក៏គប្បីឲ្យបច្ចុទ្ធរណៈ ហើយរក្សាទុក ។ បើភិក្ខុកំលោះទៅដោយមិនមានស្មារតី ព្រះថេរៈគប្បីដកចីវររបស់ខ្លួន ហើយកាន់យកចីវររបស់ភិក្ខុកំលោះ ដោយវិស្សាសៈ គប្បីរក្សាទុក ។ បើព្រះថេរៈរឭកមិនបាន តែភិក្ខុកំលោះ រឭកបាន ភិក្ខុកំលោះគប្បីដកចីវររបស់ខ្លួន ហើយកាន់យកចីវររបស់ព្រះថេរៈ ដោយវិស្សាសៈ ហើយប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អធិដ្ឋាន ចីវររបស់លោកម្ចាស់ ហើយប្រើប្រាស់ចុះ ។ ចីវររបស់ខ្លួន ភិក្ខុក៏គប្បី អធិដ្ឋាន ។ សូម្បីដោយការរឭកបានរបស់ភិក្ខុមួយអង្គយ៉ាងនេះ រមែងរួចផុត អាបត្តិបាន ដូច្នេះ ពាក្យដ៏សេសមានអត្ថរាក់ទាំងអស់ហើយ ។

បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម ក្នុងបឋមកឋិនសិក្ខាបទ ជា អកិរិយា គឺមិនអធិដ្ឋាន និងមិនវិកប្ប តែក្នុងសិក្ខាបទនេះ ជាអកិរិយា គឺ មិនបច្ចុទ្ធរណៈ ( មិនដក ) នេះប៉ុណ្ណោះ ជាការប្លែកគ្នា ។ ពាក្យដ៏សេស ក្នុងឋានៈទាំងអស់ មានន័យដូចពោលហើយ ( ក្នុងបឋមកឋិន ) ទាំងអស់ នោះឯង ។

ឧទោសិតសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[ ៣២ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅនាវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលនោះឯង អកាលចីវរ[១] កើតឡើងដល់ភិក្ខុ ១ រូប មានឈ្មោះមិនប្រាកដ លុះភិក្ខុនោះធ្វើចីវរនោះទៅមិនល្មមគ្រាន់ ។ គ្រានោះ ភិក្ខុនោះក៏លើកចីវរនោះឡើង ហើយទាញឲ្យតឹង ធ្វើឲ្យយឺតសាច់សំពត់នោះរឿយៗ ។ ព្រះដ៏មានព្រះភាគបានយាងទៅកាន់សេនាសនចារិក ទ្រង់ទតទៅឃើញភិក្ខុនោះ កំពុងតែលើកចីវរឡើងទាញរឿយៗ លុះទ្រង់ទតឃើញហើយ ទ្រង់យាងចូលទៅជិត ហើយត្រាស់សួរទៅភិក្ខុនោះថា ម្នាលភិក្ខុ បានជាអ្នកលើកចីវរឡើង ហើយទាញរឿយៗ នេះ តើព្រោះហេតុអ្វី ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន នេះជាអកាលចីវរកើតឡើងដល់ខ្ញុំព្រះអង្គៗ ធ្វើទៅមិនគ្រាន់ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គលើកចីវរនេះឡើង ហើយទាញរឿយៗ ដើម្បីឲ្យយឺតសាច់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានបំណងនឹងរកចីវរថែមទៀតដែរឬទេ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសមានបំណងដែរ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងកាលនោះថា ម្នាលភិក្ខុទាំងឡាយ

---

១-គឺចីវរដែលកើតឡើងក្នុងឱកាស ១១ ខែ គឺតាំងពីត្រឹម ថ្ងៃ ១ រោច ខែកត្តិក ទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ នេះជាអកាលចីវររបស់ ភិក្ខុដែលឥតបានក្រាលកឋិន ។ ឯភិក្ខុដែលបានក្រាលកឋិន អកាលចីវរមាន កំណត់ ៧ ខែ គឺតាំងពីត្រឹមថ្ងៃ ១ រោច ខែផល្គុណ ទៅដល់ ១៥ កើត ខែអស្សុជ ។

តថាគត អនុញ្ញាតដើម្បីឲ្យអ្នកទាំងឡាយទទួលនូវអកាលចីវរ ហើយទុកដាក់បាន ព្រោះមានសង្ឃឹមថានឹងបានចីវរថែមទៀត ។

[ ៣៣ ] សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគបានអនុញ្ញាតឲ្យទទួលអកាលចីវរទុកដាក់បាន ព្រោះមានសង្ឃឹមថា នឹងបានចីវរថែមទៀត ហើយក៏ទទួលអកាលចីវរទុកដាក់ ឲ្យលើសជាងមួយខែឡើងទៅ ។ ចីវរទាំងនោះ ក៏ជាប់គ្នាដូចបង្វេចនៅលើឈើស្នៀង ។ ព្រះអានន្ទមានអាយុនិមន្តទៅកាន់សេនាសនចារិក ជួនជាក្រឡេកមើលទៅ ឃើញចីវរទាំងឡាយនោះ ជាប់គ្នាដូចជាបង្វេចនៅលើឈើស្នៀង លុះឃើញហើយ ក៏ហៅភិក្ខុទាំងឡាយ ( នោះ ) មកសួរថា ម្នាលអាវុសោទាំងឡាយ នេះចីវររបស់លោកណា ក៏ជាប់គ្នាដូចជាបង្វេចនៅលើឈើស្នៀង ( ដូច្នេះ ) ។ ភិក្ខុទាំងឡាយប្រាប់ថា ម្នាលអាវុសោ នេះអកាលចីវររបស់យើងៗ ទុកដោយមានបំណងនឹងរកចីវរថែមទៀត ។ ព្រះអានន្ទសួរថា ម្នាលអាវុសោទាំងឡាយ ចុះចីវរទាំងនេះ លោកទុកយូរប៉ុន្មានថ្ងៃហើយ ។ ភិក្ខុទាំងឡាយប្រាប់ថា ចីវរទាំងនេះយើងទុកជាងមួយខែហើយ ។ ព្រះអានន្ទដ៏មានអាយុក៏បន្ទោសតិះដៀលបន្តុះបង្អាប់ថា មិនសមបើពួកភិក្ខុហ៊ានទទួលអកាលចីវរ យកមកទុកឲ្យលើសជាងមួយខែឡើងទៅសោះ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុបានក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងកាលនោះ ហើយត្រាស់សួរទៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុបានទទួលអកាលចីវរទុក ឲ្យ

លើសជាង១ខែមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន ។ ព្រះពុទ្ធជាម្ចាស់ ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ ពួកមោឃបុរសទាំងនោះហ៊ានទទួលអកាលចីវរ ហើយទុកឲ្យលើស ជាងមួយខែ ( ដូច្នេះ ) ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនបានដឹកនាំមនុស្សដែលមិនទាន់បានជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំមនុស្សដែល ជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយចូរសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា កាលបើចីវររបស់ភិក្ខុ សម្រេចហើយ កឋិនដោះហើយ បើអកាលចីវរកើតឡើងចំពោះភិក្ខុ ទាំងភិក្ខុ សោតក៏ត្រូវការ ( អកាលចីវរនោះ ) ត្រូវទទួលចុះ លុះទទួលរួចហើយ ត្រូវរាសរវៃធ្វើឲ្យឆាប់ បើចីវរនោះខ្វះ ធ្វើមិនគ្រាន់ទេ ភិក្ខុនោះមានបំណងថា នឹងរកចីវរមកបំពេញនូវចីវរដែលខ្វះ ( នោះ ) ត្រូវទុកចីវរនោះបានយ៉ាងយូរ បំផុតត្រឹម ១ ខែ បើទុកឲ្យលើសពី ១ ខែនោះទៅ បើទុកជាមានបំណងថា នឹងរកចីវរមកបំពេញទៀតក៏ដោយ គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៣៤ ] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយ ថា ចីវរដែលភិក្ខុធ្វើរួចហើយក្តី ចីវរបាត់ក្តី ចីវរខូចក្តី ចីវរភ្លើងឆេះក្តី សេចក្តី ចង់បានចីវរដាច់ស្រឡះហើយក្តី ។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដែលដោះហើយ បណ្តាមាតិកាទាំង ៨ យ៉ាង ដោយមាតិកាណាមួយ ឬ ពុំនោះជំនុំសង្ឃបានដោះហើយក្នុងចន្លោះ ( ខេត្តកឋិន ) ។ ( បើ ) ភិក្ខុមិន បានក្រាលគ្រងកឋិនទេ ចីវរដែលកើតឡើងក្នុងឱកាស ១១ ខែ ហៅថា អកាល

ចីវរ ( បើ ) ភិក្ខុបានក្រាលគ្រងកឋិន ចីវរដែលកើតឡើងក្នុងឱកាស ៧ ខែ ហៅថា អកាលចីវរ បើទុកជាគេពោលថាជាកាលចីវរហើយឲ្យក៏ដោយ គង់ហៅថា អកាលចីវរដូចគ្នា ។ ពាក្យថា កើតឡើង អធិប្បាយថា គប្បីកើតឡើង អំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបង្សុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី ។

[ ៣៥ ] ពាក្យថា ត្រូវការ អធិប្បាយថា កាលបើចង់បានត្រូវទទួលចុះ ។ ពាក្យថា លុះទទួលរួចហើយត្រូវរាំសរវៃធ្វើឲ្យឆាប់ អធិប្បាយថា ត្រូវធ្វើឲ្យទាន់ក្នុងរវាង ១០ ថ្ងៃ ។

[ ៣៦ ] ពាក្យថា បើចីវរនោះខ្វះធ្វើមិនគ្រាន់ទេ អធិប្បាយថា ចីវរដែលភិក្ខុធ្វើទៅហើយមិនគ្រាន់ ។ ពាក្យថា ភិក្ខុនោះត្រូវទុកចីវរនោះបានយ៉ាងយូរបំផុតត្រឹម ១ ខែ អធិប្បាយថា ភិក្ខុត្រូវទុក ( ចីវរ ) ជាយូរបំផុតត្រឹមតែ ១ ខែ ។ ពាក្យថា ដើម្បីនឹងបំពេញនូវចីវរដែលខ្វះ អធិប្បាយថា ដើម្បីសេចក្តីត្រូវការនឹងបំពេញនូវចីវរដែលខ្វះ ។ ពាក្យថា បើទុកជាមានបំណង អធិប្បាយថា មានសេចក្តីសង្ឃឹមថានឹងបានអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបង្សុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី ។

[ ៣៧ ] ពាក្យថា បើទុកឲ្យលើសពី ១ ខែនោះទៅ ទុកជាមានបំណងថានឹងរកចីវរមកបំពេញទៀតក៏ដោយ អធិប្បាយថា កាលបើមូលចីវរ ( ចីវរដើម ) កើតឡើងក្នុងថ្ងៃនោះហើយ បច្ចាសាចីវរ ( ចីវរដែលកើតឡើងដោយសេចក្តីចង់បានជាខាងក្រោយ ) ក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ ក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២

ថ្ងៃ ... ៣ ថ្ងៃ ... ៤ ថ្ងៃ ... ៥ ថ្ងៃ ... ៦ ថ្ងៃ ... ៧ ថ្ងៃ ... ៨ ថ្ងៃ ... ៩ ថ្ងៃ ... ១០ ថ្ងៃ បច្ចាសាចីវរក៏កើតឡើងក្នុងថ្ងៃទី ១០ ភិក្ខុគប្បីធ្វើចីវរឲ្យហើយក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ១១ ថ្ងៃ ... ១២ ថ្ងៃ ... ១៣ ថ្ងៃ ... ១៤ ថ្ងៃ ... ១៥ ថ្ងៃ ... ១៦ ថ្ងៃ ... ១៧ ថ្ងៃ ... ១៨ ថ្ងៃ ... ១៩ ថ្ងៃ ... ២០ ថ្ងៃ បច្ចាសាចីវរក៏កើតឡើងក្នុងថ្ងៃទី ២០ ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២១ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៩ ថ្ងៃ ។ កាលបើមូលចីវរកើតឡើង បាន ២២ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ ក្នុងរវាង ៨ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៣ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៧ ថ្ងៃ ។ កាលបើ មូលចីវរកើតឡើងបាន ២៤ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៦ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៥ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៥ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៦ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៤ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៧ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ ក្នុងរវាង ៣ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៨ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ២ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៩ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើ

ឲ្យទាន់ក្នុងរវាង ១ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ៣០ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង ( ក្នុងថ្ងៃនោះដែរ ) ភិក្ខុនោះត្រូវអធិដ្ឋាន ត្រូវវិកប្ប ត្រូវលះបង់ក្នុងថ្ងៃនោះឯង ។ បើភិក្ខុមិនបានអធិដ្ឋានក្តី មិនបានវិកប្បក្តី មិនបានលះបង់ក្តី តែអរុណរះឡើងក្នុងថ្ងៃទី ៣១ ( ចីវរនោះ ) ត្រូវនិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន នេះជាអកាលចីវររបស់ខ្ញុំទុកកន្លងហួស ១ ខែ ត្រូវនិស្សគ្គិយហើយ ឥឡូវខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ ( ត្រង់បេយ្យាលទាំង ៣ មានសេចក្តីដូចគ្នានឹងសិក្ខាបទី ១ ក្នុងវគ្គជាមួយគ្នានេះ ) ។

[ ៣៨ ] កាលបើមូលចីវរដែលមានចំណែកមិនស្មើគ្នា[១] កើតឡើងហើយ បច្ចាសាចីវរក៏កើតឡើងដែរ តែរាត្រីសល់នៅច្រើន ( បើ ) ភិក្ខុមិនចង់ធ្វើទេ ក៏មិនត្រូវធ្វើ ( ចីវរនោះឡើយ ) ។

[ ៣៩ ] ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុសម្គាល់ថាកន្លងទៅមែន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុសម្គាល់ថា មិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរដែលមិនបានអធិដ្ឋាន ភិក្ខុសម្គាល់ថា បានអធិដ្ឋានហើយ ( ក្តី ) ចីវរដែលមិនបានវិកប្ប ភិក្ខុសម្គាល់ថា បានវិកប្បហើយ ( ក្តី ) ចីវរដែលមិនបានលះបង់ ភិក្ខុសម្គាល់ថា បានលះបង់ហើយ ( ក្តី ) ចីវរដែលមិនបាត់ ភិក្ខុសម្គាល់ថាបាត់ ( ក្តី ) ចីវរដែលមិនខូចទេ ភិក្ខុសម្គាល់

---

១- មូលចីវរ ឬ បច្ចាសាចីវរដែលមានសាច់ក្រាស់ស្តើងមិនស្មើគ្នា ភិក្ខុមិនអាចនឹងដេរជាមួយគ្នាបាន ហៅថា មានចំណែកមិនស្មើគ្នា ។

ជាខូច ( ក្តី ) ចីវរភ្លើងមិនឆេះ ភិក្ខុសម្គាល់ថាភ្លើងឆេះ ( ក្តី ) ចីវរចោរផត បានយកទេ ភិក្ខុសម្គាល់ថាចោរយក ( ក្តី ) ត្រូវនិស្សគ្គិយបាចិត្តិយ ( ដូចគ្នាទាំងអស់ ) ។

[ ៤០ ] ភិក្ខុមិនបានលះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លងទៅ ១ ខែទេ ហើយភិក្ខុសម្គាល់ថា កន្លងទៅហើយ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លង ១ ខែទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លង ១ ខែទេ ភិក្ខុសម្គាល់ថា មិនទាន់កន្លងមែន មិនត្រូវអាបត្តិឡើយ ។

[ ៤១ ] វារៈសម្តែងអំពីមិនមានអាបត្តិ គឺភិក្ខុបានអធិដ្ឋានចីវរនោះក្នុងរវាងមួយខែ ១ បានវិកប្បចីវរ ១ បានលះ ១ ចីវរបាត់ ១ ចីវរខូច ១ ចីវរភ្លើងឆេះ ១ ចីវរដែលចោរដណ្តើមយកទៅ ១ គេយកចីវរដោយសេចក្តីស្និទ្ធស្នាល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា
# ចីវរវគ្គទី ១ សិក្ខាបទទី ៣
# តតិយកឋិនសិក្ខាបទ

[ ៣២ ] តតិយកឋិនសិក្ខាបទ ពាក្យថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលតទៅថា គប្បីជ្រាបវិនិច្ឆ័យតតិយកឋិនសិក្ខាបទដូចតទៅនេះ

ប្រើនបទថា **ឧស្សាបេត្វា បុនប្បុនំ វិមជ្ជតិ** សេចក្តីថា ភិក្ខុនោះសម្គាល់ថា កាលស្នាមជ្រួញបាត់ហើយ ចីវរនេះនឹងធំឡើង ទើបយកទឹកស្រោច យកជើងជាន់ យកដៃទាញឡើង ហើយស្បែតត្រង់ខ្នង ។ ចីវរនោះស្ងួតហើយ ដោយកម្តៅថ្ងៃ ក៏មានប្រមាណដូចដើមនោះឯង ។ ភិក្ខុនោះក៏ធ្វើយ៉ាងនោះដដែលទៀត ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា ទាញសន្ទឹង ហើយធ្វើឲ្យយឺតសាច់ជាច្រើនដង ។ ព្រះមានព្រះភាគគង់ត្រង់ព្រះគន្ធកុដិនោះឯង ទតឃើញភិក្ខុនោះលំបាកយ៉ាងនោះ ទើបទ្រង់ចេញអំពីព្រះគន្ធកុដិ ដូចយាងទៅកាន់សេនាសនចារិក ទ្រង់បានទៅក្នុងទីនោះ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា **អទ្ទសា ខោ ភគវា** ជាដើម ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃតតិយកឋិនសិក្ខាបទ

[ ៣៤ ] បទថា **ឯកាទសមាសេ** បានដល់ រហូត ១១ ខែដ៏សេសវៀរខែកត្តិកទី ២ មួយខែចេញ ។

បទថា **សត្តមាសេ** បានដល់ ៧ ខែដ៏សេស វៀរ ៥ ខែ គឺខែកត្តិក នោះ មួយអន្ទើ ៤ ខែក្នុងរដូវភ្លៀង ។

ត្រើនបទថា **អកាលេបិ អាទិស្ស ទិន្នំ** សេចក្តីថា ចីវរដែលទាយក ឧទ្ទិសដល់សង្ឃថា នេះជាអកាលចីវរក្តី ដែលទាយកប្រគេនដល់បុគ្គលមួយ អង្គថា ខ្ញុំប្រគេនចីវរនេះដល់លោកម្ចាស់ក្តី ដូច្នេះ ។

បទថា **សង្ឃតោ វា** សេចក្តីថា ចីវរកើតឡើងអំពីសង្ឃ ដោយ អំណាចនៃចំណែកដែលត្រូវបានដល់ខ្លួនក្តី ។

បទថា **គណតោ វា** សេចក្តីថា ពួកទាយករមែងប្រគេនដល់គណៈ យ៉ាងនេះថា ពួកខ្ញុំប្រគេនចីវរនេះដល់គណៈនៃភិក្ខុអ្នករៀនព្រះសូត្រក្តី ប្រគេន ចីវរនេះដល់គណៈនៃភិក្ខុអ្នករៀនព្រះអភិធម្មក្តី ចីវរគប្បីកើតឡើងអំពីគណៈ នោះ ដោយអំណាចនៃចំណែកដែលត្រូវបានដល់ខ្លួនក្តី ។

[ ៣៦ ] បទថា **នោ ចស្ស បារិបូរិ** គឺបើសំពត់នោះមិនទាន់គ្រប់គ្រាន់ អធិប្បាយថា ចីវរដែលគួរអធិដ្ឋានបាន ដែលភិក្ខុធ្វើដោយសំពត់ប្រមាណប៉ុន ណា ទើបគ្រប់គ្រាន់ បើចីវរនោះប្រមាណប៉ុណ្ណោះមិនទាន់មាន គឺខ្វះនោះឯង ។

ក្នុងបទថា **បច្ចាសា ហោតិ សង្ឃតោ វា** ជាដើម មានវិនិច្ឆ័យដូច្នេះ ថា មានការសង្ឃឹមអំពីសង្ឃ ឬគណៈយ៉ាងនេះថា ក្នុងថ្ងៃឈ្មោះនោះ សង្ឃ នឹងបានចីវរ គណៈនឹងបានចីវរ ចីវរនឹងកើតឡើងដល់អាត្មាអញ អំពីសង្ឃក្តី អំពីគណៈក្តីនោះឯង ។ ម្យ៉ាងទៀត សេចក្តីថា មានការសង្ឃឹមអំពីញាតិ ឬ អំពីមិត្រយ៉ាងនេះថា សំពត់ ពួកញាតិបញ្ជូនមកហើយ ពួកមិត្របញ្ជូនមក

ហើយ ដល់អាត្មាអញ ដើម្បីប្រយោជន៍ដល់ចីវរ ជនទាំងនោះមកហើយ នឹងប្រគេនចីវរ ។

ក្នុងបទថា **បំសុក្កូលតោ វា** អ្នកសិក្សាគប្បីប្រកបពាក្យថា មានការសង្ឃឹមនឹងបានយ៉ាងនេះថា អាត្មាអញនឹងបានសំពត់បង្សុកូលក្តី ។

ពីរបទថា **អត្តនោ វា ធនេន** សេចក្តីថា មានសេចក្តីសង្ឃឹមយ៉ាងនេះថា អាត្មាអញនឹងបានក្នុងថ្ងៃឈ្មោះនោះ ដោយទ្រព្យ មានកប្បាស និងអំបោះជាដើមរបស់ខ្លួនក្តី ។

[ ៣៧ ] បទថា **តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយ** សេចក្តីថា បើភិក្ខុទុកលើសជាងមួយខែយ៉ាងក្រៃលែង ជានិស្សគ្គិយបាចិត្តិយ។

តែព្រះមានព្រះភាគ មិនត្រាស់យ៉ាងនេះ ព្រោះកាលចីវរដែលសង្ឃឹមនឹងបានមក កើតឡើងក្នុងចន្លោះ ចីវរដែលសង្ឃឹមនឹងបានមក ដែលកើតឡើងតាំងអំពីថ្ងៃដែលចីវរដើមកើតឡើងមក រហូតដល់ថ្ងៃទី ២០ រមែងធ្វើចីវរដើមឲ្យមានគតិនៃខ្លួន បន្ទាប់អំពីថ្ងៃទី ២០ នោះទៅ ចីវរដើមរមែងធ្វើចីវរដែលសង្ឃឹមនឹងបានមកឲ្យមានគតិនៃខ្លួន ព្រោះហេតុនោះ ដើម្បីសម្តែងភាពពិសេសនោះ ទើបទ្រង់ត្រាស់បទភាជនៈដោយន័យជាដើមថា **តទហុប្បន្នេ មូលចីវរេ** ដូច្នេះ ។ បទថា **តទហុប្បន្នេ** ជាដើម មានអត្ថ ជាក់ច្បាស់ហើយនោះឯង ។

[ ៣៨ ] បទថា **វិសភាគេ ឧប្បន្នេ មូលចីវរេ** សេចក្តីថា បើមូលចីវរសាច់ល្អិត ចីវរដែលសង្ឃឹមនឹងបានមកសាច់គ្រោតគ្រាត មិនអាចដើម្បី

ប្រកបចូលគ្នាបាន រាត្រីក៏នៅមានសល់ គឺខែមិនទាន់ពេញនៅឡើយ ។

បទថា **ឆ អកាមា** សេចក្តីថា ភិក្ខុកាលមិនប្រាថ្នា ក៏មិនគប្បីឲ្យធ្វើចីវរ ។ បានចីវរដែលសង្ឃឹមនឹងបានមកដទៃហើយប៉ុណ្ណោះ គប្បីធ្វើខាងក្នុងកាល ។ សូម្បីចីវរដែលសង្ឃឹមនឹងបានមក គប្បីអធិដ្ឋានជាបរិក្ខារចោឡ ។ បើមូលចីវរ ជាសំពត់សាច់គ្រោតគ្រាត ចីវរដែលសង្ឃឹមនឹងបានមក ជាសំពត់សាច់ល្អិត គប្បីអធិដ្ឋានចីវរដើមឲ្យជាបរិក្ខារចោឡ ហើយទុកចីវរដែលសង្ឃឹមនឹងបានមកនោះឯង ឲ្យជាមូលចីវរវិញ ។ ចីវរនោះរមែងបានបរិហារមួយខែទៀត ភិក្ខុរមែងបានដើម្បីផ្លាស់ប្តូរគ្នានិងគ្នា រក្សាទុកជាមូលចីវរហូតដរាបតាមដែលខ្លួនប្រាថ្នា ដោយឧបាយនេះឯង ។ ពាក្យដ៏សេសមានអត្ថរាក់ទាំងអស់ហើយ ។ បកិណ្ណកៈ មានសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមកឋិនសិក្ខាបទនោះឯង ។

តតិយកឋិនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ៤២ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្ត ព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មាន ស្រីជាបុរាណទុតិយិការបស់ឧទាយិភិក្ខុដ៏មានអាយុ បួសក្នុងសម្នាក់នាងភិក្ខុនី ។ នាងភិក្ខុនីនោះ តែងមកកាន់សម្នាក់ឧទាយិភិក្ខុដ៏មានអាយុជារឿយៗ ។ ចំណែក ខាងឧទាយិភិក្ខុដ៏មានអាយុ ក៏តែងទៅកាន់សម្នាក់នាងភិក្ខុនីនោះជារឿយៗដែរ ។ វេលានោះឯង ឧទាយិភិក្ខុដ៏មានអាយុ បរិភោគភត្តក្នុងសម្នាក់នាងភិក្ខុនីនោះ ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏ស្លៀកដណ្តប់រួចយកបាត្រ និងចីវរ ចូលសំដៅទៅរកទីដែលនាងភិក្ខុនីនោះ នៅក្នុងវេលាព្រឹកព្រហាម លុះចូលទៅ ដល់ហើយ ក៏អង្គុយលើអាសនៈខាងមុខនាងភិក្ខុនីនោះ បើកអង្គជាតបង្ហាញ ។ ឯនាងភិក្ខុនីនោះ ក៏អង្គុយលើអាសនៈខាងមុខឧទាយិដ៏មានអាយុ បើកអង្គជាត បង្ហាញដែរ ។ វេលានោះ ឧទាយិភិក្ខុដ៏មានអាយុមានតម្រេក ក៏សម្លឹងមើល ទៅអង្គជាតនាងភិក្ខុនីនោះ ។ ទឹកអសុចិក៏ហូរធ្លាក់ពីអង្គជាតរបស់ឧទាយិភិក្ខុ នោះ ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏និយាយទៅនឹងភិក្ខុនីនោះថា នែប្អូនស្រី ឯងចូរទៅនាំយកទឹកមក អញនឹងលាងស្បង់ ។ នាងភិក្ខុនីនោះ តបវិញថា លោកម្ចាស់ សូមលោកម្ចាស់ឲ្យស្បង់មកខ្ញុំវិញ ខ្ញុំនឹងលាងប្រគេន ។ វេលានាះឯង នាងភិក្ខុនីនោះ ក៏បានយកទឹកអសុចិរបស់ឧទាយិភិក្ខុនោះបន្តិច ដាក់ក្នុងមាត់ យកបន្តិចដាក់ក្នុងអង្គជាត ។ នាងភិក្ខុនីនោះក៏មានគភ៌ដោយសារ ទឹកអសុចិនោះ ។ ពួកនាងភិក្ខុនីក៏និយាយយ៉ាងនេះថា នាងភិក្ខុនីនេះមិនមែន

ប្រព្រឹត្តធម៌ដ៏ប្រសើរទេ ទើបបាននាងភិក្ខុនីនេះមានគភ៌ ។ នាងភិក្ខុនីនោះតប វិញថា ម្នាលនាងទាំងឡាយ ខ្ញុំមិនបានប្រព្រឹត្តធម៌ដ៏ប្រសើរទេ ។ វេលានោះ នាងភិក្ខុនីនោះបានប្រាប់សេចក្តីនុ៎ះដល់នាងភិក្ខុនីផងគ្នា ។ នាងភិក្ខុនីទាំងឡាយ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ឧទាយិប្រើនាងភិក្ខុនីឲ្យលាងចីវរចាស់ ( របស់ខ្លួនសោះ ) ។ លំដាប់នោះ ពួកនាងភិក្ខុនីទាំងនោះបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរឧទាយិដ៏មានអាយុ ប្រើនាងភិក្ខុនីឲ្យលាងចីវរចាស់ ។ គ្រានោះ ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។បេ។ ទ្រង់សួរឧទាយិភិក្ខុដ៏មានអាយុថា ម្នាលឧទាយិឮថា អ្នកបានប្រើនាងភិក្ខុនីឲ្យលាងចីវរចាស់មែនឬ ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះ ត្រូវជាញាតិ ឬមិនមែនជាញាតិនឹងអ្នកទេ ។ ឧទាយិ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ( នាងភិក្ខុនីនោះ ) មិនត្រូវជាញាតិនឹងខ្ញុំព្រះអង្គទេ ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា នែមោឃបុរសជនមិនមែនជាញាតិ មិនស្គាល់អំពើសមគួរ ឬមិនសមគួរ អំពើនាំមកនូវសេចក្តីជ្រះថ្លា ឬមិននាំមកនូវសេចក្តីជ្រះថ្លារបស់នាងភិក្ខុនី ដែលមិនមែនជាញាតិ ( នោះទេ ) នែមោឃបុរស មិនសមបើអ្នកទៅប្រើនាងភិក្ខុនីដែលមិនមែនជាញាតិឲ្យលាងចីវរចាស់សោះ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែល

ជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀត ( នោះ ) ទេ ។បេ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រើនាងភិក្ខុនីដែលមិនមែនជាញាតិឲ្យលាងក្តី ឲ្យជ្រលក់ក្តី ឲ្យគក់ ឬ បោកក្តី នូវចីវរចាស់ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៤៣ ] ត្រង់ពាក្យថា ភិក្ខុណាមួយ ( ត្រង់បេយ្យាលទាំងពីរ ) មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងបារាជិកកណ្ឌរួចហើយ ។ នាងភិក្ខុនីដែលឥតមានជាប់ទងគន្លងអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនជាញាតិ ។ ដែលហៅថា នាងភិក្ខុនី ( នោះសំដៅយក ) ស្រីដែលបានឧបសម្បទាក្នុងសម្នាក់សង្ឃទាំង ២ ( ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ) ។ សំពត់ដែលភិក្ខុស្លៀកម្តងក្តី ដណ្តប់ម្តងក្តី ហៅថា ចីវរចាស់ ។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរលាងចីវរឲ្យអាត្មា ( យ៉ាងនេះ ) ត្រូវអាបត្តិទុក្កដ ។ ចីវរដែលនាងភិក្ខុនីលាងហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុបង្គាប់នាងភិក្ខុនីថា នាងចូរជ្រលក់ចីវរឲ្យអាត្មា ត្រូវអាបត្តិទុក្កដ ។ ចីវរដែលនាងភិក្ខុនីជ្រលក់ហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរបោកចីវរឲ្យអាត្មា ត្រូវអាបត្តិទុក្កដ ។ កាលបើចីវរដែលនាងភិក្ខុនី យកមកបោកដោយដៃក្តី ដោយដំបងក្តី អស់វារៈតែម្តង ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវលះចីវរនោះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរយ៉ាងនេះ ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរចាស់នេះ ខ្ញុំបានប្រើនាងភិក្ខុនី មិនមែនជាញាតិឲ្យលាង ជានិស្សគ្គិយហើយ ខ្ញុំសូមលះ

ចីវរនេះដល់ជំនុំសង្ឃ ។ ( ត្រង់បេយ្យាលទាំង ៣ មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ ) ។

[ ៤៤ ] នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាងនូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យលាង ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ ២ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ នាងភិក្ខុនីដែលមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យបោក ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ ២ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក

ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យបោក ឲ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក ឲ្យលាង ឲ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ ២ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ។បេ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ។បេ។ ហើយប្រើឲ្យលាងនូវចីវរចាស់របស់ភិក្ខុឯទៀត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើ ( នាងភិក្ខុនីមិនមែនជាញាតិ ) ឲ្យលាងសំពត់និសីទនៈ និងគ្រឿងកម្រាល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើនាងភិក្ខុនីដែលជាឯកតោឧបសម្បន្នា ឲ្យលាង ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ មិនត្រូវអាបត្តិឡើយ ។

[ ៤៥ ] អាបត្តិ ( មិនមានដល់ភិក្ខុ មាន ៨ យ៉ាង ) គឺនាងភិក្ខុនីដែលជាញាតិរបស់ភិក្ខុកំពុងលាងចីវររបស់ភិក្ខុ ហើយស្រាប់តែមាននាងភិក្ខុនីទី ២ ដែលមិនមែនជាញាតិ មកយកចីវរអំពីដៃនាងភិក្ខុនីនោះទៅលាងឲ្យ ១ នាងភិក្ខុនីឃើញចីវររបស់ភិក្ខុមានមន្ទិលសៅហ្មង ហើយយកមកលាងឲ្យមិនបាច់ចាំប្រើ ១ ភិក្ខុប្រើនាងភិក្ខុនីឲ្យលាងចីវរថ្មីដែលមិនទាន់បានប្រើប្រាស់ ១ ភិក្ខុប្រើនាងភិក្ខុនីឲ្យលាងគ្រឿងបរិក្ខារឯទៀត ក្រៅពីចីវរ ១ ភិក្ខុប្រើនាងសិក្ខមានាឲ្យលាងចីវរឲ្យ ១ ភិក្ខុប្រើសាមណេរីឲ្យលាងចីវរឲ្យ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់

# អដ្ឋកថា

# ចីវរវគ្គទី ១ សិក្ខាបទទី ៤

# បុរាណចីវរធោវាបនសិក្ខាបទ

[ ៤២ ] *បុរាណចីវរសិក្ខាបទ ត្រង់ពាក្យថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងបុរាណចីវរសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះ*

# អធិប្បាយ

# សិក្ខាបទវិភង្គនៃបុរាណចីវរធោវាបនសិក្ខាបទ

[ ៤៣ ] *បទថា* **យាវ សត្តមា បិតាមហយុគា** *សេចក្តីថា បិតារបស់ឪពុក ឈ្មោះថា* **បិតាមហ ។** *យុគនៃបិតាមហៈ ឈ្មោះថា* **បិតា-មហយុគ ។** *ប្រមាណនៃអាយុ លោកហៅថា* **យុគ ។** *សព្ទថា* **យុគ** *នេះ ត្រឹមតែជាវោហារនិយាយគ្នាប៉ុណ្ណោះ ។ តែដោយអត្ថ* **បិតាមហ** *នោះឯង ឈ្មោះថា* **បិតាមហយុគ ។** *បុព្វបុរសបន្ទាប់ឡើងទៅអំពីបិតាមហយុគនោះទាំងអស់ ព្រះមានព្រះភាគទ្រង់កាន់យកដោយ* **បិតាមហ** *សព្ទនោះឯង ។ ភិក្ខុនីដែលមិនទាក់ទងគ្នាមកអស់ ៧ ជួរបុរសយ៉ាងនេះ ត្រាស់ហៅថា មិនមែនបុគ្គលជាប់ទាក់ទងគ្នាមកអស់ ៧ ជួរអាយុនៃបុព្វជនក ។* **បិតាមហ** *សព្ទនេះ ជាប្រធាននៃទេសនាប៉ុណ្ណោះ ។ តែព្រោះព្រះបាលីថា* **មាតិតោ វា បិតិតោ វា** *ដូច្នេះ* **បិតាមហយុគ** *ក្តី* **បិតាមហីយុគ** *ក្តី* **មាតាមហយុគ** *ក្តី* **មាតាមហីយុគ** *ក្តី ក៏ឈ្មោះថា* **បិតាមហយុគ** *សូម្បីពួកញាតិ មានបងប្អូនប្រុស បងប្អូនស្រី ក្មួយ កូន និងចៅជាដើម របស់បិតាមហយុគជាដើម*

ទាំងអស់នោះ គប្បីជ្រាបថា ទ្រង់សង្គ្រោះចូលក្នុងបទថា **បិតាមហយុគ** នេះទាំងអស់ ។

ក្នុងយុគ ៤ គឺ **បិតាមហយុគ បិតាមហីយុគ មាតាមហយុគ** និង **មាតាមហីយុគ** នោះ មានន័យពិស្តារដូចតទៅនេះថា ភិក្ខុនីមិនមែនបុគ្គលជាប់ទាក់ទងគ្នាដោយចំណែកមាតា មិនជាប់ទាក់ទងគ្នាដោយចំណែកខាងបិតា អស់ ៧ ជួរអាយុរបស់បុព្វជនកយ៉ាងនេះ គឺបិតា បិតារបស់បិតា បិតារបស់ជីតា ( តាទួត ) បិតារបស់តាទួតនោះ ( តាលួត ) ។

អស់ ៧ ជួរយុគ ទាំងខាងលើ និងខាងក្រោមយ៉ាងនេះ គឺ បិតា ១ មាតារបស់បិតា ១ បិតានិងមាតារបស់មាតានោះ ១ បងប្អូនប្រុស ១ បងប្អូនស្រី ១ កូនប្រុស ១ កូនស្រី ១ ។

អស់ ៧ ជួរយុគយ៉ាងនេះ គឺ បិតា បងប្អូនប្រុសរបស់បិតា បងប្អូនស្រីរបស់បិតា កូនប្រុសរបស់បិតា កូនស្រីរបស់បិតា ខ្សែស្រឡាយរបស់បុត្រធីតារបស់ជនទាំងនោះ ។

អស់ ៧ ជួរយុគយ៉ាងនេះ គឺមាតា មាតារបស់មាតា មាតារបស់យាយ ( យាយទួត ) មាតារបស់យាយទួត ( យាយលួត ) ។

អស់ ៧ ជួរយុគទាំងខាងលើ និងខាងក្រោមយ៉ាងនេះ គឺមាតា ១ បិតារបស់មាតា ១ បិតា និងមាតារបស់ជីតានោះ ( តាទួត យាយទួត ) ១ បងប្អូនប្រុស ១ បងប្អូនស្រី ១ កូនប្រុស ១ កូនស្រី ១ ។

អស់ ៧ ជួរយុគយ៉ាងនេះ គឺមាតា បងប្អូនប្រុសរបស់មាតា បងប្អូន

ស្រីរបស់មាតា កូនប្រុសរបស់មាតា កូនស្រីរបស់មាតា ខ្សែស្រឡាយ កូនប្រុសកូនស្រីរបស់ជនទាំងនោះ នេះឈ្មោះថា បុគ្គលមិនមែនជាញាតិ ។

បទថា **ឧភតោសង្ឃេ** សេចក្តីថា ភិក្ខុនីដែលឧបសម្បទាដោយអដ្ឋវាចិកវិនយកម្ម គឺដោយញត្តិចតុត្ថកម្ម ក្នុងចំណែកភិក្ខុសង្ឃ ១ ដោយញត្តិចតុត្ថកម្មក្នុងចំណែកភិក្ខុនីសង្ឃ ១ ។

បទថា **សកឹ និវត្ថំបិ សកឹ បារុតំបិ** សេចក្តីថា ចីវរដែលជ្រលក់ហើយ ធ្វើកប្បស្រេច ស្លៀក ឬដណ្តប់សូម្បីត្រឹមម្តង ។ដោយហោចពាក់ទុកលើស្មា ឬលើក្បាល ដោយសំដៅយកការប្រើប្រាស់ជាធំ ដើរផ្លូវក្តី ទទូរក្បាលដេកក្តី សូម្បីចីវរនោះក៏ឈ្មោះថា ចីវរចាស់ដូចគ្នា ក្នុងកុរុន្ទីពោលថា បើភិក្ខុដេកយកចីវរទុកក្រោមដំណេក ឬយកដៃទាំងពីរលើកឡើង ធ្វើជាពិតានលើអាកាស មិនប៉ះក្បាលដើរទៅ នេះមិនឈ្មោះថា ប្រើប្រាស់ឡើយ ។

ក្នុងបទថា **ធោវាបេតិ និស្សគ្គិយំ** នេះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុនីដែលត្រូវភិក្ខុប្រើយ៉ាងនេះ រមែងរៀបចំជើងក្រាន ជញ្ជូនឧសមក បង្កាត់ភ្លើង ដងទឹកមក ដើម្បីប្រយោជន៍ដល់ការបោក រមែងត្រូវអាបត្តិទុក្កដដល់ភិក្ខុគ្រប់ៗប្រយោគរបស់ភិក្ខុនី អស់កាលដែលភិក្ខុនីនៅលើកចីវរនោះឡើង បោកគក់ចីវរនោះ លុះបោកស្រេចហើយ លើកឡើងក៏ជានិស្សគ្គិយ ។ បើភិក្ខុនីសម្គាល់ថា ចីវរមិនទាន់ស្អាត ទើបចាក់ទឹកស្រោច ឬបោកជាថ្មី ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ អស់កាលដែលមិនទាន់សម្រេច ។ សូម្បីការជ្រលក់និងការវាយ ក៏មានន័យយ៉ាងនេះ ។ ភិក្ខុនីចាក់ទឹកជ្រលក់ចុះក្នុងស្នូកសម្រាប់

ជ្រលក់ ហើយជ្រលក់ត្រឹមម្តង ធ្វើកិច្ចឯណាមួយ មុនការចាក់ទឹកជ្រលក់ជាដើមនោះ ដើម្បីប្រយោជន៍ដល់ការជ្រលក់ ឬខាងក្រោយមក ត្រឡប់ជ្រលក់ជាថ្មី ត្រូវអាបត្តិទុក្កដដល់ភិក្ខុគ្រប់ៗ ប្រយោគ ក្នុងឋានៈទាំងពួង ។ សូម្បីក្នុងការវាយ ក៏គប្បីជ្រាបប្រយោគយ៉ាងនេះ ។

# អធិប្បាយ

## បទភាជនីយនៃបុរាណចោវាបនសិក្ខាបទ

[ ៤៤ ] បទថា **អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ ធោវាបេតិ** សេចក្តីថា បើភិក្ខុមិនពោលថា នាងចូរបោកចីវរនេះឲ្យខ្ញុំ តែធ្វើកាយវិការដើម្បីប្រយោជន៍ដល់ការបោក ឲ្យត្រង់ដៃដោយដៃ ឬដាក់ក្បែរជើង ឬផ្ញើតៗ ទៅ គឺបញ្ជូនទៅក្នុងដៃរបស់សិក្ខមានា សាមណេរ សាមណេរី ឧបាសិកា និងតិរ្ច្ឆានយជាដើម ឬបោះទៅក្នុងទីជិតនៃភិក្ខុនី ដែលកំពុងបោកនៅត្រង់កំពង់ទឹក គឺក្នុងឱកាសខាងក្នុង ១២ ហត្ថ ចីវរ ឈ្មោះថា ភិក្ខុប្រើភិក្ខុនីឲ្យបោកដូចគ្នា ។ បើភិក្ខុលះឧបចារៈ ដាក់អំពីខាងអាយ ភិក្ខុនីនោះក៏បោកហើយនាំមក មិនត្រូវអាបត្តិដល់ភិក្ខុ ។ ភិក្ខុឲ្យចីវរក្នុងដៃនៃសិក្ខមានាក្តី សាមណេរក្តី ឧបាសិកាក្តី ដើម្បីប្រយោជន៍ដល់ការបោក បើសិក្ខមានានោះឧបសម្បទាហើយ ទើបបោក ក៏ត្រូវអាបត្តិដូចគ្នា ។ បើទុកក្នុងដៃនៃឧបាសក បើឧបាសកនោះ មានភេទត្រឡប់ហើយ បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ភិក្ខុនីហើយទើបបោក ត្រូវអាបត្តិដូចគ្នា ។ សូម្បីក្នុងចីវរដែលឲ្យក្នុងដៃរបស់សាមណេរ ឬរបស់ភិក្ខុក្នុងវេលាក្លាយភេទ ក៏មានន័យយ៉ាងនេះដូចគ្នា ។

ក្នុងបទថា **ធោវាបេតិ រជាបេតិ** ជាដើម មានវិនិច្ឆ័យដូច្នេះថា ចីវរជានិស្សគ្គិយដោយវត្ថុដំបូង ត្រូវអាបត្តិទុក្កដដល់ភិក្ខុដោយវត្ថុទី ២ កាលភិក្ខុឲ្យធ្វើទាំង ៣ វត្ថុ ជានិស្សគ្គិយដោយវត្ថុដំបូង ត្រូវអាបត្តិទុក្កដ ២ ដោយវត្ថុដ៏សេស ។ តែបើភិក្ខុប្រើឲ្យធ្វើការបោកជាដើមនេះតាមលំដាប់ ឬខុសលំដាប់ ក៏មានការផុតចាកអាបត្តិ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ចតុក្កៈ ៣ ពួកទុកក្នុងព្រះបាលីនេះ ។ តែបើភិក្ខុពោលថា នាងចូរជ្រលក់បោកចីវរនេះ ហើយនាំមកឲ្យខ្ញុំ ដូច្នេះ ភិក្ខុនីនោះបោកមុនហើយ ទើបជ្រលក់ជាក្រោយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយប៉ុណ្ណោះ ។ ក្នុងពាក្យដែលផ្សំគ្នាទាំងអស់ ក៏គប្បីជ្រាបដោយន័យយ៉ាងនេះ ។ បើភិក្ខុពោលថា នាងបោកហើយ ចូរនាំមក ភិក្ខុនីបោកផង ជ្រលក់ផង ប្រព្រឹត្តជាអាបត្តិ ព្រោះការបោកជាបច្ច័យតែម្យ៉ាង មិនត្រូវអាបត្តិព្រោះការជ្រលក់ឡើយ ។ គប្បីជ្រាបអនាបត្តិដោយលក្ខណៈនេះថា ភិក្ខុមិនបានប្រើ បោកឯង ព្រោះការធ្វើហួសពាក្យដែលភិក្ខុប្រើគ្រប់ៗ អន្លើ ដោយប្រការយ៉ាងនេះ ។ តែកាលភិក្ខុពោលថា កិច្ចណាដែលគប្បីធ្វើក្នុងចីវរនេះ កិច្ចនោះ ចូរជាការៈរបស់នាងទាំងអស់ ដូច្នេះ រមែងត្រូវអាបត្តិជាច្រើន ព្រោះពាក្យពោលតែមួយ ។ ឯបទទាំងនេះថា **អញ្ញាតិកាយ វេមតិកោ អញ្ញាតិកាយ ញាតិកសញ្ញី** គប្បីជ្រាបដោយពិស្តារ ដោយអំណាចនៃចតុក្កៈ ៣ ពួក ដោយន័យដូចពោលហើយនោះឯង ។

[ ៤៥ ] ពីរបទថា **ឯកតោ ឧបសម្បន្នាយ** សេចក្តីថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលប្រើភិក្ខុនី ដែលឧបសម្បទាក្នុងសម្នាក់ភិក្ខុនីទាំងឡាយឲ្យបោក ។ តែកាលប្រើភិក្ខុនី ដែលឧបសម្បទាក្នុងសម្នាក់នៃភិក្ខុទាំងឡាយឲ្យបោក ត្រូវអាបត្តិតាមវត្ថុដូចគ្នា ។ សាកិយានី ៥០០ ឈ្មោះថា ជាអ្នកឧបសម្បទាក្នុងសម្នាក់នៃភិក្ខុទាំងឡាយ ។

## អនាបត្តិនៃបុរាណចីវរធោវបនសិក្ខាបទ

[ ៤៥ ] ពីរបទថា **អវុត្តា ធោវតិ** សេចក្តីថា ភិក្ខុនីដែលមកដើម្បីឧទ្ទេសក្តី ដើម្បីឱវាទក្តី ឃើញចីវរសៅហ្មង ជួយយកទៅអំពីកន្លែងដែលទុកក្តី ឲ្យនាំមកដោយពោលថា លោកម្ចាស់ សូមឲ្យមកចុះ ខ្ញុំនឹងបោកហើយបោកក្តី ជ្រលក់ក្តី ដំក្តី ភិក្ខុនីនេះ ឈ្មោះថា បុគ្គលដែលភិក្ខុមិនបានប្រើឲ្យបោក ។ ភិក្ខុនីណា បានឮភិក្ខុប្រើភិក្ខុកំលោះ ឬសាមណេរថា លោកចូរបោកចីវរនេះ ហើយពោលថា បពិត្រលោកម្ចាស់ សូមនាំមកចុះ ខ្ញុំនឹងបោកឯង ហើយបោកក្តី កាន់យកជារបស់ខ្ញុំ ហើយបោក ជ្រលក់ឲ្យក្តី ភិក្ខុនីនេះក៏ឈ្មោះថា ជាបុគ្គលដែលភិក្ខុមិនបានប្រើ គឺបោកឯង ។

ពីរបទថា **អញ្ញំ បរិក្ខារំ** សេចក្តីថា ភិក្ខុប្រើភិក្ខុនីឲ្យបោក ឬលាងបណ្តាបរិក្ខារ មានថង់ស្បែកជើង ស្បោកបាត្រ សំពត់អង្សៈ វត្ថពន្ធចង្កេះ គ្រែ តាំង ពូក និងកន្ទេលជាដើមឯណាមួយ មិនត្រូវអាបត្តិ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថពាក់ទាំងអស់ហើយ ។

ក្នុងបណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាបុរាណចីវរធោវាបនសិក្ខាបទទី ៤ ចប់

# វិនយបិដក

## សិក្ខាបទទី ៥

[ ៤៦ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង នាងឧប្បលវណ្ណាភិក្ខុនីនៅក្នុងអន្ធវ័ន ទៀបក្រុងសាវត្ថី ។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនីលុះពេលព្រឹកឡើង ក៏បានស្លៀកដណ្តប់រួចនាំយកបាត្រ និងចីវរចូលទៅឯក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះដើរទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី រួចត្រឡប់មកអំពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្ត ហើយក៏ចូលសំដៅទៅក្នុងអន្ធវ័ន ( ព្រៃងងឹត ) ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់ព្រៃអន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបគល់ឈើមួយ ។ សម័យនោះឯង មានពួកចោរអ្នកធ្វើនូវចោរកម្ម បានសម្លាប់មេគោមួយ អារយកសាច់ រួចនាំយកចូលទៅកាន់ព្រៃអន្ធវ័ន ។ ឯមេចោរជាធំបានក្រឡេកមើលទៅឃើញនាងឧប្បលវណ្ណាភិក្ខុនីកំពុងអង្គុយសម្រាកក្នុងវេលាថ្ងៃ ទៀបគល់ឈើមួយ ។ លុះឃើញហើយ ចោរនោះក៏មានសេចក្តីត្រិះរិះថា បើប្រសិនណាពួកចោរជាកូន និងបងប្អូនអញឃើញនាងភិក្ខុនីនេះហើយ មុខជានឹងបៀតបៀននាងភិក្ខុនីនេះមិនខាន ( លុះគិតយ៉ាងនេះហើយ ) មេចោរក៏នាំពួកចោរទាំងនោះដើរទៅតាមផ្លូវដទៃវិញ វេលានោះឯង មេចោរនោះកាលបើដុំសាច់គេចម្អិនរួចស្រេចហើយ ក៏យកសាច់យ៉ាងល្អ ខ្ចប់នឹងស្លឹកឈើយកទៅព្យួរនឹងដើមឈើជិតនាងឧប្បលវណ្ណាភិក្ខុនី ហើយពោលថា នរណាមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី បានឃើញ

ដុំសាច់ដែលអញទុកឲ្យនេះហើយ ចូរនាំយកទៅចុះ រួចហើយក៏ចេញដើរទៅ ។ នាងឧប្បលវណ្ណាភិក្ខុនីចេញពីសមាធិហើយ បានឮសំដីនេះរបស់មេចោរដែលកំពុងពោលនោះ ។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនីក៏បានយកសាច់នោះទៅឯកន្លែងនៅរបស់ខ្លួន ។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនី លុះកន្លងរាត្រីនោះទៅហើយ នាងក៏ចាត់ចែងយកសាច់នោះ មកវេចជាបង្វេចដោយចីពររួចហើយក៏ហោះទៅឯអាកាស ទៅចុះក្នុងវត្តវេឡុវ័ន ។

[ ៤៧ ] សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ឧទាយិភិក្ខុដ៏មានអាយុជាអ្នកនៅចាំរក្សាវត្ត ។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនី បានចូលទៅរកឧទាយិភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏សួរទៅឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់យាងទៅណា ។ ឧទាយិប្រាប់ថា ម្នាលប្អូនស្រី ព្រះដ៏មាន-ព្រះភាគទ្រង់យាងចូលទៅបិណ្ឌបាតឯស្រុកហើយ ។ នាងឧប្បលវណ្ណាភិក្ខុនីនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាថ្វាយសាច់នេះដល់ព្រះដ៏មានព្រះភាគឲ្យទានផង ។ ឧទាយិនិយាយថា ម្នាលប្អូនស្រី នាងឲ្យព្រះដ៏មានព្រះភាគទ្រង់ឆ្អែតដោយសាច់ ( យ៉ាងណា ) ប្រសិនបើនាងឲ្យស្បង់ដល់អាត្មា អាត្មាក៏ឈ្មោះថា នាងឲ្យឆ្អែតដោយស្បង់យ៉ាងនោះដែរ ។ នាងឧប្បលវណ្ណាភិក្ខុនីតបវិញថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាមាតុគ្រាមមានលាភបានដោយកម្រណាស់ ។ មួយទៀត ចីវររបស់ខ្ញុំនេះ ជាចីវរគម្រប់ ៥ ជាទីបំផុត ខ្ញុំមិនប្រគេនលោកម្ចាស់ទេ ។ ឧទាយិនិយាយថា ម្នាលប្អូនស្រី

ដូចជាបុរសដែលឲ្យដីរ ( ទៅគេ ) គួរលះខ្សែជន្គន់ផង យ៉ាងណាមិញ ម្នាលប្អូនស្រី បើថ្វាយសាច់ដល់ព្រះដ៏មានព្រះភាគហើយ ចូរលះស្បង់របស់នាងដល់អាត្មា ក៏យ៉ាងនោះដែរ ។ គ្រានោះ នាងឧប្បលវណ្ណាភិក្ខុនី កាលបើឧទាយិដ៏មានអាយុចេះតែទទូចសូម ក៏ប្រគេនស្បង់ ហើយត្រឡប់ទៅឯលំនៅរបស់ខ្លួនវិញ ។ ពួកនាងភិក្ខុនីកាលទទួលយកបាត្រ និងចីវរពីនាងឧប្បលវណ្ណាភិក្ខុនី ក៏សួរនាងឧប្បលវណ្ណាភិក្ខុនីថា បពិត្រនាងជាម្ចាស់ ស្បង់របស់នាងតើនៅឯណា ។ នាងឧប្បលវណ្ណាភិក្ខុនី ក៏បានប្រាប់សេចក្តីនុ៎ះដល់នាងភិក្ខុនីទាំងឡាយ ។ នាងភិក្ខុនីទាំងឡាយក៏លើកទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយិមិនសមបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ មាតុគ្រាមសុទ្ធតែមានលាភបានដោយកម្រ ។ គ្រានោះ នាងភិក្ខុនីទាំងនោះក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនគួរបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិបានឮថា អ្នកឯងបានទទួលចីវរពីដៃនាងភិក្ខុនីមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះត្រូវជាញាតិនឹងអ្នកឯង ឬមិនមែនជាញាតិទេ ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ( នាងភិក្ខុនីនោះ ) មិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលមោឃបុរស បុរសដែលមិនមែន

ជាញាតិ មិនស្គាល់អំពើគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អ របស់ស្ត្រីដែលមិនមែនជាញាតិ ( នោះ ) ទេ ម្នាលមោឃបុរស អ្នកឯងហេតុអ្វី ក៏ទទួលយកចីវរអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ ( ដូច្នេះ ) ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ នឹងបានដឹកនាំមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ ( ភិក្ខុនោះ ) ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

[ ៤៨ ] សម័យនោះឯង មានពួកភិក្ខុសង្ស័យ មិនហ៊ានទទួលយកចីវរដែលត្រូវការផ្លាស់ប្តូររបស់នាងភិក្ខុនីទាំងឡាយ ។ នាងភិក្ខុនីទាំងឡាយ ក៏លើកទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនគួរបើនឹងមិនទទួលយកចីវរដែលត្រូវការផ្លាស់ប្តូររបស់យើងសោះ ។ កាលពួកនាងភិក្ខុនីទាំងនោះកំពុងលើកទោស តិះដៀលបន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នកទាំងឡាយទទួលយកចីវរ ដែលត្រូវការផ្លាស់ប្តូរគ្នារបស់សហធម្មិកបុគ្គល ៥ ពួក គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ម្នាលភិក្ខុទាំងឡាយ

តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយ ទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរគ្នានឹងពួកសហធម្មិកទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ ( ភិក្ខុនោះ ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។

[ ៤៩ ] ត្រង់ពាក្យថា ភិក្ខុណាមួយ ( ត្រង់បេយ្យាលទាំង ២ មានអធិប្បាយក្នុងបឋមបារាជិកសិក្ខាបទរួចហើយ ) ។ នាងភិក្ខុនីដែលឥតមានជាប់ទងគន្ធងអំពីចំណែកខាងមាតាក្តី ចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនជាញាតិ ។ ស្រីដែលបានឧបសម្បទាអំពីសម្នាក់ឧភតោសង្ឃ ហៅថា នាងភិក្ខុនី ។ បណ្តាចីវរទាំង ៦ ចីវរណាមួយ ដែលតូចបំផុតគួរល្មមភិក្ខុនីងវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា វៀរលែងតែផ្លាស់-ប្តូរគ្នា សេចក្តីថា លើកលែងតែចីវរដែលផ្លាស់ប្តូរគ្នា ។ ភិក្ខុទទួលយកចីវរត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទទួល ចីវរនោះ ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះចីវរនោះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះដែលខ្ញុំបានទទួលយកអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ ជានិស្សគ្គិយហើយ វៀរលែងតែផ្លាស់ប្តូរគ្នា ឥឡូវខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ ។ ( ត្រង់បេយ្យាលទាំង ៣ មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ ) ។

[ ៥០ ] នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ ទទួលចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។

[ ៥១ ] ភិក្ខុទទួលយកចីវរអំពីដៃនាងភិក្ខុនី ដែលបានឧបសម្បទាអំពីសម្នាក់ឯកតោសង្ឃ ( គឺអំពីចំណែកខាងភិក្ខុនីសង្ឃតែម្យ៉ាង ) ត្រូវអាបត្តិទុក្កដ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ មិនត្រូវអាបត្តិឡើយ ។

[ ៥២ ] អាបត្តិមិនមានដល់ភិក្ខុ ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង គឺភិក្ខុទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលជាញាតិ ១ ភិក្ខុទទួលយកចីវរដោយការផ្លាស់ប្តូរគ្នា ១ ភិក្ខុទទួលយកចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច ឬភិក្ខុទទួលយកចីវរមានតម្លៃតិច ដោយចីវរមានតម្លៃច្រើន ១ ភិក្ខុយកចីវរដោយសេចក្តីស្និទ្ធស្នាល គឺយកដោយអាងសេចក្តីទុកចិត្តគ្នា ១ ភិក្ខុយកចីវរជារបស់ខ្ចីគ្នា ១ ភិក្ខុទទួលយកគ្រឿងបរិក្ខារឯទៀតរបស់សិក្ខមានា និងសាមណេរី លើកលែងតែចីវរចេញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា
## ចីវរវគ្គទី ១ សិក្ខាបទទី ៨
## ចីវរបដិគ្គហណសិក្ខាបទ

[ ៤៦ ] ចីវរបដិគ្គហណសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងចីវរបដិគ្គហណសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា

បទថា **បិណ្ឌចារបដិក្កន្តា** ប្រែថា ត្រឡប់មកអំពីបិណ្ឌបាត ។

បទថា **យេន អន្ធវនំ តេនុបសង្កមិ** សេចក្ដីថា កាលព្រះមានព្រះភាគទ្រង់មិនទាន់បានបញ្ញត្តសិក្ខាបទ ភិក្ខុនីឈ្មោះឧប្បលវណ្ណា ដើរចូលទៅក្នុងព្រៃអន្ធវន ។

បទថា **កតកម្មា** បានដល់ អ្នកធ្វើចោរកម្ម មានពាក្យអធិប្បាយថា ប្លន់ភណ្ឌៈរបស់អ្នកដទៃ ដោយកម្ម មានការកាត់ទីតជាដើម ។

បទថា **ចោរគាមណិកោ** បានដល់ មេចោរ ។ បានឮថា មេចោរនោះ ស្គាល់ព្រះថេរីមកអំពីមុន ព្រោះដូច្នោះហើយ កាលទៅខាងមុខរបស់ពួកចោរ ឃើញព្រះថេរីនោះ ទើបពោលថា ពួកឯងកុំទៅផ្លូវនោះ ចូរមកផ្លូវនេះទាំងអស់ ដូច្នេះហើយ នាំពួកចោរទាំងនោះទៅផ្លូវដទៃ ។

ពីរបទថា **សមាធិម្ហា វុដ្ឋហិត្វា** សេចក្ដីថា បានឮថា ព្រះថេរីចេញអំពីសមាធិក្នុងវេលាដែលកំណត់ទុកនោះឯង ។ សូម្បីមេចោរនោះ បានពោលយ៉ាងនោះក្នុងខណៈនោះដូចគ្នា ព្រោះដូច្នោះ ទើបព្រះថេរីបានឮ ។ ឯព្រះថេរីកាលបានឮសំឡេងនោះ ទើបគិតថា ឥឡូវនេះ ក្នុងទីនេះ មិនមាន

សមណៈ ឬព្រាហ្មណ៍ដទៃក្រៅអំពីអាត្មាអញឡើយ ទើបកាន់យកសាច់នោះ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យទាំងឡាយ ពោលថា **អថខោ ឧប្បលវណ្ណា ភិក្ខុនី** ដូច្នេះជាដើម ។

[ ៤៧ ] បទថា **ឧទាយិស្ស** បានដល់ គង់នៅ គឺនៅសល់ អធិប្បាយថា ដល់វារៈចូលវិហារ នៅក្នុងវិហារត្រឹមតែមួយរូប ។

សួរថា ព្រោះហេតុអ្វី ទើបឧទាយិភិក្ខុពោលថា បើនាងគប្បីឲ្យអន្តរវាសកដល់ខ្ញុំ ដូច្នេះ ឆ្លើយថា ឧទាយិភិក្ខុឃើញអន្តរវាសកសាច់ម៉ដ្ឋ និងរលោង ទើបពោល ព្រោះការចង់បាន ។ ម្យ៉ាងទៀត ការចង់បានក្នុងអន្តរវាសករបស់ឧទាយិភិក្ខុនោះ តិចតួចទេ តែកោដ្ឋាសសម្បត្តិរបស់ព្រះថេរីដល់ទីបំផុត ព្រោះហេតុនោះ ទើបឧទាយិភិក្ខុគិតថា អញនឹងមើលភាពពេញលេញនៃសរីរៈរបស់ព្រះថេរីនេះ ហើយញ៉ាំងការចង់បានក្នុងទីមិនស្មើឲ្យកើតឡើង ទើបពោលយ៉ាងនេះ ។

បទថា **អន្តិមំ** បានដល់ ចីវរជាផ្ទាំងចុងក្រោយគេបង្អស់នៃចីវរ ៥ ផ្ទាំង ឈ្មោះថា ផ្ទាំងចុងក្រោយ គឺផ្ទាំងក្រោយគេ ។ ចីវរផ្ទាំងដទៃដែលវិកប្ប ឬបច្ចុទ្ធរណៈ រក្សាទុកសូម្បីដោយលេសក៏មិនមាន ព្រោះដូច្នោះ ព្រះថេរីពោលយ៉ាងនេះ ដោយអំណាចនាងទ្រទ្រង់ចីវរ ៥ ផ្ទាំង តាមដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត មិនមែនដោយការលោភ ។ ពិតហើយ ការលោភរបស់ព្រះខីណាស្រពទាំងឡាយ រមែងមិនមាន ។

បទថា **និប្បីឡិយមានា** សេចក្តីថា នាងត្រូវឧទាយិភិក្ខុសម្តែងឧបមា

ហើយ ជំទាស់ធ្ងន់ពេក ។

បទថា **អន្តរវាសកំ ឧត្វា ឧបស្សយំ អគមាសិ** សេចក្តីថា ព្រះថេរី ស្លៀកសំពត់សម្រាប់ចងដោះ ហើយបានសម្តែង ( ចីវរ ) លើបាតដៃ ប៉ុណ្ណោះប្រគេន ដោយអាការដែលមនោរថរបស់ឧទាយិភិក្ខុ នឹងមិនបាន ពេញពេញ បានទៅហើយ ។ សួរថា ព្រោះហេតុអ្វី ទើបភិក្ខុនីទាំងឡាយ ពោលទោសពួកភិក្ខុអ្នកទទួលចីវរ ដែលមិនផ្លាស់ប្តូរគ្នា ឆ្លើយថា ព្រោះជា អ្នកត្រូវខ្វះខាតដៃ គឺបច្ច័យគ្រប់សព្វគ្រប់យ៉ាងនេះថា បើលោកម្ចាស់ទាំងឡាយ មិនមានការស្និទ្ធស្នាលក្នុងពួកយើងត្រឹមប៉ុណ្ណោះ ពួកយើងនឹងដំណើរជីវិតទៅ បានដូចម្តេច ។

[ ៤៨ ] បទថា **អនុជានាមិ ភិក្ខវេ ឥមេសំ បញ្ចន្នំ** សេចក្តីថា តថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរចីវរគ្នារបស់សហធម្មិក ៥ ពួកនេះ ដែលមាន សទ្ធាស្មើគ្នា មានសីលស្មើគ្នា មានទិដ្ឋិស្មើគ្នា ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃចីវរបដិគ្គហណសិក្ខាបទ

[ ៤៩ ] ពីរបទថា **បយោគេ ទុក្កដំ** សេចក្តីថា ត្រូវអាបត្តិទុក្កដ ព្រោះអាការ មានការលាដៃចេញដើម្បីបំណងនឹងទទួលជាដើម ។

បទថា **បដិលាភេន** បានដល់ ព្រោះទទួល ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការទទួលដូច្នេះថា ភិក្ខុនីចូរឲ្យត្រង់ដៃដោយដៃក្តី ដាក់ក្បែរជើងក្តី បោះទៅខាងលើក្តី បើភិក្ខុត្រេកអរ ចីវរ ឈ្មោះថា ភិក្ខុនោះ

ទទួលហើយនោះឯង ។ បើភិក្ខុទទួលយកចីវរដែលភិក្ខុនីផ្ញើទៅក្នុងដៃរបស់សិក្ខមានា សាមណេរ សាមណេរី ឧបាសក និងឧបាសិកាជាដើម មិនត្រូវអាបត្តិ ។ បរិស័ទទាំង ៤ នាំចីវរ និងសំពត់ពណ៌ផ្សេងៗ មកដាក់ទៀបជើងនៃភិក្ខុដែលពោលធម្មកថា ឬឈរក្នុងឧបចារៈ ឬលះឧបចារៈបោះឲ្យ ។ បណ្ដាសំពត់ទាំងនោះ ចីវរណាជារបស់ភិក្ខុនីទាំងឡាយ ត្រូវអាបត្តិដល់ភិក្ខុដែលទទួលចីវរនោះដូចគ្នា ក្រៅអំពីការផ្លាស់ប្ដូរគ្នា ។

លោកពោលទុកក្នុងមហាបច្ចរី និងកុរុន្ទីថា បើចីវរទាំងឡាយ គឺបរិស័ទ ៤ បោះទៅក្នុងពេលយប់ ភិក្ខុមិនអាចដឹងបានថា នេះរបស់ភិក្ខុនី នេះរបស់បុគ្គលដទៃ មិនមានកិច្ចដោយការផ្លាស់ប្ដូរ ។ ពាក្យដែលពោលទុកក្នុងមហាបច្ចរី និងកុរុន្ទីនោះ មិនសមគ្នា ព្រោះសិក្ខាបទជាអចិត្តកៈ ។ បើភិក្ខុនីប្រគេនសំពត់ជូតទឹកភ្លៀង គប្បីធ្វើឲ្យជារបស់ផ្លាស់ប្ដូរដូចគ្នា ។ បើភិក្ខុនីដាក់ត្រង់គំនរសំរាមជាដើម ដោយតាំងចិត្តថា សូមភិក្ខុទាំងឡាយកាន់យកជាសំពត់បង្សុកូល ដូច្នេះ ភិក្ខុអធិដ្ឋានជាសំពត់បង្សុកូល កាន់យកគួរ ។

# អធិប្បាយ

## បទភាជនីយនៃចីវរបដិគ្គហណសិក្ខាបទ

[ ៥០ ] បទថា **អញ្ញាតិកាយ អញ្ញាតិកសញ្ញី** គឺជាតិកបាចិត្តិយ ។

[ ៥១ ] ពីរបទថា **ឯកតោ ឧបសម្បន្នាយ** សេចក្ដីថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលទទួលអំពីដៃរបស់ភិក្ខុនី ដែលឧបសម្បទាក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ( តែមួយចំណែក ) តែត្រូវអាបត្តិបាចិត្តិយ ( ដល់ភិក្ខុ

ដែលទទួលអំពីដៃ ) របស់ភិក្ខុនីដែលឧបសម្បទា ក្នុងសម្នាក់នៃភិក្ខុទាំង-ឡាយ ។

[ ៥២ ] ពីរបទថា **បរិវត្តេន វា វិបុលំ** សេចក្ដីថា បើភិក្ខុទទួលត្រៃចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច ឬដោយបរិក្ខារដទៃ មានថង់ស្បែកជើង ស្ពាកបាត្រ សំពត់អង្សៈ និងវត្ថុពន្ធចង្កេះជាដើម មិនត្រូវអាបត្តិ ។ តែក្នុងមហាបច្ចរីពោលថា ដោយហោចសូម្បីដោយចំណិតសម៉ ។

ពីរបទថា **វិបុលេន វា បរិត្តំ** នេះ អ្នកសិក្សាគប្បីជ្រាបដោយការវិបល្លាស ( ផ្ទុយគ្នា ) ដូចដែលពោលហើយ ។

ពីរបទថា **អញ្ញំ បរិក្ខារំ** សេចក្ដីថា បរិក្ខារប្រភេទណាមួយ មានស្ពាកបាត្រជាដើម ។ តែសំពត់តម្រងទឹក មានទំហំប៉ុនចីវរយ៉ាងតូចដែលត្រូវវិកប្បមិនគួរ ។ ចីវរណាមិនល្មមនឹងអធិដ្ឋាន ឬវិកប្ប ចីវរនោះ គួរគ្រប់យ៉ាង ។ សូម្បីសំពត់ស្រោមពូក មានទំហំប៉ុនត្រៃក៏សមគួរដូចគ្នា នឹងពោលទៅថ្វីក្នុងស្ពាកបាត្រជាដើមនោះ បទដ៏សេសមានអត្ថពាក់ទាំងអស់ហើយ ។

បណ្ដាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយាផងអកិរិយាផង ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្មវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចីវរបដិគ្គហណសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[ ៥៣ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុឈ្មោះឧបនន្ទដ៏មានអាយុជាសក្យបុត្រ ជាអ្នកឈ្លាសវៃក្នុងការសម្តែងធម៌ ។ គ្រានោះ កូនសេដ្ឋីម្នាក់មាននាម និងគោត្រមិនប្រាកដ ចូលទៅឯកន្លែងដែលឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្រលោកគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រ ហើយអង្គុយក្នុងទីសមគួរ ។ ឧបនន្ទដ៏មានអាយុជាសក្យបុត្រ បានញ៉ាំងសេដ្ឋីបុត្រនោះ ដែលអង្គុយក្នុងទីសមគួរឲ្យឃើញច្បាស់ ឲ្យកាន់យកល្អ ឲ្យកើតសេចក្តីប្រឹងប្រែងឡើង ឲ្យរីករាយស្រួល ដោយធម្មីកថា ។ គ្រានោះ សេដ្ឋីបុត្រនោះ កាលបើព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកល្អ ឲ្យក្លាហានឡើងព្រម ឲ្យរីករាយស្រួលដោយធម្មីកថាហើយ ក៏បានបវារណាពាក្យនេះនឹងឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្រថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការដោយបច្ច័យណាដែលយើងខ្ញុំអាចប្រគេនដល់លោកម្ចាស់បាន ដូចជាចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យជាភេសជ្ជបរិក្ខារ លោកម្ចាស់ត្រូវប្រាប់បច្ច័យទាំងនោះមកចុះ ។ ព្រះឧបនន្ទថា នែអ្នកដ៏មានអាយុ បើអ្នកប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដក ១ អំពីពួកសាដកដែលអ្នកកំពុងប្រើអស់នេះចុះ ។ សេដ្ឋីបុត្រនិយាយថា ទានប្រោស យើងខ្ញុំជាកូនអ្នកមានត្រកូល និងមានតែសាដក ១ ដើរទៅហាក់ដូចជាមិនសម ( មុខគួរឲ្យអៀនខ្មាស ) ទានប្រោស សូមលោក

ម្ចាស់បង្អង់ចាំសិន ទម្រាំខ្ញុំទៅផ្ទះ ខ្ញុំទៅដល់ផ្ទះហើយ នឹងបញ្ជូននូវសាដក ១ អំពីពួកសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់ជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្រ បាននិយាយពាក្យនេះនឹងសេដ្ឋីបុត្រនោះអស់វារៈ ២ ដងថា នែអ្នកដ៏មានអាយុ បើអ្នកមានប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដក ១ អំពីពួកសាដកដែលអ្នកកំពុងប្រើអស់នេះចុះ ។ សេដ្ឋីបុត្រនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្រ មានតែសាដក ១ ដើរទៅហាក់ដូចជាមិនសម ( គួរឲ្យអៀនខ្មួនណាស់ ) ទានប្រោស លោកម្ចាស់ សូមបង្អង់ចាំសិន ទម្រាំខ្ញុំទៅផ្ទះ ខ្ញុំទៅដល់ផ្ទះហើយ នឹងបញ្ជូនសាដក ១ អំពីពួកសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់បើជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទ-ភិក្ខុដ៏មានអាយុជាសក្យបុត្រ បានពោលពាក្យនេះនឹងសេដ្ឋីបុត្រនោះអស់វារៈ ៣ ដងថា នែអ្នកដ៏មានអាយុ បើអ្នកចង់ប្រគេនអាត្មា ចូរអ្នកប្រគេនសាដក ១ អំពីសាដកអស់នេះចុះ ។ សេដ្ឋីបុត្រនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្រ មានសាដកតែ ១ ដើរទៅហាក់ដូចជាមិនសម ទានប្រោស លោកម្ចាស់ សូមបង្អង់ចាំសិន ទម្រាំខ្ញុំទៅផ្ទះ ខ្ញុំទៅដល់ផ្ទះហើយ នឹងបញ្ជូនសាដក ១ អំពីសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់បើជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទភិក្ខុនិយាយថា នែអ្នកដ៏មានអាយុ អាត្មាមានប្រយោជន៍អ្វី ដោយអ្នកដែលមិនចង់ប្រគេនសោះហើយបវារណា ( ព្រោះ ) អ្នកបវារណានូវបច្ច័យណា ហើយមិនឲ្យបច្ច័យនោះ ។

សេដ្ឋីបុត្រនោះ កាលដែលឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្របង្ខិតបង្ខំ ( ញយៗ ) ក៏ប្រគេនសំពត់សាដក ១ ហើយទៅក្នុងកាលនោះឯង ។ មនុស្សទាំងឡាយឃើញសេដ្ឋីបុត្រនោះហើយ បាននិយាយពាក្យនេះថា អ្នកម្ចាស់ ព្រោះហេតុអ្វីបានជាអ្នកមានសាដកតែ ១ ដើរមកដូច្នេះ ។ គ្រានោះ សេដ្ឋីបុត្របានប្រាប់ដំណើរនោះដល់មនុស្សទាំងឡាយនោះ ។ មនុស្សទាំងឡាយក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រនេះ មានប្រាថ្នាច្រើន ឥតមានសន្តោស សមណៈពួកនេះ គេមិនងាយនឹងនិមន្តដោយធម៌បានទេ កាលបើសេដ្ឋីបុត្រនិមន្តដោយធម៌ មិនសមបីបើនឹងទទួលយកសាដកសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងនោះលើកទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ជាអ្នកសន្តោស ។បេ។ ភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្រមិនសមបីបើនឹងសុំចីវរពីសេដ្ឋីបុត្រសោះ ។ ទើបភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលដំណើរនោះដល់ព្រះដ៏មានព្រះភាគ ។ ទ្រង់ត្រាស់សួរថា នែឧបនន្ទ ឮថា អ្នកសុំចីវរពីសេដ្ឋីបុត្រមែនឬ ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ គេត្រូវជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ គេមិនមែនជាញាតិទេ ។ ទ្រង់ត្រាស់ថា នែមោឃបុរស មនុស្សមិនមែនជាញាតិ មិនដឹងការគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អរបស់មនុស្សដែលមិនមែនជាញាតិនឹងគ្នា ( នោះ ) ទេ

នែមោឃបុរស មិនគួរបើអ្នកឯងសុំចីវរពីសេដ្ឋីបុត្រដែលមិនមែនជាញាតិ ( ដូច្នោះ ) សោះ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់មនុស្សដែលនៅមិនទាន់ជ្រះថ្លាទេ មិនមែននាំមនុស្សដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយសុំចីវរចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ ( ភិក្ខុនោះ ) ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[ ៥៤ ] សម័យនោះឯង ពួកភិក្ខុជាច្រើនចេញអំពីក្រុងសាកេត ដើរតាមផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី ។ ពួកចោរចេញមកដណ្តើម ( យកបាត្រនិងចីវរ ) របស់ភិក្ខុទាំងនោះក្នុងពាក់កណ្តាលផ្លូវ ។ លំដាប់នោះ ភិក្ខុអម្បាលនោះរង្កៀសក្នុងចិត្តថា ការសុំចីវរចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហើយមិនហ៊ានសុំចីវរ ក៏ដើរទាំងអាក្រាតជ្រាំង ទៅកាន់ក្រុងសាវត្ថី ហើយថ្វាយបង្គំភិក្ខុទាំងឡាយ ។ ភិក្ខុទាំង-ឡាយក៏ពោលពាក្យយ៉ាងនេះថា នែអាវុសោទាំងឡាយ អាជីវកអស់នេះល្អ ចេះសំពះភិក្ខុទាំងឡាយដែរ ។ ភិក្ខុអាក្រាតទាំងនោះនិយាយថា ម្នាលអាវុសោ យើងមិនមែនជាអាជីវកទេ យើងជាភិក្ខុដែរ ។ ពួកភិក្ខុក៏និយាយពាក្យនេះនឹងព្រះឧបាលិដ៏មានអាយុថា នែឧបាលិដ៏មានអាយុ និមន្តលោកសង្កេតសួរមនុស្សអាក្រាតអស់នេះមើល ។ ភិក្ខុអាក្រាតទាំងឡាយនោះ លុះព្រះឧបាលិដ៏មានអាយុសង្កេតសួរ ក៏បានប្រាប់ដំណើរទុំ៉ះ ( ដោយសព្វគ្រប់ ) ។ ព្រះឧបាលិដ៏មានអាយុ

លុះបានសង្កេតសួរភិក្ខុ ( អាក្រាត ) ទាំងនោះហើយ ក៏ពោលពាក្យនេះនឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងនេះជាភិក្ខុហើយ លោកទាំងឡាយចូរឲ្យចីវរដល់ភិក្ខុ ( អាក្រាត ) ទាំងនោះផងចុះ ។ ភិក្ខុទាំងឡាយណាដែលមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្ទុះបន្ទាប់ថា ភិក្ខុទាំងឡាយមិនសមបីបើនឹងមានខ្លួនអាក្រាតដើរមកសោះ គួរតែភិក្ខុទាំងនោះបិទបាំង ( រាងកាយ ) ដោយស្មៅ ឬស្លឹកឈើហើយ សឹមមកទៅអេះ ។ ទើបភិក្ខុទាំងឡាយនោះក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលចោរដណ្តើមយកចីវរទៅក្តី ដែលមានចីវរបាត់ក្តី សុំចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិបាន ភិក្ខុ ( ដែលមានចីវរអន្តរាយ ) នោះ ចូលដល់អាវាសណាមុន បើចីវរក្នុងវត្តក្តី សំពត់កម្រាលគ្រែក្តី សំពត់កម្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមានក្នុងអាវាសនោះ ឲ្យយកសំពត់នោះស្លៀកដណ្តប់ ដោយគិតថា អញបានសំពត់នោះ ( ស្លៀកដណ្តប់សិន ) ហើយនឹងទុកវិញ បើចីវរក្នុងវត្តក្តី សំពត់សម្រាប់ក្រាលគ្រែក្តី សំពត់សម្រាប់ក្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមិនមានទេ ភិក្ខុនោះ ត្រូវបិទបាំង ( រាងកាយ ) ដោយស្មៅ ឬស្លឹកឈើហើយសឹមមក មិនត្រូវដើរមកទាំងអាក្រាតឡើយ ភិក្ខុឯណាមក ( ទាំងអាក្រាត ) ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសម្តែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សុំចីវរចំពោះ

គហបតី ឬ គហបតានីដែលមិនមែនជាញាតិ ( ភិក្ខុនោះ ) ត្រូវនិស្សគ្គិយ-បាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ឬ ភិក្ខុមានចីវរខូច នេះជាសម័យក្នុងសិក្ខាបទនោះ ។

[ ៥៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ ( ត្រង់បទយព្យាលទាំង ២ មានអធិប្បាយដូចសេចក្តីក្នុងបឋមបារាជិកសិក្ខាបទ ) ។ ជនដែលឥតមានជាប់ទងគន្លងអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គួនៃជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ បុរសណាមួយ នៅគ្រប់គ្រងផ្ទះ (បុរសនោះ) ហៅថា គហបតី ( ប្រុសមេផ្ទះ ) ។ ស្រីណាមួយនៅគ្រប់គ្រងផ្ទះ ( ស្រីនោះ ) ហៅថា គហបតានី ( ស្រីមេផ្ទះ ) ។ ដែលហៅថា ចីវរ ( នោះ ) គឺបណ្តាចីវរទាំង ៦ យ៉ាង តាមតែចីវរណាមួយក៏ដោយ ដែលមានខ្នាតបើយ៉ាងតូចណាស់ត្រឹមល្មមវិកប្បបាន ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកនូវសម័យចេញ។ ចីវររបស់ភិក្ខុដែលស្តេចទាំងឡាយរឹបយកទៅក្តី ចោរទាំង-ឡាយដណ្តើមយកទៅក្តី អ្នកលេងទាំងឡាយដណ្តើមយកទៅក្តី អ្នកណាមួយដណ្តើមយកទៅក្តី ( ភិក្ខុនោះ ) ហៅថា មានចីវរគេដណ្តើមយកហើយ ។ ចីវររបស់ភិក្ខុដែលភ្លើងឆេះក្តី ដែលទឹកបន្សាត់ទៅក្តី ដែលកណ្តុរកាត់ ឬកណ្តៀរកេរកាត់ក្តី ដែលចាស់ព្រោះប្រើប្រាស់ក្តី ( ភិក្ខុនោះ ) ហៅថា មានចីវរខូចហើយ ។ ឥតមានសម័យទេ ភិក្ខុសុំ ( ចីវរ ) ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសុំ ចីវរ ( នោះ ) ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុ

ត្រូវលះចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរយ៉ាងនេះ ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះខ្ញុំសុំចំពោះគហបតីមិនមែនជាញាតិដោយឥតមានសម័យទេ ជានិស្សគ្គិយហើយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ ( ត្រង់បេយ្យាលទាំង ៣ មានអធិប្បាយក្នុងសិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ ) ។

[៥៦] គហបតីមិនមែនញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុដឹងច្បាស់ថា ជាញាតិ មិនមានអាបត្តិឡើយ ។

[៥៧] អាបត្តិមិនមានដល់ភិក្ខុកាលសុំចីវរក្នុងសម័យគួរ ក្នុងសម្នាក់ជនទាំងឡាយជាញាតិ ក្នុងសម្នាក់ជនទាំងឡាយដែលបវារណាហើយ សុំឲ្យអ្នកដទៃ ( ដូរ ) ដោយទ្រព្យខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

## សិក្ខាបទទី ៦ ចប់

# អដ្ឋកថា

# ចីវរវគ្គទី ១ សិក្ខាបទទី ៦

# អញ្ញាតកវិញ្ញត្តិសិក្ខាបទ

[ ៥៣ ] អញ្ញាតកវិញ្ញត្តិសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងអញ្ញាតកវិញ្ញត្តិសិក្ខាបទនោះ ដែលមានវិនិច្ឆ័យដូចតទៅនេះថា

ពីរបទថា **ឧបនន្ទោ សក្យបុត្តោ** បានដល់ បណ្ឌាភិក្ខុដែលបួសអំពីសក្យត្រកូលប្រមាណ ៨ ម៉ឺនអង្គ ព្រះឧបនន្ទសក្យបុត្រ ជាភិក្ខុថោកទាបមានជាតិឡេះឡោះ ។

បទថា **បដ្ឋោ** ជាអ្នកឈ្លាសប្រតិពល មុតស្រួច ដល់ព្រមដោយសំឡេង គឺប្រកបដោយភាពជាអ្នកមានបំពង់កពីរោះ ។

បទថា **កិស្មឹ វិយ** សេចក្តីថា ប្រៀបដូចអ្វី ប្រៀបដូចបុគ្គលមានការសៅហ្មង គឺដូចគ្នានឹងខ្មាចក្រែង ដូចគ្នានឹងតក់ស្លុត ដោយអំណាចហិរិ និងឱត្តប្បៈ ។

[ ៥៤ ] បទថា **អទ្ធានមគ្គំ** សេចក្តីថា ផ្លូវវែង ពោល គឺផ្លូវឆ្ងាយមិនមែនផ្លូវក្នុងក្រុង ។

បទថា **តេ ភិក្ខូ អច្ឆិន្ទឹសុ** សេចក្តីថា បានប្លន់ គឺបានដណ្តើមយកបាត្រ និងចីវរភិក្ខុទាំងនោះទៅ ។

បទថា **អនុយុញ្ជាហិ** សេចក្តីថា លោកមេត្តាសាកសួរ ដើម្បីការជ្រាបភាពជាភិក្ខុ ។

បទថា **អនុយុញ្ជិយមានា** សេចក្តីថា ភិក្ខុទាំងនោះ ត្រូវព្រះឧបាលីសាកសួរដល់បព្វជ្ជាឧបសម្បទា អធិដ្ឋានបាត្រ និងចីវរជាដើម ។

បទថា **ឯតមត្ថំ អារោចេសុំ** សេចក្តីថា ទូលឲ្យទ្រង់ជ្រាបថា ជាភិក្ខុហើយបានក្រាបទូលរឿងដែលភិក្ខុទាំងនោះពោល ដោយន័យជាដើមថា ជាអ្នកដើរផ្លូវឆ្ងាយអំពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី ។

ក្នុងបទថា **អញ្ញាតកំ គហបតឹ វា** ជាដើម អ្នកសិក្សាគប្បីជ្រាបអនុបុព្វីកថា ចាប់ពីពាក្យដែលត្រាស់ទុកខាងដើមថា បិទបាំងហើយដោយស្មៅឬដោយស្លឹកឈើជាដើម ដោយន័យដូចពោលតទៅនេះថា បើភិក្ខុកំលោះឃើញពួកចោរហើយ កាន់យកបាត្រ និងចីវរគេចទៅ ពួកចោរដណ្តើមយកត្រឹមតែស្បង់ និងចីវររបស់ព្រះថេរៈទាំងឡាយប៉ុណ្ណោះទៅ ព្រះថេរៈទាំង-ឡាយ ដំបូង មិនគួរឲ្យសុំចីវរនោះឯង មិនគួរនឹងកាច់មែកឈើ និងក្តិចស្លឹកឈើឡើយ ។ បើពួកភិក្ខុកំលោះចោលបង្វេចទ្រព្យទាំងអស់គេចទៅ ពួកចោរដណ្តើមយកស្បង់ និងចីវររបស់ព្រះថេរៈ និងបង្វេចទ្រព្យនោះទៅ ពួកភិក្ខុកំលោះមកហើយ មិនគួរឲ្យស្បង់ និងចីវររបស់ខ្លួនដល់ព្រះថេរៈទាំង-ឡាយជាមុនទេ ព្រោះថា ពួកភិក្ខុដែលមិនត្រូវចោរដណ្តើមយកចីវរទៅ រមែងមិនអាចនឹងកាច់មែកឈើ និងស្លឹកឈើ ដើម្បីប្រយោជន៍ដល់ខ្លួន តែរមែងបានក្នុងការកាច់ ដើម្បីប្រយោជន៍ដល់ពួកភិក្ខុដែលត្រូវចោរដណ្តើមចីវរយកទៅ ។ ហើយពួកភិក្ខុដែលត្រូវចោរដណ្តើមយកចីវរទៅ រមែងបានក្នុងការកាច់ដើម្បីប្រយោជន៍ដល់ខ្លួនផង និងដល់អ្នកដទៃផង ព្រោះដូច្នោះ ព្រះថេរៈ

ទាំងឡាយ គប្បីកាច់មែកឈើ និងស្លឹកឈើ យកព្រោលជាដើមចងទាក់ ហើយគប្បីឲ្យដល់ពួកភិក្ខុកំលោះ ឬពួកភិក្ខុកំលោះ កាច់ដើម្បីប្រយោជន៍ ដល់ព្រះថេរៈទាំងឡាយ ចងហើយ ឲ្យដល់ព្រះថេរៈទាំងនោះដល់ដៃ ឬមិនឲ្យ ស្លៀកឯង ហើយឲ្យស្បង់ និងចីវររបស់ខ្លួនដល់ព្រះថេរៈទាំងឡាយ ។ មិនត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើភូតគាមឲ្យវិនាសឡើយ ។ មិនត្រូវអាបត្តិទុក្កដ ព្រោះទ្រទ្រង់សំពត់ទង់ជ័យរបស់ពួកតិរ្ថិយនោះ ។

បើក្នុងរវាងផ្លូវ មានលានរបស់ពួកជាងជ្រលក់ ឬប្រទះឃើញជនពួកដទៃ ដែលមានសភាពដូច្នោះ គប្បីឲ្យសូមចីវរ ។ ហើយពួកអ្នកស្រុកដែលត្រូវសូមទាំងនោះ ឬអ្នកស្រុកពួកដទៃ ឃើញភិក្ខុស្លៀកមែកឈើ និងស្លឹកឈើ ហើយកើតការឧស្សាហ៍ ប្រគេនសំពត់ទាំងឡាយណាដល់ភិក្ខុទាំងនោះ ។ សំពត់ទាំងនោះ ទោះមានជាយ ឬមិនមានជាយក្តី មានពណ៌ផ្សេងៗ ដូចជាពណ៌ខៀវជាដើមក្តី ជាកប្បិយក្តី អកប្បិយទាំងអស់ក្តី ភិក្ខុទាំងនោះ គួរស្លៀក និងគួរដណ្តប់បានទាំងអស់ ព្រោះពួកលោកតាំងនៅក្នុងឋានៈដែលត្រូវចោរដណ្តើមចីវរ ។ ពិតហើយ សូម្បីក្នុងគម្ពីរបរិវារក៏ពោលពាក្យនេះថា

> សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្ប ទាំងមិនបានជ្រលក់ដោយទឹកជ្រលក់ ភិក្ខុស្លៀកពាក់សំពត់នោះហើយ ដើរទៅដោយគួរតាមសេចក្តីប្រាថ្នា ភិក្ខុនោះមិនត្រូវអាបត្តិ ទាំងធម៌នោះសោតក៏ព្រះសុគតទ្រង់សម្តែងហើយ ប្រស្នានេះ ពួកលោកអ្នក

ឈ្មោសវៃ បានគិតមកហើយ ។

ពិតហើយ ប្រស្នានេះ លោកពោលសំដៅដល់ភិក្ខុ ដែលត្រូវចោរដណ្តើមចីវរ ។ បើភិក្ខុទាំងឡាយ សមាគមជាមួយនឹងពួកតិរ្ថិយ ហើយពួកតិរ្ថិយទាំងនោះប្រគេនចីវរដែលក្រងដោយស្បូវក្លាំង ក្រងដោយសម្បកឈើនិងក្រងដោយផ្លែឈើ សូម្បីសំពត់ទាំងនោះ ក៏គួរដល់ភិក្ខុស្លៀកដណ្តប់បានមិនទទួលយកលទ្ធិ គឺសូម្បីស្លៀកដណ្តប់ហើយ ក៏មិនគប្បីកាន់លទ្ធិ ( របស់តិរ្ថិយ ) ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ក្នុងពាក្យថា ភិក្ខុដើរទៅដល់វត្តណាមុន បើចីវរសម្រាប់វិហារ ឬរបស់សង្ឃក្នុងវត្តនោះមានជាដើម ឈ្មោះថា ចីវរសម្រាប់វិហារ គឺចីវរដែលពួកអ្នកស្រុកធ្វើវត្ត ហើយរៀបចំចីវរទុកដោយពោលថា បច្ច័យ ៤ ជារបស់ផ្ទាល់ខ្លួនរបស់ពួកខ្ញុំប៉ុណ្ណោះ ចូរមានដល់ការប្រើប្រាស់ ហើយតាំងទុកក្នុងវត្តដែលខ្លួនធ្វើ ចីវរនេះ ឈ្មោះថា ចីវរសម្រាប់វិហារ ។

គ្រឿងកម្រាលលើគ្រែ លោកហៅថា គ្រឿងកម្រាលខាងលើ ។

គ្រឿងកម្រាលដែលធ្វើដោយចម្រៀកសំពត់តូចៗ ដើម្បីរក្សាផ្ទៃដីដែលធ្វើបរិកម្ម លោកហៅថា សំពត់ក្រាលដី ។ ភិក្ខុទាំងឡាយក្រាលកន្ទេលលើគ្រឿងកម្រាលនោះ ហើយដើរចង្ក្រម ។

ស្រោមពូកសម្រាប់ក្រាលគ្រែ ឬតាំង ឈ្មោះថា ស្រោមពូក បើស្រោមពូក គេញាត់ពេញ ទោះរើចេញ ហើយកាន់យកក៏គួរ ។ បណ្តាចីវរ

សម្រាប់វិហារជាដើមនេះ ដូចពោលមកយ៉ាងនេះ ចីវរដែលមានក្នុងវត្តនោះ ពួកភិក្ខុដែលត្រូវចោរដណ្តើមយកទៅ សូម្បីមិនសុំអនុញ្ញាត ទោះកាន់យកស្លៀក ឬដណ្តប់ក៏បាន ។ ឯការស្លៀក ឬការដណ្តប់នោះ រមែងបានដោយបំណងថា អាត្មាអញបាន ( ស្បង់ ឬចីវរហើយ ) នឹងទុកវិញ គឺនឹងរក្សាទុកដូចដើម រមែងមិនបានដោយការដាច់មូលតម្លៃ ( គឺកាន់យកជាកម្មសិទ្ធិផ្ទាល់ខ្លួន ) ។ កាលបាន ( ស្បង់ ឬចីវរ ) អំពីញាតិក្តី អំពីឧបដ្ឋាកក្តី សូម្បីអំពីទីកន្លែងណាមួយដទៃក្តី ហើយគប្បីធ្វើឲ្យត្រឡប់ជាប្រក្រតីដើមនោះឯង ។ ភិក្ខុទៅកាន់ទីកដីដទៃហើយ គប្បីទុកដាក់ក្នុងអាវាសរបស់សង្ឃមួយកន្លែង ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ ដោយការប្រើប្រាស់ជារបស់សង្ឃ ។ បើចីវរសម្រាប់វិហារនោះទ្រុឌទ្រោម ឬបាត់បង់ទៅ ដោយការប្រើប្រាស់របស់ភិក្ខុនោះ មិនជាភណ្ឌទេយ្យឡើយ បើភិក្ខុមិនបានសំពត់ណាមួយបណ្តាសំពត់ទាំងនេះ មានសំពត់របស់គ្រហស្ថជាដើម មានស្រោមពូកជាទីបំផុត មានប្រការដូចពោលហើយ ភិក្ខុគប្បីយកស្មៅ ឬស្លឹកឈើបិទបាំងហើយមកចុះ ដូច្នេះឯង ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃអញ្ញាតកវិញ្ញត្តិសិក្ខាបទ

[ ៥៥ ] ចីវរ សូម្បីអាចារ្យ និងឧបជ្ឈាយ៍ ត្រូវចោរដណ្តើមយកទៅ សូមជនដទៃថា នាំចីវរមកចុះ អាវុសោ ហើយកាន់យកទៅ ឬកាន់យកទៅដោយវិស្សាសៈ រមែងគួរដើម្បីនឹងពោលថា ដល់នូវការសង្គ្រោះបុគ្គលនោះ

ក្នុងពាក្យថា **កេហិចិ វា អច្ឆិន្នំ** (ត្រូវបុគ្គលណាមួយដណ្តើមយកទៅក្តី) នេះ។

ម្យ៉ាងទៀត សូម្បីចីវរដែលពួកនិស្សិតបិទបាំងដោយស្មៅ និងស្លឹកឈើដោយខ្លួនឯង ហើយប្រគេនដល់ភិក្ខុ មានអាចារ្យ និងឧបជ្ឈាយ៍ជាដើម បុគ្គលត្រូវចោរដណ្តើមចីវរ រមែងគួរដើម្បីនឹងពោលថា ដល់នូវការសង្គ្រោះបុគ្គលនោះ ក្នុងពាក្យថា **បរិភោគជិណ្ណំ វា** ( ប្រើប្រាស់ចាស់ទៅក្តី ) នេះពិតហើយ កាលមានអត្ថដែលគួរពោលយ៉ាងនោះ ភិក្ខុទាំងនោះ នឹងជាអ្នកតាំងនៅក្នុងឋានៈជាអ្នកត្រូវចោរដណ្តើមចីវរ និងក្នុងឋានៈជាអ្នកមានចីវរបាត់ពិត ព្រោះដូច្នោះ អនាបត្តិព្រោះវិញ្ញត្តិ និងព្រោះបរិភោគអកប្បិយចីវរ ជារបស់សមគួរដល់ភិក្ខុទាំងនោះឯង ។

## អនាបត្តិនៃអញ្ញាតកវិញ្ញត្តិសិក្ខាបទ

[ ៥៧ ] ក្នុងពាក្យថា **ញាតកានំ បវារិតានំ** នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា មិនត្រូវអាបត្តិដល់ភិក្ខុដែលហាមាត់សុំ គឺ ដែលប្រាប់ញាតិ ឬ បុគ្គលបវារណាថា ពួកអ្នកចូរឲ្យរបស់ខ្លួនដល់ភិក្ខុទាំងនេះពិតហើយ មិនមានអាបត្តិ ឬ អនាបត្តិដល់ភិក្ខុទាំងឡាយ ដែលពួកញាតិបវារណាហើយ ។

ក្នុងពាក្យថា **អត្តនោ ធនេន** នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា មិនត្រូវអាបត្តិដល់ភិក្ខុដែលហាមាត់សុំ គឺ ជាអ្នកប្រើឲ្យចាយ ឬប្រើឲ្យដោះដូរ ដោយកប្បិយភណ្ឌរបស់ខ្លួន ដោយកប្បិយវោហារប៉ុណ្ណោះ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **បវារិតានំ** នេះ មានវិនិច្ឆ័យដូច្នេះថា ក្នុង

បច្ច័យទាំងឡាយដែលគេបវារណាទុក ដោយអំណាចនៃសង្ឃ គួរសូមតែល្មមប្រមាណប៉ុណ្ណោះ ។ ក្នុងការបវារណាចំពោះបុគ្គល គួរសុំតែចំពោះទ្រព្យដែលគេបវារណាដូចគ្នា ។ ពិតហើយ បុគ្គលណាបវារណាដោយចតុប្បច្ច័យកំណត់ទុកឯង ហើយប្រគេនទ្រព្យដែលត្រូវការ ដោយអាការយ៉ាងនេះ គឺ រមែងប្រគេនចីវរ តាមសមគួរដល់កាល រមែងប្រគេនអាហារមានបបរ និងបាយជាដើមរាល់ៗថ្ងៃ កិច្ចដែលត្រូវប្រើវាចាសូមបុគ្គលដូច្នោះមិនមាន ។ ឯបុគ្គលណាបវារណាហើយ រមែងមិនឲ្យ ព្រោះជាអ្នកល្ងង់ខ្លៅ ឬ ព្រោះជាអ្នកភ្លេចភ្លាំង បុគ្គលនោះក៏ភិក្ខុគួរសុំ ។ បុគ្គលពោលថា ខ្ញុំបវារណាផ្ទះរបស់ខ្ញុំ ភិក្ខុគប្បីទៅកាន់ផ្ទះរបស់បុគ្គលនោះហើយ គប្បីអង្គុយ គប្បីដេក តាមសប្បាយ មិនគប្បីទទួលយកអ្វីៗឡើយ ។ ឯបុគ្គលណាពោលថា ខ្ញុំសូមបវារណាទ្រព្យដែលមាននៅក្នុងផ្ទះរបស់ខ្ញុំ ដូច្នេះ គប្បីសុំទ្រព្យដែលជាកប្បិយ ដែលមាននៅក្នុងផ្ទះរបស់បុគ្គលនោះ ។ ក្នុងកុរុន្ទីពោលថា តែភិក្ខុនឹងអង្គុយក្តី ដេកក្តី ក្នុងផ្ទះមិនបាន ។

ក្នុងបទថា **អញ្ញស្សត្ថាយ** នេះ មានអត្ថទី ១ ដូច្នេះថា មិនត្រូវអាបត្តិដល់ភិក្ខុដែលសុំអំពីញាតិ និងបុគ្គលបវារណារបស់ខ្លួន ដើម្បីប្រយោជន៍ដល់ខ្លួនឯងតែម្យ៉ាងក៏ទេ ដោយពិតនោះ សូមដើម្បីប្រយោជន៍ដល់ភិក្ខុដទៃក៏មិនត្រូវអាបត្តិ ។

ចំណែកអត្ថបែបទី ២ ក្នុងបទថា **អញ្ញស្ស** នេះ ដូចតទៅនេះថា មិនត្រូវអាបត្តិដល់ភិក្ខុ ដែលហាមាត់សុំអំពីញាតិ និងអ្នកបវារណារបស់ភិក្ខុ

ដទៃ ដើម្បីប្រយោជន៍ដល់ភិក្ខុនោះឯង គឺពុទ្ធរក្ខិតៈដែលបានពោលហារថា អ្នកដទៃ ។ ពាក្យដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។

បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អញ្ញាតកវិញ្ញត្តិសិក្ខាបទទី ៦ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ៥៨ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ( ភិក្ខុមានពួក ៦ ) ចូលទៅរកភិក្ខុដែលមានចីវរចោរដណ្តើមយកទៅ ហើយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតដល់ភិក្ខុ មានចីវរដែលចោរដណ្តើមយកទៅក្តី ដែលមានចីវរវិនាសទៅក្តី ឲ្យសុំចីវរនឹង គហបតី ឬនឹងគហបតានី ដែលមិនមែនជាញាតិបាន ម្នាលអាវុសោ អ្នកទាំង-ឡាយចូរសុំចីវរទៅ ។ ពួកភិក្ខុដែលចោរដណ្តើមយកចីវរនោះឆ្លើយថា ណ្ហើយ អាវុសោ យើងបានចីវរហើយ ។ ពួកឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ យើងនឹងសុំឲ្យលោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាល អាវុសោ អ្នកទាំងឡាយ ចូរសុំចុះ ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុចូលទៅរកពួក គហបតីដែលមិនមែនជាញាតិ ហើយបានពោលពាក្យនេះថា ម្នាលអាវុសោ ភិក្ខុទាំងឡាយដែលមានចីវរចោរដណ្តើមយកទៅ ឥឡូវនេះលោកនិមន្តមក អ្នក ទាំងឡាយ ចូរប្រគេនចីវរដល់លោកទាំងនោះផងចុះ ហើយក៏សុំចីវរមានចំនួន ច្រើន ។ ក៏ក្នុងសម័យនោះឯង មានបុរសម្នាក់អង្គុយក្នុងរោងសម្រាប់ប្រជុំ បាន ពោលពាក្យនេះនឹងបុរសម្នាក់ថា លោកម្ចាស់ទាំងឡាយ ដែលមានចីវរចោរ ដណ្តើមយកទៅ ឥឡូវលោកនិមន្តមក ខ្ញុំបានប្រគេនចីវរដល់លោកម្ចាស់ទាំង នោះហើយ ។ បុរសនោះឯងពោលយ៉ាងនេះថា ខ្ញុំក៏បានប្រគេនចីវរដែរ ។ បុរសឯទៀតនិយាយយ៉ាងនេះថា ខ្ញុំក៏បានប្រគេនដែរ ។ ជនទាំងឡាយអម្បាល

នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនសមបើនឹងមិនដឹងប្រមាណហើយសុំចីវរមានចំនួនច្រើន ( យ៉ាងនេះសោះ) ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រនឹងធ្វើជំនួញសំពត់ឬថានឹងតាំងរានផ្សារលក់សំពត់ ( ទេដឹង ) ។ ពួកភិក្ខុបានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានប្រាថ្នាតិច ជាអ្នកសន្តោស ។បេ។ ភិក្ខុអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមបើនឹងមិនដឹងប្រមាណ ហើយសុំចីវរមានចំនួនច្រើន ( យ៉ាងនេះ ) សោះ ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនោះដល់ព្រះដ៏មាន-ព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយមិនដឹងប្រមាណ ហើយសុំចីវរមានចំនួនច្រើន មែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងមិនដឹងប្រមាណសុំចីវរមានចំនួនច្រើន នែមោឃបុរសទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាហើយ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា បើគហបតីក្តី គហបតានីក្តី បវារណាដល់ភិក្ខុនោះដើម្បីឲ្យកាន់យកតាមត្រូវការដោយចីវរដ៏ច្រើន ភិក្ខុនោះគប្បីត្រេកអរចំពោះចីវរនោះ តែត្រឹមអន្តរវាសក និងឧត្តរាសង្គ បើភិក្ខុត្រេកអរឲ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៥៩ ] ត្រង់ពាក្យថា ដល់ភិក្ខុនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ជនដែលមិនជាប់អំពីចំណែកមាតាក្តី អំពីចំណែកបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនញាតិ ។ មនុស្សប្រុសណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សប្រុសនោះហៅថា គហបតី ។ មនុស្សស្រីណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សស្រីនោះ ហៅថា គហបតានី ។ ពាក្យថា ចីវរច្រើន គឺចីវរមានប្រមាណច្រើន ។ ពាក្យថា នាំមកបវារណា គឺគ្រហស្ថពោលថា លោកម្ចាស់ត្រូវការចីវរប៉ុន្មាន ចូរទទួលយកប៉ុណ្ណោះចុះ ។ ពាក្យថា ភិក្ខុនោះគប្បីត្រេកអរនឹងចីវរចំពោះចីវរដែលគេនាំមកនោះ កំណត់ត្រឹមអន្តរវាសក និងឧត្តរាសង្គ គឺថា បើចីវរទាំង ៣ វិនាសទៅហើយ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរ ២ ( បើ ) ចីវរ ២ វិនាសទៅ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរ ១ ( បើ ) ចីវរវិនាសទៅតែ ១ ភិក្ខុកុំគប្បីត្រេកអរ ( នឹងចីវរឯទៀត ) ឡើយ ។ ពាក្យថា បើភិក្ខុត្រេកអរឲ្យលើសជាងកំណត់នោះ គឺភិក្ខុសុំចីវរលើសជាងកំណត់នោះ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសុំ ។ ចីវរដែលបានមកជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំសូមពីគហបតីមិនមែនជាញាតិឲ្យលើសពីកំណត់នោះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។បេ។ គប្បីឲ្យ ។បេ។ គប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៦០ ] គហបតីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយសុំចីវរឲ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតី

មិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសុំចីវរឲ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ ហើយសុំចីវរឲ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ មិនត្រូវអាបត្តិ ។

[ ៦១ ] អាបត្តិមិនមានដល់ភិក្ខុដែលនាំចីវរទៅដោយគិតថា អញនឹងនាំចីវរដែលសល់មក ដល់ភិក្ខុដែលទាយកប្រគេនដោយពាក្យថា ចីវរដែលសល់ចូរមានដល់លោកចុះ ដល់ភិក្ខុដែលទាយកប្រគេនដោយឥតមានហេតុ គឺចោរដណ្តើមយកចីវរ ដល់ភិក្ខុដែលទាយកប្រគេនដោយឥតមានហេតុ គឺចីវរបាត់ ដល់ភិក្ខុត្រេកអរនឹងចីវររបស់ញាតិទាំងឡាយ ដល់ភិក្ខុដែលត្រេកអរនឹងចីវរ របស់ជនដែលគេបវារណាឲ្យ ដល់ភិក្ខុត្រេកអរនឹងចីវរដែលបានដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទី ៧ ចប់

# អដ្ឋកថា

# ចីវរវគ្គទី ១ សិក្ខាបទទី ៧

# តទុត្តរិសិក្ខាបទ

[ ៥៨ ] *តទុត្តរិសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងតទុត្តរិសិក្ខាបទនោះ ដែលមានវិនិច្ឆ័យដូច្នេះថា*

# អធិប្បាយ

# សិក្ខាបទវិភង្គនៃតទុត្តរិសិក្ខាបទ

[ ៥៩ ] *សព្ទថា* **អភិ** *ក្នុងបទថា* **អភិហដ្ឋុំ** *ជាឧបសគ្គ មានអត្ថថា ដើម្បីនាំទៅ មានពាក្យអធិប្បាយថា ដើម្បីកាន់យក ។*

*បទថា* **បវារេយ្យ** *សេចក្តីថា គប្បីឲ្យប្រាថ្នា គឺឲ្យកើតសេចក្តីប្រាថ្នា សេចក្តីពេញចិត្ត អធិប្បាយថា គប្បីប្រាប់ គឺគប្បីនិមន្ត ។ ដើម្បីសម្តែងអាការដែលអ្នកបវារណា ដើម្បីឲ្យនាំទៅ និងគប្បីពោល ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា* **អភិហដ្ឋុំ** *យ៉ាងនេះថា លោកម្ចាស់ត្រូវការចីវរប៉ុនណា ក៏សូមទទួលយកទៅប៉ុណ្ណោះចុះ ។ ម្យ៉ាងទៀត ក្នុងបាទគាថានេះ បទថា* **ទេក្ខម្មំ ឧដ្ឋុខមតោ** *មានអត្ថថា* **ទិស្វា** *( ឃើញហើយ ) យ៉ាងណា ពីរបទថា* **អភិហដ្ឋុំ បវារេយ្យ** *ក្នុងសិក្ខាបទនេះ ក៏មានអត្ថថា បុគ្គលនោះនាំមក ហើយបវារណា ដូច្នោះ ។*

*ការនាំមកក្នុងបទថា* **អភិហារិត្វា** *នោះ មាន ២ យ៉ាង គឺការនាំមកដោយកាយ ១ ការនាំមកដោយវាចា ១ ។ បុរសម្ចាស់ផ្ទះក្តី ស្ត្រីម្ចាស់ផ្ទះក្តី*

ដែលមិនមែនញាតិនាំសំពត់ទាំងឡាយមកដោយកាយ ហើយដាក់ត្រង់ទីទៀបជើង គប្បីបវារណាថា លោកម្ចាស់ត្រូវការចីវរប៉ុនណា ក៏សូមទទួលយកទៅប៉ុណ្ណោះចុះ ។ម្យ៉ាងទៀត គប្បីពោលបវារណា ដោយវាចាថា ឃ្លាំងសំពត់របស់ពួកខ្ញុំពេញបរិបូណ៌ លោកម្ចាស់ត្រូវការចីវរប៉ុនណា ក៏សូមយកទៅប៉ុណ្ណោះចុះ ។ ក៏ព្រោះសរុបការនាំមកទាំងពីរនោះ ចូលជាមួយគ្នា ទ្រង់ត្រាស់ហៅថា បវារណាដើម្បីនាំទៅ ។

បទថា **សន្តរុត្តរបរមំ** មានវិគ្គហៈថា សំពត់ឧត្តរាសង្គ និងអន្តរវាសកយ៉ាងក្រៃលែងនៃចីវរនោះ ហេតុនោះ ទើបចីវរនោះ ឈ្មោះថា មានឧត្តរាសង្គ និងអន្តរវាសកយ៉ាងក្រៃលែង ។ មានពាក្យអធិប្បាយថា សំពត់ដណ្តប់ និងសំពត់ស្លៀក កំណត់យ៉ាងខ្ពស់នៃចីវរនោះ ។

ច្រើនបទថា **តតោ ចីវរំ សាទិតព្វំ** សេចក្តីថា ភិក្ខុគប្បីកាន់យកចីវរ មានប្រមាណប៉ុណ្ណោះ អំពីចីវរដែលគហបតីក្តី គហបតានីក្តី ដែលមិនមែនញាតិនាំមកឲ្យនោះ អធិប្បាយថា មិនគួរទទួលច្រើនជាងនេះ ។ ព្រោះថា ភិក្ខុដែលមានត្រឹមតែត្រៃចីវរប៉ុណ្ណោះ ត្រូវចោរដណ្តើមយកចីវរទៅអស់ គួរបដិបត្តិយ៉ាងនេះ ភិក្ខុដទៃគួរបដិបត្តិតាមបែបដទៃ ដូច្នោះ ដើម្បីសម្តែងវិភាគនោះ ទើបព្រះមានព្រះភាគ ត្រាស់បទភាជនៈនៃបទថា **តតោ ចីវរំ សាទិតព្វំ** នោះ ដោយន័យថា **សចេ តីណិ នដ្ឋានិ ហោន្តិ** ជាដើម ។

វិនិច្ឆ័យក្នុងបទថា **សចេ តីណិ នដ្ឋានិ** ជាដើមនោះ មានដូចតទៅនេះថា បើភិក្ខុណាមានចីវរវិនាស ៣ ផ្ទាំង ភិក្ខុនោះ គប្បីត្រេកអរត្រឹម ២

ផ្ទាំង គឺស្បៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ហើយស្បែងរកមួយផ្ទាំងទៀតអំពីទីនៃភិក្ខុដែលជាសភាគគ្នា ។ ភិក្ខុណាមានចីវរបាត់ ២ ផ្ទាំង ភិក្ខុនោះគប្បីត្រេកអរត្រឹមតែមួយផ្ទាំង ។ បើភិក្ខុត្រាច់ទៅដោយប្រក្រតី ដោយឧត្តរាសង្គ និងអន្តរវាសក គប្បីត្រេកអរត្រឹមតែ ២ ផ្ទាំង ។ កាលត្រេកអរដូច្នោះ នឹងជាបុគ្គលស្មើជាមួយភិក្ខុដែលត្រេកអរក្នុងសំពត់មួយផ្ទាំងនោះឯង ។ បាត់ ១ ផ្ទាំង មិនគប្បីត្រេកអរ ។ ភិក្ខុណាមានចីវរបាត់ទៅមួយផ្ទាំង ក្នុងបណ្តាចីវរ ៣ ផ្ទាំង ភិក្ខុនោះ មិនគួរត្រេកអរ ។ តែបណ្តាចីវរ ២ ផ្ទាំង របស់ភិក្ខុណាបាត់មួយផ្ទាំងទៅ ភិក្ខុគប្បីត្រេកកអរបានតែមួយផ្ទាំង ។ តែរបស់ភិក្ខុណាមានមួយផ្ទាំងប៉ុណ្ណោះ ហើយចីវរមួយផ្ទាំងនោះបាត់ ភិក្ខុនោះ គប្បីត្រេកអរ ២ ផ្ទាំង ។ តែសម្រាប់ភិក្ខុនេះ កាលបាត់ទៅទាំង ៥ ផ្ទាំង គប្បីត្រេកអរ ២ ផ្ទាំង ។ កាលបាត់ ៤ ផ្ទាំង គប្បីត្រេកអរមួយផ្ទាំង ។ កាលបាត់ ៣ ផ្ទាំង មិនគប្បីត្រេកអរក្នុងអ្វីឡើយ ។ ក្នុងចីវរដែលបាត់ទៅ ២ ផ្ទាំងក្តី ១ ផ្ទាំងក្តី នឹងបាច់ពោលទៅថ្វី ពិតហើយ ភិក្ខុណាមួយ គប្បីតាំងនៅក្នុងភាពជាអ្នកមានឧត្តរាសង្គ និងអន្តរវាសកយ៉ាងក្រៃលែង ។ ក្រៃលែងជាងនោះទៅរមែងមិនបាន ពាក្យដូចពោលមកនេះ ជាលក្ខណៈក្នុងសេចក្តីនេះ ។

[ ៦១ ] ពីរបទថា **សេសកំ អាហរិស្សាមិ** សេចក្តីថា ខ្ញុំនឹងធ្វើចីវរ ២ ផ្ទាំង ហើយនឹងនាំសំពត់ដ៏សេសមកសងវិញ ។

បទថា **ន អច្ឆិន្នការណា** សេចក្តីថា ពួកទាយកប្រគេនដោយអំណាចនៃគុណ មានភាពជាពហូសូតជាដើម ។

ក្នុងបទថា **ញាតកានំ** ជាដើម សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុ ដែលត្រេកអរក្នុងចីវររបស់ពួកញាតិប្រគេន ដែលត្រេកអរក្នុងរបស់ពួកជនបវារណាប្រគេន ដែលត្រេកអរដោយទ្រព្យរបស់ខ្លួន ។

ម្យ៉ាងទៀត ក្នុងអដ្ឋកថាទាំងឡាយ លោកពោលថាតាមប្រក្រតីនោះឯង ទោះសូមចីវរច្រើន ក្នុងទីនៃពួកញាតិ និងជនបវារណាក៏គួរ ព្រោះហេតុដែលត្រូវពួកចោរជាដើមដណ្តើមទៅ គួរនឹងសុំតែល្មមប្រមាណប៉ុណ្ណោះ ។ ពាក្យនោះ មិនសមដោយព្រះបាលី ព្រោះសិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់បញ្ញត្ត ព្រោះរឿងសូមដើម្បីប្រយោជន៍ដល់ភិក្ខុដទៃប៉ុណ្ណោះ ព្រោះដូច្នោះ ទើបក្នុងសិក្ខាបទនេះ ទ្រង់មិនត្រាស់ថា ដើម្បីប្រយោជន៍ដល់ភិក្ខុដទៃ ។ ពាក្យដ៏សេសមានអត្ថរាក់ទាំងអស់ហើយ ។

បណ្ឌាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះ ក៏មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

តទុត្តរិសិក្ខាបទទី ៧ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ៦២ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តព្រះជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះ បុរសម្នាក់បាន និយាយពាក្យនេះនឹងប្រពន្ធថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ ។ កាលដែលបុរសនោះ កំពុងនិយាយពាក្យយ៉ាងនេះ ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាត មួយអង្គបានឮ ( ពាក្យនោះច្បាស់ ) ។ ទើបភិក្ខុនោះចូលទៅរកព្រះឧបនន្ទដ៏ មានអាយុជាសក្យបុត្រ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងព្រះ ឧបនន្ទដ៏មានអាយុជាសក្យបុត្រថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នក មានបុណ្យច្រើន ( ព្រោះ ) ក្នុងឱកាសឯណោះ មានបុរសម្នាក់និយាយ ពាក្យនេះ នឹងប្រពន្ធថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បុរសនោះជាឧបដ្ឋាកខ្ញុំ ។ ព្រះឧប-នន្ទដ៏មានអាយុជាសក្យបុត្រ ចូលទៅរកបុរសនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ ឮថា អ្នកមាន ប្រាថ្នានឹងឲ្យអាត្មាស្លៀកដណ្តប់ចីវរមែនឬ ។ បុរសនោះនិយាយថា មែន លោកម្ចាស់ ខ្ញុំគិតយ៉ាងនេះថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ ចីវរ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកមានប្រាថ្នាឲ្យអាត្មាស្លៀក ដណ្តប់ចីវរ ចូរឲ្យអាត្មាស្លៀកដណ្តប់ចីវរបែបយ៉ាងនេះចុះ ( ព្រោះថា ) បើ អាត្មាមិនប្រើប្រាស់នូវចីវរណា អាត្មានឹងធ្វើខនឲ្យ ជាអ្នកស្លៀកដណ្តប់នូវចីវរ នោះដូចម្តេចបាន ។ ឯបុរសនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា

ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រអស់នេះ មានសេចក្តីប្រាថ្នាច្រើន មិនមានសន្តោស ពួកសមណៈអស់នេះ ទាយកមិនងាយនឹងឲ្យស្លៀកដណ្តប់ចីវរទេ មិនសមបើលោកម្ចាស់ឧបនន្ទ ដែលអញមិនទាន់បវារណាមុន ហើយមកកំណត់ចីវរ ( យ៉ាងនេះ ) ឡើយ ។ ភិក្ខុទាំងឡាយបានឮពាក្យបុរសនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុទាំងឡាយណាមានប្រាថ្នាតិច ជាអ្នកសន្តោស ។បេ។ ភិក្ខុអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្រ គេមិនទាន់បវារណាមុន ហើយចូលទៅរកគហបតី ហើយកំណត់ចីវរ ( យ៉ាងនេះ ) ទេ ។ គ្រានោះ ភិក្ខុអម្បាលនោះក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯង គេមិនបានបវារណាមុន ហើយចូលទៅរកគហបតី ហើយកំណត់ចីវរមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ម្នាលឧបនន្ទ គ្រហស្ថនោះ ជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ ។ បពិត្រព្រះដ៏មានព្រះភាគ គ្រហស្ថនោះមិនមែនជាញាតិទេ ។ ទ្រង់ត្រាស់ថា ម្នាលមោឃបុរស ជនមិនមែនជាញាតិរមែងមិនដឹងការសមគួរក្តី មិនសមគួរក្តី ការល្អិតល្អក្តី មិនល្អិតល្អក្តី របស់ជនដែលមិនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯង ដែលគេមិនបានបវារណាមុន ហើយចូលទៅរកគហបតីមិនមែនជាញាតិ ហើយកំណត់ចីវរដូចម្តេចបាន ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យកើតសេចក្តី ជ្រះថ្លាដល់ជនទាំង-ឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើត សេចក្តីជ្រះថ្លាដល់

ជនទាំងឡាយដែលជ្រះថ្លាហើយទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា តម្លៃចីវរដែលគហបតីក្តី គហបតានីក្តី មិនមែនជាញាតិចំពោះភិក្ខុហើយតាំងទុកថា ខ្ញុំនឹងទិញចីវរដោយតម្លៃចីវរនេះ ហើយនឹងឲ្យភិក្ខុឈ្មោះនេះស្លៀកដណ្តប់ចីវរ ។ បើភិក្ខុនោះ ដែលគេមិនបានបវារណាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ល្អហើយអ្នកដ៏មានអាយុ អ្នកចូរទិញចីវរមានបែបយ៉ាងនេះក្តីៗ ដោយតម្លៃចីវរនេះ ហើយឲ្យអាត្មា ស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៦៣ ] ត្រង់ពាក្យថា ចំពោះភិក្ខុ គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្លៀកដណ្តប់ចីវរ ។ ជនដែលមិនជាប់អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី ៧ ហៅថាមិនមែនជាញាតិ ។ បុរសណាមួយនៅគ្រប់គ្រងផ្ទះ បុរសនោះហៅថា គហបតី ។ ស្រីណាមួយនៅគ្រប់គ្រងផ្ទះ ស្រីនោះហៅថា គហបតានី ។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី កែវផលិកក្តី សំពត់ឫសក្លាតក្តី អម្បោះក្តី កប្បាសក្តី ហៅថា តម្លៃចីវរ ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺ ដោយតម្លៃចីវរដែលតាំងឡើងចំពោះ ។ ពាក្យថា ទិញ គឺប្តូរគ្នា ។ ពាក្យថា អញនឹងឲ្យស្លៀកដណ្តប់ គឺថា អញនឹងប្រគេន ។ ពាក្យថា បើភិក្ខុនោះ គឺតម្លៃចីវរដែលទាយកតម្កល់ទុកចំពោះភិក្ខុណា គឺភិក្ខុនោះឯង ។ ពាក្យថា គេមិនបានបវារណា គឺគេមិនទាន់និយាយមុនថា បពិត្រលោកដ៏ចម្រើន លោកត្រូវការ

ដោយចីវរដូចម្តេច ខ្ញុំនឹងទិញចីវរដូចម្តេចប្រគេនលោក ។ ពាក្យថា ចូលទៅ គឺទៅកាន់ផ្ទះ ( គេ ) ឬចូលទៅរកគេក្នុងទីណាមួយ ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី សាច់ជិតក្តី សាច់ម៉ដ្តក្តី ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺដោយតម្លៃចីវរដែលតាំងឡើងចំពោះ ។ ពាក្យថា បែបយ៉ាងនេះក្តីៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ដ្តក្តី ។ ពាក្យថា ទិញ គឺប្តូរគ្នា ។ ពាក្យថា ចូរឲ្យស្មៀកដណ្តប់ គឺចូរឲ្យ ។ ពាក្យថា ព្រោះអាស្រ័យចង់បានចីវរល្អ គឺជាអ្នកត្រូវការចីវរល្អ ជាអ្នកត្រូវការចីវរមានតម្លៃច្រើន ។ ទាយកទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ដ្តក្តី តាមសម្តីភិក្ខុនោះ ភិក្ខុនោះត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលប្រើ ចីវរនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរភិក្ខុត្រូវលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះគេមិនបានបវារណាមុន ខ្ញុំចូលទៅរកគហបតីមិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ ភិក្ខុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យចីវរដល់លោកដ៏មានអាយុ ។

[ ៦៤ ] គហបតីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុសម្គាល់ថា ជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា

មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ មិនត្រូវអាបត្តិ ។

[ ៦៥ ] អាបត្តិមិនមានដល់ភិក្ខុ ដែលកំណត់ចីវរក្នុងសម្នាក់ជនជាញាតិ ជនដែលបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរដើម្បីប្រយោជន៍ភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលទាយកមានប្រាថ្នានឹងទិញចីវរមានតម្លៃច្រើនប្រគេន ឲ្យទិញចីវរមានតម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា

## ចីវរវគ្គទី ១ សិក្ខាបទទី ៨

## បឋមឧបក្ខដសិក្ខាបទ

[ ៦២ ] *បឋមឧបក្ខដសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងបឋមឧបក្ខដសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា*

*ក្នុងបទថា* **អត្ថាវុសោ មំ សោ ឧបដ្ឋាកោ** *នេះ មានអត្ថយ៉ាងនេះថា លោកដ៏មានអាយុ បុរសដែលលោកនិយាយដល់ដែលមានសភាពបែបនេះនោះ ជាឧបដ្ឋាករបស់ខ្ញុំ មាន ។*

*បទថា* **អបិមយ្យា ឯវំ ហោតិ** *សេចក្ដីថា បពិត្រលោកម្ចាស់ ការពិត ខ្ញុំតាំងចិត្តទុកយ៉ាងនោះ ។ បាឋៈថា* **អបិមេយ្យា ឯវំ ហោតិ** *ប្រែថា បពិត្រលោកម្ចាស់ សូម្បីខ្ញុំក៏មានការគិតយ៉ាងនេះ ដូច្នេះក៏មាន ។*

# អធិប្បាយ

## សិក្ខាបទវិភង្គនៃបឋមឧបក្ខដសិក្ខាបទ

[ ៦៣ ] *បទថា* **ឧទ្ទិស្ស** *ដែលមាននៅក្នុងបទថា* **ភិក្ខុំ បនេវ ឧទ្ទិស្ស** *នេះ មានអត្ថថា អាងដល់ គឺប្រារព្ធដល់ ។ ព្រោះទ្រព្យសម្រាប់តម្លៃចីវរដែលគហបតីក្ដី គហបតានីម្ចាស់ផ្ទះក្ដី ត្រៀមរៀបចំទុកចំពោះភិក្ខុណា រាប់ថាជាការដែលបុគ្គលនោះត្រៀមរៀបចំហើយ ដើម្បីប្រយោជន៍ដល់ភិក្ខុនោះ ដូច្នោះ ក្នុងបទភាជនៈនៃបទថា* **ភិក្ខុំ បនេវ ឧទ្ទិស្ស** *នោះ ទើបព្រះឧបាលីពោលថា ដើម្បីប្រយោជន៍ដល់ភិក្ខុ ។*

បទថា **ភិក្ខុំ អារម្មណំ ករិត្វា** បានដល់ ធ្វើភិក្ខុឲ្យជាបច្ច័យ ។ ពិតហើយ ទ្រព្យតម្លៃចីវរដែលគហបតីក្តី គហបតានីក្តី ត្រៀមរៀបចំទុកចំពោះភិក្ខុណា រមែងឈ្មោះថា ត្រូវបានបុគ្គលធ្វើភិក្ខុនោះឲ្យជាបច្ច័យ បម្រុងទុកដោយពិតប្រាកដនោះឯង ព្រោះហេតុនោះ ទើបពោលថា ធ្វើភិក្ខុឲ្យជាអារម្មណ៍ ។ សេចក្តីពិត សូម្បីបច្ច័យក៏មកហើយដោយឈ្មោះថា អារម្មណ៍ ក្នុងបទថា **លភតិ មារោ អារម្មណំ** ប្រែថា មាររមែងបានបច្ច័យ ដូច្នេះជាដើម ។

ឥឡូវនេះ ដើម្បីសម្តែងអាការរបស់កត្តា ( អ្នកធ្វើ ) ក្នុងបទថា **ឧទ្ទិស្ស** នេះ ទើបព្រះមានព្រះភាគត្រាស់ថា បំណាងនឹងឲ្យភិក្ខុស្លៀកដណ្តប់ ។ ពិតហើយ គហបតីដែលបំណាងឲ្យភិក្ខុស្លៀកដណ្តប់នោះ និងបម្រុងទុកចំពោះភិក្ខុនោះ មិនមែន ( បម្រុងទុក ) ព្រោះហេតុដទៃឡើយ ព្រោះហេតុនោះ ទើបគហបតីនោះ ឈ្មោះថា ជាអ្នកបំណាងនឹងឲ្យគ្រង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ដែលបំណាងឲ្យភិក្ខុស្លៀកដណ្តប់ ។

ពីរបទថា **អញ្ញាតកស្ស គហបតិស្ស វា** មានអត្ថថា ដែលគហបតីមិនមែនជាញាតិក្តី ។ ពិតហើយ ពាក្យនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ តែក្នុងបទភាជនៈ ព្រះមានព្រះភាគដើម្បីនឹងមិនពិចារណាព្យញ្ជនៈ សម្តែងអត្ថតែម្យ៉ាង ទើបត្រាស់បទជាដើមថា **អញ្ញាតកោ ឆាម ។បេ។ គហបតិ ឆាម** ដូច្នេះ ។

បទថា **ចីវរចេតាបន្នំ** ប្រែថា មូលតម្លៃនៃចីវរ ។ ក៏ព្រោះមូលតម្លៃ

នៃចីវរនោះ រមែងជារបស់ណានីមួយ ក្នុងបណ្តាទ្រព្យ មានប្រាក់ជាដើម ដូច្នោះ ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគត្រាស់បទថា **ហិរញ្ញំ វា** ជាដើម ។

ពីរបទថា **ឧបក្ខដំ ហោតិ** បានដល់ ជាទ្រព្យដែលគេមានបម្រុង គឺរួបរួមទុក ។ ក៏ព្រោះបទថា **ហិរញ្ញំ វា** ជាដើមនេះ គឺព្រះមានព្រះភាគទ្រង់សំដែងមូលតម្លៃចីវរនោះ ជារបស់គហបតីនោះ មានបំណងទុកហើយ ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់មិនលើកបទ **ឧបក្ខដំ ឆាម** ឡើង ហើយត្រាស់បទភាជនៈចែកទុកដោយឡែក ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកទ្រព្យដែលគេបម្រុងទុក ទើបត្រាស់ថា **ឥមិនា** ជាដើម ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទថា **ឥមិនា** នោះ ទើបត្រាស់ថា **បច្ចុបដ្ឋិតេន** ប្រែថា ដោយទ្រព្យដែលគេឧទ្ទិសចំពោះ ។ ពិតហើយ មូលតម្លៃនៃចីវរ ដែលគហបតីបម្រុងទុក គឺរួបរួមទុកហើយ ឈ្មោះថា ជាទ្រព្យដែលគេមានបំណងចំពោះដូច្នេះឯង ។

បទថា **អច្ឆាទេស្សាមិ** ជាសំនួនវោហារ ។ តែអត្ថក្នុងបទថា **អច្ឆាទេស្សាមិ** នេះ ដូច្នេះថា ខ្ញុំនឹងឲ្យដល់ភិក្ខុមានឈ្មោះនេះ ។ ព្រោះហេតុនោះឯង សូម្បីក្នុងបទភាជនៈនៃបទថា **អច្ឆាទេស្សាមិ** នោះ ទើបទ្រង់ត្រាស់ថា **ទស្សាមិ** ប្រែថា ខ្ញុំនឹងឲ្យ ។

ក្នុងបទថា **តត្រ ចេ សោ ភិក្ខុ** នេះ មានការភ្ជាប់បទយ៉ាងនេះថា បើភិក្ខុនោះ បុគ្គលមិនបានបវារណាទុកមុន ចូលទៅរកហើយ ដល់នូវការ

កំណត់ក្នុងចីវរ ក្នុងសម្នាក់របស់គហបតី ឬគហបតានីនោះ ។

បណ្តាបទទាំងនោះ កាលអត្ថនៃបទថា **ឧបសង្កមិត្វា** ប្រែថា ចូលទៅទៅរកហើយនេះ សម្រេចដោយបទថា **គន្ត្វា** ប្រែថា ទៅហើយនេះឯង ទើបព្រះមានព្រះភាគត្រាស់ថា កាន់ផ្ទះ ដូច្នេះ ដោយអំណាចវោហារខាងច្រើន ។ អត្ថក្នុងបទថា **គន្ត្វា** នេះ យ៉ាងនេះថា ទាយកនោះនៅក្នុងទីណា ទៅហើយក្នុងទីនោះ ។ ព្រោះដូច្នោះ ទើបត្រាស់ដដែលទៀតថា ចូលទៅរកហើយក្នុងទីណាមួយ ។

ពីរបទថា **វិកប្បំ អាបជ្ជេយ្យ** សេចក្តីថា ដល់នូវការកំណត់ពិសេសក្រៃលែង គឺ ចាត់ចែងយ៉ាងក្រៃលែង ។ តែក្នុងបទភាជនៈដើម្បីសម្តែងហេតុ ជាគ្រឿងឲ្យដល់ការកំណត់ប៉ុណ្ណោះ ទើបត្រាស់ថា **អាយតំ វា** ជាដើម ។

សព្ទថា **សាធុ** ជានិបាត ចុះក្នុងការអង្វរ ។

សព្ទថា **វត** ជានិបាត ប្រព្រឹត្តទៅក្នុងការរំពឹង ។

ភិក្ខុរមែងអាងខ្លួនឯង ដោយបទថា **មំ** ( អាត្មា ) ។

រមែងស្រែក គឺរមែងហៅអ្នកដទៃថា **អាយស្មា** ( អ្នក ) ។

ពាក្យទាំងអស់នេះ ត្រឹមតែជាព្យញ្ជនៈ មានអត្ថងាយយល់ទាំងអស់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ មិនត្រាស់អធិប្បាយទុកក្នុងបទភាជនៈនៃបទថា **សាធុ** ជាដើមនោះ ។

ពីរបទថា **កល្យាណកម្យតំ ឧបាទាយ** សេចក្តីថា កាន់យកភាពជា

បុគ្គលចង់បានក្នុងចីវរដែលល្អ គឺភាពជាអ្នកប្រាថ្នាចីវរដែលវិសេសក្រៃលែង ដោយចិត្ត ។ បទថា **ឧបាទាយ** នោះ ភ្ជាប់គ្នានឹងបទថា **អាបជ្ជេយ្យ ចេ** នេះ ។ ម្យ៉ាងទៀត ព្រោះហេតុដែលភិក្ខុណាកាន់យកភាពជាអ្នកចង់បានក្នុងចីវរល្អ រមែងដល់នូវការកំណត់ ភិក្ខុនោះ រមែងជាបុគ្គលមានសេចក្តីត្រូវការចីវរល្អ គឺមានសេចក្តីត្រូវការដោយចីវរដែលមានតម្លៃច្រើន ដូច្នោះ ក្នុងបទភាជនៈនៃបទថា **កល្យាណកម្យតំ ឧបាទាយ** នោះ ទើបទ្រង់លះព្យញ្ជនៈចោល ត្រាស់ពាក្យនោះប៉ុណ្ណោះ ដើម្បីសម្តែងចំពោះអត្ថដែលត្រូវការ ។ តែព្រោះអាបត្តិមិនទាន់ដល់ទីបំផុត ដោយហេតុត្រឹមតែការដល់នូវការកំណត់ចីវរនោះប៉ុណ្ណោះឡើយ ដូច្នោះ ទើបត្រាស់បទថា **តស្ស វចនេន** ប្រែថា តាមពាក្យរបស់ភិក្ខុនោះជាដើម ។

## អនាបត្តិនៃបឋមឧបក្ខដសិក្ខាបទ

[ ៦៥ ] ក្នុងបទថា **អនាបត្តិ ញាតកានំ** ជាដើម អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា មិនត្រូវអាបត្តិដល់ភិក្ខុដែលដល់នូវការកំណត់ក្នុងចីវររបស់ពួកញាតិ ។

បទថា **មហគ្ឃំ ចេតាបេតុកាមស្ស អប្បគ្ឃំ ចេតាបេតិ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលពោលដល់គហបតី ដែលប្រាថ្នានឹងឲ្យតម្លៃចីវរ មានតម្លៃ ២០ បាទថា កុំឡើយ ដោយចីវរមានតម្លៃ ២០ បាទ នេះដល់អាត្មា ចូរឲ្យចីវរមានតម្លៃ ១០ បាទ ឬ ៨ បាទចុះ ។

បទថា **អប្បគ្ឃំ** នេះ ត្រាស់ទុកដើម្បីរាំងតម្លៃដែលច្រើនពេកនោះ

ឯង ។ តែសូម្បីក្នុងចីវរដែលស្មើគ្នា ( មានតម្លៃប៉ុនគ្នា ) ក៏មិនត្រូវអាបត្តិ ។ ឯចីវរនោះស្មើគ្នាដោយអំណាចនៃតម្លៃប៉ុណ្ណោះ មិនមែនដោយអំណាចប្រមាណ ( ទំហំ ) ។ ពិតហើយ សិក្ខាបទនេះ មានការឲ្យបន្ថែមតម្លៃ ព្រោះដូច្នោះ សូម្បីនិយាយនឹងគហបតីដែលប្រាថ្នានឹងឲ្យតម្លៃអន្តរវាសក មានតម្លៃ ២០ បាទ ថា ចូរឲ្យចីវរមានតម្លៃត្រឹមប៉ុណ្ណេះ ដូច្នេះក៏គួរ ។ ពាក្យដ៏សេសមានអត្ថ ងាយយល់ទាំងអស់ហើយ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងតទុត្តិយសិក្ខាបទនោះឯង ។

ឧបក្ខដសិក្ខាបទទី ៨ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ៦៦ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះឯង បុរសម្នាក់ បាននិយាយពាក្យនេះនឹងបុរសម្នាក់ថា ខ្ញុំនឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ ចីវរ ។ ឯបុរសនោះបានពោលយ៉ាងនេះថា ខ្ញុំឯងក៏នឹងឲ្យព្រះឧបនន្ទជាម្ចាស់ ស្លៀកដណ្តប់ចីវរដែរ ។ ភិក្ខុមួយរូបជាអ្នកប្រព្រឹត្តបិណ្ឌបាត បានឮពាក្យចរចា គ្នានៃបុរសទាំងឡាយនោះ ។ ភិក្ខុនោះ ក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជា សក្យបុត្រ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មាន អាយុជាសក្យបុត្រថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យច្រើន ( ព្រោះ ) ក្នុងឱកាសឯណោះមានបុរសម្នាក់បាននិយាយពាក្យនេះនឹងបុរស ម្នាក់ថា ខ្ញុំនឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរ ។ ឯបុរសនោះក៏និយាយ យ៉ាងនេះថា ខ្ញុំឯងក៏នឹងឲ្យព្រះឧបនន្ទជាម្ចាស់ ស្លៀកដណ្តប់ចីវរដែរ ។ ព្រះឧបនន្ទ បាននិយាយថា ម្នាលអាវុសោ បុរសទាំងនោះជាឧបដ្ឋាករបស់ខ្ញុំ ។ លំដាប់ នោះ ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រចូលទៅរកបុរសទាំងនោះ លុះចូល ទៅដល់ហើយ បាននិយាយពាក្យនេះនឹងបុរសទាំងនោះថា ម្នាលអាវុសោ ឮថា អ្នកទាំងឡាយ ចង់ឲ្យអាត្មាស្លៀកដណ្តប់ចីវរមែនឬ ។ បុរសទាំងនោះឆ្លើយថា មែនលោកម្ចាស់ យើងទាំងឡាយបានគិតយ៉ាងនេះថា យើងខ្ញុំនឹងឲ្យព្រះឧបនន្ទ ជាម្ចាស់ ស្លៀកដណ្តប់ចីវរទាំងឡាយ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកទាំងឡាយ ចង់ឲ្យអាត្មាស្លៀកដណ្តប់ចីវរទាំងឡាយ អ្នកទាំងឡាយ ចូរ

ឲ្យអាត្មាស្លៀកដណ្តប់ដោយចីវរបែបយ៉ាងនេះចុះ បើអាត្មាមិនត្រូវប្រើប្រាស់ចីវរទាំងឡាយណា អាត្មានឹងស្លៀកដណ្តប់នូវចីវរទាំងឡាយនោះ ដូចម្តេចបាន ។ គ្រានោះ បុរសទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំង-ឡាយ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រនេះមានប្រាថ្នាច្រើន មិនមានសន្តោស សមណៈទាំងនេះ គេមិនងាយនឹងប្រគេនចីវរទេ មិនសមបីបើព្រះឧបនន្ទជាម្ចាស់ ដែលយើងទាំងឡាយមិនបានបវារណាជាមុន ហើយចូលមកកំណត់ចីវរសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យបុរសទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្រ ដែលគេឥតបានបវារណាមុន ហើយចូលទៅរកគហបតី ហើយកំណត់ចីវរសោះ ។ ភិក្ខុទាំងនោះក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងគេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតី កំណត់ចីវរមែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ម្នាលឧបនន្ទ ជនទាំងឡាយនោះជាញាតិ ឬមិនមែនជាញាតិទេ ។ បពិត្រព្រះដ៏មានព្រះភាគ ជនទាំងនោះមិនមែនជាញាតិទេ ។ ម្នាលមោឃបុរស ជនដែលមិនមែនជាញាតិ រមែងមិនដឹងការសមគួរ ឬមិនសមគួរ ការល្អិតល្អ ឬមិនល្អិតល្អរបស់ជនទាំងឡាយមិនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯងគេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតីមិនមែនជាញាតិ កំណត់ចីវរ ដូចម្តេចបាន ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់

ជនទាំងឡាយមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា តម្លៃចីវរផ្សេងគ្នាដែលគហបតីក្ដី គហបតានីក្ដី មិនមែនជាញាតិទាំង ២ នាក់ចំពោះភិក្ខុ ១ រូប ហើយតម្កល់ទុកថា យើងទាំងឡាយនឹងទិញចីវរទាំងឡាយ ១ ម្នាក់ ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះ ហើយនឹងឲ្យភិក្ខុឈ្មោះនេះស្លៀកដណ្ដប់ចីវរទាំងឡាយ ។ បើភិក្ខុនោះគេមិនបានបវារណាជាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្ដីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ស្រួលហើយ អ្នកដ៏មានអាយុទាំងឡាយ នាក់ទាំងពីរ ចូររួបរួមជាមួយគ្នា ទិញចីវរបែបយ៉ាងនេះផងៗ ដោយតម្លៃចីវរ ម្ចាស់ផ្សេងគ្នាទាំងនេះ ហើយឲ្យអាត្មាស្លៀកដណ្ដប់ចុះ ភិក្ខុនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៦៧ ] ត្រង់ពាក្យថា ចំពោះភិក្ខុមួយរូប គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្លៀកដណ្ដប់ ។ ពាក្យថា ទាំង ២ នាក់ គឺជនទាំង ២ ។ ជនទាំងឡាយមិនបានជាប់អំពីចំណែកខាងមាតាក្ដី អំពីចំណែកខាងបិតាក្ដី ដរាបដល់គូនៃជីដូនជីតាទី ៧ ហៅថា មិនមែនញាតិ ។ ប្រុសទាំងឡាយឯណាមួយនៅគ្រប់គ្រងផ្ទះ ប្រុសទាំងនោះ ហៅថា គហបតី ។ ស្រីទាំងឡាយឯណាមួយ នៅគ្រប់គ្រងផ្ទះ ស្រីទាំងនោះ ហៅថា គហបតានី ។ ប្រាក់ក្ដី មាសក្ដី កែវមណីក្ដី កែវមុក្ដាក្ដី កែវមរកត ឬកែវពព្រុស ពេជ្រក្អែកថ្នាក្ដី កែវផលិកក្ដី សំពត់ ឬ សក្លាតក្ដី អម្បោះក្ដី កប្បាសក្ដី ហៅថា តម្លៃចីវរ ។

ពាក្យថា ដោយតម្លៃចីវរទាំងឡាយនេះ គឺដោយតម្លៃចីវរដែលតម្កល់ក្នុងទីចំពោះមុខ ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា នឹងឲ្យស្លៀកដណ្តប់ គឺនឹងឲ្យ ។ ពាក្យថា បើភិក្ខុនោះ គឺតម្លៃចីវរដែលទាយកចំពោះភិក្ខុរូបណា ហើយតម្កល់ទុក គឺភិក្ខុរូបនោះឯង ។ ពាក្យថា គេមិនបានបវារណាមុន គឺទាយកមិនបាននិយាយមុនថា ទានប្រោស លោកម្ចាស់ត្រូវការចីវរបែបដូចម្តេច ។ យើងទាំងឡាយនឹងទិញចីវរបែបដូចម្តេចប្រគេនលោកម្ចាស់ ។ ពាក្យថា ចូលទៅ គឺទៅកាន់ផ្ទះ ឬចូលទៅរកគេក្នុងទីណាមួយ ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ដ្តក្តី ។ ពាក្យថា ដោយតម្លៃចីវរទាំងនេះ គឺ តម្លៃចីវរទាំងឡាយ ដែលតម្កល់ក្នុងទីចំពោះមុខ ។ ពាក្យថា បែបយ៉ាងនេះផងៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ដ្តក្តី ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា ចូរឲ្យស្លៀកដណ្តប់ គឺចូរប្រគល់ឲ្យ ។ ពាក្យថា អ្នកទាំង ២ ចូររួបរួមជាមួយគ្នា គឺអ្នកទាំង ២ ចូររួបរួមគ្នា ។ ពាក្យថា ព្រោះអាស្រ័យសេចក្តីចង់បាន ចីវរល្អ គឺភិក្ខុមានសេចក្តីត្រូវការដោយចីវរស្អាត ត្រូវការដោយចីវរមានតម្លៃច្រើន ។ ទាយកទាំងឡាយទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ល្អិតក្តី តាមពាក្យភិក្ខុនោះ ភិក្ខុនោះ ត្រូវទុក្កដក្នុងប្រយោគដែលប្រើចីវរនោះ ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុត្រូវលះយ៉ាងនេះ ។បេ។ បពិត្រ ព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះគេមិនបានបវារណាជាមុន ខ្ញុំចូលទៅរកគហបតី មិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។បេ។ សង្ឃ

គប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៦៨ ] គហបតីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតីទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតីទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ គេមិនបានបវារណាមុន ហើយចូលទៅរកគហបតីទាំងឡាយ កំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ មិនជាអាបត្តិ ។

[ ៦៩ ] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរក្នុងសម្នាក់ជនជាញាតិទាំងឡាយ ដល់ភិក្ខុដែលជនបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលញុំាងទាយកមានប្រាថ្នាទិញចីវរមានតម្លៃច្រើន ឲ្យទិញចីវរមានតម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា

## ចីវរវគ្គទី ១ សិក្ខាបទទី ៩

## ទុតិយឧបក្ខដសិក្ខាបទ

*បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងទុតិយឧបក្ខដសិក្ខាបទដោយន័យនេះឯង ។ ព្រោះថា សិក្ខាបទដំបូងនោះ ដូចគ្នានឹងអនុប្បញ្ញត្តិនៃសិក្ខាបទទី ២ នេះថា ក្នុងសិក្ខាបទមុន ភិក្ខុគ្រាន់តែធ្វើការបៀតបៀនដល់មនុស្សម្នាក់ប៉ុណ្ណោះ ក្នុងសិក្ខាបទទី ២ ធ្វើដល់មនុស្សពីរនាក់ ។ នេះជាការប្លែកគ្នាក្នុងសិក្ខាបទនេះ ពាក្យដ៏សេស ដូចគ្នានឹងសិក្ខាបទមុននោះឯង ។ អ្នកសិក្សាគប្បីជ្រាបថា ត្រូវអាបត្តិដល់ភិក្ខុ ដែលធ្វើការបៀតបៀនដល់មនុស្សច្រើននាក់កាន់យក ដូចធ្វើដល់មនុស្សពីរនាក់កាន់យក ដូច្នោះ ។*

*ពណ៌នាទុតិយឧបក្ខដសិក្ខាបទទី ៩ ចប់*

# វិនយបិដក

## សិក្ខាបទទី ១០

[ ៧០ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង អាមាត្យធំជាឧបដ្ឋាករបស់ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រ បញ្ជូនតម្លៃចីវរទៅដោយបម្រើ ដើម្បីព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រដោយពាក្យថា អ្នកចូរទិញចីវរដោយតម្លៃចីវរនេះ ហើយចូរឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរចុះ ។ ឯបម្រើនោះក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្រថា បពិត្រលោក-ម្ចាស់ដ៏ចម្រើន តម្លៃចីវរនេះខ្ញុំនាំមកចំពោះលោកដ៏មានអាយុ សូមលោកដ៏មានអាយុទទួលយកតម្លៃចីវរ (នេះ) ចុះ ។ កាលបើបម្រើនោះនិយាយយ៉ាងនេះហើយ ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ បានពោលពាក្យនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរដ៏សមគួរដោយកាលគួរ ។ កាលបើព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ពោលយ៉ាងនេះហើយ បម្រើនោះបានពោលពាក្យនេះនឹងព្រះឧបនន្ទសក្យបុត្រដ៏មានអាយុថា អ្នកណាមួយជាវេយ្យាវច្ចករ[១] របស់លោកដ៏មានអាយុ មានដែរឬ ។ សម័យនោះ ឧបាសកម្នាក់បានទៅកាន់អារាម ដោយមានកិច្ចការនីមួយ ។ គ្រានោះព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ បានពោលពាក្យនេះនឹងបម្រើ នោះថា ម្នាលអាវុសោឧបាសកនេះឯងជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ ឯបម្រើនោះ

---

១-អ្នកទទួលធ្វើការខ្វល់ខ្វាយបម្រើ ។

ក៏ពន្យល់ឧបាសកនោះ ហើយចូលទៅរកព្រះឧបនន្ទ សក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទសក្យបុត្រដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន វេយ្យាវច្ចករដែលលោក ដ៏មានអាយុចង្អុលប្រាប់នោះ ខ្ញុំបានពន្យល់រួចហើយ សូមលោកដ៏មានអាយុ ចូលទៅរកគេចុះ វេយ្យាវច្ចករនោះ នឹងឲ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរ ដោយកាលដ៏គួរ ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ មិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកឡើយ ។ អមាត្យធំនោះ បញ្ជូនបម្រើទៅក្នុងសម្នាក់ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ អស់វារៈជាគម្រប់ ២ ដងថា លោកម្ចាស់ចូរប្រើចីវរនោះ យើងខ្ញុំចង់ឲ្យលោកម្ចាស់ប្រើប្រាស់ចីវរនោះ ។ ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ក៏មិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកនោះអស់វារៈ ២ ដង ។ មហាមាត្យនោះបញ្ជូនបម្រើទៅក្នុងសម្នាក់ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ អស់វារៈ ៣ ដងថា លោកម្ចាស់ចូរប្រើប្រាស់ចីវរនោះ យើងខ្ញុំចង់ឲ្យលោកម្ចាស់ ប្រើប្រាស់ចីវរនោះ ។ សម័យនោះឯង ជាសម័យនៃអ្នកនៅក្នុងនិគម ។ ក៏អ្នកនិគមបានធ្វើកតិកា ( ប្តេជ្ញា ) គ្នាថា អ្នកណាមកក្រោយគេ ត្រូវលក់អ្នកនោះ ៥០ កហាបណៈ ។ លំដាប់នោះ ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅរកឧបាសកនោះ លុះចូលទៅជិតហើយ បានពោលពាក្យនេះនឹងឧបាសកនោះថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ ឧបាសកនោះ តបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់សូមបង្អង់ថ្ងៃនេះមួយថ្ងៃសិន ( ព្រោះ ) ថ្ងៃនេះ ជាសម័យ ( ប្តេជ្ញាគ្នា ) នៃអ្នកនៅក្នុងនិគម អ្នកនិគមធ្វើប្តេជ្ញាគ្នាថា អ្នកណា មកក្រោយគេ ត្រូវលក់អ្នកនោះ ៥០ កហាបណៈ ។ ព្រះឧបនន្ទក៏

លុកចាប់ថ្នក់ថា ម្នាលអាវុសោ ចូរអ្នកឲ្យចីវរដល់អាត្មាក្នុងថ្ងៃនេះឯង ។ ឯឧបាសកដែលព្រះឧបនន្ទសក្យបុត្រដ៏មានអាយុជំរិតទារ ក៏ទិញចីវរប្រគេនឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយបានទៅដល់ ( និគមនោះ ) ជាខាងក្រោយគេ ។ មនុស្សទាំងឡាយបានពោលពាក្យនេះនឹងឧបាសកនោះថា អ្នកជាម្ចាស់ អ្នកមកក្នុងកាលជាខាងក្រោយគេព្រោះហេតុអ្វី យើងឈ្នះអ្នក ៥០ កហាបណៈហើយ ។ ទើបឧបាសកនោះប្រាប់ដំណើរនុ៎ះដល់មនុស្សទាំងអម្បាលនោះ ។មនុស្សទាំង-ឡាយ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រអម្បាលនេះ មានសេចក្ដីប្រាថ្នាធំ ឥតមានសន្ដោស មិនងាយអ្នកណានឹងធ្វើការខ្វល់ខ្វាយបម្រើ ដល់សមណៈអម្បាលនេះទេ ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ កាលបើឧបាសកពោលថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ចាំសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ ហើយ ។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ កាលបើឧបាសកនិយាយថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ឲ្យសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯង កាលឧបាសកពោលថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនព្រមបង្អង់ចាំមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាល

មោឃបុរស អ្នកឯងកាលដែលឧបាសកពោលថា លោកម្ចាស់ សូមលោកបន្អន់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនសមបើមិនបន្អន់ឲ្យគេទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ស្តេចក្តី រាជអមាត្យក្តី ព្រាហ្មណ៍ក្តី គហបតីក្តី បញ្ជូនតម្លៃចីវរទៅដោយបម្រើចំពោះភិក្ខុមួយរូបថា អ្នកឯងចូរទិញចីវរដោយតម្លៃចីវរនេះ ហើយចូរឲ្យភិក្ខុឈ្មោះនេះស្លៀកដណ្តប់ចីវរចុះ ។ បើបម្រើនោះចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា លោកម្ចាស់ តម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ លោកដ៏មានអាយុសូមទទួលយកតម្លៃចីវរចុះ ។ ភិក្ខុនោះត្រូវនិយាយពាក្យយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរ សមគួរដោយកាលដ៏គួរ ។ បើបម្រើនោះពោលនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយជាវេយ្យាវច្ចកររបស់លោកដ៏មានអាយុ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសកថា ម្នាលអាវុសោ អ្នកនេះឯងជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ បើបម្រើនោះពន្យល់វេយ្យាវច្ចករនោះហើយក៏ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុបង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបានពន្យល់ហើយ សូមលោកដ៏មានអាយុចូលទៅរក ( គេ ) ចុះ គេនឹងឲ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរដោយកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ

គប្បីចូលទៅតាំងទារ ដាស់តឿនវេយ្យាវច្ចករពីរបីលើកថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ កាលបើភិក្ខុទៅតាំងទារ ទៅដាស់តឿនអស់ពីរបីលើក ក៏ញុំាងចីវរនោះឲ្យសម្រេចបាន ការនេះជាការល្អ បើញុំាងចីវរនោះឲ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅឈរស្ងៀមចំពោះមុខ ៤ លើក ៥ លើក ៦ លើកយ៉ាងច្រើន កាលបើភិក្ខុឈរស្ងៀមនៅចំពោះមុខ ៤ លើក ៥ លើក ៦ លើកយ៉ាងច្រើន ញុំាងចីវរនោះឲ្យសម្រេចបាន នេះជាការល្អ បើធ្វើចីវរនោះឲ្យសម្រេចមិនបានទេ ហើយភិក្ខុនោះចេះតែព្យាយាមឲ្យលើសអំពីកំណត់នោះទាល់តែបានចីវរនោះមក ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ បើភិក្ខុញុំាងចីវរនោះឲ្យសម្រេចមិនបានទេ បម្រើនោះនាំតម្លៃចីវរមកដើម្បីភិក្ខុនោះអំពីសម្នាក់អ្នកណា ភិក្ខុគប្បីទៅខ្លួនឯង ឬប្រើបម្រើទៅក្នុងសម្នាក់អ្នកនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរណា ទៅចំពោះភិក្ខុរូបណា តម្លៃចីវរនោះមិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុរូបនោះទេ អ្នកដ៏មានអាយុ ចូរទារយករបស់ខ្លួនវិញចុះ ទ្រព្យរបស់អ្នកទាំងឡាយចូរកុំឲ្យវិនាស ការនេះជាសាមីចិកម្ម ( សេចក្ដីប្រព្រឹត្តគួរ ) ក្នុងសិក្ខាបទនោះ ។

[ ៧១ ] ត្រង់ពាក្យថា ចំពោះភិក្ខុមួយរូប សេចក្ដីថា ដើម្បីប្រយោជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្លៀកដណ្ដប់ចីវរ ។ អ្នកណាមួយសោយរាជសម្បត្តិ អ្នកនោះឈ្មោះថា ស្ដេច ។ អ្នកណាមួយគួរទទួលបាយ និងបៀវត្សរ៍របស់ស្ដេច អ្នកនោះឈ្មោះថា រាជអមាត្យ ។ ជនជាព្រាហ្មណ៍ដោយជាតិ ឈ្មោះថា ព្រាហ្មណ៍ ។ ដែលហៅថា គហបតី គឺជនដ៏សេស វៀរលែងស្ដេច រាជអមាត្យ និងព្រាហ្មណ៍ចេញ ហៅថា គហបតី ។

ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមកិតក្តី កែវផលិក ហៅថា ថ្លៃចីវរ ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺតម្លៃចីវរដែលគេតម្កល់ទុកចំពោះ ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា ឲ្យស្លៀកដណ្តប់ គឺឲ្យ ។ ថាបើបម្រើនោះចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា លោកម្ចាស់តម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ ។ លោកដ៏មានអាយុ ចូរទទួលយកតម្លៃចីវរចុះ ។ ភិក្ខុនោះគប្បីនិយាយយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ ។ បើបម្រើនោះនិយាយនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយជាវេយ្យាវច្ចកររបស់លោកដ៏មានអាយុ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសក ( ប្រាប់គេថា ) ម្នាលអាវុសោ បុគ្គលនេះឯង ជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ មិនគប្បីពោលនឹងបម្រើនោះថា អ្នកចូរឲ្យដល់បុគ្គលនោះក្តី ថាបុគ្គលនោះនឹងទុកដាក់ក្តី ថាបុគ្គលនោះនឹងដូរក្តី ថាបុគ្គលនោះនឹងទិញក្តី ។ បើបម្រើនោះពន្យល់វេយ្យាវច្ចករនោះ ហើយចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុ បង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះខ្ញុំបានពន្យល់ហើយ សូមលោកដ៏មានអាយុ ចូលទៅរក ( គេ ) ចុះ វេយ្យាវច្ចករនោះនឹងឲ្យលោកស្លៀកដណ្តប់ចីវរដោយកាលគួរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ ត្រូវចូលទៅរកវេយ្យាវច្ចករ ហើយដាស់តឿនរំលឹកពីរបីលើកថា ម្នាលអ្នកដ៏មានអាយុ អាត្មាត្រូវការចីវរ ។ មិនគប្បីនិយាយថា អ្នកចូរឲ្យចីវរដល់អាត្មា ចូរនាំចីវរមកឲ្យអាត្មា ចូរដូរចីវរឲ្យអាត្មា ចូរចាត់ចែងចីវរឲ្យអាត្មា ។ ភិក្ខុគប្បី

និយាយនឹងវេយ្យាវច្ចករនោះ អស់វារៈ ២ ដងផង គប្បីនិយាយអស់វារៈ ៣ ដងផង ។ បើភិក្ខុញ៉ាំងចីវរឲ្យសម្រេចបាន ការនេះជាការល្អ បើភិក្ខុនោះញ៉ាំងចីវរឲ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅក្នុងទីនោះ ហើយឈរស្ងៀមក្នុងទីចំពោះមុខ មិនគប្បីអង្គុយលើអាសនៈ មិនគប្បីទទួលអាមិស មិនគប្បីនិយាយធម៌ ។ កាលបើវេយ្យាវច្ចករនោះសួរថា លោកមកព្រោះហេតុអ្វី ភិក្ខុគប្បីនិយាយថា ម្នាលអ្នកដ៏មានអាយុ អ្នកចូរដឹងចុះ ។ ថាបើភិក្ខុអង្គុយលើអាសនៈក្តី ទទួលអាមិសក្តី និយាយធម៌ក្តី ឈ្មោះថា កាច់កិរិយាឈរ ។ ភិក្ខុគប្បីឈរអស់វារៈ ២ ដងផង គប្បីឈរអស់វារៈ ៣ ដងផង គប្បីទារ ៤ ដង ហើយឈរ ៤ ដង ( បើ ) ទារ ៥ ដងហើយ គប្បីឈរ ២ ដង ( បើ ) ទារ ៦ ដងហើយ មិនគប្បីឈរ ( ទៀត ) ទេ ។ កាលបើភិក្ខុព្យាយាមឲ្យលើសពីកំណត់នោះ ឲ្យចីវរនោះសម្រេចបាន ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលព្យាយាម ចីវរដែលបានមកជានិស្សគ្គិយ ចីវរនោះ ភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុគប្បីលះយ៉ាងនេះ ។បេ។ បពិត្រ ព្រះសង្ឃដ៏ចម្រើន ចីវរនេះខ្ញុំឲ្យសម្រេចបាន ដោយទារលើសពី ៣ ដង ដោយឈរលើសពី ៦ ដង ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យលោកដ៏មានអាយុ ។ បើភិក្ខុឲ្យចីវរនោះសម្រេចមិនបានទេ ថ្លៃចីវរដែលគេនាំមកដើម្បីភិក្ខុនោះអំពីសម្នាក់បុគ្គលណា ភិក្ខុគប្បីទៅក្នុងសម្នាក់បុគ្គលនោះខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរណាទៅចំពោះភិក្ខុ តម្លៃចីវរនោះ មិនសម្រេចប្រយោជន៍បន្តិច

បន្តួចដល់ភិក្ខុនោះទេ អ្នកដ៏មានអាយុទាំងឡាយ ចូរតៀនទារយករបស់ខ្លួនចុះ ទ្រព្យរបស់អ្នកទាំងឡាយចូរកុំឲ្យវិនាស ។ ពាក្យថា ការនេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ គឺថា ការនេះ ជាសភាពដ៏សមគួរតាមធម៌ក្នុងសិក្ខាបទនោះ ។

[ ៧២ ] ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសម្គាល់ថា លើសមែន ( ហើយ ) ឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសង្ស័យ ហើយឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសម្គាល់ថា នៅខ្វះ ហើយឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសម្គាល់ថា លើស ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសម្គាល់ថា ថយ ជាអនាបត្តិ ។

[ ៧៣ ] អាបត្តិមិនមានដល់ភិក្ខុញុំាងចីវរឲ្យសម្រេចដោយទារ ( ត្រឹម ) ៣ ដង ឈរ ( ត្រឹម ) ៦ ដង ដល់ភិក្ខុញុំាងចីវរឲ្យសម្រេចដោយទារខ្វះពី ៣ ដង ឈរខ្វះពី ៦ ដង ដល់ភិក្ខុដែលមិនបានតឹងទារ វេយ្យាវច្ចករគេឲ្យ ( ឯង ) ដល់ភិក្ខុដែលម្ចាស់របស់ទារឲ្យ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

ចីវរវគ្គទី ១ ចប់

## ឧទ្ទាននៃចីវរវគ្គនោះដូច្នេះ គឺ

សំពត់អតិរេកចីវរដែលបានមកហើយ មិនបានវិកប្បអធិដ្ឋាន ក្នុងវេលាដែលអស់អំណាចអានិសង្សកឋិនហើយ ទុកឲ្យកន្លងដប់រាត្រី ១ ក្នុងវេលាដែលអស់អំណាចអានិសង្សកឋិនហើយ ភិក្ខុនៅប្រាសចាកត្រៃចីវរឲ្យកន្លងមួយរាត្រី ១ ភិក្ខុទុកអកាលចីវរឲ្យហួសពីមួយខែ ១ ភិក្ខុប្រើនាងភិក្ខុនីមិនមែនជាញាតិឲ្យលាងចីវរចាស់ ១ ភិក្ខុទទួលចីវរពីដៃនាងភិក្ខុនីមិនមែនជាញាតិ ១ ភិក្ខុសូមចីវរពីគ្រហស្ថមិនមែនជាញាតិ ១ ភិក្ខុសូមចីវរហួសពីអន្តរវាសក ( ស្បង់ ) និងឧត្តរាសង្គ ( ចីវរ ) ១ ភិក្ខុទៅនិយាយនឹងគ្រហស្ថដែលមិនមែនជាញាតិ មិនបានបវារណា ដែលគេបម្រុងនឹងប្រគេនចីវរ ឲ្យគេប្រគេនចីវរឲ្យល្អ ១ ភិក្ខុទៅនិយាយនឹងគ្រហស្ថច្រើនរូបមិនមែនជាញាតិ មិនមែនជនដែលបានបវារណា ឲ្យគេរួបរួមថ្លៃជាមួយគ្នា ដើម្បីទិញចីវរឲ្យល្អ ១ ភិក្ខុទៅ តឹងទារចីវរអំពីវេយ្យាវច្ចករហួសពី ៣ ដង និងឈរហួសពី ៦ ដង ១ ។

# អដ្ឋកថា

## ចីវរវគ្គទី ១ សិក្ខាបទទី ១០

## រាជសិក្ខាបទ

[ ៧០ ] រាជសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងរាជសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា

ពីរបទថា **ឧបាសកំ សញ្ញាបេត្វា** បានដល់ ឲ្យឧបាសកយល់ហើយ អធិប្បាយថា ពោលហើយយ៉ាងនេះថា អ្នកចូរទិញចីវរដោយមូលតម្លៃនេះ ហើយប្រគេនព្រះថេរៈ ។

បទថា **បញ្ញាសពន្ធោ**[១] មានពាក្យអធិប្បាយថា ត្រូវ ( ពិន័យ ) ៥០ កហាបណៈ ។ បាឋៈថា **បញ្ញាសពទ្ធោ** ក៏មាន ។

ច្រើនបទថា **អជ្ជុណ្ហោ ភន្តេ អាគមេហិ** សេចក្ដីថា បពិត្រលោកម្ចាស់ ថ្ងៃនេះ សូមឈប់សិន គឺបង្អង់ឲ្យខ្ញុំត្រឹមតែមួយថ្ងៃ ។

បទថា **បរាមសិ** ប្រែថា បានប្រកាន់ទុក ។

បទថា **ជិនោសិ** សេចក្ដីថា អ្នកត្រូវពួកខ្ញុំឈ្នះ គឺឈ្នះអ្នក ៥០ កហាបណៈ អធិប្បាយថា លោកត្រូវឲ្យ ៥០ កហាបណៈ ។

---

១- បិដកថា បញ្ញាសពទ្ធោ ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃរាជសិក្ខាបទ

[ ៧១ ] បទថា **រាជភោគ្គោ** មានវិគ្គហៈថា ឈ្មោះថា រាជអមាត្យ ព្រោះ មានបៀវត្ស និងគប្បីបរិភោគ ឬគប្បីប្រើប្រាស់ពីព្រះរាជា ។ បាឋៈថា **រាជភោគោ** ក៏មាន សេចក្ដីថា អ្នកមានភោគៈ ( ភាពជាធំ ) អំពីរាជា ។ បទថា **បហិណេយ្យ** ប្រែថា គប្បីបញ្ជូនទៅ តែព្រោះមានអត្ថងាយយល់ ទើបព្រះមានព្រះភាគមិនបានត្រាស់បទភាជនៈនៃបទថា **បហិ-ណេយ្យ** នោះទុក ។ ឯបទថា **បហិណេយ្យ** នេះ ព្រះមានព្រះភាគមិនបានត្រាស់បទភាជនៈទុក យ៉ាងណា សូម្បីបទថា **ចីវរំ ឥត្តន្នាមំ ភិក្ខុំ** ជាដើម ក៏ដូច្នោះដែរ បណ្ឌិតគប្បីជ្រាបថា ទ្រង់មិនបានត្រាស់បទភាជនៈទុក ព្រោះមានអត្ថងាយយល់យ៉ាងនោះ ។

បទថា **អាភតំ** ប្រែថា នាំមកហើយ ។

ពីរបទថា **កាលេន កប្បិយំ** គឺដោយកាលដែលដល់នូវភាពសមគួរ សេចក្ដីថា ពួកយើងនឹងទទួលចីវរដែលគួរក្នុងវេលាពួកយើងត្រូវការ ។

បទថា **វេយ្យាវច្ចករោ** បានដល់ អ្នកធ្វើកិច្ច សេចក្ដីថា ជាកប្បិយ-ការក ( អ្នកធ្វើរបស់ឲ្យគួរ ) ។ បទថា **សញ្ញត្តោ សោ មយា** សេចក្ដីថា មនុស្សដែលលោកម្ចាស់ប្រាប់ជាវេយ្យាវច្ចករនោះ ខ្ញុំប្រាប់ឲ្យយល់ហើយ គឺប្រាប់ដោយប្រការដែលលោកម្ចាស់ មានសេចក្ដីត្រូវការដោយចីវរ បុគ្គលនោះនឹងប្រគេនដល់លោកម្ចាស់ ។

បទថា **អត្ថោ មេ អាវុសោ ចីវរេន** នេះ ជាពាក្យសម្ដែងលក្ខណៈ

នៃការទារ ( ដោយវាចា ) ។ ពិតហើយ វោហារនេះគួរពោល យ៉ាងទៀត អត្ថនៃបទថា **អាវុសោ** អាត្មាមានសេចក្តីត្រូវការដោយចីវរនោះ គួរពោលដោយភាសាមួយ ។ លក្ខណៈនេះ ឈ្មោះថា លក្ខណៈនៃការទារ ។ ឯបទថា **ទេហិ មេ ចីវរំ** ប្រែថា ចូរឲ្យចីវរដល់អាត្មាជាដើម ត្រាស់ទុកដើម្បីសម្តែងអាការដែលមិនគួរពោល ។ ពិតហើយ ពាក្យទាំងនេះ ឬអត្ថរបស់ពាក្យទាំងនេះ មិនគួរពោលដោយភាសាណាមួយឡើយ ។

បទថា **ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ** សេចក្តីថា វេយ្យាវច្ចៈនោះ ដែលភិក្ខុគប្បីពោលពាក្យនេះឯងជាគម្រប់ ៣ ដងថា អាវុសោ អាត្មាត្រូវការចីវរ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកំណត់ការទារ ដែលលើកឡើងសម្តែងក្នុងពាក្យថា គប្បីទារ គប្បីដាស់តឿន ២-៣ ដង យ៉ាងនេះហើយឥឡូវនេះ កាលទ្រង់សម្តែងអត្ថដោយសង្ខេបនៃបទទាំងនេះថា **ទ្វិត្តិក្ខត្តុំ ចោទយមានោ សារយមានោ តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ** ទើបត្រាស់ថា បើភិក្ខុប្រាប់វេយ្យាវច្ចករនោះឲ្យចាត់ចែងសម្រេច ការឲ្យចាត់ចែងសម្រេចបានយ៉ាងនេះ នោះជាការល្អ កាលទារដល់ ៣ ដងយ៉ាងនេះ បើចាត់ចែងចីវរនោះឲ្យសម្រេចបាន គឺរមែងអាចដើម្បីឲ្យសម្រេចដោយអំណាច ( ធ្វើ ) ឲ្យ ខ្លួនបានមក ការចាត់ការឲ្យសម្រេចបាននេះ នោះជាការល្អ គឺឲ្យសម្រេចប្រយោជន៍ប្រពៃល្អ ។

បទថា **ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ**

នេះ ជាការសម្តែងលក្ខណៈនៃការឈរ ។ ឯបទថា **ជក្ខុត្ថុបរមំ** នេះ ប្រាប់ការៈនបុំសកលិង្គ ។ ពិតហើយ ភិក្ខុនេះគប្បីឈរស្ងៀមចំពោះចីវរ ៦ ដង យ៉ាងច្រើន មិនគប្បីធ្វើកិច្ចណាមួយដទៃឡើយ នេះជាលក្ខណៈនៃការឈរ ។ កាលទ្រង់សម្តែងភាពជាអ្នកស្ងៀម ( ដែលត្រាស់ ) ទុកក្នុងបទថា **តុណ្ហី-ភូតេន** នោះ ដែលជាសាធារណៈដល់ការឈរគ្រប់ៗ លើកជាមុន ទើបព្រះដ៏មានព្រះភាគត្រាស់បទថា **តត្ថ គន្ត្វា តុណ្ហីភូតេន** ជាដើមក្នុងបទភាជនៈ ។

## អធិប្បាយ ការនារ និងការឈរ

បណ្តាបទទាំងនោះ ពីរបទថា **ន អាសនេ និសីទិតព្វំ** សេចក្តីថា ភិក្ខុដែលវេយ្យាវច្ចៈពោលថា សូមអង្គុយទីនេះចុះលោកម្ចាស់ ក៏មិនគួរអង្គុយឡើយ ។

ពីរបទថា **ន អាមិសំ បដិគ្គហេតព្វំ** សេចក្តីថា សូម្បីបុគ្គលនោះអង្វរថា សូមលោកម្ចាស់ទទួលអាមិស មានយាគូ និងខាទនីយជាដើមត្រឹមតែបន្តិចបន្តួចចុះ ក៏មិនគួរទទួល ។

ពីរបទថា **ន ធម្មោ ភាសិតព្វោ** សេចក្តីថា សូម្បីបុគ្គលនោះអង្វរថា សូមពោលមង្គល ឬអនុមោទនាចុះ ក៏មិនគួរពោលអ្វីឡើយ ។ កាលត្រូវបុគ្គលនោះសួរតែម្យ៉ាងថា លោកម្ចាស់មកព្រោះហេតុដូចម្តេច គប្បីប្រាប់បុគ្គលនោះថា អ្នកចូរដឹងខ្លួនឯងចុះ ពិតហើយ បទថា **បុច្ឆិយមានោ** នេះជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ ម្យ៉ាងទៀត អ្នកសិក្សាគប្បីឃើញអត្ថក្នុងបទថា **បុច្ឆិយមានោ** នេះ យ៉ាងនេះថា ត្រូវបុគ្គលនោះតាំងបញ្ហា

សួរ ។ ពិតហើយ បុគ្គលណារមែងតាំងបញ្ហាសួរ ភិក្ខុគួរឆ្លើយចំពោះបុគ្គលនោះប៉ុណ្ណោះឯង ។

ពីរបទថា **ឋានំ ភញ្ជតិ** រមែងកាច់នូវហេតុនៃការមក ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការបន្ថែម និងការបន្ថយក្នុងការទារ ៣ ដង និងការឈរ ៦ ដង ដែលទ្រង់ត្រាស់ទុកហើយ ទើបត្រាស់ពាក្យជាដើមថា **ចតុក្ខត្តុំ ចោទេត្វា** ជាដើម ។ មួយាងទៀត ក្នុងព្រះបាលីដែលត្រាស់ឲ្យបន្ថយការឈរ ២ ដង ដោយបន្ថែមការទារម្តង ព្រោះដូច្នោះ ទើបទ្រង់សម្តែងលក្ខណៈថា ការទារម្តងប៉ុនគ្នានឹងការឈរ ២ ដង ។ មានពាក្យអធិប្បាយថា ដោយលក្ខណៈដូចពោលមកនេះ ភិក្ខុទារ ៣ ដង គប្បីឈរបាន ៦ ដង ទារ ២ ដង គប្បីឈរបាន ៨ ដង ទារម្តង គប្បីឈរបាន ១០ ដង ដូចទ្រង់ត្រាស់ថា ទារ ៦ ដងហើយ មិនគប្បីឈរយ៉ាងណា ឈរ ១២ ដងហើយ ក៏មិនគប្បីទារ ដូច្នោះ ពាក្យដូច្នេះក៏មានដូចគ្នា ។

ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងការទារ និងការឈរទាំង ២ នោះយ៉ាងនេះថា បើភិក្ខុទារតែម្យ៉ាង មិនឈរ រមែងបានការទារ ៦ ដង បើឈរតែម្យ៉ាង មិនទារ រមែងបានការឈរ ១២ ដង ។ បើទារខ្លះ ឈរខ្លះ គប្បីបន្ថយការឈរ ២ ដង អំពីការទារម្តង បណ្តាការទារ និងការឈរនោះ ភិក្ខុណាទៅទាររឿយៗ មួយថ្ងៃប៉ុណ្ណោះ ដល់ទៅ ៦ ដង ឬទៅត្រឹមតែម្តង តែនិយាយ ៦ ដងថា អ្នកមានអាយុ អាត្មាត្រូវការចីវរ ម្យ៉ាងទៀត

ទៅឈររឿយៗ មួយថ្ងៃប៉ុណ្ណោះ ដល់ទៅ ១២ ដង ឬទៅត្រឹមតែម្តង តែឈរក្នុងទីនោះៗ ១២ ដង ភិក្ខុនោះ រមែងកាច់ការទារទាំងអស់ និងការឈរទាំងអស់ នឹងពោលទៅថ្វី ក្នុងរឿងកាច់ការទារ និងការឈររបស់ភិក្ខុដែលធ្វើយ៉ាងនេះ ក្នុងថ្ងៃផ្សេងគ្នានោះ ។

បទថា **យតស្ស ចីវរចេតាបន្នំ អាភតំ** សេចក្តីថា ទ្រព្យដែលសម្រាប់តម្លៃចីវរ ដែលគេនាំមកដើម្បីភិក្ខុនោះអំពីព្រះរាជា ឬអំពីរាជអមាត្យណា បាឋៈថា **យត្វស្ស** ក៏មាន ។ អត្ថយ៉ាងនេះដូចគ្នា ។ អាចារ្យទាំង-ឡាយសូធ្យថា **យត្តស្ស** ក៏មាន និងពោលអត្ថថា ទ្រព្យតម្លៃចីវរដែលគេបញ្ជូនមកដើម្បីភិក្ខុនោះ ក្នុងទីណា ។ តែព្យញ្ជនៈមិនសមទំនង ។

បទថា **តត្ថ** សេចក្តីថា ក្នុងសម្នាក់នៃព្រះរាជា ឬរាជអមាត្យនោះ ។ ពិតហើយ បទថា **តត្ថ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។

បទថា **ន តំ តស្ស ភិក្ខុនោ កិញ្ចិ អត្ថំ អនុភោតិ** សេចក្តីថា ទ្រព្យសម្រាប់តម្លៃចីវរនោះ មិនឲ្យសម្រេចកម្មសូម្បីតិចតួច គឺមានប្រមាណតិចតួចដល់ភិក្ខុនោះ ។

បទថា **យុញ្ជន្តាយស្មន្តោ សកំ** សេចក្តីថា អ្នកទាំងឡាយ ចូរទារយកទ្រព្យរបស់ខ្លួន គឺចូរតាមយកទ្រព្យនោះទៅវិញចុះ ។

បទថា **មា វោ សកំ វិនស្ស** សេចក្តីថា ទ្រព្យផ្ទាល់ខ្លួនរបស់អ្នកចូរកុំបាត់បង់ទៅឡើយ ម្យ៉ាងទៀត ភិក្ខុណារមែងមិនទៅឯង ទាំងមិនបញ្ជូនទូតទៅ ភិក្ខុនោះ រមែងត្រូវអាបត្តិទុក្កដ ព្រោះលះបង់វត្ត ។

# អធិប្បាយ កប្បិយការក និងវេយ្យាវច្ចៈ

សួរថា ក្នុងកប្បិយការកទាំងពួង គប្បីបដិបត្តិយ៉ាងនេះឬ ឆ្លើយថា មិនត្រូវបដិបត្តិ ( យ៉ាងនេះជានិច្ចនោះទេ ) ។

ពិតហើយ ឈ្មោះថា កប្បិយការកនេះ ដោយសង្ខេបមាន ២ យ៉ាង គឺដែលត្រូវសម្តែង ១ ដែលមិនត្រូវសម្តែង ១ ក្នុង ២ ពួកនោះ កប្បិយ-ការកដែលត្រូវសម្តែង មាន ២ គឺដែលភិក្ខុអ្នកសម្តែង ១ ដែលទូតសម្តែង ១ ។ សូម្បីកប្បិយការកដែលមិនត្រូវសម្តែង ក៏មាន ២ យ៉ាង គឺកប្បិយ-ការកដែលហាមាត់ខ្លួនឯងចំពោះមុខ ១ កប្បិយការកកំបាំងមុខ ១ ។ បណ្តា កប្បិយការកដែលភិក្ខុសម្តែងជាដើមនោះ កប្បិយការកដែលភិក្ខុសម្តែង មាន ៤ យ៉ាង ដោយអំណាចចំពោះមុខ និងកំបាំងមុខ ។ កប្បិយការកដែលទូត សម្តែងក៏ដូចគ្នា ។

សេចក្តីនេះដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ រមែងបញ្ជូនអកប្បិយវត្ថុ ទៅដោយទូត ដើម្បីប្រយោជន៍ដល់ចីវរសម្រាប់ភិក្ខុ ។ ទូតចូលទៅរកភិក្ខុ អង្គនោះ ពោលថា បពិត្រលោកម្ចាស់ លោកអ្នកមានឈ្មោះយ៉ាងនេះបញ្ជូន អកប្បិយវត្ថុនេះមក ដើម្បីប្រយោជន៍ដល់ចីវរសម្រាប់លោកម្ចាស់ សូម លោកម្ចាស់ទទួលអកប្បិយវត្ថុនោះ ។ ភិក្ខុឃាត់ថា អកប្បិយវត្ថុនេះ មិនគួរ ទេ ។ ទូតសួរថា បពិត្រលោកម្ចាស់ វេយ្យាវច្ចៈរបស់លោកម្ចាស់មានឬ ហើយវេយ្យាវច្ចៈទាំងឡាយ ដែលពួកឧបាសកអ្នកត្រូវការបុណ្យប្រាប់ទុកថា ពួកអ្នកចូរធ្វើការបម្រើដល់ភិក្ខុទាំងឡាយក្តី វេយ្យាវច្ចៈពួកខ្លះ ដែលជាមិត្រ ធ្លាប់ឃើញរាប់អានគ្នាមក របស់ភិក្ខុទាំងឡាយមានក្តី បណ្តាវេយ្យាវច្ចៈទាំង

នោះឯណាទីមួយ អង្គុយនៅក្នុងសម្នាក់របស់ភិក្ខុ ក្នុងខណៈនោះ ។ ភិក្ខុបង្ហាញបុគ្គលនោះថា បុគ្គលនេះជាវេយ្យាវច្ចៈរបស់ភិក្ខុទាំងឡាយ ដូច្នេះ ។ ទូតប្រគល់អកប្បិយវត្ថុក្នុងដៃរបស់វេយ្យាវច្ចៈនោះ ប្រាប់ថា អ្នកចូរទិញចីវរប្រគេនព្រះថេរៈផង ដូច្នេះ ហើយក៏ចៀសចេញទៅ នេះឈ្មោះថា វេយ្យាវច្ចៈដែលភិក្ខុបង្ហាញចំពោះមុខ ។

បើវេយ្យាវច្ចៈ មិនបានអង្គុយនៅក្នុងសម្នាក់របស់ភិក្ខុទេ ភិក្ខុរមែងបង្ហាញឡើងថា ជនឈ្មោះនេះ ក្នុងស្រុកឈ្មោះនោះ ជាវេយ្យាវច្ចៈរបស់ភិក្ខុទាំងឡាយ ទូតនោះទៅប្រគល់អកប្បិយវត្ថុទុកក្នុងដៃរបស់វេយ្យាវច្ចៈនោះ ប្រាប់ថា អ្នកគប្បីទិញចីវរប្រគេនព្រះថេរៈ មកប្រាប់ដល់ភិក្ខុហើយ ទើបចៀសចេញទៅ ។ វេយ្យាវច្ចៈនេះ ឈ្មោះថា ភិក្ខុសម្តែងក្នុងទីកំបាំងមុខប្រភេទទី ១ ។

ឯទូតនោះមិនបានមកប្រាប់ខ្លួនឯងឡើយ តែត្រឡប់ជាពឹងអ្នកដទៃឲ្យទៅប្រាប់ថា បពិត្រលោកម្ចាស់ ទ្រព្យសម្រាប់តម្លៃចីវរ ខ្ញុំបានប្រគល់ទុកក្នុងដៃបុគ្គលនោះ សូមលោកម្ចាស់ទទួលយកចីវរចុះ ។ វេយ្យាវច្ចៈនេះឈ្មោះថា អ្នកដែលភិក្ខុបង្ហាញមិនចំពោះមុខប្រភេទទី ២ ។

ទូតនោះមិនបានពឹងអ្នកដទៃឡើយ តែទៅប្រាប់ភិក្ខុឯងថា ខ្ញុំនឹងប្រគល់ទ្រព្យសម្រាប់តម្លៃចីវរទុកក្នុងដៃនៃបុគ្គលនោះ សូមលោកម្ចាស់ទទួលយកចីវរចុះ ។ បុគ្គលនោះឈ្មោះថា វេយ្យាវច្ចៈដែលភិក្ខុបង្ហាញមិនចំពោះមុខប្រភេទទី ៣ ។ ដោយប្រការដូចពោលមកនេះ វេយ្យាវច្ចៈ ៤ ពួកនេះ គឺ

ដែលភិក្ខុសម្តែងចំពោះមុខ ១ ពួក ភិក្ខុបង្ហាញមិនចំពោះមុខ ៣ ពួក ឈ្មោះថា វេយ្យាវច្ចៈដែលភិក្ខុបង្ហាញ ។ ក្នុងវេយ្យាវច្ចៈ ៤ ពួកនេះ ភិក្ខុគប្បីបដិបត្តិដោយន័យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងរាជសិក្ខាបទនេះឯង ។

ភិក្ខុមួយអង្គទៀត ត្រូវទូតសួរហើយ ដោយន័យមុននោះឯង ព្រោះវេយ្យាវច្ចៈមិនមាន ឬព្រោះមិនចង់ឲ្យចាត់ការ ទើបពោលថា ពួកអាត្មាមិនមានកប្បិយការក ហើយក្នុងខណៈនោះ មានបុគ្គលខ្លះមកដល់ ទើបទូតប្រគល់អកប្បិយវត្ថុទុកក្នុងដៃរបស់បុគ្គលនោះ ហើយពោលថា លោកម្ចាស់គប្បីទទួលយកចីវរអំពីដៃរបស់បុគ្គលនេះចុះ ហើយចៀសចេញទៅ វេយ្យាវច្ចៈនេះ ឈ្មោះថា ជាបុគ្គលដែលទូតបង្ហាញចំពោះមុខ ។

នៅមានទូតដទៃទៀត ចូលទៅកាន់ស្រុក ហើយប្រគល់អកប្បិយវត្ថុទុកក្នុងដៃរបស់បុគ្គលណាមួយដែលស្រឡាញ់រាប់អានខ្លួន ហើយមកប្រាប់ ឬពឹងពាក់អ្នកដទៃទៅប្រាប់ដោយន័យមុននោះឯង ឬពោលថា ខ្ញុំឲ្យទ្រព្យតម្លៃចីវរទុកក្នុងដៃរបស់បុគ្គលឈ្មោះនោះ លោកម្ចាស់គប្បីទទួលយកចីវរចុះដូច្នេះ ហើយចៀសចេញទៅ ។ ក្នុងវេយ្យាវច្ចៈទី ៣ នេះ ឈ្មោះថា ជាបុគ្គលដែលទូតបង្ហាញមិនចំពោះមុខ ដោយប្រការដូចពោលមកនេះ វេយ្យាវច្ចៈ ៤ ពួកទាំងនេះ គឺវេយ្យាវច្ចៈដែលទូតបង្ហាញចំពោះមុខ ១ ពួក វេយ្យាវច្ចៈដែលទូតបង្ហាញមិនចំពោះមុខ ៣ ពួក ឈ្មោះថា វេយ្យាវច្ចៈដែលទូតបង្ហាញក្នុងវេយ្យាវច្ចៈ ៤ ពួកនេះ ភិក្ខុគប្បីបដិបត្តិដោយន័យដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងមេណ្ឌកសិក្ខាបទនោះឯង ។

សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មនុស្សទាំងនោះទុកដាក់មាស និងប្រាក់ក្នុងដៃកប្បិយការកទាំងឡាយ ដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយប្រគេនរបស់នោះ ដោយមាស និងប្រាក់នេះចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយ ( ដែលកើត ) អំពីមាស និងប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា អ្នកត្រូវត្រេកអរ ត្រូវស្វែងរកមាស និងប្រាក់ ដោយបរិយាយណាមួយឡើយ ដូច្នេះ ។

ក្នុងអធិការនៃវេយ្យាវច្ចៈ ៤ ពួកដែលទូតសម្តែងនេះ មិនមានកំណត់ក្នុងការទារ ។ ការដែលភិក្ខុមិនត្រេកអរក្នុងមូលតម្លៃ ត្រេកអរតែក្នុងកប្បិយភណ្ឌ ដោយការទារ ឬដោយការឈរ សូម្បីមួយពាន់ដងក៏គួរ ។ បើវេយ្យាវច្ចៈនោះមិនឲ្យ គប្បីតាំងកប្បិយការកដទៃឲ្យនាំមកក៏បាន បើកប្បិយការកដទៃប្រាថ្នានឹងនាំមក ភិក្ខុគប្បីប្រាប់ដល់ម្ចាស់ទ្រព្យ បើមិនប្រាថ្នាក៏មិនត្រូវប្រាប់ ។

ភិក្ខុមួយអង្គទៀត ត្រូវទូតសួរដោយន័យមុនដូចគ្នា ពោលថា ពួកអាត្មាមិនមានកប្បិយការក ។ អ្នកដទៃអំពីទូតនោះ ឈរនៅជិតៗ នោះ បានឮទើបពោលថា អ្នកដ៏ចម្រើន ចូរនាំមកចុះ ខ្ញុំនឹងទិញចីវរប្រគេនលោកម្ចាស់ដូច្នេះ ។ ទូតពោលថា អញ្ជើញចុះអ្នកដ៏ចម្រើន អ្នកគប្បីប្រគេន ហើយប្រគល់ទុកក្នុងដៃរបស់បុគ្គលនោះ មិនប្រាប់ដល់ភិក្ខុឡើយ ហើយចៀស

ចេញទៅ ។ នេះឈ្មោះថា កប្បិយការកអ្នកហាមាត់ឯងចំពោះមុខ ។

ទូតម្នាក់ទៀតប្រគល់អកប្បិយវត្ថុទុកក្នុងដៃឧបដ្ឋាករបស់ភិក្ខុ ឬអ្នកដទៃ ប្រាប់ថា អ្នកគប្បីឲ្យចីវរដល់ព្រះថេរៈ ហើយចៀសចេញទៅអំពីទីនោះឯង នេះឈ្មោះថា កប្បិយការកកំបាំងមុខ ដូច្នោះ ទើបកប្បិយការកទាំង ២ នេះ ឈ្មោះថា កប្បិយការកដែលទូតមិនបានសម្ដែង ។ ក្នុងកប្បិយការកទាំង ២ នេះ គប្បីបដិបត្តិដូចក្នុងអញ្ញាតកសិក្ខាបទ និងអប្បវារិតសិក្ខាបទ ដូច្នោះ ។ បើកប្បិយការកដែលទូតមិនបានសម្ដែងទាំងឡាយ នាំចីវរមកប្រគេនឯង ភិក្ខុគប្បីទទួល បើមិនបាននាំមកប្រគេន កុំគប្បីពោលពាក្យណាមួយឡើយ ។

បទថា **ទូតេន ចីវរចេតាបនំ បហិណេយ្យ** នេះ គ្រាន់តែជាទេសនាប៉ុណ្ណោះ សូម្បីក្នុងពួកកប្បិយការក ដែលនាំអកប្បិយវត្ថុមកប្រគេន ដើម្បីប្រយោជន៍ដល់បិណ្ឌបាតជាដើមដោយខ្លួនឯង ក៏មានន័យយ៉ាងនេះដូចគ្នា ។ ភិក្ខុនឹងទទួលដើម្បីប្រយោជន៍ដល់ខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះ មិនសមគួរ ។

## វិធីបដិបត្តិ ក្នុងមាស និងប្រាក់

បើបុគ្គលណាមួយ នាំយកមាស និងប្រាក់មកពោលថា ខ្ញុំប្រគេនមាស និងប្រាក់នេះដល់សង្ឃ លោកម្ចាស់ទាំងឡាយចូរសាងអារាម វិហារ ចេតិយ ឬរោងឆាន់ជាដើមឯណានីមួយក៏ដោយ នឹងទទួលមាស និងប្រាក់នេះ មិនសមគួរ ។ ក្នុងមហាបច្ចរីពោលទុកថា ព្រោះថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុអង្គណាដែលទទួលដើម្បីប្រយោជន៍ដល់អ្នកដទៃ ។ បើភិក្ខុបដិសេធថា ភិក្ខុទាំងឡាយ នឹងទទួលមាស និងប្រាក់នេះ មិនគួរ ។ បុគ្គលនោះពោលថា

មាស និងប្រាក់ នឹងនៅក្នុងដៃរបស់ពួកជាងឈើ ឬពួកកម្មករ សូមលោកម្ចាស់ទាំងឡាយជ្រាបការងារដែលគេធ្វើល្អ និងមិនល្អតែម្យ៉ាង ដូច្នេះហើយប្រគល់ទុកក្នុងដៃពួកជាងឈើ ឬពួកកម្មករទាំងនោះ ទើបចៀសចេញទៅភិក្ខុទទួលក៏គួរ បើបុគ្គលនោះពោលថា មាស និងប្រាក់នៅក្នុងដៃនៃពួកមនុស្សរបស់ខ្ញុំក្តី នៅក្នុងដៃរបស់ខ្ញុំក្តី លោកម្ចាស់គប្បីឲ្យដំណឹងទៅដើម្បីប្រយោជន៍ដល់បុគ្គលដែលខ្ញុំនឹងត្រូវឲ្យមាស និងប្រាក់តែម្យ៉ាង យ៉ាងនេះក៏គួរ ។

បើពួកបុគ្គលនោះមិនប្រាប់ពួកសង្ឃ គណៈ ឬបុគ្គល ពោលថា ខ្ញុំទាំង-ឡាយប្រគេនប្រាក់ និងមាសនេះដល់ចេតិយ ដល់វិហារ ប្រគេនដើម្បីនវកម្ម ដូច្នេះ ភិក្ខុបដិសេធមិនគួរ ។ គប្បីប្រាប់ដល់ពួកកប្បិយការកថា ជនពួកនេះពោលពាក្យនេះ ។ តែកាលបុគ្គលនោះពោលថា សូមលោកម្ចាស់ទាំងឡាយទទួលទុកដាក់ដើម្បីប្រយោជន៍ដល់ចេតិយជាដើមចុះ គប្បីបដិសេធថា ការដែលពួកអាត្មាទទួលទុកដាក់ មិនសមគួរ ។

បើបុគ្គលពួកខ្លះនាំយកប្រាក់និងមាសមកច្រើន ពោលថា ខ្ញុំសូមប្រគេនប្រាក់ និងមាសនេះដល់សង្ឃ សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យ ៤ ចុះ បើសង្ឃទទួលប្រាក់ និងមាសនោះ ត្រូវអាបត្តិទាំងទទួល ទាំងបរិភោគ ។ បើបណ្តាភិក្ខុទាំងនោះ ភិក្ខុណាមួយ បដិសេធថា របស់នេះមិនគួរ ។ ហើយឧបាសកពោលថា បើមិនគួរនឹងជារបស់ខ្ញុំវិញ ដូច្នេះហើយ ចៀសចេញទៅ ភិក្ខុនោះ ភិក្ខុអង្គខ្លះមិនគប្បីពោលពាក្យណាមួយថា លោកម្ចាស់ធ្វើលាក

សង្ឃឲ្យអន្តរាយ ព្រោះភិក្ខុណាចោទលោក ភិក្ខុនោះឯង ជាអ្នកត្រូវអាបត្តិ ជាប់ខ្លួន តែភិក្ខុនោះឯងធ្វើភិក្ខុដ៏ច្រើនមិនឲ្យត្រូវអាបត្តិ ។ បើភិក្ខុទាំងឡាយ បដិសេធថា មិនគួរ បុគ្គលនោះពោលថា នឹងនៅក្នុងដៃរបស់ពួកកប្បិយ-ការក ឬនឹងនៅក្នុងដៃនៃពួកមនុស្សរបស់ខ្ញុំ ឬក្នុងដៃរបស់ខ្ញុំ សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដូច្នេះ គួរ ។

ម្យ៉ាងទៀត បើគេប្រគេនដើម្បីប្រយោជន៍ដល់ចតុប្បច្ច័យ គប្បីបង្អោនទៅដើម្បីបច្ច័យដែលត្រូវការ ។ បើគេប្រគេនដើម្បីប្រយោជន៍ដល់ចីវរ គប្បីបង្អោនទៅក្នុងចីវរប៉ុណ្ណោះ ។ បើមិនមានសេចក្តីត្រូវការដោយចីវរនោះ សង្ឃលំបាកដោយបច្ច័យ មានបិណ្ឌបាតជាដើម គប្បីអបលោកដើម្បីសេចក្តីល្អដល់សង្ឃ ហើយបង្អោនទៅដើម្បីប្រយោជន៍ដល់បិណ្ឌបាតជាដើម ។ សូម្បីក្នុងអកប្បិយវត្ថុដែលគេប្រគេន ដើម្បីប្រយោជន៍ដល់បិណ្ឌបាត និងគិលាន-ប្បច្ច័យ ក៏មានន័យដូច្នេះ ។

ម្យ៉ាងទៀត អកប្បិយវត្ថុដែលគេប្រគេន ដើម្បីប្រយោជន៍ដល់សេនា-សនៈ គប្បីបង្អោនទៅក្នុងសេនាសនៈទាំងអស់ ព្រោះសេនាសនៈជាគរុភណ្ឌ បើពួកភិក្ខុលះសេនាសនៈទៅ សេនាសនៈនឹងវិនាស ក្នុងកាលដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយ សូម្បីចំណាយសេនាសនៈ ហើយបរិភោគ ( បច្ច័យ ) បាន ។

ព្រោះដូច្នោះ ដើម្បីរក្សាសេនាសនៈទុក ភិក្ខុកុំធ្វើឲ្យដាច់មូលតម្លៃ គប្បីបរិភោគល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ មិនមែនតែប្រាក់មាសតែម្យ៉ាង

ប៉ុណ្ណោះទេ សូម្បីអកប្បិយវត្ថុដទៃ មានស្រែ និងសួនជាដើមក៏ភិក្ខុមិនគួរទទួល ។

# ការបដិបត្តិក្នុងបឹង និងស្រះជាដើម

បើបុគ្គលណាមួយ ពោលថា បឹងធំ ឲ្យសម្រេចសន្ទូង ៣ ដង របស់ខ្ញុំមាន ខ្ញុំសូមប្រគេនបឹងធំនោះដល់សង្ឃ បើសង្ឃទទួលបឹងធំនោះ ត្រូវអាបត្តិក្នុងការទទួលផង ក្នុងការបរិភោគផងដូចគ្នា ។ តែភិក្ខុណាបដិសេធបឹងធំនោះ ភិក្ខុនោះ ក៏ភិក្ខុអង្គខ្លះមិនគួរពោលពាក្យណាមួយ ដោយន័យមុនដូចគ្នា ។ ព្រោះថា ភិក្ខុណាចោទលោក ភិក្ខុនោះត្រូវអាបត្តិខ្លួនឯង ។ តែលោកមួយអង្គឯង បានធ្វើឲ្យភិក្ខុច្រើនអង្គមិនត្រូវអាបត្តិ ។

ម្យ៉ាងទៀត បុគ្គលណាពោលថា ខ្ញុំប្រគេនបឹងធំ ដូច្នោះដូចគ្នា ត្រូវពួកភិក្ខុបដិសេធថា មិនគួរ បើនៅតែពោលថា បឹងនោះ និងបឹងនោះ ចូរមានដល់សង្ឃ បឹងនោះរមែងគួរបានដូចម្ដេច គប្បីប្រាប់បុគ្គលនោះថា គេនឹងធ្វើឲ្យជាកប្បិយ ហើយប្រគេនទេដឹង បុគ្គលនោះសួរថា ប្រគេនដូចម្ដេច ទើបជាកប្បិយ គប្បីពោលថា អ្នកពោលប្រគេនថា សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យ ៤ ដូច្នេះ ។ បើបុគ្គលនោះពោលថា សាធុ លោកម្ចាស់សូមលោកម្ចាស់ទាំងឡាយ បរិភោគបច្ច័យ ៤ ចុះ ដូច្នេះ គួរ ។

បើបុគ្គលនោះពោលថា សូមលោកម្ចាស់ទាំងឡាយទទួលបឹងចុះ ត្រូវពួកភិក្ខុទាំងឡាយពោលថា មិនគួរ ហើយសួរថា កប្បិយការកមានឬ កាលភិក្ខុឆ្លើយថា មិនមាន ទើបពោលថា បុគ្គលឈ្មោះនោះនឹងចាត់ការបឹងនេះក្ដី

នឹងនៅក្នុងការមើលថែរបស់បុគ្គលនោះក្តី ក្នុងការមើលថែរបស់ខ្ញុំក្តី សូមសង្ឃបរិភោគកប្បិយកណ្ឌចុះ ដូច្នេះ នឹងទទួល គួរ ។ បើទាយកនោះ ត្រូវភិក្ខុបដិសេធថា មិនគួរ ហើយពោលថា មនុស្សទាំងឡាយ នឹងបរិភោគទឹក នឹងបោកគក់របស់របរ ពួកម្រឹគ និងបក្សី នឹងផឹក សូម្បីការពោលយ៉ាងនេះ ក៏សមគួរ ។

បើពួកទាយកត្រូវភិក្ខុបដិសេធថា មិនគួរ ហើយនៅតែពោលថា សូមលោកម្ចាស់ទាំងឡាយទទួល ដោយសំដៅដល់របស់សមគួរជាធំចុះ ភិក្ខុទោះពោលថា សាធុ ឧបាសក សង្ឃនឹងផឹកទឹក នឹងបោកលាងរបស់របរ ពួកម្រឹគ និងបក្សីនឹងផឹកស៊ី ដូច្នេះហើយ បរិភោគ គួរ ។ បើទាយកពោលថា ខ្ញុំប្រគេនបឹង ឬស្រះបោក្ខរណីដល់សង្ឃ ភិក្ខុទោះពោលពាក្យជាដើមថា សាធុ ឧបាសក សង្ឃនឹងផឹកទឹក ហើយបរិភោគប្រើប្រាស់ គួរដូចគ្នា ។

បើពួកភិក្ខុសូមហត្ថកម្ម និងជីកកប្បិយបឋវី ដោយដៃរបស់ខ្លួនឯង ធ្វើស្រះទឹកដើម្បីត្រូវការទឹក បើពួកអ្នកស្រុកអាស្រ័យស្រះនោះ ធ្វើស្រូវឲ្យសម្រេច ហើយប្រគេនកប្បិយកណ្ឌក្នុងវិហារ គួរ ។ បើពួកអ្នកស្រុកនោះឯងជីកដីរបស់សង្ឃ ដើម្បីឧបការៈដល់សង្ឃ ហើយប្រគេនកប្បិយកណ្ឌអំពីសន្ទូងដែលអាស្រ័យស្រះទឹកនោះសម្រេចហើយ សូម្បីកប្បិយកណ្ឌនេះ ក៏សមគួរ ។ បើអ្នកស្រុកពោលថា សូមលោកម្ចាស់ទាំងឡាយ តាំងកប្បិយ-ការកឲ្យពួកខ្ញុំបានម្នាក់ ភិក្ខុទោះតាំងឲ្យក៏បាន ។

ម្យ៉ាងទៀត បើពួកអ្នកស្រុកនោះ ត្រូវរាជពលីបៀតបៀន នាំគ្នាគេច

ទៅ អ្នកស្រុកដទៃធ្វើឲ្យ នឹងមិនប្រគេនរបស់ណាមួយដល់ភិក្ខុទាំងឡាយ ពួកភិក្ខុហួងហែងទឹកក៏បាន ។ ឯការហួងហែងទឹកនោះ រមែងបានក្នុងរដូវធ្វើស្រែប៉ុណ្ណោះ មិនមែនក្នុងរដូវដែលរួចស្រែហើយនោះទេ ។ បើពួកអ្នកស្រុកពោលថា បពិត្រលោកម្ចាស់ សូម្បីកាលមុន ពួកអ្នកស្រុកបានអាស្រ័យទឹកនេះ ធ្វើស្រែមិនមែនឬ កាលនោះ គប្បីប្រាប់ដល់ពួកអ្នកស្រុកថា អ្នកស្រុកពួកនោះ គាត់បានធ្វើឧបការៈយ៉ាងនេះ និងយ៉ាងនេះដល់សង្ឃ និងបានប្រគេនកប្បិយកណ្ឌយ៉ាងនេះ ។ បើពួកអ្នកស្រុកពោលថា សូម្បីពួកខ្ញុំក៏នឹងប្រគេន ដូច្នេះ យ៉ាងនេះក៏គួរ ។

បើភិក្ខុអង្គខ្លះមិនយល់ ទទួលស្រះ ឬឲ្យសាងស្រះ ដោយអកប្បិយវោហារ ស្រះនោះ ពួកភិក្ខុមិនគួរបរិភោគប្រើប្រាស់ឡើយ ។ សូម្បីកប្បិយកណ្ឌដែលអាស្រ័យស្រះនោះបានមក ក៏ជាអកប្បិយដូចគ្នា ។ បើម្ចាស់របស់ ( ស្រះ ) កូនប្រុស និងកូនស្រីរបស់បុគ្គលនោះក្តី បុគ្គលណាមួយដទៃដែលកើតក្នុងវង្សរបស់បុគ្គលនោះក្តី ជ្រាបថា ភិក្ខុទាំងឡាយលះបង់ហើយ ទើបប្រគេនដោយកប្បិយវោហារជាថ្មី ស្រះនោះ គួរ ។ កាលវង្សត្រកូលរបស់បុគ្គលនោះដាច់សូន្យ បុគ្គលណាជាម្ចាស់របស់ជនបទនោះ អ្នកនោះរឹបយកហើយប្រគេនមកវិញ ដូចរាជមហេសី ព្រះនាមថា អនុឡាទេវីរឹបយកចំណែកទឹកដែលភិក្ខុក្នុងចិត្តលតាបព៌តមកហើយ ប្រគេនវិញដូច្នោះ យ៉ាងនេះ ក៏គួរ ។

ទោះធ្វើការកាយដីឡើង និងធ្វើទំនប់ស្រះថ្មី ក្នុងស្រះដែលទទួលទុក

ដោយអំណាចនៃទឹក ជាកប្បិយវោហារ រមែងគួរដល់ភិក្ខុដែលមានចិត្តបរិសុទ្ធ តែការដែលភិក្ខុឃើញពួកអ្នកស្រុកអាស្រ័យស្រះនោះ ធ្វើសន្ទូង នឹងតាំងកប្បិយការក មិនគួរ ។ បើពួកអ្នកស្រុកប្រគេនកប្បិយភណ្ឌឯង គួរទទួល បើពួកអ្នកស្រុកមិនប្រគេន មិនគួរទារ មិនគួរតឿន ។ ការដែលតាំងកប្បិយ-ការកក្នុងស្រះដែលទទួលទុកដោយអំណាចនៃបច្ច័យ គួរ ។ តែនឹងធ្វើការកាយដីឡើង និងធ្វើទំនប់ស្រះជាដើម មិនគួរ បើពួកកប្បិយការកធ្វើឯងប៉ុណ្ណោះ ទើបគួរកាលលជ្ជីភិក្ខុអ្នកឈ្លាស ប្រើពួកកប្បិយការកធ្វើការកាយដីឡើងជាដើម ស្រះទឹកនឹងជាកប្បិយ ព្រោះការទទួលក៏ពិត សូម្បីយ៉ាងនោះ ក៏ជាការបរិភោគមិនល្អ ដូចបិណ្ឌបាតដែលលាយថ្នាំពិស និងដូចភោជនដែលលាយអកប្បិយមំសៈ ដូច្នោះ ព្រោះកប្បិយភណ្ឌដែលលាយដោយវត្ថុដែលកើតអំពីប្រយោគរបស់ភិក្ខុជាបច្ច័យ ជាអកប្បិយដល់ពួកភិក្ខុទូទៅដូចគ្នា ។

បើមិនទាន់មានឱកាសដើម្បីទឹក ភិក្ខុនឹងចាត់ការចំពោះទឹកប៉ុណ្ណោះយ៉ាងនេះថា អ្នកចូរធ្វើដោយប្រការដែលទំនប់របស់ស្រះនឹងមាំទាំ ទប់ទឹកបានច្រើន គឺចូរធ្វើឲ្យទឹកជន់ឡើងប្រៀបប្រាំង ដូច្នេះ គួរ ។

## វិធីបដិបត្តិក្នុងពូជ និងផ្លែឈើដែលបានព្រោះអាស្រ័យស្រះ

ជនទាំងឡាយកំពុងរំលត់ភ្លើងត្រង់ជើងក្រាន ពោលថា ពួកអ្នកចូរបានឧទកកម្មមុនចុះ ឧបាសក ដូច្នេះក៏គួរ ។ តែបើពោលថា អ្នកចូរធ្វើសន្ទូង ហើយនាំមក មិនគួរ ។ បើភិក្ខុឃើញទឹកក្នុងស្រះច្រើនពេក ឲ្យធ្វើប្រឡាយបង្ហូរទឹកចេញអំពីចំហៀង ឬខ្នងស្រះ ឲ្យកាប់ព្រៃ ឲ្យធ្វើភ្លឺស្រែទាំងឡាយ មិន

កាន់ចំណែកប្រក្រតីក្នុងភ្លឺស្រែដើម កាន់យកចំណែកដែលលើស គិតគូរយក កហាបណៈថា អ្នកទាំងឡាយចូរឲ្យកហាបណៈប្រមាណប៉ុណ្ណេះ ក្នុងសន្ទូង ក្រៅរដូវកាល ឬក្នុងសន្ទូងថ្មីដែលមិនបានកំណត់ទុក ជាអកប្បិយដល់ភិក្ខុ គ្រប់អង្គ ។

ម្យ៉ាងទៀត ភិក្ខុណាមិនបានពោលថា ពួកអ្នកចូរភ្ជួរ ចូរសាប ព្រោះ ប៉ុន់ដីយ៉ាងនេះថា សម្រាប់ផ្ទៃដីប្រមាណប៉ុណ្ណេះក្តី មានចំណែកឈ្មោះ ប្រមាណប៉ុណ្ណេះក្តី កាលពួកអ្នកស្រែពោលថា ពួកខ្ញុំធ្វើសន្ទូងក្នុងចំណែក ផ្ទៃដីប៉ុណ្ណេះ សូមលោកម្ចាស់ទាំងឡាយ កាន់យកនូវចំណែកឈ្មោះប្រមាណ ប៉ុណ្ណេះ យកខ្សែ ឬឈើប្រត់វាស់ ដើម្បីកំណត់ប្រមាណផ្ទៃដីក្តី ឈររក្សា ត្រង់ទីលានក្តី ឲ្យជញ្ជូនចេញទៅអំពីលានក្តី ឲ្យរក្សាទុកក្នុងជង្រុកក្តី ផល ដែលកើតឡើងអំពីផ្ទៃដីនោះ ជាអកប្បិយដល់ភិក្ខុអង្គនោះប៉ុណ្ណោះ ។

បើពួកអ្នកស្រែទាំងឡាយ នាំកហាបណៈមក ពោលថា កហាបណៈ ទាំងនេះ ពួកខ្ញុំនាំមកដើម្បីសង្ឃ ហើយភិក្ខុអង្គណាមួយ ពោលថា អ្នកចូរនាំ សំពត់មកដោយកហាបណៈប៉ុណ្ណេះ ចូររៀបចំបបរជាដើម ដោយកហាបណៈ ប្រមាណប៉ុណ្ណេះ ដោយការសម្គាល់ថា សង្ឃមិនទទួលកហាបណៈ ទ្រព្យ ដែលពួកអ្នកស្រែនាំមក ជាអកប្បិយដល់ពួកភិក្ខុទូទៅ ។ សួរថា ព្រោះហេតុ អ្វី ឆ្លើយថា ព្រោះភិក្ខុបាត់បែងកហាបណៈ ។

បើពួកអ្នកស្រែនាំស្រូវមក ពោលថា ស្រូវនេះ ពួកខ្ញុំនាំមកដើម្បីសង្ឃ ហើយភិក្ខុអង្គណាមួយពោលថា ពួកអ្នកចូរនាំយកវត្ថុនោះ និងវត្ថុនេះ មក

ដោយស្រូវប្រមាណប៉ុណ្ណេះ ដោយន័យមុននោះឯង ទ្រព្យដែលពួកអ្នកស្រែនាំមក ជាអកប្បិយ ចំពោះភិក្ខុនោះប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះភិក្ខុចាត់ចែងស្រូវ ។

បើពួកអ្នកស្រែនាំយកអង្ករ ឬអបរណ្ណជាតិមកពោលថា ពួកខ្ញុំនាំទ្រព្យនេះមកដើម្បីសង្ឃ ។ ភិក្ខុអង្គណាមួយពោលថា ពួកអ្នកចូរនាំយកវត្ថុនេះនិងវត្ថុនេះ មកដោយអង្ករមានប្រមាណប៉ុណ្ណេះ ដោយន័យមុននោះឯង ទ្រព្យដែលពួកអ្នកស្រែនាំមក ជាកប្បិយដល់ភិក្ខុទាំងឡាយ ព្រោះហេតុអ្វី ព្រោះភិក្ខុចាត់ចែងអង្ករជាដើមដែលជាកប្បិយ ។ មិនត្រូវអាបត្តិ ព្រោះលក់ដូរ និងព្រោះប្រាប់កប្បិយការក ។

តែក្នុងគ្រាមុន ភិក្ខុមួយអង្គនៅឯចិត្តលតាបព៌ត បានធ្វើមណ្ឌល ( រូបព្រះចន្ទ ) ទុកលើផែនដី ក្បែរទ្វារសាលាមុខ ៤ ដើម្បីឲ្យកើតការយល់ដល់ពួកញោមវត្ត ដោយរំពឹងថា ឱហ្ន៎ ពួកញោមវត្ត គប្បីចៀននំប្រមាណប៉ុណ្ណេះដើម្បីសង្ឃ ក្នុងថ្ងៃស្អែកនេះ ។ អារាមិកជនអ្នកឈ្លាស ឃើញមណ្ឌលនោះហើយ បានធ្វើយ៉ាងនោះ ក្នុងថ្ងៃទី ២ កាលពួកអ្នកស្រុកវាយស្គរប្រជុំសង្ឃហើយ ទើបកាន់យកនំទៅ ប្រាប់ព្រះសង្ឃត្ថេរថា បពិត្រលោកម្ចាស់ ក្នុងកាលមុននេះ ពួកខ្ញុំមិនធ្លាប់បានឮឪពុកម្តាយ មិនធ្លាប់បានស្តាប់ជីដូន ជីតា ( និទានប្រាប់ហេតុការណ៍ ) យ៉ាងនេះឡើយ ។ លោកម្ចាស់អង្គណា បានធ្វើសញ្ញាត្រង់ទ្វារសាលាមុខ ៤ ដើម្បីប្រយោជន៍ដល់នំ ឥឡូវនេះ ចាប់ពីថ្ងៃនេះទៅ សូមលោកម្ចាស់ទាំងឡាយ ប្រាប់តាមការពេញចិត្ត

រាល់ៗអន្តចុះ ពួកខ្ញុំនឹងនៅជាផាសុក ព្រះមហាថេរៈត្រឡប់អំពីទីនោះភ្លាម ។ សូម្បីភិក្ខុមួយរូប ក៏មិនទទួលនំឡើយ ។ ក្នុងកាលមុន ភិក្ខុទាំងឡាយ រមែង មិនធាន់នំ ដែលកើតក្នុងអារាមនោះយ៉ាងនេះ ព្រោះដូច្នោះ

ភិក្ខុអ្នកមិនប្រមាទ មិនលះការបដិបត្តិដុសខាត់កិលេស មិន គប្បីធ្វើការឡេះឡោះ ដើម្បីប្រយោជន៍ដល់អាមិស សូម្បីក្នុង វត្ថុដែលជាកប្បិយ ដូច្នេះឯង ។

ម្យ៉ាងទៀត សូម្បីស្រះបោក្ខរណី ទំនប់ និងប្រឡាយជាដើម ក៏មាន ន័យដូចពោលទុកហើយ ក្នុងស្រះនេះដូចគ្នា ។ បើទាយកពោលថា ខ្ញុំប្រគេន ស្រែ ឬអារាមឯណាមួយ ដែលជាកន្លែងដាំដុះបុព្វន្នជាតិ អបរន្នជាតិ អំពៅ និងដូងជាដើម ភិក្ខុគប្បីបដិសេធថា មិនគួរ ហើយបដិបត្តិដោយន័យដូច ពោលហើយ ក្នុងស្រះនោះឯង ។ ក្នុងវេលាទាយកពោលដោយកប្បិយ វោហារថា ខ្ញុំប្រគេនដើម្បីប្រយោជន៍ដល់ការបរិភោគបច្ច័យ ៤ ភិក្ខុគួរទទួល បើទាយកពោលថា ខ្ញុំប្រគេនអារាម ប្រគេនព្រៃ គួរទទួល ។

បើពួកអ្នកស្រុក ភិក្ខុមិនបានបង្គាប់ទេ កាត់ដើមឈើក្នុងព្រៃនោះ ញុំាង អបរន្នជាតិជាដើមឲ្យដល់ព្រមហើយ ប្រគេនចំណែកដល់ភិក្ខុទាំងឡាយ ទោះ ទទួលក៏គួរ ។ ពួកអ្នកស្រុកមិនប្រគេន មិនគួរទារ មិនគួរតឿន ។

បើពួកអ្នកស្រុកនាំគ្នាភៀសខ្លួនទៅ ព្រោះអន្តរាយណាមួយ មនុស្ស ពួកដទៃធ្វើ ហើយមិនប្រគេនវត្ថុណាមួយ ដល់ភិក្ខុទាំងឡាយឡើយ គប្បី ហាមឃាត់ជនទាំងនោះ ។ បើពួកជនទាំងនោះពោលថា ក្នុងកាលមុនពួកអ្នក

ស្រុកបានធ្វើស្រែក្នុងទីនេះ មិនមែនឬ លំដាប់នោះ គប្បីប្រាប់ថា ពួកអ្នកស្រុកមុននោះ គេបានឲ្យកប្បិយកណ្ឌយ៉ាងនេះៗ ដល់សង្ឃ បើពួកអ្នកស្រុកនោះពោលថា សូម្បីពួកខ្ញុំក៏នឹងប្រគេនដូចគ្នា យ៉ាងនេះ គួរ ។

ពួកអ្នកស្រុកពោលសំដៅដល់ ទឹកដីដែលសាបព្រោះសន្ទូងកន្លែងខ្លះថា ខ្ញុំនឹងប្រគេនតំបន់ គួរ ។ តែភិក្ខុទាំងឡាយ មិនគួរបោះសសរ ឬដាក់ដុំថ្មដើម្បីកំណត់ព្រំប្រទល់ឯងឡើយ ព្រោះហេតុអ្វី ព្រោះធម្មតាផែនដី មានតម្លៃរាប់មិនបាន ភិក្ខុគប្បីត្រូវអាបត្តិបារាជិក សូម្បីដោយហេតុត្រឹមបន្តិចបន្តួច ។ តែគប្បីប្រាប់ពួកអារាមិកជនថា ព្រំរបស់ពួកយើងទៅដល់ទីនេះ ។ បើពួកអារាមិកជនកាន់យកហួសទៅ មិនត្រូវអាបត្តិ ព្រោះពោលដោយបរិយាយ ។ បើព្រះរាជា និងរាជអមាត្យជាដើមបោះបង្គោលឯង ហើយប្រគេនថា សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យ ៤ ចុះ ការប្រគេននោះ គួរដូចគ្នា ។

បើបុគ្គលណាមួយ ជីកស្រះខាងក្នុងដែនសីមា ឬលើកប្រឡាយទៅដោយកាត់ក្នុងជីវត្ត រមែងទម្លាយលានព្រះចេតិយ និង លានពោធិព្រឹក្សជាដើម គប្បីហាមឃាត់ ។ បើសង្ឃបានវត្ថុណាមួយ ហើយមិនឃាត់ ព្រោះជួន់ក្នុងអាមិស ភិក្ខុមួយអង្គហាម ភិក្ខុអង្គនោះប៉ុណ្ណោះជាអធិបតី ។ បើភិក្ខុមួយអង្គពោលថា ពួកអ្នកចូរជីកទៅ មិនហាម គឺជាបក្សពួករបស់អ្នកស្រុកទាំងនោះឯង សង្ឃហាមឃាត់ សង្ឃប៉ុណ្ណោះជាអធិបតី ។ ពិតហើយ ក្នុងសង្ឃកម្ម ភិក្ខុអង្គណាធ្វើកម្មជាធម៌ ភិក្ខុអង្គនោះជាធំ ។ បើបុគ្គលដែលត្រូវភិក្ខុហាមហើយ នៅតែចចេសធ្វើ គប្បីលុបដីប្រឡាយដែលគេជីកទុកខាង

ក្រោម ដោយអាចម៍ដីខាងក្រោម កាយអាចម៍ដីខាងលើ លុបខាងលើឲ្យពេញ ។

ព្រះមហាសុមត្ថេរ ពោលថា បើបុគ្គលណានីមួយ បំណងនឹងប្រគេនអំពៅ ឬអបរន្នជាតិ ឬផ្លែរុក្ខជាតិវល្លិ៍ មានឃ្លោក និងត្រឡាចជាដើម តាមដែលកើតហើយនោះឯង ពោលថា ខ្ញុំប្រគេនចម្ការអំពៅ ចម្ការអបរន្នជាតិរណ្ដៅ ( សម្រាប់ដាំ ) ផ្លែរុក្ខជាតិវល្លិ៍ទាំងអស់នេះ ដូច្នេះ មិនគួរ ព្រោះបុគ្គលនោះប្រារព្ធព្រមនឹងវត្ថុ ( គឺចម្ការ ) ។ ឯព្រះមហាបទុមត្ថេរពោលថា នុ៎ះគ្រាន់តែជាវោហារប៉ុណ្ណោះ ព្រោះទឹកដីនោះនៅជារបស់ពួកម្ចាស់ទ្រព្យនោះឯង ព្រោះហេតុនោះ ទើបគួរ ។

## អធិប្បាយ ក្នុងទាសៈ អារាមិកជន និងបសុសត្វ

ទាយកពោលថា ពួកខ្ញុំប្រគេនទាសៈ ការប្រគេននោះមិនគួរ ។ បើទាយកពោលថា ខ្ញុំប្រគេនញោមវត្ត ប្រគេនវេយ្យាវច្ចៈ ប្រគេនកប្បិយការក ដូច្នេះទើបគួរ ។ បើអារាមិកជននោះ ធ្វើការងាររបស់សង្ឃប៉ុណ្ណោះទាំងមុនភត្ត និងក្រោយភត្ត ភិក្ខុគប្បីធ្វើការព្យាបាល ដោយថ្នាំគ្រប់យ៉ាងដល់បុគ្គលនោះ ដូចគ្នានឹងសាមណេរដែរ បើបុគ្គលនោះធ្វើការងាររបស់សង្ឃមុនភត្តតែមួយចំណែក ខាងក្រោយភត្តទៅ ធ្វើការងាររបស់ខ្លួន មិនគប្បីឲ្យអាហារក្នុងវេលាល្ងាច ។ សូម្បីជនពួកណា ធ្វើការងាររបស់សង្ឃតាមវារៈ ៥ ថ្ងៃ ឬតាមវារៈបក្ខ ក្នុងវេលាដ៏សេស បែរជាទៅធ្វើការងាររបស់ខ្លួន គប្បីឲ្យភត្ត និងអាហារ ដល់បុគ្គលនោះក្នុងវេលាធ្វើប៉ុណ្ណោះ បើការងាររបស់

សង្ស័យមិនមាន ពួកបុគ្គលនោះធ្វើការងាររបស់ខ្លួនឯងចិញ្ចឹមជីវិត បើពួកបុគ្គលនោះនាំយកមូលតម្លៃហត្ថកម្មមកប្រគេន គប្បីទទួល ។ បើពួកគេមិនប្រគេន ក៏មិនគប្បីពោលវាចាណាមួយឡើយ ។ ការទទួលទាសៈជាងជ្រលក់សំពត់ក្តី ទាសៈជាងតម្បាញឯណាមួយក្តី ដោយឈ្មោះថា អារាមិកជន គួរ ។

បើពួកទាយកពោលថា ពួកខ្ញុំប្រគេនគោទាំងឡាយ ដូច្នេះ ភិក្ខុគប្បីហាមពួកគេថា មិនគួរ បើមានពួកអ្នកស្រុកសួរថា គោនេះ លោកម្ចាស់បានមកអំពីណា គប្បីប្រាប់គេថា ពួកបណ្ឌិតប្រគេនទុកដើម្បីប្រយោជន៍ដល់ការបរិភោគបញ្ចគោរស បើពួកអ្នកស្រុកពោលថា សូម្បីពួកខ្ញុំក៏ប្រគេនដើម្បីប្រយោជន៍បរិភោគបញ្ចគោរស ដូច្នេះ គួរ ។ សូម្បីក្នុងបសុសត្វ មានមេពពែជាដើម ក៏មានន័យដូច្នេះ ។

ពួកអ្នកស្រុកពោលថា ពួកខ្ញុំប្រគេនដំរី សេះ ក្របី មាន់ ជ្រូក ដូច្នេះ ទទួល មិនគួរ ។ បើពួកអ្នកស្រុកខ្លះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយជាអ្នកខ្វល់ខ្វាយតិចចុះ ពួកខ្ញុំនឹងទទួលសត្វទាំងនេះ ហើយប្រគេនកប្បិយភណ្ឌដល់លោកម្ចាស់ទាំងឡាយ ហើយទទួលទុក រមែងគួរ ។ ទោះលែងចោលក្នុងព្រៃ ដោយពោលថា មាន់ និងជ្រូកទាំងនេះ ចូរទៅតាមសប្បាយចុះ ដូច្នេះ ក៏គួរ ។ កាលបុគ្គលពោលថា ពួកខ្ញុំប្រគេនស្រះនេះ ស្រែនេះ ចម្ការនេះដល់វិហារ ភិក្ខុនឹងបដិសេធមិនបានដូច្នេះឯង ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថរាក់ទាំងអស់ហើយ ដូច្នេះឯង ។

បណ្តាសមុដ្ឋានជាដើម ក្នុងសិក្ខាបទនេះ ក៏មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រាជសិក្ខាបទ ចប់

វគ្គទី ១ ចប់

# វិនយបិដក

## កោសិយវគ្គ សិក្ខាបទទី ១

[ ៧៤ ] *សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអគាឡវ-ចេតិយ ទៀបក្រុងអាឡវី ។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុចូលទៅរកពួកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរស្ងោរនាងទាំងឡាយឲ្យច្រើន នឹងឲ្យយើងខ្លះ យើងក៏ចង់ធ្វើសន្ថតលាយដោយសូត្រដែរ ។ ជនអ្នកធ្វើសូត្រទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមបើនឹងចូលទៅរកយើង ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរស្ងោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ពួកយើងណាធ្វើសត្វមានជីវិតតូចៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាស ព្រោះហេតុសេចក្តីចិញ្ចឹមជីវិតខ្លួន និងកូនប្រពន្ធ ពួកយើងទាំងនោះ ឈ្មោះថាមិនមានលាភផង ឈ្មោះថាបានទ្រព្យដោយអាក្រក់ផង ។ ភិក្ខុទាំងឡាយបានឮពាក្យជនអម្បាលនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងចូលទៅរកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ អ្នកទាំងឡាយចូរស្ងោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ។ ភិក្ខុទាំងឡាយនោះក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយចូលទៅរកពួកអ្នកធ្វើសូត្រ*

ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្វាវនាងឲ្យច្រើន នឹងឲ្យយើងខ្ចះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ពិតមែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន ។ ព្រះពុទ្ធ ដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនសមបើនឹងចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាល អ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរស្វារនាងឲ្យច្រើន នឹងឲ្យយើងខ្ចះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ម្នាលមោឃបុរសទាំងឡាយ អំពើ ដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង ។បេ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុ ណាមួយឲ្យគេធ្វើសន្ថតលាយដោយសូត្រ សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវ អាបត្តិបាចិត្តិយ ។

[ ៧៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ ក្នុងបារាជិកកណ្ឌរួចហើយ ។ គ្រឿងកម្រាលដែលមិនបានត្បាញ គេស្នាច់ សម្រេចតែម្តង ហៅថា សន្ថត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុលាយដោយ សរសៃសូត្រ សូម្បី ១ សរសៃ ហើយធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ត្រូវអាបត្តិ ទុក្កដក្នុងប្រយោគដែលធ្វើ សន្ថតដែលបានមកជានិស្សគ្គិយ ភិក្ខុត្រូវលះ ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ សន្ថតនោះ ភិក្ខុត្រូវលះយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតលាយដោយ

សូត្រនេះ ខ្ញុំឲ្យគេធ្វើ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថ័តនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៧៦ ] សន្ថ័តភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេច សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បីអ្នកដទៃត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[ ៧៧ ] អាបត្តិមិនមានដល់ភិក្ខុដែលធ្វើសំពត់ពិតានក្តី សំពត់កម្រាលលើទីដែលគេបូកលាបក្តី វនាំងក្តី ពូកក្តី ខ្នើយក្តី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ១

## កោសិយសិក្ខាបទ

[ ៧៤-៧៥ ] កោសិយសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងកោសិយសិក្ខាបទនោះ ដែលមានវិនិច្ឆ័យដូចតទៅនេះថា

[ ៧៥ ] ត្រើនបទថា **សន្ថរិត្វា កតំ ហោតិ** សេចក្ដីថា សន្ថតដែលក្រាលសរសៃសូត្រត្រួតៗ គ្នា លើផ្ទៃដែលរាបស្មើ ហើយយកបាយម៉ានជាដើមចាក់ចូលទៅ ហើយស្ងាច់ ។

ក្នុងបទថា **ឯកេនបិ កោសិយំសុនា មិស្សិត្វា** នេះ អ្នកសិក្សា គប្បីជ្រាបវិនិច្ឆ័យថា សន្ថតដែលលាយ ( សូត្រ ) ដោយអំណាចនៃការពេញចិត្តរបស់ខ្លួន ចូរលើកទុក សូម្បីឲ្យល់បក់យកសរសៃសូត្រមួយសរសៃ ទៅធ្លាក់ចុះក្នុងទីស្ងាច់សន្ថតនោះ យ៉ាងនេះ ក៏ឈ្មោះថា សន្ថតលាយ ( ដោយសូត្រ ) ដូចគ្នា ពាក្យដ៏សេសគ្រប់ៗ អន្ទើ មានអត្ថរាក់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ១១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កោសិយសិក្ខាបទទី ១ ចប់

# វិនយបិដក

## សិក្ខាបទី ២

[ ៧៨ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងកូដាគារសាលា ក្នុងមហាវន ទៀបក្រុងវេសាលី ។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈទាំងនេះ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមបើ នឹងឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ ដូចជាពួកគ្រហស្ថ ជាអ្នកបរិភោគកាមសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានប្រាថ្នាតិច ។បេ។ ភិក្ខុអម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធសោះ ។ ភិក្ខុអម្បាលនោះ ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយឲ្យគេធ្វើ សន្ថតដោយរោមចៀមខ្មៅសុទ្ធ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធទេ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នា ធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឲ្យគេ

ធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ៧៩ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា រោមចៀមខ្មៅ ( នោះសំដៅយក ) រោមចៀមខ្មៅទាំងពីរយ៉ាង គឺ រោមចៀមខ្មៅពីកំណើត ១ រោមចៀមខ្មៅពីគ្រឿងជ្រលក់ ១ ។ គ្រឿងកម្រាលដែលគេមិនត្បាញ គ្រាន់តែគេស្អាច់ ហើយធ្វើឲ្យសម្រេច ហៅថា សន្ថត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថតដែលបានមកជា និស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះខ្ញុំឲ្យគេធ្វើដោយរោមចៀមខ្មៅសុទ្ធ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ ។បេ។ សង្ឃត្រូវឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយត្រូវឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៨០ ] សន្ថតដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឲ្យសម្រេចដោយខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថតដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថតដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថតដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេច សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើសន្ថតខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បី

ប្រយោជន៍បុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសន្ថតដែលបុគ្គលដទៃធ្វើ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[ ៨១ ] អាបត្តិមិនមានដល់ភិក្ខុធ្វើសំពត់ពិតានក្តី គ្រឿងកម្រាលផែនដីក្តី នៅំងក្តី ពូកក្តី ខ្នើយក្តី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ២

## សុទ្ធកាឡកសិក្ខាបទ

[ ៧៨ ] *សុទ្ធកាឡកសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងសុទ្ធកាឡកសិក្ខាបទនោះ បទថា* **សុទ្ធកាឡកានំ** *សេចក្តីថា ខ្មៅសុទ្ធ គឺមិនលាយដោយរោមចៀមដទៃ ។ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងកោសិយសិក្ខាបទនោះឯង ។*

*សុទ្ធកាឡកសិក្ខាបទទី ២ ចប់*

# វិនយបិដក

## សិក្ខាបទទី ៣

[ ៨២ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានបុញ្ញសិរី ព្រះអង្គគង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមមិនឲ្យភិក្ខុប្រើគេឲ្យធ្វើសន្ថត់ដោយរោមចៀមខ្មៅសុទ្ធ ក៏នាំគ្នាប្រើគេឲ្យធ្វើសន្ថត់ដោយរោមចៀមខ្មៅសុទ្ធដូច្នោះ តែលាយរោមចៀមសបន្តិចត្រង់ជាយ ។ ភិក្ខុទាំងឡាយណា អ្នកមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោល តិះដៀល បន្ទះបន្ទាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងទៅឲ្យគេធ្វើសន្ថត់ដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយយករោមចៀមសលាយបន្តិចត្រង់ជាយប៉ុណ្ណោះទេ ។ គ្រានោះភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គមានព្រះបន្ទូលសួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកប្រើឲ្យគេធ្វើសន្ថត់ដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិចត្រង់ជាយពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសោះសូន្យ ហេតុដូចម្តេចបានជាពួកអ្នកឲ្យគេធ្វើសន្ថត់ដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិចត្រង់ជាយដូច្នោះ ម្នាលបុរសសោះសូន្យ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថាភិក្ខុកាលឲ្យគេធ្វើសន្ថត់ថ្មីគប្បីកាន់

យករោមចៀមខ្មៅសុទ្ធ ២ ភាគ រោមចៀមសភាគទី ៣ ( ១ ភាគ ) រោមចៀមក្រហមភាគទី ៤ ( ១ ភាគ ) ។ បើភិក្ខុឲ្យគេធ្វើសន្ថតថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធ ២ ភាគ រោមចៀមសភាគទី ៣ រោមចៀមក្រហមភាគទី ៤ ទេ សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ៨៣ ] សន្ថតដែលធ្វើជាដំបូង ហៅថា សន្ថតថ្មី ។ គ្រឿងកម្រាលដែលមិនបានត្បាញ គេស្មាច់សម្រេចតែម្តង ហៅថា សន្ថត ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ គឺធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ។ ពាក្យថា គប្បីកាន់យករោមចៀមខ្មៅសុទ្ធ ២ ភាគនោះ គឺភិក្ខុត្រូវថ្លឹងរោមចៀមខ្មៅសុទ្ធ ២ ជញ្ជីង ហើយសឹមកាន់យក ។ ពាក្យថា រោមចៀមសភាគទី ៣ នោះ គឺរោមចៀមសមួយជញ្ជីង ។ ពាក្យថា រោមចៀមក្រហមភាគទី ៤ នោះ គឺរោមចៀមក្រហមមួយជញ្ជីង ។ ពាក្យថា បើភិក្ខុឲ្យគេធ្វើសន្ថតថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធ ២ ភាគ រោមចៀមសភាគទី ៣ រោមចៀមក្រហមភាគទី ៤ គឺថា ភិក្ខុធ្វើឯងក្តី ប្រើឲ្យគេធ្វើក្តី នូវសន្ថតថ្មី មិនលាយរោមចៀមសមួយជញ្ជីង រោមចៀមក្រហមមួយជញ្ជីងទេ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ វេលាបានមក សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះខ្ញុំឲ្យគេធ្វើមិនបានលាយដោយរោមចៀមសមួយជញ្ជីង រោមចៀមក្រហមមួយជញ្ជីង ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៨៤ ] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ស្រេច ( គ្រាក្រោយ ) ឲ្យ

សម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើសន្ថ័តដោយខ្លួនឯងមិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកដទៃធ្វើសន្ថ័តមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកដទៃធ្វើសន្ថ័តមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេច សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីប្រយោជន៍ដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសន្ថ័តដែលអ្នកដទៃគេធ្វើហើយ យកមកប្រើប្រាស់ ក៏ត្រូវអាបត្តិទុក្កដ ។

[ ៨៥ ] អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថ័ត យករោមចៀមសមួយជញ្ជីង ( ១ ភាគ ) រោមចៀមក្រហម ១ ជញ្ជីង ( ១ ភាគ ) មិនមានដល់ភិក្ខុធ្វើសន្ថ័តដោយយករោមចៀមសច្រើន យករោមចៀមក្រហមច្រើនជាង កំណត់នោះ មិនមានដល់ភិក្ខុធ្វើសន្ថ័ត យករោមចៀមសសុទ្ធ ក្រហមសុទ្ធ មិនមានដល់ភិក្ខុយករោមចៀមធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជាវនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុ ជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ៣

## ទ្វេភាគសិក្ខាបទ

[ ៨២ ] ទ្វេភាគសិក្ខាបទ បទថា **នវេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងទ្វេភាគសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **អន្តេ អាទិ-យិត្វា** សេចក្តីថា ឲ្យបិទរោមចៀមពណ៌សទុកត្រង់ជាយនៃសន្ថត ដូចអនុវាត ត្រង់ជាយសំពត់ដូច្នោះ ។

[ ៨៣ ] ពីរបទថា **ទ្វេ ភាគា** ប្រែថា ពីរចំណែក ។

បទថា **អាទាតព្វា** ប្រែថា គប្បីកាន់យក ។

បទថា **គោចរិយានំ** ប្រែថា មានពណ៌ក្រហម ។

បទថា **ទ្វេ តុលា អាទាតព្វា** លោកពោលសំដៅយកភិក្ខុដែលបំណងនឹងធ្វើដោយរោមចៀម ៤ ចំណែក ។ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថាដោយអត្ថ គឺទ្រង់សម្តែងពាក្យនេះនោះឯងថា ភិក្ខុមានបំណងនឹងធ្វើដោយរោមចៀម មានប្រមាណប៉ុនណា ក្នុងរោមចៀមមានប្រមាណប៉ុណ្ណោះ រោមចៀមខ្មៅ ២ ចំណែក រោមចៀមស ១ ចំណែក រោមចៀមក្រហម ១ ចំណែក ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ហើយ ។

សូម្បីសមុដ្ឋានជាដើម ក៏ដូចកោសិយសិក្ខាបទនោះឯង ។ សិក្ខាបទនេះ អ្នកសិក្សាគប្បីជ្រាបថា ជាកិរិយា និងអកិរិយាតែម្យ៉ាង ព្រោះកាន់យក និងមិនកាន់យក ដើម្បីធ្វើដូច្នេះឯង ។

ទ្វេភាគសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ៨៦ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏គ្រានោះឯង ភិក្ខុទាំងឡាយ ឲ្យគេធ្វើសន្ថតរាល់ឆ្នាំ ។ ភិក្ខុទាំងនោះជាអ្នកអង្វរច្រើន ជាអ្នកសុំច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនគួរបើនឹងឲ្យគេធ្វើសន្ថតរាល់ឆ្នាំយ៉ាងនេះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ក៏ពួកយើងធ្វើសន្ថតម្តង ប្រើបាន ៥ ឆ្នាំខ្លះ ៦ ឆ្នាំខ្លះ ក្មេងរបស់យើងទាំងឡាយជុះដាក់ខ្លះ នោមដាក់ខ្លះ កណ្តុរកាត់ខ្លះ (ក៏គង់ប្រើបានយូរដល់ត្រឹមនោះ ) ចំណែកពួកសមណៈ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ទាំងនេះ ឲ្យគេធ្វើសន្ថតរាល់ៗ ឆ្នាំ សមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រនេះ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា អ្នកមានប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរបើនឹងឲ្យគេធ្វើសន្ថតរាល់ឆ្នាំឡើយ ពួកភិក្ខុទាំងនេះជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មា

ត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយឲ្យគេធ្វើ សន្ថតរាល់ឆ្នាំ ភិក្ខុទាំងឡាយជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ដូច្នេះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ឯបុរសសោះសូន្យទាំងនោះ មិនគួរបើនឹងឲ្យគេធ្វើសន្ថតរាល់ឆ្នាំឡើយ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសន្ថតថ្មី គប្បីប្រើប្រាស់ឲ្យដល់ ៦ ឆ្នាំ ។ បើប្រើប្រាស់មិនទាន់ដល់ ៦ ឆ្នាំទេ លះបោលក្តី មិនបានលះបោលក្តី នូវសន្ថតនោះ ហើយឲ្យគេធ្វើសន្ថតថ្មី ដទៃទៀត សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយហើយ ដោយប្រការដូច្នេះ ។

[ ៨៧ ] សម័យនោះឯង ភិក្ខុមួយរូបមានជំងឺឈឺ នៅក្នុងនគរកោសម្ពី ។ ពួកញាតិបានប្រើបម្រើទៅក្នុងសម្នាក់ភិក្ខុនោះ ដោយពាក្យថា សូមលោកដ៏ចម្រើន និមន្តមក យើងខ្ញុំទាំងឡាយនឹងទំនុកបម្រុង ។ ភិក្ខុទាំងឡាយ

ក៏បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅចុះ ពួកញាតិនឹងបាន ថែទាំលោក ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុឲ្យគេធ្វើសន្ថតថ្មី គប្បីប្រើប្រាស់ឲ្យដល់ ៦ ឆ្នាំ ក៏ខ្ញុំមានជំងឺ មិនអាចនឹងនាំយកសន្ថតទៅបាន ខ្ញុំលះសន្ថតចេញ ហើយ មិនសប្បាយទេ ( ហេតុនេះ ) ខ្ញុំមិនទៅទេ ។ ភិក្ខុទាំងឡាយ ក្រាបទូល ដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ព្រោះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយ ក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យសន្មត សម្មតិដល់ភិក្ខុឈឺ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីឲ្យដោយសន្មតសម្មតិ យ៉ាងនេះ ភិក្ខុឈឺនោះគប្បីចូលទៅរកសង្ឃ គ្រងចីវរឆៀងស្មាម្ខាង ហើយ ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីពោល យ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាមានជំងឺ មិនអាច នឹងនាំយកសន្ថតទៅផងបានទេ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមសន្មតសម្មតិនឹងសង្ឃ ។ ភិក្ខុឈឺនោះគប្បីសូមសម្មតិអស់វារៈ ២ ដងផង គប្បីសូមសម្មតិអស់វារៈ ៣ ដងផង ។ ភិក្ខុអ្នកឈ្លាសអង់អាច គប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចកាន់យកសន្ថតទៅផងបានទេ ។ ភិក្ខុនោះ សូមសន្មតសម្មតិនឹងសង្ឃ ។ បើការសន្មតសន្ថតនេះ មានកាលដ៏សមគួរដល់ សង្ឃហើយ សង្ឃគប្បីឲ្យសន្មតសម្មតិដល់ភិក្ខុឈ្មោះនេះ ។ នេះជាវាចា

ប្រកាសឲ្យសង្ឃដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចកាន់យកសន្ថតទៅផងបាន ។ ភិក្ខុឈឺនោះ សូមសន្ថតសម្មតិនឹងសង្ឃ ។ សង្ឃឲ្យការសន្មតសន្ថតដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យសន្មតសន្ថតដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ សង្ឃបានឲ្យការសន្មតសន្ថតដល់ភិក្ខុឈ្មោះនេះហើយ ។ ការសន្មតសន្ថតនេះគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ ។ ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសន្ថតថ្មី គប្បីប្រើប្រាស់ឲ្យអស់ ៦ ឆ្នាំ ។ បើមិនទាន់ដល់ ៦ ឆ្នាំទេ លះបោលសន្ថតនោះក្តី មិនលះបោលក្តី ហើយឲ្យគេធ្វើសន្ថតថ្មីដទៃទៀត វៀរលែងតែភិក្ខុបានសម្មតិ ( អំពីសង្ឃ ) សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[ ៨៨ ] សន្ថតដែលទើបនឹងធ្វើ ហៅថា សន្ថតថ្មី ។ គ្រឿងកម្រាលដែលគេគ្រាន់តែស្មាច់ មិនបានត្បាញ ហៅថា សន្ថត ។ ត្រង់ពាក្យថា ឲ្យគេធ្វើនោះ គឺធ្វើឯង ឬឲ្យគេធ្វើ ។ ពាក្យថា គប្បីប្រើប្រាស់ឲ្យអស់ ៦ ឆ្នាំ គឺគប្បីប្រើប្រាស់យ៉ាងច្រើនត្រឹម ៦ ឆ្នាំ ។ ពាក្យថា បើមិនទាន់ដល់ ៦ ឆ្នាំទេ គឺថយពី ៦ ឆ្នាំចុះមក ។ ពាក្យថា លះបោលសន្ថតនោះក្តី គឺបានឲ្យសន្ថតនោះទៅអ្នកដទៃ ។ ពាក្យថា មិនលះបោលក្តី គឺ មិនបានឲ្យដល់អ្នកណានីមួយ ។ ពាក្យថា

វៀរលែងតែភិក្ខុដែលបានសម្មតិ ( អំពីសង្ឃ ) គឺ លើកលែងនូវភិក្ខុដែលបានសម្មតិ ( អំពីសង្ឃ ) ។ ( កាលប្រើប្រាស់មិនទាន់គ្រប់ ៦ ឆ្នាំ ) ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី នូវសន្ថតដទៃថ្មីទៀត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថតនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះខ្ញុំឲ្យគេធ្វើថ្មី ( តែខ្ញុំប្រើប្រាស់សន្ថតចាស់ ) មិនទាន់ដល់ ៦ ឆ្នាំនៅឡើយ ( សន្ថតថ្មី ) ជានិស្សគ្គិយ ព្រោះគ្មានភិក្ខុសម្មតិ ខ្ញុំសូមលះនូវសន្ថតនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៨៩ ] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ហើយ ( គ្រាក្រោយ ) ទើបបង្ហើយដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ហើយ ឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុធ្វើបង្ហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ៩០ ] អាបត្តិមិនមានដល់ភិក្ខុប្រើប្រាស់សន្ថតចាស់ដល់ ៦ ឆ្នាំ ហើយធ្វើសន្ថតថ្មីទៀត មិនមានដល់ភិក្ខុប្រើប្រាស់សន្ថតចាស់លើសពី ៦ ឆ្នាំ ហើយធ្វើសន្ថតថ្មី មិនមានដល់ភិក្ខុធ្វើដោយខ្លួនឯង ឬឲ្យអ្នកដទៃធ្វើដើម្បីប្រយោជន៍ដល់អ្នកដទៃ មិនមានដល់ភិក្ខុបានសន្ថតដែលអ្នកដទៃធ្វើយកមកប្រើប្រាស់ មិនមានដល់ភិក្ខុយកសន្ថតធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូក

លាបក្តី ជាវនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុដែលបានសម្មតិ មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ៤ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ៤

## ឆព្វស្សសិក្ខាបទ

[ ៨៦ ] ឆព្វស្សសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលតទៅនេះ ពីរបទថា **ហទន្តិបិ ឩហទន្តិបិ** មានអត្ថដែលលោកពោលទុកថា ពួកក្មេងៗ ជុះដាក់ខ្លះ នោមដាក់ខ្លះខាងលើសន្ថតទាំងឡាយ ។

ព្រះបុស្សទេវត្ថេរពោលថា ភិក្ខុបានទទួលសម្មតិយ៉ាងនេះថា សន្ថតសង្ឃសន្មតឲ្យហើយដល់ភិក្ខុឈ្មោះនេះ រមែងបានដើម្បីធ្វើសន្ថតក្នុងទីដែលខ្លួនទៅដល់ អស់វេលាដែលរោគមិនទាន់ជា ។ បើភិក្ខុជារោគហើយ ត្រឡប់អាពាធទៀត ដោយរោគដើមនោះឯង បរិហារ ( ការគ្រប់គ្រង ) នោះឯងនៅរក្សានៅឡើយ មិនមានកិច្ចដែលនឹងត្រូវសន្មតជាថ្មីទៀតឡើយ ។

ចំណែកព្រះឧបតិស្សត្ថេរពោលថា អាពាធនោះកម្រើកឡើងក្តី អាពាធដទៃក្តី លោកបានឈ្មោះថា ជាអ្នកអាពាធមួយគ្រា គឺបានហើយនោះឯង មិនមានកិច្ចដែលនឹងត្រូវសន្មតជាថ្មី ។

បទថា **ឱរេន ចេ ឆន្នំ វស្សានំ** បានដល់ ក្នុងចំណែកខាងក្នុង គឺខាងក្នុង ។ តែក្នុងបទភាជនៈដើម្បីសម្តែងត្រឹមតែសង្ខ្យា ទើបត្រាស់ថា នៅខ្វះ ៦ ឆ្នាំ ។

[ ៩០ ] បទថា **អនាបត្តិ ឆព្វស្សានិ ករោតិ** សេចក្តីថា រមែងធ្វើសន្ថតក្នុងវេលាគ្រប់ ៦ ឆ្នាំបរិបូណ៌ ។ សូម្បីក្នុងបទទី ២ គប្បីឃើញអត្ថ

យ៉ាងនេះថា ធ្វើក្នុងវេលាលើស ៦ ឆ្នាំទៅ ។ សេចក្ដីពិត ភិក្ខុនោះនឹងធ្វើរហូត ៦ ឆ្នាំក៏ទេ ។ ពាក្យដ៏សេសមានអត្ថរាក់ទាំងអស់ហើយ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងកោសិយសិក្ខាបទនោះឯង តែសិក្ខាបទនេះ ជាកិរិយា និងជាអកិរិយា ដូច្នេះ ។

ឆព្វស្សសិក្ខាបទទី ៤ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ៩១ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីនឹងលាក់ខ្លួនសម្ងំបាន ៣ ខែ អ្នកណាមួយកុំគប្បីចូលទៅរកតថាគត លើកលែងតែភិក្ខុមួយរូប ដែលជាអ្នកនាំយកនូវបិណ្ឌបាតទៅឲ្យ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា ព្រះករុណា ព្រះអង្គ ភិក្ខុទីមួយមិនបានចូលមករកព្រះដ៏មានព្រះភាគក្នុងទីនេះជាប្រាកដ លើកលែងតែភិក្ខុមួយរូប ដែលជាអ្នកនាំយកបិណ្ឌបាតទៅថ្វាយ ។ ក៏វេលានោះឯង សង្ឃក្នុងក្រុងសាវត្ថី បានប្តេជ្ញាគ្នាថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគប្រាថ្នាដើម្បីនឹងបានសម្រាកព្រះអង្គនៅបាន ៣ ខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុមួយរូប ដែលជាអ្នកនាំយកបិណ្ឌបាត ទៅថ្វាយនោះ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះសម្តែងអាបត្តិបាចិត្តិយចេញ ។

[ ៩២ ] គ្រានោះ ភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុ ព្រមដោយបរិស័ទ បានចូលទៅគាល់សម្តេចព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ បានថ្វាយបង្គំគាល់ព្រះអង្គក្នុងទីដ៏សមគួរ សេចក្តីស្រុះស្រួលរាក់ទាក់មួយអន្លើដោយពួកអាគន្តុកភិក្ខុ នេះជាកិច្ចដែលព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់ប្រព្រឹត្តសន្សំទុកមកហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរពាក្យនេះ នឹងឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុថា ម្នាលឧបសេន

អ្នករាល់គ្នាល្មមអត់ទ្រាំបានដែរឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលដែរឬ អ្នករាល់គ្នាដើរផ្លូវឆ្ងាយមក មិនលំបាកទេឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមធន់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួល ម្យ៉ាងទៀត បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ ដើរផ្លូវឆ្ងាយមក មិនបានលំបាកទេ ។ ក៏សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ឧបសេនវង្គន្តបុត្រដ៏មានអាយុ អង្គុយជិតព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ បង្សុកូលទាំងឡាយ ជាទីគាប់ចិត្តរបស់អ្នកដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បង្សុកូល ទាំងឡាយ មិនជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គទេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ក៏អ្នកប្រព្រឹត្តបង្សុកូល ( នោះ ) ដើម្បីអ្វី ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ( ព្រោះ ) ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គប្រព្រឹត្តបង្សុកូល ខ្ញុំព្រះអង្គក៏ត្រូវប្រព្រឹត្តបង្សុកូលយ៉ាងនោះដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុយ៉ាងនេះថា ម្នាលឧបសេន បរិស័ទរបស់អ្នកនេះប្រកបដោយសេចក្តីជ្រះថ្លា ម្នាលឧបសេន អ្នកទូន្មានបរិស័ទដូចម្តេច ។ ឧបសេនភិក្ខុដ៏មានអាយុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រណា មកសូមឧបសម្បទានឹងខ្ញុំព្រះអង្គៗ រមែងប្រាប់កុលបុត្រនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល បើអ្នកនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូលដែរ ខ្ញុំនឹងឲ្យអ្នកបានឧបសម្បទា បើអ្នកណាទទួលស្តាប់

ខ្ញុំព្រះអង្គៗ នឹងឲ្យអ្នកនោះបានឧបសម្បទា បើអ្នកណាមិនទទួលស្តាប់ខ្ញុំព្រះអង្គៗបេ។ ខ្ញុំព្រះអង្គមិនឲ្យអ្នកនោះបានឧបសម្បទាទេ អ្នកណាសូមនិស្ស័យនឹងខ្ញុំព្រះអង្គៗ នឹងប្រាប់អ្នកនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល បើអ្នកនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូលដែរ ខ្ញុំនឹងឲ្យនិស្ស័យដល់អ្នក បើអ្នកណាទទួលស្តាប់ខ្ញុំព្រះអង្គៗ នឹងឲ្យនិស្ស័យដល់អ្នកនោះ បើមិនទទួលស្តាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឲ្យនិស្ស័យដល់អ្នកនោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរមែងណែនាំបរិស័ទដោយអាការយ៉ាងនេះឯង ។ ព្រះដ៏មានព្រះភាគត្រាស់ប្រទានពរសាធុការថា ឧបសេន ល្អហើយៗ ឧបសេនអ្នកណែនាំបរិស័ទល្អពិតហើយ ឧបសេន អ្នកដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថី ដែរឬទេ ។ ឧបសេនភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សង្ឃបានប្តេជ្ញាហើយក្នុងក្រុងសាវត្ថីថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាដើម្បីនឹងសម្ងំកម្រោកព្រះអង្គនៅអស់ ៣ ខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុមួយរូបអ្នកនាំយកបិណ្ឌបាតទៅថ្វាយ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃគប្បីឲ្យភិក្ខុនោះសម្តែងអាបត្តិបាចិត្តិយចេញ ។ ភិក្ខុឧបសេនក្រាបទូលថា បពិត្រព្រះអង្គចម្រើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយសេចក្តីប្តេជ្ញារបស់ខ្លួនខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្តទេម្យ៉ាងទៀត នឹងមិនដកចេញនូវសិក្ខាបទ ដែលទ្រង់បានបញ្ញត្តទុកហើយទេ

នឹងប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលទ្រង់បញ្ញត្តទុកមកហើយ ។ ព្រះមានព្រះភាគត្រាស់ថា ល្អណាស់ហើយឧបសេន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្តហើយ ម្យ៉ាងទៀត មិនត្រូវដកនូវសិក្ខាបទដែលតថាគតបញ្ញត្តហើយ ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលតថាគតបានបញ្ញត្តទុកហើយ ឧបសេន តថាគតបានបញ្ញត្តឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត និងប្រព្រឹត្តបង្សុកូលចូលទៅរកតថាគតតាមសប្បាយចុះ ។ ក៏គ្រានោះឯង ភិក្ខុច្រើនរូបឈរនៅជិតខ្លោងទ្វារខាងក្រៅ បាននិយាយគ្នាថា យើងទាំងឡាយ ត្រូវឲ្យលោកឧបសេនវង្គន្តបុត្រដ៏មានអាយុ សម្តែងអាបត្តិបាចិត្តិយចេញ ។ វេលានោះ ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុ ព្រមទាំងបរិស័ទ ក្រោកចេញចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ភិក្ខុទាំងនោះបាននិយាយពាក្យនេះនឹងឧបសេនវង្គន្តបុត្រដ៏មានអាយុក្នុងវេលានោះថា អាវុសោឧបសេន អ្នកដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីដែរឬ ។ ឧបសេនភិក្ខុបាននិយាយតបថា អាវុសោ ព្រះដ៏មានព្រះភាគក៏បានត្រាស់សួរខ្ញុំយ៉ាងនេះថា ម្នាលឧបសេន អ្នកបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សេចក្តីប្តេជ្ញាសង្ឃបានធ្វើហើយក្នុងក្រុងសាវត្ថីថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នានឹងសម្ងំសម្រាកព្រះអង្គនៅអស់ ៣ ខែ ភិក្ខុណាមួយ កុំគប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ លើកលែងតែភិក្ខុមួយរូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយប៉ុណ្ណោះ ភិក្ខុណាចូល

ទៅគាល់ព្រះដ៏មានព្រះភាគ ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះ សម្តែងអាបត្តិបាចិត្តិយចេញ ។ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយសេចក្តីប្រថ្នារបស់ខ្លួន ខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត នឹងមិនដកនូវពុទ្ធប្បញ្ញត្ត ដែលព្រះអង្គបានបញ្ញត្តទុកស្រេចហើយ នឹងប្រព្រឹត្តកាន់យក តាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតហើយថា ភិក្ខុទាំងឡាយណា ជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល ភិក្ខុទាំងឡាយនោះ ចូលទៅរកតថាគតតាមសប្បាយចុះ ។ គ្រានោះ ភិក្ខុទាំងនោះបានពោលថា ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុបានពោលពាក្យពិតមែន ភិក្ខុមិនត្រូវបញ្ញត្ត នូវសិក្ខាបទដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត មិនត្រូវដកនូវសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ។

[ ៩៣ ] ភិក្ខុទាំងឡាយបានឮ ( ដំណឹង ) ថា ឮថាព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត អ្នកប្រព្រឹត្តបង្សុកូលចូលទៅរកតថាគតតាមសប្បាយចុះ ។ ភិក្ខុទាំងនោះកាលប្រាថ្នានឹងឃើញព្រះដ៏មានព្រះភាគ ទើបលះបោលនូវសន្ថតទាំងឡាយ ហើយសមាទានអារញ្ញកង្គធុតង្គ បិណ្ឌបាតិកង្គធុតង្គ និងបង្សុកូលិកង្គធុតង្គ ។ លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកសេនាសនៈ ព្រមដោយភិក្ខុទាំងឡាយច្រើនរូប បានទតព្រះនេត្រឃើញនូវសន្ថតទាំងឡាយ ដែលពួកភិក្ខុ បោលរាត់រាយក្នុងទីនោះៗ លុះទតឃើញហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា

ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី ពួកអ្នកក៏លះបោលសន្ថ័តទាំងឡាយនេះក្នុងទីនោះៗ ។ ទើបភិក្ខុទាំងនោះក្រាបទូលព្រះដ៏មានព្រះភាគតាម ដំណើរទុំះ ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺ ដើម្បីសេចក្តីប្រពៃដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ដើម្បីនឹងសង្កត់សង្កិននូវបុគ្គលទាំងឡាយអ្នកមានគំនិតអាក្រក់ ១ ដើម្បីនៅសប្បាយនៃភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់ ១ ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយជាបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយដែលនឹងមានទៅខាងមុខ ១ ដើម្បីសេចក្តីជ្រះថ្លានៃបុគ្គលទាំងឡាយអ្នកមិនទាន់ជ្រះថ្លា ១ ដើម្បីញុំាងបុគ្គលអ្នកជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម ១ ដើម្បីសេចក្តីអនុគ្រោះដល់ព្រះវិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើសន្ថ័ត សម្រាប់ទ្រាប់អង្គុយ គប្បីយកសន្ថ័តចាស់មួយចំអាមព្រះសុគតដោយជុំវិញ ( មកផ្សំលាយនឹងសន្ថ័តថ្មី ) ដើម្បីនឹងធ្វើសន្ថ័តថ្មីនោះឲ្យខូចពណ៌ ។ បើភិក្ខុឲ្យគេធ្វើនិសីទនសន្ថ័តថ្មី មិនយកសន្ថ័តចាស់មួយចំអាមព្រះសុគតដោយជុំវិញ ( មកផ្សំលាយនឹងសន្ថ័តថ្មីទេ ) សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ៩៤ ] ដែលហៅថា និសីទនៈនោះ គឺកម្រាលដែលប្រកបដោយជាយ ។ ដែលហៅថា សន្ថ័តនោះ គឺកម្រាលដែលគេគ្រាន់តែស្មាច់ មិនបាន

ត្បាញ ។ ត្រង់ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯង ឬឲ្យគេធ្វើ ។ សន្ថតសូម្បីស្មៀក ម្តង សូម្បីដណ្តប់ម្តង ហៅថា សន្ថតចាស់ ។ ពាក្យថា គប្បីយកសន្ថត ចាស់មួយចំអាមព្រះសុគតដោយជុំវិញ ( មកលាយនឹងសន្ថតថ្មី ) ដើម្បីធ្វើ សន្ថតថ្មីនោះឲ្យខូចពណ៌ គឺថា ភិក្ខុត្រូវកាត់ ( សន្ថតចាស់ ) ជាវង់មូលក្តី ជា ៤ ជ្រុងក្តី ហើយយកមកលាតក្រាលលាយចុះ ក្នុងទីមួយ ឬសិតហើយ លាតក្រាលក្តី ដើម្បីធ្វើឲ្យជារបស់ខ្ជាប់ខ្ជួន ។ ពាក្យថា បើភិក្ខុមិនយកសន្ថត ចាស់មួយចំអាមព្រះសុគតដោយជុំវិញ ( មកលាយនឹងសន្ថតថ្មីទេ ) គឺថា ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី នូវសន្ថតសម្រាប់ទ្រាប់អង្គុយថ្មី មិនយកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែល ធ្វើ សន្ថតនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ។ ភិក្ខុគប្បីលះដល់ សង្ឃ ឬគណៈ ឬបុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាង នេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតសម្រាប់ទ្រាប់អង្គុយនេះ ខ្ញុំឲ្យ គេធ្វើមិនបានកាត់យកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៩៥ ] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងនៅមិនទាន់ហើយ ( គ្រាក្រោយ ) ធ្វើឲ្យហើយដោយខ្លួនឯងម្តងទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯង មិនទាន់ហើយ ឲ្យអ្នកដទៃបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃ ធ្វើមិនទាន់ហើយ ភិក្ខុធ្វើឲ្យហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។

អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។

[ ៩៦ ] អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថតថ្មី យកសន្ថតចាស់មួយចំអាមព្រះសុគតដោយជុំវិញមកលាយ មិនមានដល់ភិក្ខុកាលរកសន្ថតចាស់មិនបានមួយចំអាម ធ្វើលាយតែបន្តិច មិនមានដល់ភិក្ខុកាលរកសន្ថតចាស់បន្តិចមិនបានធ្វើមិនបានលាយ មិនមានដល់ភិក្ខុបានសន្ថតដែលអ្នកដទៃធ្វើ យកមកប្រើប្រាស់ មិនមានដល់ភិក្ខុធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជារនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា
# កោសិយវគ្គទី ២ សិក្ខាបទទី ៩
# និសីទនសន្ថតសិក្ខាបទ

និសីទនសន្ថតសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងនិសីទនសន្ថតសិក្ខានោះ ដែលមានវិនិច្ឆ័យដូចតទៅនេះថា ពីរបទថា **ឥច្ឆាមហំ ភិក្ខវេ** សេចក្តីថា បានឮថា ព្រះមានព្រះភាគទ្រង់មិនទតឃើញសត្វដែលគួរឲ្យត្រាស់ដឹងមួយណាឡើយ អស់កាលខាងក្នុង ៣ ខែនោះ ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះ ។ សូម្បីយ៉ាងនោះ ព្រះអង្គក៏ទ្រង់ធ្វើព្រះធម្មទេសនាដោយអំណាចនៃតន្តិបវេណី ។

ម្យ៉ាងទៀត ព្រោះទ្រង់បានរំពឹងយ៉ាងនេះថា កាលតថាគតធ្វើឱកាសពួនសម្ងំ ភិក្ខុទាំងឡាយ នឹងធ្វើកតិកាវត្តមិនជាធម៌ ឧបសេនៈនឹងទម្លាយកតិកាវត្តដែលមិនប្រពៃនោះ តថាគតនឹងជ្រះថ្លាជាមួយភិក្ខុនោះ ហើយអនុញ្ញាតឲ្យភិក្ខុទាំងឡាយចូលគាល់ បន្ទាប់មក ពួកភិក្ខុដែលបំណងនឹងសួរសុខទុក្ខតថាគតជាច្រើន នឹងសមាទានធុតង្គទាំងឡាយ ហើយតថាគតនឹងបញ្ញត្តសិក្ខាបទ ព្រោះសន្ថតដែលភិក្ខុទាំងនោះចោលរាត់រាយជាបច្ច័យ ។ ដូច្នោះទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ ក្នុងការពួនសម្ងំនេះ មានអានិសង្សច្រើនយ៉ាងនេះឯង ។

បទថា **សបរិសោ យេន ភគវា តេនុបសង្កមិ** សេចក្តីថា បានឮថា ព្រះថេរៈបានទទួលការតិះដៀលក្នុងខន្ធកសិក្ខាបទនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានវស្សាក្រោម ១០ មិនគប្បីឲ្យកុលបុត្របួសឡើយ ភិក្ខុណាបំបួស

ភិក្ខុនោះត្រូវអាបត្តិទុក្កដ ដោយន័យជាដើមយ៉ាងនេះថា ម្នាលមោឃបុរស ហេតុអ្វី អ្នកនៅជាបុគ្គលដែលអ្នកដទៃគួរទូន្មានប្រៀនប្រដៅ នឹងសម្គាល់ដើម្បីឲ្យឱវាទ ដើម្បីប្រៀនប្រដៅអ្នកដទៃ ទើបគិតថា ព្រះសាស្តា ទ្រង់អាស្រ័យបរិស័ទរបស់អញ ទ្រង់បានប្រទានការតិះដៀលដល់អញ ឥឡូវនេះអញនឹងញុំាងព្រះមានព្រះភាគឲ្យបន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ដោយព្រះភក្ត្របរិបូណ៌ ដោយអាការគ្រប់អន្លើ មានសិរី ដូចព្រះចន្ទ ១៥ កើតនោះឯង ហើយនឹងប្រទានសាធុការ ព្រោះអាស្រ័យបរិស័ទនោះឯង ជាកុលបុត្រមានហទយៈបរិសុទ្ធ ដើរផ្លូវកន្ទង់ទៅបានជាង ១០០ យោជន៍ បានដឹកនាំបរិស័ទ ជាបុគ្គលដែលភិក្ខុប្រមាណ ៥០០ អង្គ ចោមរោមហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគទៀត ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គីតិកាចារ្យពោលថា **សបរិសោ យេន ភគវា តេនុបសង្កមិ** ជាដើម ។ ពិតហើយ បុគ្គលណាមួយ មិនអាចនឹងឲ្យព្រះពុទ្ធទាំងឡាយប្រោសប្រាណដោយប្រការដទៃ ក្រៅអំពីវត្តសម្បត្តិនេះឡើយ ។

ពាក្យថា **ភគវតោ អវិទូរេ និសិន្នោ** សេចក្តីថា ភិក្ខុនោះជាអ្នកអស់សេចក្តីសង្ស័យ ព្រោះជាអ្នកបរិសុទ្ធដល់វត្តសម្បត្តិ ទើបអង្គុយក្នុងទីជិតព្រះមានព្រះភាគ ដូចសីហៈអង្គុយក្បែរគុហានៃភ្នំមាស ដូច្នោះ ។

បទថា **ឯតទវោច** សេចក្តីថា គឺព្រះមានព្រះភាគ ត្រាស់ពាក្យនេះដើម្បីលើករឿងរ៉ាវឡើង ។

ពាក្យថា **មនាបានិ តេ ភិក្ខុ បំសុកូលានិ** សេចក្តីថា ម្នាលភិក្ខុ

សំពត់បង្សុកូលទាំងនេះ ជាទីពេញចិត្តរបស់អ្នកឬ គឺអ្នកកាន់តាមការពេញចិត្ត តាមការគាប់ចិត្តរបស់ខ្លួនឬ ។

ដោយពាក្យថា **ន ខោ មេ ភន្តេ មណាបានិ** នេះ ភិក្ខុនោះរមែងសម្ដែងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានកាន់តាមការពេញចិត្ត តាមការគាប់ចិត្តរបស់ខ្លួនទេ គឺខ្ញុំព្រះអង្គជាអ្នកត្រូវឧបជ្ឈាយ៍ឲ្យកាន់ ដូចបុគ្គលត្រូវបង្គាប់ឲ្យកាន់ ដោយការប្រចាប់ក និងដោយការវាយត្រង់ក្បាល ដូច្នោះ ។

បទថា **បញ្ញាយិស្សតិ** សេចក្ដីថា នឹងជាអ្នកប្រាកដ គឺជាអ្នកមានឈ្មោះបោះសំឡេង ។ មានពាក្យអធិប្បាយថា នឹងប្រាកដក្នុងកតិកានោះ ។

ពាក្យថា **ន មយំ អប្បញ្ញត្តំ បញ្ញាបេស្សាម** សេចក្ដីថា យើងទាំងឡាយ ឈ្មោះថា ជាសាវក នឹងមិនបញ្ញត្តសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់មិនបានបញ្ញត្តទុក ។ ពិតហើយ វិស័យ គឺ ការបញ្ញត្តិសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្តក្ដី ដកសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយក្ដី ដោយន័យថា បាចិត្តិយ ទុក្កដជាដើមនេះ ជាពុទ្ធវិស័យ ។

ដោយបទថា **សមាទាយ** នេះ ឧបសេនភិក្ខុសម្ដែងថា យើងទាំងឡាយនឹងសមាទានសិក្ខាបទនោះៗ ហើយទទួលថា សាធុដោយល្អ ដូច្នេះហើយ នឹងសិក្សាក្នុងសិក្ខាបទទាំងពួង តាមដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុក។ ព្រះមានព្រះភាគ ទ្រង់មានព្រះទ័យប្រោសប្រាណហើយ ទ្រង់បានធ្វើសាធុការទៀត ដល់ឧបសេនភិក្ខុនោះថា សាធុ សាធុ ។

បទសន្ធិថា **អនុញ្ញាតាវុសោ** កាត់បទជា **អនុញ្ញាតំ អាវុសោ** ប្រែថា

( លោកដ៏មានអាយុទាំងឡាយ ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ) ។

បទថា **បិហាន្ត** ប្រែថា ធ្វើការសង្ស៊ែម ។

ពីរបទថា **សន្ថតានិ ឧជ្ឈិត្វា** សេចក្ដីថា លះបង់សន្ថតទាំងពួងហើយ ព្រោះជាអ្នកមានសេចក្ដីសម្គាល់ក្នុងសន្ថតថា ជាចីវរផ្ទាំងទី ៥ ។

ពាក្យថា **ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ** សេចក្ដីថា ព្រះមានព្រះភាគទតឃើញសន្ថតទាំងឡាយដេរដាស ហើយទ្រង់ព្រះតម្រិះថា មិនមានហេតុក្នុងការដែលនឹងញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ទៅ តថាគតនឹងសម្ដែងឧបាយក្នុងការប្រើប្រាស់ដល់ភិក្ខុទាំងនោះ ហើយទ្រង់ធ្វើធម្មីកថា ត្រាស់តឿនភិក្ខុទាំង-ឡាយ ។

ពាក្យថា **សកឹ និវត្ថំបិ សកឹ ចារុតំបិ** បានដល់ អង្គុយ និងដេកហើយម្ដង ។

បទថា **សាមន្តា** សេចក្ដីថា គប្បីកាន់យកដោយប្រការដែលខ្លួនកាត់យកជាវង្វង់ ឬជា ៤ ជ្រុងអំពីជាយម្ខាង មានប្រមាណ ១ ចំអាម ។ តែភិក្ខុកាលនឹងក្រាល គប្បីក្រាលចុះក្នុងឯកទេស ឬហែកចេញហើយ ក្រាលឲ្យផ្សំគ្នា ដោយន័យដូចពោលក្នុងព្រះបាលីនោះឯង ។ សន្ថតដែលភិក្ខុស្ងាច់ហើយយ៉ាងនេះ នឹងជារបស់មាំទាំក្រៃលែងឡើង ។ ពាក្យដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។ សមុដ្ឋានជាដើមនៃសិក្ខាបទនេះ ដូចគ្នានឹងទ្វេភាគ-សិក្ខាបទ ព្រោះទាំងជាកិរិយា ដូច្នេះឯង ។

និសីទនសន្ថតសិក្ខាបទ ចប់

ក្នុងសន្ថត ៥ ប្រភេទនេះ សន្ថត ៣ ប្រភេទខាងដើម អ្នកសិក្សាគប្បីជ្រាបថា ធ្វើវិនយកម្មហើយបានមក មិនគួរប្រើប្រាស់ ២ ប្រភេទខាងក្រោយធ្វើវិនយកម្មហើយបានមក ប្រើប្រាស់ គួរ ។

# វិនយបិដក

## សិក្ខាបទទី ៦

[ ៩៧ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏គ្រានោះឯង កាលភិក្ខុមួយរូប ចូលទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏បានរោមចៀមជាច្រើន ក្នុងពាក់កណ្តាលផ្លូវ ( ដោយទាយកប្រគេន ) ។ ភិក្ខុនោះក៏ចងវេចរោមចៀមទាំងឡាយនោះជាបង្វេចដោយឧត្តរាសង្គ ( ចីពរ ) ហើយទៅ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ នាំគ្នានិយាយចំអកថា ព្រះករុណា រោមចៀមព្រះករុណាទិញមកថ្លៃប៉ុន្មាន និងបានចំណេញប៉ុន្មាន ។ កាលមនុស្សទាំងឡាយនោះ និយាយចំអកដូច្នេះហើយ ភិក្ខុនោះក៏មានសេចក្តីអៀនខ្មាស ។ ភិក្ខុនោះទៅដល់ក្រុងសាវត្ថី ក៏ឈរទម្លាក់រោមចៀមទាំងនោះ ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឈរទម្លាក់ចោលនូវរោមចៀមទាំងនេះដើម្បីអ្វី ។ ភិក្ខុនោះនិយាយតបថា អាវុសោ ព្រោះហេតុតែរោមចៀមទាំងនេះ បានជាមនុស្សទាំងឡាយនាំគ្នានិយាយចំអកខ្ញុំ ហេតុនេះឯង ( ទើបខ្ញុំទម្លាក់ចោលចេញ ) ។ ភិក្ខុទាំងឡាយនោះសួរថា ម្នាលអាវុសោ លោកនាំយករោមចៀមទាំងនេះមកអំពីទីមានចម្ងាយប៉ុន្មាន ។ ភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំនាំរោមចៀមទាំងនេះមកអស់ទីឆ្ងាយជាង ៣ យោជន៍ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្ទុះបន្អាប់ថា ភិក្ខុមិនសមបើនឹងនាំយករោមចៀម មកអស់ទីឆ្ងាយជាង ៣ យោជន៍ដូច្នេះឡើយ ។ គ្រានោះ ភិក្ខុទាំងនោះក៏ក្រាបទូល

ដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងនាំយករោមចៀមមកឆ្ងាយជាង ៣ យោជន៍មែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគដំណើរនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស ហេតុដូចម្តេច បានជាអ្នកឯងនាំយករោមចៀមមកកាន់ចម្ងាយផ្លូវជាង ៣ យោជន៍ដូច្នេះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនញុំាងអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទយ៉ាងនោះថា រោមចៀមទាំងឡាយកើតឡើងដល់ភិក្ខុអ្នកដើរផ្លូវឆ្ងាយ កាលបើភិក្ខុប្រាថ្នា គប្បីទទួលយកបាន លុះទទួលហើយ បើមិនមានអ្នកនាំយកទៅឲ្យទេ គប្បីនាំយកទៅដោយដៃខ្លួនឯង កាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹម ៣ យោជន៍ កាលបើមិនមានអ្នកនាំយកទៅឲ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯង លើសពីកំណត់នោះទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[ ៩៨ ] ត្រង់ពាក្យថា ភិក្ខុដើរផ្លូវឆ្ងាយ គឺភិក្ខុអ្នកដើរទៅតាមផ្លូវ ។ ពាក្យថា រោមចៀមទាំងឡាយកើតឡើង គឺថា រោមចៀមទាំងឡាយកើតឡើងអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបង្សុកូលក្តី ដោយទ្រព្យរបស់ខ្លួនក្តី ។ ពាក្យថា កាលបើភិក្ខុប្រាថ្នា គឺថា កាលបើភិក្ខុចង់បាន ត្រូវទទួលយកបាន ។ ពាក្យថា លុះទទួលហើយ គប្បីនាំទៅដោយដៃខ្លួនឯងកាន់ចម្ងាយផ្លូវយ៉ាងច្រើន ៣ យោជន៍ គឺថា ភិក្ខុគប្បីនាំទៅដោយដៃខ្លួនឯង

ត្រឹម ៣ យោជន៍យ៉ាងច្រើន ។ ពាក្យថា បើមិនមានអ្នកនាំយកទៅឲ្យ គឺគ្មានអ្នកដទៃទីមួយ ស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី នាំយកទៅឲ្យ ពាក្យថា កាលបើមិនមានអ្នកនាំយកទៅឲ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯងលើសពីកំណត់នោះទៅ គឺថា ភិក្ខុឈានជំហានទី ១ ឲ្យលើសអំពី ៣ យោជន៍ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យលើសទៅ រោមចៀមទាំងនោះជានិស្សគ្គិយ កាលភិក្ខុឋិតនៅក្នុងខាងក្នុង ៣ យោជន៍ តែបោលរោមចៀមឲ្យធ្លាក់ចុះខាងក្រៅ ៣ យោជន៍ រោមចៀមទាំងនោះក៏ជានិស្សគ្គិយ ភិក្ខុដាក់ចុះនូវរោមចៀមក្នុងយានក្តី ក្នុងបង្វេចក្តីនៃអ្នកដទៃ គេមិនដឹង ឲ្យកន្លង ៣ យោជន៍ទៅ រោមចៀមទាំងនោះ ក៏ជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីលះយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន រោមចៀមទាំងឡាយនេះ ខ្ញុំបាននាំមកឲ្យលើសអំពី ៣ យោជន៍ទៅហើយ ជានិស្សគ្គិយ ខ្ញុំសូមលះនូវរោមចៀមទាំងឡាយនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ៩៩ ] ទីលើសអំពី ៣ យោជន៍ ភិក្ខុសម្គាល់ថា លើសមែន ហើយនាំរោមចៀមឲ្យលើសអំពី ៣ យោជន៍ទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទីលើសអំពី ៣ យោជន៍ ភិក្ខុសង្ស័យ ហើយនាំរោមចៀមឲ្យលើសអំពី ៣ យោជន៍ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទីលើសអំពី ៣ យោជន៍ ភិក្ខុសម្គាល់ថា មិនទាន់លើស

ហើយនាំរោមចៀមឲ្យលើសអំពី ៣ យោជន៍ទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទីខ្វះអំពី ៣ យោជន៍ ភិក្ខុសម្គាល់ថា លើស ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ទីខ្វះអំពី ៣ យោជន៍ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ទីខ្វះអំពី ៣ យោជន៍ ភិក្ខុសម្គាល់ថា ខ្វះមែន មិនត្រូវអាបត្តិ ។

[ ១០០ ] អាបត្តិមិនមានដល់ភិក្ខុនាំយករោមចៀមទៅត្រឹម ៣ យោជន៍ មិនមានដល់ភិក្ខុនាំយកទៅថយអំពី ៣ យោជន៍ មិនមានដល់ភិក្ខុនាំយកទៅក្តី នាំត្រឡប់មកក្តីត្រឹម ៣ យោជន៍ មិនមានដល់ភិក្ខុប្រាថ្នាដើម្បីនឹងនៅ តែត្រូវទៅកាន់ទីមានចម្ងាយផ្លូវ ៣ យោជន៍ ហើយនាំយករោមចៀមទៅកាន់ទីដទៃចាកទីនោះ ( ភិក្ខុនាំរោមចៀមទៅក្នុងទីណាៗ មានចម្ងាយបីៗ យោជន៍ ហើយមិនបានប្រកបដោយកិច្ច មានឧទ្ទេស និងបរិបុច្ឆាជាដើម ឬដោយសក្ការៈ មានបច្ច័យជាដើមក្នុងទីនោះ ហើយនឹងនាំរោមចៀមចេញអំពីទីនោះទៅកាន់ទីដទៃៗ កំណត់ត្រឹមតែបីៗ យោជន៍ក៏បាន ដរាបដល់រយយោជន៍ក៏បាន ) មិនមានដល់ភិក្ខុត្រឡប់បានរោមចៀមដែលចោរលួចយកទៅ ហើយនាំយកទៅ មិនមានដល់ភិក្ខុត្រឡប់បានរោមចៀមដែលលះបង់ដោយវិន័យកម្ម ហើយនាំយកទៅ មិនមានដល់ភិក្ខុឲ្យអ្នកដទៃនាំយកទៅ មិនមានដល់ភិក្ខុនាំយករបស់ដែលធ្វើហើយ ( ធ្វើសម្រេចជា សំពត់កម្ពល ព្រំ និងសន្ថត ជាដើម ) មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ៦

## ឯឡកលោមសិក្ខាបទ

[ ៩៧ ] ឯឡកលោមសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងឯឡកលោមសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះ បទថា **ឧប្បណ្ឌេសុំ** សេចក្តីថា ពួកអ្នកស្រុកពោលពាក្យចំអន់ជាដើមថា បពិត្រលោកម្ចាស់ ( រោមចៀមនេះ ) លោកម្ចាស់ទិញមកដោយតម្លៃប៉ុន្មាន ។

[ ៩៧ ] ពីរបទថា **មិតកោវ អាសុម្ភិ** សេចក្តីថា ពួកអ្នកស្រុកជញ្ជូនបាច់ឧសដ៏ធំមកអំពីព្រៃ អស់កម្លាំងហើយ បោះចុះទៅ ទាំងដែលកំពុងឈរយ៉ាងណា ភិក្ខុនេះបានបោះ ( រោមចៀម ) ឲ្យធ្លាក់ចុះទៅ ដូច្នោះ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃឯឡកលោមសិក្ខាបទ

[ ៩៨ ] បទថា **សហត្ថា** ប្រែថា ដោយដៃខ្លួនឯង ។ មានពាក្យអធិប្បាយថា នាំទៅដោយខ្លួនឯង ។

ពីរបទថា **ពហិតិយោជនំ ចាតេតិ** សេចក្តីថា បោះចេញទៅខាងក្រៅ ៣ យោជន៍ ។ កាលរោមចៀមធ្លាក់ទៅដោយមិនមានអន្តរាយ លុះផុតអំពីដៃជានិស្សគ្គិយបាចិត្តិយដ៏ច្រើន តាមចំនួនសរសៃរោម ។ បើរោមចៀមដែលបោះទៅនោះប៉ះត្រង់ដើមឈើ ឬសសរខាងក្រៅ ៣ យោជន៍ ហើយខ្ទាតមកធ្លាក់ក្នុង ( ទី ៣ យោជន៍ ) ទៀត មិនត្រូវអាបត្តិ ។ បើបង្វេចរោមចៀម

ធ្លាក់ចុះដល់ផែនដី ឈប់ហើយរមៀលទៅ ត្រឡប់មកខាងក្នុង ( ៣ យោជន៍ ) ទៀត ត្រូវអាបត្តិពិត ។

ភិក្ខុឈរខាងក្នុង យកដៃ ឬជើង ឬឈើច្រត់ប្រមៀលទៅ បង្វេចរោមចៀម ទោះឈប់ក្ដី មិនឈប់ក្ដី រមៀលចេញទៅ ត្រូវអាបត្តិដូចគ្នា ។ ភិក្ខុទុកដោយតាំងចិត្តថា អ្នកដទៃនឹងនាំទៅ បើមានមនុស្សនោះនាំរោមចៀមទៅ ត្រូវអាបត្តិដូចគ្នា ។ រោមចៀមដែលភិក្ខុទុកដោយចិត្តបរិសុទ្ធ ខ្យល់បក់ទៅ ឬអ្នកដទៃធ្វើឲ្យធ្លាក់ទៅខាងក្រៅដោយធម្មតារបស់ខ្លួន ក៏ត្រូវអាបត្តិដូចគ្នា ។ ព្រោះភិក្ខុមានឧស្សាហ៍ និង ព្រោះសិក្ខាបទនេះជាអចិត្តកៈ ។ តែក្នុងកុរុន្ទីជាដើម ពោលអនាបត្តិទុក ព្រោះរោមចៀមដែលត្រូវខ្យល់បក់ទៅ ឬបុគ្គលដទៃធ្វើឲ្យធ្លាក់ទៅខាងក្រៅអំពីនេះ អនាបត្តិដែលលោកពោលទុកនោះ មិនសមជាមួយបាលីនៃអនាបត្តិវារៈ ។

ភិក្ខុធ្វើកញ្ចប់ទាំងសងខាងឲ្យជាប់តែមួយ កាលទុកឲ្យកញ្ចប់មួយនៅខាងក្នុងដែន កញ្ចប់មួយទៀតឲ្យនៅខាងក្រៅដែន នៅរក្សានៅឡើយ ។ សូម្បីក្នុងអំរែកដែលទាក់ទងជាមួយគ្នា ក៏មានន័យដូចគ្នានេះ ។ បើរោមចៀម ភិក្ខុគ្រាន់តែដាក់ទុកត្រង់ចុងដងរែក មិនបានចងឡើយ រមែងរក្សាអាបត្តិមិនបាន ។ កាលភិក្ខុផ្លាស់ប្ដូរ សូម្បីរោមចៀមដែលជាប់តគ្នាទៅដាក់ជំនួស ក៏ត្រូវអាបត្តិដូចគ្នា ។

ក្នុងបទថា **អញ្ញស្ស យានេ វា** នេះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុទុកលើយាន ឬលើខ្នងដំរីជាដើមដែលកំពុងទៅ ដោយតាំងចិត្តថា កាលម្ចាស់

របស់គេមិនដឹង វាទឹងនាំទៅឯង បើយានោះកន្លងហួស ៣ យោជន៍ មិនត្រូវអាបត្តិក្នាមឡើយ សូម្បីក្នុងយានដែលកំពុងឈប់ ក៏មានន័យយ៉ាងនេះដូចគ្នា ។ បើភិក្ខុទុករោមចៀមលើយាន ឬលើខ្នងដំរីជាដើម ដែលនៅស្ងៀម ហើយឡើងបរ ឬជិះទៅក្ដី ដេញពីក្រោយ ឬហៅឲ្យដើរតាមទៅក្ដី មិនត្រូវអាបត្តិ ព្រោះព្រះបាលីថា ភិក្ខុឲ្យអ្នកដទៃជួយនាំទៅ តែក្នុងកុរុន្ទីជាដើមពោលថា ត្រូវអាបត្តិ ។ ពាក្យនោះ មិនសមដោយពាក្យនេះថា ភិក្ខុឲ្យអ្នកដទៃជួយនាំទៅ ។ ក្នុងអដ្ឋកថានទានជាអាបត្តិ ព្រោះសុង្កឃាដ ( រំលងដែនគយ ) ។ ពិតហើយ អាបត្តិណា ក្នុងអដ្ឋកថានទាននោះ អាបត្តិនោះ ជាអនាបត្តិ ក្នុងសិក្ខាបទនេះ អាបត្តិណាក្នុងសិក្ខាបទនេះ អាបត្តិនោះ ជាអនាបត្តិ ក្នុងអដ្ឋកថានទាននោះ ។

ភិក្ខុទៅដល់ទីកន្លែងនោះ បញ្ជូនចិត្តទៅទីដទៃក្ដី ត្រូវពួកចោរជាដើមបៀតបៀន រំលងហួសទៅក្ដី ត្រូវអាបត្តិដូចគ្នា ។ គប្បីជ្រាបចំនួនអាបត្តិតាមចំនួនសរសៃរោមក្នុងឋានៈទាំងពួង ។

## អនាបត្តិនៃឯឡកលោមសិក្ខាបទ

[ ១០០ ] ប្រើនបទថា **តិយោជនំ វាសាធិប្បាយោ គន្ត្វា តតោ បរំ ហរតិ** សេចក្ដីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលនាំទៅ សូម្បីរាប់រយយោជន៍យ៉ាងនេះ គឺព្រោះមិនបានឧទ្ទេស និងបរិបុច្ឆាជាដើម ក្នុងទីដែលខ្លួនទៅហើយ ទើបភិក្ខុទៅក្នុងទីដទៃបន្តអំពីនោះ ទៅក្នុងទីដទៃសូម្បីអំពីទីនោះ ។

ពីរបទថា **អច្ឆិន្នំ បដិលភិត្វា** សេចក្ដីថា ពួកចោរដណ្ដើមយករោមចៀមនោះទៅ ដឹងថា មិនមានប្រយោជន៍ ហើយឲ្យមកវិញ មិនត្រូវអាបត្តិ

ដល់ភិក្ខុដែលនាំរោមចៀមនោះទៅ ។

ពីរបទថា **និស្សជ្ជំ បដិលភិត្វា** សេចក្តីថា បានរោមចៀមដែលធ្វើវិនយកម្មហើយឲ្យមកវិញ ។

បទថា **កតភណ្ឌំ** សេចក្តីថា រោមចៀមដែលគេធ្វើជារបស់ មានសំពត់កម្ពល ព្រំ និងសន្ថតជាដើមឯណាមួយ ដោយហោចសូម្បីត្រឹមតែចងដោយសរសៃអំបោះ ។ មយ៉ាងទៀត ភិក្ខុណា ស៊ករោមចៀមចូលក្នុងស្បោកបាត្រខ្ទះក្តី ក្នុងសំពត់ត្របោមក្បាលជង្គង់ក្តី សំពត់អង្សៈ និងវត្ថពន្ធចង្កេះជាដើមក្តី ក្នុងស្រោមកាំបិត ដើម្បីការពារច្រេះកន្ត្រៃជាដើមក្តី ដោយហោចអាពាធដោយខ្យល់ ស៊ករោមចៀមទុកក្នុងប្រហោងត្រចៀក ហើយដើរទៅមិនត្រូវអាបត្តិដល់ភិក្ខុនោះដូចគ្នា តែរោមចៀមដែលចងដោយអំបោះ ( ទុកក្នុងចន្លោះស្បែកជើង និងស្បោកបាត្រជាដើម ) រមែងតាំងនៅក្នុងឋានៈ នៃរោមចៀម ដែលធ្វើជារបស់របរ ។ ភិក្ខុធ្វើឲ្យជាផ្នួងសក់ ហើយនាំទៅ នេះឈ្មោះថា ជាលេសគេចវាង ប្រព្រឹត្តជាអាបត្តិដូចគ្នា ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

បណ្តាសមុដ្ឋានជាដើម ក្នុងឯឡកលោមសិក្ខាបទនេះ ឈ្មោះថា ឯឡកលោមសមុដ្ឋាន ( មានរោមចៀមជាដែនកើត ) រមែងកើតឡើងតាមកាយ ១ កាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឯឡកលោមសិក្ខាបទទី ៦ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ១០១ ] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ គ្រានោះឯង ពួកឆព្វគ្គិយប្រើនាងភិក្ខុនី ទាំងឡាយឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិត ឬត្រដោះខ្លះនូវរោមចៀមទាំងឡាយ ។ ភិក្ខុនីទាំងឡាយ កាល ( ធ្វើកិច្ច ) លាង ជ្រលក់ សិតនូវរោមចៀម ( ដូច្នោះ ) ទើបលះចោលនូវការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ គ្រានោះ នាងមហាបជាបតិគោតមីភិក្ខុនីចូលទៅគាល់ សម្តេចព្រះដ៏មានព្រះភាគ លុះចូលទៅហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយបានឋិតក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគមានបន្ទូល នឹងនាងមហាបជាបតិគោតមី ដែលកំពុងឋិតនៅក្នុងទីដ៏សមគួរយ៉ាងនេះថា នែព្រះនាងគោតមី នាងភិក្ខុនីទាំងឡាយជាអ្នកមិនប្រមាទ ជាអ្នកមានព្យាយាមដុតកម្តៅបាប ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែរឬទេ ។ ព្រះនាងមហាបជាបតិគោតមីទូលថា បពិត្រព្រះអង្គ ពួកនាងភិក្ខុនីមិនប្រមាទឯណាបាន លោកម្ចាស់ឆព្វគ្គិយទាំងឡាយ ប្រើពួកនាងភិក្ខុនីឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំងឡាយ កាលបើភិក្ខុនីទាំងឡាយមានរវល់ លាង ជ្រលក់ សិត នូវរោមចៀមទាំងឡាយ ( ដូច្នោះហើយ ) ទើបលះចោលការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ព្រះនាងមហាបជាបតិគោតមីឲ្យឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ។

គ្រានោះ ព្រះនាងមហាបជាបតិគោតមី កាលបើព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រោះនិទាននេះ គ្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំនូវភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ឆាក់ពួកភិក្ខុឆព្វគ្គិយថា នែភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ ប្រើពួកនាងភិក្ខុនីឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំងឡាយ ពិតមែនឬទេ ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែភិក្ខុទាំងឡាយ ពួកនាងភិក្ខុនីទាំងនោះជាញាតិរបស់អ្នកទាំងឡាយ ឬមិនមែនជាញាតិទេ ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនីទាំងនោះ មិនមែនជាញាតិទេ ។ ព្រះដ៏មាន-ព្រះភាគត្រាស់ថា នែមោឃបុរសទាំងឡាយ ជនទាំងឡាយដែលមិនមែនជាញាតិរមែងមិនដឹងនូវកម្មដ៏សមគួរ ឬមិនសមគួរ និងកម្មជាទីជ្រះថ្លា ឬមិនជាទីជ្រះថ្លានៃស្ត្រីទាំងឡាយ ដែលមិនមែនជាញាតិទេ នែមោឃបុរសទាំងឡាយ កាលបើអំពើ ដែលប្រកបដោយទោសយ៉ាងនេះ ពួកអ្នកក៏ហ៊ានប្រើភិក្ខុនីទាំងឡាយដែលមិនមែនជាញាតិឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំង-ឡាយ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់បុគ្គល ដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រើនាងភិក្ខុនីមិនមែនជាញាតិ ឲ្យលាងក្តី ឲ្យជ្រលក់ក្តី ឲ្យសិត ឬត្រដោះក្តី នូវរោមចៀម

ទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[ ១០២ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ភិក្ខុនីដែលមិនជាប់សាច់ញាតិអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូនៃជីដូនជីតា ជាគម្រប់ ៧ ត ឈ្មោះថា មិនមែនជាញាតិ ។ ស្រីបានឧបសម្បទាក្នុងឧភតោសង្ឃ[១] ឈ្មោះថា នាងភិក្ខុនី ។ ភិក្ខុបង្គាប់ថា នាងចូរលាង ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលលាងហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុបង្គាប់ថា នាងចូរជ្រលក់ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលជ្រលក់ហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុបង្គាប់ថា នាងចូរសិត ឬត្រដោះ ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលសិត ឬត្រដោះហើយ ជានិស្សគ្គិយ រោមចៀមដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីលះយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន រោមចៀមទាំងនេះ ខ្ញុំបានប្រើនាងភិក្ខុនីមិនមែនជាញាតិឲ្យលាងហើយ ជានិស្សគ្គិយ ខ្ញុំសូមលះរោមចៀមទាំងនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[ ១០៣ ] ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាងនូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ

---

១- បានដល់ សង្ឃ ២ ចំណែក គឺភិក្ខុសង្ឃ ១ ចំណែក ភិក្ខុនីសង្ឃ ១ ចំណែក ។

ហើយប្រើឲ្យលាង ឲ្យជ្រលក់ នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និង និស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និង និស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ ឲ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិ ទុក្កដ ២ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ នូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យលាង នូវរោមចៀមទាំងឡាយ ត្រូវ អាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើ ឲ្យជ្រលក់ ឲ្យសិត ឲ្យលាង នូវរោមចៀម ទាំងឡាយ ត្រូវអាបត្តិទុក្កដ ២ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត នូវរោមចៀមទាំងឡាយ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែន ញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យលាង នូវរោម ចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែន ញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យជ្រលក់ នូវ រោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិន

មែនញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យលាង ឲ្យជ្រលក់នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ ២ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ។បេ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ ។បេ។ ភិក្ខុប្រើភិក្ខុនីឲ្យលាងនូវរោមចៀមភិក្ខុដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើភិក្ខុនីដែលបានឧបសម្បទាអំពីឯកតោសង្ឃឲ្យលាង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ ។

[ ១០៤ ] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យភិក្ខុនីជាញាតិលាងរោមចៀម ស្រាប់តែមានភិក្ខុនីឯទៀតមិនមែនជាញាតិ ( មកកាន់យករោមចៀមអំពីដៃភិក្ខុនីនោះទៅលាងឲ្យ ) មិនមានដល់ភិក្ខុដែលមិនប្រើ ស្រាប់តែភិក្ខុនីមិនមែនជាញាតិ យករោមចៀមទៅលាងឲ្យ មិនមានដល់ភិក្ខុដែលប្រើភិក្ខុនីមិនមែនជាញាតិ ឲ្យលាងភណ្ឌៈដទៃ ដែលធ្វើហើយនៅមិនទាន់ប្រើប្រាស់ មិនមានដល់ភិក្ខុដែលប្រើនាងសិក្ខមានាឲ្យលាង មិនមានដល់ភិក្ខុដែលប្រើនាងសាមណេរីឲ្យលាង ( នូវរោមចៀមទាំងឡាយ ) មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា

# កោសិយវគ្គ សិក្ខាបទទី ៧

# ឯឡកលោមធោវាបនសិក្ខាបទ

[ ១០១ ] *ឯឡកលោមធោវាបនសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលតទៅថា បណ្ដាបទទាំងនោះ បទថា* **រេញ្ចន្តិ** *ប្រែថា រមែងលះ គឺ រមែងលះបង់ មានពាក្យអធិប្បាយថា រមែងមិនអាចដើម្បីប្រកបរឿយៗ ។*

*ពាក្យដ៏សេសក្នុងឯឡកលោមធោវាបនសិក្ខាបទនេះ ព្រមទាំងសមុដ្ឋានជាដើម មានន័យដូចពោលហើយ ក្នុងបុរាណចីវរសិក្ខាបទនោះឯង ។*

*ឯឡកលោមធោវាបនសិក្ខាបទទី ៧ ចប់*

# វិនយបិដក

## សិក្ខាបទទី ៨

[ ១០៥ ] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏មានបុណ្យសិរី ទ្រង់គង់ក្នុងអារាមវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្រ ជាជីតុនរបស់ត្រកូលមួយ ជាអ្នកទទួលភត្តជានិច្ច ។ ខាទនីយភ្គី ភោជនីយភ្គី ឯណាមួយ កើតឡើងក្នុងត្រកូលនោះៗ តែងបែងចំណែកអំពីនោះទុកឲ្យឧបនន្ទភិក្ខុសក្យបុត្រ ។ ក៏វេលានោះឯង ត្រកូលនោះបានសាច់មកក្នុងវេលាល្ងាច ។ ត្រកូលនោះ បានបែងចំណែកសាច់នោះ ទុកប្រគេនឧបនន្ទសក្យបុត្រដ៏មានអាយុ ។ ក្មេងតូចនៃត្រកូលនោះ ភ្ញាក់អំពីព្រលឹមហើយស្រែកយំទារសាច់ថា ឲ្យសាច់មកខ្ញុំ ។ បុរសប្តីនោះ ទើបនិយាយនឹងប្រពន្ធយ៉ាងនេះថា នាងចូរឲ្យចំណែកសាច់របស់លោកម្ចាស់ ដល់ក្មេងនេះទៅ យើងចាំទិញសាច់ដទៃប្រគេនលោកវិញ ។ វេលានោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់ដោយបាត្រចីវរ ក្នុងសម័យព្រឹកព្រហាមហើយដើរចូលទៅកាន់ត្រកូលនោះ លុះទៅដល់ហើយ បានអង្គុយលើអាសនៈដែលគេតាក់តែងបម្រុងទុក ។ បុរសនោះទើបចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឧបនន្ទសក្យបុត្រ ដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងឧបនន្ទសក្យបុត្រដ៏មានអាយុយ៉ាងនេះថា ព្រះករុណាខ្ញុំករុណាបានសាច់ក្នុងពេលល្ងាចម្សិលមិញ ខ្ញុំបានបែងចំណែកសាច់ នោះទុកប្រគេនលោកម្ចាស់ បពិត្រលោកម្ចាស់ ក្មេងតូចនេះភ្ញាក់អំពីព្រលឹម

ឡើង ស្រែកយំទារថា ឲ្យសាច់មកខ្ញុំ ខ្ញុំករុណាបានយកសាច់ចំណែករបស់លោកម្ចាស់ ឲ្យក្មេងតូចទៅហើយ ព្រះករុណា លោកម្ចាស់នឹងឲ្យខ្ញុំទិញអ្វីមកដោយកហាបណៈ ( នេះ ) ។ ឧបនន្ទដ៏មានអាយុសួរថា អាវុសោ អ្នកបរិច្ចាគកហាបណៈដល់អាត្មាឬ ។ បុរសនោះតបថា ព្រះករុណាលោកម្ចាស់ខ្ញុំករុណាបរិច្ចាគដល់លោកម្ចាស់ ។ ឧបនន្ទភិក្ខុនិយាយថា អាវុសោ អ្នកចូរប្រគេនកហាបណៈនោះដល់អាត្មាចុះ ។ បុរសនោះទើប ប្រគេនកហាបណៈទៅឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយពោលទោសតិះដៀល បន្ទោកបន្ទាបថា យើងទាំងឡាយទទួលរូបិយ ( បានដល់ មាស ប្រាក់ ) បាន យ៉ាងណា ពួកសមណសក្យបុត្រអម្បាលនេះ ក៏ទទួលរូបិយ បានយ៉ាងនោះដែរ ។ ភិក្ខុទាំងឡាយបានឮបុរសនោះពោលទោសតិះដៀល បន្ទោកបន្ទាបហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ រមែងពោលទោសតិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ ឧបនន្ទសក្យបុត្រដ៏មានអាយុមកទទួលយករូបិយ ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនេះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែឧបនន្ទ ឮថា អ្នកទទួលរូបិយពិតមែនឬទេ ។ ឧបនន្ទភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទើបទ្រង់ តិះដៀលថា នែមោឃបុរសអ្នកឯងមិនសមបើនឹងទទួលយករូបិយទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ឬធ្វើបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទទួលខ្លួនឯងក្តី

ប្រើគេឲ្យទទួលក្តី នូវមាសប្រាក់ឬមួយត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យ មាសប្រាក់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[ ១០៦ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ( លោហៈវិសេសមានពណ៌លឿង ) បើដូចជាពណ៌នៃព្រះសាស្តា ឈ្មោះថា មាស ។ កហាបណៈក្តី មាសកដែលធ្វើដោយជាតិលោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តី រមែងដល់នូវវោហារ ( គេចាយវាយបាន ) ហៅថា ប្រាក់ ។ ពាក្យថា ទទួលដោយខ្លួនឯង គឺកាន់យកដោយខ្លួនឯង មាសប្រាក់ដែលកាន់យកដោយខ្លួនឯងនោះ ជានិស្សគ្គិយ ។ ពាក្យថា ប្រើគេឲ្យទទួល គឺញុំាងអ្នកដទៃឲ្យកាន់យកមាសប្រាក់នោះ ជានិស្សគ្គិយ ។ ពាក្យថា ឬត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យនោះ សេចក្តីថា ភិក្ខុត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យដោយវាចាថា មាសប្រាក់នេះ ចូរជារបស់លោកម្ចាស់ចុះ មាសប្រាក់នោះ ជានិស្សគ្គិយ ។ មាសប្រាក់នោះ ភិក្ខុគប្បីលះក្នុងកណ្តាលនៃសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ ។ ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី ពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃចម្រើន ខ្ញុំបានទទួលនូវរូបិយៗ នេះខ្ញុំត្រូវលះបង់ ខ្ញុំសូមលះបង់នូវរូបិយនេះដល់សង្ឃ ។ ភិក្ខុលះហើយ គប្បីសម្តែងអាបត្តិចេញ ។ ភិក្ខុដែលឆ្លាសអង់អាច គប្បីទទួលដឹងនូវអាបត្តិ ។ បើញោមវត្តក្តី ឧបាសកក្តី មកក្នុងទីនោះ ភិក្ខុគប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹងនូវរូបិយនេះចុះ បើគេពោលថា លោកម្ចាស់

ឲ្យនាំយកនូវវត្ថុអ្វីមកដោយរូបិយនេះ ។ ភិក្ខុកុំគប្បីពោលថា អ្នកចូរនាំយកនូវរបស់នេះ ឬរបស់នេះមក ភិក្ខុគប្បីប្រាប់វត្ថុដែលគួរ គឺសប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅ ។ បើញោមវត្ត ឬឧបាសកអ្នកចាត់ការនោះ ផ្លាស់ប្តូររូបិយនោះ ហើយនាំយកវត្ថុដ៏គួរមក ភិក្ខុទាំងពួងគប្បីបរិភោគបានទាំងអស់ លើកលែងតែភិក្ខុអ្នកទទួលរូបិយមួយចេញ បើអ្នកចាត់ការនោះបានវត្ថុដែលគួរយ៉ាងនេះមក នេះជាការល្អ បើមិនបានទេ ភិក្ខុគប្បីពោលនឹងគេថា នែអ្នកដ៏មានអាយុ អ្នកចូរបោលរូបិយនេះទៅ ។ បើគេបោលរូបិយនោះទៅ នេះជាការល្អ បើគេមិនបោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ ( មួយរូប ) ប្រកបដោយអង្គ ៥ ជាអ្នកបោលនូវរូបិយ គឺភិក្ខុដែលមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ ស្គាល់នូវរូបិយដែលបោលហើយ ឬនៅមិនទាន់បោល ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសន្មតភិក្ខុជាអ្នកបោលរូបិយយ៉ាងនេះ ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ ( អ្នកបោលរូបិយ ) ជាមុន ។ ភិក្ខុអ្នកឆ្លាសអង់អាច លុះអង្វររួចហើយ ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកបោលនូវរូបិយ ។ នេះជាញត្តិ ដែលប្រកាសឲ្យសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវភិក្ខុឈ្មោះនេះឲ្យជាអ្នកបោល នូវរូបិយ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកបោលនូវរូបិយ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មាន

អាយុអន្ថណា លោកដ៏មានអាយុអន្ថនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកចោលនូវរូបិយហើយ ។ ការសន្មត គួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកម្មនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។ ភិក្ខុដែលសង្ឃសន្មតហើយនោះ មិនត្រូវកំណត់ទីហើយ ទើបចោលរូបិយនោះទេ ។ បើភិក្ខុនោះកំណត់ទីហើយ ទើបទម្លាក់ចោល ត្រូវអាបត្តិទុក្កដ ។

[ ១០៧ ] រូបិយ ភិក្ខុសម្គាល់ថា រូបិយមែន ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសង្ស័យហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ របស់មិនមែនរូបិយ ភិក្ខុសម្គាល់ថា ជារូបិយ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនរូបិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនរូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ មិនត្រូវអាបត្តិ ។

[ ១០៨ ] អាបត្តិមិនមានដល់ភិក្ខុដែលរើសយកដោយខ្លួនឯង ឬប្រើគេឲ្យរើសយកនូវរូបិយដែលធ្លាក់ចុះក្នុងអារាមក្តី ក្នុងលំនៅរបស់ខ្លួនក្តី ដោយគិតថា រូបិយនេះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា
## កោសិយវគ្គ សិក្ខាបទទី ៨
## រូបិយសិក្ខាបទ

[ ១០៥ ] *រូបិយសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងរូបិយសិក្ខាបទនោះ ដែលមានវិនិច្ឆ័យដូចតទៅនេះ បទថា* **បដិ-វិសោ** *ប្រែថា បែងចែក ។*

## អធិប្បាយ
## សិក្ខាបទវិភង្គនៃរូបិយសិក្ខាបទ

*ក្នុងបទថា* **ជាតរូបរជតំ** *នេះ បទថា* **ជាតរូប** *ជាឈ្មោះនៃមាស ក៏ព្រោះមាសនោះ ដូចគ្នានឹងឆវិវណ្ណនៃព្រះតថាគត ព្រោះដូច្នោះ ទើបលោកពោលទុកក្នុងបទភាជនៈថា លោកហៅព្រះឆវិវណ្ណរបស់ព្រះសាស្តា ។ អត្ថនៃបទភាជនៈនោះថា លោហៈវិសេស មានពណ៌ដូចព្រះឆវិវណ្ណរបស់ព្រះសាស្តានេះឈ្មោះថា* **ជាតរូប។** *ឯប្រាក់ លោកហៅថា* **រូបិយ** *ក្នុងពាក្យទាំងឡាយថា ស័ង្ខ សិលា កែវពពាល ប្រាក់ មាសជាដើម តែក្នុងសិក្ខាបទនេះ លោកបំណងយកកហាបណៈជាដើមឯណាមួយ ដែលឲ្យដល់ការចាយវាយបាន ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា* **រជតំ** *នោះ ទើបលោកពោលពាក្យថា កហាបណៈ លោហមាសក ដូច្នេះជាដើម ។*

*បណ្តាបទថា* **កហាបណោ** *ជាដើមនោះ កហាបណៈដែលគេធ្វើដោយមាសក្តី ធ្វើដោយប្រាក់ក្តី កហាបណៈធម្មតាក្តី ឈ្មោះថា* **កហាបណោ។**

មាសកដែលធ្វើដោយទន់ដែងជាដើម ឈ្មោះថា **លោហមាសក។**

មាសកដែលធ្វើដោយខ្លឹមឈើក្តី ដោយថ្នាំងឫស្សីក្តី ដោយហោចសូម្បី មាសកដែលគេធ្វើដោយស្លឹកត្នោត របទាជារូប ក៏ឈ្មោះថា មាសកឈើ មាសកដែលគេធ្វើដោយអាចម៍ល័ខក្តី ដោយជ័រក្តី ដំបំប៉ោងឲ្យកើតរូបផុសឡើង ឈ្មោះថា មាសកជ័រ ។

ដោយបទថា **យេ វោហារំ គច្ឆន្តិ** នេះ លោកសង្គ្រោះយកមាសកទាំងអស់ ដែលប្រើជាមាត្រាទិញលក់ក្នុងជនបទ ក្នុងវេលាទិញលក់គ្នា ដោយហោច ធ្វើដោយឆ្អឹងក្តី ធ្វើដោយស្បែកក្តី ធ្វើដោយគ្រាប់នៃផ្លែឈើក្តី ដំបំផុសឲ្យចេញជារូបក្តី មិនបានដំបំផុសឲ្យចេញជារូបក្តី ។ វត្ថុ ៤ យ៉ាង គឺប្រាក់ មាស ទាំងអស់នេះយ៉ាងនេះ ( និង ) មាសកមាស មាសកប្រាក់ មានប្រភេទដូចពោលហើយ ទាំងអស់នេះ ចាត់ជាវត្ថុនៃនិស្សគ្គិយ វត្ថុទាំងនេះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវពពាល ទទឹម កែវមក៌ត ធញ្ញជាតិ ៧ ប្រការ ទាសី ទាសា ស្រែ ចម្ការ អារាមផ្កាឈើ អារាមផ្លែឈើជាដើម ចាត់ជាវត្ថុនៃទុក្កដ ។ វត្ថុនេះ គឺអំបោះ ផាល ផ្ទាំងសំពត់ កប្បាសអបរន្នជាតិជាអនេកប្រការ និងភេសជ្ជៈ មានទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅជាដើម ចាត់ជាកប្បិយវត្ថុ ។

បណ្តានិស្សគ្គិយវត្ថុ និងទុក្កដវត្ថុនោះ ភិក្ខុទទួលនិស្សគ្គិយវត្ថុដើម្បីប្រយោជន៍ខ្លួនឯងក្តី ដើម្បីប្រយោជន៍ដល់សង្ឃក្តី គណៈ បុគ្គល និងចេតិយក្តី រមែងមិនគួរ ត្រូវនិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុដែលទទួលដើម្បីប្រយោជន៍

ខ្ទង់ឯង ។ ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលទទួលដើម្បីប្រយោជន៍ដល់វត្ថុដ៏សេស ត្រូវអាបត្តិទុក្កដតែម្យ៉ាងដល់ភិក្ខុដែលទទួលទុក្កដវត្ថុ ដើម្បីប្រយោជន៍គ្រប់យ៉ាង មិនត្រូវអាបត្តិក្នុងកប្បិយវត្ថុ ។ ត្រូវអាបត្តិបាចិត្តិយ ដោយអំណាចដែលមកក្នុងរតនសិក្ខាបទខាងមុខ ដល់ភិក្ខុដែលទទួលវត្ថុ មានប្រាក់ជាដើម ទាំងអស់ ដោយកិច្ចនៃភណ្ឌាគារិក ដើម្បីនឹងរក្សាទុក ។

## អធិប្បាយ អំពីការទទួលការប្រើឱ្យទទួល និងការបដិបត្តិក្នុងរូបិយ

បទថា **ឧគ្គណ្ហេយ្យ** ប្រែថា គប្បីកាន់យក ។ ព្រោះកាលភិក្ខុទទួលយក ទើបត្រូវអាបត្តិ ដូច្នោះ ទើបក្នុងបទភាជនៈនៃបទថា **ឧគ្គណ្ហេយ្យ** នោះ លោកពោលថា ភិក្ខុទទួលឯង ជានិស្សគ្គិយបាចិត្តិយ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យយ៉ាងនេះ ។

ក្នុងការទទួលឯង និងប្រើឲ្យទទួលនោះ មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិតែ ១ ដល់ភិក្ខុដែលទទួលឯង ឬប្រើឲ្យទទួលវត្ថុ ១ ក្នុងបណ្ដាកណ្ដុះគឺមាស ប្រាក់ កហាបណៈ និងមាសក ។ បើភិក្ខុទទួលឯងក្ដី ប្រើឲ្យទទួលក្ដី រាប់ពាន់យ៉ាងរួមគ្នា ត្រូវអាបត្តិដ៏ច្រើនតាមចំនួនវត្ថុ តែក្នុងមហាបច្ចរី និងកុរុន្ទីពោលរួមគ្នាថា ត្រូវអាបត្តិដោយរាប់របក្នុងថង់ដែលចងទុកជួរៗក្ដី ឬក្នុងភាជនៈដែលដាក់មិនពេញ ។ ចំណែកក្នុងថង់ដែលចងយ៉ាងណែន ឬភាជនៈដែលផ្ទុកពេញ ជាអាបត្តិតែ ១ ប៉ុណ្ណោះ ។

ចំណែកក្នុងការត្រេកអរនូវប្រាក់មាស ដែលគេទុកដាក់ មានវិនិច្ឆ័យ

ដូច្នេះ កាលបុគ្គលពោលថា នេះជារបស់លោកម្ចាស់ សូម្បីភិក្ខុត្រេកអរដោយចិត្ត ជាអ្នកប្រាថ្នាដើម្បីនឹងទទួលដោយកាយ និងវាចា តែបែរជាបដិសេធថា របស់នេះមិនគួរ មិនត្រូវអាបត្តិឡើយ សូម្បីឃាត់ដោយកាយ និងវាចា ជាអ្នកមានចិត្តបរិសុទ្ធ មិនត្រេកអរដោយគិតថា របស់នេះមិនគួរដល់អញឡើយ មិនត្រូវអាបត្តិដូចគ្នា ។ ពិតហើយ បណ្ដាទ្វារទាំង ៣ ដែលភិក្ខុឃាត់ហើយ ដោយទ្វារណាមួយ ឈ្មោះថា ឃាត់ហើយពិត ។ តែបើមិនឃាត់ដោយកាយ និងវាចា ទទួលដោយចិត្ត រមែងត្រូវអាបត្តិក្នុងកាយទ្វារ និងវចីទ្វារ មានការមិនធ្វើជាសមុដ្ឋាន ព្រោះមិនធ្វើការឃាត់ដែលខ្លួនគប្បីធ្វើដោយកាយ និងវាចា ។ តែឈ្មោះថា អាបត្តិតាមមនោទ្វារមិនមាន ។ បុគ្គលណាមួយដាក់ប្រាក់ និងមាសទាំងរយ ទាំងពាន់ទុកទៀបជើង ដោយពោលថា របស់នេះ សូមជារបស់លោកម្ចាស់ចុះ ។ ភិក្ខុឃាត់ថា របស់នេះមិនគួរ ឧបាសកក៏ពោលថា ខ្ញុំលះបង់ប្រគេនចំពោះលោកម្ចាស់ ហើយក៏ចៀសចេញទៅ ។ មានបុគ្គលដទៃមកក្នុងទីនោះ សួរថា នេះអ្វីលោកម្ចាស់ ភិក្ខុប្រាប់ពាក្យដែលឧបាសកនោះ និងខ្លួននិយាយគ្នា បើបុគ្គលនោះពោលថា ខ្ញុំទុកដាក់ឲ្យលោកម្ចាស់ សូមលោកម្ចាស់បង្ហាញទីទុក ។ ភិក្ខុគប្បីឡើងទៅកាន់ប្រាសាទដល់ជាន់ទី ៧ ហើយគប្បីប្រាប់ថា ទីនេះជាទីទុក តែកុំគប្បីប្រាប់ថា ចូរទុកក្នុងទីនេះ ។ អកប្បិយវត្ថុ ( មាស និងប្រាក់ជាដើម ) រមែងឈ្មោះថា អាស្រ័យវត្ថុដែលជាកប្បិយ និងអកប្បិយ តាំងនៅដោយពាក្យប្រាប់មានប្រមាណប៉ុណ្ណេះ គប្បីបិទទ្វារ ហើយថែរក្សា ។

បើឧបាសកកាន់យកបាត្រ និងចីវរ ដែលជារបស់លក់ដូរឯណាមក កាលបុគ្គលនោះពោលថា លោកម្ចាស់ត្រូវការវត្ថុនេះទេ គប្បីពោលថា ឧបាសក ពួកអាត្មាមានសេចក្ដីត្រូវការវត្ថុនេះ ហើយវត្ថុឈ្មោះនេះក៏មាន តែមិនមានកប្បិយការក ។ បើបុគ្គលនោះពោលថា ខ្ញុំនឹងជាកប្បិយការក សូមលោកម្ចាស់បើកទ្វារមកចុះ គប្បីបើកទ្វារ ហើយពោលថា តាំងនៅក្នុងឱកាសនោះ មិនគប្បីពោលថា អ្នកចូរកាន់យករបស់នេះ ។ សូម្បីយ៉ាងនេះ អកប្បិយវត្ថុ ឈ្មោះថា អាស្រ័យវត្ថុដែលជាកប្បិយ និងអកប្បិយ តាំងនៅដូចគ្នា ។ បើបុគ្គលនោះកាន់យកកហាបណៈនោះហើយ ប្រគេនកប្បិយភណ្ឌដល់លោក គួរ ។ បើបុគ្គលនោះកាន់យកច្រើនពេក គប្បីប្រាប់បុគ្គលនោះថា ពួកអាត្មា នឹងមិនយកភណ្ឌៈរបស់អ្នកទេ ចូររក្សាទុកវិញចុះ ។

ក្នុងបទថា **សង្ឃមជ្ឈេ និស្សជ្ជិតព្វំ** នេះ ព្រះមានព្រះភាគ ទ្រង់មិនត្រាស់ថា គប្បីលះដល់សង្ឃក្ដី គណៈក្ដី បុគ្គលក្ដី ព្រោះធម្មតា រូបិយជាអកប្បិយ ។ មួយាងទៀត ព្រោះរូបិយនោះ ត្រឹមតែភិក្ខុទទួលទុកប៉ុណ្ណោះ លោកមិនបានចាយវាយកប្បិយភណ្ឌណា ដោយរូបិយនោះ ដូច្នោះ ដើម្បីទ្រង់សម្ដែងការប្រើប្រាស់ដោយឧបាយ ទើបត្រាស់ថា គប្បីលះក្នុងជំនុំសង្ឃ ។

បទថា **កប្បិយំ អាចិក្ខិតព្វំ សប្បិ វា** សេចក្ដីថា គប្បីប្រាប់យ៉ាងនេះថា ឧបាសក ទឹកដោះថ្លាក្ដី ប្រេងក្ដី រមែងគួរដល់បព្វជិតទាំងឡាយ ។

បទថា **រូបិយបដិគ្គាហកំ ឋបេត្វា សព្វេហេវ បរិភុញ្ជិតព្វំ** សេចក្ដីថា ភិក្ខុទាំងអស់គប្បីចែកគ្នាបរិភោគ ។ ភិក្ខុដែលទទួលរូបិយ មិនគប្បី

ទទួលចំណែកដែលចែក សូម្បីបានចំណែកដែលឲ្យដល់ពួកភិក្ខុដទៃ ឬអារាមិកជន ហើយនឹងបរិភោគ ក៏មិនគួរ ។ ដោយហេាច ទឹកដោះថ្លាក្តី ប្រេងក្តី ដែលសត្វតិរច្ឆាន មានស្វាជាដើមលួចយកទៅអំពីចំណែកដែលចែកនោះទុកក្នុងព្រៃ ឬជ្រុះអំពីដៃរបស់សត្វទាំងនោះ នៅជារបស់តិរច្ឆានហួងហែងក្តី ជារបស់បង្សុកូលក្តី មិនគួរទាំងអស់ ។ សូម្បីនឹងអប់សេនាសនៈដោយទឹកអំពៅ ដែលបានមកអំពីចំណែកចែកនោះ ក៏មិនគួរ នឹងអុជប្រទីបដោយប្រេះ ឬប្រេង ហើយដេកក្តី ធ្វើកសិណាបរិកម្មក្តី អានគម្ពីរក្តី ដោយពន្លឺនៃប្រទីប ក៏មិនគួរ ម្យ៉ាងទៀត ទោះបីលាបដំបៅត្រង់រាងកាយដោយប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម អំពីចំណែកចែកនោះ ក៏មិនគួរដូចគ្នា ។

មនុស្សទាំងឡាយ យកវត្ថុនោះទិញគ្រែ និងតាំងជាដើមក្តី សាងឧបោសថាគារក្តី ធ្វើរោងឆាន់ក្តី នឹងបរិភោគប្រើប្រាស់ ក៏មិនគួរ ។ សូម្បីម្ទប់ ( នៃរោងឆាន់ជាដើម ) ដែលផ្សាយទៅតាមខេត្តរបស់ផ្ទះ ក៏មិនគួរ ។ ម្ទប់ដែលហួសដែនទៅ គួរ ព្រោះជារបស់ជ្រមក ។ និងដើរទៅតាមផ្លូវក្តី ស្ពានក្តី ទូកក្តី ក្បូនក្តី ដែលគេចំណាយវត្ថុនោះធ្វើ មិនគួរ នឹងផឹក ឬប្រើប្រាស់ទឹកដែលជន់ឡើងពេញមាត់ស្រះបោក្ខរណី ដែលគេជីកដោយវត្ថុនោះ ក៏មិនគួរ ។ តែកាលទឹកខាងក្នុង ( ស្រះ ) មិនមាន ទឹកដែលហូរមកថ្មី ឬទឹកភ្លៀងដែលហូរទៅ គួរ ។ សូម្បីទឹកដែលមកថ្មី ទិញមកព្រមគ្នានឹងស្រះបោក្ខរណីដែលទិញមក ( ដោយវត្ថុនោះ ) ក៏មិនគួរ ។

សង្ឃតាំងវត្ថុនោះជារបស់ធ្វើ ( ចងការ ) បរិភោគបច្ច័យ សូម្បីបច្ច័យ

ទាំងនោះ ក៏មិនគួរដល់លោក ។ សូម្បីអាហារដែលសង្ឃទទួល ( ដោយវត្ថុនោះ ) ក៏មិនគួរដើម្បីបរិភោគប្រើប្រាស់ ។ បើដីក្តី ពូជក្តី ជាអកប្បិយនឹងប្រើប្រាស់ក្តី ឬបរិភោគផ្លែ ក៏មិនគួរទាំងអស់ បើភិក្ខុទិញផ្ទៃដីតែម្យ៉ាងដាំពូជដទៃ បើបរិភោគផ្លែ គួរ ។ បើពូជ ភិក្ខុទិញមកដាំត្រង់ដី ដែលជាកប្បិយ បរិភោគផ្លែឈើ មិនគួរ អង្គុយ ឬដេកលើផ្ទៃដី គួរ ។

បទថា **សចេ សោ ឆឌ្ឌេតិ** សេចក្តីថា គេបោះចោលទៅក្នុងទីឯណាមួយ ។ បើបុគ្គលមិនចោលក្តី កាន់យកទៅឯងក្តី មិនគប្បីឃាត់បុគ្គលនោះឡើយ ។

បទថា **នោ ចេ ឆឌ្ឌេតិ** សេចក្តីថា បើបុគ្គលនោះមិនកាន់យកទៅនិងមិនចោល ចៀសចេញទៅតាមសេចក្តីប្រាថ្នា ដោយគិតថា ប្រយោជន៍អ្វីរបស់អញដោយការខ្វល់ខ្វាយនេះ ។ លំដាប់នោះ សង្ឃគប្បីសន្មតភិក្ខុដែលមានលក្ខណៈ តាមដែលព្រះមានព្រះភាគត្រាស់ទុកហើយ ឲ្យជាអ្នកចោលរូបិយ ។

## អត្ថនៃភិក្ខុអ្នកចោលរូបិយ

ក្នុងបទថា **យោ ន ឆន្ទាគតឹ** ជាដើម មានវិនិច្ឆ័យដូច្នេះថា ភិក្ខុដែលធ្វើវត្ថុនោះដើម្បីខ្លួន ឬលើកខ្លួនឡើងអាង ដោយអំណាចនៃការលោភ ឈ្មោះថា រមែងដល់នូវការលំអៀង ព្រោះស្រឡាញ់ កាលបៀតបៀនអ្នកដទៃដោយអំណាចនៃទោសៈថា ភិក្ខុនេះ មិនដឹងបែបបទឡើយ មិនដឹងវិន័យឈ្មោះថា រមែងដល់នូវការលំអៀងព្រោះទោសៈ ។ កាលដល់នូវភាពជាអ្នក

ភ្លេចភ្លាំង និងមិនមានស្មារតី ដោយអំណាចមោហៈ ឈ្មោះថា រមែងដល់នូវការលំអៀងព្រោះវង្វេង ។ កាលមិនអាចបោល ព្រោះខ្លាចភិក្ខុដែលទទួលរូបិយ ឈ្មោះថា រមែងដល់នូវការលំអៀងព្រោះខ្លាច ។ ភិក្ខុដែលមិនធ្វើយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រមែងមិនដល់នូវការលំអៀង ព្រោះស្រឡាញ់ ។បេ។ រមែងមិនដល់នូវការលំអៀងព្រោះខ្លាច ។

ពីរបទថា **អនិមិត្តំ កត្វា** បានដល់ មិនធ្វើឲ្យមានទីចំណាំ អធិប្បាយថា ភិក្ខុដែលបោលរូបិយនោះបិទភ្នែក ហើយមិនក្រឡេកមើល ដូចលាមកមិនកំណត់និមិត្តត្រង់ទីធ្លាក់ គប្បីបោលឲ្យធ្លាក់ទៅក្នុងស្ទឹង ក្នុងជ្រោះ ឬក្នុងគុម្ពឈើ ។ ក្នុងរូបិយដែលភិក្ខុគប្បីវៀរវៀសយ៉ាងនេះ ព្រះមានព្រះភាគក៏ត្រាស់ប្រាប់ដោយការបរិភោគប្រើប្រាស់ដល់ភិក្ខុទាំងឡាយ ដោយបរិយាយ ។ ការបរិភោគបច្ច័យដែលកើតឡើង អំពីរូបិយនោះ រមែងមិនសមគួរដល់ភិក្ខុដែលទទួលរូបិយ ដោយបរិយាយណាមួយឡើយ ។ ការបរិភោគបច្ច័យដែលកើតឡើងនេះ មិនគួរដល់ភិក្ខុដែលទទួលរូបិយនោះ យ៉ាងណា បច្ច័យដែលកើតឡើងព្រោះការអួតឧត្តរិមនុស្សធម្ម ដែលមិនមានពិតក្តី ព្រោះកុលទូសកកម្មក្តី ព្រោះការបោកបញ្ឆោតជាដើមក្តី រមែងមិនគួរដល់ភិក្ខុនោះ និងដល់ភិក្ខុដទៃ ដូច្នោះ សូម្បីបច្ច័យដែលកើតឡើងដោយធម៌ ដោយត្រឹមត្រូវ បើមិនបានពិចារណា ហើយបរិភោគ ក៏មិនគួរ ។

ពិតហើយ ការបរិភោគមាន ៤ យ៉ាង គឺថេយ្យបរិភោគ ( បរិភោគដូចចោរ ) ១ ឥណបរិភោគ ( បរិភោគមានបំណុល ) ១ ទាយជ្ជបរិភោគ

( បរិភោគដូចទទួលមត៌ក ) ១ សាមីបរិភោគ ( បរិភោគដូចម្ចាស់ទ្រព្យ ) ១ បណ្តាការបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់ភិក្ខុដែលទ្រុស្តសីលដែលអង្គុយបរិភោគ សូម្បីក្នុងជំនុំសង្ឃ ឈ្មោះថា ថេយ្យបរិភោគ ។ ការបរិភោគមិនបានពិចារណារបស់ភិក្ខុអ្នកមានសីល ឈ្មោះថា ឥណបរិភោគ ព្រោះដូច្នោះ ភិក្ខុអ្នកមានសីលគប្បីពិចារណាចីវរ គ្រប់ខណៈដែលបរិភោគ ប្រើប្រាស់ ។ បិណ្ឌបាត គប្បីពិចារណាគ្រប់ពំនូត ។ កាលមិនអាចធ្វើយ៉ាងនោះ គប្បីពិចារណាក្នុងកាលមុនឆាន់ ក្រោយឆាន់ បឋមយាម មជ្ឈិមយាម និងបច្ឆិមយាម ។ បើភិក្ខុមិនបានពិចារណា អរុណរះ រមែងតាំងនៅក្នុងឋានៈឥណបរិភោគនេះ ។ សូម្បីសេនាសនៈ ក៏គប្បីពិចារណាគ្រប់ៗ ខណៈដែលប្រើប្រាស់ ។ ការមានសតិជាបច្ច័យ ទាំងក្នុងខណៈទទួល ទាំងក្នុងខណៈបរិភោគភេសជ្ជៈ រមែងគួរ ។ បើមិនដូច្នោះ ក៏ត្រូវអាបត្តិដល់ភិក្ខុដែលធ្វើសតិក្នុងការទទួល មិនធ្វើក្នុងការបរិភោគតែម្យ៉ាង តែមិនត្រូវអាបត្តិដល់ភិក្ខុដែលមិនធ្វើសតិក្នុងការទទួល តែធ្វើសតិក្នុងវេលាបរិភោគ ។

សុទ្ធិមាន ៤ យ៉ាង គឺទេសនាសុទ្ធិ ( បរិសុទ្ធដោយការសម្តែង ) ១ សំវរសុទ្ធិ ( បរិសុទ្ធដោយសង្រួម ) ១ បរិយដ្ឋិសុទ្ធិ ( បរិសុទ្ធដោយការស្វែងរក ) ១ បច្ចវេក្ខណសុទ្ធិ ( បរិសុទ្ធដោយពិចារណា ) ១ ។ បណ្តាសុទ្ធិ ៤ យ៉ាងនោះ បាតិមោក្ខសំវរសីល ឈ្មោះថា ទេសនាសុទ្ធិ ។ បាតិ-មោក្ខសំវរសីលនោះ លោកហៅថា ទេសនាសុទ្ធិ ព្រោះបរិសុទ្ធដោយការសម្តែង ។ ឥន្ទ្រិយសំវរសីល ឈ្មោះថា សំវរសុទ្ធិ ។ ឥន្ទ្រិយសំវរសីល

នោះ លោកហៅថា សំវរសុទ្ធិ ព្រោះបរិសុទ្ធដោយការសង្រួម គឺការតាំងចិត្ត អធិដ្ឋានថា អាត្មាអញ នឹងមិនធ្វើយ៉ាងនេះទៀតឡើយ ។ អាជីវបារិសុទ្ធសីល ឈ្មោះថា បរិយេដ្ឋិសុទ្ធ ( ទីខ្លះជាបរិយេដ្ឋិសុទ្ធិក៏មាន ) ។ អាជីវបារិសុទ្ធសីល នោះ លោកហៅថា បរិយេដ្ឋិសុទ្ធិ ព្រោះជាការបរិសុទ្ធ ដោយការស្វែងរក របស់ភិក្ខុដែលលះអនេសនា ហើយញ៉ាំងបច្ច័យទាំងឡាយឲ្យកើតឡើងដោយ ធម៌ ដោយស្មោះស្មើ ។ បច្ចយបរិភោគសន្និស្សិតសីល ឈ្មោះថា បច្ចវេក្ខ-ណសុទ្ធិ ។ ពិតហើយ បច្ចយបរិភោគសន្និស្សិតសីលនោះ លោកហៅថា បច្ចវេក្ខណសុទ្ធិ ព្រោះបរិសុទ្ធដោយការពិចារណា ដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកដោយន័យជាដើមថា ភិក្ខុរមែងពិចារណាដោយឧបាយ ហើយសេព ចីវរ ដូច្នេះ ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា តែមិនត្រូវអាបត្តិដល់ភិក្ខុ ដែលមិនធ្វើសតិក្នុងការទទួល តែធ្វើសតិក្នុងការបរិភោគ ។ ការបរិភោគ បច្ច័យរបស់សេក្ខបុគ្គល ៧ ពួក ឈ្មោះថា ទាយជ្ជបរិភោគ ពិតហើយ សេក្ខបុគ្គល ៧ ពួកនោះ ជាឱរសរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើប ជាទាយាទនៃបច្ច័យ ដែលជារបស់ពុទ្ធបិតា បរិភោគនូវបច្ច័យទាំងនោះ ។

សួរថា សេក្ខបុគ្គលទាំងនោះ បរិភោគបច្ច័យរបស់ព្រះដ៏មានព្រះភាគ ឬបរិភោគបច្ច័យរបស់ពួកគ្រហស្ថ ឆ្លើយថា បច្ច័យទាំងនោះ សូម្បីពួក គ្រហស្ថឲ្យក៏ពិតហើយ តែឈ្មោះថា ជារបស់ព្រះមានព្រះភាគ ព្រោះព្រះមាន ព្រះភាគទ្រង់អនុញ្ញាត ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា សេក្ខបុគ្គលទាំង នោះ បរិភោគបច្ច័យរបស់ព្រះមានព្រះភាគ ។ ក្នុងធម្មទាយាទសូត្រ ជាគ្រឿង

សាធកៈក្នុងការបរិភោគបច្ច័យ របស់ព្រះមានព្រះភាគនេះ ។

ការបរិភោគរបស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា សាមីបរិភោគ ពិតហើយ ព្រះខីណាស្រពទាំងឡាយនោះ ឈ្មោះថា បរិភោគជាម្ចាស់ ព្រោះកន្លងភាពជាទាសៈនៃតណ្ហាបានហើយ ។ បណ្តាការបរិភោគទាំង ៤ យ៉ាងនេះ សាមីបរិភោគ និងទាយជ្ជបរិភោគ រមែងគួរដល់ភិក្ខុគ្រប់ជំពូក ។ ឥណបរិភោគ មិនសមគួរឡើយ ។ ក្នុងថេយ្យបរិភោគ មិនមានពាក្យពោលដល់ឡើយ ។

ការបរិភោគ មាន ៤ ដទៃទៀត គឺលជ្ជីបរិភោគ អលជ្ជីបរិភោគ ធម្មិយបរិភោគ អធម្មិយបរិភោគ ។ បណ្តាការបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អលជ្ជីភិក្ខុ រួមជាមួយលជ្ជីភិក្ខុ សមគួរ ។ មិនគប្បីកាត់អាបត្តិលោកឡើយ ។ ការបរិភោគរបស់លជ្ជីភិក្ខុ រួមនឹងអលជ្ជីភិក្ខុ រមែងគួរ អស់កាលដែលលោកមិនទាន់ដឹង ។ ព្រោះថា ធម្មតាភិក្ខុជាអលជ្ជីមកអំពីដំបូងមិនមាន ។ ព្រោះដូច្នោះ គប្បីស្តីថាលោកក្នុងវេលាដឹងថា លោកជាអលជ្ជីដោយពាក្យថា លោកធ្វើការល្មើសក្នុងកាយទ្វារ និងវចីទ្វារ ការធ្វើនោះ មិនសមគួរឡើយ លោកកុំធ្វើយ៉ាងនេះ ។ បើលោកមិនអើពើ នៅតែធ្វើទៀត បើនៅតែធ្វើការបរិភោគរួមជាមួយអលជ្ជីនោះ សូម្បីលោកក៏ក្លាយជាអលជ្ជីទៅដែរ ។ ឯភិក្ខុណា ធ្វើការបរិភោគរួមជាមួយអលជ្ជី ដែលជាភារៈរបស់ខ្លួនភិក្ខុនោះ ភិក្ខុដទៃឃើញហើយ គប្បីហាមប្រាម បើលោកមិនព្រមវៀរចាក សូម្បីភិក្ខុអង្គនេះក៏ជាអលជ្ជីដូចគ្នា អលជ្ជីភិក្ខុមួយអង្គ រមែងធ្វើឲ្យភិក្ខុទៅជា

អលជ្ជីបាន សូម្បីរាប់រយអន្លើយ៉ាងនេះ ។ ឈ្មោះថា អាបត្តិក្នុងការបរិភោគរួមគ្នារវាងអលជ្ជី និងអលជ្ជី រមែងមិនមាន ។ ការបរិភោគរួមរវាងលជ្ជី និងលជ្ជី ដូចគ្នានឹងខត្តិយកុមារ ២ អង្គ សោយរួមគ្នា ក្នុងសុវណ្ណភាជនៈ ។ ការបរិភោគជាធម៌ និងមិនជាធម៌ អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃបច្ច័យនោះឯង ។

ក្នុងការបរិភោគជាធម៌ និងមិនជាធម៌នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា បើបុគ្គលជាអលជ្ជី សូម្បីបិណ្ឌបាតក៏មិនជាធម៌ គួរវៀរសទាំង ២ ចំណែក ។ បុគ្គលជាអលជ្ជី តែបិណ្ឌបាតជាធម៌ ភិក្ខុទាំងឡាយវៀរសបុគ្គលហើយ មិនគប្បីទទួលបិណ្ឌបាត ។ តែក្នុងមហាបច្ចរីពោលថា បុគ្គលទ្រុស្ត-សីល បានឧទ្ទេសភត្តជាដើមអំពីសង្ឃហើយ ប្រគេនដល់សង្ឃនោះឯងឧទ្ទេសភត្តជាដើមនេះ រមែងគួរ ព្រោះប្រព្រឹត្តទៅតាមដែលគេប្រគេននោះឯង ។ បុគ្គលជាលជ្ជី បិណ្ឌបាតមិនជាធម៌ បិណ្ឌបាតគួរវៀរស មិនគួរទទួលយកឡើយ បុគ្គលជាលជ្ជី សូម្បីបិណ្ឌបាតក៏ជាធម៌ រមែងគួរ ។

មានការសរសើរ ២ យ៉ាង និងការបរិភោគ ២ យ៉ាងទៀត គឺការសរសើរលជ្ជី ១ ការសរសើរអលជ្ជី ១ ធម្មបរិភោគ ១ អាមិសបរិភោគ ១ ក្នុងការសរសើរ និងការបរិភោគនោះ ការសរសើរលជ្ជី ដល់អលជ្ជី គួរ ។ លោកមិនគួរត្រូវកាត់អាបត្តិ ។ បើលជ្ជីសរសើរអលជ្ជី រមែងអារាធនាដោយអនុមោទនា អារាធនាដោយធម្មកថា ឧបត្ថម្ភក្នុងត្រកូលទាំងឡាយ សូម្បីអលជ្ជីក្រៅអំពីនេះ ក៏ពោលសរសើរលោកក្នុងបរិស័ទថា អាចារ្យរបស់ពួក

យើង រមែងជាបុគ្គលដូច្នេះ និងដូច្នេះ ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា រមែងធ្វើសាសនាឲ្យវិនាស គឺឲ្យអន្តរធានទៅ ។

បណ្តាធម្មបរិភោគ និងអាមិសបរិភោគ ក្នុងបុគ្គលណា អាមិសបរិភោគសមគួរក្នុងបុគ្គលនោះ សូម្បីធម្មបរិភោគ ក៏សមគួរ ។ លោកពោលទុក ( ក្នុងអដ្ឋកថាទាំងឡាយ ) ថា គម្ពីរណា តាំងនៅក្នុងទីបំផុត នឹងវិនាសទៅដោយកាលកន្លងទៅនៃបុគ្គលនោះ ទោះរៀនយកគម្ពីរនោះ ដោយធម្មានុគ្រោះគួរ ។ ក្នុងការអនុគ្រោះធម៌នោះ មានរឿងដូចតទៅនេះ

## រឿងគណ្ឋះអំពីមនុស្សអាក្រក់ដើម្បីអនុគ្រោះធម៌

បានឮថា ក្នុងយុគមហាភ័យ មានភិក្ខុអ្នកជំនាញក្នុងមហានិទ្ទេសត្រឹមមួយអង្គប៉ុណ្ណោះ ។ គ្រានោះ ព្រះឧបជ្ឈាយ៍របស់ព្រះតិស្សត្ថេរ អ្នកទ្រទ្រង់និកាយ ៤ ឈ្មោះមហាតិបិដកត្ថេរពោលនឹងព្រះមហារក្ខិតត្ថេរថា អាវុសោមហារក្ខិតៈ លោកចូររៀនយកមហានិទ្ទេសនៃភិក្ខុនោះចុះ ។ ភិក្ខុប្រាប់ថា បានឮថា លោកម្ចាស់អង្គនេះ ជាបុគ្គលអាក្រក់លាមក ខ្ញុំនឹងមិនរៀនយកឡើយ ឧបជ្ឈាយ៍ពោលថា រៀនយកចុះ អាវុសោ ខ្ញុំនឹងអង្គុយជិតៗ លោក ព្រះថេរៈពោលថា សាធុ លោកម្ចាស់ លោកម្ចាស់អង្គុយផង ខ្ញុំនឹងរៀនយកហើយផ្តើមរៀនជាប់តគ្នា ទាំងយប់ទាំងថ្ងៃ ថ្ងៃចុងក្រោយ ឃើញស្ត្រីខាងក្នុងគ្រែ ហើយប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបានឮមកអំពីមុនហើយនោះឯង បើខ្ញុំគប្បីដឹងយ៉ាងនេះ នឹងមិនគប្បីរៀនធម៌ក្នុងសម្នាក់មនុស្សដូច្នេះឡើយ ។ ព្រះមហាថេរៈជាច្រើន បានរៀនយកក្នុងសម្នាក់របស់ព្រះថេរៈនោះហើយ បាន

ប្រតិស្ឋានមហានិទ្ទេសទុកបន្តមក ។

# អធិប្បាយ

## បទភាជនីយនៃរូបិយសិក្ខាបទ

[ ១០៧ ] ឯមាស និងប្រាក់ទាំងអស់ អ្នកសិក្សាគប្បីជ្រាបថា ដល់នូវការសង្គ្រោះថា រូបិយទាំងអស់ ក្នុងបទថា **រូបយេ រូបិយសញ្ញី** នេះ ។

ពីរបទថា **រូបិយេ វេមតិកោ** សេចក្ដីថា កើតមានសេចក្ដីសង្ស័យដោយន័យជាដើមថា ជាមាស ឬទង់ដែងហ្ន៎ ។

ពីរបទថា **រូបិយេ អរូបិយសញ្ញី** សេចក្ដីថា មានការសម្គាល់ក្នុងមាសជាដើមថា ជាទង់ដែងជាដើម ។

ម្យ៉ាងទៀត បុគ្គលអ្នកប្រាថ្នាក្នុងបុណ្យទាំងឡាយ មានស្នំរបស់ព្រះរាជាជាដើមប្រគេនប្រាក់ និងមាស ដាក់ទុកក្នុងកត្ត របស់គួរទំពា គ្រឿងក្រអូបនិងកំញានជាដើម ប្រគេនផ្អាំងសំពត់តូចៗ រួមទឹកឃាបណៈ ដែលខ្ចប់ទុកត្រង់ជាយសំពត់ជាដើមនោះឯងដល់ភិក្ខុទាំងឡាយ ដែលត្រាច់បិណ្ឌបាតសំពត់ភិក្ខុទាំងឡាយទទួលយក ដោយសម្គាល់ថា កត្តាហារជាដើមក្ដី សម្គាល់ថាសំពត់ក្ដី ភិក្ខុនេះ គប្បីជ្រាបថា ជាអ្នកមានការសម្គាល់ក្នុងរូបិយ ថាមិនមែនរូបិយ ទទួលយករូបិយ ដោយអាការយ៉ាងនេះ ។

តែភិក្ខុអ្នកទទួល គប្បីកំណត់ឲ្យល្អថា របស់នេះ អញបានក្នុងផ្ទះមួយនេះ ព្រោះថា បុគ្គលដែលប្រគេនរបស់ដោយមិនមានសតិ បានសតិហើយនឹងត្រឡប់មក ( សុំយកទៅវិញ ) លំដាប់នោះ ភិក្ខុគប្បីប្រាប់បុគ្គលនោះថា

អ្នកចូរពិនិត្យមើលសំពត់របស់អ្នក ដូច្នេះ ។ បទដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។

បណ្ដាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជួនកាលជាកិរិយា ព្រោះត្រូវដោយការទទួល ជួនកាលជាអកិរិយា ត្រូវព្រោះមិនធ្វើការហាមឃាត់ ពិតហើយ ក្នុងរូបិយសិក្ខាបទ អញ្ញវាទកសិក្ខាបទ និងឧបស្សុតិសិក្ខាបទ ទាំង ៣ មានកំណត់ដូចគ្នា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ បណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រូបិយសិក្ខាបទទី ៨ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ១០៩ ] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ក្នុងអារាមជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុឆព្វគ្គិយ ប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនសមបើនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ដូចជាពួកគ្រហស្ថ អ្នកបរិភោគនូវកាមទេ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ រមែងពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយ មិនសមនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗទេ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គមានបន្ទូលសួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ពិតមែនឬទេ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបើនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ដូច្នោះទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ឬមួយនាំពួកអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង មិនបានទេ ។បេ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ វត្ថុដែលទិញមកនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[ ១១០ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ មាសប្រាក់ដែលធ្វើសម្រេចជារូបហើយក្តី មិនទាន់បានធ្វើជារូបក្តី ធ្វើខ្លះ មិនបានធ្វើខ្លះក្តី ហៅថា រូបិយមានប្រការផ្សេងៗ ។ រូបិយដែលគេធ្វើសម្រាប់ពាក់លើក្បាលក្តី ពាក់ឰដ៏កក្តី ពាក់នឹងដៃក្តី ពាក់នឹងជើងក្តី ពាក់នឹងចង្កេះក្តី ហៅថា រូបិយធ្វើសម្រេចហើយ ។ រូបិយដែលនៅជាដុំ ហៅថា រូបិយគេមិនទាន់ធ្វើសម្រេច ។ រូបិយដែលធ្វើសម្រេចជារូប និងមិនទាន់ធ្វើសម្រេចជារូប ទាំង ២ យ៉ាងនេះ ហៅថា រូបិយគេបានធ្វើខ្លះ មិនបានធ្វើខ្លះ ។ មាសក្តី កហាបណៈក្តី មាសកធ្វើដោយជាតិលោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តី នៅចាយវាយបាន ហៅថា រូបិយ ។ ពាក្យថា ប្រព្រឹត្ត សេចក្តីថា ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយ ដោយរូបិយដែលធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលគេមិនទាន់ធ្វើសម្រេចហើយ ដោយរូបិយដែលគេធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ ដោយរូបិយដែលធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយ ដោយរូបិយដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវ

រូបិយដែលមិនទាន់ធ្វើសម្រេចហើយ ដោយរូបិយ ដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចខ្លះ ដោយរូបិយ ដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលគេធ្វើសម្រេចហើយ ដោយរូបិយដែលគេធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយមិនទាន់ធ្វើសម្រេច ដោយរូបិយដែលធ្វើសម្រេចហើយខ្លះ និងមិនទាន់ធ្វើសម្រេចខ្លះ រូបិយនោះជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ ដោយរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ រូបិយនោះជានិស្សគ្គិយ ។ រូបិយដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះក្នុងទីកណ្តាលនៃសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះឯង។ ភិក្ខុនោះគប្បីចូលទៅរកសង្ឃ ហើយពាក់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយប្រហោងផ្គងអញ្ជលី ពោលយ៉ាងនេះ ( នឹងសង្ឃ ) ថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំជាអ្នកប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ រូបិយវត្ថុរបស់ខ្ញុំនេះ ជានិស្សគ្គិយ ខ្ញុំសូមលះនូវរូបិយវត្ថុនេះដល់សង្ឃ ។ លុះលះស្រេចហើយ គប្បីសម្តែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសអង់អាច គប្បីទទួលសម្តែងអាបត្តិ ។ បើញោមវត្ត ឬឧបាសកមកក្នុងទីនោះ ភិក្ខុទាំងឡាយគប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹងនូវរូបិយវត្ថុនេះចុះ បើគេពោលថា ពួកលោកម្ចាស់ត្រូវការឲ្យខ្ញុំនាំយកអ្វីមកដោយរូបិយវត្ថុនេះ ។ ភិក្ខុទាំងឡាយមិន

គប្បីពោលថា អ្នកចូរនាំយកនូវវត្ថុនេះ ឬរបស់នេះមកឡើយ ។ គប្បីប្រាប់តែរបស់ដែលគួរ គឺជាសប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅក៏បាន ។ បើគេផ្លាស់ប្តូរដោយរូបិយវត្ថុនោះ ហើយនាំយករបស់ដែលគួរមក ភិក្ខុទាំងពួងគប្បីបរិភោគបាន វៀរលែងតែភិក្ខុអ្នកទិញដូរដោយរូបិយចេញ ។ បើភិក្ខុបានរបស់គួរយ៉ាងនេះ នេះជាការល្អ បើមិនបានទេ គប្បីពោលនឹងគេថា អាវុសោ អ្នកចូរបោលនូវរូបិយនោះទៅ ។ បើគេបោលទៅ នេះជាការល្អ បើគេមិនបោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ ( មួយរូប ) ដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកបោលនូវរូបិយ គឺភិក្ខុមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ ដឹងនូវរូបិយដែលខ្លួនបានបោល និងមិនទាន់បោល ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសន្មតយ៉ាងនេះ ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ ( អ្នកបោលនូវរូបិយ ) ជាមុន ។ ភិក្ខុអ្នកឆ្លាសអង់អាច លុះអង្វររួចហើយ ត្រូវប្រកាសសង្ឃឲ្យដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយសោត សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកបោលនូវរូបិយ។ នេះជាញត្តិដែលប្រកាសឲ្យសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវភិក្ខុឈ្មោះនេះឲ្យជាអ្នកបោលនូវរូបិយ ។ ការសន្មតិភិក្ខុឈ្មោះនេះឲ្យជាអ្នកបោលនូវរូបិយ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មត

ឲ្យជាអ្នកចោលនូវរូបិយហើយ ។ សម្មតិកម្មនេះ គួរដល់សង្ឃ ហេតុនោះ សង្ឃទើបស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសម្មតិកម្មនេះ ដោយអាការស្ងៀមនៅ យ៉ាងនេះ ។ ភិក្ខុដែលសង្ឃសន្មតនោះ កុំគប្បីកំណត់ទីហើយចោលនូវរូបិយ នោះ ។ បើភិក្ខុនោះកំណត់ទីហើយចោល ត្រូវអាបត្តិទុក្កដ ។

[ ១១១ ] រូបិយ ភិក្ខុសម្គាល់ថា រូបិយមែន ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសម្គាល់ថា រូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិ បាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ ហើយទិញដូរ នូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែន រូបិយ ភិក្ខុសម្គាល់ថា រូបិយ ត្រូវអាបត្តិ ទុក្កដ ។ មិនមែនរូបិយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែន រូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ មិនត្រូវអាបត្តិ ។

[ ១១២ ] អាបត្តិមិនមានដល់ភិក្ខុឆ្កួត និងភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា

## កោសិយវគ្គ សិក្ខាបទទី ៩

## រូបិយសំវោហារសិក្ខាបទ

[ ១០៩ ] *រូបិយសំវោហារសិក្ខាបទ បទថា* **នេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងរូបិយសំវោហារសិក្ខាបទនោះ ដូចមានវិនិច្ឆ័យដូចតទៅនេះ បទថា* **នានប្បការកំ** *បានដល់ ច្រើនប្រការ ដោយអំណាចរូបិយដែលធ្វើ ( ជារូបកណ្ឌៈ ) និងមិនបានធ្វើ ( ជារូបកណ្ឌៈ ) ជាដើម ។*

*បទថា* **រូបិយសំវោហារំ** *បានដល់ ការផ្លាស់ប្តូរដោយមាស និងប្រាក់ ។*

*បទថា* **សមាបជ្ជន្តិ** *សេចក្តីថា ពួកឆព្វគ្គិយភិក្ខុមើលមិនឃើញទោសក្នុងការផ្លាស់ប្តូរដោយមាស និងប្រាក់ដែលទទួលទុកហើយ ព្រះមានព្រះភាគទ្រង់ហាមការទទួលតែម្យ៉ាង ទើបធ្វើ ( ការផ្លាស់ប្តូរដោយរូបិយ ) ។*

## អធិប្បាយ

## សិក្ខាបទវិភង្គនៃរូបិយសំវោហារសិក្ខាបទ

[ ១១០ ] *ក្នុងបទថា* **សីសូបគំ** *ជាដើម មានវិនិច្ឆ័យដូច្នេះថា មាសប្រាក់ រូបកណ្ឌៈ ដែលឈ្មោះថា* **សីសូបគ** *ព្រោះអត្ថថា ប្រដាប់ក្បាល ។ ក្នុងគម្ពីរទាំងឡាយ រចនាទុកជា* **សីសូបកំ** *ក៏មាន ។ បទថា* **សីសូបកំ** *នេះ ជាឈ្មោះគ្រឿងប្រដាប់ក្បាលប្រភេទណាមួយ ។ ក្នុងបទទាំងពួងក៏មានន័យដូច្នេះ ។*

ក្នុងបទថា **កាតេន កតំ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបការលក់ទិញដោយរូបិយសុទ្ធៗ ប៉ុណ្ណោះ ។

# អធិប្បាយ
# បទភាជនីយនៃរូបិយសំវោហារសិក្ខាបទ

[ ១១០ ] ខ្ញុំនឹងពោលវិនិច្ឆ័យក្នុងបទថា **រូបិយេ រូបិយសញ្ញី** ជាដើមតទៅថា បណ្ដាវត្ថុដែលពោលហើយក្នុងសិក្ខាបទមុន កាលភិក្ខុលក់ទិញនិស្សគ្គិយវត្ថុ ដោយនិស្សគ្គិយវត្ថុ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទមុន ព្រោះការទទួលមូលតម្លៃ ព្រោះការលក់ទិញរបស់ដទៃៗ ជានិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះឯង សូម្បីកាលលក់ទិញទុក្កដវត្ថុ ឬកប្បិយវត្ថុ ដោយនិស្សគ្គិយវត្ថុ ក៏មានន័យយ៉ាងនេះដូចគ្នា ។

ពិតហើយ អ្នកសិក្សាគប្បីជ្រាបតិកៈថា ភិក្ខុមានការសម្គាល់ក្នុងរូបិយថាជារូបិយ លក់ទិញរបស់ដែលមិនមែនរូបិយជាដើម នេះជាតិកៈមួយទៀត សូម្បីមិនបានត្រាស់ទុក ព្រោះអនុលោមដល់តិកៈទី ២ ដែលត្រាស់ទុកថា ភិក្ខុមានការសម្គាល់ក្នុងវត្ថុដែលមិនមែនរូបិយ ថារូបិយ លក់ទិញរូបិយជាដើមនេះ ។ ពិតហើយ ភិក្ខុលក់ទិញរូបិយរបស់អ្នកដទៃ ដោយរបស់មិនមែនរូបិយរបស់ខ្លួនក្ដី លក់ទិញវត្ថុដែលមិនមែនរូបិយរបស់អ្នកដទៃដោយរូបិយរបស់ខ្លួនក្ដី សូម្បីដោយការលក់ទិញទាំង ២ ប្រការ ក៏ចាត់ជាធ្វើការលក់ទិញដោយរូបិយដូចគ្នា ។ ព្រោះដូច្នោះ ទើបក្នុងបាលីត្រាស់តិកៈមួយប៉ុណ្ណោះ ក្នុងចំណែករូបិយតែម្ខាងដូច្នេះឯង ។

កាលភិក្ខុលក់ទិញវត្ថុនៃនិស្សគ្គិយ ដោយវត្ថុនៃទុក្កដ ជាទុក្កដដោយសិក្ខាបទមុន ព្រោះការទទួលតម្លៃ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះ ព្រោះផ្លាស់ប្តូរក្នុងកាលជាខាងក្រោយ ព្រោះលក់ទិញគុរុភណ្ឌ សូម្បីលក់ទិញទុក្កដវត្ថុនោះឯង ឬកប្បិយវត្ថុដល់វត្ថុនៃទុក្កដ ត្រូវអាបត្តិទុក្កដ ដោយសិក្ខាបទមុន ព្រោះការទទួលតម្លៃ ត្រូវទុក្កដដូចគ្នា ដោយសិក្ខាបទនេះ ព្រោះលក់ទិញក្នុងកាលជាខាងក្រោយ ។ ព្រោះហេតុអ្វី ព្រោះទិញលក់ដោយអកប្បិយវត្ថុ ។

ចំណែកក្នុងអដ្ឋកថាអន្ធកៈពោលថា បើភិក្ខុដល់នូវការទិញដូរ ជានិស្សគ្គិយបាចិត្តិយ ពាក្យនោះ លោកពោលទុកមិនប្រពៃ ព្រោះហេតុអ្វី ព្រោះឈ្មោះថា ការទិញដូរ ក្រៅអំពីការឲ្យ និងការទទួលមិនមាន ហើយកយវិក្កយសិក្ខាបទ ព្រះមានព្រះភាគត្រាស់សំដៅយកការផ្លាស់ប្តូរកប្បិយវត្ថុ ដោយកប្បិយវត្ថុប៉ុណ្ណោះ ។ ឯការផ្លាស់ប្តូរនោះ ក្រៅអំពីសហធម្មិក ។

សិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់សំដៅយកការទិញដូររូបិយ និងវត្ថុមិនមែនរូបិយ ដោយរូបិយ និងការទិញដូររូបិយ ដោយរបស់មិនមែនរូបិយ ឯការទិញដូរវត្ថុនៃទុក្កដ ដោយវត្ថុនៃទុក្កដ មិនបានត្រាស់ទុកក្នុងបាលីក្នុងសិក្ខាបទនេះ និងមិនបានត្រាស់ទុកក្នុងបាលី ក្នុងកយវិក្កយសិក្ខាបទនោះឡើយ ។ ក្នុងការទិញដូរវត្ថុនៃទុក្កដ ដោយវត្ថុនៃទុក្កដនេះ មិនគួរនឹង ( ជាអនាបត្តិ ) ព្រោះដូច្នោះ ពួកអាចារ្យដែលដឹងព្រះបំណងនៃព្រះមានព្រះភាគទើបពោលពាក្យថា ព្រោះទទួលវត្ថុនៃទុក្កដ ត្រូវអាបត្តិទុក្កដ យ៉ាងណា សូម្បី

ព្រោះទិញលក់វត្ថុនៃទុក្កដនោះ ដោយវត្ថុនៃទុក្កដនោះឯង ត្រូវអាបត្តិទុក្កដ ក៏ត្រឹមត្រូវហើយ យ៉ាងនោះដូចគ្នា ។

ម្យ៉ាងទៀត កាលភិក្ខុទិញដូរវត្ថុនិស្សគ្គិយដោយកប្បិយវត្ថុ ជាអនាបត្តិដោយសិក្ខាបទមុន ព្រោះជាការទទួលមូលតម្លៃ ជានិស្សគ្គិយបាចិត្តិយដោយសិក្ខាបទនេះ ព្រោះផ្លាស់ប្តូរក្នុងកាលខាងក្រោយ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុមានសេចក្តីសម្គាល់ក្នុងវត្ថុមិនមែនរូបិយ ថាមិនមែនរូបិយ ទិញដូររូបិយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ កាលភិក្ខុទិញលក់វត្ថុនៃទុក្កដ ដោយកប្បិយវត្ថុនោះឯង មិនត្រូវអាបត្តិយ៉ាងនោះ ព្រោះការទទួលមូលតម្លៃ ត្រូវអាបត្តិទុក្កដដោយសិក្ខាបទនេះ ព្រោះការផ្លាស់ប្តូរខាងក្រោយ ។ ព្រោះហេតុអ្វី ព្រោះទិញដូរវត្ថុជាអកប្បិយ ។

ម្យ៉ាងទៀត កាលភិក្ខុផ្លាស់ប្តូរកប្បិយវត្ថុដោយកប្បិយវត្ថុ ក្រៅអំពីសហធម្មិក មិនត្រូវអាបត្តិដោយសិក្ខាមុន ព្រោះការទទួលមូលតម្លៃ ។ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយកយវិក្កយសិក្ខាបទខាងមុខ ព្រោះការផ្លាស់ប្តូរខាងក្រោយ ។ កាលភិក្ខុកាន់យកផុតការទិញដូរទៅ មិនត្រូវអាបត្តិសូម្បីក្នុងសិក្ខាបទខាងមុខ ។ តែត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលប្រកបដោយការរកផលចំណេញ ។

ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាបបត្តចតុក្កៈនេះ ដែលសម្តែងដល់ភាពដែលរូបិយសំរៅហារសិក្ខាបទនេះ ជូន់ ។ សេចក្តីពិស្តារថា ភិក្ខុណាទទួលយករូបិយ ហើយជួលឲ្យជីករ៉ែដែកឡើងដោយរូបិយនោះ ឲ្យជាងដែករំលាយ

រ៉ែដែកនោះ ហើយឲ្យធ្វើបាត្រដោយលោហៈនោះ ។ បាត្រនេះឈ្មោះថា ជាមហាអកប្បិយ ភិក្ខុនោះ មិនអាចធ្វើឲ្យជាកប្បិយបានដោយឧបាយណាមួយឡើយ ។ បើទម្លាយបាត្រនោះហើយ ឲ្យជាងធ្វើផ្តិល ។ សូម្បីផ្តិលនោះក៏ជាអកប្បិយ ឲ្យធ្វើកាំបិត សូម្បីឈើស្ទន់ដែលកាប់ដោយកាំបិតនោះ ក៏ជាអកប្បិយ ឲ្យធ្វើផ្លែសន្ទូច សូម្បីត្រីដែលគេឲ្យស្លាប់ដោយសន្ទូចនោះ ក៏ជាអកប្បិយ ។ ភិក្ខុឲ្យជាងដុតកាំបិតឲ្យក្តៅ ហើយកម្តៅទឹក ឬទឹកដោះស្រស់ឲ្យក្តៅ សូម្បីទឹកដោះស្រស់នោះ ក៏ជាអកប្បិយដូចគ្នា ។

ក្នុងមហាបច្ចរីពោលថា ភិក្ខុណាទទួលរូបិយ ហើយទិញបាត្រដោយរូបិយនោះ សូម្បីបាត្រនេះរបស់ភិក្ខុនោះ ក៏ជាអកប្បិយ មិនសមគួរដល់សហធម្មិកទាំង ៥ ឡើយ ។ តែភិក្ខុនោះ អាចធ្វើបាត្រនោះឲ្យជាកប្បិយបាន ។ ពិតហើយ បាត្រនោះនឹងជាកប្បិយបាន លុះណាតែឲ្យតម្លៃដើមដល់ម្ចាស់តម្លៃ និងកាលឲ្យបាត្រដល់ម្ចាស់របស់បាត្រ ។ ភិក្ខុឲ្យកប្បិយភណ្ឌ ហើយទទួលយកទៅប្រើប្រាស់ គួរ ។

ឯភិក្ខុណា ឲ្យទទួលយករូបិយទុកហើយ ទៅកាន់ត្រកូលជាងដែក មួយអន្លើដោយកប្បិយការក ឃើញបាត្រហើយ ពោលថា បាត្រនេះអាត្មាពេញចិត្ត កប្បិយការកឲ្យរូបិយនោះហើយ ឲ្យជាងដែកយល់ព្រម សូម្បីបាត្រនោះដែលភិក្ខុនោះកាន់យកដោយកប្បិយវោហារ ដូចគ្នានឹងបាត្រទី ២ នោះឯងចាត់ជាអកប្បិយដូចគ្នា ព្រោះភិក្ខុទទួលមូលតម្លៃ ។

សួរថា ព្រោះហេតុអ្វី ទើបមិនគួរដល់សហធម្មិកដ៏សេស ឆ្លើយថា

ព្រោះមិនលះបង់មូលតម្លៃ ។

ម្យ៉ាងទៀត ភិក្ខុណា មិនទទួលរូបិយ ទៅកាន់ត្រកូលជាងដែក មួយអន្ទើដោយកប្បិយការក ដែលទាយកបញ្ជូនមកថា សូមអ្នកទិញបាត្រប្រគេនព្រះថេរៈៗ ឃើញបាត្រហើយ ឲ្យកប្បិយការកចាយកហាបណៈថា អ្នកចូរទទួលយកកហាបណៈទាំងនេះ ហើយឲ្យបាត្រនេះហើយ បានកាន់យកទៅ បាត្រនេះមិនគួរដល់ភិក្ខុអង្គនេះប៉ុណ្ណោះ ព្រោះប្រើពាក្យមិនប្រពៃ តែគួរដល់ភិក្ខុពួកដទៃ ព្រោះមិនបានទទួលតម្លៃ ។

បានឮថា ឧបជ្ឈាយ៍ព្រះមហាសុមត្ថេរ មានឈ្មោះថា អនុរុទ្ធត្ថេរ ដាក់បាត្របែបនេះរបស់ខ្លួនឲ្យពេញ ដោយទឹកដោះថ្លា ហើយលះដល់សង្ឃ សូម្បីសទ្ធិវិហារិករបស់ព្រះចុល្លនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏មានបាត្រដូច្នោះដូចគ្នា ។ ព្រះថេរៈប្រាប់ឲ្យដាក់បាត្រនោះឲ្យពេញដោយទឹកដោះថ្លា ហើយលះដល់សង្ឃដូច្នេះឯង ។ នេះឈ្មោះថា អកប្បិយបត្តចតុក្កៈ ។ បើភិក្ខុមិនទទួលរូបិយ ទៅកាន់ត្រកូលនៃជាងដែក មួយអន្ទើដោយកប្បិយការក ដែលទាយកបញ្ជូនមកថា ចូរអ្នកទិញបាត្រប្រគេនព្រះថេរៈៗ ឃើញបាត្រហើយ ពោលថា បាត្រនេះ អាត្មាពេញចិត្តក្តី អាត្មានឹងយកបាត្រនេះក្តី ហើយកប្បិយការកចាយរូបិយនោះឲ្យហើយ ឲ្យជាងដែកយល់ព្រម ។ បាត្រនេះគួរគ្រប់យ៉ាង គួរដល់ការបរិភោគ សូម្បីព្រះពុទ្ធទាំងឡាយ ។

ពីរបទថា **អរូបិយេ រូបិយសញ្ញី** បានដល់ មានការសម្គាល់ក្នុងស្ពាន់ជាដើម ថាជាមាសជាដើម ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្តីថា បើភិក្ខុទិញដូរវត្ថុដែលមិនមែនរូបិយ ដោយវត្ថុមិនមែនរូបិយ មានសេចក្តីសម្គាល់ថា ជារូបិយនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យ ក៏មានន័យយ៉ាងនេះ ។ តែមិនត្រូវអាបត្តិដល់ភិក្ខុដែលមានសេចក្តីសម្គាល់ថា មិនមែនរូបិយ សូម្បីធ្វើការទិញដូរ មួយអន្លើដោយសហធម្មិកទាំង ៥ ថា លោកចូរកាន់យករបស់ឈ្មោះនេះ ហើយឲ្យរបស់ឈ្មោះនេះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រូបិយសំវោហារសិក្ខាបទទី ៩ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[១១៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានយស ទ្រង់គង់ក្នុងអារាមជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះឧបនន្ទដ៏មាន-អាយុ ជាបុត្រនៃសក្យ ប្រសប់ធ្វើចីវរកម្ម ។ ឧបនន្ទភិក្ខុនោះ យកកំណាត់សំពត់ចាស់ៗ ទៅធ្វើសង្ឃាដិ ធ្វើកិច្ចជ្រលក់គក់បោកល្អហើយ យកមកដណ្តប់ ។ គ្រានោះឯង បរិព្វាជកម្នាក់ដណ្តប់សំពត់ដ៏មានតម្លៃច្រើន ហើយចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងឧបនន្ទសក្យបុត្រដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ សង្ឃាដិរបស់លោកនេះល្អមែន លោកចូរប្តូរនឹងសំពត់របស់យើងចុះ ។ ឧបនន្ទភិក្ខុនិយាយតបថា ម្នាលអាវុសោ អ្នកចូរដឹងចុះ ( អ្នកមើលសិន ) ។ បរិព្វាជកនិយាយថា អើ អាវុសោ យើងដឹង ។ ឧបនន្ទភិក្ខុបានឲ្យនូវសង្ឃាដិនោះដោយវាចាថា ហ៎ អាវុសោ ។ បរិព្វាជកនោះទើបដណ្តប់នូវសង្ឃាដិនោះ ហើយបានទៅកាន់អារាមរបស់បរិព្វាជក ។ បរិព្វាជកទាំងឡាយបាននិយាយពាក្យនេះ នឹងបរិព្វាជកនោះថា ម្នាលអាវុសោ សង្ឃាដិរបស់អ្នកនេះល្អមែន អ្នកបានមកអំពីទីណា ។ បរិព្វាជកនោះតបថា ម្នាលអាវុសោ យើងបានប្តូរដោយសំពត់របស់យើងនោះមក ។ ពួកបរិព្វាជកសួរថា ម្នាលអាវុសោ សង្ឃាដិរបស់អ្នកនេះនឹងធន់នៅបានប៉ុន្មានថ្ងៃ ឯសំពត់របស់អ្នកពីមុននោះប្រសើរជាង ។ បរិព្វាជកនោះទើបគិតថា បរិព្វាជកទាំងឡាយបានពោលនូវពាក្យនោះ ជាពាក្យពិតមែន

សង្ឃាដិរបស់អញនេះ នឹងធន់នៅបានប៉ុន្មានថ្ងៃ សំពត់របស់អញនោះឯង ប្រសើរ ទើបចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧបនន្ទដ៏មានអាយុជាសក្យបុត្រថា ណ្ហើយចុះ អ្នកចូរ យកសង្ឃាដិ របស់អ្នកទៅវិញចុះ ចូរឲ្យសំពត់មកយើងវិញ ។ ឧបនន្ទភិក្ខុ បាននិយាយថា ម្នាលអាវុសោ យើងបានប្រាប់អ្នកហើយថា អ្នកចូរដឹង ( ចូរ មើលសិន ) ដូច្នេះមិនមែនទេឬ យើងមិនឲ្យទេ ។ ឯបរិព្វាជកនោះក៏ ពោលទោសតិះដៀល បន្តុះបង្អាប់ថា សូម្បីគ្រហស្ថក៏រមែងឲ្យនូវវត្ថុនោះដល់ គ្រហស្ថ ដែលមានសេចក្តីក្តៅក្រហាយដែរ ចុះហេតុអ្វី បព្វជិតត្រឡាំង ក៏ មិនឲ្យដល់បព្វជិតដូចគ្នា ។ ភិក្ខុទាំងឡាយបានឮបរិព្វាជកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រ ដ៏មានអាយុ មិនគួរនឹងប្រព្រឹត្តទិញដូររបស់មួយអន្លើដោយបរិព្វាជកទេ ។ ភិក្ខុ ទាំងនោះក៏នាំគ្នា ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គ ត្រាស់សួរថា ឧបនន្ទ ឮថា អ្នកឯងប្រព្រឹត្តទិញដូររបស់ មួយអន្លើដោយ បរិព្វាជក ពិតមែនឬ ។ ឧបនន្ទភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែ មោឃបុរស អ្នកឯងមិនគួរនឹងប្រព្រឹត្តទិញដូររបស់ មួយអន្លើដោយបរិព្វាជក ទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលដែល មិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង

មិនបានទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយប្រព្រឹត្តទិញដូររបស់មានប្រការផ្សេងៗ របស់នោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ១១៤ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ បរិក្ខារទាំងឡាយ គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហោចទៅ សូម្បីតែដុំនៃលម្អិត[១] សូម្បីឈើស្ទន់ សូម្បីអំបោះរងជើង ហៅថា វត្ថុមានប្រការផ្សេងៗ ។ ពាក្យថា ប្រព្រឹត្តទិញដូរ សេចក្តីថា ភិក្ខុពោលពាក្យមិនសមគួរថា អ្នកចូរឲ្យនូវវត្ថុនេះ ( បានដល់ គ្រឿងប្រើប្រាស់ទាំងអស់ ) ដោយរបស់នេះចុះ អ្នកចូរនាំយកវត្ថុនេះ ដោយរបស់នេះចុះ អ្នកចូរប្តូរវត្ថុនេះ ដោយរបស់នេះចុះ អ្នកចូរទិញនូវវត្ថុនេះ ដោយរបស់នេះចុះ ត្រូវអាបត្តិទុក្កដ កាលណាបើភិក្ខុធ្វើទ្រព្យរបស់ខ្លួនឲ្យតាំងនៅក្នុងដៃនៃអ្នកដទៃ ធ្វើទ្រព្យរបស់អ្នកដទៃឲ្យមកតាំងនៅក្នុងដៃរបស់ខ្លួនវិញ ហៅថា ទិញ ហៅថា លក់ ទ្រព្យដែលភិក្ខុទិញលក់នោះជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬ ដល់គណៈ ឬដល់បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំប្រព្រឹត្តទិញដូរនូវទ្រព្យមានប្រការផ្សេងៗ ទ្រព្យរបស់ខ្ញុំនេះជានិស្សគ្គិយ ខ្ញុំសូមលះទ្រព្យនេះដល់សង្ឃ ។បេ។ សង្ឃគប្បីឲ្យ ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។បេ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

---

១- បានដល់ ដុំកម្មេចដែលគេប្រើសម្រាប់ដុសខ្លួនវេលាងូតទឹកដើម្បីឲ្យជ្រះក្អែល ឬជារោគជាដើម ។

[ ១១៥ ] ទ្រព្យដែលខ្ជួនទិញដូរ ភិក្ខុសម្គាល់ថា ទិញដូរ ទ្រព្យនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងទ្រព្យដែលខ្ជួនទិញដូរ ទ្រព្យនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទ្រព្យដែលខ្ជួនទិញដូរ ភិក្ខុសម្គាល់ថា មិនមែនទ្រព្យទិញដូរវិញ ទ្រព្យនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ទ្រព្យដែលខ្ជួនមិនបានទិញដូរ ភិក្ខុសម្គាល់ថា ទ្រព្យទិញដូរវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យ ក្នុងទ្រព្យដែលខ្ជួនមិនបានទិញដូរ ត្រូវអាបត្តិទុក្កដ ។ ទ្រព្យដែលខ្ជួនមិនបានទិញដូរ ភិក្ខុសម្គាល់ថា ទ្រព្យមិនបានទិញដូរ មិនត្រូវអាបត្តិ ។

[ ១១៦ ] អាបត្តិមិនមានដល់ភិក្ខុដែលគ្រាន់តែសួរតម្លៃ ដល់ភិក្ខុដែលប្រាប់ដល់កប្បិយការក ដល់ភិក្ខុដែលពោលថា ទ្រព្យនេះរបស់យើងមាន យើងត្រូវការដោយទ្រព្យនេះផង នេះផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

កោសិយវគ្គទី ២ ចប់

## ចំនួននៃសិក្ខាបទក្នុងកោសិយវគ្គនោះគឺ

ភិក្ខុធ្វើសន្ថ័តដោយរោមចៀមលាយសូត្រ ១ ភិក្ខុធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ១ ភិក្ខុធ្វើសន្ថ័តត្រូវយករោមចៀមខ្មៅពីរភាគមកលាយ ១ ភិក្ខុធ្វើសន្ថ័តថ្មីហើយ ត្រូវប្រើប្រាស់ឲ្យបាន ៦ ឆ្នាំ ១ ភិក្ខុធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយ ត្រូវកាត់យកសន្ថ័តចាស់មកលាយ ១ ភិក្ខុកាន់យករោមចៀមដែលកើតឡើងពាក់កណ្តាលផ្លូវបានត្រឹម ៣ យោជន៍ ១ ភិក្ខុប្រើនាងភិក្ខុនីឲ្យលាងជ្រលក់គក់រោមចៀម ១ ភិក្ខុទទួលរូបិយ ១ ភិក្ខុលក់ទិញដោយរូបិយ ១ ភិក្ខុលក់ទិញផ្លាស់ប្តូរដោយកប្បិយវត្ថុ ១ ។

# អដ្ឋកថា
# កោសិយវគ្គ សិក្ខាបទទី ១០
# កយវិក្កយសិក្ខាបទ

[ ១១៣ ] កយវិក្កយសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងកយវិក្កយសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះ ពាក្យថា **កតិ-ហាបិ ត្យាយំ** គឺសង្ឃាដីមួយផ្ទាំងនេះរបស់លោក នឹងនៅបានប៉ុន្មានថ្ងៃ ៗ ក្នុងបទថា **កតិហាបិ** នេះ **ហា** សព្ទ ជាបទបូរណៈ **បិ** សព្ទ ប្រព្រឹត្តទៅ ក្នុងការតិះដៀល អធិប្បាយថា សង្ឃាដីរបស់លោកមួយផ្ទាំងនេះទុព្វល នឹងនៅបានប៉ុន្មានថ្ងៃ ម្យ៉ាងទៀត បាឋៈថា **កតិហំបិ ត្យាយំ** ក៏មាន ៗ បណ្ដាបទទាំងនោះ បទថា **កតិហំ** គឺអស់ថ្ងៃប៉ុន្មាន ៗ មានពាក្យអធិប្បាយថា បានប៉ុន្មានថ្ងៃ ៗ បទដ៏សេសមានន័យដូចពោលហើយដូចគ្នា ៗ ពាក្យថា **កតិ-ហាបិ ម្យាយំ** នេះ ក៏គប្បីជ្រាបដោយន័យនេះដូចគ្នា ៗ

ក្នុងបទថា **គិហីបិ នំ គិហិស្ស** នេះ សព្ទថា **នំ** ជានិបាត ចុះក្នុងអត្ថនៃនាមសព្ទ ៗ មានអធិប្បាយថា ធម្មតាថា សូម្បីគ្រហស្ថ ក៏គង់សងឲ្យដល់គ្រហស្ថ ៗ

# អធិប្បាយ
# សិក្ខាបទវិភង្គនៃកយវិក្កយសិក្ខាបទ

[ ១១៤ ] បទថា **នានប្បការកំ** គឺមានបែបមិនមែនតិច ដោយអំណាចនៃកប្បិយភណ្ឌ មានចីវរជាដើម ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា

**ឆាឈប្បការកំ** នោះ ទើបទ្រង់សម្ដែងចំពោះកប្បិយភណ្ឌ ផ្ដើមអំពីចីវរ មាន អំបោះជាយសំពត់ជាទីបំផុត ។ ពិតហើយ ការផ្លាស់ប្ដូរដោយអកប្បិយភណ្ឌ រមែងមិនដល់ការសង្គ្រោះចូលក្នុងការទិញដូរ ។

បទថា **កយវិក្កយំ** បានដល់ ការទិញ និងការដូរ ។ ភិក្ខុកាលកាន់ យកកប្បិយភណ្ឌរបស់អ្នកដទៃ ដោយន័យជាដើមថា អ្នកចូរឲ្យវត្ថុនេះដោយ វត្ថុនេះ ឈ្មោះថា រមែងដល់នូវការទិញ សូម្បីឲ្យកប្បិយភណ្ឌរបស់ខ្លួន ឈ្មោះថា រមែងដល់នូវការដូរ ។

បទថា **អជ្ឈាចរតិ** គឺរមែងប្រព្រឹត្តមិនសមគួរ អធិប្បាយថា រមែង ពោលវាចាហួសប្រមាណ ។

បទថា **យតោ កយិតញ្ច ហោតិ វិក្កីតញ្ច** សេចក្ដីថា ក្នុងវេលាធ្វើ ភណ្ឌៈរបស់អ្នកដទៃឲ្យនៅក្នុងដៃរបស់ខ្លួន ឈ្មោះថា ទិញ ហើយក្នុងវេលា ធ្វើភណ្ឌៈរបស់ខ្លួនឲ្យនៅក្នុងដៃរបស់អ្នកដទៃ ឈ្មោះថា លក់ ។ តែដោយ បទនេះ ក្នុងបាលីលោកសម្ដែងភណ្ឌៈរបស់ខ្លួនមុន ដោយអនុរូបដល់ពាក្យថា **ឥមំ** ជាដើម ។

បទថា **និស្សជ្ជិតព្វំ** សេចក្ដីថា គប្បីលះបង់កប្បិយភណ្ឌដែលទទួល យកអំពីដៃរបស់អ្នកដទៃ ដោយអំណាចនៃការទិញលក់យ៉ាងនេះ ។ ការទិញ ដូរយ៉ាងនេះ ជាមួយពួកគ្រហស្ថ និងអ្នកបួសដ៏សេស វៀរសហធម្មិកទាំង ៥ ដោយហោចជាមួយមាតាបិតា ក៏មិនគួរ ។

វិនិច្ឆ័យក្នុងការទិញលក់នោះ ដូចតទៅនេះថា សំពត់ និងសំពត់ក៏ដោយ

អាហារ និងអាហារក៏ដោយ ចូរលើកទុក ភិក្ខុពោលដល់កប្បិយកណ្ឌឯណា មួយថា អ្នកចូរឲ្យវត្ថុនេះ ដោយវត្ថុនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពោលយ៉ាង នោះហើយ ឲ្យកណ្ឌៈរបស់ខ្លួនសូម្បីដល់មាតា ក៏ត្រូវទុក្កដ ។ ភិក្ខុដែល មាតាពោលថា លោកចូរឲ្យវត្ថុនេះដោយវត្ថុនេះ ឬពោលថា លោកចូរឲ្យវត្ថុ នេះ ខ្ញុំនឹងឲ្យវត្ថុនេះដល់លោក ហើយកាន់យកកណ្ឌៈ សូម្បីរបស់ម្ដាយដើម្បី ខ្លួន ក៏ត្រូវអាបត្តិទុក្កដ កាលកណ្ឌៈរបស់ខ្លួនដល់ដៃរបស់អ្នកដទៃ និងកាល កណ្ឌៈរបស់អ្នកដទៃដល់ដៃរបស់ខ្លួន ជានិស្សគ្គិយ ។ តែកាលភិក្ខុពោលនឹង មាតាក្ដី បិតាក្ដីថា ញោមចូរឲ្យវត្ថុនេះ មិនជាការហាមាត់សូមឡើយ ។ កាល ភិក្ខុពោលថា សូមញោមកាន់យកវត្ថុនេះ មិនជាការញុំាងសទ្ធាទេយ្យឲ្យធ្លាក់ ចុះឡើយ។ បើភិក្ខុនិយាយនឹងបុគ្គលមិនមែនញាតិថា អ្នកចូរឲ្យរបស់នេះ ជា ការហាមាត់សុំ បើពោលថា អ្នកចូរកាន់យកវត្ថុនេះ ជាការញុំាងសទ្ធា-ទេយ្យឲ្យធ្លាក់ចុះ ។ បើភិក្ខុដល់នូវការទិញដូរថា អ្នកចូរឲ្យវត្ថុនេះដោយវត្ថុ នេះ ជានិស្សគ្គិយ ។ ព្រោះដូច្នោះ ភិក្ខុដែលផ្លាស់ប្ដូរកប្បិយកណ្ឌ គប្បីផ្លាស់ ប្ដូរជាមួយមាតាបិតា ឲ្យផុតការទិញដូរជាមួយពួកបុគ្គល ដែលមិនមែនញាតិ ឲ្យផុតអាបត្តិ ៣ ។

ក្នុងកប្បិយកណ្ឌនោះ មានវិធីដោះដូរដូចតទៅនេះថា ភិក្ខុមានអង្ករ ជា ស្បៀងដើរផ្លូវ ។ លោកឃើញបុរសកាន់បាយក្នុងចន្លោះផ្លូវ ហើយពោលថា អាត្មាមានអង្ករ ហើយអាត្មាមិនមានសេចក្ដីត្រូវការដោយអង្ករនេះទេ តែមាន សេចក្ដីត្រូវការដោយបាយដូច្នេះ ។ បុរសទទួលយកអង្ករ ហើយប្រគេនបាយ

គួរ មិនត្រូវអាបត្តិទាំង ៣ ។ ដោយហោចសូម្បីត្រឹមតែនិមិត្តកម្ម ក៏មិនត្រូវអាបត្តិ ព្រោះហេតុអ្វី ព្រោះមានមូលហេតុ ។ ហើយព្រះមានព្រះភាគ បានត្រាស់ពាក្យនេះទុកខាងមុខនោះឯងថា ភិក្ខុពោលថា អាត្មាមានវត្ថុនេះ តែមានសេចក្តីត្រូវការដោយវត្ថុនេះ និងវត្ថុនេះ ដូច្នេះ ។

ម្យ៉ាងទៀត ភិក្ខុណា មិនធ្វើយ៉ាងនេះ ដោះដូរថា អ្នកចូរឲ្យវត្ថុនេះដោយវត្ថុនេះ ត្រូវអាបត្តិតាមវត្ថុពិត ។ ភិក្ខុឃើញអ្នកស៊ីដែល ហើយពោលថា អ្នកចូរបរិភោគបាយនេះ ហើយចូរនាំកម្មេចល័ខ ឬឧសមកឲ្យ ហើយឲ្យ ( បាយ ) ។ ជានិស្សគ្គិយជាច្រើន តាមចំនួនកម្មេចល័ខ និងចំនួនឧស ។ ភិក្ខុពោលថា ពួកអ្នកបរិភោគបាយនេះហើយ ចូរធ្វើកិច្ចមួយនេះ ហើយឲ្យពួកជាងសិប្បៈ មានជាងច្ចាក់ក្តុកជាដើម ធ្វើបរិក្ខារនោះៗ បណ្តាបរិក្ខារ មានធម្មក្រកជាដើម ឬប្រើពួកជាងជ្រលក់ឲ្យជ្រលក់សំពត់ ត្រូវអាបត្តិតាមវត្ថុនោះឯង ។ ភិក្ខុឲ្យពួកខ្នាន់ប្រកេសកោរសក់ ឲ្យពួកកម្មករធ្វើនវកម្ម ត្រូវអាបត្តិតាមវត្ថុដូចគ្នា ។ បើភិក្ខុមិនពោលថា ពួកអ្នកបរិភោគអាហារនេះហើយ ចូរធ្វើកិច្ចនេះ ពោលថា អ្នកចូរបរិភោគអាហារនេះ អ្នកបរិភោគហើយ (ក្តី) នឹងបរិភោគក្តី ចូរជួយធ្វើកិច្ចឈ្មោះនេះ រមែងសមគួរ ។ ក្នុងការឲ្យធ្វើបរិក្ខារជាដើមនេះ កណ្ឌៈរបស់អ្នកដទៃ ដែលនៅក្នុងការទទួលខុសត្រូវរបស់ខ្លួន ឈ្មោះថា ភិក្ខុគប្បីលះ រមែងមិនមាន ក្នុងការបោកសំពត់ ឬក្នុងការកោរសក់ ឬក្នុងនវកម្ម មានការជម្រះដីជាដើមក៏ពិត សូម្បីដូច្នោះ ព្រោះលោកពោលទុកយ៉ាងធ្ងន់ ក្នុងមហាអដ្ឋកថា ដែលបុគ្គលណាមួយ មិនអាចជំទាស់ពាក្យនោះបាន ព្រោះហេតុនោះ ភិក្ខុគប្បីសម្តែងអាបត្តិបាចិត្តិយ ព្រោះការ

ដួលបោកសំពត់ជាដើមនេះ ដូចសម្តែងអាបត្តិបាចិត្តិយ ព្រោះនិស្សគ្គិយវត្ថុដែលខ្លួនប្រើប្រាស់ហើយ ឬវិនាសហើយ ដូច្នោះ ។

# អធិប្បាយ

## បទភាជនីយនៃកយវិក្កយសិក្ខាបទ

[ ១១៥ ] ក្នុងបទថា **កយវិក្កយេ កយវិក្កយសញ្ញី** ជាដើម អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា ភិក្ខុណា ដល់នូវការទិញដូរ ភិក្ខុនោះ ចូរជាអ្នកមានសេចក្តីសម្គាល់ក្នុងការទិញដូរនោះថា ជាការទិញដូរក្តី មានសេចក្តីសង្ស័យក្តី មានការសម្គាល់ថា មិនមែនជាការទិញដូរក្តី ជាអាបត្តិនិស្សគ្គិយបាចិត្តិយទាំងអស់ ។ ក្នុងចុល្លត្តិកៈ ត្រូវអាបត្តិទុក្កដដូចគ្នាទាំងពីរបទ ។

## អនាបត្តិនៃកយវិក្កយសិក្ខាបទ

[ ១១៦ ] ពីរបទថា **អគ្ឃំ បុច្ឆតិ** សេចក្តីថា ភិក្ខុសួរថា បាត្ររបស់អ្នកនេះតម្លៃប៉ុន្មាន កាលម្ចាស់របស់បាត្រពោលថា តម្លៃប៉ុណ្ណេះ បើកប្បិយ-ភណ្ឌនៃភិក្ខុនោះមានតម្លៃច្រើន ហើយភិក្ខុប្រាប់ឧបាសកនោះ យ៉ាងនេះថា ឧបាសក វត្ថុនេះមានតម្លៃច្រើន អ្នកចូរឲ្យបាត្ររបស់អ្នកដល់អ្នកដទៃចុះ ។ ឯឧបាសកបានឮពាក្យនោះពោលថា ខ្ញុំនឹងថែមផ្តិលដទៃឲ្យទៀត ទោះទទួលយកក៏គួរ ។ របស់នោះធ្លាក់ទៅក្នុងលក្ខណៈដែលត្រាស់ទុកថា អាត្មាមានវត្ថុនេះជាដើម ។ បើបាត្រនោះមានតម្លៃថ្លៃ ភណ្ឌៈរបស់ភិក្ខុមានតម្លៃថោក ហើយម្ចាស់បាត្រមិនដឹងថា ភណ្ឌៈនោះមានតម្លៃថោក ភិក្ខុកុំគប្បីទទួលយកបាត្រគប្បីប្រាប់ថា របស់អាត្មាមានតម្លៃថោក ។ ពិតហើយ កាលភិក្ខុពោល

បញ្ឆោតថា មានតម្លៃច្រើន ទទួលយក ( បាត្រ ) ដល់នូវភាពជាបុគ្គលដែល
វិនយធរគប្បីវាយតម្លៃទ្រព្យ ហើយកាត់អាបត្តិ ។ បើម្ចាស់របស់បាត្រពោល
ថា ណ្ហើយចុះ លោកម្ចាស់ តម្លៃដែលលើសនឹងជាបុណ្យរបស់ខ្ញុំ ហើយ
ប្រគេន គួរ ។

ពីរបទថា **កប្បិយការកស្ស អាចិក្ខតិ** សេចក្តីថា ភិក្ខុធ្វើអ្នកដទៃ
វៀរបុគ្គលដែលខ្លួនទទួលភណ្ឌៈអំពីដៃ ដោយហោចសូម្បីកូនក្តី បងប្អូនប្រុស
របស់បុគ្គលនោះក្តី ឲ្យជាកប្បិយការក ហើយប្រាប់ថា អ្នកចូរយករបស់
ឈ្មោះនេះផង ឲ្យវត្ថុនេះផង ។ បើកូន ឬបងប្អូនប្រុសនោះ ជាមនុស្សឈ្លាស
ជ្រើសរើស តម្លៃដដែលៗ ហើយ ទើបទទួលយក ភិក្ខុគប្បីឈរនៅស្ងៀម ។
បើបុគ្គលនោះជាអ្នកមិនឈ្លាស មិនស្គាល់កាន់យក ឈ្មួញនឹងបោកបញ្ឆោត
បុគ្គលនោះ ភិក្ខុគប្បីប្រាប់បុគ្គលនោះថា អ្នកកុំយក ដូច្នេះ ។

ក្នុងបទថា **ឥទំ អម្ហាកំ អត្ថិ** អាត្មាមានវត្ថុនេះជាដើម មានវិនិច្ឆ័យ
ដូច្នេះ ភិក្ខុពោលថា ប្រេង ឬទឹកដោះថ្លា ដែលទទួលប្រគេនហើយនេះរបស់
អាត្មាមាន តែអាត្មាត្រូវការរបស់ដទៃ ដែលមិនទាន់បានប្រគេន បើបុគ្គលនោះ
ទទួលយកប្រេង ឬទឹកដោះថ្លានោះ ឲ្យប្រេង ឬទឹកដោះថ្លាដទៃ កុំគប្បីឲ្យ
វាល់ប្រេងរបស់ខ្លួនមុន ព្រោះហេតុអ្វី ព្រោះមានប្រេងនៅសល់ក្នុងនាឡិ
ប្រេង ។ ប្រេងដ៏សេសនោះ នឹងគប្បីធ្វើប្រេងដែលមិនបានទទួលប្រគេន
របស់ភិក្ខុដែលវាល់ជាក្រោយ ឲ្យវិនាសទៅ ដូច្នេះឯង ។ ពាក្យដ៏សេស
មានអត្ថងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កយវិក្កយសិក្ខាបទទី ១០ ចប់

វគ្គទី ២ ចប់

# វិនយបិដក

## បត្តវគ្គ សិក្ខាបទទី ១

[ ១១៧ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានយស ទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្សំបាត្រទុកជាច្រើន ។ មនុស្សទាំងឡាយដើរទៅវិហារបានឃើញ នាំគ្នាពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្រ មិនសមបីបើ នឹងសន្សំបាត្រទុកជាច្រើនទេ សមណៈទាំងឡាយជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្រ នឹងធ្វើនូវជំនួញបាត្រ ឬនឹងតាំងរានផ្សារលក់ភាជន៍ដី ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងប្រើប្រាស់អតិរេកបាត្រ[១] ឡើយ ។ ខណៈនោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយប្រើប្រាស់អតិរេកបាត្រពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏ទ្រង់ឥស្សរិយយសត្រាស់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់អតិរេកបាត្រទេ ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬថា នាំឲ្យជ្រះថ្លា

---

១- បាត្រដែលលើស គឺបាត្រដែលមិនបានវិកប្ប មិនបានអធិដ្ឋាន។

ក្រៃលែងដល់ពួកជនដែលមានសេចក្តីជ្រះថ្លារួចហើយទេ ។បេ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទ្រទ្រង់នូវអតិរេកបាត្រ អតិរេកបាត្រនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

[ ១១៨ ]សម័យនោះ អតិរេកបាត្រកើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ឯព្រះអានន្ទដ៏មានអាយុ ប្រាថ្នានឹងប្រគេនបាត្រនោះ ដល់ព្រះសារីបុត្រដ៏មានអាយុ ។ ចំណែកព្រះសារីបុត្រដ៏មានអាយុនៅក្រុងសាកេត ។ គ្រានោះព្រះអានន្ទដ៏មានអាយុ ក៏មានបរិវិតក្កថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តរួចហើយថា អតិរេកបាត្រភិក្ខុមិនគប្បីទ្រទ្រង់ ក៏អតិរេកបាត្រនេះកើតឡើងដល់អញ ហើយអញក៏ចង់ប្រគេនបាត្រនេះដល់ព្រះសារីបុត្រដ៏មានអាយុ ឯព្រះសារីបុត្រដ៏មានអាយុគង់នៅក្រុងសាកេត ( កិច្ចនេះ ) ខ្លួនអញ ត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ខណៈនោះ អានន្ទដ៏មានអាយុ បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ប៉ុន្មានថ្ងៃទៀតសារីបុត្រនឹងមក ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ប្រហែលជា ៩ ថ្ងៃ ឬ ១០ ថ្ងៃទៀត ទើបលោកនិមន្តមក ។ គ្រោះនិទាននេះដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទ្រទ្រង់នូវអតិរេក-បាត្របាន ១០ ថ្ងៃជាកំណត់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែង

ឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អតិរេកបាត្រ ភិក្ខុទ្រទ្រង់ទុកបានត្រឹម កំណត់ ១០ ថ្ងៃ កន្លងហួសអំពីនោះទៅអតិរេកបាត្រនោះ ជានិស្សគ្គិយ ភិក្ខុ ត្រូវអាបត្តិបាចិត្តិយ ។

[ ១១៩ ] ត្រង់ពាក្យថា ត្រឹមកំណត់ ១០ ថ្ងៃនោះ គឺភិក្ខុគប្បីរក្សាទុក បានត្រឹម ១០ ថ្ងៃជាយ៉ាងច្រើន ។ បាត្រដែលភិក្ខុមិនបានអធិដ្ឋាន មិនបាន វិកប្ប ហៅថា អតិរេកបាត្រ ។ ដែលហៅថា បាត្រៗ នោះមាន ២ យ៉ាង គឺបាត្រដែក ១ បាត្រដី ១ ។ ខ្នាតនៃបាត្រមាន ៣ យ៉ាង គឺបាត្រយ៉ាងធំ បាត្រយ៉ាងកណ្តាល បាត្រយ៉ាងតូច ។បាត្រចំណុះបាយនៃអង្ករកន្លះអាឡ្ហក (គឺ ២ នាឡិមគធៈ ) ចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤ និងចំណុះ ម្ហូបល្មមសមគួរនឹងបាយនោះ ហៅថា បាត្រយ៉ាងធំ ។ បាត្រចំណុះបាយនៃ អង្ករ ១ នាឡិមគធៈ ចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤ នឹង ចំណុះម្ហូបល្មមសមគួរដល់បាយនោះ ហៅថា បាត្រយ៉ាងកណ្តាល ។ បាត្រ ចំណុះបាយនៃអង្ករ ១ បត្ថៈ គឺកន្លះនាឡិមគធៈ ចំណុះខាទនីយស្មើចំណែក បាយជាគម្រប់ ៤ នឹងចំណុះម្ហូបល្មមសមគួរដល់បាយនោះ ហៅថា បាត្រ យ៉ាងតូច បាត្រដែលធំហួស ឬតូចហួសជាងប្រមាណនោះ មិនហៅថា បាត្រទេ ។

[ ១២០ ] កាលភិក្ខុទុកបាត្រឲ្យកន្លងហួសអំពីកំណត់នោះទៅ បាត្រនោះ ជានិស្សគ្គិយ គឺជានិស្សគ្គិយក្នុងពេលអរុណទី ១១ រះឡើង ហើយភិក្ខុត្រូវ លះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់ បាត្រយ៉ាងនោះឯង ។

[ ១២១ ] ភិក្ខុនោះគប្បីចូលទៅរកសង្ឃ ហើយធ្វើចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុទាំងឡាយដែលជាចាស់ រួចហើយ អង្គុយច្រហោង ប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន បាត្ររបស់ខ្ញុំនេះកន្លងហួស ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់សង្ឃ ។ ភិក្ខុនោះលុះលះបង់ហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុដែលឆ្លាសប្រតិពល គប្បីទទួលដឹងអាបត្តិ ( របស់ភិក្ខុនោះ ) ។ បាត្រដែលភិក្ខុលះបង់ហើយ សង្ឃត្រូវឲ្យ ( ដល់លោកជាម្ចាស់ដើមវិញ ) ដោយពោលពាក្យប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បាត្រនេះជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយដល់សង្ឃ ។ បើកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវបាត្រនេះដល់ភិក្ខុឈ្មោះនេះវិញ ។

[ ១២២ ] ភិក្ខុអង្គនោះគប្បីចូលទៅរកពួកភិក្ខុច្រើន ហើយធ្វើចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះនឹងគណៈភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចម្រើន បាត្ររបស់ខ្ញុំនេះកន្លងហួស ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់លោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុនោះលុះលះបង់ហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីទទួលដឹងអាបត្តិ ( របស់ភិក្ខុនោះ ) ។ បាត្រដែលភិក្ខុលះបង់ហើយ គណៈភិក្ខុត្រូវឲ្យ ( ដល់លោកវិញ ) ដោយពោលពាក្យយ៉ាងនេះថា សូមលោកដ៏មានអាយុទាំងឡាយ

ស្តាប់ខ្ញុំ បាត្រនេះជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយ ដល់លោកដ៏មានអាយុទាំងឡាយ ។ បើកម្មនេះមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យបាត្រនេះដល់ភិក្ខុឈ្មោះនេះវិញ ។

[ ១២៣ ] ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុមួយអង្គ ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយអង្គុយប្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះ នឹងភិក្ខុមួយអង្គថា ម្នាលអ្នកដ៏មានអាយុ បាត្ររបស់ខ្ញុំនេះកន្លងហួស ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់លោកដ៏មានអាយុ ។ លុះភិក្ខុនោះលះបង់ហើយត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុមួយអង្គនោះ ត្រូវទទួលដឹងអាបត្តិ ( របស់ភិក្ខុនោះ ) ។ បាត្រដែលភិក្ខុនោះ លះបង់ហើយ ត្រូវបុគ្គលនោះឲ្យវិញ ដោយពោលថា ខ្ញុំឲ្យបាត្រនេះដល់លោកដ៏មានអាយុវិញ ។

[ ១២៤ ] បាត្រដែលកន្លងហួស ១០ ថ្ងៃហើយ ភិក្ខុសម្គាល់ថា កន្លងហើយមែន បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលកន្លងហួស ១០ ថ្ងៃ តែភិក្ខុមានសេចក្តីសង្ស័យ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលកន្លងហួស ១០ ថ្ងៃហើយ តែភិក្ខុសម្គាល់ថាមិនទាន់កន្លង បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បានអធិដ្ឋាន ភិក្ខុសម្គាល់ថាបានអធិដ្ឋានហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បានវិកប្ប ភិក្ខុសម្គាល់ថា បានវិកប្បហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់

បានលះបង់ ភិក្ខុសម្គាល់ថាបានលះបង់ហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បាត់ ភិក្ខុសម្គាល់ថាបាត់ហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់ខូចទេ តែភិក្ខុសម្គាល់ថាខូចហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បែក ភិក្ខុសម្គាល់ថាបែកហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលចោរមិនទាន់ដណ្តើម ភិក្ខុសម្គាល់ថាចោរដណ្តើមយកទៅហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ១២៥ ] ភិក្ខុមិនលះបង់បាត្រ ដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ( បាត្រនោះ ) ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុសម្គាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុសម្គាល់ថា មិនទាន់កន្លងជាអនាបត្តិ ។

[ ១២៦ ] អាបត្តិមិនមានដល់ភិក្ខុដែលបានអធិដ្ឋាន បានវិកប្ប បានលះបង់ឲ្យទៅគេ ដល់ភិក្ខុដែលមានបាត្របាត់វិនាសបែកទៅ ចោរដណ្តើមយកទៅ ភិក្ខុដទៃកាន់យកដោយវិស្សាសៈ ក្នុងរវាង ១០ ថ្ងៃ ដល់ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ ។

[ ១២៧ ] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនបានឲ្យនូវបាត្រដែលភិក្ខុលះបង់ហើយទៅម្ចាស់បាត្រវិញ ។ ភិក្ខុទាំងឡាយបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាត្រដែល

គេលះបង់ហើយ ភិក្ខុមិនឲ្យវិញមិនគួរទេ ភិក្ខុណាមិនឲ្យវិញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

## សិក្ខាបទទី ១ ចប់

# អដ្ឋកថា

# បត្តវគ្គ សិក្ខាបទទី ១

# បត្តសិក្ខាបទ

[ ១១៧ ] *បត្តសិក្ខាបទ មានបទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងបត្តសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះថា បទថា* **បត្តវណិជ្ជំ** *សេចក្ដីថា ពួកសមណៈ ពូជពង្សក្យបុត្រ នឹងត្រាច់ធ្វើការលក់បាត្រ ឬបើករាន លក់ភាជនៈដី ក្នុងស្រុក និងនិគមជាដើម ។ ភាជនៈ លោកហៅថា* **អាមត្ត** *( ក្នុងបទថា* **អាមត្តិកាបណំ** *) ភាជនៈទាំងនោះ ជាទំនិញរបស់ជនពួកណា ជនទាំងនោះ ឈ្មោះថា* **អាមត្តិកា** *( អ្នកមានភាជនៈជាជំនួញ ) ។ រានផ្សាររបស់អ្នកមានភាជនៈជាទំនិញនោះ ឈ្មោះថា* **អាមត្តិកាបណា** ។ *អធិប្បាយថា រានលក់ដូររបស់ពួកស្មូនឆ្នាំង ។*

# អធិប្បាយ

# សិក្ខាបទវិភង្គនៃបត្តសិក្ខាបទ

[ ១១៩ ] *ច្រើនបទថា* **តយោ បត្តស្ស វណ្ណា** *បានដល់ ទំហំនៃបាត្រ ៣ ខ្នាត ។*

*ពីរបទថា* **អឌ្ឍាឡ្ហកោទនំ គណ្ហាតិ** *សេចក្ដីថា រមែងដាក់បាយនៃអង្ករ ២ នាឡិ ដោយនាឡិមគធៈ ។ ក្នុងអន្ធកអដ្ឋកថា ពោលថា ដែលឈ្មោះថា មួយនាឡិមគធៈ មាន ១២ បលៈកន្លះ ក្នុងមហាអដ្ឋកថា ពោលថា ក្នុងកោះសីហឡ នាឡិតាមប្រក្រតី ធំ នាឡិរបស់ជនជាតិទមិឡ តូច នាឡិ*

មគធៈ ជានាឡិត្រូវខ្នាត ។ កន្លះនាឡិ ដោយនាឡិមគធៈនោះ ជាមួយនាឡិសីហឡ ។

បទថា **ចតុព្ភាគំ ខាទនីយំ** សេចក្ដីថា របស់ទំពាប្រមាណប៉ុនចំណែកទី ៤ នៃបាយ ។ ខាទនីយនោះ គប្បីជ្រាបដោយអំណាចនៃសម្លសណ្ដែកបាយ ល្មមចាប់ដោយដៃបាន ។

ពីរបទថា **តទុបិយំ ព្យញ្ជនំ** សេចក្ដីថា ម្ហូប មានត្រី សាច់ ជ្រក់ផ្លែឈើ និងទំពាំងជាដើម ដែលសមគួរដល់បាយនោះ ។

ក្នុងបាត្រនោះ មានវិនិច្ឆ័យដូចតទៅនេះថា គប្បីយកអង្ករនៃស្រូវសាលីចាស់ដែលមិនបាក់ ដែលស្រិតបរិសុទ្ធល្អហើយ ២ នាឡិគមធៈ ចម្អិនឲ្យទៅជាបាយដោយអង្ករទាំងនោះមិនជាត់ទឹក មិនជាបាយពងបង្កួយ មិនជ្រាយមិនជាដុំ ជ្រួយឲ្យល្អ ឲ្យដូចជាគំនរផ្កាម្លិះក្រពុំក្នុងថ្នាំង ហើយដាក់ចុះក្នុងបាត្រមិនឲ្យសល់ បន្ថែមសម្លឧត្តរិភង្គ ដែលផ្សំដោយគ្រឿងផ្សំគ្រប់យ៉ាង មិនខាប់ពេក មិនរាវពេក ល្មមចាប់នឹងដៃបាន ប្រមាណប៉ុនចំណែកទី ៤ នៃបាយនោះ បន្ទាប់ពីនោះ ទើបបន្ថែមម្ហូប មានត្រី សាច់ជាដើមចូលទៅសមគួរ ដល់បាយជាពំនូតៗ រហូតគ្រប់គ្រាន់នឹងពំនូតបាយយ៉ាងក្រៃលែង ។ ឯទឹកដោះថ្លាប្រេង ទឹកដោះជូរ និងទឹកអង្ករជាដើម មិនគួររាប់ ។ ព្រោះរបស់ទាំងនោះមានគតិដូចបាយនោះឯង មិនអាចដើម្បីនឹងបន្ថយចុះ និងមិនអាចបន្ថែមឡើងបាន ។ អាហារដែលដាក់ចូលយ៉ាងនេះ ទាំងអស់នោះ បើតាំងនៅស្មើខាងក្រោមនៃកណ្ដាប់មាត់បាត្រ កាលយកសរសៃអំបោះ ឬចម្រៀកឈើ ( ដក់

ត្នោត ) កៀសទៅ ( របស់ក្នុងបាត្រនេះ ) ត្រូវទីបំផុតខាងក្រោមនៃសរសៃអំបោះ ឬចម្រៀកឈើនោះ ( គឺរបស់ក្នុងបាត្រ មានបាយពីរនាឡិជាដើមនេះ ត្រូវទីបំផុតខាងក្រោមនៃអំបោះ ឬចម្រៀកឈើ ឬជក់ត្នោតរបស់បុគ្គល ត្រូវកៀសដោយអំបោះ ឬចម្រៀកឈើ ឬដោយជក់ត្នោត ) នោះ បាត្រនេះឈ្មោះថា បាត្រខ្នាតធំ ( យ៉ាងកណ្ដាល ) ។ បើរបស់ក្នុងបាត្រនោះកំពង់ជាកំពូល ហួស ( កណ្ដាប់មាត់បាត្រ ) នោះឡើងមក បាត្រនេះឈ្មោះថា បាត្រខ្នាតធំ យ៉ាងតូច ។ បើរបស់ក្នុងបាត្រនោះមិនដល់កណ្ដាប់ ( មាត់បាត្រ ) នៅខាងក្រោមប៉ុណ្ណោះ បាត្រនេះ ឈ្មោះថា បាត្រខ្នាតធំ យ៉ាងធំ ។

បទថា **នាឡិកោទនំ** បានដល់ បាយនៃអង្ករមួយនាឡិ ដោយនាឡិមគធៈ ។

បទថា **បត្ថោទនំ** បានដល់ បាយកន្លះនាឡិ ដោយនាឡិមគធៈ ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ តែមានសេចក្ដីប្លែកគ្នា ក្នុងហេតុត្រឹមតែឈ្មោះដូចតទៅនេះថា បើរបស់មានបាយមួយនាឡិជាដើម ទាំងអស់នោះ ដែលដាក់ចូលហើយ នៅស្មើកណ្ដាប់មាត់ខាងក្រោម ដោយមានន័យដូចពោលហើយនោះឯង បាត្រនេះឈ្មោះថា បាត្រខ្នាតកណ្ដាល ( យ៉ាងកណ្ដាល ) ។ បើរបស់កំពង់ជាកំពូលហួសកណ្ដាប់មាត់បាត្រឡើងមក បាត្រនេះ ឈ្មោះថា បាត្រខ្នាតកណ្ដាលយ៉ាងតូច ។ បើមិនដល់កណ្ដាប់មាត់នោះ នៅត្រឹមខាងក្រោមប៉ុណ្ណោះ បាត្រនេះ ឈ្មោះថា បាត្រខ្នាតកណ្ដាលយ៉ាងធំ ។

បើរបស់ទាំងអស់ មានបាយប្រមាណកន្ទះនាឡិជាដើម ដែលដាក់ចូលហើយ នៅស្មើកណ្ដាប់ខាងក្រោម ( នៃមាត់បាត្រ ) បាត្រនេះឈ្មោះថា បាត្រខ្នាតតូច ( យ៉ាងកណ្ដាល ) ។ បើរបស់កំពង់ជាកំពូលហួសកណ្ដាប់មាត់បាត្រនោះឡើងមក បាត្រនេះឈ្មោះថា បាត្រខ្នាតតូចយ៉ាងតូច ។ បើរបស់មិនដល់កណ្ដាប់មាត់បាត្រនោះ នៅខាងក្រោមប៉ុណ្ណោះ បាត្រនេះឈ្មោះថា បាត្រខ្នាតតូចយ៉ាងធំ ។ អ្នកសិក្សាគប្បីជ្រាបបាត្រទាំង ៩ ប្រភេទនេះដោយប្រការដូចពោលមកដូច្នេះឯង ។

បណ្ដាបាត្រ ៩ ប្រភេទនោះ បាត្រ ២ ប្រភេទ គឺបាត្រខ្នាតធំយ៉ាងធំ ១ បាត្រខ្នាតតូចយ៉ាងតូច ១ មិនឈ្មោះថា ជាបាត្រ ( ជាបាត្រប្រើមិនបាន ) ។ ពិតហើយ ពាក្យថា ធំជាងនោះមិនមែនបាត្រ តូចជាងនោះមិនមែនបាត្រ នេះត្រាស់សំដៅយកបាត្រ ២ ប្រភេទនោះ ។ ពិតហើយ បណ្ដាបាត្រ ២ ប្រភេទ បាត្រខ្នាតធំយ៉ាងធំ គឺធំជាងនោះ ទ្រង់ត្រាស់ថា មិនមែនបាត្រ ព្រោះធំជាងខ្នាតធំ ។ ហើយបាត្រខ្នាតតូចយ៉ាងតូច គឺតូចជាងនោះ ទ្រង់ត្រាស់ថា មិនមែនបាត្រ ព្រោះតូចជាងខ្នាតតូច ។ ព្រោះដូច្នោះ បាត្រទាំងនេះ គួរប្រើប្រាស់ជាភាជនៈ មិនគួរអធិដ្ឋាន មិនគួរវិកប្ប ។ ចំណែកបាត្រ ៧ ប្រភេទ ក្រៅពីនេះ គប្បីអធិដ្ឋាន ឬ វិកប្បទុកប្រើប្រាស់ចុះ ។

[ ១២០ ] កាលភិក្ខុមិនធ្វើយ៉ាងនេះ ឲ្យបាត្រនោះកន្លង ១០ ថ្ងៃទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ គឺកាលភិក្ខុឲ្យបាត្រទាំង ៧ ប្រភេទកន្លងកាលមាន ១០ ថ្ងៃ យ៉ាងក្រៃលែងទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដូច្នេះ ។

[ ១២៥ ] បទថា **និស្សគ្គិយំ បត្តំ អនិស្សជ្ជិត្វា បរិភុញ្ជតិ** គប្បីជ្រាបសេចក្តីថា ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគយ៉ាងនេះ គឺកាលកិក្ខុហុតបបរ ហើយលាងបាត្រ ត្រូវអាបត្តិទុក្កដ កាលឆាន់របស់គួរទំពា ឆាន់កត្តាហារ ហើយលាងបាត្រ ត្រូវអាបត្តិទុក្កដ ។

## អនាបត្តិនៃបត្តសិក្ខាបទ

[ ១២៦ ] ក្នុងបទថា **អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ** នេះ អ្នកសិក្សាគប្បីជ្រាបបាត្រដែលបានប្រមាណ ជាបាត្រគួរអធិដ្ឋាន និងវិកប្បដោយន័យដូចពោលយ៉ាងនេះថា បាត្រដែកដុតហើយ ដោយការដុត ៥ ភ្លើង បាត្រដីដុតហើយ ដោយការដុត ២ ភ្លើង ទើបគួរអធិដ្ឋាន ។ បាត្រទាំង ២ ប្រភេទ កាលឲ្យមូលតម្លៃដែលគួរឲ្យហើយនោះឯង បើការដុតនៅខ្វះសូម្បីត្រឹមតែម្តង ឬមិនទាន់បានឲ្យមូលតម្លៃត្រឹមមួយកាកណិក មិនគួរអធិដ្ឋាន ។ បើម្ចាស់បាត្រពោលថា សូមលោកម្ចាស់ឲ្យបន្ទ្រប់ ក្នុងវេលាលោកម្ចាស់មានតម្លៃក៏បាន សូមលោកម្ចាស់គួរអធិដ្ឋានប្រើប្រាស់ចុះ ដូច្នេះក៏មិនគួរអធិដ្ឋានពិត ព្រោះថា មិនដល់នូវការរាប់ថាជាបាត្រ ព្រោះការដុតនៅខ្វះ មិនដល់នូវភាពជាបាត្ររបស់ខ្លួន នៅជារបស់អ្នកដទៃនោះឯង ព្រោះមូលតម្លៃទាំងអស់ ឬចំណែកមួយមិនទាន់បានឲ្យ ព្រោះដូច្នោះ កាលដុត និងកាលឲ្យមូលតម្លៃស្រេចហើយនោះឯង ទើបជាបាត្រគួរអធិដ្ឋាន បាត្រដែលគួរអធិដ្ឋានទាំងនោះ ទើបគួរវិកប្ប ។ បាត្រនោះមកដល់ដៃហើយក្តី មិនទាន់មកដល់ក្តី គួរអធិដ្ឋាន ឬគួរវិកប្បនោះឯង ។

បើជាងបាត្របានមូលតម្លៃហើយក្តី ជាអ្នកបំណាងប្រគេនឯងក្តី ពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងធ្វើបាត្រប្រគេនលោកម្ចាស់ ដុតហើយក្នុងថ្ងៃឈ្មោះនោះ នឹងទុកដាក់ ហើយភិក្ខុឲ្យកន្លង ១០ ថ្ងៃទៅ អំពីថ្ងៃដែលជាងធ្វើបាត្រនោះកំណត់ទុក ជានិស្សគ្គិយបាចិត្តិយ ។ បើជាងបាត្រពោលថា ខ្ញុំនឹងធ្វើបាត្រប្រគេនលោកម្ចាស់ ដុតហើយ នឹងបញ្ជូនដំណឹងមកឲ្យជ្រាប ហើយធ្វើដូច្នោះ ចំណែកភិក្ខុបុគ្គលដែលជាងបាត្រនោះពឹងពាក់ទៅ មិនប្រាប់ដល់ភិក្ខុនោះ ភិក្ខុដទៃឃើញ ឬបានឮ ទើបប្រាប់ថា អាវុសោ បាត្ររបស់លោកសម្រេចហើយ ការប្រាប់របស់ភិក្ខុនោះមិនជាប្រមាណ ។ តែក្នុងវេលាដែលភិក្ខុត្រូវជាងបាត្រនោះពឹងពាក់នោះឯងប្រាប់ កាលភិក្ខុឲ្យកន្លង ១០ ថ្ងៃ ទៅ ចាប់ពីថ្ងៃដែលបានឮពាក្យប្រាប់របស់ភិក្ខុនោះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ បើជាងបាត្រពោលថា ខ្ញុំនឹងធ្វើបាត្រប្រគេនលោកម្ចាស់ ដុតហើយ នឹងបញ្ជូនទៅក្នុងដៃរបស់ភិក្ខុណាមួយ ហើយធ្វើតាមពាក្យសម្តីនោះ តែភិក្ខុដែលទទួលបាត្រយកមកទុកក្នុងបរិវេណរបស់ខ្លួនហើយ មិនប្រាប់ដល់ភិក្ខុនោះ ភិក្ខុដទៃណាមួយពោលថា លោកម្ចាស់ បាត្រដែលបានមកថ្មី ល្អឬទេ ភិក្ខុពោលថា លោកម្ចាស់ បាត្រឯណា ភិក្ខុនោះពោលថា ជាងបាត្របញ្ជូនមកក្នុងដៃរបស់ភិក្ខុឈ្មោះនេះ ។ ពាក្យសម្តីរបស់ភិក្ខុនេះ ក៏មិនជាប្រមាណ ។ តែក្នុងវេលាដែលភិក្ខុនោះឲ្យបាត្រ កាលភិក្ខុទុកឲ្យកន្លង ១០ ថ្ងៃទៅ រាប់អំពីថ្ងៃដែលបានបាត្រមក ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ព្រោះដូច្នោះ កុំឲ្យកន្លង ១០ ថ្ងៃ គប្បីអធិដ្ឋាន ឬវិកប្ប ។

# ការអធិដ្ឋានបាត្រ

បណ្តាការអធិដ្ឋាន និងវិកប្បនោះ អធិដ្ឋានមាន ២ គឺអធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ ភិក្ខុកាលអធិដ្ឋានដោយអំណាចនៃការអធិដ្ឋាន ២ យ៉ាងនោះ គប្បីបច្ចុទ្ធរណៈបាត្រចាស់ដែលតាំងនៅចំពោះមុខ ឬក្នុងទីកំបាំងមុខយ៉ាងនេះថា **ឥមំ បត្តំ បច្ចុទ្ធរាមិ** ប្រែថា ខ្ញុំដកបាត្រនេះក្តី ឬថា **ឯតំ បត្តំ បច្ចុទ្ធរាមិ** ប្រែថា ខ្ញុំដកបាត្រនោះក្តី ឲ្យដល់ភិក្ខុដទៃហើយ យកដៃអង្អែលបាត្រថ្មី ដែលតាំងនៅក្នុងទីកន្លែងឯណាមួយ ធ្វើការរំពឹងដោយចិត្ត ហើយធ្វើកាយវិការអធិដ្ឋានដោយកាយ ឬបន្លឺវាចា ហើយអធិដ្ឋានដោយវាចាថា **ឥមំ បត្តំ អធិដ្ឋាមិ** ប្រែថា ខ្ញុំអធិដ្ឋាននូវបាត្រនេះ ។

ក្នុងអធិដ្ឋានវិស័យនេះ អធិដ្ឋានមាន ២ យ៉ាង ។ បើបាត្រនៅក្នុងហត្ថបាស គប្បីបន្លឺវាចាថា **ឥមំ បត្តំ អធិដ្ឋាមិ** ខ្ញុំអធិដ្ឋានបាត្រនេះ បើបាត្រនោះនៅក្នុងបន្ទប់ក្តី ប្រាសាទជាន់លើក្តី ក្នុងវិហារជិតខាងក្តី ភិក្ខុគប្បីកំណត់ទីដែលបាត្រតាំងនៅ ហើយគប្បីបន្លឺវាចាថា **ឯតំ បត្តំ អធិដ្ឋាមិ** ខ្ញុំអធិដ្ឋានបាត្រនោះ ។ ភិក្ខុអ្នកអធិដ្ឋាន សូម្បីអធិដ្ឋានមួយអង្គឯងក៏គួរ សូម្បីអធិដ្ឋានក្នុងសម្នាក់ភិក្ខុដទៃក៏គួរ ។ ការអធិដ្ឋានក្នុងសម្នាក់ភិក្ខុដទៃ មានអានិសង្សដូចតទៅនេះ បើលោកកើតការសន្ទិះសង្ស័យថា បាត្រ អាត្មាអញអធិដ្ឋានហើយឬនៅហ្ន៎ ដូច្នេះ ភិក្ខុមួយអង្គទៀត នឹងជាសាក្សីនៀនឲ្យរឭកបាន កាត់ការសង្ស័យនោះ ។ បើភិក្ខុអង្គខ្លះ បានបាត្រមកចំនួន ១០ ខ្ទង់ឯង បំណងនឹងប្រើប្រាស់ទាំងអស់នោះឯង មិនគប្បីអធិដ្ឋានទាំងអស់ ។ អធិដ្ឋានបាត្រ ១ ហើយ ថ្ងៃរះឡើង បច្ចុទ្ធបាត្រនោះ ហើយអធិដ្ឋានបាត្រ ១ ថ្មី ៗ ដោយ

ឧបាយនេះ នឹងបានបរិហារ ( ការរក្សា ) អស់រយៈនៃឆ្នាំ ។

## ការដាច់អធិដ្ឋាននៃបាត្រ

សួរថា ការដាច់អធិដ្ឋាន គប្បីមានដល់ភិក្ខុដែលមិនប្រមាទយ៉ាងនេះបានឬ ឆ្លើយថា គប្បីមាន បើភិក្ខុនេះឲ្យបាត្រដល់ភិក្ខុដទៃក្តី ត្រឡប់យល់ខុសក្តី ពោលលាសិក្ខាក្តី ធ្វើមរណកាលក្តី ប្រែភេទក្តី បច្ចុទ្ធរោលក្តី បាត្រមានប្រហោងធ្លុះក្តី បាត្ររមែងដាច់អធិដ្ឋាន ហើយពាក្យនេះ អាចារ្យទាំងឡាយក៏បានពោលទុកថា

ការដាច់អធិដ្ឋាន រមែងមានដោយការឲ្យ ១ ត្រឡប់យល់ខុស ១ លាសិក្ខា ១ ធ្វើមរណកាល ១ ភេទត្រឡប់ ១ បច្ចុទ្ធ ឬ ដក ១ និងមានប្រហោងធ្លុះជាគម្រប់ ៧ ដូច្នេះ ។

សូម្បីព្រោះចោរលួច និងការកាន់យកដោយវិស្សាសៈ បាត្រក៏ដាច់អធិដ្ឋានដូចគ្នា ។ បាត្រនឹងដាច់អធិដ្ឋានដោយប្រហោងធ្លុះ មានប្រមាណប៉ុនណា នឹងដាច់អធិដ្ឋានដោយប្រហោងធ្លុះល្មមគ្រាប់ថ្កៅជ្រុះចេញបាន នឹងញាត់ចូលបាន ។

ពិតហើយ បណ្តាធញ្ញជាតិ ៧ ប្រភេទ គ្រាប់ថ្កៅនេះ ជាគ្រាប់ធញ្ញជាតិយ៉ាងតូច កាលប្រហោងនោះបិទឲ្យត្រឡប់ជាប្រក្រតី ដោយកម្ទេចដែក ឬដោយស្ពាន់ហើយ គប្បីអធិដ្ឋានបាត្រនោះជាថ្មីខាងក្នុង ១០ ថ្ងៃ ។ ក្នុងការអធិដ្ឋានដែលត្រាស់ទុកក្នុងបទថា **អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ** នេះ មានវិនិច្ឆ័យត្រឹមប៉ុណ្ណោះឯង ។

# ការវិកប្បបាត្រ

ក្នុងការវិកប្ប មានវិនិច្ឆ័យដូចតទៅនេះថា វិកប្បមាន ២ យ៉ាង គឺ វិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។ វិកប្បចំពោះមុខដូចម្តេច គឺភិក្ខុគប្បីដឹងថា បាត្រមាន ១ ឬច្រើន នឹងទុកក្នុងទីជិត ឬមិនបានទុកក្នុងទីជិត ហើយពោលថា **ឥមំ បត្តំ** នូវបាត្រនេះក្តី **ឥមេ បត្តេ** នូវបាត្រទាំងនេះក្តី **ឯតំ បត្តំ** នូវបាត្រនោះក្តី **ឯតេ បត្តេ** នូវបាត្រទាំងនោះក្តី ហើយពោលថា **តុយ្ហំ វិកប្បេមិ** ខ្ញុំវិកប្បដល់លោក នេះឈ្មោះថា វិកប្បចំពោះមុខមួយបែប ដោយវិធីវិកប្បមានប្រមាណប៉ុណ្ណេះ នឹងរក្សាទុកដាក់ គួរ ។ តែប្រើប្រាស់ក្តី ចំណាយក្តី អធិដ្ឋានក្តី មិនគួរ ។ តែកាលភិក្ខុទទួលវិកប្ប ពោលយ៉ាងនេះថា **មយ្ហំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** បាត្រនេះរបស់ខ្ញុំ លោកចូរប្រើប្រាស់ ចូរចំណាយក្តី ចូរធ្វើតាមបច្ច័យក្តី ដូច្នេះ ឈ្មោះថា ដក ។ ចាប់ផ្តើមអំពីនោះ សូម្បីការប្រើប្រាស់ជាដើម គួរ ។

ម្យ៉ាងទៀត ភិក្ខុជ្រាបថា បាត្រមាន ១ ឬច្រើន ហើយទុកជិត ឬមិនបានទុកជិតយ៉ាងនោះដូចគ្នា ពោលថា **ឥមំ បត្តំ** នូវបាត្រនេះក្តី **ឥមេ បត្តេ** នូវបាត្រទាំងឡាយនេះក្តី **ឯតំ បត្តំ** នូវបាត្រនោះក្តី **ឯតេ បត្តេ** នូវបាត្រទាំងឡាយនោះក្តី ក្នុងសម្នាក់របស់ភិក្ខុនោះឯង ហើយប្រារព្ធឈ្មោះបណ្តាសហធម្មិកទាំង ៥ ណាមួយ គឺអ្នកណាមួយដែលខ្លួនពេញចិត្ត ហើយគប្បីពោលថា **តិស្សស្ស ភិក្ខុនោ វិកប្បេមិ** ខ្ញុំវិកប្បដល់ភិក្ខុឈ្មោះតិស្សៈដូច្នេះក្តី **តិស្សាយ ភិក្ខុនិយា ... តិស្សាយ សិក្ខមានាយ ... តិស្សស្ស សាមណេរស្ស ... តិស្សាយ សាមណេរិយា វិកប្បេមិ** ខ្ញុំវិកប្បដល់ភិក្ខុនី

*ឈ្មោះតិស្សា ... ដល់សិក្ខមានាឈ្មោះតិស្សា ... ដល់សាមណេរឈ្មោះតិស្សៈ ... ដល់សាមណេរីឈ្មោះតិស្សា ដូច្នេះក្តី នេះឈ្មោះថា វិកប្បចំពោះមុខមួយបែបទៀត ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ទោះទុកដាក់ គួរ តែបណ្តាកិច្ច មានការបរិភោគជាដើម សូម្បីកិច្ចណាមួយ ក៏មិនគួរ ។ តែកាលភិក្ខុអ្នកទទួលវិកប្បនោះពោលថា* **តិស្សស្ស ភិក្ខុនោ សន្តកំ ។បេ។ តិស្សាយ សាមណេរិយា សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** *បាត្រនេះរបស់ភិក្ខុឈ្មោះតិស្សៈ ។បេ។ របស់សាមណេរីឈ្មោះតិស្សា សូមលោកប្រើប្រាស់ក្តី សូមចំណាយក្តី សូមធ្វើតាមបច្ច័យក្តី ដូច្នេះហើយ ឈ្មោះថា ដក ។ ចាប់អំពីនោះ សូម្បីការបរិភោគជាដើម ក៏សមគួរ ។*

*វិកប្បកំបាំងមុខដូចម្តេច គឺភិក្ខុជ្រាបថា បាត្រមានមួយក្តី ច្រើនក្តី ទុកក្នុងទីជិតក្តី ក្នុងទីឆ្ងាយក្តី យ៉ាងនោះឯង ហើយពោលថា* **ឥមំ បត្តំ** *នូវបាត្រនេះក្តី* **ឥមេ បត្តេ** *នូវបាត្រទាំងនេះក្តី* **ឯតំ បត្តំ** *នូវបាត្រនោះក្តី* **ឯតេ បត្តេ** *នូវបាត្រទាំងនោះក្តី ហើយពោលថា* **តុយ្ហំ វិកប្បនត្ថាយ ទម្មិ** *ខ្ញុំឲ្យដល់លោកដើម្បីត្រូវការវិកប្បដូច្នេះ ។*

*ភិក្ខុអ្នកទទួលវិកប្បនោះ គប្បីសួរលោកថា នរណាជាមិត្រ ឬជាសម្លាញ់ឃើញគ្នារបស់លោក ។ លំដាប់នោះ ភិក្ខុអ្នកវិកប្ប គប្បីពោលថា* **តិស្សោ ភិក្ខុ** *ភិក្ខុឈ្មោះតិស្សៈ ។បេ។ ឬ* **តិស្សា សាមណេរី** *សាមណេរីឈ្មោះតិស្សាដោយន័យមុននោះឯង ។ ភិក្ខុនោះ គប្បីពោលទៀតថា* **អហំ តិស្សស្ស ភិក្ខុនោ ទម្មិ ។បេ។** *ឬថា* **តិស្សាយ សាមណេរិយា ទម្មិ** *ខ្ញុំឲ្យដល់*

ភិក្ខុឈ្មោះតិស្សៈ ។បេ។ ឬថា ខ្ញុំឲ្យដល់សាមណេរីឈ្មោះតិស្សា នេះឈ្មោះថា វិកប្បកំបាំងមុខ ។ ដោយការវិកប្បត្រឹមប៉ុណ្ណោះ ទោះរក្សាទុក គួរ តែបណ្តាកិច្ច មានការបរិភោគជាដើម សូម្បីកិច្ចណាមួយ មិនគួរ ។ កាលភិក្ខុអ្នកទទួលវិកប្បពោលថា **តុម្ហាកំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** បាត្រនេះ របស់ភិក្ខុឈ្មោះនេះ លោកចូរប្រើប្រាស់ក្តី ចូរចំណាយក្តី ចូរធ្វើតាមបច្ច័យក្តី ដោយន័យដូចពោលហើយ ក្នុងវិកប្បចំពោះមុខបែបទី ២ នោះឯង រមែងឈ្មោះថា ដក ។ ចាប់អំពីនោះទៅ សូម្បីការប្រើប្រាស់ជាដើម ក៏គួរ ។ តែការបែកផ្សេងគ្នានៃវិកប្បទាំង ២ យ៉ាងនេះ និងលំដាប់នៃការពណ៌នាដែលនៅសល់ទាំងអស់ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងពណ៌នានៃបឋមកឋិនសិក្ខាបទនោះ ឯងមួយអន្លើដោយសមុដ្ឋានជាដើម ដូច្នេះឯង ។

បត្តសិក្ខាបទទី ១ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[ ១២៨ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលសម្រេចឥរិយាបថក្នុងនិគ្រោធារាម ជិតក្រុងកបិលវត្ថុ នាដែនសក្កៈ ។ សម័យនោះឯង ស្មូនឆ្នាំងម្នាក់ បវារណាភិក្ខុទាំងឡាយដោយពាក្យថា លោកម្ចាស់ទាំងឡាយណាមានសេចក្តីត្រូវការដោយបាត្រ ខ្ញុំព្រះករុណានឹងប្រគេនបាត្រដល់លោកម្ចាស់អង្គនោះៗ ។ ខណៈនោះឯង ភិក្ខុទាំងឡាយមិនដឹងប្រមាណ សូមបាត្រទាំងឡាយ ជាច្រើន ។ ពួកភិក្ខុណាមានបាត្រតូចៗ ភិក្ខុទាំងនោះក៏សូមបាត្រធំៗ ។ ពួកភិក្ខុណាដែលមានបាត្រធំៗ ភិក្ខុទាំងនោះក៏សូមបាត្រតូចៗ ។ គ្រានោះឯង ស្មូនឆ្នាំងនោះរវល់ធ្វើបាត្រជាច្រើនប្រគេនពួកភិក្ខុ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍ សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមខ្លួនក៏មិនបាន កូននិងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោត ក៏ព្រួយលំបាក ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធ ជាសក្យបុត្រ មិនដឹងប្រមាណ ហើយសូមបាត្រជាច្រើន ស្មូនឆ្នាំងនេះរវល់តែធ្វើបាត្រជាច្រើន ប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើនូវភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនបាន កូននិងប្រពន្ធទាំង-ឡាយរបស់ស្មូនឆ្នាំងនោះសោត ក៏ព្រួយលំបាក ។ ភិក្ខុទាំងឡាយបានស្តាប់ច្បាស់ពាក្យដែលមនុស្សទាំងឡាយនោះ កំពុងពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ភិក្ខុទាំងឡាយមិនដឹងប្រមាណ

ហើយសូមបាត្រជាច្រើន ។ ខណៈនោះ ពួកភិក្ខុនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយមិនដឹងប្រមាណ ហើយសូមបាត្រជាច្រើន ពិតមែនឬ ។ ភិក្ខុទាំងឡាយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរមោឃបុរសទាំងនោះ មិនដឹងប្រមាណ ហើយសូមបាត្រជាច្រើន ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឲ្យរឹងរឹតតែជ្រះថ្លា ដល់ពួកជនដែលជ្រះហើយក៏ទេ ។បេ។ លុះត្រាស់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថា ត្រាស់ហៅពួកភិក្ខុមក ទើបទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសូមបាត្រឡើយ ភិក្ខុណាសូម ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[ ១២៩ ] សម័យនោះឯង ភិក្ខុមួយរូបមានបាត្របែក ។ ឯភិក្ខុនោះសង្ស័យថា ការសូមបាត្រ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ មិនហ៊ានសូមបាត្រ ក៏ប្រព្រឹត្តបិណ្ឌបាតដោយដៃទទេ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្រ មិនសមបីបើនឹងចរទៅបិណ្ឌបាតដោយដៃទទេ ដូចជាពួកតិរ្ថិយសោះ ។ ភិក្ខុទាំងឡាយ បានស្តាប់ច្បាស់ នូវពាក្យដែលមនុស្សទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា

ត្រាស់ហៅពួកភិក្ខុមក ហើយទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក ត្រូវសូមបាត្របាន ។

[ ១៣០ ] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ព្រះដ៏មានព្រះភាគ បានទ្រង់អនុញ្ញាតឲ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក គួរសូមបាត្របាន ដូច្នេះ សូម្បីមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច ក៏គ្មានដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ។ គ្រានោះ ស្មូនឆ្នាំងនោះរវល់ធ្វើបាត្រជាច្រើន ប្រគេនភិក្ខុទាំងឡាយ ដូចកាលជាន់មុន ក៏មិនអាចនឹងធ្វើភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននិងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះក៏ព្រួយលំបាក ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ដូចកាលជាន់មុនទៀតថា ហេតុអ្វី បានជាសមណៈទាំងឡាយ ជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្រមិនដឹងប្រមាណ សូមបាត្រគេជាច្រើន ស្មូនឆ្នាំងនេះ រវល់តែធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍ដទៃសម្រាប់ចំណាយបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននិងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោត ក៏ព្រួយលំបាក ។ ភិក្ខុទាំងឡាយបានឮពាក្យដែលពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាពួកឆព្វគ្គិយភិក្ខុ មានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច មិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ មានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច ក៏មិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ហេតុអ្វី បានជាអ្នកទាំងឡាយមានបាត្របែកតែបន្តិចបន្តួចខ្លះ ធ្លុះតែបន្តិចបន្តួចខ្លះ ដាច់តែបន្តិចបន្តួចខ្លះ ស្នាមប្រេះតែបន្តិចបន្តួចខ្លះ ក៏មិនដឹងប្រមាណ ហើយនាំគ្នា សូមបាត្រជាច្រើន ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ មានបាត្រមិនទាន់មានចំណងគ្រប់ ៥ អន្លើ ឲ្យគេរកបាត្រថ្មីទៀត (បាត្រនោះ) ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនោះត្រូវលះបង់បាត្រនោះក្នុងភិក្ខុបរិស័ទ ។ បាត្រណាជាទីបំផុតរបស់ភិក្ខុបរិស័ទនោះ បាត្រនោះ ភិក្ខុដែលបានសន្មតត្រូវប្រគល់បាត្រនោះឲ្យដល់ភិក្ខុនោះ ដោយពាក្យថា ម្នាលភិក្ខុ នេះបាត្ររបស់លោកៗ គប្បីប្រើប្រាស់ត្រាតែបែក ។ នេះជាសាមីចិកម្ម (គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ ។

[ ១៣១ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ បាត្រដែលគ្មានចំណង ឬមានចំណងតែមួយអន្លើ ឬពីរអន្លើ

បីអន្លើ បួនអន្លើ ហៅថា បាត្រមានចំណាំងមិនទាន់ដល់ ៥ អន្លើ បាត្រដែលមានស្នាមប្រេះបែក មិនទាន់ដល់ពីរធ្នាប់ ហៅថា បាត្រមិនទាន់មានឱកាសនៃចំណាំង ។ បាត្រដែលមានស្នាមប្រេះបែកប្រមាណដល់ ២ ធ្នាប់ ហៅថា បាត្រមានឱកាសនៃចំណាំង ( មួយអន្លើ ) ។ ដែលហៅថាបាត្រថ្មី សំដៅយកការសូមបាត្រជាប្រមាណ ។ ពាក្យថា ឲ្យគេរក សេចក្តីថា ភិក្ខុសូមបាត្រត្រូវអាបត្តិទុក្កដតាមប្រយោគ បាត្រនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ ក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងពួងត្រូវយកបាត្រដែលភិក្ខុបានអធិដ្ឋានហើយ ទៅប្រជុំគ្នា ។ ភិក្ខុមិនត្រូវអធិដ្ឋានបាត្រអាក្រក់ទុក ដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន ។ បើភិក្ខុអធិដ្ឋានបាត្រអាក្រក់ទុក ដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់បាត្រយ៉ាងនេះ ។

[ ១៣២ ] ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន បាត្រ ( ថ្មី ) របស់ខ្ញុំនេះ គឺខ្ញុំមានបាត្រ ( ចាស់ ) មិនទាន់មានចំណាំងគ្រប់ ៥ អន្លើ ខ្ញុំឲ្យគេរក បាត្រទៀត បាត្រនេះជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់សង្ឃ ។ លុះភិក្ខុលះបង់បាត្ររួចហើយ ត្រូវសម្តែងអាបត្តិចេញ ។ ភិក្ខុអ្នកឈ្លាសអង់អាចត្រូវទទួលអាបត្តិ ។ សង្ឃត្រូវសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកប្រគល់បាត្រ គឺ ភិក្ខុណាមួយដែលមិនបានប្រព្រឹត្តទៅដោយឆន្ទាគតិ ១ ទោសាគតិ ១

មោហាគតិ ១ ភយាគតិ ១ ដឹងនូវបាត្រដែលគេបានទទួល និងមិនទាន់បានទទួល ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ ភិក្ខុឈ្លាសត្រូវអង្វរភិក្ខុ ( នោះ ) ជាមុន ។ លុះភិក្ខុឈ្លាសប្រតិពលអង្វររួចហើយគប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំបើកម្មនេះមាន កាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកប្រគល់បាត្រ ។ នេះវាចាប្រកាសសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ព្រះសង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវពោលឡើង ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រហើយ ។ ការសន្មតនេះសមគួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។ ភិក្ខុដែលសង្ឃសន្មតហើយនោះ ត្រូវប្រគល់បាត្រ ( ឲ្យព្រះថេរៈ ) ។ ភិក្ខុនោះត្រូវប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះថេរៈ ទទួលយកបាត្រចុះ ។ បើព្រះថេរៈទទួល ( បាត្រនោះ ) ភិក្ខុនោះត្រូវយកបាត្ររបស់ព្រះថេរៈប្រគល់ឲ្យភិក្ខុទី ២ ព្រះថេរៈ មិនត្រូវខានទទួលយកបាត្រនោះទេ ដោយសេចក្តីអាណិតភិក្ខុនោះ ភិក្ខុណាមួយមិនទទួល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះមិនត្រូវប្រគល់បាត្រដល់ភិក្ខុដែលគ្មានបាត្រទេ ។ ភិក្ខុនោះត្រូវប្រគល់បាត្រ ដោយឧបាយនេះ

ត្រាតែដល់ភិក្ខុខ្ទីក្នុងសង្ឃ ។ បាត្រណាមួយដែលជាទីបំផុត របស់ភិក្ខុបរិស័ទនោះ ភិក្ខុដែលសង្ឃបានសន្មតនោះ ត្រូវប្រគល់បាត្រឲ្យទៅភិក្ខុនោះ ដោយវាចាថា នែភិក្ខុ បាត្ររបស់លោកនេះ លោកចូរប្រើប្រាស់ត្រាតែបែក ។ ភិក្ខុនោះ មិនត្រូវទុកបាត្រក្នុងទីមិនគួរ មិនត្រូវប្រើប្រាស់បាត្រនោះ ដោយការប្រើប្រាស់មិនសមគួរ មិនត្រូវចោលបាត្រនោះឡើយ ។ ដោយពាក្យថា បាត្រនេះអប្រិយណាស់ បាត់ទៅចុះ ខូចទៅចុះ ឬបែកទៅចុះ បើភិក្ខុទុកដាក់មិនគួរក្តី ប្រើប្រាស់ដោយការប្រើប្រាស់មិនសមគួរក្តី លះបង់ចោលទៅក្តី ត្រូវអាបត្តិទុក្កដ ។ ពាក្យថា នេះជាសាមីចិកម្ម ( គឺការប្រពៃ ) ក្នុងការលះបង់បាត្រនោះ គឺថា ពាក្យនេះជាពាក្យសមគួរតាមធម៌ ក្នុងរឿងលះបង់បាត្រនោះ ។

[ ១៣៣ ] ភិក្ខុមានបាត្រមិនទាន់មានចំណាង ( បើ ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង ( បើ ) សុំបាត្រមានចំណាងតែមួយអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង ( បើ ) សុំបាត្រមានចំណាងតែពីរអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង ( បើ ) សុំបាត្រមានចំណាងបីអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង ( បើ ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្ទើ ( បើ ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្ទើ ( បើ ) សុំបាត្រមានចំណាងតែមួយអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្ទើ ( បើ ) សុំបាត្រ

មានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ ( បើ ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ ( បើ ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ ( បើ ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ ( បើ ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ ( បើ ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ ( បើ ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ ( បើ ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ ( បើ ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយ បាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ ( បើ ) សុំបាត្រមានចំណាង តែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ ( បើ ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ ( បើ ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ ( បើ ) សុំបាត្រមានចំណាង បួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ ( បើ ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ ( បើ ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាង

បួនអន្លើ ( បើ ) សុំបាត្រមានចំណាំងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបួនអន្លើ (បើ) សុំបាត្រមានចំណាំងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបួនអន្លើ ( បើ ) សុំបាត្រមានចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ១៣៤ ] ភិក្ខុមានបាត្រគ្មានចំណាំង ( បើ ) សុំបាត្រគ្មានឱកាសនៃចំណាំង ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងតែមួយអន្លើ ( បើ ) សុំបាត្រគ្មានឱកាសនៃចំណាំង ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... (បើ ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងពីរអន្លើ ( បើ ) សុំបាត្រគ្មានឱកាសនៃចំណាំង ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបីអន្លើ ( បើ ) សុំបាត្រគ្មានឱកាសនៃចំណាំង ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រ

មានឱកាសនៃចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណងបួនអន្លើ ( បើ ) សុំបាត្រគ្មានឱកាសនៃចំណង ... ( បើ ) សុំបាត្រមានឱកាសនៃចំណងតែមួយអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណងពីរអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ១៣៥ ] ភិក្ខុមានបាត្រគ្មានឱកាសនៃចំណង ( បើ ) សុំបាត្រឥតចំណង ... បាត្រមានចំណងតែមួយអន្លើ ... បាត្រមានចំណងពីរអន្លើ ... បាត្រមានចំណងបីអន្លើ ... ( បើ ) សុំបាត្រមានចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណងតែមួយអន្លើ ( បើ ) សុំបាត្រគ្មានចំណង ... បាត្រមានចំណងតែមួយអន្លើ ... បាត្រមានចំណងពីរអន្លើ ... បាត្រមានចំណងបីអន្លើ ... ( បើ ) សុំបាត្រមានចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណងពីរអន្លើ ( បើ ) សុំបាត្រឥតចំណង ... បាត្រមានចំណងតែមួយអន្លើ ... បាត្រមានចំណងពីរអន្លើ ... បាត្រមានចំណងបីអន្លើ ... ( បើ ) សុំបាត្រមានចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណងបីអន្លើ ( បើ ) សុំបាត្រឥតចំណង ... បាត្រមានចំណងតែមួយអន្លើ ... បាត្រមានចំណងពីរអន្លើ ... បាត្រមានចំណងបីអន្លើ ... ( បើ ) សុំបាត្រមានចំណងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណងបួនអន្លើ ( បើ ) សុំបាត្រឥតចំណង ... បាត្រមានចំណងតែមួយអន្លើ ... បាត្រមានចំណងពីរអន្លើ ...

បាត្រមានចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ១៣៦ ] ភិក្ខុមានបាត្រឥតឱកាសនៃចំណាំង ( បើ ) សុំបាត្រឥតឱកាសនៃចំណាំង ... បាត្រមានឱកាសនៃចំណាំងតែមួយអន្លើ... បាត្រមានឱកាសនៃចំណាំងពីរអន្លើ ... បាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ( បើ ) សុំបាត្រឥតឱកាសនៃចំណាំង ... បាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... បាត្រមានឱកាសនៃចំណាំងពីរអន្លើ ... បាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាំងពីរអន្លើ (បើ) សុំបាត្រឥតឱកាសនៃចំណាំង ... បាត្រមានឱកាសនៃចំណាំងមួយអន្លើ... បាត្រមានឱកាសនៃចំណាំងពីរអន្លើ... បាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាំងបីអន្លើ ( បើ ) សុំបាត្រឥតឱកាសនៃចំណាំង ... បាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... បាត្រមានឱកាសនៃចំណាំងពីរអន្លើ ... បាត្រមានឱកាសនៃចំណាំងបីអន្លើ ... ( បើ ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាំងបួនអន្លើ ( បើ ) សុំបាត្រឥតឱកាសនៃចំណាំង ... បាត្រមានឱកាសនៃចំណាំងតែមួយអន្លើ ... បាត្រមានឱកាសនៃចំណាំងពីរអន្លើ ... បាត្រមានឱកាសនៃចំណាំង បីអន្លើ ...

( បើ ) សុំបាត្រ មានឱកាស នៃចំណាប់ជូនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ១៣៧ ] អាបត្តិមិនត្រូវដល់ភិក្ខុដែលមានបាត្របាត់ ដល់ភិក្ខុមានបាត្របែក ដល់ភិក្ខុសុំបាត្រអំពីសម្នាក់ពួកញាតិ ដល់ភិក្ខុសុំបាត្រអំពីសម្នាក់ពួកជនដែលបវារណា ដល់ភិក្ខុសុំបាត្រដើម្បីឲ្យអ្នកដទៃ ដល់ភិក្ខុបានបាត្រមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា

## បត្តវគ្គ សិក្ខាបទទី ២

### ឩនបញ្ចពន្ធនសិក្ខាបទ

[ ១២៨ ] ឩនបញ្ចពន្ធនសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងឩនបញ្ចពន្ធនសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ន យាបេតិ** សេចក្តីថា ស្មូនឆ្នាំងនោះ ត្រូវធុញទ្រាន់គិតក្នុងការយកឆ្នាំងនោះ ហេតុនោះ បើមិនទាន់បានជាព្រះអរិយសាវកហើយ គង់នឹងដល់នូវការអាក់អន់ចិត្តដទៃទៅក៏បាន ។ តែព្រោះលោកជាសោតាបន្នបុគ្គល ខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះ មិនល្មមនឹងចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា សូម្បីខ្លួនឯងក៏មិនល្មមនឹងរស់នៅបាន បុត្រ និងភរិយាក៏ដល់នូវសេចក្តីលំបាក ។

[ ១៣០ ] ក្នុងបទថា **ឩនបញ្ចពន្ធនេន** នេះ មានវិនិច្ឆ័យដូចតទៅនេះ ថា បាត្រដែលឈ្មោះថា មានចំណងតិចជាង ៥ អន្លើ ព្រោះមានស្នាមប្រេះក្រោម ៥ កន្លែង ។ អធិប្បាយថា បាត្រនោះ មានស្នាមប្រេះមិនគ្រប់ ៥ អន្លើ ។ មានបាត្រមានស្នាមមិនគ្រប់ ៥ នោះ ។ ( បទនេះជា ) តតិយាវិភត្តិ ចុះក្នុងលក្ខណៈនៃឥត្ថម្ភូត ក្នុងវាក្យបញ្ញាសនោះ សូម្បីបាត្រមិនទាន់មានស្នាមប្រេះ និងមានស្នាមប្រេះមិនគ្រប់ ៥ អន្លើ ព្រោះមិនទាន់មានដោយប្រការទាំងពួង ដូច្នោះ ទើបក្នុងបទភាជនៈ ព្រះមានព្រះភាគត្រាស់ពាក្យថា **អពន្ធនោ វា** ជាដើម និងព្រោះត្រាស់ពាក្យថា មានចំណងក្រោម ៥ អន្លើ

ដូច្នេះ ភិក្ខុណាមានបាត្រមានចំណាំគ្រប់ ៥ អន្លើ បាត្រនោះ របស់ភិក្ខុនោះ មិនឈ្មោះថា បាត្រ ព្រោះដូច្នោះ ទើបគួរសូមបាត្រថ្មីបាន ។ ព្រោះដែលឈ្មោះថា ចំណាំនេះ កាលនឹងមានឱកាសនៃចំណាំ ទើបមានកាលនឹងមិនមានឱកាសចំណាំ ក៏មិនមាន ដូច្នោះ ដើម្បីទ្រង់សម្ដែងលក្ខណៈនៃផលនោះ ទើបត្រាស់បទថា **អពទ្ធោកាសោ នាម** ជាដើម ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃឩនបញ្ចពន្ធនសិក្ខាបទ

[ ១៣១ ] បទថា **ទ្វង្គុលា រាជិ ន ហោតិ** បានដល់ មិនមានស្នាមប្រេះ សូម្បីមួយអន្លើប្រវែងប្រមាណ ២ អង្គុលី ខាងក្រោមកណ្ដាប់មាត់ ។

បទថា **យស្ស ទ្វង្គុលា រាជិ ហោតិ** សេចក្ដីថា បាត្រដែលមានចំណាំ ១ ដូច្នេះ គប្បីយកដែកចោះបាត្រ ចោះទីបំផុតមាត់ក្រោមរបស់ស្នាមនោះបិទភ្ជាប់ហើយ ចងរឹតដោយខ្សែអំបោះ និងសម្បកឈើជាដើម ឬដោយលួសសំណ ។ គប្បីផ្សារស្នាមប្រេះនោះដោយបន្ទះសំណ ឬដោយជ័រសម្រាប់បិទឯណាមួយ ដើម្បីទ្រទ្រង់អាមិសឲ្យនៅជាប់ ហើយបាត្រនោះ គប្បីអធិដ្ឋានទុកប្រើប្រាស់ចុះ ។ ម្យ៉ាងទៀត គប្បីចងធ្វើប្រហោងឲ្យតូច ។ តែបិទដោយក្រមួនឃ្មុំ អាចម៍ល័ខ និងជ័រស្រល់ជាដើមសុទ្ធៗ មិនគួរ និងរម្ងាស់ទឹកអំពៅ លាយដោយកម្ទេចថ្ម បិទ គួរ ។ តែបាត្រដែលភិក្ខុយកដែកចោះៗក្នុងទីជិតកណ្ដាប់មាត់ នឹងបែកព្រោះបន្ទះដែកចោះ ព្រោះដូច្នោះ ទើបគួរចោះខាងក្រោម ។ តែសម្រាប់បាត្រដែលមានស្នាម ២ អន្លើ ឬត្រឹម ១

កន្លែងប្រមាណ ៤ អង្គុលី គួរឲ្យគ្រឿងចង ២ អន្ទើ គប្បីឲ្យគ្រឿងចង ៣ កន្លែងនៃបាត្រដែលមានស្នាម ៣ អន្ទើ ឬមានត្រឹម ១ កន្លែងដែលវែងដល់ទៅ ៦ អង្គុលី ។ គប្បីឲ្យគ្រឿងចង ៤ អន្ទើដល់បាត្រដែលមានស្នាមប្រេះ ៤ កន្លែង ឬមានត្រឹម ១ កន្លែងដែលវែងដល់ទៅ ៨ អង្គុលី បាត្រដែលមានចំណង ៥ អន្ទើ ឬមានត្រឹមតែមួយកន្លែង តែវែងទៅរហូត ១០ អង្គុលី ទោះចងក៏ដោយ មិនចងក៏ដោយ មិនឈ្មោះថា បាត្រឡើយ គួរសូមបាត្រថ្មី នេះជាវិនិច្ឆ័យក្នុងបាត្រដីជាបឋម ។

ចំណែកវិនិច្ឆ័យក្នុងបាត្រដែក គប្បីជ្រាបដូចតទៅនេះថា បើមានប្រហោងធ្លុះ ៥ កន្លែង ឬច្រើនជាង ហើយប្រហោងធ្លុះទាំងនោះ ផ្សារដោយកម្ទេចដែកដោយស្ងួន ឬដោយដុំដែកមូល ជារបស់រលីង គួរប្រើប្រាស់បាត្រនោះឯង មិនគួរសូមបាត្រថ្មីឡើយ ។ តែបើមានប្រហោងធ្លុះតែ ១ តែជាប្រហោងធំ សូម្បីផ្សារដោយដុំដែកមូល ក៏មិនរលោង អាមិសជាប់ត្រង់បាត្របាន ជាអកប្បិយ បាត្រនេះ មិនមែនបាត្រ គួរសូមបាត្រថ្មីបាន ។

[ ១៣២ ] ពីរបទថា **ថេរោ វត្តព្វោ** សេចក្តីថា ភិក្ខុសម្តែងអានិសង្សក្នុងបាត្រ ហើយគប្បីប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ បាត្រនេះ មានខ្នាតត្រឹមត្រូវស្អាតល្អ សមគួរដល់ព្រះថេរៈ សូមលោកម្ចាស់ទទួលបាត្រនោះទុកចុះ ។

ពីរបទថា **យោ ច គណ្ហាយ្យ** សេចក្តីថា កាលព្រះថេរៈមិនទទួលដើម្បីអនុគ្រោះ ត្រូវអាបត្តិទុក្កដ ។ តែព្រោះសេចក្តីសន្តោស មិនត្រូវអាបត្តិ

ដល់ភិក្ខុដែលមិនទទួលដោយគិតថា នឹងមានប្រយោជន៍អ្វី ដល់អាត្មាអញ ដោយបាត្រដទៃនោះ ។

បទថា **បត្តបរិយន្តោ** បានដល់ បាត្រដែលផ្លាស់ប្តូរគ្នាយ៉ាងនេះ តាំងនៅខាងចុង ។

បទថា **អទេសេ** សេចក្តីថា ភិក្ខុនោះមិនគប្បីរក្សាបាត្រនោះ ក្នុងទីមិនគួរ មានគ្រែ តាំង ម្ជុលឈើ ដៃកែវជាដើម គប្បីទុកដាក់ក្នុងទីដែលខ្លួនទុកដាក់បាត្រល្អអំពីមុននោះឯង ។ សេចក្តីពិត ទីទុកដាក់បាត្រ ព្រះមានព្រះភាគត្រាស់ទុកហើយ ក្នុងខន្ធកៈនោះឯង ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងទម្របាត្រ ដូច្នេះ ។

បទថា **ន អភោគេន** គឺ មិនគប្បីប្រើបាត្រដោយការប្រើមិនសមគួរ មានការដាំបបរ និងដាំទឹកជ្រលក់ជាដើម ។ តែកាលកើតអាពាធក្នុងចន្លោះផ្លូវ កាលភាជនៈដទៃមិនមាន នឹងយកដីឥដ្ឋលាប ហើយដាំបបរ ឬដាំទឹកក្តៅ គួរ ។

បទថា **ន វិស្សជ្ជេតព្វោ** សេចក្តីថា មិនគួរឲ្យដល់អ្នកដទៃ ។ តែបើសទ្ធិវិហារិក ឬ អន្តេវាសិកដាក់បាត្រដែលល្អដទៃទុកជំនួស កាន់យកទៅដោយគិតថា បាត្រនេះ គួរដល់អញ បាត្រនេះ គួរដល់ព្រះថេរៈ ដូច្នេះ គួរ ឬភិក្ខុដទៃកាន់យកបាត្រនោះហើយ ប្រគេនបាត្ររបស់ខ្លួន ក៏គួរ ។ មិនមានកិច្ចដែលត្រូវពោលថា លោកចូរយកបាត្ររបស់ខ្ញុំនោះឯងមក ។

[ ១៣៧ ] ក្នុងបទថា **បវារិតានំ** នេះ មានអធិប្បាយថា ក្នុងកុរុន្ទី

ពោលថា ភិក្ខុមានបាត្រស្រាំត្រឹម ៥ អន្លើ ទោះសូមបាត្រថ្មីក្នុងទីដែលគេបវារណាទុក ដោយអំណាចនៃសង្ឃ គួរ សូម្បីមានបាត្រស្រាំក្រោម ៥ អន្លើ នឹងសូមក្នុងទីដែលគេបវារណាទុក ដោយអំណាចនៃបុគ្គល ក៏គួរដូច្នេះ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឩនបញ្ចពន្ធនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[ ១៣៨ ] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារជេតពន ដែលជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ក្បែរក្រុងសាវត្ថី ។ គ្រានោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រាថ្នានឹងធ្វើទីជ្រកកោន ទើបឲ្យគេជម្រះសម្អាតញកភ្នំ ក្បែរក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ[១] ជាធំក្នុងដែន មគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះព្រះរាជដំណើរ ទៅដល់ហើយ ក៏បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ទ្រង់គង់នៅក្នុងទីសមគួរហើយ ទើបមានព្រះរាជឱង្ការនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា លោកម្ចាស់ លោកឲ្យគេ ធ្វើអ្វី ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពចង់ធ្វើកន្លែង ជ្រកកោន បានជាឲ្យគេជម្រះសម្អាតញកភ្នំ ។ ទ្រង់ក៏សួរថា លោកម្ចាស់ដ៏ ចម្រើន លោកម្ចាស់ត្រូវការអារាមិកជន ( មនុស្សថែទាំរក្សាអារាម ) ឬទេ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ អារាមិកជន ព្រះដ៏ទ្រង់ព្រះភាគ មិនទាន់ទ្រង់អនុញ្ញាតនៅឡើយទេ ។ ទ្រង់ត្រាស់ថា លោកម្ចាស់ បើដូច្នោះ លោកម្ចាស់គួរទូលសួរព្រះដ៏ទ្រង់ព្រះភាគ ហើយសឹមមកប្រាប់ញោម ។ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏ទទួលព្រះរាជឱង្ការ ព្រះបាទពិម្ពិសារសេនិយរាជជាធំ ក្នុងដែនមគធៈថា ថ្វាយព្រះពរមហារាជ ។ ខណៈនោះឯងបិលិន្ទវច្ឆត្ថេរ

---

១-ស្តេចជាធំលើសេនាទាហាន គង់សំដៅសេចក្តីថា ព្រះបាទពិម្ពិសារទ្រង់ជាមហាក្សត្រិយ៍សឹក បានជាមានគុណស័ព្ទមេទ័ពនាំមុខថា សេនិយោ មាគធោ រាជា ។

ដ៏មានអាយុបានពន្យល់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈឲ្យទ្រង់ឃើញច្បាស់ ឲ្យទ្រង់សមាទាន ឲ្យទ្រង់ក្លៀវក្លា ឲ្យទ្រង់រីករាយ ដោយធម្មីកថា ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដែលបិលិន្ទវច្ឆត្ថេរដ៏មានអាយុបានឲ្យទ្រង់ ឃើញជាក់ស្តែង ឲ្យទ្រង់សមាទាន ឲ្យទ្រង់ក្លៀវក្លា ឲ្យទ្រង់រីករាយដោយធម្មីកថាហើយ ទ្រង់ក៏ក្រោកចាកអាសនៈបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយទ្រង់ធ្វើប្រទក្សិណយាត្រាចេញទៅ ។ លំដាប់នោះ បិលិន្ទ-វច្ឆត្ថេរដ៏មានអាយុ ប្រើបម្រើទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់ចង់ប្រទានអារាមិកជនឲ្យ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគួរបដិបត្តិដូចម្តេច ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគជាម្ចាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សម្តែងធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអារាមិកជន ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ជាគម្រប់ពីរដង លុះយាងចូលទៅហើយ ទើបទ្រង់បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីដ៏សមគួរមួយ ។ លុះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ គង់ស្រួលបួលហើយ មានព្រះបន្ទូលនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា បពិត្រលោកម្ចាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតអារាមិកជន ហើយឬ ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ ព្រះអង្គបានអនុញ្ញាតហើយ ។ ទ្រង់ត្រាស់ថា បពិត្រលោកដ៏ចម្រើន បើដូច្នោះ ញោម ប្រគេនអារាមិកជន

ម្នាក់ដល់លោកម្ចាស់ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ទ្រង់ប្តេជ្ញាថា ប្រគេនអារាមិកជនដល់ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយក៏ភ្លេចព្រះស្មារតី យូរបន្តិចទៅទ្រង់រឭកឃើញវិញ ទើបទ្រង់ត្រាស់ហៅមហាអមាត្យម្នាក់ ជាអ្នកសម្រេចរាជការទាំងពួងថា នៃមហាអមាត្យ អារាមិកជនណា ដែលយើងបម្រុងនឹងប្រគេនលោកម្ចាស់ អារាមិកជននោះ យើងបានប្រគេនលោកហើយឬ ។ មហាអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព អារាមិកជនទ្រង់មិនទាន់ប្រគេនដល់លោកម្ចាស់នៅឡើយទេ ។ ស្តេចត្រាស់សួរថា នៃមហាអមាត្យ រាប់ពីរាត្រីនេះទៅបានប៉ុន្មានរាត្រីហើយ ។ លំដាប់នោះ មហាអមាត្យនោះ បានរាប់រាត្រីសព្វគ្រប់ហើយ ក្រាបទូលព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដូច្នេះថា បពិត្រ សម្មតិទេព បាន ៥០០ រាត្រីហើយ ។ ស្តេចត្រាស់ថា នៃមហាអមាត្យ បើដូច្នោះ អ្នកចូរប្រគេនអារាមិកជន ៥០០ នាក់ទៅលោកម្ចាស់ចុះ ។ មហាអមាត្យនោះ ទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុង ដែនមគធៈថា សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយៗ បានប្រគេនអារាមិកជន ៥០០ នាក់ដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ។ ទីនោះ បានជាស្រុកមួយ ផ្សេងដោយឡែក ។ ជនទាំងឡាយ ហៅស្រុកនោះថា អារាមិកគ្រាមខ្លះ ហៅថា បិលិន្ទវច្ឆគ្រាមខ្លះ ។

[ ១៣៩ ] សម័យនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុជាជីតុនក្នុងស្រុកនោះ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ

និងចីវរ ចូលទៅបិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាម នាវេលាព្រឹកព្រហាម ។ សម័យនោះឯង មានល្បែងមហោស្រពក្នុងស្រុកនោះ ។ ពួកក្មេងៗ បានប្រដាប់តាក់តែងដោយផ្កាកម្រង លេងមហោស្រព ។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងបិលិន្ទវច្ឆគ្រាម បានចូលទៅកាន់លំនៅរបស់អារាមិកជនម្នាក់ លុះចូលទៅហើយ ទើបអង្គុយលើអាសនៈដែលគេរៀបចំប្រគេន ។ សម័យនោះឯង ធីតារបស់ស្រីរក្សាអារាមនោះ ឃើញទារកឯទៀតៗ ប្រដាប់តាក់តែងដោយផ្កាកម្រង ហើយក៏យំសុំថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់មកខ្ញុំ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា នាងទារិកានេះយំទារអ្វី ។ ស្រីរក្សាអារាមទូលថា លោកម្ចាស់ នាងទារិកានេះឃើញទារកឯទៀតៗ ប្រដាប់តាក់តែងដោយផ្កាកម្រង បានជាយំទារថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់មកខ្ញុំ យើងខ្ញុំជាអ្នកក្រលំបាកនឹងបានផ្កាកម្រងមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា ។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ចាប់រង្វេលស្មៅមួយ ហើយនិយាយពាក្យនេះ នឹងស្រីរក្សាអារាមនោះថា ហ៏ ! នាងចូរបំពាក់រង្វេលស្មៅនេះលើក្បាល របស់ក្មេងស្រីនោះចុះ ។ ពេលនោះ ស្រីរក្សាអារាមនោះ យករង្វេលស្មៅនោះបំពាក់លើក្បាលរបស់នាងទារិកានោះ ។ រង្វេលស្មៅនោះក៏ក្លាយជាកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់ ។ កម្រងមាសបែបនោះ សូម្បីក្នុងព្រះរាជវាំងស្តេចក៏រកគ្មានដែរ ។ មនុស្សទាំងឡាយទៅក្រាបទូលព្រះបាទ

ពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ថា បពិត្រសម្មតិទេព កម្រងមាស ក្នុងផ្ទះរបស់អារាមិកជនឯណោះ ល្អល្អះមុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់ សូម្បីក្នុងព្រះរាជវាំងរបស់ព្រះអង្គ ក៏ពុំមានកម្រងមាសដូច្នោះដែរ មនុស្សក្រទុគ៌តនោះនឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេជាប្រាកដ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់ឲ្យរាជបុរស ទៅកោះពួកត្រកូលអារាមិកជននោះមក ។ វេលាព្រឹកព្រហាម បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ចូលទៅបិណ្ឌបាត នាបិលិន្ទវច្ឆគ្រាម ជាគម្រប់ពីរដង កាលដើរទៅបិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាមជាលំដាប់ៗ ទៅ ទើបចូលទៅកាន់លំនៅរបស់អារាមិកជននោះ លុះចូលទៅដល់ហើយ សួរពួកជនដែលជាទីស្និទ្ធស្នាលថា ត្រកូលអារាមិកជននេះទៅណាទៅ ។ ពួកជនពិតថា លោកម្ចាស់ ស្តេចឲ្យរាជបុរសចាប់ចងយកទៅហើយ ព្រោះហេតុតែកម្រងមាសនោះឯង ។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏ចូលទៅកាន់រាជនិវេសន៍ របស់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ លុះទៅដល់ហើយ គង់លើអាសនៈដែលគេតាក់តែងប្រគេន ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះដល់ហើយក៏ថ្វាយបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់គង់ស្រួលបួលហើយ ទើបបិលិន្ទវច្ឆត្ថេរដ៏មានអាយុថ្វាយព្រះពរថា បពិត្រមហារាជ ហេតុអ្វី បានជាព្រះអង្គឲ្យរាជបុរសទៅចាប់ត្រកូលអារាមិកជន

មកឃុំ ។ ព្រះបាទពិម្ពិសារត្រាស់ថា លោកម្ចាស់ នាផ្ទះរបស់អារាមិកជននោះ មានកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់មានតម្លៃ សូម្បីក្នុងវាំងរបស់ញោមក៏មិនមានកម្រងមាសដូច្នោះដែរ អ្នកក្រត់ទុគ៌តនោះ នឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេហើយ ។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏អធិដ្ឋានប្រាសាទរបស់ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ឲ្យក្លាយជាមាសទៅ ។ ប្រាសាទទាំងនោះ ក៏ក្លាយទៅជាមាសទាំងអស់ ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ មាសនេះច្រើនដល់ម៉្លេះ ព្រះអង្គបានមកពីណា ។ ស្តេចត្រាស់ថា ខ្ញុំមិនដឹងទេលោកម្ចាស់ របស់ទាំងនេះ ប្រហែលជាសម្រេចដោយឥទ្ធានុភាព[1] របស់លោកម្ចាស់ទេដឹង ហើយត្រាស់ឲ្យដោះលែងត្រកូលអារាមិកជននោះទៅ ។

[ ១៨០ ] មនុស្សទាំងឡាយឮដំណឹងថា បិលិន្ទវច្ឆត្ថេរជាម្ចាស់ បានសម្តែងឥទ្ធិបាដិហារិយៈ (ឥទ្ធិឫទ្ធិដ៏អស្ចារ្យចម្លែក) ជាងមនុស្សធម៌ដ៏ខ្ពង់ខ្ពស់ដល់បរិស័ទ ព្រមទាំងព្រះរាជា ហើយក៏មានចិត្តត្រេកអរជ្រះថ្លា នាំយកនូវភេសជ្ជៈ ៥ យ៉ាង មកបូជាបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ភេសជ្ជៈ ៥ នោះ គឺសប្បិ ( ទឹកដោះរាវ ) នវនីតៈ ( ទឹកដោះខាប់ ) តេលៈ ( ប្រេង ) មធុ ( ទឹកឃ្មុំ ) ផាណិតៈ ( ទឹកអំពៅឬស្ករអំពៅ ) ។ ឯបិលិន្ទវច្ឆត្ថេរដ៏មានអាយុ តែងបានភេសជ្ជៈ ៥ ហើយរមែងចែករបស់ដែលលោកបានមកៗ ទៅដល់បរិស័ទ ( សិស្សរបស់លោក ) ដោយប្រក្រតី ។ ឯបរិស័ទរបស់លោកនោះ

---

១-គឺសម្រេចដោយឫទ្ធិដែលព្រះថេរៈអធិដ្ឋាន ។

តែងបានភេសជ្ជៈទាំងនោះច្រើនរឿយៗ ។ បានដាក់ទុករបស់ដែលបានមកៗ ក្នុងថ្លាងផង ក្នុងក្អមផង ខ្ទប់នឹងសំពត់សម្រាប់ត្រងទឹកផង ទុកក្នុងបង់យាមផង គ្រាតែពេញ ហើយព្យួរទុកតាមបង្អួចដេរដាស ។ ភេសជ្ជៈទាំងនោះក៏សើម លេចហៀរចេញពាសពេញ ។ វិហារទាំងឡាយ ក៏ដេរដាសពាសពេញដោយសត្វកណ្តុរទាំងឡាយ ។ មនុស្សទាំងឡាយ កាលដើរទៅកាន់វិហារចារិកបានឃើញហើយទើបពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈពួកនេះជាកូនចៅព្រះពុទ្ធសក្យបុត្រ មានកណ្ឌៈតម្កល់ទុកក្នុងឃ្លាំង ដូចជា ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈដែរ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា មិនសមបើ ពួកភិក្ខុមកព្យាយាមដើម្បីសេចក្តីល្មោភច្រើន មានសភាពដូច្នេះឡើយ ។ ទើបពួកភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះទៅក្រាបទូលដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុព្យាយាមដើម្បីសេចក្តីល្មោភច្រើន មានសភាពដូច្នេះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបីបើពួកមោឃបុរសទាំងនោះ មកព្យាយាមដើម្បីសេចក្តីល្មោភច្រើន មានសភាពដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកបានធ្វើមកនេះ មិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬ ថែមសេចក្តីជ្រះថ្លា

ដល់ជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន ភេសជ្ជៈនេះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ បើភិក្ខុទុកឲ្យកន្លងកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៤១ ] ត្រង់ពាក្យថា ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន គឺ សប្បិ[១] របស់គោក្តី សប្បិរបស់ពពែក្តី សប្បិរបស់ក្របីក្តី ឈ្មោះថា សប្បិ ( ទឹកដោះរាវ ) ។ សាច់របស់សត្វទាំងឡាយណា ដែលសមគួរដល់ពុទ្ធានុញ្ញាត សប្បិរបស់សត្វទាំងឡាយនោះ ក៏សមគួរដែរ ។ ដែលហៅថា ទឹកដោះខាប់ គឺ ទឹកដោះខាប់របស់សត្វទាំងនោះឯង ។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វង ប្រេងធ្វើពីខ្លាញ់រាវ ឈ្មោះថា ប្រេង ។ ទឹកផ្អែមកើតពីមេឃ្មុំជាដើម ឈ្មោះថា ទឹកឃ្មុំ ។ ទឹកកើតពីដើមអំពៅ ឈ្មោះថា ទឹកអំពៅ ។ ពាក្យថា ភិក្ខុទទួលភេសជ្ជៈនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ មានអធិប្បាយថា ភេសជ្ជៈទាំងនោះគប្បីទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ ។ បើទុកឲ្យកន្លងកំណត់នោះទៅ ភេសជ្ជៈនោះជានិស្សគ្គិយ គឺថា ជានិស្សគ្គិយក្នុងកាលអរុណរះឡើងក្នុងថ្ងៃទី ៨ ភេសជ្ជៈដែលជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ

---

១-ទឹកដោះរាវរបស់គោ គេះ ពពែជាដើម ហៅថា សប្បិ ។

ភិក្ខុត្រូវលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ភេសជ្ជៈរបស់ខ្ញុំនេះ កន្លងហួស ៧ ថ្ងៃហើយ ជានិស្សគ្គិយវត្ថុ ខ្ញុំសូមលះបង់ភេសជ្ជៈនេះដល់សង្ឃ ។ សេចក្តីតអំពីនេះទៅ មានសេចក្តីដូចគ្នានឹង សិក្ខាបទទី ១ នៃចីវរវគ្គ ។

[ ១៤២ ] កាលភេសជ្ជៈកន្លងហួស ៧ ថ្ងៃទៅហើយ ភិក្ខុសម្គាល់ថា កន្លងហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ កាលភេសជ្ជៈកន្លង ៧ ថ្ងៃហួសទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ កាលភេសជ្ជៈកន្លងហួស ៧ ថ្ងៃទៅហើយ ភិក្ខុសម្គាល់ថា មិនទាន់កន្លង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ( ភេសជ្ជៈនោះ ) ភិក្ខុមិនទាន់បានតាំងចិត្តទុកទេ ភិក្ខុសម្គាល់ថា បានតាំងចិត្តទុកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់បានលះបង់ទេ តែភិក្ខុសម្គាល់ថា បានលះបង់ហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់បាត់ទៅទេ ភិក្ខុសម្គាល់ថា បាត់ទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់វិនាសទៅទេ តែភិក្ខុសម្គាល់ថា វិនាសហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈភ្លើងមិនទាន់ឆេះទេ តែភិក្ខុសម្គាល់ថា ភ្លើងឆេះហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈចោរមិនទាន់លួចយកទៅទេ តែភិក្ខុសម្គាល់ថា ចោរលួចយកទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៤៣ ] ភិក្ខុត្រឡប់បានភេសជ្ជៈដែលខ្លួនលះបង់ហើយ មិនត្រូវយកមកបរិភោគ ប្រើប្រាស់ដោយកាយ មិនត្រូវយកមកឆាន់ ។ ( ភេសជ្ជៈនោះ )

ភិក្ខុគប្បីបង្អោនចូលទៅក្នុងប្រទីប ឬក្នុងវត្ថុមានពណ៌ខ្មៅ[១] ។ ភិក្ខុដទៃគប្បីបរិភោគប្រើប្រាស់ដោយកាយបាន តែមិនត្រូវយកមកឆាន់ ។ ភេសជ្ជៈមិនទាន់កន្លង ៧ ថ្ងៃទេ ភិក្ខុសម្គាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងភេសជ្ជៈដែលមិនទាន់កន្លង ៧ ថ្ងៃ ត្រូវអាបត្តិទុក្កដ ។ ភេសជ្ជៈមិនទាន់កន្លង ៧ ថ្ងៃ ភិក្ខុសម្គាល់ថា មិនទាន់កន្លង មិនត្រូវអាបត្តិឡើយ ។

[ ១៤៤ ] អាបត្តិមិនមានដល់ភិក្ខុដែលតាំងចិត្តទុក[២] ( ក្តី ) លះបង់បោល ( ក្តី ) នូវភេសជ្ជៈ ដល់ភិក្ខុដែលមានភេសជ្ជៈបាត់ទៅ ( ក្តី ) វិនាសទៅ ( ក្តី ) ភ្លើងឆេះ ( ក្តី ) ចោរលួចទៅយកទៅ ( ក្តី ) គេយកទៅដោយសេចក្តីស្និទ្ធស្នាល ( ក្តី ) ដល់ភិក្ខុដែលបរិច្ចាគលះបង់ដាច់ស្រឡះឥតអាល័យ ឲ្យអនុបសម្បន្ន ហើយទទួលយកមកបរិភោគវិញ ក្នុងរវាង ៧ ថ្ងៃ ដល់ភិក្ខុឧម្មត្តកៈ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ៣ ចប់

១- យកទៅលាយនឹងវត្ថុទាំងឡាយ មានធ្យូងជាដើមសម្រាប់លាប មានលាបជញ្ជាំងជាដើម ។

២- គឺរវាង ៧ ថ្ងៃ ភិក្ខុផ្ទេរភេសជ្ជៈនោះឲ្យទៅជារបស់ដទៃក្រៅពីរបស់ឆាន់ គឺ ធ្វើជាថ្នាំលាបក្បាល លាបដំបៅ លាបភ្នែកជាដើម ។

# អដ្ឋកថា
## បត្តវគ្គ សិក្ខាបទទី ៣
## ភេសជ្ជសិក្ខាបទ

[ ១៣៨ ] បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា

ព្រះរាជាទ្រង់ទតឃើញកិក្ខុទាំងឡាយ ម្ចីម្នាជម្រះញកភ្នំ ដើម្បីប្រយោជន៍ជាទីស្នាក់អាស្រ័យរបស់ព្រះថេរៈ ព្រះរាជាមានបំណងប្រគេនអារាមិកជន ទើបត្រាស់សួរថា **អត្ថោ ភន្តេ** ជាដើម ។

បទថា **ទាជិយេក្កោ** ប្រែថា ជាស្រុកមួយដោយឡែក ។

[ ១៣៩ ] បទថា **មាលាកិតេ** បានដល់ ធ្វើកម្រងផ្កា គឺទ្រទ្រង់ទុកនូវកម្រងផ្កា អធិប្បាយថា ប្រដាប់ដោយកម្រងផ្កា ។

បទថា **តិណណ្ឌុបកំ** ប្រែថា រង្វេលស្មៅ ( មកុដស្មៅ ) ។

បទថា **បដិមុញ្ចិ** ប្រែថា ពាក់ទុក ( លើក្បាល ) ។

បទថា **សា អហោសិ សុវណ្ណមាលា** សេចក្តីថា រង្វេលស្មៅនោះគ្រាន់តែពាក់លើក្បាលរបស់ទារិកាប៉ុណ្ណោះ បានក្លាយជាកម្រងផ្កាមាស ដោយអំណាចនៃការអធិដ្ឋានរបស់ព្រះថេរៈ ។ ពិតហើយ ព្រះថេរៈអធិដ្ឋានរង្វេលស្មៅនោះ ដែលគ្រាន់តែដាក់លើក្បាលប៉ុណ្ណោះថា ចូរក្លាយជាកម្រងផ្កាមាស ។

បទថា **ទុតិយម្បិ ខោ ។បេ។ ឧបសង្កមិ** បានដល់ ព្រះថេរៈបានទៅរកក្នុងថ្ងៃរះនោះឯង ។

*ពីរបទថា* **សុវណ្ណាតិ អធិមុច្ចិ** *បានដល់ ព្រះថេរៈបានអធិដ្ឋានថា ចូរសម្រេចជាមាស ។*

*[ ១៤០ ] ពីរបទថា* **បញ្ច ភេសជ្ជានិ** *បានដល់ ភេសជ្ជៈ ៥ មានទឹកដោះថ្លា ជាដើម ។*

*បទថា* **ពាហុល្លិកា** *បានដល់ ដែលបដិបត្តិដើម្បីភាពជាអ្នកល្មោភដោយបច្ច័យ ។*

*ក្នុងបទថា* **កោលម្ពេបិ ឃដេបិ** *នេះ ជាភាជនៈមាត់ទូលាយ ឈ្មោះថា* **កោលម្ព** *។*

*បទថា* **ឱលីនវិលីនានិ** *បានដល់ ហៀរតំណក់ចុះមកខាងក្រោម ត្រង់មាត់ទាំងពីរខាង ។*

*បទថា* **ឱកិណ្ណាវិកិណ្ណា** *សេចក្តីថា ពួកកណ្តុរកាយផ្ទៃដីដេរដាស និងកាត់ជញ្ជាំងរត់ស្ទុះទៅមក ខាងលើដេរដាស ព្រោះក្លិននៃភេសជ្ជៈ ៥ មានទឹកដោះថ្លាជាដើម ។*

*បទថា* **អន្តោកោដ្ឋាគារិកា** *បានដល់ មានឃ្លាំងចាត់ចែងទុកខាងក្នុង ។*

*បទថា* **បដិសាយនីយានិ** *បានដល់ ដែលគួរលិទ្ធភក្ស អធិប្បាយថា គួរបរិភោគ ។*

## អធិប្បាយ

## សិក្ខាបទវិភង្គនៃភេសជ្ជសិក្ខាបទ

*[ ១៤១ ] បទថា* **ភេសជ្ជានិ** *សេចក្តីថា ភេសជ្ជៈទាំងឡាយ នឹងធ្វើ*

កិច្ចនៃភេសជ្ជៈក្តី មិនធ្វើក្តី ក៏បានវោហារ ( ថាជាភេសជ្ជៈ ) យ៉ាងនេះ ។

ដោយបទថា **គោសប្បិ** ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងទឹកដោះថ្លា ដែលប្រាកដក្នុងលោក ហើយទ្រង់សម្តែងសង្គ្រោះយកទឹកដោះថ្លា សប្បិនៃសត្វពួកដទៃ មានម្រឹគ រមាំង និងទន្សាយជាដើមចូល ដោយពាក្យថា **យេសំ មំសំ កប្បតិ** នេះ ។ ពិតហើយ សត្វទាំងឡាយណាមានទឹកដោះ សត្វទាំងនោះ ក៏មានទឹកដោះថ្លាផងដែរ ។ តែទឹកដោះថ្លារបស់សត្វទាំងនោះ រកបានងាយក្តី រកបានលំបាកក្តី ក៏ត្រាស់ទុកដើម្បីការមិនវង្វេង ។ សូម្បីទឹកដោះខាប់ ក៏យ៉ាងនោះ ។

ពីរបទថា **សន្និធិការកំ បរិភុញ្ជិតព្វានិ** សេចក្តីថា គប្បីធ្វើការសន្សំ គឺរក្សាទុកបរិភោគ ។ សេចក្តីនេះដូចម្តេច បណ្តាភេសជ្ជៈ មានទឹកដោះថ្លាជាដើម ដែលមកក្នុងព្រះបាលី នឹងពោលដល់ទឹកដោះថ្លាមុន ដែលភិក្ខុទទួលប្រគេនមុនឆាន់ គួរឆាន់លាយអាមិសក៏បាន ប្រាសចាកអាមិសក៏បាន ក្នុងវេលាមុនឆាន់ក្នុងថ្ងៃនោះ ។ តាំងអំពីក្រោយពេលឆាន់ទៅ គប្បីឆាន់ប្រាសចាកអាមិសបានរហូត ៧ ថ្ងៃ សូម្បីកន្លង ៧ ថ្ងៃទៅ បើភិក្ខុរក្សាទុកក្នុងភាជនៈ ១ ជានិស្សគ្គិយ ១ បើរក្សាទុកក្នុងភាជនៈច្រើន ជានិស្សគ្គិយច្រើនតាមចំនួនវត្ថុ ។

ទឹកដោះថ្លា ដែលភិក្ខុទទួលប្រគេនក្នុងបច្ឆាភត្ត គួរឆាន់បានមិនលាយអាមិស រហូត ៧ ថ្ងៃ ។ ភិក្ខុនឹងបរិភោគទឹកដោះថ្លា ដែលខ្លួនធ្វើឲ្យជាឧគ្គហិត ( ចាប់ពាល់មុនប្រគេន ) រក្សាទុកក្នុងវេលាមុនឆាន់ក្តី ក្រោយឆាន់ក្តី រមែង

មិនគួរ គប្បីបង្អោនទៅប្រើ ក្នុងកិច្ចដទៃ មានការលាបជាដើម ។ សូម្បីកន្លង ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិ ព្រោះដល់នូវភាពជារបស់មិនគួរបរិភោគ ។ សមដូចព្រះតម្រាស់ត្រាស់ទុកថា ជារបស់គួរលិទ្ធភក្ស ។

បើអនុបសម្បន្នធ្វើទឹកដោះថ្លា ដោយទឹកដោះខាប់ ដែលទទួលប្រគេនទុកក្នុងវេលាមុនឆាន់ប្រគេន ទោះឆាន់ជាមួយអាមិសក្នុងបុរេភត្ត គួរ បើភិក្ខុធ្វើឯង ឆាន់មិនលាយអាមិស រមែងគួរ សូម្បីអស់ ៧ ថ្ងៃ ។ តែទឹកដោះថ្លាដែលបុគ្គលណាមួយ ធ្វើដោយទឹកដោះខាប់ ដែលទទួលប្រគេនក្នុងវេលាក្រោយភត្ត គួរឆាន់បានមិនលាយអាមិស រហូត ៧ ថ្ងៃដូចគ្នា ។

## អធិប្បាយ ក្នុងសប្បិ និងនវនីត

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងសប្បិ ( ទឹកដោះថ្លា ) ដែលធ្វើដោយនវនីត ( ទឹកដោះខាប់ ) ( ដែលភិក្ខុធ្វើឲ្យ ) ជាឧគ្គហិតដោយន័យនៃសប្បិសុទ្ធៗ ដូចដែលពោលទុកហើយពីមុននោះឯង ។ សប្បិធ្វើដោយខីរៈ ( ទឹកដោះស្រស់ ) ដែលភិក្ខុទទួលប្រគេនទុកមុនឆាន់ក្តី ដោយទធិ ( ទឹកដោះជូរ ) ក្តី ដែលអនុបសម្បន្នធ្វើ គួរឆាន់បាន សូម្បីលាយអាមិស ក្នុងវេលាមុនឆាន់ថ្ងៃនោះ ។ ដែលភិក្ខុធ្វើឯង គួរឆាន់ប្រាសចាកអាមិសតែម្យ៉ាង ក្នុងខាងក្រោយឆាន់ មិនគួរ ។

ពិតហើយ កាលភិក្ខុកម្តៅនវនីត មិនចាត់ជាសាមបក្ក ( ចម្អិនឯង ) ។ តែបើឆាន់អាមិស មួយអន្លើដោយនវនីតនោះ ដែលជាសាមបក្ក រមែងមិនគួរ ។ តាំងអំពីបុរេភត្តទៅ មិនគួរដូចគ្នា ។ មិនត្រូវអាបត្តិសូម្បីកន្លង ៧ ថ្ងៃ

ទៅ ព្រោះទទួលប្រគេនទាំងវត្ថុ សមដូចព្រះតម្រាស់ថា ទទួលប្រគេនភេសជ្ជៈ ទាំងនោះហើយជាដើម តែសប្បិដែលធ្វើដោយទឹកដោះ និងទធិ ដែលភិក្ខុទទួលប្រគេនក្នុងវេលាធាន់ គួរបង្អោនទៅប្រើក្នុងកិច្ច មានការលាបខ្លួនជាដើម ។ សប្បិដែលធ្វើដោយទឹកដោះ ទធិ ដែលជាឧគ្គហិត សូម្បីក្នុងវេលាបុរេភត្ត ( ក៏គួរបង្អោនចូលទៅក្នុងកិច្ច មានការលាបខ្លួនជាដើម ) ។ មិនត្រូវអាបត្តិ ព្រោះសប្បិទាំង ២ យ៉ាង ដែលលើស ៧ ថ្ងៃទៅ ។ ក្នុងសប្បិរបស់ពួកសត្វដែលមានសាច់ជាអកប្បិយ ក៏មានន័យយ៉ាងនេះដូចគ្នា តែសេចក្តីប្លែកគ្នាមានដូចតទៅនេះថា ជានិស្សគ្គិយដោយនវនីត និងសប្បិដែលមកហើយក្នុងព្រះបាលីណា ក្នុងព្រះបាលីនោះ ត្រូវអាបត្តិទុក្កដ ដោយសប្បិរបស់ពួកសត្វ ដែលមានសាច់ជាអកប្បិយនេះ ។ ក្នុងអដ្ឋកថាអន្ធកៈ លោកជំទាស់សប្បិ និងនវនីតរបស់មនុស្សទុក ធ្វើឲ្យសមគួរដល់ហេតុ ។ សប្បិ និងនវនីតរបស់មនុស្សនោះ លោកជំទាស់ទុកមិនប្រពៃ ព្រោះអាចារ្យទាំងឡាយ អនុញ្ញាតទុកក្នុងអដ្ឋកថាទាំងពួង ។ សូម្បីការវិនិច្ឆ័យសប្បិ និងនវនីតរបស់មនុស្សនោះ នឹងមានសម្តែងខាងមុខ ។ សូម្បីនវនីតដែលមកហើយក្នុងព្រះបាលី ភិក្ខុទទួលប្រគេនក្នុងបុរេភត្ត ទោះបីធាន់លាយនឹងអាមិស ក្នុងបុរេភត្តថ្ងៃនោះ គួរតាំងអំពីបច្ឆាភត្តទៅ ធាន់មិនលាយអាមិស ទើបគួរ ។ ព្រោះកន្លង ៧ ថ្ងៃទៅ នវនីតដែលរក្សាទុកក្នុងភាជនៈផ្សេងៗ គ្នា ជានិស្សគ្គិយតាមចំនួនភាជនៈ ក្នុងនវនីតដែលរក្សាទុកជាដុំៗ មិនលាយឡំគ្នា សូម្បីក្នុងភាជនៈមួយ ក៏ជានិស្សគ្គិយតាមចំនួនដុំ ។ នវនីតដែលភិក្ខុទទួលប្រគេនទុកក្នុងបច្ឆាភត្ត អ្នក

សិក្សាគប្បីជ្រាបដោយន័យនៃសប្បិដូចគ្នា ឯសេចក្ដីប្លែកគ្នាក្នុងនវនីតនេះ មានដូច្នេះ គឺជុំទធិក្ដី តំណក់តក្កៈ ( ទឹកដោះជូរមានពពុះ ) មាន ព្រោះដូច្នោះទើបពួកព្រះថេរៈចំនួនពាក់កណ្ដាលបានពោលថា ដែលសម្អាតហើយ គួរ ។ ព្រះមហាសីវត្ថេរពោលថា តាំងអំពីពេលដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ នវនីត កាលស្រង់ឡើងអំពីតក្កៈប៉ុណ្ណោះ ភិក្ខុទាំងឡាយឆាន់បាន ។ ព្រោះហេតុនោះ ភិក្ខុកាលឆាន់នវនីត គប្បីជម្រះ គឺជួសយកទធិ តក្កៈ រុយនិងស្រមោចក្រហមជាដើមចេញ ហើយឆាន់ចុះ ។ ភិក្ខុប្រាថ្នានឹងរម្ងាស់ឲ្យជាសប្បិ ឆាន់ និងរម្ងាស់សូម្បីនវនីតដែលមិនទាន់សម្អាត ក៏គួរ ក្នុងនវនីតនោះវត្ថុណាដែលជាទធិក្ដី ជាតក្កៈក្ដី វត្ថុនោះនឹងដល់នូវការអស់ទៅ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ មិនទាន់ឈ្មោះថា ទទួលប្រគេនព្រមទាំងវត្ថុអធិប្បាយដូចពោលមកនេះ ជាអធិប្បាយរបស់ព្រះមហាសីវត្ថេរ ។ តែភិក្ខុទាំងឡាយដែលច្រើនដោយសេចក្ដីរង្កៀស រមែងរង្កៀសសូម្បីក្នុងនវនីតដែលរម្ងាស់នោះ ព្រោះរម្ងាស់មួយអន្ទើនឹងអាមិស ។ ឥឡូវនេះ អ្នកសិក្សាគប្បីកាន់យកន័យនៃអាបត្តិ អនាបត្តិ ការបរិភោគ និងមិនបរិភោគក្នុងនវនីតដែលចាប់ពាល់ ហើយរក្សាទុក ក្នុងនវនីតដែលភិក្ខុទទួលប្រគេនខីរៈ និងទធិក្នុងបុរេភត្ត ហើយធ្វើក្នុងនវនីតដែលភិក្ខុទទួលប្រគេនខីរៈ និងទធិនោះក្នុងបច្ឆាភត្ត ហើយធ្វើក្នុងនវនីតដែលធ្វើដោយខីរៈ និងទធិដែលជាឧគ្គហិត និងក្នុងនវនីតរបស់ពួកសត្វ ដែលមានមំសៈជាអកប្បិយ ទាំងអស់ដោយលំដាប់ដូចពោលហើយក្នុងសប្បិនោះឯង ។ ពួកអ្នកស្រុក រមែងចាក់សប្បិខ្លះ នវនីត

ខ្លះ ប្រេងដែលចម្រាញ់ហើយខ្លះ ប្រេងដែលមិនទាន់ចម្រាញ់ខ្លះ ចូលក្នុងសប្បិនោះឯង របស់ភិក្ខុទាំងឡាយ ដែលចូលទៅដើម្បីភិក្ខាប្រេង ។ តំណក់តក្កៈ និងទធិខ្លះ គ្រាប់បាយខ្លះ កន្ទក់ខ្លះ ប្រភេទរុយខ្លះ មាននៅក្នុងសប្បិនោះ សប្បិនោះ ភិក្ខុធ្វើឲ្យឆ្អិនដោយកម្ដៅថ្ងៃហើយ ហើយត្រងយក ចាត់ជាសត្តាហកាលិក ។

ឯការដែលភិក្ខុនឹងចម្រាញ់ជាមួយកេសជ្ជៈ ដែលទទួលប្រគេនហើយធ្វើនត្ថុចូលតាមច្រមុះ គួរ ។ បើក្នុងសម័យភ្លៀងរលឹម សាមណេរដែលជាអ្នកលជ្ជី កាលនឹងដោះការចម្អិនអាមិសឲ្យផុតទៅ ដូចដែលពួកភិក្ខុមិនដាំបាយដោយអង្ករ និងកន្ទក់ជាដើមដែលធ្លាក់ចូលទៅក្នុងសប្បិនោះ ធ្វើឲ្យរលាយក្នុងភ្លើង ហើយត្រង រម្ងាស់ប្រគេនជាថ្មី រមែងគួររហូត ៧ ថ្ងៃ ដោយន័យមុនដូចគ្នា ។

## អធិប្បាយ អំពីប្រេង

បណ្ដាប្រភេទប្រេង នឹងពោលក្នុងប្រេងល្ងមុន ដែលទទួលប្រគេនក្នុងបុរេភត្ត សូម្បីលាយអាមិស រមែងគួរក្នុងវេលាមុនឆាន់ ។ តែតាំងអំពីបច្ឆាភត្តទៅ ប្រាសចាកអាមិសប៉ុណ្ណោះ ទើបគួរ ។ អ្នកសិក្សាគប្បីជ្រាបភាពដែលប្រេងល្ងនោះ ជានិស្សគ្គិយតាមចំនួនភាជនៈ ព្រោះកន្លង ៧ ថ្ងៃទៅ ។ ប្រេងល្ងដែលទទួលប្រគេន ក្នុងបច្ឆាភត្ត ប្រាសចាកអាមិសប៉ុណ្ណោះ ទើបគួររហូត ៧ ថ្ងៃ ។ ទោះបរិភោគប្រេងល្ងដែលធ្វើឲ្យជាឧគ្គហិត រក្សាទុកមិនគួរគួរបង្អោនចូលទៅក្នុងកិច្ច មានការលាបក្បាលជាដើម ។ សូម្បីព្រោះកន្លង

ទៅ ៧ ថ្ងៃ ក៏មិនត្រូវអាបត្តិ ។ ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ល្ងក្នុងបុរេភត្ត ធ្វើលាយអាមិស រមែងគួរក្នុងបុរេភត្ត ។ តាំងអំពីបច្ឆាភត្តទៅ ជារបស់មិនគួរបរិភោគតាមមាត់ គប្បីបង្អោនទៅក្នុងកិច្ច មានការលាបក្បាលជាដើម សូម្បីហួស ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិ ។ ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ល្ងក្នុងបច្ឆាភត្ត ហើយធ្វើ ជារបស់មិនគួរបរិភោគតាមមាត់ដូចគ្នា ព្រោះទទួលប្រគេនទាំងវត្ថុ សូម្បីក្នុងកាលកន្លងទៅ ៧ ថ្ងៃ មិនត្រូវអាបត្តិ គប្បីបង្អោនទៅក្នុងកិច្ច មានការលាបក្បាលជាដើម សូម្បីក្នុងប្រេងដែលធ្វើដោយគ្រាប់ល្ងដែលភិក្ខុចាប់ប៉ះពាល់ក្នុងបុរេភត្ត ឬក្នុងបច្ឆាភត្ត ក៏មានន័យយ៉ាងនេះដូចគ្នា ។

ប្រេងដែលលីងគ្រាប់ល្ង ដែលភិក្ខុទទួលប្រគេនក្នុងបុរេភត្ត ហើយចំហុយម្សៅល្ង ឬស្រុះដោយទឹកក្តៅធ្វើ បើអនុបសម្បន្នធ្វើ សូម្បីលាយអាមិស រមែងគួរក្នុងបុរេភត្ត ។ បើខ្លួនឯងធ្វើ រើសយកវត្ថុចេញហើយ កុំឲ្យមានអាមិស ទើបគួរក្នុងបុរេភត្ត ។ ព្រោះជាប្រេងដែលម្ចាស់ឯង ទើបលាយអាមិស មិនគួរ ។ ព្រោះជារបស់ដែលទទួលប្រគេន ទាំងវត្ថុពីរយ៉ាង ទើបមិនគួរទំពាស៊ី ចាប់ពីបច្ឆាភត្តទៅ គប្បីបង្អោន ចូលទៅក្នុងការលាបក្បាលជាដើម ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិ តែបើទឹកក្តៅមានតិច ទឹកនោះគ្រាន់តែប្រោះចុះប៉ុណ្ណោះ ជាអព្វោហារិក រមែងមិនដល់នូវការរាប់ថា ជាសាមបក្ក ។ សូម្បីក្នុងប្រេងគ្រាប់ស្ពៃជាដើមដែលភិក្ខុទទួលប្រគេនព្រមទាំងវត្ថុ ក៏មានវិនិច្ឆ័យដូចដែលពោលហើយ ក្នុងប្រេងល្ងដែល

មិនមានវត្ថុនោះឯង ។

បើភិក្ខុអាចធ្វើប្រេង អំពីលម្អិតនៃគ្រាប់ស្ពៃជាដើម ដែលទទួលប្រគេនទុកក្នុងបុរេភត្ត ដែលម្ចាស់ដោយកម្តៅថ្ងៃ ប្រេងនោះសូម្បីលាយនឹងអាមិស រមែងគួរក្នុងបុរេភត្ត ។ តាំងអំពីបច្ឆាភត្តទៅ មិនលាយដោយអាមិស ទើបគួរ ។ ក្នុងកាលកន្លងទៅ ៧ ថ្ងៃ ជានិស្សគ្គិយ ។

ម្យ៉ាងទៀត ព្រោះភិក្ខុទាំងឡាយចំហុយលម្អិតគ្រាប់ស្ពៃ និងគ្រាប់ស្រគំជាដើម និងលីងគ្រាប់ល្ហុងប្រេង ហើយធ្វើប្រេងយ៉ាងនេះ ដូច្នោះ ប្រេងនោះរបស់ភិក្ខុទាំងឡាយនោះ ដែលពួកអនុបសម្បន្នធ្វើ សូម្បីលាយអាមិសក៏គួរក្នុងវេលាបុរេភត្ត ។ ព្រោះវត្ថុជាយាវជីវិក ទើបមិនមានទោស ។ ក្នុងការទទួលប្រគេនព្រមទាំងវត្ថុដូច្នេះឯង ។ ប្រេងគ្រាប់ស្ពៃជាដើម ដែលខ្លួនធ្វើឯង គប្បីបរិភោគ ដោយការបរិភោគប្រាសចាកអាមិសតែម្យ៉ាង អស់កាល ៧ ថ្ងៃ ។ ប្រេងដែលធ្វើដោយគ្រាប់ស្ពៃជាដើម ដែលជាឧគ្គហិត មិនគួរបរិភោគ តែគួរក្នុងការប្រើប្រាស់ខាងក្រៅ ។ កាលកន្លងទៅ ៧ ថ្ងៃ ក៏មិនត្រូវអាបត្តិ ។ ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ស្ពៃ ស្រគំ និងល្ហុងប្រេង ដើម្បីនឹងធ្វើប្រេង ហើយធ្វើក្នុងថ្ងៃនោះឯង ជាសត្តាហកាលិក ធ្វើក្នុងថ្ងៃស្អែកឡើង គួរបរិភោគបាន ៦ ថ្ងៃ ធ្វើក្នុងថ្ងៃទី ៣ គួរបរិភោគបាន ៥ ថ្ងៃ ធ្វើក្នុងថ្ងៃទី ៤ គួរ ៣ ថ្ងៃ ... ក្នុងថ្ងៃទី ៥ គួរ ២ ថ្ងៃ ... ក្នុងថ្ងៃទី ៦ គួរមួយថ្ងៃ ... ក្នុងថ្ងៃទី ៧ គួរក្នុងថ្ងៃនោះប៉ុណ្ណោះ ។ បើនៅសល់រហូតដល់អរុណរះឡើង ជានិស្សគ្គិយ ។ បើធ្វើក្នុងថ្ងៃទី ៨ មិនគួរទំពាស៊ីឡើយ តែគួរក្នុងការប្រើ

ប្រាសាទខាងក្រៅ ព្រោះជារបស់មិនទាន់លះបង់ ។ បើមិនធ្វើក្នុងកាលគ្រាប់ស្ងួត ដែលខ្លួនទទួលទុកដើម្បីប្រយោជន៍ដល់ប្រេងជាដើម កន្លងកាល ៧ ថ្ងៃទៅ ត្រូវអាបត្តិទុក្កដតែម្យ៉ាង ។

ម្យ៉ាងទៀត ប្រេងដូង គ្រាប់ស្ពៅ ពទ្រ សង្ក្ស៍រ និងសំរោងជាដើម ដែលមិនបានមកក្នុងព្រះបាលីក៏នៅមាន ។ កាលភិក្ខុទទួលប្រគេនប្រេងទាំងនោះហើយ ឲ្យកន្លង ៧ ថ្ងៃទៅ ត្រូវអាបត្តិទុក្កដ ។ ក្នុងដូងជាដើមនេះ មានសេចក្តីប្លែកគ្នាដូច្នេះថា គប្បីកំណត់វត្ថុនៃយាវកាលិកដ៏សេសហើយ ដឹងវិធីការនៃសាមបក្កសវត្ថុក ( ដែលទទួលទាំងវត្ថុ ហើយចម្អិនឯង ) របស់ដែលទទួលប្រគេនក្នុងបុរេភត្ត ទទួលប្រគេនក្នុងបច្ឆាភត្ត និងឧគ្គហិតវត្ថុទាំងអស់ តាមន័យ ដូចពោលហើយនោះឯង ។

## អធិប្បាយ ប្រេងធ្វើអំពីខ្លាញ់សត្វផ្សេងៗ

បទថា **វសាភេសជ្ជំ** បានដល់ ខ្លាញ់នៃសត្វ ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ ជាភេសជ្ជៈ គឺខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា ។ បណ្តាខ្លាញ់ ៥ ប្រភេទនេះ ខ្លាញ់ខ្លាឃ្មុំ ព្រះមានព្រះភាគទ្រង់អនុញ្ញាតខ្លាញ់នៃសត្វដែលមានមំសៈជាអកប្បិយទាំងអស់ វៀរខ្លាញ់មនុស្សចេញ ។ ម្យ៉ាងទៀត ខ្លាញ់ក្រពើ ( ឬខ្លាញ់ឆ្លាម ) ក៏ព្រះមានព្រះភាគទ្រង់កាន់យកហើយ ដោយសព្ទថា ត្រី តែព្រោះក្រពើជាសត្វកាច ទើបទ្រង់ត្រាស់ចែកទុកដោយឡែកៗ ក្នុងបាលីនេះ ទ្រង់អនុញ្ញាតខ្លាញ់នៃពួកសត្វ ដែលមានសាច់ជាកប្បិយគ្រប់

ប្រភេទ ដោយសព្ទថា ត្រីជាដើម ។

ពិតហើយ ក្នុងពួកមំសៈ មានសាច់មនុស្ស ដំរី សេះ ឆ្កែ ពស់ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ១០ ប្រភេទ ជាអកប្បិយ ។ បណ្ដាខ្លាញ់ ខ្លាញ់មនុស្សតែម្យ៉ាងជាអកប្បិយ ។ បណ្ដាអវយវៈដទៃ មានទឹកដោះជាដើម ឈ្មោះថា ជាអកប្បិយមិនមាន ។ ខ្លាញ់ដែលពួកអនុបសម្បន្នធ្វើនិងត្រងហើយ ភិក្ខុទទួលប្រគេនក្នុងបុរេភត្ត សូម្បីលាយអាមិស ក៏គួរក្នុងបុរេភត្តនោះ ។ តាំងអំពីបច្ឆាភត្តទៅ មិនលាយដោយអាមិស ទើបគួរ រហូត ៧ ថ្ងៃ ។ វត្ថុណាដែលដូចគ្នានឹងធូលីដ៏ល្អិត ជាមំសៈក្តី សរសៃក្តី ឆ្អឹងក្តី ឈាមក្តី លាយនៅក្នុងខ្លាញ់នោះ វត្ថុនេះ ចាត់ជាអព្វោហារិក ។

បើភិក្ខុទទួលប្រគេនខ្លាញ់ធ្វើខ្លាញ់ឯង ទទួលប្រគេន ហើយរម្លាស់ត្រងស្រេចក្នុងបុរេភត្ត គប្បីបរិភោគ ដោយបរិភោគប្រាសចាកអាមិសរហូត ៧ ថ្ងៃ ពិតហើយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ការបរិភោគដោយប្រាសចាកអាមិស ទើបត្រាស់ពាក្យនេះថា ទទួលប្រគេនក្នុងកាលរម្លាស់រួចស្រេចក្នុងកាលត្រង ក្នុងកាលគួរដើម្បីបរិភោគ ដូចបរិភោគប្រេង ។ សាច់ដែលល្អិតជាដើម សូម្បីក្នុងខ្លាញ់ដែលទទួលប្រគេន ហើយចម្រាញ់ ត្រងនោះ ក៏ជាអព្វោហារិកដូចគ្នា តែនឹងទទួលប្រគេន ឬរម្លាស់ក្នុងបច្ឆាភត្ត មិនគួរ ។

សមដូចពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំង-ឡាយ បើខ្លាញ់ដែលភិក្ខុបានទទួលក្នុងវិកាល រម្លាស់ក្នុងវិកាល ត្រងក្នុងវិកាល បើភិក្ខុបរិភោគនូវខ្លាញ់នោះ ត្រូវអាបត្តិទុក្កដ ៣ ម្នាលភិក្ខុទាំងឡាយ

បើភិក្ខុទទួលប្រគេនខ្លាញ់ក្នុងកាល រម្ងាស់ក្នុងវិកាល ត្រងក្នុងវិកាល បើភិក្ខុបរិភោគខ្លាញ់នោះ ត្រូវអាបត្តិទុក្កដ ២ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទទួលប្រគេនក្នុងកាល រម្ងាស់ក្នុងកាល ត្រងក្នុងវិកាល បើបរិភោគខ្លាញ់នោះ ត្រូវអាបត្តិទុក្កដ ១ ម្នាលភិក្ខុទាំងឡាយ បើប្រេងភិក្ខុទទួលប្រគេនក្នុងកាល រម្ងាស់ក្នុងកាល ត្រងក្នុងកាល បើភិក្ខុបរិភោគខ្លាញ់នោះ មិនត្រូវអាបត្តិដូច្នេះ ។

តែពួកអន្តេវាសិក សួរព្រះឧបតិស្សត្ថេរថា បពិត្រលោកម្ចាស់ សប្បិ នវនីត និងប្រេង ដែលភិក្ខុចម្រាញ់រួមគ្នា ហើយស្រង់កាកចេញ គួរ ឬមិនគួរ ព្រះថេរៈឆ្លើយថា មិនគួរទេ អាវុសោ បានឮថា ព្រះថេរៈវង្វៀសក្នុងសប្បិ នវនីត សន្សោមខ្លាញ់ដែលភិក្ខុចម្រាញ់រួមគ្នា ហើយស្រង់កាកចេញនេះ ដូចក្នុងកាកប្រេងល្ងដែលរម្ងាស់ ។

ក្រោយមក ពួកអន្តេវាសិកសួរធ្ងន់ឡើងថា បពិត្រលោកម្ចាស់ ដុំទធិក្ដី តំណក់តក្កៈក្ដី មាននៅក្នុងនវនីតៗ នោះ គួរ ឬមិនគួរ ព្រះថេរៈឆ្លើយថា អ្នកមានអាយុ សូម្បីនវនីតនោះ ក៏មិនគួរ ។ លំដាប់នោះ ទើបពួកអន្តេវាសិកសួរលោកថា បពិត្រលោកម្ចាស់ ខ្លាញ់ដែលរម្ងាស់រួមគ្នា ត្រងហើយ មានកម្ដៅខ្លាំង រមែងបំបាត់រោគបាន ព្រះថេរៈព្រមទទួលថា សាធុ អាវុសោ ដូច្នេះ ។

តែព្រះមហាសុមត្ថេរពោលថា ខ្លាញ់របស់សត្វដែលមានសាច់ជាកប្បិយ រមែងគួរក្នុងការបរិភោគលាយអាមិស ខ្លាញ់របស់ពួកសត្វ ដែលមានសាច់ជាអកប្បិយក្រៅពីនេះ គួរក្នុងការបរិភោគប្រាសចាកអាមិស ។

ឯព្រះមហាបទុមត្ថេរបដិសេធថា ពោលថាដូច្នេះ ហើយពោលថា ពួកភិក្ខុអាពាធដោយរោគខ្យល់ បន្ទំមខាញ់ខ្លាឃ្មុំ និងជ្រូកជាដើមចូលទៅក្នុងបបរដែលស្ងោរដោយទឹកចត់ ដែលជាឫសឈើ ៥ ប្រភេទ ហើយហុតបបរ បបរនោះបំបាត់រោគបាន ព្រោះមានការក្តៅខ្លាំង ដូច្នេះ ទើបពោលថា គួរ ។

## អធិប្បាយ អំពីទឹកឃ្មុំ

ពីរបទថា **មធុ ឆាម មក្ខិកាមធុ** បានដល់ ទឹកផ្អែមដែលពួកឃ្មុំធំ ឃ្មុំតូច និងប្រភេទមេប្រួត ដែលមានឈ្មោះថា សត្វល្អិតធ្វើទឹកផ្អែមនោះ ។ ទឹកឃ្មុំនោះ ភិក្ខុទទួលប្រគេនមុនឆាន់ សូម្បីនឹងបរិភោគលាយអាមិស ក្នុងបុរេភត្ត ក៏គួរ ។ តាំងអំពីបច្ឆាភត្តទៅ គួរបរិភោគប្រាសចាកអាមិសតែម្យ៉ាង រហូត ៧ ថ្ងៃ ក្នុងកាលកន្លង ៧ ថ្ងៃទៅ បើទឹកឃ្មុំកកក្រាស់ដូចគ្នានឹងជ័រ ( រម្ងាស់ឲ្យខាស់ ) ធ្វើជាដុំតូចដុំធំរក្សាទុក ឬទឹកឃ្មុំប្រភេទក្រៅអំពីនេះ រក្សាទុកក្នុងភាជនៈផ្សេងៗ គ្នា ជានិស្សគ្គិយច្រើនតាមចំនួនវត្ថុ បើមានត្រឹមតែមួយដុំប៉ុណ្ណោះក្តី ទឹកឃ្មុំខ្វះក្រៅពីនេះក្តី ដែលទុកក្នុងភាជនៈមួយ ជានិស្សគ្គិយត្រឹមតែមួយ ។ ទឹកឃ្មុំដែលជាឧគ្គហិត គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ គប្បីបង្អោនចូលទៅក្នុងកិច្ចដទៃ មានលាបដំបៅជាដើម ។ សម្បុកឃ្មុំ ឬក្រមួនឃ្មុំ បើទឹកឃ្មុំមិនជាប់ ជាយាវជីវិក ។ តែបើមានទឹកឃ្មុំជាប់ មានគតិដូចទឹកឃ្មុំដូចគ្នា ។ មេឃ្មុំខ្ទួនវែង មានស្លាប ឈ្មោះថា **ចិរិក** មេព្រួតធំ ខ្ទួនខ្មៅ មានស្លាបរឹង មានឈ្មោះថា **តុម្ពល** ក្នុងសម្បុកនៃមេឃ្មុំទាំងនោះ មានទឹកឃ្មុំដូចគ្នានឹងជ័រ ។ ទឹកឃ្មុំនោះជាយាវជីវិក ។

# អធិប្បាយ អំពីទឹកអំពៅ

*បទថា* **ផាណិតន្នាម ឧច្ឆុម្ហា និព្វត្តំ** *សេចក្ដីថា ទឹកអំពៅប្រភេទដែលមិនទាន់រម្ងាស់ ឬដែលរម្ងាស់ហើយមិនមានកាក ឬដែលមិនមានកាកសូម្បីទាំងអស់ រហូតដល់ទឹកអំពៅស្រស់ គប្បីជ្រាបថា ទឹកអំពៅ ។ ទឹកអំពៅនោះដែលភិក្ខុទទួលប្រគេនមុនឆាន់ សូម្បីលាយអាមិស ក៏គួរក្នុងបុរេភត្ត ។ បើអំពីបច្ឆាភត្តទៅ មិនលាយដោយអាមិស ទើបគួររហូត ៧ ថ្ងៃ ។ ក្នុងកាលកន្លង ៧ ថ្ងៃទៅ ជានិស្សគ្គិយតាមចំនួនវត្ថុ ។ ដុំស្ករអំពៅសូម្បីច្រើនដែលភិក្ខុធ្វើឲ្យតូចហើយ ទុកក្នុងភាជនៈជាមួយគ្នា រមែងរលាយចូលគ្នាយ៉ាងណែន ជានិស្សគ្គិយត្រឹមតែមួយប៉ុណ្ណោះ ។ ទឹកអំពៅដែលជាឧគ្គហិត គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ គប្បីបង្អោនចូលទៅក្នុងកិច្ចដទៃ មានការអប់កុដិជាដើម ។*

*ផាណិតដែលគេធ្វើដោយទឹកអំពៅស្រស់ ដែលមិនទាន់បានត្រង ភិក្ខុទទួលប្រគេនក្នុងវេលាមុនឆាន់ បើអនុបសម្បន្នធ្វើ សូម្បីលាយអាមិសក៏គួរ ។ បើភិក្ខុធ្វើឯង ទាល់តែមិនលាយដោយអាមិស ទើបគួរ ។ ចាប់អំពីបច្ឆាភត្តទៅ មិនគួរបរិភោគតាមមាត់ ព្រោះជាសវត្ថុក ។ សូម្បីក្នុងកាលកន្លងទៅ ៧ ថ្ងៃ ក៏មិនត្រូវអាបត្តិ ។ សូម្បីបុគ្គលធ្វើដោយទឹកអំពៅស្រស់ ភិក្ខុទទួលប្រគេនទាំងមិនបានត្រងក្នុងបច្ឆាភត្ត ក៏មិនគួរបរិភោគតាមមាត់ដូចគ្នា ។ ក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិ សូម្បីក្នុងផាណិតដែលភិក្ខុទទួលប្រគេនទាំងដើម ហើយធ្វើ ក៏មានន័យយ៉ាងនេះ ។*

*ផាណិតដែលធ្វើដោយទឹកអំពៅស្រស់ ត្រង និង ទទួលប្រគេនក្នុង*

បុរេភត្ត បើអនុបសម្បន្នធ្វើ សូម្បីលាយអាមិស ក៏គួរក្នុងបុរេភត្ត ។ តាំងអំពីបច្ឆាភត្តទៅ មិនលាយដោយអាមិស ទើបគួររហូត ៧ ថ្ងៃ ។ បើភិក្ខុធ្វើឯង មិនលាយអាមិស រមែងគួរក្នុងបុរេភត្ត ចាប់ពីបច្ឆាភត្តទៅ មិនលាយអាមិសដូចគ្នា គួររហូត ៧ ថ្ងៃ តែផាណិតធ្វើដោយទឹកអំពៅស្រស់ដែលត្រង់ទទួលប្រគេន ហើយក្នុងបច្ឆាភត្ត ប្រាសចាកអាមិសប៉ុណ្ណោះ ទើបគួរអស់កាល ៧ ថ្ងៃ ផាណិតដែលជាឧគ្គហិត មានន័យដូចពោលហើយដូចគ្នា ។

ក្នុងមហាអដ្ឋកថាពោលថា ផាណិតដែលធ្វើដោយអំពៅដុតក្តី ផាណិតដែលធ្វើដោយអំពៅគាបក្តី គួរតែក្នុងបុរេភត្តប៉ុណ្ណោះ ឯក្នុងមហាបច្ចរីតាំងសំណួរថា ផាណិតដែលម្ចាស់ទាំងវត្ថុ ( កាក ) នេះ គួរ ឬមិនគួរ ដូច្នេះ ហើយពោលថា ផាណិតដែលធ្វើដោយទឹកអំពៅស្រស់ ឈ្មោះថា មិនគួរក្នុងបច្ឆាភត្ត រមែងមិនមាន ។ ពាក្យនោះ ត្រឹមត្រូវហើយ ។

ផាណិតដែលធ្វើអំពីផ្កាស្រគំ ដែលធ្វើដោយទឹកត្រជាក់ ទោះបីលាយអាមិស ក៏គួរក្នុងបុរេភត្ត ចាប់អំពីបច្ឆាភត្តទៅ មិនលាយដោយអាមិស ទើបគួរអស់កាល ៧ ថ្ងៃ ។ ក្នុងកាលកន្លងទៅ ៧ ថ្ងៃ ត្រូវអាបត្តិ ទុក្កដតាមចំនួនវត្ថុ ឯផាណិតស្រគំដែលគេបន្ថែមទឹកដោះធ្វើ ជាយាវកាលិក ។ តែជនទាំង-ឡាយដួស ពពុះទឹកដោះចេញហើយ ជម្រះខណ្ឌសក្ករៈ គឺដុំស្ករឲ្យស្អាត ព្រោះដូច្នោះ ខណ្ឌសក្ករៈនោះ គួរ ។ ចំណែកផ្កាស្រគំស្រស់ គួរក្នុងបុរេភត្ត លីងហើយក៏គួរ លីងហើយ បុកផ្សំដោយរបស់ដទៃ មានគ្រាប់ល្ងជាដើម ឬមិនផ្សំក្តី ក៏គួរ ។

បើជនទាំងឡាយកាន់យកផ្កាស្រគំនោះ ប្រកបបចូលគ្នា ( ផ្សំ ) ដើម្បីមេរ័យ ផ្កាស្រគំដែលផ្សំហើយនោះ រមែងមិនគួរតាំងអំពីពូជ ។ ផាណិតនៃផ្លែឈើដែលជាយាវកាលិកទាំងអស់ មានចេក ផ្លែឥន្ទូលាំ ( ទីខ្លះ ថាផ្លែល្មុ ) ស្វាយ ខ្នុរ ខ្នុរសម្ល និងអំពិលជាដើម ជាយាវកាលិកដូចគ្នា ជនទាំងឡាយធ្វើផាណិត ដោយមេ្ទសទុំ ផាណិតនោះ ជាយាវជីវិក ។

ពីរបទថា **តានិ បដិគ្គហេត្វា** សេចក្តីថា បើភិក្ខុទទួលប្រគេនភេសជ្ជៈ ៥ យ៉ាង មានសប្បិជាដើម ទាំងអស់នេះរក្សាទុកមិនបែកគ្នាក្នុងភាជន៍មួយ កាលកន្លង ៧ ថ្ងៃទៅហើយ ជានិស្សគ្គិយតែមួយប៉ុណ្ណោះ បើបំបែកគ្នា ជានិស្សគ្គិយ ៥ ។ ភេសជ្ជៈ ៥ យ៉ាង ដែលមិនទាន់កន្លង ៧ ថ្ងៃ ភិក្ខុអាពាធក្តី មិនអាពាធក្តី គួរបរិភោគតាមសប្បាយ ដោយន័យដូចពោលហើយ ។

## ពុទ្ធានុញ្ញាត ៧ យ៉ាង

អនុញ្ញាតដែលទ្រង់អនុញ្ញាតចំពោះ មាន ៧ យ៉ាង គឺអនុញ្ញាតចំពោះអាពាធ ១ ចំពោះបុគ្គល ១ ចំពោះកាល ១ ចំពោះសម័យ ១ ចំពោះបទេស ១ ចំពោះខ្វាញ់ ១ ចំពោះភេសជ្ជៈ ១ ។

បណ្តាអនុញ្ញាតចំពោះ ៧ យ៉ាងនោះ ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះអាពាធ បានដល់ ប្រការដែលទ្រង់អនុញ្ញាតចំពោះអាពាធយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ឆៅ ឈាមស្រស់ ដល់ភិក្ខុដែលមានអាពាធកើតអំពីអមនុស្ស ។ សាច់ឆៅ និងឈាមស្រស់នោះ គួរដល់ភិក្ខុអាពាធ ដោយអាពាធនោះតែម្យ៉ាង មិនគួរដល់ភិក្ខុដទៃឡើយ ។ ឯសាច់ឆៅ

និងឈាមស្រស់នោះ ជាកប្បិយក្តី អកប្បិយក្តី រមែងគួរទាំងអស់ ទាំងក្នុងកាល និងក្នុងវិកាល ។

ការដែលទ្រង់អនុញ្ញាតចំពោះបុគ្គល បានដល់ សិក្ខាបទដែលទ្រង់អនុញ្ញាតចំពោះបុគ្គលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការទំពាអៀង ដល់ភិក្ខុអ្នកទំពាអៀងជាប្រក្រតី ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំខ្ជាក់អាហារចេញមកខាងក្រៅទ្វារមាត់ ហើយលេបចូលទៅវិញ ។ ការរើអៀងនោះ គួរដល់ភិក្ខុដែលមានជាតិជាអ្នកទំពាអៀងប៉ុណ្ណោះ មិនគួរដល់ភិក្ខុដទៃឡើយ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះកាល បានដល់ ទ្រង់អនុញ្ញាតចំពោះកាលដែលភិក្ខុត្រូវពស់ចឹក យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យថ្នាំមហាវិកដ ៤ យ៉ាង គឺ គូថ ( អាចម៍ ) ១ មុត្ត ( ទឹកនោម ) ១ ផេះ ១ ដី ១ ។ ថ្នាំមហាវិកដនោះ ចំពោះក្នុងកាលនោះ សូម្បីមិនទទួលប្រគេន គួរក្នុងកាលដទៃមិនគួរឡើយ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះសម័យ បានដល់ អនាបត្តិទាំង-ឡាយ ដែលទ្រង់អនុញ្ញាតចំពោះសម័យនោះ ដោយន័យជាដើមថា ( ត្រូវអាបត្តិបាចិត្តិយ ) ព្រោះគណៈភោជន វៀរតែមានសម័យ ដូច្នេះជាដើម ។ អាបត្តិទាំងនោះ ជាអាបត្តិចំពោះក្នុងសម័យនោះប៉ុណ្ណោះ ក្នុងសម័យដទៃមិនគួរឡើយ ។

ដែលឈ្មោះថា អនុញ្ញាតចំពោះបទេស បានដល់ សង្ឃកម្ម មានឧបសម្បទាជាដើម ដែលទ្រង់អនុញ្ញាតចំពោះក្នុងបច្ចន្តបទេស យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការឧបសម្បទាដោយគណៈ មានវិនយធរជាគម្រប់ ៥ ក្នុងបច្ចន្តជនបទបែបនេះ ។ សង្ឃកម្ម មានឧបសម្បទាជាដើមនោះ រមែងគួរចំពោះក្នុងបច្ចន្តជនបទនោះប៉ុណ្ណោះ ក្នុងមជ្ឈិមបទេសមិនគួរឡើយ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះខ្លាញ់ បានដល់ បទដែលទ្រង់អនុញ្ញាតភេសជ្ជៈ ដោយឈ្មោះនៃខ្លាញ់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ជាភេសជ្ជៈ ។ ខ្លាញ់ភេសជ្ជៈនោះ របស់ពួកសត្វមានខ្លាញ់ជាកប្បិយ និងអកប្បិយទាំងអស់ វៀរតែខ្លាញ់របស់មនុស្សចេញ គួរដើម្បីបរិភោគ ដូចបរិភោគប្រេង ដល់ភិក្ខុទាំងឡាយដែលត្រូវការដោយប្រេង ដូច្នោះ ។

ឈ្មោះថា ទ្រង់អនុញ្ញាតចំពោះភេសជ្ជៈ បានដល់ សប្បិ នវនីត ប្រេង ទឹកឃ្មុំ ទឹកអំពៅដែលអាចផ្សាយទៅ ដើម្បីសម្រេចអាហារកិច្ច ដែលទ្រង់អនុញ្ញាតទុកដោយឈ្មោះនៃភេសជ្ជៈ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភេសជ្ជៈ ៥ យ៉ាង ។ ភេសជ្ជៈទាំងឡាយ ៥ នោះ ភិក្ខុទទួលហើយគប្បីបរិភោគបានតាមសប្បាយ ក្នុងបុរេភត្ត ក្នុងថ្ងៃនោះ តាំងអំពីបច្ឆាភត្តទៅកាលមានហេតុ គប្បីបរិភោគបានរហូត ៧ ថ្ងៃ ដោយន័យដូចពោលហើយ ។

## អធិប្បាយ

## បទភាជនីយនៃភេសជ្ជសិក្ខាបទ

[១៤២] បទថា **សត្តាហាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ**

សេចក្ដីថា សប្បិភេសជ្ជៈនោះ មានប្រមាណប៉ុនគ្រាប់ស្ពៃ ល្មមនឹងយកម្រាមដៃធ្វើ ហើយលិទ្ធដោយអណ្ដាតម្ដង ក៏ភិក្ខុចាំបាច់ត្រូវលះដោយពិត និងគប្បីសម្ដែងអាបត្តិបាចិត្តិយចេញ ។

[ ១៤៣ ] បទថា **ន កាយិកេន បរិភោគេន បរិភុញ្ជិតព្វំ** សេចក្ដីថា កុំគប្បីយកលាបរាងកាយ ឬលាបដំបៅត្រង់រាងកាយ ។ សប្បិបរិក្ខារ មានសំពត់កាសាវៈ ឈើប្រត់ ស្បែកជើង ទ្រនាប់ជូតជើង គ្រែ និងតាំងជាដើម ត្រូវភេសជ្ជៈដែលជានិស្សគ្គិយទាំងនោះប្រឡាក់ហើយ ជារបស់មិនគួរបរិភោគ ។ ក្នុងមហាបច្ចរីពោលថា ទីសម្រាប់ដៃចាប់ សប្បិក្នុងសន្ទះទ្វារ និងបង្អួច ក៏មិនគួរលាប ។ ក្នុងមហាអដ្ឋកថាពោលថា តែផ្សំចុះក្នុងទឹកចត់ហើយ គួរលាបសន្ទះទ្វារ និងបង្អួចបាន ។

[ ១៤៤ ] បទថា **អនាបត្តិ អន្តោសត្តាហំ អធិដ្ឋេតិ** សេចក្ដីថា ខាងក្នុង ៧ ថ្ងៃ ភិក្ខុអធិដ្ឋានសប្បិ ប្រេង និងខ្លាញ់ទុក ជាប្រេងលាបក្បាល ឬជាប្រេងសម្រាប់បន្តក់ អធិដ្ឋានទឹកឃ្មុំទុកជាថ្នាំលាបដំបៅ ទឹកអំពៅជាគ្រឿងអប់កុដិ មិនត្រូវអាបត្តិ ។ បើភិក្ខុបំណងនឹងប្រាថ្នាសម្រិតប្រេងដែលអធិដ្ឋានទុកហើយ ក្នុងភាជនៈដាក់ប្រេងដែលមិនទាន់បានអធិដ្ឋាន បើក្នុងភាជនៈមានប្រហោងតូច ប្រេងដែលហូរសន្សើមៗ ចូលទៅ ត្រូវប្រេងចាស់ខ្លះឡើងមក លិច គប្បីអធិដ្ឋានជាថ្មី ។ បើភាជនៈមាត់ទូលាយ ប្រេងច្រើនហូរចូលទៅយ៉ាងរហ័ស រហូតលិចប្រេងចាស់ មិនមានកិច្ចដែលត្រូវអធិដ្ឋានជាថ្មីឡើយ ពិតហើយ ប្រេងនោះ មានគតិដូចប្រេងដែលអធិដ្ឋានហើយ ។ អ្នកសិក្សាគប្បីជ្រាបការសម្រិតប្រេងដែលមិនបានអធិដ្ឋាន ចុះក្នុងភាជនៈដាក់

ប្រេងដែលអធិដ្ឋានហើយ ដោយន័យនេះ ។

ក្នុងបទថា **វិស្សជ្ជេតិ** មានវិនិច្ឆ័យដូច្នេះថា បើភេសជ្ជៈនោះ ជារបស់ពីរម្ចាស់ ភិក្ខុមួយអង្គទទួលប្រគេន មិនទាន់បានចែកគ្នា ក្នុងកាលកន្លង ៧ ថ្ងៃទៅ មិនត្រូវអាបត្តិទាំងពីរអង្គ តែមិនគួរបរិភោគ ។ បើភិក្ខុអង្គណាទទួលប្រគេន អង្គនោះពោលនឹងភិក្ខុមួយអង្គទៀតថា លោកដ៏មានអាយុ ប្រេងនេះដល់កំណត់ ៧ ថ្ងៃហើយ លោកចូរប្រើប្រាស់ប្រេងនោះចុះ ដូច្នេះហើយ លោកមិនធ្វើការបរិភោគ តើត្រូវអាបត្តិដល់បុគ្គលណា ឆ្លើយថា មិនត្រូវអាបត្តិដល់បុគ្គលណាទាំងអស់ ។ ព្រោះហេតុអ្វី ព្រោះភិក្ខុដែលទទួលប្រគេន ក៏លះហើយ និងព្រោះភិក្ខុមួយរូបទៀត ក៏មិនបានទទួលប្រគេន ។

បទថា **វិនស្សេតិ** បានដល់ ជារបស់បរិភោគមិនបាន ។

ក្នុងបទថា **ចត្តេន** ជាដើម មានវិនិច្ឆ័យដូច្នេះថា ភេសជ្ជៈដែលភិក្ខុលះហើយ អស់អាល័យហើយ ដោយចិត្តណា ចិត្តនោះ ព្រះមានព្រះភាគត្រាស់ហៅថា លះបង់ហើយ បោលហើយ លែងអាល័យហើយ ។ ត្រាស់ហៅបុគ្គលដែលមិនមានការជាប់ជំពាក់ដោយចិត្តនោះ ។ អធិប្បាយថា ជាអ្នកមិនមានការជាប់ជំពាក់យ៉ាងនោះ ឲ្យហើយដល់សាមណេរ ។ ពាក្យនេះត្រាស់ទុកព្រោះហេតុដូចម្ដេច ឆ្លើយថា ព្រះមហាសុមត្ថេរពោលថា ត្រាស់ទុកដើម្បីសម្ដែងថា មិនត្រូវអាបត្តិដល់ភិក្ខុដែលឲ្យហើយ ក្នុងខាងក្នុង ៧ ថ្ងៃយ៉ាងនោះ ខាងក្រោយបានឲ្យមកវិញ ហើយឆាន់ ។

ឯព្រះមហាបទុមត្ថេរពោលថា ប្រេងនេះ ភិក្ខុមិនគួរស្ទូម ព្រោះថា ក្នុង

ការបរិភោគជាថ្មី ដែលប្រេងនោះឲ្យទៅហើយខាងក្នុង ៧ ថ្ងៃ មិនមានអាបត្តិឡើយ តែត្រាស់ពាក្យនេះ ក៏ដើម្បីសម្តែងថា មិនត្រូវអាបត្តិ ព្រោះបរិភោគប្រេងដែលកន្លង ៧ ថ្ងៃទៅ ព្រោះហេតុនោះ ភេសជ្ជៈដែលគេប្រគេនហើយយ៉ាងនេះ បើសាមណេរចម្អិនហើយ ឬមិនបានចម្អិន ប្រគេនដល់ភិក្ខុនោះដើម្បីធ្វើនត្ថុ ភិក្ខុទទួលហើយ គប្បីធ្វើនត្ថុ ។ បើសាមណេរជាអ្នកល្ងង់ខ្លៅមិនដឹងប្រគេន ភិក្ខុដទៃគប្បីប្រាប់លោកថា នែសាមណេរ អ្នកមានប្រេងឬសាមណេរ ទទួលថា មាន លោកម្ចាស់ ភិក្ខុនោះគប្បីប្រាប់ថា យកមកចុះខ្ញុំនឹងធ្វើថ្នាំ ប្រគេនព្រះថេរៈ ប្រេងរមែងគួរ សូម្បីដោយ ( ការកាន់យក ) យ៉ាងនេះ ។ ពាក្យដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាអកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ភេសជ្ជសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ១៤៥ ] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលទ្រង់គង់នៅវត្តជេតវន មហាវិហារ ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ ពេលនោះឯង ព្រះទ្រង់យសជាម្ចាស់ទ្រង់អនុញ្ញាតវស្សិកសាដិក ( សំពត់ងូតទឹកភ្លៀង ) ដល់ភិក្ខុទាំងឡាយហើយ ។ ពួកភិក្ខុឆព្វគ្គិយបានដំណឹងថា ព្រះទ្រង់យសជាម្ចាស់ទ្រង់អនុញ្ញាតវស្សិកសាដិកហើយ ក៏នាំគ្នាស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀងមុនគេ ហើយធ្វើប្រើប្រាស់ក៏មុនគេដែរ កាលសំពត់ងូតទឹកភ្លៀងចាស់ខូចខាតហើយ ( ឆព្វគ្គិយភិក្ខុ ) ក៏ងូតទឹកភ្លៀងដោយខ្លួនទទេ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយ មិនសមបីបើនឹងប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀង ហើយប្រញាប់ធ្វើប្រើប្រាស់សោះ កាលសំពត់វស្សិកសាដិកចាស់ខូចខាតហើយ ក៏ត្រឡប់ងូតទឹកភ្លៀងដោយខ្លួនទទេទៅវិញ ។ គ្រានោះពួកភិក្ខុទាំងនោះក៏នាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះទ្រង់ជោគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ គេថាពួកអ្នកឯងប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀងមុនគេ ប្រញាប់ធ្វើប្រើប្រាស់មុនគេ លុះសំពត់វស្សិកសាដិកចាស់ខូចហើយ ត្រឡប់ជាងូតទឹកភ្លៀងដោយខ្លួនទទេទៅវិញ ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានជោគជាម្ចាស់ ទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស មិនសមបីបើ

ពួកអ្នកឯង ប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀងមុនគេ ប្រញាប់ធ្វើប្រើប្រាស់មុនគេ លុះសំពត់ងូតទឹកភ្លៀងចាស់គ្រាំគ្រា ត្រឡប់ជានាំគ្នាងូតទឹកភ្លៀងដោយខ្លួនទទេសោះ ម្នាលមោឃបុរសទាំងឡាយ អំពើនេះ មិននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុកំណត់ដឹងថា ខែ ១ ជាខាងចុងនៃគិម្ហរដូវ[១] គប្បីស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ភិក្ខុកំណត់ដឹងថា នៅកន្លះខែ ជាខាងចុងនៃគិម្ហរដូវទៀត គប្បីធ្វើឲ្យស្រេចហើយប្រើប្រាស់ចុះ ។ បើមិនទាន់ដល់ខែ ១ ជាខាងចុងនៃគិម្ហរដូវទេ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង និងមិនទាន់ដល់កន្លះខែ ជាខាងចុងគិម្ហរដូវទេ ភិក្ខុធ្វើឲ្យស្រេចហើយ ប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៤៦ ] ត្រង់ពាក្យថា ភិក្ខុកំណត់ដឹងថា ខែ ១ ជាខាងចុងនៃគិម្ហរដូវ ត្រូវស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង មានអធិប្បាយថា អំពីដើមមក មនុស្សទាំងឡាយណា ធ្លាប់ប្រគេនសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ពួកភិក្ខុគប្បីចូលទៅរកមនុស្សទាំងឡាយនោះ ហើយពោលយ៉ាងនេះថា ពេលនេះជាកាលនៃវស្សិកសាដិក ពេលនេះ ជាសម័យនៃវស្សិកសាដិក សូម្បីពួក

---

១- តាំងតែ ១ រោចខែជេស្ឋ ទៅដល់ថ្ងៃពេញបូណ៌មីខែអាសាឍ្ហ ហៅថា ខែ ១ ជាខាងចុងគិម្ហរដូវ ។ តាំងតែ ១ កើត ខែអាសាឍ្ហ ទៅដល់ថ្ងៃពេញបូណ៌មី ហៅថា កន្លះខែជាខាងចុងគិម្ហរដូវ ។

មនុស្សឯទៀតគេតែងប្រគេនសាដិកចីវរសម្រាប់ងូតទឹកភ្លៀងដែរ ។ ពួកភិក្ខុមិនត្រូវនិយាយថា អ្នកទាំងឡាយចូរឲ្យសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ដល់អាត្មា ចូរនាំយកសាដិកចីវរសម្រាប់ងូតទឹកភ្លៀងមកឲ្យអាត្មា ចូរផ្លាស់ប្តូរសាដិកចីវរសម្រាប់ងូតទឹកភ្លៀងឲ្យអាត្មា ចូរទិញសាដិកចីវរសម្រាប់ងូតទឹកភ្លៀងឲ្យអាត្មា ។ ពាក្យថា ភិក្ខុកំណត់ដឹងថា នៅកន្លះខែជាខាងចុង គិម្ហរដូវទៀត គប្បីធ្វើឲ្យស្រេច ហើយប្រើប្រាស់ចុះ គឺ ភិក្ខុគប្បីធ្វើឲ្យស្រេច ហើយប្រើប្រាស់ក្នុងកន្លះខែជាខាងចុងគិម្ហរដូវ ។ ពាក្យថា បើមិនទាន់ដល់ខែ ១ ជាខាងចុងនៃគិម្ហរដូវទេ គឺ ថ្ងៃមុនពីមួយខែជាខាងចុងគិម្ហរដូវ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ចីវរនោះជានិស្សគ្គិយ ។ ពាក្យថា មិនទាន់ដល់កន្លះខែជាខាងចុងគិម្ហរដូវទេ គឺ ថ្ងៃមុនពីកន្លះខែជាខាងចុងគិម្ហរដូវ ភិក្ខុធ្វើស្រេចហើយប្រើប្រាស់ សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ឲ្យស្រឡះដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន វស្សិកសាដិកចីវររបស់ខ្ញុំនេះ ខ្ញុំស្វែងរកបានមកក្នុងកាលមុនពីមួយខែ ជាខាងចុងគិម្ហរដូវ ធ្វើស្រេចហើយប្រើប្រាស់ ក្នុងកាលមុនពីកន្លះខែជាខាងចុងគិម្ហរដូវ សំពត់នេះជានិស្សគ្គិយ ខ្ញុំសូមលះបង់នូវវស្សិកសាដិកចីវរនេះដល់សង្ឃ ។បេ។ ពាក្យតពីនេះទៅមានសេចក្តី ដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គ ។

[ ១៤៧ ] ខាងចុងគិម្ហរដូវនៅលើស ១ ខែ ភិក្ខុសម្គាល់ថា លើសមែន ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

ខាងចុងគិម្ហរដូវនៅលើស ១ ខែ តែភិក្ខុមានសេចក្តីសង្ស័យ ហើយស្វែងរកវស្សិកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើស ១ ខែ ភិក្ខុសម្គាល់ថានៅខ្វះ ហើយស្វែងរកវស្សិកសាដិកចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុសម្គាល់ថា លើសមែន ហើយធ្វើឲ្យស្រេច ប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើឲ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុសម្គាល់ថា នៅខ្វះ ហើយធ្វើឲ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ វស្សិកសាដិកចីវររបស់ភិក្ខុមានតែភិក្ខុស្រាតងូតទឹកភ្លៀង ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់ ១ ខែ ភិក្ខុសម្គាល់ថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់ ១ ខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវ នៅខ្វះមិនដល់ ១ ខែ ភិក្ខុសម្គាល់ថា នៅខ្វះមិនដល់ ១ ខែមែន មិនត្រូវអាបត្តិ ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ភិក្ខុសម្គាល់ថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវ នៅខ្វះមិនដល់កន្លះខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវ នៅខ្វះមិនដល់កន្លះខែ ភិក្ខុសម្គាល់ថា មិនដល់កន្លះខែមែន មិនត្រូវអាបត្តិឡើយ ។

[ ១៤៨ ] អាបត្តិមិនមានដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅសល់ ១ ខែ ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថា

ខាងចុងគិម្ហរដូវនៅសល់កន្លះខែទៀត ហើយធ្វើឲ្យស្រេច ប្រើប្រាស់ ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅខ្វះមិនដល់មួយខែ ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ហើយធ្វើឲ្យស្រេច ប្រើប្រាស់ ដល់ភិក្ខុដែលស្វែងរកសាដិកចីវរបានស្រេចហើយ ( ស្រាប់តែដឹងជាខាងក្រោយថា ) គេលើកមួយខែជាខាងដើមនៃវស្សានរដូវ ( ឆ្នាំមានខែអធិកមាស ) ដល់ភិក្ខុដែលស្លៀកវស្សិកសាដិកនោះហើយ ( ទើបដឹងថា ) គេលើកខែ ១ ជាខាងដើមនៃវស្សានរដូវ ដល់ភិក្ខុដែលលាងវស្សិកសាដិកហើយតម្កល់ទុក ដល់ភិក្ខុដែលប្រើប្រាស់វស្សិកសាដិកក្នុងកាលដ៏គួរ ដល់ភិក្ខុមានចីវរ[១] ដែលចោរដណ្តើមយកទៅ ដល់ភិក្ខុមានចីវរបាត់[២] ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ[៣] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ៤ ចប់

---

១-ពាក្យថា ចីវរក្នុងទីនេះសំដៅយក វស្សិកសាដិកចីវរ បើចោរដណ្តើមយកសំពត់របស់ភិក្ខុនោះទៅ ហើយភិក្ខុនោះងូតទឹកភ្លៀងដោយខ្លួនទទេ មិនត្រូវអាបត្តិទុក្កដ ព្រោះស្រាតងូតទឹកភ្លៀង។

២-បើភិក្ខុមានចីវរដទៃៗ ក្រៅពីវស្សិកសាដិកចីវរដែលបាត់ទៅនោះ នឹងស្លៀកក្តី នឹងស្វែងរកក្តី នូវសំពត់វស្សិកសាដិក ក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ បើភិក្ខុមានវស្សិកសាដិកចីវរបាត់វិញ ហើយស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដឡើយ ។

៣-បើភិក្ខុស្លៀកសំពត់វស្សិកសាដិកមានតម្លៃច្រើនងូតទឹក ហើយមានចោរដណ្តើមយកទៅ ភិក្ខុស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដទេ ។ ម្យ៉ាងទៀត ពួកចោរលួចយកសំពត់ដទៃ ក្រៅពីវស្សិកសាដិកចីវរ ដែលភិក្ខុមិនទាន់បានស្លៀកហើយ បើភិក្ខុស្លៀកសំពត់វស្សិកសាដិក ក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវនិស្សគ្គិយបាចិត្តិយទេ ។

# អដ្ឋកថា

## បត្តវគ្គ សិក្ខាបទទី ៤

## វស្សិកសាដិកសិក្ខាបទ

[ ១៤៥ ] *វស្សិកសាដិកសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងវស្សិកសាដិកសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា ពីរបទថា* **វស្សិកសាដិក អនុញ្ញាតា** *សេចក្តីថា សំពត់ងូតទឹកភ្លៀង ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកហើយ ក្នុងរឿងនាងវិសាខា ក្នុងចីវរក្ខន្ធកៈ ។*

*បទថា* **បដិកច្ចេវ** *ប្រែថា មុនគេនោះឯង ។*

# អធិប្បាយ

## សិក្ខាបទវិភង្គនៃវស្សិកសាដិកសិក្ខាបទ

[ ១៤៦ ] *ប្រើនបទថា* **មាសោ សេសោ គិម្ហានំ** *សេចក្តីថា ១ ខែ ខាងចុងនៃគិម្ហរដូវ ដែលមាន ៤ ខែនោះ ។*

*បទថា* **កត្វា** *សេចក្តីថា ឲ្យសម្រេចចុះដោយការដេរ ជ្រលក់ និងវិកប្បជាទីបំផុត ។ ភិក្ខុកាលធ្វើ គប្បីធ្វើមួយផ្ទាំងប៉ុណ្ណោះ ហើយអធិដ្ឋានក្នុងសម័យ អធិដ្ឋានពីរផ្ទាំង មិនគួរ ។*

*បទថា* **អតិរេកមាសេ សេសេ គិម្ហានេ** *បានដល់ កាលខែដែលមានឈ្មោះថា រដូវក្តៅនៅសល់លើស ១ ខែ ។*

*តែអ្នកសិក្សាតាំងនៅក្នុងពាក្យថា* **អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ កត្វា និវាសេតិ** *( ប្រើប្រាស់ក្នុងរដូវក្តៅដែលនៅសល់ជាងកន្លះខែ ) នេះ*

ហើយ គប្បីជ្រាបខេត្តនៃសំពត់ងូតទឹកភ្លៀង ៤ ខេត្ត គឺខេត្តនៃការស្វែងរក ១ ខេត្តនៃការធ្វើ ១ ខេត្តនៃការស្លៀកដណ្តប់ ១ ខេត្តនៃការអធិដ្ឋាន ១ និងសម័យ ២ គឺកុច្ឆិសម័យ ១ បិដ្ឋិសម័យ ១ និងចតុក្កៈ ២ គឺបិដ្ឋិសមយ-ចតុក្កៈ ១ កុច្ឆិសមយចតុក្កៈ ១ ។

បណ្តាខេត្ត សម័យ និងចតុក្កៈទាំងនោះ ១ខែកន្លះ តាំងពីថ្ងៃ ១ រោច ក្រោយអំពីថ្ងៃ ១៥ កើត ខែជេស្ឋទៅ រហូតដល់ថ្ងៃឧបោសថ ក្នុងកាឡបក្ខ នេះជាខេត្តនៃការស្វែងរក និងខេត្តនៃការធ្វើ ។ ពិតហើយ ក្នុងរវាងនេះ ភិក្ខុស្វែងរកសំពត់ងូតទឹកភ្លៀង ដែលមិនទាន់បាន នឹងធ្វើសំពត់ងូតទឹកភ្លៀង ដែលបានហើយ គួរ ដែលស្លៀកដណ្តប់ និងអធិដ្ឋាន មិនគួរ ។ ១ខែកន្លះ តាំងអំពីថ្ងៃ ១ រោច ក្រោយថ្ងៃឧបោសថក្នុងកាឡបក្ខទៅ រហូតដល់ថ្ងៃ ១៥ កើត ខែ អាសាឍ នេះជាខេត្តនៃការស្វែងរក ការធ្វើ និងការស្លៀកដណ្តប់ ទាំង ៣ ។ ពិតហើយ ក្នុងចន្លោះនេះ ទោះស្វែងរកសំពត់ងូតទឹកភ្លៀង ដែលមិនទាន់បានក្តី ធ្វើសំពត់ដែលបានហើយក្តី ស្លៀកដណ្តប់ក្តី គួរ ។ តែអធិដ្ឋានតែម្យ៉ាង មិនគួរ ។ តាំងពីថ្ងៃ ១ រោច ក្រោយអំពីថ្ងៃ ១៥ កើត ខែអាសាឍទៅ រហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក ៤ខែនេះ ជាខេត្តនៃការស្វែងរក ការធ្វើ ការស្លៀកដណ្តប់ និងអធិដ្ឋាន ទាំង ៤ ។ ពិតហើយ ក្នុងចន្លោះនេះ ទោះស្វែងរកសំពត់ងូតទឹកភ្លៀង ដែលមិនទាន់បានក្តី ធ្វើសំពត់ដែលបានហើយក្តី ប្រើប្រាស់ក្តី អធិដ្ឋានក្តី គួរ ។ គប្បីជ្រាបខេត្ត ៤ យ៉ាងនេះប៉ុណ្ណោះ ។

ម្យ៉ាងទៀត តាំងអំពីថ្ងៃ ១ រោច ក្រោយអំពីថ្ងៃ ១៥ កើត ខែកត្តិក ទៅ រហូតដល់ថ្ងៃ ១៥ កើត ដើមខែអាសាឍ ៧ ខែនេះ ឈ្មោះថា បិដ្ឋិ-សម័យ ( ខ្នងសម័យ ) ។ ពិតហើយ ក្នុងចន្លោះនេះ កាលភិក្ខុធ្វើការជាស់តឿនសតិ ដោយន័យជាដើមថា កាលនៃសំពត់ងូតទឹកភ្លៀង ហើយឲ្យចីវរគឺសំពត់ងូតទឹកភ្លៀងសម្រេចអំពីទីនៃបុគ្គលដែលមិនមែនជាញាតិ និងមិនមែនបវារណា ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះ កាលធ្វើវិញ្ញត្តិ ដោយន័យជាដើមថា អ្នកចូរឲ្យចីវរ គឺសំពត់ងូតទឹកភ្លៀងដល់អាត្មា ហើយឲ្យសម្រេច ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ កាលធ្វើការជាស់តឿនសតិ ដោយន័យដូចពោលហើយនេះឯងឲ្យសម្រេចអំពីទីនៃញាតិ និងបុគ្គលបវារណា ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះឯង កាលធ្វើវិញ្ញត្តិឲ្យសម្រេច មិនត្រូវអាបត្តិដោយអញ្ញា-តកវិញ្ញត្តិសិក្ខាបទ សមដូចព្រះតម្រាស់ដែលត្រាស់ទុកក្នុងគម្ពីរបរិវារថា

> ភិក្ខុសូមចីវរនឹងមាតា តែមិនមែនជាចីវរដែលមាតាបង្អោនទៅដើម្បីសង្ឃ ភិក្ខុនោះត្រូវអាបត្តិ ព្រោះហេតុអ្វី មួយទៀត ភិក្ខុមិនត្រូវអាបត្តិ ព្រោះសូមចីវរនឹងពួកញាតិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

ប្រស្នានេះ លោកពោលសំដៅដល់សេចក្តីនេះឯង គប្បីជ្រាបបិដ្ឋិ-សម័យ ក្នុងចតុក្កៈយ៉ាងនេះ ។

ម្យ៉ាងទៀត តាំងអំពីថ្ងៃ ១ រោច ក្រោយអំពីថ្ងៃ ១៥ កើតនៃខែជេស្ឋ

ទៅរហូតដល់ថ្ងៃ ១៥ កើតខែកត្តិក ៥ ខែនេះ ឈ្មោះថា កុច្ចិសម័យ ( ពោះសម័យ ) ។ ពិតហើយ ក្នុងចន្លោះនេះ កាលភិក្ខុធ្វើការដាស់តឿនសតិដោយន័យដូចពោលហើយនោះឯង ឲ្យចីវរ គឺសំពត់ងូតទឹកភ្លៀងសម្រេចអំពីទីនៃបុគ្គលដែលមិនមែនញាតិ និងមិនបានបវារណា ត្រូវអាបត្តិទុក្កដ ព្រោះខូចទំនៀម ។ តែពួកអ្នកស្រុកដែលធ្លាប់ប្រគេនចីវរ គឺសំពត់ងូតទឹកភ្លៀង ក្នុងកាលមុន ទោះបីបុគ្គលមិនមែនញាតិ និងមិនមែនបុគ្គលបវារណារបស់ខ្លួន ក៏មិនមានការខូចទំនៀម ព្រោះធ្វើការដាស់តឿនសតិក្នុងជនទាំងនោះ ទ្រង់អនុញ្ញាតទុក ។ កាលភិក្ខុធ្វើវិញ្ញត្តិឲ្យសម្រេច ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ព្រោះហេតុអ្វី ព្រោះខុសនឹងព្រះតម្រាស់ថា ភិក្ខុចូលទៅរកពួកអ្នកស្រុក ដែលធ្លាប់ប្រគេនចីវរ គឺសំពត់ងូតទឹកភ្លៀងពីមុន ហើយគប្បីពោលយ៉ាងនេះ ដូច្នេះជាដើម ។

ឯចីវរ គឺសំពត់ងូតទឹកភ្លៀងនេះ តាមប្រក្រតី រមែងមានក្នុងពួកទាយកដែលប្រគេនសំពត់ងូតទឹកភ្លៀងនោះឯង ។ កាលភិក្ខុដាស់តឿនឲ្យកើតសតិដោយន័យដូចពោលហើយនោះឯង ហើយឲ្យសម្រេចអំពីទីនៃបុគ្គលដែលជាញាតិ និងអ្នកបវារណា មិនត្រូវអាបត្តិដោយសិក្ខាបទនេះ កាលធ្វើវិញ្ញត្តិឲ្យសម្រេច មិនត្រូវអាបត្តិ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ ពិតហើយ ពាក្យថា មិនគប្បីប្រាប់ទាយកថា ចូរឲ្យដល់អាត្មានេះ ត្រាស់សំដៅដល់បុគ្គលដែលមិនមែនញាតិ និងមិនមែនបវារណានោះឯង ។ គប្បីជ្រាបកុច្ចិសមយ-ចតុក្កៈយ៉ាងនេះ ។

# អធិប្បាយ
## បទភាជនីយនៃវស្សិកសាដិកសិក្ខាបទ

[ ១៤៧ ] ក្នុងបទថា **គណ្ហា កាយំ ឱវស្សាបេតិ អាបត្តិ ទុក្កដស្ស** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ភិក្ខុអាក្រាតកាយងូតទឹកភ្លៀងនោះ ព្រះ-វិនយធរកុំកាត់អាបត្តិតាមចំនួនគ្រាប់ភ្លៀង គប្បីកាត់អាបត្តិទុក្កដគ្រប់ៗ ប្រយោគ ដោយអំណាចសម្រេចការងូតទឹក ។ ឯភិក្ខុនោះ ងូតទឹកដែលស្រក់ ចុះមកអំពីអាកាស ក្នុងទីលានកណ្ដាលវាលប៉ុណ្ណោះ ( ទើបត្រូវអាបត្តិទុក្កដ ) ។ កាលងូតនៅក្នុងបន្ទប់ទឹក និងក្នុងបឹងជាដើម ឬដោយទឹកដែលប្រើថ្នាំងជងងូត មិនត្រូវអាបត្តិឡើយ ។

[ ១៤៨ ] ក្នុងបទថា **វស្សំ ឧក្កឌ្ឍិយតិ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា កាលបើសំពត់ងូតទឹកភ្លៀងសម្រេចហើយ ពួកភិក្ខុឲ្យខែខាងចុងរដូវអស់ទៅហើយ ចូងខែខាងដើមនៃរដូវភ្លៀងនោះឯង ចូងមកជាចុងរដូវក្ដៅទៀត គប្បីបោកសំពត់ងូតទឹកភ្លៀងរក្សាទុក មិនត្រូវអធិដ្ឋាន មិនត្រូវវិកប្បបានបរិហាររហូត ២ ខែ គប្បីអធិដ្ឋានក្នុងថ្ងៃវស្សូបនាយិកា ( ថ្ងៃចូលវស្សា )។ បើសំពត់ងូតទឹកភ្លៀង ភិក្ខុមិនបានធ្វើ ព្រោះភ្លេច ឬព្រោះសំពត់មិនគ្រប់គ្រាន់ក្ដី រមែងបានបរិហារអស់កាល ៦ ខែ គឺ ២ ខែនោះផង ៤ ខែក្នុងរដូវភ្លៀងផង តែបើភិក្ខុក្រាលកឋិនក្នុងខែកត្តិក រមែងបានបរិហារ ៤ ខែទៀត រួមជា ១០ ខែ ដោយប្រការយ៉ាងនេះ ។ បន្ទាប់អំពី ១០ ខែនោះទៅ ទោះមានការសង្ឃឹម ( ថានឹងបានសំពត់ងូតទឹកភ្លៀង ) របស់ភិក្ខុដែលធ្វើឲ្យជាចីវរដើមរក្សាទុក បានបរិហារ ១ ខែទៀត ដូច្នោះ ទើបបានបរិហាររហូត ១១ ខែ

ដោយប្រការយ៉ាងនេះ ។

សួរថា បើសំពត់ងូតទឹកភ្លៀងដែលបានហើយ និងសម្រេចហើយ ក្នុងកាលថ្ងៃចូលវស្សាមិនទាន់មកដល់ ដោយអំណាចនៃ ១ ថ្ងៃ និង ២ ថ្ងៃជា-ដើម រហូតដល់ ១០ ថ្ងៃក្តី ខាងក្នុងវស្សាក្តី គប្បីអធិដ្ឋានក្នុងកាលណា ឆ្លើយថា ពាក្យនេះ លោកមិនបានបរិយាយទុកក្នុងអដ្ឋកថាទាំងឡាយ ពួកយើងមានអត្តនោមតិយ៉ាងនេះថា បើសំពត់ងូតទឹកភ្លៀងដែលសម្រេចហើយ ខាងក្នុង ១០ ថ្ងៃ តាំងអំពីថ្ងៃដែលបានមក គប្បីអធិដ្ឋានខាងក្នុង ១០ ថ្ងៃនោះឯង ។ ដែលសម្រេចក្នុងកាលកន្លង ១០ ថ្ងៃទៅ គប្បីអធិដ្ឋានក្នុងថ្ងៃនោះ បើមិនទាន់គ្រប់ ១០ ថ្ងៃ មិនគប្បីឲ្យកន្លងចីវរកាលទៅឡើយ ព្រោះហេតុអ្វី ព្រោះព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអធិដ្ឋានត្រៃចីវរ មិនមែនឲ្យវិកប្ប ឲ្យអធិដ្ឋានសំពត់ងូតទឹកភ្លៀងរហូត ៤ ខែ ក្នុងរដូវភ្លៀង បន្ទាប់អំពីនោះទៅ គប្បីវិកប្ប ។ ព្រោះដូច្នោះ ទើបមិនត្រូវអាបត្តិ សូម្បីព្រោះកន្លង ១០ថ្ងៃទៅ មុនអំពីថ្ងៃចូលវស្សា ។ សមដូចព្រះតម្រាស់ថា ភិក្ខុគប្បីទុកអតិរេកចីវរបាន ១០ ថ្ងៃយ៉ាងក្រៃលែង ព្រោះដូច្នោះ សំពត់ងូតទឹកភ្លៀងដែលបានមក និងសម្រេចហើយក្នុងកាលថ្ងៃចូលវស្សាមិនទាន់មកដល់ ដោយអំណាចនៃ ១ ថ្ងៃ និង ២ ថ្ងៃជាដើម រហូតដល់ ១០ ថ្ងៃ ឬខាងក្នុងវស្សា គប្បីអធិដ្ឋានខាងក្នុង ១០ ថ្ងៃ ឬក្នុងថ្ងៃនោះ ដោយន័យដូចពោលហើយនោះឯង បើមិនទាន់គ្រប់ ១០ ថ្ងៃ ក៏មិនគប្បីឲ្យកន្លងចីវរ-កាលឡើយ ។

ក្នុងអធិការនៃសំពត់ងូតទឹកភ្លៀងនោះ គប្បីមានប្រស្នាថា ព្រោះព្រះបាលីថា តថាគតអនុញ្ញាតឲ្យអធិដ្ឋានរហូត ៤ ខែ ក្នុងរដូវភ្លៀង ខាងក្នុង ៤ ខែ នឹងអធិដ្ឋានក្នុងពេលណាមួយ ក៏គួរប្រើបាន កាលបើមានពាក្យយ៉ាងនេះ ពាក្យដែលត្រាស់ទុកថា តថាគតអនុញ្ញាតឲ្យអធិដ្ឋានសំពត់រំប្ងូសបានអស់កាលដែលនៅមានអាពាធ ហើយសូម្បីសំពត់រំប្ងូសនោះ ក៏មិនគួរឲ្យកន្លង ១០ ថ្ងៃ បើមានការកន្លង ១០ ថ្ងៃទៅយ៉ាងនោះ ពាក្យថា គប្បីទុកអតិរេកចីវរបាន ១០ ថ្ងៃយ៉ាងយូរនេះ ក៏នឹងខុសទៅ ព្រោះដូច្នោះ ទើបបណ្ឌិតគួរកាន់យកពាក្យ តាមដែលពោលហើយនោះចុះ , ឬថា បានហេតុដែលមិនសមទំនងដទៃហើយ ក៏គួរលះបង់ចេញ ។

ម្យ៉ាងទៀត សូម្បីក្នុងកុរុន្ទីក៏ពោលទុកក្នុងទីបំផុតនៃនិស្សគ្គិយថា សំពត់ងូតទឹកភ្លៀង គួរអធិដ្ឋានក្នុងកាលណា ឯសំពត់ងូតទឹកភ្លៀងដែលសម្រេចហើយខាងក្នុង ១០ ថ្ងៃ តាំងអំពីថ្ងៃដែលបានមក គួរអធិដ្ឋានខាងក្នុង ១០ ថ្ងៃនោះឯង បើសំពត់មិនគ្រប់គ្រាន់ រមែងបានបរិហារទៅរហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក ។

បទថា **អច្ឆិន្នចីវរស្ស** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកចំពោះសំពត់ងូតទឹកភ្លៀងប៉ុណ្ណោះ ពិតហើយ អាបត្តិមិនមានដល់ភិក្ខុនោះ ដែលអាក្រាតកាយ ព្រោះញ៉ាំងទឹកភ្លៀងឲ្យស្រោចរាងកាយ ។

ក្នុងបទថា **អាបទាសុ** នេះ ឧបទ្រវ គឺចោរ ឈ្មោះថា អន្តរាយនៃភិក្ខុដែលស្លៀកសំពត់ងូតទឹកភ្លៀងមានតម្លៃថ្លៃ ហើយងូត ពាក្យដ៏សេស ក្នុងសិក្ខាបទនេះមានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វស្សិកសាដិកសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ១៤៩ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់ក្នុងវត្ត ជេតពន ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះ នឹងភិក្ខុដែលជាសទ្ធិវិហារិក របស់ព្រះថេរៈជាបងថា នែអាវុសោ អ្នកចូរមក យើងនឹងចៀសចេញទៅកាន់ ចារិកក្នុងជនបទ ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណា ទៅ មិនបានទេ ( ដ្បិត ) ខ្ញុំករុណាមានចីវរចាស់គ្រាំគ្រាហើយ ។ ឧបនន្ទភិក្ខុនិយាយថា មកចុះអាវុសោ ខ្ញុំនឹងឲ្យចីវរលោក ហើយបានឲ្យចីវរទៅភិក្ខុនោះ ។ ភិក្ខុនោះ បានឮថា ព្រះដ៏មានព្រះភាគម្ចាស់នឹងទ្រង់ពុទ្ធដំណើរទៅកាន់ ចារិកក្នុងជនបទ ។ ទើបភិក្ខុនោះត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញមិនចៀស ទៅកាន់ចារិកក្នុង ជនបទជាមួយនឹងឧបនន្ទសក្យបុត្រដ៏មានអាយុទេ អញមុខជានឹងទៅកាន់ចារិក ក្នុងជនបទជាមួយនឹងព្រះដ៏មានព្រះភាគវិញ ។ លំដាប់នោះ ឧបនន្ទសក្យបុត្រ ដ៏មានអាយុ និយាយពាក្យនេះនឹងភិក្ខុនោះថា ឥឡូវនេះ អាវុសោ លោកចូរមក យើងនឹងនាំគ្នាទៅក្នុងជនបទ ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចម្រើន ខ្ញុំ ករុណាមិនទៅកាន់ចារិកក្នុងជនបទជាមួយនឹងលោកទេ ខ្ញុំករុណាមុខជានឹងទៅ កាន់ចារិកក្នុងជនបទ ជាមួយនឹងព្រះដ៏មានព្រះភាគវិញ ។ ឧបនន្ទខឹងអន់ចិត្ត ហើយពោលថា អាវុសោ ខ្ញុំបានឲ្យចីវរណាដល់លោក ( ព្រោះ ) លោកថា នឹងទៅកាន់ចារិកជាមួយនឹងខ្ញុំ ( ថាដូច្នោះហើយ ) ក៏ដណ្តើមយកចីវរមកវិញ ។

គ្រានោះ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាមាន សេចក្តីប្រាថ្នាតិច ។បេ។ ទើបភិក្ខុទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា មិនទំនងសោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ឲ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ជាខឹងអាក់អន់ចិត្ត ដណ្តើមយកមកវិញ ។ លំដាប់នោះ ភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះ ក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់ ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានឲ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកពីគេមកវិញមែនឬ ។ ឧបនន្ទសក្យបុត្រ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះសម្ពុទ្ធ ដ៏ទ្រង់យសជាម្ចាស់ទ្រង់តិះដៀលថា ម្នាលមោឃបុរស មិនសមបីបើអ្នកឯង បានឲ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកចីវរ ពីគេមកវិញសោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យ ជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំឲ្យជនទាំងឡាយ ដែល ជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឲ្យចីវរ ដល់ភិក្ខុ ( ដទៃ ) ដោយខ្លួនឯងហើយ ខឹងអន់ចិត្ត ដណ្តើមយក ( ចីវរ ) មក វិញក្តី ប្រើឲ្យគេដណ្តើមយកមកវិញក្តី ភិក្ខុនោះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៥០ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខា បទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដល់ភិក្ខុ គឺដល់ភិក្ខុដទៃ ។ ពាក្យថា ខ្លួនឯង គឺបានឲ្យទៅខ្លួនឯង ។ ដែលហៅថា ចីវរនោះ បានដល់ ចីវរ

៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន ។ ពាក្យថា ខឹងអន់ចិត្ត គឺមិនត្រេកអរ មានចិត្តក្តួលក្តៅ រឹងរូស ។ ពាក្យថា ដណ្តើមយកមកវិញ គឺដណ្តើមយកមកដោយខ្លួនឯងវិញ ចីវរនោះជានិស្សគ្គិយ ។ ពាក្យថា ប្រើគេឲ្យដណ្តើមយកមកវិញ គឺភិក្ខុបង្គាប់អ្នកដទៃ ( ឲ្យដណ្តើមយកមកវិញ ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ទៅតែម្តងទេ អ្នកទទួលបង្គាប់ទៅដណ្តើមយកច្រើនដង ចីវរទាំងនោះជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានឲ្យទៅភិក្ខុ ( ដទៃ ) ដោយខ្លួនឯងហើយ ខ្ញុំត្រឡប់ដណ្តើមយកមកវិញ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ ក្នុងចីវរវគ្គ ។

[ ១៥១ ] ភិក្ខុសម្គាល់បុគ្គលដែលជាឧបសម្បន្ន[១] ថាឧបសម្បន្ន ពិតមែន ហើយឲ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកវិញក្តី ប្រើឲ្យអ្នកដទៃ ដណ្តើមយកមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងបុគ្គលដែលជាឧបសម្បន្ន ហើយឲ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ជាក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឲ្យអ្នកដទៃ ដណ្តើមមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់ បុគ្គលដែលជាឧបសម្បន្ន ថាអនុបសម្បន្ន[២] ទៅវិញក៏ត្រឡប់ក្រោធខឹង អន់ចិត្ត

---

១- អ្នកដែលបាន ឧបសម្បទា ជាភិក្ខុភាវៈដោយត្រឹមត្រូវហើយ ហៅថា ឧបសម្បន្ន ។

២- បានដល់ បុគ្គលក្រៅពីភិក្ខុ មានសាមណេរជាដើម ។

ហើយឲ្យចីវរទៅដោយខ្លួនឯង ដណ្ដើមយកមកខ្លួនឯងវិញក្ដី ប្រើឲ្យអ្នកដទៃដណ្ដើមយកមកវិញក្ដី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុឲ្យបរិក្ខារដទៃ ហើយត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្ដើមយកមកខ្លួនឯងវិញក្ដី ប្រើឲ្យអ្នកដទៃដណ្ដើមយកមកវិញក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឲ្យចីវរក្ដី បរិក្ខារដទៃក្ដី ទៅអនុបសម្បន្ន ហើយក្រោធខឹងអន់ចិត្ត ដណ្ដើមយកមកខ្លួនឯងវិញក្ដី ប្រើឲ្យអ្នកដទៃដណ្ដើមយកមកវិញក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់អនុបសម្បន្នជាឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងបុគ្គលដែលជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់អនុបសម្បន្នថា អនុបសម្បន្នពិតមែន ត្រូវអាបត្តិទុក្កដ ។

[ ១៥២ ] អាបត្តិមិនមានដល់ភិក្ខុ ដែលភិក្ខុអ្នកទទួលចីវរនោះគេឲ្យត្រឡប់មកវិញ ឬភិក្ខុ ដែលមានសេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកទទួលចីវរនោះហើយ កាន់យកមកវិញ ដល់ភិក្ខុដែលឆ្កួតចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា

# បត្តវគ្គ សិក្ខាបទទី ៥

# ចីវរអច្ឆិន្ទនសិក្ខាបទ

[ ១៤៩ ] *ចីវរអច្ឆិន្ទនសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងចីវរអច្ឆិន្ទនសិក្ខាបទ ដូចវិនិច្ឆ័យតទៅនេះថា ច្រើនបទថា* **យំបិ ត្យាហំ** *កាត់បទជា* **យំបិ តេ អហំ** *ប្រែថា ខ្ញុំបានឲ្យចីវរណាដល់លោក បានឮថា ព្រះឧបនន្ទនោះគិតថា ភិក្ខុនេះ នឹងនាំបាត្រ ចីវរ ស្បែកជើង និងសំពត់ក្រាលដេករបស់អញទៅកាន់ទីចារិកជាមួយអញ ទើបបានឲ្យហើយ ព្រោះហេតុនោះឯង ទើបលោកពោលយ៉ាងនេះ ។*

# អធិប្បាយ

# សិក្ខាបទវិភង្គនៃចីវរអច្ឆិន្ទនសិក្ខាបទ

[ ១៥០ ] *បទថា* **អច្ឆិន្ទិ** *ប្រែថា បានកាន់យកហើយ ដោយកម្លាំង ។ តែព្រោះកាន់យកដោយសម្គាល់របស់ខ្លួន ទើបមិនត្រូវបារាជិកដល់លោក ។ ព្រោះលោកធ្វើឲ្យលំបាក ហើយកាន់យកចីវរ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តអាបត្តិ ។*

*បទថា* **សយំ អច្ឆិន្ទតិ និស្សគ្គិយំ ចាចិត្តិយំ** *សេចក្តីថា សម្រាប់ភិក្ខុដែលដណ្តើមយកចីវរមួយផ្ទាំង និងច្រើនផ្ទាំង ដែលទាក់ទងជាមួយគ្នា ត្រូវអាបត្តិតែមួយ ។ បើភិក្ខុដណ្តើមយកចីវរច្រើនផ្ទាំង ដែលមិនទាក់ទងជាមួយគ្នា និងតាំងនៅបែកគ្នា កាលប្រើឲ្យអ្នកដទៃយកមកឲ្យ ដោយប្រាប់យ៉ាង*

នេះថា លោកចូរយកសង្ឃាដីមក ចូរយកឧត្តរាសង្គមក ត្រូវអាបត្តិច្រើន តាមចំនួនវត្ថុ ។ កាលពោលថា លោកចូរនាំចីវរទាំងអស់ដែលខ្ញុំឲ្យហើយ មកវិញ ក៏ត្រូវអាបត្តិជាច្រើន ព្រោះពាក្យពោលតែមួយនោះ ។

បទថា **អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស** សេចក្ដីថា ប្រើថា លោកចូរកាន់យកចីវរ ត្រូវអាបត្តិទុក្កដ ១ ។ ភិក្ខុអ្នកប្រើកាន់យកចីវរច្រើន ក៏ត្រូវអាបត្តិបាចិត្តិយ ១ បើភិក្ខុពោលថា លោកចូរយកសង្ឃាដីមក ចូរយក ឧត្តរាសង្គមក ត្រូវអាបត្តិទុក្កដគ្រប់ៗ ម៉ាត់ ។ បើពោលថា លោកចូរយកចីវរ ដែលខ្ញុំឲ្យទាំងអស់មកវិញ ត្រូវអាបត្តិជាច្រើន ព្រោះពាក្យពោលតែមួយ ។

# អធិប្បាយ

## បទភាជនីយនៃចីវរអច្ឆិន្ទនសិក្ខាបទ

[ ១៥១ ] ពីរបទថា **អញ្ញំ បរិក្ខារំ** សេចក្ដីថា បរិក្ខារឯណាមួយ វៀរ ចីវរយ៉ាងតូចដែលគួរវិកប្បបាន ដោយហោចសូម្បីតែម្ជុល ។ សូម្បីក្នុងម្ជុល ទាំងឡាយដែលខ្ចប់រក្សាទុក ក៏ត្រូវអាបត្តិទុក្កដជាច្រើនតាមចំនួនវត្ថុ ក្នុងម្ជុល ដែលខ្ចប់ទុកជួរៗ ( ក៏ត្រូវអាបត្តិទុក្កដជាច្រើនតាមចំនួនវត្ថុ ) យ៉ាងនោះដូច គ្នា ។ ក្នុងមហាបច្ចរីពោលថា ក្នុងម្ជុលទាំងឡាយដែលគេចងទុកណែន ត្រូវ អាបត្តិទុក្កដ ១ ប៉ុណ្ណោះ សូម្បីក្នុងម្ជុលដែលគេទុកក្នុងបំពង់ម្ជុល ក៏មានន័យ យ៉ាងនេះដូចគ្នា ។ សូម្បីក្នុងកេសជ្ជៈ មានគ្រឿងក្តៅ ៣ ប្រភេទដែលគេទុក ក្នុងថង់យាម ចងទុកជួរ និងចងយ៉ាងណែន ក៏មានន័យយ៉ាងនេះដូចគ្នា ។

[ ១៥២ ] ពីរបទថា **សោ វា ទេតិ** សេចក្ដីថា ឲ្យវិញយ៉ាងនេះថា

បពិត្រលោកម្ចាស់ ចីវរនេះសមគួរដល់លោកម្ចាស់ប៉ុណ្ណោះ ដូច្នេះក្តី ។ ម្យ៉ាងទៀត ភិក្ខុកំលោះនោះ ត្រូវព្រះថេរៈនោះពោលពាក្យជាដើមយ៉ាងនេះថា អាវុសោ ខ្ញុំបានឲ្យចីវរដល់លោក ដោយសង្ឃឹមថា នឹងធ្វើវត្ត និងបដិវត្ត នឹងកាន់ឧបជ្ឈាយ៍ នឹងរៀនទូវធម៌ក្នុងសម្នាក់របស់ខ្ញុំ តែឥឡូវនេះ លោកមិនធ្វើវត្ត មិនកាន់ឧបជ្ឈាយ៍ មិនរៀនធម៌ ដូច្នេះ ទើបសងវិញថា បពិត្រលោកម្ចាស់ លោកម្ចាស់និយាយហាក់ដូចជាត្រូវការចីវរ នេះចីវររបស់លោកម្ចាស់ ។ ភិក្ខុដែលទទួលទៅនោះ ឲ្យវិញដោយអាការយ៉ាងនេះក្តី ឬថា ព្រះថេរៈពោលដល់ភិក្ខុកំលោះដែលចៀសទៅកាន់ទិសថា ពួកលោកចូរឲ្យភិក្ខុនោះត្រឡប់ ភិក្ខុនោះមិនត្រឡប់ ព្រះថេរៈប្រាប់ថា ពួកលោកចូរដណ្តើមចីវរទុក បើដូច្នេះ លោកត្រឡប់ជាការល្អ ។ បើលោកពោលថា ពួកលោកមើលទៅនិយាយ ដើម្បីត្រូវការបាត្រ និងចីវរ ពួកលោកចូរទទួលយកវាទៅចុះ ហើយឲ្យមកវិញ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា ភិក្ខុដែលទទួលទៅនោះ ឲ្យវិញឯងក្តី ។

ម្យ៉ាងទៀត ព្រះថេរៈឃើញលោកសឹក ហើយពោលថា ខ្ញុំបានឲ្យបាត្រ និងចីវរដល់លោក ដោយសង្ឃឹមថា នឹងធ្វើវត្ត ឥឡូវនេះ លោកក៏សឹកទៅហើយ ។ ចំណែកភិក្ខុកំលោះដែលសឹកទៅ និយាយថា សូមលោកទទួលយកបាត្រ និងចីវររបស់លោកទៅវិញចុះ ហើយក៏ឲ្យមកវិញ ។ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា ភិក្ខុដែលទទួលទៅនោះ ឲ្យមកវិញឯងក្តី ។ តែនឹងឲ្យដោយពោលយ៉ាងនេះថា ខ្ញុំឲ្យដល់លោកដែលកាន់ឧបជ្ឈាយ៍ ក្នុងសម្នាក់របស់ខ្ញុំប៉ុណ្ណោះ ខ្ញុំមិនឲ្យដល់បុគ្គលដែលកាន់ឧបជ្ឈាយ៍ក្នុងទីដទៃ ខ្ញុំឲ្យចំពោះ

ដល់បុគ្គលដែលធ្វើវត្ត មិនឲ្យដល់បុគ្គលដែលមិនធ្វើវត្ត ខ្ញុំឲ្យដល់បុគ្គលរៀនធម៌ប៉ុណ្ណោះ មិនឲ្យដល់បុគ្គល មិនរៀនធម៌ឡើយ ខ្ញុំឲ្យដល់បុគ្គលមិនសឹកប៉ុណ្ណោះ មិនឲ្យដល់បុគ្គលសឹកឡើយ ដូច្នេះ មិនគួរ ។ ត្រូវអាបត្តិទុក្កដដល់អ្នកឲ្យ ។ តែនឹងប្រើឲ្យនាំមកឲ្យវិញ គួរ ។ កិក្ខុដែលដណ្តើមយកចីវរដែលខ្លួនលះបង់ឲ្យហើយ ទារយកមកវិញ ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ រាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ រមែងកើតតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយ វាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះ ។

ចីវរអច្ឆិន្ទនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[ ១៥៣ ] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ បាន សូមអំបោះមកជាច្រើន ក្នុងសម័យធ្វើចីវរកម្ម ។ លុះធ្វើចីវរសម្រេចហើយ មានអំបោះសេសសល់ជាច្រើន ។ ទើបពួកឆព្វគ្គិយភិក្ខុបានជំនុំគ្នា ដូច្នេះថា ម្នាលអាវុសោ បើដូច្នេះ មានតែពួកយើងនឹងសូមអំបោះដទៃមកថែមទៀត ហើយឲ្យពួកជាងតម្បាញត្បាញចីវរ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុទៅសូម អំបោះឯទៀតមក ហើយក៏ឲ្យជាងតម្បាញត្បាញចីវរ ។ កាលត្បាញចីវររួច ហើយ អំបោះនៅសេសសល់ជាច្រើន ពួកឆព្វគ្គិយភិក្ខុក៏ទៅសូមអំបោះដទៃៗ មកថែមទៀត ហើយឲ្យពួកជាងតម្បាញត្បាញចីវរជាគម្រប់ពីរដង ។ កាល គេត្បាញរួចហើយ អំបោះនៅសល់ជាច្រើន ។ ពួកឆព្វគ្គិយភិក្ខុទៅសូមអំបោះ ដទៃៗ មកថែមទៀត ហើយឲ្យពួកជាងតម្បាញ ត្បាញចីវរជាគម្រប់បីដង ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅ ព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងទៅសូមអំបោះមកដោយខ្លួនឯង ហើយឲ្យ ពួកជាងតម្បាញត្បាញចីវរឲ្យសោះ ភិក្ខុទាំងឡាយ បានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ ថា ឆព្វគ្គិយភិក្ខុមិនសមបើនឹងទៅសូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួក

ជាងតម្បាញត្បាញចីវរឲ្យ (ដូច្នេះ) សោះ ។ ទើបភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកឯង ទៅសូមអំបោះមកនឹងខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យ ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស ពួកអ្នកឯង មិនសមបើហ៊ានទៅសូមអំបោះមកនឹងខ្លួនឯង ហើយឲ្យពួកជាងតម្បាញ ត្បាញចីវរឲ្យ ( ដូច្នេះ ) សោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើមកនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា និងមិននាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ សូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញ ចីវរឲ្យ ភិក្ខុនោះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៥៤ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌឯនោះ ។ ពាក្យថា ដោយខ្លួនឯង គឺ សូមមកខ្លួនឯង ។ ដែលហៅថា អំបោះ បានដល់ អំបោះ ៦ យ៉ាង គឺ អំបោះដែលកើតពីសម្បកឈើ ១ អំបោះដែលកើតពីកប្បាស ១ សូត្រ ១ អំបោះដែលកើតពីរោមសត្វ ១ អំបោះដែលកើតពីធ្មៃ ១ អំបោះកើតពីកន្ទៈ (គឺយករបស់ខាងដើមទាំង ៥ មកធ្វើជាអំបោះ ) ១ ។ ពាក្យថា ឲ្យពួកជាងតម្បាញ ត្បាញ គឺ ប្រើពួកជាងតម្បាញឲ្យត្បាញ ត្រូវអាបត្តិទុក្កដតាមប្រយោគ ។ ចីវរនោះ ជានិស្សគ្គិយ

ក្នុងខណៈដែលបានមក ភិក្ខុគប្បីលះដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានសូមអំពោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញ ចីវរនេះជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតពីនេះទៅ មានសេចក្ដីដូចគ្នានឹងសិក្ខាបទ ទី ១ នៃចីវរវគ្គ ។

[ ១៥៥ ] ភិក្ខុសម្គាល់ចីវរដែលឲ្យគេត្បាញរួចហើយថា ឲ្យគេត្បាញរួចហើយពិតមែន ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងចីវរដែលឲ្យគេត្បាញរួចហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់ចីវរដែលឲ្យគេត្បាញរួចហើយថា មិនមែនចីវរដែលឲ្យគេត្បាញទេ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់ចីវរ ដែលមិនមែនឲ្យគេត្បាញថា ចីវរដែលឲ្យគេត្បាញហើយ ត្រូវអាបត្តិទុក្កដ ។ មិនមែនចីវរដែលឲ្យគេត្បាញទេ តែភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ចីវរដែលមិនមែនឲ្យគេត្បាញថា មិនមែនចីវរដែលឲ្យគេត្បាញពិតមែន មិនត្រូវអាបត្តិឡើយ ។

[ ១៥៦ ] អាបត្តិមិនមានដល់ភិក្ខុ ដែលសូមអំពោះមកដើម្បីដេរចីវរ ដើម្បីធ្វើសំពត់អាយោគ ដើម្បីធ្វើវត្ថពន្ធចង្កេះ ដើម្បីធ្វើយោគបាត្រ ដើម្បីធ្វើស្បោកបាត្រ ដើម្បីធ្វើសំពត់ត្រងទឹក ដល់ភិក្ខុដែលសូមអំពោះអំពីពួកញាតិ ដល់ភិក្ខុដែលសូមអំពោះពីពួកជន ដែលបានបវារណាទុក ដល់ភិក្ខុដែលសូមអំពោះដើម្បីជាប្រយោជន៍ដល់ភិក្ខុដទៃ ដល់ភិក្ខុដែលបានមកដោយទ្រព្យរបស់

ខ្ជួន ដល់ភិក្ខុដែលខូចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ៦ ចប់

## អដ្ឋកថា

## បត្តវគ្គ សិក្ខាបទទី ៦

## សុត្តវិញ្ញត្តិសិក្ខាបទ

[ ១៥៣ ] *សុត្តវិញ្ញត្តិសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងសុត្តវិញ្ញត្តិសិក្ខាបទ មានវិនិច្ឆ័យដូចតទៅនេះ*

## អធិប្បាយ

## សិក្ខាបទវិភង្គនៃសុត្តវិញ្ញត្តិសិក្ខាបទ

[ ១៥៤ ] *បទថា* **ខោមំ** *បានដល់ អំបោះដែលធ្វើដោយសម្បកឈើ ឈ្មោះខោមៈ ។*

*បទថា* **កប្បាសិកំ** *បានដល់ អំបោះដែលកើតអំពីកប្បាស ។*

*បទថា* **កោសេយ្យំ** *បានដល់ អំបោះដែលត្បាញដោយសរសៃសូត្រ ។*

*បទថា* **កម្ពលំ** *បានដល់ អំបោះធ្វើដោយរោមចៀម ។*

*បទថា* **សាណំ** *បានដល់ អំបោះដែលធ្វើដោយសម្បកសាណៈ (ធ្មៃ) ។*

*បទថា* **ភង្គំ** *អាចារ្យមួយពួកពោលថា បានដល់ អំបោះដែលធ្វើដោយព្រាលមួយប្រភេទដោយឡែក ។ តែអំបោះដែលធ្វើផ្សំគ្នាដោយសម្ភារៈទាំង ៥ យ៉ាងនោះ អ្នកសិក្សាគប្បីជ្រាបថា* **ភង្គំ** ។

*ប្រើនបទថា* **វាយាបេតិ បយោគេ ទុក្កដំ** *សេចក្ដីថា បើជាងតម្បាញមិនមានកី និងត្រល់ជាដើម ជាងគិតថា អញនឹងនាំរបស់ទាំងនោះមកអំពីព្រៃទើបសំលៀងកាំបិត ឬពូថៅ តាំងអំពីនោះទៅ ជាងនោះធ្វើប្រយោគណាមួយ*

ដើម្បីគ្រឿងឧបករណ៍ក្តី ដើម្បីនឹងត្បាញចីវរក្តី ត្រូវអាបត្តិទុក្កដដល់ភិក្ខុគ្រប់ៗ ប្រយោគនោះ របស់ជាងតម្បាញក្នុងកិច្ចទាំងពួង ។ កាលជាងតម្បាញត្បាញសំពត់បានប្រវែងបណ្តោយប្រមាណ ១ ចំអាម និងទទឹងប្រមាណ ១ ហត្ថ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ តែក្នុងមហាបច្ចរីពោលថា ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយគ្រប់ៗ ឈើបន្ទឹង ដល់ភិក្ខុដែលឲ្យជាងត្បាញរហូតដល់ទីបំផុត ( រហូតរួចស្រេច ) ។ សូម្បីពាក្យនោះ ក៏គប្បីជ្រាបថា លោកពោលសំដៅយកប្រមាណនេះឯង ។ ពិតហើយ ប្រមាណសំពត់យ៉ាងតូចគួរវិកប្បបាន ទើបដល់នូវការរាប់ថា ជាចីវរ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វាយាបេតិ បយោគេ ទុក្កដំ** នេះ យ៉ាងនេះថា នឹងពោលដល់អំបោះមុន ភិក្ខុសូមឯង ជាអកប្បិយ អំបោះដ៏សេស ដែលកើតឡើងដោយអំណាចនៃញាតិជាដើម ជាកប្បិយ ។ សូម្បីជាងតម្បាញក៏មិនមែនញាតិ និងមិនមែនជនបវារណា ភិក្ខុបានមកដោយការសូម ជាអកប្បិយ ។ ជាងតម្បាញដ៏សេស ជាកប្បិយ ។ បណ្តាអំបោះនិងជាងតម្បាញទាំងនោះ អំបោះដែលជាអកប្បិយ ជានិស្សគ្គិយដល់ភិក្ខុដែលឲ្យជាងតម្បាញ ជាអកប្បិយត្បាញ ដោយន័យដូចពោលហើយអំពីមុន ។

ម្យ៉ាងទៀត កាលភិក្ខុឲ្យជាងតម្បាញ ដែលជាអកប្បិយនោះឯងត្បាញអំបោះដែលជាកប្បិយ ត្រូវអាបត្តិទុក្កដ ដូចជានិស្សគ្គិយខាងដើមនោះឯង ។ កាលភិក្ខុឲ្យជាងតម្បាញអកប្បិយនោះឯង ត្បាញអំបោះជាកប្បិយ និងអកប្បិយ បើចីវរដូចជាខ្នង់ស្រែ ជាប់គ្នាប៉ុនប្រមាណនៃចីវរខ្នាតតូចយ៉ាងនេះ គឺផ្នែកទី ១

សម្រេចដោយអំបោះកប្បិយសុទ្ធៗ ផ្នែកទី ២ សម្រេចដោយអំបោះអកប្បិយ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ផ្នែក ដែលសម្រេចដោយអកប្បិយ ។ ត្រូវអាបត្តិទុក្កដក្នុង ( ផ្នែកដែលសម្រេចដោយអំបោះដែលជាកប្បិយ ) ក្រៅអំពីនេះយ៉ាងនោះដូចគ្នា ។ បើមានច្រើនផ្នែក តិចច្រើនជាងគ្នា ទំហំចីវរដែលគួរវិកប្បយ៉ាងតូចនោះ ដោយហោចសូម្បីប៉ុនអណ្តាតភ្លើង ក៏ត្រូវអាបត្តិទុក្កដ តាមចំនួនផ្នែកគ្រប់ៗ ផ្នែក ។ បើចីវរត្បាញដោយអំបោះ ដែលឆ្លាស់លំដាប់គ្នាមួយសរសៃក្តី ត្បាញឲ្យអំបោះកប្បិយនៅផ្នែកបណ្តោយ ឲ្យអំបោះអកប្បិយនៅផ្នែកទទឹងក្តី ត្រូវអាបត្តិទុក្កដគ្រប់ៗ ឈើបន្ទឹង ។

ពិតហើយ កាលភិក្ខុប្រើឲ្យជាងតម្បាញកប្បិយត្បាញដោយអំបោះជាអកប្បិយ ត្រូវអាបត្តិទុក្កដ ដូចត្រូវនិស្សគ្គិយខាងដើម ។ កាលភិក្ខុឲ្យជាងតម្បាញកប្បិយនោះឯងត្បាញអំបោះដែលជាកប្បិយ និងអកប្បិយ បើផ្នែកនៃអំបោះអកប្បិយច្រើនផ្នែក ទំហំប៉ុនចីវរយ៉ាងតូច ឬតូចជាងក្នុងផ្នែកអំបោះអកប្បិយទាំងនោះ ត្រូវអាបត្តិទុក្កដដោយចំនួនផ្នែក ។ ក្នុងផ្នែកអំបោះដែលជាកប្បិយទាំងឡាយ មិនត្រូវអាបត្តិ ។ បើចីវរត្បាញដោយអំបោះឆ្លាស់លំដាប់គ្នាម្តងមួយសរសៃក្តី ត្បាញឲ្យអំបោះកប្បិយនៅផ្នែកបណ្តោយ ឲ្យអំបោះអកប្បិយនៅផ្នែកទទឹងក្តី ត្រូវអាបត្តិទុក្កដគ្រប់ៗ ឈើបន្ទឹង ។

បើមានជាងតម្បាញ ២ នាក់ ជាងម្នាក់ជាកប្បិយ ជាងម្នាក់ជាអកប្បិយ ហើយអំបោះក៏ជាអកប្បិយ បើជាងតម្បាញ ២ នាក់នោះផ្លាស់គ្នាត្បាញ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ឈើបន្ទឹង ដែលជាងអកប្បិយត្បាញ ត្រូវអាបត្តិទុក្កដ

ក្នុងចីវរដែលតូចចុះមក ។ ត្រូវអាបត្តិទុក្កដក្នុងផ្នែកទាំង ២ ដែលជាឯកប្បិយត្បាញ បើជាងតម្បាញទាំង ២ នាក់ ចាប់ត្រល់ត្បាញជាមួយគ្នា ត្រូវអាបត្តិទុក្កដគ្រប់ៗ ឈើបន្ទឹង ។ បើអំបោះជាកប្បិយ ហើយចីវរមានផ្នែកដោយការខណ្ឌដូចខ្ទង់ស្រែជាដើម ត្រូវអាបត្តិទុក្កដគ្រប់ៗ ផ្នែក ដែលជាងអកប្បិយត្បាញ ។ ក្នុងផ្នែកដែលជាងកប្បិយត្បាញ មិនត្រូវអាបត្តិ បើជាងតម្បាញទាំង ២ ចាប់ត្រល់ជាមួយគ្នា ត្រូវអាបត្តិទុក្កដគ្រប់ៗ ឈើបន្ទឹង ។

បើអំបោះជាកប្បិយផង អកប្បិយផង បើជាងតម្បាញទាំង ២ នាក់ នោះផ្លាស់គ្នាត្បាញ ក្នុងពេលដែលសម្រេចដោយអំបោះអកប្បិយ មានទំហំប៉ុនចីវរយ៉ាងតូច ដែលជាងអកប្បិយត្បាញ ត្រូវអាបត្តិបាចិត្តិយតាមចំនួនផ្នែក ។ ត្រូវអាបត្តិទុក្កដក្នុងផ្នែកទាំងឡាយ ដែលតូចចុះមក និងដែលសម្រេចដោយអំបោះកប្បិយ ។ ត្រូវអាបត្តិទុក្កដដូចគ្នា ក្នុងពេលដែលសម្រេចដោយអំបោះអកប្បិយ ដែលបានទំហំត្រូវខ្នាត ឬតូចចុះមក ដែលជាងកប្បិយត្បាញ ។ ក្នុងផ្នែកដែលសម្រេចដោយអំបោះកប្បិយ មិនត្រូវអាបត្តិ ។

បើជាងតម្បាញទាំង ២ នាក់ ត្បាញដោយអំបោះដែលឆ្លាស់គ្នាមួយសរសៃៗ ក្តី ត្បាញឲ្យអំបោះអកប្បិយនៅខាងបណ្តោយ ឲ្យអំបោះកប្បិយនៅខាងទទឹងក្តី សូម្បីជាងទាំង ២ នាក់ចាប់ត្រល់ត្បាញជាមួយគ្នាក្តី ត្រូវអាបត្តិទុក្កដរាល់ឈើបន្ទឹង ក្នុងចីវរដែលមិនមានផ្នែក ។ ឯអត្ថថា ក្នុងចីវរដែលមានផ្នែកត្រូវអាបត្តិទុក្កដជាច្រើន ដោយអំណាចនៃផ្នែក នេះមិនប្រាកដក្នុងមហាអដ្ឋថា តែប្រាកដក្នុងមហាបច្ចរីជាដើម ក្នុងអដ្ឋកថានេះ ប្រាកដ

ដោយអាការគ្រប់យ៉ាង ដូច្នេះ ។

បើអំបោះជាកប្បិយក្តី ជាងតម្បាញជាកប្បិយក្តី គឺជាញាតិ និងជាបុគ្គលបវារណា ឬភិក្ខុជួលមកដោយមូលតម្លៃ មិនត្រូវអាបត្តិ ព្រោះការប្រើឲ្យត្បាញជាបច្ច័យ ។ តែភិក្ខុកាលនឹងការពារអាបត្តិ ព្រោះការកន្លង ១០ ថ្ងៃជាបច្ច័យ គប្បីអធិដ្ឋានចីវរដែលត្បាញហើយនោះឯង ក្នុងកាលដែលជាងត្បាញ បានទំហំប៉ុនចីវរដែលគួរវិកប្ប ។ ព្រោះថា ចីវរដែលជាងតម្បាញឲ្យសម្រេច ដោយកន្លង ១០ ថ្ងៃទៅ នឹងគប្បីជានិស្សគ្គិយ ដូច្នេះឯង ។

សូម្បីក្នុងចីវរដែលពួកញាតិជាដើមលើកឡើង ហើយប្រគេនថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទទួលយកចីវរនេះ ដើម្បីលោកម្ចាស់ក៏មានន័យយ៉ាងនេះដូចគ្នា ។ បើជាងតម្បាញដែលភិក្ខុជួលមកយ៉ាងនេះ ឬជាអ្នកបំណងនឹងប្រគេនឯង ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងត្បាញចីវរប្រគេនលោកម្ចាស់ ក្នុងថ្ងៃឈ្មោះនោះ ហើយនឹងរក្សាទុក បើភិក្ខុទុកឲ្យកន្លង ១០ ថ្ងៃទៅអំពីថ្ងៃដែលជាងតម្បាញនោះកំណត់ទុក ត្រូវអាបត្តិនិស្សគ្គិយបាចិ-ត្តិយ ។ បើជាងមិនបានពោលថា ខ្ញុំនឹងត្បាញចីវរប្រគេនលោកម្ចាស់ ហើយនឹងបញ្ជូនដំណឹងទៅឲ្យជ្រាប ហើយធ្វើដូចពាក្យដែលពោលទុក តែភិក្ខុដែលគេពឹងពាក់ទៅ មិនប្រាប់ដល់ភិក្ខុនោះ ភិក្ខុអន្តេវាសិកដទៃឃើញក្តី បានឮក្តី ហើយប្រាប់ថា បពិត្រលោកម្ចាស់ ចីវររបស់លោកម្ចាស់សម្រេចហើយ ការប្រាប់របស់ភិក្ខុនេះ មិនជាប្រមាណ ។ តែក្នុងវេលាលោកឲ្យកន្លង ១០ ថ្ងៃទៅ ចាប់តាំងអំពីថ្ងៃដែលលោកបានឮពាក្យរបស់ភិក្ខុ ដែលជាងតម្បាញនោះពឹងពាក់ទៅ

នោះឯងប្រាប់ ទើបត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

បើជាងតម្បាញពោលថា ខ្ញុំត្បាញចីវរដើម្បីលោក ហើយនឹងបញ្ជូនទៅប្រគេនក្នុងដៃរបស់ភិក្ខុអង្គខ្លះ ហើយធ្វើតាមពាក្យដែលពោលនោះ តែភិក្ខុដែលទទួលចីវរទៅ រក្សាទុកត្រង់បរិវេណរបស់ខ្លួន មិនប្រាប់ដល់លោក ភិក្ខុដទៃអង្គខ្លះពោលថា លោកម្ចាស់ ចីវរដែលមកប្អីស្អាតដែរឬ លោកពោលថា ចីវរឯណាលោកម្ចាស់ ទើបភិក្ខុនោះឆ្លើយថា ចីវរដែលគេផ្ញើមកក្នុងដៃនៃភិក្ខុឈ្មោះនេះ វាចារបស់ភិក្ខុនេះ ក៏មិនជាប្រមាណ ។ លុះណាភិក្ខុនោះប្រគេនចីវរ កាលលោកឲ្យកន្លង ១០ ថ្ងៃទៅ រាប់ពីថ្ងៃដែលខ្លួនបានចីវរនោះមក ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ តែបើជួលឲ្យត្បាញ ជារបស់ដែលភិក្ខុមិនទាន់ឲ្យថ្លៃ នៅរក្សានៅឡើយ ដរាបណាដែលថ្លៃឈ្នួលនៅសល់ សូម្បីត្រឹមមួយកាកណិក ។

[ ១៥៦ ] បទថា **អនាបត្តិ ចីវរំ សិព្វេតុំ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលសូមអំបោះ ដើម្បីដេរចីវរ ។

ក្នុងចីវរទាំងឡាយ គឺសំពត់រុំជង្គង់ជាដើម មានអធិប្បាយថា បទថា **អាយោគេ** ជាដើម ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃនិមិត្ត ។ មិនត្រូវអាបត្តិដល់ភិក្ខុដែលសូមអំបោះ មានសំពត់រុំជង្គង់ជាដើមជានិមិត្ត ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។

ក្នុងសិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣

ដូច្នេះឯង ។

## សុត្តវិញ្ញត្តិសិក្ខាបទទី ៦ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ១៥៧ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្ត ជេតវន ជាអារាមរបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានបុរសម្នាក់ កាលចេញទៅកាន់និរាសស្ថាន បាននិយាយនឹងប្រពន្ធថា ចូរនាងថ្លឹងអំបោះ យកទៅឲ្យជាងតម្បាញឯណោះ ហើយប្រាប់ឲ្យគេត្បាញចីវរទុកទៅ ចាំអញត្រឡប់មកវិញ នឹងប្រគេនចីវរ ( នោះ ) ឲ្យព្រះឧបនន្ទជាម្ចាស់គ្រង ។ ភិក្ខុមួយរូបជាអ្នកកាន់បិណ្ឌចារិកវត្ត បានឮពាក្យដែលបុរសនោះនិយាយហើយ ។ ទើបភិក្ខុនោះ ចូលទៅរកឧបនន្ទដ៏មានអាយុ លុះដល់ហើយ បាននិយាយពាក្យនេះនឹងឧបនន្ទសក្យបុត្រដ៏មានអាយុថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យធំ ព្រោះបុរសម្នាក់នៅទីឯណោះ កាលគាត់ចេញទៅកាន់និរាសស្ថាន បាននិយាយនឹងប្រពន្ធគាត់ថា ចូរនាងថ្លឹងអំបោះ (សម្រាប់ត្បាញចីវរ ) ហើយយកទៅឲ្យជាងតម្បាញឯណោះ ឲ្យគេត្បាញចីវរទុកឲ្យ ( អញ ) ចាំអញត្រឡប់មកវិញ នឹងប្រគេនចីវរឲ្យព្រះឧបនន្ទជាម្ចាស់គ្រង ។ ឧបនន្ទដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ ការនោះពិតមែនហើយ ព្រោះបុរសនោះជាញោមឧបដ្ឋាករបស់ខ្ញុំ ។ ឯជាងតម្បាញនោះ ជាញោមឧបដ្ឋាករបស់ឧបនន្ទសក្យបុត្រដ៏មានអាយុមែន ។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅរកជាងតម្បាញនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងជាងតម្បាញនោះថា ម្នាលអ្នកដ៏មានអាយុ ចីវរនេះ គេត្បាញចំពោះអាត្មា អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែន ត្បាញឲ្យស្មើល្អ

រឹតតម្បាញឲ្យតឹង កួតឲ្យល្អ សិតឲ្យស្អាត ។ ជាងតម្បាញឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន គេប៉ីងអំបោះទាំងនេះមកឲ្យខ្ញុំករុណាថា អ្នកឯងចូរត្បាញចីវរដោយអំបោះនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនអាចធ្វើឲ្យវែងឲ្យទូលាយ ឲ្យណែនបានទេ បពិត្រលោកម្ចាស់ ប៉ុន្តែខ្ញុំករុណា អាចត្បាញឲ្យស្មើល្អ រឹតតម្បាញឲ្យតឹង កួតឲ្យល្អ សិតឲ្យស្អាតបាន ។ ឧបនន្ទដ៏មានអាយុពោលថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយឲ្យណែនល្អចុះ អំបោះនោះមិនខ្វះទេ ។ លំដាប់នោះ ជាងតម្បាញនោះបញ្ចូលអំបោះ ដែលបានមកទាំងប៉ុន្មានទៅក្នុងតម្បាញអស់ហើយ ទើបចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងស្រីនោះថា នែនាងដ៏ចម្រើន ឥឡូវត្រូវការអំបោះ ( ថែមទៀត ) ។ នាងនោះតឡប់សួរថា នែអ្នកខ្ញុំបានប្រាប់អ្នកហើយថា អ្នកចូរត្បាញចីវរ ដោយអំបោះប៉ុណ្ណេះឲ្យគ្រាន់ ។ ជាងតម្បាញឆ្លើយថា នែនាងដ៏ចម្រើន នាងបានប្រាប់ខ្ញុំថា អ្នកចូរត្បាញចីវរដោយអំបោះប៉ុណ្ណោះក៏ពិតមែនហើយ តែព្រះឧបនន្ទជាម្ចាស់ លោកនិយាយយ៉ាងនេះនឹងខ្ញុំថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែនល្អ អំបោះនោះមិនខ្វះទេ ។ ស្រីនោះក៏ឲ្យអំបោះទៅជាងតម្បាញក្នុងពេលក្រោយនេះ ប្រហែលអំបោះដែលបានឲ្យពេលមុនដែរ ។ ឯឧបនន្ទសក្យបុត្រដ៏មានអាយុ បានដំណឹងថា បុរសនោះត្រឡប់មកអំពីនិវាសស្ថានហើយ ។ ឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅកាន់លំនៅរបស់បុរសនោះលុះចូលទៅហើយ ក៏អង្គុយលើអាសនៈដែលគេចាត់ចែងស្រាប់ ។ ឯបុរស

នោះក៏ចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះអង្គុយស្រួលបួលហើយ ក៏និយាយពាក្យនេះនឹងប្រពន្ធថា នាងឯងបានឲ្យជាងតម្បាញត្បាញចីវររួចហើយឬ ។ ប្រពន្ធឆ្លើយថា ចាះ អ្នកជាម្ចាស់ ខ្ញុំបានឲ្យគេត្បាញចីវររួចហើយ ។ ប្តីទាររកថា នាងចូរយកមក អញនឹងប្រគេនចីវរឲ្យព្រះឧបនន្ទជាម្ចាស់គ្រង ។ លំដាប់នោះ ស្រីនោះ បាននាំយកចីវរនោះទៅឲ្យស្វាមី ហើយក៏ប្រាប់សេចក្តីនុ៎ះឲ្យដឹង ។ ទើបបុរសនោះប្រគេនចីវរនោះដល់ឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រទាំងនេះ ជាអ្នកប្រាថ្នាច្រើន មិនសន្តោស យើងមិនងាយនឹងឲ្យសមណៈពួកនេះស្លៀកដណ្តប់ចីវរបានទេ អញមិនបានបវារណាព្រះឧបនន្ទជាម្ចាស់មកពីមុនទេ មិនសមបើនឹងហ៊ានចូលទៅរកជាងតម្បាញ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺរិះគន់ ចង់បានហួសហេតុ ) ។ ភិក្ខុទាំងឡាយបានឮបុរសនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុ គេមិនបានបវារណាមកពីមុនសោះ មិនសមបើ នឹងហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺរិះគន់ចង់បានហួសហេតុ ) ។ លំដាប់នោះ ភិក្ខុទាំងនោះនាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ឧបនន្ទ គេថាអ្នកឯង ជនជាម្ចាស់

ចីវរ គេមិនបានបវារណាមកពីមុនសោះ ហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺ រិះគន់ ចង់បានហួសហេតុ ) ពិតមែនឬ ។ ឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ បុរសនោះជាញាតិរបស់អ្នកឯងឬមិនមែនជាញាតិទេ ។ ឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ បុរសនោះមិនមែនជាញាតិទេ ។ ម្នាលមោឃបុរស បុគ្គលមិនមែនជាញាតិ តែងមិនទទួលដឹងនូវការសមគួរ និងមិនសមគួរ ការល្អិតល្អ និងមិនល្អិតល្អ របស់បុគ្គលដែលមិនមែនជាញាតិទេ នែមោឃបុរស ក្នុងរឿងចីវរនោះ ( បើ ) ម្ចាស់ចីវរគេមិនបានបវារណាមកពីដើមទេ អ្នកឯងមិនសមបើ នឹងហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺរិះគន់ចង់បានល្អឲ្យហួសហេតុ ដូច្នេះសោះ ) នែមោឃបុរស អំពើដែលអ្នកឯងធ្វើមកនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យជន ដែលជ្រះថ្លាស្រាប់ហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា គហបតី ( គឺបុរសជាម្ចាស់ផ្ទះ ) ក្តី គហបតានី ( គឺស្រីជាម្ចាស់ផ្ទះ ) ក្តី ដែលមិនមែនជាញាតិ ឲ្យជាងតម្បាញត្បាញចីវរចំពោះភិក្ខុណាមួយ ។ បើភិក្ខុនោះ ដែលអ្នកម្ចាស់ចីវរ គេមិនបានបវារណាមកពីមុនក្នុងរឿងចីវរនោះ អាចហ៊ានចូលទៅរកជាងតម្បាញ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺរិះគន់ចង់បានល្អឲ្យហួសហេតុ ) គឺពោលថា

នៃអ្នកដ៏មានអាយុ ចីវរនេះគេឲ្យត្បាញចំពោះអាត្មា អ្នកទាំងឡាយចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យមានសាច់ញឹក ឲ្យស្មើល្អ រឹតឲ្យតឹងល្អ ចូរត្រដោះកួត ហើយសិតឲ្យល្អ សឹមអាត្មាថែមរង្វាន់ឲ្យអ្នកបន្តិចបន្តួច ។ ភិក្ខុនោះ លុះនិយាយយ៉ាងនោះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឲ្យ ដោយហោចទៅ ទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត ( មួយវែ្ធត ) ក៏ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៥៨ ] ត្រង់ពាក្យថា ចំពោះភិក្ខុណាមួយ គឺដើម្បីជាប្រយោជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឲ្យជាអារម្មណ៍ ហើយចង់ឲ្យភិក្ខុស្លៀកដណ្តប់ចីវរ ។ គហបតីដែលមិនជាប់ជំពាក់ ( ជាសាច់ញាតិ ) ពីចំណែកខាងមាតាក្តី បិតាក្តី រៀងរាល់ដល់គូជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ បុគ្គលណាមួយដែលគ្រប់គ្រងគេហដ្ឋាន បុគ្គលនោះ ហៅថា គហបតី ។ ស្រីណាមួយដែលគ្រប់គ្រងគេហដ្ឋាន ស្រីនោះហៅថា គហបតានី ។ ពាក្យថា ជាងតម្បាញ បានដល់ពួកអ្នកធ្វើការត្បាញ ។ បណ្តាចីវរ ៦ យ៉ាង ចីវរយ៉ាងណានីមួយ យ៉ាងតូចបំផុត ល្មមសម្រេចកិច្ចវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា ឲ្យត្បាញ គឺថាឲ្យបាក់អំបោះ ឬសូត្រធ្វើសំពត់ ។ ពាក្យថា បើភិក្ខុនោះ សេចក្តីថា ម្ចាស់ចីវរឲ្យត្បាញចីវរចំពោះភិក្ខុអង្គណា សំដៅយកភិក្ខុនោះ ។ ពាក្យថា គេមិនបានបវារណាមកពីមុន គឺមិនបាននិយាយគ្នាទុកមកពីមុនថា បពិត្រលោកម្ចាស់ លោកត្រូវការចីវរយ៉ាងណា ខ្ញុំករុណានឹងឲ្យជាងតម្បាញ ត្បាញចីវរយ៉ាងណាប្រគេនលោក ។ ពាក្យថា ចូលទៅរកជាងតម្បាញ គឺទៅផ្ទះជាងតម្បាញ ឬចូលទៅរកគេក្នុងកន្លែងណាមួយ ។ ពាក្យថា ដល់នូវកិរិយាកំណត់ក្នុងចីវរ

គឺនិយាយថា នែអ្នកដ៏មានអាយុ ចីវរនេះ គេឲ្យត្បាញចំពោះអាត្មាហើយ អ្នកទាំងឡាយចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យសាច់ញឹក ធ្វើឲ្យស្មើល្អ រឹតឲ្យតឹងល្អ ត្រដុះកួតឲ្យល្អ និងសិតឲ្យល្អ សឹមអាត្មាឯងនឹងថែមរបស់អ្វីៗ ឲ្យពួកអ្នកដ៏មានអាយុខ្លះមិនខាន ។ ពាក្យថា ភិក្ខុនោះលុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឲ្យ ដោយហោចទៅ ទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត អធិប្បាយថា បបរក្តី បាយក្តី របស់គួរទំពាស៊ីក្តី ហៅថា បិណ្ឌបាត ដោយហោចទៅសូម្បីដុំលម្អិតសម្រាប់ងូតក្តី ឈើស្ទន់ក្តី អំបោះរងជើងក្តី ភិក្ខុសម្តែងធម៌ឲ្យស្តាប់ក្តី ( ក៏ហៅថា បិណ្ឌបាតក្នុងសិក្ខាបទនេះដែរ ) ។ បើជាងតម្បាញត្បាញចីវរឲ្យវែងក្តី ឲ្យទូលាយក្តី ឲ្យមានសាច់ញឹកក្តី តាមពាក្យ ( បង្គាប់ ) របស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដតាមប្រយោគ ។ ចីវរនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ថា ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំករុណានេះ ម្ចាស់ចីវរមិនបានបវារណាមកពីមុនទេ ខ្ញុំករុណាបានចូលទៅរកពួកជាងតម្បាញរបស់គហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺចង់បានល្អហួសហេតុ) ចីវរនេះជានិស្សគ្គិយ ខ្ញុំករុណាសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតអំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមនោះហើយ ។

[ ១៥៩ ] ភិក្ខុសម្គាល់គហបតីមិនមែនជាញាតិ ថាមិនមែនជាញាតិពិតមែន គេមិនបានបវារណាមកពីដើមទេ ចូលទៅរកជាងតម្បាញរបស់គហបតី

ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមកពីមុន ចូលទៅរកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយា កំណត់ក្នុងចីវរ ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់គហបតីដែលមិនមែនជាញាតិ ជាជាញាតិ គេមិនបានបវារណាទុកមុន ចូលទៅរកពួកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់គហបតីដែលជាញាតិ ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យនឹងគហបតីដែលជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់គហបតីដែលជាញាតិ ថាជាញាតិពិតមែន មិនត្រូវអាបត្តិអ្វីឡើយ ។

[ ១៦០ ] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសម្នាក់នៃពួកគហបតីដែលជាញាតិ ដល់ភិក្ខុដែលកំណត់ចីវរក្នុងសម្នាក់នៃពួកគហបតីដែលបានបវារណា ដល់ភិក្ខុដែលកំណត់ចីវរ ដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលធ្វើចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលម្ចាស់ចីវរ គេចង់ឲ្យត្បាញចីវរមានតម្លៃច្រើន តែភិក្ខុឲ្យគេត្បាញចីវរមានតម្លៃតិចវិញ ដល់ភិក្ខុដែលឆ្កួតចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា

## បត្តវគ្គ សិក្ខាបទទី ៧

## មហាបេសការសិក្ខាបទ

[ ១៥៧ ] *មហាបេសការសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងមហាបេសការសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះ ពីរបទថា* **សុត្តំ ធារយិត្វា** *បានដល់ ថ្លឹងអំបោះឲ្យបានកំណត់មួយបលៈ ។*

## អធិប្បាយ

## សិក្ខាបទវិភង្គនៃមហាបេសការសិក្ខាបទ

[ ១៥៨ ] *បទថា* **អប្បិតំ** *ប្រែថា ឲ្យណែន ។*

*បទថា* **សុវីតំ** *បានដល់ ឲ្យជារបស់ដែលត្បាញល្អ គឺឲ្យជារបស់ដែលត្បាញស្មើក្នុងទីគ្រប់អន្លើ ។*

*បទថា* **សុប្បវាយិតំ** *បានដល់ សន្ធឹងឲ្យល្អ គឺសន្ធឹងឲ្យតឹងស្មើក្នុងទីគ្រប់អន្លើ ។*

*បទថា* **សុវិលេខិតំ** *ប្រែថា ឲ្យជារបស់ត្រដោះល្អ ដោយគ្រឿងត្រដោះ ។*

*បទថា* **សុវិតច្ឆិតំ** *ប្រែថា ឲ្យជារបស់សិតល្អដោយស្និត ( ដោយប្រាស ) អធិប្បាយថា ឲ្យជារបស់ជម្រះរៀបរយ ។*

*បទថា* **បដិពទ្ធំ** *ប្រែថា ការខ្វះខាត ។*

*បទថា* **តន្តេ** *សេចក្តីថា នាំចូលទៅក្នុងតម្បាញដែលសន្ធឹងទៅតាមបណ្តោយនោះឯង ។*

ប្រែថាបទថា **តត្រ ចេសោ ភិក្ខុ** សេចក្តីថា ក្នុងស្រុក ឬនិគមដែលពួកជាងតម្បាញទាំងនោះនៅ ។

ពីរបទថា **វិកប្បំ អាបជ្ជេយ្យ** សេចក្តីថា ដល់នូវការកំណត់យកពិសេស គឺចាត់ចែងយ៉ាងក្រៃលែង ។ តែក្នុងបាលី ដើម្បីទ្រង់សម្តែងអាការដែលជាហេតុឲ្យភិក្ខុដល់នូវការកំណត់យក ទើបព្រះមានព្រះភាគត្រាស់ថា **ឥទំ ខោ អាវុសោ** ជាដើម ។

ពីរបទថា **ធម្មំបិ ភណតិ** បានដល់ ពោលធម្មកថា ។ ព្រះមានព្រះភាគទ្រង់សម្តែងអាការ គឺការបន្ថែមអំបោះប៉ុណ្ណោះ ដោយពាក្យថា បុគ្គលនោះធ្វើឲ្យវែងក្តី ឲ្យធំទូលាយក្តី ឲ្យណែនក្តី តាមពាក្យរបស់ភិក្ខុនោះ ។

ពីរបទថា **បុព្វេ អប្បវារិតោ** បានដល់ ជាបុគ្គលដែលម្ចាស់របស់ចីវរទាំងឡាយ មិនបានបវារណា ។ ពាក្យដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

មហាបេសការសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ១៦១ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯងមហាមាត្យម្នាក់ កាលចេញទៅកាន់ទីនិវាសដ្ឋាន ជាទីព្រាត់ប្រាស បានប្រើបម្រើទៅក្នុងសម្នាក់ភិក្ខុទាំងឡាយ ដោយពាក្យថា លោកម្ចាស់ទាំងឡាយ ចូរនិមន្តមក ខ្ញុំនឹងថ្វាយសំពត់ចំណាំវស្សា ។ ឯពួកភិក្ខុសង្ស័យថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតសំពត់ចំណាំវស្សាដល់ពួកភិក្ខុ ដែលចាំវស្សាហើយ ទើបមិននាំគ្នាមក ( ព្រោះវេលានៅមិនទាន់ចេញវស្សា ) ។ លំដាប់នោះមហាអមាត្យនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា អញបានប្រើបម្រើទៅហើយ មិនសមបីបើលោកម្ចាស់ទាំងឡាយមិននិមន្តមក ខ្លួនអញចេញទៅក្នុងកងទ័ព ការរស់នៅ ឬស្លាប់ទៅ មិនងាយដឹងទេ ។ ភិក្ខុទាំងឡាយបានឮមហាអមាត្យនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបពួកភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទទួលអច្ចេកចីវរទុកដាក់បាន ។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយ ទទួលអច្ចេកចីវរទុកដាក់បាន ហើយក៏ទទួលអច្ចេកចីវរ ទុកឲ្យកន្លងហួសចីវរកាលទៅ ។ ភិក្ខុទាំងឡាយបានវេចខ្ចប់នូវចីវរទាំងនោះ ព្យួរទុកនឹងខ្សែស្បៀង ។

អានន្ទត្ថេរដ៏មានអាយុ ដើរទៅតាមទីសេនាសនៈ ក៏បានឃើញចីវរទាំងនោះ ដែលភិក្ខុខ្ចប់ព្យួរទុកនឹងខ្សែស្បៀង លុះឃើញហើយ ទើបហៅភិក្ខុទាំងឡាយ មកសួរថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះដែលគេព្យួរទុកនឹងខ្សែស្បៀង តើជារបស់អ្នកណា ។ ពួកភិក្ខុឆ្លើយថា អាវុសោ អច្ចេកចីវររបស់យើងខ្ញុំ ទាំងឡាយ ។ អានន្ទត្ថេរសួរទៀតថា ម្នាលអាវុសោ ចីវរទាំងនេះ លោក រាល់គ្នាបានដាក់ទុកមកយូរអស់កាលប៉ុន្មានហើយ ។ ទើបភិក្ខុទាំងនោះ បាន ប្រាប់កាលដែលខ្លួនបានដាក់ទុកចីវរនោះ ដល់ព្រះអានន្ទត្ថេរ ដ៏មានអាយុ ។ អានន្ទត្ថេរដ៏មានអាយុក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនសមបើ នឹងទទួលអច្ចេកចីវរ ហើយទុកឲ្យកន្លងចីវរកាលទៅ ។ លំដាប់នោះ ព្រះ អានន្ទត្ថេរដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទទួលអច្ចេកចីវរ ហើយ បណ្តោយឲ្យកន្លងហួសចីវរកាលទៅ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូម ទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបីបើពួកមោឃបុរសនោះ ទទួលអច្ចេកចីវរ ហើយបណ្តោយឲ្យកន្លងហួស ចីវរកាលទៅទេ ម្នាលភិក្ខុទាំងឡាយ អំពើ ដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិន ទាន់ជ្រះថ្លាផង មិននាំឲ្យជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងផង ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើង នូវសិក្ខាបទនេះ យ៉ាងនេះថា ថ្ងៃពេញបូណ៌មី ខែកត្តិក ដែលជាខែទី ៣ នៃវស្សានរដូវ នៅខ្វះ

១០ ថ្ងៃទៀតនឹងគ្រប់ ( គឺថ្ងៃ ៥ កើតខែអស្សុជ ) បើអច្ចេកចីវរកើតឡើង ដល់ភិក្ខុៗ សម្គាល់ថាជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលហើយ គប្បីទុក ដាក់ដរាបអស់សម័យចីវរកាល បើភិក្ខុទុកយូរឲ្យ ហួសកំណត់នោះទៅ ត្រូវ អាបត្តិនិស្សគ្គិយបាចិត្តិយ ។

[ ១៦២ ] ត្រង់ពាក្យថា ខ្វះ ១០ ថ្ងៃទៀត គឺនៅខ្វះ ១០ ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ។ ថ្ងៃបវារណាក្នុងខែកត្តិក តថាគតត្រាស់ហៅថា ថ្ងៃ ពេញបូណ៌មីនៃខែកត្តិក ដែលជាខែទី ៣ នៃវស្សានរដូវ ។ ដែលហៅថា អច្ចេកចីវរនោះ គឺសំពត់ដែលបុគ្គលណាមួយ ត្រូវការនឹងចេញទៅក្នុងកងទ័ពក្តី ត្រូវការនឹងចេញទៅកាន់និវាសដ្ឋានក្តី ជាមនុស្សមានជំងឺក្តី ស្រីមានគភ៌ក្តី បុគ្គលឥតសទ្ធា ត្រឡប់មានសទ្ធាកើតឡើងក្តី ។ បុគ្គលគ្មានសេចក្តីជ្រះថ្លា ត្រឡប់ជាមានសេចក្តីជ្រះថ្លាកើតឡើងក្តី ។ បើបុគ្គលនោះ ប្រើបម្រើទៅកាន់ សម្នាក់ភិក្ខុទាំងឡាយ ( ចំពោះចីវរណា ) ដោយពាក្យថា លោកម្ចាស់ទាំងឡាយ សូមនិមន្តមក ខ្ញុំព្រះករុណានឹងប្រគេនសំពត់វស្សាវាសិក ( សំពត់ចំណាំ វស្សា ) ។ ចីវរនេះឈ្មោះថា អច្ចេកចីវរ (គឺចីវរដែលបុគ្គលធ្វើដោយប្រួសរាន់) ។ ពាក្យថា ភិក្ខុសម្គាល់ថា ជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលរួចហើយ គប្បីទុកដរាបអស់សម័យចីវរកាល សេចក្តីថា ភិក្ខុត្រូវធ្វើសេចក្តីសម្គាល់ថា នេះជាអច្ចេកចីវរ ហើយទុកដាក់ចុះ ។ ដែលហៅថា សម័យចីវរកាលនោះ គឺថា

---

១- បើភិក្ខុមិនបានក្រាលកឋិនទេ ចីវរកាលមានតែ ១ ខែ គឺរាប់តាំងពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើតខែកត្តិក បើបានក្រាលកឋិន ចីវរកាលមាន ៥ ខែ គឺរាប់តាំងពីថ្ងៃ ១ រោច ខែអស្សុជ ទៅដល់ថ្ងៃ ១៥ កើតខែផល្គុណ នេះហៅថា ចីវរកាលសម័យ ។

បើភិក្ខុមិនបានក្រាលកឋិនទេ នោះត្រូវកំណត់យកខែ ខាងចុង[១] នៃវស្សានរដូវ ១ ខែ បើបានក្រាលកឋិន ត្រូវកំណត់យក ៥ ខែ ។ ពាក្យថា បើភិក្ខុទុកដាក់ឲ្យហួសកំណត់នោះទៅ គឺថា បើមិនបានក្រាលកឋិន ភិក្ខុបណ្ដោយឲ្យអចេ្ចកចីវរកន្លងថ្ងៃខាងចុងនៃវស្សានរដូវ គឺថ្ងៃពេញបូណ៌មីខែកត្តិកទៅ អចេ្ចកចីវរនោះជានិស្សគ្គិយ ។ បើភិក្ខុក្រាលកឋិនរួចហើយ បណ្ដោយឲ្យអចេ្ចកចីវរកន្លងហួសថ្ងៃដែលភិក្ខុដោះកឋិនទៅ អចេ្ចកចីវរនោះ ជានិស្សគ្គិយដែរ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះថា ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន អចេ្ចកចីវររបស់ខ្ញុំនេះ ខ្ញុំទុកឲ្យកន្លងចីវរកាលទៅហើយ ចីវរនេះជានិស្សគ្គិយ ខ្ញុំករុណាសូមលះបង់អចេ្ចកចីវរនេះដល់សង្ឃ ។ សេចក្ដីតអំពីនេះទៅ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។

[ ១៦៣ ] អចេ្ចកចីវរពិតមែន ភិក្ខុសម្គាល់ថា ជាអចេ្ចកចីវរ បើភិក្ខុទុកឲ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងអចេ្ចកចីវរ ហើយទុកឲ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ អចេ្ចកចីវរមែន ភិក្ខុសម្គាល់ថា មិនមែនជាអចេ្ចកចីវរ ទុកឲ្យកន្លងហួសសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់អចេ្ចកចីវរដែលមិនបានអធិដ្ឋាន ថាបានអធិដ្ឋានហើយក្ដី សម្គាល់អចេ្ចកចីវរដែលមិនបានវិកប្ប ថាបានវិកប្បរួចមកហើយក្ដី សម្គាល់អចេ្ចកចីវរ ដែលមិនបានលះបង់ ថាលះបង់ហើយក្ដី សម្គាល់អចេ្ចកចីវរ ដែលមិនបាត់ ថា បាត់

ទៅហើយក្តី សម្គាល់អច្ចេកចីវរដែលមិនវិនាស ថាវិនាសហើយក្តី សម្គាល់អច្ចេកចីវរ ដែលភ្លើងមិនឆេះ ថាភ្លើងឆេះហើយក្តី សម្គាល់អច្ចេកចីវរ ដែលចោរមិនបានប្លន់ ថាចោរប្លន់យកទៅហើយក្តី ហើយទុកឲ្យកន្លង ហួសចីវរកាលទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមិនលះបង់ចីវរដែល ជានិស្សគ្គិយហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់សំពត់ដែលមិនមែនអច្ចេកចីវរ ថាជាអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងសំពត់ដែលមិនមែនអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់សំពត់ដែលមិនមែនជាអច្ចេកចីវរ ថាមិនមែនអច្ចេកចីវរ មិនត្រូវអាបត្តិឡើយ ។

[ ១៦៤ ] អាបត្តិមិនមានដល់ភិក្ខុដែលបានអធិដ្ឋានអច្ចេកចីវរទុក ( ក្តី ) វិកប្បទុក ( ក្តី ) លះបង់ឲ្យគេ ( ក្តី ) ដល់ភិក្ខុដែលមានអច្ចេកចីវរបាត់ទៅ ( ក្តី ) វិនាសទៅ ( ក្តី ) ភ្លើងឆេះ ( ក្តី ) ចោរដណ្តើមយកទៅ ( ក្តី ) សហធម្មិកកាន់យកទៅដោយសេចក្តីស្និទ្ធស្នាល ( ក្តី ) ខាងក្នុងសម័យចីវរកាល ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា

## បត្តវគ្គ សិក្ខាបទទី ៨

## អច្ចេកចីវរសិក្ខាបទ

[ ១៦០ ] *អច្ចេកចីវរសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងអច្ចេកចីវរសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា បទថា* **ទសាហានាគតំ** *សេចក្តីថា ថ្ងៃទាំងឡាយ ១០ ឈ្មោះថា* **ទសាហា** ។ *( ១៥ កើត ខែអស្សុជ ) នៅមិនទាន់មកដល់ដោយថ្ងៃ ១០ នោះ ឈ្មោះថា* **ទសាហានាគត** *អធិប្បាយថា ខ្វះ ១០ ថ្ងៃ ។ ក្នុងថ្ងៃ ១៥ កើត ដែលមិនទាន់មកដល់ ១០ ថ្ងៃទៀតនោះ ។ ទុតិយាវិកត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយអំណាចនៃអច្ចន្តសំយោគ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា* **ទសាហានាគតំ** *នោះ ទើបត្រាស់ថា* **ទសាហានាគតាយ** ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃអច្ចេកចីវរសិក្ខាបទ

[ ១៦២ ] *ឯបទថា* **បវារណាយ** *នេះ ជាពាក្យប្រកបតាមក្រោយ ដើម្បីកុំឲ្យសង្ស័យ ដើម្បីនឹងសម្តែងបវារណាដែលត្រាស់ទុកថា* **ទសាហា-នាគតា** *ដោយសរុប ។*

## អធិប្បាយ ការកើតនៃអច្ចេកចីវរ

*បទថា* **កត្តិកតេមាសិកបុណ្ណមំ** *ប្រែថា ថ្ងៃបុណ្ណមីដែលគ្រប់ ៣ ខែ*

នៃដើមខែកត្តិក ។ ក្នុងបទថា **កត្តិកតេមាសិកបុណ្ណមំ** នេះ ក៏ជាទុតិយា-វិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិដោយន័យមុនដូចគ្នា ព្រោះប្រកបតាមក្រោយបទដើម ។ មានពាក្យអធិប្បាយថា ថ្ងៃមហាបវារណាដំបូង លោកហៅថា **ឧសាបាណាគតា** តាំងអំពីកាលណាទៅ បើអច្ចេកចីវរគប្បី កើតឡើងដល់ភិក្ខុពិតប្រាកដ រាល់ថ្ងៃទាំងនោះឯង ( ក្នុង ១០ ថ្ងៃនោះ ថ្ងៃណាមួយ ) ។ ភិក្ខុដឹងថា នេះជាអច្ចេកចីវរ ( ចីវរប្រញាប់ ) គប្បីទទួលទុកបានទាំងអស់ ។

ដោយបទថា **ឧសាបាណាគតំ កត្តិកតេមាសិកបុណ្ណមំ** នោះ គឺព្រះអង្គទ្រង់សម្តែងកាលជាទីទុកចីវរដែលកើតឡើង ចាប់តាំងអំពីថ្ងៃ ៥ កើតនៃជុណ្ហបក្ខនៃបវារណា ។ ឯកាលជាទីទុកដាក់ចីវរនោះ សម្រេចដោយពាក្យថា គប្បីទ្រទ្រង់អតិរេកចីវរបាន ១០ ថ្ងៃយ៉ាងក្រៃលែងនេះក៏ពិត តែទ្រង់សម្តែងរឿង ហាក់ដូចជាមិនធ្លាប់មាន ដោយអំណាចនៃរឿងដែលកើតឡើង ហើយទ្រង់បញ្ញត្តសិក្ខាបទទុក ។

ចីវរប្រញាប់ លោកហៅថា **អច្ចេកចីវរ ។** ដើម្បីសម្តែងចីវរនោះជាសំពត់បន្ទាន់ ទើបត្រាស់ពាក្យថា បុគ្គលបំណងនឹងទៅក្នុងកងទ័ពក្តីជាដើម ។

បណ្តាបទទាំងនោះ ដោយបទថា **សទ្ធា** នេះ ទ្រង់សម្តែងហេតុត្រឹមតែសទ្ធាធម្មតាប៉ុណ្ណោះ ។

ដោយបទថា **បសាទោ** នេះ ទ្រង់សម្តែងសទ្ធាដ៏ខ្លាំងក្លា មានសេចក្តីបរិសុទ្ធល្អ ។

ចីវរដែលទាយកមានបំណងនឹងប្រគេន ដោយហេតុទាំងនេះ ទើបបញ្ជូន

ទូតមកក្តី មកប្រាប់ឯងក្តី យ៉ាងនេះថា ខ្ញុំនឹងប្រគេនសំពត់ចំណាំវស្សា បាន ឈ្មោះថា អច្ចេកចីវរ ក្នុងបទថា **ឯតំ អច្ចេកចីវរំ ឆាម** នេះឯង ។ តែទោះ ចីវរដែលភិក្ខុបច្ចុទ្ធ ( ដក ) ដែលចីវរមិនមែនជាអច្ចេកចីវរ កើតឡើងតាំង អំពីថ្ងៃ ៦ កើត ហើយរក្សាទុកដាក់ ក៏បានបរិហារនេះដូចគ្នា ។

ប្រើនបទថា **សញ្ញាណំ កត្វា និក្ខិបិតព្វំ** បានដល់ គប្បីធ្វើគ្រឿង ចំណាំឯណាមួយ រក្សាទុក ។ ពាក្យថា គប្បីធ្វើគ្រឿងចំណាំ ហើយទុកដាក់ នេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីអ្វី ព្រោះថា បើភិក្ខុទាំងឡាយចែកអច្ចេក-ចីវរនោះមុនថ្ងៃបវារណា ភិក្ខុដែលបានសំពត់អច្ចេកចីវរនោះទៅ ត្រូវជាអ្នកមិន ដាច់វស្សា ។ តែបើអ្នកដាច់វស្សា ចីវរនឹងក្លាយជារបស់សង្ឃ ព្រោះដូច្នោះ នឹងត្រូវកំណត់ចែកឲ្យល្អ ( ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះទុក ) ។

## អធិប្បាយ

## បទភាជនីយនៃអច្ចេកចីវរ

[ ១៦៣ ] បទយ៉ាងនេះថា **អច្ចេកចីវរេ អច្ចេកចីវរសញ្ញី** ជាដើម ព្រះមានព្រះភាគត្រាស់សំដៅយកចំពោះចីវរដែលចែកគ្នាហើយ ។ តែបើមិន ទាន់បានចែកគ្នាក្តី ជាចីវរដែលទុកដាក់ក្នុងឃ្លាំងរបស់សង្ឃក្តី សូម្បីកន្លងសម័យ ទៅ ក៏មិនត្រូវអាបត្តិ ។ អតិរេកចីវរបានបរិហារ ១០ ថ្ងៃ ដោយប្រការដូច្នេះ ត្រៃចីវរមិនមានបរិហារឡើយសូម្បីមួយថ្ងៃ ។ អ្នកសិក្សាគប្បីជ្រាបថា ចីវរ គឺ សំពត់ងូតទឹកភ្លៀងដែលមិនទាន់បានធ្វើ កាលមិនបានក្រាលកឋិន បានបរិហារ ៥ ខែ កាលបន្ថែមរដូវភ្លៀង ( បន្ថែមអធិកមាស ) បានបរិហារ ៦ ខែ កាល

បានក្រាលកឋិន បានបរិហារ ៤ ខែទៀត បានបរិហារ ១ ខែទៀត ដោយអំណាចការអធិដ្ឋានឲ្យជាមូលចីវរ កាលមានសេចក្តីសង្ឃឹមថានឹងបាន (សំពត់) ក្នុងថ្ងៃចុងក្រោយនៃហេមន្តរដូវ ( ខែត្រជាក់ ) រួមបានបរិហារ ១១ ខែ យ៉ាងនេះ ។ អច្ចេកចីវរ កាលមិនបានក្រាលកឋិន បានបរិហារ ១ ខែ និង ១១ ថ្ងៃ បើបានក្រាលកឋិន បានបរិហារ ៥ ខែ និង ១១ ថ្ងៃ បន្ទាប់អំពីនោះទៅ មិនបានបរិហារសូម្បី ១ ថ្ងៃឡើយ ។

បទថា **អច្ចេកចីវរេ** បានដល់ ក្នុងចីវរដទៃដែលប្រហាក់ប្រហែលនឹងអច្ចេកចីវរ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ពាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានកឋិនជាសមុដ្ឋាន ជាអកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អច្ចេកចីវរសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ១៦៥ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយនៅចាំវស្សាហើយ ទៅនៅក្នុងសេនាសនៈដែលឋិតនៅក្នុងព្រៃ ។ ពួកចោរខែកត្តិកគិតគ្នាថា ពួកភិក្ខុបានលាភ ( ច្រើន ) ហើយក៏នាំគ្នាមកបៀតបៀន ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្តែងធម្មីកថាត្រាស់ហៅភិក្ខុ ទាំងឡាយមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃ តថាគតអនុញ្ញាតឲ្យទុកបណ្តាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន ។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃទុកដាក់បណ្តាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន ។ ពួកភិក្ខុនោះក៏បានទុកដាក់បណ្តាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះហើយ នៅប្រាសចាកហួស ៦ រាត្រី ។ ចីវរទាំងនោះបាត់ទៅខ្លះ ខូចខាតទៅខ្លះ ភ្លើងឆេះខ្លះ កណ្តុរកាត់ខ្លះ ។ ភិក្ខុទាំងឡាយមានសំពត់អាក្រក់ មានចីវរសៅហ្មង ។ ពួកភិក្ខុ ( ឯទៀត ) សួរយ៉ាងនេះថា នែអាវុសោ ហេតុម្តេចបានជាអ្នកទាំងឡាយ មានសំពត់អាក្រក់ មានចីវរសៅហ្មង ។ ភិក្ខុទាំងនោះក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នា

តិច ។បេ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ចុះហេតុអ្វី បានជាភិក្ខុទាំងឡាយទុកបណ្តាចីវរទាំង ៣ ចីវរណាមួយក្នុង ចន្លោះផ្ទះ ( គឺក្នុងភូមិ ឬក្នុងស្រុក ) ហើយនៅប្រាសចាក ( ត្រៃចីវរ ) នោះ ហួស ៦ រាត្រី ។ ខណៈនោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុទុកបណ្តាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស ៦ រាត្រី ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានយសជាម្ចាស់ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុះហេតុអ្វីបានជាពួកមោឃបុរសទាំងនោះ ទុកបណ្តាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស ៦ រាត្រីទៅ នែភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាផង មិនមែននាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតផង ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើភិក្ខុទាំងឡាយចាំវស្សារួចហើយ លុះដល់ថ្ងៃពេញបូណ៌មីខែកត្តិក សេនាសនៈទាំងឡាយណា ដែលតាំងនៅក្នុងព្រៃដែលគេសម្មតិថាជាទីមានសេចក្តីរង្កៀស មានភ័យចំពោះមុខ កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយ មានសភាពដូច្នោះ បើមានចំណង់នឹងទុកចីវរ គប្បីទុកបណ្តាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ។ តែបើភិក្ខុនោះមានហេតុ អ្វីនីមួយល្មមឲ្យនៅប្រាសចាកចីវរនោះបាន ភិក្ខុនោះ គប្បីនៅប្រាសចាកចីវរនោះយ៉ាង

យូរត្រឹម ៦ រាត្រី ។ បើនៅប្រាសចាកឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសេចក្តីសម្មតិ អំពីសង្ឃ ។

[ ១៦៦ ] ត្រង់ពាក្យថា ចាំវស្សារួចហើយ គឺចេញវស្សាហើយ ។ ពាក្យថា ពេញបូណ៌មីខែកត្តិក គឺថា ព្រះដ៏មានព្រះភាគត្រាស់សំដៅយកខែទី ៤ ( នៃវស្សានរដូវ ) ឈ្មោះថា កត្តិក ។ ពាក្យថា សេនាសនៈទាំងឡាយណាដែលតាំងនៅក្នុងព្រៃ គឺសេនាសនៈដែលតាំងនៅក្នុងព្រៃ មានចម្ងាយពីស្រុក ៥០០ ធ្នូរដ្ឋ កំណត់យ៉ាងជិតបំផុត ។ ដែលហៅថា ទីមានសេចក្តីរង្កៀសនោះ បានដល់ ឱកាសដែលពួកចោរអាស្រ័យនៅ បរិភោគ ឈរ អង្គុយ ដេក មានប្រាកដក្នុងអារាម ឬឧបចារៈនៃអារាម ។ ដែលហៅថា ទីមានភ័យចំពោះមុខនោះ គឺក្នុងអារាម ឬឧបចារៈនៃអារាម ប្រាកដថា មានពួកចោរសម្លាប់មនុស្សទាំងឡាយ ប្រាកដថា មានពួកចោរប្លន់ ប្រាកដថា មានពួកចោរវាយដំ ។ ពាក្យថា កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ គឺថា កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពយ៉ាងនេះ ។ ពាក្យថា បើមានចំណង់ គឺកាលប្រាថ្នា ( នឹងទុកចីវរ ) ។ ពាក្យថា បណ្តាចីវរទាំង ៣ ចីវរណាមួយ គឺភិក្ខុទុកសង្ឃាដិ ឬឧត្តរាសង្គ ( ចីពរ ) ឬអន្តរវាសក ( ស្បង់ ) ។ ពាក្យថា គប្បីទុកក្នុងចន្លោះផ្ទះ គឺគប្បីទុកក្នុងស្រុកជាទីគោចរដោយជុំវិញបាន ។ ពាក្យថា តែបើភិក្ខុនោះមានហេតុអ្វីមួយល្មមឲ្យនៅប្រាសចាកចីវរនោះបាន គឺមានហេតុមានកិច្ចដែលត្រូវធ្វើ ។ ពាក្យថា ភិក្ខុនោះគប្បីនៅប្រាសចាកចីវរនោះយ៉ាងយូរត្រឹម ៦ រាត្រី គឺ ភិក្ខុគប្បីនៅប្រាសចាកត្រឹម ៦ រាត្រីជាយ៉ាងយូរ ។ ពាក្យថា វៀរលែងតែភិក្ខុដែល

បានសេចក្តីសម្មតិអំពីសង្ឃ គឺ លើកទុកតែភិក្ខុ ដែលបានសេចក្តីសម្មតិអំពីសង្ឃ ។ ពាក្យថា បើនៅប្រាសចាកឲ្យហួសពីកំណត់នោះទៅ មានអធិប្បាយថា កាលអរុណរះឡើងក្នុងថ្ងៃទី ៧ ចីវរនោះជានិស្សគ្គិយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំនេះ ដែលខ្ញុំនៅប្រាសហើយអស់កាលជាង ៦ រាត្រី ជានិស្សគ្គិយព្រោះមិនមានភិក្ខុសម្មតិ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។បេ។ ពាក្យតអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។

[ ១៦៧ ] ចីវរកន្លងហួសជាង ៦ រាត្រី ភិក្ខុសម្គាល់ថា ហួសជាងហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែលកន្លងហួស ៦ រាត្រីហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ចីវរកន្លងហួស ៦ រាត្រី ភិក្ខុសម្គាល់ថា នៅខ្វះ ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ចីវរដែលភិក្ខុមិនទាន់បានដកអធិដ្ឋាន ភិក្ខុសម្គាល់ថា បានដកអធិដ្ឋានហើយ ( ក្តី ) ចីវរដែលភិក្ខុមិនទាន់បានលះបង់ទេ សម្គាល់ថា បានលះបង់ហើយ ( ក្តី ) ចីវរមិនបាត់ទេ ភិក្ខុសម្គាល់ថា បាត់ទៅហើយ ( ក្តី ) ចីវរមិនវិនាសទេ ភិក្ខុសម្គាល់ថា វិនាសទៅហើយ ( ក្តី ) ចីវរភ្លើងមិនឆេះទេ ភិក្ខុសម្គាល់ថា ភ្លើងឆេះហើយ ( ក្តី ) ចីវរដែលចោរ មិនបានលួចយកទេ

ភិក្ខុសម្គាល់ថា ចោរលួចយកទៅហើយ ( ក្តី ) បើនៅប្រាសចាក ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុ ដែលបានសម្មតិអំពីសង្ឃ ។ ភិក្ខុមិនលះបង់ចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី តែភិក្ខុសម្គាល់ថាលើសហើយ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី ភិក្ខុសម្គាល់ថា មិនទាន់ដល់ ៦ រាត្រី មិនត្រូវអាបត្តិ ។

[ ១៦៨ ] អាបត្តិមិនមានដល់ភិក្ខុដែលនៅប្រាសចាកចីវរត្រឹម ៦ រាត្រី ដល់ភិក្ខុដែលនៅប្រាសចាកខ្វះពី ៦ រាត្រីចុះមក ដល់ភិក្ខុដែលនៅប្រាសចាក ៦ រាត្រី ហើយត្រឡប់មកកាន់ដែនស្រុកនោះវិញ ឈប់នៅកន្លែងណាមួយ ហើយចៀសចេញទៅ ដល់ភិក្ខុដកអធិដ្ឋាន ( ក្តី ) លះបង់ ( ក្តី ) ក្នុង ៦ រាត្រីចុះមក ចីវរបាត់ទៅ ( ក្តី ) វិនាសទៅ ( ក្តី ) ភ្លើងឆេះ ( ក្តី ) ចោរដណ្តើមយកទៅ ( ក្តី ) សហធម្មិកកាន់យកទៅដោយស្និទ្ធស្នាល ( ក្តី ) ក្នុង ៦ រាត្រីចុះមក ដល់ភិក្ខុដែលបានសម្មតិ ( អំពីសង្ឃ ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា
# បត្តវគ្គ សិក្ខាបទទី ៩
# សាសង្កសិក្ខាបទ

[ ១៦៥ ] សាសង្កសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលក្នុងសាសង្កសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះថា ពីរបទថា **វុដ្ឋវស្សា អារញ្ញកេសុ** សេចក្តីថា ភិក្ខុទាំងឡាយនោះ សូម្បីកាលមុនក៏នៅក្នុងព្រៃដូចគ្នា ។ តែភិក្ខុទាំងនោះ នៅចាំវស្សាក្នុងសេនាសនៈជិតស្រុកភូមិ ដោយអំណាចនៃបច្ច័យ ព្រោះជាអ្នកមានចីវរទុព្វល ជាអ្នកមានចីវរសម្រេចហើយ ពិភាក្សាគ្នាថា ឥឡូវនេះ ពួកយើងអស់បលិពោធហើយ នឹងធ្វើសមណធម៌ ទើបនាំគ្នានៅក្នុងសេនាសនៈព្រៃ ។

បទថា **កត្តិកចោរកា** បានដល់ ពួកចោរក្នុងខែកត្តិក ។

បទថា **បរិបាតេន្តិ** សេចក្តីថា រមែងបៀតបៀន គឺវត់ខាត់ខ្វែងទៅមកក្នុងទីនោះ ហើយធ្វើឲ្យភ័យខ្លាច ឲ្យគេចទៅ ។

ពីរបទថា **អន្តរឃរេ និក្ខិបិតុំ** បានដល់ ដើម្បីទុកដាក់ខាងក្នុងស្រុក ។

ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យទុកដាក់ក្នុងចន្លោះស្រុក ដើម្បីរក្សាចីវរទុក ព្រោះធម្មតាថា បច្ច័យទាំងឡាយជារបស់រកបានលំបាក ដោយត្រឹមត្រូវតាមធម៌ ពិតហើយ ភិក្ខុអ្នកមានការជុសខាត់ មិនអាចដើម្បីនឹងសូមចីវរសូម្បីនឹងមាតា ។ តែព្រះអង្គទ្រង់មិនហាមការនៅព្រៃ ព្រោះជាការសមគួរដល់ភិក្ខុទាំងឡាយ ។

ក្នុងបទថា **ឧបវស្សំ ខោ បន** នេះ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **ឧបវស្សំ** គឺចូលហើយ មានពាក្យអធិប្បាយថា ចូលចាំវស្សាហើយ ។ ពិតហើយ បណ្ឌិតគប្បីឃើញនិគ្គហិត ក្នុងពាក្យថា **ឧបវស្សំ** នេះ ដូចក្នុងបទ មានបទថា **ឧបសម្បជ្ជំ** ជាដើម ។ សេចក្ដីថា ចូលដល់រដូវភ្លៀងនិងនៅហើយ ( ចូលចាំវស្សា និងបវារណាហើយ ) ។ បទថា **ឧបវស្សំ** នេះ សម្ពន្ធដោយបទនេះថា **តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ** ប្រែថា ភិក្ខុនៅក្នុងសេនាសនៈ ដែលមានសភាពបែបនោះ ។

លោកអធិប្បាយទុកដូចម្ដេច លោកពោលទុកថា ភិក្ខុចូលដល់រដូវភ្លៀងនិងនៅហើយ ( ចូលវស្សា និងបវារណាហើយ ) និងនៅក្នុងសេនាសនៈព្រៃដែលគេសន្មតថា ជាទីរង្កៀស មានភ័យចំពោះមុខបែបនោះ អស់កាលជាទីបំផុតនៃថ្ងៃ ១៥ កើតបច្ឆិមកត្តិក បន្ទាប់អំពីនោះមក កាលប្រាថ្នា គប្បីទុកចីវរ ៣ ផ្ទាំង ផ្ទាំងណាមួយក្នុងចន្លោះស្រុក បាន ។

ម្យ៉ាងទៀត ព្រោះថា ភិក្ខុណាចូលចាំវស្សាហើយ នៅរហូតដល់ថ្ងៃ ១៥ កើតខែបឋមកត្តិក ភិក្ខុអង្គនោះ ជាអ្នកនៅខាងក្នុងនៃពួកភិក្ខុដែលនៅចាំវស្សាហើយ ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់មិនធ្វើការពិចារណាព្យញ្ជនៈ ដែលស្មុគស្មាញក្រៃលែងនេះ សម្ដែងបុគ្គលដែលគួរដល់ការទុកដាក់ចីវរតែម្យ៉ាងក្នុងបទភាជនៈ ទើបត្រាស់បទថា **វុដ្ឋវស្សានំ** ដូច្នេះ ។ សូម្បីបទថា **វុដ្ឋ-វស្សានំ** នោះ ក៏សម្ពន្ធនឹងពាក្យនេះថា **ភិក្ខុ សេនាសនេសុ វិហរន្តោ** ភិក្ខុកាលនៅក្នុងសេនាសនៈ ។ ពិតហើយ ក្នុងបទថា **វុដ្ឋវស្សានំ** នេះ មាន

អត្ថដូច្នេះថា នៅក្នុងសេនាសនៈទាំងឡាយរបស់ពួកភិក្ខុដែលនៅចាំវស្សាហើយ ។ មានពាក្យអធិប្បាយថា ភិក្ខុណាមួយ នៅខាងក្នុងនៃភិក្ខុទាំងឡាយដែលមានសភាពបែបនេះ ។ លក្ខណៈនៃព្រៃ ខ្ញុំបានពោលហើយក្នុងការពណ៌នានៃអទិន្នាទានសិក្ខាបទ ។ ឯសេចក្តីប្លែកគ្នា មានដូចតទៅនេះថា បើវត្តមានរបងគប្បីវាស់តាំងអំពីសសរខឿននៃស្រុកដែលមានរបង និងអំពីទឹកខ្ទេងដែលគួរព័ទ្ធរបងនៃស្រុកដែលមិនមានរបងទៅ រហូតដល់របងវត្ត ។ បើជាវត្តដែលមិនបានព័ទ្ធរបង ទីកន្លែងណា ជាកន្លែងជំបូងគេបង្អស់ ទោះជាសេនាសនៈក្តី រោងឆាន់ក្តី ទីប្រជុំប្រចាំក្តី ដើមពោធិ៍ក្តី ចេតិយក្តី បើមាននៅឆ្ងាយអំពីសេនាសនៈ គប្បីវាស់យកទីនោះ ឲ្យជាដែនកំណត់ ។

បើមានស្រុកនៅជិត ពួកភិក្ខុនៅឯវត្ត រមែងបានឮសំឡេងរបស់ពួកអ្នកស្រុក តែមិនអាចទៅផ្លូវត្រង់បាន ព្រោះមានភ្នំ និងស្ទឹងជាដើមរាំងហើយផ្លូវណាជាផ្លូវប្រក្រតីរបស់ស្រុកនោះ សូម្បីនឹងត្រូវទៅដោយទូក ក៏គប្បីកំណត់យកទី ៥០០ ធ្នូរផ្លូវអំពីស្រុកដោយផ្លូវនោះ ។ តែភិក្ខុណាបិទរាំងផ្លូវក្នុងទីនោះៗ ដើម្បីញុំាងស្រុកជិតឲ្យដល់ព្រមដោយអង្គ ភិក្ខុនេះគប្បីជ្រាបថា ជាចោរធុតង្គ ។

បទថា **សាសង្កសម្មតានិ** ប្រែថា ដែលគេសន្មតថា ជាទីមានរង្កៀស អធិប្បាយថា ដែលគេសន្មតហើយយ៉ាងនោះ ។ តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងការណ៍ជាហេតុឲ្យសេនាសនៈទាំងនោះ ដែលគេសន្មតថា ជាទីមានរង្កៀស ទើបត្រាស់បទថា **អារាមេ អារាមូបចារេ** ជាដើម ។ សេនាសនៈដែល

ប្រព្រឹត្ត ទៅដោយភ័យចំពោះមុខ ឈ្មោះថា **សបដិភយ** អធិប្បាយថា មានភ័យខ្លាំងក្លានៅចំពោះមុខ ។ តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងការណ៍ ជាហេតុឲ្យសេនាសនៈទាំងនោះ ជាទីមានភ័យចំពោះមុខ ទើបត្រាស់បទថា **អារាមេ អារាមូបចារេ** ជាដើម ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃសាសង្កសិក្ខាបទ

[ ១៦៦ ] បទថា **សមន្តា គោចរគាមេ និក្ខិបេយ្យ** សេចក្តីថា កាលមានអង្គគ្រប់ គប្បីទុកដាក់ក្នុងគោចរគាមដែលខ្លួនពេញចិត្តគ្រប់ទិសាភាគ ដោយជុំវិញនៃសេនាសនៈ ។

ក្នុងសេនាសនៈព្រៃនោះ មានអង្គសម្បត្តិដូចតទៅនេះថា ភិក្ខុចូលវស្សា ក្នុងថ្ងៃចូលវស្សាដំបូង បវារណាក្នុងថ្ងៃមហាបវារណា នេះជាអង្គ ១ ។ បើភិក្ខុចូលវស្សា ក្នុងថ្ងៃចូលវស្សាក្រោយក្តី មានវស្សាដាច់ក្តី រមែងមិនបាន ដើម្បីនឹងទុកដាក់ ។ ជាខែកត្តិកប៉ុណ្ណោះ នេះជាអង្គទី ២ ។ ក្រៅអំពីខែកត្តិក ទៅ រមែងមិនបានដើម្បីនឹងទុកដាក់ ។ ជាសេនាសនៈដែលប្រកបដោយប្រមាណយ៉ាងជិត ៥០០ ធ្នូវត្ថុប៉ុណ្ណោះ នេះជាអង្គទី ៣ ។ ក្នុងសេនាសនៈដែលមានចម្ងាយជិតជាងនេះ ឬមានចម្ងាយលើសមួយគាវុតទៅ រមែងមិនបាន ( ដើម្បីនឹងទុកដាក់ ) ។ ពិតហើយ ភិក្ខុដែលត្រាច់បិណ្ឌបាត ហើយអាចត្រឡប់មកកាន់វត្តទាន់ពេលឆាន់ ក្នុងសេនាសនៈណា សេនាសនៈនោះ ទ្រង់បំណងយកក្នុងសិក្ខាបទនេះ។ តែភិក្ខុដែលទទួលនិមន្តទុក ទៅអស់ចម្ងាយ

ផ្លូវដល់កន្លះយោជន៍ខ្លះ មួយយោជន៍ខ្លះ ហើយត្រឡប់មកដើម្បីនឹងនៅ ។ នេះមិនជាប្រមាណឡើយ ។ ជាសេនាសនៈដែលមានការរង្កៀស និងមានភ័យចំពោះមុខប៉ុណ្ណោះ នេះជាអង្គទី ៤ ។ ពិតហើយ ភិក្ខុដែលនៅក្នុងសេនាសនៈមិនមានសេចក្តីរង្កៀស មិនមានភ័យចំពោះមុខ សូម្បីប្រកបដោយអង្គ ក៏មិនបានដើម្បីនឹងទុកដាក់ ដូច្នេះឯង ។

ពីរបទថា **អញ្ញត្រ ភិក្ខុសម្មតិយា** សេចក្តីថា វៀរទុកតែកោសម្ពិកសម្មតិដែលទ្រង់អនុញ្ញាតទុកក្នុងឧទ្ទេសិតសិក្ខាបទ ។ បើមានភិក្ខុណាសន្មតនោះសោត នឹងនៅប្រាសចាកលើស ៦ រាត្រីទៅក៏គួរ ។

[ ១៦៨ ] បទថា **បុន គាមសីមំ ឱក្កមិត្វា** សេចក្តីថា បើមានសេនាសនៈនៅទិសខាងកើតអំពីគោចរគ្រាម ហើយភិក្ខុនេះនឹងទៅកាន់ទិសខាងលិច លោកមិនអាចមកកាន់សេនាសនៈឲ្យទាន់អរុណទី ៧ វះ គៀងចូលកាន់គាមសីមា ស្នាក់នៅក្នុងសភា ឬក្នុងទីណាទីមួយ ជ្រាបដំណឹងកាលនៃចីវរហើយ ទើបចៀសទៅ គួរ ។

ភិក្ខុដែលមិនអាចយ៉ាងនោះ គប្បីឈរក្នុងទីដែលទៅហើយនោះឯង បច្ចុទ្ធ ( ដក ) ចោល ។ ចីវរនឹងតាំងនៅក្នុងឋានៈនៃអតិរេកចីវរ ដូច្នេះឯង ពាក្យដ៏សេសក្នុងសិក្ខាបទនេះ រាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានកឋិនជាសមុដ្ឋាន កើតឡើងតាមកាយ និងវាចា ១ តាមកាយវាចានិងចិត្ត ១ ជាអកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សាសង្កសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[ ១៦៩ ] សម័យនោះ ព្រះពុទ្ធដ៏មានយសជាម្ចាស់ កាលគង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯងមានប្រជុំជនមួយពួក ក្នុងក្រុងសាវត្ថីតាក់តែងកត្ត ព្រមទាំងចីវរ ប្រគេនដល់សង្ឃ ដោយសេចក្តីព្រមព្រៀងគ្នាថា ពួកយើងនឹងនិមន្តឲ្យសង្ឃឆាន់ហើយប្រគេនចីវរឲ្យគ្រង ។ លំដាប់នោះ ពួកភិក្ខុឆព្វគ្គិយចូលទៅរកប្រជុំជនពួកនោះលុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងប្រជុំជនពួកនោះថា នែអ្នកមានអាយុទាំងឡាយ ពួកអ្នកឯងចូរប្រគេនចីវរទាំងនេះមកពួកអាត្មាចុះ ។ ជនពួកនោះនិយាយថា លោកម្ចាស់ ពួកខ្ញុំករុណាមិនបានប្រគេនទេ ឯចង្ហាន់ព្រមទាំងចីវរ ពួកខ្ញុំករុណាធ្លាប់ចាត់ចែងទុកប្រគេនដល់សង្ឃតែរាល់ឆ្នាំ ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា នែអាវុសោ ពួកទាយករបស់សង្ឃក៏មានច្រើន ចង្ហាន់របស់សង្ឃក៏មានច្រើន ពួកយើងអាស្រ័យពឹងពាក់នឹងអ្នកទាំងឡាយ ទើបនៅក្នុងទីនេះបាន បើអ្នកទាំងឡាយមិនឲ្យមកពួកអាត្មា អ្នកណាហ្ន៎ គេនឹងឲ្យដល់ពួកអាត្មា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកចូរឲ្យចីវរទាំងនេះមកពួកអាត្មាចុះ ។ លំដាប់នោះ ប្រជុំជនពួកនោះ កាលបើពួកឆព្វគ្គិយភិក្ខុនិយាយគ្គិះគ្នៀលណាស់ទៅ ទើបប្រគេនចីវរដែលខ្លួនតាក់តែងទាំងប៉ុន្មាន ទៅពួកឆព្វគ្គិយភិក្ខុ ហើយអង្គាសសង្ឃដោយចង្ហាន់ ( តែម្យ៉ាង ) ។ ពួកភិក្ខុណាដឹងថា ចង្ហាន់ព្រមទាំងចីវរដែលគេតាក់តែងទុកសម្រាប់ប្រគេនសង្ឃ តែមិនដឹងថា ចីវរគេប្រគេនដល់ពួកភិក្ខុឆព្វគ្គិយទៅហើយ ភិក្ខុទាំងនោះ ទើបពោល

យ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកចូរវេរប្រគេនចីវរ ដល់សង្ឃទៅ ។ ឯប្រជុំជនពួកនោះឆ្លើយថា បពិត្រលោកម្ចាស់ទាំងឡាយ ចីវរដែលគាត់តែងទុកប្រគេនសង្ឃគ្មានទេ ( ព្រោះ ) ពួកភិក្ខុឆព្វគ្គិយបង្អោនទៅ ដើម្បីខ្លួនលោកអស់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយដឹងថាលាភគេបង្អោនទៅដើម្បីសង្ឃហើយ ហេតុអ្វី បានជាត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ។ លំដាប់នោះ ពួកភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯង ដឹងថាលាភគេបង្អោនទៅដើម្បីសង្ឃហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោសការនោះ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់បន្ទោសថា នែពួកមោឃបុរស ពួកអ្នកឯងដឹងថា លាភគេបង្អោនទៅដើម្បីរបស់សង្ឃហើយ ចុះហេតុអ្វី បានជាបង្អោនមកដើម្បីខ្លួនវិញ នែពួកមោឃបុរស ដំណើរនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយកាលដឹងហើយ បង្អោននូវលាភរបស់សង្ឃ ដែលគេនឹងបង្អោនទៅ ( ដើម្បីសង្ឃ ) មកដើម្បីខ្លួនវិញ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[ ១៧០ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទបឋម

បារាជិករួចហើយ ។ ដែលហៅថា ដឹង ( ក្នុងសិក្ខាបទនេះ ) គឺដឹងខ្លួនឯងក្តី អ្នកដទៃមកប្រាប់ភិក្ខុនោះក្តី អ្នកម្ចាស់ទាននោះមកប្រាប់ ( ដល់ភិក្ខុនោះ ) ក្តី ។ ដែលហៅថារបស់សង្ឃនោះ គឺទាយកបានវេរប្រគេនបរិច្ចាគដល់សង្ឃហើយ ។ ដែលហៅថា លាភនោះ បានដល់ ចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សជំងឺ ដោយហោចទៅ ដុំនៃលម្អិតក្តី ឈើស្ទន់ក្តី អំបោះវេងជើងក្តី ក៏ហៅថាលាភដែរ ។ ដែលហៅថា បង្អោននោះ គឺម្ចាស់ទានបញ្ចេញវាចាថា ពួកយើងនឹងឲ្យ ពួកយើងនឹងធ្វើ ។ ភិក្ខុបង្អោន ( លាភ ) មកដើម្បីខ្លួន ត្រូវអាបត្តិទុក្កដតាមប្រយោគ ។ លាភនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំដឹងថា លាភនេះ ទាយកបង្អោនទៅដើម្បីរបស់សង្ឃហើយ ខ្ញុំត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ( លាភនេះ ) ជានិស្សគ្គិយ ខ្ញុំសូមលះបង់លាភនេះដល់សង្ឃ ។បេ។ ពាក្យតអំពីនេះទៅមាន សេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។ ភិក្ខុសម្គាល់ក្នុងលាភដែលទាយកបានបង្អោនហើយ ថាទាយកបានបង្អោនមកមែន ហើយបង្អោនមកដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងលាភដែលទាយកបានបង្អោនទៅហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងលាភ ដែលទាយកបានបង្អោនទៅហើយ ថាមិនទាន់បង្អោនទៅទេ ត្រឡប់បង្អោនមកដើម្បីខ្លួន មិនត្រូវអាបត្តិ ។ លាភដែលទាយក បង្អោនទៅ

ដើម្បីសង្ឃហើយ ភិក្ខុបង្អោនទៅដើម្បីសង្ឃដទៃក្តី ដើម្បីចេតិយក្តី ត្រូវអាបត្តិទុក្កដ ។ លាភដែលទាយកបង្អោនទៅដើម្បី ចេតិយហើយ ភិក្ខុត្រឡប់បង្អោនទៅដើម្បីចេតិយដទៃក្តី សង្ឃក្តី គណៈក្តី បុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ លាភដែលទាយកបង្អោនទៅដើម្បីបុគ្គល ភិក្ខុត្រឡប់បង្អោនទៅដើម្បី បុគ្គលឯទៀតក្តី សង្ឃក្តី គណៈក្តី ចេតិយក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងលាភ ដែលទាយកបានបង្អោនទៅហើយ ថាបានបង្អោនទៅហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងលាភ ដែលទាយកមិនបានបង្អោនទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងលាភ ដែលគេមិនបានបង្អោនទៅ ថាគេមិនបានបង្អោនទៅ មិនត្រូវអាបត្តិឡើយ ។

[ ១៧១ ] អាបត្តិមិនមានដល់ភិក្ខុដែលទាយកគេសួរថា យើងទាំងឡាយនឹងវេរប្រគេនក្នុងទីណា ហើយប្រាប់គេថា ទេយ្យធម៌របស់អ្នកទាំងឡាយ គួរបាននូវការបរិភោគក្តី គួរបាននូវការជួសជុលក្តី គួរតាំងនៅអស់កាលដ៏យូរក្តីក្នុងទីណា ម្យ៉ាងទៀត បើចិត្តរបស់អ្នកទាំងឡាយជ្រះថ្លាក្នុងទីណា អ្នកទាំងឡាយចូរវេរប្រគេនក្នុងទីនោះៗចុះ ដល់ភិក្ខុឧបចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

បត្តវគ្គទី ៣ ចប់

ចំនួនសិក្ខាបទក្នុងបត្តវគ្គនោះ គឺ

សិក្ខាបទទី ១-២ និយាយអំពីបាត្រ សិក្ខាបទទី ៣ និយាយអំពីថ្នាំ សិក្ខាបទទី ៤ និយាយអំពីសំពត់ងូតទឹកភ្លៀង សិក្ខាបទទី ៥ និយាយអំពីការឲ្យចីវរ សិក្ខាបទទី ៦ និយាយអំពីការសូមអំបោះគេមកខ្លួនឯង សិក្ខាបទទី ៧ និយាយអំពីការប្រើគេឲ្យត្បាញ សិក្ខាបទទី ៨ និយាយអំពីអច្ចេកចីវរ សិក្ខាបទទី ៩ និយាយអំពីទីមានសេចក្តីរង្កៀស សិក្ខាបទទី ១០ និយាយអំពីការបង្អោនលាភរបស់សង្ឃ ។

[១៧២] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយ បរិសុទ្ធហើយឬ ខ្ញុំសួរជាគម្រប់ពីរដងផង លោកទាំងឡាយបរិសុទ្ធហើយឬ ខ្ញុំសួរជាគម្រប់បីដងផង លោកទាំងឡាយបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនេះបានជានៅស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

និស្សគ្គិយកណ្ឌ ចប់

# អដ្ឋកថា

## បត្តវគ្គទី ៣ សិក្ខាបទទី ១០

## បរិណតសិក្ខាបទ

[ ១៦៩ ] *បរិណតសិក្ខាបទ បទថា* **តេន សមយេន** *ជាដើម ខ្ញុំនឹងពោលក្នុងបរិណតសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះថា បទថា* **បូគស្ស** *ប្រែថា ពួកក្រុម សេចក្តីថា ពួកអ្នកបំពេញធម៌ ។*

*បទថា* **បដិយត្តំ** *ប្រែថា តាក់តែងហើយ ។*

*ដោយបទថា* **ពហូ សង្ឃស្ស ភត្តា** *នេះ ពួកឆព្វគ្គិយភិក្ខុ រមែងសម្តែងអត្ថថា សង្ឃមានភត្តជាច្រើន គឺមានផ្លូវកើតលាភមិនមែនតិច សង្ឃមិនខ្វះខាតដោយអ្វីមួយឡើយ ។*

*បទថា* **ឱណោជេថ** *ប្រែថា ពួកអ្នកចូរប្រគេន ។*

*សួរថា ការដែលភិក្ខុពោលយ៉ាងនេះ គួរឬទេ ឆ្លើយថា ព្រោះហេតុអ្វីដែលថា មិនគួរ ព្រោះថា ភត្តដែលគេនាំមកចំពោះនេះ ជារបស់ដែលគេនាំមកតាក់តែងទុក ដើម្បីប្រយោជន៍ដល់សង្ឃក្នុងសម័យមួយ ។ ធម្មតាបយុត្តវាចា ( ការហាមាត់សូម ) រមែងមិនមានក្នុងបច្ច័យ មានចីវរជាដើម ដែលគេនាំមកបម្រុងទុក និងក្នុងចំណែកដែលគេឧទ្ទិសចំពោះទុក ។*

# អធិប្បាយ

## សិក្ខាបទវិភង្គនៃបរិណតសិក្ខាបទ

[ ១៧០ ] បទថា **សង្ឃិកំ** ប្រែថា របស់សង្ឃមាន ។ ពិតហើយ លាភនោះ សូម្បីមិនទាន់ដល់ដៃ ក៏រាប់ថា ជារបស់សង្ឃដោយបរិយាយមួយ ព្រោះគេបង្អោនទៅដើម្បីសង្ឃហើយ តែក្នុងបទភាជនៈ ព្រះឧបាលីសម្តែង លាភនៃសង្ឃដោយត្រង់នោះឯង ដោយអំណាចការពន្រឹកសេចក្តីយ៉ាងនេះថា ដែលឈ្មោះថា របស់សង្ឃ បានដល់ របស់ដែលគេប្រគេនហើយ បរិច្ចាគ ហើយដល់សង្ឃ ។

ព្រះមានព្រះភាគ ត្រាស់វត្ថុដែលសង្ឃគួរបាន ដោយបទថា **លាភំ** ។ ដោយហេតុនោះឯង ក្នុងនិទ្ទេសនៃបទថា **លាភំ** នោះ ទើបត្រាស់បទថា **ចីវរំបិ** ជាដើម ។

បទថា **បរិណតំ** បានដល់ ដែលគេប្រគេនសង្ឃ គឺដែលគេតាំងទុក ជារបស់បង្អោនទៅដើម្បីសង្ឃ ឧទ្ទិសទៅដើម្បីសង្ឃ ។ ដើម្បីទ្រង់សម្តែង ការណ៍ជាហេតុដែលគេបង្អោនលាភនោះទៅ ទើបព្រះមានព្រះភាគ ត្រាស់បទ ភាជនៈថា គឺ ដែលគេបន្ទឺវាចាថា ពួកខ្ញុំនឹងថ្វាយ នឹងធ្វើ ដូច្នេះ ។

ពីរបទថា **បយោគេ ទុក្កដំ** សេចក្តីថា ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ ដែលបង្អោនលាភ ដែលគេបង្អោនទៅ ( ដើម្បីសង្ឃ ) មកដើម្បីខ្លួន ។ ជា និស្សគ្គិយ ព្រោះបានមក គឺ ព្រោះលាភនោះដល់ដៃ ។ តែបើរបស់នោះ គឺ គេប្រគេនសង្ឃហើយ នឹងទទួលយករបស់ដែលគេប្រគេនសង្ឃហើយនោះមក មិនគួរ គប្បីប្រគេនដល់សង្ឃនោះឯង ។ បើភិក្ខុណាបន្ទំស៊ីជាមួយពួកអារា- មិកជន សង្ឃគប្បីវាយតម្លៃកណ្តះនោះ កាត់អាបត្តិដល់ភិក្ខុនោះ ។ តែជា

និស្សគ្គិយបាចិត្តិយដល់ភិក្ខុដែលដឹងថា លាភ គេបង្អោនទៅដើម្បីសង្ឃ ហើយបង្អោនលាភដែលគេបង្អោនទៅហើយ របស់ពួកសហធម្មិកក្តី របស់ពួកគ្រហស្ថក្តី ដោយហោចសូម្បីរបស់ម្តាយ មកដើម្បីខ្លួនថា អ្នកចូរឲ្យរបស់នេះដល់អាត្មា ហើយកាន់យក ។ ត្រូវអាបត្តិបាចិត្តិយសុទ្ធៗ ដល់ភិក្ខុដែលបង្អោនទៅដើម្បីអ្នកដទៃ យ៉ាងនេះថា អ្នកចូរឲ្យដល់ភិក្ខុនេះ ។ ភិក្ខុបង្អោនបាត្រមួយ ឬចីវរមួយផ្ទាំងមកដើម្បីខ្លួន បង្អោនបាត្រមួយ ឬចីវរមួយផ្ទាំង ដើម្បីអ្នកដទៃ ទាំងជានិស្សគ្គិយបាចិត្តិយផង ទាំងជាសុទ្ធិកបាចិត្តិយផង ។ ក្នុងបាត្រ និងចីវរច្រើន ក៏មានន័យនេះដូចគ្នា សេចក្តីនេះ សមដូចពាក្យដែលព្រះឧបាលិត្ថេរពោលទុកថា

> ភិក្ខុត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ និងសុទ្ធកបាចិត្តិយក្នុងខណៈជាមួយគ្នា ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

បញ្ហានេះ លោកពោលសំដៅយកការបង្អោន ( លាភ ) ។ ឯភិក្ខុណាដឹងថា សំពត់ងូតទឹកភ្លៀង គេបង្អោនទៅដើម្បីសង្ឃ សូម្បីក្នុងផ្ទះរបស់មាតា ក្នុងសម័យនៃសំពត់ងូតទឹកភ្លៀង ហើយបង្អោនយកទៅដើម្បីខ្លួន ជានិស្សគ្គិយដល់ភិក្ខុនោះ បង្អោនទៅដើម្បីអ្នកដទៃ ជាសុទ្ធិកបាចិត្តិយ ។ ពួកអ្នកស្រុកប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើសង្ឃភត្ត ទើបនាំសប្បិ និងប្រេងជាដើមមក ។ បើភិក្ខុអាពាធ ដឹងថា គេបង្អោនទៅដើម្បីប្រគេនសង្ឃហើយ នៅតែសូមវត្ថុណាមួយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយដូចគ្នា ។ បើភិក្ខុអាពាធ

នោះសួរថា សប្បិជាដើមរបស់ពួកអ្នកដែលនាំមក មានឬ កាលពួកទាយក ឆ្លើយថា មានលោកម្ចាស់ ហើយពោលថា ពួកអ្នកឲ្យដល់អាត្មាបានខ្លះ ដូច្នេះ គួរ ។ សូម្បីពួកឧបាសករង្កៀសភិក្ខុអាពាធនោះ ពោលថា សូម្បីសង្ឃ រមែងបានសប្បិជាដើម ដែលពួកខ្ញុំប្រគេននេះឯង ។ និមន្តលោកម្ចាស់ទទួល ចុះ សូម្បីយ៉ាងនេះ ក៏គួរ ។

បទថា **សង្ឃស្ស បរិណតំ អញ្ញសង្ឃស្ស** សេចក្ដីថា បង្អោនលាភ ដែលគេបង្អោនទៅដើម្បីប្រគេនសង្ឃក្នុងវត្តមួយក្ដី ដែលគេបង្អោនទៅចំពោះ វត្តដទៃក្ដី ដោយពោលថា ពួកអ្នកចូរប្រគេនដល់សង្ឃក្នុងវត្តឈ្មោះនោះ ។

បទថា **ចេតិយស្ស វា** សេចក្ដីថា បង្អោនទៅដើម្បីចេតិយយ៉ាងនេះថា ប្រគេនសង្ឃ មានប្រយោជន៍អ្វី ពួកអ្នកចូរធ្វើការបូជាដល់ព្រះចេតិយដូច្នេះក្ដី ។

ក្នុងបទថា **ចេតិយស្ស បរិណតំ** នេះ មានវិនិច្ឆ័យដូច្នេះថា សូម្បី នឹងបូជាផ្កាត្រង់ចេតិយដទៃអំពីដើមឈើផ្កា ដែលគេកំណត់ដាំទុកដើម្បីប្រយោជន៍ ដល់ចេតិយដទៃ ក៏មិនគួរ តែឃើញឆត្រ ឬទង់ជ្វាលា ដែលគេបូជាទុក ដល់ចេតិយមួយ ហើយឲ្យបូជារបស់ដ៏សេសដល់ចេតិយដទៃ គួរ ។

ពីរបទថា **បុគ្គលស្ស បរិណតំ** សេចក្ដីថា ដោយហោចសូម្បីអាហារ ដែលគេបង្អោនទៅដើម្បីឆ្កែ ភិក្ខុបង្អោនទៅដើម្បីឆ្កែដទៃ យ៉ាងនេះថា អ្នកកុំ ឲ្យដល់ឆ្កែឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ តែបើពួកទាយកពោលថា ពួកខ្ញុំចង់ប្រគេនកត្ដដល់សង្ឃ ចង់បូជាព្រះចេតិយ ។ ចង់ប្រគេនបរិក្ខារដល់ ភិក្ខុមួយអង្គ នឹងប្រគេនតាមការពេញចិត្ត របស់ពួកលោកម្ចាស់ សូមលោក

ម្ចាស់ប្រាប់មកចុះ ពួកខ្ញុំនឹងប្រគេនក្នុងទីណា កាលពួកទាយកពោលយ៉ាងនេះហើយ ភិក្ខុនោះ គប្បីប្រាប់ពួកទាយកថា ពួកអ្នកចូរប្រគេនក្នុងទីដែលពួកអ្នកប្រាថ្នាចុះ ។ តែបើពួកទាយកសួរតែម្យ៉ាងថា ពួកខ្ញុំនឹងប្រគេនក្នុងទីណា ភិក្ខុគប្បីពោលតាមន័យដែលមកហើយ ក្នុងបាលីនោះឯង ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ពាក់ទាំងអស់ហើយ ។

សិក្ខាបទនេះមានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត មានវេទនា ៣ ដូច្នេះ ។

បរិណតសិក្ខាបទវណ្ណនា ក្នុងអដ្ឋកថាព្រះវិន័យ

ឈ្មោះ សមន្តប្បាសាទិកា ចប់

តឹសកណ្ឌ ចប់

# វិនយបិដក

## បាចិត្តិយកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយ ៩២ ទាំងនេះឯង តែងមកកាន់ឧទ្ទេស ។

## មុសាវាទវគ្គ សិក្ខាបទទី ១

[ ១៧៣ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ព្រះអង្គគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ហត្ថកភិក្ខុជាសក្យបុត្រ ជាអ្នកហុចពាក្យសម្តី ។ ហត្ថកភិក្ខុនោះ ចរចាជាមួយនឹងតិរ្ថិយទាំងឡាយ គេចកែសម្តីហើយ ទទួលដឹងហើយ ទទួលដឹងហើយ ត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ ។ តិរ្ថិយទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាហត្ថកភិក្ខុជាសក្យបុត្រ ពោលចរចាជាមួយនឹងយើងទាំងឡាយ គេចកែសម្តីហើយទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយពោលឲ្យខុសពីកំណត់នោះវិញ ។ ភិក្ខុទាំងឡាយ បានឮតិរ្ថិយទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុទាំងនោះ ចូលទៅរកហត្ថកភិក្ខុជាសក្យបុត្រ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងហត្ថកភិក្ខុជាសក្យបុត្រថា ម្នាលអាវុសោហត្ថកៈ បានឮថា អ្នកពោលចរចា

មួយអន្លើដោយ តិរ្ថិយទាំងឡាយ គេចកែសម្តីហើយទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហក ដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ មែនឬដូចម្តេច ។ ហត្ថកភិក្ខុឆ្លើយថា ម្នាលអាវុសោ ធម្មតាតិរ្ថិយទាំងឡាយនុ៎ះ ត្រូវតែបុគ្គលឯណានីមួយផ្ចាញ់ផ្ចាលចេញ មិនត្រូវឲ្យការឈ្នះទៅតិរ្ថិយទាំង-ឡាយនោះទេ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំង-ឡាយនោះពោលទោសតិះដៀល បន្ទុះបន្អាប់ថា ចុះហេតុអ្វី បានជាហត្ថកភិក្ខុ ជាសក្យបុត្រពោលចរចាមួយអន្លើដោយតិរ្ថិយទាំងឡាយ គេចកែសម្តីហើយ ទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ និយាយពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ ។ ទើបភិក្ខុទាំងឡាយនោះ យកសេចក្តីនោះ ក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះហត្ថកភិក្ខុជាសក្យបុត្រ ក្នុងពេលនោះថា ម្នាលហត្ថកភិក្ខុ បានឮថា អ្នកពោលចរចាមួយអន្លើដោយតិរ្ថិយទាំងឡាយ គេចកែសម្តីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ តើពិតមែនឬ ។ ហត្ថកភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នែបុរសទទេ ចុះហេតុអ្វីបានជា

អ្នកឯងពោលចរចាមួយអន្ទើដោយត្រិយទាំងឡាយ គេចកែសម្តីហើយទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសម្តីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ នៃមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លា ឬថា នឹងនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

[១៧៤] ដែលហៅថា ពោលពាក្យកុហកដោយដឹងខ្លួននោះ បានដល់វាចា សម្តី គន្លងពាក្យ វចីភេទ វិញ្ញត្តិ ប្រព្រឹត្តទៅក្នុងវាចារបស់បុគ្គល ដែលធ្វើគំនិតនឹងពោលឲ្យខុសជាប្រធាន និងវោហារមិនមែនរបស់ព្រះអរិយៈ ៨ យ៉ាង គឺ ការដែលមិនបានឃើញនិយាយថា អញឃើញ ១ មិនឮ និយាយថា អញឮ ១ មិនបានពាល់ត្រូវ និយាយថា អញបានពាល់ត្រូវ ១ មិនដឹងច្បាស់ និយាយថា អញបានដឹងច្បាស់ ១ ឃើញនិយាយថា អញមិនឃើញ ១ ឮ និយាយថា អញមិនឮ ១ បានពាល់ត្រូវ និយាយថា អញមិនបានពាល់ត្រូវ ១ ដឹងច្បាស់ និយាយថា អញមិនដឹងច្បាស់ ១ ។

[១៧៥] ដែលហៅថា មិនឃើញ គឺ មិនឃើញដោយភ្នែក ។ ដែលហៅថា មិនឮ គឺ មិនឮដោយត្រចៀក ។ ដែលហៅថា មិនពាល់ត្រូវ គឺ មិនហិតដោយច្រមុះ មិនលិទ្ធដោយអណ្តាត មិនប៉ះពាល់ដោយកាយ ។ ដែលហៅថា មិនដឹងច្បាស់ គឺ មិនដឹងច្បាស់ដោយចិត្ត ។ ដែលហៅថា ឃើញ

គឺ ឃើញដោយភ្នែក ។ ដែលហៅថា ឮ គឺ ឮដោយត្រចៀក ។ ដែលហៅថា ពាល់ត្រូវ គឺ ហិតដោយច្រមុះ លិទ្ធដោយអណ្តាត ប៉ះពាល់ដោយកាយ ។ ដែលហៅថា ដឹងច្បាស់ គឺ ដឹងច្បាស់ដោយចិត្ត ។

[ ១៧៦ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញដូច្នេះ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញ ដោយអាការ ៤ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ[១] ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុ ដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៥ យ៉ាង គឺ មុននឹងពោល ដឹងថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនចំពោះវត្ថុដែលខ្លួនមិនឃើញ ថា អាត្មាឃើញ ដោយអាការ ៦ យ៉ាង គឺ មុននឹងពោល គិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោល

---

១- គឺលាក់បំបិទបំបាំងសេចក្តីឃើញខុសរបស់ខ្លួន ។

កុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តី គាប់ចិត្ត ១ បិទបាំងនូវសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៧ យ៉ាង គឺមុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោល ដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថាអញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលមិនឮថា អាត្មាឮ ។បេ។ វត្ថុដែលមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវ ។បេ។ កិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោល គិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ កិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ ដោយអាការ ៤ យ៉ាង ។បេ។ ៥ យ៉ាង ។បេ។ ៦ យ៉ាង ។បេ។ អាការ ៧ យ៉ាង គឺមុននឹងពោល គិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិ បាចិត្តិយ ។

[១៧៧] កិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ

ថាអាត្មាឃើញផង ថាអាត្មាឮផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញផង ថាអាត្មាពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញផង ថាអាត្មាដឹងច្បាស់ផង ដោយអាការ ៣ យ៉ាងត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញផង ឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮ ថាអាត្មាឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនមិនឮ ថាអាត្មាឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮ ថាអាត្មាឮផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮ ថាអាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮ ថាអាត្មាឮផង ពាល់ត្រូវផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុ

និយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮ ថាអាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនបានពាល់ត្រូវ ថាអាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវ ថាអាត្មាពាល់ត្រូវផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួន មិនបានពាល់ត្រូវ ថាអាត្មាពាល់ត្រូវផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវ ថាអាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវ ថាអាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវ ថាអាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ ថាអាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ ថាអាត្មាដឹងច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ ថា អាត្មាដឹងច្បាស់ផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ ថាអាត្មាដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ ថាអាត្មាដឹងច្បាស់ផង ឃើញផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួន មិនដឹងច្បាស់ ថាអាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង

ត្រូវអាបត្តិបាចិត្តិយ ។បេ។

[១៧៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានឃើញ ថាអាត្មាមិនឃើញ ដោយអាការ ៣ យ៉ាង គឺមុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនចំពោះវត្ថុដែលខ្លួនបានឃើញ ថាអាត្មាមិនឃើញ ដោយអាការ ៤ យ៉ាង ។បេ។ អាការ ៥ យ៉ាង ។បេ។ អាការ ៦ យ៉ាង ។បេ។ អាការ ៧ យ៉ាង គឺមុននឹងពោល គិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនបានឮ ថាអាត្មាមិនបានឮ ដោយអាការ ៣ យ៉ាង ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានពាល់ត្រូវ ថាអាត្មាមិនបានពាល់ត្រូវ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនបានដឹងច្បាស់ ថាអាត្មាមិនបានដឹងច្បាស់ ដោយអាការ ៣ យ៉ាង គឺមុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនដឹងច្បាស់ថាអាត្មាមិនដឹងច្បាស់ អាការ ៤ យ៉ាង ។បេ។ អាការ ៥ យ៉ាង ។បេ។

អាការ ៦ យ៉ាង ។បេ។ អាការ ៧ យ៉ាង មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោល ដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។

[១៧៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឃើញ ថាអាត្មាឮវិញ ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឃើញ ថាអាត្មាបានពាល់ត្រូវវិញ ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឃើញ ថាអាត្មាដឹងច្បាស់វិញ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឃើញ ថាអាត្មាឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឃើញ ថាអាត្មាឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឃើញ ថាអាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮ ថាអាត្មាពាល់ត្រូវ ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឮ ថាអាត្មាដឹងច្បាស់ ។បេ។ វត្ថុដែលខ្លួនឮ ថាអាត្មាឃើញ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮ ថាអាត្មាពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនឮ ថាអាត្មាពាល់ត្រូវផង ឃើញផង ។បេ។ វត្ថុដែលខ្លួនឮ ថាអាត្មាពាល់ត្រូវផង

ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនពាល់ត្រូវ ថាអាត្មាដឹងច្បាស់ ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនពាល់ត្រូវ ថាអាត្មាឃើញ ។បេ។ វត្ថុដែលខ្លួនពាល់ត្រូវ ថាអាត្មាឮ ។បេ។ វត្ថុដែលខ្លួនពាល់ត្រូវ ថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនពាល់ត្រូវ ថាអាត្មាដឹងច្បាស់ផង ឮផង ។បេ។ វត្ថុដែលខ្លួនពាល់ត្រូវ ថាអាត្មាដឹងច្បាស់ផង ឃើញផង ឮផង ។បេ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញ ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនដឹងច្បាស់ ថា អាត្មាឮ ។បេ។ វត្ថុដែលខ្លួនដឹងច្បាស់ ថាអាត្មាពាល់ត្រូវវិញ ។បេ។ វត្ថុដែលខ្លួនដឹងច្បាស់ ថាអាត្មាឃើញផង ឮផង ដោយអាការ ៣ យ៉ាង ។បេ។ វត្ថុដែលខ្លួនដឹងច្បាស់ ថាអាត្មាឃើញផង ពាល់ត្រូវផង ។បេ។ វត្ថុដែលខ្លួន ដឹងច្បាស់ ថាអាត្មាឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។បេ។

[១៨០] ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនឃើញ ( ក្តី ) មិនជឿវត្ថុដែលខ្លួនបានឃើញ ( ក្តី ) វេ្ញកមិនបានទូវវត្ថុដែលខ្លួនឃើញហើយ ( ក្តី ) ភ្លេចនូវវត្ថុដែលខ្លួនបានឃើញ ( ក្តី ) ហើយពោលពាក្យកុហក ដោយដឹងខ្លួន ថា អាត្មាឃើញផង ឮផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិ បាចិត្តិយ ។បេ។ ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួនថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងពាក្យដែលខ្លួនបានឮ ( ក្តី ) មិនជឿពាក្យដែលខ្លួន បានឮ ( ក្តី ) វេ្ញកមិនបាន

នូវពាក្យដែលខ្លួនបានឮ ( ក្តី ) ភ្លេចពាក្យដែល ខ្លួនឮហើយ ( ក្តី ) ។បេ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនបានពាល់ត្រូវ ( ក្តី ) មិនជឿវត្ថុដែលខ្លួនបានពាល់ត្រូវ( ក្តី ) វង្វេងមិនបាននូវវត្ថុដែលខ្លួនបានពាល់ត្រូវ ( ក្តី ) ភ្លេចវត្ថុដែលខ្លួនបានពាល់ត្រូវ ( ក្តី ) ។បេ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) មិនជឿ ហេតុដែលខ្លួនបានដឹងច្បាស់ ( ក្តី ) វង្វេងមិនបាននូវហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) ហើយពោលពាក្យ កុហកដោយដឹងខ្លួនថា អាត្មាអញដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។បេ។ ថាអាត្មាដឹងច្បាស់ផង ឮផង ។បេ។ ថាអាត្មាដឹងច្បាស់ផង ពាល់ត្រូវផង ។បេ។ ថាអាត្មាដឹងច្បាស់ផង ឃើញផង ឮផង ។បេ។ ថា អាត្មាដឹងច្បាស់ផង ឃើញផង ពាល់ត្រូវផង ។បេ។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង គឺមុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) មិនជឿហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) វង្វេងមិនបាននូវហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ ( ក្តី ) ហើយពោលពាក្យកុហកដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៤ យ៉ាង ។បេ។ អាការ ៥ យ៉ាង ។បេ។ អាការ ៦ យ៉ាង ។បេ។ អាការ ៧ យ៉ាង គឺមុននឹងពោល ដឹងថាអញនឹងពោល

កុហក ១ កំពុងពោល ដឹងថា អញពោលកុហក ១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។

[១៨១] អាបត្តិមិនមានដល់ភិក្ខុពោលដោយញាប់មាត់ ដល់ភិក្ខុពោលដោយភ្លាត់មាត់ ( ភិក្ខុពោលដោយរហ័ស ឈ្មោះថា ពោលដោយញាប់មាត់ , ភិក្ខុគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃ ក្រៅអំពីគំនិតនោះវិញ ឈ្មោះថា ពោលដោយភ្លាត់មាត់ ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

បឋមសិក្ខាបទ ចប់

# អដ្ឋកថា

## ខុទ្ទកកណ្ឌវណ្ណនា

[ ១៧៣ ] ខុទ្ទកសិក្ខាបទពួកណា សង្គ្រោះតាមវគ្គ មាន ៩ វគ្គ ប្រតិស្ឋានហើយដោយល្អ ឥឡូវនេះ នឹងមានការពណ៌នាសិក្ខាបទទាំងនោះ ដូចតទៅនេះ

## ចាចិត្តិយមុសាវាទវគ្គ

## មុសាវាទសិក្ខាបទ

បណ្ដាវគ្គទាំង ៩ នោះ ( បណ្ដាខុទ្ទកសិក្ខាបទទាំងនោះ ) គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃមុសាវាទវគ្គមុន ។

បទថា **ហត្ថកោ** ជាឈ្មោះរបស់ព្រះថេរៈនោះ បុត្ររបស់ស្ដេចសក្យៈឈ្មោះថា សក្យបុត្រ ។ បានឮថា ក្នុងសម័យពុទ្ធកាល បុរស ៨ ម៉ឺននាក់បានចេញបួសអំពីសក្យត្រកូល ។ ព្រះហត្ថកៈនោះជាបុគ្គលម្នាក់ ក្នុងបណ្ដាបុរស ៨ ម៉ឺននាក់នោះ ។

បទថា **វាទក្ខិត្តោ** សេចក្ដីថា ត្រូវពាក្យពោលដែលខ្លួនកំណត់ទុកយ៉ាងនេះថា អញនឹងធ្វើវាទៈ ( លើកវាទៈ ) បន្សាត់ទៅ គឺប្រានទៅ អធិប្បាយថា រុញទៅ គឺបញ្ជូនទៅកាន់សម្នាក់របស់ពួកបរវាទី ។ ម្យ៉ាងទៀត ហត្ថកភិក្ខុនោះ ត្រូវចិត្តរបស់ខ្លួនបន្សាត់ទៅក្នុងវាទៈ រមែងប្រាកដក្នុងទីកន្លែងដែលមានការលើកវាទៈគ្នាគ្រប់គ្រា ព្រោះហេតុនោះ ទើបលោកឈ្មោះថា ត្រូវបន្សាត់ទៅក្នុងវាទៈ ( ជាអ្នកពោលគេចកែសម្ដី ) ។

បទថា **អវជានិត្វា បដិជានាតិ** សេចក្ដីថា ហត្ថកភិក្ខុនោះកំណត់ទោសឯណាមួយ ក្នុងពាក្យរបស់ខ្លួនបាន គេចកែសម្ដីទៅថា នេះមិនមែនពាក្យរបស់ខ្ញុំ កាលនិយាយទៅៗ សង្កេតបានថា មិនមានទោស ហើយព្រមទទួលថា នេះជាពាក្យរបស់ខ្ញុំ ។

បទថា **បដិជានិត្វា អវជានាតិ** សេចក្ដីថា កាលលោកកំណត់អានិសង្សក្នុងពាក្យខ្លះបាន ក៏ព្រមទទួលថា នេះជាពាក្យរបស់ខ្ញុំ កាលនិយាយតទៅទៀត កំណត់ទោសក្នុងពាក្យសម្ដីនោះបាន ក៏គេចកែសម្ដីថា នេះមិនមែនពាក្យរបស់ខ្ញុំ ដូច្នេះ ។

បទថា **អញ្ញេនញ្ញំ បដិចរតិ** សេចក្ដីថា រមែងបិទបាំង គឺរមែងបិទបាំង បានដល់ បិទបាំងហេតុឯណាមួយ ដោយហេតុឯណាមួយ គឺពោលហេតុថា រូបមិនទៀង ព្រោះជារបស់គប្បីដឹងបាន ហើយត្រឡប់ពោលហេតុជាដើមថា ព្រោះមានការកើតជាធម្មតា ។

តែក្នុងកុរុន្ទីពោលថា រមែងពោលរឿងដទៃជាច្រើន ព្រោះហេតុដែលនឹងបិទបាំងប្បដិញ្ញា និងការគេចកែសម្ដីនោះ ។

ក្នុងបទថា **ឯតស្ស** ជាដើមនោះ មានអធិប្បាយដូចតទៅនេះថា លោករមែងពោលពាក្យដ៏ច្រើន មានពាក្យថា នរណាពោល ពោលដូចម្ដេច ពោលទីណា ដូច្នេះជាដើម ដើម្បីបិទបាំងពាក្យប្បដិញ្ញា និងពាក្យគេចកែសម្ដីនោះ ក្នុងមហាអដ្ឋកថា លោកពោលទុកទៀតថា គេចកែហើយប្បដិញ្ញា និងប្បដិញ្ញាហើយគេចកែនោះឯង ឈ្មោះថា បិទបាំងរឿងដទៃ ដោយរឿងដទៃ ។

ពីរបទថា **សម្បជានមុសា ភាសតិ** បានដល់ ពោលកុហកដោយដឹងខ្លួន ។

ប្រើនបទថា **សង្កេតំ កត្វា វិសំវាទេតិ** សេចក្តីថា ធ្វើការកំណត់ថា ការលើកវាទៈចូរមានក្នុងប្រទេស ឈ្មោះនោះ ក្នុងបណ្តាកាល មានបុរេភត្តជាដើមឈ្មោះនោះ ដូច្នេះហើយ ទៅមុន ឬក្រោយអំពីពេលដែលខ្លួនកំណត់ទុក ហើយពោលថា ចូរមើលចុះអាវុសោ ពួកតិរ្ថិយមិនមកហើយ ចាញ់ហើយដូច្នេះ ចៀសចេញទៅ ។

បទថា **សម្បជានមុសាវាទេ** បានដល់ ព្រោះការពោលកុហកទាំងដែលដឹងខ្លួន ហើយនឹងកំពុងដឹង ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃមុសាវាទសិក្ខាបទ

[ ១៧៤ ] បទថា **សម្បជានបុរេក្ខារស្ស** បានដល់ ដែលពោលធ្វើចិត្ត ដែលគិតនឹងពោលឲ្យឃ្លៀងឃ្លាតជាប្រធាន ។

ចេតនាញ៉ាំងពាក្យសម្តីដែលទាក់ទង ក្នុងមិច្ឆាវាចាឲ្យតាំងឡើង ឈ្មោះថា **វាចា**។

លោកសម្តែងសំឡេងដែលតាំងឡើងដោយចេតនានោះ ដោយពាក្យថា **គិរា**។

គន្លងនៃពាក្យសម្តី ឈ្មោះថា **ព្យបថ**។ វាចានោះឯង លោកហៅថា **ព្យបថ** ព្រោះជាគន្លងរបស់ជនដទៃដែលដល់នូវទិដ្ឋានុគតិ ។

ការបន្ទឹវាចាដែលមានការយល់គ្នាថា ជាពាក្យពោល ឈ្មោះថា **វចី-ភេទ ។** វាចាមានប្រភេទផ្សេងៗ គ្នានោះឯង លោកហៅយ៉ាងនេះ ( ថា វចីភេទ ) ។

វចីវិញ្ញត្តិ ឈ្មោះថា វិញ្ញត្តិដែលប្រព្រឹត្តទៅតាមវាចា ។ ដោយអាការយ៉ាងនេះ អ្នកសិក្សាគប្បីជ្រាបថា ដោយបទដំបូង ព្រះឧបាលីពោលត្រឹមតែចេតនាសុទ្ធ ដោយ ៣ បទត្រង់កណ្តាល ពោលចេតនាដែលប្រកបដោយសំឡេង ដែលតាំងឡើងដោយចេតនានោះ ឯ ១ បទចុងក្រោយ ពោលចេតនាដែលប្រកបដោយវិញ្ញត្តិ ។

វោហារ ( ពាក្យសម្តី ) របស់ពួកជនដែលមិនមែនព្រះអរិយៈ គឺពួកពាលបុថុជ្ជន ឈ្មោះថា **អនរិយវោហារ ។**

## អធិប្បាយ

## បទភាជនីយនៃមុសាវាទសិក្ខាបទ

[ ១៧៥ ] ព្រះឧបាលី កាលសម្តែងសម្បជានមុសាវាទយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងលក្ខណៈនៃអនរិយវោហារ ដែលរាប់ជាសម្បជាន-មុសាវាទ ដែលពោលទុកខាងចុង ទើបពោលពាក្យថា **អទិដ្ឋំ ឆាម** ជាដើមដូច្នេះ ។

ក្នុងបទថា **អទិដ្ឋំ** ជាដើមនោះ បណ្ឌិតគប្បីជ្រាបថា ដោយន័យនេះថា ពាក្យសម្តីក្តី ចេតនាជាហេតុញុំាងពាក្យសម្តីនោះឲ្យប្រាកដឡើងក្តី របស់ភិក្ខុដែលពោលរឿងខ្លួនមិនឃើញយ៉ាងនេះថា ខ្ញុំឃើញ ឈ្មោះថា អនរិយ-

វោហារម្យ៉ាង ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបសន្និដ្ឋានក្នុងពាក្យថា **អទិដ្ឋំ ទិដ្ឋំ មេ** ជា-ដើមនេះថា អារម្មណ៍ដែលខ្លួនមិនបានទទួល ដោយអំណាចនៃចក្ខុ ឈ្មោះថា មិនឃើញ ដែលមិនបានទទួលដោយអំណាចនៃសោតៈ ឈ្មោះថា មិនបានឮ ដែលមិនបានទទួលធ្វើឲ្យដូចទាក់ទងគ្នានឹងឥន្ទ្រិយ ៣ ដោយអំណាចនៃឃានិ-ន្ទ្រិយជាដើម ឈ្មោះថា មិនដឹង ដែលវិញ្ញាណសុទ្ធតែម្យ៉ាងក្រៅពីឥន្ទ្រិយ ៥ មិនបានទទួល ឈ្មោះថា មិនដឹង ។

តែក្នុងព្រះបាលី ព្រះមានព្រះភាគត្រាស់ទេសនាដោយន័យដែលប្រាកដច្បាស់ហើយ យ៉ាងនេះថា ដែលឈ្មោះថា មិនឃើញ គឺ មិនឃើញដោយភ្នែក ដូច្នេះឯង ។

បណ្តាអារម្មណ៍ដែលបានឃើញជាដើម ខ្លួនឯងក្តី អ្នកដទៃក្តី ឃើញហើយ ឈ្មោះថា ទិដ្ឋៈទាំងអស់ ។ អារម្មណ៍ដែលឈ្មោះថា សុតៈ មុតៈ និងវិញ្ញាតៈក៏យ៉ាងនេះ នេះជាបរិយាយមួយបែប ។ ឯបរិយាយមួយទៀត អារម្មណ៍ណាដែលខ្លួនឃើញឯង អារម្មណ៍នោះ រាប់ថា ជាទិដ្ឋៈពិត ។ ក្នុងសុតៈជាដើមក៏មានន័យយ៉ាងនេះ ។ អារម្មណ៍ណា ដែលអ្នកដទៃឃើញ អារម្មណ៍នោះ រមែងតាំងនៅក្នុងឋានៈនៃអារម្មណ៍ដែលខ្លួនបានឮ ។ សូម្បីអារម្មណ៍ មានសុតៈជាដើម ក៏មានន័យយ៉ាងនេះ ។

[ ១៧៦ ] ឥឡូវនេះ ព្រះឧបាលី កាលនឹងលើកអាបត្តិឡើងសម្តែងដោយអំណាចនៃអនរិយវោហារទាំងនោះ ទើបពោលពាក្យថា **តីហាការេហិ**

ជាដើម ។ បណ្ឌិតគប្បីជ្រាបអត្ថនៃបទថា **តីហាការេហិ** ជាដើមនោះ ដោយន័យដូចខ្ញុំពោលហើយ ក្នុងបាលីចតុត្ថបារាជិកវណ្ណនា មានពាក្យថា ភិក្ខុពោលសម្បជានមុសាវាទថា ខ្ញុំសម្រេចបឋមជ្ឈាន ត្រូវអាបត្តិបារាជិកដោយអាការ ៣ ដូច្នេះជាដើមនោះឯង ។ ពិតហើយ ក្នុងបាលីចតុត្ថបារាជិកនោះ លោកពោលទុកត្រឹមពាក្យថា **បឋមំ ឈានំ សមាបជ្ជឹ** ខ្ញុំសម្រេចបឋមជ្ឈាន ហើយតែម្យ៉ាង ក្នុងសិក្ខាបទនេះ ពោលទុកថា **អទិដ្ឋំ ទិដ្ឋំ មេ** មិនឃើញពោលថា ខ្ញុំឃើញដូច្នេះ ។ ក្នុងបាលីចតុត្ថបារាជិកនោះ ពោលទុកថា **អាបត្តិ បារាជិកស្ស** ( ត្រូវអាបត្តិបារាជិក ) ។ ក្នុងសិក្ខាបទនេះពោលថា **អាបត្តិ បាចិត្តិយស្ស** ( ត្រូវអាបត្តិបាចិត្តិយ ) ដូច្នេះ ។ មានសេចក្តីប្លែកគ្នាត្រឹមក្នុងវត្ថុ និងអាបត្តិយ៉ាងនេះ ។ ពាក្យដ៏សេស មានលក្ខណៈដូចគ្នាទាំងអស់ ។ សូម្បីពាក្យជាដើមថា **តីហាការេហិ ទិដ្ឋេ វេមតិកោ** ក៏គប្បីជ្រាបអត្ថដោយន័យដូចពោលហើយ ក្នុងបាលីទុដ្ឋទោសសិក្ខាបទវណ្ណនា យ៉ាងនេះថា **ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ ទិដ្ឋេ វេមតិកោ** ( ភិក្ខុចោទនោះបានឃើញភិក្ខុ ដែលត្រូវបារាជិកធម៌ មានសេចក្តីសង្ស័យក្នុងវត្ថុដែលបានឃើញ ដូច្នេះជាដើមនោះឯង ) ។ ក្នុងសិក្ខាបទនេះ ត្រឹមតែពាក្យបាលីប៉ុណ្ណោះប្លែកគ្នា ( ពីបាលីចតុត្ថបារាជិក ) ។ ឯក្នុងអត្ថ ព្រមទាំងវេវាទ មិនមានការផ្សេងគ្នាអ្វីឡើយ ។

## អនាបត្តិនៃមុសាវាទសិក្ខាបទ

[ ១៨១ ] ពីរបទថា **សហសា ភណតិ** សេចក្តីថា ភិក្ខុមិនបានពិចា-

វណាក្តី មិនបានជញ្ជឹងគិតក្តី និយាយដោយរហ័សដល់វត្ថុដែលមិនឃើញ ថា ខ្ញុំឃើញ ។

បទថា **អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណាតិ** សេចក្តីថា កាលខ្ញុំនឹងគួរនឹងពោលពាក្យថា **ចីវរំ** ( ចីវរ ) តែបែរជាពោលថា **ចីរំ** ( យូរ ) ដូច្នេះ ជាដើម ព្រោះភាពជាអ្នកទន់ខ្សោយក្នុងការគិត ព្រោះជាអ្នកស្ពឹក ព្រោះភាពជាអ្នកភ្លេចភ្លាំង ។ តែភិក្ខុណាដែលសាមណេរសួរថា បពិត្រលោកម្ចាស់ មានឃើញឧបជ្ឈាយ៍របស់ខ្ញុំទេ ដូច្នេះ ធ្វើការលេងលេង ពោលថា ឧបជ្ឈាយ៍របស់លោក ទឹមរទេះដឹកឧសទៅហើយទេដឹងក្តី កាលសាមណេរ បានឮសំឡេងស្អែចចកហើយ សួរថា នេះសំឡេងសត្វអ្វីលោកម្ចាស់ ភិក្ខុពោលថា នេះសំឡេងរបស់ពួកអ្នកជួយគ្នាលើកកង់ដែលជាប់គក់របស់ម្តាយ លោកឯងដែលកំពុងទៅដោយយានដូច្នេះក្តី យ៉ាងនេះ ពោលពាក្យដទៃ មិនមែនព្រោះលេង មិនមែនព្រោះភ្លាំងភ្លាត់ ភិក្ខុនោះរមែងត្រូវអាបត្តិពិត ។ នៅមានពាក្យសម្តីម្យ៉ាងទៀត ឈ្មោះថា **បូរណកថា** គឺភិក្ខុមួយអង្គបានប្រេង តិចតួចក្នុងស្រុក ហើយត្រឡប់មកកាន់វិហារ និយាយនឹងសាមណេរថា លោកទៅណាថ្ងៃនេះ ស្រុកមានតែប្រេងតែម្យ៉ាង ដូច្នេះក្តី បានដុំនំដែលគេទុក ក្នុងកំប្រោងពោលជាមួយសាមណេរថា ថ្ងៃនេះ មនុស្សទាំងឡាយក្នុងស្រុកយកកំប្រោងជាច្រើនដាក់នំទៅ ដូច្នេះក្តី នេះចាត់ជាមុសាវាទដូចគ្នា ។ ពាក្យដ៏សេសងាយទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

មុសាវាទសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[១៨២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯងឆព្វគ្គិយភិក្ខុទាំងឡាយ ឈ្លោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺ ជេរប្រទេច ដោយជាតិខ្លះ ឈ្មោះខ្លះ គោត្រខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀលបន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏បានជាឆព្វគ្គិយភិក្ខុទាំងឡាយឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺ ជេរប្រទេច ដោយជាតិខ្លះ ឈ្មោះខ្លះ គោត្រខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ។ ភិក្ខុទាំងនោះ យកសេចក្តីនុ៎ះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះបរមគ្រូត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយឈ្លោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាស្រឡាញ់ពោលចាក់ដោតភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេច ដោយជាតិខ្លះ ឈ្មោះខ្លះ គោត្រខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងនោះក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះ

សព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែបុរសសាបសូន្យចាកមគ្គផល ទាំងឡាយ ចុះហេតុអ្វី បានជាអ្នកទាំងឡាយឈ្លោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេច ដោយជាតិខ្លះ ។បេ។ ដោយពាក្យជេរដ៏ថោកទាបខ្លះ នែពួកមោឃបុរស ការនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ និងមិនមែននាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ លុះព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ កាលពីដើមមានព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងតក្កសិលា ( ព្រាហ្មណ៍នោះ ) មានគោមួយ ឈ្មោះនន្ទិវិសាល ។ ម្នាលភិក្ខុទាំងឡាយក្នុងកាលនោះ គោឈ្មោះនន្ទិវិសាល បាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ចូរអ្នកទៅនិយាយភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះមួយរយ ដែលចងភ្ជាប់គ្នាឲ្យរួចបាន ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រាហ្មណ៍នោះ បានភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះចំនួនមួយរយដែលចងភ្ជាប់គ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះចងរទេះមួយរយភ្ជាប់គ្នា រួចក៏ទឹមគោឈ្មោះនន្ទិវិសាល ហើយនិយាយថា នែគោកៀច ឯងខំទាញទៅ នែគោកៀច ឯងខំអូសទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ គោឈ្មោះនន្ទិវិសាលក៏ឈរទ្រឹងក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះ

ក៏ចាញ់សេដ្ឋីអស់មួយពាន់កហាបណៈ ហើយក៏សុបសៅក្នុង កាលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទើបគោនន្ទិវិសាលបាននិយាយពាក្យនេះ នឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ហេតុអ្វី ក៏អ្នកសុបសៅ ។ ព្រាហ្មណ៍ឆ្លើយថា នែគោដ៏ចម្រើន បានជាសុបសៅ ព្រោះអ្នកឯងឲ្យខ្ញុំចាញ់សេដ្ឋីអស់មួយពាន់កហាបណៈ ។ គោនន្ទិវិសាលសួរថា ព្រាហ្មណ៍ ខ្ញុំមិនមែនជាសត្វកៀច ចុះហេតុអ្វីក៏អ្នកឯងហៅខ្ញុំថា សត្វកៀច ព្រាហ្មណ៍ចូរអ្នកឯងទៅភ្នាល់នឹងសេដ្ឋីដាក់ពីរពាន់កហាបណៈថា គោរបស់ខ្ញុំទាញរទេះចំនួនមួយរយ ដែលគេចងភ្ជាប់គ្នាបាន តែថាអ្នកឯងកុំហៅខ្ញុំថាគោកៀចទៀត ព្រោះខ្ញុំមិនមែនជាគោកៀចទេ ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះភ្នាល់នឹងសេដ្ឋីដាក់ពីរពាន់កហាបណៈ ដោយពាក្យថា គោរបស់ខ្ញុំអាចទាញរទេះចំនួនមួយរយ ដែលគេចងភ្ជាប់គ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះក៏ចងរទេះចំនួនមួយរយភ្ជាប់គ្នា រួចទឹមគោនន្ទិវិសាល ហើយបាននិយាយពាក្យនេះក្នុង ពេលនោះថា ម្នាលគោដ៏ចម្រើន ចូរអ្នកឯងទាញទៅ ម្នាលគោដ៏ចម្រើន ចូរអ្នកឯងអូសទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះគោនន្ទិវិសាលក៏ទាញរទេះចំនួនមួយរយ ដែលគេចងភ្ជាប់គ្នាឲ្យរើលទៅបាន ។

[ ១៨៤ ] បុគ្គលត្រូវពោលតែពាក្យដែលជាទីគាប់ចិត្តម្យ៉ាង ពាក្យដែលមិនជាទីគាប់ចិត្ត សូម្បីតែម្តងក៏មិនត្រូវពោលឡើយ ( ព្រាហ្មណ៍ ) ពោលពាក្យជាទីគាប់ចិត្ត ( គោនន្ទិវិសាល ) ក៏នាំទៅនូវភារៈជាទម្ងន់រួច ហើយញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យផងមានសេចក្តីពេញចិត្ត

ព្រោះព្រាហ្មណ៍នោះបានទ្រព្យផង ព្រោះការងាររបស់ខ្លួនផង ។

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ ពាក្យជេរប្រទេចមិនជាទីគាប់ចិត្តដល់តថាគតក្នុងកាលនោះ សម្តីជេរប្រទេចមិនជាទីគាប់ចិត្តក្នុងកាលឥឡូវនេះដូចម្តេចបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិបាចិត្តិយ ។

[ ១៨៦ ] ដែលហៅថា ពាក្យចាក់ដោតនោះ គឺ ភិក្ខុពោលចាក់ដោតដោយអាការ ១០ យ៉ាង គឺ ជាតិ ១ ឈ្មោះ ១ គោត្រ ១ ការងារ ១ សិល្បសាស្ត្រ ១ អាពាធ ១ ភេទ ១ កិលេស ១ អាបត្តិ ១ ពាក្យជេរដ៏ថោកទាប ១ ។

[១៨៧] ដែលហៅថា ជាតិ គឺជាតិមាន ២ យ៉ាង បានដល់ ហីនជាតិ ( ជាតិថោកទាប ) ១ ឧក្កដ្ឋជាតិ ( ជាតិខ្ពង់ខ្ពស់ ) ១ ។ ដែលហៅថា ហីនជាតិ គឺជាតិមនុស្សចណ្ឌាល ជាតិជាងត្បាញផែង ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរទេះ ជាតិអ្នកចោលសំរាម ជាតិទាំងនេះ ហៅថា ហីនជាតិ ។ ដែលហៅថា ឧក្កដ្ឋជាតិ គឺ ជាតិក្សត្រិយ៍ ជាតិព្រាហ្មណ៍ ជាតិទាំងនេះ ហៅថា ឧក្កដ្ឋជាតិ ។

[១៨៨] ដែលហៅថា នាម គឺ នាមមាន ២ យ៉ាង បានខាងឯហីននាម ១ ឧក្កដ្ឋនាម ។ ដែលហៅថា ហីននាម គឺ អវកណ្ណកនាម ជវកណ្ណនាម ធនិដ្ឋកនាម សវិដ្ឋកនាម កុលវឌ្ឍកនាម ពុំនោះសោត នាមណាដែលគេ មើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ

នាមទាំងនេះហៅថា ហីននាម ។ ដែលហៅថា ឧក្កដ្ឋនាម គឺ នាមដែលប្រកប ព្រមចំពោះដោយព្រះពុទ្ធ ប្រកបព្រមចំពោះដោយព្រះធម៌ ប្រកបព្រមចំពោះ ដោយព្រះសង្ឃ ពុំនោះសោត នាមណាដែលគេមិនមើលងាយ គេមិនបន្ទាប បន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ នាមទាំងនេះហៅថា ឧក្កដ្ឋនាម ។

[ ១៨៩ ] ដែលហៅថា គោត្រ គឺគោត្រមាន ២ យ៉ាង បានខាង ហីនគោត្រ ១ ឧក្កដ្ឋគោត្រ ១ ។ ដែលហៅថា ហីនគោត្រ គឺការទ្វាជគោត្រ ពុំនោះសោត គោត្រណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេ ពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ គោត្រទាំងនេះហៅថា ហីន គោត្រ ។ ដែលហៅថា ឧក្កដ្ឋគោត្រ គឺ គោតមគោត្រ មោគ្គល្លានគោត្រ កច្ចាយនគោត្រ វាសេដ្ឋគោត្រ ពុំនោះសោត គោត្រណាដែលគេមិនមើល ងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មាន ក្នុងជនបទនោះៗ គោត្រទាំងនេះ ហៅថា ឧក្កដ្ឋគោត្រ ។

[ ១៩០ ] ដែលហៅថា ការងារ គឺ ការងារមាន ២ យ៉ាង បានដល់ ការងារថោកទាប ១ ការងារដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថាការងារដ៏ថោកទាប គឺការងាររបស់អ្នកចាំងឈើ ការងាររបស់អ្នកចោលផ្កា ( ចោលសំរាម ) ។ ពុំនោះសោត ការងារណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេ ពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះ ហៅថា ការងារដ៏ថោកទាប ។ ដែលហៅថា ការងារដ៏ខ្ពង់ខ្ពស់ គឺការភ្ជួររាស់ ការ

ជួញប្រែ ការរក្សាគោ ពុំនោះសោត ការងារណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះ ហៅថា ការងារដ៏ខ្ពង់ខ្ពស់ ។

[ ១៩១ ] ដែលហៅថា សិល្បសាស្ត្រ គឺសិល្បសាស្ត្រមាន ២ យ៉ាង បានដល់ សិល្បសាស្ត្រដ៏ថោកទាប ១ សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា សិល្បសាស្ត្រដ៏ថោកទាប គឺសិល្បសាស្ត្រអ្នកត្បាញផែង សិល្ប-សាស្ត្រអ្នកធ្វើឆ្នាំង សិល្បសាស្ត្រអ្នកត្បាញសំពត់ សិល្បសាស្ត្រអ្នកធ្វើស្បែក ( ឬសិល្បសាស្ត្រអ្នកធ្វើរថ ) សិល្បសាស្ត្រខ្មាន់ព្រះកេស ពុំនោះសោត សិល្បសាស្ត្រណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ សិល្បសាស្ត្រទាំងនេះហៅថា សិល្បសាស្ត្រដ៏ថោកទាប ។ ដែលហៅថា សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ គឺ រាប់ដោយដៃទទេ រាប់ដោយវិធីទព្វន្ត ការសរសេរអក្សរ ពុំនោះសោត សិល្ប-សាស្ត្រណា ដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ សិល្បសាស្ត្រទាំងនេះហៅថា សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ។

[ ១៩២ ] បណ្តាអាពាធទាំងឡាយសុទ្ធតែថោកទាបទាំងអស់ ចំណែកខាងអាពាធទឹកនោមផ្អែម ( រោគប្រមេះ ) ហៅថា អាពាធយ៉ាងស្រាល ។

[១៩៣] ដែលហៅថា ភេទ គឺភេទមាន ២ យ៉ាង បានដល់ ភេទដ៏ថោកទាប ១ ភេទដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ភេទថោកទាប គឺភេទខ្ពស់ពេក

ទាបពេក ខ្មៅពេក សពេក ភេទទាំងនេះ ហៅថា ភេទថោកទាប ។ ដែលហៅថា ភេទខ្ពង់ខ្ពស់ គឺភេទមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ភេទទាំងនេះហៅថា ភេទខ្ពង់ខ្ពស់ ។

[១៩៤] ឯកិលេសទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ។

[១៩៥] ឯអាបត្តិទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ចំណែកខាងសោតាបត្តិ និងសមាបត្តិ សុទ្ធតែខ្ពង់ខ្ពស់ទាំងអស់ ។

[១៩៦] ដែលហៅថា ជេរ គឺជេរមាន ២ យ៉ាង បានដល់ ជេរយ៉ាងថោកទាប ១ ជេរយ៉ាងខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ជេរយ៉ាងថោកទាប គឺ ជេរថាលោកជាសត្វអូដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក[១] លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ជេរដោយ **យ** អក្ខរ[២] ក្តី ដោយ **ភ** អក្ខរ[៣] ក្តី ដោយនិមិត្តបុរស និងនិមិត្តស្រ្តីក្តី ជេរទាំងនេះហៅថា ជេរយ៉ាងថោកទាប ។ ដែលហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ គឺជេរថា លោកជាបណ្ឌិត លោកឆ្លៀវឆ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត[៤] លោកជាធម្មកថិក[៥] លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ជេរទាំងនេះហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ ។

[១៩៧] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យមានមុខចុះក្រោម[៦] ចំពោះឧបសម្បន្នផងគ្នា ពោលចំពោះបុគ្គល

---

១- សត្វកើតក្នុងស្ថានគ្មានសេចក្តីចម្រើន ។ ២-៣ យ អក្ខរៈ និង ភ អក្ខរៈនោះ ជាឈ្មោះនៃមេថុនធម្ម ។ ៤- អ្នកចេះដឹងធម្មវិន័យច្រើន ។ ៥- អ្នកសម្តែងធម៌ ។ ៦- ធ្វើមិនឲ្យមានអំណាចតេជះ ។

ដែលមានជាតិថោកទាប ដោយពាក្យថោកទាប គឺថា និយាយចំពោះឧបសម្បន្ន ជាតិចណ្ឌាល ជាតិអ្នកធ្វើផែនឫស្សី ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរថ ជាតិអ្នកចោលសំរាម ដោយពាក្យថា លោកជាមនុស្សចណ្ឌាល ជាអ្នកធ្វើផែន ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ១៩៨ ] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ដោយពាក្យថោកទាប គឺថា និយាយចំពោះឧបសម្បន្នជាតិក្សត្រ ជាតិព្រាហ្មណ៍ ដោយពាក្យថា អ្នកឯងជាអ្នកចណ្ឌាល ជាជាងផែន ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ១៩៩ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺ និយាយចំពោះឧបសម្បន្នជាតិអ្នកចណ្ឌាល ជាតិអ្នកជាងផែន ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរថ ជាតិអ្នកចោលសំរាម ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០០ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នដែលមានជាតិ

ជាក្សត្រិយ៍ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០១ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមថោកទាបដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្ន ដែលមាននាមជា អវកណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០២ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមខ្ពង់ខ្ពស់ដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្ន ដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៣ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នផងគ្នា ពោលចំពោះនាមថោកទាបដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្ន មាននាមជាអវកណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកឈ្មោះពុទ្ធរក្ខិត លោកឈ្មោះធម្មរក្ខិត លោកឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៤ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅនាមដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៥ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្រថោកទាប ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នជាកោសិយគោត្រ ភារ-ទ្វាជគោត្រ ដោយពាក្យថា លោកជាកោសិយគោត្រ លោកជាភារទ្វាជ-គោត្រ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៦ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺពោលសំដៅឧបសម្បន្នជាគោតមគោត្រ ជាមោគ្គ-ល្លានគោត្រ ជាកច្ចាយនគោត្រ ជាវាសេដ្ឋគោត្រ ដោយពាក្យថា លោកជាកោសិយគោត្រ ជាភារទ្វាជគោត្រ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[២០៧] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្រដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាកោសិយគោត្រ ជាភារទ្វាជ គោត្រ ដោយពាក្យថា លោកជាគោតមគោត្រ លោកជាមោគ្គល្លានគោត្រ

លោកជាកច្ចាយនគោត្រ លោកជាវាសេដ្ឋគោត្រ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៨ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាគោតមគោត្រ ជាមោគ្គល្លានគោត្រ ជាកច្ចាយនគោត្រ ជាវាសេដ្ឋគោត្រ ដោយពាក្យថា លោកជាគោតមគោត្រ លោកជាមោគ្គល្លានគោត្រ លោកជាកច្ចាយនគោត្រ លោកជាវាសេដ្ឋគោត្រ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២០៩ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នថា ជាអ្នកចាំងឈើ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាជាងចាំងឈើ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១០ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នថា ជាអ្នកភ្ជួររាស់ ជាអ្នកជួញប្រែ ជាអ្នករក្សាគោ ដោយពាក្យថា លោកជាជាងចាំងឈើ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១១ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោក

ទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នថា ជាជាងចាំងឈើ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាអ្នកក្ដួរកាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១២ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នថា ជាអ្នកក្ដួរកាស់ អ្នកជំនួញ អ្នករក្សាគោ ដោយពាក្យថា លោកជាអ្នកក្ដួរកាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១៣ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថា ពោលសំដៅឧបសម្បន្នថា ជាជាងត្បាញផែង ជាស្មូនឆ្នាំង ជាជាងតម្បាញ ជាជាងស្បែក ជាខ្មាន់ព្រះកេស ដោយពាក្យថា លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងតម្បាញ លោកជាជាងស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១៤ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដៃទទេ អ្នករាប់ដោយវិធីទព្វន្ត អ្នកសរសេរអក្សរ ( នាយស្មៀន ) ដោយពាក្យថា

លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងតម្បាញ លោកជាអ្នកធ្វើស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វាចា ។

[ ២១៥ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្ទាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាជាងត្បាញផែង ស្មូនឆ្នាំង ជាងតម្បាញ អ្នកធ្វើស្បែក ខ្មាន់ព្រះកេស ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីទព្វន្ត លោកជាអ្នកសរសេរអក្សរ ( នាយស្មៀន ) ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១៦ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្ទាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដោយដៃទទេ អ្នករាប់ដោយវិធីទព្វន្ត អ្នកសរសេរអក្សរ ( នាយស្មៀន ) ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីទព្វន្ត លោកជាអ្នកសរសេរអក្សរ ( នាយស្មៀន ) ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វាចា ។

[ ២១៧ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្ទាប់បន្ថោនចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យដ៏ថោកទាប គឺថា ពោលសំដៅឧបសម្បន្នបុគ្គលដែលកើតឃ្លង់ បូស ស្រែង រោគរីងរៃ ឆ្កួតជ្រូក ដោយពាក្យថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោកជាមនុស្សស្រែង លោកជាមនុស្សកើតរោគរីងរៃ

លោកជាមនុស្សត្រួតជ្រុក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១៨ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធដ៏ខ្ពង់ខ្ពស់ ( អាពាធស្រាល ) ដោយពាក្យដ៏ថោកទាប គឺថា ពោលសំដៅឧបសម្បន្នបុគ្គលដែលមានអាពាធទឹកនោមផ្អែម ( កើតប្រមេះផ្អែមមាត់ ) ដោយពាក្យថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោកជាមនុស្សកើតស្រែង លោកជាមនុស្សកើតរោគរីងរៃ លោកជាមនុស្សត្រួតជ្រុក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២១៩ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅ ឧបសម្បន្នភិក្ខុដែលជាមនុស្សឃ្លង់ មនុស្សកើតបូស មនុស្សកើតស្រែង មនុស្សកើតរោគរីងរៃ មនុស្សត្រួតជ្រុក ដោយពាក្យថា លោកជាមនុស្សមានអាពាធទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២០ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នបុគ្គល ដែលជាអ្នកមានអាពាធ ទឹកនោមផ្អែម ដោយពាក្យថា លោកជាមនុស្សមានអាពាធទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២១ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅកេទថោកទាប ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលខ្វស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោកខ្វស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២២ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅកេទដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយពាក្យថា លោកខ្ពស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៣ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកេទថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោកមិនខ្មៅពេក លោកមិនសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៤ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកេទដ៏ខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោក

មិនខ្មៅពេក លោកមិនសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៥ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលរាគៈគ្របសង្កត់ហើយ ទោសៈគ្របសង្កត់ហើយ មោហៈគ្របសង្កត់ហើយ ដោយពាក្យថា លោកត្រូវរាគៈគ្របសង្កត់ហើយ លោកត្រូវទោសៈគ្រប់សង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វាចា ។

[ ២២៦ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដ៏ខ្ពង់ខ្ពស់ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកត្រូវរាគៈគ្របសង្កត់ហើយ លោកត្រូវទោសៈគ្របសង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៧ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលត្រូវរាគៈគ្របសង្កត់ហើយ ត្រូវទោសៈគ្របសង្កត់ហើយ ត្រូវមោហៈគ្របសង្កត់ហើយ ដោយពាក្យថា លោកប្រាសចាករាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៨ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្អាប់បន្ថោក ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅធម៌ដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុ ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកប្រាសចាករាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២២៩ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្អាប់បន្ថោក ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិថុល្លច្ច័យ ត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុព្ភាសិត ដោយពាក្យថា លោកត្រូវអាបត្តិបារាជិក លោកត្រូវអាបត្តិសង្ឃាទិសេស លោកត្រូវអាបត្តិថុល្លច្ច័យ លោកត្រូវអាបត្តិបាចិត្តិយ លោកត្រូវអាបត្តិបាដិទេសនីយ លោកត្រូវអាបត្តិទុក្កដ លោកត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះត្រូវអាបត្តិ បាចិត្តិយគ្រប់ៗ វាចា ។

[ ២៣០ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្អាប់បន្ថោក ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលជាសោតាបន្ន ដោយពាក្យថា លោកត្រូវអាបត្តិបារាជិក ។បេ។ លោកត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣១ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោនចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុ ដែលត្រូវអាបត្តិបារាជិក ។បេ។ ត្រូវអាបត្តិទុក្កដសិត ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣២ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុ ដែលជាសោតាបន្ន ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣៣ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោនចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថា ពោលសំដៅសត្វអូដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាសត្វអូដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកមិនមានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣៤ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់

ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្នភិក្ខុ ដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាសត្វអូដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣៥ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្ទាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាបដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅសត្វអូដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានគតិល្អតែម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[ ២៣៦ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្ទាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ដោយពាក្យខ្ពង់ខ្ពស់ គឺថា ពោលសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា ។

[២៣៧] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នា

ដើម្បីបន្អាប់បន្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះ គឺនិយាយថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទ ជាជាងធ្វើរទេះ ជាអ្នកចោលសំរាម ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗវាចា ។

[ ២៣៨ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្អាប់បន្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាក្សត្រិយ៍ ជាព្រាហ្មណ៍ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៣៩ ] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបន្អាប់បន្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះអវកណ្ណក ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាកោសិយគោត្រ ជាភារទ្វាជគោត្រ ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាគោតមគោត្រ ជាមោគ្គល្លានគោត្រ ជាកច្ចាយនគោត្រ ជាវាសេដ្ឋគោត្រ ។បេ។ ថាក្នុងលោកនេះ មានមនុស្សពួកខ្លះជាជាងចាំង ជាអ្នកចោលផ្កា ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាអ្នកភ្ជួររាស់ ជាឈ្មួញ ជាអ្នករក្សាគោ ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាជាង

ត្បាញផែងបបុស ជាស្មូនឆ្នាំង ជាជាងតម្បាញ ជាអ្នកធ្វើស្បែក ជាខ្មាន់ព្រះ-កេស ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាអ្នករាប់ដៃទទេ ជាអ្នករាប់ដោយវិធីនព្វន្ត ជាអ្នកសរសេរអក្សរ ( ស្មេរ ) ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាមនុស្សគម្លង់ ជាមនុស្សកើតបូស ជាមនុស្សស្រែង ជាមនុស្សកើតរោគរីងរៃ ជាមនុស្ស ធ្លួតជ្រូក ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ កើតរោគប្រមេះ ទឹកនោមផ្អែម ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវរាគៈគ្របសង្កត់ ត្រូវទោសៈគ្របសង្កត់ ត្រូវមោហៈគ្របសង្កត់ ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។បេ។ ថាក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវអាបត្តិបារាជិក ។បេ។ ត្រូវអាបត្តិទុព្ភាសិត ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសោតាបន្នបុគ្គល ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសត្វអូដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក មនុស្សទាំងនោះគ្មានគតិល្អទេ មនុស្សទាំងនោះមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវ អាបត្តិទុក្កដគ្រប់ៗ វាចា ។

[២៤០] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បន្ទាប់បន្ថោក ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ជនទាំងនោះ

គ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដ គ្រប់ៗ វាចា ។

[ ២៤១ ] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បន្ថាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។បេ។ ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បន្ថាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយ ណាមួយជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាងទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៤២ ] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បន្ថាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាងត្បាញផែងឫស្សី មិនមែនអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនអ្នកចោលសំរាម ។បេ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាង ប្រាកដដល់យើងទាំងឡាយ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៤៣ ] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បន្ថាប់បន្ថោនចំពោះអនុបសម្បន្នបុគ្គល ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប

។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប ។បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ ។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺ និយាយសំដៅអនុបសម្បន្នបុគ្គល ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា អ្នកឯងជាបណ្ឌិត អ្នកឯងជាអ្នកឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុ-ស្សូត អ្នកឯងជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៨៤ ] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាមនុស្សឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៨៥ ] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ហើយពោលយ៉ាងនេះ គឺនិយាយថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។បេ។ ថាមនុស្សទាំងឡាយណាមួយជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក

ត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។ ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសំរាម ។បេ។ ថាយើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយ ដំណើរល្អតែម្យ៉ាង ប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា ។

[ ២៤៦ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺពោលសំដៅបុគ្គលជាមនុស្សចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោកជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិទុព្ភាសិតគ្រប់ៗ វាចា ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅដល់បុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាជាតិក្សត្រិយ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោក

ជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិទុក្កដសិត គ្រប់ៗ វាចា ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅ បុគ្គលថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថានិយាយសំដៅឧបសម្បន្នភិក្ខុជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទជាជាងធ្វើរថ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាក្សត្រិយ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុ ដែលជាក្សត្រិយ ជាព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រិយ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុក្កដសិត គ្រប់ៗ វាចា ។បេ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប ។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប ។បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ ។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាអ្នកឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជា

ធម្មកថិក ដំណើរអាក្រក់មិនមានដល់លោកទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់លោក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៨៧ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបន្អាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។បេ។ ជាក្នុងលោកនេះ មានមនុស្សពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៨៨ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបន្អាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។បេ។ ជាមនុស្សទាំងឡាយណាមួយជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៨៩ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបន្អាប់បន្ថោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នក

ចោលសំរាម ។បេ។ ថាយើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់ មិនមានដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៥០ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប ។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប ។បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ ។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅអនុបសម្បន្នបុគ្គល ដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា អ្នកឯងជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៥១ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសម្រាម ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់មនុស្សទាំងឡាយនោះទេ

ដំណើរល្អតែម្យ៉ាងប្រាកដដល់មនុស្សទាំងឡាយនោះ ត្រូវអាបត្តិទុក្កដសិត គ្រប់ៗ វាចា ។

[ ២៥២ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេងក៏ ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសំរាម ។បេ។ ថាមនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៥៣ ] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេងក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសំរាម ។បេ។ ថាយើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាង ប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា ។

[ ២៥៤ ] អាបត្តិមិនមានដល់ភិក្ខុធ្វើសេចក្តីអធិប្បាយជាប្រធាន[១] ដល់ភិក្ខុធ្វើធម៌ជាប្រធាន[២] ដល់ភិក្ខុធ្វើពាក្យប្រៀនប្រដៅជាប្រធាន[៣] ដល់

---

១- ភិក្ខុ ពណ៌នានូវសេចក្តីអធិប្បាយរបស់បាលី ។ ២- ភិក្ខុបង្រៀនបាលី ។ ៣- ភិក្ខុអាស្រ័យពាក្យប្រៀនប្រដៅ ហើយនិយាយដោយន័យ ជាដើមថា អ្នកឯងជាចណ្ឌាល អ្នកឯងកុំធ្វើបាប អ្នកឯងបានជាងនឹងហើយកុំឲ្យងងឹតតទៅទៀត ឡើយ ។

ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តអណ្តែតអណ្តូង ដល់ភិក្ខុដែលវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា

## មុសាវាទវគ្គ

## ឱមសវាទសិក្ខាបទ

[ ១៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ

បណ្តាបទទាំងនោះ បទថា **ឱមសន្តិ** គឺរមែងពោលទ្រគោះ ។

បទថា **ខុំសេន្តិ** គឺរមែងជេរ ។

បទថា **វម្ភេន្តិ** គឺរមែងប្រទេចផ្តាសា ។

[ ១៨៣ ] ដោយបទថា **ភូតបុព្វំ** ព្រះមានព្រះភាគ ទ្រង់នាំរឿងនេះមកសម្តែង ដើម្បីទ្រង់តិះដៀលការពោលចាក់ដោត ។

បទថា **នន្ទិ** ក្នុងបទថា **នន្ទិវិសាលោ នាម** នេះ ជាឈ្មោះរបស់គោនោះឯង ។ ឯគោនោះ មានស្នែងធំវែង ព្រោះហេតុនោះ ទើបម្ចាស់តាំងឈ្មោះថា **នន្ទិវិសាល** ដោយសម័យនោះ ព្រះពោធិសត្វជាគោឈ្មោះនន្ទិវិសាល ។ ព្រាហ្មណ៍ចិញ្ចឹមគោនោះយ៉ាងល្អពន់ពេក ដោយអាហារ មានបបរ និងបាយជាដើម ។ សម័យនោះ គោនន្ទិវិសាលនោះ កាលអនុគ្រោះព្រាហ្មណ៍ ទើបពោលពាក្យថា សូមលោកម្ចាស់ទៅចុះ ដូច្នេះជាដើម ។

ពីរបទថា **តន្តេវអជ្ឈាសិ** សេចក្តីថា សូម្បីក្នុងកាលនៃអហេតុកបដិសន្ធិ គោនន្ទិវិសាល រមែងស្គាល់ពាក្យពោលគំរោះគម្រើយ របស់អ្នកដទៃបាន ដោយជាពាក្យមិនជាទីពេញចិត្ត ព្រោះហេតុនោះ គោនោះប្រាថ្នាដើម្បីសម្តែងទោសដល់ព្រាហ្មណ៍ ទើបឈរនៅស្ងៀម ។

ប្រើនបទថា **សកដសតំ អតិពទ្ធំ បវឌ្ឍសិ** សេចក្ដីថា ព្រះពោធិ-សត្វ កាលនឹងអូសរទេះ ១០០ ដែលបញ្ឈរទុកតាមលំដាប់ ស៊កឈើទុកខាងក្រោម ធ្វើឲ្យជាប់គ្នា ដែលផ្ទុកពេញដោយសណ្ដែកបាយ សណ្ដែករាជមាស និងខ្សាច់ជាដើម ។ រទេះ ១០០ គ្រឿង ជារបស់ដែលខ្លួនត្រូវអូសទៅក្នុងកាលការិលមួយជុំ ហើយ ( ឈ្នះ ) ក៏ពិត តែ ( ព្រះពោធិសត្វ ) ក៏បានទាញទៅរហូតដល់ទីប្រមាណ ១០០ រទេះ ដើម្បីឲ្យរទេះក្រោយ ចតក្នុងទីដែលរទេះមុខចតហើយ ។ ពិតហើយ ព្រះពោធិសត្វទាំងឡាយ រមែងមិនមានការធ្វើដែលធូរថយឡើយ ។

[ ១៨៤ ] បាទគាថាថា **តេន ចត្តមនោ អហុ** សេចក្ដីថា គោនន្ទិ-វិសាលនោះ មានចិត្តត្រេកអរ ព្រោះការបានទ្រព្យរបស់ព្រាហ្មណ៍នោះ និងព្រោះការងាររបស់ខ្លួន ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃឱមសវាទ

[ ១៨៦ ] ក្នុងបទថា **អក្កោសេនាតិ** នេះ ព្រះមានព្រះភាគទ្រង់បំណងនឹងបែកទុកខាងមុខថា ពាក្យជេរមាន ២ យ៉ាង គឺពាក្យជេរដែលថោកទាប ១ ពាក្យជេរខ្ពង់ខ្ពស់ ១ ព្រោះដូច្នោះ ទើបទ្រង់មិនត្រាស់ដូចដែលត្រាស់អំពីមុនថា រមែងជេរដោយពាក្យដែលថោកទាបខ្លះ ត្រាស់ទុកយ៉ាងនេះថា **អក្កោ-សេន** ( ដោយពាក្យជេរដូច្នេះ ) ។

# អធិប្បាយ

## បទភាជនីយនៃឱមសវាទសិក្ខាបទ

[ ១៨៧ ] *ជាតិនៃបុគ្គលដែលធ្វើជាងចាំងឈើ ឈ្មោះថា* **វេណជាតិ។** *អាចារ្យពួកខ្លះពោលថា* **វេឡុការជាតិ** *ដូច្នេះក៏មាន ។*

*ជាតិនៃព្រានម្រឹគជាដើម ឈ្មោះថា* **នេសាទជាតិ។**

*ជាតិនៃបុគ្គលអ្នកធ្វើស្បែក ឈ្មោះថា* **រថការជាតិ** *( ជាតិនៃអ្នកធ្វើរថ ) ។*

*ជាតិនៃអ្នកចាក់ផ្កា ឈ្មោះថា* **បុក្កុសជាតិ** *( ជាតិអ្នកចាក់សំរាម ) ។*

[ ១៨៨ ] *ពាក្យថា* **អវកណ្ណកា** *ជាឈ្មោះរបស់ពួកទាសៈ ព្រោះដូច្នោះ ទើបជាពាក្យថោកទាប ។*

*បទថា* **ឱញាតំ** *ប្រែថា ដែលគេមើលងាយ ភិក្ខុពួកខ្លះសូធ្យថា* **ឧញ្ញាតំ** *ដូច្នេះក៏មាន ។*

*បទថា* **អវញ្ញាតំ** *ប្រែថា ដែលគេបន្ទាបបន្ថោក ។*

*បទថា* **ហីឡិតំ** *ប្រែថា ដែលគេស្អប់ខ្ពើម ។*

*បទថា* **បរិភូតំ** *ប្រែថា ដែលគេមើលងាយថា នឹងមានប្រយោជន៍អ្វីដោយមនុស្សនេះ ។*

*បទថា* **អចិតីកតំ** *ប្រែថា ដែលគេមិនធ្វើនូវការគោរពកោតក្រែង ។*

[ ១៩០ ] *ការងារជាងឈើ ឈ្មោះថា* **កោដ្ឋកកម្ម។**

[ ១៩១ ] *ម្រាមមេដៃ ឈ្មោះថា* **មុទ្ទា** *( វិជ្ជាជាងរាប់ ) ។ ការរាប់ដ៏សេស មានការរាប់មិនដាច់ខ្សែជាដើម ឈ្មោះថា* **គណនា។** *គំនូសអក្សរ*

ឈ្មោះថា **លេខា** ( វិជ្ជានៃការសរសេរ ) ។

[ ១៩២ ] រោគទឹកនោមផ្អែម លោកហៅថា រោគឧក្កដ្ឋ ព្រោះមិនមាន វេទនា ។

[ ១៩៦ ] បទថា **ចាដិកវ៉្ហា** ប្រែថា គប្បីប្រាថ្នា ។

ពីរបទថា **យការេន វា ភការេន វា** សេចក្តីថា ពាក្យជេរដែល ប្រកបដោយ **យ** អក្ខរៈ និង **ភ** អក្ខរៈ ( ឈ្មោះថា ពាក្យជេរថោកទាប )។

ក្នុងបទថា **កាដកោដចិកាយ វា** នេះ និមិត្តនៃបុរស ឈ្មោះថា **កាដ** និមិត្តនៃស្ត្រី ឈ្មោះថា **កោដចិកា** ។ ពាក្យជេរដែលប្រកបដោយ បទទាំងនោះឯណា ពាក្យជេរនោះ ឈ្មោះថា ថោកទាប ។

[ ១៩៧ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់លើកអាបត្តិឡើងកាត់ ដោយអំណាចនៃប្រភេទរបស់អក្កោសវត្ថុ មានជាតិជាដើមនោះ ទើបត្រាស់ ពាក្យថា **ឧបសម្បន្នោ ឧបសម្បន្នំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ៣ បទថា **ខុំសេតុកាមោ វម្ភេតុកាមោ មង្កុ-កត្តុកាមោ** សេចក្តីថា ដែលបំណងនឹងជេរ បំណងនឹងតិះដៀល បំណងនឹង ធ្វើឲ្យអប្បយស ។

ពីរបទថា **ហីនេ ហីនំ** បានដល់ ដោយពាក្យពោលដល់ជាតិដែល ថោកទាប គឺដោយជាតិដែលអាក្រក់ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយឧបាយយ៉ាងនេះ ។

ម្យ៉ាងទៀត បណ្តាបទទាំងនេះ ភិក្ខុកាលពោលឲ្យថោកទាប ដោយ

ពាក្យដ៏លាមក សូម្បីពោលពាក្យពិតក៏ដោយ លោកក៏ត្រូវបាចិត្តិយគ្រប់ៗ វាចា ព្រោះជាអ្នកបំណងនឹងពោលចាក់ដោត ។ កាលពោលឲ្យជាបុគ្គលអាក្រក់ដោយពាក្យដែលល្អ សូម្បីពោលពាក្យមិនពិតក៏ដោយ ក៏គង់ត្រូវអាបត្តិបាចិត្តិយ ដោយសិក្ខាបទនេះ ព្រោះជាអ្នកបំណងនឹងពោលចាក់ដោត មិនមែនដោយសិក្ខាបទមុន ។ ឯភិក្ខុណាពោលពាក្យជាដើមថា ឯងជាចណ្ឌាលល្អ ឯងជាព្រាហ្មណ៍ល្អ ឯងជាចណ្ឌាលថោកទាប ឯងជាព្រាហ្មណ៍ថោកទាប ដូច្នេះ សូម្បីភិក្ខុនោះ ព្រះវិនយធរគប្បីកាត់ដោយអាបត្តិដូចគ្នា ។

[ ២៣៧-២៤៤ ] ក្នុងវារៈថា **សន្តិ ឥធេកច្ចេ** ជាដើមនេះ ត្រូវអាបត្តិទុក្កដ ព្រោះជាពាក្យពោលទ្រគោះបោះបោក ។

[២៤៥ ] សូម្បីក្នុងវារៈថា **យេ នូន ឧ មយំ** ដូច្នេះជាដើម ក៏មានន័យដូច្នេះដូចគ្នា ។ តែក្នុងអនុបសម្បន្ន ត្រូវអាបត្តិទុក្កដតែម្យ៉ាង ក្នុងវារៈទាំង ៤ ។ តែដោយពាក្យថា **ចោរោសិ គណ្ឋិភេទកោសិ** ( ឯងជាចោរ ឯងជាអ្នកទម្លាយគុក ) ជាដើម គ្រប់ៗ វារៈ ត្រូវទុក្កដដូចគ្នា ទាំងឧបសម្បន្នទាំងអនុបសម្បន្ន ។

[ ២៤៦-២៥៣ ] ម្យ៉ាងទៀត ព្រោះបំណងក្នុងការលេង ត្រូវទុព្ភាសិតគ្រប់ៗ វារៈ ទាំងឧបសម្បន្ន ទាំងអនុបសម្បន្ន ។ ភាពជាអ្នកមានបំណងក្នុងការលេង និងសើចលេង ឈ្មោះថា ជាអ្នកមានបំណងនឹងលេង ។ ក្នុងសិក្ខាបទនេះ វៀរភិក្ខុចេញ សត្វទាំងអស់ មានភិក្ខុនីជាដើម បណ្ឌិតគប្បីជ្រាបថា តាំងនៅក្នុងឋានៈនៃអនុបសម្បន្នទាំងអស់ ។

[ ២៥៤ ] ក្នុងបទថា **អត្ថបុរេក្ខារស្ស** ជាដើម គប្បីជ្រាបថា ភិក្ខុពោល អត្ថនៃព្រះបាលី ឈ្មោះថា **អត្ថបុរេក្ខារស្ស** ( អ្នកយកអត្ថជាប្រធាន ) ។ ភិក្ខុបង្រៀនព្រះបាលីគប្បីជ្រាបថា **ធម្មបុរេក្ខារ** ( អ្នកយកធម៌ជាប្រធាន ) ។ អ្នកតាំងនៅក្នុងការបង្រៀន ពោលដោយន័យជាដើមថា សូម្បីឥឡូវនេះ អ្នកក៏ជាមនុស្សប្រណ្ឌាល អ្នកកុំធ្វើបាបឡើយ កុំជាអ្នកមានងងឹតមក ងងឹតទៅខាងមុខឡើយ ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា **អនុសាសនីបុរេក្ខារ** ( អ្នកយកការបង្រៀនជាប្រធាន ) ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខ-វេទនា ដូច្នេះឯង ។

តែក្នុងអាបត្តិទាំងនេះ អាបត្តិទុព្ភាសិត កើតតាមវាចា និងចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាអកុសលចិត្ត មានវេទនា ២ គឺសុខវេទនា ១ ឧបេក្ខាវេទនា ១ ។

ឱមសវាទសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[ ២៥៥ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ តែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយ យកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីកហេតុទាំង-ឡាយ ដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីកហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង ។ ពួកភិក្ខុណាមួយដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្ទុះបន្អាប់ថា ហេតុអ្វីបានជាពួកឆព្វគ្គិយភិក្ខុតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយ ដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះ ហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយ ដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងផង ។ គ្រានោះ ពួកភិក្ខុទាំងនោះក៏បានក្រាបទូលរឿងនុ៎ះចំពោះព្រះមានព្រះភាគជាម្ចាស់ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា

ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយតែងពាំនាំ ពាក្យញុះញង់របស់ភិក្ខុទាំងឡាយដែលបង្កហេតុប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះ ហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយ យកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយ ដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង ( រឿងនេះ ) ពិតឬ ។ ពួកឆព្វគ្គិយភិក្ខុក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបើអ្នកទាំងឡាយ នឹងពាំនាំពាក្យញុះញង់របស់ពួកភិក្ខុដែលបង្កហេតុ ប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយ យកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ម៉្លោះហើយ សេចក្តីបង្កហេតុទាំងឡាយ ដែលមិនទាន់កើតក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយ ដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នករាល់គ្នាធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា ។

[ ២៥៦ ] ដែលហៅថា ពាក្យញុះញង់ គឺញុះញង់ដោយអាការ ២ យ៉ាង បានខាងឯបុគ្គលចង់ឲ្យគេស្រឡាញ់ខ្លួន ១ ចង់បំបែកគេ ១ ។ ភិក្ខុពាំនាំពាក្យញុះញង់ដោយអាការ ១០ យ៉ាង គឺដោយជាតិក្តី ដោយនាមក្តី ដោយគោត្រក្តី ដោយការងារក្តី ដោយសិល្បសាស្រ្តក្តី ដោយអាពាធក្តី ដោយភេទក្តី ដោយធម៌ជាគ្រឿងសៅហ្មងក្តី ដោយអាបត្តិក្តី ដោយពាក្យជេរក្តី ។ ដែលហៅថា ជាតិ គឺជាតិមាន ២ យ៉ាង បានខាងជាតិថោកទាប ១ ជាតិខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ជាតិថោកទាបនោះ គឺ ជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ ជាតិអ្នកចោលសំរាម ប៉ុណ្ណេះ ឈ្មោះថា ជាតិថោកទាប ។ ដែលហៅថា ជាតិខ្ពង់ខ្ពស់នោះ គឺ ជាតិក្សត្រិយ ជាតិព្រាហ្មណ៍ ប៉ុណ្ណេះឈ្មោះថា ជាតិខ្ពង់ខ្ពស់ ។បេ។ ដែលហៅថា ពាក្យជេរនោះ គឺ ពាក្យជេរមាន ២ យ៉ាង បានខាងពាក្យជេរដ៏ថោកទាប ១ ពាក្យជេរដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ពាក្យជេរដ៏ថោកទាបនោះ គឺជេរថា អ្នកឯងជាសត្វអូដ្ឋ អ្នកឯងជាពពែ អ្នកឯងជាគោ អ្នកឯងជាលា អ្នកឯងជាសត្វតិរច្ឆាន អ្នកឯងជាសត្វនរក សុគតិរបស់អ្នកឯងគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងមានដល់អ្នកឯង ពុំនោះសោត ជេរដោយ **យ** អក្ខរៈ ឬដោយ **ភ** អក្ខរៈ ឬដោយបុរិសនិមិត្ត និងឥត្ថីនិមិត្ត ប៉ុណ្ណេះឈ្មោះថា ពាក្យជេរដ៏ថោកទាប ។ ដែលហៅថា ពាក្យជេរដ៏ខ្ពង់ខ្ពស់នោះ គឺជេរថា អ្នកឯងជាបណ្ឌិត អ្នកឯងជាមនុស្សឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុស្សូត អ្នកឯងជាធម្មកថិក ទុគ្គតិរបស់អ្នកឯងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់អ្នកឯង ប៉ុណ្ណេះ ឈ្មោះថា ពាក្យជេរដ៏ខ្ពង់ខ្ពស់ ។

[ ២៥៧ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុហើយ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះ លោកថា លោកជាជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ ជាតិអ្នកចោលសំរាម ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៥៨ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាក្សត្រិយ ជាព្រាហ្មណ៍ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៥៩ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកឈ្មោះអវកណ្ណក ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៦០ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៦១ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាកោសិយគោត្រ ភារទ្វាជគោត្រ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៦២ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាគោតមគោត្រ មោគ្គល្លានគោត្រ កច្ចាយនគោត្រ វាសេដ្ឋគោត្រ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៣ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាជាងចាំង ជាអ្នកចោលទូវផ្កា ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៤ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាអ្នកភ្ជួររាស់ ជាអ្នកជួញ ជាអ្នករក្សាគោ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៥ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាជាងផែងបបុស ជាស្ទូនថ្នាំង ជាជាងតម្បាញ ជាជាងស្បែក ជាខ្មាន់ព្រះកេស ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៦ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាអ្នករាប់ដៃទទេ ជាហោរ ជាស្មៀន ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៧ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ ពោលចំពោះលោកថា លោកជាមនុស្សឃ្លង់ ជាមនុស្សដំបៅពក ជាមនុស្សស្រែង ជាមនុស្សកើត រោគរីងរៃ ជាមនុស្សឆ្កួតជ្រូក ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៨ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាមនុស្សកើតរោគប្រមេះផ្អែម ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៦៩ ] ឧបសម្បន្នភិក្ខុឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាបុគ្គលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧០ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាបុគ្គលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧១ ] ឧបសម្បន្នភិក្ខុឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាបុគ្គលមានរាគៈរួបរឹតហើយ មានទោសៈរួបរឹតហើយ មានមោហៈ រួបរឹតហើយ

( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧២ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាមនុស្សប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧៣ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកត្រូវអាបត្តិបារាជិកហើយ ត្រូវអាបត្តិសង្ឃាទិសេសហើយ ត្រូវអាបត្តិថុល្លច្ច័យហើយ ត្រូវអាបត្តិបាចិត្តិយហើយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដហើយ ត្រូវអាបត្តិទុព្ភាសិតហើយ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧៤ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាបុគ្គលដល់ហើយនូវសោតាបត្តិផល ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ មាត់ ។

[ ២៧៥ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាសត្វអូដ្ឋ ជាសត្វពពែ ជាសត្វគោ ជាសត្វលា ជាសត្វតិរច្ឆាន ជាសត្វនរក សុគតិរបស់លោកគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងប្រាកដដល់លោក ( ភិក្ខុអ្នកញុះ-

ញន់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧៦ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះ និយាយចំពោះលោកថា លោកជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់លោកគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់លោក ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។

[ ២៧៧ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះ ជនពួកខ្លះ ជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសំរាម ក៏សឹងមាន ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ ពោលចំពោះលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។

[ ២៧៨ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះ ជនពួកខ្លះជាក្សត្រិយ ជាព្រាហ្មណ៍ ក៏សឹងមាន ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។បេ។

[ ២៧៩ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោក

នេះ ជនទាំងឡាយពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ក៏សឹងមាន ទុគ្គតិរបស់លោកទាំងនោះគ្មានទេ សុគតិតែម្យ៉ាង នឹងប្រាកដដល់លោកទាំងនោះ ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែន ពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។

[ ២៨០ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណា ពិតជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសំរាម ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោល ចំពោះលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។បេ។ ឧបសម្បន្នភិក្ខុឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នាហើយ នាំពាក្យញុះញង់ ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណាពិតជា បណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់ ជនទាំងនោះគ្មានទេ សុគតិតែម្យ៉ាង នឹងប្រាកដដល់ជនទាំងនោះ ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះ លោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។

[ ២៨១ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើង ទាំងឡាយ មិនមែនជាចណ្ឌាល មិនមែនជាជាងផែង មិនមែនជាអ្នកនេសាទ

មិនមែនជាជាងរថ មិនមែនជាអ្នកចោលសំរាម ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលសំដៅលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។បេ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ទុគ្គតិរបស់ពួកយើងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់ពួកយើង ឯភិក្ខុនោះ ( ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិទុក្កដរាល់ៗ មាត់ ។

[ ២៨២ ] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀត ត្រូវអាបត្តិបាចិត្តិយរាល់ៗ មាត់ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្នភិក្ខុឮពាក្យរបស់អនុបសម្បន្នបុគ្គល ហើយនាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់អនុបសម្បន្នបុគ្គលហើយ នាំពាក្យញុះញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។

[ ២៨៣ ] អាបត្តិមិនមានដល់ភិក្ខុ អ្នកមិនចង់ឲ្យគេស្រឡាញ់ខ្លួន ដល់ភិក្ខុ មិនប្រាថ្នាឲ្យគេបែកគ្នា ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា

## មុសាវាទវគ្គ

## បេសុញ្ញវាទសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ

[ ២៥៥ ] បទថា **ភណ្ឌនជាតានំ** បានដល់ អ្នកកើតជម្លោះទាស់ទែងគ្នាហើយ ។ ចំណែកខាងដើមនៃការវិវាទគ្នា ឈ្មោះថា **ភណ្ឌន** ( ជម្លោះ ) គឺការប្រឹក្សាគ្នាក្នុងបក្ខពួករបស់ខ្លួន មានពាក្យថា កាលអ្នកដទៃពោលយ៉ាងនេះថា កម្មយ៉ាងនេះ ដែលបុគ្គលនេះ និងបុគ្គលនេះធ្វើហើយ ពួកយើងនឹងពោលយ៉ាងនេះជាដើម ( ឈ្មោះថា **ភណ្ឌន** ការទាស់ទែង ) ។ ការកន្ទងល្មើសផ្លូវកាយ និងវាចាឲ្យត្រូវអាបត្តិ ឈ្មោះថា **កលហ** ( ការឈ្លោះ ) ។ ការពោលប្រកែកគ្នា ឈ្មោះថា **វិវាទ** ។ ពួកភិក្ខុដែលដល់នូវការវិវាទគ្នានោះ ឈ្មោះថា **វិវាទាបន្ន** ។

បទថា **បេសុញ្ញំ** បានដល់ នូវវាចាស៊ីកសៀត ។ មានពាក្យអធិប្បាយថា នូវវាចាធ្វើឲ្យសាបសូន្យភាពជាទីស្រឡាញ់ដល់គ្នានឹងគ្នា ។

បទថា **ភិក្ខុបេសុញ្ញេ** បានដល់ ព្រោះស៊ីកសៀតភិក្ខុទាំងឡាយ អធិប្បាយថា ព្រោះពាក្យស៊ីកសៀត ដែលភិក្ខុស្តាប់អំពីភិក្ខុហើយ នាំចូលទៅប្រាប់ដល់ភិក្ខុ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃបេសុញ្ញវាទសិក្ខាបទ

[ ២៥៦ ] ពីរបទថា **ទ្វីហិ អាការេហិ** បានដល់ ដោយហេតុ ២ យ៉ាង ។

បទថា **បិយកម្យស្ស វា** គឺរបស់អ្នកប្រាថ្នាឲ្យខ្លួនជាទីស្រឡាញ់របស់អ្នកដទៃថា អញនឹងជាទីស្រឡាញ់របស់បុគ្គលនេះ យ៉ាងនេះក្តី ។

បទថា **ភេទាធិប្បាយស្ស វា** គឺរបស់បុគ្គលប្រាថ្នានូវការបែកបាក់នៃបុគ្គលមួយ និងបុគ្គលណាមួយថា បុគ្គលនេះ ចូរបែកចេញអំពីបុគ្គលនេះ ដោយអាការយ៉ាងនេះក្តី ។

បទទាំងពួង មានបទថា **ជាតិតោបិ** ជាដើម មានន័យដូចពោលហើយក្នុងសិក្ខាបទមុននោះឯង ។ សូម្បីក្នុងសិក្ខាបទនេះ ជនទាំងអស់ ទោះភិក្ខុនីជាដើមក្តី ក៏ឈ្មោះថា អនុបសម្បន្នដែរ ។

[ ២៨៣ ] ពីរបទថា **ន បិយកម្យស្ស ន ភេទាធិប្បាយស្ស** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលឃើញភិក្ខុមួយអង្គកំពុងជេរ និងមួយអង្គអត់ធន់បាន ហើយពោលព្រោះខ្លួនជាអ្នកច្រើនដោយការតិះដៀល ចំពោះមនុស្សអាក្រក់តែម្យ៉ាងថា ដោយទំនងនេះថា ឱ បុគ្គលមិនខ្មាសបាប បែរជាសម្គាល់បុគ្គលល្អឈ្មោះនេះថា ខ្លួនគួរស្តីថាបានជានិច្ច បទដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ វាចា និងចិត្ត ១ កាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

បេសុញ្ញវាទសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ២៨៤ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយបង្ហាញធម៌ជាបទ ចំពោះពួកឧបាសក ។ ឧបាសកទាំងឡាយក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្ទុះបន្អាប់ថា មិនសមបីបើពួកឆព្វគ្គិយបង្ហាញធម៌ជាបទ ចំពោះពួកឧបាសកទាំងឡាយៗ ក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ។ គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបង្ហាញធម៌ជាបទ ចំពោះឧបាសកទាំងឡាយៗ ក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ( រឿងនេះ ) ពិតឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបីអ្នកទាំងឡាយបង្ហាញធម៌ជាបទ ចំពោះពួកឧបាសកៗ ក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ម្នាលបុរសទទេទាំងឡាយ កម្មដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ

បង្រៀនធម៌ជាបទ ចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ។

[ ២៨៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា អនុបសម្បន្ននោះ គឺជនទាំងអស់ លើកលែងតែភិក្ខុ និងភិក្ខុនីចេញ ហៅថា អនុបសម្បន្ន ។

[ ២៨៦ ] ដែលហៅថា បទនោះ គឺបទ ១ អនុបទ ១ អន្វក្ខរៈ ១ អនុព្យញ្ជនៈ[១] ១ ។ ដែលហៅថា ជាបទនោះ គឺឧបសម្បន្នទាំងអនុបសម្បន្ន ផ្តើមតាំងព្រមគ្នា បញ្ចប់ព្រមគ្នា ។ ដែលហៅថា ជាអនុបទនោះ គឺឧបសម្បន្ន ទាំងអនុបសម្បន្នផ្តើមតាំងផ្សេងគ្នា បញ្ចប់ព្រមគ្នា ។ ដែលហៅថា អន្វក្ខរៈនោះ គឺ ឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នទទួលថា រូ ព្រមគ្នា ។ ដែលហៅថា អនុព្យញ្ជនៈនោះ គឺ ឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នបញ្ចេញសំឡេង ( ដោយរហ័ស ) ថា វេទនា អនិច្ចា[២] ដូច្នេះ ឈ្មោះថា បង្រៀនជាអនុព្យញ្ជនៈ ។ បទណាក្តី អនុបទណាក្តី អន្វក្ខរៈណាក្តី អនុព្យញ្ជនៈណាក្តី ទាំងអស់នុ៎ះ ឈ្មោះថា ធម៌ជាបទ ( គឺជាចំណែក ) ។ ពាក្យដែលជាពុទ្ធភាសិត សាវកភាសិត ឥសិភាសិត ទេវតាភាសិត ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យនូវបាលី ឈ្មោះថា ធម៌ ។ ពាក្យថា បង្រៀន សេចក្តីថា ភិក្ខុបង្រៀនដោយបទ ត្រូវអាបត្តិ

---

១- អក្ខរៈមួយៗ ហៅថា អន្វក្ខរៈ ប្រជុំនៃអក្ខរៈមួយស័ព្ទៗ ហៅថា អនុព្យញ្ជនៈ ប្រជុំនៃអក្ខរៈ និងអនុព្យញ្ជនៈ ហៅថា បទ បទទី ១ ហៅថា បទ បទទី ២ ហៅថា អនុបទ ។ ២- ភិក្ខុប្រាប់ថា រូបំ អនិច្ចំ សាមណេរ ចាប់សូត្រថា វេទនា អនិច្ចា បទខាងដើម គឺ រូបំ និងវេទនានោះ ជាផ្សេងគ្នា ដល់បទខាងចុង គឺ អនិច្ចំ និងអនិច្ចានោះ ជាត្រូវស្មើគ្នា គឺស្មើត្រង់ថា អនិច្ចៗ នោះឯង ។

បាចិត្តិយរាល់ៗ បទ ។ ភិក្ខុបង្រៀនដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ៗ អក្ខរៈ ។

[ ២៨៧ ] អនុបសម្បន្ន ភិក្ខុសម្គាល់ថាអនុបសម្បន្នពិតមែន ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្នពិតមែន តែភិក្ខុមានសេចក្ដីសង្ស័យ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន តែភិក្ខុសម្គាល់ថាឧបសម្បន្នទៅវិញ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន តែភិក្ខុសម្គាល់ថាអនុបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន ភិក្ខុសម្គាល់ថា ឧបសម្បន្នពិតមែន មិនត្រូវអាបត្តិ ។

[ ២៨៨ ] អាបត្តិមិនមានដល់ភិក្ខុរៀនបាលីជាមួយ ( នឹងអនុបសម្បន្ន ) ដល់ភិក្ខុស្វាធ្យាយជាមួយ ( នឹងអនុបសម្បន្ន ) ដល់ភិក្ខុកំពុងសូត្រគម្ពីរដែលស្ទាត់ដោយច្រើន ដល់ភិក្ខុថាជាមួយនឹងអនុបសម្បន្នកំពុងសូត្រធម៌ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់

# អដ្ឋកថា

# មុសាវាទវគ្គ

# បទសោធម្មសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ

[ ២៨៤ ] បទថា **អប្បតិស្សា** បានដល់ មិនកោតក្រែង អធិប្បាយថា កាលធម្មគ្គិយភិក្ខុពោលថា នែឧបាសកទាំងឡាយ សូម្បីពាក្យសម្ដីក៏មិនចង់ស្ដាប់ គឺមិនអើពើ ។ ម្យ៉ាងទៀត សេចក្ដីថា មិនមានការកោតក្រែង មិនប្រព្រឹត្តឱនលំទោន ។

បទថា **អសភាគវុត្តិកា** បានដល់ អ្នកមានការរស់នៅមិនត្រូវអធ្យាស្រ័យ អធិប្បាយថា ដែលមានការប្រព្រឹត្តមិនដំណើរទៅ ដូចដែលពួកឧបាសកគួរប្រព្រឹត្តក្នុងពួកភិក្ខុ ។

បទថា **បទសោ ធម្មំ វាចេយ្យ** សេចក្ដីថា ឲ្យពោលធម៌ជាបទជាបទរួមគ្នា ( ជាមួយអនុបសម្បន្ន ) អធិប្បាយថា ឲ្យពោល ( ធម៌ ) ជាកោដ្ឋាសៗ ( ជាចំណែកៗ ) ។ ក៏ព្រោះបទដែលមានឈ្មោះថា កោដ្ឋាសនោះ មាន ៤ យ៉ាង ដូច្នោះ ដើម្បីសម្ដែងបទទាំង ៤ យ៉ាងនោះ ទើបព្រះឧបាលីពោលទុកក្នុងបទភាជនៈថា បទ អនុបទ អនុអក្ខរៈ អនុព្យញ្ជនៈ ។

[ ២៨៤ ] បណ្ដា **បទ** ជាដើមនោះ **បទ** សំដៅយកបាទទី ១ នៃគាថា អនុបទ សំដៅយកបាទទី ២ អនុអក្ខរៈ សំដៅយកអក្សរមួយតួៗ អនុព្យញ្ជនៈ សំដៅយកព្យញ្ជនៈចុងក្រោយដូចគ្នានឹងព្យញ្ជនៈដើម ។ អ្នកសិក្សា

គប្បីជ្រាបការផ្សេងគ្នាក្នុងបទជាដើមនោះយ៉ាងនេះថា អក្ខរៈមួយតួប្រភេទណាមួយ ឈ្មោះថា អនុអក្ខរៈ ប្រជុំអក្ខរៈ ឈ្មោះថា អនុព្យញ្ជនៈ ប្រជុំអក្ខរៈនិងអនុព្យញ្ជនៈ ឈ្មោះថា បទ , បទទី ១ ក៏ឈ្មោះថា បទ , បទទី ២ ឈ្មោះថា អនុបទ ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បទំ នាម ឯកតោ បដ្ឋបេត្វា ឯកតោ ឱសាបេន្តិ** ដូចតទៅនេះថា កាលភិក្ខុឲ្យពោលធម៌ ទាក់ទងដោយគាថា ផ្ដើមបទដំបូងថា **មនោបុព្វង្គមា ធម្មា** ដំណាលគ្នានឹងអនុបសម្បន្ន ហើយឲ្យចប់ដំណាលគ្នា ។ សម្រាប់ភិក្ខុដែលឲ្យពោលយ៉ាងនេះ ក៏គប្បីកាត់អាបត្តិបាចិត្តិយជាច្រើនតាមចំនួនបទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនុបទំ នាម បាទេន្តំ បដ្ឋបេត្វា ឯកតោ ឱសាបេន្តិ** ដូចតទៅនេះថា កាលព្រះថេរៈពោលថា **មនោបុព្វង្គមា ធម្មា** ដូច្នេះ សាមណេរពោលបទនោះមិនទាន់ ទើបពោលបទទី ២ ព្រមគ្នាថា **មនោសេដ្ឋា មនោមយា ។** ភិក្ខុ និងសាមណេរទាំង ២ អង្គនេះ ឈ្មោះថា ផ្ដើមផ្សេងគ្នា ឲ្យចប់ព្រមគ្នា ។ សម្រាប់ភិក្ខុដែលពោលយ៉ាងនេះ ក៏គប្បីកាត់អាបត្តិបាចិត្តិយជាច្រើនតាមចំនួនអនុបទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អន្វក្ខរំ នាម រូបំ អនិច្ចន្តិ វុច្ចមានោ រូតិ ឱបាទេតិ** ដូចតទៅនេះថា ភិក្ខុបង្រៀនសាមណេរថា នែសាមណេរ លោកចូរថា **រូបំ អនិច្ចំ** ហើយពោលព្រមគ្នា ត្រឹមតែ **រូ** អក្ខរៈប៉ុណ្ណោះ ហើយក៏ឈប់ សម្រាប់ភិក្ខុដែលឲ្យពោលយ៉ាងនេះ ក៏គប្បីកាត់អាបត្តិបាចិត្តិយ

ជាច្រើនតាមចំនួនអនុអក្ខរៈ ។ សូម្បីក្នុងគាថាពន្ធ បណ្ឌិតរមែងបានន័យដូច្នេះ ដូចគ្នានោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនុព្យញ្ជនំ ឆាម រូបំ អនិច្ចន្តិ វុច្ច-មានោ វេទនា អនិច្ចាតិ សទ្ទំ និច្ឆារេតិ** ដូចតទៅនេះថា សាមណេរឲ្យប្រាប់សូត្រនេះថា **រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា** ជាដើម ព្រះថេរៈប្រាប់ថា **រូបំ អនិច្ចំ** ដូច្នេះ បន្ទឹវាចាពោលអនិច្ចបទនេះថា **វេទនា អនិច្ចា** ព្រមគ្នានឹងអនិច្ចបទរបស់ព្រះថេរៈថា **រូបំ អនិច្ចំ** នេះ ព្រោះជាអ្នកមានបញ្ញាវាងវៃ ។ ភិក្ខុដែលឲ្យពោលយ៉ាងនេះ ព្រះវិនយធរគប្បីកាត់អាបត្តិបាចិត្តិយជាច្រើនតាមចំនួនអនុព្យញ្ជនៈ ។ ឯសេចក្តីសង្ខេបក្នុងបទទាំងនេះ មានដូច្នេះថា បណ្តាបទជាដើមនេះ ភិក្ខុពោលបទណាមួយព្រមគ្នា រមែងត្រូវអាបត្តិដោយបទនោះៗ ។

## អធិប្បាយ ភាសិត ៤ មានពុទ្ធភាសិតជាដើម

វិនយបិដកទាំងអស់ អភិធម្មបិដក ធម្មបទ ចរិយាបិដក ឧទាន ឥតិ-វុត្តកៈ ជាតក សុត្តនិបាត វិមានវត្ថុ បេតវត្ថុ និងព្រះសូត្រទាំងឡាយ មានព្រហ្មជាលសូត្រជាដើម ឈ្មោះថា **ពុទ្ធភាសិត** ។

ធម៌ដែលពួកសាវ័ក ដែលទាក់ទងក្នុងបរិស័ទ ៤ ពោលទុក មានអនង្គណសូត្រ សម្មាទិដ្ឋិសូត្រ អនុមានសូត្រ ចូឡវេទល្លសូត្រ មហា-វេទល្លសូត្រជាដើម ឈ្មោះថា **សាវកភាសិត** ។

ធម៌ដែលពួកបរិព្វាជកខាងក្រៅពោលទុក មានបរិព្វាជកវគ្គទាំងអស់

ពាក្យបុច្ឆារបស់ព្រាហ្មណ៍ ១៦ នាក់ ដែលជាកូនសិស្សរបស់ព្រាហ្មណ៍ឈ្មោះពាវរី ឈ្មោះថា **ឥសិភាសិត** ។

ធម៌ដែលពួកទេវតាពោលទុក ឈ្មោះថា **ទេវតាភាសិត** ។ ទេវតាភាសិតនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃរឿង មានទេវតាសំយុត្ត ទេវបុត្តសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត និងសក្កសំយុត្តជាដើម ។

បទថា **អត្ថូបសញ្ហិតោ** បានដល់ ធម៌ដែលអាស្រ័យអដ្ឋកថា ។

បទថា **ធម្មូបសញ្ហិតោ** បានដល់ ធម៌ដែលអាស្រ័យព្រះបាលី ។ បទទាំង ២ នេះ ព្រះឧបាលីពោលធម៌ដែលអាស្រ័យព្រះនិព្វាន ដែលប្រាសចាកវដ្តៈនោះឯង សូម្បីពោលដល់ធម៌ដែលអាស្រ័យព្រះនិព្វាន ប្រាសចាកវដ្តៈក៏ពិត សូម្បីដូច្នោះ ក៏ជាអាបត្តិដល់ភិក្ខុ ដែលឲ្យពោលធម៌ក្នុងពេលឡើងកាន់សង្គីតិទាំង ៣ លើក ដោយបទដូចគ្នា ។ មិនត្រូវអាបត្តិក្នុងពាក្យដែលអាស្រ័យព្រះនិព្វាន ដែលលោករចនាទុក ដោយចងជាសិលោកគាថា ( ពាក្យស្លោក ) ជាដើម ដោយអំណាចភាសាផ្សេងៗ ។

សូម្បីក្នុងសូត្រដែលមិនបានលើកឡើងកាន់សង្គីតិទាំង ៣ លើក គឺ **កុលុម្ពសូត្រ រាជោវាទសូត្រ តិក្ខិន្ទ្រិយសូត្រ ចតុបរិវត្តសូត្រ** និង **នន្ទោបនន្ទសូត្រ** ក៏ត្រូវអាបត្តិដូចគ្នា សូម្បីការទូន្មានស្តេចនាគ ឈ្មោះ **អបលាល** អាចារ្យក៏ពោលទុក ( ដោយអំណាចញុំាងឲ្យកើតអាបត្តិ ) តែក្នុងមហាបច្ចរីបដិសេធ ( អធិប្បាយថា មិនត្រូវអាបត្តិ ) ។

ក្នុងបដិភាណផ្ទាល់ខ្លួនរបស់ព្រះថេរៈ ក្នុងមេណ្ឌកមិលិន្ទបញ្ហា មិនត្រូវ

អាបត្តិ ។ ( តែ ) ត្រូវអាបត្តិក្នុងពាក្យសម្តីដែលព្រះថេរៈនាំមកពោលដើម្បីឲ្យព្រះរាជាទ្រង់យល់ព្រម ។

អាចារ្យទាំងឡាយពោលថា បករណ៍ទាំងឡាយ មាន **វណ្ណបិដក អង្គុលិមាលបិដក រដ្ឋបាលគជ្ជិត អាឡវកគជ្ជិត គុឡ្ហឧម្មគ្គ គុឡ្ហវេស្សន្តរ គុឡ្ហវិនយ វេទល្លបិដក** ជាដើម មិនជាពុទ្ធវចនៈឡើយ ( សូត្រទាំងនេះជាសូត្រខាងមហាយាន ) ។

អាចារ្យពួកខ្លះពោលថា ធម៌ឈ្មោះថា **សីលូបទេស** ព្រះធម្មសេនាបតីពោលទុកក្នុងធម៌នោះ ជាអាបត្តិដូចគ្នា នៅមានបករណ៍ដទៃ ដូចជា **មគ្គកថា អារម្មណកថា វុឌ្ឍិករណ្ឌកញ្ញាណវត្ថុ** និង **អសុភកថា** ជាដើម ក្នុងបករណ៍ទាំងនោះ លោកចែកពោធិបក្ខិយធម៌ ៣៧ ទុក ។ ក្នុងពុតង្គប្បញ្ហា លោកចែកបដិបទាទុក ព្រោះហេតុនោះ ទើបលោកពោលថា ត្រូវអាបត្តិក្នុងបករណ៍ទាំងនោះ ។

តែក្នុងអដ្ឋកថាមហាបច្ចរី ពោលអនាបត្តិទុកក្នុងប្រភេទ **រាជោវាទសូត្រ តិក្ខិន្ទ្រិយសូត្រ ចតុបរិវត្តសូត្រ នន្ទោបនន្ទសូត្រ កុលុម្ពសូត្រ** ( សូត្រនេះជាសូត្រខាងមហាយាន ) នោះឯង ដែលមិនឡើងកាន់សង្គីតិ ហើយកំណត់អត្ថទុកដូច្នេះថា បណ្តាពាក្យដ៏សេស ចំពោះពាក្យដែលលោកនាំមកអំពីពុទ្ធវចនៈពោលទុកប៉ុណ្ណោះ ជាវត្ថុនៃអាបត្តិ ក្រៅអំពីនេះ មិនជាវត្ថុនៃអាបត្តិឡើយ ។

# អនាបត្តិនៃបទសោធម្មសិក្ខាបទ

[ ២៨៨ ] ក្នុងបទថា **ឯកតោ ឧទ្ទិសាបេន្តោ** សេចក្តីថា ភិក្ខុរៀនបាលីរួមជាមួយគ្នានឹងអនុបសម្បន្ន ហើយពោលព្រមគ្នា មិនត្រូវអាបត្តិឡើយ ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅនេះថា ឧបសម្បន្ន និងអនុបសម្បន្ននោះ សូមឲ្យអាចារ្យសូត្រ អាចារ្យគិតថា អញនឹងសូត្រដល់ឧបសម្បន្ន និងអនុបសម្បន្នទាំង ២ ដែលអង្គុយហើយ ទើបសូត្រព្រមគ្នា នឹងលោកទាំងនោះ ត្រូវអាបត្តិដល់អាចារ្យ មិនត្រូវអាបត្តិដល់ភិក្ខុដែលរៀនយក មួយអន្លើនឹងអនុបសម្បន្ននោះ ។ សូម្បីឧបសម្បន្ន និងអនុបសម្បន្ន ទាំង ២ ឈររៀន ក៏មានន័យយ៉ាងនេះដូចគ្នា ភិក្ខុកំលោះអង្គុយ សាមណេរឈរ មិនត្រូវអាបត្តិដល់អាចារ្យអ្នកប្រាប់ បើអាចារ្យគិតថា អញនឹងពោលដល់ភិក្ខុអង្គុយ ។ បើភិក្ខុកំលោះឈរ ចំណែកសាមណេរអង្គុយ ក៏មិនត្រូវអាបត្តិដល់អាចារ្យអ្នកពោលដែរ បើអាចារ្យគិតថា អញពោលដល់ភិក្ខុដែលឈរ ។

បើសាមណេរមួយអង្គអង្គុយក្នុងចំណោមភិក្ខុច្រើនរូប ជាអចិត្តកាបត្តិដល់អាចារ្យដែលឲ្យពោលធម៌ដោយបទ ក្នុងសាមណេរដែលនៅអង្គុយដែរ ។

បើសាមណេរឈរ ឬអង្គុយលះឧបចារៈ ព្រោះសាមណេរមិនទាក់ទងនៅក្នុងពួកភិក្ខុដែលអាចារ្យឲ្យពោល ( ធម៌ដោយបទ ) ទើបលោកដល់នូវការរាប់ថា រៀនយកគម្ពីរដោយលួចលាក់ ចេញទៅដោយភាគនៃទិសមួយព្រោះដូច្នោះ ទើបមិនត្រូវអាបត្តិ ( ដល់អាចារ្យ ) ។

បទថា **ឯកតោ សជ្ឈាយំ ករោន្តោ** សេចក្តីថា ឧបសម្បន្នកាលធ្វើការស្វាធ្យាយរួមគ្នាជាមួយអនុបសម្បន្នសូធ្យព្រមគ្នាជាមួយអនុបសម្បន្ននោះ

ឯង មិនត្រូវអាបត្តិ ។ សូម្បីភិក្ខុរៀនឧទ្ទេសក្នុងសម្នាក់នៃអនុបសម្បន្ន សូធ្យ រួមគ្នាជាមួយអនុបសម្បន្ននោះ ក៏មិនត្រូវអាបត្តិ ព្រោះថា ឧបសម្បន្ននេះ ក៏ដល់នូវការរាប់ថា ធ្វើការស្វាធ្យាយព្រមគ្នាពិត ។

បទថា **យេភុយ្យេន បគុណំ គន្ថំ ភណន្តំ ឱបាតេតិ** សេចក្តីថា បើក្នុងគាថាតែមួយ បាទនីមួយៗ មិនទាន់ចាំបាន បាទដ៏សេសចាំបាន នេះឈ្មោះថា គម្ពីរដែលស្ទាត់ជំនាញដោយច្រើន ។ សូម្បីក្នុងព្រះសូត្រ អ្នកសិក្សាគប្បីជ្រាបដោយន័យដូច្នេះ ។ មិនត្រូវអាបត្តិដល់ភិក្ខុដែលសូធ្យទាក់ឲ្យគន្ថៈនោះនៅគាំង ទើបសូធ្យព្រមគ្នា ដោយគិតថា លោកចូរសូត្រយ៉ាងនេះ ។

ពីរបទថា **ឱសារេន្តំ ឱបាតេតិ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលពោលជាមួយអនុបសម្បន្នដែលសូធ្យបៀតបៀន ( សូធ្យបន្ទំ ) ក្នុងចំណោមបរិស័ទថា លោកចូរសូធ្យយ៉ាងនេះ ហើយសូធ្យព្រមគ្នាជាមួយអនុបសម្បន្ននោះ ។ ឯពាក្យណា ដែលលោកពោលទុកក្នុងអដ្ឋកថាមហាបច្ចរីជាដើមថា ភិក្ខុដែលអនុបសម្បន្នពោលថា លោកម្ចាស់កុំសូធ្យជាមួយខ្ញុំ បើសូធ្យ ជាអនាបត្តិ ដូច្នេះ ។ ពាក្យនោះមិនមានក្នុងមហាអដ្ឋកថាទេ ។ ឯភាវៈនៃពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាមហាបច្ចរីជាដើមនោះ មិនមានឡើយ ត្រឹមត្រូវហើយ ( ឯការដែលអាបត្តិមិនមានដល់ភិក្ខុនោះ ត្រឹមត្រូវហើយ ) ។ ព្រោះហេតុអ្វី ព្រោះអាបត្តិកើតអំពីការធ្វើ ។ តែកាលមានការកាន់យកអត្ថក្រៅអំពីនេះ សិក្ខាបទនេះ គប្បីជាកិរិយាផង អកិរិយាផង បទដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានធម៌ដោយបទសមុដ្ឋាន កើតឡើងតាមវាចា ១ វាចា និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បទសោធម្មសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៥

[២៨៩] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ កាលគង់នៅអគាឡវចេតិយ ជិតក្រុងអាឡវី ។ សម័យនោះឯង ពួកឧបាសកតែងមកកាន់អារាមដើម្បីនឹងស្តាប់ធម៌ ។ កាលបើធម្មកថិកសម្តែងធម៌ចប់ហើយ ពួកភិក្ខុជាថេរៈក៏ទៅកាន់ទីដែលខ្លួននៅ ។ ភិក្ខុបួសថ្មីទាំងឡាយ ក៏ភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយ ថ្ងូរស្រមុកដេកលក់ជាមួយនឹងឧបាសកទាំងឡាយក្នុងសាលាសម្រាប់ធ្វើបុណ្យនោះឯង ។ ឧបាសកទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនទំនងជាមនុស្សភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយ ថ្ងូរស្រមុកសិងលក់ឡើយ ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ឧបាសកទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា មិនសមបីភិក្ខុទាំងឡាយសិងជាមួយនឹងអនុបសម្បន្នឡើយ ។ ខណៈនោះឯង ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយឮថា ពួកភិក្ខុទៅសិងជាមួយនឹងអនុបសម្បន្ន ( រឿងនេះ ) ពិតឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនទំនងដេកជាមួយនឹងអនុបសម្បន្នសោះ ម្នាលភិក្ខុទាំងឡាយកម្មនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង ។

[ ២៩០ ] គ្រានោះឯង ព្រះដ៏មានព្រះភាគ កាលគង់នៅក្រុងអាឡវីគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិក នាក្រុងកោសម្ពីទ្រង់យាងដោយលំដាប់ទៅ ក៏បានដល់ក្រុងកោសម្ពីនោះឯង ។ បានឮថាព្រះដ៏មានព្រះភាគទ្រង់សម្រេចឥរិយាបថនៅពទរិការាមជិតក្រុងកោសម្ពីនោះ ។ ភិក្ខុទាំងឡាយ បានពោលពាក្យនេះនឹងរាហុលដ៏មានអាយុថា ម្នាលរាហុលដ៏មានអាយុ សិក្ខាបទព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់បញ្ញត្តដូច្នេះថា ភិក្ខុមិនត្រូវដេកជាមួយនឹងអនុបសម្បន្នទេ ម្នាលរាហុល ( សាមណេរ ) ដ៏មានអាយុអ្នកចូរដឹងនូវទីសិងចុះ ។ គ្រានោះ រាហុលដ៏មានអាយុរកទីសិងមិនបាន ក៏ទៅសិងក្នុងវច្ចកុដិ ។ ខណៈនោះ ព្រះដ៏មានព្រះភាគទ្រង់តើនអំពីយប់ ក្នុងវេលាបច្ចូសសម័យនៃរាត្រី ហើយយាងចូលទៅទីវច្ចកុដិ លុះយាងចូលទៅដល់ហើយ ទ្រង់ឲ្យនូវព្រះសូរសៀង ( គឺគ្រហែមតាមទំនៀមវច្ចកុដិវត្ត ) ។ ឯរាហុលដ៏មានអាយុ ក៏គ្រហែមត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថានរណានៅក្នុងវច្ចកុដិនេះ ។ រាហុលក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគខ្ញុំព្រះអង្គឈ្មោះរាហុល ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលរាហុលហេតុអ្វីបានជាអ្នក មកដេកក្នុងវច្ចកុដិនេះ ។ គ្រានោះ រាហុលដ៏មានអាយុក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ

ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ សម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នកទាំងឡាយ សម្រេចទីដេកជាមួយនឹងអនុបសម្បន្នអស់ពីរ ឬបីយប់បាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាងពីរយប់ ឬបីយប់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[ ២៩១ ] ត្រង់ពាក្យថា ភិក្ខុណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា អនុបសម្បន្ននោះ គឺ លើកលែងតែភិក្ខុចេញ ក្រៅអំពីនោះ ជាអនុបសម្បន្នទាំងអស់ ។ ពាក្យថា លើសជាងពីរយប់ ឬបីយប់ឡើងទៅ គឺច្រើនជាងពីរយប់បីយប់ ។ ពាក្យថា ជាមួយ សេចក្តីថា ជាមួយគ្នា ។ ដែលហៅថា ទីដេក គឺ ទីដែលគេប្រក់ទាំងអស់ ដែលគេបិទបាំងទាំងអស់ ដែលគេប្រក់ដោយច្រើន ដែលគេបិទបាំងដោយច្រើន ។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា កាលបើព្រះអាទិត្យក្នុងថ្ងៃជាគម្រប់ ៤ អស្តង្គតទៅហើយ កាលបើអនុបសម្បន្នដេក ភិក្ខុក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុដេក អនុបសម្បន្នក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ពុំនោះសោត នៅដេកទាំងពីរនាក់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកទាំងពីរនាក់ក្រោកឡើងហើយ ដេកទៅវិញរឿយៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ២៩២ ] អនុបសម្បន្ន ភិក្ខុសម្គាល់ថាអនុបសម្បន្ន សម្រេចនូវទីដេករួមគ្នាលើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន តែភិក្ខុមានសេចក្តីសង្ស័យ ហើយសម្រេចនូវទីដេករួមគ្នា លើសជាង

ពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន ភិក្ខុសម្គាល់ថាឧបសម្បន្នទៅវិញ ហើយសម្រេចទូវទីដេករួមគ្នា លើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុត្រូវអាបត្តិទុក្កដក្នុងទីដែលប្រក់បាន ពាក់កណ្ដាល បិទបាំងពាក់កណ្ដាល ។ ឧបសម្បន្ន ភិក្ខុសម្គាល់ថា អនុ-បសម្បន្ន ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន តែភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន ភិក្ខុសម្គាល់ថាជាឧបសម្បន្នពិតមែនជាអនាបត្តិ ។

[ ២៩៣ ] អាបត្តិមិនមានដល់ភិក្ខុនៅអស់ ពីររាត្រីឬបីរាត្រី ( គឺដេកនៅជាមួយអនុបសម្បន្ន ) ដល់ភិក្ខុដែលដេកនៅថយអំពី ពីរឬបីរាត្រីចុះមកដល់ភិក្ខុដែលដេកនៅបានពីររាត្រីរួចហើយ ចេញទៅអំពីពេល មុនអរុណរះនៃរាត្រីជាគម្រប់បីហើយទើបមកដេកនៅជាថ្មីទៀត ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេប្រក់ទាំងអស់ តែគេមិនបានបិទបាំងទាំងអស់ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេបិទបាំងជិត តែគេប្រក់មិនពេញ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេមិនបានប្រក់ដោយច្រើន ( គឺប្រក់បានបន្តិចបន្តួច ) ។ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេ មិនបានបិទបាំងដោយច្រើន ( គឺបិទបាំងបន្តិចបន្តួច ) ដល់ភិក្ខុអ្នកអង្គុយ អនុបសម្បន្នដេក ដល់ភិក្ខុដេក អនុបសម្បន្នអង្គុយ ឬភិក្ខុដែលអង្គុយពីរនាក់នឹងអនុបសម្បន្ន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា

## មុសាវាទវគ្គ

## សហសេយ្យកសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូចតទៅនេះថា

[ ២៨៩ ] ពីរបទថា **មុដ្ឋស្សតី អសម្បជានា** នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចការមិនធ្វើសតិសម្បជញ្ញៈក្នុងបុព្វភាគ ។ ក្នុងកាលដែលចិត្តធ្លាក់ចុះកាន់ភវង្គ សតិសម្បជញ្ញៈនឹងមានអំពីណា ។

បទថា **វិក្កុជ្ជមានា** គឺមមើមមាយ ។

បទថា **កាកច្ឆមានា** បានដល់ បន្លឺសំឡេងមិនមានសេចក្តី ដូចសំឡេងក្អែកតាមប្រមុះ ។

បទថា **ឧបាសកា** បានដល់ ពួកឧបាសកដែលក្រោកឡើងមុន ។

[ ២៩០ ] ពីរបទថា **ឯតទវោចុំ** សេចក្តីថា ភិក្ខុទាំងឡាយបានពោលពាក្យនេះថា នែរាហុល សិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់បញ្ញត្តទុកហើយ ដូច្នេះ ដោយគោរពក្នុងសិក្ខាបទនោះឯង ។ តែដោយប្រក្រតី ព្រោះការគោរពក្នុងព្រះមានព្រះភាគ និងព្រោះរាហុលជាអ្នកស្រឡាញ់ក្នុងការសិក្សា ភិក្ខុទាំងនោះ កាលរាហុលសាមណេរនោះមកកាន់ទីលំនៅ ទើបរៀបចំគ្រែតូចៗ ឬបន្ទះក្តារណាមួយដែលនៅមាន ហើយប្រគេនចីវរ ( សង្ឃាដី ) ឬឧត្តរាសង្គ ដើម្បីឲ្យធ្វើជាគ្រឿងទទួលក្បាល ។ ក្នុងការដែលរាហុលសាមណេរជាអ្នកប្រាថ្នាក្នុងការសិក្សានោះ ( មានពាក្យជាគ្រឿងសាធកៈ ) ដូចតទៅ

នេះថា បានឮថា ភិក្ខុទាំងឡាយឃើញរាហុលសាមណេរនោះ កំពុងមកអំពីចម្ងាយ រមែងដាក់អំបោស និងបង្គីសំរាមទុកខាងក្រៅ ។ បន្ទាប់មក កាលភិក្ខុពួកដទៃពោលថា អាវុសោ នរណាយកមកទុកចោល ដូច្នេះ ភិក្ខុមួយពួកទៀតនឹងពោលយ៉ាងនេះថា អាវុសោ រាហុលសាមណេរត្រាច់មកក្នុងប្រទេសនេះ ប្រហែលលោកទុកចោលទេដឹង ឯរាហុលសាមណេរនោះ មិនធ្លាប់ពោលសូម្បីតែម្តងថា នេះមិនមែនជាការធ្វើរបស់ខ្ញុំទេ ក៏ទុកដាក់អំបោសជាដើមនោះហើយ សូមខមាទោសភិក្ខុទាំងឡាយជាមុន ទើបទៅ ។

ប្រើនបទថា **វច្ចកុដិយំ សេយ្យំ កប្បេសិ** សេចក្តីថា រាហុលសាមណេរនោះ ចម្រើននូវភាពជាអ្នកស្រឡាញ់ក្នុងសិក្ខានោះឯង ទើបមិនទៅកាន់សម្នាក់នៃព្រះធម្មសេនាបតី ព្រះមហាមោគ្គល្លាន និងព្រះអានន្ទត្ថេរជាដើម សម្រេចការដេកក្នុងវច្ចកុដិ ត្រង់បន្ទន់របស់ព្រះមានព្រះភាគ ។ បានឮថា កុដិនោះ គេបិទសន្ទះទ្វារទុក ធ្វើការប្រោះព្រំដោយគ្រឿងក្រអូប មានកម្រងផ្កាព្យួរទុកដេរដាស តាំងនៅដូចចេតិយដ្ឋាន មិនគួរដល់ការបរិភោគប្រើប្រាស់របស់អ្នកដទៃឡើយ ។

ពីរបទថា **ឧត្តរិ ទិរត្តតិរត្តំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់បានប្រទានបរិហារ ៣ រាត្រី ដើម្បីធ្វើការសង្គ្រោះដល់ពួកសាមណេរ ។ ពិតហើយ ការដែលភិក្ខុឲ្យពួកកុមារក្នុងត្រកូលបួសហើយ មិនអនុគ្រោះ មិនសមគួរ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃសហសេយ្យសិក្ខាបទ

[ ២៩១ ] បទថា **សហសេយ្យំ** គឺការដេករួមគ្នា ។សួរថាការដេក ពោល គឺការទម្រេតកាយ លោកហៅថា **សេយ្យ** ។ ភិក្ខុទាំងឡាយដេកក្នុងសេនាសនៈណា សេនាសនៈនោះ ( លោកហៅថា **សេយ្យ** គឺទីដេក ) ។ បណ្ដាទីដេកទាំង ២ យ៉ាងនោះ ដើម្បីទ្រង់សម្ដែងសេនាសនៈមុន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **សេយ្យា នាម សព្វច្ឆន្នា** ដូច្នេះជាដើម ។

ដើម្បីទ្រង់សម្ដែងការសណ្ដូកកាយ ទើបត្រាស់បទថា **អនុបសម្បន្នេ និបន្នេ ភិក្ខុ និបជ្ជតិ** ( កាលអនុបសម្បន្នដេក ភិក្ខុក៏ដេក ) ជាដើម ។ ព្រោះដូច្នោះ ក្នុងបទថា **សេយ្យំ កប្បេយ្យ** នេះ មានអត្ថដូច្នេះថា ភិក្ខុចូលទៅកាន់ទីដេក ពោល គឺសេនាសនៈ គប្បីសម្រេច គឺគប្បីចាត់ចែង បានដល់ ញុំាងការដេក គឺការសណ្ដូកកាយឲ្យសម្រេច ។

ដោយបទថា **សព្វច្ឆន្នា** ជាដើម ព្រះមានព្រះភាគត្រាស់លក្ខណៈនៃទីដេក ពោល គឺសេនាសនៈនោះ ។ ព្រោះហេតុនោះ សេនាសនៈណាប្រក់ទាំងអស់នោះឯង ខាងលើដោយគ្រឿងប្រក់ ៥ យ៉ាង ឬដោយវត្ថុណាមួយក៏ដោយ ទីដេកនេះ ឈ្មោះថា ប្រក់ទាំងអស់ ។

តែក្នុងអដ្ឋកថាទាំងឡាយ លោកកាន់យកវោហារដែលប្រាកដ ពោលដោយពាក្យស្រួលមាត់ថា ទីដេកដែលប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាង ឈ្មោះថា ប្រក់ទាំងអស់ ដូច្នេះ សូម្បីលោកពោលពាក្យហើយក៏ពិត ក៏មិនអាចធ្វើឲ្យមិនត្រូវអាបត្តិដល់ភិក្ខុដែលនៅក្នុងកុដិសំពត់បាន ព្រោះដូច្នោះ អ្នក

សិក្សាគប្បីជ្រាបគ្រឿងប្រក់ និងគ្រឿងបាំងក្នុងសិក្ខាបទនេះ ប្រភេទណាមួយ ដែលអាចបិទបាំងបាន ។

ពិតហើយ កាលកាន់យកគ្រឿងប្រក់ ៥ យ៉ាងប៉ុណ្ណោះ ការដេករួមក្នុងកុដិ សូម្បីប្រក់ដោយបទុះក្តារ ក៏មិនគប្បីមាន ។ សេនាសនៈណា ដែលគេខណ្ឌតាំងអំពីផែនដីឡើង រហូតដល់ដំបូល ដោយកំពែង ឬដោយវត្ថុណាមួយក៏ដោយ ដោយហោចសូម្បីដោយសំពត់ ទីដេកនេះ គប្បីជ្រាបថា បាំងទាំងអស់ ។

លោកពោលទុកក្នុងអដ្ឋកថាកុរុន្ទីថា ទីដេកសូម្បីគេការពារដោយគ្រឿងការពារ មានកំពែងជាដើម កម្ពស់ ១ ហត្ថ ១ ចំអាម ដោយបរិយាយយ៉ាងទាបបំផុត មិនប៉ះដំបូល ចាត់ថា បាំងទាំងអស់ដូចគ្នា ។ ព្រោះទីប្រក់ខាងលើច្រើនជាង ដែលមិនបានប្រក់តិចក្តី ទីដែលគេបិទបាំងដោយជុំវិញច្រើនជាងក្តី ទីដែលមិនបានបិទបាំងតិចក្តី ដូច្នោះ ទីដេកនេះ ឈ្មោះថា ប្រក់ដោយច្រើន បាំងដោយច្រើន ។

ប្រាសាទដែលប្រកបដោយលក្ខណៈយ៉ាងនេះ សូម្បី ៧ ជាន់ មានឧបចារៈតែមួយក្តី សាលាមុខ ៤ មានបន្ទប់រាប់រយ ក៏ដល់នូវការរាប់ថា ទីដេកតែមួយពិត ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ទីដេកនោះ ទើបត្រាស់ពាក្យថា ក្នុងថ្ងៃទី ៤ កាលព្រះអាទិត្យអស្តង្គតហើយ អនុបសម្បន្នដេក ភិក្ខុក៏ដេក ត្រូវអាបត្តិបាចិត្តិយ ដូច្នេះជាដើម ។ ហើយជាអាបត្តិបាចិត្តិយ ដោយគ្រាន់តែដេកលើទីដេកនោះប៉ុណ្ណោះ ។

បើសាមណេរច្រើនអង្គ ភិក្ខុមួយអង្គ ត្រូវអាបត្តិបាចិត្តិយជាច្រើនតាមចំនួនសាមណេរ បើសាមណេរទាំងនោះ ក្រោកដេកៗ ភិក្ខុត្រូវអាបត្តិគ្រប់ៗប្រយោគរបស់សាមណេរទាំងនោះ ។ ដោយការក្រោកដេកៗ របស់ភិក្ខុ ត្រូវអាបត្តិដល់ភិក្ខុ ព្រោះប្រយោគរបស់ភិក្ខុនោះឯង ។

បើភិក្ខុច្រើនអង្គ សាមណេរមួយអង្គ សូម្បីសាមណេរមួយអង្គ ក៏ធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុទាំងអស់ ។ សូម្បីដោយការក្រោកដេកៗ របស់សាមណេរនោះ ក៏ត្រូវអាបត្តិដល់ភិក្ខុទាំងឡាយដូចគ្នា ។ សូម្បីក្នុងការដែលភិក្ខុ និងសាមណេរច្រើនអង្គ ទាំងពីរចំណែក ក៏មានន័យយ៉ាងនេះដូចគ្នា ។

## អធិប្បាយ ចតុក្កៈ ៤ មានអាវាសចតុក្កៈជាដើម

ន័យម្យ៉ាងទៀត ក្នុងសិក្ខាបទនេះ គប្បីជ្រាបចតុក្កៈ មានអាវាសមួយកន្លែងជាដើម ។ សេចក្តីពិស្តារថា ភិក្ខុណា សម្រេចការដេករួមគ្នាជាមួយអនុបសម្បន្នត្រឹមតែមួយរូប ក្នុងអាវាសមួយជាមួយគ្នា អស់ ៣ រាត្រី ត្រូវអាបត្តិរាល់ថ្ងៃ ចាប់អំពីថ្ងៃទី ៤ ដល់ភិក្ខុនោះ ចំណែកភិក្ខុណា សម្រេចការដេករួមអស់ ៣ រាត្រីជាមួយអនុបសម្បន្ន ផ្សេងគ្នាច្រើននាក់ ក្នុងអាវាសមួយនោះឯង ត្រូវអាបត្តិរាល់ថ្ងៃដល់ភិក្ខុនោះ ( ចាប់អំពីថ្ងៃទី ៤ ) សូម្បីភិក្ខុណាសម្រេចការដេករួមអស់ ៣ រាត្រីជាមួយអនុបសម្បន្ន ត្រឹមតែមួយរូបប៉ុណ្ណោះក្នុងអាវាសផ្សេងគ្នា ត្រូវអាបត្តិរាល់ថ្ងៃដល់ភិក្ខុនោះ ( ចាប់ពីថ្ងៃទី ៤ ទៅ ) ។ ភិក្ខុណាដើរផ្លូវអស់ចម្ងាយរាប់រយយោជន៍ សម្រេចការដេករួម ( អស់ ៣ រាត្រី ) ជាមួយអនុបសម្បន្ន ផ្សេងគ្នាច្រើននាក់ ក្នុងអាវាសផ្សេងៗ គ្នា ត្រូវ

អាបត្តិដល់ភិក្ខុនោះរាល់ៗ ថ្ងៃ រាប់ពីថ្ងៃទី ៤ ទៅ ។

ឈ្មោះថា សហសេយ្យាបត្តិនេះ រមែងកើតសូម្បីជាមួយសត្វតិរច្ឆាន ព្រោះព្រះបាលីថា វៀរតែភិក្ខុចេញ ឈ្មោះថា អនុបសម្បន្នទាំងអស់ ។ ក្នុងសហសេយ្យាបត្តិនោះ ការកំណត់សត្វតិរច្ឆាន គប្បីជ្រាបដោយន័យដូចពោលហើយក្នុងមេថុនធម្មាបត្តិនោះឯង ព្រោះហេតុនោះ សូម្បីបណ្តាសត្វតិរច្ឆានប្រភេទជើង ៤ មានទន្សង ឆ្មា និងត្រកួតជាដើម តិរច្ឆានប្រភេទខ្លះ ចូលទៅដេកក្នុងទីមានឧបចារៈតែមួយជាមួយគ្នា ក្នុងសេនាសនៈដែលជាលំនៅរបស់ភិក្ខុ រាប់ថា ជាការដេករួមដូចគ្នា ។ បើសត្វនោះចូលទៅតាមប្រហោងដានដែលមានប្រហោង តាំងនៅលើជញ្ជាំងនៃប្រាសាទដែលគេសាងទុកខាងលើសសរទាំងឡាយ ដែលមានជញ្ជាំងមិនជាប់តគ្នាផ្ទៃខាងលើ ហើយដេកនៅខាងលើឈើធ្នឹម ចេញទៅតាមប្រហោងធ្នឹមនោះឯង មិនត្រូវអាបត្តិដល់ភិក្ខុដែលដេករួមខាងក្រោមប្រាសាទ ។

បើមានប្រហោងលើដំបូល សត្វនោះចូលទៅតាមប្រហោងនោះ នៅខាងក្នុងដំបូល ហើយចេញទៅតាមប្រហោងដើមនោះឯង មិនត្រូវអាបត្តិដល់ភិក្ខុដែលដេករួមខាងក្នុងដំបូល ត្រង់ផ្ទៃជាន់លើ ដែលមានឧបចារៈផ្សេងគ្នា មិនត្រូវអាបត្តិដល់ភិក្ខុដែលដេកត្រង់ផ្ទៃជាន់ក្រោម ។ បើពួកភិក្ខុឡើងទៅខាងក្នុងប្រាសាទទាំងនោះ ប្រើប្រាស់ល្វែងទាំងអស់ៗ មានឧបចារៈជាមួយគ្នា ត្រូវអាបត្តិដល់ភិក្ខុដែលដេកលើល្វែងណានីមួយ បណ្តាល្វែងទាំងអស់នោះ ។

ភិក្ខុដេកក្នុងសេនាសនៈ ដែលមានជញ្ជាំងជាបង្អា ដែលសាងដោយ

អាការដូចសភា សត្វព្រាបជាដើមចូលទៅដេកក្នុងទីទាំងឡាយ មានរូប ដែលធ្វើជារូបសត្វសាហាវជាដើម ក៏ត្រូវអាបត្តិដូចគ្នា ។ សត្វព្រាបជាដើមដេកខាងក្នុងសំយាបដែលលយចេញទៅខាងក្រៅជញ្ជាំង មិនត្រូវអាបត្តិ ។ បើសេនាសនៈមួល ឬ ៤ ជ្រុង មានបន្ទប់រាប់រយ ដោយជួរបន្ទប់ដែលមានដំបូលតែមួយ ។ បើពួកភិក្ខុចូលទៅក្នុងសេនាសនៈនោះ តាមទ្វារសាធារណៈ ទ្វារណាមួយហើយ បង្កួសចូលទៅក្នុងបន្ទប់ទាំងអស់ ដែលមានឧបចារបន្ទប់ មិនបានខណ្ឌដោយជញ្ជាំងឲ្យដាច់ពីគ្នា កាលអនុបសម្បន្នដេកហើយ ក្នុងបន្ទប់ ១ ក៏ត្រូវអាបត្តិដល់ភិក្ខុទាំងឡាយ ដែលដេកគ្រប់ៗ បន្ទប់ ។

បើបន្ទប់ទាំងឡាយមានយ៉មុខ ហើយយ៉មុខមិនប្រក់ខាងលើ បើជាទីមានផ្ទៃដែលខ្ពស់ អនុបសម្បន្នដេកត្រង់យ៉មុខ មិនធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុទាំងឡាយដែលដេកក្នុងបន្ទប់ឡើយ តែបើយ៉មុខមានដំបូលជាប់ជាមួយដំបូលនៃបន្ទប់នោះឯង អនុបសម្បន្នដេកត្រង់យ៉មុខនោះ ធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុគ្រប់អង្គ ព្រោះហេតុអ្វី ព្រោះជាបន្ទប់ប្រក់ទាំងអស់ និងបាំងទាំងអស់ ។ ពិតហើយ ជញ្ជាំងបន្ទប់នោះឯង ជាគ្រឿងខណ្ឌយ៉មុខនោះផងដែរ សមដោយន័យនេះឯង ក្នុងអដ្ឋកថាទាំងឡាយ ទើបលោកអាចារ្យកាត់អាបត្តិ ទុកក្នុងទ្វារទាំង ៤ នៃគ្រឿងខណ្ឌនោះ ( ជញ្ជាំង ) លោហៈប្រាសាទ ។ តែពាក្យណាដែលលោកពោលទុកក្នុងអដ្ឋកថាអន្ធកថា ពាក្យថា ក្នុងយ៉មុខដែលមិនបានបិទបាំងជាអនាបត្តិ លោកពោលសំដៅយកយ៉មុខផ្ទៃខាងលើ ក្រៅអំពីផ្ទៃផែនដី ដូច្នេះពាក្យនោះ លោកពោលសំដៅយកបន្ទប់ជួរ ដែលមានដំបូលតែមួយ ដែល

សាងទុកជាសង្កាត់ផ្សេងគ្នា ក្នុងដែនអន្ធកៈ ពាក្យដែលលោកពោលទុកថា លើផ្ទៃក្រៅអំពីផ្ទៃដី ក្នុងអដ្ឋកថាអន្ធកៈនោះ មិនមានក្នុងអដ្ឋកថាទាំងឡាយឡើយ ទាំងមិនសមនឹងព្រះបាលី ។ សេចក្តីពិត ផ្ទៃដី ទោះកម្ពស់ដល់ទៅ ១០ ហត្ថ ក៏មិនដល់នូវការរាប់ថា ជាគ្រឿងខណ្ឌបាន ។ ព្រោះដូច្នោះ ពាក្យណាដែលលោកពោលប្រមាណនៃផ្ទៃដីទុកក្នុងសិក្ខាបទទី ២ ក្នុងអន្ធកអដ្ឋកថានោះ ហើយពោលថា ឋានៈ ពោល គឺផ្ទៃដីនោះ ឈ្មោះថា ខណ្ឌដោយឧបចារៈតែមួយ ដូច្នេះ ពាក្យនោះ បណ្ឌិតមិនគួរកាន់យក ។

មហាប្រាសាទទាំងឡាយណា ដែលមានទ្រង់ទ្រាយជាសាលា ១ ខ្នង ២-៣ ខ្នង និង ៤ ខ្នង ភិក្ខុលាងជើងក្នុងឱកាសមួយ ហើយចូលទៅ អាចដើរវិលជុំវិញទៅបានក្នុងទីគ្រប់កន្លែង ក្នុងមហាប្រាសាទទាំងនោះ ភិក្ខុរមែងមិនផុតអំពីសហសេយ្យាបត្តិ បើប្រាសាទដែលគេសាងកំណត់ឧបចារៈទុកក្នុងទីនោះៗ ត្រូវអាបត្តិចំពោះក្នុងទីមានឧបចារៈជាមួយគ្នាប៉ុណ្ណោះ ។

ពួកជាងធ្វើជញ្ជាំងខណ្ឌត្រង់កណ្តាលនៃមណ្ឌប ដែលមានដំបូលបូកដោយបាយអ ប្រកបដោយទ្វារ ២ អនុបសម្បន្នចូលទៅតាមទ្វារមួយ ដេកក្នុងខេត្តម្ខាង ភិក្ខុដេកក្នុងខេត្តម្ខាង មិនត្រូវអាបត្តិ ។ ត្រង់ជញ្ជាំងមិនមានប្រហោងដែលល្មមសត្វតិរច្ឆាន មានទន្សងជាដើមចូលទៅបាន ពួកទន្សងដេកនៅក្នុងខេត្តម្ខាង មិនត្រូវអាបត្តិដូចគ្នា ព្រោះផ្ទះមិនឈ្មោះថា មានឧបចារៈតែមួយ ដោយប្រហោងឡើយ បើពួកជាងចោះត្រង់កណ្តាលជញ្ជាំង ហើយធ្វើទ្វារទុកប្រព្រឹត្តជាអាបត្តិ ព្រោះជាទីមានឧបចារៈតែមួយ ។ ភិក្ខុទាំងឡាយបិទសន្ទះទ្វារនោះហើយដេក ត្រូវអាបត្តិដូចគ្នា ។ ព្រោះការបិទទ្វារ ផ្ទះនឹង

ឈ្មោះថា មានឧបចារៈផ្សេងគ្នា ឬទ្វារនឹងឈ្មោះថា មិនមែនទ្វារក៏មិនមែន ។ ព្រោះសន្ទះទ្វារ គេធ្វើទុកដើម្បីប្រយោជន៍សម្រាប់ប្រើប្រាស់ ដោយការបិទបើកបានតាមសប្បាយ មិនមែនដើម្បីមិនឲ្យប្រើប្រាស់ទេ ។ បើភិក្ខុទាំង-ឡាយយកឥដ្ឋទាំងឡាយបិទទ្វារនោះដដែលទៀត មិនរាប់ថាទ្វារឡើយ រមែងតាំងនៅក្នុងការៈដែលមានឧបចារៈផ្សេងៗគ្នាដូចដើមនោះឯង ។ ខឿនចេតិយ ( ផ្ទះចេតិយ ) មានយ៉មុខវែង សន្ទះទ្វារមួយនៅខាងក្នុង មួយនៅខាងក្រៅ អនុបសម្បន្នដេកក្នុងចន្លោះទ្វារទាំង ៣ រមែងធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុដែលដេកខាងក្នុងខឿនចេតិយ ព្រោះមានឧបចារៈតែមួយ ។

មានពាក្យចោទសួរថា ក្នុងបទថា **ឪឃមុខំ** ជាដើមនោះ អាចារ្យអ្នកចោទសួរណា គប្បីមានបំណងដូច្នេះថា ឈ្មោះថា ទីដែលមានឧបចារៈតែមួយ និងមានឧបចារៈផ្សេងគ្នានេះ ព្រះមានព្រះភាគត្រាស់ទុកហើយ ក្នុងឧទ្ទោសិតសិក្ខាបទ តែក្នុងសិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់ពាក្យត្រឹមប៉ុណ្ណោះថា ដែលឈ្មោះថា ទីដេក បានដល់ ទីដេកដែលគេប្រក់ទាំងអស់ បាំងអស់ បាំងដោយច្រើន ប្រក់ដោយច្រើន បាំងដោយច្រើន ដូច្នេះប៉ុណ្ណោះ និងបន្ទប់ដែលបិទទ្វារហើយ រាប់ថា បាំងទាំងអស់ដូចគ្នា ព្រោះហេតុនោះ ក្នុងខឿននៃចេតិយនោះ ទើបជាអាបត្តិដល់ភិក្ខុដែលដេករួមជាមួយអនុប-សម្បន្នខាងក្នុងប៉ុណ្ណោះ មិនត្រូវអាបត្តិដល់ភិក្ខុដែលដេករួមជាមួយអនុប-សម្បន្នខាងក្រៅឡើយ ។

អាចារ្យអ្នកសួរនោះ ដែលសកវាទីគប្បីពោលជំទាស់យ៉ាងនេះថា ក្នុងខឿនចេតិយដែលមិនបិទទ្វារ ហេតុអ្វី ទើបត្រូវអាបត្តិដល់ភិក្ខុដែលដេករួមជា

មួយអនុបសម្បន្នខាងក្រៅទៅវិញ អាចារ្យអ្នកសួរគប្បីឆ្លើយថា ព្រោះយ៉មុខ និងបន្ទប់ប្រក់ទាំងអស់ ។

សកវាទីសួរថា បើបិទបន្ទប់ហើយ ដំបូលរុះរើចេញបានឬ អាចារ្យអ្នកចោទឆ្លើយថា រើចេញមិនបាន ព្រោះយ៉មុខ និងបន្ទប់បាំងទាំងអស់ ទើបរើមិនបាន ។

សកវាទីសួរថា ជញ្ជាំងខណ្ឌ ( យ៉មុខ ) រើចេញបានឬ អាចារ្យនឹងអ្នកចោទពោលថា រើចេញមិនបាន ( ព្រោះ ) ឧបចារៈខណ្ឌដោយសន្ទះទ្វារ ។ អាចារ្យអ្នកចោទនឹងដំណើរទៅឆ្ងាយពន់ពេក ដោយន័យយ៉ាងនេះហើយ នឹងវិលត្រឡប់មករកការមានឧបចារៈតែមួយ និងឧបចារៈផ្សេងគ្នានោះឯងទៀត ។

ន័យម្យ៉ាងទៀត បើអត្ថនឹងគប្បីជាការយល់បានងាយ ដោយហេតុត្រឹមតែព្យញ្ជនៈតែម្យ៉ាងសោត ទីដេកប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាង ប្រភេទណាមួយប៉ុណ្ណោះ ទើបរាប់ជាទីដេកបាន តាមព្រះបាលីថា ប្រក់ទាំងអស់ ទីដេកប្រក់ដោយគ្រឿងប្រក់ដទៃមិនមែនឡើយ ។ កាលបើយ៉ាងនេះ ក៏មិនគប្បីត្រូវអាបត្តិក្នុងទីដេក ដែលប្រក់ដោយបន្ទះក្តារជាដើម ។ ព្រោះមិនត្រូវអាបត្តិនោះ សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកដើម្បីប្រយោជន៍ណា ប្រ-យោជន៍នោះឯងគប្បីវិនាសទៅ ។ នឹងខូចប្រយោជន៍នោះទៅក្តី មិនខូចក្តី ហេតុអ្វី នឹងទៅកាន់យកពាក្យដែលព្រះមានព្រះភាគមិនបានត្រាស់ទុកទៅវិញ ឬបុគ្គលណាវិញ ដែលពោលថា គួរកាន់យកពាក្យដែលព្រះមានព្រះភាគមិន

បានត្រាស់ទុក ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ពាក្យនេះទុក ក្នុងអនិយតសិក្ខាបទទាំង ២ ថា អាសនៈដែលឈ្មោះថា កំបាំង គឺជាអាសនៈដែលគេបាំងដោយជញ្ជាំងសន្ទះទ្វារ កន្ទេលផែង វាំងនន ដើមឈើ សសរ ឬស៊ុមឯណាមួយ ដូច្នេះ ។

ព្រោះដូច្នោះ ក្នុងអនិយតសិក្ខាបទនោះ លោកកាន់យកអាសនៈដែលគេបិទបាំងដោយវត្ថុណាមួយ យ៉ាងណា ក្នុងសិក្ខាបទនេះ បណ្ឌិតក៏គប្បីកាន់យកសេនាសនៈនោះ យ៉ាងនោះ ។ ព្រោះហេតុនោះ សេនាសនៈណាមួយទោះតូចក្តី ធំក្តី ជាប់គ្នាក្តី មិនជាប់គ្នាក្តី ដោយវត្ថុដទៃ វែងក្តី មូលក្តី ៤ ជ្រុងក្តី មានផ្ទៃតែមួយជាន់ក្តី មានផ្ទៃច្រើនជាន់ក្តី ដែលមានឧបចារៈតែមួយជាសហសេយ្យាបត្តិ ក្នុងសេនាសនៈនោះៗ ទាំងអស់ ដែលប្រក់ទាំងអស់បាំងទាំងអស់ក្តី ប្រក់ដោយច្រើន ដោយគ្រឿងបិទបាំងឯណាមួយក្តី ដូច្នេះ ។

ក្នុងពាក្យថា ប្រក់ពាក់កណ្តាល បាំងពាក់កណ្តាល ត្រូវអាបត្តិទុក្កដនេះ ក្នុងមហាបច្ចរីក៏ពោលថា ត្រូវទុក្កដដូចគ្នា សូម្បីក្នុងពាក្យជាដើម យ៉ាងនេះថា ប្រក់ទាំងអស់ បាំងពាក់កណ្តាល ។ តែក្នុងមហាអដ្ឋកថាពោលថា ក្នុងសេនាសនៈដែលប្រក់ទាំងអស់ បាំងដោយច្រើន ត្រូវអាបត្តិបាចិត្តិយ ក្នុងសេនាសនៈប្រក់ទាំងអស់ បាំងពាក់កណ្តាល ត្រូវអាបត្តិបាចិត្តិយ ប្រក់ដោយច្រើន បាំងពាក់កណ្តាល ត្រូវអាបត្តិបាចិត្តិយ បាំងទាំងអស់ ប្រក់ដោយច្រើន ត្រូវអាបត្តិបាចិត្តិយ បាំងទាំងអស់ ប្រក់ពាក់កណ្តាល ត្រូវអាបត្តិបាចិត្តិយ បាំងដោយច្រើន ប្រក់ពាក់កណ្តាល ត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាចិត្តិយ ៧ រួមនឹងបាចិត្តិយដែលត្រាស់ទុកក្នុងបាលី ។ ( ក្នុងមហាអដ្ឋកថា ) ពោល

ថា ក្នុងសេនាសនៈប្រក់ទាំងអស់ បាំងតិចតួច ត្រូវអាបត្តិទុក្កដ ប្រក់ដោយច្រើន បាំងតិចតួច ត្រូវអាបត្តិទុក្កដ បាំងទាំងអស់ ប្រក់តិចតួច ត្រូវអាបត្តិទុក្កដ បាំងដោយច្រើន ប្រក់តិចតួច ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុក្កដ ៥ រួមគ្នានឹងទុក្កដក្នុងបាលី ។ ក្នុងសេនាសនៈដែលប្រក់ពាក់កណ្តាល បាំងតិចតួចជាអនាបត្តិ បាំងពាក់កណ្តាល ប្រក់តិចតួច ជាអនាបត្តិ ប្រក់តិចតួច បាំងតិចតួច ជាអនាបត្តិ ។

ក្នុងពាក្យថា ក្នុងទីប្រក់ទាំងអស់ មិនបាំងទាំងអស់នេះ លោកពោលថា មានបំណងយក **សេតច្ឆត្តមណ្ឌបវណ្ណា** ។ ផ្ទៃដីរមែងមិនដល់នូវការរាប់ថាជាជញ្ជាំងខណ្ឌបាន យ៉ាងណា សូម្បីពាក្យថា ក្នុងទីប្រក់ទាំងអស់ មិនបាំងទាំងអស់នេះ បណ្ឌិតក៏គប្បីជ្រាបពាក្យថា ផ្ទៃដីមិនដល់នូវការរាប់ថា ជាជញ្ជាំងដែលខណ្ឌបាននេះ ក៏យ៉ាងនោះ ។ បទដ៏សេសមានអត្ថពាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សហសេយ្យសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[ ២៩៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះអនុរុទ្ធដ៏មានអាយុនិមន្តទៅក្រុងសាវត្ថី ក្នុងកោសលជនបទ បានចូលទៅកាន់ស្រុកមួយក្នុងវេលាល្ងាច ។ សម័យនោះឯង ក្នុងស្រុកនោះ មានផ្ទះសម្រាប់សម្នាក់ ដែលស្រីម្នាក់បានសង់ទុកហើយ ។ គ្រានោះឯង ព្រះអនុរុទ្ធដ៏មានអាយុចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី បើនាងមិនមានសេចក្តីចង្អៀតចង្អល់ទេ អាត្មាសូមនៅក្នុងផ្ទះសម្នាក់បានមួយយប់ ។ ស្រីនោះទូលតបថា និមន្តគង់នៅចុះលោកម្ចាស់ ។ សូម្បីពួកជនអ្នកដំណើរដទៃទៀត ក៏ចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងស្រីនោះថា បពិត្រនាងជាម្ចាស់ បើនាងមិនមានសេចក្តីចង្អៀតចិត្តទេ យើងទាំងឡាយសូមនៅក្នុងផ្ទះសម្នាក់បានមួយយប់ ។ ស្រីនោះប្រាប់ថា មានសមណៈជាម្ចាស់មួយអង្គនុ៎ះ លោកចូលទៅមុនហើយ បើសមណៈនុ៎ះលោកព្រម អ្នកទាំងឡាយចូរនៅចុះ ។ គ្រានោះឯង អ្នកដំណើរទាំងនោះក៏ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានទូលពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន បើលោកមិនមានសេចក្តីចង្អៀតចិត្តទេ ខ្ញុំករុណាទាំងឡាយ សូមនៅក្នុងផ្ទះសម្នាក់ ( នេះ ) បានមួយយប់ផង ។ ព្រះអនុរុទ្ធប្រាប់ថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយនៅចុះ ។ ឯស្រីនោះ ក៏មានចិត្តប្រតិព័ទ្ធក្នុងព្រះអនុរុទ្ធដ៏មានអាយុ

តាំងអំពីបានឃើញ ។ លំដាប់នោះ ស្រីនោះក៏ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ នឹងគង់នៅប្រឡូកប្រឡំដោយមនុស្សទាំងឡាយនេះមិនស្រួលទេ បពិត្រលោកដ៏ចម្រើន ចាំខ្ញុំករុណារៀបចំគ្រែតូចមួយខាងក្នុងដើម្បីលោកម្ចាស់ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏ទទួលព្រមដោយតុណ្ហីភាព ។ ឯស្រីនោះក៏រៀបចំគ្រែតូច ខាងក្នុងដោយខ្លួនឯង ដើម្បីព្រះអនុរុទ្ធដ៏មានអាយុ ហើយប្រដាប់តាក់តែងរាងកាយ ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានពិតពាក្យនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់មានរូបល្អគួរទស្សនាការ នាំមកនូវសេចក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អដែរ គួរមើលមើល នាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចម្រើន ខ្ញុំករុណាសូមធ្វើជាប្រពន្ធរបស់លោកម្ចាស់ ។ កាលដែលស្រីនោះនិយាយយ៉ាងនេះហើយ ព្រះអនុរុទ្ធដ៏មានអាយុក៏ស្ងៀមនៅ ។ ស្រីនោះបាននិយាយពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុ ជាគម្រប់ពីរដងទៀត ។បេ។ ជាគម្រប់បីដងទៀតថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់មានរូបល្អ គួរទស្សនាការ នាំមកនូវសេចក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អ គួរមើលមើល នាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ព្រមទទួលយកនូវខ្ញុំករុណា និងសម្បត្តិទាំងពួងចុះ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏ស្ងៀមនៅអស់វារៈជាគម្រប់បីដងផង ។ ឯស្រីនោះក៏ដាក់សំពត់សាដកទាំងអស់ផុតចេញ ( ពីខ្លួន ) ហើយដើរខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ ខាងមុខ

នៃព្រះអនុរុទ្ធដ៏មានអាយុ ។ ខណៈនោះ ព្រះអនុរុទ្ធ ដ៏មានអាយុក៏សង្រួមនូវឥន្ទ្រិយទាំងឡាយ ហើយមិនបានក្រឡេកមើល មិនចរចានឹងស្រីនោះឡើយ ។ ឯស្រីនោះក៏លាន់មាត់ថា អើហ្ន៎ គួរឲ្យអស្ចារ្យ ពេកណាស់ អើហ្ន៎ មិនដែលឃើញទេតើ មនុស្សទាំងឡាយជាច្រើន រមែងបញ្ជូនមកដោយរយកហាបណៈខ្លះ ដោយពាន់កហាបណៈខ្លះ ដើម្បីរូបអញ ឯសមណៈនេះ អញខំលួងលោមដល់ម្ល៉េះដោយខ្លួនឯង ក៏ឥតមានត្រូវការ ចំពោះខ្លួនអញ និងទ្រព្យសម្បត្តិទាំងពួងដល់តិចសោះ ( ជាដូច្នេះ ) ហើយ ក៏ស្លៀកសំពត់សាដក ហើយក្រាបចុះដោយត្បូងទៀបបាទានៃព្រះអនុរុទ្ធដ៏មានអាយុ ហើយសូមខមាទោសនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណា ជាស្រីមានកំហុសហើយ ព្រោះខ្ញុំព្រះករុណាជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិនឈ្លាសខ្ញុំឯណាដែលបានធ្វើនូវកំហុស មានសភាពយ៉ាងនេះហើយ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ ទទួលនូវកំហុសតាមទោសរបស់ខ្ញុំព្រះករុណានោះ ដើម្បីនឹងសង្រួមតទៅទៀត ។ ព្រះអនុរុទ្ធក៏តបថា ម្នាលប្អូនស្រី ណ្ហើយចុះនាងមានកំហុសហើយ ព្រោះនាង ជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិនឈ្លាសនាងណាដែលបានធ្វើនូវកំហុស មានសភាពយ៉ាងនេះហើយ ម្នាលប្អូនស្រី តែនាងឯងបានឃើញនូវកំហុសដោយកំហុសពិត ហើយសម្តែងដោយសមគួរតាមធម៌ យើងនឹងទទួលនូវកំហុស របស់នាងឯងនោះបាន អ្នកណាមួយបានឃើញនូវកំហុសដោយកំហុសពិត ហើយសម្តែងដោយសមគួរតាមធម៌ ហើយតាំងនៅក្នុងសេចក្តីសង្រួមតទៅ ម្នាលប្អូនស្រី ការនេះជាសេចក្តីចម្រើនរបស់

អ្នកនោះ ក្នុងអរិយវិន័យ ។ ឯស្រីនោះ លុះកន្លងរាត្រីនោះទៅ ក៏បវារណា និមន្តព្រះអនុរុទ្ធដ៏មានអាយុឲ្យឆាន់បង្អែម និងចម្អាបដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ហើយអង្គុយនៅក្នុងទីដ៏សមគួរ ជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុ ដែលឆាន់ហើយ និងលាងបាត្រ លាងដៃរួចហើយ ។ ព្រះអនុរុទ្ធដ៏មានអាយុ បានពន្យល់ស្រី ដែលអង្គុយក្នុងទីដ៏សមគួរនោះឲ្យយល់ច្បាស់ ឲ្យទទួលយក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាប្រកបដោយធម៌ ។ ឯស្រីនោះ លុះព្រះអនុរុទ្ធដ៏មានអាយុបានពន្យល់ឲ្យយល់ច្បាស់ ឲ្យទទួលយក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចា ប្រកបដោយធម៌ហើយ ក៏បាននិយាយពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ពាក្យនេះភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចម្រើន ពាក្យនេះភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចម្រើន បុគ្គលផ្ងារឡើងនូវភាជន៍ដែលគេផ្កាប់ចុះ ឬ បើកចេញនូវវត្ថុដែលគេបិទបាំងទុក ពុំនោះសោតដូចបុគ្គលប្រាប់ផ្លូវ ដល់មនុស្សដែលវង្វេងផ្លូវ ឬដូចបុគ្គលកាន់ប្រទីបទ្រោលក្នុងទីងងឹត បំភ្លឺដល់មនុស្សដែលមានចក្ខុឲ្យឃើញរូបគ្នាបាន សេចក្តីនេះមានឧបមាដូចម្តេចមិញ ព្រះអនុរុទ្ធជាម្ចាស់បានប្រកាសធម៌ ដោយបរិយាយដ៏ច្រើន ក៏មានឧបមេយ្យដូច្នោះដែរ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះដ៏មានព្រះភាគនោះ ព្រមទាំងព្រះធម៌ និងព្រះភិក្ខុសង្ឃ ថាជាទីពឹងទីរឭក សូមលោកម្ចាស់ចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសិកាដល់នូវ ( ត្រៃ ) សរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមតទៅ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុនិមន្តទៅក្រុងសាវត្ថី ហើយបានប្រាប់សេចក្តីនេះ ដល់

ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ព្រះអនុរុទ្ធដ៏មានអាយុ មិនគួរនឹងទៅអាស្រ័យទីដេកជាមួយនឹងមាតុគ្រាមសោះ ។ ខណៈនោះ ភិក្ខុទាំងនោះក៏បានទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធ បានឮថា អ្នកសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមពិតមែនឬ ។ ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលអនុរុទ្ធ អ្នកមិនគួរនឹងសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមទេ ម្នាលអនុរុទ្ធ អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

[ ២៩៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។បេ។ ដែលហៅថា មាតុគ្រាមនោះ គឺស្រីមនុស្ស ឯយក្ខស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ដោយហោចទៅសូម្បីតែក្មេងស្រីដែលកើតក្នុងថ្ងៃនោះ ( ក៏ហៅថា មាតុគ្រាមដែរ ) នឹងបាច់ពោលថ្វី ដល់មនុស្សស្រីដែលធំ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា ។ ដែលហៅថា ទីដេក គឺទីដេកដែលគេប្រក់ទាំងអស់ គេបិទបាំងទាំងអស់ គេប្រក់ដោយច្រើន គេបិទបាំងដោយច្រើន ។ ពាក្យថា សម្រេចទីដេក សេចក្តីថា វេលាព្រះអាទិត្យអស្តង្គតហើយ មាតុគ្រាមដេក ភិក្ខុក៏ដេកដែរ ភិក្ខុត្រូវអាបត្តិ

បាចិត្តិយ ។ កាលភិក្ខុដេក មាតុគ្រាមក៏ដេកដែរ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ពុំនោះសោត ជនទាំង ២ គឺភិក្ខុ និងមាតុគ្រាមដេកព្រមគ្នា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីរនោះក្រោកឡើង ហើយដេកទៅវិញរឿយៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ២៩៦ ] មាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាមពិតមែន ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម តែភិក្ខុមានសេចក្តីសង្ស័យ ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុត្រូវអាបត្តិទុក្កដ ( ព្រោះដេក ) ក្នុងទីដេកដែលគេប្រក់បានពាក់កណ្តាល គេបិទបាំងបានពាក់កណ្តាល ។ ភិក្ខុសម្រេចទីដេកជាមួយនឹងយក្ខស្រីក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី តិរច្ឆានញីក្តី ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថាមិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ ។

[ ២៩៧ ] ( អាបត្តិមិនមានដល់ភិក្ខុសម្រេចទីដេកជាមួយនឹងមាតុគ្រាម ) ក្នុងទីដែលគេប្រក់ទាំងអស់ តែមិនបានបិទបាំងជុំវិញ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាមក្នុងទីដែលគេបិទបាំងជុំវិញ តែគេមិនបានប្រក់សោះឡើយ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាមក្នុងទីដែលគេមិនបានប្រក់ដោយច្រើន គឺ ប្រក់បានបន្តិចបន្តួច គេមិនបានបិទបាំងដោយច្រើន គឺបិទបាំងបន្តិចបន្តួច ដល់ភិក្ខុ

ដែលអន្ទុយ មាតុគ្រាមដេក ដល់ភិក្ខុដេក មាតុគ្រាមអន្ទុយ ដល់ភិក្ខុដែលអន្ទុយ មាតុគ្រាមក៏អន្ទុយទាំងពីរនាក់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ៦

# អដ្ឋកថា

# មុសាវាទវគ្គ

# ទុតិយសហសេយ្យកសិក្ខាបទ

*គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសហសេយ្យកសិក្ខាបទ ដូចតទៅនេះ*

*[ ២៩៤ ] បទថា* **អាវសថាគារំ** *បានដល់ ផ្ទះសម្នាក់របស់ពួកអាគន្តុកៈ ។*

*ពីរបទថា* **បញ្ញត្តំ ហោតិ** *បានដល់ ជាទីកន្លែងដែលស្ត្រីនោះសាងទុកព្រោះជាអ្នកប្រាថ្នាបុណ្យ ។*

*បទថា* **យេន សា ឥត្ថី តេនុបសង្កមិ** *សេចក្តីថា ព្រះអនុរុទ្ធបានឮពួកអ្នកស្រុកថា មានផ្ទះសម្នាក់ដែលគេសង់ទុកក្នុងទីឈ្មោះនោះ ដូច្នេះ ទើបចូលទៅរក ។*

*បទថា* **គន្ធគន្ធិនី** *មានវិគ្គហៈថា ក្លិននៃគ្រឿងក្រអូប មានក្រស្នា និងកំញានជាដើម ឈ្មោះថា ក្លិនគ្រឿងក្រអូប ក្លិនគ្រឿងក្រអូបនោះ មានដល់ស្រីនោះ ហេតុនោះ ទើបស្រីនោះ ឈ្មោះថា* **គន្ធគន្ធិនី** *អ្នកមានក្លិនក្រអូប ។*

*ពីរបទថា* **សាដកំ និក្ខិបិត្វា** *សេចក្តីថា ស្រីនោះគិតថា ហេតុអ្វីហ្ន៎ លោកម្ចាស់អង្គនេះ សូម្បីឃើញអាការប្លែកបែបនេះគប្បីកើតតម្រេក ដូច្នេះ ទើបបានធ្វើយ៉ាងនោះ ។*

*បទថា* **ឱក្ខិបិត្វា** *បានដល់ ដាក់ចុះ ( នូវឥន្ទ្រិយ ) ។*

*ការខុសក្លាំងក្លាត់ ឈ្មោះថា ទោសដែលប្រព្រឹត្តកន្លង ។*

ពីរបទថា **មំ អចុត្តមា** បានដល់ ប្រព្រឹត្តទៅកន្ទង គឺគ្របសង្កត់នូវខ្ញុំ ។ បទដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងសិក្ខាបទមុន នោះឯង ។ ឯការប្លែកគ្នា មានត្រឹមប៉ុណ្ណេះ គឺក្នុងសិក្ខាបទមុនត្រូវអាបត្តិក្នុង ថ្ងៃទី ៤ ក្នុងសិក្ខាបទនេះ ត្រូវអាបត្តិសូម្បីក្នុងថ្ងៃទី ១ ។ ត្រូវអាបត្តិទុក្កដ (ដល់ភិក្ខុដែលសម្រេចការដេករួមគ្នា) ជាមួយស្រីយក្ខ និងស្រីប្រេត ដែល មានរូបប្រាកដ និងសត្វតិរច្ឆានញី ចំពោះត្រង់វត្ថុនៃមេថុនធម្ម ។ ឯសត្វ តិរច្ឆានញីដ៏សេស ជាអនាបត្តិ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទ មុននោះឯង ដូច្នេះឯង ។

ទុតិយសហសេយ្យសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ២៩៨ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្ត ជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលណោះឯង ឧទាយិដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូល ក្នុងក្រុងសាវត្ថី តែងចូលទៅរកត្រកូលទាំងឡាយច្រើន ។ លំដាប់នោះ ឧទាយិដ៏មានអាយុ វេលាព្រឹកព្រហាម ក៏ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រចីវរ ចូលទៅរកត្រកូលមួយ ។ គ្រានោះឯង ស្រីជាមេផ្ទះ អង្គុយជិតទ្វារផ្ទះ ។ ស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏អង្គុយជិតទ្វារផ្ទះសម្នាក់ ។ លំដាប់នោះ ឧទាយិដ៏មានអាយុ ចូលទៅរកស្រីជាមេផ្ទះ លុះចូលទៅហើយ ក៏សម្តែងធម៌ជិតត្រចៀកស្រីជាមេផ្ទះ ។ ទើបស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា សមណៈនោះ ជាសហាយរបស់ម្តាយក្មេក ឬនិយាយចង់គ្នា ។ ពេលនោះ ឧទាយិដ៏មានអាយុ លុះសម្តែងធម៌ជិតត្រចៀកស្រីជាមេផ្ទះហើយ ក៏ចូលទៅរកស្រីជាកូនប្រសានៃស្រីមេផ្ទះ លុះចូលទៅហើយ ក៏សម្តែងធម៌ជិតត្រចៀក ស្រីជាកូនប្រសានៃស្រីមេផ្ទះ ( នោះទៀត ) ។ ទើបស្រីជាមេផ្ទះមានសេចក្តីត្រិះរិះដូច្នេះថា សមណៈនោះ ជាសហាយរបស់ស្រីជាកូនប្រសានៃអញជាមេផ្ទះ ឬថា និយាយចង់គ្នា ។ លំដាប់នោះ ឧទាយិដ៏មានអាយុ លុះសម្តែងធម៌ជិតត្រចៀកស្រីជាកូនប្រសានៃស្រីមេផ្ទះហើយ ក៏ចៀសចេញទៅ ។ គ្រានោះឯង ស្រីជាមេផ្ទះបាននិយាយពាក្យនេះនឹងស្រីជាកូនប្រសានៃខ្លួនជាមេផ្ទះថា នែហង សមណៈនោះបាននិយាយពាក្យអ្វីខ្លះ នឹងហងឯង ។

ស្រីជាកូនប្រសាតបថា បពិត្រអ្នកម៉ែ សមណៈនោះសម្តែងធម៌ដល់ខ្ញុំ ចំណែកឯអ្នកម៉ែ សមណៈនោះបាននិយាយពាក្យអ្វីឲ្យខ្ញុំ ។ ម្តាយក្មេកប្រាប់ថា សមណៈ នោះសម្តែងធម៌ដល់អញដែរ ។ ស្រីទាំងពីរនាក់នោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយិ មិនសមបីបើនឹងសម្តែងធម៌ ( ខ្សឹប ) ជិតត្រចៀកមាតុគ្រាមសោះ ធម្មតាសមណៈ គួរតែសម្តែងធម៌ដោយសំឡេងក្បោះក្បាយដោយច្បាស់លាស់ទេតើ ។ ភិក្ខុទាំងឡាយបានឮពាក្យស្រីទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនសមបីបើនឹងសម្តែងធម៌ដល់មាតុគ្រាមសោះ ។ ឯភិក្ខុទាំងនោះ ក៏នាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧទាយិ បានឮថា អ្នកឯងសម្តែងធម៌ដល់មាតុគ្រាម ពិតមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែនហើយ ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងសម្តែងធម៌ដល់មាតុគ្រាមទេ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ សម្តែងធម៌ដល់មាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយដោយប្រការដូច្នេះ ។

[២៩៩] សម័យនោះឯង ពួកឧបាសិកាឃើញភិក្ខុទាំងឡាយ ក៏និយាយ

ពាក្យនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណាសូមអារាធនា សូមលោកម្ចាស់ទាំងឡាយ មេត្តាសម្តែងធម៌ឲ្យទាន ពួកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ការសម្តែងធម៌ដល់មាតុគ្រាមមិនគួរទេ ។ ពួកឧបាសិកាទូលថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណាសូមអារាធនា សូមលោកម្ចាស់ទាំងឡាយ មេត្តាសម្តែងធម៌ត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឲ្យទានចុះ ពួកខ្ញុំករុណា អាចចាំធម៌បាន ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ ពួកភិក្ខុនិយាយថា ម្នាលប្អូនស្រី ការសម្តែងធម៌ដល់មាតុគ្រាមមិនគួរទេ ថាដូច្នោះហើយ ក៏មានសេចក្តីរង្កៀសខានសម្តែងធម៌ទៅ ។ ពួកឧបាសិកាក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា មិនសមបីបើលោកម្ចាស់ទាំងឡាយ ពួកយើងខ្ញុំអង្វរទាំងម៉្លេះ ក៏មិនសម្តែងធម៌ឲ្យទានសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យឧបាសិកាទាំងនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសម្តែងធម៌ដល់មាតុគ្រាម បានត្រឹមតែប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសម្តែងធម៌ដល់មាតុគ្រាម លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

[ ៣០០ ] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានដឹងថា ព្រះដ៏មានព្រះភាគ

បានអនុញ្ញាតឲ្យភិក្ខុសម្ដែងធម៌ដល់មាតុគ្រាម បានត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ហើយ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះ ក៏ឲ្យបុរសដែលមិនដឹងក្ដី អង្គុយជិត ហើយសម្ដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬ ប្រាំមួយម៉ាត់ឡើងទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា មិនសមបីបើពួកឆព្វគ្គិយភិក្ខុឲ្យបុរសដែលមិនដឹងក្ដី អង្គុយជិត ហើយសម្ដែងធម៌ដល់មាតុគ្រាម លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅសោះ ឯភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយឲ្យបុរសដែលមិនដឹងក្ដីអង្គុយជិតហើយសម្ដែងធម៌ដល់មាតុគ្រាម លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបីបើអ្នកទាំងឡាយឲ្យបុរសដែលមិនដឹងក្ដីអង្គុយជិត ហើយសម្ដែងធម៌ដល់មាតុគ្រាមលើសពី ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខានេះយ៉ាងនេះថា ភិក្ខុណាមួយ សម្ដែងធម៌ដល់មាតុគ្រាម លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានបុរសដែលដឹងក្ដី ( អង្គុយជិត ) ។

[ ៣០១ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី

១ នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺមនុស្សស្រីដែលដឹងក្តី អាច ដឹងពាក្យល្អពាក្យអាក្រក់ ពាក្យទ្រគោះ ពាក្យមិនទ្រគោះ ឯយក្ខស្រី ប្រេតស្រី តិរច្ឆានញីមិនហៅថាមាតុគ្រាមទេ ។ ពាក្យថា លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ឡើងទៅ គឺច្រើនជាង ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ។ ដែលហៅថា ធម៌ គឺធម៌ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងទុកហើយ សាវកសម្តែងទុកហើយ ឥសី សម្តែងទុកហើយ ទេវតាសម្តែងទុកហើយ ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យ នូវបាលី ។ ពាក្យថា សម្តែង គឺភិក្ខុសម្តែងដោយបទ ត្រូវអាបត្តិបាចិត្តិយ រាល់ៗ បទ ។ ភិក្ខុសម្តែងដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ៗ អក្ខរៈ ។ ពាក្យថា វៀរលែងតែមានបុរសដែលដឹងក្តី គឺលើកលែងតែបុរសដែលដឹងក្តី ។ ដែលហៅថា អ្នកដឹងក្តី គឺបុរសដែលអាចដឹងនូវពាក្យល្អ ពាក្យអាក្រក់ ពាក្យទ្រគោះ ពាក្យមិនទ្រគោះ ។

[ ៣០២ ] មាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាម ហើយសម្តែងធម៌ឲ្យ លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី ( នៅជិតខាង ) ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ហើយសម្តែងធម៌ ឲ្យលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី ( នៅជិត ខាង ) ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម ហើយសម្តែងធម៌ឲ្យលើសពី ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មាន បុរសដឹងក្តី ( នៅជិតខាង ) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្តែងធម៌ឲ្យលើស ពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដល់យក្ខស្រីក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី

តិរច្ឆានញីមានរាងកាយដូចមនុស្សស្រីក្តី ដោយគ្មានបុរសដឹងក្តី ( នៅជិតខាង ) ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិអ្វីឡើយ ។

[ ៣០៣ ] អាបត្តិមិនមានដល់ភិក្ខុដែលសម្តែងធម៌ ( ដល់មាតុគ្រាម ) មានបុរសដឹងក្តី ( នៅជិតខាង ) ដល់ភិក្ខុសម្តែងធម៌ត្រឹម ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសម្តែងធម៌តិចជាងប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសម្តែងធម៌ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ក្រោកឡើងហើយ អង្គុយទៅវិញសម្តែងទៀត ដល់ភិក្ខុដែលសម្តែងធម៌ដល់មាតុគ្រាមដែលក្រោកឡើងហើយ អង្គុយទៅវិញក្នុងខណៈនោះ ដល់ភិក្ខុសម្តែងធម៌ដល់មាតុគ្រាមឯទៀត ( ក្រៅពីមាតុគ្រាមដែលបានសម្តែងឲ្យស្តាប់ហើយ ) ដល់ភិក្ខុដែលមាតុគ្រាមសួរប្រស្នា ហើយឆ្លើយដោះប្រស្នា ( នោះ ) ដល់ភិក្ខុសម្តែងធម៌ឲ្យអ្នកដទៃស្តាប់ មាតុគ្រាមអង្គុយស្តាប់ផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា

## មុសាវាទវគ្គ

## ធម្មទេសនាសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ

[ ២៩៨ ] ស្រីមេផ្ទះ ឈ្មោះថា **ឃរណី**។

បទថា **និវេសនទ្វារេ** បានដល់ ទ្វារធំនៃនិវេសន៍ ( ផ្ទះ ) ។

ស្រីកូនប្រសាក្នុងផ្ទះនោះ ឈ្មោះថា **ឃរសុណ្ហា** ។

បទថា **អាវសថទ្វារេ** បានដល់ ត្រង់ទ្វារបន្ទប់ដេក ។

បទថា **វិសទ្ទេន** បានដល់ ដោយសំឡេងជាក់ច្បាស់ល្អ ។

បទថា **វិវដេន** បានដល់ បើកផ្លារ គឺមិនបិទបាំង ។

ពីរបទថា **ធម្មោ ទេសេតព្វោ** សេចក្តីថា ព្រះធម្មកថិកគួរសម្តែងធម៌ ដោយសរណៈ និងសីលជាដើមនេះ ។

[ ២៩៩ ] បទថា **អញ្ញាតុំ** គឺ ( អាច ) ដឹងទូទៅបាន ។

[ ៣០០ ] ពីរបទថា **វិញ្ញុនា បុរិសវិគ្គហេន** សេចក្តីថា ( វៀរ ) បុរសអ្នកដឹងក្តី មិនមែនយក្ខ មិនមែនប្រេត មិនមែនតិរច្ឆាន សូម្បីអ្នកកាឡាខូនជាបុរស ។

## អនាបត្តិនៃធម្មទេសនាសិក្ខាបទ

[ ៣០៣ ] ច្រើនបទថា **អនាបត្តិ វិញ្ញុនា បុរិសវិគ្គហេន** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុ ដែលសម្តែងធម៌សូម្បីច្រើនដល់ស្រីឈរជាមួយបុរស

ដែលដឹងក្ដី ។

បទថា **ឆប្បញ្ចវាចាហិ** សេចក្ដីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលសម្ដែង ( ធម៌ ) ដោយវាចា ៥ ឬ ៦ ម៉ាត់ ។ ក្នុងបទថា **ឆប្បញ្ចវាចាហិ** នេះ បណ្ឌិតគប្បីជ្រាបប្រមាណនៃវាចា ក្នុងធម៌ទាំងពួងយ៉ាងនេះ គឺគាថាមួយបាទ ឈ្មោះថា វាចាមួយម៉ាត់ ។ បើភិក្ខុបំណាងនឹងពោលអដ្ឋកថាក្ដី ឬមានរឿង ធម្មបទ និងជាតកជាដើមក្ដី និងពោលត្រឹម ៥ ឬ ៦ បទប៉ុណ្ណោះ គួរ បើ ពោលព្រមដោយបាលី គប្បីពោលធម៌កុំឲ្យលើស ៦ បទ យ៉ាងនេះ គឺអំពី ព្រះបាលីមួយបទ អំពីអដ្ឋកថា ៥ បទ ។ ពិតហើយ ធម៌មានប្រភេទដូច ពោលក្នុងបទសោធម្ម ចាត់ជាធម៌ដូចគ្នាទាំងអស់ ក្នុងសិក្ខាបទនេះ ។

ពីរបទថា **តស្មឹ ខណេ** គឺសម្ដែងក្នុងខណៈនោះ ។ មួយវិញទៀត បទ ថា **តស្មឹ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ សេចក្ដីថា រមែងសម្ដែង ដល់ស្រីនោះ ។

ពីរបទថា **អញ្ញស្ស មាតុគាមស្ស** សេចក្ដីថា ភិក្ខុអង្គុយលើអាសនៈ មួយ សម្ដែងធម៌ដល់មាតុគ្រាមរាប់រយនាក់ យ៉ាងនេះ គឺសម្ដែងដល់ស្រីម្នាក់ ហើយសម្ដែងដល់ស្រីដទៃដែលមកក្រោយៗ ទៀត ។ ក្នុងមហាបច្ចរីអដ្ឋកថា ពោលទុកថា ភិក្ខុពោលថា អាត្មានឹងសម្ដែងគាថាដល់ពួកនាងម្នាក់មួយគាថា ពួកនាងចូរស្ដាប់គាថានោះ ហើយសម្ដែងធម៌ដល់ពួកមាតុគ្រាម ដែលអង្គុយ ប្រជុំគ្នា មិនត្រូវអាបត្តិ ។ ភិក្ខុធ្វើការដាក់ចិត្តតាំងពីដំបូងថា អាត្មាអញនឹង ពោលគាថាដល់ស្រីម្នាក់មួយគាថា ដូច្នេះ ហើយប្រាប់ឲ្យដឹងមុន ទើបសម្ដែង

សមគួរ ។

ប្រេីនបទថា **បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ** សេចក្ដីថា មាតុគ្រាមសួរថា បពិត្រលោកម្ចាស់ ឈ្មោះថា ទីឃនិកាយ សម្ដែងអត្ថដូចម្ដេច ភិក្ខុដែលស្ដ្រីសួរបញ្ហាយ៉ាងនេះ ទោះបីពោលទីឃនិកាយទាំងអស់ ក៏មិនត្រូវអាបត្តិ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ ជាបទសោធម្មសមុដ្ឋាន កើតឡើងតាមវាចា ១ វាចានិងចិត្ត ១ ជាកិរិយាផង អកិរិយាផង ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ធម្មទេសនាសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ៣០៤ ] សម័យនោះ ព្រះភគវន្តសម្ពុទ្ធជាម្ចាស់ កាលគង់នៅកូដាគារសាលាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯង មានភិក្ខុច្រើនរូប ជាមិត្របានជួបប្រទះគ្នាថ្មី និងមិត្រស្និទ្ធស្នាលមាំមួន បាននៅចាំវស្សាប្របច្នេរស្ទឹងវគ្គុមុទា ។ វេលានោះឯង ដែនវជ្ជីកើតទុរ្ភិក្ស ( អត់បាយ ) មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តីស្លាប់ មានឆ្អឹងស ( ដេរដាសលើផែនដី ) និងទិញដូរស្រូវអង្ករ លុះតែមានស្លាកកាន់ជាសម្គាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិតដោយការព្យាយាមស្វែងរកអាហារ ។ ខណៈនោះ ភិក្ខុទាំងនោះគិតគ្នាដូច្នេះថា ឥឡូវនេះ ដែនវជ្ជីកើតទុរ្ភិក្ស ( អត់បាយ ) មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តីស្លាប់ មានឆ្អឹងស ( ដេរ-ដាសលើផែនដី ) និងទិញដូរស្រូវអង្ករ លុះតែមានស្លាកកាន់ជាសម្គាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិតដោយការព្យាយាមស្វែងរកអាហារឡើយ តើយើងនឹងគិតធ្វើឧបាយដូចម្តេចហ្ន៎ ឲ្យបានសាមគ្គីស្មោះស កុំឲ្យមានវិវាទទាស់ទែងគ្នា នៅចាំវស្សាឲ្យបានស្រួលផង កុំឲ្យ លំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ បើដូច្នោះ យើងត្រូវទទួលរ៉ាប់រងការងាររបស់គ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះ គង់នឹងនឹកនាឲ្យអាហារដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏បានសាមគ្គីស្មោះស មិនវិវាទ

ទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថនោះ អាវុសោ ណ្ហើយចុះ យើងត្រូវធ្វើអ្នកជាបម្រើនាំដំណឹងដល់ពួកគ្រហស្ថវិញ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះ គង់នឹងនឹកនាឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងនឹងព្រមព្រៀងស្មោះស មិនវិវាទទាស់ទែងគ្នានៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងារ របស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នកបម្រើនាំដំណឹងដល់ពួកគ្រហស្ថ អាវុសោ ណ្ហើយចុះ យើងនឹងពោលសរសើរនូវឧត្តរិមនុស្សធម៌ ដល់គ្នានឹងគ្នា ដល់ពួកគ្រហស្ថវិញថា ភិក្ខុឯណោះបានឈានទី ១ ភិក្ខុឯណោះបានឈានទី ២ ភិក្ខុឯណោះបានឈានទី ៣ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះអរហន្ត ភិក្ខុឯណោះបានវិជ្ជា ៣ ភិក្ខុឯណោះបានអភិញ្ញា ៦ កាលបើយើងពោលយ៉ាងនេះហើយ គ្រហស្ថទាំងនោះគង់នឹងនឹកនា ឲ្យអាហារបិណ្ឌ-បាតដល់យើងមិនខាន បើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសេចក្តីសាមគ្គីស្មោះស មិនវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួល ហើយមិនលំបាកដោយបិណ្ឌបាតផង ។ ភិក្ខុទាំងនោះក៏យល់ព្រមថា អាវុសោ ពួកយើងពោលសរសើរគុណឧត្តរិមនុស្សធម៌ណា របស់គ្នាយើងទៅវិញទៅមក

ដល់ពួកគ្រហស្ថ ការពោលសរសើរគុណឧត្តរិមនុស្សធម៌នេះស្រួលហើយ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏បានពោលសរសើរគុណឧត្តរិមនុស្សធម៌ទៅវិញទៅមកដល់ពួកគ្រហស្ថថា ភិក្ខុឯណោះបានឈានទី ១ ។បេ។ ភិក្ខុឯណោះបានអភិញ្ញា ៦ ។ គ្រានោះ មនុស្សទាំងឡាយនោះ ក៏និយាយគ្នាថា អើហ្ន៎ យើងរាល់គ្នាបានភិក្ខុបែបនេះ មកនៅចាំវស្សា ហៅពេញជាលាភរបស់យើង ឈ្មោះថា យើងបានបុណ្យដោយងាយណាស់ហ្ន៎ តាំងពីដើមមកដល់ឥឡូវនេះ យើងរាល់គ្នាមិនដែលបានពួកភិក្ខុមានសីល មានធម៌ជាកុសល ដូចបែបនេះ មកនៅចាំវស្សាសោះឡើយ ។ មនុស្សទាំងនោះ តែងប្រគេនភោជនាហារ[១] យ៉ាងណាដល់ភិក្ខុទាំងឡាយ ភោជនីយាហារយ៉ាងនោះ មិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនបានជូនទៅមាតាបិតា កូនប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្រ អមាត្យ និងញាតិសាលោហិតសោះឡើយ ( ម្យ៉ាងទៀត ) ធ្លាប់ប្រគេនខាទនីយ[២] គ្រឿងសម្រាប់ភ្លក្ស[៣] និងទឹកបាន[៤] យ៉ាងណាដល់ពួកភិក្ខុ ខាទនីយ និងគ្រឿងភ្លក្សទឹកបានយ៉ាងនោះ ក៏មិនហ៊ានបរិភោគផឹកខ្លួនឯងឡើយ ហើយមិនបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្រ អមាត្យ និងញាតិសាលោហិត សោះឡើយ ។ គ្រានោះឯង ភិក្ខុទាំងនោះ ( លុះបានអាហារធាន់បរិបូណ៌ ) ក៏មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរ

---

១- ភោជនមាន ៥ យ៉ាង គឺបាយ ១ នំ ១ សត្តុ ១ ត្រី ១ សាច់ ១ ។ ២- ខាទនីយ បានខាងឯមើមឈើ ផ្លែឈើជាដើម ។ ៣- បានខាងឯគ្រឿងសម្រាប់បរិភោគ គឺទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ។ ៤- ទឹកបាននោះ បានខាងទឹកបាន ៨ យ៉ាង មានទឹកបានធ្វើអំពីផ្លែស្វាយ ផ្លែព្រីងជាដើម ។

មុខស្រស់បស់ សម្បុរស្បែកក៏ផូរផង់ ។

[ ៣០៥ ] ភិក្ខុទាំងឡាយកាលបើចេញវស្សារួចហើយ តែងនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាទំនៀមមិនដែលខានឡើយ ។ វេលានោះឯង ភិក្ខុទាំងនោះលុះបាននៅចាំវស្សាគ្រប់ ៣ ខែហើយ ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈ រួចនាំយកបាត្រ និងចីវរចូលទៅក្រុងវេសាលី ដើរទៅតាមលំដាប់ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដែលគង់នៅឯកូដាគារសាលា ក្នុងព្រៃមហាវនទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ សម័យនោះឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ សឹងមានកាយស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ។ ចំណែកខាងពួកភិក្ខុដែលនៅទៀបត្រើយស្ទឹងវគ្គុមុទា មានសម្បុរល្អ មានឥន្ទ្រិយពេញលេញមានសម្បុរមុខក៏ស្រស់បស់ សម្បុរស្បែកក៏ផូរផង់ ។ ឯទំនៀមរបស់ព្រះតថាគតសម្ពុទ្ធទាំងឡាយ ព្រះអង្គតែងស្មោះសចំពោះជាមួយនឹងអាគន្តុកភិក្ខុ គឺភិក្ខុដែលទើបនឹងមកដល់ថ្មី ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ធន់បានឬទេ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះស មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏

មានព្រះភាគ យើងខ្ញុំពល់គ្នាល្មមប្រព្រឹត្តទៅបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំពល់គ្នាមានសេចក្ដីសាមគ្គីស្មោះស មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតផង ។ ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបនូវហេតុហើយ ត្រាស់សួរក៏មាន ជ្រាបហើយ មិនត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ ត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ មិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយ ទ្រង់ត្រាស់សួរតែកម្មដែលប្រកបដោយប្រយោជន៍ កម្មដែលមិនប្រកបដោយប្រ-យោជន៍ ព្រះអង្គមិនទ្រង់ត្រាស់សួរឡើយ ព្រះតថាគតទាំងឡាយ ព្រះអង្គផ្ដាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ ដោយអរិយមគ្គ ជ្រះស្រឡះអស់ហើយ ព្រះភគវន្តសម្ពុទ្ធទាំងឡាយ ទ្រង់សួរបញ្ជាក់ពួកភិក្ខុដោយហេតុ ២ ប្រការ គឺសួរដោយទ្រង់ព្រះតម្រិះថា តថាគតនឹងសម្ដែងធម៌ ១ និងបញ្ញត្តនូវសិក្ខាបទដល់ពួកសាវ័ក ១ ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយអ្នកទាំង-ឡាយបានជាមានសេចក្ដីសាមគ្គីស្មោះស មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាត តើដោយហេតុអ្វី ។ គ្រានោះភិក្ខុអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ( ដោយសព្វគ្រប់ ) ។ ទើបព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ពាក្យរបស់អ្នកទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។ ព្រះភគវន្តសម្ពុទ្ធ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អ្នក

រាល់គ្នា មិនសមបើនឹងហ៊ានពោលសរសើរគុណឧត្តរិមនុស្សធម៌ របស់គ្នា និងគ្នាចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ឆ្អែតផ្ទៃទេ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនបាននាំឲ្យកើតសេចក្ដីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម៌ ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះឧត្តរិមនុស្សធម៌នោះ ភិក្ខុបានពិតមែន ។

[៣០៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងបារាជិកកណ្ឌ សិក្ខាបទទី ១ ហើយ ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងតែភិក្ខុ និងភិក្ខុនីចេញ ក្រៅអំពីនោះហៅថា អនុបសម្បន្នទាំងអស់ ។

[ ៣០៧ ] ដែលហៅថា ឧត្តរិមនុស្សធម្ម[១] នោះ សំដៅយកឈាន ១ វិមោក្ខ ១ សមាធិ ១ សមាបត្តិ ១ ញាណទស្សនៈ ១ មគ្គភាវនា ១ ផលសច្ឆិកិរិយា ១ កិលេសប្បហាន ១ ចិត្តវិនីវរណៈ ១ សុញ្ញាគារអភិរតិ ១ ។

[៣០៨] បទថា **ឈាន** គឺសំដៅយកបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន។ បទថា វិមោក្ខ គឺសំដៅយកសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ។ បទថា **សមាធិ** គឺសំដៅយកសុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ។ បទថា **សមាបត្តិ** គឺសំដៅយកសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ ។បទថា **ញាណ** គឺ សំដៅយកវិជ្ជា ៣ ។ បទថា **មគ្គភាវនា** គឺសំដៅយក សតិប្បដ្ឋាន ៤ សម្មប្បធាន

---

១- ពួកឧត្តរិមនុស្សធម្មនេះបានអធិប្បាយក្នុងបារាជិកទី ៤ រួចហើយ ។

៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ បទថា **ផលសច្ឆិកិរិយា** គឺកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។ បទថា **កិលេសប្បហាន** គឺកិរិយាលះរាគៈ លះទោសៈ លះមោហៈ ។ បទថា **ចិត្តវិនីវរណៈ** គឺ ចិត្តដែលប្រាសចាករាគៈ ចិត្តដែលប្រាសចាកទោសៈ ចិត្តដែលប្រាសចាកមោហៈ ។ សុញ្ញាគារេអភិរតិ គឺសេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ដោយទុតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ដោយតតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ដោយចតុត្ថជ្ឈាន ។

[ ៣០៩ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានរួចហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាកំពុងចូលបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកចូលបឋមជ្ឈានហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកបានបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺ ភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺ ភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១០ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាត្មាជាអ្នកបាននូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១១ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាធិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១២ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មា បានចូល កំពុងចូល ជាអ្នកចូលនូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាបត្តិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៣ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវត្រៃវិជ្ជា អាត្មាជាអ្នកបាននូវត្រៃវិជ្ជា អាត្មាជាអ្នកស្ទាត់ក្នុងត្រៃវិជ្ជា ត្រៃវិជ្ជាអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មា

បានដល់ កំពុងដល់ ជាអ្នកដល់នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ អាត្មាជាអ្នកបាននូវឥទ្ធិបាទទាំង ៤ អាត្មាជាអ្នកស្ទាត់ក្នុងឥទ្ធិបាទទាំង ៤ ឥទ្ធិបាទទាំង ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៥ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវឥន្ទ្រិយ ៥ ពលៈ ៥ អាត្មាជាអ្នកបាននូវពលៈ ៥ អាត្មាជាអ្នកស្ទាត់ក្នុងពលៈ ៥ ពលៈ ៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៦ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវពោជ្ឈង្គទាំង ៧ អាត្មាជាអ្នកបាននូវពោជ្ឈង្គទាំង ៧ អាត្មាជាអ្នកស្ទាត់ក្នុងពោជ្ឈង្គទាំង ៧ ពោជ្ឈង្គទាំង ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៧ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាជាអ្នកបាននូវមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាជាអ្នកស្ទាត់ក្នុងមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ មគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៨ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវសោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល អាត្មាជាអ្នកបាននូវអរហត្តផល អាត្មាជាអ្នកស្ទាត់ក្នុង

អរហត្តផល អរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១៩ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា រាគៈអាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មាបានលះបង់ហើយ បានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២០ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាករាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មាប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២១ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ អាត្មាជាអ្នកបាននូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយក្នុងផ្ទះដ៏ស្ងាត់ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២២ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាជាអ្នកបានូវបឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាបាន

ធ្វើបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង តតិយជ្ឈានផង ។បេ។ បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចតុត្ថជ្ឈានផង បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៣ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អប្ប-ណិហិតសមាធិផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អប្បណិហិតសមាធិផង បឋមជ្ឈានផង អប្បណិហិតសមាធិផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៤ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង បឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៥ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកស្ទាត់ក្នុងបឋម-ជ្ឈានផង ត្រៃវិជ្ជាផង បឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៦ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សតិប្បដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង បឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៧ ] ពាក្យថា ប្រាប់ គឺភិក្ខុប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ឥន្ទ្រិយ ៥ ផង ពលៈ ៥ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពលៈ ៥ ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ពលៈ ៥ ផង បឋមជ្ឈានផង ពលៈ ៥ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៨ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាជាអ្នកស្ទាត់ក្នុង

បឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង បឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២៩ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង បឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣០ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អរហត្តផលផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អរហត្តផលផង បឋមជ្ឈានផង អរហត្តផលផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣១ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង អាត្មាលះបង់រាគៈហើយផង អាត្មាលះបង់ទោសៈហើយផង អាត្មាលះបង់មោហៈហើយផង រាគៈ ទោសៈ មោហៈ អាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានលោស់ចោលហើយ បានរើឡើងហើយ បាន

គាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣២ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាករាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣៣ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង តតិយជ្ឈានផង ។បេ។ ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈានផង ចតុត្ថជ្ឈានផង ទុតិយ-ជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង ។បេ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង បឋ-មជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិ បាចិត្តិយ ។បេ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈផង អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន

ផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង អាត្មាជាអ្នកបានទូវបឋមជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចិត្តរបស់អាត្មា ប្រាសចាកមោហៈផង បឋមជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។បេ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣៤ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានដល់ហើយនូវបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង វិជ្ជា ៣ ផង សតិប្បដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង ឥន្ទ្រិយ ៥ ផង ពលៈ ៥ ផង ពោជ្ឈង្គ ៧ ផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។បេ។ រាគៈអាត្មាបានកម្ចាត់ចេញហើយផង ទោសៈអាត្មាបានកម្ចាត់ចេញហើយផង មោហៈអាត្មាបានកម្ចាត់ចេញហើយផង រាគៈ ទោសៈ មោហៈ អាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាករាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មា

ប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣៥ ] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ តែត្រឡប់ជាពោលថា អាត្មាបានចូលទុតិយជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវត្រឹមអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ ត្រឡប់ជាពោលថា អាត្មាបានចូលតតិយជ្ឈាន ចតុត្ថជ្ឈាន សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ ត្រៃវិជ្ជា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល រាគៈអាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មាបានលះបង់ហើយ រាគៈ ទោសៈ មោហៈ អាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយបានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាករាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មាប្រាសចាកមោហៈ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។

[ ៣៣៦ ] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ដល់អនុ-បសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ ។បេ។ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ តែត្រឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ត្រូវត្រឹមអាបត្តិទុក្កដ ។បេ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈតែត្រឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។បេ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុប-សម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកទោសៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង ។បេ។ ចិត្តរបស់អាត្មាប្រាសចាកទោសៈ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើ

អនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។

[ ៣៣៧ ] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ដល់អនុបសម្បន្ន ថា អាត្មាបានចូលទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង ។បេ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង តែត្រឡប់ជានិយាយថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។

[ ៣៣៨ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា ភិក្ខុអង្គណានៅក្នុងវិហាររបស់អ្នក ភិក្ខុអង្គនោះបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ភិក្ខុនោះជាអ្នកបាននូវបឋមជ្ឈាន ភិក្ខុនោះ ជាអ្នកស្ទាត់ក្នុងបឋមជ្ឈាន បឋមជ្ឈានភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈានភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានដល់ហើយ កំពុងដល់ ជាអ្នកដល់នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ភិក្ខុនោះជាអ្នកបាននូវអប្បណិហិតសមាធិ ភិក្ខុនោះជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ

ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានដល់ហើយនូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ ត្រៃវិជ្ជា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល ។បេ។ រាគៈភិក្ខុនោះបានលះបង់ហើយ ទោសៈភិក្ខុនោះបានលះបង់ហើយ មោហៈ ភិក្ខុនោះបានលះបង់ហើយ រាគៈ ទោសៈ មោហៈ ភិក្ខុនោះបានខ្ជាក់ចោលហើយ បានជម្រះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់ភិក្ខុនោះប្រាសចាករាគៈ ចិត្តរបស់ភិក្ខុនោះប្រាសចាកទោសៈ ចិត្តរបស់ភិក្ខុនោះប្រាសចាកមោហៈ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅគ្រប់គ្រងវិហាររបស់អ្នក ភិក្ខុណាប្រើប្រាស់ចីវររបស់អ្នក ភិក្ខុណាបរិភោគបិណ្ឌបាតរបស់អ្នក ភិក្ខុណាប្រើប្រាស់សេនាសនៈរបស់អ្នក ភិក្ខុណាបរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូល

ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ងាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[ ៣៣៩ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា វិហាររបស់អ្នកភិក្ខុណានៅគ្រប់គ្រងហើយ ចីវររបស់អ្នកភិក្ខុណាបានប្រើប្រាស់ហើយ បិណ្ឌបាតរបស់អ្នកភិក្ខុណាបានបរិភោគហើយ សេនាសនៈរបស់អ្នកភិក្ខុណាបានប្រើប្រាស់ហើយ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ភិក្ខុណាបានបរិភោគហើយ ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូល ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ងាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[ ៣៤០ ] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អ្នកឯងបានឲ្យវិហារ អ្នកឯងបានឲ្យចីវរ អ្នកឯងបានឲ្យបិណ្ឌបាត អ្នកឯងបានឲ្យសេនាសនៈ អ្នកឯងបានឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះអាស្រ័យនូវភិក្ខុណា ភិក្ខុនោះបានចូលហើយនូវចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ។បេ។ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[ ៣៤១ ] អាបត្តិមិនមានដល់ភិក្ខុដែលប្រាប់ឧត្តរិមនុស្សធម៌ដែលខ្លួនបានពិតប្រាកដដល់ឧបសម្បន្នបុគ្គល ១ ដល់ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា

## មុសាវាទវគ្គ

## ភូតារោចនសិក្ខាបទទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ

[ ៣០៤ ] ពាក្យណា ដែលខ្ញុំគួរនឹងពោលមុន ក្នុងវត្ថុកថា ពាក្យទាំងអស់នោះមានន័យដូចដែលពោលហើយ ក្នុងចតុត្ថបារាជិកវណ្ណនានោះឯង ឯការប្លែកគ្នា មានដូចតទៅនេះថា ក្នុងចតុត្ថបារាជិកនោះ ពួកភិក្ខុប្រាប់ឧត្តរិមនុស្សធម្មដែលមិនមានពិត ក្នុងសិក្ខាបទនេះ ប្រាប់ឧត្តរិមនុស្សធម្មដែលមានពិត ។ បុថុជ្ជនទាំងឡាយប្រាប់ឧត្តរិមនុស្សធម្មដែលមានពិត ។ ព្រះអរិយៈទាំងឡាយមិនប្រាប់ឡើយ ។ ពិតហើយ ឈ្មោះថា បយុត្តវាចា ( វាចាដែលបន្លឺព្រោះហេតុនៃផ្ទៃ ) មិនមានដល់ព្រះអរិយៈទាំងឡាយ ។ តែកាលអ្នកដទៃប្រាប់គុណរបស់ខ្លួនឯង លោកក៏មិនហាមអ្នកដទៃនោះឡើយ និងត្រេកអរក្នុងបច្ច័យទាំងឡាយដែលកើតឡើង ដោយអាការដែលមិនជ្រាបថាកើតឡើង ( ព្រោះការប្រាប់គុណរបស់ខ្លួន ) ។

[ ៣០៥ ] ក្នុងបទថា **អបិ ខោ តេ ភិក្ខុ ភគវតោ ឯតមត្ថំ អារោចេសុំ** ជាដើម បណ្ឌិតគប្បីជ្រាបថា ភិក្ខុទាំងឡាយណា ពោលគុណនៃឧត្តរិមនុស្សធម្ម ភិក្ខុទាំងនោះបានក្រាបទូលហើយ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ គុណវិសេសរបស់ពួកអ្នក មានពិតឬ ភិក្ខុទាំងអស់នោះទូលទទួលប្តេជ្ញាថា បពិត្រព្រះអង្គដ៏ចម្រើន មានពិត ព្រោះថា ឧត្តរិមនុស្សធម្មមានពិតក្នុងខ្លួននៃព្រះអរិយៈទាំងឡាយ ព្រោះដូច្នោះ ទើបកាលនោះ ព្រះមាន

ព្រះភាគមិនត្រាស់ថា **មោឃបុរិសា** ព្រោះភិក្ខុទាំងនោះលាយឡំដោយព្រះអរិយៈ ត្រាស់ថា **កច្ចិត្ថ ឆាម តុម្ហេ ភិក្ខវេ** ហើយ ទើបត្រាស់ពាក្យជាដើមថា **ឧទរស្ស ការណា** ដូច្នេះ ។

ក្នុងបទ មានបទថា **កច្ចិត្ថ ឆាម តុម្ហេ ភិក្ខវេ** ជាដើមនោះ ព្រោះព្រះអរិយៈទាំងឡាយស្តាប់ពាក្យរបស់អ្នកដទៃ ត្រូវពួកអ្នកស្រុកជ្រះថ្លាហើយសួរដោយន័យជាដើមថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់ជាសោតាបន្នឬ ដូច្នេះ មានប្រក្រតីឃើញថា មិនមានទោស ក្នុងកាលសិក្ខាបទដែលព្រះមានព្រះភាគទ្រង់មិនទាន់បញ្ញត្ត ទើបប្តេជ្ញាការសម្រេចគុណវិសេសរបស់ខ្លួន និងរបស់អ្នកដទៃ ព្រោះជាអ្នកមានចិត្តបរិសុទ្ធ ហើយលោកទាំងនោះ កាលប្តេជ្ញាយ៉ាងនេះ សូម្បីត្រេកអរនូវបិណ្ឌបាតដែលបុថុជ្ជនដទៃពោលគុណនៃឧត្តរិមនុស្សធម្ម ព្រោះហេតុនៃផ្ទៃឲ្យកើតឡើងហើយ ដោយភាពជាអ្នកមានចិត្តបរិសុទ្ធ ទើបហាក់ដូចជាពោលគុណនៃឧត្តរិមនុស្សធម្ម ព្រោះហេតុនៃផ្ទៃ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ដោយសព្វសង្គាហិកន័យថា ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី ទើបពួកអ្នកពោលសរសើរឧត្តរិមនុស្សធម្មនៃគ្នានឹងគ្នា ដល់គ្រហស្ថទាំងឡាយ ព្រោះហេតុនៃផ្ទៃទៅវិញ ដូច្នេះ ។ ពាក្យដ៏សេស ដូចគ្នាក្នុងចតុត្ថបារាជិកទាំងអស់ហើយ ។

តែក្នុងការចែកសិក្ខាបទ ក្នុងចតុត្ថបារាជិកនោះ ត្រូវបារាជិក និងថុល្លច្ច័យតែម្យ៉ាង តែក្នុងសិក្ខាបទនេះ ជាបាចិត្តិយ និងទុក្កដ ព្រោះជាគុណដែលមានពិត នេះជាការប្លែកគ្នា បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

បទថា **ឧបសម្បន្នស្ស ភូតំ អារោចេតិ** ប្រាប់គុណវិសេសដែលមានពិតដល់ឧបសម្បន្ននេះ លោកពោលសំដៅយកឧត្តរិមនុស្សធម្មនោះឯង ។ ពិតហើយ ភិក្ខុដែលត្រូវទទួចសួរក្នុងពេលបរិនិព្វាន និងក្នុងកាលដទៃ ទោះប្រាប់គុណដែលមានពិតដល់ឧបសម្បន្នក៏គួរ ។ម្យ៉ាងទៀត ទោះប្រាប់គុណ គឺ សុត្តៈ បរិយត្តិ និងសីល ដល់អនុបសម្បន្នក៏គួរ មិនត្រូវអាបត្តិដល់ភិក្ខុដែលជាដើមបញ្ញត្តិ តែបទថា **ឧម្មត្តកស្ស** នេះ ព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងសិក្ខាបទនេះ ព្រោះហេតុអ្វី លោកពិចារណាទុកក្នុងអដ្ឋកថាមហាបច្ចរីថា ព្រោះថា អ្នកដែលដល់ព្រមដោយទិដ្ឋិ មិនមានការឆ្កួត ឬមានចិត្តរវើរវាយឡើយដូច្នេះ តែលោកដែលបានឈាន គប្បីឆ្កួតបានក្នុងកាលឈានវិនាស ។ សម្រាប់បុគ្គលនោះក៏មិនគួរពោលអនាបត្តិ ដែលមានការប្រាប់ឈានដែលខ្លួនមានពិតជាបច្ច័យ ព្រោះឈានដែលមានពិតនោះឯង មិនមានដូច្នេះឯង ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ ឈ្មោះថា ភូតារោចនសិក្ខាបទ កើតឡើងដោយសមុដ្ឋាន ៣ ដែលមិនបានត្រាស់ទុកខាងដើម គឺតាមកាយ ១ តាមវាចា ១ តាមកាយនិងវាចា ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ២ ដោយជាកុសលចិត្ត និងជាអព្យាកតចិត្ត មានវេទនា ២ គឺសុខវេទនា និងឧបេក្ខាវេទនា ដូច្នេះឯង ។

ភូតារោចនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ៣៨២ ] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុ បានឈ្លោះនឹងពួកឆព្វគ្គិយភិក្ខុ ( គឺភិក្ខុមានពួក ៦ ) ។ ឧបនន្ទនោះត្រូវអាបត្តិសញ្ចេតនិកៈ ( សង្ឃាទិសេស ) គឺធ្វើទឹកសុក្កឲ្យឃ្លាតចេញ ហើយបានសូមបរិវាសអំពីជំនុំសង្ឃដើម្បីអាបត្តិនោះ ។ ជំនុំសង្ឃក៏បានឲ្យបរិវាសដល់ឧបនន្ទនោះ ដើម្បីអាបត្តិនោះ ។ វេលានោះឯង ក្រុងសាវត្ថីមានជនមួយពួក ( គេបានចាត់ចែង ) កត្តថ្វាយសង្ឃ ។ ឯឧបនន្ទនោះ កំពុងនៅក្នុងបរិវាស បានអង្គុយចុងអាសនៈក្នុងរោងកត្ត ។ ពួកឆព្វគ្គិយភិក្ខុក៏បាននិយាយប្រាប់ឧបាសកទាំងនោះថា អាវុសោ ឧបនន្ទសក្យបុត្រដ៏មានអាយុនេះ ជាទីសរសើរ ជាជីតុនរបស់អ្នកទាំងឡាយ តែងឆាន់កោជនដែលគេឲ្យ ដោយសទ្ធាដោយដៃណា យកដៃនោះឯងព្យាយាម ធ្វើឲ្យអសុចិហូរចេញ ឧបនន្ទនោះត្រូវអាបត្តិសញ្ចេតនិកៈ ព្រោះធ្វើទឹកសុក្កឲ្យឃ្លាតចេញ ហើយបានសូមបរិវាសអំពីជំនុំសង្ឃ ដើម្បីអាបត្តិនោះ ជំនុំសង្ឃក៏បានឲ្យបរិវាស ដល់ឧបនន្ទនោះដើម្បីអាបត្តិនោះ ឧបនន្ទនោះ ឥឡូវកំពុងនៅបរិវាស ហើយអង្គុយនៅក្នុងទីបំផុតអាសនៈ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងហ៊ានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុសម្បន្នបុគ្គលសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងហ៊ានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គលសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។

[ ៣៤៣ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបារាជិកសិក្ខាបទទី ១ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ អាបត្តិបារាជិក ៤ និងអាបត្តិសង្ឃាទិសេស ១៣ ឈ្មោះថា ទុដ្ឋុល្លាបត្តិ ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងភិក្ខុ និងភិក្ខុនីចេញ ក្រៅអំពីនោះ ហៅថា អនុបសម្បន្នទាំងអស់ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាប់ដល់ស្រីក្តី ដល់ប្រុសក្តី ដល់គ្រហស្ថក្តី ដល់អ្នកបួសក្តី ។ ពាក្យថា វៀរលែងតែភិក្ខុដែលសង្ឃ សម្មតិឲ្យប្រាប់ គឺលើកតែភិក្ខុដែលបានសេចក្តីសម្មតិអំពីសង្ឃ ។

[ ៣៤៤ ] ឯសេចក្តីសម្មតិរបស់ភិក្ខុដែលសង្ឃកំណត់ឲ្យមាន ៤ យ៉ាង គឺសម្មតិកំណត់អាបត្តិ មិនកំណត់ត្រកូល ១ សម្មតិកំណត់ត្រកូល មិនកំណត់

អាបត្តិ ១ សម្មតិកំណត់អាបត្តិ និងត្រកូល ១ សម្មតិមិនកំណត់អាបត្តិ មិនកំណត់ត្រកូល ១ ។ ដែលហៅថា កំណត់អាបត្តិនោះ គឺអាបត្តិ ( ប៉ុន្មាន ) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់អាបត្តិប៉ុណ្ណោះ ។ ដែលហៅថា កំណត់ត្រកូល ( នោះ ) គឺត្រកូល ( ប៉ុន្មាន ) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មត ត្រូវប្រាប់ ( អាបត្តិ ) ដល់ត្រកូលប៉ុណ្ណោះ ។ ដែលហៅថា កំណត់អាបត្តិ និងកំណត់ត្រកូល ( នោះ ) គឺអាបត្តិ ( ប៉ុន្មាន ) ដែលសង្ឃកំណត់ឲ្យហើយ និងត្រកូល ( ប៉ុន្មាន ) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់ ( អាបត្តិប៉ុណ្ណោះ ) ដល់ត្រកូលប៉ុណ្ណោះបាន ។ ដែលហៅថា មិនកំណត់អាបត្តិ មិនកំណត់ត្រកូល ( នោះ ) គឺអាបត្តិ ( ប៉ុន្មាន ) ដែលសង្ឃមិនកំណត់ឲ្យហើយ និងត្រកូល ( ប៉ុន្មាន ) ដែលសង្ឃមិនកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់អាបត្តិ ដែលសង្ឃមិនកំណត់ឲ្យប៉ុណ្ណោះ ដល់ត្រកូលដែលសង្ឃមិនកំណត់ឲ្យប៉ុណ្ណោះបាន ។

[ ៣៨៥ ] ( មយ៉ាងទៀត ) ត្រង់ពាក្យថា កំណត់អាបត្តិ គឺពួកអាបត្តិណាដែលសង្ឃបានកំណត់ឲ្យហើយ ភិក្ខុមិនប្រាប់អាបត្តិទាំងនោះ ទៅប្រាប់ពួកអាបត្តិដទៃវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា កំណត់ត្រកូល គឺពួកគ្រហស្ថណាដែលសង្ឃបានកំណត់ឲ្យហើយ ភិក្ខុមិនប្រាប់ពួកត្រកូលនោះ បែរជាប្រាប់ត្រកូលទាំងឡាយដទៃវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា កំណត់អាបត្តិ និងកំណត់ត្រកូល គឺពួកអាបត្តិណា ដែលសង្ឃបានកំណត់ឲ្យក្តី ពួកត្រកូលណាដែលសង្ឃបានកំណត់ឲ្យក្តី ភិក្ខុនោះមិនប្រាប់អាបត្តិទាំងនោះ មិនប្រាប់

ត្រកូលទាំងនោះ ទៅប្រាប់អាបត្តិឯទៀត ត្រកូលឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា មិនកំណត់អាបត្តិ មិនកំណត់ត្រកូល ( នោះ ) គឺភិក្ខុនោះប្រាប់អនុបសម្បន្នដោយអាបត្តិណាៗ ត្រកូលណាៗ ក៏ដោយ មិនត្រូវអាបត្តិឡើយ ។

[ ៣៨៦ ] ទុដ្ឋុល្លាបត្តិ ភិក្ខុដឹងច្បាស់ថា ទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសម្មតិឲ្យប្រាប់ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។ ទុដ្ឋុល្លាបត្តិ ភិក្ខុសម្គាល់ថា អទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុសង្ឃសន្មតឲ្យប្រាប់ ។

[ ៣៨៧ ] ភិក្ខុប្រាប់អទុដ្ឋុល្លាបត្តិ ( ដល់អនុបសម្បន្ន ) ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រាប់អជ្ឈាចារអាក្រក់ក្តី[១] មិនសូវអាក្រក់ក្តី[២] របស់អនុបសម្បន្ន គឺសាមណេរ ( ដល់អនុបសម្បន្នដទៃ ) ត្រូវអាបត្តិទុក្កដ ។ អទុដ្ឋុល្លាបត្តិ ភិក្ខុសម្គាល់ថា ទុដ្ឋុល្លាបត្តិវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងអទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ ។ អទុដ្ឋុល្លាបត្តិ ភិក្ខុសម្គាល់ថា អទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ ។

[ ៣៨៨ ] អាបត្តិមិនមានដល់ភិក្ខុដែលប្រាប់តែវត្ថុ[៣] មិនប្រាប់អាបត្តិ

---

១- សាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ ៥ ខាងដើម ឈ្មោះថា អជ្ឈាចារអាក្រក់ ។ ២- សាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ ៥ ខាងចុង ឈ្មោះថា អជ្ឈាចារមិនសូវអាក្រក់ ។ ៣- ភិក្ខុប្រាប់ថា ភិក្ខុនេះត្រូវសុក្កវិសដ្ឋិ ( គឺធ្វើសុក្កឲ្យឃ្លាតចេញ ) ជាដើម ហៅថា ប្រាប់តែវត្ថុ ។

ដល់ភិក្ខុដែលប្រាប់តែអាបត្តិ[៤] មិនប្រាប់វត្ថុ ដល់ភិក្ខុដែលបានសេចក្តីសម្មតិអំពីសង្ឃ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

## សិក្ខាបទទី ៩ ចប់

៤- ភិក្ខុប្រាប់ថា ភិក្ខុ នេះត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេសជាដើម ហៅថា ប្រាប់តែអាបត្តិ ។

# អដ្ឋកថា

## មុសាវាទវគ្គ

## ទុដ្ឋុល្លារោចនសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ

[ ៣៤២ ] លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ព្រះមានព្រះភាគត្រាស់បារាជិកទុកក្នុងព្រះបាលីថា អាបត្តិដែលឈ្មោះថា អាក្រក់ថោបទាបបានដល់ បារាជិក ៤ សង្ឃាទិសេស ១៣ ដូច្នេះ ដើម្បីសម្តែងអត្ថនៃ **ទុដ្ឋុល្ល** សព្ទ តែសង្ឃាទិសេស ទ្រង់បំណាងយកក្នុងសិក្ខាបទនេះ ។ ក្នុងបាលីនោះមានការពិចារណាដូចតទៅនេះថា បើភិក្ខុប្រាប់បារាជិក មិនគប្បីជាបាចិត្តិយសោត ។ សូម្បីកាលមានសព្ទថា **ឧបសម្បន្ន** សម្រាប់ភិក្ខុ និងភិក្ខុនីក្នុងសិក្ខាបទណា លោកមិនបំណាងយកភិក្ខុនី ក្នុងសិក្ខាបទនោះ វៀរភិក្ខុចេញដ៏សេសក្រៅអំពីនេះ លោកហៅថា អនុបសម្បន្ន យ៉ាងណា ក្នុងសិក្ខាបទនេះ ក៏យ៉ាងនោះ កាលមានសព្ទថា **ទុដ្ឋុល្ល** សម្រាប់បារាជិក និងសង្ឃា-ទិសេស បើទ្រង់មិនបំណាងយកបារាជិក ព្រះមានព្រះភាគ ក៏គប្បីត្រាស់ពាក្យនេះប៉ុណ្ណោះថា អាបត្តិដែលឈ្មោះថា ថោកទាប បានដល់ សង្ឃាទិសេស ១៣ ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃទុដ្ឋុល្លារោចនសិក្ខាបទ

[ ៣៤៣ ] ក្នុងបទថា **ទុដ្ឋុល្លា នាម អាបត្តិ** ជាដើមនោះ មានមតិ

របស់អាចារ្យខ្លះថា ភិក្ខុណាត្រូវបារាជិកហើយ ភិក្ខុនោះឃ្លាតហើយចាកភិក្ខុ-ភាវៈ ព្រោះហេតុនោះ ភិក្ខុកាលប្រាប់អាបត្តិរបស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ កាលមានអធិប្បាយយ៉ាងនេះ សូម្បីភិក្ខុជេរក៏គប្បីត្រូវអាបត្តិទុក្កដ និងត្រូវអាបត្តិបាចិត្តិយប៉ុណ្ណោះ ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងបារាជិក) ថា បុគ្គលជាអ្នកមិនបរិសុទ្ធ ត្រូវធម៌ គឺបារាជិកឯណាមួយ បើបុគ្គលជាអ្នកមានការយល់ថាបរិសុទ្ធ ឲ្យបុគ្គលនោះធ្វើឱកាស ហើយពោលមានបំណងនឹងជេរ ត្រូវឱមសវាទ ។ កាលបាលីត្រូវវិចារណ៍យ៉ាងនេះ បាចិត្តិយនោះឯងរមែងប្រាកដដល់បុគ្គលប្រាប់អាបត្តិបារាជិក ។ នឹងប្រាកដក៏ពិត តែព្រះអដ្ឋកថាចារ្យប៉ុណ្ណោះ ជាគោលអាងបាន ក្នុងបទថា **ទុដ្ឋុល្លា នាម អាបត្តិ** នេះ ព្រោះ ( ពាក្យថា ព្រះមានព្រះភាគត្រាស់បារាជិកទុកដើម្បីទ្រង់សម្តែងអត្ថនៃ **ទុដ្ឋុល្ល** សព្ទ តែសង្ឃាទិសេសទ្រង់បំណងយកក្នុងសិក្ខាបទនេះ ) ព្រះអដ្ឋកថាចារ្យពោលទុកហើយ ក្នុងអដ្ឋកថាទាំងពួង ។ ការវិចារណ៍ដទៃមិនមាន ។

ខាងដើម ខ្ញុំក៏បានពោលទុកហើយថា ធម៌ និងវិន័យណាដែលព្រះមុនីត្រាស់ហើយ ធម៌ និងវិន័យនោះ ដែលឱរសទាំងឡាយរបស់ព្រះសម្ពុទ្ធនោះដឹងហើយយ៉ាងនោះឯង ដូច្នេះជាដើម ។

ពិតហើយ ព្រះអដ្ឋកថាចារ្យទាំងឡាយ រមែងដឹងបំណងរបស់ព្រះ-សម្ពុទ្ធ ។ ឯពាក្យរបស់ព្រះអដ្ឋកថាចារ្យនោះ បណ្ឌិតគប្បីជ្រាបដោយបរិយាយដូច្នេះថា សមដូចព្រះតម្រាស់ត្រាស់ទុកថា វៀរតែភិក្ខុដែលបានទទួលសម្មតិ

ឯការប្រាប់ដល់ភិក្ខុបានទទួលសម្មតិ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដើម្បីប្រយោជន៍ក្នុងការសង្រួមតទៅ គឺដើម្បីប្រយោជន៍កុំឲ្យត្រូវអាបត្តិដូច្នោះទៀត ហើយមិនមែនដើម្បីប្រកាសត្រឹមតែទោសរបស់ភិក្ខុនោះ ទាំងមិនមែនដើម្បីរារាំងទីពឹងរបស់ភិក្ខុនោះក្នុងសាសនានេះឡើយ ហើយភាពជាភិក្ខុរបស់បុគ្គលត្រូវបារាជិក ដោយមិនត្រូវអាបត្តិបែបនោះទៀត មិនមាន ព្រោះហេតុនោះ ពាក្យដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ព្រះមានព្រះភាគត្រាស់បារាជិកទុក ដើម្បីសម្តែងអត្ថនៃ **ទុដ្ឋុល្ល** សព្ទ តែសង្ឃាទិសេសទ្រង់បំណាងយកក្នុងសិក្ខាបទនេះ ដូច្នេះ គឺលោកពោលត្រឹមត្រូវហើយ ។

## អធិប្បាយ

## បទភាជនីយនៃទុដ្ឋុល្លារោចនសិក្ខាបទ

[ ៣៨៤ ] ក្នុងបទថា **អញ្ញត្រ ភិក្ខុសម្មតិយា អាបត្តិបរិយន្តា** ជាដើម មានវិនិច្ឆ័យ ដូច្នេះថា ភិក្ខុសម្មតិដែលព្រះមានព្រះភាគត្រាស់ទុកនេះ មិនបានមកក្នុងសិក្ខាបទខ្វះទេ តែព្រោះភិក្ខុសម្មតិ ត្រាស់ទុកក្នុងសិក្ខាបទនេះប៉ុណ្ណោះឯង ទើបគួរជ្រាបថា សង្ឃឃើញភិក្ខុដែលត្រូវអាបត្តិរឿយៗ ហើយអបលោក ៣ ដង ធ្វើដោយភាពជាអ្នកស្វែងរកប្រយោជន៍ដល់ភិក្ខុនោះថា ភិក្ខុនេះនឹងដល់នូវការសង្រួមតទៅ ដោយហិរិ និងឱត្តប្បៈក្នុងអ្នកដទៃយ៉ាងនេះ ។

[ ៣៨៧ ] បទថា **អទុដ្ឋុល្លំ អាបត្តឹ អារោចេតិ អាបត្តិ ទុក្កដស្ស** សេចក្តីថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុ ដែលប្រាប់កងអាបត្តិទាំង ៥ កង ។ ក្នុងមហាបច្ចរីកាត់ទុក្កដតែម្យ៉ាង ដល់ភិក្ខុដែលប្រាប់អាបត្តិបារាជិក ។

ក្នុងបទថា **អនុបសម្បន្នស្ស ទុដ្ឋុល្លំ វា អទុដ្ឋុល្លំ វា អជ្ឈាចារំ** នេះ លោកពោលសេចក្តីទុកថា សិក្ខាបទ ៥ ខាងដើម ឈ្មោះថា អជ្ឈាចារថោកទាប ដ៏សេសឈ្មោះថា អជ្ឈាចារមិនថោកទាប ឯសុក្កវិសដ្ឋិ កាយសំសគ្គៈ ទុដ្ឋុល្លវាចា និងអត្តកាម ឈ្មោះថា អជ្ឈាចាររបស់ភិក្ខុនោះ ។

## អនាបត្តិនៃទុដ្ឋុល្លារោចនសិក្ខាបទ

[ ៣៤៨ ] ពីរបទថា **វត្ថុំ អារោចេតិ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលប្រាប់យ៉ាងនេះថា ភិក្ខុនេះត្រូវសុក្កវិសដ្ឋិ ត្រូវកាយសំសគ្គៈ ត្រូវទុដ្ឋុល្លវាចា ត្រូវអត្តកាម ។

ពីរបទថា **អាបត្តឹ អារោចេតិ** សេចក្តីថា ភិក្ខុពោលថា ភិក្ខុនេះត្រូវបារាជិក ត្រូវសង្ឃាទិសេស ត្រូវថុល្លច្ច័យ ត្រូវបាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត ដូច្នេះ ជាអនាបត្តិ ។ បើភិក្ខុប្រាប់អាបត្តិភ្ជាប់នឹងវត្ថុ ដោយពាក្យជាដើមថា ភិក្ខុនេះបញ្ចេញអសុចិ ត្រូវសង្ឃាទិសេសដូច្នេះប៉ុណ្ណោះ ទើបជាអាបត្តិ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះ ។

ទុដ្ឋុល្លារោចនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[ ៣៨៩ ] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអាគាឡវចេតិយ ក្បែរក្រុងអាឡវី ។ គ្រានោះឯង ពួកអាឡវិកភិក្ខុ កាលធ្វើនវកម្ម ក៏ជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះនូវផែនដី មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនសមបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ហ៊ានបៀតបៀនវត្ថុរស់ ដែលមានឥន្ទ្រិយ ១ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោសតិះដៀលបន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកអាឡវិកភិក្ខុ មិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីសោះ ។ វេលានោះឯងភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដី ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលតបវិញថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីទេ នែមោឃបុរសទាំងឡាយ ព្រោះពួកមនុស្សមានសេចក្តីសម្គាល់ថា ផែនដីជាវត្ថុ

មានជីវិត នៃមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី នូវផែនដី ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៥០ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ផែនដី បានដល់ ផែនដីមាន ២ យ៉ាង គឺជាតបឋវី ផែនដីមានដីច្រើនជាងវត្ថុឯទៀត ១ អជាតបឋវី ផែនដីមានដីតិចជាងវត្ថុឯទៀត ១ ។ ដែលហៅថា ជាតបឋវី ( នោះ ) គឺអាចម៍ដីសុទ្ធ ដីស្អិតសុទ្ធ ដីមានថ្មតិច មានក្រួសតិច មានបំណែកអំបែងតិច មានក្រួសវ៉ានតិច មានខ្សាច់តិច មានអាចម៍ដីច្រើន មានដីស្អិតច្រើន ឬជាផែនដីគេមិនដែលដុត តថាគតហៅថា ជាតបឋវី ។ មួយវិញទៀត គំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ត្រូវជាង ៤ ខែ គំនរនេះឯងតថាគតហៅថា ជាតបឋវីដែរ ។ ដែលហៅថា អជាតបឋវី ( នោះ ) គឺផែនដីដែលមានថ្មសុទ្ធ មានក្រួសសុទ្ធ មានបំណែកអំបែងសុទ្ធ មានក្រួសវ៉ានសុទ្ធ មានខ្សាច់សុទ្ធ មានអាចម៍ដីតិច មានដីស្អិតតិច មានថ្មច្រើន មានក្រួសច្រើន មានបំណែក អំបែងច្រើន មានក្រួសវ៉ានច្រើន មានខ្សាច់ច្រើន ជាផែនដីដែលគេដុត ហើយ តថាគតក៏ហៅថា អជាតបឋវី ។ មួយវិញទៀត គំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ចុះថយពី ៤ ខែមក

ផែនដីនេះ តថាគតក៏ហៅថា អជាតបឋវីដែរ ។

[ ៣៥១ ] ត្រង់ពាក្យថា ជីកដោយខ្លួនឯង គឺភិក្ខុជីកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើអ្នកដទៃឲ្យជីក គឺភិក្ខុបង្គាប់អ្នកដទៃឲ្យជីក ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់មនុស្សឲ្យជីកតែម្តង មនុស្សនោះទៅជីកច្រើនដង ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៥២ ] ផែនដីមែន ភិក្ខុសម្គាល់ថាផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ផែនដីមែន តែភិក្ខុមានសេចក្តីសង្ស័យ ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី ត្រូវអាបត្តិទុក្កដ ។ ផែនដីមែន ភិក្ខុមានសេចក្តីសម្គាល់ថាមិនមែនផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី មិនត្រូវអាបត្តិឡើយ ។ ទីដែលមិនមែនជាផែនដី ភិក្ខុមានសេចក្តីសម្គាល់ថាផែនដី ត្រូវអាបត្តិទុក្កដ ។ ទីមិនមែនជាផែនដី ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ទីមិនមែនជាផែនដី ភិក្ខុសម្គាល់ថា មិនមែនផែនដី មិនត្រូវអាបត្តិឡើយ ។

[ ៣៥៣ ] អាបត្តិមិនមានដល់ភិក្ខុដែលពោលថា អ្នកឯងចូរដឹងនូវវត្ថុនេះ អ្នកឯងចូរឲ្យនូវវត្ថុនេះ អ្នកឯងចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ

អ្នកឯងចូរធ្វើនូវវត្ថុនេះ ឲ្យជារបស់សមគួរ ដល់ភិក្ខុមិនបានក្លែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

ចំនួនសិក្ខាបទក្នុងមុសាវាទវគ្គនោះ គឺ

សម្បជានមុសាវាទ ១ ឱមសវាទ ១ បេសុញ្ញវាទ ១ បទសោធម្ម ១ បឋមសហសេយ្យ ១ ទុតិយសហសេយ្យ ១ ធម្មទេសនា ១ ភូតារោចនៈ ១ ទុដ្ឋុល្លាបត្តិ ១ បឋវីខណនៈ ១ ។

សិក្ខាបទទី ១០ ចប់

មុសាវាទវគ្គ ជាដំបូង

# អដ្ឋកថា

## មុសាវាទវគ្គ

## បឋវីខណនសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះថា

## អធិប្បាយ

## សិក្ខាបទវិភង្គនៃបឋវីខណនសិក្ខាបទ

[ ៣៥០ ] ព្រះមានព្រះភាគ ទ្រង់សម្តែងបឋវីពិត និងបឋវីមិនពិត ដោយបទនេះថា **ជាតា ច បឋវី អជាតា ច បឋវី** ដូច្នេះ ក្នុងបទទាំងឡាយ មានបទថា **អប្បទាសាណា** ជាដើម អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា ជាតបឋវីនេះ មានថ្មតិច ដូច្នោះ ទើបឈ្មោះថា **អប្បទាសាណា** ។ ក្នុងបទថា **អប្បទាសាណា** ជាដើមនោះ គប្បីជ្រាបថា មានថ្មធំជាងមួយក្តាប់ដៃ ។ ក្រួសគប្បីជ្រាបថា មានទំហំប៉ុនមួយក្តាប់ដៃ ។ សំណល់អំបែងឈ្មោះថា **កឋលា** ។ ដុំក្រួសដែលប្រាកដ ( ក្រួសវាម ) ឈ្មោះថា **មរុម្ពា** ។ ខ្សាច់នោះឯងឈ្មោះថា **វាលុកា**។

ពីរបទថា **យេភុយ្យេន បំសុ** សេចក្តីថា ក្នុង ៣ ចំណែក ២ ចំណែកជាដីសុទ្ធ ១ ចំណែកជាថ្មឯណានីមួយជាដើម ។

បទថា **អទឌ្ឍាបិ** សេចក្តីថា ដែលមិនបានដុតដោយភ្លើង ដោយប្រការណានីមួយ ដោយអំណាចនៃជើងប្រានដែលដុតបាត្រ និងឡជាងធ្នាំងជាដើម ។ ឯបឋវីដែលមិនបានដុតនោះ មិនមានផ្សេងដទៃ គប្បីជ្រាបថាជាបឋវីប្រភេទ

ណាទីមួយ មានដីល្បាប់សុទ្ធជាដើម ។

ពីរបទថា **យេភុយ្យេន សក្ខរា** បានដល់ មានដុំក្រួសច្រើនជាង បាន ឮថា ក្នុងហត្ថិកុច្ឆិប្រទេស ពួកភិក្ខុឲ្យជីកដីមកពេញមួយបង្គី ហើយលាងក្នុង ប្រឡាយ ដឹងថា ជាបឋវី មានក្រួសដោយច្រើន ទើបជីកស្រះបោក្ខរណី ដោយខ្លួនឯង ។

ពីរបទថា **អប្បបំសុ អប្បមត្តិកា** ដែលមាននៅត្រង់កណ្ដាល បន្ថែម ចូលពួក ៥ មានថ្មដោយច្រើននោះឯង ។ ពិតហើយ ពាក្យនេះ ជាពាក្យ សម្ដែងប្រភេទនៃបឋវីទាំងពីរនោះឯង ។

[ ៣៥១ ] ក្នុងបទថា **សយំ ខណតិ អាបត្តិ ចាចិត្តិយស្ស** នេះ អ្នកសិក្សា គប្បីជ្រាបថា ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ គ្រាដែលជីក ។

បទថា **សកឹ អាណត្តោ ពហុកំបិ ខណតិ** សេចក្ដីថា បើអ្នកទទួល ប្រើជីកអស់ ១ ថ្ងៃ ក៏ត្រូវអាបត្តិបាចិត្តិយ ១ ប៉ុណ្ណោះដល់អ្នកប្រើ ។ បើ អ្នកទទួលប្រើជាមនុស្សខ្ជិលច្រអូស អ្នកប្រើចាំបាច់ប្រើរឿយៗ ត្រូវអាបត្តិ បាចិត្តិយដល់ភិក្ខុដែលប្រើគ្រប់ៗ វាចា បាលីវណ្ណនាមានប្រមាណប៉ុណ្ណេះ ។

## ចាលិមុត្តក ពោលអំពីការជីកដី

ឯវិនិច្ឆ័យក្រៅព្រះបាលី មានដូចតទៅនេះថា ភិក្ខុពោលថា អ្នកចូរជីក ស្រះបោក្ខរណី ដូច្នេះ គួរ ព្រោះថា ស្រះដែលជីកហើយប៉ុណ្ណោះ ទើបឈ្មោះ ថា ជាស្រះបោក្ខរណី ដូច្នោះ វោហារនេះ ជាកប្បិយវោហារ ។ ក្នុងពាក្យ ជាដើមថា ចូរជីកបឹងអណ្ដូង រណ្ដៅ ដូច្នេះ ក៏មានន័យយ៉ាងនេះដូចគ្នា ។ តែ

បើពោលថា ចូរជីកឱកាសនេះ ចូរជីកស្រះបោក្ខរណីក្នុងឱកាសនេះ ដូច្នេះ មិនគួរ បើពោលមិនកំណត់ពិតប្រាកដថា ចូរជីកមើម ចូរជីកឫស ដូច្នេះ គួរ បើពោលថា ចូរជីកវល្លិ៍នេះ ចូរជីកមើមក្តី ឫសក្តីក្នុងឱកាសនេះ ដូច្នេះ មិនគួរ កាលស្តាស្រះបោក្ខរណី អាចនឹងយកផ្ទាំងកាយភក់រាវៗចេញបាន ទោះនាំភក់នោះចេញ គួរ ។ បើនាំភក់ដែលរីងចេញ មិនគួរ ។ ភក់ស្ងួតព្រោះកម្តៅថ្ងៃ បែកក្រហែង ក្នុងភក់ស្ងួតនោះ ចំណែកណាមិនជាប់នឹងផែនដីខាងក្រោម បើនាំភក់នោះចេញ គួរ ។ ឈ្មោះថា ដីក្រហែង( ដីស្រួយព្រោះទឹករីងស្ងួត )មាននៅក្នុងប្រឡាយ រមែងរបើកព្រោះត្រូវខ្យល់បក់ បើនាំយកបន្ទុះដីនោះចេញ គួរ ។ ប្រាំងនៃស្រះបោក្ខរណីជាដើម បាក់ធ្លាក់ចូលទៅត្រង់មាត់ទឹក បើភ្លៀងធ្លាក់ស្រោចក្រោម ៤ ខែ នឹងគាស់ចេញ ឬវាយចេញ ក៏គួរ បើលើស ៤ ខែ មិនគួរ ។ បើធ្លាក់ចូលក្នុងទឹកតែម្តង សូម្បីភ្លៀងធ្លាក់ស្រោចលើស ៤ ខែហើយ ក៏គួរ ព្រោះភ្លៀងធ្លាក់ចូលទៅតែក្នុងទឹកប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយជីកអណ្តូងទឹកលើថ្មដា បើកម្ទេចតូចធ្លាក់ចូលទៅក្នុងអណ្តូងថ្មនោះ តាំងអំពីដំបូងនោះឯង ផង់ល្អិតនោះត្រូវភ្លៀងធ្លាក់ស្រោច លុះកន្លងទៅបាន ៤ ខែ ទើបដល់នូវការរាប់ថា ជាអកប្បិយបឋវី កាលទឹករីងហើយ ពួកភិក្ខុស្តាអណ្តូងថ្ម និងញែកកម្ទេចល្អិតៗ នោះចេញ មិនគួរ ។ បើពេញដោយទឹកអំពីមុន ធូលីល្អិតដែលធ្លាក់ចូលទៅតាមក្រោយ បើវែកផង់ធូលីនោះចេញ គួរ ។ ពិតហើយ កាលភ្លៀងធ្លាក់ក្នុងអណ្តូងថ្មនោះ ទឹករមែងធ្លាក់ចូលក្នុងទឹកប៉ុណ្ណោះ ។ ផង់ធូលីល្អិតដែលមាននៅលើថ្មនោះ ផង់ធូលី

នោះ កាលត្រូវភ្លៀងធ្លាក់ជោកហើយ ក៏ជាប់គ្នាវិញ បើបំណែកផង់ធូលីនោះចេញ ដោយកន្ទុនពី ៤ ខែទៅ មិនគួរ ។

ដំបូកកើតឡើងត្រង់ញកឯង មិនមានមនុស្សធ្វើ បើបំបែកចេញតាមការងាយស្រួល គួរ ។ បើដំបូកកើតឡើងក្នុងទីវាល ត្រូវភ្លៀងធ្លាក់ស្រោចក្រោម ៤ ខែប៉ុណ្ណោះ ទើបគួរ ។ ក្នុងដីស្អិតរបស់កណ្តៀរដែលពូនជាប់នឹងដើមឈើជាដើម មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីដីអាចម៍ជន្លេន ដីដែលកណ្តុរកាយ និងក្រហែងជើងគោជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។ ភក់ដែលត្រូវកាប់ដោយក្រចកជើងគោ ហៅថា ក្រហែងក្រចកគោ ។ បើក្រហែងក្រចកគោនោះជាប់គ្នានឹងផែនដីខាងក្រោម ទោះរយៈមួយថ្ងៃ នឹងបំបែកចេញមិនគួរ ។ ភិក្ខុកាន់យកដីឥដ្ឋដែលត្រូវនង្គ័លកាត់ ក្នុងទីដែលអ្នកស្រែភ្ជួរ ក៏មានន័យយ៉ាងនេះដូចគ្នា ។

សេនាសនៈចាស់ មិនមានដំបូលក្តី មានដំបូលធ្លុះក្តី ត្រូវភ្លៀងលិចស្រោចលើស ៤ ខែ រមែងដល់នូវការរាប់ថា ជាតបឋវីដូចគ្នា ។ ភិក្ខុទោះកាន់យកគ្រឿងប្រក់ដំបូលក្តី ឬគ្រឿងឧបករណ៍ មានបង្កង់ជាដើមដែលសល់អំពីសេនាសនៈចាស់នោះ ដោយសម្គាល់ថា អញនឹងយកឥដ្ឋ នឹងយកបង្កង់ នឹងយកជើងទ្រជញ្ជាំង នឹងយកក្តារក្រាល នឹងយកសសរថ្ម ដូច្នេះ គួរ ។ ដីស្អិតធ្លាក់ចុះជាប់នឹងគ្រឿងដំបូលជាដើមនោះ មិនជាអាបត្តិ តែត្រូវអាបត្តិដល់ភិក្ខុដែលយកដីស្អិតដែលលាបត្រង់ជញ្ជាំង ។ បើដីដុំណាមួយមិនសើម ភិក្ខុកាន់យកដុំដីនោះ មិនត្រូវអាបត្តិ ។

ឯក្នុងផ្ទះមានគំនរដី កាលគំនរដីនោះ ត្រូវភ្លៀងធ្លាក់ស្រោចពេញមួយថ្ងៃ ទើបជនទាំងឡាយប្រក់ផ្ទះ បើគំនរដីសើមទាំងអស់នោះកន្លងទៅបាន ៤ ខែ ក្លាយជាជាតបឋវីដូចគ្នា ។ បើចំណែកខាងលើរបស់គំនរដីនោះសើម ខាងក្នុងមិនសើម បើប្រើឲ្យពួកកប្បិយការកជីកយកដី ប៉ុនចំនួនដែលសើមចេញហើយ ដោយកប្បិយវោហារ ប្រើប្រាស់ដីសុទ្ធដ៏សេសតាមសប្បាយ ក៏គួរ ។ ពិតហើយ ដីដែលសើមដោយទឹក ហើយចាប់ជាប់ស្អិតដូចគ្នានោះឯង រាប់ថាជាជាតបឋវី ដីក្រៅពីនេះមិនមែនឡើយ ។

កំពែងដីស្អិតនៅក្នុងទីវាល បើត្រូវភ្លៀងធ្លាក់ស្រោចលើស ៤ ខែ រមែងដល់នូវការរាប់ថា ជាជាតបឋវី ។ បើភិក្ខុយកដៃសើមចាប់ពាល់ដីស្រួយដែលជាប់នៅត្រង់ជាតបឋវីនោះ គួរ ។ បើកំពែងឥដ្ឋតាំងនៅក្នុងឋានៈជាសំណល់អំបែងឥដ្ឋដោយច្រើន ទោះជីកកកាយចេញតាមសប្បាយ ក៏បាន ។

ភិក្ខុនឹងរង្គៀកយកសសរត្រង់មណ្ឌប ដែលតាំងនៅក្នុងទីវាលទៅមកៗ ធ្វើឲ្យដីបែក មិនគួរ ដកឡើងត្រង់ប៉ុណ្ណោះ ទើបគួរ សម្រាប់ភិក្ខុដែលកាន់យកដើមឈើងាប់ក្តី ដង្កត់ឈើងាប់ដទៃក្តី ក៏មានន័យនេះឯង ។ ភិក្ខុទាំង-ឡាយយកកំណាត់ឈើគាស់ថ្ម ឬដើមឈើប្រមៀលទៅ ដើម្បីការកសាងផែនដីក្នុងទីរមៀលទៅនោះបែកជាស្នាម បើភិក្ខុទាំងឡាយ មានចិត្តបរិសុទ្ធប្រមៀលទៅ មិនត្រូវអាបត្តិ តែបើភិក្ខុទាំងឡាយជាអ្នកប្រាថ្នានឹងទម្លាយផែនដី ដោយលេសនោះឯង ប្រព្រឹត្តជាអាបត្តិ ។ ភិក្ខុអូសមែកឈើជាដើមទៅក្តី ពុះឌសលើផែនដីក្តី ក៏មានន័យយ៉ាងនេះដូចគ្នា។ នឹងជំ ឬដោតវត្ថុណាមួយ

មានធ្អឹង មូល និងបន្ទាជាដើម ចូលទៅក្នុងផែនដី ក៏មិនគួរ ។ ទោះបន្ទោបង់បស្សាវៈ ដោយគិតយ៉ាងនេះថា អញនឹងធ្វើឲ្យបែកផែនដីដោយកម្លាំងនៃខ្សែទឹកនោម ក៏មិនគួរ កាលដីបែកដោយទឹកនោមនោះ ប្រព្រឹត្តជាអាបត្តិ ។ ទោះយកអំបោសបោសដី ដោយគិតថា អញនឹងធ្វើផែនដីដែលមិនស្មើ ឲ្យស្មើដូច្នេះ មិនគួរ ។ ការពិត គួរបោសដោយសេចក្ដីសនវត្តប៉ុណ្ណោះ ។

ភិក្ខុពួកខ្លះបុកផែនដីដោយចុងឈើច្រត់ យកចុងមេជើងខ្វាំផែនដី ដើរចង្ក្រមទម្លាយផែនដីដដែលហើយដដែលទៀត ដោយគិតថា អញនឹងបង្ហាញទីកន្លែងដែលអញចង្ក្រម ដូច្នេះ កម្មដូច្នោះ មិនគួរគ្រប់អន្លើ ។ តែបើភិក្ខុធ្វើសមណធម៌ ដើម្បីលើកស្ទួយសេចក្ដីព្យាយាម មានចិត្តបរិសុទ្ធ ចង្ក្រម គួរ ។ កាលធ្វើ ( ការដើរចង្ក្រមលើផែនដី ) ទោះដីបែក ក៏មិនត្រូវអាបត្តិ ។ ភិក្ខុទាំងឡាយ ត្រដុសដៃត្រង់ផែនដី ដោយគិតថា អញជូតដៃ មិនគួរ ឯភិក្ខុដែលមិនត្រដុស តែដាក់ដៃសើមលើផែនដី ហើយផ្ដិតយកលម្អងធូលីទៅ ក៏បាន ។ ភិក្ខុពួកខ្លះកើតរោគរមាស់ និងស្រែងជាដើម ទើបត្រដុសអវយវៈតូចធំលើទី មានមាត់ច្រាំងជាដើម ការធ្វើនោះមិនសមគួរ ។

## អធិប្បាយ
## បទភាជនីយនៃបឋវីខណនសិក្ខាបទ

[ ៣៥២ ] ពីរបទថា **ខណតិ វា ខណាបេតិ វា** សេចក្ដីថា ភិក្ខុជីកឯងក្ដី ប្រើអ្នកដទៃជីកក្ដី ( នូវផែនដី ) ដោយហោចសូម្បីដោយចុងម្រាមជើងក្ដី ដោយអំបោសក្ដី ។

ពីរបទថា **ភិន្ទតិ វា ភិន្ទាបេតិ វា** សេចក្តីថា ភិក្ខុទម្លាយឯងក្តី ប្រើឲ្យអ្នកដទៃទម្លាយក្តី ដោយហោចសូម្បីតែចាក់ទឹក ។

ពីរបទថា **ឌហតិ វា ឌហាបេតិ វា** សេចក្តីថា ភិក្ខុដុតឯងក្តី ឲ្យអ្នកដទៃដុតក្តី ដោយហោចអប់បាត្រ ។ ភិក្ខុដុតឯងក្តី ប្រើអ្នកដទៃឲ្យដុតក្នុងទីមានប្រមាណប៉ុនណា ត្រូវអាបត្តិបាចិត្តិយ មានប្រមាណប៉ុណ្ណោះ ។ ភិក្ខុកាលដុតបាត្រ គប្បីដុតក្នុងទីដែលធ្លាប់ដុតហើយនោះឯង ។ បើដាក់ភ្លើងចុះក្នុងផែនដី ដែលភ្លើងមិនធ្លាប់ឆេះ មិនគួរ តែបើដាក់ភ្លើងលើអំបែងសម្រាប់ដុតបាត្រ គួរ ។ ដាក់ភ្លើងលើគំនរឧស ភ្លើងនោះឆេះឧសទាំងនោះ ហើយភ្លើងនឹងឆេះរាលទៅដី មិនគួរ ។ ក្នុងទីដែលមានឥដ្ឋ និងថ្មជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។ ពិតហើយ ក្នុងទីនោះ បើដាក់ភ្លើងចុះលើគំនរ ឥដ្ឋនោះឯង គួរ ព្រោះហេតុអ្វី ព្រោះឥដ្ឋជាដើមនោះ មិនមែនជាពូជនៃភ្លើង ។ ពិតហើយ ឥដ្ឋជាដើមនោះមិនដល់នូវការរាប់ថា ជាពូជនៃភ្លើង ។ បើដុតភ្លើងត្រង់ជង្គត់ស្ងួត និងដើមឈើស្ងួតជាដើម ក៏មិនគួរ ។

បើភិក្ខុដុតភ្លើងដោយគិតថា អាត្មាអញនឹងពន្លត់ភ្លើងដែលមិនទាន់ដល់ផែនដីជាមុន ហើយសឹមទៅ ដូច្នេះ គួរ ។ តែក្រោយមក មិនអាចរំលត់បាន ជាអនាបត្តិ ព្រោះមិនមែនវិស័យ ។ ភិក្ខុកាន់គប់ភ្លើងដើរទៅ កាលដៃត្រូវភ្លើងរលាក ក៏ដាក់ចុះត្រង់ផែនដី ជាអនាបត្តិ ។ លោកពោលទុកក្នុងមហាបច្ចរីថា បើបន្ថែមពូជបង្កាត់ភ្លើង ក្នុងទីដែលគប់ភ្លើងធ្លាក់នោះឯង គួរ ។ លោកពោលទុកក្នុងមហាបច្ចរីនោះឯងទៀតថា ទីប្រមាណប៉ុនណាក្នុង

ផែនដី ដែលត្រូវភ្លើងឆេះ ចំហាយក្តៅចូលទៅដល់ បើជីកទីទាំងអស់នោះចេញ គួរ ។

ភិក្ខុណាមិនស្គាល់ឈើក្តួត ឲ្យភ្លើងកើតដោយឈើក្តួត យកដៃលើកភ្លើងឡើងហើយពោលថា ខ្ញុំនឹងធ្វើដូចម្តេច ភិក្ខុដទៃប្រាប់ថា ចូរធ្វើឲ្យឆេះឡើង លោកពោលថា ភ្លើងនឹងឆេះដៃខ្ញុំ ទើបប្រាប់ថា ចូរធ្វើដូចដែលវាមិនឆេះ ។ តែមិនគប្បីប្រាប់ថា ចូរបោះចោលត្រង់ផែនដី ។ បើភ្លើងឆេះដៃលោកបោះចោលជាអនាបត្តិ ព្រោះលោកមិនបានបោះចោល ដោយតាំងចិត្តថា អាត្មាអញនឹងដុតផែនដីឡើយ ។ លោកពោលទុកក្នុងកុរុន្ទីថា សូម្បីបង្កាត់ភ្លើង ក្នុងទីដែលភ្លើងធ្លាក់ចុះ ក៏គួរ ។

## អនាបត្តិនៃបឋវីខណនសិក្ខាបទ

[ ៣៥៣ ] ក្នុងបទថា **អនាបត្តិ ឥមំ ជាន** ជាដើម អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះ គឺ ( ជាអនាបត្តិដល់ភិក្ខុដែលពោលថា ) ចូរដឹងរណ្តៅសម្រាប់សសរនេះ ចូរដឹងដីឥដ្ឋដុំធំ ចូរដឹងដីស្អិតលាយអង្កាម ចូរឲ្យដីស្អិតដុំធំ ចូរឲ្យដីលាយអង្កាម ចូរនាំដីស្អិតមក ចូរនាំដីស្រួយមក អាត្មាត្រូវការដីស្អិត ត្រូវការដីស្រួយ ចូរធ្វើរណ្តៅឲ្យជាកប្បិយសម្រាប់សសរនេះ ចូរធ្វើដីស្អិតនេះឲ្យ ជាកប្បិយ ចូរធ្វើដីស្រួយនេះឲ្យជាកប្បិយ ។

បទថា **អសញ្ចិច្ច** សេចក្តីថា កាលភិក្ខុប្រមៀលថ្ម និងដើមឈើជា-ដើមទៅ ឬដើរយកឈើច្រត់ៗ ទៅ ផែនដីបែក ផែនដីនោះឈ្មោះថា ភិក្ខុមិនបានក្លែងធ្វើឲ្យបែកទេ ព្រោះលោកមិនបានតាំងចិត្តទម្លាយយ៉ាងនេះថា អញ

នឹងទម្លាយ ( ផែនដី ) ដោយឈើប្រត់នេះ ជាអនាបត្តិដល់ភិក្ខុ មិនក្មែង ដោយប្រការដូច្នេះ ។

បទថា **អសតិយា** សេចក្តីថា ភិក្ខុបញ្ជូនចិត្តទៅទីដទៃ ឈរនិយាយពាក្យណាមួយនឹងបុគ្គលខ្លះ យកមេជើង ឬឈើប្រត់គូរផែនដីទៅបណ្តើរៗ ជាអនាបត្តិដល់ភិក្ខុដែលគូសវាស ឬទម្លាយ ( ផែនដី ) ដោយមិនមានសតិយ៉ាងនេះ ។

បទថា **អជានន្តស្ស** សេចក្តីថា ភិក្ខុមិនដឹងផែនដីដែលភ្លៀងធ្លាក់ស្រោចខាងក្នុងផ្ទះ ដែលប្រក់ដំបូលជិតហើយថា ជាអកប្បិយបឋវី ទើបជីកចេញដោយសម្គាល់ថា ជាកប្បិយបឋវីក្តី មិនដឹងថា អញជីក អញទម្លាយ អញដុតភ្លើងក្តី កើប ឬបាជាដើមដើម្បីត្រូវការរក្សាទុកតែម្យ៉ាងក្តី ដៃត្រូវភ្លើងឆេះបោះចោលទៅក្តី មិនត្រូវអាបត្តិដល់ភិក្ខុមិនដឹងយ៉ាងនេះ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះ ។

បឋវីខណណសិក្ខាបទ ចប់

មុសាវាទវគ្គទី ១ ចប់បរិបូណ៌ តាមពណ៌នានុក្រម

# វិនយបិដក

## ភូតគាមវគ្គសិក្ខាបទទី ១

[ ៣៥៤ ] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអាគាឡវចេតិយ ទៀបក្រុងអាឡវី ។ គ្រានោះឯង ពួកភិក្ខុនៅក្នុងក្រុងអាឡវី កាលធ្វើនវកម្ម ក៏កាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះនូវដើមឈើ ។ មានភិក្ខុមួយរូប នៅក្រុងអាឡវីកាប់ឈើមួយដើម ។ មានទេវតាមួយអង្គ អាស្រ័យនៅលើដើមឈើនោះ បាននិយាយពាក្យនេះ នឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកចង់ធ្វើទីនៅរបស់ខ្លួន មិនត្រូវកាប់ទីនៅរបស់ខ្ញុំទេ ។ ភិក្ខុនោះមិនអើពើ ( នឹងពាក្យទេវតានោះ ) ក៏ចេះតែកាប់ឈើនោះទៅ ក៏ត្រូវដៃទារករបស់ទេវតានោះ ។ វេលានោះឯង ទេវតានោះត្រិះរិះដូច្នេះថា បើដូច្នោះ ខ្លួនអញត្រូវសម្លាប់ភិក្ខុនេះក្នុងទីនេះ ។ ខណៈនោះឯង ទេវតានោះត្រិះរិះដូច្នេះវិញថា ខ្លួនអញសម្លាប់ភិក្ខុនេះ ក្នុងទីនេះដោយអំពើណា អំពើនេះមិនសមគួរដល់ខ្លួនអញសោះឡើយ បើដូច្នោះ អញត្រូវក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគសិន ។ គ្រានោះឯង ទេវតានោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ( ដោយសព្វគ្រប់ ) ។ ព្រះសាស្តាជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលទេវតា ពាក្យដែលអ្នកថា ប្រពៃពេកណាស់ ម្នាលទេវតា អ្នកឯងមិនបានសម្លាប់ភិក្ខុនោះ ត្រូវពិតហើយ ម្នាលទេវតា បើអ្នកសម្លាប់ភិក្ខុនោះថ្ងៃនេះហើយ ម្នាលទេវតា អ្នកឯងត្រូវបាននូវបាបជាច្រើន នែទេវតា អ្នកឯងចូរត្រឡប់ទៅវិញចុះ ក្នុងទីឯណោះ មានឈើមួយដើមយ៉ាងស្ងាត់ អ្នកឯង

ចូរទៅនៅអាស្រ័យនូវឈើនោះចុះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះ-ដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងផង ប្រើអ្នកដទៃឲ្យកាប់ផង នូវដើមឈើសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ រមែងបៀតបៀននូវវត្ថុ ដែលមានជីវិត មានឥន្ទ្រិយតែមួយ ។ ភិក្ខុទាំងឡាយ បានឮពាក្យ មនុស្សទាំង-ឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនៅក្នុងក្រុងអាឡវី មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើសោះ ។ គ្រានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយ មិនគួរបើនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះនូវដើមឈើទេ នែមោឃបុរសទាំងឡាយ ព្រោះពួកមនុស្សមានសេចក្តីសម្គាល់ថា ដើមឈើមានជីវិត នែ មោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬពួកមនុស្សដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៥៥ ] ពូជមាន ៥ យ៉ាង គឺ ពូជកើតពីមើមឬឫស ១ ពូជកើតពីដើម ១ ពូជកើតពីថ្នាំង ១ ពូជកើតពីចុង ឬគល់ ១ ពូជកើតពីពូជ ( គឺផ្លែ ) ១ ពូជទាំង ៥ នេះ ហៅថា ភូតគាម ។ ដែលហៅថា ពូជកើតពីមើមឬឫស ( នោះសំដៅយក ) រមៀត ខ្ញី លំពាន់ ប្រស់ អាចម៍ធ្មឹស រំដេងស្បូវក្លាំង និងក្រវាញជ្រូក មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃ ណាកើតពីមើម ឬឫស ដុះពីមើម ឬឫស វត្ថុប៉ុណ្ណោះ ឈ្មោះថា ពូជកើតពីមើម ឬឫស ( ដូចគ្នា ) ។ ដែលហៅថា ពូជកើតពីដើម ( នោះសំដៅយក ) ដើមពោធិ៍ ដើមជ្រៃ ដើមលាប ដើមល្វា ដើមជ្រៃក្រឹម ដើមក្រសាំង មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណា កើតពីដើម ដុះពីដើម វត្ថុប៉ុណ្ណោះ ហៅថា ពូជកើតពីដើម ។ ដែលហៅថា ពូជកើតពីថ្នាំង ( នោះ សំដៅយក ) អំពៅ ឫស្សី និងបបុស មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយ ដទៃណាកើតពីថ្នាំង ដុះពីថ្នាំង វត្ថុប៉ុណ្ណោះហៅថា ពូជកើតពីថ្នាំង ។ ដែលហៅថា ពូជកើតពីចុងឬគល់ ( នោះសំដៅយក ) ជីរលើងលាក់ ស្ទឹកគ្រៃ វល្លិ៍អណ្តាត-ត្រកួត ម្យ៉ាងទៀត សូម្បីវត្ថុទាំងឡាយណា កើតពីចុងឬគល់ ដុះពីចុងឬគល់ វត្ថុប៉ុណ្ណោះ ហៅថា ពូជកើតពីចុង ឬគល់ ( ដូចគ្នា ) ។ ដែលហៅថា ពូជកើតពីពូជ ( នោះសំដៅយក ) បុព្វណ្ណជាតិ បានដល់ ស្រូវ ៧ ប្រការ មានស្រូវស ស្រូវក្រហម និងពោតជាដើម អបរណ្ណជាតិបានដល់ សណ្តែក-បាយ សណ្តែករាជមាសជាដើម ម្យ៉ាងទៀត សូម្បីវត្ថុទាំងឡាយណា កើតពី

ពូជ ដុះពីពូជ វត្ថុប៉ុណ្ណេះហៅថា ពូជកើតពីពូជជា គម្រប់ ៥ ។

[ ៣៥៦ ] វត្ថុជាពូជមែន ភិក្ខុសម្គាល់ថា ពូជ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី ត្រូវអាបត្តិបាចិត្តិយ ។ ពូជមែន ភិក្ខុមានសេចក្តីសង្ស័យ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី ត្រូវអាបត្តិទុក្កដ ។ ពូជមែន ភិក្ខុសម្គាល់ថា មិនមែនពូជ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី មិនត្រូវអាបត្តិឡើយ ។ វត្ថុមិនមែនពូជ ភិក្ខុសម្គាល់ថា ពូជ ត្រូវអាបត្តិទុក្កដ ។ វត្ថុមិនមែនពូជ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វត្ថុមិនមែនពូជ ភិក្ខុ សម្គាល់ថា មិនមែនពូជ មិនត្រូវអាបត្តិឡើយ ។

[ ៣៥៧ ] អាបត្តិមិនមានដល់ភិក្ខុដែលនិយាយថា អ្នកចូរដឹងនូវវត្ថុនេះ អ្នកចូរឲ្យនូវវត្ថុនេះ អ្នកចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ អ្នកចូរធ្វើនូវវត្ថុនេះឲ្យសមគួរ ដល់ភិក្ខុមិនបានក្លែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់

# អដ្ឋកថា

## ភូតគាមវគ្គ

## ភូតគាមសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃភូតគាមវគ្គដូចតទៅនេះ

[ ៣៥៤ ] បទថា **អនាធិយន្តោ** គឺមិនស្តាប់ពាក្យរបស់ទេវតានោះ ។

ប្រើនបទថា **ទារកស្ស ពាហុំ អាកោដេសិ** សេចក្តីថា ភិក្ខុនោះ មិនអាចទប់ពូថៅដែលងាឡើងទើបកាត់យកដៃត្រង់ទីជិតដោះរបស់ទារកដែល ដេកលើវិមានទិព្វ ដែលតាំងនៅលើដើមឈើ ដែលទេវតានោះបានមកអំពី សម្នាក់របស់ស្តេចចតុមហារាជិកា ដែលកន្លងបង់វិស័យនៃភ្នែករបស់ពួក មនុស្ស ។

ក្នុងបទថា **ន ខោ បនេតំ បដិរូបំ** ជាដើម មានពណ៌នាដោយសង្ខេប ដូចតទៅនេះថា បានឮថា ក្នុងព្រៃហិមពាន្ត មានការប្រជុំទេវតារាល់ៗ កន្លះ ខែម្តង ក្នុងព្រៃហិមពាន្តនោះ ពួកទេវតារមែងសួរដល់រុក្ខធម៌ថា អ្នកតាំងនៅ ក្នុងរុក្ខធម៌ ឬមិនតាំងនៅក្នុងរុក្ខធម៌ទេ ។ ឈ្មោះថា រុក្ខធម៌ បានដល់ ការ ដែលរុក្ខទេវតាមិនធ្វើការប្រទូស្តផ្លូវចិត្ត ក្នុងកាលដើមឈើត្រូវកាប់ ។ បណ្តា ទេវតាទាំងនោះ ទេវតាអង្គណាមិនតាំងនៅក្នុងរុក្ខធម៌ ទេវតាអង្គនោះរមែងមិន បានចូលកាន់ទីប្រជុំ ។ ទេវតាអង្គនោះបានមើលឃើញទោស មានការមិនតាំង នៅក្នុងរុក្ខធម៌ជាបច្ច័យនេះ ដោយប្រការដូច្នេះ និងរឭកដល់បុព្វចរិយា ក្នុង គ្រាដែលព្រះតថាគតសោយព្រះជាតិជាស្តេចដំរី ឈ្មោះឆទ្ទន្តជាដើម ដោយ

ក្រសែនៃព្រះធម្មទេសនា ដែលខ្លួនធ្លាប់ស្តាប់មកចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបទេវតានោះមានការរំពឹងថា **ន ខោ បនេតំ បដិរូបំ ។បេ។ ជីវិតា វោរោបេយ្យំ** ( ឯការដែលអញផ្តាច់ជីវិតភិក្ខុរូបនេះ ចោលក្នុងទីនេះ មិនសមគួរឡើយ ) ដូច្នេះ ។ ឯការគិតនេះថា បើដូច្នោះ អញគួរក្រាបទូលរឿងនេះដល់ព្រះមានព្រះភាគ ដូច្នេះ ក៏មានដល់ទេវតានោះ ដែលគិតយ៉ាងនេះថា ភិក្ខុនេះជាកូនមានឪពុក ព្រះមានព្រះភាគទ្រង់បានឮអជ្ឈាចារនេះរបស់ភិក្ខុនោះហើយ ទ្រង់នឹងរាំងមារយាទ ទ្រង់នឹងបញ្ញត្តសិក្ខាបទពិតប្រាកដ ។

បទថា **សចជ្ជ ត្វំ ទេវតេ** សេចក្តីថា ម្នាលទេវតា បើអ្នក ( ផ្តាច់ជីវិតភិក្ខុរូបនោះ ) ក្នុងថ្ងៃនេះសោត ។

បទថា **បសវេយ្យាសិ** ប្រែថា គប្បីឲ្យកើត គឺគប្បីឲ្យកើតឡើង ។ ឯព្រះមានព្រះភាគកាលត្រាស់យ៉ាងនេះហើយ ដើម្បីឲ្យទេវតានោះយល់ព្រម ទើបត្រាស់គាថានេះថា

> បុគ្គលណាឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូច
> សារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថា
> ជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ ។

ក្នុងកាលចប់ព្រះគាថា ទេវតានោះបានតាំងនៅក្នុងសោតាបត្តិផល ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ដល់បរិស័ទដែលប្រជុំព្រមគ្នាហើយ ទើបទ្រង់ភាសិតគាថានេះទៀតថា

ភិក្ខុណា បន្ទោបង់សេចក្ដីក្រោធ ដែលឆួលឡើងហើយ ដូច
បុគ្គលបន្សាបពិសពស់ ដែលជ្រួតជ្រាបទៅ ដោយឱសថទាំង
ឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់
សកសំណាកចាស់គ្រាំគ្រាចេញ ដូច្នោះ ។

បណ្ដាគាថាទាំង ២ នោះ គាថាទី ១ ព្រះធម្មសង្គាហកាចារ្យលើក
ឡើងកាន់សង្គាហៈក្នុងធម្មបទ គាថាទី ២ លើកឡើងកាន់សង្គាហៈក្នុងសុត្ត-
និបាត ឯរឿងលើកឡើងកាន់សង្គាហៈក្នុងវិនយបិដកនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់កំពុងសម្ដែងធម៌នោះឯង ទ្រង់
ប្រមើលមើលទីលំនៅរបស់ទេវតានោះ ទតឃើញទីកន្លែងសមគួរហើយ ទើប
ត្រាស់ថា នែទេវតា ក្នុងទីឱកាសឈ្មោះនោះ មានដើមឈើទំនេរ អ្នកចូរទៅ
នៅត្រង់ដើមឈើនោះចុះ ។ បានឮថា ដើមឈើនោះ មិនមានក្នុងដែនអាឡវី
មាននៅខាងក្នុងកំពែងនៃវត្តជេតពន ដែលមានទេវបុត្រជាម្ចាស់ដើមឈើ ចុតិ
ទៅហើយ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ដើមឈើនោះទំនេរហើយ ។
ចាប់តាំងអំពីកាលនោះមក ទេវតានោះបានការរក្សាអំពីព្រះសម្មាសម្ពុទ្ធ បាន
ជាពុទ្ធុបដ្ឋាយិកា ។ ក្នុងគ្រាមានទេវសមាគម កាលទេវតាដែលមានសក្តិធំ
ទាំងឡាយមកដល់ ទេវតាពួកដទៃដែលមានសក្តិតូច រមែងថយក្រោយទៅ
រហូតទល់មហាសមុទ្រ និងភ្នំចក្រវាល ។ ឯទេវតានេះអង្គុយស្ដាប់ធម៌ក្នុង
លំនៅរបស់ខ្លួននោះឯង ។ ទេវតានោះអង្គុយស្ដាប់បញ្ហាទាំងអស់ ដែលពួក
ភិក្ខុសួរក្នុងបឋមយាម និងដែលពួកទេវតាសួរក្នុងមជ្ឈិមយាម លើវិមាននោះ

ឯង ។ សូម្បីមហារាជទាំង ៤ មកកាន់ទីបម្រើរបស់ព្រះមានព្រះភាគ កាលនឹងទៅ ក៏សួរសុខទុក្ខនោះជាមុនហើយ ទើបទៅ ។

## អធិប្បាយ ពាក្យថា ភូតគាម

ក្នុងបទថា **ភូតគាមបាតព្យតាយ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ដែលឈ្មោះថា **ភូត** ព្រោះអត្ថថា កើតផង ជំចម្រើនឡើងផង ។ អធិប្បាយថា រមែងកើត រមែងចម្រើន ឬអធិប្បាយថា កើតហើយ ចម្រើនហើយ ។

បទថា **គាមោ** ប្រែថា គំនរ ។ គំនរនៃភូតទាំងឡាយ ហេតុនោះទើបឈ្មោះថា **ភូតគាម** ។ មយ៉ាងទៀត គំនរ គឺភូត ឈ្មោះថា ភូតគាម ។ បទថា **ភូតគាម** នោះ ជាឈ្មោះនៃស្មៅ និងដើមឈើពណ៌ខៀវស្រស់ដែលបញ្ឈរដើមហើយជាដើម ។

ភាវៈនៃការផ្តាច់បង់ ឈ្មោះថា **បាតព្យតា** ( ការធ្វើឲ្យវិនាស ) អធិប្បាយថា ភាវៈដែលបុគ្គលគប្បីបរិភោគ ប្រើប្រាស់ តាមការពេញចិត្ត ដោយការកាត់ និងការវាយជាដើម ។ ព្រោះភាពជាអ្នកធ្វើភូតគាមឲ្យវិនាស នោះនៃភិក្ខុនោះ ។ ពាក្យនេះជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្ត ។ អធិប្បាយថា ជាបាចិត្តិយ ព្រោះភាពជាអ្នកបំផ្លាញភូតគាមជាហេតុ គឺព្រោះការកាប់ភូតគាមជាដើមជាបច្ច័យ ។

## អធិប្បាយ
## សិក្ខាបទវិភង្គនៃភូតគាមសិក្ខាបទ

[ ៣៥៥ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងចែកភូតគាម

នោះ ទើបត្រាស់ពាក្យជាដើម **ភូតគាមោ ឆាម បញ្ច ពីជជាតានិ** ដូច្នេះ ។

លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ក្នុងបទថា **ភូតគាម** ជាដើមនោះ ព្រះមានព្រះភាគទ្រង់លើកភូតគាមឡើង ដោយបទថា **ភូតគាមោ ឆាម** ដូច្នេះហើយ ត្រាស់បទថា **បញ្ច ពីជជាតានិ** ជាដើម ដើម្បីទ្រង់សម្ដែងពូជដែលនៅមាន ទើបភូតគាមនៅមាន ។ កាលមានយ៉ាងនេះ បទថា **យានិ វា បនញ្ញានិបិ អត្ថិ មូលេ ជាយន្តិ** ជាដើម ក៏មិនសមគ្នា ។ ពិតហើយ ពូជ ៥ យ៉ាង មានពូជកើតពីមើមជាដើម មិនមែនកើតនៅត្រង់មើមជាដើមឡើយ តែពូជទាំងនោះ កាលនឹងកើតត្រង់មើមជាដើម ក៏ឈ្មោះថា **មូលពីជ** ជាដើម ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបពណ៌នាក្នុងបទថា **ភូតគាមោ ឆាម** ជាដើមនេះ យ៉ាងនេះថា បទថា **ភូតគាមោ ឆាម** ជាបទគួរបែក ។

បទថា **បញ្ច** ជាការកំណត់ចំនួននៃភូតគាមនោះ ។

បទថា **ពីជជាតានិ** ជាបទសម្ដែងលម្អិតក្នុងធម៌ដែលបានកំណត់ ។ អត្ថនៃបទថា **ពីជជាតានិ** នោះថា ដែលឈ្មោះថា **ពីជជាត** ព្រោះអត្ថថា កើតអំពីប្រភេទគ្រាប់ ។ ពាក្យនេះ ជាឈ្មោះនៃពូជ មានដើមឈើជាដើម ។ ន័យម្យ៉ាងទៀត ពូជទាំងនោះផង កើតហើយផង គឺចេញហើយ បានដល់ មានស្លឹកនិងឫសដុះចេញហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ពីជជាត** ។ ដោយបទថា **ពីជជាត** គឺលោកធ្វើការសង្គ្រោះយកពូជ មានឫជាដើម ដែលគេផ្សាំទុកក្នុងខ្សាច់សើមជាដើម ដែលមានស្លឹក ឬឫសដុះឡើងហើយ ។

ឥឡូវនេះ ពូជ មានដើមឈើជាដើម ដែលត្រាស់ហៅថា ពីជជាត

ព្រោះកើតអំពីពូជពួកណា កាលទ្រង់សម្តែងពូជទាំងនោះ ទើបព្រះមានព្រះភាគត្រាស់បទថា **មូលពីជំ** ជាដើម ។ ឧទ្ទេសនៃពូជ មានពូជកើតអំពីមើមជាដើមនោះ ប្រាកដជាក់ច្បាស់ហើយ ដូច្នេះ ។ ក្នុងពាក្យថា ពូជដទៃឯណានីមួយ ក្នុងបណ្តាពូជ មានពូជកើតអំពីមើម ដុះត្រង់មើមនេះ ក្នុងឧទ្ទេសព្រះមានព្រះភាគទ្រង់សម្តែងពូជដែលកើតអំពីគ្រាប់ ។

ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទថា **យានិ វាបនញ្ញានិ** ជាដើមនេះ យ៉ាងនេះថា ពូជដទៃណាមួយ ក្នុងបណ្តាពូជ មានគុម្ពឈើ វល្លិ៍ និងដើមឈើជាដើម ដែលកើត និងដុះឡើងត្រង់មើម មានប្រភេទ ដូចជាមើមដំឡូង ក្រចាប់ ឈូកក្រហម ឈូកខៀវ ឈូកស ព្រលិត ត្រាវ និងប្រទៀងជាដើម គុម្ពឈើ វល្លិ៍ និងដើមឈើជាដើមនោះ រមែងកើត និងរមែងដុះត្រង់មើមណា មើមនោះ ព្រះមានព្រះភាគត្រាស់ហើយក្នុងបាលី ពូជកើតអំពីមើម មានរមៀតជាដើម ទាំងអស់នេះ ឈ្មោះថា **មូលពីជ**។ ក្នុងខន្ធពីជ ( ពូជដែលដុះអំពីថ្នាំង ) ជាដើម ក៏មានន័យដូច្នេះ ។

ម្យ៉ាងទៀត បណ្តាពូជទាំងឡាយ មានពូជដែលកើតអំពីដើមជាដើមនេះ ពូជពួកណា មានដើមម្កាក់ ដើមប្រទៀង ដើមជ្រលាត់ដៃ រលួសផ្អុង ដើមកណិការជាដើម បណ្ឌិតគប្បីឃើញថា ពូជដែលកើតអំពីដើម ពូជទាំងឡាយមានវល្លិ៍មិនមានឫស វល្លិ៍ ៤ ជ្រុង វល្លិ៍ដីប៉ីជាដើម បណ្ឌិតគប្បីឃើញថា ពូជកើតអំពីថ្នាំង ពូជ មានផ្ចិ ម្ទេះ សិរមាន់ជាដើម បណ្ឌិតគប្បីឃើញថា ពូជកើតអំពីត្រួយ ពូជ មានគ្រាប់ស្វាយ ព្រីង និងខ្នុរជាដើម គប្បីជ្រាបថា

ពូជកើតអំពីគ្រាប់ ។

## អធិប្បាយ

## បទភាជនីយនៃភូតគាមសិក្ខាបទ

[ ៣៥៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិ អនាបត្តិ និងប្រភេទនៃការធ្វើឲ្យវិនាស ដោយអំណាចសញ្ញា (ឈ្មោះ) ក្នុងបទដែលទ្រង់ត្រាស់ថា **ភូតគាមចាតព្យតាយ ចាចិត្តិយំ** ( ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើភូតគាមឲ្យវិនាស ) ទើបត្រាស់បទថា **ពីជេ ពីជសញ្ញី** ជាដើម ។

ភូតគាមដែលកើតអំពីគ្រាប់ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហៅថា ពូជ ក្នុងបទថា **ពីជេ ពីជសញ្ញី** នោះ ដូចបាយនៃអង្ករស្រូវសាលី គេតែងហៅថា បាយនៃស្រូវសាលី ក្នុងបទថា **សាលីនពោរ ខិទនំ ភុញ្ជតិ** ជាដើម ដូច្នោះ ។ ឯពូជដែលលោកកាត់ចេញទុកឲ្យផុតអំពីភូតគាមដែលព្រះមានព្រះភាគទ្រង់ត្រាស់ ក្នុងបទថា **ពីជគាមភូតគាមសមារម្ភា បដិវិរតោ** ជាដើម ជាវត្ថុនៃទុក្កដ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបជាមួយបទដើមនៃសិក្ខាបទវិភង្គ ត្រង់បទថា **ភូតគាមោ ឆាម** ហើយគប្បីជ្រាបអត្ថក្នុងបទថា **ពីជេ ពីជសញ្ញី** នេះ យ៉ាងនេះថា ភិក្ខុមានការសម្គាល់ក្នុងពូជ ដែលមានឈ្មោះថា ភូតគាមជាជាពូជ យកសស្ត្រាជាដើមកាត់ឯងក្តី ឲ្យអ្នកដទៃកាត់ក្តី យកដុំថ្មជាដើមវាយឯងក្តី ប្រើអ្នកដទៃឲ្យវាយក្តី នាំយកភ្លើងចូលទៅដុតឯងក្តី ប្រើអ្នកដទៃ

ឲ្យដុតក្តី ត្រូវអាបត្តិបាចិត្តិយ ។ តែបណ្ឌិតមិនគប្បីកាន់យកតាមព្រះបាលី កាត់អាបត្តិបាចិត្តិយ ព្រោះការធ្វើឲ្យវិនាសនូវពូជក្រៅអំពីភូតគាមជាដើម ។

# អធិប្បាយ ពីជគាម និងភូតគាម

ពិតហើយ ក្នុងភូតគាមសិក្ខាបទនេះ មានវិនិច្ឆយកថាដូចតទៅនេះថា ភិក្ខុធ្វើភូតគាមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ធ្វើពីជគាម ៥ យ៉ាង ក្រៅអំពីភូតគាម ត្រូវអាបត្តិទុក្កដ ។ ឈ្មោះថា ពីជគាម និងភូតគាមនេះ នៅក្នុងទឹកក៏មាន នៅលើគោកក៏មាន ។ បណ្តាពីជគាម និងភូតគាមដែលនៅក្នុងទឹក និងលើគោកទាំង ២ នោះ ពីជគាម និងភូតគាមដែលនៅក្នុងទឹក គឺសេវាលជាតិ ( សារាយ ) ដែលមានស្លឹក និងមិនមានស្លឹកទាំងអស់ មានប្រភេទដូចជាចកធំ និងចកតូចជាដើម ដោយហោចសូម្បីស្មៅទឹក បណ្ឌិតគប្បីជ្រាបថា ភូតគាម ។ ឈ្មោះថា ស្មៅ ខាងលើរឹង មានពណ៌ខៀវចាស់ ខាងក្រោមទន់ មានពណ៌ខៀវ ។

បណ្តាសេវាលជាតិនោះ ឫសរបស់សារាយណាចាក់ចុះនៅក្នុងផែនដី ផែនដីជាឋានរបស់សារាយនោះ ។ ទឹកជាឋានរបស់សារាយ ដែលអណ្តែតទៅមកលើទឹក ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលធ្វើភូតគាម ដែលនៅក្នុងផែនដី ក្នុងទីណាមួយក្តី លើកឡើងផ្លាស់ទៅកាន់ទីដទៃក្តី ។ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលធ្វើភូតគាមឲ្យវិនាស ដែលអណ្តែតទៅមកលើទឹកដូចគ្នា តែបើយកដៃទាំង ២ ញែកទៅខាងនោះ ខាងនេះ ហើយងូតទឹក គួរ ។ ពិតហើយ ទឹកទាំងមូលជាឋានរបស់សារាយដែលនៅក្នុងទឹកនោះ ព្រោះហេតុនោះ សារាយ

ទាំងនោះ មិនទាន់រាប់ថា ភិក្ខុផ្លាស់ទៅកាន់ទីដទៃ ដោយហេតុ មានប្រមាណ ប៉ុណ្ណោះឡើយ ។ តែបើក្លែងលើកឡើងអំពីទឹក ដោយវៀរទឹកចេញ មិនគួរ ។ បើលើកឡើងមួយអន្ទើដោយទឹក ហើយដាក់ចុះក្នុងទឹកវិញ គួរ ។ សារាយ ចេញមកតាមតម្រងទឹក គួរឲ្យកប្បិយជាមុន សឹមបរិភោគទឹក ។ ភិក្ខុដកវល្លិ៍ និងស្មៅដែលកើតក្នុងទឹក មានគុម្ពព្រលិត និងគុម្ពឈូកជាដើមឡើងអំពីទឹកក្តី ធ្វើឲ្យវិនាសក្នុងទឹកនោះឯងក្តី ត្រូវអាបត្តិបាចិត្តិយ ។ ធ្វើគុម្ពឧប្បល និងគុម្ព ឈូកជាដើមឲ្យវិនាស ដែលអ្នកដទៃដកឡើងហើយ ត្រូវអាបត្តិទុក្កដ ។ ពិត ហើយ គុម្ពឧប្បល ឬគុម្ពឈូកជាដើមដែលអ្នកដទៃដកឡើងនោះ រមែងដល់ ឫស សង្គ្រោះចូលក្នុងពីជគាម ។ សារាយ គឺចក និងចកធំ ដែលគេលើក ឡើងអំពីទឹកហើយ មិនទាន់ក្រៀមស្ងួត រមែងដល់នូវការសង្គ្រោះចូលក្នុង ពូជដែលកើតអំពីត្រួយ ។ ក្នុងអដ្ឋកថាមហាបច្ចរីជាដើមពោលទុកថា ចកមិន មានឫស និងពន្លក និងស្លែជាដើម ជាវត្ថុនៃទុក្កដ ។ ហេតុក្នុងពាក្យនោះ មិន ប្រាកដ ក្នុងអន្ធកអដ្ឋកថាពោលទុកថា នៅមិនទាន់ជាភូតគាមដែលបរិបូណ៌ ហេតុនោះ ទើបត្រូវអាបត្តិទុក្កដ ។ សូម្បីអន្ធកអដ្ឋកថានោះ ក៏មិនស៊ីគ្នា ( ក្នុង ព្រះបាលី ) ។ ពិតហើយ ព្រះមានព្រះភាគកាត់អាបត្តិបាចិត្តិយ ព្រោះភូតគាម កាត់អាបត្តិទុក្កដ ព្រោះពីជគាម ។

ឈ្មោះថា ភូតគាមដែលមិនបរិបូណ៌ ជាកោដ្ឋាសទី ៣ មិនបានមកក្នុង ព្រះបាលី មិនបានមកក្នុងអដ្ឋកថាទាំងឡាយឡើយ ។ បើគប្បីមានមតិថា ចក មិនមានឫស និងពន្លកនោះ នឹងដល់នូវការសង្គ្រោះចូលក្នុងពីជគាមសោត

ពាក្យនោះក៏មិនគួរ ព្រោះពូជនោះ មិនជាមូលហេតុនៃភូតគាមឡើយ ។ ន័យម្យ៉ាងទៀត ពាក្យថា បណ្ដាឋានដែលធ្ងន់ និងស្រាល ភិក្ខុគួរតាំងនៅក្នុងឋានដែលធ្ងន់ នេះជាលក្ខណៈនៃវិន័យ ។

## អធិប្បាយ ភូតគាមដែលកើតលើគោក

វិនិច្ឆ័យក្នុងភូតគាមដែលកើតលើគោក មានដូចតទៅថា ចំណែកដ៏សេសនៃប្រភេទដើមឈើដែលត្រូវកាប់ រាប់ថា ជាដង្គត់ឈើដែលខៀវស្រស់ ។ ក្នុងដង្គត់ឈើខៀវស្រស់នោះ ដង្គត់នៃដើមថ្ងាន់ ដើមអំបែងថ្ងៃ ដើមបយង្គុ និងដើមខ្នុរជាដើម រមែងដុះឡើងបាន ។ ដង្គត់ឈើនោះ លោកសង្គ្រោះចូលដោយភូតគាម ដង្គត់នៃដើមត្នោត និងដើមដូងជាដើម រមែងមិនដុះឡើងទេ ដង្គត់នៃដើមត្នោតជាដើមនោះ លោកសង្គ្រោះចូលដោយពីជគាម ឯគល់ចេកដែលមិនទាន់ធ្លាក់ត្រយោង លោកសង្គ្រោះដោយភូតគាម គល់ដែលធ្លាក់ត្រយោងហើយ លោកសង្គ្រោះជាពីជគាម តែដើមចេកដែលធ្លាក់ត្រយោងហើយ លោកសង្គ្រោះចូលដោយភូតគាមដូចគ្នា ដរាបណានៅមានស្លឹកពណ៌ខៀវ ។ ឫស្សីដែលចេញផ្លែហើយក៏ដូច្នោះដែរ ។ តែឫស្សីក្នុងវេលាស្ងួតមកតាំងអំពីចុង ទើបដល់នូវការសង្គ្រោះដោយពីជគាម សង្គ្រោះដោយពីជគាមប្រភេទណា ដោយពីជគាមប្រភេទកើតអំពីថ្នាំង អ្វីកើតអំពីដើមឫស្សីនោះពិតហើយ បើអ្វីៗ ( មែក ឬស្លឹក ) មិនគប្បីកើត ។ ( នៅទីនឹងដើមឫស្សីចេញផ្លែ ) គប្បីដល់នូវការសង្គ្រោះចូលក្នុងភូតគាម ។ ជនទាំងឡាយកាប់ដើមរាជព្រឹក្សជាដើម គរជាគំនរទុក ។ មែកទាំងឡាយសូម្បីប្រមាណមួយ

ហត្ថ ដុះចេញអំពីកំណាត់មែក ដែលគេរជាគំនរទុក រមែងដល់នូវការសង្គ្រោះចូលដោយពីជគាមដូចគ្នា ។ ជនទាំងឡាយដោតចូលក្នុងផែនដី ដើម្បីប្រយោជន៍ជាមណ្ឌបក្តី ដើម្បីប្រយោជន៍ជារបងក្តី ដើម្បីបំណងនឹងជាំវល្លិ៍ក្តី កាលឫស និងស្លឹកដុះចេញហើយ រមែងដល់នូវការរាប់ថា ជាភូតគាមទៀតដោយពិត សូម្បីយ៉ាងនោះ កាលដុះត្រឹមតែពកឫស ឬត្រឹមតែពកស្លឹក ក៏សង្គ្រោះចូល ក្នុងពីជគាមប៉ុណ្ណោះ ។

គ្រាប់ប្រភេទណានីមួយ ដែលជនទាំងឡាយកប់ក្នុងផែនដី យកទឹកស្រោចក្តី ជនទាំងឡាយដាក់ដីសើមចូលក្នុងផើងជាដើម បណ្តុះក្តី គ្រាប់ទាំងអស់នោះ កាលដុះត្រឹមតែពកឫស ឬត្រឹមពកស្លឹក ក៏ចាត់ជាពីជគាមប៉ុណ្ណោះ ។ បើឫសទាំងឡាយ និងពន្លកខាងលើដុះចេញ ក៏នៅចាត់ជាពីជ-គាមដដែល ដរាបណា ពន្លកមិនទាន់មានពណ៌ខៀវ កាលស្លឹកនៃសណ្តែកបាយជាដើមដុះឡើងក្តី កាលពន្លកនៃស្រូវជាដើមខៀវស្រស់ កើតក្នុងស្លឹកមានពណ៌ខៀវហើយ រមែងដល់នូវការសង្គ្រោះចូលជាភូតគាម ។

ឫសនៃគ្រាប់ត្នោតទាំងឡាយ ដុះចេញដំបូង ដូចខ្នាយជ្រូក កាលដុះចេញហើយ ក៏ចាត់ជាពីជគាមដូចគ្នា ដរាបណាស្រទាប់ស្លឹកខាងលើមិនទាន់លាចេញ ។ ពន្លកដុះទម្លុះសម្បកដូងចេញ ដូចឈើកន្ទុះ ចាត់ជាពីជគាមនោះឯង ដរាបដល់វេលាដែលស្រទបត្របកស្លឹកខៀវ ដូចស្នែងម្រឹគមិនទាន់មាន សូម្បីកាលឫសមិនទាន់ចេញ ស្រទាប់ស្លឹកដូច្នោះកើតឡើងហើយ ក៏ដល់នូវការសង្គ្រោះចូលក្នុងភូតគាម ដែលមិនមានឫស ។

ប្រភេទគ្រាប់ មានគ្រាប់ស្វាយជាដើម ព្រះវិនយធរ គប្បីកាត់ដូចប្រភេទគ្រាប់ស្រូវជាដើម បញ្ចើក្អែក ឬរុក្ខជាតិឯណាមួយក្តី ដែលកើតត្រង់ដើមឈើហើយ រុំព័ទ្ធដើមឈើ ដើមឈើនោះឯង ជាឋានរបស់បញ្ចើក្អែកជាដើមនោះ ។ ភិក្ខុធ្វើបញ្ចើក្អែកជាដើមនោះឲ្យវិនាសក្តី ដកឡើងអំពីដើមឈើនោះក្តី ត្រូវអាបត្តិបាចិត្តិយ ។

វល្លិ៍មួយប្រភេទមិនមានឫស រមែងព័ន្ធព័ទ្ធគុម្ពឈើ និងកំណាត់ឈើដូចវង់ចិញ្ចៀន ( វល្លិ៍មាស ) សូម្បីវល្លិ៍នោះ ក៏មានវិនិច្ឆ័យយ៉ាងនេះដូចគ្នា ត្រង់យ៉មុខនៃផ្ទះ កំពែង កញ្ចុះ និងចេតិយជាដើម មានស្លែទឹកពណ៌ខៀវ ជាបណាស្លែមិនទាន់ដុះស្លឹក ២-៣ សន្លឹក រមែងដល់នូវការសង្គ្រោះចូលជាពីជគាមដែលកើតអំពីត្រួយ ។ បើស្លឹកទាំងឡាយកើតហើយ ជាវត្ថុនៃបាចិត្តិយ ព្រោះហេតុនោះ បើឲ្យបូកកំបោរក្នុងឋានៈដូច្នោះ មិនគួរ ។ ឲ្យបូកកំបោរដែលល្អិតត្រង់ទីដែលអនុបសម្បន្នបូកហើយ គួរ ។ បើក្នុងរដូវក្តៅ ស្លែទឹកក្រៀមជាប់ បើយកអំបោសជាដើមបោសស្លែទឹកនោះចេញ គួរ ។ ស្លែទឹកខាងក្រៅថ្នាំងសម្រាប់ដាក់ទឹកផឹកជាដើម ជាវត្ថុនៃទុក្កដ បើស្លែនៅខាងក្នុង ជាអព្វោហារិក ។ សូម្បីផ្សិតដែលដុះត្រង់ឈើជម្រះធ្មេញ និងទំជាដើម ជាអព្វោហារិកដូចគ្នា ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា បើជញ្ជាំងដែលគេលាបដោយជ័រឈើ ដុះជាផ្សិត ភិក្ខុគប្បីជ្រលក់សំពត់ឲ្យសើមពូតហើយ ជូតចុះ ។

បាសាណជាតិ បាសាណទទ្ទុ សេវាល សេលេយ្យក ( ផ្សិតថ្ម ស្លែថ្ម

ចកថ្ម និងផ្កាថ្ម ) ជាដើម មិនទាន់មានពណ៌ខៀវ និងមិនទាន់មានស្លឹក ជាវត្ថុនៃទុក្កដ ។ ផ្សិត ជាវត្ថុនៃទុក្កដ ដរាបណានៅក្រពុំ ។ តែកាលរីកហើយ ជាអព្វោហារិក ។ ភិក្ខុបេះផ្សិតអំពីដើមឈើស្រស់ កេះយកសម្បកដើមឈើចេញ ព្រោះហេតុនោះ ទើបត្រូវអាបត្តិបាចិត្តិយ ព្រោះការធ្វើឲ្យរបកសម្បកឈើនោះ សូម្បីក្នុងក្រម៉ឈើ ក៏មានន័យយ៉ាងនេះដូចគ្នា ។ ក្រម៉នៃដើមរាជ-ព្រឹក្ស និងដើមថ្វាន់ជាដើម ដែលរបូតហើយ តែនៅតោងជាប់ កាលភិក្ខុកាន់យកក្រម៉នោះ មិនត្រូវអាបត្តិ ។ សូម្បីជ័រឈើហូរចេញអំពីដើមឈើ ហើយជាប់តាមដើមក្តី ជាប់នៅត្រង់ដើមឈើស្ងួតក្តី បើភិក្ខុកាន់យក គួរ ។ បើកាន់យកអំពីដើមឈើដែលស្រស់ មិនគួរ ។ សូម្បីក្នុងអាចម៍ល័ខ ក៏មានន័យយ៉ាងនេះដូចគ្នា ។ កាលភិក្ខុអង្រួនដើមឈើ ឲ្យស្លឹកទុំជ្រុះក្តី ធ្វើឲ្យផ្កា មានផ្កាកណិការជាដើមជ្រុះក្តី ត្រូវអាបត្តិបាចិត្តិយទាំងអស់ ។ ភិក្ខុចារឹកតួអក្សរលើដើមឈើ មានដើមរាជព្រឹក្ស និងដើមប្រលាត់ដៃជាដើម ត្រង់ទីដែលទន់ក្តី ត្រង់ស្លឹកត្នោតដែលជាប់នៅលើដើមត្នោតជាដើមនោះក្តី ដោយការពិសដៃ ក៏មានន័យនេះឯង ។

កាលពួកសាមណេរកំពុងជ្រើសរើសផ្កាដើម្បីបេះ ភិក្ខុទាញមែកចុះឲ្យក៏គួរ តែភិក្ខុកុំគប្បីអប់ទឹកផឹកដោយផ្កាឈើទាំងនោះ ។ បើភិក្ខុត្រូវការអប់ក្លិនក្នុងទឹក គប្បីលើកសាមណេរឡើង ហើយឲ្យបេះផ្កាឲ្យ ។ សូម្បីមែកឈើដែលមានផ្លែ ខ្លួនឯងត្រូវការទំពាធាន់ កុំគប្បីទាញចុះមក គប្បីលើកសាមណេរឡើង ហើយឲ្យបេះផ្លែឈើ ។ បើចាប់ទាញមកជាមួយសាមណេរទាំងឡាយ

ដែលកំពុងដកដើមឈើ ឬវល្លិឯណាមួយ មិនគួរ តែដើម្បីឲ្យកើតការខស្សាហ៍ដល់សាមណេរទាំងនោះ ទោះចាប់ត្រង់ចុងសម្តែងអាកប្បកិរិយា ធ្វើដូចជាទាញ គួរ ។

ភិក្ខុចូតមែកឈើ ដែលមានមែកដុះឡើង ដែលខ្លួនមិនបានឲ្យអនុបសម្បន្នធ្វើឲ្យជាកប្បិយ កាន់យកដើម្បីប្រយោជន៍ដល់ការបក់រុយជាដើម ត្រង់សម្បក ឬត្រង់ស្លឹក ដោយហោចសូម្បីក្រចកដៃ ត្រូវអាបត្តិទុក្កដ ។ សូម្បីក្នុងខ្ទឹមស្រស់ជាដើម ក៏មានន័យនេះឯង ។ បើឫសនៃខ្ទឹមស្រស់ ដែលភិក្ខុឲ្យគេកប្បិយហើយ ទុកដាក់ក្នុងដីដែលត្រជាក់ ខ្ទឹមដុះឡើង នឹងកាត់ចំណែកខាងលើ គួរ ។ បើដុះពន្លក កាត់ចំណែកខាងក្រោមក៏គួរ ។ បើឫស និងពន្លកពណ៌ខៀវកើតហើយ កាត់ មិនគួរ ។

ពីរបទថា **ឆិន្ទតិ វា ឆេទាបេតិ វា** សេចក្តីថា ភិក្ខុកាលបោសផែនដីដោយគិតថា អញនឹងកាត់ស្មៅឯងក្តី ប្រើអ្នកដទៃឲ្យកាត់ក្តី ដោយហោចសូម្បីសរសៃអំបោស ។

ពីរបទថា **ភិន្ទតិ វា ភេទាបេតិ វា** សេចក្តីថា ដោយហោចសូម្បីដើរចង្ក្រម ក្លែងយកជើងទាំង ២ ជាន់ទៅ ដោយគិតថា របស់ណាដាច់ក៏ចូរដាច់ទៅ របស់ណាបែកក៏ចូរបែកទៅ អញនឹងបង្ហាញទីដែលអញចង្ក្រម ដូច្នេះ រមែងទម្លាយឯងក្តី ឲ្យអ្នកដទៃទម្លាយក្តី នូវស្មៅ និងវល្លិជាដើម ។ បើភិក្ខុធ្វើស្មៅ និងវល្លិឲ្យជាកំណួច ស្មៅ និងវល្លិដាច់ សូម្បីធ្វើឲ្យជាកំណួចនោះក៏មិនគួរ ។

ជនទាំងឡាយរមែងបោះឈើពីងពាង ( ទីងមោងយន្តពីងពាង ) ចង បន្ទាត្រង់ដើមត្នោតជាដើម ដើម្បីមិនឲ្យពួកចោរឡើងលួច ការធ្វើយ៉ាងនោះ មិនគួរដល់ភិក្ខុ ។ បើទីងមោងយន្តពីងពាង ត្រឹមតែបិទភ្ជាប់ត្រង់ដើមឈើ ប៉ុណ្ណោះ មិនរួតរឹតដើមឈើ គួរ សូម្បីនឹងពោលថា អ្នកចូរកាត់ដើមឈើ ចូរកាត់វល្លិ៍ ចូរដកមើម ចូរដកឫស ដូច្នេះក៏គួរ ព្រោះជាពាក្យពោលមិន កំណត់ពិតប្រាកដ ។ តែបើកំណត់ដោយពាក្យជាដើមថា ចូរកាប់ដើមឈើនេះ មិនគួរ ។ សូម្បីការប្រារព្ធឈ្មោះ ដោយពោលពាក្យជាដើមថា ចូរកាប់ ចូរ វាយ ចូរដកដើមស្វាយ វល្លិ៍៤ ជ្រុង មើមត្រាវ ដំឡូង ស្មៅដំណេកទន្សាយ ក្រម៉ដើមឈើនោះ ដូច្នេះ ក៏ជាពាក្យមិនកំណត់ពិតប្រាកដដូចគ្នា ។ ពិតហើយ ពាក្យជាដើមថា ដើមស្វាយនេះប៉ុណ្ណោះ ឈ្មោះថា ជាពាក្យកំណត់ពិតប្រាកដ ពាក្យនោះ មិនគួរ ។

ពីរបទថា **បចតិ វា បចាបេតិ វា** សេចក្តីថា បណ្ឌិតគប្បីជ្រាបពាក្យ ទាំងពួងដោយន័យដូចពោលហើយ ក្នុងបរិវណ្ណនាសិក្ខាបទនោះឯងថា ដោយ ហោចសូម្បីបំណងនឹងអប់បាត្រ ក្នុងបន្ដាត់ភ្លើងខាងលើគំនរស្មៅជាដើម ដុត ឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី ដូច្នេះ ។ តែបើពោលមិនកំណត់ពិតប្រាកដថា ចូរស្ងោរសណ្តែកបាយ ចូរស្ងោរសណ្តែករាជមាសជាដើម គួរ ។ បើពោល យ៉ាងនេះថា ចូរស្ងោរសណ្តែកបាយទាំងនេះ ចូរស្ងោរសណ្តែករាជមាសទាំង នេះ មិនគួរ ។

# អនាបត្តិនៃភូតគាមសិក្ខាបទ

[ ៣៥៧ ] ក្នុងបទថា **អនាបត្តិ ឥមំ ជាន** ជាដើម បណ្ឌិតគប្បីឃើញអត្ថយ៉ាងនេះថា អ្នកចូរដឹងមូលកេសជ្ជៈនេះ ចូរឲ្យឫសឈើក្តី ស្លឹកឈើនេះក្តី ចូរនាំដើមឈើ ឬវល្លិ៍នេះមកក្តី អាត្មាត្រូវការផ្កាក្តី ផ្លែក្តី ស្លឹកឈើនេះក្តី ចូរធ្វើដើមឈើក្តី វល្លិ៍ក្តី ផ្លែឈើនេះក្តី ឲ្យជាកប្បិយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ភិក្ខុធ្វើការដោះភូតគាម ។ តែភិក្ខុកាលបរិភោគគប្បីឲ្យអនុបសម្បន្នកប្បិយម្តងទៀត ដើម្បីដោះពាក្យថា ពីជគាម ។

ការធ្វើកប្បិយក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបដោយក្រសែនៃសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុឆាន់ផ្លែឈើដោយសមណកប្ប ៥ យ៉ាង គឺផ្លែដែលគេអុជ ឬកម្តៅដោយភ្លើង ១ ដែលគេចោះពុះចិតដោយសស្ត្រា ១ ដែលគេចុចដោយក្រចក ១ ដែលគ្មានពូជដុះតទៅ ១ មានពូជដែរ តែគួរបន្ទិចគ្រាប់ចេញបាន ១ ជាគម្រប់ ៥ ។

បណ្តាបទទាំងនោះ បទថា **អគ្គិបរិចិតំ** មានអត្ថថា ពោល គឺស្រុះដុត អាំងហើយដោយភ្លើង ។

បទថា **សត្ថបរិចិតំ** មានអត្ថថា ចុច គឺពុះ កាត់ ឬចាក់ហើយដោយកាំបិតតូចៗ ។ ក្នុងពាក្យថា ចុចដោយក្រចក ក៏មានន័យនេះឯង ។ ផ្លែឈើដែលមិនមានគ្រាប់ និងផ្លែដែលបន្ទិចគ្រាប់ចេញហើយ ជាកប្បិយដោយខ្លួនឯងស្រេចស្រាប់ ។

ភិក្ខុកាលធ្វើកប្បិយដោយភ្លើង គប្បីធ្វើដោយបណ្តាភ្លើងឧស និងភ្លើងអាចម៍គោណាមួយ ដោយហោចសូម្បីបន្ទះលោហៈដែលក្តៅ ឯវត្ថុនោះចាប់

ទុកម្ខាង គប្បីពោលថា **កប្បិយំ** ( ភិក្ខុប្រើដោយពាក្យថា **កប្បិយំ ករោហិ** អនុបសម្បន្នយកដៃចាប់របស់ដែលត្រូវកប្បិយនោះ ដៃមួយចាប់វត្ថុ មានកាំបិតជាដើមហើយ កាត់ ពុះ ឬចោះ ត្រង់របស់នោះ ព្រមដោយវាចាថា **កប្បិយំ ភន្តេ** ជាការស្រេច ) ហើយធ្វើចុះ ។

កាលធ្វើដោយកាំបិត សម្តែងស្នាមកាត់ ស្នាមពុះដោយចុង ឬដោយមុខនៃកាំបិតដែលធ្វើដោយលោហៈឯណាមួយ ដោយហោចសូម្បីដោយម្ជុល និងកាំបិតកាត់ក្រចកជាដើម ។ គប្បីពោលថា **កប្បិយំ** ហើយធ្វើចុះ ។

បើធ្វើកប្បិយដោយក្រចក កុំគប្បីធ្វើដោយក្រចកស្អុយ ។ ឯក្រចកនៃពួកមនុស្ស សត្វជើង ៤ មានសីហៈ ខ្លាធំ ខ្លាដំបង និងស្វាជាដើម និងក្រចកបក្សីទាំងឡាយ ដែលជារបស់ស្រួចមុត គប្បីធ្វើដោយក្រចកទាំងនោះ ក្រចកនៃសត្វ មានសេះ ក្របី ជ្រូក ម្រឹគ និងគោជាដើម មិនមុតឡើយ កុំគប្បីធ្វើដោយក្រចកទាំងនោះ ។ ទោះបីធ្វើក៏មិនឈ្មោះថា ធ្វើ ។ ឯក្រចកដំរី មិនជាក្រចកដូចម្រឹគឡើយ ។ បើធ្វើកប្បិយដោយក្រចកដំរីទាំងនោះ គួរ ។ តែការធ្វើកប្បិយដោយក្រចកទាំងឡាយណា គួរ គប្បីសម្តែងការកាត់ ការចុចដោយក្រចកទាំងនោះ ដែលកើតនៅក្នុងទីនោះក្តី ដែលលើកឡើងកាន់ក្តី ពោលថា **កប្បិយំ** ហើយធ្វើចុះ ។

បណ្តាពូជជាដើមទាំងនោះ សូម្បីពូជគរជាគំនរប៉ុនភ្នំក្តី ដើមឈើរាប់ពាន់ដែលគេកាត់ហើយ ធ្វើឲ្យជាគំនរតែមួយក្តី អំពៅមួយបាច់ធំ ដែលគេចងរួមគ្នាក្តី កាលធ្វើពីជគាមមួយគ្រាប់ មែកឈើមួយមែក ឬអំពៅមួយដើមឲ្យ

ជាកប្បិយហើយ ឈ្មោះថា ធ្វើឲ្យជាកប្បិយហើយទាំងអស់ ។ អំពៅដើម និងឧស ជារបស់ដែលគេចងរួមគ្នា ។ អនុបសម្បន្ន ទោះចោះឧសដោយ តាំងចិត្តថា អញនឹងធ្វើអំពៅឲ្យជាកប្បិយ ដូច្នេះ ក៏គួរដូចគ្នា ។ តែបើរបស់ ដែលគេចងបាច់ដោយខ្សែ ឬដោយវល្លិណា បើចាក់ខ្សែ ឬវល្លិនោះ មិនគួរ ។ ជនទាំងឡាយដាក់ល្អីឲ្យពេញដោយកំណាត់អំពៅ ហើយនាំមក កាលធ្វើអំពៅ មួយកំណាត់ឲ្យជាកប្បិយហើយ កំណាត់អំពៅទាំងអស់ ឈ្មោះថា ធ្វើឲ្យ កប្បិយហើយដូចគ្នា ។

បើពួកទាយកនាំភត្ត ដែលលាយដោយម្ទេសទុំជាដើមមក ភិក្ខុពោលថា ចូរធ្វើឲ្យគួរ បើអនុបសម្បន្នចាក់ត្រង់គ្រាប់បាយ ក៏គួរដូចគ្នា ។ ទោះក្នុង គ្រាប់ល្ង និងអង្ករជាដើម ក៏ន័យនេះដូចគ្នា ។ តែម្ទេសទុំជាដើមនោះ ដែល គេដាក់ក្នុងបបរ មិនតាំងនៅជាប់ជាមួយគ្នាឡើយ ។ បណ្តាម្ទេសទុំជាដើមនោះ គប្បីកប្បិយ គឺចាក់ត្រង់ផ្លែនោះឯង ។ សរសៃក្នុងផ្លែខ្វិតជាដើម ខាងក្នុងរបេះ ដាច់សម្បក ហើយរលុង ( នៅខាងក្នុង ) ភិក្ខុគប្បីឲ្យដំបំបែកហើយ សឹម ធ្វើកប្បិយ ។ បើនៅជាប់ជាមួយគ្នា ( ជាមួយសម្បក ) ទោះធ្វើកប្បិយ ទាំងសម្បក ( លលាដ៏ ) ក៏គួរ ។

បទថា **អសញ្ចិច្ច** សេចក្តីថា កាលភិក្ខុប្រមៀលថ្ម និងដើមឈើជា ដើមក្តី អូសមែកឈើក្តី យកឈើច្រត់ៗ ផែនដីដើរទៅក្តី ស្មៅជាដើមដាច់ ទៅ ស្មៅទាំងនោះ ឈ្មោះថា ត្រូវភិក្ខុមិនបានគិតធ្វើឲ្យដាច់ ព្រោះមិនបាន ផ្តោតចិត្តកាត់យ៉ាងនេះថា អញនឹងកាត់ស្មៅ ដោយការប្រមៀលជាដើមនោះ

អាបត្តិមិនមានដល់ភិក្ខុ ដែលមិនក្លែងផ្តាច់យ៉ាងនេះ ។

បទថា **អសតិយា** សេចក្តីថា បញ្ជូនចិត្តទៅកាន់ទីដទៃ ឈរនិយាយអ្វីមួយ ជាមួយបុគ្គលណាម្នាក់ យកចុងឈើប្រត់ ឬដៃក្តិចស្មៅ ឬវល្លិក្តី មិនត្រូវអាបត្តិដល់ភិក្ខុ ដែលកាត់ព្រោះមិនមានសតិយ៉ាងនេះ ។

បទថា **អជានន្តស្ស** សេចក្តីថា ភិក្ខុមិនដឹងថា ពីជគាមក្តី ភូតគាមក្តី មាននៅខាងក្នុងនេះ ទាំងមិនដឹងថា ខ្លួនកំពុងកាត់ ជាក់ពន្លាក ចបជីក និងចបត្រង់របង ឬត្រង់ពំនូកចំបើង ដើម្បីទុកដាក់តែម្យ៉ាង ឬកាលត្រូវភ្លើងឆេះដៃ បោះភ្លើងចោលក្តី បើក្នុងទីនោះ ស្មៅជាដើមដាច់ក្តី ត្រូវភ្លើងឆេះក្តី ជាអនាបត្តិ ។

តែក្នុងគម្ពីរ អដ្ឋកថា ក្នុងមនុស្សវិគ្គហបារាជិកវណ្ណនា លោកពោលទុកថា បើភិក្ខុត្រូវដើមឈើរលំសង្កត់ក្តី ធ្លាក់ចុះក្នុងរណ្តៅក្តី ហើយអាចដើម្បីនឹងកាត់ដើមឈើ ហើយប្រមៀលដើមឈើនោះចេញ ឬជីកផែនដី ហើយចេញមក ភិក្ខុមិនគួរធ្វើដោយខ្លួនឯងឡើយ សូម្បីព្រោះហេតុនៃជីវិត បើភិក្ខុដទៃជីកផែនដីក្តី កាត់ដើមឈើក្តី កាត់កំណាត់ឈើអំពីឈើស្រស់ គាស់ដើមឈើនោះទៅ ហើយឲ្យភិក្ខុនោះចេញមក គួរ ជាអនាបត្តិ ។ ហេតុក្នុងពាក្យនោះមិនប្រាកដ តែប្រាកដត្រឹមតែសូត្រមួយនេះប៉ុណ្ណោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដុតភ្លើងកាត់ ឲ្យធ្វើការការពារ ក្នុងកាលភ្លើងព្រៃកំពុងឆេះមក ដូច្នេះ ។ បើ ( ការជីកដីជាដើម ) អនុលោមចូលសូត្រនេះបាន ក៏មិនអាចបានហេតុផ្សេងគ្នាយ៉ាងនេះថា ដើម្បីខ្លួនឯង មិនគួរ ដើម្បីអ្នក

ដទៃ គួរ ។

បើក្នុងសូត្រនេះ អាចារ្យអ្នកចោទគប្បីពោលថា ភិក្ខុដែលធ្វើដើម្បីប្រយោជន៍ខ្លួនឯង រមែងធ្វើដោយអកុសលចិត្ត ព្រោះស្រឡាញ់ខ្លួនប៉ុណ្ណោះ តែភិក្ខុដទៃធ្វើឲ្យ ដោយសេចក្ដីករុណា ព្រោះហេតុនោះ ទើបជាអនាបត្តិ ។ សូម្បីពាក្យដែលពោលដើម្បីប្រយោជន៍ដល់ខ្លួននោះ ក៏មិនជាហេតុ ។ ពិតហើយ ភិក្ខុរមែងត្រូវអាបត្តិនេះ សូម្បីដោយកុសលចិត្ត តែព្រោះពាក្យនេះលោកពោលទុកក្នុងអដ្ឋកថាគ្រប់អន្លើ ទើបមិនអាចជំទាស់បាន ទើបបណ្ឌិតគួរស្វែងរកភាពត្រឹមត្រូវក្នុងពាក្យនេះ ម្យ៉ាងទៀត គប្បីទទួលទុកដោយជឿតាមអដ្ឋកថាចារ្យទាំងឡាយចុះ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះ ។

ភូតគាមសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[ ៣៥៨ ] សម័យនោះ ព្រះដ៏ទ្រង់យស កាលគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ឆន្នភិក្ខុដ៏មានអាយុ ប្រព្រឹត្តអនាចារ ដោយខ្លួនឯង កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោល បិទបាំងនូវពាក្យដទៃដោយពាក្យដទៃ ( គឺពោលបន្ទែបន្ទប់ ) ទៅវិញដោយ ពាក្យថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិ ដោយប្រការដូចម្តេច លោកទាំងឡាយពោលចំពោះបុគ្គលណា លោកទាំង-ឡាយពោលថាអ្វី ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុ ទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុ សាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនសមបើនឹងពោល បិទបាំងនូវពាក្យដទៃ ដោយពាក្យដទៃថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោល ចំពោះបុគ្គលណា លោកទាំងឡាយពោលថាអ្វី ។ គ្រានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់សួរបញ្ជាក់ទៅនឹងឆន្នភិក្ខុដ៏មានអាយុថា ម្នាលឆន្ន បានឮថា អ្នកឯងកាល ដែលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ហើយពោលបិទបាំង នូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ ។បេ។ លោកទាំង-ឡាយពោលថាដូចម្តេច ពាក្យនេះពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូម ទ្រង់ព្រះមេត្តាប្រោស ពាក្យនេះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ

ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនគួរបើនឹងពោលបិទបាំងនូវពាក្យដទៃ ដោយពាក្យដទៃថា នរណាត្រូវអាបត្តិ ។បេ។ លោកទាំងឡាយពោលដូចម្តេច នែមោឃបុរស អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំមនុស្សទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យបានជ្រះថ្លាឡើងក៏ទេ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសរួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរលើកនូវអញ្ញវាទកកម្ម[១] ដល់ឆន្នភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្ម យ៉ាងនេះ ភិក្ខុដែលឈ្លាសអង់អាចត្រូវប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ ( ដ្បិត ) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃ ដោយពាក្យដទៃវិញ ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ ។ នេះជាវាចាសម្រាប់ផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ ( ដ្បិត ) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃ ដោយពាក្យដទៃវិញ ។ ឥឡូវនេះ ព្រះសង្ឃលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ ។ ការលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុសមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគួរស្ងៀម ( បើ ) មិនសមគួរដល់លោកម្ចាស់អង្គណាទេ លោកម្ចាស់អង្គនោះត្រូវពោលឡើង ។ អញ្ញវាទកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុហើយ ។

---

១- អំពើដែលសង្ឃត្រូវធ្វើដល់ភិក្ខុអ្នកពោលពាក្យដទៃ គឺពោលពាក្យបន្ទែបន្ទប់ ។

អញ្ញវាទកកម្មសមគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាព្រះសង្ឃស្មៀមនៅ ។ ខ្ញុំចាំទុកនូវរឿងនេះដោយកិរិយាស្មៀមនៅយ៉ាងនេះ ។

[ ៣៥៩ ] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តដល់ភិក្ខុទាំងឡាយ យ៉ាងនេះហើយ ។

[ ៣៦០ ] សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុកំពុងសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គិតថា អាត្មាអញ កាលពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ មុខជានឹងត្រូវអាបត្តិ ( មិនខានឡើយ ) ហើយក៏ស្មៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃមិនសមបើនឹងស្មៀមនៅមិនស្តី នាំឲ្យសង្ឃលំបាកសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរឆន្នភិក្ខុដ៏មានអាយុថា នែឆន្ន បានឮថា អ្នកឯង កាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយស្មៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់

បន្ទោសថា នែមោឃបុរស អ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាកទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេដែរ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសរួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរលើកនូវវិហេសកកម្ម[១] ដល់ឆន្នភិក្ខុចុះ ។ ម្នាលភិក្ខុទាំង-ឡាយ សង្ឃត្រូវលើកនូវវិហេសកកម្មយ៉ាងនេះ គឺ ភិក្ខុដែលវាងវៃអង់អាចគួរផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ ដ្បិតឆន្នភិក្ខុនេះ កាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ ( ដ្បិត ) ឆន្នភិក្ខុនេះ កាលដែលសង្ឃសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ ឥឡូវសង្ឃលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ ។ ការដែលលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀមនៅ ( បើ ) មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវពោលឡើង ។ វិហេសកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុរួចហើយ ។

---

១- អំពើដែលសង្ឃត្រូវធ្វើដល់ភិក្ខុអ្នកនាំសង្ឃ ឲ្យបានសេចក្តីលំបាក ។

ការ ដែលលើកនូវវិហេសកកម្មសមគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅមិនស្តី ។ ខ្ញុំចាំទុកនូវរឿងនេះ ដោយការៈស្ងៀមនៅយ៉ាងនេះ ។

[ ៣៦១ ] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយព្រោះពោលនូវពាក្យដទៃ ( ឬ ) ព្រោះធ្វើសង្ឃឲ្យបានសេចក្តីលំបាក ។

[ ៣៦២ ] ដែលហៅថា ពោលនូវពាក្យដទៃ ( នោះ ) គឺភិក្ខុ ( ណាមួយ ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបឡើងនូវវត្ថុ និងអាបត្តិនោះ ត្រឡប់ជាបិទបាំងនូវពាក្យដទៃ ដោយពាក្យដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំងឡាយពោលដូចម្តេច ភិក្ខុនេះឈ្មោះថា ពោលនូវពាក្យដទៃ ។

[ ៣៦៣ ] ដែលហៅថា ធ្វើឲ្យសង្ឃបានសេចក្តីលំបាក ( នោះ ) គឺភិក្ខុ ( ណាមួយ ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបនូវវត្ថុ និងអាបត្តិនោះ ហើយស្ងៀមមិនស្តី នាំឲ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនេះឈ្មោះថា ធ្វើឲ្យសង្ឃបានសេចក្តីលំបាក ។

[ ៣៦៤ ] កាលបើអញ្ញវាទកកម្មសង្ឃមិនបានលើកឡើងទេ ភិក្ខុ ( ណា

មួយ ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបឡើងនូវវត្ថុ និងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំង-ឡាយពោលដូចម្តេច ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ កាលបើវិហេសកកម្មដែលសង្ឃមិនបានលើកឡើងទេ ភិក្ខុណាដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តីចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបឡើងនូវវត្ថុ និងអាបត្តិនោះ ស្ងៀមមិនស្តីនាំឲ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[ ៣៦៥ ] កាលបើអញ្ញវាទកកម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ ( ណាមួយ ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបើកឡើងនូវវត្ថុ និងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ ។បេ។ លោកទាំងឡាយពោលដូចម្តេច ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ កាលបើវិហេសកកម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ ( ណាមួយ ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តីចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបនូវវត្ថុ និងអាបត្តិនោះ ស្ងៀមមិនស្តី នាំឲ្យសង្ឃបាន

សេចក្តីលំបាក ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[ ៣៦៦ ] កម្មប្រកបដោយធម៌ ភិក្ខុសម្គាល់ថា កម្មប្រកបដោយធម៌ តែពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ ហើយពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសម្គាល់ថា កម្មមិនប្រកបដោយធម៌វិញ ហើយពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសម្គាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសម្គាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[ ៣៦៧ ] អាបត្តិមិនត្រូវដល់ភិក្ខុដែលមិនដឹងសេចក្តី ហើយសួរ ដល់ភិក្ខុដែលមានជំងឺ ហើយមិននិយាយ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ការបន្តហេតុប្រកួតប្រកាន់ ជម្លោះវិវាទនឹងនាំឲ្យវល់ដល់សង្ឃ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ក្រែងសង្ឃបែកគ្នា ( ឬ ) ក្រែងសង្ឃប្រាំងប្រាត់នឹងគ្នា ដល់ភិក្ខុដែលមិននិយាយដោយគិតថា សង្ឃមុខជានឹងធ្វើកម្មមិនត្រូវតាមធម៌ផង ជាពួកផង ចំពោះភិក្ខុដែលមិនគួរដល់កម្មផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា

## ភូតគាមវគ្គ

## អញ្ញវាទសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ

[ ៣៥៨ ] ពីរបទថា **អនាចារំ អាចរិត្វា** គឺធ្វើវត្ថុដែលមិនគួរធ្វើ មានពាក្យអធិប្បាយថា ត្រូវអាបត្តិក្នុងកាយទ្វារ និងវចីទ្វារ ។

ពីរបទថា **អញ្ញេនញ្ញំ បដិចរតិ** បានដល់ រមែងបិទបាំង គឺបិទ គឺបន្ទប់សង្កត់ពន្លិចពាក្យដទៃដោយពាក្យដទៃ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងវិធីបិទបាំងនោះ ទើបត្រាស់បទថា **កោ អាបន្នោ** ជាដើម ។ ក្នុងពាក្យនោះ មានវចនសម្ពន្ធ ដូចតទៅនេះថា បានឮថា ឆន្នភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយឃើញការប្រព្រឹត្តល្មើសឯណានីមួយហើយ សាកសួរដោយអាបត្តិក្នុងចំណោមសង្ឃថា នែអាវុសោ លោកជាអ្នកត្រូវអាបត្តិមែនឬ ក៏ពោលថា នរណាត្រូវ ដូច្នេះ ។

លំដាប់នោះ កាលភិក្ខុទាំងឡាយពោលថា គឺលោកហ្នឹងឯង ទើបពោលថា ខ្ញុំត្រូវអាបត្តិអ្វី ខណៈនោះ កាលភិក្ខុទាំងឡាយពោលថា គឺអាបត្តិបាចិត្តិយ ឬទុក្កដ កាលនឹងសួរវត្ថុ ទើបពោលថា ខ្ញុំត្រូវអាបត្តិព្រោះវត្ថុដូចម្តេច លំដាប់នោះ កាលពួកភិក្ខុពោលថា ព្រោះវត្ថុឈ្មោះនោះ ទើបសួរថា ខ្ញុំត្រូវដូចម្តេច ហើយខ្ញុំធ្វើអ្វី ទើបត្រូវ ដូច្នេះ។ គ្រានោះ កាលពួកភិក្ខុពោលថា ធ្វើការប្រព្រឹត្តល្មើសឈ្មោះនេះ ទើបត្រូវ ក៏ពោលថា ពួកលោកនិយាយ

ជាមួយនរណា ដូច្នេះ ពេលនោះ កាលពួកភិក្ខុពោលថា ពួកខ្ញុំនិយាយហ្នឹងលោក ទើបពោលថា ពួកលោកនិយាយរឿងអ្វី ។

ម្យ៉ាងទៀត ក្នុងបទថា **កោ អាបន្នោ** នេះ មានវិធីបិទបាំងពាក្យដទៃដោយពាក្យដទៃ ក្រៅព្រះបាលីដូចតទៅនេះថា ភិក្ខុត្រូវពួកភិក្ខុពោលថា ពួកខ្ញុំឃើញកហាបណៈ ( ប្រាក់ ) ក្នុងថង់របស់លោកៗ ធ្វើកម្មមិនសមគួរយ៉ាងនេះដើម្បីអ្វី ហើយពោលថា ដែលពួកលោកឃើញត្រឹមត្រូវហើយ តែនោះមិនមែនកហាបណៈ វាជាដុំសំណ ដូច្នេះក្តី ត្រូវពួកភិក្ខុពោលថា ពួកខ្ញុំឃើញលោកផឹកស្រា លោកធ្វើកម្មមិនសមគួរយ៉ាងនេះ ដើម្បីអ្វី ហើយពោលថា ដែលពួកលោកឃើញត្រឹមត្រូវហើយ តែនោះមិនមែនសុរា ជាតំណក់ថ្នាំ ឈ្មោះអរិដ្ឋ គេធ្វើឡើងដើម្បីជាថ្នាំដូច្នេះក្តី ពួកភិក្ខុពោលថា ពួកខ្ញុំឃើញលោកអង្គុយក្នុងអាសនៈកំបាំងជាមួយមាតុគ្រាម លោកធ្វើកម្មមិនសមគួរយ៉ាងនេះ ដើម្បីអ្វី ហើយពោលថា ដែលលោកឃើញ រាប់ថា ត្រឹមត្រូវហើយ តែក្នុងទីនោះ មានបុរសដឹងក្តីនៅជាមួយ ព្រោះហេតុអ្វី ទើបលោកមិនឃើញបុរសនោះ ដូច្នេះក្តី ត្រូវពួកភិក្ខុសួរថា លោកឃើញការល្មើសដូច្នេះខ្លះឬទេ ផ្អៀងត្រចៀកទៅ ពោលថា មិនបានឮក្តី ដាក់ភ្នែកចូលទៅរកពួកភិក្ខុដែលខ្សឹបសួរក្នុងទីជិតត្រចៀកក្តី បណ្ឌិតគប្បីជ្រាបថា ជាការពោលបិទបាំងដោយពាក្យសម្តី ។

ពីរបទថា **អញ្ញវាទកំ រោបេតុ** សេចក្តីថា សង្ឃប្រូវលើកអញ្ញវាទកកម្មឡើង គឺចូរឲ្យតាំងឡើង ។ សូម្បីក្នុងបទថា **វិហេសកំ រោបេតុ** នេះ ក៏

ន័យដូចគ្នា ។

[៣៦១] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អញ្ញវាទកេ វិហេសកេ បាចិត្តិយំ** នេះ តទៅថា ពាក្យណារមែងពោលសេចក្តីដទៃក្រៅអំពីសំណួរ ព្រោះដូច្នោះ ពាក្យនោះឈ្មោះថា **អញ្ញវាទក** ។ បទថា **អញ្ញវាទក** នេះ ជាឈ្មោះនៃការបិទបាំងពាក្យសម្តី ( បិទបាំងហេតុដទៃដោយហេតុដទៃ ) ។

ភាពជាអ្នកស្ងៀមណា រមែងធ្វើសង្ឃឲ្យលំបាក ព្រោះដូច្នោះ ភាពជាអ្នកស្ងៀមនោះ ឈ្មោះថា **វិហេសក** ។ បទថា **វិហេសក** នេះ ជាឈ្មោះនៃភាពជាបុគ្គលស្ងៀម ព្រោះភាពជាអ្នកពោលពាក្យដទៃ ព្រោះភាពជាបុគ្គលឲ្យលំបាកនោះ ។

ដោយបទថា **បាចិត្តិយំ** នេះ ព្រះមានព្រះភាគដាក់អាបត្តិបាចិត្តិយ ២ ក្នុងវត្ថុ ២ ។

## អធិប្បាយ
## បទភាជនីយនៃអញ្ញវាទកសិក្ខាបទ

[ ៣៦៤ ] ពីរបទថា **អរោបិតេ អញ្ញវាទកេ** បានដល់ ព្រោះភាពជាបុគ្គលពោលពាក្យដទៃដែលសង្ឃមិនបានលើកឡើងដោយកម្មវាចា ។ សូម្បីក្នុងបទថា **អរោបិតេ វិហេសកេ** នេះ ក៏មានន័យនេះដូចគ្នា ។

[ ៣៦៦ ] ក្នុងបទថា **ធម្មកម្មេ ធម្មកម្មសញ្ញី** ជាដើម គប្បីជ្រាបអត្ថដោយន័យនេះថា អញ្ញវាទកវិហេសករោបនកម្មនោះ ដែលសង្ឃធ្វើហើយ បើកម្មនោះជាកម្មប្រកបដោយធម៌ ហើយភិក្ខុនោះមានសេចក្តីសម្គាល់ក្នុងកម្ម

នោះថា ជាកម្មប្រកបដោយធម៌ នៅធ្វើភាពជាអ្នកពោលពាក្យដទៃ និងភាព ជាអ្នកធ្វើឲ្យលំបាក កាលនោះភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះជាអ្នក ពោលពាក្យដទៃ និងព្រោះជាអ្នកឲ្យលំបាកនោះ ។

## អនាបត្តិនៃអញ្ញវាទកសិក្ខាបទ

[ ៣៦៧ ] ពីរបទថា **អជានន្តោ បុច្ឆតិ** សេចក្ដីថា ភិក្ខុកាលមិនដឹងថា ខ្លួនត្រូវអាបត្តិ ទើបពោលថា លោកទាំងឡាយនិយាយអ្វី ខ្ញុំមិនដឹងឡើយ ។

ពីរបទថា **គិលានោ ន កថេតិ** សេចក្ដីថា ភិក្ខុមានព្យាធិត្រង់មាត់ ដូចជាព្យាធិដែលជាហេតុឲ្យមិនអាចនឹងនិយាយបាន ។

ក្នុងបទថា **សង្ឃស្ស ភណ្ឌនំ វា** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថ ដោយ ន័យនេះថា ភិក្ខុមានសេចក្ដីសម្គាល់ថា កាលអញពោលក្នុងជំនុំសង្ឃ ការវិវាទ ការឈ្លោះទាស់ទែង ការប្រកួតប្រកាន់ ឬការវិវាទនឹងមានដល់សង្ឃ ព្រោះការពោលនោះជាបច្ច័យ ការវិវាទនោះ សូមកុំមានឡើយ ទើបមិន និយាយ បទដ៏សេសងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាម វាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយាក៏មាន ជាអកិរិយាក៏ មាន ពិតហើយ កាលភិក្ខុបិទបាំងពាក្យសម្ដី ជាកិរិយា កាលធ្វើឲ្យលំបាក ព្រោះភាពជាអ្នកនៅស្ងៀម ជាអកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជា លោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

អញ្ញវាទសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[ ៣៦៨ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ តែងក្រាលនូវសេនាសនៈផង តែងឧទ្ទិសនូវភត្តផងដល់សង្ឃ ។ លំដាប់នោះ មេត្តិយភុម្មជកភិក្ខុទើបនឹងបួសថ្មីផង ជាមនុស្សមានបុណ្យតិចផង អស់ទាំងសេនាសនៈណា ដ៏ថោកថយរបស់សង្ឃ សេនាសនៈទាំងនោះ ត្រូវបានមកពួកភិក្ខុទាំងនោះ មួយទៀត ភត្តទាំងឡាយណាដ៏ថោកថយ ក៏ត្រូវបានមកពួកភិក្ខុទាំងនោះដែរ ។ ពួកមេត្តិយភុម្មជកភិក្ខុនោះក៏បង្គាប់ភិក្ខុទាំងឡាយ ឲ្យពោលទោសព្រះទព្វមល្លបុត្តដ៏មានអាយុថា ព្រះទព្វមល្លបុត្ត ក្រាលសេនាសនៈតាមសេចក្តីគាប់ចិត្តរបស់ខ្លួន ម្យ៉ាងទៀត លោកឧទ្ទិសនូវភត្តតាមសេចក្តីគាប់ចិត្តរបស់ខ្លួន ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា មេត្តិយភុម្មជកភិក្ខុទាំងឡាយ មិនសមបើនឹងបង្គាប់ភិក្ខុទាំងឡាយ ឲ្យពោលទោសព្រះទព្វមល្លបុត្តដ៏មានអាយុសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។បេ។ ទ្រង់ត្រាស់សួរចំពោះមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយ បង្គាប់ភិក្ខុទាំងឡាយឲ្យពោលទោសទព្វមល្លបុត្ត ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា

ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសម បើនឹងបង្គាប់ពួកភិក្ខុ ( ដទៃ ) ឲ្យពោលទោសទព្វមល្លបុត្តសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុ ( ដទៃ ) ឲ្យពោលទោសភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ បានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះ ។

[ ៣៦៩ ] សម័យនោះឯង ពួកមេត្តិយភុម្មជកភិក្ខុគិតគ្នាថា ការដែលប្រើភិក្ខុ ( ដទៃ ) ឲ្យពោលទោស ព្រះដ៏មានព្រះភាគបានហាមរួចហើយ ព្រោះហេតុនោះ ភិក្ខុទាំងឡាយមុខជានឹងបានឮ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ហើយក៏តិះដៀលព្រះទព្វមល្លបុត្តដ៏មានអាយុ ជិតពួកភិក្ខុ ( ដទៃ ) ថា ព្រះទព្វមល្លបុត្តរៀបចំសេនាសនៈតាមសេចក្តីគាប់ចិត្ត ( របស់ខ្លួន ) ផង ចាត់ចែងភត្តតាមសេចក្តីគាប់ចិត្ត ( របស់ខ្លួន ) ផង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកមេត្តិយភុម្មជកភិក្ខុ មិនសមបើនឹងហ៊ានតិះដៀលព្រះទព្វមល្លបុត្តដ៏មានអាយុសោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។បេ។ ទ្រង់ត្រាស់សួរ ចំពោះនឹងមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំង-ឡាយតិះដៀលទព្វមល្លបុត្តពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់

មេត្តាប្រាស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងតិះដៀលទព្វមល្លបុត្ត ទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យ ពោលទោស ( ភិក្ខុផងគ្នាឬ ) តិះដៀល ( ភិក្ខុផងគ្នា ) ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៧០ ] ដែលហៅថា ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យពោលទោស ( នោះ ) គឺ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់បង្អោន ចំពោះឧបសម្បន្នបុគ្គល ដែលសង្ឃ សន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នក ចែកនូវបបរក្តី ឲ្យជាអ្នកចែកនូវផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជា អ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ឬតិះដៀលឧបសម្បន្នបុគ្គល ( នោះ ) ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៧១ ] កម្មប្រកបដោយធម៌ ភិក្ខុសម្គាល់ថា កម្មប្រកបដោយធម៌ ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ( ឬ ) តិះដៀល ( ភិក្ខុផងគ្នា ) ត្រូវ អាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងកម្មប្រកបដោយធម៌ ហើយ បង្គាប់ភិក្ខុដទៃឲ្យពោលទោស ( ឬ ) តិះដៀល ( ភិក្ខុផងគ្នា ) ត្រូវអាបត្តិ បាចិត្តិយ ។ កម្មប្រកបដោយធម៌ តែភិក្ខុសម្គាល់ថា កម្មមិនប្រកបដោយ ធម៌វិញ ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ( ឬ ) តិះដៀល ( ភិក្ខុផងគ្នា )

ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៧២ ] ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យពោលទោសក្តី តិះដៀលដោយខ្លួនឯងក្តី នូវអនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបន្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបន្អាប់បន្ថោនចំពោះឧបសម្បន្នបុគ្គល ដែលសង្ឃមិនបានសន្មត ឲ្យជាអ្នកក្រាលសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នកចែកនូវបបរក្តី ឲ្យជាអ្នកចែកនូវផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោសក្តី តិះដៀលដោយខ្លួនឯងក្តី នូវឧបសម្បន្នបុគ្គលក្តី នូវអនុបសម្បន្នបុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបន្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបន្អាប់បន្ថោន ចំពោះអនុបសម្បន្នបុគ្គល ដែលសង្ឃបានសន្មត ឬមិនបានសន្មត ឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នកចែកនូវបបរក្តី ឲ្យជាអ្នកចែកផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ឬតិះដៀលដោយខ្លួនឯង នូវឧបសម្បន្នបុគ្គលក្តី អនុបសម្បន្នបុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសម្គាល់ថា កម្មប្រកបដោយធម៌វិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសម្គាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[ ៣៧៣ ] អាបត្តិមិនមានដល់ភិក្ខុដែលបង្គាប់ភិក្ខុដទៃឲ្យពោលទោសក្តីតិះដៀលដោយខ្ជួនឯងក្តី នូវភិក្ខុដែលជាអ្នកធ្វើការសង្ឃ ដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិជាប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា
## ភូតគាមវគ្គ
## ឧជ្ឈាបនកសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូចតទៅនេះ

[ ៣៦៨ ] ត្រើនបទថា **ឆព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេន្តិ** សេចក្តីថា ពួកមេត្តិយ និងភុម្មជកភិក្ខុ កាលពោលពាក្យជាដើមថា **ឆន្ទាយ ឆព្វោ មល្ល-បុត្តោ** ( ទព្វមល្លបុត្ររៀបចំសេនាសនៈដោយឆន្ទាគតិ ) ដូច្នេះ ឈ្មោះថា ញុំាងភិក្ខុទាំងឡាយនោះឲ្យមើលងាយ គឺឲ្យសម្លឹងមើលព្រះទព្វៈនោះ ដោយសេចក្តីប្រមាថ ម្យ៉ាងទៀត សេចក្តីថា រមែងឲ្យគិតទៅក្នុងផ្លូវអាក្រក់ ឯក្នុងបទថា **ឧជ្ឈាយន្តិ** នេះ គប្បីជ្រាបលក្ខណៈ ( នៃសព្ទ ) តាមគន្លងនៃគម្ពីរសព្ទសាស្ត្រ ។ បាឋៈថា **ឱជ្ឈាបេន្តិ** ដូច្នេះក៏មាន ។ សេចក្តីក៏យ៉ាងនេះដូចគ្នា ។

បទថា **ឆន្ទាយ** បានដល់ ដោយសេចក្តីស្រឡាញ់ពេញចិត្ត គឺដោយធ្លាក់ចូលជាបក្ខពួក អធិប្បាយថា រមែងរៀបចំសេនាសនៈដែលប្រណីតដើម្បីពួកភិក្ខុដែលជាសម្លាញ់ធ្លាប់រាប់អានគ្នារបស់ខ្លួន ដោយការស្រឡាញ់ពេញចិត្តនោះ ។

បទថា **ខីយន្តិ** គឺពួកមេត្តិយ និងភុម្មជកភិក្ខុ កាលពោលពាក្យថា **ឆន្ទាយ ឆព្វោ មល្លបុត្តោ** ជាដើម ឈ្មោះថា រមែងប្រកាស ។

[ ៣៦៩ ] ក្នុងបទថា **ឧជ្ឈាបនកេ ខីយនកេ ចាចិត្តិយំ** នេះ មាន

វិនិច្ឆ័យថា ពួកមេត្តិយ និងភុម្មជកភិក្ខុ រមែងឲ្យលើកទោសពាក្យណា ពាក្យនោះ ឈ្មោះថា **ឧជ្ឈាបនក** ហើយពោលតិះដៀលដោយពាក្យណា ពាក្យនោះឈ្មោះថា **ខីយនក** ព្រោះភាពជាអ្នកពោលទោស និងព្រោះភាពជាអ្នកពោលតិះដៀលនោះ ។

ដោយបទថា **បាចិត្តិយំ** ព្រះមានព្រះភាគ ដាក់អាបត្តិ ២ ក្នុងវត្ថុ ២ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃឧជ្ឈាបនកសិក្ខាបទ

[ ៣៧០ ] បទទាំងឡាយថា **ឧជ្ឈាបនកំ នាម ឧបសម្បន្នំ សង្ឃេន សម្មតំ សេនាសនបញ្ញាបកំ វា ។បេ។ អប្បមត្តកវិស្សជ្ជកំ វា** ដូច្នេះ ភ្ជាប់សេចក្តីជាមួយបទថា **មង្កុកត្តុកាមោ** ( មានបំណងនឹងធ្វើនូវសេចក្តីបន្ទាប់បន្ថោន ) នេះ ។

ដោយអំណាចនៃបទទាំងនេះថា **អវណ្ណំ កត្តុកាមោ អយសំ កត្តុកាមោ** បណ្ឌិតគប្បីធ្វើការផ្លាស់វិភត្តិក្នុងបទថា **ឧបសម្បន្នំ** ជាដើមយ៉ាងនេះថា **ឧបសម្បន្នស្ស** ដូច្នេះ ។

ព្រោះក្នុងបទថា **ឧជ្ឈាបេតិ វា ខីយតិ វា អាបត្តិ បាចិត្តិយស្ស** នេះ ព្រះមានព្រះភាគ ទ្រង់លើកបទមាតិកាឡើងយ៉ាងនេះថា **ខីយនកំ នាម** ដូច្នេះហើយ គប្បីត្រាស់វិភង្គដែលត្រាស់ហើយនោះឯងនៃបទថា **ឧជ្ឈាបនកំ នាម** នេះ ( តែ ) សេចក្តីប្លែកគ្នាដទៃ ( ក្នុងសិក្ខាបទនេះ ) មិនមាន ដូចក្នុងអញ្ញវាទកសិក្ខាបទ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ

ទ្រង់មិនលើកឡើងផង ទ្រង់មិនចែកបទមាតិកានោះផង ចែកទុកដោយឡែក ទ្រង់ធ្វើពាក្យនិគមប៉ុណ្ណោះទុករួមគ្នា ។

# អធិប្បាយ

## បទភាជនីយនៃឧជ្ឈាបនកសិក្ខាបទ

[ ៣៧១ ] ក្នុងបទជាដើមថា **ធម្មកម្មេ ធម្មកម្មសញ្ញី** នេះ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យថា សម្មតិកម្មណាសង្ឃធ្វើហើយ ដើម្បីឧបសម្បន្ននោះ បើកម្មនោះជាកម្មប្រកបដោយធម៌ ហើយភិក្ខុនោះមានសេចក្ដីសម្គាល់ក្នុងកម្មនោះថា កម្មប្រកបដោយធម៌ រមែងធ្វើការលើកទោស និងពោលទោសតិះដៀល លំដាប់នោះ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះភាពជាអ្នកពោលទោស និងពោលតិះដៀលនោះ ។

[ ៣៧២ ] ក្នុងបទថា **អនុបសម្បន្នំ ឧជ្ឈាបេតិ វា ខីយតិ វា** មានអត្ថថា ភិក្ខុរមែងញ៉ាំងអនុបសម្បន្នដទៃ ឲ្យពោលទោសឧបសម្បន្ន ដែលសង្ឃសម្មតិហើយក្ដី ឲ្យមើលងាយក្ដី តិះដៀលលោកក្នុងសម្នាក់នៃអនុបសម្បន្ននោះក្ដី ។

បទថា **ឧបសម្បន្នំ សង្ឃេន អសម្មតំ** សេចក្ដីថា ដែលសង្ឃមិនបានសន្មតដោយកម្មវាចា គឺបុគ្គលដែលសង្ឃលើកការៈឲ្យថា នេះជាការៈរបស់លោកតែម្យ៉ាងក្ដី នាំការៈនោះទៅដោយខ្លួនឯងក្ដី ដើម្បីការទៅសប្បាយរបស់ភិក្ខុទាំងឡាយ ។ ម្យ៉ាងទៀត អធិប្បាយថា ( រមែងឲ្យពោលទោសឧបសម្បន្ន ) ដែលធ្វើកម្មដូច្នោះ ក្នុងអាវាសដែលមានភិក្ខុ ២-៣ អង្គ ។

ឯការឲ្យសម្មតិ ១៣ យ៉ាងដល់អនុបសម្បន្ន រមែងមិនគួរដោយពិតសូម្បីយ៉ាងនោះ អនុបសម្បន្នដែលបានទទួលសម្មតិ ក្នុងគ្រាជាឧបសម្បន្នក្រោយមក តាំងនៅក្នុងភាពជាអនុបសម្បន្ន ព្រះមានព្រះភាគត្រាស់សំដៅយកអនុបសម្បន្ននោះថា បុគ្គលដែលសង្ឃសន្មតក្តី ក្នុងបទថា **អនុបសម្បន្នំ សង្ឃេន សម្មតំ វា អសម្មតំ វា** នេះ ។ តែសង្ឃក្តី ភិក្ខុដែលសង្ឃសន្មតក្តី ប្រគល់ការៈដល់សាមណេរអង្គណា ដែលឈ្លាសតែម្យ៉ាងថា លោកចូរធ្វើកម្មនេះ ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់សំដៅដល់សាមណេរដូច្នោះថាដែលសង្ឃមិនបានសន្មតក្តី ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខ-វេទនា ដូច្នេះ ។

ឧជ្ឈាបនកសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ៣៧៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះ ភិក្ខុទាំងឡាយបានតែងតាំងគ្រឿងសេនាសនៈ នៅទីវាល ហើយកំដៅកាយក្នុងកាលហេមន្តរដូវ ( សម័យដែលមានទឹកសន្សើម ) កាលបើគេប្រាប់ភត្តកាល គឺ និមន្តឆាន់ ហើយកាលនឹងដើរចេញទៅចាកទីនោះ មិនរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ។ ឯគ្រឿងសេនាសនៈទទឹកដោយទឹកសន្សើមជោកអស់ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងតែងតាំងគ្រឿងសេនាសនៈ នៅទីវាល ហើយកាលនឹងដើរចេញទៅមិនរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈក៏ជោកជាំដោយទឹកសន្សើម គ្រានោះភិក្ខុទាំងនោះ បានក្រាបទូល សេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់បានត្រាស់សួរនូវភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុបានតែងតាំងគ្រឿងសេនាសនៈនៅទីវាល កាលនឹងដើរចេញទៅ មិនបានរើយក មកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបាន

*ប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈក៏ជោកជាំដោយទឹកសន្សើម ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលអ្នកទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងតែងតាំងគ្រឿង សេនាសនៈនៅទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ឯគ្រឿងសេនាសនៈក៏ជោកជាំដោយទឹកសន្សើម ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយលាត ឬសន្ទឹងខ្លួនឯងក្តី ឲ្យគេលាតក្តី នូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះមកទុកដាក់ឯង មិនបានប្រើគេឲ្យរើយកមកទុកដាក់ ហើយឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅត្រូវ អាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។*

*[ ៣៧៥ ] សម័យនោះ មានភិក្ខុច្រើនរូបនៅក្នុងទីវាល លុះព្រឹកឡើងក៏នាំគ្នាជញ្ជូនយកគ្រឿងសេនាសនៈទៅ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានទតឃើញភិក្ខុទាំងនោះកំពុងតែជញ្ជូនយកគ្រឿងសេនាសនៈទៅអំពីព្រឹក ។ លុះទ្រង់បានទតហើយ ទើបទ្រង់ធ្វើនូវធម្មីកថា ព្រោះរឿងនេះ ដំណើរនេះ ហើយ*

ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វក្អែកក្តី ពួកសត្វខ្ទួនក្តី មិនបានបន្ទោបង់នូវឧច្ចារៈដាក់ក្នុងទីណា តថាគតអនុញ្ញាតឲ្យទុកដាក់គ្រឿងសេនាសនៈក្នុងទីនោះ គឺ ដូចជាមណ្ឌប ឬរុក្ខមូល ( ម្លប់ឈើ ) អស់កាល ៨ ខែ គឺ កំណត់យកខែដែលគ្មានភ្លៀង ។

[ ៣៧៦ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ សេនាសនៈដែលគេបានប្រគេន ឬបានលះដល់សង្ឃ ហៅថា សេនាសនៈរបស់សង្ឃ ។ ដែលហៅថា គ្រែ បានដល់ គ្រែ ៤ យ៉ាង គឺ គ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង ១ គ្រែដែលមានមេជាប់នឹងជើង ១ គ្រែដែលមានជើងដូចជាជើងក្តាម[1] ១ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ១ ។ ដែលហៅថា តាំង បានដល់ តាំងមាន ៤ យ៉ាង គឺ តាំងដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង ១ តាំងដែលមានមេគេបន្ទាំជាប់នឹងជើង ១ តាំងដែលមានជើង ដូចជាជើងក្តាម[2] ១ តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ១ ។ ដែលហៅថា ពូក បានដល់ ពូក ៥ យ៉ាង គឺ ពូកដែលគេញាត់ដោយរោមសត្វ ១ ពូកដែលគេញាត់សម្បកឈើ ១ ពូកដែលគេញាត់កំណាត់សំពត់ ១ ពូកដែលគេញាត់ស្មៅ ១ ពូកដែលគេញាត់ស្លឹកឈើ ១ ។ ដែលហៅថា កៅអី គឺ កៅអីដែលគេធ្វើដោយសម្បកឈើក្តី ធ្វើដោយស្បូវក្លាំងក្តី ធ្វើដោយស្មៅយ៉ាប្លងក្តី ធ្វើដោយស្មៅជំពោកទន្សាយក្តី ដែលគេរុំហើយចងភ្ជាប់គ្នា

---

១-២ គ្រែដែលមានជើងដូចជាជើងសេះ ជើងពពែជាដើម ឯតាំងក៏មានជើងដូចជាគ្រែដែរ ។

ខាងក្នុង ។ ពាក្យថា លាត គឺ តម្កល់ទុកដោយខ្លួនឯង ។ ពាក្យថា ប្រើគេឲ្យលាត គឺ ប្រើបុគ្គលដទៃឲ្យតម្កល់ទុក ។ ភិក្ខុប្រើអនុបសម្បន្នបុគ្គលឲ្យតម្កល់ទុក សេចក្តីខ្វល់នឹងមានដល់ភិក្ខុអ្នកប្រើនោះ ។ ភិក្ខុប្រើឧបសម្បន្នបុគ្គលឲ្យតម្កល់ទុក សេចក្តីខ្វល់នឹងមានដល់ភិក្ខុអ្នកតម្កល់ទុកនោះ ។ ពាក្យថា កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ គឺ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង ។ ពាក្យថា មិនបានប្រើគេឲ្យរើយកមកទុកដាក់ គឺ មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ ។ ពាក្យថា ឥតបានប្រាប់ ( អ្នកដទៃ ) ហើយដើរចេញទៅ គឺ កាលដែលភិក្ខុមិនបានប្រាប់ភិក្ខុផងគ្នាក្តី សាមណេរក្តី ឧបាសកក្តី ហើយដើរកន្លង ១ លេឌ្ឌុបាត[១] របស់មជ្ឈិមបុរសទៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៧៧ ] របស់សង្ឃ ភិក្ខុសម្គាល់ថា របស់សង្ឃ ហើយតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុកនៅក្នុងទីវិហារ កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃ ឲ្យរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ ( អ្នកដទៃ ) ហើយដើរចេញទៅត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងរបស់សង្ឃ ហើយតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុកក្នុងទីវិហារ កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃ ឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ)ហើយ

១- ចម្ងាយ មួយបោះដុំដីដែលមជ្ឈិមបុរសបោះចោលទៅ ។

ដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ របស់សង្ឃ ភិក្ខុមានសេចក្តីសម្គាល់ថា ជារបស់បុគ្គលទៅវិញ ហើយតម្កល់ទុកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យតម្កល់ទុកក្តី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ ( អ្នកដទៃ ) ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុកនូវគ្រឿងទ្រនាប់ក្តី គ្រឿងកម្រាលគ្រែ ឬតាំងក្តី គ្រឿងកម្រាលផែនដីក្តី កន្ទេលទន់ក្តី ប្រមខណ្ឌ គឺ គ្រឿងកម្រាល ដែលគេធ្វើដោយស្បែកខ្លាជាដើមក្តី គ្រឿងសម្រាប់ជូតជើងក្តី តាំងដែលគេធ្វើដោយផែនក្តារក្តី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈទាំងនោះ ឬមិនបានប្រាប់ ( អ្នកដទៃ ) ហើយចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។ របស់បុគ្គល ភិក្ខុមានសេចក្តីសម្គាល់ថា ជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងរបស់បុគ្គល ត្រូវអាបត្តិទុក្កដ ។ របស់បុគ្គល ភិក្ខុមានសេចក្តីសម្គាល់ថា ជារបស់បុគ្គល វត្ថុជារបស់បុគ្គលនៃភិក្ខុឯទៀត ( ដែលមិនមែនជាវិស្សាសៈ ) ត្រូវអាបត្តិទុក្កដ ។ វត្ថុជារបស់បុគ្គល ភិក្ខុកាន់យកដោយសេចក្តី ( ស្និទ្ធស្នាល ) ដូចជារបស់ខ្លួន មិនត្រូវអាបត្តិឡើយ ។

[ ៣៧៨ ] អាបត្តិមិនមានដល់ភិក្ខុដែលបានរើយកគ្រឿងសេនាសនៈមកទុកដាក់ដោយខ្លួនឯង ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើអ្នកដទៃឲ្យរើ

យកគ្រឿងសេនាសនៈមកទុកដាក់ ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់ ( អ្នកដទៃ ) ហើយដើរចេញទៅ ដល់ភិក្ខុដែលហាលគ្រឿងសេនាសនៈ ហើយដើរចេញទៅ ( ដោយគិតថា នឹងត្រឡប់មកយកទុកវិញ ) ដល់ភិក្ខុ ដែលមានគ្រឿងសេនាសនៈ ដែលមានបុគ្គលណាមួយមកបៀតបៀន[១] ដល់ភិក្ខុ ដែលមានសេចក្តីអន្តរាយ[២] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់

---

១- បើមានភិក្ខុចាស់បង្គាប់ភិក្ខុនោះឲ្យក្រោកចេញចាកទីសេនាសនៈ ហើយកាន់យកដោយខ្លួនលោកក្តី ឬមានយក្ខក្តី ប្រេតក្តី វាមកអន្ទ្រយនៅលើសេនាសនៈ នោះ ឬមានជនជាធំណាមួយមកដល់ហើយ កាន់យកគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះ ឈ្មោះថា មានបុគ្គលណាមួយមកបៀតបៀន ។ម្យ៉ាងទៀត កាលបើមានពួកសត្វ មានរាជសីហ៍ និងខ្លាជាដើម វាមកក្នុងប្រទេសហើយ ឈរនៅជិតគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះ ឈ្មោះថា មានបុគ្គលណាមួយមកបៀតបៀន ដូចគ្នាដែរ ។ តែមានបុគ្គលណាមួយ មកបៀតបៀនយ៉ាងនេះហើយ ទុកជាភិក្ខុមិនបានរើយកគ្រឿងសេនាសនៈនោះមកទុកដាក់ ក៏មិនត្រូវអាបត្តិឡើយ ។ ២- គឺអន្តរាយជីវិត ឬអន្តរាយព្រហ្មចរិយធម៌ ។

# អដ្ឋកថា

## ភូតគាមវគ្គ

## បឋមសេនាសនសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ

[ ៣៧៤ ] ពីរបទថា **ហេមន្តិកេ កាលេ** បានដល់ ក្នុងហេមន្តរដូវ គឺក្នុងរដូវសន្សើមធ្លាក់ ។

ពីរបទថា **កាយំ ឱតាបេន្តា** បានដល់ អង្គុយលើគ្រែ និងតាំងជាដើម ហើយផ្អែកកាយ អាំងកម្ដៅថ្ងៃដែលមានពន្លឺតិច ។

ពីរបទថា **កាលេ អារោចិតេ** បានដល់ កាលគេប្រាប់កត្តកាលឯណាមួយ មានបបរ និងភត្តជាដើម ។

ពីរបទថា **ឱវដ្ឋំ ហោតិ** បានដល់ ត្រូវទឹកសន្សើមធ្លាក់ជោកជាំ ។

[ ៣៧៥ ] បទថា **អវស្សិកសង្កេតេ** សេចក្ដីថា អស់កាល ៨ ខែ គឺ ៤ ខែក្នុងហេមន្តរដូវ ៤ ខែក្នុងគិម្ហរដូវ ដែលមិនបានបញ្ញត្តយ៉ាងនេះថា ខែទាំងឡាយនៃរដូវភ្លៀង ។

បទថា **មណ្ឌបេ វា** បានដល់ ក្នុងមណ្ឌបធ្វើដោយមែកឈើក្ដី ក្នុងមណ្ឌបធ្វើដោយបន្ទះក្ដារក្ដី ។

បទថា **រុក្ខមូលេ វា** បានដល់ ខាងក្រោមនៃដើមឈើណាមួយក្ដី ។

ច្រើនបទថា **យត្ថ កាកា វា កុលលា វា ន ឩធហន្តិ** សេចក្ដីថា ក្អែក និងខ្លែងទាំងនេះក្ដី បក្សីពួកដទៃក្ដី ធ្វើសម្បុកដោយការនៅជាប្រចាំក្នុង

ដើមឈើណា នឹងមិនបន្ទោបង់លាមកដាក់សេនាសនៈនោះ តថាគតអនុញ្ញាត ឲ្យទុកត្រង់គល់ឈើដូច្នោះ ព្រោះហេតុនេះ បក្សីទាំងឡាយស្វែងរកចំណី សម្រាកត្រង់ដើមឈើណា ហើយហើរទៅ បើទុកត្រង់គល់នៃដើមនោះ ក៏គួរ ។ តែបក្សីទាំងឡាយធ្វើសម្បុកនៅដោយការនៅជាប្រចាំត្រង់ដើមឈើណា មិន គប្បីទុកដាក់ត្រង់គល់ឈើនោះឡើយ ។

ព្រោះព្រះបាលីថា **អដ្ឋ មាសេ** ដូច្នេះ ក្នុងជនបទទាំងឡាយណា ភ្លៀង មិនធ្លាក់ក្នុងរដូវភ្លៀង សូម្បីក្នុងជនបទទាំងឡាយនោះ ទោះទុកអស់ ៤ ខែ ក៏មិនគួរដូចគ្នា ។

ព្រោះព្រះបាលីថា **អវស្សិកសង្កេតេ** ដូច្នេះ ក្នុងជនបទទាំងឡាយណា ភ្លៀងធ្លាក់ក្នុងហេមន្តរដូវ ក្នុងជនបទទាំងនោះ បើទុកក្នុងទីវាល សូម្បីក្នុង ហេមន្តរដូវ ក៏មិនគួរ ឯក្នុងគិម្ហរដូវ ផ្ទៃមេឃបរិសុទ្ធ ប្រាសចាកពពកក្នុងទី ទូទៅ ក្នុងវេលាដូច្នេះ ទោះទុកដាក់គ្រែ និងតាំងក្នុងទីវាល ដោយករណីចាំ បាច់ណាមួយ គួរ ។

ភិក្ខុដែលសមាទានអព្ភោកាសិកធុតង្គ ក៏គួរស្គាល់វត្ត ។ ពិតហើយ បើ លោកមានគ្រែចំណែកបុគ្គល ក៏គប្បីដេកលើគ្រែចំណែកបុគ្គលនោះឯង កាល កាន់យកគ្រែរបស់សង្ឃ គប្បីកាន់យកគ្រែដែលត្បាញដោយផ្តៅ ឬដោយផ្ទៃ កាលគ្រែត្បាញដោយផ្តៅ ឬដោយផ្ទៃនោះមិនមាន គប្បីកាន់យកគ្រែចាស់ ។ កាលគ្រែចាស់នោះមិនមាន គប្បីកាន់យកគ្រែដែលត្បាញថ្មីក្តី ដែលពាស ដោយស្បែកក្តី កាលកាន់យកហើយ គិតថា អញនឹងសមាទានរុក្ខមូលយ៉ាង

ឧក្រិដ្ឋ សមាទានអព្ភោកាសយ៉ាងឧក្រិដ្ឋ ដូច្នេះហើយ មិនធ្វើសូម្បីកុដិដែលបាំងដោយចីវរ រៀបគ្រែតាំងនោះក្នុងទីវាលក្តី ត្រង់គល់ឈើ ហើយដេកក្នុងគ្រាដែលមិនមែនសម័យ រមែងមិនគួរ ។ បើភិក្ខុមិនអាចរក្សាកុដិដែលធ្វើចីវរទាំង ៤ ជាន់មិនឲ្យទទឹកបាន មានភ្លៀងធ្លាក់ជោកជាំអស់ ៧ ថ្ងៃ ( ទោះបីរៀបចំគ្រែតូចដេក ) ក៏គួរ ព្រោះគ្រែដេកប្រព្រឹត្តទៅតាមរាងកាយរបស់ភិក្ខុ ។

ពួកមនុស្សមានចិត្តជ្រះថ្លា ក្នុងសីលសម្បទារបស់ភិក្ខុទាំងឡាយដែលនៅក្នុងតូបស្លឹកឈើក្នុងព្រៃ ទើបប្រគេនគ្រែ និងតាំងថ្មី ពោលថា សូមលោកម្ចាស់ទាំងឡាយប្រើប្រាស់ ដោយប្រើប្រាស់ជារបស់សង្ឃចុះ ។ ភិក្ខុទាំងឡាយដែលនៅហើយ នឹងចេញទៅ គប្បីឲ្យដំណឹងដល់ភិក្ខុដែលស្និទ្ធស្នាលគ្នា ក្នុងវិហារជិតខាង ហើយសឹមទៅ ។ បើមិនមានពួកភិក្ខុដែលស្និទ្ធស្នាលគ្នា គប្បីទុកដាក់ក្នុងទីដែលភ្លៀងមិនលិចស្រោច ហើយសឹមទៅ ។ បើមិនមានទីគត់ភ្លៀង គប្បីបញ្ឈរទុកត្រង់ដើមឈើ ហើយសឹមទៅ ។

ភិក្ខុកាន់យកអំបោសត្រង់លានព្រះចេតិយ ទៅបោសលានរោងឆាន់ក្តីលានរោងឧបោសថក្តី ទីណាមួយ មានបរិវេណដែលសម្រាកពេលថ្ងៃ និងរោងភ្លើងជាដើម លាង គោះ ( អំបោសនោះ ) ហើយគប្បីទុកអំបោសក្នុងរោងនោះឯងទៀត ។ សូម្បីភិក្ខុដែលកាន់យកអំបោសក្នុងទីកន្លែងណាមួយមានរោងឧបោសថជាដើម ទៅបោសបរិវេណដ៏សេស ក៏មានន័យដូច្នេះ ។ ចំណែកភិក្ខុណាបោសផ្លូវដែលត្រាច់បិណ្ឌបាត បំណងនឹងទៅ ( បិណ្ឌបាត ) តែម្តង ភិក្ខុនោះបោសហើយ គប្បីទុកដាក់ត្រង់សាលា បើមានក្នុងរវាងផ្លូវ

នោះ ។ បើមិនមានសាលា កំណត់ថាមេឃមិនទាន់ខ្មៅនៅឡើយ ដឹងថាភ្លៀងមិនទាន់ធ្លាក់ រហូតដល់ខ្លួនចេញមកអំពីស្រុក រក្សាទុកក្នុងទីណាមួយ ហើយត្រឡប់មក គប្បី ( យកមក ) ទុកដាក់ក្នុងទីដើមវិញ ។

ក្នុងមហាបច្ចរីពោលថា បើភិក្ខុដឹងថា ភ្លៀងនឹងធ្លាក់ ទុកដាក់ក្នុងកណ្តាលវាល ត្រូវអាបត្តិទុក្កដ ដូច្នេះ ។ តែបើអំបោសជារបស់ដែលគេទុកដាក់ដើម្បីប្រយោជន៍សម្រាប់បោសក្នុងទីនោះឯង ភិក្ខុទោះបោសក្នុងទីនោះៗ ហើយទុកដាក់ក្នុងទីនោះឯង គួរ ។ ភិក្ខុអ្នកបោសរោងឆាន់ គួរស្គាល់វត្ត វត្តក្នុងការបោសរោងឆាន់នោះ ដូច្នេះ គឺគប្បីបោសប្រមូលខ្សាច់តាំងអំពីក្នុងកៀរមកទុកខាងមុខ គឺ ត្រង់មាត់ទ្វារ ហើយយកដៃទាំងពីរកើបសំរាមទៅចោលខាងក្រៅ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃបឋមសេនាសនសិក្ខាបទ

[ ៣៧៦ ] គ្រែដែលគេជាប់ត្រង់ជើង ស៊ិកមេគ្រែទាំងឡាយចូលទៅក្នុងជើងគ្រែនោះ ឈ្មោះថា **មសារក** ។

គ្រែដែលគេធ្វើមេគ្រែគាបជើងគ្រែ ដោយលក្ខណៈដូចបល្ល័ង្ក ឈ្មោះថា **ពុន្ទិកាពទ្ធ** ។

គ្រែដែលគេធ្វើដោយជើងដូចគ្នានឹងជើងនៃសត្វ មានសេះ និងពពែជាដើម ឈ្មោះថា **កុលិរបាទក** ( គ្រែដែលមានជើងដូចជើងក្តាម ) ឬគ្រែដែលមានជើងបែបណាមួយនេះ លោកហៅថា គ្រែមានជើងដូចជើងក្តាម ។

ឯគ្រែឈ្មោះថា **អាហច្ចបាទកា** នេះ លោកពោលទុកក្នុងបាលីខាងមុខនោះឯង យ៉ាងនេះថា គ្រែដែលចោះតួគ្រែធ្វើ ឈ្មោះថា **អាហច្ចបាទកា** ( គ្រែមានជើងគ្រាន់តែស៊កទុក ) ។ ព្រោះហេតុនោះ គ្រែដែលចោះមេគ្រែទាំងឡាយ ហើយស៊កជន្ទញចូលទៅក្នុងមេគ្រែនោះ វាយកន្ទះក្នុងខាងលើ បណ្ឌិតគប្បីជ្រាបថា គ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់គ្រែ សូម្បីក្នុងតាំង ក៏មានន័យយ៉ាងនេះដូចគ្នា ។

ប្រើនបទថា **អដ្ឋោ សំវេធេត្វា ពន្ធំ ហោតិ** សេចក្តីថា កៅអីដែលគេត្បាញឲ្យធំទាំងខាងក្រោម និងខាងលើ ត្រង់កណ្តាលតូច មានសណ្ឋានដូចស្គរ ។ បានឮថា ជនទាំងឡាយធ្វើកៅអីនេះពាសដោយស្បែកសីហៈ និងខ្លាធំត្រង់កណ្តាលក៏មាន ។ ក្នុងសេនាសនៈនេះ ឈ្មោះថា ស្បែកដែលជាអកប្បិយ មិនមាន ។ ពិតហើយ សូម្បីសេនាសនៈដែលជាវិការនៃមាសក៏គួរ ព្រោះហេតុនោះ ទើបសេនាសនៈនោះជារបស់មានតម្លៃច្រើន ។

បទថា **អនុបសម្បន្នំ សន្ថរាបេតិ តស្ស បរិពោធោ** សេចក្តីថា ជាធុរៈរបស់អនុបសម្បន្នដែលត្រូវប្រើឲ្យទុកដាក់ ។

បទថា **លេឌ្ឌុបាតំ អតិក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស** សេចក្តីថា ភិក្ខុដើរហួសមួយលេឌ្ឌុបាតរបស់បុរសដែលមានកម្លាំងខ្នាតកណ្តាលទៅ ត្រូវអាបត្តិបាចិត្តិយ ។

ក្នុងបទថា **លេឌ្ឌុបាតំ អតិក្កមន្តស្ស** ជាដើមនេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះថេរៈធ្វើកត្តកិច្ចក្នុងរោងឆាន់ ហើយប្រើភិក្ខុកំលោះថា លោក

ចូរទៅរៀបចំគ្រែ តាំង ក្នុងទីសម្រាកពេលថ្ងៃ ភិក្ខុកំលោះនោះធ្វើតាមពាក្យប្រើ ហើយអង្គុយ ។ ព្រះថេរៈត្រាច់ទៅតាមការពេញចិត្ត ហើយទើបទៅក្នុងទីសម្រាកពេលថ្ងៃនោះ ដាក់ចង្ហាន់ និងឧត្តរាសង្គទុក ។ ចាប់អំពីពេលនោះទៅ ជាធុរៈរបស់ព្រះថេរៈ ។ ព្រះថេរៈអង្គុយហើយ កាលចេញទៅមិនទុកដាក់ឯង មិនប្រើគេឲ្យទុកដាក់ ត្រូវអាបត្តិបាចិត្តិយ ក្នុងកាលដើរកន្លងហួសមួយលេឌ្ឌុបាតទៅ ។

បើព្រះថេរៈមិនដាក់ចង្ហាន់ និងសង្ឃាដីទុកលើគ្រែ និងតាំងនោះទេ ចង្ក្រមបណ្ដើរ ប្រើភិក្ខុកំលោះថា លោកទៅបានហើយ ភិក្ខុគប្បីប្រាប់ថា បពិត្រលោកម្ចាស់ នេះ គ្រែ តាំង បើព្រះថេរៈស្គាល់ទំនៀម គប្បីពោលថា លោកទៅចុះ ខ្ញុំនឹងធ្វើឲ្យជាប្រក្រតីដើម ។ បើព្រះថេរៈជាអ្នកល្ងង់ខ្លៅ មិនបានសិក្សាក្នុងទំនៀម នឹងសម្លុតគំហកភិក្ខុកំលោះថា ទៅចុះ កុំមកឈរក្នុងទីនេះ ខ្ញុំមិនឲ្យ ( នរណាមួយ ) អង្គុយ មិនឲ្យ ( នរណាមួយ ) ដេកឡើយ ភិក្ខុកំលោះប្រាប់ថា បពិត្រលោកម្ចាស់ៗ សិងតាមសប្បាយចុះ បានលេសថ្វាយបង្គំហើយ គប្បីទៅចុះ ។ កាលភិក្ខុកំលោះនោះទៅហើយ ជាភារៈរបស់ព្រះថេរៈនោះប៉ុណ្ណោះ ។ បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិដល់ព្រះថេរៈនោះដោយន័យមុននោះឯង ។

បើក្នុងខណៈដែលប្រើនោះឯង ភិក្ខុកំលោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំមានកិច្ចចាំបាច់ធ្វើឯណាមួយ មានការជុសលាងរបស់របរជាដើម ហើយព្រះថេរៈពោលជាមួយលោកថា លោករៀបចំគ្រែហើយ ចូរទៅចុះ ដូច្នេះ

ហើយ ចេញពីរោងឆាន់ទៅក្នុងទីដទៃ វិនយធរគប្បីកាត់អាបត្តិ ( ព្រះថេរៈ ) ដោយជំហាន បើព្រះថេរៈទៅអង្គុយក្នុងអាសនៈនោះឯង ជាអាបត្តិដល់ព្រះថេរៈនោះ ក្នុងកាលដើរកន្លងហួសមួយលេឌ្ឌុបាតទៅ ដូចន័យមុននោះឯង ។

បើព្រះថេរៈប្រើសាមណេរ កាលសាមណេររៀបចំគ្រែ និងតាំង ក្នុងរោងឆាន់នោះ ហើយអង្គុយ ព្រះថេរៈចេញទៅកាន់ទីដទៃអំពីរោងឆាន់ ព្រះវិនយធរគប្បីកាត់អាបត្តិដោយជំហាន ។ ព្រះថេរៈទៅអង្គុយ ហើយទៅក្នុងវេលាជាក្រោយ គប្បីកាត់អាបត្តិក្នុងកាលដើរកន្លងហួសមួយលេឌ្ឌុបាតទៅ ។

បើព្រះថេរៈកាលប្រើ ប្រើថា លោកកាលរៀបចំគ្រែ និងតាំងហើយ ចូរអង្គុយចាំត្រង់គ្រែ និងតាំងនោះផង ដូច្នេះ រមែងបានដើម្បីនឹងទៅក្នុងទីដែលខ្លួនប្រាថ្នា ។ ឯភិក្ខុអ្នកទទួលប្រើ កាលមិនធ្វើឲ្យជាប្រក្រតី ខ្លួនឯងដើរទៅត្រូវអាបត្តិបាចិត្តិយ ក្នុងកាលដើរហួសមួយលេឌ្ឌុបាតទៅ ។

ក្នុងរោងការប្រជុំ ភិក្ខុទាំងឡាយរៀបចំគ្រែ និងតាំង ហើយអង្គុយ , ក្នុងវេលានឹងទៅ គប្បីប្រាប់ដល់អារាមិកបុរស( ញោមវត្ត ) ថា អ្នកទាំង-ឡាយ ចូរទុកដាក់គ្រែ និងតាំងនេះ ដូច្នេះ ត្រូវអាបត្តិដល់ភិក្ខុដែលមិនប្រើហើយទៅ កាលភិក្ខុដើរកន្លងហួសមួយលេឌ្ឌុបាតទៅ ។

ធម្មតាការស្តាប់ធម៌ ក្នុងសម័យប្រជុំធំអាចមាន ភិក្ខុទាំងឡាយនាំយកគ្រែ និងតាំងមកអំពីរោងឧបោសថខ្លះ រោងឆាន់ខ្លះ រៀបចំទុកក្នុងទីស្តាប់ធម៌នោះ ជាភារៈរបស់ពួកភិក្ខុម្ចាស់អាវាសប៉ុណ្ណោះ ។ បើពួកភិក្ខុអាគន្តុកៈកាន់យកទៅ ដោយអាងថា នេះសម្រាប់ឧបជ្ឈាយ៍របស់អញ នេះសម្រាប់អាចារ្យ

របស់អញ ដូច្នេះ ចាប់អំពីពេលនោះទៅ ជាភារៈរបស់អាគន្តុកៈនោះប៉ុណ្ណោះ ក្នុងកាលចេញទៅ បើមិនទុកដាក់ឲ្យដូចដើម ដើរកន្លងមួយលេឌ្ឌុបាតទៅ ប្រព្រឹត្តជាអាបត្តិ ។

តែក្នុងមហាបច្ចរីពោលទុកថា រយៈពេលដែលភិក្ខុពួកដទៃមិនទាន់មកអង្គុយ ជាភារៈរបស់ពួកភិក្ខុដែលរៀបចំ កាលពួកភិក្ខុទាំងឡាយដទៃមកអង្គុយហើយ ជាភារៈរបស់ពួកភិក្ខុដែលអង្គុយ បើពួកភិក្ខុដែលអង្គុយទាំងនោះ មិនទុកដាក់ឯងក្តី មិនប្រើឲ្យទុកដាក់ក្តី ហើយទៅ ត្រូវអាបត្តិទុក្កដ ព្រោះហេតុអ្វី ព្រោះមិនបានប្រាប់ឲ្យរៀបចំ ។

កាលរៀបចំធម្មាសនៈហើយ ភិក្ខុអ្នកសូធ្យ ឬអ្នកសម្តែងធម៌មិនទាន់មកដរាបណា ជាភារៈរបស់ពួកភិក្ខុអ្នករៀបចំដរាបនោះ កាលភិក្ខុអ្នកសូធ្យក្តី អ្នកសម្តែងធម៌ក្តី មកអង្គុយហើយ ជាភារៈរបស់ភិក្ខុនោះ ។ បើមានការស្តាប់ធម៌ពេញមួយថ្ងៃ និងពេញមួយយប់ ភិក្ខុអ្នកសូធ្យ ឬអ្នកសម្តែងធម៌ក្រោកទៅ ភិក្ខុដទៃមកអង្គុយ ភិក្ខុណាមួយមកអង្គុយ ជាភារៈនៃភិក្ខុនោះៗ ។ តែកាលក្រោកឡើង គប្បីពោលថា អាសនៈនោះជាភារៈរបស់លោក ហើយសឹមទៅ ។ បើភិក្ខុអ្នកសូធ្យ អ្នកសម្តែងធម៌ក្រៅអំពីនេះ មិនទាន់មកដល់នោះឯង ភិក្ខុដែលអង្គុយមុន ក្រោកទៅ ហើយភិក្ខុដែលអង្គុយមុននេះ មកអង្គុយខាងក្នុងឧបចារៈទីកន្លែងនោះឯង ព្រះវិនយធរមិនគប្បីកាត់អាបត្តិដល់ភិក្ខុដែលក្រោកទៅ ។ បើភិក្ខុអ្នកសូធ្យ និងអ្នកសម្តែងធម៌មិនទាន់មកនោះឯង ភិក្ខុដែលអង្គុយមុនក្រោកចាកអាសនៈ ដើរហួសមួយលេឌ្ឌុបាតទៅ ព្រះ-

វិនយធរ គប្បីកាត់អាបត្តិដល់ភិក្ខុនោះ ។ តែក្នុងមហាបច្ចរី ពោលន័យនេះទុកថា គ្រប់ៗ កន្លែង ក្នុងកាលដើរហួសលេឌ្ឌុបាតទៅ ត្រូវទុក្កដក្នុងជំហានទី ១ ត្រូវបាចិត្តិយក្នុងជំហានទី ២ ។

## អធិប្បាយ

## បទភាជនីយនៃបឋមសេនាសនសិក្ខាបទ

[ ៣៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចិមិលិកំ វា** ជាដើម ដូច្នេះថា កម្រាលដែលគេធ្វើទុកដើម្បីរក្សាពណ៌ត្រង់ផ្ទៃបាត ឬផ្ទៃជញ្ជាំងដែលធ្វើបរិកម្មដោយបាយអជាដើម ឈ្មោះថា **ចិមិលិកា** ។ ជនទាំងឡាយក្រាលកម្រាលនោះទុកខាងក្រោម ហើយក្រាលកន្ទេលផែនពីលើ ។

គ្រឿងកម្រាលដែលគួរក្រាលទុកលើគ្រែ និងតាំង ឈ្មោះថា កម្រាលគ្រែ ។ ប្រភេទនៃកម្រាល មានកន្ទេលផែនជាដើម ដែលគួរក្រាលទុកលើផ្ទៃ ឈ្មោះថា កម្រាលផ្ទៃដី ។ កន្ទេលដែលគេធ្វើដោយស្លឹកត្នោតក្តី សម្បកផ្តៅក្តី ឈ្មោះថា កន្ទេលសាច់ទន់ ។ បណ្តាស្បែកសត្វ មានសីហៈ ខ្លាធំ ខ្លាដំបង ខ្លារខិន ខ្លាឃ្មុំជាដើម ស្បែកប្រភេទណាមួយ ឈ្មោះថា បន្ទះស្បែកពិតហើយ ឈ្មោះថា ស្បែកដែលលោកហាមក្នុងការបរិភោគសេនាសនៈមិនប្រាកដក្នុងអដ្ឋកថាទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ហាមចំពោះក្នុងបរិហារស្បែកសីហៈជាដើម ។

គ្រឿងជូតដែលគេធ្វើដោយខ្សែតូចៗ ក្តី ដោយសំពត់ចាស់ក្តី ដើម្បីជូតជើង ឈ្មោះថា គ្រឿងជូតជើង ។

តាំងដែលគេធ្វើដោយបន្ទះក្តារ ឈ្មោះថា តាំងក្តារ ។ ម្យ៉ាងទៀត បាន ដល់ បន្ទះក្តារ និងតាំងដែលធ្វើដោយឈើ ។ គ្រឿងឈើជាដើមទាំងអស់ លោកសង្គ្រោះដោយតាំងបន្ទះក្តារនោះតែក្នុងមហាបច្ចរីពោលទុកដោយពិស្តារ នោះឯងថា ភិក្ខុដាក់ជើងទម្របាត្រ គម្របបាត្រ និងក្បៀងជូតជើង ផ្ទិតស្លឹក ត្នោត ផ្ទិតស្លឹកឈើ គ្រឿងឈើឯណានីមួយ ដោយហោចត្រឡោកដងទឹក ស័ង្កដាក់ទឹកផឹកទុកក្នុងទីវាល ហើយទៅ ត្រូវអាបត្តិទុក្កដ ។ តែក្នុងមហា អដ្ឋកថា ន័យនេះលោកសម្តែងទុកក្នុងសិក្ខាបទទី ២ ។ ភិក្ខុស្ងោរទឹកជ្រលក់ ចីវរក្នុងទីវាល ហើយគប្បីទុកដាក់របស់ប្រើប្រាស់ទាំងពួង គឺភាជនៈទឹក ជ្រលក់ ត្រឡោកដងទឹកជ្រលក់ ស្នូកទឹកជ្រលក់ទុកក្នុងរោងភ្លើង ។ បើរោង ភ្លើងមិនមាន គប្បីទុកក្នុងញកដែលទឹកភ្លៀងមិនលិចស្រោច កាលញកនោះ មិនមាន សូម្បីទុកដាក់ក្នុងទីដែលពួកភិក្ខុឃ្លាំមើលថែ ហើយចេញទៅក៏គួរ ។

ពីរបទថា **អញ្ញស្ស បុគ្គលិកេ** សេចក្តីថា ក្នុងមហាបច្ចរីជាដើមពោល ថា ការកាន់យកដោយវិស្សាសៈក្នុងបុគ្គលណាមិនឡើង ត្រូវអាបត្តិទុក្កដ ព្រោះទ្រព្យរបស់បុគ្គលនោះ តែវិស្សាសៈក្នុងបុគ្គលណាឡើង ទ្រព្យរបស់ បុគ្គលនោះ រមែងដូចជារបស់ផ្ទាល់ខ្លួន ។

[ ៣៧៨ ] ពីរបទថា **អាបុច្ឆំ គច្ឆតិ** សេចក្តីថា បុគ្គលណាជាភិក្ខុក្តី សាមណេរក្តី អារាមិកបុរសក្តី ជាលជ្ជី រមែងសម្គាល់ដូចជាការៈរបស់ខ្លួន ភិក្ខុណាពោលលាបុគ្គលប្រភេទនោះ ហើយទៅ ជាអនាបត្តិដល់ភិក្ខុនោះ ។

ពីរបទថា **ឱតាបេន្តោ គច្ឆតិ** ភិក្ខុយកចេញហាលត្រង់កម្តៅថ្ងៃ ទៅ

ដោយគិតថា អញនឹងមកទុកដាក់ មិនត្រូវអាបត្តិដល់ភិក្ខុដែលទៅយ៉ាងនេះ ។

## អនាបត្តិនៃបឋមសេនាសនសិក្ខាបទ

បទថា **កេនចិ បលិពុទ្ធំ ហោតិ** សេចក្តីថា សេនាសនៈត្រូវបៀតបៀនដោយអន្តរាយណាមួយ ។ បើភិក្ខុចាស់ជាងឲ្យផ្លាស់ទីកន្លែងចេញហើយ កាន់យក ( សេនាសនៈ ) ក្តី យក្ខ ឬប្រេតមកអង្គុយក្តី ឥស្សរជនមកដណ្តើមយកក្តី សេនាសនៈរាប់ថា ត្រូវហួងហែង ( ការពារ ) កាលសត្វសាហាវ មានសីហៈ និងខ្លាធំជាដើម មកកាន់ប្រទេសនោះ ហើយស្នាក់នៅសេនាសនៈរាប់ថា ត្រូវបៀតបៀនដូចគ្នា មិនជាអាបត្តិដល់ភិក្ខុដែលមិនទុកដាក់ ហើយទៅ ព្រោះសេនាសនៈត្រូវអន្តរាយណាមួយបៀតបៀនយ៉ាងនេះ ។

បទថា **អាបទាសុ** គឺព្រោះអន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈ ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមកាយ និងវាចា ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយាផង អកិរិយាផង ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមសេនាសនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៥

[ ៣៧៩ ] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមានពួក ១៧ ជាសម្លាញ់នឹងគ្នា ។ ភិក្ខុទាំងនោះ កាលនឹងនៅក៏នៅជាមួយគ្នា កាលនឹងដើរក៏ដើរជាមួយគ្នា ។ ភិក្ខុទាំងនោះឯង បានក្រាលគ្រឿងកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃណាមួយ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់វិញ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ ( អ្នកដទៃ ) ឡើយ ស្រាប់តែចៀសចេញទៅ ។ ឯពួកសត្វកណ្ដៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា កោតតែភិក្ខុទាំង ១៧ រូប ហ៊ានក្រាលគ្រឿងកម្រាល សម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ ( អ្នកដទៃ ) ឡើយ ស្រាប់តែចៀសចេញទៅ ឯពួកសត្វកណ្ដៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏បានក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ( ដោយសព្វគ្រប់ ) ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរចំពោះភិក្ខុទាំងនោះថា នែភិក្ខុទាំងឡាយ ឮថា ភិក្ខុមានពួក ១៧ រូប

បានក្រាលកម្រាល សម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលដែលដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់នូវកម្រាលសម្រាប់ដេកនោះ ឥតទាំងបានប្រាប់ ( អ្នកដទៃ ) ឡើយ ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈពួកសត្វកណ្ដៀរវាក៏កោរកាត់ខូចអស់ ជាពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ មិនសមបើនឹងក្រាលគ្រឿងកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលដែលដើរចេញទៅ ក៏មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ហើយឥតទាំងប្រាប់ ( អ្នកដទៃ ) សោះឡើយ ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈទាំងនោះ ពួកសត្វកណ្ដៀរវាក៏កោរកាត់ខូចអស់ ម្នាលភិក្ខុទាំងឡាយ អំពើនេះ នឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ក្រាល ឬប្រើគេឲ្យក្រាល នូវកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៨០ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងបឋមបារាជិកសិក្ខាបទខាងដើមហើយ ។ វិហារដែលគេបានវេរប្រគេន ឬគេបានលះបង់

ដល់សង្ឃហើយ ហៅថា វិហាររបស់សង្ឃ ។ ពូក គ្រឿងទ្រនាប់ កម្រាលគ្រែ ឬតាំង កម្រាលផែនដី កន្ទេលទន់ ប្រមខណ្ឌ ( កំណាត់ស្បែក ) និសីទនៈ ( សំពត់សម្រាប់ទ្រាប់អង្គុយ ) កម្រាលដែលគេធ្វើដោយស្មៅ កម្រាលដែលគេធ្វើដោយស្លឹក ហៅថា កម្រាលសម្រាប់ដេក ។ ពាក្យថា ក្រាល គឺ ក្រាលដោយខ្លួនឯង ។ ពាក្យថា ប្រើគេឲ្យក្រាល គឺ ប្រើអ្នកដទៃឲ្យក្រាល ។ ពាក្យថា កាលនឹងដើរចេញទៅ មិនបានរើយកគ្រឿងកម្រាលនោះមកទុកដាក់ដោយខ្លួនឯង គឺ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង ។ ពាក្យថា មិនបានប្រើគេឲ្យរើយកមកទុកដាក់ គឺ មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ឡើយ ។ ពាក្យថា ឥតបានប្រាប់ ( អ្នកដទៃ ) ហើយដើរចេញទៅ គឺ មិនបានប្រាប់ភិក្ខុក្តី សាមណេរក្តី ញោមវត្តក្តី ហើយដើរទៅកន្លងរបងវត្តដែលគេបិទបាំងត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុកាលបើដើរកន្លងឧបចារវត្ត ដែលគ្មានរបង ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៨១ ] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា ជារបស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតប្រាប់ ( អ្នកដទៃ ) ឡើយ ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារជារបស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក កាលដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមក

ទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា ជារបស់បុគ្គលទៅវិញ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាល នូវកម្រាលសម្រាប់ដេក កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រាប់គេឲ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រាប់គេឲ្យរើយកមកទុកដាក់ នូវ កម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុក្រាលដោយខ្លួនឯងក្តី ប្រើគេឲ្យក្រាលក្តី នូវគ្រែ ឬតាំងក្នុងវិហារក្តី ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រែ និងតាំងនោះ ឬឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថា ជាវិហាររបស់សង្ឃទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ។ វិហារជារបស់បុគ្គល ភិក្ខុដឹងច្បាស់ថា ជារបស់បុគ្គល គឺ វិហារដែលជារបស់បុគ្គលនៃភិក្ខុដទៃ ( ដែលមិនមែនជាវិស្សាសៈ ) ត្រូវអាបត្តិទុក្កដ ។ វិហារជារបស់

បុគ្គល ( ដែលជាទីស្និទ្ធស្នាលនឹងខ្លួន ) មិនត្រូវអាបត្តិឡើយ ។

[ ៣៨២ ] អាបត្តិមិនមានដល់ភិក្ខុ ដែលបានរើកម្រាលយកមកទុកដាក់ដោយខ្លួន រួចហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើគេឲ្យរើយកមកទុកដាក់ ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់ ( អ្នកដទៃ ) រួចហើយដើរចេញទៅ ដល់ភិក្ខុមានកម្រាលដែលមានបុគ្គលណាមួយ ចូលទៅបៀតបៀន[១] ដល់ភិក្ខុដែលមានសេចក្តីអាឡោះអាល័យ[២] បានដើរចេញទៅឈរក្នុងទីនោះ ប្រាប់ ( បុគ្គលណាមួយ ) ថា ភិក្ខុនោះមានសេចក្តីអន្តរាយ[៣] នីមួយមកបៀតបៀនហើយ ដល់ភិក្ខុមានសេចក្តីអន្តរាយកើតឡើង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

១-២ បានអធិប្បាយក្នុងសិក្ខាបទទី ៤ ខាងដើមរួចជាស្រេច ។ ៣- តាមន័យក្នុងអដ្ឋកថាថា ភិក្ខុកាលចេញដើរទៅ គិតថា អាត្មាអញនឹងត្រឡប់មក រៀបចំទុកដាក់កម្រាលវិញក្នុងថ្ងៃនេះ លុះទៅដល់ទីដែលខ្លួនប្រាថ្នានឹងទៅនៅនោះ ក៏មានសេចក្តី អន្តរាយកើតឡើង មិនអាចនឹងត្រឡប់មកវិញបាន ។

# អដ្ឋកថា

## ភូតគាមវគ្គ

## ទុតិយសេនាសនសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសេនាសនសិក្ខាបទដូចតទៅនេះថា

[ ៣៧៩ ] ពូកគ្រែក្តី ពូកតាំងក្តី ឈ្មោះថា ពូក ។ កម្រាល មានកម្រាលរក្សាជីជាដើម មានប្រការដូចពោលហើយក្នុងសិក្ខាបទមុននោះឯង ។ សំពត់ក្រាលអង្គុយមានជាយ គប្បីជ្រាបថា **និសីទន** ។ លោកពោលពាក្យមានប្រមាណប៉ុណ្ណេះថា សំពត់បាវារ សំពត់កោជវៈ ( ព្រំ ) ឈ្មោះថា **បច្ចត្ថរណា** ។

គ្រឿងកម្រាលស្មៅប្រភេទណាមួយ ឈ្មោះថា **តិណសណ្ឋារោ** ។ ក្នុងគ្រឿងកម្រាលធ្វើដោយស្លឹកឈើ ក៏មានន័យដូច្នេះ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃទុតិយសេនាសនសិក្ខាបទ

[ ៣៨០ ] ក្នុងបទថា **បរិក្ខេបំ អតិក្កាមេន្តស្ស** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលឈានជំហានទី ១ ទៅ ត្រូវអាបត្តិបាចិត្តិយក្នុងជំហានទី ២ ។ ពីរលេឌ្ឌុបាតអំពីសេនាសនៈ ឈ្មោះថា ឧបចារៈនៃអារាមដែលមិនមានរបង ។

# អធិប្បាយ
## បទភាជនីយនៃទុតិយសេនាសនសិក្ខាបទ

[ ៣៨១ ] ក្នុងបទថា **អនាបុច្ឆំ វា គច្ឆេយ្យ** នេះ គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះថា កាលមានភិក្ខុគប្បីលាភិក្ខុ ។ បើមិនមានភិក្ខុគប្បីលាសាមណេរ បើសាមណេរមិនមាន គប្បីលាញោមវត្ត បើញោមវត្តមិនមានគប្បីលាម្ចាស់របស់វិហារ អ្នកកសាងវត្ត ឬបុគ្គលណាមួយ ក្នុងវង្សត្រកូលរបស់បុគ្គលនោះ ។ បើម្ចាស់របស់វិហារក្តី អ្នកកើតក្នុងវង្សត្រកូលរបស់បុគ្គលនោះមិនមានក្តី ភិក្ខុគប្បីដាក់គ្រែលើថ្ម ៤ ដុំ ហើយលើកគ្រែ តាំងដ៏សេសឡើងដាក់លើគ្រែនោះ រួមទាំងទីដេក ១០ យ៉ាង មានពូកជាដើម គរទុកខាងលើ ហើយទុកដាក់ភណ្ឌៈឈើ ភណ្ឌៈដី បិទទ្វារ និងបង្អួច បំពេញគមិកវត្ត ហើយសឹមទៅ ។

បើសេនាសនៈ ភ្លៀងលិចស្រោចបាន ហើយស្មៅ ឬឥដ្ឋដែលគេនាំមកដើម្បីប្រក់ក៏មាន បើអាចក៏គប្បីប្រក់ ។ បើមិនអាចគប្បីទុកគ្រែ និងតាំងក្នុងឱកាសដែលភ្លៀងមិនលិចស្រោច ហើយសឹមទៅ ។ បើសេនាសនៈភ្លៀងលិចទាំងអស់ បើអាចគប្បីទុកក្នុងផ្ទះរបស់ពួកឧបាសកខាងក្នុងស្រុក ។ បើពួកឧបាសកទាំងនោះមិនព្រមទទួល ពោលថា បពិត្រលោកម្ចាស់ ធម្មតារបស់សង្ឃជាគរុភណ្ឌ ពួកខ្ញុំខ្លាចភ័យ មានភ្លើងឆេះជាដើម ដូច្នេះ ភិក្ខុទោះដាក់គ្រែលើដុំថ្ម សូម្បីក្នុងឱកាសកណ្តាលវាល ហើយទុកដាក់តាំងជាដើមដ៏សេស ដោយន័យដូចពោលហើយពីមុននោះឯង យកស្មៅទាំងឡាយ និងស្លឹកឈើបិទបាំង ហើយសឹមទៅ ក៏គួរ ។ ពិតហើយ របស់ដែលនៅសល់

ក្នុងទីនោះ សូម្បីត្រឹមតែបម្រៀកនៃចំណែកខ្លះ ( នៃគ្រែ ) ក៏ចាត់ជាឧបការៈ ដល់ពួកភិក្ខុដទៃដែលមកក្នុងទីនោះ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **វិហារស្ស ឧបចារេ** ជាដើម ដូច្នេះថា បរិវេណ ឈ្មោះថា ឧបចារៈនៃវិហារ ។ រោងឆាន់ដែលគេសាងទុកក្នុង បរិវេណ ឈ្មោះថា ឧបដ្ឋានសាលា បារាំដែលគេសាងទុកនៅក្នុងបរិវេណ ឈ្មោះថា មណ្ឌប ។ គល់ឈើក្នុងបរិវេណ ឈ្មោះថា រុក្ខមូល ។ នេះជា ន័យដែលលោកពោលទុកក្នុងអដ្ឋកថាកុរុន្ទីមុន ។ លោកពោលន័យទុកហើយ ពិត សូម្បីដូច្នោះ បន្ទប់ខាងក្នុងក្តី សេនាសនៈដែលការពារបានក្តី បាំងទាំង អស់ឯណាមួយក្តី គប្បីជ្រាបថា ជាវិហារ ។

ពីរបទថា **វិហារស្ស ឧបចារេ** បានដល់ ក្នុងឱកាសខាងក្រៅជិតវិហារ នោះ ។ បទថា **ឧបដ្ឋានសាលាយំ វា** បានដល់ ក្នុងរោងឆាន់ក្តី ។

បទថា **មណ្ឌបេ វា** បានដល់ មណ្ឌបដែលជាទីប្រជុំនៃមនុស្សច្រើន ដែលមិនបានបាំងក្តី បាំងក្តី ។ ក្នុងគល់ឈើមិនមានពាក្យដែលគប្បីពោល ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្តីថា ព្រោះកាលភិក្ខុក្រាលទីដេក ១០ យ៉ាង មានប្រការដូចពោលហើយខាងក្នុងបន្ទប់ជាដើម និងក្នុងទីការពារ បាន ហើយទៅ ទីដេកក្តី សេនាសនៈក្តី រមែងវិនាស ព្រោះកណ្តៀរជាដើម នឹងក្លាយជាដំបូកកណ្តៀរទៅនោះឯង ដូច្នោះ ទើបលោកកាត់អាបត្តិបាចិត្តិយ តែសម្រាប់ភិក្ខុដែលក្រាលទុកក្នុងទីមានឧបដ្ឋានសាលាជាដើមខាងក្រៅហើយ ទៅ គ្រាន់តែទីដេកប៉ុណ្ណោះបាត់បង់ទៅ ព្រោះជាកន្លែងដែលការពារមិនបាន

សេនាសនៈមិនវិនាស ។ ព្រោះដូច្នោះ ទើបលោកកាត់អាបត្តិទុក្កដ ក្នុងឧបដ្ឋានសាលាជាដើមនេះ ។

វិនិច្ឆ័យក្នុងបទថា **មញ្ចំ វា បីឋំ វា** ជាដើមនេះ គប្បីជ្រាបដូច្នេះថា ព្រោះកណ្ដៀរទាំងឡាយ មិនអាចស៊ីគ្រែ និងតាំងភ្លាមៗ ឡើយ ដូច្នោះ ភិក្ខុទុកគ្រែតាំងនោះ ក្នុងវិហារ ហើយទៅ លោកក៏កាត់អាបត្តិទុក្កដ ។ ឯក្នុងឧបចារៈនៃវិហារ ពួកភិក្ខុ កាលត្រាច់ពិនិត្យមើលវិហារ ឃើញគ្រែ និងតាំងនោះហើយ គប្បីទុកដាក់ ។

## អនាបត្តិនៃទុតិយសេនាសនៈសិក្ខាបទ

[ ៣៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧទ្ធរិត្វា គច្ឆតិ** នេះ ដូច្នេះថា ភិក្ខុកាលទុកដាក់ឯង ហើយទៅ គប្បីរើយកគ្រឿងត្បាញរបស់គ្រែ និងតាំងចេញ អស់ហើយ រុំព្យួរទុកលើស្នួចីវរ ហើយសឹមទៅ សូម្បីភិក្ខុដែលមកនៅខាងក្រោយ ចងគ្រែ និងតាំងជាថ្មី កាលនឹងទៅ ក៏គប្បីធ្វើយ៉ាងនោះដូចគ្នា ។ ភិក្ខុដែលក្រាលទីដេកអំពីខាងក្នុងជញ្ជាំង ទៅដល់ខាងក្រៅជញ្ជាំង ហើយនៅក្នុងវេលានឹងទៅ គប្បីទុកដាក់ក្នុងទីដែលខ្លួនកាន់យកពីមុននោះឯង ។ បើភិក្ខុលើកចុះមកអំពីជាន់លើនៃប្រាសាទ ហើយនៅខាងក្រោមប្រាសាទ ក៏មានន័យនេះឯង ។ ភិក្ខុនឹងរៀបចំគ្រែ តាំង ទុកក្នុងទីសម្រាកពេលថ្ងៃ និងទីសម្រាក ពេលយប់ហើយ ក្នុងវេលាចេញទៅ គប្បីទុកក្នុងទីដើម ក្នុងទីដែលខ្លួនយកមកនោះឯង ។

ក្នុងបទថា **អាបុច្ឆំ គច្ឆតិ** នេះ មានវិនិច្ឆ័យទីគួរលោ និងមិនគួរលោ

ដូចតទៅនេះថា សាលាណា ជាសាលាវែងក្តី ជាសាលាស្លឹកឈើក្តី នៅលើផែនដី ឬក៏ផ្ទះដែលគេសាងលើសសរឈើទាំងឡាយណាមួយ ជាទីដែលកណ្តៀរឡើងបាន ភិក្ខុកាលចៀសចេញទៅអំពីសាលាវែងជាដើមនោះ គប្បីលាជាមុន ហើយសឹមចៀសចេញទៅ ព្រោះថា ទីនោះមិនមានបុគ្គលណាបដិបត្តិត្រឹម ២-៣ ថ្ងៃ កណ្តៀរទាំងឡាយ រមែងតាំងឡើង ។

ឯសេនាសនៈណា ជាសេនាសនៈដែលគេធ្វើទុកលើថ្មដា ឬលើសសរថ្មក្តី គុហាត្រង់ភ្នំថ្មក្តី សេនាសនៈដែលបូកដោយបាយអក្តី ក្នុងសេនាសនៈណាមិនមានការសង្ស័យ ក្នុងរឿងកណ្តៀរ កាលភិក្ខុចៀសចេញទៅអំពីទីនោះ ទោះពោលលាក្តី មិនពោលលាក្តី ហើយទៅ ក៏គួរ តែការលាជាទំនៀម ( របស់អ្នកទៅ ) បើកណ្តៀរទាំងឡាយឡើងតាមផ្លូវណាមួយក្នុងសេនាសនៈដូច្នោះបាន គួរលាជាមុន ហើយសឹមទៅ ។

ឯអាគន្តុកភិក្ខុណា ប្រព្រឹត្តតាមភិក្ខុដែលកាន់សេនាសនៈនៃសង្ឃ មិនកាន់សេនាសនៈសម្រាប់ខ្លួននៅ សេនាសនៈនោះ ជាធុរៈរបស់ភិក្ខុរូបមុននោះឯង ដរាបណា ភិក្ខុនោះមិនទាន់កាន់ ( សេនាសនៈសម្រាប់ខ្លួន ) ។ បើចាប់ពីភិក្ខុនោះកាន់យកសេនាសនៈហើយ នៅដោយឥស្សរៈរបស់ខ្លួន ជាធុរៈនៃភិក្ខុអាគន្តុកៈនោះឯង ។ បើទាំងពីរអង្គចែកគ្នា ហើយកាន់យក ជាធុរៈរបស់លោកទាំងពីរអង្គនោះឯង ។

តែក្នុងមហាបច្ចរីពោលទុកថា បើភិក្ខុ ២-៣ អង្គ រួមគ្នារៀបចំ ក្នុងវេលាទៅ គួរលាគ្រប់អង្គ ។ បើបណ្តាភិក្ខុទាំងនោះ អង្គណាមួយទៅមុន ធ្វើ

ការចងចិត្តថា អន្តក្រោយនឹងបដិបត្តិ ហើយទៅ រមែងសមគួរ ។ ការផុត ( អំពីអាបត្តិ ) រមែងមិនមានដល់ភិក្ខុអន្តក្រោយ សូម្បីចងចិត្តទុក ។ ភិក្ខុច្រើនរូបបញ្ជូនភិក្ខុមួយរូបឲ្យទៅក្រោល ។ ក្នុងវេលាចេញទៅ ភិក្ខុទាំងអស់គប្បីលា ឬគប្បីបញ្ជូនភិក្ខុមួយរូបទៅលា ។ ភិក្ខុនាំយកគ្រែ និងតាំងជាដើមមកអំពីទីដទៃ សូម្បីនៅក្នុងទីដទៃ ក្នុងវេលាចេញទៅ គប្បីនាំទៅទុកត្រង់ទីដើមវិញនោះឯង ។ បើភិក្ខុនាំមកអំពីទីដទៃ ហើយប្រើប្រាស់ ភិក្ខុដទៃដែលចាស់ជាងមកដល់ គប្បីហាមលោក គប្បីប្រាប់ថា បពិត្រលោកម្ចាស់ គ្រែតាំង ខ្ញុំនាំមកអំពីអាវាសដទៃ លោកម្ចាស់គប្បីធ្វើឲ្យដូចប្រក្រតីដើម ។ កាលភិក្ខុចាស់ជាងនោះទទួលថា ខ្ញុំនឹងធ្វើយ៉ាងនោះ ដូច្នេះ ភិក្ខុនេះចេញទៅក៏គួរ ។ ពិតហើយ កាលភិក្ខុនាំទៅក្នុងទីដទៃយ៉ាងនេះ ប្រើប្រាស់ដូចប្រើជារបស់សង្ឃ គ្រែ និងតាំងនោះ វិនាសទៅក្តី ចាស់គ្រាំគ្រាទៅក្តី ត្រូវពួកចោរលួចទៅក្តី មិនជាភណ្ឌទេយ្យឡើយ ។ តែបើភិក្ខុប្រើប្រាស់ជារបស់បុគ្គល រមែងជាភណ្ឌទេយ្យ ។ ម្យ៉ាងទៀត ភិក្ខុប្រើប្រាស់គ្រែ តាំងរបស់អ្នកដទៃ ដូចប្រើជារបស់សង្ឃក្តី ដូចប្រើជារបស់បុគ្គលក្តី គ្រែ តាំង វិនាសទៅជាភណ្ឌ-ទេយ្យ ដូចគ្នា ។

បទថា **កេនចិ បលិពុទ្ធំ ហោតិ** សេចក្តីថា សេនាសនៈមានហេតុឯណាមួយ បណ្តាហេតុ មានភិក្ខុចាស់ជាង ឥស្សរជន យក្ខ សីហៈ ពាឡ-ម្រឹគ និងពស់វែកជាដើមពាំង ។

ក្នុងបទថា **សាបេក្ខោ គន្ត្វា តត្ថ ឋិតោ អាបុច្ឆតិ កេនចិ បលិ-**

**ពុទ្ធោ ហោតិ** គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុនៅមានអាល័យយ៉ាងនេះថា អញ នឹងមកបដិបត្តិក្នុងថ្ងៃនេះឯង ទៅកាន់ប្រាំងស្ទឹង ឬចន្លោះស្រុក ហើយឈរក្នុងទីដែលលោកកើតគំនិតគិតនឹងទៅនោះឯង បញ្ជូនបុគ្គលណាមួយទៅលា ឬមានហេតុឯណាមួយ បណ្ដាហេតុ មានទឹកឡើងប្រៀបប្រាំង ព្រះរាជា និងចោរជាដើមរាំង ភិក្ខុត្រូវអន្តរាយរាំង មិនអាចត្រឡប់មកបាន ដោយហេតុដូចពោលនេះ ជាអនាបត្តិដល់ភិក្ខុនោះ ។ បទដ៏សេសព្រមទាំងសមុដ្ឋានជាដើម មានន័យដូចពោលហើយ ក្នុងបឋមសេនាសនសិក្ខាបទនោះឯង ។

ទុតិយសេនាសនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[ ១ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ បៀតបៀនយកទីដេកល្អៗ ញុំាងភិក្ខុទាំងឡាយឲ្យក្រោកចេញទៅ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា យើងទាំងឡាយនៅចាំវស្សានៅក្នុងទីនេះដោយឧបាយដូចម្តេចហ្ន៎ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅដេកជ្រៀតបៀត ភិក្ខុចាស់ទាំងឡាយ ដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីនឹងចូល ទៅដេកជ្រៀតបៀតពួកភិក្ខុចាស់សោះ ។ ទើបភិក្ខុទាំងនោះ នាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នករាល់គ្នាចូលទៅដេកជ្រៀតបៀតភិក្ខុចាស់ទាំងឡាយពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯង មិនគួរនឹងចូលទៅដេកជ្រៀតបៀតពួកភិក្ខុចាស់សោះឡើយ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយ ចូលទៅជ្រៀតបៀតនូវភិក្ខុដែលចូលទៅនៅមុនហើយ សម្រេចនូវ

ទីដេក ក្នុងវិហាររបស់សង្ឃ ដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រោះធ្វើនូវសេចក្តីជ្រៀតបៀតនោះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ ។

[២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ វិហារដែលគេលះប្រគេនដល់សង្ឃ ហៅថា វិហាររបស់សង្ឃ ។ ដែលហៅថា ដឹង គឺ ភិក្ខុដឹងថា ភិក្ខុនេះចាស់ ដឹងថា ភិក្ខុនេះឈឺ ដឹងថា វិហារនេះសង្ឃបានឲ្យហើយ ។ ពាក្យថា ចូលទៅជ្រៀតបៀត គឺចូលទៅជ្រៀតជ្រែក ។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក ក្នុងឧបចារៈ[១] នៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ( លើទីដេកនោះ ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវសេចក្តីជ្រៀតបៀតនេះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ សេចក្តីថា គ្មានហេតុដទៃនីមួយ ដែលក្រៅពីការចូលទៅដេកជ្រៀតបៀតនោះឡើយ ។

[៣] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា វិហាររបស់សង្ឃមែន ហើយចូលទៅដេកជ្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយចូលទៅដេកជ្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា របស់បុគ្គលវិញ ហើយចូលទៅដេកជ្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក វៀរលែងតែឧបចារៈនៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ។

---

១-ឧបចារៈគ្រែ និងតាំង តាមអដ្ឋកថា ថាកំណត់ពីរហត្ថមួយចំអាម ។

ភិក្ខុអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុក្រាល ឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក ក្នុងឧបចារៈនៃវិហារក្តី ក្នុងឧបដ្ឋាននៃ សាលាក្តី[១] ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថារបស់សង្ឃ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថារបស់បុគ្គល ដទៃ ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គល គឺ វិហារនៃភិក្ខុដទៃ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់បុគ្គល គឺ វិហាររបស់ខ្លួនឯង ។

[៤] អាបត្តិមិនមានដល់ភិក្ខុដែលមានជំងឺចូលទៅក្តី ដល់ភិក្ខុដែលត្រូវត្រជាក់ ឬក្តៅបៀតបៀន ហើយចូលទៅក្តី ដល់ភិក្ខុមានសេចក្តីអន្តរាយក្តី ដល់ភិក្ខុឆ្កួតក្តី ដល់ភិក្ខុដើមបញ្ញត្តិក្តី ។

សិក្ខាបទទី ៦ ចប់

---

[១] ប្រែថា សាលាសម្រាប់បម្រើ តែអដ្ឋកថាថា បានដល់ សាលាសម្រាប់ឆាន់ ឬរោងឆាន់ ។

# អដ្ឋកថា

## ភូតគាមវគ្គទី ២

## អនុបខជ្ជសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូចតទៅនេះ

[១] បទថា **បលិពុទ្ធន្តិ** សេចក្តីថា ពួកឆព្វគ្គិយភិក្ខុទៅដល់មុន ជញ្ជូនបាត្រ និងចីវរទៅឈរពាំង ។

បទថា **ថេរេ ភិក្ខូ វុឌ្ឍាបេន្តិ** សេចក្តីថា កាន់យកតាមលំដាប់វស្សាហើយពោលថា លោកដ៏មានអាយុ ( ទីនេះ ) គួរដល់ពួកខ្ញុំ ដូច្នេះហើយឲ្យផ្លាស់ចេញទៅទីដទៃ ។

បទថា **អនុបខជ្ជ សេយ្យំ កប្បេន្តិ** សេចក្តីថា ពួកឆព្វគ្គិយភិក្ខុចូលទៅជ្រៀតជ្រៀតពោលថា បពិត្រលោកម្ចាស់ ចំពោះទីគ្រែប៉ុណ្ណោះសមគួរដល់ពួកលោក មិនមែនវិហារទាំងអស់ទេ ឥឡូវនេះ ទីនេះគួរបានពួកខ្ញុំ ដូច្នេះរៀបចំគ្រែ និងតាំង ហើយអង្គុយខ្លះ ដេកខ្លះ ធ្វើការស្វាធ្យាយខ្លះ ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃអនុបខជ្ជសិក្ខាបទ

[២] បទថា **ជានំ** បានដល់ ដឹងថា ភិក្ខុនេះមិនគួរត្រូវផ្លាស់ទីកន្លែង ។ ដោយហេតុនោះឯង ក្នុងវិភង្គ គឺការបែកនៃបទថា **ជានំ** នោះ ទើបព្រះមានព្រះភាគត្រាស់បទជាដើមថា **វុឌ្ឍោតិ ជានាតិ** ប្រែថា ដឹងថា ជាព្រះថេរៈចាស់ ពិតហើយ ភិក្ខុចាស់ ជាអ្នកមិនគួរផ្លាស់ទៅទីដទៃ ព្រោះជាអ្នកចាស់

*ជរា ភិក្ខុអ្នកមានអាពាធ ក៏ជាអ្នកមិនគួរផ្លាស់ ព្រោះជាអ្នកអាពាធ ។ សង្ឃកំណត់ភាពជាអ្នកមានឧបការៈ និងភាពជាអ្នកមានគុណវិសេសនៃភណ្ឌាគារិកភិក្ខុក្ដី នៃធម្មកថិកភិក្ខុ និងវិនយធរជាដើមក្ដី នៃភិក្ខុដែលជាអាចារ្យបង្រៀនគណៈក្ដី ទើបសន្មតវិហារឲ្យ ដើម្បីឲ្យនៅជាប្រចាំ ។ ព្រោះហេតុនោះ សង្ឃឲ្យវិហារដល់ភិក្ខុណា ភិក្ខុនោះ ឈ្មោះថា ជាអ្នកមិនគួរឲ្យផ្លាស់កន្លែង ។ ក្នុងបទថា* **វុឌ្ឍោតិ ជានាតិ** *ជាដើមនេះ សង្ឃប៉ុណ្ណោះនឹងឲ្យសេនាសនៈដែលសមគួរដល់ភិក្ខុអាពាធក៏ពិត សូម្បីដូច្នោះ ភិក្ខុអាពាធក៏ចែកទុកមួយផ្នែក ដើម្បីសម្ដែងថា ជាអ្នកមានសេនាសនៈដែលសង្ឃមិនទាន់អបលោកឲ្យ ក៏មិនគួរបៀតបៀន គួរអនុគ្រោះ ដូច្នេះ ។*

## អធិប្បាយ

## បទភាជនីយនៃអនុប្បខជ្ជសិក្ខាបទ

[៣] *ក្នុងបទថា* **ឧបចារំ** *នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ១ ហត្ថ ១ ចំអាមដោយជុំវិញក្នុងវិហារធំ ឈ្មោះថា ឧបចារៈនៃគ្រែ និងតាំង ។ ក្នុងវិហារតូច ១ ហត្ថ ១ ចំអាមអំពីទីដែលអាចរៀបចំគ្រែតាំងបាន ( ឈ្មោះថា ឧបចារៈនៃគ្រែតាំង ) ។ ផ្លូវ ១ ហត្ថ ១ ចំអាម ចាប់ពីទីដាក់ជុំថ្មសម្រាប់លាងជើង ដែលដាក់ត្រង់ទ្វារ និងទីបន្ទោបង់បស្សាវៈ សម្រាប់ភិក្ខុដែលលាងជើងចូលទៅ និងភិក្ខុដែលចេញទៅដើម្បីបន្ទោបង់បស្សាវៈ រហូតដល់គ្រែ និងតាំង ឈ្មោះថា ឧបចារៈ ។ ភិក្ខុណាប្រាថ្នានឹងសម្រេចការដេកជ្រៀតបៀត ក្រាលឯងក្ដី ឲ្យអ្នកដទៃក្រាលក្ដី នូវទីដេកក្នុងឧបចារៈនៃភិក្ខុ*

ដែលឈរនៅត្រង់ឧបចារៈនៃគ្រែក្តី តាំងនោះក្តី ដែលចូល ឬចេញក្តី ភិក្ខុនោះត្រូវ អាបត្តិទុក្កដ ។

ក្នុងបទថា **អភិនិសីទតិ វា អភិនិបជ្ជតិ វា** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិបាចិត្តិយ ដោយគ្រាន់តែអង្គុយសង្កត់ខ្លះ ព្រោះហេតុត្រឹមតែដេកលើខ្លះ បើភិក្ខុធ្វើការអង្គុយ និងការដេកទាំងពីរយ៉ាង ត្រូវអាបត្តិបាចិត្តិយ ២ ។ កាលក្រោក ហើយអង្គុយ ឬក្រោក ហើយដេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ប្រយោគ ។

បណ្ឌិតគប្បីជ្រាបប្រភេទនៃទុក្កដ សូម្បីក្នុងទុក្កដវារៈ មានបទថា **វិហារស្ស ឧបចារេ** ដូច្នេះជាដើម ក្នុងបទថា **ឧបចារំ ឋបេត្វា សេយ្យំ សន្ថរតិ វា សន្ថរាបេតិ វា** នេះ និងពាក្យដទៃក្រៅអំពីនេះ ដូចជា ប្រភេទនៃអាបត្តិបាចិត្តិយ ដែលត្រាស់ទុកក្នុងការធ្វើកិច្ចទាំង ២ គឺអង្គុយសង្កត់ និងដេកសង្កត់ ក្នុងបទថា **អភិនិសីទតិ វា អភិនិបជ្ជតិ វា** នេះ និងក្នុងប្រភេទនៃប្រយោគដូច្នោះ ។ ព្រោះមិនត្រូវការដោយវិសភាគបុគ្គល ដូច្នេះ នៅក្នុងវិហារជាមួយគ្នា ឬក្នុងបរិវេណជាមួយគ្នា ដូច្នោះ ទើបលោកហាមការនៅនៃវិសភាគបុគ្គលនោះ ក្នុងទីគ្រប់អន្លើនោះឯង ។

សូម្បីក្នុងបទថា **អញ្ញស្ស បុគ្គលិកេ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សេនាសនៈផ្ទាល់ខ្លួននៃបុគ្គលដែលស្និទ្ធស្នាលគ្នា ដូចគ្នានឹងរបស់ផ្ទាល់ខ្លួននៃខ្លួនដូចគ្នា មិនត្រូវអាបត្តិក្នុងសេនាសនៈផ្ទាល់ខ្លួនបុគ្គលរបស់អ្នកស្និទ្ធស្នាលគ្នានោះ ។

[ ៤ ] បទថា **អាបទាសុ** សេចក្តីថា បើមានអន្តរាយនៃជីវិត និង ព្រហ្មចរិយៈដល់ភិក្ខុដែលនៅខាងក្រៅ ព្រោះអន្តរាយមានសភាពបែបនោះ មិនត្រូវអាបត្តិដល់ភិក្ខុដែលចូលទៅ ( ខាងក្នុង ) ។ បទដ៏សេសរាក់ទាំង អស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា ជាសញ្ញា-វិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសលចិត្ត ជាទុក្ខ-វេទនា ដូច្នេះឯង ។

អនុប្បខជ្ជសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ៥ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុ ( ភិក្ខុមានពួក ១៧ រូប ) នាំគ្នាជួសជុលវិហារធំមួយ មាននៅក្នុងបច្ចន្តប្រទេស ដោយគិតគ្នាថា យើងទាំងឡាយនឹងនៅចាំវស្សា ក្នុងទីនេះ ។ ពួកឆព្វគ្គិយភិក្ខុ ( ភិក្ខុមានពួក ៦ រូប ) បានឃើញពួកសត្តរសវគ្គិយភិក្ខុនាំគ្នាជួសជុលវិហារ លុះឃើញហើយ បាននិយាយគ្នាយ៉ាងនេះថា ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុនេះ នាំគ្នាជួសជុលវិហារ បើដូច្នោះ យើងទាំងឡាយនឹងធ្វើឲ្យភិក្ខុទាំងនោះចៀសចេញទៅ ។ ឆព្វគ្គិយភិក្ខុពួកខ្លះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សូមលោកទាំងឡាយបង្អង់ចាំឲ្យសត្តរសវគ្គិយភិក្ខុទាំងឡាយ ជួសជុលវិហាររួចសិន លុះជួសជុលស្រេចហើយ យើងទាំងឡាយនឹងធ្វើភិក្ខុទាំងនោះឲ្យចៀសចេញទៅ ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុបាននិយាយពាក្យនេះនឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ ហេតុដូចម្តេច ក៏ពួកលោកមិនប្រាប់យើងជាមុនសិន យើងទាំងឡាយនឹងបានជួសជុលវិហារឯទៀតវិញ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ ក្រែងវិហារនោះជារបស់សង្ឃទេដឹង ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា អើអាវុសោ វិហារជារបស់សង្ឃ ។

ពួកឆព្វគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារជាវិហារធំ ពួកលោកក៏នៅបាន ពួកយើងក៏នៅបាន ពួកឆព្វគ្គិយភិក្ខុ និយាយដដែលទៀតថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ហើយមានចិត្តកម្រើកខឹងឡើង នាំគ្នាចាប់ក កន្ត្រាក់ ទាញចេញទៅ ។ ពួកសត្តរសវគ្គិយភិក្ខុនោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុ កន្ត្រាក់កទាញចេញ ក៏នាំគ្នាយំ ។ ទើបភិក្ខុទាំងឡាយ ( ភិក្ខុដទៃចាកភិក្ខុ ពីរពួកនោះ ) បាននាំគ្នាសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាពួក លោកយំ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា ម្នាលអាវុសោ ឆព្វគ្គិយ ភិក្ខុទាំងនេះ មានចិត្តកម្រើកខឹង នាំគ្នាបណ្តេញពួកយើងចេញចាកវិហាររបស់ សង្ឃ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំង-ឡាយនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសម បីនឹងមានចិត្តក្រោធខឹង ទន់ទាញភិក្ខុទាំងឡាយ ចេញចាកវិហាររបស់សង្ឃ សោះ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់សួរពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំង-ឡាយ ឮថា អ្នកទាំងឡាយមានចិត្តក្រោធខឹង ទន់ទាញភិក្ខុទាំងឡាយចេញ ចាកវិហារជារបស់សង្ឃ មែនឬទេ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូម ទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀល ថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបីនឹងមានចិត្តក្រោធ

ខឹង ទង់ទាញភិក្ខុទាំងឡាយ ចេញចាកវិហាររបស់សង្ឃសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយមានចិត្តក្រោធខឹងនឹងភិក្ខុផងគ្នា ហើយទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ចេញចាកវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

[៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ ។ ពាក្យថា មានចិត្តក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តដែលទោសៈកម្ចាត់បង់ មានចិត្តរឹងរូស ។

[៧] វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ឈ្មោះថា វិហាររបស់សង្ឃ ។ ពាក្យថា ទង់ទាញឯង គឺ ភិក្ខុចាប់យកពីក្នុងបន្ទប់ ហើយទង់ទាញទៅឯរបៀងវិហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុចាប់យកពីក្នុងរបៀង ហើយទង់ទាញទៅខាងក្រៅ ក៏ត្រូវអាបត្តិបាចិត្តិយ ។ ទុកជាភិក្ខុទង់ទាញភិក្ខុឲ្យកន្លងទ្វារទាំងឡាយជាច្រើន តែដោយប្រយោគមួយក៏ត្រូវអាបត្តិបាចិត្តិយតែមួយ ។ ពាក្យថា ប្រើគេឲ្យទង់ទាញនោះ គឺបង្គាប់អ្នកដទៃ ( ភិក្ខុអ្នកបង្គាប់នោះ ) ក៏ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែវារៈម្តង អ្នកទទួលបង្គាប់ទៅទង់ទាញភិក្ខុដទៃឲ្យកន្លងទ្វារសូម្បីច្រើន ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ ។

[៨] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថាជារបស់សង្ឃដដែល ហើយ

មានចិត្តក្រោធខឹង ទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយមានចិត្តក្រោធខឹង ទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថាជារបស់បុគ្គលទៅវិញ ហើយមានចិត្តក្រោធខឹង ទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី នូវបរិក្ខាររបស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី នូវភិក្ខុឲ្យចាកឧបចារៈនៃវិហារក្តី ចាកឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្លប់ឈើក្តី ចាកទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី នូវបរិក្ខារនៃភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី នូវអនុបសម្បន្នឲ្យចាកវិហារក្តី ចាកឧបចារៈនៃវិហារក្តី ចាកឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្លប់ឈើក្តី ចាកទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទន់ទាញឯងក្តី ប្រើគេឲ្យទន់ទាញក្តី នូវបរិក្ខាររបស់អនុបសម្បន្នោះ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថា ជារបស់សង្ឃ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថាជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ព្រោះវិហារជារបស់បុគ្គលនៃភិក្ខុដទៃ គឺ វិហាររបស់គេ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់បុគ្គលនៃខ្លួន គឺ វិហាររបស់ខ្លួនឯង ។

[ ៩ ] អាបត្តិមិនមានដល់ភិក្ខុដែលទន់ទាញឯង ឬប្រើគេឲ្យទន់ទាញនូវ

ភិក្ខុអលជ្ជី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញ នូវបរិក្ខាររបស់ភិក្ខុអលជ្ជីនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុឆ្កួត ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុឆ្កួតនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុជាអ្នកធ្វើនូវសេចក្ដីបង្កហេតុក្ដី អ្នកធ្វើនូវសេចក្ដីប្រកួតប្រកាន់ក្ដី អ្នកធ្វើនូវសេចក្ដីទាស់ទែងក្ដី អ្នកធ្វើនូវ ពាក្យឡេះឡោះតាមតែរួចពីមាត់ក្ដី[១] អ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃក្ដី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុនោះចេញ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវអន្តេវាសិក ឬសទ្ធិវិហារិក ដែលប្រព្រឹត្តមិនត្រឹមត្រូវ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់អន្តេវាសិក ឬសទ្ធិវិហារិក ដែលប្រព្រឹត្តមិនត្រឹមត្រូវនោះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

---

១- ពោលពាក្យជាតិរច្ឆានកថា ឬនិយាយសរសើរពីស្រី និងប្រុសជាដើម ។ តាមន័យអដ្ឋកថា

# អដ្ឋកថា

## ភូតគាមវគ្គទី ៨

## និក្កឌ្ឍនសិក្ខាបទ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូចតទៅនេះ*

## អធិប្បាយ

## សិក្ខាបទវិភង្គនៃនិក្កឌ្ឍនសិក្ខាបទ

*[៧] បទថា* **ឯកេន បយោគេន អហុកេបិ ទ្វារេ អតិក្កាមេតិ** *សេចក្តីថា ក្នុងសេនាសនៈទាំងឡាយ ទោះជាប្រាសាទ ៤-៥ ជាន់ក្តី សាលា ៤ មុខមានខ្លោងទ្វារ ៦-៧-៨ ក្តី ភិក្ខុចាប់ដើមដៃទាំង ២ ក្តី ត្រង់កក្តី ឲ្យឈានចេញទៅដោយប្រយោគមួយ មិនសម្រាកក្នុងចន្លោះ ត្រូវអាបត្តិបាចិត្តិយ ១ ប៉ុណ្ណោះ កាលអូសសម្រាកៗ ឲ្យឈានចេញទៅ ដោយប្រយោគផ្សេងៗ ត្រូវអាបត្តិបាចិត្តិយជាច្រើន តាមចំនួនទ្វារ ។ កាលមិនយកដៃចាប់អូស ឬទាញ ដេញទៅដោយវាចា ពោលថា ចូរចេញទៅ ក៏មានន័យដូច្នេះ ។*

*វិនិច្ឆ័យក្នុងបទថា* **អញ្ញំ អណាបេតិ** *នេះ គប្បីជ្រាបដូច្នេះថា គ្រាន់តែប្រើថា ចូរអូសភិក្ខុនេះចេញទៅ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុដែលបានទទួលប្រើតែម្តងនោះ ឲ្យឈានផុតទ្វារ ច្រើនកន្លែង ក៏ត្រូវអាបត្តិបាចិត្តិយ ១ ប៉ុណ្ណោះ បើភិក្ខុដែលទទួលប្រើកំណត់យ៉ាងនេះថា ចូរអូសចូងទ្វារនេះចេញទៅក្តី ចូរអូសរហូតដល់ទ្វារធំ ដូច្នេះក្តី ត្រូវអាបត្តិបាចិត្តិយ តាមចំនួនទ្វារ ។*

## អធិប្បាយ

## បទភាជនីយនៃនិក្កឌ្ឍនសិក្ខាបទ

[៨] ពីរបទថា **តស្ស បរិក្ខារំ** សេចក្តីថា ភិក្ខុណាជញ្ជូនចេញឯងក្តី ប្រើឲ្យជញ្ជូនចេញក្តី នូវរបស់ឯណាមួយ ដែលជារបស់ផ្ទាល់ខ្លួននៃភិក្ខុទាំងនោះ ដូចជា បាត្រ ចីវរ ធម្មក្រក គ្រែ តាំង ពូក និងខ្នើយជាដើម ដោយហោចសូម្បីកម្មេចល័ខ ត្រូវអាបត្តិទុក្កដដល់ភិក្ខុនោះជាច្រើនតាមចំនួននៃវត្ថុ ។ លោកពោលទុកក្នុងមហាបច្ចរីថា ក្នុងទ្រព្យទាំងនោះ ដែលម្ចាស់ទ្រព្យចងយ៉ាងណែន ជាអាបត្តិ ១ ប៉ុណ្ណោះ ។

វិនិច្ឆ័យក្នុងបទថា **អញ្ញស្ស បុគ្គលិកេ** នេះ គប្បីជ្រាបដូច្នេះថា របស់ផ្ទាល់ខ្លួននៃបុគ្គលអ្នកស្និទ្ធស្នាល ដូចគ្នានឹងរបស់ផ្ទាល់ខ្លួននៃខ្លួននោះឯង ។ ក្នុងទីគ្រប់អន្លើ អ្នកសិក្សាគប្បីជ្រាបន័យដូចក្នុងពាក្យនេះ ។ តែក្នុងទីណាដែលមានសេចក្តីប្លែកគ្នា យើងនឹងពោលទុកក្នុងទីនោះ ។

## អនាបត្តិនៃនិក្កឌ្ឍនសិក្ខាបទ

[៩] វិនិច្ឆ័យក្នុងពាក្យថា **អលជ្ជឹ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា** ជាដើម គប្បីជ្រាបដូច្នេះថា ភិក្ខុរមែងដេញភិក្ខុដែលបង្កជម្លោះ និងដែលធ្វើវិវាទដល់គ្នានឹងគ្នាប៉ុណ្ណោះ ចេញអំពីសង្ឃារាមទាំងមូល ។ ព្រោះថា លោកបានបក្ខពួកហើយ គប្បីបំបែកសង្ឃក៏បាន ។ ឯពួកភិក្ខុអលជ្ជីជាដើម ភិក្ខុគប្បីអូសទាញអំពីលំនៅរបស់ខ្លួនប៉ុណ្ណោះ បើដេញលោកទាំងនោះចេញអំពីសង្ឃារាមទៅ មិនគួរ ។

បទថា **ឧម្មត្តកស្ស** បានដល់ មិនត្រូវអាបត្តិដល់ភិក្ខុដែលឆ្កួត ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តក: ជាលោកវជ្ជ: ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះ ។

និក្កឌ្ឍនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ១០ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុ ២ រូប ១ រូប នៅថ្នាក់ខាងក្រោម ១ រូប នៅថ្នាក់ខាងលើ ក្នុងវិហាររបស់សង្ឃ ភិក្ខុដែលនៅខាងលើ អង្គុយចុះដោយរហ័ស សង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) ។ ជើងគ្រែ ( នោះ ) ក៏របូតធ្លាក់ចុះមកទង្គិចក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះបានស្រែកសំឡេងឮប្លែក ។ ភិក្ខុទាំងឡាយបានស្ទុះទៅសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីក៏លោកស្រែក ។ ភិក្ខុនោះបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបីនឹងមកអង្គុយចុះដោយរហ័ស សង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) លើថ្នាក់ក្នុងវិហាររបស់សង្ឃសោះ ទើបភិក្ខុទាំងឡាយនោះ នាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ឮថាអ្នកឯងអង្គុយចុះដោយរហ័សសង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) លើថ្នាក់ក្នុងវិហាររបស់សង្ឃ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងមកអង្គុយចុះដោយ

រហ័ស សន្ធត់គ្រែដែលមានជើងគ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) លើថ្នាក់ក្នុងវិហាររបស់សង្ឃទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលអ្នកមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ អង្គុយចុះដោយរហ័សសន្ធត់ ឬដេកសន្ធត់នូវគ្រែក្តី នូវតាំងក្តី ដែលមានជើង គ្រាន់តែស៊កទុក ( ដោយបណ្តោះអាសន្ន ) លើថ្នាក់ក្នុងវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

[១១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ហៅថា វិហាររបស់សង្ឃ ។

[១២] ធ្នើរ ( ដែលគេធ្វើខ្ពស់ ) មិនទង្គិចក្បាលមជ្ឈិមបុរស ហៅថា ថ្នាក់ ។ គ្រែដែលមានជើងគ្រាន់តែស៊កចូលក្នុងមេ ហើយតាំងទុក ហៅថា គ្រែដែលមានជើងគ្រាន់តែស៊កទុក ។ តាំងដែលមានជើងគ្រាន់តែស៊កចូលក្នុងមេ ហៅថា តាំងដែលមានជើងគ្រាន់តែស៊កទុក ។ ពាក្យថា អង្គុយសន្ធត់ គឺ ភិក្ខុអង្គុយសន្ធត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ដេកសន្ធត់ គឺ ភិក្ខុដេកសន្ធត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១៣] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា ជារបស់សង្ឃមែន ហើយ អង្គុយសន្ធត់ ឬដេកសន្ធត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ ( ដែលគេតាំងទុក ) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហារ

របស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ ( ដែលគេតាំងទុក ) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថា ជារបស់បុគ្គលវិញ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ ( ដែលគេតាំងទុក ) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថា ជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសម្គាល់ថា ជារបស់បុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គលនៃភិក្ខុដទៃ គឺវិហាររបស់គេ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់ខ្លួន គឺ វិហាររបស់ខ្លួនឯង ។

[ ១៤ ] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយ ឬដេកសង្កត់លើគ្រែក្តី តាំងក្តី ដែលគេតម្កល់ទុកលើទីដែលមិនមែនថ្នាក់ លើទីទាបដែលដើរទង្គិចក្បាល ទីដែលមិនបានប្រើប្រាស់ខាងក្រោមឲ្យជាទីនៅ ទីដែលគេក្រាលជិតដោយនោបលើគ្រែ ឬតាំងនោះដែលគេដាក់គន្លឹះហើយ ដល់ភិក្ខុដែលឈរនៅលើគ្រែ ឬតាំងនោះ ហើយកាន់យក ឬព្យួរនូវបរិក្ខារ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា

## ភូតគាមវគ្គទី ២

## វេហាសកុដិសិក្ខាបទ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ បទថា **ឧបរិវេហាសកុដិយា** បានដល់ លើកុដិ ២ ជាន់ក្តី លើកុដិ ៣ ជាន់ក្តី ដែលខាងលើមិនបានក្រាលផ្ទៃ ។

បទថា **មញ្ចំ សហសា អភិនិសីទតិ** បានដល់ អង្គុយសង្កត់ គឺអង្គុយអុកគ្រែដោយរហ័ស ។ ម្យ៉ាងទៀត បទថា **មញ្ចំ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ សេចក្តីថា អង្គុយលើគ្រែ ។ បទថា **អភិ** នេះ គ្រាន់តែជាឧបសគ្គ ដើម្បីធ្វើឲ្យបទមានលម្អប៉ុណ្ណោះ ។

បទថា **បតិត្វា** គឺធ្លាក់ចុះ របូតចេញហើយ ។ ព្រោះថា ខាងលើនៃជើងគ្រែនោះ សូម្បីកន្ទាស់ក៏មិនបោះខ្ទាស់ ព្រោះដូច្នោះ ជើងគ្រែ ទើបរបូតចេញ ។

បទថា **វិស្សរមកាសិ** គឺបានធ្វើសំឡេងស្រែកខ្លាំងខុសប្រក្រតី ។

# អធិប្បាយ

## បទភាជនីយវេហាសកុដិសិក្ខាបទ

[១២] បទថា **វេហាសកុដិ នាម មជ្ឈិមស្ស បុរិសស្ស អសីសឃដ្ដា** សេចក្តីថា កុដិណាមិនប៉ះក្បាលនៃមជ្ឈិមបុរស ដោយធ្នឹមដែលទាបជាងគេ

បង្អស់ ( កុដិនោះឈ្មោះថា វេហាសកុដិ ) ។ ដោយពាក្យនេះ ព្រះសម្ពុទ្ធ ទ្រង់សម្តែងវេហាសកុដិ ដែលទ្រង់បំណងហើយក្នុងសិក្ខាបទនេះ ។ ( តែ ) ទ្រង់មិនបានសម្តែងលក្ខណៈនៃវេហាសកុដិទុកឡើយ ។ ពិតហើយ កុដិមាន ២ ជាន់ក្តី ៣ ជាន់ក្តី ប្រភេទណានីមួយ ខាងលើមិនបានក្រាលផ្ទៃ ព្រះសម្ពុទ្ធ ត្រាស់ហៅថា **វេហាសកុដិ** ។ តែក្នុងសិក្ខាបទនេះ បំណងយកវេហាសកុដិ ដែលមិនប៉ះក្បាល ។ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃអាបត្តិ ក្នុងការអង្គុយ សន្កត់ជាដើម ដោយអំណាចនៃបយោគ ដោយន័យដូចពោលហើយពីមុន នោះឯង ។

## អនាបត្តិនៃវេហាសកុដិសិក្ខាបទ

[ ១៤ ] បទថា **អវេហាសកុដិយា** សេចក្តីថា មិនត្រូវអាបត្តិក្នុង សាលាស្លឹក ដែលគេធ្វើលើផែនដីជាដើម ។ ព្រោះថា មិនអាចដើម្បីនឹងធ្វើ ការបៀតបៀនដល់អ្នកដទៃក្នុងកុដិ មានបណ្ណសាលាជាដើមនោះ ។

បទថា **សីសឃដ្តាយ** សេចក្តីថា កុដិណាទង្គិចក្បាលបានជាអនាបត្តិ ក្នុងកុដិនោះ ។ ព្រោះថា បុគ្គលណាមួយ មិនឱន មិនអាចដើរ ទៅក្នុង ប្រាសាទជាន់ក្រោមក្នុងកុដិនោះបាន ដូច្នោះ នឹងមិនមានការបៀតបៀនដល់ អ្នកដទៃ ព្រោះមិនមែនជាទីកន្លែងសញ្ចារ ។

បីបទថា **ហេដ្ឋា អបរិភោគំ ហោតិ** សេចក្តីថា ខាងក្រោម ជាទីប្រើ ប្រាស់មិនបាន ព្រោះទុកដាក់សម្ភារៈជាដើម ។ សូម្បីក្នុងកុដិនោះ ក៏ជា អនាបត្តិ ។

បាចិត្តិយកណ្ឌ ភូតគាមវគ្គ សិក្ខាបទទី ៨

ពីរបទថា **បធរសញ្ញិតំ ហោតិ** សេចក្ដីថា ផ្ទៃខាងលើកុដិណា គេក្រាលយ៉ាងក្រាស់ ដោយបន្ទះក្ដារក្ដី ធ្វើបរិកម្មដោយបាយអជាដើមក្ដី ទោះក្នុងកុដិនោះក៏ជាអនាបត្តិ ។

បទថា **បដាណិ ធិន្នា ហោតិ** សេចក្ដីថា បានបោះកន្លាស់ទុកត្រង់ចុងជើងគ្រែ និងតាំងជាដើម ។ កាលភិក្ខុអង្គុយលើគ្រែ និងតាំងណា ( ជើងគ្រែ ) មិនធ្លាក់ចុះមក សូម្បីភិក្ខុអង្គុយលើគ្រែ និងតាំងដូច្នោះ ក៏ជាអនាបត្តិ ។

បទថា **តស្មិំ ឋិតោ** សេចក្ដីថា ភិក្ខុឈរលើគ្រែ និងតាំង ដែលមានជើងស៊ក ( ចូលក្នុងមេគ្រែក្ដី មេតាំងក្ដី ) ចាប់យកចីវរ ឬវត្ថុណាមួយដែលព្យួរលើដៃកែវជាដើមខាងលើ ឬព្យួរវត្ថុដទៃ ជាអនាបត្តិដល់ភិក្ខុនោះ ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វេហាសកុដិសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[១៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង មហាមាត្យជាឧបដ្ឋាករបស់ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេធ្វើវិហារប្រគេនឆន្នភិក្ខុដ៏មានអាយុ ។ លំដាប់នោះ ឆន្នភិក្ខុដ៏មានអាយុបានឲ្យគេប្រក់ និងបូកលាបវិហារដែលគេធ្វើស្រេចហើយនោះញយៗ វិហារនោះធ្ងន់ហួសកំណត់ ក៏បាក់រលំចុះមក ។ គ្រានោះ ឆន្នភិក្ខុដ៏មានអាយុក៏ជញ្ជូនយកស្មៅ និងឈើទៅធ្វើ ( វិហារទៀត ) បៀតបៀនស្រែស្រូវរបស់ព្រាហ្មណ៍ម្នាក់ឲ្យខូចខាតទៅ ។ ទើបព្រាហ្មណ៍នោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបើនឹងមកបៀតបៀនស្រែស្រូវរបស់យើងឲ្យខូចខាតទៅសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ព្រាហ្មណ៍នោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ មិនគួរនឹងឲ្យគេប្រក់រឿយៗ បូកលាបរឿយៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះ ធ្ងន់ហួសកំណត់បាក់រលំចុះមកសោះ ។ ភិក្ខុអម្បាលណោះ នាំគ្នាក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឆន្ន ឮថា អ្នកឯងឲ្យគេប្រក់រឿយៗ និងបូកលាបរឿយៗ នូវវិហារ ដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ បាក់រលំ

ចុះមក ពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯង មិនសមបើនឹងឲ្យគេប្រក់រឿយៗ និងបូកលាបរឿយៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ បាក់រលំចុះមកទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើវិហារធំ គប្បីឈរ ( លាបបូកញយៗ បាន ) កំណត់ទីមានឱកាសត្រឹមតែសន្ទឹកទ្វារ[១] ( និងសន្ទឹកបង្អួច ) ដើម្បីទុកប្រើប្រាស់នូវទ្វារ និងដើម្បីបរិកម្មនូវសន្ទឹកបង្អួច ឯដំបូល ភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ ( នោះទើប ) ប្រក់បានត្រឹមពីរ ឬបីជាន់ បើភិក្ខុប្រក់ឲ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ ក៏គង់ត្រូវអាបត្តិបាចិត្តិយ ។

[១៦] ដែលហៅថា វិហារធំ សំដៅយកវិហារដែលមានទាយកជាម្ចាស់របស់ ។ ដែលហៅថា វិហារ គឺវិហារដែលគេបូកខាងក្នុងក្តី បូកខាងក្រៅក្តី បូកទាំងខាងក្នុងខាងក្រៅក្តី ។ ពាក្យថា ឲ្យគេធ្វើ គឺ ធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ។ ពាក្យថា កំណត់ទីមានឱកាសត្រឹមតែសន្ទឹកទ្វារ គឺ កំណត់ត្រឹម

---

១- ក្នុងមហាបច្ចរីថា មានទំហំមួយហត្ថមួយចំអាម រាប់អំពីមេទ្វារចេញទៅ ក្នុងកុរុន្ទីថា កំណត់ត្រឹមសន្ទឹកទ្វារទាំងពីរជាប្រមាណ ក្នុងមហាអដ្ឋកថាថា សន្ទឹកទ្វារនោះ មួយហត្ថមួយចំអាមក៏មាន ពីរហត្ថក៏មាន ពីរហត្ថមួយចំអាមក៏មាន ។

ហត្ថបាសដោយជុំវិញនៃក្របទ្វារ ។ ពាក្យថា ដើម្បីទុកប្រើប្រាស់នូវទ្វារ គឺ ដើម្បីបើកបិទនូវទ្វារ ។ ពាក្យថា ដើម្បីបរិកម្មនូវសន្ទឹកបង្អួច សេចក្តីថា ( តថាគតអនុញ្ញាត ) នូវវត្ថុមានពណ៌ស ពណ៌ខ្មៅ ពណ៌រង់ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ៍ ក្បាច់ធ្មេញមករ និងក្បាច់ឈ្មោះបញ្ចបដ្ដិក[1] ដើម្បីបរិកម្មនូវសន្ទឹកបង្អួច ។ ពាក្យថា ឯជំបូល ភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ ( នោះទើប ) ប្រក់បានត្រឹមពីរបីជាន់ ឯដំណាំនោះ បានដល់ វត្ថុដែលត្រូវស៊ីមុន ( គឺស្រូវ ៧ ប្រការ មានស្រូវស ស្រូវក្រហមជាដើម ) និងវត្ថុដែលត្រូវស៊ីក្រោយ ( បានដល់ សណ្តែកបាយ សណ្តែករាជមាស ជាដើម ) ។ បើភិក្ខុឈរធ្វើការប្រក់ ក្នុងទីមានដំណាំ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុប្រើគេឲ្យប្រក់ម្តងរួចទៅហើយ ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរដង ដល់គ្រាទីបី ត្រូវបង្គាប់គេ ហើយចៀសចេញទៅ ។ កាលភិក្ខុប្រើគេឲ្យប្រក់មួយជាន់រួចហើយ ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរជាន់ ដល់ជាន់ទីបី ត្រូវបង្គាប់គេ ហើយចៀសចេញទៅ ។

[ ១៧ ] ត្រង់ពាក្យថា បើភិក្ខុប្រក់ឲ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ សេចក្តីថា កាលភិក្ខុប្រើគេឲ្យប្រក់ដោយក្បឿង ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ផែនក្បឿង ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយថ្ម ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ផែនថ្ម ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយកំបោរ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ដុំកំបោរ ។ កាលភិក្ខុប្រើគេឲ្យប្រក់

---

១- ក្បាច់ដែលមានស្រទាប់ ៥ ឬជាន់ ៥ ។

ដោយស្មៅ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ កណ្តាប ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្លឹកឈើ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ សន្លឹក ។

[ ១៨ ] វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសម្គាល់ថា លើសមែន ហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសង្ស័យហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសម្គាល់ថា ខ្វះវិញ ហើយធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុ សម្គាល់ថា លើស ហើយ ( ធ្វើថែម ) ត្រូវអាបត្តិទុក្កដ ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសម្គាល់ថា មិនទាន់ដល់មែន មិនត្រូវអាបត្តិ ។

[ ១៩ ] អាបត្តិមិនមានដល់ភិក្ខុ ដែលបូកប្រក់វិហារត្រឹមពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់វិហារមិនដល់ពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់លេណ ( ទីពួន ) គុហា កុដិប្រក់ដោយស្មៅ ធ្វើដើម្បីប្រយោជន៍ដល់អ្នកដទៃ ធ្វើដោយទ្រព្យរបស់ខ្លួន ទីសេនាសនៈទាំងពួង វៀរលែងតែកុដិសម្រាប់នៅរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា
# ភូតគាមវគ្គទី ២
# មហល្លកវិហារសិក្ខាបទ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូចតទៅនេះ

ក្នុងឱកាសទំហំបណ្ដោយទទឹងរបស់សន្ទះទ្វារ ដោយជុំវិញនៃសន្ទះទ្វារ ឈ្មោះថា **ទ្វារកោស** ( ក្របទ្វារ ) ក្នុងបទថា **យាវ ទ្វារកោសា** នេះ ។ តែក្នុងមហាបច្ចរីពោលទុកថា ១ ហត្ថ ១ ចំអាម វាស់អំពីសន្ទឹកទ្វារ ។ ក្នុងកុរុន្ទីពោលថា ទំហំប៉ុនសន្ទឹកទ្វារទាំង ២ ផ្នែកនៃទ្វារ ។ ក្នុងមហាអដ្ឋកថាពោលថា ឈ្មោះថា សន្ទឹកទ្វារមានទំហំ ១ ហត្ថ ១ ចំអាម ក៏មាន ២ ហត្ថក៏មាន ២ ហត្ថ ១ ចំអាមក៏មាន ។ ពាក្យក្នុងមហាអដ្ឋកថានោះ ពោលល្អហើយ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សំដៅយកអត្ថនោះឯង ទើបទ្រង់ធ្វើការកំណត់ទុកយ៉ាងខ្ពស់ ដូច្នេះថា កំណត់ត្រឹមហត្ថបាសដោយជុំវិញនៃសន្ទឹកទ្វារ ។

បទថា **អគ្គឡដ្ឋបនាយ** សេចក្ដីថា ដើម្បីដាក់ទ្វារព័ន្ធ ( ក្របទ្វារ ) ព្រមទាំងសន្ទះទ្វារ អធិប្បាយថា ដើម្បីមិនឲ្យកម្រើកនៃគ្របទ្វារ និងសន្ទឹកទ្វារ ។ ពិតហើយ បទភាជនៈថា **ទ្វារដ្ឋបនាយ** នេះ ព្រះមានព្រះភាគក៏ត្រាស់សំដៅយកអត្ថនេះនោះឯង ។ ក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះថា សន្ទឹកទ្វារដែលវិលរហ័ស រមែងប៉ះជញ្ជាំងក្នុងវេលាបើក រមែងខ្ទប់គ្របទ្វារក្នុងវេលាបិទ ជញ្ជាំងរមែងកក្រើក ដោយការប៉ះខ្ទប់នោះ ព្រោះជញ្ជាំង

កក្រើកនោះ ដីរមែងធូរ កាលធូរហើយ រមែងរលុង ឬរបូតចុះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យាវ ទ្វារកោសា អគ្គឡដ្ឋបនាយ** ដូច្នេះ ។

បណ្ឌិតគប្បីឃើញអត្ថក្នុងពាក្យយ៉ាងនេះថា ព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងមាតិកា មិនបានត្រាស់ទុកក្នុងបទភាជនៈឡើយថា កិច្ចឈ្មោះនេះ គួរធ្វើក៏ពិត តែដើម្បីដាក់ក្របប៉ុនណាអំពីក្របនៃទ្វារ គប្បីបូកឯង ឬគប្បីឲ្យបូករឿយៗ ដោយអនុលោមតាមអត្ថប្បត្តិហេតុថា កិក្ខុឲ្យបូករឿយៗ ឲ្យលាបរឿយៗ ដូច្នេះ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃមហល្លកវិហារសិក្ខាបទ

[ ១៦ ] ឯក្នុងពាក្យដែលត្រាស់ទុកក្នុងបទភាជនៈថា **បិដ្ឋិសង្ឃាដស្ស សាមន្តា ហត្ថបាសា** គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា វិហារណាមានទ្វារត្រង់កណ្តាល និងមានជញ្ជាំងខ្ពស់នៅផ្នែកខាងលើ ហត្ថបាសជុំវិញក្នុងទិសទាំង ៣ ជាឧបចារៈ នៃវិហារនោះ ។ សម្រាប់វិហារតូច មានឧបចារៈក្នុងទិសទាំង ២ ។ ក្នុងវិហារតូចនោះ សន្ទឹកទ្វារដែលបើកចេញ រមែងប៉ះខ្ទប់ជញ្ជាំងណា ជញ្ជាំងនោះ ក៏មិនទាន់រាប់ថា ជាឧបចារៈដោយសព្វគ្រប់ឡើយ តែដោយកំណត់យ៉ាងឧក្រិដ្ឋ ទ្រង់អនុញ្ញាតហត្ថបាសដោយជុំវិញ ក្នុងទិសទាំង ៣ ( និង ) ទ្រង់អនុញ្ញាតការបូកលាប ដើម្បីធ្វើទ្វារឲ្យណែន ។ តែបើមានឱកាសដែលគួរលាបក្នុងចំណែកខាងលើនៃទ្វារ ទោះលាបឱកាសនោះ ក៏គួរ ។

ក្នុងបទថា **អាលោកសន្ធិបរិកម្មាយ** នេះ ព្រះមានព្រះភាគត្រាស់ហៅសន្ទឹកបង្អួចថា **អាលោកសន្ធិ** ។ ក្នុងពាក្យអធិប្បាយមានដូច្នេះថា សន្ទឹកបង្អួចទាំងនោះ ក្នុងវេលាបើក ប៉ះចំណែកនៃជញ្ជាំងប្រមាណ ១ ចំអាមខ្វះជាង ១ ចំអាមខ្វះ ។ ក្នុងពាក្យថា **អាលោកសន្ធិ** នេះ រមែងបានឧបចារៈក្នុងទិសទាំងពួង ព្រោះហេតុនោះ ឱកាសប្រមាណប៉ុនទំហំនៃសន្ទឹកបង្អួចក្នុងទិសទាំងពួង ភិក្ខុគប្បីលាបឯង ឬគប្បីប្រើឲ្យលាប ដើម្បីប្រយោជន៍ដល់ការបរិកម្មសន្ទឹកបង្អួច ។

បទថា **សេតវណ្ណំ** ជាដើម មិនមែនជាការចែកបទមាតិកា ។ ពិតហើយ ឈ្មោះថា វិហារ នឹងជារបស់ជូន់ដោយពណ៌សជាដើមនេះ ក៏ទេដែរ ហេតុនោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាត ( ពណ៌សជាដើម ) ទុកក្នុងបទភាជនៈនោះឯង ។ ព្រោះហេតុនោះ ភិក្ខុគប្បីធ្វើកិច្ចគ្រប់យ៉ាង មានការលាបបូកបាយអជាដើមនេះតាមសប្បាយ ។

## អធិប្បាយ ការបរិកម្មលើដំបូល

ដើម្បីទ្រង់សម្តែងកម្ម គឺការលាប ដែលភិក្ខុគប្បីធ្វើយ៉ាងនោះហើយ សម្តែងកម្មដែលភិក្ខុគប្បីធ្វើលើដំបូលទៀត ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **ទ្វិត្តិច្ឆទនស្ស** ជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូចតទៅនេះថា បទថា **ទ្វិត្តិច្ឆទនស្ស បរិយាយំ** គឺ ( ឲ្យ ) ការប្រក់ដំបូលបាន ២-៣ ជាន់ ។ ការប្រក់ លោកហៅថា **បរិយាយ** ។ អធិប្បាយថា គប្បីតាំងចិត្តប្រក់ឲ្យបាន ២-៣ ជង ។

*ពីរបទថា* **អបហរិតេ ឋិតេន** *គឺឈរនៅក្នុងទីប្រាសចាករបស់មានពណ៌ខៀវ ។ ក្នុងបទថា* **ហរិតំ** *នេះ ទ្រង់បំណាងយកបុព្វណ្ណជាតិ មានស្រូវ ៧ ប្រការ និងអបរន្នជាតិ មានសណ្តែកបាយ សណ្តែកពងមាស ល្ង សណ្តែកជ្រូង ឃ្លោក និងត្រឡាចជាដើម ។ ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ថា ដែលឈ្មោះថា របស់ខៀវស្រស់ បានដល់បុព្វណ្ណជាតិ និងអបរន្នជាតិ ។*

*ក្នុងបទថា* **សចេ ហរិតេ ឋិតោ អធិដ្ឋាតិ អាបត្តិ ទុក្កដស្ស** *នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ពូជដែលគេព្រោះក្នុងស្រែណា ដំបូងមិនទាន់សម្រេច ( មិនទាន់ដុះ ) ក្តី កាលភ្លៀងធ្លាក់ហើយ នឹងសម្រេចក្តី ពូជនេះក៏ដល់នូវការរាប់ថា ជាវត្ថុមានពណ៌ខៀវដូចគ្នា ។ ព្រោះដូច្នោះ ភិក្ខុឈរក្នុងស្រែដែលមានសភាពបែបនោះ ក៏មិនគួរបរិកម្ម ។ គប្បីឈរបរិកម្មក្នុងទីប្រាសចាករបស់ពណ៌ខៀវប៉ុណ្ណោះ ។*

*ក្នុងរឿងបរិកម្មប្រាសចាករបស់មានពណ៌ខៀវ ក្នុងស្រែដែលព្រោះពូជហើយនោះ មានកំណត់ដូចតទៅនេះ គឺភិក្ខុអង្គុយនៅត្រង់ផ្លូវក្តី ជហ្វាផ្ទះកំពូលក្តី កំពូលខាងលើក្តី សម្លឹងមើលសំយាបដំបូល ឃើញមនុស្សឈរលើភូមិភាគណា និងមនុស្សឈរត្រង់ភូមិភាគណា រមែងឃើញភិក្ខុនោះអង្គុយនៅខាងលើ គប្បីឈរត្រង់ភូមិភាគនោះ រមែងមិនបានឈរបរិកម្មក្នុងទីដែលប្រាសចាករបស់មានពណ៌ខៀវ ខាងក្នុងបទេសនោះចូលមក ព្រោះហេតុអ្វី ព្រោះបទេសនេះ ជាឱកាសដែលនឹងបាក់ចុះមកនៃវិហារ ក្នុងកាល*

ដែលរលំ ។

ការប្រក់ត្រង់ៗ ទៅមិនអម ឈ្មោះថា ប្រក់តាមជួរ ក្នុងបទថា **មគ្គេន ឆាទេន្តស្ស** នេះ ការប្រក់តាមជួរនោះ រមែងមានដោយឥដ្ឋ ថ្ម និងបាយអ ។

បទថា **ទ្វេ មគ្គេ អធិដ្ឋហិត្វា** សេចក្តីថា ផ្លូវពីជួរ បើប្រក់មិនល្អ រមែងបានដើម្បីនឹងរើសចេញ ហើយឲ្យប្រក់ជារឿយៗ ។ ព្រោះដូច្នោះ គប្បីប្រក់ឯង ២ ជួរ ដូចដែលខ្លួនត្រូវការ ហើយជួរទី ៣ គប្បីប្រាប់ថា តពីនេះទៅ ចូរប្រក់យ៉ាងនេះ ហើយចៀសចេញទៅ ។

បទថា **បរិយាយេន** ប្រែថា ដោយការប្រក់ជាជាន់ៗ ។ ការប្រក់យ៉ាងនេះ រមែងបានដោយស្មៅ និងស្លឹកឈើ ។ ព្រោះហេតុនោះ ក្នុងការប្រក់នេះ ភិក្ខុគប្បីប្រក់ឯង ២ ជាន់ តាមដែលខ្លួនត្រូវការហើយ ជាន់ទី ៣ គប្បីប្រាប់ថា ទីនេះ ចូរប្រក់យ៉ាងនេះ ហើយចៀសចេញទៅ បើមិនចៀសទៅ គប្បីឈរស្ងៀម ។ ការប្រក់ទាំងអស់នេះ គប្បីជ្រាបថា ខាងលើដំបូល ។ ភិក្ខុទាំងឡាយយល់ថា វិហារដែលប្រក់ត្រួតលើគ្នាជាន់ៗ ទឹកភ្លៀងមិនងាយលិចឡើយ ទើបប្រក់យ៉ាងនេះ ។

[ ១៧ ] បទថា **តតោ ចេ ឧត្តរឹ** សេចក្តីថា លើស ៣ ជួរ ឬ ៣ ជាន់ឡើងទៅ គឺក្នុងជួរទី ៤ ឬក្នុងជាន់ទី ៤ ។

បទថា **ការេន្ស ការេន្ស** គឺក្នុងកណ្តាបស្មៅគ្រប់ៗ កណ្តាប ។ បទដ៏សេស ក្នុងសិក្ខាបទនេះរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

មហល្លកវិហារសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងអាគាឡវចេតិយ ទៀបស្រុកអាឡវី ។ គ្រានោះឯង ភិក្ខុស្រុកអាឡវីទាំងឡាយ កាលធ្វើនូវនវកម្ម ( កម្មទើបតែកសាងថ្មី ) ដឹងថា ទឹកមានសត្វ ក៏ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្ទុះបន្អាប់ថា ពួកភិក្ខុស្រុកអាឡវី ដឹងថា ទឹកមានសត្វហើយ មិនសមបីនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះសោះឡើយ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថា ទឹកមានសត្វហើយ ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងដឹងថា ទឹកមានសត្វហើយ មិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬមួយញុំាំងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ ។បេ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយដឹងថា ទឹកមានសត្វហើយ ស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅ ឬដី ត្រូវអាបត្តិបាចិត្តិយ ។

[ ២១ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្តី ឈ្មោះថា ភិក្ខុដឹង ។

[ ២២ ] ត្រង់ពាក្យថា ស្រោចឯង គឺ ភិក្ខុស្រោចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើគេឲ្យស្រោច គឺ ភិក្ខុបង្គាប់អ្នកដទៃឲ្យស្រោច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រើតែម្តង ហើយអ្នកទទួលបង្គាប់ទៅស្រោចច្រើនដង ភិក្ខុអ្នកប្រើ ត្រូវអាបត្តិបាចិត្តិយ ។ ( ទឹក ) មានសត្វ ភិក្ខុសម្គាល់ថា ( ទឹក ) មានសត្វមែន ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅ ឬដី ត្រូវអាបត្តិបាចិត្តិយ ។ ( ទឹក ) មានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅ ឬដី ត្រូវអាបត្តិទុក្កដ ។ ( ទឹក ) មានសត្វ ភិក្ខុសម្គាល់ថា គ្មានសត្វវិញ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅ ឬដី មិនត្រូវអាបត្តិអ្វីឡើយ ។ ( ទឹក ) មិនមានសត្វ ភិក្ខុសម្គាល់ថា មានសត្វ ត្រូវអាបត្តិទុក្កដ ។ ( ទឹក ) មិនមានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ( ទឹក ) មិនមានសត្វ ភិក្ខុសម្គាល់ថា មិនមានសត្វ មិនត្រូវអាបត្តិអ្វីឡើយ ។

[ ២៣ ] អាបត្តិមិនមានដល់ភិក្ខុមិនក្លែង ដល់ភិក្ខុមិនមានស្មារតី ដល់ភិក្ខុមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

ភូតគាមវគ្គទី ២ ចប់

## ចំនួនសិក្ខាបទក្នុងភូតគាមវគ្គនោះ គឺ

ភិក្ខុធ្វើភូតគាមឲ្យដាច់ចាកទី ១ ភិក្ខុយករឿងដទៃមកបន្ទប់ដើម្បីបិទបាំងទោសខ្លួន ១ ភិក្ខុលើកទោសភិក្ខុអ្នកធ្វើការសង្ឃ ១ ភិក្ខុយកគ្រែ តាំង ពូក កៅអី របស់សង្ឃទៅចោលក្នុងទីវាល ហើយចៀសចេញទៅ ១ ភិក្ខុយកកម្រាលរបស់សង្ឃទៅក្រាលចោល ហើយចៀសចេញទៅ ១ ភិក្ខុដេកបៀតជ្រៀតភិក្ខុអ្នកនៅមុនក្នុងកុដិសង្ឃ ១ ភិក្ខុទឹងទែងភិក្ខុឯទៀត ហើយបណ្តេញចាកវិហាររបស់សង្ឃ ១ ភិក្ខុអង្គុយ ឬដេកលើគ្រែមានជើងស៊កទុក ១ ភិក្ខុលាបបូកវិហារញយៗ បានកំណត់ត្រឹមសន្ទឹកទ្វារ ឬសន្ទឹកបង្អួចដោយជុំវិញ ១ ភិក្ខុយកទឹកមានសត្វស្រោចស្មៅ ឬដី ១ ។

# អដ្ឋកថា

## ភូតគាមវគ្គទី ១

## សប្បាណកសិក្ខាបទ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១០ ដូចតទៅនេះ*

[២០] *ពីរបទថា* **ជានំ សប្បាណកំ** *បានដល់ ដឹងដោយប្រការណា មួយថា ទឹកនេះមានសត្វតូចៗ ។*

*ពីរបទថា* **សិញ្ចេយ្យ វា សិញ្ចាបេយ្យ វា** *សេចក្តីថា ភិក្ខុគប្បីយក ទឹកនោះស្រោចឯងក្តី ប្រើអ្នកដទៃឲ្យស្រោចក្តី ។*

# អធិប្បាយ

## សិក្ខាបទវិភង្គនៃសប្បាណសិក្ខាបទ

[២២] *បទនេះថា* **សិញ្ចេយ្យាតិ សយំ សិញ្ចតិ** *ដូច្នេះ ក្នុងព្រះបាលី អ្នកសិក្សាគប្បីជ្រាបអត្ថដោយន័យដូចពោលហើយ ក្នុងសិក្ខាបទមុននោះឯង ។ កាលភិក្ខុស្រោចមិនឲ្យខ្សែទឹកនោះដាច់ ត្រូវអាបត្តិតែ ១ ក្នុងទឹកមួយផ្ទាំង ក្នុងភាជនៈគ្រប់យ៉ាងក៏ន័យនេះ ។ តែត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ដល់ ភិក្ខុដែលស្រោចធ្វើឲ្យខ្សែទឹកដាច់ ។ ភិក្ខុធ្វើប្រឡាយឲ្យជាផ្លូវត្រង់ ( ទឹក ) ទោះហូរអស់មួយថ្ងៃក្តី ជាអាបត្តិ ១ ប៉ុណ្ណោះ បើភិក្ខុបិទក្នុងទីនោះៗ ហើយ បង្ហូរទឹកទៅតាមផ្លូវដទៃ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ បើស្មៅមាន ច្រើន ដាក់ពេញរទេះ ភិក្ខុដាក់ចុះក្នុងទឹកដោយប្រយោគមួយ ត្រូវអាបត្តិ ១*

ប៉ុណ្ណោះ ។ ភិក្ខុចោលស្មៅ ឬស្លឹកឈើម្តងមួយសរសៃ ម្តងមួយសន្លឹក ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ ក្នុងដីស្អិតក្តី ក្នុងវត្ថុដទៃ មានឈើ ភក់ និងអាចម៍គោជាដើមក្តី ក៏ន័យនេះឯង ។ ឯវិធីចោលស្មៅ និងដីក្នុងទឹកនេះ មិនបានត្រាស់សំដៅទឹកច្រើនទេ ។ ទឹកណា កាលចោលស្មៅ និងដីចុះទៅ នឹងដល់នូវការស្ងួតទៅក្តី ទៅជាល្អក់ក្តី ក្នុងទឹកណាដែលពួកសត្វតូចៗ នឹងស្លាប់ក្តី បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅដល់ទឹកប្រភេទនោះ បទដ៏សេសក្នុងសិក្ខាបទនេះ រាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តក: ជាបណ្ណត្តិវជ្ជ: ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះ ។

សប្បាណកសិក្ខាបទ ចប់

ភូតគាមវគ្គទី ២ ចប់បរិបូណ៌

តាមវណ្ណនានុក្រម

# វិនយបិដក

## ឱវាទវគ្គ សិក្ខាបទទី ១

[ ២៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំង-ឡាយ ទូន្មានភិក្ខុនីទាំងឡាយ ក៏បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុបានគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយ ទូន្មានពួកភិក្ខុនី បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងទាំងឡាយក៏ទូន្មានភិក្ខុនីដែរ ។ វេលានោះ ពួកឆព្វគ្គិយភិក្ខុនាំគ្នាចូលទៅរកភិក្ខុនីទាំងឡាយហើយបាននិយាយយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរមករកពួកយើងៗ នឹងទូន្មាន ។ គ្រានោះ ភិក្ខុនីទាំងឡាយនោះ ក៏ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយហើយអង្គុយក្នុងទីគួរមួយ ។ ពួកឆព្វគ្គិយភិក្ខុធ្វើធម្មីកថាបន្តិចបន្តួចដល់ពួកភិក្ខុនី ហើយក៏ពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចបញ្ជូនពួកភិក្ខុនីឲ្យត្រឡប់ទៅវិញ ដោយពាក្យថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរទៅវិញចុះ ។ គ្រានោះ ភិក្ខុនីទាំងឡាយនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពួកភិក្ខុនីនោះ ដែលឈរក្នុងទីដ៏សម

គួរ ដោយពុទ្ធដីកាយ៉ាងនេះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទ ( នោះ ) បាន បរិបូណ៌សម្រេចហើយឬ ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឱវាទ ( នោះ ) នឹងបរិបូណ៌សម្រេចមកពីណា ព្រោះលោកម្ចាស់ឆព្វគ្គិយ ទាំងឡាយធ្វើធម្មីកថាតែបន្តិចបន្តួចប៉ុណ្ណោះ ហើយពោលតិរច្ឆានកថាឲ្យកន្លង អស់មួយថ្ងៃ រួចក៏បញ្ជូនខ្ញុំព្រះអង្គទាំងឡាយឲ្យត្រឡប់មកវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់ យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ភិក្ខុនីទាំងឡាយ នោះ លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យ អាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរ នេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ ឆព្វគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ ធ្វើ ធម្មីកថាដល់ភិក្ខុនីទាំងឡាយតិចណាស់ ពោលតែតិរច្ឆានកថាឲ្យកន្លងអស់ មួយថ្ងៃ ហើយក៏បញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួក ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះ ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯង មិនសមបើនឹងធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយតិចពេក ពោលតែតិរច្ឆានកថា ឲ្យកន្លងអស់មួយថ្ងៃ ហើយបញ្ជូនភិក្ខុនីទាំងឡាយឲ្យត្រឡប់ទៅវិញសោះ នែ មោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នាធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែ

ជ្រះថ្លាឡើងមិនបាន ។បេ។ លុះព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីយ៉ាងនេះ សង្ឃត្រូវអារាធនាភិក្ខុ ( នោះ ) ជាមុនសិន ។ លុះអារាធនារួចហើយ ភិក្ខុអ្នកឈ្លាសអង់អាច គប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ នេះជាវាចាប្រកាសសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសម្មតិភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះអស់វារៈ ២ ដង ផង ។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈ ៣ ដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសម្មតិភិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីហើយ ។

សម្មតិកម្មនេះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការនៅស្ងៀមយ៉ាងនេះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលនូវឆព្វគ្គិយភិក្ខុទាំងឡាយ ដោយបរិយាយជាច្រើន ។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ដែលសង្ឃមិនបានសន្មត ហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយ ដោយប្រការយ៉ាងនេះ ។

[២៥] សម័យនោះឯង ភិក្ខុជាថេរៈទាំងឡាយដែលសង្ឃបានសន្មតរួចហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយ ក៏បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ បានគិតគ្នាថា អាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយដែលសង្ឃបានសន្មតហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយ បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល អាវុសោ បើដូច្នោះ មានតែពួកយើងទៅកាន់ទីក្នុងសីមា ហើយសន្មតគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី រួចប្រដៅពួកភិក្ខុនី ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុ នាំគ្នាទៅកាន់ទីក្នុងសីមា ហើយសន្មតគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយចូលទៅរកភិក្ខុនីទាំងឡាយ ពោលយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ សង្ឃបានសន្មតពួកយើងហើយ នាងទាំងឡាយចូរមករកពួកយើងចុះ យើងនឹងប្រដៅទូន្មាន ។ ទើបភិក្ខុនីទាំងឡាយនោះ ចូលទៅរកឆព្វគ្គិយភិក្ខុទាំង

ឡាយ លុះចូលទៅដល់ហើយ ថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ ធ្វើធម្មីកថាបន្តិចបន្តួចដល់ភិក្ខុនីទាំងឡាយ ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃទៅ រួចក៏បញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញដោយពាក្យថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរទៅវិញចុះ ។ ទើបភិក្ខុនីទាំងនោះ នាំគ្នាចូលទៅកាន់ទីគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនីទាំងឡាយ ដែលឈរនៅក្នុងទីដ៏សមគួរនោះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទបានសម្រេចបរិបូណ៌ឬទេ ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឱវាទនឹងបានសម្រេចបរិបូណ៌មកពីឯណា លោកម្ចាស់ឆព្វគ្គិយទាំង-ឡាយ ធ្វើធម្មីកថាបន្តិចបន្តួច ហើយពោលតែតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចក៏បញ្ជូនយើងខ្ញុំឲ្យត្រឡប់មកវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ ភិក្ខុនីអម្បាលនោះ លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយព្រះធម្មី-កថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ រួចសួរបញ្ជាក់ពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយឮថា អ្នកទាំងឡាយ ធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយបន្តិចបន្តួច ហើយពោល

តិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចក៏បញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបីនឹងធ្វើធម្មីកថាបន្តិចបន្តួចដល់ពួកភិក្ខុនី ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចបញ្ជូនភិក្ខុនីទាំងនោះ ឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមួយញ៉ាំងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ ។បេ។ ទ្រង់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមក ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គ ៨ ឲ្យជាអ្នកប្រដៅភិក្ខុនី គឺ ភិក្ខុជាអ្នកមានសីល សង្រួមតាមបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ ( មារយាទ ) និងទីគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ភិក្ខុជាពហុស្សូត ទ្រទ្រង់ពុទ្ធវចនៈសន្សំនូវពុទ្ធវចនធម៌ទាំងឡាយណា ពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង តែងប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថទាំងព្យញ្ជនៈ ឲ្យបរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះចាំច្រើនហើយ ទ្រទ្រង់ហើយ សន្សំហើយ ដោយវាចាដ៏ស្ទាត់រត់មាត់ ចូលចិត្ត ច្បាស់លាស់ យល់ត្រូវល្អដោយទិដ្ឋិ ១ ចំណែកបាតិមោក្ខទាំងពីរ ភិក្ខុនោះ ក៏ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់

វត់មាត់ កាត់សេចក្តីបានដោយល្អ ដោយសុត្តៈ ( គឺឧទ្ទកៈ និងបរិវារៈ ) ដោយអនុព្យញ្ជនៈ ១ ភិក្ខុនោះមានវាចាពោលត្រឹមត្រូវ ដោយសិថិលធនិតជាដើម មានសំឡេងពីរោះ ១ ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ១ ភិក្ខុនោះជាអ្នកអាចដើម្បីនឹងប្រដៅភិក្ខុនីបាន ១ ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្លងគរុធម៌នឹងភិក្ខុនីដែលស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ បួសចំពោះព្រះដ៏មានព្រះភាគនេះ ១ ភិក្ខុនោះមានវស្សា ២០ ឬមានវស្សាជាងម្តៃ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតនូវភិក្ខុដែលប្រកបដោយ អង្គទាំងឡាយ ៨ នេះ ឲ្យជាអ្នកប្រដៅភិក្ខុនី ។

[២៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុដែលឈ្មោះថា សង្ឃមិនបានសន្មតនោះ គឺសង្ឃមិនបានសន្មតដោយញត្តិចតុត្ថកម្មវាចា ។ ពួកស្រីដែលឈ្មោះថាភិក្ខុនីនោះ បានដល់ ស្រីដែលបានឧបសម្បទាហើយក្នុងឧភតោសង្ឃ ។

[២៧] ត្រង់ពាក្យថា ប្រដៅ គឺភិក្ខុទូន្មានដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រដៅដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសម្នាក់សង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។

[២៨] ភិក្ខុដែលសង្ឃសន្មតនោះ គប្បីបោសប្រាសនូវទីបរិវេណ រួចត្រូវតាំងទឹកឆាន់ និងទឹកប្រើប្រាស់ តែងតាំងនូវសេនាសនៈទុក ហើយនាំយកភិក្ខុជាគម្រប់ពីរទៅអង្គុយនៅចុះ ។ ភិក្ខុនីទាំងឡាយ គប្បីទៅក្នុងទីនោះ ហើយថ្វាយបង្គំនូវភិក្ខុនោះ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ ភិក្ខុដែលសង្ឃ

សន្និតនោះ គប្បីសួរភិក្ខុនីទាំងឡាយថា ម្នាលនាងទាំងឡាយ ពួកនាងព្រម ព្រៀងគ្នាហើយឬ បើភិក្ខុនីទាំងឡាយពោលថា លោកម្ចាស់ នាងខ្ញុំទាំងឡាយ ព្រមព្រៀងគ្នាហើយ ភិក្ខុគប្បីសួរថា ម្នាលនាងទាំងឡាយ គរុធម៌ ៨ ចាំ ស្ទាត់រត់មាត់ហើយឬ ។ បើភិក្ខុនីទាំងឡាយពោលតបថា បពិត្រលោកម្ចាស់ ចាំស្ទាត់រត់មាត់ហើយ ភិក្ខុគប្បីឲ្យឱវាទដោយពាក្យថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ។ បើភិក្ខុនីទាំងឡាយពោលថា គរុធម៌មិនទាន់ស្ទាត់ទេ លោកម្ចាស់ ភិក្ខុគប្បីសូត្រប្រាប់ភិក្ខុនីថា ភិក្ខុនីឧបសម្បទាហើយបាន ១០០ វស្សា ត្រូវធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្មដល់ ភិក្ខុ ( សូម្បី ) ឧបសម្បទាហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យ ល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបដល់អស់មួយជីវិត ១ ។ ភិក្ខុនី មិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យ ល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត ១ ។ ភិក្ខុនី ត្រូវប្រាថ្នាធម៌ ២ ប្រការ គឺការសាកសួរនូវឧបោសថ ១ ការចូលទៅទទួល ឱវាទ ១ អំពីភិក្ខុសង្ឃគ្រប់ៗ កន្លះខែ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត ១ ។ ភិក្ខុនីនៅចាំ វស្សារួចហើយ ត្រូវបវារណាក្នុងឧភតោសង្ឃ ដោយហេតុ ៣ យ៉ាង គឺ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត ១ ។ ភិក្ខុនីត្រូវគរុ- កាបត្តិ ( ជាសតេកិច្ឆា ) ហើយត្រូវប្រព្រឹត្តបក្ខមានត្តក្នុងឧភតោសង្ឃ នេះជា

ធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងជរាបអស់មួយជីវិត ១ ។ ភិក្ខុនីត្រូវស្វែងរកឧបសម្បទាក្នុងឧភតោសង្ឃដល់សិក្ខមានាដែលមានសិក្ខាសិក្សាក្នុងធម៌ទាំងឡាយ ៦ អស់ពីរវស្សាហើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងជរាបអស់មួយជីវិត ១ ។ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចផ្ដាសាភិក្ខុដោយបរិយាយណាមួយឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងជរាបអស់មួយជីវិត ១ ។ ពួកភិក្ខុនីមិនត្រូវស្ដីប្រដៅពួកភិក្ខុឡើយ ពួកភិក្ខុត្រូវស្ដីប្រដៅដល់ពួកភិក្ខុនីបាន តាំងអំពីថ្ងៃនេះជាដើម នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងជរាបអស់មួយជីវិត ១ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ ភិក្ខុពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយបែកគ្នាជាពួកៗ ភិក្ខុបេះតែពោលនូវគរុធម៌ ៨ ដដែល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានប្រគល់ឱវាទឲ្យដល់ភិក្ខុនី ត្រឡប់ពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។

[ ២៩ ] កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ពួកភិក្ខុសម្គាល់ថាជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក

ពួកភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣០ ] ភិក្ខុសង្ស័យក្នុងកម្មមិនជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថាជាពួកមែន ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣១ ] កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថាជាពួកមែន ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣២ ] កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៣ ] កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថាបែកគ្នាជាពួកវិញហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៣៤ ] កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនមែនជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថាព្រមព្រៀងគ្នា ហើយ

ប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៥] កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថា ជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[ ៣៦ ] កម្មជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថា ជាពួកមែន ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៧] កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសម្គាល់ថា ជាពួកមែន ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៨] កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនមែនជាធម៌វិញ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[៣៩] កម្មជាធម៌ ភិក្ខុមានសេចក្តីសង្ស័យ ភិក្ខុនីសង្ឃ ព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយ

ប្រដៅ ។បេ។ ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

[ ៤០ ] កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថា បែកគ្នាជាពួកវិញ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសម្គាល់ថា ព្រមព្រៀងគ្នាមែន ហើយប្រដៅ មិនត្រូវអាបត្តិអ្វីឡើយ ។

[ ៤១ ] អាបត្តិមិនមានដល់ភិក្ខុដែលសម្តែងនូវបាលីនៃគរុធម៌ ៨ ដល់ភិក្ខុដែលសម្តែងនូវអដ្ឋកថានៃគរុធម៌ ៨ ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសម្តែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់

# អដ្ឋកថា

## ឱវាទវគ្គទី ៣

## ឱវាទសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃឱវាទវគ្គដូចតទៅនេះ

[២៤] ក្នុងបទថា **លាភិនោ ហោន្តិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុនីទាំងឡាយ រមែងមិនប្រគេនឯង មិនប្រើអ្នកដទៃឲ្យប្រគេនដល់ព្រះថេរៈទាំងនោះ តែពួកកុលធីតាដែលចេញបួសអំពីត្រកូលធំ រមែងដៅចំពោះព្រះ-អសីតិមហាសាវកថា ព្រះថេរៈឈ្មោះនោះ និងឈ្មោះនោះ រមែងពោលប្រដៅ ហើយពោលសរសើរគុណដែលមាន ដូចជា សីល សុត្តៈ អាចារៈ ជាតិ និងគោត្រជាដើមរបស់អសីតិមហាសាវកទាំងនោះ តាមក្រសែនៃពាក្យសម្តីរបស់ពួកជនជាញាតិ ដែលមកកាន់សម្នាក់របស់ខ្លួន ដែលកំពុងសួរថា បពិត្រ អ្នកនាងម្ចាស់ ពួកនាងបានទទួលឱវាទ ឱវាទ បរិបុច្ឆាអំពីទីណាដូច្នេះ ៗ ពិតហើយ គុណដែលមានបែបនេះ គួរដើម្បីនឹងពោល ៗ ព្រោះហេតុនោះ ទើបពួកមនុស្សដែលមានចិត្តជ្រះថ្លា បាននាំយកលាភ និងសក្ការៈដ៏ច្រើនមក ដូចជា ចីវរជាដើមទៅប្រគេនដល់ព្រះថេរៈទាំងឡាយ ព្រោះហេតុនោះ ទើបធម្មសង្គាហកៈទាំងឡាយពោលថា **លាភិនោ ហោន្តិ ចីវរ ។បេ។ បរិក្ខារំ** ដូច្នេះ ៗ

ពីរបទថា **ភិក្ខុនិយោ ឧបសង្កមិត្វា** សេចក្តីថា បានឮថា បណ្តាភិក្ខុនីទាំងនោះ ភិក្ខុនីអង្គណាមួយ ក៏មិនមកក្នុងសម្នាក់របស់ឆព្វគ្គិយភិក្ខុទាំងនោះ

តែពួកឆព្វគ្គិយភិក្ខុមានចិត្តដែលតណ្ហាក្នុងលាភអូសទាញទៅរឿយៗ បានទៅកាន់សម្នាក់នៃភិក្ខុនីទាំងនោះ ។ ទើបព្រះធម្មសង្គាហកៈទាំងឡាយសំដៅដល់ការទៅកាន់សម្នាក់ភិក្ខុនីរបស់ឆព្វគ្គិយភិក្ខុនោះ បានពោលពាក្យថា **ភិក្ខុនិយោ ឧបសង្កមិត្វា** ដូច្នេះ ។ សូម្បីភិក្ខុនីទាំងនោះបានធ្វើតាមពាក្យសម្ដីរបស់ពួកឆព្វគ្គិយភិក្ខុនោះឯង ព្រោះជាអ្នកមានចិត្តជ្រួលជ្រើម ។ ដោយហេតុនោះ ទើបធម្មសង្គាហកៈទាំងឡាយពោលពាក្យថា **អថខោ តា ភិក្ខុនិយោ ។បេ។ និសីទឹសុ** ដូច្នេះ ។

បទថា **តិរច្ឆានកថំ** បានដល់ ពាក្យសម្ដីដែលឥតប្រយោជន៍ មានច្រើនយ៉ាង មានរាជកថាជាដើម ដែលជាការរារាំងក្នុងការទៅកាន់ស្ថានសួគ៌ ។

បទថា **ឥទ្ធោ** ប្រែថា សម្រេចហើយ អធិប្បាយថា មានប្រយោជន៍ជ្រាលជ្រៅ មានរសច្រើន ប្រកបដោយលក្ខណៈបដិសេធ ។

ក្នុងបទថា **អនុជានាមិ ភិក្ខវេ** នេះ បណ្ឌិតគប្បីជ្រាបថា ព្រោះឆព្វគ្គិយភិក្ខុទាំងនោះ កាលត្រូវព្រះមានព្រះភាគត្រាស់ហាមថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលប្រៀនប្រដៅភិក្ខុនីទាំងឡាយ ដូច្នេះ នឹងគប្បីចងអាឃាតក្នុងព្រះតថាគត ហើយជាអ្នកចូលដល់អបាយ ព្រោះជាអ្នកមិនទាន់ឃើញសច្ចៈ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ចៀសវាងភាពជាអ្នកចូលដល់អបាយនោះនៃឆព្វគ្គិយភិក្ខុទាំងនោះ ទ្រង់បំណងនឹងរារាំងឆព្វគ្គិយភិក្ខុទាំងនោះទុកខាងក្រៅពីការពោលប្រៀនប្រដៅភិក្ខុនី ដោយឧបាយដទៃនោះឯង ទើបទ្រង់អនុញ្ញាតភិក្ខុនោវាទកសម្មតិនេះ ។

[ ២៥ ] ព្រះមានព្រះភាគទ្រង់អនុញ្ញាត ( ភិក្ខុនោវាទកសម្មតិ ) ព្រោះមានព្រះបំណងនឹងពាំងភិក្ខុទាំងនោះទុកខាងក្រៅ ក្នុងសិក្ខាបទនេះ យ៉ាងនេះ កាលទ្រង់ធ្វើតទៅខាងមុខ ទើបត្រាស់បទថា **អនុជានាមិ ភិក្ខវេ អដ្ឋ-ហង្គេហិ សមន្នាគតំ** ជាដើម ។ ពិតហើយ អង្គទាំង ៨ នេះ មិនទាន់ធ្លាប់មានដល់ពួកឆព្វគ្គិយភិក្ខុ សូម្បីតែការយល់សប្តិឡើយ ។

# អធិប្បាយ អង្គ ៨

បណ្ឌិតគប្បីជ្រាបវិគ្គហៈក្នុងបទថា **សីលវា** នោះថា សីលរបស់ភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា ជាអ្នកមានសីល ។ ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្តែងសីលដែលមាន និងប្រការដែលសីលនោះមានដល់ភិក្ខុនោះ ដូចម្តេចទើបឈ្មោះថា មាន ទើបបានត្រាស់បទថា **បាតិ-មោក្ខសំវរសំវុតោ** ជាដើម ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះថា សំវរៈ គឺបាតិមោក្ខ ឈ្មោះថា បាតិមោក្ខសំវរៈ ។ ភិក្ខុអ្នកសង្រួម គឺប្រកបដោយបាតិមោក្ខសំវរៈនោះ ហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា អ្នកសង្រួមដោយបាតិមោក្ខសំវរៈ ។

បទថា **វិហរតិ** ប្រែថា ប្រព្រឹត្តទៅ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងវិភង្គថា ត្រង់ពាក្យថា បាតិមោក្ខ បានដល់ សីល ការតាំងមាំ កិច្ចខាងដើម ការប្រព្រឹត្តការសង្រួម ការរវាំង ប្រធាន ប្រមុខ នៃការដល់នូវកុសលធម៌ទាំងឡាយ ។ ពាក្យថា សំវរៈ គឺការមិនកន្លង ដែលប្រព្រឹត្តទៅក្នុងកាយ ការដែលមិនកន្លង ដែលប្រព្រឹត្តទៅក្នុងវាចា ការមិន

កន្លងដែលប្រព្រឹត្តទៅក្នុងកាយ និងក្នុងវាចា ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជីប្រកបព្រមដោយការសង្រួម ក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ។ ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

បទថា **អាចារគោចរសម្បន្នោ** សេចក្តីថា លះអគោចរ មានកន្លែងស្រីពេស្យាជាដើម ដោយអាចារៈដែលការពារមិច្ឆាជីវៈ មានការមិនឲ្យឫស្សីជាដើម ហើយដល់ព្រមដោយគោចរ មានត្រកូលដែលសម្បូរដោយសទ្ធាជាដើម ឈ្មោះថា អ្នកដល់ព្រមដោយអាចារៈ និងគោចរ ។

បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** បានដល់ អ្នកមានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ សូម្បីមានប្រមាណតិចតួច ។ មានពាក្យអធិប្បាយថា មានប្រក្រតីឃើញទោសទាំងនោះ ដោយភាពជាភ័យ ។

បទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** សេចក្តីថា បណ្តាសិក្ខាបទដែលរាប់ជា ៣ យ៉ាង ដោយភាពជាអធិសីលសិក្ខាជាដើម សមាទានកាន់យកដោយប្រពៃ បានដល់ ទទួលយកដោយល្អ សិក្សាមិនលះបោលសិក្ខាបទនោះៗ ។ នេះជាសេចក្តីសង្ខេបក្នុងពាក្យថា **អាចារគោចរសម្បន្នោ** នេះ ឯអ្នកត្រូវការសេចក្តីពិស្តារ គប្បីកាន់យកក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ក្នុងអដ្ឋកថានៃវិភង្គប្បករណ៍ ឈ្មោះសម្មោហវិនោទនី ឬអំពី

វិសុទ្ធិមគ្គបករណ៍ ។

សុតៈរបស់ភិក្ខុនោះច្រើន ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា **ពហុស្សុត** ។ ភិក្ខុណាទ្រទ្រង់នូវសុតៈទុក ហេតុនោះ ទើបភិក្ខុនោះឈ្មោះថា **សុតធរ** អធិប្បាយថា ពាក្យដែលភិក្ខុនោះបានស្តាប់ ឈ្មោះថា **ពហុស្សុត** សុតៈនោះ មិនមែនត្រឹមតែស្តាប់តែម្យ៉ាងនោះឡើយ ដោយពិត រមែងទ្រទ្រង់សុតៈនោះផង សុតៈសន្សំក្នុងភិក្ខុនោះ ដូចរតនៈដែលរក្សាទុកក្នុងហិប ហេតុនោះ ទើបភិក្ខុនោះឈ្មោះថា មានការសន្សំសុតៈ ។ ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងការមិនសាបសូន្យទៅ ដោយកាលយូរនៃសុតៈ ដែលភិក្ខុនោះទ្រទ្រង់ទុក ដូចរតនៈដែលរក្សាទុកក្នុងប្រអប់ ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសុតៈនោះដោយសរុប ទើបត្រាស់បទថា **យេ តេ ធម្មា** ជាដើម ពាក្យនោះ មានន័យដូចពោលហើយ ក្នុងវេរញ្ជកណ្ឌនោះឯង តែនេះជាពាក្យត្រាស់បញ្ជាក់ដដែលក្នុងសិក្ខាបទនេះ ។ ធម៌បែបនោះ គឺភិក្ខុនោះស្តាប់ហើយច្រើន ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា **ពហុស្សុត** ធម៌ទាំងនោះ ដែលភិក្ខុនោះទ្រទ្រង់ទុកបាន ហេតុនោះ ទើបភិក្ខុនោះឈ្មោះថា **សុតធរ** ធម៌ទាំងនោះដែលភិក្ខុនោះសន្សំទុកដោយវាចា តាមសម្លឹងដោយចិត្ត ចាក់ធ្លុះល្អហើយដោយទិដ្ឋិ ហេតុនោះ ទើបភិក្ខុនោះឈ្មោះថា **សុតសន្និចយ** ។

បណ្តាបទទាំងនោះ ពីរបទថា **វចសា បរិចិតា** បានដល់ ដែលភិក្ខុនោះធ្វើឲ្យរត់មាត់ ។

បទថា **មនសានុបេក្ខិតា** សេចក្តីថា ដែលភិក្ខុសម្លឹងដោយចិត្តហើយ រមែងហាក់ដូចជាបំភ្លឺដោយពន្លឺប្រទីប ១០០០ ដល់លោកដែលពិចារណា ។

ពីរបទថា **ទិដ្ឋិយា សុប្បដិវិទ្ធា** សេចក្តីថា ធម៌ទាំងឡាយ រមែងត្រូវបានភិក្ខុនោះចាក់ធ្លុះហើយដោយល្អ គឺធ្វើឲ្យប្រចក្សហើយ ដោយបញ្ញា ដោយអត្ថ និងដោយការណៈ ។

## ពហុស្សុត ៣ ពួក

ភិក្ខុដែលឈ្មោះថា **ពហុស្សុត** នេះ មាន ៣ ពួក គឺ **និស្សយ-មុច្ចនក** អ្នកលួមផុតនិស្ស័យ ១ **បរិសុបដ្ឋាបក** អ្នកឲ្យបរិស័ទឧបដ្ឋាក ១ **ភិក្ខុនោវាទក** អ្នកប្រៀនប្រដៅភិក្ខុនី ១ ។ បណ្តាពហុស្សុតទាំង ៣ នោះ ភិក្ខុដែលជា **និស្សយមុច្ចនក** មានវស្សា ៥ ដោយឧបសម្បទា គប្បីទន្ទេញមាតិកា ២ ( ដឹងច្បាស់ភិក្ខុមាតិកា និងភិក្ខុនីមាតិកា ) ឲ្យស្ទាត់ជំនាញរត់មាត់ ដោយកំណត់យ៉ាងទាបជាងគេទាំងអស់ គប្បីរៀនភាណវារ ៤ អំពីសុត្តន្តបិដក ដើម្បីប្រយោជន៍ដល់ធម្មស្សវនៈ ក្នុងថ្ងៃនៃបក្ខទាំងឡាយ គប្បីរៀនកថាមគ្គឯណាមួយ ដូចជាអន្ធកវិន្ទសូត្រ មហារាហុលោវាទសូត្រ អម្ពដ្ឋសូត្រ ដើម្បីប្រយោជន៍ដល់ការពោលបកិណ្ណកធម៌ ដល់ជនដែលមករក គប្បីរៀនគាថាអនុមោទនា ៣ យ៉ាង ដើម្បីប្រយោជន៍ក្នុងការអនុ-មោទនាក្នុងសង្ឃភត្ត ការងារមង្គល និងអពមង្គល គប្បីរៀនវិនិច្ឆ័យកម្ម និងមិនមែនកម្ម ដើម្បីឧបោសថ និងបវារណាជាដើម គប្បីរៀនកម្មដ្ឋានឯណាមួយ មានព្រះអរហត្តជាទីបំផុត ដោយអំណាចនៃសមាធិក្តី ដោយអំណាច

នៃវិបស្សនាក្តី ដើម្បីធ្វើសមណធម៌ គប្បីរៀន ( ពុទ្ធវចនៈ មានព្រះសូត្រ ៤ កាណវារជាដើម ) ត្រឹមប៉ុណ្ណោះ ។ ពិតហើយ ដោយការរៀនប្រមាណប៉ុណ្ណោះ ភិក្ខុនេះរមែងឈ្មោះថា ជាពហុស្សូត ជាអ្នកប្រាកដក្នុងទិស ៤ រមែងបានដើម្បីនៅដោយភាពជាឥស្សរៈរបស់ខ្លួន ក្នុងទីណាមួយ ។

ភិក្ខុដែលជា **បរិស្សុបដ្ឋាបក** មានវស្សា ១០ ដោយឧបសម្បទា គប្បីធ្វើវិភង្គទាំង ២ ឲ្យជំនាញរត់មាត់ ដើម្បីដឹកនាំបរិស័ទ ក្នុងអភិវិន័យ ដោយកំណត់យ៉ាងទាបបំផុត ។ បើមិនអាច គប្បីធ្វើ ( វិភង្គទាំង ២ ) ឲ្យគួរដល់ការផ្លាស់ប្តូរគ្នាជាមួយភិក្ខុ ៣ រូប គប្បីរៀនកម្ម និងមិនមែនកម្ម និងខន្ធកវត្ត តែដើម្បីដឹកនាំបរិស័ទក្នុងអភិធម្ម បើជាអ្នកពោលមជ្ឈិមនិកាយ គប្បីរៀនមូលបណ្ណាសកៈ ។ អ្នកពោលទីឃនិកាយ គប្បីរៀនមហាវគ្គ ។ អ្នកពោលសំយុត្តនិកាយ គប្បីរៀនវគ្គទាំង ៣ ខាងដើម ឬមហាវគ្គ ។ អ្នកពោលអង្គុត្តរនិកាយ គប្បីរៀនពាក់កណ្តាលនិកាយខាងដើម ឬខាងចុង ។ បើមិនអាចសូម្បីរៀនខាងដើម តាំងអំពីតិកនិបាតទៅក៏បាន តែក្នុងមហាបច្ចរីពោលថា អ្នករៀនយកនិបាត ១ ឬរៀនយកចតុក្កនិបាត ឬបញ្ចកនិបាតក៏បាន ។ អ្នកពោលជាតក គប្បីរៀនយកជាតក ព្រមទាំងអដ្ឋកថា បើរៀនទាបជាងជាតក ព្រមទាំងអដ្ឋកថា មិនគួរ ។ លោកពោលទុកក្នុងមហាបច្ចរីថា សូម្បីរៀនយកធម្មបទ ព្រមទាំងវត្ថុនិទាន ក៏គួរ ។

សួរថា បើជ្រើសរើសរៀនយកនិកាយនោះៗ មានទីឃនិកាយជាដើម ត្រឹមមូលបណ្ណាសកៈ គួរ ឬមិនគួរ ឆ្លើយថា លោកបដិសេធទុកក្នុងអដ្ឋកថា

កុរុន្ទីថា មិនគួរ ។ ក្នុងអដ្ឋកថាក្រៅអំពីនេះ មិនមានការពោលទុកឡើយ ។ ក្នុងអភិធម្មលោកមិនបានពោលថា គួររៀនយកអ្វីៗ ភិក្ខុណាជំនាញក្នុង វិនយ-បិដក និងអភិធម្មបិដក ព្រមទាំងអដ្ឋកថា តែមិនមានគន្ថៈ មានប្រការដូចដែលពោលក្នុងសុត្តន្តបិដក ភិក្ខុនោះរមែងមិនបានដើម្បីនឹងឲ្យបរិស័ទឧបដ្ឋាកឡើយ ។ តែភិក្ខុណារៀនគន្ថៈ មានប្រមាណដូចពោលហើយអំពីសុត្តន្តបិដកខ្លះ អំពីវិនយបិដកខ្លះ ភិក្ខុនេះជា **បរិស្សូបដ្ឋាបក** ជាពហុស្សូត ជាទិសា-បាមោក្ខ ទៅបានតាមសេចក្តីប្រាថ្នា រមែងបានដើម្បីឲ្យបរិស័ទឧបដ្ឋាក ។ ឯភិក្ខុអ្នកឲ្យឱវាទភិក្ខុនី គប្បីរៀនបិដក ៣ មួយអន្លើដោយអដ្ឋកថា ។ បើមិនមានសមត្ថភាព គប្បីធ្វើអដ្ឋកថានៃនិកាយ ១ បណ្តានិកាយទាំង ៤ ឲ្យជំនាញ ។ ព្រោះថា ចេះក្នុងនិកាយ ១ ក៏អាចដើម្បីពោលដោះស្រាយប្រស្នាក្នុងនិកាយដ៏សេសបាន ។ បណ្តាបករណ៍ ៧ គប្បីធ្វើអដ្ឋកថានៃបករណ៍ ៤ ឲ្យជំនាញ ។ ព្រោះថា ដោយន័យដែលបាន ( ចេះ ) ក្នុងអដ្ឋកថាទាំង ៤ បករណ៍នោះ ក៏អាចដើម្បីពោលស្រាយប្រស្នាក្នុងបករណ៍ដ៏សេសបាន ។ ឯវិនយបិដក មានអត្ថផ្សេងៗ គ្នា មានហេតុផ្សេងៗ គ្នា ព្រោះហេតុនោះ ភិក្ខុអ្នកទូន្មានភិក្ខុនី គប្បីធ្វើវិនយបិដកនោះ មួយអន្លើដោយអដ្ឋកថាឲ្យជំនាញនោះឯង ដោយការរៀនសុតៈ មានប្រមាណប៉ុណ្ណេះ ភិក្ខុដែលប្រៀនប្រដៅភិក្ខុនី ឈ្មោះថា ជាបុគ្គលមានសុតៈច្រើន ។

ចំណែកពាក្យថា **ឧភយានិ ខោ បនស្ស** ជាដើម ព្រះមានព្រះភាគត្រាស់ទុកដោយឡែក ព្រោះកាលពហុស្សូតមានអង្គ ៩ ដទៃ មានគ្រប់ទាំង

អស់ បើរៀនវិនយបិដក ព្រមទាំងអដ្ឋកថាចេញ រមែងមិនគួរនោះឯង ។

បណ្តាបទទាំងនោះ បទថា **វិត្ថារេន** បានដល់ មួយអន្លើដោយឧភតោវិភង្គ ។

បទថា **ស្វាគតានិ** គឺមកហើយដោយល្អ ។ បាតិមោក្ខទាំង ២ មកហើយដោយប្រការណា ទើបរាប់ថា មកហើយដោយល្អ ដើម្បីសម្តែងប្រការនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **សុវិភត្តានិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សុវិភត្តានិ** បានដល់ ចែកបានល្អ គឺវៀរចាកទោស គឺបទដែលធ្លាក់ចុះខាងក្រោយ និងប្របូកប្រឡល់គ្នា ។

បទថា **សុប្បវត្តីនិ** បានដល់ ជំនាញរត់មាត់ ។

ពីរបទថា **សុវិនិច្ឆិតានិ សុត្តសោ** បានដល់ មានវិនិច្ឆ័យល្អហើយ ដោយអំណាចនៃសូត្រដែលគប្បីនាំមកអំពីខន្ធកៈ និងបរិវារ ។

បទថា **អនុព្យញ្ជនសោ** បានដល់ វិនិច្ឆ័យបានរៀបរយ ដោយការបរិបូណ៌នៃអក្ខរបទ និងដោយអំណាចនៃសូត្រ គឺមិនដាច់ធ្លាក់ចុះ មិនមានអក្ខរៈដែលខុសភ្លាំងភ្លាត់ ។ អដ្ឋកថាលោកសម្តែងទុកដោយបទថា ដោយអនុព្យញ្ជនៈនេះ ពិតហើយ វិនិច្ឆ័យនេះ រមែងមានមកអំពីអដ្ឋកថា ។

បទថា **កល្យាណវាចោ** សេចក្តីថា បុគ្គលដល់ព្រមដោយវាចារបស់អ្នកក្រុង ដែលមានបទ និងព្យញ្ជនៈច្បាស់លាស់ តាមពាក្យដែលសមគួរដល់សិថិល និងធនិតជាដើម គឺប្រកបដោយវាចាឲ្យដឹងនូវអត្ថបានដោយស្រួល មិនមានទោស ។

បទថា **កល្យាណវាក្ករណោ** ប្រែថា មានសំឡេងទន់ផ្អែម ពិតហើយ មាតុគ្រាម ជាអ្នកត្រេកអរក្នុងការសម្បូរនៃសំឡេង ព្រោះហេតុនោះ ទើបនាងមើលងាយពាក្យនិយាយដែលវៀរចាកភាពសម្បូរនៃសំឡេង សូម្បីមានបទ និងព្យញ្ជនៈច្បាស់លាស់ក៏ដោយ ។

ពាក្យថា **យេភុយ្យេន ភិក្ខុនីនំ បិយោ ហោតិ មនាបោ** សេចក្ដីថា ឈ្មោះថា ភិក្ខុដែលជាទីស្រឡាញ់នៃភិក្ខុនីទាំងអស់ រកបានលំបាក ។ តែត្រូវជាទីស្រឡាញ់ ជាទីត្រេកអររបស់ពួកភិក្ខុនីដែលជាពហុស្សូត ជាបណ្ឌិត ព្រោះការដល់ព្រមនៃសីល និងអាចារៈ ។

ពាក្យថា **បដិពលោ ហោតិ ភិក្ខុនិយោ ឱវទិតុំ** សេចក្ដីថា កាលសម្ដែងសូត្រ និងហេតុ ឈ្មោះថា ជាអ្នកអាចដើម្បីគំរាមដោយវដ្ដភ័យ ហើយពោលទូន្មានភិក្ខុនីទាំងឡាយ គឺកាលសម្ដែងធម៌ដល់ភិក្ខុនីទាំងនោះ ។

បទថា **កាសាយវត្ថវសនាយ** ប្រែថា ដែលស្លៀកសំពត់ជ្រលក់ដោយទឹកចត់ ។

បទថា **គរុធម្មំ** សេចក្ដីថា កាលនៅជាគ្រហស្ថ មិនធ្លាប់ត្រូវកាយសំសគ្គៈ ជាមួយភិក្ខុនីក្ដី មិនធ្លាប់ត្រូវមេថុនធម្មក្នុងសិក្ខមានា និងសាមណេរី ។ ពិតហើយ មាតុគ្រាម កាលរឭកដល់កម្មដែលភិក្ខុធ្វើទុកក្នុងកាលមុន រមែងមិនធ្វើសេចក្ដីគោរពក្នុងធម្មទេសនារបស់ភិក្ខុ សូម្បីដែលតាំងនៅក្នុងសំវរៈ ។ ម្យ៉ាងទៀត នាងនឹងញ៉ាំងគំនិតឲ្យកើតឡើងក្នុងអសទ្ធម្មនោះឯង ។

បទថា **វីសតិវស្សោ វា** សេចក្ដីថា ដែលមានវស្សា ២០ ដោយឧប-

សម្បទាក្តី មានវស្សាជាង ២០ អំពីឧបសម្បទានោះក្តី ។ ភិក្ខុនោះ សូម្បី ប្រឡូកប្រឡំជាមួយវត្ថុដែលជាសត្រូវនឹងគ្នា មានរូបបែបនោះរឿយៗ ក៏មិន ភ្លាំងភ្លាត់ដល់ការខូចសីល ដូចភិក្ខុកំលោះឡើយ ។ ភិក្ខុនោះពិចារណាមើល វ័យរបស់ខ្លួនហើយ រមែងជាអ្នកមានកម្លាំងល្មមកម្ចាត់ធុរៈ ក្នុងឋានៈ ដែលមិនសមគួរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វីសតិ-វស្សោ វា ហោតិ អតិរេកវីសតិវស្សោ វា ។**

បណ្តាអង្គទាំង ៨ នេះ បណ្ឌិតគប្បីជ្រាបថា ពាក្យថា ជាអ្នកមាន សីលជាដើម ជាអង្គទី ១ ពាក្យថា ជាពហុស្សូតជាដើម ជាអង្គទី ២ ពាក្យ ថា ( បាតិមោក្ខ ) ទាំង ២ នោះឯងរបស់លោកជាដើម ជាអង្គទី ៣ ពាក្យ ថា ជាអ្នកមានវាចាពីរោះ មានសំឡេងទន់ផ្អែម ជាអង្គទី ៤ ពាក្យថា ជាទី ស្រឡាញ់ ជាទីពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ជាអង្គទី ៥ ពាក្យ ថា ជាអ្នកអាចប្រៀនប្រដៅភិក្ខុនីទាំងឡាយ ជាអង្គទី ៦ ពាក្យថា ភិក្ខុនោះ មិនធ្លាប់ប្រព្រឹត្តកន្លងគរុធម៌នឹងភិក្ខុនី ជាអង្គទី ៧ ពាក្យថា មានវស្សា ២០ ជាដើម ជាអង្គទី ៨ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃឱវាទសិក្ខាបទ

[ ២៦ ] បទថា **ញត្តិចតុត្ថេន** បានដល់ ( ដោយញត្តិចតុត្ថកម្ម ) មានន័យដូចពោលហើយ ក្នុងរឿងមុនៗ នោះឯង ។

[ ២៧ ] បទថា **គរុធម្មេហិ** គឺដោយធម៌ដែលធ្ងន់ ។ ពិតហើយ ធម៌ទាំងនោះ ព្រះមានព្រះភាគត្រាស់ហៅថា គរុធម៌ ព្រោះជាធម៌ដែលភិក្ខុនីទាំងឡាយគប្បីធ្វើការគោរព ទទួលយក ។

ក្នុងពាក្យថា **ឯកតោ ឧបសម្បន្នំ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុណា រមែងពោលប្រៀនប្រដៅដោយគរុធម៌ដល់ភិក្ខុនីដែលឧបសម្បទាក្នុងសម្នាក់នៃភិក្ខុនីទាំងឡាយតែមួយចំណែក ត្រូវអាបត្តិទុក្កដដល់ភិក្ខុនោះ ។ តែជាអាបត្តិតាមវត្ថុនោះឯង ( ដល់ភិក្ខុដែលប្រៀនប្រដៅភិក្ខុនី ) ដែលឧបសម្បទាក្នុងសម្នាក់នៃពួកភិក្ខុ ។

## អធិប្បាយ

## បទភាជនីយ៍នៃឱវាទសិក្ខាបទ

[ ២៨ ] ពីរបទថា **បរិវេណំ សម្មជ្ជិត្វា** សេចក្ដីថា បើបរិវេណមិនស្អាត ឬសូម្បីស្អាតហើយក្នុងវេលាព្រឹក ត្រឡប់ជាស្មោកគ្រោកព្រោះស្មៅនិងស្លឹកឈើជាដើម និងកើតមានការរាត់រាយខ្ចាត់ខ្ចាយដោយខ្យាច់ ព្រោះត្រូវជាន់ដោយជើង ភិក្ខុដែលបានទទួលសម្មតិគប្បីបោសប្រាស ។ ពិតហើយ ភិក្ខុនីទាំងឡាយនោះ ឃើញបរិវេណនោះមិនស្អាត គប្បីហាក់ដូចជាបុគ្គលមិនចង់ស្ដាប់ ដោយសម្គាល់ថា លោកម្ចាស់មិនដឹកនាំសូម្បីពួកភិក្ខុកំលោះដែលជានិស្សិតករបស់ខ្លួនក្នុងវត្តបដិបត្តិ ល្អតែសម្ដែងធម៌តែម្យ៉ាង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **បរិវេណំ សម្មជ្ជិត្វា** ។

ភិក្ខុនីទាំងឡាយដើរមកពីក្នុងស្រុក រមែងស្រេកទឹក និងអស់កម្លាំង ភិក្ខុនីទាំងនោះ ទើបសង្ឃឹមចំពោះនូវទឹកផឹក និងការធ្វើឲ្យដៃជើង និងមុខត្រជាក់ ។ កាលបើទឹកមិនមាន ភិក្ខុនីទាំងនោះកើតការមិនគោរពដោយន័យមុននោះឯង ហើយជាអ្នកមិនបំណងនឹងស្តាប់ធម៌ក៏បាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **ចានីយំ បរិភោជនីយំ ឧបដ្ឋបេត្វា** ។

បទថា **អាសនំ** សេចក្តីថា ភិក្ខុដែលបានទទួលសម្មតិនោះ ទើបរៀបចំទីអង្គុយ មានតាំងតូច បន្ទះក្តារ កន្ទេលទន់ និងកន្ទេលផែងជាដើម ដោយហោចសូម្បីស្លឹកឈើដែលល្មមនឹងកាច់បាន ដោយគិតយ៉ាងនេះថា ទីនេះនឹងជាទីអង្គុយរបស់ភិក្ខុនីទាំងនោះ ហើយគប្បីប្រាថ្នាបុរស អ្នកដឹងក្តីជាសម្លាញ់ ដើម្បីដោះអាបត្តិ ព្រោះការសម្តែងធម៌ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ទុតិយំ គហេត្វា** ដូច្នេះ ។

បទថា **និសីទិតព្វំ** សេចក្តីថា មិនគប្បីអង្គុយក្នុងទីបំផុតនៃវិហារដោយពិត គប្បីអង្គុយក្នុងទីប្រជុំនៃបុគ្គលទូទៅ ជិតទ្វាររោងឧបោសថ ឬរោងឆាន់ត្រង់កណ្តាលវិហារ ។

បទថា **សមគ្គត្ថ** សេចក្តីថា នាងទាំងឡាយមកព្រមព្រៀងគ្នាអស់ហើយឬ ។

បទថា **វត្តន្តិ** ប្រែថា ( គរុធម៌ ៨ ) ចាំបានហើយឬ អធិប្បាយថា ជំនាញ រត់មាត់ហើយឬ ។

បទថា **និយ្យាទេតព្វោ** ប្រែថា គប្បីប្រគល់ឲ្យ ។

បទថា **ឱសារេតព្វា** បានដល់ គប្បីប្រាប់បាលី ។

ពាក្យថា **វស្សសតុបសម្បន្នាយ** ជាដើម ជាពាក្យសម្ដែងបាលីដែលភិក្ខុអ្នកបានទទួលសម្មតិគប្បីប្រាប់ ។

បណ្ដាបទទាំងនោះ បទថា **សាមីចិកម្មំ** បានដល់ វត្តដែលសមគួរ មានការចៀសផ្លូវឲ្យឱកាស បក់ផ្លិត និង សួរដោយអើពើ ដោយទឹកផឹក ជាដើម ។ បណ្ដាវត្ត មានការអភិវាទជាដើមនេះ ឈ្មោះថា ការក្រាបថ្វាយបង្គំភិក្ខុ ដែលភិក្ខុនីគប្បីធ្វើពិត ទោះក្នុងស្រុកក្ដី ក្រៅស្រុកក្ដី ខាងក្នុងវិហារក្ដី ខាងក្រៅវិហារក្ដី ក្នុងលំផ្លែកស្រុកក្ដី ក្នុងច្រកផ្លូវក្ដី ដោយហោចសូម្បីកាលការបណ្ដេញ ព្រោះហេតុព្រះរាជាយាងមក ប្រព្រឹត្តទៅក្ដី កាលភ្លៀងកំពុងធ្លាក់ក្ដី ក្នុងផែនដីមានភក់ជាដើមក្ដី មានឆត្រ និងបាត្រនៅក្នុងដៃក្ដី ត្រូវដំរី និងសេះជាដើមដេញក្ដី ។ ភិក្ខុនីឃើញពួកភិក្ខុចូលកាន់ទីភិក្ខាចារ ដើរជាជួរជាប់គ្នាជាជួរតែមួយ នឹងថ្វាយបង្គំក្នុងទីមួយកន្លែង ដោយពោលថា ខ្ញុំថ្វាយបង្គំលោកម្ចាស់ ដូច្នេះ ក៏គួរ ។ បើភិក្ខុទាំងឡាយដើរវៀចម្ងាយក្នុងចន្លោះឆ្ងាយគ្នា ១២ ហត្ថ គប្បីថ្វាយបង្គំម្ដងមួយអង្គ ទោះបីថ្វាយបង្គំភិក្ខុទាំងឡាយដែលអង្គុយក្នុងទីប្រជុំធំ ក្នុងទីមួយកន្លែងប៉ុណ្ណោះក៏បាន ។ សូម្បីអញ្ជលិកម្មក៏ន័យនេះ ។ ភិក្ខុនីអង្គុយហើយ ក្នុងទីណាមួយ គប្បីធ្វើការក្រោកទទួល គប្បីធ្វើកម្មនោះៗ ក្នុងទី និងវេលាដែលសមគួរ ដល់សាមីចិកម្មនោះ ។

បទថា **សក្កត្វា** គឺធ្វើដោយប្រការនូវធម៌ដែលខ្លួនធ្វើហើយ និងធ្វើហើយដោយល្អ ។

បទថា **គរុកត្វា** គឺឲ្យកើតការគោរពក្នុងកម្មនោះ ។

បទថា **មានេត្វា** គឺធ្វើការស្រឡាញ់ដោយចិត្ត ( ពិតៗ ) ។

បទថា **បូជេត្វា** គឺធ្វើការបូជាដោយកិច្ច ៣ យ៉ាងនេះឯង ។

បទថា **អនតិក្កមនីយោ** គឺភិក្ខុនីមិនគប្បីកន្លងល្មើស ។

ក្នុងពាក្យថា **អភិក្ខុកេ អាវាសេ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បើភិក្ខុទាំងឡាយ អ្នកឲ្យឱវាទ មិនបាននៅក្នុងឱកាសខាងក្នុងរយៈចម្ងាយកន្លះយោជន៍អំពីសម្នាក់នៃភិក្ខុនី អាវាសនេះ ឈ្មោះថា អាវាសមិនមានភិក្ខុ ។ ភិក្ខុនីទាំងឡាយមិនគប្បីនៅចាំវស្សាក្នុងអាវាសមិនមានភិក្ខុនោះ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា អាវាសដែលភិក្ខុនីទាំងឡាយមិនអាចទៅដើម្បីស្តាប់ឱវាទក្តី ដើម្បីនៅរួមគ្នាក្តី ឈ្មោះថា មិនមានភិក្ខុ នឹងមិនអាចដើម្បីនឹងទៅទីដទៃអំពីសម្នាក់ភិក្ខុនីនោះ ខាងក្រោយភត្ត ស្តាប់ធម៌ហើយត្រឡប់មក ។ បើពួកញាតិក្តី ពួកឧបដ្ឋាកក្តី ពោលនឹងភិក្ខុនីទាំងឡាយដែលមិនបំណងនឹងនៅចាំវស្សាក្នុងអាវាសនោះ យ៉ាងនេះថា សូមនៅចុះអ្នកនាងម្ចាស់ ពួកខ្ញុំនឹងនាំភិក្ខុមកដូច្នេះ គួរ ។

បើភិក្ខុទាំងឡាយមានបំណងនឹងនៅចាំវស្សាក្នុងប្រទេស មានប្រមាណដូចយើងពោលហើយ មកស្នាក់សូម្បីត្រង់បាំងដែលធ្វើដោយមែកឈើ ទោះមួយយប់ ត្រូវពួកអ្នកស្រុកនិមន្តទុក ទើបមិនបំណងនឹងទៅ សូម្បីដោយការប្រាថ្នាដែលភិក្ខុនឹងមកនៅចាំវស្សាត្រឹមប៉ុណ្ណោះ ក៏ឈ្មោះថា អាវាសមានភិក្ខុ ពួកភិក្ខុនីទោះចាំវស្សាក្នុងអាវាសនេះ ក៏គួរ ។ កាលចាំវស្សា គប្បីសំណូមពរ

ភិក្ខុទាំងឡាយក្នុងថ្ងៃ ១៣ កើតនៃបក្ខនោះឯងថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងនៅដោយឱវាទរបស់លោកម្ចាស់ទាំងឡាយ ។

ទីលំនៅរបស់ភិក្ខុទាំងឡាយក្នុងទីកន្លះយោជន៍ ដោយផ្លូវត្រង់អំពីសម្នាក់ភិក្ខុនីណា មានអន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈ ដល់ពួកភិក្ខុនីដែលទៅដោយផ្លូវនោះ កាលទៅដោយផ្លូវដទៃ មានរយៈឆ្ងាយជាងកន្លះយោជន៍ អាវាសនេះ រមែងតាំងនៅក្នុងឋានៈនៃអាវាស មិនមានភិក្ខុដូចគ្នា ។ តែបើមានសម្នាក់ភិក្ខុនីដទៃនៅក្នុងទីផុតភ័យ ឆ្ងាយអំពីសម្នាក់ភិក្ខុនីនោះប្រមាណមួយគាវុត ភិក្ខុនីទាំងនោះគប្បីសំណូមពរភិក្ខុនីពួកនោះ ហើយត្រឡប់ទៅសំណូមពរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយ អន្តរាយមានក្នុងផ្លូវត្រង់ដល់ពួកខ្ញុំ កាលទៅផ្លូវដទៃ មានចម្ងាយជាងកន្លះយោជន៍ តែក្នុងចន្លោះផ្លូវមានសម្នាក់ភិក្ខុនីដទៃ ឆ្ងាយពីសម្នាក់របស់ពួកខ្ញុំប្រមាណមួយគាវុត ពួកខ្ញុំនឹងនៅដោយឱវាទដែលមកហើយ ក្នុងសម្នាក់ភិក្ខុនីនោះ អំពីសម្នាក់លោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំងនោះគប្បីទទួលយល់ព្រម ។ តាំងអំពីនោះទៅ ភិក្ខុនីទាំងនោះគប្បីមកកាន់សម្នាក់ភិក្ខុនីនោះ ធ្វើឧបោសថក្ដី សួរសុខទុក្ខភិក្ខុនីទាំងនោះក្ដី ហើយត្រឡប់ទៅកាន់សម្នាក់របស់ខ្លួននោះឯង ធ្វើឧបោសថក៏បាន ។

បើភិក្ខុទាំងឡាយប្រាថ្នានឹងនៅចាំវស្សា មកកាន់វិហារក្នុងថ្ងៃ ១៤ កើត ពួកភិក្ខុនីសួរថា លោកម្ចាស់នៅចាំវស្សាក្នុងទីនេះឬ ភិក្ខុពោលថា អើ ដូច្នោះឯង ភិក្ខុនីទាំងនោះប្រាប់ថា បពិត្រលោកម្ចាស់ បើដូច្នោះ ពួកខ្ញុំនឹងនៅ

អាស្រ័យឱវាទរបស់លោកម្ចាស់ទាំងឡាយ ដូច្នេះ ក្នុងថ្ងៃរះឡើង មិនឃើញការសម្បូរនៃអាហារក្នុងស្រុក គិតថា ពួកយើងមិនអាចនៅក្នុងទីនេះបាន ទើបចៀសចេញទៅ បើភិក្ខុនីទាំងនោះទៅកាន់វិហារ ក្នុងថ្ងៃឧបោសថ មិនឃើញភិក្ខុទាំងនោះ សួរថា អាវាសមានសភាពបែបនេះ គប្បីធ្វើដូចម្តេច ឆ្លើយថា ភិក្ខុទាំងឡាយនៅក្នុងអាវាសណា គប្បីទៅចូលវស្សាក្នុងថ្ងៃចូលវស្សាក្រោយក្នុងអាវាសនោះក្តី ធ្វើការចងចិត្តថា ភិក្ខុទាំងឡាយនឹងមកចូលវស្សាក្នុងថ្ងៃចូលវស្សាក្រោយ ហើយគប្បីនៅដោយឱវាទក្នុងសម្នាក់របស់ពួកភិក្ខុដែលមកហើយ ។

បើក្នុងថ្ងៃចូលបច្ឆិមវស្សាក៏មិនមានភិក្ខុអង្គខ្លះមក ហើយក្នុងចន្លោះផ្លូវមានរាជភ័យ ចោរភ័យ ឬទុព្ភិក្ខភ័យ ក៏ប្រព្រឹត្តជាអាបត្តិដល់ភិក្ខុនីដែលនៅក្នុងអាវាសមិនមានភិក្ខុ ។ សូម្បីដាច់វស្សាទៅ ក៏ជាអាបត្តិ គប្បីរក្សាអាបត្តិមានការដាច់វស្សាជាហេតុនោះទុក ។ ពិតហើយ ក្នុងអន្តរាយទាំងឡាយលោកកាត់ជាអនាបត្តិដល់ភិក្ខុនីដែលនៅក្នុងអាវាស មិនមានភិក្ខុ ។

បើភិក្ខុទាំងឡាយមកចូលវស្សាហើយ ចៀសចេញទៅវិញដោយហេតុណាមួយក្តី ពួកភិក្ខុនីគប្បីនៅតទៅ ។ សមដូចពាក្យព្រះមានព្រះភាគត្រាស់ទុកថា មិនត្រូវអាបត្តិដល់ភិក្ខុនី ដែលមានពួកភិក្ខុនៅចាំវស្សា ហើយចៀសចេញទៅក្តី សឹកទៅក្តី ស្លាប់ក្តី ចូលពួក ( ទៅចូលសាសនាដទៃ ) ក្តី ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ តែកាលបវារណា គប្បីទៅបវារណាក្នុងអាវាសដែលមានពួកភិក្ខុ ។

បទថា **អឌ្ឍមាសំ** ប្រែថា រាល់កន្លះខែម្តង ។

បីបទថា **ទ្វេ ធម្មា បច្ចាសឹសិតព្វា** គឺគប្បីប្រាថ្នាធម៌ ២ យ៉ាង ។

បទថា **ឧបោសថបុច្ឆកំ** ប្រែថា សួរដល់ឧបោសថ ។ ក្នុងការសួរដល់ឧបោសថនោះ ក្នុងឧបោសថ ១៥ កើត គប្បីសួរឧបោសថក្នុងថ្ងៃ ១៤ កើតនៃបក្ខ ក្នុងឧបោសថ ១៤ កើត គប្បីសួរឧបោសថក្នុងថ្ងៃ ១៣ កើតនៃបក្ខ ។ តែក្នុងមហាបច្ចរីពោលថា គប្បីទៅសួរក្នុងតិថី ១៣ កើតនៃបក្ខនោះឯងថា ឧបោសថនេះ ១៤ កើត ឬ ១៥ កើត ។ ក្នុងថ្ងៃឧបោសថ គប្បីចូលទៅដើម្បីប្រយោជន៍ដល់ឱវាទ តាំងពីថ្ងៃ ១ រោចទៅ គប្បីទៅដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ។ ព្រះមានព្រះភាគ ទ្រង់មិនប្រទានឱកាសដល់កម្មដទៃ ទ្រង់បញ្ញត្តការជាប់តគ្នាក្នុងសម្នាក់នៃភិក្ខុទាំងឡាយប៉ុណ្ណោះ ដល់ពួកភិក្ខុនីដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះមាតុគ្រាមមានបញ្ញាតិច ។ ពិតហើយ មាតុគ្រាមមានបញ្ញាតិច ការស្តាប់ធម៌ជានិច្ច មានឧបការៈច្រើនដល់លោក ។ កាលបើយ៉ាងនេះ ភិក្ខុនីទាំងឡាយនឹងមិនធ្វើមានះថា លោកម្ចាស់ទាំងឡាយ រមែងដឹងធម៌ដែលពួកយើងដឹងប៉ុណ្ណោះ ហើយនឹងចូលទៅអង្គុយជិតភិក្ខុសង្ឃ ធ្វើបព្វជ្ជាឲ្យមានប្រយោជន៍ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើ ( ការបញ្ញត្ត ) យ៉ាងនោះ ។ ឯភិក្ខុនីទាំងឡាយសម្គាល់ថា យើងទាំងឡាយនឹងបដិបត្តិតាមដែលទ្រង់ប្រៀនប្រដៅ ទើបចូលទៅកាន់វិហារមិនដាច់ទាំងអស់នេះឯង ។

សមដូចពាក្យ ដែលធម្មសង្គាហកាចារ្យពោលទុកថា សម័យនោះឯង

ភិក្ខុនីសង្ឃទាំងអស់ រមែងទៅទទួលឱវាទ ។ ពួកមនុស្សរមែងពោលទោស តិះដៀល លើកទោសថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុពួកនេះ ទាំងនេះ ជាស្រីកំណាន់របស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះ នឹងត្រេកអរជាមួយ ភិក្ខុនីទាំងនេះ ដូច្នេះ ។ ទើបភិក្ខុទាំងឡាយ ក្រាបទូលរឿងនេះដល់ព្រះមានព្រះភាគ ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃ មិនត្រូវទៅទទួលឱវាទ ( ព្រមគ្នា ) ទាំងអស់ទេ បើទៅត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី បួន ឬប្រាំរូប ទៅទទួលឱវាទ ( ម្តងៗ បាន ) ដូច្នេះ ។ សូម្បីយ៉ាងនោះ ពួកអ្នកស្រុកក៏ពោលទោស ទៀតដូចគ្នា ព្រះមានព្រះភាគត្រាស់ទៀតថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុនីពីរ ឬបីរូប ទៅទទួលឱវាទ ដូច្នេះ ។

ព្រោះហេតុនោះឯង ភិក្ខុនីសង្ឃគប្បីសំណូមពរភិក្ខុនី ២-៣ រូប ហើយ បញ្ជូនទៅថា ទៅចុះអ្នកនាងម្ចាស់ ចូរសូមការចូលទៅទទួលឱវាទជាមួយភិក្ខុសង្ឃថា បពិត្រអ្នកនាងម្ចាស់ ភិក្ខុនីសង្ឃសូមការចូលទៅដើម្បីទទួលឱវាទ ភិក្ខុសង្ឃ ដូច្នេះ ភិក្ខុនីទាំងនោះគប្បីទៅកាន់អារាម បន្ទាប់អំពីនោះ គប្បីចូល ទៅរកភិក្ខុមួយរូប ដែលទទួលឱវាទ ថ្វាយបង្គំហើយ ភិក្ខុនីមួយរូបគប្បីប្រាប់ ភិក្ខុនោះ យ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃរមែងថ្វាយបង្គំបាទានៃ ភិក្ខុសង្ឃ ហើយសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់បានឮ ថា ភិក្ខុនីសង្ឃ សូមបានការចូលមកដើម្បីទទួលឱវាទ ដូច្នេះ ។

ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុដែលសម្តែងបាតិមោក្ខ ហើយគប្បីពោល

យ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃរមែងថ្វាយបង្គំបាទានៃភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់បានឮថា ភិក្ខុនីសង្ឃសូមបាននូវការចូលមកដើម្បីទទួលឱវាទ ដូច្នេះ ។ ភិក្ខុអ្នកសម្តែងបាតិមោក្ខគប្បីពោលថា មានភិក្ខុអង្គខ្លះដែលសង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនីឬ បើមានភិក្ខុអង្គខ្លះដែលសង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនី ភិក្ខុដែលសម្តែងបាតិមោក្ខ គប្បីពោលថា ភិក្ខុឈ្មោះនោះ សង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនី ភិក្ខុនីសង្ឃគួរចូលទៅរកភិក្ខុនោះ ដូច្នេះ ។

បើមិនមានភិក្ខុដែលសង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនីទេ ភិក្ខុអ្នកសម្តែងបាតិមោក្ខ គប្បីពោលថា លោកដ៏មានអាយុអង្គណា អាចប្រៀនប្រដៅពួកភិក្ខុនី បើមានភិក្ខុអង្គខ្លះអាចប្រៀនប្រដៅពួកភិក្ខុនីផង ភិក្ខុនោះជាអ្នកប្រកបដោយអង្គ ៨ ផង គប្បីសន្មតភិក្ខុនោះ ហើយពោលថា ភិក្ខុឈ្មោះនោះ សង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនី ភិក្ខុនីសង្ឃគួរចូលទៅរកភិក្ខុនោះចុះ ។

តែភិក្ខុណាមួយក៏មិនអាចប្រៀនប្រដៅពួកភិក្ខុនី ភិក្ខុអ្នកសម្តែងបាតិមោក្ខគប្បីពោលថា មិនមានភិក្ខុអង្គណាមួយ ដែលសង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនីទេ ភិក្ខុនីសង្ឃចូរឲ្យដល់ព្រមដោយកម្មដែលគួរជ្រះថ្លាចុះ ។ ពិតហើយ ដោយពាក្យប្រមាណប៉ុណ្ណេះ សាសនាសង្គ្រោះដោយត្រៃសិក្ខាទាំងមូល គឺលោកប្រាប់ហើយ ។ ភិក្ខុនោះទទួលថា សាធុ ហើយគប្បីប្រាប់ដល់ភិក្ខុនីទាំងឡាយ ក្នុងថ្ងៃ ១ កើត ។

សូម្បីភិក្ខុនីសង្ឃ គប្បីបញ្ជូនភិក្ខុនីទាំងនោះទៅថា ទៅចុះអ្នកនាងម្ចាស់

ចូរសួរថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃរមែងបានការចូលមកដើម្បីទទួលឱវាទឬ ភិក្ខុនីទាំងនោះទទួលថា សាធុ អ្នកនាងម្ចាស់ ហើយទៅកាន់អារាម ចូលទៅរកភិក្ខុនោះ គប្បីពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃរមែងបានការចូលមកដើម្បីទទួលឱវាទឬ ភិក្ខុនោះគប្បីពោលថា មិនមានភិក្ខុណាមួយដែលសង្ឃសន្មតឲ្យជាអ្នកប្រៀនប្រដៅភិក្ខុនីទេ ភិក្ខុនីសង្ឃចូរឲ្យដល់ព្រមដោយកម្មដែលគួរជ្រះថ្លាចុះ ភិក្ខុនីទាំងនោះ គប្បីទទួលថា សាធុ លោកម្ចាស់ ។

លោកពោលពហុវចនៈថា **តាហិ** ដោយអំណាចនៃភិក្ខុនីទាំងឡាយដែលមកព្រមគ្នា ។ បណ្តាភិក្ខុនីទាំងនោះ ភិក្ខុនីមួយរូបគប្បីពោល និងគប្បីទទួល ។ ភិក្ខុនីក្រៅពីនេះ គប្បីជាសម្លាញ់របស់ភិក្ខុនីនោះ ។ បើភិក្ខុនីសង្ឃក្តី ភិក្ខុសង្ឃក្តី មិនគ្រប់ ( អង្គជាសង្ឃ ) ។ ឬទាំងពីរចំណែកត្រឹមតែជាគណៈក្តី បុគ្គលប៉ុណ្ណោះក្តី ភិក្ខុនីមួយរូប ត្រូវបញ្ជូនទៅអំពីសម្នាក់ភិក្ខុនីច្រើនកន្លែង ដើម្បីប្រយោជន៍ដល់ឱវាទក្តី ។ ក្នុងពាក្យថា **ភិក្ខុនីសង្ឃោ វា ឆ បូរតិ** ជាដើមនោះ មានវចនានុក្រមដូចតទៅនេះ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយរមែងថ្វាយបង្គំបាទាភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ បានឮថា ពួកភិក្ខុនីសូមបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ខ្ញុំថ្វាយបង្គំបាទាភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ បានឮថា ខ្ញុំគប្បីបានការចូលមកដើម្បី

ទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំបាទាលោកម្ចាស់ទាំងឡាយផង សូមការចូលមកដើម្បីទទួលឱវាទផង បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីសង្ឃគប្បីបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយថ្វាយបង្គំបាទាលោកម្ចាស់ទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីទាំងឡាយ គប្បីបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ខ្ញុំរមែងថ្វាយបង្គំបាទាលោកម្ចាស់ទាំងឡាយ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ ខ្ញុំគប្បីបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃរមែងថ្វាយបង្គំបាទាលោកម្ចាស់ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ បានឮថា ភិក្ខុនីសង្ឃគប្បីបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយរមែងថ្វាយបង្គំបាទាលោកម្ចាស់ផង សូមការចូលមកដើម្បីទទួលឱវាទផង បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយគប្បីបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ខ្ញុំថ្វាយបង្គំបាទាលោកម្ចាស់ផង សូមការចូលមកដើម្បីទទួលឱវាទផង បពិត្រលោកម្ចាស់ ខ្ញុំគប្បីបានចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនីគប្បីពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំភិក្ខុនីទាំងឡាយថ្វាយបង្គំ ហើយភិក្ខុនីថ្វាយបង្គំបាទារបស់ភិក្ខុសង្ឃ របស់លោកម្ចាស់ទាំងឡាយ របស់លោកម្ចាស់ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកម្ចាស់ បានឮថា ភិក្ខុសង្ឃសូមបាន ... បានឮថា ភិក្ខុនីទាំងឡាយសូមបាន ... និងបានឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ ១ ។

ភិក្ខុនោះ គប្បីពោលក្នុងវេលាធ្វើឧបោសថយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ភិក្ខុនីទាំងឡាយ រមែងថ្វាយបង្គំបាទាភិក្ខុសង្ឃ និងសូមការចូលមកដើម្បីទទួលឱវាទ បពិត្រលោកដ៏ចម្រើន បានឮថា ភិក្ខុនីទាំងឡាយសូមបានការចូលមកដើម្បីទទួលឱវាទ ។ បពិត្រលោកដ៏ចម្រើន ភិក្ខុនីថ្វាយបង្គំបាទាភិក្ខុសង្ឃផង សូមការចូលមកដើម្បីទទួលឱវាទផង បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា ភិក្ខុនីសូមបានការចូលមកដើម្បីទទួលឱវាទ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភិក្ខុនីសង្ឃ ។បេ។ បពិត្រលោកដ៏ចម្រើន ភិក្ខុនីថ្វាយបង្គំបាទារបស់លោកដ៏មានអាយុទាំងឡាយផង សូមការចូលមកដើម្បីទទួលឱវាទផង បពិត្រលោកដ៏ចម្រើន បានឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ ។ បពិត្រលោកដ៏ចម្រើន ភិក្ខុនីសង្ឃថ្វាយបង្គំ ភិក្ខុនីទាំងឡាយថ្វាយបង្គំផង ភិក្ខុនីថ្វាយបង្គំបាទារបស់ភិក្ខុសង្ឃរបស់លោកដ៏មានអាយុទាំងឡាយផង សូមការចូលមកដើម្បីទទួលឱវាទផង បានឮថា ភិក្ខុនីសង្ឃចូរបាន ... បានឮថា ភិក្ខុនីទាំងឡាយសូមបាន ... និងបានឮថា ភិក្ខុនីចូរបានការចូលមកដើម្បីទទួលឱវាទ ។

ចំណែកភិក្ខុដែលសូធ្យបាតិមោក្ខ បើមានភិក្ខុដែលសង្ឃសន្មត គប្បីពោលដោយន័យមុននោះឯងថា ភិក្ខុនីសង្ឃគប្បីចូលទៅរកភិក្ខុអង្គនោះ ភិក្ខុនីទាំងឡាយគប្បីចូលទៅរកភិក្ខុអង្គនោះ ភិក្ខុនីគប្បីចូលទៅរកភិក្ខុអង្គនោះដូច្នេះ ។ បើភិក្ខុអ្នកបានទទួលសម្មតិមិនមាន គប្បីពោលថា ភិក្ខុនីសង្ឃចូរឲ្យដល់ព្រម ដោយកម្មដែលគួរជ្រះថ្លាចុះ ភិក្ខុនីទាំងឡាយចូរឲ្យដល់ព្រម ... ភិក្ខុនីចូរឲ្យដល់ព្រមដោយកម្មដែលគួរជ្រះថ្លាចុះ ។ ភិក្ខុដែលទទួលឱវាទ គប្បីនាំត្រឡប់ទៅប្រាប់យ៉ាងនោះ ក្នុងថ្ងៃបាដិបទ ( ១ កើត ឬ ១ រោច ) ។

ភិក្ខុដទៃ វៀរភិក្ខុដែលល្ងង់ខ្លៅ ភិក្ខុអាពាធ និងភិក្ខុត្រៀមដំណើរនឹងចេញទៅ សូម្បីភិក្ខុដែលនៅព្រៃជាវត្ត នឹងមិនទទួលឱវាទមិនបាន សមដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលើកលែងតែភិក្ខុល្ងង់ លើកលែងតែភិក្ខុឈឺ និងភិក្ខុអ្នកដំណើរ ឲ្យភិក្ខុដែលក្រៅពីនេះទទួលឲ្យឱវាទបាន ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលមានបំណងនឹងទៅក្នុងថ្ងៃឧបោសថ គឺត្រង់ថ្ងៃ ១៤-១៥ កើតក្តី ក្នុងថ្ងៃបាដិបទក្តី ឈ្មោះថា អ្នកត្រៀមនឹងទៅ ។ សូម្បីទៅក្នុងថ្ងៃនៃបក្ខទី ២ នឹងមិនទទួលក៏មិនបាន គឺត្រូវអាបត្តិដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រកែកមិនព្រមទទួលឱវាទទេ ភិក្ខុណាមិនព្រមទទួលត្រូវអាបត្តិទុក្កដ ដូច្នេះនោះឯង ។

ភិក្ខុទទួលឱវាទហើយ មិនប្រាប់ក្នុងរោងឧបោសថក្តី មិនត្រឡប់ទៅប្រាប់ពួកភិក្ខុនីទាំងឡាយក្នុងថ្ងៃបាដិបទក្តី រមែងមិនគួរ ។ សមដូចពាក្យដែល

ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុមិនប្រាប់ឱវាទ ( ដល់ភិក្ខុនី ) ទេ ភិក្ខុណាមិនប្រាប់ ត្រូវអាបត្តិទុក្កដ ។ សូម្បីពាក្យដទៃក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិននាំឱវាទទៅប្រាប់មិនបាន ភិក្ខុណាមិននាំទៅប្រាប់ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ដូច្នេះ ។

បណ្តាភិក្ខុ ដែលនាំឱវាទទៅប្រាប់ទាំងនោះ ភិក្ខុដែលសមាទានអារញ្ញិកធុតង្គ គប្បីធ្វើការកំណត់សន្យាដើម្បីនាំទៅប្រាប់ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកនៅក្នុងព្រៃទទួលឲ្យឱវាទផង ឲ្យធ្វើសេចក្តីសង្កេត ( សេចក្តីកំណត់ ) ផងថា អាត្មាអញនឹងនាំទៅប្រាប់ក្នុងទីនោះ ដូច្នេះ ។ ព្រោះហេតុនោះ ភិក្ខុអ្នកនៅព្រៃជាវត្ត បើបានភិក្ខាក្នុងស្រុកដែលជាលំនៅរបស់ភិក្ខុនីទាំងឡាយ គប្បីត្រាច់ទៅក្នុងស្រុកនោះឯង ជួបពួកភិក្ខុនី ប្រាប់ហើយ សឹមទៅ ។ បើត្រង់ស្រុកនោះ កត្តជារបស់រកបានលំបាកសម្រាប់លោក គប្បីត្រាច់ទៅក្នុងស្រុកជិតខាង ហើយមកស្រុករបស់ពួកភិក្ខុនីធ្វើយ៉ាងនោះឯង ។ បើនឹងត្រូវទៅឆ្ងាយ គប្បីធ្វើការសន្យាថា ខ្ញុំនឹងចូលទៅកាន់សភា មណ្ឌប ឬគល់ឈើឈ្មោះនោះ ជិតទ្វារស្រុករបស់ពួកនាង ពួកនាងគប្បីមកត្រង់សភាជាដើមនោះ ។ ពួកភិក្ខុនីគប្បីទៅត្រង់សភាជាដើមនោះ បើមិនទៅមិនបាន ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវខានទៅកាន់ទីដែលសង្ឃកំណត់ទីហើយទេ ភិក្ខុនីណាមិនទៅ ត្រូវអាបត្តិទុក្កដដូច្នេះ ។

ក្នុងពាក្យថា **ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតុំ** នេះ មានវិនិច្ឆ័យថា ភិក្ខុនីទាំងឡាយបវារណាដោយខ្លួនឯង ក្នុងថ្ងៃ ១៤ កើត ហើយគប្បីបវារណាក្នុងភិក្ខុសង្ឃ ក្នុងថ្ងៃឧបោសថ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបវារណានឹងភិក្ខុនីសង្ឃក្នុងថ្ងៃនេះ ហើយបវារណានឹងភិក្ខុសង្ឃក្នុងថ្ងៃស្អែកទៀត ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះ ដោយន័យដូចដែលត្រាស់ទុកក្នុងភិក្ខុនីខន្ធកៈនោះឯង ។ សមដូចពាក្យដែលព្រះឧបាលីពោលទុកថា សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាបវារណាហើយ ធ្វើឲ្យកើតកោលាហល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុនី ១ រូប ដែលឆ្លាសប្រតិពលឲ្យបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ ( ជំនួសភិក្ខុនីសង្ឃ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវសន្មតយ៉ាងនេះ គប្បីសូមភិក្ខុនីជាមុន លុះសូមរួចហើយ ត្រូវភិក្ខុនីដែលឆ្លាសប្រតិពល ប្រកាសសង្ឃថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ ។ នេះជាញត្តិ ។ បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ ។ ការសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ សមគួរដល់នាងជាម្ចាស់

អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃហើយ ។ ការសន្មតសមគួរដល់សង្ឃ ព្រោះហេតុនោះ បានសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ភិក្ខុនីដែលសង្ឃសន្មតហើយនោះ គប្បីនាំភិក្ខុនីសង្ឃចូលទៅរកភិក្ខុសង្ឃ ធ្វើចីពរទៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយប្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ឥឡូវនេះ ភិក្ខុនីសង្ឃ បវារណានឹងភិក្ខុសង្ឃ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយនឹងសម្តែងចេញ ។ បពិត្រលោកម្ចាស់ទាំងឡាយ ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ ភិក្ខុនីសង្ឃសូមបវារណានឹងភិក្ខុសង្ឃ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយ នឹងសម្តែងចេញ ។

បើភិក្ខុនីសង្ឃមិនគ្រប់ ( អង្គជាសង្ឃ ) ភិក្ខុនីដែលសង្ឃសន្មតគប្បីពោល ៣ ដង យ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយបវារណាភិក្ខុសង្ឃ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី បពិត្រលោក

ម្ចាស់ សូមភិក្ខុសង្ឃអាស្រ័យសេចក្ដីអនុគ្រោះ ពោលនឹងពួកភិក្ខុនី ភិក្ខុនីទាំងឡាយឃើញហើយ នឹងសម្ដែង ឬថា បពិត្រលោកម្ចាស់ ខ្ញុំបវារណាភិក្ខុសង្ឃ ដោយបានឃើញក្ដី ដោយបានឮក្ដី ដោយរង្កៀសក្ដី បពិត្រលោកម្ចាស់ សូមភិក្ខុសង្ឃអាស្រ័យសេចក្ដីអនុគ្រោះ ស្ដីប្រដៅនឹងខ្ញុំ ខ្ញុំឃើញហើយ នឹងសម្ដែង ដូច្នេះ ។

បើភិក្ខុសង្ឃមិនគ្រប់ ( ជាសង្ឃ ) គប្បីពោល ៣ ដង យ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃបវារណានឹងលោកម្ចាស់ទាំងឡាយ ដោយបានឃើញក្ដី ដោយបានឮក្ដី ដោយរង្កៀសក្ដី សូមលោកម្ចាស់ទាំងឡាយអាស្រ័យការអនុគ្រោះ ស្ដីប្រដៅនឹងភិក្ខុនីសង្ឃ ភិក្ខុនីសង្ឃឃើញនឹងសម្ដែង ឬពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃបវារណានឹងលោកម្ចាស់ ដោយបានឃើញក្ដី ដោយបានស្ដាប់ក្ដី ដោយរង្កៀសក្ដី សូមលោកម្ចាស់ទាំងឡាយអាស្រ័យការអនុគ្រោះ ស្ដីប្រដៅនឹងភិក្ខុនីសង្ឃ ភិក្ខុនីសង្ឃឃើញ នឹងសម្ដែង ដូច្នេះ ។

កាលមិនគ្រប់សង្ឃទាំងពីរចំណែក គប្បីពោល ៣ ដង យ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ភិក្ខុនីទាំងឡាយបវារណានឹងលោកម្ចាស់ទាំង-ឡាយ ដោយបានឃើញក្ដី ដោយបានឮក្ដី ដោយរង្កៀសក្ដី សូមលោកម្ចាស់ទាំងឡាយអាស្រ័យការអនុគ្រោះ ស្ដីប្រដៅនឹងភិក្ខុនីសង្ឃ ភិក្ខុនីសង្ឃឃើញនឹងសម្ដែង ឬពោលថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយ បវារណានឹងលោកម្ចាស់ ៗ បានឃើញក្ដី ដោយបានឮក្ដី ដោយរង្កៀសក្ដី បពិត្រលោក

ម្ចាស់ សូមលោកម្ចាស់អាស្រ័យការអនុគ្រោះ ស្តីប្រដៅនឹងភិក្ខុនី ភិក្ខុនីឃើញ នឹងសម្តែង ដូច្នេះ ឬពោលថា បពិត្រលោកម្ចាស់ ខ្ញុំបវារណានឹងលោកម្ចាស់ទាំងឡាយ ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី សូមលោកម្ចាស់ទាំងឡាយអាស្រ័យការអនុគ្រោះ ស្តីប្រដៅនឹងខ្ញុំ ខ្ញុំឃើញហើយ នឹងសម្តែង ឬពោលថា បពិត្រលោកម្ចាស់ ខ្ញុំបវារណានឹងលោកម្ចាស់ដោយបានឃើញក្តី ដោយបានឮក្តី ដោយរង្កៀសក្តី សូមលោកម្ចាស់អាស្រ័យការអនុគ្រោះ ស្តីប្រដៅនឹងខ្ញុំ ខ្ញុំឃើញហើយ នឹងសម្តែង ដូច្នេះ ។

ការប្រព្រឹត្តមានត្ត និងការស្វែងរកឧបសម្បទា នឹងមានច្បាស់ក្នុងទីតាមគួរដល់ឋានៈនោះឯង ។

បទថា **ន ភិក្ខុនិយា កោចិ បរិយាយេន** សេចក្តីថា ភិក្ខុនីមិនគប្បីជេរ មិនគប្បីបរិភាសភិក្ខុដោយអក្កោសវត្ថុ ១០ ឬដោយពាក្យទ្រគោះឯណាមួយ និងមិនគប្បីគំរាមភិក្ខុដោយភ័យណាមួយឡើយ ។

បទថា **ឱវដោ** បានដល់ បិទ គឺរាំង ហាមឃាត់ ។ ពាក្យសម្តីនោះឯង ឈ្មោះថា វចនបថ ។

បទថា **អនោវដោ** បានដល់ មិនបិទ គឺមិនរាំង មិនហាមឃាត់ ។ ព្រោះហេតុនោះ ភិក្ខុនីតាំងនៅក្នុងឋានៃភាពជាឥស្សរៈ គឺក្នុងឋានៃភាពជាប្រធាន កុំគប្បីស្តីថា កុំគប្បីប្រៀនប្រដៅភិក្ខុដោយបរិយាយណាមួយថា លោកចូរឈានទៅមុខយ៉ាងនេះ លោកចូរថយក្រោយយ៉ាងនេះ ចូរស្លៀកយ៉ាងនេះ ដណ្តប់យ៉ាងនេះ ។ បើឃើញទោសហើយ នឹងសម្តែងទោសដែលមានដោយ

ន័យជាដើមថា ព្រះមហាថេរៈទាំងឡាយ ក្នុងកាលមុន រមែងមិនឈានទៅមុខ មិនឈានថយក្រោយ មិនស្លៀក មិនដណ្តប់យ៉ាងនេះ រមែងមិនទ្រទ្រង់សំពត់កាសាវៈដូច្នេះ មិនមានក្អែកយ៉ាងនេះ ដូច្នេះ គួរ ។

ចំណែកភិក្ខុទាំងឡាយ ស្តីថា ប្រៀនប្រដៅភិក្ខុនីតាមសប្បាយថា នាងសមណីចាស់នេះ រមែងស្លៀកយ៉ាងនេះ រមែងដណ្តប់យ៉ាងនេះ កុំស្លៀកយ៉ាងនេះ កុំដណ្តប់យ៉ាងនេះ កុំធ្វើកម្មទាក់ទងដោយគ្រាប់ល្ង និងទាក់ទងដោយស្លឹកឈើជាដើម គួរ ។

ពីរបទថា **សមគ្គម្ហាយ្យាតិ ភណន្តំ** បានដល់ នឹងភិក្ខុនីសង្ឃដែលពោលថា ពួកខ្ញុំព្រមព្រៀងគ្នា លោកម្ចាស់ ។

បទថា **អញ្ញំ ធម្មំ ភណតិ** បានដល់ ( បង្រៀន ) សូត្រក្តី អភិធម្មដទៃក្តី ពួកភិក្ខុនីរមែងសង្ឃឹមចំពោះឱវាទ ដោយពាក្យថា **សមគ្គម្ហាយ្យ** ព្រោះហេតុនោះ ទើបត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលពោលធម៌ដទៃ វៀរតែឱវាទ ។

ពីរបទថា **ឱវាទំ អនិយ្យាទេត្វា** បានដល់ មិនពោលថា នែប្អូនស្រីនេះឱវាទ កម្ម គឺភិក្ខុនោវាទកសម្មតិ ( ការសន្មតភិក្ខុអ្នកប្រៀនប្រដៅភិក្ខុនី ) អ្នកសិក្សាគប្បីជ្រាបថា កម្ម ក្នុងពាក្យថា **អធម្មកម្មេ** ជាដើម ។

## អធិប្បាយ

## បទភាជនីយនៃឱវាទសិក្ខាបទ

[ ២៩ ] បណ្តាកម្ម មានអធម្មកម្មជាដើមនោះ ក្នុងកម្មមិនជាធម៌ត្រូវអាបត្តិបាចិត្តិយ ១៨ ដោយអំណាច ៩ ពីរពួក ៗ ក្នុងធម្មកម្ម ជាអនាបត្តិ

ក្នុងបទចុងក្រោយនៃពួក ៩ ពួកទី ២ ។ ក្នុងបទដ៏សេស ត្រូវអាបត្តិទុក្កដ ១៧ ។

## អនាបត្តិនៃឱវាទសិក្ខាបទ

[ ៤១ ] ពីរបទថា **ឧទ្ទេសំ ទេន្តោ** បានដល់ អ្នកសម្តែងបាលីនៃគរុធម៌ ៨ ។

ពីរបទថា **បរិបុច្ឆំ ទេន្តោ** សេចក្តីថា អ្នកពោលអដ្ឋកថានៃបាលីគរុធម៌ដែលស្ទាត់ជំនាញហើយនោះឯង ។

ប្រើនបទថា **ឱសារេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ** សេចក្តីថា ភិក្ខុដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ រមែងសូធ្យបាលីគរុធម៌ ៨ ភិក្ខុដែលឲ្យឱវាទ ដែលឲ្យបរិបុច្ឆាយ៉ាងនេះ និងភិក្ខុដែលភិក្ខុនីពោលថា និមន្តសូធ្យចុះ សូធ្យគរុធម៌ ៨ មិនជាអាបត្តិបាចិត្តិយដល់ភិក្ខុនោះ មិនជាអាបត្តិទុក្កដដល់ភិក្ខុដែលពោលធម៌ដទៃ ។

ប្រើនបទថា **បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ** សេចក្តីថា ភិក្ខុនីរមែងសួរបញ្ហាអាស្រ័យគរុធម៌ក្តី អាស្រ័យធម៌ មានខន្ធជាដើមក្តី ។ មិនត្រូវអាបត្តិដល់ភិក្ខុដែលពោលឆ្លើយប្រស្នានោះ ។

ពីរបទថា **អញ្ញស្សត្ថាយ ភណន្តំ** សេចក្តីថា ភិក្ខុនីទាំងឡាយចូលទៅរកភិក្ខុដែលកំពុងសម្តែងធម៌ក្នុងបរិស័ទ ៤ ហើយស្តាប់ ។ ក្នុងការពោលដើម្បីប្រយោជន៍ដល់អ្នកដទៃនោះ ជាអនាបត្តិដល់ភិក្ខុ ។

ពីរបទថា **សិក្ខមានាយ សាមណេរិយា** គឺជាអនាបត្តិដល់ភិក្ខុដែលសម្តែងដល់សិក្ខមានា និងសាមណេរីទាំងនោះ ។ បទដ៏សេស មានអត្ថរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទ កើតឡើងតាមវាចា ១ តាមវាចា និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឱវាទសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[ ៤២ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយ ប្រដៅពួកភិក្ខុនីដោយវេនជាលំដាប់ៗ ។ សម័យនោះឯង ព្រះចូឡបន្ថកដ៏មានអាយុ ត្រូវវេនប្រដៅភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនិយាយគ្នាថា ថ្ងៃនេះ ឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់ចូឡបន្ថកគង់ពោលនូវឧទាននោះឯងដដែលៗ ឥតប្រែប្រួល ។ ភិក្ខុនីទាំងនោះនាំគ្នាចូលទៅរកព្រះចូឡបន្ថកដ៏មានអាយុ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះចូឡបន្ថកដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ឯព្រះចូឡបន្ថកដ៏មានអាយុបាននិយាយនឹងភិក្ខុនីទាំងនោះ ដែលអង្គុយនៅហើយក្នុងទីដ៏សមគួរ ដោយពាក្យយ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ ។ ពួកភិក្ខុនីតបថា ព្រមព្រៀងគ្នាហើយលោកម្ចាស់ ។ ព្រះចូឡបន្ថកសួរថា ម្នាលនាងទាំងឡាយ គរុធម៌ ៨ ចាំស្ទាត់ហើយឬ ។ ពួកភិក្ខុនីតបថា ចាំស្ទាត់ហើយលោកម្ចាស់ ។ ព្រះចូឡបន្ថកប្រាប់ថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ហើយបានពោលនូវឧទាននេះដដែលថា

> សេចក្តីសោកទាំងឡាយ រមែងមិនមានដល់មុនី ដែលមានអធិ-
> ចិត្ត មិនប្រមាទ សិក្សានៅក្នុងផ្លូវនៃមោនធម៌ ( គឺអរហ-
> ត្តញ្ញាណ ) មិនញាប់ញ័រ ( ដោយលោកធម៌ ) មានចិត្តស្ងប់

( ចាកកិលេស ) តែងមានស្មារតីជានិច្ច ។

[៤៣] ភិក្ខុនីទាំងឡាយ បាននិយាយគ្នាយ៉ាងនេះថា យើងទាំងឡាយ បាននិយាយគ្នាទុកមកហើយថា វេលាថ្ងៃនេះ ឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់ចូឡបន្ថកគង់នឹងពោលនូវឧទាននោះឯងដដែលក្នុងកាលឥឡូវហ្នឹង ។ ព្រះចូឡបន្ថកដ៏មានអាយុបានស្តាប់ពាក្យនិយាយចរចានេះរបស់ភិក្ខុនីទាំងឡាយនោះហើយ ។ គ្រានោះ ព្រះចូឡបន្ថកដ៏មានអាយុ ហោះទៅកាន់វិហាស្ថាន ហើយចង្ក្រមខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បង្ហុយផ្សែងខ្លះ បញ្ចេញពន្លឺភ្លើងខ្លះ បំបាត់ខ្លួនទៅខ្លះ ហើយពោលឧទាននោះទៀតផង និងពុទ្ធវចនៈដទៃជាច្រើនផង ព្ធដ៏អាកាសវាលទទេ ។ ភិក្ខុនីទាំងឡាយបាននិយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើងទាំងឡាយ សេចក្តីអស្ចារ្យ ( នេះ ) ចម្លែកពេកណាស់ ម្នាលគ្នាយើងទាំងឡាយ ហេតុមិនធ្លាប់កើតៗ ហើយ ឱវាទដែលសម្រេចបរិបូណ៌ ដូចជាឱវាទរបស់លោកម្ចាស់ចូឡបន្ថកយ៉ាងនេះ កាលពីដើមយើងមិនធ្លាប់បាន ( ស្តាប់ ) ទេ ។ លំដាប់នោះ ព្រះចូឡបន្ថកដ៏មានអាយុប្រដៅភិក្ខុនីអម្បាលនោះដរាបដល់យប់ ហើយបញ្ជូនទៅវិញថា ម្នាលនាងទាំងឡាយ ពួកនាងចូរទៅចុះ ។ វេលានោះទ្វារនគរគេបិទហើយ ភិក្ខុនីទាំងនោះ ក៏នៅខាងក្រៅនគរ លុះព្រឹកឡើងទើបចូលទៅកាន់នគរ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយនេះ មិនមែនជាព្រហ្មចារិនី ( មិនមែនជាអ្នកប្រព្រឹត្តល្អ ) ទេ នៅជាមួយនឹងភិក្ខុទាំងឡាយ ក្នុងអារាមហើយ ទើបតែចូលមកកាន់នគរក្នុងកាលឥឡូវនេះ ។

ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សអេម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ចូឡបន្ថកដ៏មានអាយុ កាលព្រះអាទិត្យអស្តង្គតហើយ មិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលចូឡបន្ថក ឮថា កាលព្រះអាទិត្យអស្តង្គត ហើយអ្នកឯងទៅប្រដៅភិក្ខុនីទាំងឡាយពិតមែនឬ ។ ព្រះចូឡបន្ថកដ៏មានអាយុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលចូឡបន្ថក កាលព្រះអាទិត្យអស្តង្គតទៅហើយ អ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ម្នាលចូឡបន្ថក អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខានេះយ៉ាងនេះថា ភិក្ខុបើទុកជាសង្ឃបានសន្មតហើយ កាលបើព្រះអាទិត្យអស្តង្គតហើយ ទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។

[៤៤] ដែលហៅថា សង្ឃបានសន្មតនោះ គឺសង្ឃសន្មតដោយញត្តិចតុត្ថកម្មវាចា ។ ត្រង់ពាក្យថា ព្រះអាទិត្យអស្តង្គតហើយ សេចក្តីថា ព្រះអាទិត្យលិចចុះហើយ ។ ពួកស្រីដែលបានឧបសម្បទាក្នុងជំនុំសង្ឃ ២ ចំណែក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ សេចក្តីថា ភិក្ខុប្រដៅភិក្ខុនីដោយគរុធម៌ ៨ ក្តី ដោយធម៌ដទៃក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៤៥] ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសម្គាល់ថា អស្តង្គតមែន ហើយ

ទៅប្រដៅ ( ភិក្ខុនី ) ត្រូវអាបត្តិបាចិត្តិយ ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសម្គាល់ថា មិនទាន់អស្តង្គត ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រដៅភិក្ខុនីដែលឧបសម្បទាហើយក្នុងជំនុំសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យ មិនទាន់អស្តង្គត ភិក្ខុសម្គាល់ថាអស្តង្គតហើយ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសម្គាល់ថាមិនទាន់អស្តង្គត មិនត្រូវអាបត្តិអ្វីឡើយ ។

[៤៦] អាបត្តិមិនមានដល់ភិក្ខុដែលសម្តែងនូវបាលីនៃគរុធម៌ ៨ ដល់ភិក្ខុដែលសម្តែងនូវអដ្ឋកថានៃគរុធម៌ ៨ ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសម្តែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា
# ឱវាទវគ្គទី ៣
# អត្ថង្គតសិក្ខាបទ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ២ ដូចតទៅនេះ*

[ ៤២ ] *បទថា* **បរិយាយេន** *គឺតាមវារៈ សេចក្តីថា តាមលំដាប់ ។*

*បទថា* **អធិចេតសោ** *គឺដែលមានអធិចិត្ត អធិប្បាយថា បុគ្គលប្រកប ដោយចិត្តដែលក្រៃលែងជាងចិត្តទាំងអស់ គឺអរហត្តផលចិត្ត ។*

*បទថា* **អប្បមជ្ជតោ** *គឺបុគ្គលមិនប្រមាទ មានពាក្យអធិប្បាយថា បុគ្គល ប្រកបដោយការបំពេញកុសលធម៌ជាប់តគ្នា ដោយសេចក្តីមិនប្រមាទ ។*

*បទថា* **មុនិនោ** *សេចក្តីថា ញាណ ត្រាស់ហៅថា* **មោន** *ព្រោះដឹង លោកទាំងពីរយ៉ាងនេះថា បុគ្គលណារមែងដឹងលោកទាំង ២ បុគ្គលនោះ តថាគតហៅថា មុនី ព្រោះហេតុនោះ ឬព្រះខីណាស្រព លោកហៅថា មុនី ព្រោះប្រកបដោយញាណនោះ ដល់មុនីនោះ ។*

*ពីរបទថា* **មោនបថេសុ សិក្ខតោ** *សេចក្តីថា អ្នកសិក្សានៅក្នុងផ្លូវនៃ ញាណឈ្មោះ* **មោន** *ពោល គឺអរហត្តមគ្គញាណ គឺក្នុងពោធិបក្ខិយធម៌ ៣៧ ក្តី ក្នុងត្រៃសិក្ខាក្តី ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយកបដិបទា ជាចំណែកខាងដើម ។ ព្រោះដូច្នោះ អ្នកសិក្សាគប្បីឃើញអត្ថក្នុងពាក្យថា* **មុនិនោ មោនបថេសុ សិក្ខតោ** *នេះ យ៉ាងនេះថា មុនី អ្នកសិក្សានៅក្នុង ធម៌ជាចំណែកខាងដើមយ៉ាងនេះ ដល់នូវភាពជាមុនី ដោយការសិក្សានេះ ។*

បទព្រះគាថាថា **សោកា ន ភវន្តិ តាទិនោ** សេចក្តីថា សេចក្តីសោកទាំងឡាយ ព្រោះរឿងព្រាត់ប្រាសចាកឥដ្ឋារម្មណ៍ជាដើមជាខាងក្នុង ( ក្នុងចិត្ត ) រមែងមិនមានដល់ព្រះខីណាសវមុនី ដែលជាអ្នកមិនញាប់ញ័រ ។ ម្យ៉ាងទៀត ក្នុងបទថា **តាទិនោ** នេះ មានអត្ថយ៉ាងនេះថា សេចក្តីសោកទាំងឡាយ រមែងមិនមានដល់មុនី ដែលប្រកបដោយលក្ខណៈ មិនញាប់ញ័រមានសភាពបែបនេះ ។

បទថា **ឧបសន្តស្ស** បានដល់ អ្នកស្ងប់រម្ងាប់ ព្រោះស្ងប់កិលេសមានរាគៈជាដើមបាន ។

បទថា **សទា សតីមតោ** បានដល់ ភិក្ខុមិនវៀរចាកសតិអស់កាលជានិច្ច ព្រោះជាអ្នកដល់នូវការបរិបូណ៌នៃសតិ ។

[ ៤៣ ] ពីរបទថា **អាកាសេ អន្តលិក្ខេ** បានដល់ ក្នុងអាកាសពោល គឺកណ្តាលវេហាស៍ មិនមែនអាកាសដែលបើកកសិណ និងមិនមែនអាកាស ជាគ្រឿងកំណត់រូប ។

ពីរបទថា **ចង្កមតិបិ តិដ្ឋតិបិ** សេចក្តីថា ព្រះចុល្លបន្ថកត្ថេរបានឮពាក្យរបស់ភិក្ខុនីទាំងនោះ គិតថា ភិក្ខុនីទាំងនេះ មើលស្រាលអាត្មាអញថា ព្រះថេរៈអង្គនេះ ចេះធម៌ប្រមាណប៉ុណ្ណោះឯង ណ្ហើយចុះ ឥឡូវនេះ អញនឹងសម្តែងអានុភាពរបស់ខ្លួនដល់ភិក្ខុនីទាំងនេះ ទើបញ៉ាំងសេចក្តីគោរពច្រើនក្នុងធម៌ឲ្យកើតឡើងហើយ ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញហើយសម្តែងឥទ្ធិបាដិហារិយ៍ដែលមានសភាពបែបនេះ គឺដើរចង្រ្កមក្នុងអាកាស

កណ្ដាលវេហាស៍ខ្លះ ។បេ។ បាត់ខ្លួនទៅក្នុងថ្មខ្លះ ។

បណ្ដាបទទាំងនោះ បទថា **អន្តរធាយតិបិ** សេចក្ដីថា បាត់ខ្លួនខ្លះ គឺមិនប្រាកដឲ្យឃើញខ្លះ ។

បទថា **តញ្ចេវ ឧទានំ ភណតិ អញ្ញាញ្ច ពហុំ ពុទ្ធវចនំ** សេចក្ដីថា បានឮថា ព្រះថេរៈត្រូវឲ្យរៀនគាថានេះរបស់ព្រះថេរៈ ដែលជាបងរបស់ខ្លួនថា

ផ្កាឈូក ( ក្រហមប្រាល ) រីកក្នុងវេលាព្រឹក មានក្លិនក្រអូប មិនប្រាសចាកក្លិន យ៉ាងណា អ្នកចូរមើលនូវព្រះ-សម្មាសម្ពុទ្ធ មានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿងដូចព្រះអាទិត្យដែលរុងរឿងក្នុងអាកាស យ៉ាងនោះឯង ។

ព្រះថេរៈបានស្វាធ្យាយ ដល់ទៅ ៤ ខែ តែមិនអាចធ្វើឲ្យចាំស្ទាត់បាន ។

គ្រានោះ ព្រះថេរៈ ( ជាបង ) ទើបបណ្ដេញព្រះចុល្លបន្ថកៈនោះទៅអំពីវិហារ ដោយពោលថា លោកជាអភព្វបុគ្គលក្នុងសាសនានេះ ។ លោកបានឈរយំត្រង់ខ្លោងទ្វារ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលពុទ្ធវេនេយ្យសត្វ ទតឃើញលោកហើយ ទើបយាងទៅក្បែរលោក ដូចយាងចារិកទៅកាន់វិហារចារិក ត្រាស់ថា ចុល្លបន្ថកៈ អ្នកយំធ្វើអ្វី ទើបព្រះថេរៈក្រាបទូលរឿងរ៉ាវនោះ ។ លំដាប់នោះ ទើបព្រះមានព្រះភាគទ្រង់ប្រទានកំណាត់សំពត់ដ៏ស្អាតដល់លោក ត្រាស់ថា អ្នកចូរអង្អែលសំពត់នេះ បរិកម្មថា សំពត់ជូតធូលី ។ លោកទទួលថា សាធុ ហើយអង្គុយក្នុងលំនៅរបស់

ខ្ជួន អង្កែលទីបំផុតផ្នែកមួយនៃសំពត់នោះ ។ ទីដែលត្រូវស្នាបអង្កែលនោះ បានក្លាយជាពណ៌ខ្មៅ ។ លោកត្រឡប់បានសេចក្តីសង្វេគថា ឱ ! សំពត់បរិសុទ្ធយ៉ាងនេះ អាស្រ័យអត្តភាពនេះ ត្រឡប់ជាមានពណ៌ខ្មៅ ដូច្នេះ ហើយទើបប្រារព្ធវិបស្សនា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា លោកប្រារព្ធសេចក្តីព្យាយាម ទ្រង់បានភាសិតឱភាសគាថានេះថា **អធិចេតសោ** ជាដើម ។ ព្រះថេរៈសម្រេចអរហត្តផលក្នុងវេលាចប់គាថា ព្រោះហេតុនោះ ទើបព្រះថេរៈគោរពស្រឡាញ់គាថានេះតាមប្រក្រតីនេះឯង ។ លោកពោលគាថានោះ ដើម្បីឲ្យជ្រាបការគោរព និងស្រឡាញ់គាថានេះ និងនាំពុទ្ធវចនៈដទៃដែលនាំមកពោលក្នុងចន្លោះ ។ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យទាំងឡាយពោលថា ពោលនូវឧទាននោះឯង និងពុទ្ធវចនៈដទៃដ៏ច្រើន ។

## អធិប្បាយ

## បទភាជនីយនៃអត្ថង្គតសិក្ខាបទ

[ ៤៥ ] ពីរបទថា **ឯកតោ ឧបសម្បន្នាយ** បានដល់ ភិក្ខុនីដែលឧបសម្បទាក្នុងភិក្ខុនីសង្ឃ ។ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលពោលប្រៀនប្រដៅភិក្ខុនី ដែលឧបសម្បទាក្នុងភិក្ខុសង្ឃ ។ បទដ៏សេសក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ហើយ ។ សិក្ខាបទនេះ មានសមុដ្ឋានដូចបទសោធម្មសិក្ខាបទនោះឯង ។

អត្ថង្គតសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[៤៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនឈ្មោះសក្កៈ ។ គ្រានោះឯង ឆព្វគ្គិយភិក្ខុទាំង-ឡាយ ចូលទៅកាន់លំនៅរបស់ភិក្ខុនី ហើយប្រដៅឆព្វគ្គិយភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយ បាននិយាយបបួលឆព្វគ្គិយភិក្ខុនីយ៉ាងនេះថា ម្នាលនាងទាំង-ឡាយ ពួកនាងចូរមកយើងនឹងទៅទទួលឱវាទ ( ជាមួយគ្នា ) ។ ឆព្វគ្គិយ-ភិក្ខុនីនិយាយថា ម្នាលនាងទាំងឡាយ យើងទាំងឡាយនាំគ្នាទៅព្រោះហេតុនៃឱវាទធ្វើអ្វី ដ្បិតឆព្វគ្គិយភិក្ខុជាម្ចាស់ទាំងឡាយ មកប្រដៅពួកយើងក្នុងលំនៅនេះហើយ ។ ភិក្ខុនីទាំងឡាយនាំគ្នាពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងចូលដល់លំនៅភិក្ខុនី ហើយប្រដៅភិក្ខុនីទាំង-ឡាយទេ ។ លំដាប់នោះ ភិក្ខុនីអម្បាលនោះប្រាប់ដំណើរនោះដល់ភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំង-ឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនី ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនី ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំង-ឡាយ ពួកអ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនី

ទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៤៨] សម័យនោះឯង ព្រះមហាបជាបតិគោតមីភិក្ខុនីមានជំងឺ ភិក្ខុជាថេរៈទាំងឡាយ ចូលទៅកាន់លំនៅព្រះមហាបជាបតិគោតមីភិក្ខុនី លុះចូលទៅដល់ហើយ បាននិយាយសួរព្រះមហាបជាបតិគោតមីភិក្ខុនីយ៉ាងនេះថា ម្នាលព្រះនាងគោតមី សរីរយន្តព្រះនាង ល្មមអត់ទ្រាំបានដែរឬទេ ល្មមប្រព្រឹត្តទៅបានស្រួលដែរឬទេ ។ ព្រះមហាបជាបតិគោតមីភិក្ខុនីតបថា លោកម្ចាស់ សរីរយន្តខ្ញុំមិនអាចអត់ទ្រាំបានទេ ខ្ញុំមិនអាចប្រព្រឹត្តទៅបានស្រួលទេ បពិត្រលោកម្ចាស់ទាំងឡាយ ណ្ហើយចុះ សូមពួកលោកម្ចាស់សំដែងធម៌ឲ្យទាន ។ ភិក្ខុទាំងនោះនិយាយថា ម្នាលនាង កិរិយាដែលភិក្ខុចូលមកកាន់លំនៅរបស់ភិក្ខុនី ហើយសំដែងធម៌ដល់ភិក្ខុនី មិនគួរឡើយ ហើយមានសេចក្តីសង្ស័យ ( យ៉ាងនេះ ) ក៏មិនហ៊ានសំដែងធម៌ឡើយ ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ស្បៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ ក្នុងវេលាព្រឹក ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់ព្រះមហាបជាបតិគោតមី លុះដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេតាំងទុក ។ ព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទ្រង់ត្រាស់សួរព្រះមហាបជាបតិគោតមីយ៉ាងនេះថា ព្រះ

នាងគោតមី សរីរយន្តព្រះនាងល្មមអត់ទ្រាំបានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានស្រួលដែរឬ ។ ព្រះនាងទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលមុនភិក្ខុជាថេរៈទាំងឡាយ មកសម្តែងធម៌ដល់ខ្ញុំព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គមានសេចក្តីសប្បាយ ក៏ឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហើយ ព្រោះហេតុនោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្តីខ្លាចក្រែង ទើបមិនហ៊ានសម្តែង សេចក្តីមិនសប្បាយមានដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ព្រះមហាបជាបតិគោតមីឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីដែលមានជំងឺបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុនីមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[៤៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុនីទាំងឡាយនៅក្នុងទីណា សូម្បីអស់រាត្រី ១ ទីនោះហៅថា ទីនៅរបស់ភិក្ខុនី ។ ពាក្យថា ចូលដល់ គឺទៅក្នុងទីនោះ ។ ពួកស្រីដែលបានឧបសម្បទាក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ

គឺភិក្ខុប្រដៅដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកលែងតែមានសម័យ ។ ភិក្ខុនីមិនអាចទៅទទួលឱវាទ ឬទៅនៅរួមសង្ឃកម្មបាន ហៅថា មានជំងឺ ។

[៥០] ភិក្ខុសម្គាល់ភិក្ខុនីដែលបានឧបសម្បទាហើយ ថាបានឧបសម្បទាមែន ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងភិក្ខុនីដែលបានឧបសម្បទាហើយ ចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុនីឧបសម្បទាហើយ ភិក្ខុសម្គាល់ថា មិនទាន់បានឧបសម្បទាទេ ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុប្រដៅភិក្ខុនីដោយធម៌ដទៃ ( ក្រៅពីគរុធម៌ ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងស្រីមិនទាន់បានឧបសម្បទា ថាបានឧបសម្បទាហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងស្រីដែលមិនទាន់បានឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងស្រីដែលមិនទាន់បានឧបសម្បទា ថាមិនទាន់ឧបសម្បទាមែន មិនត្រូវអាបត្តិអ្វីឡើយ ។

[ ៥១ ] អាបត្តិមិនមានដល់ភិក្ខុដែលប្រដៅភិក្ខុនីក្នុងសម័យ ដល់ភិក្ខុដែលសំដែងបាលីនៃគរុធម៌ ៨ ដល់ភិក្ខុដែលសំដែងអដ្ឋកថានៃគរុធម៌ ៨ ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ ដើម្បីអ្នក

ជទៃ ហើយភិក្ខុនីចូលស្ដាប់ផង ដល់ភិក្ខុដែលប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា
# ឱវាទវគ្គទី ៣
# ភិក្ខុនីឧបស្សយសិក្ខាបទ

គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៣ ដូច្នេះថា

[ ៥០ ] ក្នុងពាក្យជាដើមថា **អញ្ញត្រ សមយា ឱវទតិ អាបត្តិ បាចិត្តិយស្ស** ជាដើម បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុ ដែលពោលប្រៀនប្រដៅដោយគរុធម៌ ៨ ប៉ុណ្ណោះ ពោលបង្រៀនដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។

ពីរបទថា **ឯកតោ ឧបសម្បន្នំ** បានដល់ ភិក្ខុនីដែលឧបសម្បទាក្នុងភិក្ខុនីសង្ឃ ។ តែត្រូវអាបត្តិបាចិត្តិយពិត ដល់ភិក្ខុដែលពោលបង្រៀនភិក្ខុនីដែលឧបសម្បទាក្នុងពួកភិក្ខុសង្ឃ ។ម្យ៉ាងទៀត ខាងមុខអំពីនេះទៅ ក្នុងទីគ្រប់អន្លើនៃពាក្យដែលលោកពោលទុកថា **ឯកតោ ឧបសម្បន្នំ** បណ្ឌិតគប្បីឃើញអត្ថយ៉ាងនេះដូចគ្នា ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមកាយ និងវាចា ១ តាមវាចា និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ភិក្ខុនីឧបស្សយសិក្ខាបទ ចប់

# បកិណ្ណកៈក្នុងភិក្ខុនីឧបស្សយសិក្ខាបទ

ក្នុងសិក្ខាបទទី ៣ នេះ លោកពោលបកិណ្ណកៈទុកក្នុងមហាបច្ចរី ដូចតទៅនេះថា បើភិក្ខុមិនបានទទួលសម្មតិ កាលព្រះអាទិត្យអស្តង្គតហើយ ចូលទៅកាន់សម្នាក់ភិក្ខុនី ពោលទូន្មានដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ៣ ។ កាលទូន្មានដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ ២ បាចិត្តិយ ១ ។

សេចក្តីនេះដូចម្តេច សេចក្តីថា ត្រូវទុក្កដ មានការមិនបានទទួលសន្មតជាមូល ១ ត្រូវអាបត្តិទុក្កដ មានការចូលទៅកាន់សម្នាក់ភិក្ខុនី ហើយពោលទូន្មានដោយធម៌ដទៃជាមូល ១ ត្រូវអាបត្តិបាចិត្តិយ មានការពោលទូន្មានកាលព្រះអាទិត្យអស្តង្គតហើយជាមូល ១ ។ ភិក្ខុបានទទួលសន្មតហើយកាលព្រះអាទិត្យអស្តង្គតហើយ ទៅក្នុងសម្នាក់ភិក្ខុនីនោះ ពោលទូន្មានដោយគរុធម៌ ៨ ជាអនាបត្តិ ១ និងត្រូវបាចិត្តិយ ២ ។

សេចក្តីនេះដូចម្តេច សេចក្តីថា ជាអនាបត្តិ ព្រោះជាអ្នកបានទទួលសន្មត ជាបាចិត្តិយ ២ គឺព្រោះពោលទូន្មានក្នុងកាលព្រះអាទិត្យអស្តង្គតហើយជាមូល ១ មានការទៅពោលទូន្មានដោយគរុធម៌ ៨ ជាមូល ១ ។ ភិក្ខុពោលទូន្មានដោយធម៌ដទៃនោះឯង ជាអនាបត្តិ ១ ជាទុក្កដ ១ ជាបាចិត្តិយ ១ ។

សេចក្តីនេះដូចម្តេច សេចក្តីថា ជាអនាបត្តិ ព្រោះបានទទួលសន្មត ជាទុក្កដ ព្រោះមានការទៅពោលទូន្មានដោយធម៌ដទៃជាមូល ១ ជាបាចិត្តិយមានការពោលទូន្មានក្នុងកាលព្រះអាទិត្យលិចហើយជាមូល ១ ។ តែសម្រាប់ភិក្ខុដែលបានទទួលសន្មតក្តី មិនបានទទួលសន្មតក្តី ទៅពោលទូន្មានក្នុងពេល

ថ្ងៃ បណ្ឌិតគប្បីទាញអាបត្តិបាចិត្តិយ មានការពោលទូន្មានក្នុងពេលយប់ជាមូលចេញ ១ ហើយជ្រាបអាបត្តិ និងអនាបត្តិដ៏សេសដូច្នេះឯង ។

បកិណ្ណកៈក្នុងភិក្ខុនីឱបស្សយសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[៥២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី តែងបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ ពួកឆព្វគ្គិយភិក្ខុនិយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ថ្វីឡើយ ពួកឆព្វគ្គិយភិក្ខុមកនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយនិយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់ និងប្រៀនប្រដៅពួកភិក្ខុនីប៉ុន្មានទេ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំង-ឡាយ ក៏ថ្វីឡើយ ពួកអ្នកឯងមកពោលយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ

មិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំង-ឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ពោលយ៉ាងនេះថា ភិក្ខុទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ត្រូវអាបត្តិបាចិត្តិយ ។

[៥៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ព្រោះហេតុតែអាមិស សេចក្ដីថា ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា ។

[៥៤] ពាក្យថា ពោលយ៉ាងនេះ សេចក្ដីថា ភិក្ខុណាប្រាថ្នាដើម្បីនឹងធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីនឹងធ្វើបន្អាប់យស ប្រាថ្នាដើម្បីនឹងធ្វើនូវសេចក្ដីបន្អាប់បន្ថោនចំពោះឧបសម្បន្នដែលសង្ឃសន្មត ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា ( ភិក្ខុនោះ ) ត្រូវអាបត្តិបាចិត្តិយ ។

[៥៥] កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌មែន ហើយពោលយ៉ាង

នេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនមែនជាធម៌វិញ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។

[៥៦] ភិក្ខុណាប្រាថ្នាដើម្បីធ្វើនូវពាក្យជំនៀល ប្រាថ្នាដើម្បីធ្វើបន្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបន្អាប់បន្អោនចំពោះឧបសម្បន្នដែលសង្ឃមិនបានសន្មតឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។

[ ៥៧ ] ភិក្ខុណាប្រាថ្នាដើម្បីធ្វើនូវពាក្យជំនៀល ប្រាថ្នាដើម្បីធ្វើបន្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបន្អាប់បន្អោនចំពោះអនុបសម្បន្នបុគ្គលដែលសង្ឃសន្មតក្តី មិនបានសន្មតក្តី ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺពោលថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។

[៥៨] កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មជាធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសម្គាល់ថា កម្មមិនមែនជាធម៌ ត្រូវអាបត្តិទុក្កដ ។

[៥៩] អាបត្តិមិនមានដល់ភិក្ខុដែលពោលចំពោះភិក្ខុផងគ្នា ដែលជាអ្នកប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជាដោយប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់

# អដ្ឋកថា

## ឱវាទវគ្គទី ៣

## អាមិសសិក្ខាបទ

[៥២] វិនិច្ឆ័យក្នុងសិក្ខាបទទី ៤ គប្បីជ្រាបដូច្នេះថា បទថា **ន ពហុ-កតា** គឺមិនធ្វើការតាំងចិត្ត ( ទូន្មានពិត ) អធិប្បាយថា មិនធ្វើការគោរព ច្រើនក្នុងធម៌ពោលទូន្មាន ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃអាមិសសិក្ខាបទ

[ ៥៤ ] អ្នកសិក្សាគប្បីជ្រាបអត្ថនៃបទទាំងឡាយថា **ភិក្ខុនោវាទកំ អវណ្ណំ កត្តុកាមោ** ជាដើម ដោយន័យដូចដែលពោលហើយ ក្នុងឧជ្ឈាប-នកសិក្ខាបទនោះឯង ។

## អធិប្បាយ

## បទភាជនីយនៃអាមិសសិក្ខាបទ

[ ៥៦ ] ភិក្ខុដែលបានទទួលសម្មតិក្តី សង្ឃប្រគល់ភារៈឲ្យក្តី គប្បីជ្រាប ថា ឈ្មោះថា ភិក្ខុមិនបានទទួលសន្មតិ ក្នុងពាក្យថា **ឧបសម្បន្នំ សង្ឃេន អសម្មតំ** នេះ ។

[ ៥៧ ] ឯក្នុងពាក្យថា **អនុបសម្បន្នំ សង្ឃេន សម្មតំ វា អសម្មតំ វា** នេះ ភិក្ខុដែលបានទទួលសន្មតកាលនៅជាភិក្ខុ ហើយតាំងនៅក្នុងភូមិនៃ

សាមណេរ គប្បីជ្រាបថា បានទទួលសន្មតិ ។ សាមណេរដែលជាពហូស្សុត ត្រូវភិក្ខុ អ្នកបានទទួលសន្មតិ ឬសង្ឃប្រគល់ភារៈឲ្យ គប្បីជ្រាបថា ជាអ្នកមិនបានទទួលសន្មតិ ពាក្យដ៏សេសរាក់ទាំងអស់ហើយ ព្រោះមានន័យដូចពោលហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខ-វេទនា ដូច្នេះ ។

អាមិសសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ៦០ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាតតាមផ្លូវឬច្រកមួយ ក្នុងក្រុងសាវត្ថី ។ មានភិក្ខុនីមួយរូបទៀត ក៏ត្រាច់ទៅបិណ្ឌបាតតាមផ្លូវ ឬច្រកនោះដែរ ។ ទើបភិក្ខុនោះ និយាយនឹងភិក្ខុនីនោះយ៉ាងនេះថា ម្នាលនាង នាងចូរទៅក្នុងឱកាសឯណោះ គេប្រគេនភិក្ខា ។ ឯភិក្ខុនីនោះក៏និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ចូរទៅក្នុងឱកាសឯណោះចុះ គេប្រគេនចង្ហាន់ ។ ភិក្ខុ និងភិក្ខុនីនេះបានស្គាល់គ្នា ព្រោះបានឃើញគ្នាញឹកញយ ។ គ្រានោះឯង សង្ឃកំពុងចែកចីវរគ្នា ។ លំដាប់នោះ ភិក្ខុនីនោះកាលទៅទទួលឱវាទ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ថ្វាយបង្គំភិក្ខុនោះហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ ភិក្ខុនោះបាននិយាយនឹងភិក្ខុនីដែលឋិតនៅក្នុងទីដ៏សមគួរនោះ យ៉ាងនេះថា ម្នាលនាង ចំណែកចីវរនេះរបស់យើង នាងនឹងត្រូវការដែរឬទេ ។ ភិក្ខុនីនោះឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំករុណាមានចីវរចាស់ហើយ ។ ភិក្ខុនោះឲ្យចីវរដល់ភិក្ខុនីនោះ ។ ចំណែកភិក្ខុនោះជាអ្នកមានចីវរទុព្វលភាព ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរធ្វើចីវររបស់អ្នកក្នុងកាលឥឡូវនេះចុះ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំង-ឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោល

ទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមគួរនឹងឲ្យចីវរដល់ភិក្ខុនីទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងបានឲ្យចីវរដល់ភិក្ខុនី ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលតបថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ភិក្ខុនីនោះជាញាតិរបស់អ្នកឯង ឬមិនមែនញាតិទេ ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស បុរសមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរ ឬមិនសមគួរ ល្អិតល្អ ឬមិនល្អិតល្អ របស់ស្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនគួរនឹងឲ្យចីវរដល់ភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឲ្យចីវរដល់ភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៦១] សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យ មិនហ៊ានផ្លាស់ប្តូរចីវរនឹងភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនាំគ្នាពោលទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបីនឹងមិនហ៊ានផ្លាស់ប្តូរចីវរនឹងពួកយើងសោះ ភិក្ខុទាំងឡាយបានឮពួកភិក្ខុនីនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ហើយទ្រង់ហៅ

ភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ គឺភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ នេះបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឲ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ វៀរតែផ្លាស់ប្តូរគ្នា ។

[៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានសម្ពន្ធជាប់ជាវង្សគ្នាមកអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនជាញាតិ ។ ស្រីដែលបានឧបសម្បទាហើយ ក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតដ៏គួរដល់វិកប្បបាន ហៅថា ចីវរ ។ ពាក្យថា វៀរលែងតែផ្លាស់ប្តូរគ្នា សេចក្តីថា ភិក្ខុឲ្យ ( ចីវរដល់ភិក្ខុនីមិនមែនញាតិ ) ត្រូវអាបត្តិបាចិត្តិយ លើកលែងតែផ្លាស់ប្តូរគ្នា ។

[៦៣] ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ ភិក្ខុឲ្យចីវរដល់ភិក្ខុនីដែលបានឧបសម្បទា

អំពីសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ វៀរលែងតែផ្លាស់ប្តូរគ្នា ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ ។

[ ៦៤ ] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុដែលផ្លាស់ប្តូរចីវរគ្នា ដល់ភិក្ខុដែលប្តូរយកចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច ឬចីវរមានតម្លៃតិច ដោយចីវរមានតម្លៃច្រើន ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវររបស់ខ្លួនដោយសេចក្តីស្និទ្ធស្នាល ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវរ ជារបស់ខ្ចីគ្នា ដល់ភិក្ខុដែលឲ្យបរិក្ខារដទៃ វៀរលែងតែចីវរ ដល់ភិក្ខុដែលឲ្យចីវរដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា
## ទុតិយវគ្គទី ៣
## ចីវរទានសិក្ខាបទ

[៦០] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៥ ដូច្នេះថា បទថា **វិសិខាយ** ប្រែថា ក្នុងច្រកផ្លូវ ។

ពីរបទថា **បិណ្ឌាយ ចរតិ** សេចក្ដីថា រមែងត្រាច់ទៅរឿយៗ ដោយអំណាចនៃការត្រាច់ទៅជាប្រចាំ ។

បទថា **សន្ទិដ្ឋា** គឺបានជាសម្លាញ់ឃើញគ្នា ។ បទដ៏សេសក្នុងសិក្ខាបទនេះ ដោយបទមានអត្ថពាក់ ដោយវិនិច្ឆ័យគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងចីវរបដិគ្គហនសិក្ខាបទនោះឯង មួយអន្លើដោយសមុដ្ឋានជាដើម ។ ពិតហើយ ក្នុងចីវរបដិគ្គហនសិក្ខាបទនោះ ភិក្ខុជាអ្នកទទួល ឯក្នុងសិក្ខាបទនេះ ភិក្ខុនីជាអ្នកទទួល នេះជាការប្លែកគ្នា ពាក្យដ៏សេសទាំងអស់ដូចគ្នានោះឯង ។

ចីវរទានសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[ ៦៥ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ជាអ្នកប្រសប់ធ្វើចីវរកម្ម ។ មានភិក្ខុនីមួយរូបចូលទៅកាន់ទីដែលឧទាយិដ៏មានអាយុនៅ លុះចូលទៅដល់ហើយ បាននិយាយនឹងឧទាយិដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ដេរចីវរឲ្យខ្ញុំផង ។ គ្រានោះ ឧទាយិដ៏មានអាយុក៏ដេរចីវរ ហើយធ្វើកិច្ចជ្រលក់គក់បោកដ៏ល្អ រួចធ្វើរូបគំនូរត្រង់កណ្តាលចីវរ ស្រេចហើយ បត់ទុកឲ្យភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុនីនោះទៅកាន់លំនៅឧទាយិដ៏មានអាយុ លុះទៅដល់ហើយ បាននិយាយនឹងឧទាយិដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ចីវររបស់លោកម្ចាស់នោះដូចម្តេចទៅ ។ ឧទាយិឆ្លើយថា ម្នាលប្អូនស្រី ហ៏ នាងចូរនាំយកចីវរនេះទៅទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឃមកទទួលឱវាទ ចូរដណ្តប់ចីវរនេះ ដើរទៅតាមក្រោយៗ ភិក្ខុនីសង្ឃក្នុងកាលណោះ ។ លំដាប់នោះ ភិក្ខុនីនោះនាំយកចីវរនោះទៅ ទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឃមកទទួលឱវាទ នាងក៏ដណ្តប់ចីវរនោះដើរទៅតាមក្រោយៗ ភិក្ខុនីសង្ឃ ក្នុងកាលណោះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីអម្បាលនេះ ជាស្រីគ្មានកោតញញើត ជាស្រីអ្នកលេង គ្មានអៀនខ្មាស មិនសមបើនឹងគូរគំនូរក្នុងចីវរសោះ ។ ភិក្ខុនីទាំងឡាយបាននិយាយ សួរគ្នាយ៉ាង

នេះថា នេះជាការងាររបស់អ្នកណា ភិក្ខុនីទាំងឡាយឆ្លើយថា នេះជាការងាររបស់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនិយាយគ្នាថា ជនទាំងឡាយណាជាអ្នកគ្មានសេចក្តីកោតញញើត ជាអ្នកលេង ជាអ្នកគ្មានសេចក្តីអៀនខ្មាស កម្មមានសភាពយ៉ាងនេះ ក៏គង់មិនល្អដល់ជនទាំងឡាយនោះ នឹងពោលទៅថ្វីដល់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនោះនាំគ្នាប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុ មិនគួរនឹងដេរចីវរដល់ភិក្ខុនីសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧទាយិ ឮថា អ្នកឯងដេរចីវរឲ្យភិក្ខុនីពិតមែនឬ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែឧទាយិ ភិក្ខុនីនោះជាញាតិរបស់អ្នកឯង ឬមិនមែនជាញាតិទេ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស មិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស ប្រុសដែលមិនមែនជាញាតិ រមែងមិនស្គាល់កម្មដ៏សមគួរក្តី មិនសមគួរក្តី កម្មជាទីជ្រះថ្លាក្តី មិនជាទីជ្រះថ្លាក្តីរបស់ស្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនសមគួរនឹងដេរចីវរឲ្យភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ដេរឯង ឬប្រើគេឲ្យដេរនូវចីវរឲ្យភិក្ខុនីមិនមែនញាតិ ( ភិក្ខុនោះ ) ត្រូវអាបត្តិបាចិត្តិយ ។

[៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានជាប់តវង្សត្រកូលមកអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគួជីដូនជីតា ជាគម្រប់ ៧ ហៅថា មិនមែនញាតិ ។ ស្រីដែលបានឧបសម្បទាហើយ ក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា ដេរឯង គឺភិក្ខុដេរដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយរាល់ៗ ផ្ទៃម្ជុល ។ ពាក្យថា ប្រើគេឲ្យដេរ គឺភិក្ខុបង្គាប់អ្នកដទៃឲ្យដេរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ដេរច្រើនដង ត្រូវអាបត្តិបាចិត្តិយ ( តែមួយ ) ។

[៦៧] ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិមែន ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសម្គាល់ថា ជាញាតិ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរដើម្បីភិក្ខុនីដែលបានឧបសម្បទា អំពីសង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ មានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសម្គាល់ថា ជាញាតិមែន មិនត្រូវអាបត្តិអ្វីឡើយ ។

[៦៨] អាបត្តិមិនមានដល់ភិក្ខុដែលដេរចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុ

ដែលដេរឯង ឬប្រើគេឲ្យដេរនូវបរិក្ខារដទៃ ក្រៅពីចីវរ ( ឲ្យភិក្ខុនី ) ឲ្យសិក្ខមានា ឬឲ្យសាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

## សិក្ខាបទទី ៦ ចប់

# អដ្ឋកថា

## ឱវាទវគ្គទី ៣

## ចីវរសិព្វនសិក្ខាបទ

[៦៥] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៦ ដូច្នេះ ពាក្យថា **ឧទាយិ** បានដល់ លោកឧទាយិភិក្ខុ ។ បទថា **បដ្ឋោ** ប្រែថា ដែលមានសមត្ថភាព មានពាក្យអធិប្បាយថា ជាអ្នកយល់ និងជាអ្នកឈ្លាស ។

ពីរបទថា **អញ្ញតរា ភិក្ខុនី** បានដល់ ភិក្ខុនីដែលជាករិយាពីដើមនៃឧទាយិភិក្ខុនោះឯង ។

បទថា **បដិភាណចិត្តំ** បានដល់ មានភាពស្រស់ស្អាត ដែលធ្វើដោយបដិភាណរបស់ខ្លួន បានឮថា លោកឧទាយិនោះ ជ្រលក់ចីវរហើយ បានធ្វើរូបស្រី និងប្រុសកំពុងធ្វើមេថុន ដោយពណ៌ផ្សេងៗ ត្រង់កណ្តាលនៃចីវរនោះ ។ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យទាំងឡាយ បានពោលថា **មជ្ឈេ បដិភាណចិត្តំ វុដ្ឋាបេត្វា** ជាដើម ។

បទថា **យថាសំហដំ** គឺតាមផ្នត់ដែលបត់ទុកហើយនោះឯង ។

បទថា **ចីវរំ** បានដល់ ចីវរដែលអាចស្លៀក ឬដណ្តប់បាន ។ ពិតហើយ ក្នុងមហាបច្ចរីជាដើម លោកក៏បានពោលទុកយ៉ាងនេះ ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃចីវរសិព្វនសិក្ខាបទ

[៦៦] ក្នុងបទថា **សយំ សិព្វេតិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុ

ធ្វើក្តី កាត់ក្តី ដោយតាំងចិត្តថា អញនឹងដេរ ត្រូវអាបត្តិទុក្កដ ។ តែជាអាបត្តិបាចិត្តិយ ព្រោះការចាក់ម្ជុលគ្រប់ៗ គ្រាដែលដេរ ដល់ភិក្ខុដែលដេរ ព្រោះព្រះបាលីថា ( ត្រូវអាបត្តិបាចិត្តិយ ) គ្រប់ៗ ស្នាមម្ជុល ដូច្នេះ ។ បើភិក្ខុមិនទាញម្ជុលចេញឲ្យផុតកន្ទុយ ចេះតែយកចុងចាក់ទៅ សូម្បី ១០០ ដង កាលពេញម្ជុលហើយទើបទាញចេញ ត្រូវអាបត្តិបាចិត្តិយ ១ ប៉ុណ្ណោះ ។

បទថា **សព្វំ អាណត្តោ** បានដល់ ភិក្ខុដែលប្រើតែម្តងថា អ្នកចូរដេរចីវរ ។

បទថា **ពហុកំ បិ សិព្វតិ** សេចក្តីថា សូម្បីអ្នកទទួលប្រើញុំាងសុចិកម្មទាំងអស់ឲ្យសម្រេច ហើយឲ្យចីវរសម្រេចចុះ ក៏ត្រូវអាបត្តិបាចិត្តិយ ១ ប៉ុណ្ណោះ ។ តែបើលោកបានទទួលពាក្យប្រើថា កម្មដែលគប្បីធ្វើក្នុងចីវរនេះជាភារៈរបស់អ្នក ដូច្នេះហើយ ទើបធ្វើត្រូវអាបត្តិបាចិត្តិយដល់អ្នកប្រើគ្រប់ៗ ស្នាមម្ជុលនីមួយៗ ។ ត្រូវអាបត្តិបាចិត្តិយជាច្រើន ព្រោះពាក្យតែមួយ ដល់ភិក្ខុអ្នកប្រើ ។ ឯក្នុងការប្រើរឿយៗ មិនមានពាក្យគប្បីពោលឡើយ ។

បើអាចារ្យ និងឧបជ្ឈាយ៍កំពុងដេរចីវរដើម្បីពួកភិក្ខុនី ដែលជាញាតិរបស់ខ្លួន ចំណែកនិស្សិតកៈ ( កូនសិស្សដែលអាស្រ័យនិស្ស័យនឹងលោក ) ពួកណា របស់លោកទាំងនោះដេរឯង ដោយតាំងចិត្តថា ពួកយើងនឹងធ្វើអាចរិយវត្ត និងឧបជ្ឈាយវត្ត ឬកបិនវត្ត ជាអាបត្តិជាច្រើនដល់ពួកនិស្សិតកៈនោះ តាមចំនួនស្នាមម្ជុល ។ អាចារ្យ និងឧបជ្ឈាយ៍ប្រើឲ្យពួកអន្តេវាសិកដេរ ដើម្បីពួកភិក្ខុនីដែលជាញាតិរបស់ខ្លួន ត្រូវអាបត្តិទុក្កដដល់អាចារ្យ និង

ឧបជ្ឈាយ៍ ត្រូវអាបត្តិបាចិត្តិយ ដល់ពួកអន្តេវាសិក ។ ពួកអន្តេវាសិកនិមន្ត ឲ្យអាចារ្យ និងឧបជ្ឈាយ៍ជួយដេរ ដើម្បីពួកភិក្ខុនីជាញាតិរបស់ខ្លួន សូម្បីក្នុងការដែលអន្តេវាសិក និមន្តអាចារ្យ និងឧបជ្ឈាយ៍ជួយដេរនោះ ក៏មានន័យដូចគ្នា ។ ចីវរជារបស់ភិក្ខុនីដែលជាញាតិ ទាំងចំណែកអន្តេវាសិក ទាំងចំណែកអាចារ្យ និងឧបជ្ឈាយ៍ តែអាចារ្យ និងឧបជ្ឈាយ៍ លួងលោមពួកអន្តេវាសិកឲ្យដេរ ត្រូវអាបត្តិទុក្កដ ដល់ជនទាំងពីរចំណែក ។ ព្រោះហេតុអ្វី ព្រោះចីវរពួកអន្តេវាសិកដេរ ដោយការសម្គាល់ថា មិនមែនញាតិ ( និង ) ព្រោះអាចារ្យ និងឧបជ្ឈាយ៍ដឹកនាំក្នុងវត្ថុដែលមិនគួរ ។ ព្រោះដូច្នោះ ទើបគួរប្រាប់ថា នេះជាចីវររបស់ញោមស្រីលោក នេះជាចីវររបស់ប្អូនស្រី ហើយឲ្យពួកលោកជួយដេរ ។

[៦៨] ពីរបទថា **អញ្ញំ បរិក្ខារំ** បានដល់ បរិក្ខារឯណាមួយ មានថង់ស្បែកជើងជាដើម ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចីវរសិព្វនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ៦៩ ] សម័យនោះឯង ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ កាលគង់នៅវត្ត ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយ ជាមួយគ្នា ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្តី ប្រពន្ធដើរទៅយ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះពុទ្ធជាសក្យ-បុត្រ ដើរទៅមួយអន្លើដោយភិក្ខុនីទាំងឡាយ យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយ ពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោល ទោស តិះដៀលបន្តុះបង្អាប់ថា មិនសមបីបើឆព្វគ្គិយភិក្ខុទាំងឡាយបបួល ភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាល ភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជា មួយគ្នា ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មាន ព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងបបួលភិក្ខុនីដើរទៅ កាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែន នាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយបបួល

ភិក្ខុនី ដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅសូម្បីកាន់ទីជាលំនៅនៃស្រុកមួយ ( ភិក្ខុនោះ ) ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៧០] សម័យនោះឯង ភិក្ខុ និងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយអំពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី កាលនោះ ភិក្ខុនីទាំងឡាយនោះឃើញពួកភិក្ខុនោះហើយ បានពោលពាក្យនេះថា យើងទាំងឡាយនឹងទៅជាមួយនឹងលោកម្ចាស់ទាំងឡាយ ភិក្ខុទាំងនោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នាមិនគួរទេ នាងទាំងឡាយទៅមុនឬ ឬយើងទាំងឡាយនឹងទៅមុន ។ ភិក្ខុនីទាំងនោះឆ្លើយថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ទាំងឡាយជាបុរសដ៏ប្រសើរ គួរតែលោកម្ចាស់ទាំងឡាយនិមន្តទៅមុន ។ កាលភិក្ខុនីទាំងនោះដើរទៅជាខាងក្រោយនៃភិក្ខុទាំងឡាយដល់ពាក់កណ្តាលផ្លូវ ចោរទាំងឡាយក៏ដណ្តើមយក ( បាត្រនិងចីវរ ) ផង ប្រទូស្តផង ( កំហែងធ្វើសេវនកិច្ច ) ក្នុងកាលនោះឯង ។ ទើបភិក្ខុនីទាំងនោះទៅដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនី ។ ពួកភិក្ខុនីប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុ ។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នា ក្នុងផ្លូវដែលគួរនឹងទៅ ដោយមានគ្នីគ្នាជាពួកដែលគេសន្មតថា ប្រកបដោយសេចក្តី

វង្វៀស ប្រកបដោយភ័យចំពោះមុខ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីទៅកាន់ទីជាលវែ្វកនៃស្រុកមួយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺផ្លូវដែលគួរនឹងទៅដោយមានគ្នីគ្នាជាពួក ១ ដែលគេសន្មតថា ប្រកបដោយសេចក្តីវង្វៀស ១ ដែលប្រកបដោយភ័យចំពោះមុខ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[៧១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងឧភតោសង្ឃ ។ ពាក្យថា ជាមួយគ្នា សេចក្តីថា ពួកជាមួយគ្នា ។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយនឹងទៅ បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងទៅ បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងទៅ ម្នាលនាង យើងទាំងឡាយនឹងទៅ យើងទាំងឡាយនឹងទៅក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ដោយហោចទៅសូម្បីទៅកាន់ទីជាលវែ្វកនៃស្រុកមួយ សេចក្តីថា ( ភិក្ខុបបួលភិក្ខុនី ដើរជាមួយគ្នាទៅ ) ក្នុងទីជាចន្លោះនៃស្រុក ក្នុងស្រុកមានចម្ងាយល្មមមាន់ ហើរទៅដល់ ( គឺមួយរយៈមាន់ហើរ ) ត្រូវអាបត្តិបាចិត្តិយ ។ ( ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ ) ក្នុងព្រៃដែលមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ កន្លះយោជន៍ ។ ពាក្យថា វៀរលែងតែមានសម័យ សេចក្តីថា លើក

ទុកតែមានសម័យ ។ ដែលហៅថា ផ្លូវដែលគួរនឹងទៅដោយមានគ្នីគ្នាជាពួក គឺផ្លូវ ដែលបុគ្គលឥតមានគ្នីគ្នា មិនអាចដើរទៅបាន ។ ដែលហៅថា ផ្លូវប្រកបដោយសេចក្តីរង្កៀស គឺកន្លែងដែលចោរអាស្រ័យនៅក៏ប្រាកដ កន្លែងដែលចោរបរិភោគអាហារក៏ប្រាកដ កន្លែងដែលចោរឈរនៅក៏ប្រាកដ កន្លែងដែលចោរអង្គុយក៏ប្រាកដ កន្លែងដែលចោរដេកក៏ប្រាកដ ក្នុងផ្លូវនោះ ។ ដែលហៅថា ផ្លូវប្រកបដោយភ័យចំពោះមុខ គឺផ្លូវនោះដែលចោរទាំងឡាយសម្លាប់មនុស្សក៏ប្រាកដ ប្លន់មនុស្សក៏ប្រាកដ វាយដំមនុស្សក៏ប្រាកដ ។ ភិក្ខុដើរទៅកាន់ផ្លូវដែលប្រកបដោយភ័យចំពោះមុខ ហើយឃើញផ្លូវមិនប្រកបដោយភ័យចំពោះមុខវិញ ត្រូវបញ្ជូនភិក្ខុនីទៅ ដោយពាក្យថា ម្នាលនាងទាំងឡាយនាងទាំងឡាយចូរទៅចុះ ។

[៧២] ភិក្ខុបបួលគ្នា ហើយសម្គាល់ថា បបួលមែន ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាលង្វែគនៃស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងការដែលបានបបួលគ្នា ហើយដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្លោះនៃស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុបបួលគ្នា ហើយសម្គាល់ថា មិនបានបបួល ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្លោះនៃស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុបបួល តែភិក្ខុនីមិនបបួល ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានបបួលគ្នា ហើយសម្គាល់ថាបានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុ

សង្ស័យក្នុងការដែលមិនបានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ថា មិនបានបបួលក្នុងការដែលមិនបានបបួល មិនត្រូវអាបត្តិឡើយ ។

[៧៣] អាបត្តិមិនមានដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនីហើយដើរទៅ ដល់ភិក្ខុដែលភិក្ខុនីបបួល តែភិក្ខុមិនបានបបួល ដល់ភិក្ខុ និងភិក្ខុនីដែលទៅដោយខុសសង្កេត ដល់ភិក្ខុដែលទៅ ( ជាមួយនឹងភិក្ខុនី ) ដោយមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា

## ឱវាទវគ្គទី ៣

## សំវិធានសិក្ខាបទ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៧ ដូច្នេះថា បទថា **បច្ឆាគច្ឆន្តីនំ ចោរា អច្ឆិន្ទឹសុ** សេចក្តីថា កាលពួកភិក្ខុនីទៅតាមក្រោយ ពួកចោរបានដណ្តើមយកបាត្រ និងចីវរទៅ ។

បទថា **ទូសេសុំ** បានដល់ ពួកចោរប្រទូស្តពួកភិក្ខុនីទាំងនោះ អធិប្បាយថា ឲ្យដល់នូវការដាច់សីល ។

បទថា **សំវិធាយ** គឺបបួលគ្នា អធិប្បាយថា ធ្វើការណាត់គ្នាក្នុងវេលានឹងទៅ ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃសំវិធានសិក្ខាបទ

[ ៧១ ] មាន់ចេញអំពីស្រុកណា ហើយដើរទៅកាន់ស្រុកដទៃ ស្រុកនេះលោក ហៅថា មួយរយៈមាន់ទៅដល់ ក្នុងបទថា **កុក្កុដសម្បាទេ** នេះ ។ ក្នុងបទនោះ មានអត្ថចំពោះពាក្យដូចតទៅនេះថា មាន់ទាំងឡាយរមែងដើររកស៊ីទៅដល់ស្រុកនេះ ហេតុនោះ ទើបស្រុកនោះឈ្មោះថា ជាទីទៅដល់ ។ សត្វណា ទៅដល់ គឺសត្វមាន់ ។ ការត្រាច់ទៅដល់របស់ពួកមាន់ ឈ្មោះថា **កុក្កុដសម្បាទ** ។ ម្យ៉ាងទៀត ការទៅដល់ ឈ្មោះថា **សម្បាទ** ។ ការទៅ

ដល់របស់ពួកមាន់មាននៅត្រង់ស្រុកនេះ ព្រោះហេតុនោះ ទើបស្រុកនេះឈ្មោះថា **កុក្កុដសម្បាទ** ។ បាឋៈថា **កុក្កុដសម្បាតេ** ក៏មាន ។ មាន់ហើរឡើងអំពីដំបូលផ្ទះនៃស្រុកណា ហើយទៅធ្លាក់ចុះត្រង់ដំបូលផ្ទះនៃស្រុកដទៃ ស្រុកនេះលោកហៅថា មួយជួរមាន់ហើរដល់ ក្នុងបាឋៈថា **កុក្កុដសម្បាតេ** នោះ ។ ឯអត្ថពាក្យក្នុងបទនេះ បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

ស្រុកសូម្បីមានប្រការដូចពោលហើយ ២ យ៉ាងនេះ ជិតគ្នាពេកណាស់ រមែងមិនមានឧបចារៈ ។ ក្នុងអដ្ឋកថាពោលទុកថា សំឡេងមាន់ដែលរងាវក្នុងវេលាជិតភ្លឺ ក្នុងស្រុកណា បានឮទៅដល់ក្នុងស្រុកបន្ទាប់ទៅ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ចន្លោះស្រុក ក្នុងវត្តដែលចង្អៀតដោយពួកស្រុក ដូច្នោះ ។ លោកពោលពាក្យនោះទុកហើយក៏ពិត សូម្បីដូច្នោះ ក៏ត្រូវអាបត្តិដូចគ្នាដល់ភិក្ខុដែលឈានចុះកាន់ឧបចារៈនៃស្រុក សូម្បីមានរយៈឆ្ងាយគ្នាប្រមាណមួយហត្ថក្តាប់ដែលអ្នកស្រុកវៀរទុក ព្រោះព្រះបាលីថា ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ចន្លោះស្រុក ដូច្នេះ ។ ពាក្យនោះមិនសមនឹងព្រះបាលី ។ បើស្រុកដែលមានសភាពបែបនេះ ដោយវោហារ ដែលបានហើយយ៉ាងនោះ ព្រោះមិនជិតគ្នា រមែងបានវោហារថា មួយជួរមាន់ហើរដល់ដូច្នេះក្តី មួយជួរ មាន់ហើរមិនដល់ដូច្នេះក្តី ព្រោះជាស្រុកជិតគ្នា ព្រោះដូច្នោះ ទើបមិនសមនឹងព្រះបាលី ដូច្នេះឯង ។ ឯក្នុងស្រុកក្រៅអំពីនេះ ការដើរហួសឧបចារៈស្រុកនោះទៅ នឹងឈានចុះកាន់ឧបចារៈស្រុកដទៃប៉ុណ្ណោះ មិនប្រាកដ ។ ព្រោះដូច្នោះ ដែល

លើកអាបត្តិឡើងកាត់ ទើបមិនប្រាកដដូចគ្នា ។

វិនិច្ឆ័យអាបត្តិក្នុងបទថា **គាមន្តរេ គាមន្តរេ អាបត្តិ ចាចិត្តិយស្ស** នោះ ដូចតទៅនេះថា ពិតហើយ ក្នុងវេលាបបួលគ្នា បើភិក្ខុ និងភិក្ខុនីទាំង ២ ឈរបបួលគ្នា ក្នុងសម្នាក់ភិក្ខុនីក្តី ក្នុងចន្លោះវត្តក្តី ក្នុងរោងឆាន់ក្តី ក្នុងលំនៅនៃតិរ្ថិយក្តី ជាអនាបត្តិ បានឮថា ភូមិនេះជាកប្បិយភូមិ ។ ព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយមិនកាត់អាបត្តិទុក្កដ ព្រោះការបបួលជាបច្ច័យក្នុងសម្នាក់នៃភិក្ខុនីជាដើមនេះ ត្រូវអាបត្តិបាចិត្តិយតាមវត្ថុនោះឯង ដល់ភិក្ខុដែលដើរទៅ ។

បើភិក្ខុ និងភិក្ខុនីបបួលគ្នាខាងក្នុងស្រុក ត្រង់ផ្លូវជិតទ្វារសម្នាក់របស់ភិក្ខុនីក្តី ក្នុងទីដទៃ មានផ្លូវបែកជា ៤ ផ្លូវបែកជា ៣ និងរោងជំរឺជាដើមក្តី ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលបបួលគ្នាយ៉ាងនេះហើយ ទើបចេញអំពីស្រុកទៅ ជាអនាបត្តិ ព្រោះការចេញអំពីស្រុក តែព្រោះឈានជើងចូលកាន់ឧបចារៈនៃស្រុកបន្ទាប់នោះ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុ ។ លោកពោលទុកក្នុងមហាបច្ចរីថា សូម្បីការឈានចូលដល់ឧបចារៈនោះ ត្រូវអាបត្តិទុក្កដក្នុងជំហានទី ១ ត្រូវអាបត្តិបាចិត្តិយក្នុងជំហានទី ២ ។ ភិក្ខុចេញអំពីស្រុកហើយ តែមិនទាន់ឈានចូលកាន់ឧបចារៈ នៃស្រុកបន្ទាប់នោះដរាបណា សូម្បីបបួលគ្នាក្នុងចន្លោះនេះ ក៏ត្រូវអាបត្តិទុក្កដដល់ភិក្ខុដរាបនោះ ។ ក្នុងការឈានជាន់ឧបចារៈនៃស្រុកបន្ទាប់នោះ មិនត្រូវអាបត្តិដោយន័យមុនដូចគ្នា ។ បើភិក្ខុនិង ភិក្ខុនីមានបំណងនឹងទៅកាន់ស្រុកឆ្ងាយ ត្រូវអាបត្តិទុក្កដគ្រប់ៗ ទីដែល

ចូលដល់ ( ឧបចារៈនៃស្រុក ) ដោយរាប់ឧបចារៈនៃស្រុក ។

លោកពោលទុកក្នុងមហាបច្ចរីថា តែជាអានាបត្តិ ព្រោះការដើរហួសស្រុកនោះទៅ តែបើភិក្ខុនីគិតថា អញនឹងទៅកាន់ស្រុកឈ្មោះនោះ ហើយដើរចេញពីសម្នាក់ទៅ ឯភិក្ខុក៏គិតថា អញនឹងទៅកាន់ស្រុកឈ្មោះនោះ ហើយដើរចេញពីវិហារ បែរមុខទៅកាន់ស្រុកនោះឯង បើភិក្ខុ និងភិក្ខុនីទាំង ២ ជួបគ្នាត្រង់ទ្វារស្រុក ហើយសួរគ្នាថា លោកម្ចាស់ទៅទីណា ទៅស្រុកឈ្មោះនោះ នាងម្ចាស់ទៅទីណា ពោលថា ខ្ញុំក៏ទៅស្រុកនោះដូចគ្នា ទើបបបួលគ្នាថា មកចុះនាង ពួកយើងនឹងទៅជាមួយគ្នា ហើយដើរទៅ ជាអនាបត្តិ ព្រោះហេតុអ្វី ព្រោះថា ភិក្ខុ និងភិក្ខុនីចេញទៅដោយតាំងចិត្តថា អញនឹងទៅតាំងពីដំបូងនោះឯង ។ ពាក្យដែលពោលក្នុងមហាបច្ចរីនោះ មិនសមនឹងបាលី មិនសមជាមួយអដ្ឋកថាដ៏សេស ។

ពីរបទថា **អឌ្ឍយោជនេ អឌ្ឍយោជនេ** សេចក្តីថា ភិក្ខុដើរហួសកន្លះយោជន៍ៗ ទៅ ក្នុងខណៈដែលគិតថា ឥឡូវនេះ យើងនឹងដើរហួសទៅ ត្រូវអាបត្តិទុក្កដក្នុងជំហានទី ១ ត្រូវអាបត្តិបាចិត្តិយក្នុងជំហានទី ២ ។ ពិតហើយ ន័យនេះជាអាបត្តិក្នុងខណៈដែលដើរហួសទៅ ជាអនាបត្តិក្នុងការឈានចូលឧបចារៈ ។

# អធិប្បាយ

## បទភាជនីយនៃសំវិធានសិក្ខាបទ

[ ៧២ ] ពីរបទថា **ភិក្ខុ សំវិទហាតិ** សេចក្តីថា ភិក្ខុឃើញភិក្ខុនីត្រង់

ទ្វារស្រុកក្តី ត្រង់ថ្នល់ក្តី ពោលថា នាងធ្លាប់ទៅកាន់ស្រុកឈ្មោះនោះទេ ភិក្ខុនីឆ្លើយថា ខ្ញុំមិនធ្លាប់ទៅទេលោកម្ចាស់ ភិក្ខុពោលថា មកចុះ យើងនឹងទៅជាមួយគ្នាក្តី ខ្ញុំនឹងទៅស្អែកនេះ នាងក៏គប្បីមកដែរ ដូច្នេះក្តី ។

# អនាបត្តិនៃសំវិធានសិក្ខាបទ

[ ៧៣ ] ពីរបទថា **ភិក្ខុនី សំវិធាយ** សេចក្តីថា ភិក្ខុនីឃើញភិក្ខុចេញពីស្រុក ដើម្បីថ្វាយបង្គំព្រះចេតិយ ក្នុងស្រុកដទៃ ទើបពោលថា លោកម្ចាស់ៗ ទៅណា ភិក្ខុឆ្លើយថា ខ្ញុំទៅកាន់ស្រុកឈ្មោះនោះ ដើម្បីថ្វាយបង្គំព្រះចេតិយ ដូច្នេះ ។ ភិក្ខុនីនោះឯង សុំខ្លួនយ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំក៏នឹងទៅដែរ ភិក្ខុមិនបានបបួលឡើយ ។

វិនិច្ឆ័យក្នុងពាក្យថា **វិសង្កេតេន** នេះ គប្បីជ្រាបដូច្នេះថា ភិក្ខុ និងភិក្ខុនីពោលថា យើងនឹងទៅជុំគ្នាមុនឆាន់ ហើយទៅក្រោយឆាន់ ពោលថា យើងនឹងមកជុំគ្នាក្នុងថ្ងៃនេះ ហើយទៅក្នុងថ្ងៃស្អែក យ៉ាងនេះជាអនាបត្តិ ព្រោះខុសសង្កេត តែបើមានការខុសសន្យាក្នុងទ្វារក្តី ខុសសន្យាក្នុងផ្លូវក្តី ប្រព្រឹត្តជាអាបត្តិពិត ។

បទថា **អាបទាសុ** សេចក្តីថា ព្រោះដែលត្រូវប្លន់ អ្នកជនបទទាំង-ឡាយ នាំគ្នាឡើងកាន់យាន ធ្វើដំណើរក្តី ឬរទេះកៀសខ្លួនទៅក្តី ជាអនាបត្តិក្នុងអន្តរាយ មានសភាពដូច្នេះ ។ ពាក្យដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតឡើងតាមកាយ ១ តាមកាយ និងវាចា ១ តាមកាយ និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សំវិធានសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ៧៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបបួលពួកភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្តីប្រពន្ធ ជិះលេងលើទូកមួយ យ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ បបួលពួកភិក្ខុនីជិះលេងលើទូកមួយជាមួយគ្នា យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយ មិនគួរបើនឹងបបួលពួកភិក្ខុនីឡើងជិះទូកមួយជាមួយគ្នាទេ ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សួរចំពោះឆព្វគ្គិយភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយបបួលពួកភិក្ខុនី ឡើងជិះទូកជាមួយគ្នាពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលពួកភិក្ខុនីឡើងជិះទូកមួយជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះ

ថ្វាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខា-បទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ទៅប្រាសទឹកក្តី ទៅបណ្តោយទឹកក្តី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ សិក្ខា-បទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

[៧៥] សម័យនោះឯង ភិក្ខុ និងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយអំពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី ។ ក្នុងទីកណ្តាលផ្លូវ មានស្ទឹងមួយដែលគេតែងតែឆ្លង ។ ទើបភិក្ខុនីទាំងឡាយនោះ បានពោលពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា យើងទាំងឡាយនឹងឆ្លងមួយអន្លើដោយលោកម្ចាស់ទាំងឡាយដែរ ។ ភិក្ខុទាំងឡាយនោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា មិនគួរទេ ( បើដូច្នោះ ) នាងទាំងឡាយឆ្លងទៅមុនឬៗ យើងទាំងឡាយនឹងឆ្លងទៅមុន ។ ភិក្ខុនីទាំងឡាយឆ្លើយថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ទាំងឡាយ ជាបុរសដ៏ប្រសើរ លោកម្ចាស់ទាំង-ឡាយចូរឆ្លងទៅមុនចុះ ។ កាលភិក្ខុនីទាំងឡាយនោះ ឆ្លងទៅជាខាងក្រោយចោរទាំងឡាយក៏ដណ្តើមយក ( បាត្រ និងចីវរ ) ផង ប្រទូស្តផង ក្នុងកាលណោះ ។ លុះភិក្ខុនីទាំងឡាយនោះទៅដល់ក្រុងសាវត្ថីហើយ ក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីក៏ប្រាប់សេចក្តីនោះដល់ភិក្ខុទាំង-ឡាយ ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ឲ្យភិក្ខុបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ដើម្បីឆ្លងទទឹង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ទៅប្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ( ភិក្ខុនោះ ) ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង ។

[៧៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។បេ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសម្នាក់នៃឧភតោសង្ឃ[១] ។ ពាក្យថា ជាមួយគ្នា គឺពួកជាមួយ ។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយនឹងឡើងជិះទូក បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងឡើងជិះទូក បពិត្រលោកម្ចាស់ យើងទាំង-ឡាយនឹងឡើងជិះទូក ម្នាលនាង យើងទាំងឡាយនឹងឡើងជិះទូក យើងទាំង-ឡាយនឹងឡើងជិះទូកក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនីឡើងជិះទូក ភិក្ខុក៏ឡើងជិះដែរ ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុឡើងជិះទូក ភិក្ខុនីក៏ឡើងជិះដែរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុ និងភិក្ខុនីឡើងជិះទូកស្មើគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ទៅប្រាសទឹក សេចក្តីថា នាវាទៅខាងទីលើទឹក ។ ពាក្យថា ទៅបណ្តោយទឹក សេចក្តីថា នាវាទៅទីខាងក្រោមទឹក ។ ពាក្យថា វៀរលែងតែការឆ្លងទទឹង សេចក្តីថា លើកទុកតែការឆ្លងទទឹង ។ ( ភិក្ខុបបួលភិក្ខុនីឡើងជិះទូក ) ទៅក្នុងស្រុក ចម្ងាយមាន់ល្មមហើរទៅដល់ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ចន្លោះស្រុក ។ ( ភិក្ខុបបួលភិក្ខុនីឡើងជិះទូក ) ទៅក្នុងព្រៃ មិនមែនជាស្រុក ត្រូវអាបត្តិ

១- សង្ឃ ២ ពួក គឺភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១ ។

បាចិត្តិយគ្រប់ៗ កន្ទះយោជន៍ ។

[៧៧] ការដែលបានបបួលហើយ ភិក្ខុសម្គាល់ថា បានបបួលគ្នាមែន ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងការដែលបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង ។ ការដែលបានបបួលគ្នា ភិក្ខុសម្គាល់ថា មិនបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង ។ ភិក្ខុបបួល ភិក្ខុនីមិនបានបបួល ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ តែភិក្ខុសម្គាល់ថា បានបបួលគ្នាហើយ ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ ភិក្ខុសម្គាល់ថា មិនបានបបួលគ្នាមែន មិនត្រូវអាបត្តិ ។

[ ៧៨ ] អាបត្តិមិនមានដល់ភិក្ខុដែលឆ្លងទទឹង ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនី ហើយឡើងជិះទូក ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនី តែភិក្ខុនីបបួល ដល់ភិក្ខុដែលឡើងជិះទូកជាមួយគ្នានឹងភិក្ខុនី ដោយខុសសង្កេតគ្នា ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

# អដ្ឋកថា

## ឧទកវគ្គទី ៣

## ឧទកេហាសិក្ខាបទ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៨ ដូចតទៅនេះ បទថា **សរីរធាតុ** បានដល់ បបួលគ្នាដើម្បីលេងជាប្រធាន ដោយអំណាចមិត្តសន្ថវៈ ដែលជាសេចក្ដីរីករាយរបស់សត្វលោក ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃឧទកេហាសិក្ខាបទ

[៧៦] បទថា **ឧទ្ធគ្គាមិនី** គឺលេងបញ្ចោសក្រសែរបស់ស្ទឹងឡើងទៅ ។ ព្រោះបុគ្គលដែលលេងកីឡាអុំទូក ដែលអុំឡើងបញ្ចោសទឹក ដោយអុំឡើងទៅ លោកហៅថា ដោយសារទូកឡើងទឹកទៅ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទថា **ឧទ្ធគ្គាមិនី** នោះ ដើម្បីសម្ដែងចំពោះអត្ថប៉ុណ្ណោះ ទើបត្រាស់ថា **ឧជ្ជវនិកាយ** ( អុំបញ្ចោសខ្សែទឹក ) ដូច្នេះ ។

បទថា **អធោគាមិនី** គឺលេងបណ្ដោយក្រសែទឹកចុះទៅ ។ ក៏ព្រោះបុគ្គលអ្នកលេងកីឡាអុំទូក ដែលលេងបណ្ដោយខ្សែទឹក ដោយលេងចុះទៅខាងក្រោម ហៅថា ជិះទូកបណ្ដោយទឹកទៅ ។ ដោយហេតុនោះ ក្នុងបទភាជនៈនៃបទថា **អធោគាមិនី** នោះ ដើម្បីសម្ដែងអត្ថដូចគ្នា ទើបត្រាស់ថា **ឱជវនិកាយ** ( លេងបណ្ដោយទឹក ) ដូច្នេះ ក្នុងទូកនោះ ជនទាំងឡាយ

រមែងអុំទូកណាទៅលើក្តី ក្រោមក្តី ដើម្បីឲ្យដល់កំពង់ចំណត មិនជាអាបត្តិក្នុងការអុំទូកនោះ ទៅទីនោះ ។

បទថា **តិរិយន្តរណាយ** នេះ ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ក្នុងបទថា **គាមន្តរេ គាមន្តរេ** នេះ មានវិនិច្ឆ័យដូច្នេះថា ស្ទឹងណាដែលត្រើយម្ខាងជាប់គ្នាដោយស្រុក កំណាត់មួយជួរមាន់ហើរ ត្រើយម្ខាងជាព្រៃមិនមានស្រុក ក្នុងវេលាទៅមាត់ប្រាំងដែលមានស្រុកនៃស្ទឹងនោះ ត្រូវអាបត្តិបាចិត្តិយជាច្រើន ដោយអំណាចចន្លោះស្រុក ។ ក្នុងវេលាទៅត្រង់មាត់ប្រាំងដែលមិនមានស្រុក ត្រូវអាបត្តិបាចិត្តិយច្រើន ដោយរាល់កន្លះយោជន៍ ។ តែស្ទឹងណាមានទទឹងមួយយោជន៍ សូម្បីក្នុងការទៅត្រង់កណ្តាលនៃស្ទឹងនោះ ក៏គប្បីជ្រាបបាចិត្តិយច្រើន ដោយការរាប់កន្លះយោជន៍ ។

## អនាបត្តិនៃនាវាភិរុហនសិក្ខាបទ

[៧៨] ក្នុងបទថា **អនាបត្តិ តិរយន្តរណាយ** នេះ មានវិនិច្ឆ័យដូច្នេះថា មិនមែនស្ទឹងតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីភិក្ខុណាចេញពីកំពង់ឈ្មោះមហាតិដ្ឋ: ទៅកាន់កំពង់ឈ្មោះតម្ពលិត្តិក្តី ឈ្មោះសុវណ្ណភូមិក្តី ជាអនាបត្តិដល់ភិក្ខុនោះ ។ ពិតហើយ គ្រប់ៗ អដ្ឋកថា លោកវិភាគអាបត្តិទុកក្នុងស្ទឹងប៉ុណ្ណោះ មិនមែនក្នុងសមុទ្រឡើយ ។

ក្នុងបទថា **វិសង្កេតេន** នេះក៏ជាអនាបត្តិ ព្រោះខុសសង្កេតក្នុងវេលា

ប៉ុណ្ណោះ ។ តែបើទៅដោយខុសសង្កេត ព្រោះកំពង់ក្តី ទូកក្តី ប្រព្រឹត្តជាអាបត្តិនោះឯង ។ ពាក្យដ៏សេស មួយអន្លើដោយសមុដ្ឋានជាដើម ដូចគ្នានឹងសំវិធានសិក្ខាបទនោះឯង ។

នាវាភិរុហនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ៧៩ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ភិក្ខុនីឈ្មោះ ថុល្លនន្ទា ជាជីតុនរបស់ត្រកូលមួយ ជាភិក្ខុនី ប្រកបដោយនិច្ចភត្ត ចំណែក គហបតីនោះ ក៏បាននិមន្តពួកភិក្ខុជាថេរៈទៅផង ។ គ្រានោះឯង ភិក្ខុនីឈ្មោះ ថុល្លនន្ទាស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរក្នុងវេលាព្រឹក ហើយចូល ទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងគហបតី នោះថា ម្នាលគហបតី ខាទនីយភោជនីយាហារមានប្រមាណច្រើននេះ គេ ចាត់ចែងដើម្បីអ្វី ។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំបាននិមន្តព្រះ ថេរៈទាំងឡាយមកឆាន់ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះ ថេរៈទាំងនោះ គឺព្រះថេរៈណាខ្លះ ។ គហបតីឆ្លើយថា ព្រះសារីបុត្រជាម្ចាស់ ព្រះមោគ្គល្លានជាម្ចាស់ ព្រះមហាកច្ចានៈជាម្ចាស់ ព្រះមហាកោដ្ឋិតៈជាម្ចាស់ ព្រះមហាកប្បិនជាម្ចាស់ ព្រះមហាចុន្ទជាម្ចាស់ ព្រះអនុរុទ្ធជាម្ចាស់ ព្រះរេវតៈ ជាម្ចាស់ ព្រះឧបាលិជាម្ចាស់ ព្រះអានន្ទជាម្ចាស់ ព្រះរាហុលជាម្ចាស់ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា ម្នាលគហបតី កាលព្រះថេរៈមហានាគដ៏ ប្រសើរ មាននៅទេតើ ហេតុដូចម្តេច ក៏អ្នកទៅនិមន្តពួកកូនក្មេងមកវិញ ។ គហបតីសួរថា បពិត្រលោកម្ចាស់ ព្រះថេរៈមហានាគដ៏ប្រសើរទាំងនោះមាន ព្រះនាមដូចម្តេចខ្លះ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា លោកម្ចាស់ទេវទត្ត លោកម្ចាស់កោកាលិកៈ លោកម្ចាស់កដមោរកតិស្សកៈ លោកម្ចាស់ខណ្ឌ-

ទេវីបុត្រ លោកម្ចាស់សមុទ្ទទត្តៈ ។ កាលភិក្ខុនីឈ្មោះថុល្លនន្ទាកំពុងតែនិយាយពាក្យនេះ មិនទាន់អស់នៅឡើយ ។ ស្រាប់តែភិក្ខុជាថេរៈទាំងឡាយចូលមកក្នុងពេលនោះ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះថេរៈមហានាគដ៏ប្រសើរទាំងឡាយ អ្នកបាននិមន្តហើយពិតមែនឬ ។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ឥឡូវនេះ លោកម្ចាស់បានធ្វើនូវព្រះថេរៈមហានាគដ៏ប្រសើរទាំងឡាយ ថាជាកូនក្មេង លោកម្ចាស់ត្រឡប់ធ្វើពួកភិក្ខុជាកូនក្មេង ថាជាមហានាគដ៏ប្រសើរទៅវិញ ( ថាដូច្នោះហើយ ) ក៏ចាប់ទាញភិក្ខុនីឈ្មោះថុល្លនន្ទាចេញពីផ្ទះផង និច្ចកត្ត ( គឺចង្ហាន់ដែលផ្គត់ផ្គង់ជានិច្ច ) ក៏ផ្តាច់បង់ចេញ គឺឈប់ឲ្យតទៅទៀតផង ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្ទុះបង្អាប់ថា ទេវទត្តបានដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងទេ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថាអ្នកដឹងហើយ ឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ពិតមែនឬ ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងទេ ម្នាលមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយ ឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៨០] សម័យនោះឯង មានភិក្ខុមួយរូប ចេញពីក្រុងរាជគ្រឹះទៅបួស ហើយទៅកាន់ត្រកូលញាតិ ។ មនុស្សទាំងឡាយនិយាយគ្នាថា លោកម្ចាស់ដ៏ចម្រើន ខាននិមន្តមកយូរហើយ ( ថាដូច្នោះហើយ ) ក៏នាំគ្នាធ្វើចង្ហាន់ប្រគេនដោយគោរព ។ មានភិក្ខុនីម្នាក់ជាជីតុនរបស់ត្រកូលនោះ បាននិយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរឲ្យចង្ហាន់ដល់លោកម្ចាស់ចុះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា ការដឹងហើយបរិភោគបិណ្ឌបាតដែលភិក្ខុនីចាត់ចែង ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ ( សង្ស័យដូច្នោះហើយ ) ក៏មិនទទួល ( បិណ្ឌបាតនោះ ) ហើយមិនអាចនឹងត្រាច់ទៅ ដើម្បីបិណ្ឌបាតទៀតផង ក៏អត់ចង្ហាន់ក្នុងពេលនោះឯង ។ ទើបភិក្ខុនោះទៅអារាម ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលចង្ហាន់មានគ្រហស្ថប្រារព្ធជាមុនហើយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលដឹងឆាន់បិណ្ឌបាត ដែលភិក្ខុនីចាត់ចែងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយកាលដឹងហើយ ឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថបានប្រារព្ធជាមុន ។

[៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងឯងក្តី ជនទាំងឡាយដទៃដឹងហើយ ប្រាប់ដល់ភិក្ខុនោះក្តី ភិក្ខុនីនោះប្រាប់ក្តី ។ ដែលហៅថា ភិក្ខុនី គឺស្ត្រី

ដែលបានឧបសម្បទា ក្នុងសម្នាក់ឧភតោសង្ឃ ។ ដែលហៅថា ចាត់ចែង ( គឺភិក្ខុនីនិយាយប្រាប់ដល់ជន ) ដែលមិនចង់ឲ្យ មិនចង់ធ្វើទាន ក្នុងកាលមុនថា លោកម្ចាស់នេះជាអ្នកពោល លោកម្ចាស់នេះជាពហុស្សុត លោកម្ចាស់នេះជាអ្នកចេះព្រះសូត្រ លោកម្ចាស់នេះទ្រទ្រង់វិន័យ លោកម្ចាស់នេះជាធម្មកថិក អ្នកទាំងឡាយចូរឲ្យ ( ចង្ហាន់ ) ដល់លោកម្ចាស់អង្គនេះ ចូរធ្វើ ( ចង្ហាន់ ) ដល់លោកម្ចាស់នេះ ភិក្ខុនីនេះ ហៅថា ចាត់ចែង ។ ដែលហៅថា បិណ្ឌបាត បានដល់ភោជនទាំង ៥ ភោជនណាមួយ ។ ពាក្យថា វៀរលែងតែចង្ហាន់ដែលគ្រហស្ថគេប្រារព្ធជាមុន សេចក្តីថា លើកទុកតែចង្ហាន់ដែលគ្រហស្ថគេផ្តើមជាមុន ។ ដែលហៅថា គ្រហស្ថប្រារព្ធ គឺជនទាំងឡាយជាញាតិក្តី បិណ្ឌបាតដែលគេបវារណាក្តី ចង្ហាន់ដែលគេតាក់តែងជាប្រក្រតីក្តី ។ ភិក្ខុទទួលបិណ្ឌបាត ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែបិណ្ឌបាតដែលគ្រហស្ថប្រារព្ធជាមុន ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វារៈដែលលេបចូល ។

[៨២] ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុសម្គាល់ថា ភិក្ខុនីចាត់ចែង ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន ។ ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុមានសេចក្តីសង្ស័យ ហើយឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន ។ ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុសម្គាល់ថា មិនបានចាត់ចែងទេ និងចង្ហាន់ដែលគ្រហស្ថបានប្រារព្ធជាមុន ហើយឆាន់ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុឆាន់ភោជនដែលភិក្ខុនីបានឧបសម្បទាក្នុងឯកតោសង្ឃបានចាត់ចែង ត្រូវអាបត្តិទុក្កដ វៀរលែងតែ

ភោជនដែលគ្រហស្ថគេប្រារព្ធឡើងជាមុន ។ ភិក្ខុសម្គាល់ភោជនដែលភិក្ខុនីមិនបានចាត់ចែង ថាបានចាត់ចែងទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យ ក្នុងភោជនដែលភិក្ខុនីមិនបានចាត់ចែង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ភោជនដែលភិក្ខុនីមិនបានចាត់ចែង ថាមិនបានចាត់ចែង មិនត្រូវអាបត្តិ ។

[ ៨៣ ] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជន ដែលគ្រហស្ថប្រារព្ធឡើងមុន ដល់ភិក្ខុដែលឆាន់ភោជនដែលសិក្ខមានាចាត់ចែង ដល់ភិក្ខុដែលឆាន់ភោជនដែលសាមណេរីចាត់ចែង អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា
# ឱវាទវគ្គទី ៣
# បរិចាចនសិក្ខាបទ

[៧៩] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៩ ដូច្នេះ បទថា **មហាថេរេ តិដ្ឋមានេ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា កាលព្រះថេរៈជាធំទាំងឡាយមានប្រាកដ ។ ម្យ៉ាងទៀត អ្នកសិក្សាគប្បីឃើញបាឋៈដ៏សេសក្នុងពាក្យនេះដូច្នេះថា ឃើញព្រះថេរៈជាធំទាំងឡាយមានប្រាកដ ។ សេចក្តីពិត កាលពោលដោយប្រការក្រោយនេះ សេចក្តីមិនសមឡើយ ។

ពាក្យដែលមិនទាន់ដល់ទីបំផុត ដល់ត្រង់កណ្តាលនៃការផ្តើម និងទីបំផុត ឈ្មោះថា **អន្តរាកថា** ។

បទថា **វិប្បកតា** គឺកំពុងធ្វើការនិយាយ ។

បទថា **សច្ចំ មហាថេរា ទោ តយា គហបតិ** សេចក្តីថា ភិក្ខុនីថុល្លនន្ទាផ្ទៀងមើល ឃើញព្រះថេរៈទាំងឡាយកំពុងចូលមក ដឹងថា ព្រះថេរៈទាំងនោះបានឮហើយ ទើបពោលយ៉ាងនេះ ។

បទថា **ភិក្ខុនីបរិចាចិតំ** បានដល់ ដែលភិក្ខុនីដឹកនាំឲ្យប្រគេន ។ អធិប្បាយថា ដែលភិក្ខុនីឲ្យសម្រេច គឺធ្វើឲ្យជារបស់គួរបាន ដោយការប្រកាសគុណ ។ តែក្នុងបទភាជនៈនៃបទនោះ ដើម្បីសម្តែងភិក្ខុនី និងអាការដែលភិក្ខុនីនោះចាត់ចែងប្រគេន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទា ក្នុងសម្នាក់ឧភតោសង្ឃ ។ ដែលហៅថា ចាត់ចែង គឺ ( ភិក្ខុនីនិយាយប្រាប់ ) ដល់ជនដែលមិនចង់ឲ្យ មិន

ចង់ធ្វើទានក្នុងកាលមុន ដូច្នេះជាដើម ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃបរិចាចនសិក្ខាបទ

[ ៨១ ] ក្នុងបទថា **បុព្វេ គិហិសមារម្ភា** នេះ មានវិនិច្ឆ័យដូច្នេះថា បទថា **បុព្វេ** ប្រែថា តាំងអំពីខាងដើម កត្តដែលគេផ្តើមទុកហើយ ហៅថា **សមារម្ភ** ។ បទថា **សមារម្ភ** នេះ ជាឈ្មោះនៃកត្តដែលគេត្រៀមទុកហើយ ។ ការផ្តើមនៃពួកគ្រហស្ថ ឈ្មោះថា **គិហិសមារម្ភ** ។ កត្តណាដែលពួកគ្រហស្ថផ្តើមទុកជាខាងដើមមុន ភិក្ខុនីណែនាំឲ្យប្រគេន ភិក្ខុឆាន់បិណ្ឌបាតដទៃ ក្រៅអំពីកត្តនោះ គឺវៀរបិណ្ឌបាតនោះចេញ ប្រព្រឹត្តជាអាបត្តិ មានពាក្យអធិប្បាយថា តែជាអនាបត្តិដល់ភិក្ខុដែលឆាន់បិណ្ឌបាត ដែលពួកគ្រហស្ថចាត់ចែងទុកនោះ ។ ចំណែកក្នុងបទភាជនៈ ព្រះឧបាលីពោលទុកថា **គិហិសមារម្ភោ នាម ញាតកា វា ហោន្តិ បវារិតា** ដូច្នេះ ដើម្បីសម្តែងតែអត្ថប៉ុណ្ណោះ មិនអើពើដល់ព្យញ្ជនៈ ព្រោះបិណ្ឌបាតដែលពួកញាតិ និងបុគ្គលបវារណា មិនបានប្រារព្ធទុកដើម្បីប្រយោជន៍ដល់ភិក្ខុ គឺគេប្រារព្ធទុកហើយ ដោយអត្ថ ព្រោះគប្បីឲ្យនាំមកបានតាមសប្បាយ ។

បទថា **បកតិប្បដិយត្តំ វា** សេចក្តីថា ជាកត្តដែលគេចាត់ចែងទុកដើម្បីប្រយោជន៍ដល់ភិក្ខុនោះឯង តាមប្រក្រតីថា ពួកយើងនឹងប្រគេនដល់ព្រះថេរៈ ដូច្នេះ ។

តែក្នុងមហាបច្ចរីពោលទុកដោយមិនប្លែកគ្នាថា ជាភត្តដែលគេចាត់ចែងទុកថា នឹងប្រគេនដល់ពួកភិក្ខុ មិនបានប្រារព្ធថា ភិក្ខុអង្គនោះ ឬអង្គដទៃទេ ។

## អនាបត្តិនៃបរិបាចនសិក្ខាបទ

[៨៣] បទថា **បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ** បានដល់ជា អនាបត្តិក្នុងបបរ និងរបស់គួរទំពា និងផ្លែឈើតូចធំទាំងអស់ សូម្បីភិក្ខុនី ណែនាំឲ្យប្រគេនក៏ដោយ ។ បទដ៏សេសរាក់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក កើតឡើងតាមកាយ និងចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បរិបាចនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣០

[ ៨៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ស្ត្រីជាគូពីដើម របស់ឧទាយិដ៏មានអាយុ បួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីនោះតែង មកក្នុងសម្នាក់ឧទាយិដ៏មានអាយុរឿយៗ ។ ចំណែកខាងឧទាយិដ៏មានអាយុ តែងទៅក្នុងសម្នាក់ភិក្ខុនីនោះរឿយៗ ។ គ្រានោះ ឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីនោះតែម្នាក់ឯង ។ ភិក្ខុទាំងឡាយណា មាន សេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះ បង្អាប់ថា ចុះហេតុអ្វី បានជាឧទាយិដ៏មានអាយុម្នាក់ឯងសម្រេចការអង្គុយក្នុង ទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ឯង ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិ-ភិក្ខុ ឮថា អ្នកឯងតែម្នាក់ឯងសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនី តែ ម្នាក់ឯង ពិតមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នក ឯងតែម្នាក់ឯង មិនគួរនឹងសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ ឯងទេ នែមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាក្រៃលែងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនី តែ

ម្នាក់នឹងម្នាក់ ( ភិក្ខុនោះ ) ត្រូវអាបត្តិបាចិត្តិយ ។

[៨៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសម្នាក់ឧភតោសង្ឃ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយ ។ ពាក្យថា តែម្នាក់និងម្នាក់ គឺភិក្ខុ និងភិក្ខុនី ។ ដែលហៅថា ទីស្ងាត់ គឺទីកំបាំងភ្នែក ១ ទីកំបាំងត្រចៀក ១ ។ ដែលហៅថា ទីកំបាំងភ្នែក គឺទីដែលគេមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ក៏មិនអាចនឹងមើលឃើញបាន ។ ដែលហៅថា ទីកំបាំងត្រចៀក គឺទីដែលគេមិនអាចដើម្បីស្តាប់ពាក្យពោលជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា កាលភិក្ខុនីអង្គុយ ភិក្ខុអង្គុយជិតក្តី ដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុអង្គុយ ភិក្ខុនីអង្គុយជិតក្តី ដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីររូប ( គឺភិក្ខុ និងភិក្ខុនី ) អង្គុយក្តី ជនទាំងពីររូប ( គឺភិក្ខុ និងភិក្ខុនី ) ដេកក្តី ត្រូវអាបត្តិបាចិត្តិយ ។

[ ៨៦ ] ទីស្ងាត់ ភិក្ខុក៏សម្គាល់ថា ទីស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែមួយនឹងមួយ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់ តែភិក្ខុសង្ស័យ ហើយអង្គុយ ជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់ ភិក្ខុសម្គាល់ថា មិនស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ទីមិនស្ងាត់ ភិក្ខុសម្គាល់ថា ទីស្ងាត់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទីមិនស្ងាត់ ត្រូវអាបត្តិទុក្កដ ។ ទីមិនស្ងាត់ ភិក្ខុក៏សម្គាល់ថា មិនស្ងាត់ មិនត្រូវអាបត្តិឡើយ ។

[ ៨៧ ] អាបត្តិមិនមានដល់ភិក្ខុ ដែលមានបុរសណាទីមួយដែលដឹងសេចក្តីនៅជាពីរនាក់នឹងខ្លួន ដល់ភិក្ខុដែលឈរមិនអង្គុយ ដល់ភិក្ខុដែលមានបំណងនៅទីមិនស្ងាត់ហើយ( អង្គុយ ) ដល់ភិក្ខុដែលមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

ឱវាទវគ្គជាគម្រប់ ៣ ចប់

### ចំនួនសិក្ខាបទនៃឱវាទវគ្គនេះមាន ១០ គឺ

អសម្មតសិក្ខាបទ ( ភិក្ខុនោវាទសិក្ខាបទ ) ១ អត្ថង្គតសិក្ខាបទ ១ ឧបស្សយសិក្ខាបទ ( ភិក្ខុនូបស្សយ ) ១ អាមិសសិក្ខាបទ ១ ទានសិក្ខាបទ ( ចីវរទានសិក្ខាបទ ) ១ សិព្វនសិក្ខាបទ ( ចីវរសិព្វនសិក្ខាបទ ) ១ អទ្ធានសិក្ខាបទ ( សំវិធានសិក្ខាបទ ) ១ នាវាភិរុហនសិក្ខាបទ ១ កុញ្ចនសិក្ខាបទ ( បរិបាចនសិក្ខាបទ ) ១ ឯកោឯកាយសិក្ខាបទ ( រហោនិសជ្ជសិក្ខាបទ ) ១ ។

# អដ្ឋកថា

# ឱវាទវគ្គទី ៣

# រហោនិសជ្ជសិក្ខាបទ

[ ៨៤ ] វិនិច្ឆ័យក្នុងសិក្ខាបទទី ១០ គប្បីជ្រាបដូច្នេះថា អត្ថនៃព្រះបាលី និងវិនិច្ឆ័យទាំងអស់ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចបានពោលហើយ ក្នុងអនិយតសិក្ខាបទទី ២ នោះឯង ។ ពិតហើយ សិក្ខាបទនេះមានគោលកំណត់តែមួយ ដូចគ្នានឹងអនិយតសិក្ខាបទទី ២ និងជាមួយសិក្ខាបទទី ៤ នៃព្រះឧបនន្ទខាងដើម ។ តែព្រះមានព្រះភាគទ្រង់បញ្ញត្តទុកដោយឡែក ដោយអំណាចនៃហេតុដែលកើតឡើងដូច្នេះឯង ។

*រហោនិសជ្ជសិក្ខាបទ ចប់*

*ឱវាទវគ្គទី ៣ ចប់បរិបូណ៌*

*តាមវណ្ណនានុក្រម*

# វិនយបិដក

## ភោជនវគ្គ សិក្ខាបទទី ១

[ ៨៨ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានពួកជន មួយពួកនៅជិតក្រុងសាវត្ថី បាននាំគ្នាតាក់តែងបិណ្ឌបាតក្នុងផ្ទះសម្នាក់ ឬរោង ទាន ។ ឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ដល់មិនបានបិណ្ឌបាត ក៏ នាំគ្នាទៅកាន់ផ្ទះសម្នាក់ ឬរោងទាន ( នោះ ) ។ មនុស្សទាំងឡាយនិយាយ គ្នាថា លោកម្ចាស់ទាំងឡាយខានទិមន្តមកយូរណាស់ហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាអង្គាសដោយគោរព ។ កាលនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ នាំគ្នា ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក ចូលទៅកាន់ក្រុង សាវត្ថីដើម្បីបិណ្ឌបាត ដល់មិនបានក៏នាំគ្នាទៅកាន់ផ្ទះសម្នាក់ ឬរោងទាន ( នោះ ) ហើយឆាន់ក្នុងថ្ងៃជាគម្រប់ពីរផង ក្នុងថ្ងៃជាគម្រប់បីផង ។ ទើប ឆព្វគ្គិយភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយទៅអារាម ធ្វើអ្វី យើងគួរតែមកក្នុងផ្ទះសម្នាក់ ឬរោងទាននេះប៉ុណ្ណោះបានហើយ ។ ឆព្វគ្គិយភិក្ខុទាំងឡាយ នៅហើយនៅទៀត ក្នុងផ្ទះសម្នាក់នោះឯង នាំគ្នាឆាន់ នៅអាវសថបិណ្ឌបាត ( គឺបិណ្ឌបាតក្នុងផ្ទះសម្នាក់ ឬ រោងទាននោះ ) ។ តិរ្ថិយទាំងឡាយក៏ចៀសចេញទៅ ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ មិនគួរនឹង

នៅត្រាំត្រែង ឆាន់អាវសថបិណ្ឌបាត អាវសថបិណ្ឌបាតមិនមែនជនតាក់តែង ដើម្បីតែពួកសមណៈនេះទេ អាវសថបិណ្ឌបាត ជនតាក់តែងដើម្បីជនទាំងឡាយទាំងពួងរាល់គ្នា ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់( ដូច្នោះ )ហើយ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយមិនគួរនឹងនៅត្រាំត្រែង ឆាន់អាវសថបិណ្ឌបាតសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាត ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងនៅត្រាំត្រែង ឆាន់អាវសថបិណ្ឌបាតទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិននាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា អាហារក្នុងផ្ទះសម្នាក់ ឬរោងទាន ភិក្ខុត្រូវឆាន់បានតែម្ដង បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៨៩] សម័យនោះឯង ព្រះសារីបុត្រដ៏មានអាយុ និមន្តទៅក្រុងសាវត្ថី

ក្នុងកោសលជនបទ បានចូលទៅកាន់ផ្ទះសម្នាក់ ឬរោងទាន ១ ។ មនុស្ស ទាំងឡាយនិយាយគ្នាថា ព្រះថេរៈខាននិមន្តមកយូរណាស់ហើយ ( ថាដូច្នោះ ហើយ ) ក៏នាំគ្នាអង្គាសដោយគោរព ។ លំដាប់នោះ ព្រះសារីបុត្រដ៏មាន អាយុឆាន់រួចហើយ ក៏មានអាពាធជាទម្ងន់ ។ លោកមិនអាចនឹងចៀសចេញ ពីផ្ទះសម្នាក់ ឬរោងទាននោះទៅបាន ។ ទើបមនុស្សទាំងឡាយនោះ បាន ពោលពាក្យនេះនឹងព្រះសារីបុត្រដ៏មានអាយុ ក្នុងថ្ងៃជាគម្រប់ពីរថា បពិត្រ ព្រះថេរៈដ៏ចម្រើន សូមលោកនិមន្តឆាន់ចុះ ។ ព្រះសារីបុត្រដ៏មានអាយុមាន សេចក្តីសង្ស័យថា ការដែលនៅត្រាំត្រែង ឆាន់បិណ្ឌបាតក្នុងផ្ទះសម្នាក់ ឬរោង ទាន ព្រះដ៏មានព្រះភាគបានហាមហើយៗ មិនទទួលបិណ្ឌបាត ក៏អត់ចង្ហាន់ ក្នុងពេលនោះ ។ គ្រានោះ ព្រះសារីបុត្រដ៏មានអាយុនិមន្តទៅកាន់ក្រុងសាវត្ថី ហើយតំណាលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយៗ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះ ដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើ ធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំង ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជំងឺអាស្រ័យនៅរឿយៗ ឆាន់ភោជនក្នុង រោងទានបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខា បទនេះ យ៉ាងនេះថា បិណ្ឌបាតក្នុងរោងទាន ភិក្ខុមិនមានជំងឺត្រូវឆាន់បានតែ ម្តង បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

[ ៩០ ] ភិក្ខុដែលអាចដើម្បីចៀសចេញពីរោងទាននោះទៅបាន ហៅថា

មិនមានជំងឺ ។ ភិក្ខុដែលមិនអាចដើម្បីចៀសចេញពីរោងទាននោះទៅបាន ហៅថា មានជំងឺ ។ ដែលហៅថា បិណ្ឌបាតក្នុងរោងទាន បានដល់ ភោជនទាំង ៥ យ៉ាង ភោជនណាមួយ ដែលគេតាក់តែងក្នុងសាលាក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី មិនចំពោះបុគ្គលណា គេតាក់តែងកំណត់ល្មមមួយឆ្អែត ( គ្រប់ៗ គ្នា ) ។ ភិក្ខុមិនមានជំងឺ ត្រូវឆាន់បានតែម្តង បើទទួលឲ្យហួសពីកំណត់នោះទៅ ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វារៈដែលលេបចូលទៅ ។

[ ៩១ ] ខ្លួនមិនមានជំងឺ ភិក្ខុសម្គាល់ថា មិនមានជំងឺ ហើយបរិភោគអាវសថបិណ្ឌបាត ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនមានជំងឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគ អាវសថបិណ្ឌបាតឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនមានជំងឺ ភិក្ខុសម្គាល់ថា មានជំងឺ ហើយឆាន់អាវសថបិណ្ឌបាត ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមានជំងឺ ភិក្ខុសម្គាល់ថា មិនមានជំងឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជំងឺ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជំងឺ ភិក្ខុសម្គាល់ថា មានជំងឺ មិនត្រូវអាបត្តិឡើយ ។

[ ៩២ ] អាបត្តិមិនមានដល់ភិក្ខុមានជំងឺ ដល់ភិក្ខុមិនមានជំងឺឆាន់តែម្តង ដល់ភិក្ខុដែលដើរទៅក្តី ដើរមកក្តី ហើយឆាន់[១] ដល់ភិក្ខុដែលជនជាម្ចាស់ទាន

---

១- បានដល់ ភិក្ខុមានដំណើរចេញពីស្រុកមួយទៅស្រុកមួយ ចម្ងាយផ្លូវទៅមួយថ្ងៃ មកមួយថ្ងៃ ថ្ងៃទី ១ ទៅឆាន់ម្តង ថ្ងៃទី ២ ត្រឡប់មកវិញឆាន់ម្តងទៀត ។

គេនិមន្តឲ្យឆាន់ ដល់ភិក្ខុដែលឆាន់បិណ្ឌបាតដែលគេតាក់តែងចំពោះ ដល់ភិក្ខុដែលឆាន់បិណ្ឌបាត ដែលគេតាក់តែងមិនដល់មួយចម្អែត អាបត្តិមិនមានដល់ភិក្ខុព្រោះឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់

# អដ្ឋកថា

## ភោជនវគ្គទី ៤

## អាវសថបិណ្ឌសិក្ខាបទ

[៨៨] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ១ នៃភោជនវគ្គដូចតទៅនេះ ជុំបាយ ក្នុងរោងទាន ឈ្មោះថា **អាវសថបិណ្ឌ** អធិប្បាយថា អាហារដែលគេធ្វើក្នុងរោងទាន រាំងរបងដោយជុំវិញ មានកំណត់បន្ទប់ និងសំយាបមុខទុកជាច្រើន រៀបចំគ្រែ និងតាំងទុកតាមសមគួរដល់ពួកអាគន្តុកៈ អ្នកឈឺ ស្រីមានគភ៌ និងបព្វជិត ហើយចាត់ចែងទុកក្នុងរោងទាននោះ ព្រោះជាអ្នកមានសេចក្តីត្រូវការបុណ្យ គឺវត្ថុគ្រប់យ៉ាង មានបបរ បាយ និងថ្នាំសង្កូវជាដើម ជារបស់ដែលគេរៀបចំទុកដើម្បីឲ្យទាន ដល់ពួកអ្នកដំណើរជាដើមនោះ ។

បទថា **ភិយ្យោបិ** គឺស្អែកនេះ ។

បទថា **អបសក្កន្តិ** គឺរមែងចៀសទៅ ។

ពីរបទថា **មនុស្សា ឧជ្ឈាយន្តិ** សេចក្តីថា ពួកអ្នកស្រុកមិនឃើញពួកតិត្ថិយ ទើបសួរថា ពួកតិត្ថិយទៅណាអស់ បានឮថា ពួកតិត្ថិយឃើញឆព្វគ្គិយ-ភិក្ខុទាំងនេះហើយ ក៏ចៀសចេញទៅ ទើបនាំគ្នាលើកទោស ។

[៨៩] បទថា **កុក្កុច្ចាយន្តោ** សេចក្តីថា ធ្វើសេចក្តីរង្កៀស គឺឲ្យកើតសេចក្តីសម្គាល់ថា មិនគួរ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃអាវសថបិណ្ឌសិក្ខាបទ

[៩០] ត្រើនបទថា **សក្កោតិ តម្ហា អាវសថា បក្កមិតុំ** សេចក្ដីថា រមែង អាចដើម្បីនឹងទៅបានកន្លះយោជន៍ ឬមួយយោជន៍ ។ បទថា **ន សក្កោតិ** គឺ រមែងមិនអាចដើម្បីនឹងទៅអស់ទីប្រមាណប៉ុណ្ណោះនោះឯង ។

បទថា **អនោទិស្ស** សេចក្ដីថា ជារបស់ដែលគេរៀបចំទុក ដើម្បីមនុស្សគ្រប់ជំពូក មិនឧទ្ទិសចំពោះលទ្ធិយ៉ាងនេះថា ដល់លទ្ធិពួកនេះប៉ុណ្ណោះក្ដី ដល់ពួកអ្នកបួសមានប្រមាណប៉ុណ្ណោះប៉ុណ្ណោះក្ដី ។

បទថា **យាវទត្ថោ** សេចក្ដីថា ជារបស់ដែលគេរៀបចំទុក មានល្មមដល់សេចក្ដីត្រូវការ មិនកំណត់កោជនថា មានប្រមាណប៉ុណ្ណោះ ។

បទថា **សកឹ ភុញ្ជិតព្វោ** គឺគប្បីឆាន់បានមួយថ្ងៃ ។ ចាប់ពីថ្ងៃទី ២ ទៅ ត្រូវអាបត្តិទុក្កដក្នុងការទទួលប្រគេន ត្រូវបាចិត្តិយគ្រប់ៗ ពំនូតដែលលេប ។

ឯវិនិច្ឆ័យក្នុងសិក្ខាបទនេះ មានដូច្នេះថា កោជនដែលត្រកូលមួយ ឬត្រកូលផ្សេងៗ រួមគ្នារៀបចំទុកក្នុងទីតែមួយក្ដី ក្នុងទីផ្សេងៗ គ្នាក្ដី ក្នុងទីមិនពិតប្រាកដយ៉ាងនេះ គឺថ្ងៃនេះមួយកន្លែង ស្អែកនេះមួយកន្លែងក្ដី ។ ភិក្ខុឆាន់មួយថ្ងៃក្នុងទីកន្លែងមួយហើយ ក្នុងថ្ងៃទី ២ នឹងឆាន់ក្នុងទីនោះ ឬក្នុងទីដទៃ មិនគួរ ។ តែកោជនដែលត្រកូលផ្សេងៗ រៀបចំទុកក្នុងទីផ្សេងៗ គ្នា ភិក្ខុឆាន់មួយថ្ងៃក្នុងទីកន្លែងមួយ ហើយក្នុងថ្ងៃទី ២ ឆាន់ក្នុងទីដទៃ គួរ ។ ក្នុងមហាបច្ចរីពោលថា ភិក្ខុឆាន់អស់លំដាប់ ហើយផ្ដើមឆាន់ជាថ្មី មិនគួរ ដូច្នេះ

សូម្បីគណៈជាមួយគ្នា គណៈផ្សេងគ្នា ស្រុកតែមួយ និងស្រុកផ្សេងគ្នា ក៏ន័យនេះឯង ។ ឯកត្តាហារណាដែលត្រកូលតែមួយរៀបចំ ឬត្រកូលផ្សេងៗរួមគ្នារៀបចំទុក ដាច់រយៈទៅក្នុងចន្លោះ ព្រោះមិនមានអន្តរជាដើម ភត្តាហារនោះ ក៏មិនគួរឆាន់ ។ លោកពោលទុកក្នុងមហាបច្ចរីថា បើត្រកូលទាំង-ឡាយកាត់ដាច់ថា ពួកយើងនឹងមិនអាចឲ្យ កាលកើតចិត្តបរិសុទ្ធឡើង ទើបផ្ដើមឲ្យជាថ្មី ទោះត្រឡប់មកឆាន់ទៀត មួយថ្ងៃមួយដងក៏បាន ។

## អនាបត្តិនៃអាវសថបិណ្ឌសិក្ខាបទ

[៩២] ពីរបទថា **អនាបត្តិ គិលានស្ស** បានដល់ ជាអនាបត្តិដល់ភិក្ខុអាពាធ ដែលសម្រាកឆាន់ ។

បទថា **គច្ឆន្តោ វា** សេចក្ដីថា ភិក្ខុណា កាលទៅឆាន់មួយថ្ងៃក្នុងវាងផ្លូវ និងក្នុងទីទៅដល់ហើយ ឆាន់មួយថ្ងៃទៀត ជាអនាបត្តិដល់ភិក្ខុនោះ ទោះក្នុងភិក្ខុដែលមក ក៏មានន័យដូច្នេះឯង ។ ពិតហើយ ភិក្ខុដែលទៅហើយត្រឡប់មក រមែងបានដើម្បីឆាន់ក្នុងចន្លោះផ្លូវមួយថ្ងៃ និងក្នុងដំណើរត្រឡប់មកទៀតមួយថ្ងៃ ។ កាលភិក្ខុគិតថា នឹងទៅឆាន់ហើយចេញទៅ ទឹកឡើងពេញស្ទឹងក្ដី មានភ័យ គឺចោរក្ដី លោកត្រឡប់មកហើយ ដឹងថា ផុតភ័យហើយទៅ រមែងអាចដើម្បីឆាន់ទៀតមួយថ្ងៃ ពាក្យទាំងអស់ដូចពោលមកនេះ លោកពោលទុកក្នុងមហាបច្ចរីជាដើម ។

បទថា **ឧទ្ទិស្ស បញ្ញត្តោ ហោតិ** សេចក្ដីថា ជារបស់ដែលគេឧទ្ទិសចំពោះដល់ភិក្ខុទាំងឡាយប៉ុណ្ណោះ ។

បទថា **ន យាវទត្ថោ** សេចក្តីថា មិនមែនជារបស់ដែលគេរៀបចំទុក គ្រប់គ្រាន់ដល់សេចក្តីត្រូវការ គឺមានត្រឹមបន្តិចបន្តួច ទោះឆាន់ភោជនដូច្នោះជានិច្ច ក៏គួរ ។

ត្រើនបទថា **បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ** បានដល់ ជាអនាបត្តិក្នុងរបស់គ្រប់ប្រភេទ ដូចជាបបរ របស់គួរទំពា និងផ្លែឈើតូចធំជាដើម ពិតហើយ ភិក្ខុទោះឆាន់ភោជន មានយាគូជាដើមជានិច្ច ក៏គួរ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អវសថបិណ្ឌសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវទត្តមានលាភសក្ការៈសាបសូន្យហើយ ព្រមទាំងបរិស័ទ ក៏នាំគ្នាដើរសូមរឿយៗ ក្នុងពួកត្រកូលហើយឆាន់ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធ បុត្រសក្យរាជ មិនគួរនឹងនាំគ្នា ដើរសូមរឿយៗ ក្នុងពួកត្រកូល ហើយឆាន់សោះ ( ធម្មតាមនុស្ស ) អ្នកណាមួយដែលមិនគាប់ចិត្តនឹងភោជនល្អ អ្នកណាមួយដែលមិនពេញចិត្តនឹងភោជនដ៏ឆ្ងាញ់ពិសា ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះពោលទោស តិះដៀលបន្តុះបង្អាប់ ( ដូច្នោះ ) ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្ត ព្រមទាំងបរិស័ទ មិនគួរនឹងនាំគ្នាដើរសូមរឿយៗ ក្នុងត្រកូលទាំងឡាយហើយឆាន់សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថា អ្នកឯងព្រមទាំងបរិស័ទ នាំគ្នាដើរសូមរឿយៗ ក្នុងត្រកូលទាំងឡាយហើយឆាន់ ពិតមែនឬ ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងព្រមទាំងបរិស័ទ មិនគួរនឹងដើរសូមរឿយៗ ក្នុងត្រកូលទាំងឡាយ ហើយឆាន់ទេ ម្នាលមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិននាំ

ជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាក្រៃលែងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុឆាន់គណៈភោជន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ៩៤ ] សម័យនោះឯង មនុស្សទាំងឡាយនិមន្តពួកភិក្ខុដែលមានជំងឺដោយភត្ត ។ ពួកភិក្ខុសង្ស័យ មិនទទួល ដោយគិតថា គណៈភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ទើបពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជំងឺឆាន់គណៈភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ៩៥ ] សម័យនោះឯង មនុស្សទាំងឡាយតាក់តែងចង្ហាន់ ព្រមទាំងចីវរ ក្នុងសម័យចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងនិមន្តលោកម្ចាស់ទាំងឡាយឲ្យឆាន់ រួចហើយនឹងប្រគេនចីវរ ឲ្យស្លៀកដណ្តប់ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួល ដោយគិតថា គណៈភោជន ព្រះដ៏

មានព្រះភាគទ្រង់ហាមហើយ ។ ចីវរក៏កើតឡើងដល់ភិក្ខុដោយស្តួចស្តើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយឆាន់គណៈភោជនបានក្នុងសម័យនៃចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេឲ្យចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៦] សម័យនោះឯង មនុស្សទាំងឡាយនិមន្តពួកភិក្ខុដែលជាអ្នកធ្វើចីវរដោយចង្ហាន់ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួល ដោយគិតថា គណៈភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណៈភោជនបាន ក្នុងសម័យដែលធ្វើចីវរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៧] សម័យនោះឯង ភិក្ខុទាំងឡាយទៅកាន់ផ្លូវឆ្ងាយ មួយអន្លើដោយមនុស្សទាំងឡាយ ។ ឯភិក្ខុទាំងនោះ និយាយពាក្យនេះ នឹងមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរបង្អង់ចាំមួយរំពេច យើងទាំងឡាយនឹងត្រាច់ទៅដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយនោះនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ក្នុងទីនេះចុះ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួល ដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជនក្នុងសម័យដែលដើរផ្លូវឆ្ងាយ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុង សិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើនូវចីវរ ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៨] សម័យនោះឯង ភិក្ខុទាំងឡាយទៅដោយទូក មួយអន្លើដោយមនុស្សទាំងឡាយ ។ ឯភិក្ខុទាំងនោះនិយាយពាក្យនេះនឹងមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរអែបទូកទៀបឆ្នេរមួយរំពេចសិន យើងទាំងឡាយនឹងត្រាច់ទៅដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយនោះនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ឆាន់ចង្ហាន់ក្នុងទីនេះ

ចុះ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា គណៈភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុ ឆាន់គណៈភោជនក្នុងសម័យឡើងជិះទូកបាន ម្នាលភិក្ខុទាំង ឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវ អាបត្តិបាចិត្តិយ ព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯ សម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេន ចីវរ ១ សម័យដែលធ្វើចីវរ ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ ១ សម័យ ដែលឡើងជិះទូក ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏ មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៩] សម័យនោះឯង ភិក្ខុទាំងឡាយ នៅចាំវស្សាក្នុងទិសទាំងឡាយ លុះចេញវស្សារួចហើយ ក៏នាំគ្នាមកឯក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះដ៏មាន ព្រះភាគ ។ ពួកមនុស្សឃើញភិក្ខុទាំងឡាយមកពីវជ្ជសីមា[១] ផ្សេងៗគ្នា ហើយក៏និមន្តឆាន់ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា គណៈ ភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តី នុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យអ្នកទាំងឡាយ ឆាន់គណៈភោជនក្នុងមហាសម័យបាន ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា

---

១- រាជអាណាចក្រដទៃ ប្រទេសដទៃ ដែនដទៃ ។

ភិក្ខុត្រូវអាបត្តិបាចិត្តិយព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើនូវចីវរ ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ ១ សម័យដែលឡើងជិះទូក ១ សម័យដែលមានភិក្ខុច្រើន ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

[១០០] សម័យនោះឯង ( មានបុរសម្នាក់ ) ត្រូវជាញាតិសាលោហិតរបស់ព្រះបាទមាគធសេនិយពិម្ពិសាររាជ បានបួសក្នុងសម្នាក់អាជីវកទាំងឡាយ ។ លំដាប់នោះ អាជីវកនោះចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសាររាជ ហើយបានទូលពាក្យនេះ ចំពោះព្រះបាទមាគធសេនិយពិម្ពិសាររាជថា បពិត្រមហារាជ អាត្មាប្រាថ្នាដើម្បីធ្វើនូវភត្តជារបៀបបាសណ្ឌសុទ្ធ[១] ។ ព្រះបាទមាគធសេនិយពិម្ពិសាររាជ ត្រាស់ថា បពិត្រលោកដ៏ចម្រើន បើលោកនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឆាន់មុនសិន ( ទើប ) យើងត្រូវធ្វើយ៉ាងនេះ ( បាន ) ។ អាជីវកនោះក៏ប្រើបម្រើទៅក្នុងសម្នាក់ភិក្ខុទាំងឡាយ ក្នុងពេលនោះថា ភិក្ខុទាំងឡាយសូមទទួលចង្ហាន់របស់ខ្ញុំ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា គណៈភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ គ្រានោះ អាជីវកនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដល់ហើយក៏ពោលពាក្យជាទីរាក់ទាក់ជាមួយនឹងព្រះ

---

១- គឺរបៀបធ្វើភត្តរបស់មិច្ឆាទិដ្ឋិ ក្រៅអំពីព្រះពុទ្ធសាសនា ។

ដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលបុគ្គលគប្បីរីករាយ ដែលបុគ្គលគប្បីរឭក ស្រេចហើយ ក៏ស្ថិតនៅក្នុងទីដ៏សមគួរ ។ អាជីវកនោះ លុះស្ថិតនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា ព្រះគោតមដ៏ចម្រើន ជាអ្នកបួស ខ្ញុំព្រះអង្គក៏ជាអ្នកបួសដែរ អ្នកបួសគួរទទួលដុំបាយរបស់អ្នកបួសផងគ្នា ព្រះគោតមដ៏ចម្រើន សូមទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ អាជីវកនោះ ដឹងច្បាស់ថាព្រះដ៏មានព្រះភាគទទួលនិមន្តន៍ហើយក៏ចៀសចេញទៅក្នុងពេលនោះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាហៅភិក្ខុទាំងឡាយមកជួបជុំក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណៈភោជន ក្នុងសម័យនៃសមណភត្តបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយព្រោះឆាន់គណៈភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើនូវចីវរ ១ សម័យដែលដើរផ្លូវឆ្ងាយ ១ សម័យដែលឡើងជិះទូក ១ សម័យដែលមានភិក្ខុច្រើនអង្គ ១ សម័យនៃសមណភត្ត ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[ ១០១ ] ដែលហៅថា គណៈភោជន គឺភិក្ខុ ៤ រូប ដែលគេនិមន្តចេញឈ្មោះភោជនទាំង ៥ ដោយភោជនណាមួយ ហើយឆាន់ភោជនណា

ភោជនទុំះ ហៅថា គណៈភោជន ។ ពាក្យថា វៀរលែងតែមានសម័យ គឺ លើកទុកតែមានសម័យ ( គឺហេតុដែលគួរនឹងឆាន់បាន ) ។ ដែលហៅថា សម័យមានជំងឺ ដោយហោចទៅសូម្បីតែជើងទាំងឡាយដែលបែក ( បាក់ផ្លោ ក៏ហៅថា មានជំងឺ ) ភិក្ខុដឹងថាខ្លួនមានសម័យឈឺថ្កាត់ហើយ គប្បីឆាន់ គណៈភោជនបាន ។ ដែលហៅថា សម័យដែលគេប្រគេនចីវរ គឺថា កាល បើភិក្ខុមិនបានក្រាលកឋិនទេ ( សម័យនៃចីវរទាន ) បានត្រឹមតែ ១ ខែ គឺ ខែជាខាងចុងនៃវស្សានរដូវ[១] បើភិក្ខុបានក្រាលកឋិន ( សម័យនៃចីវរទាន ) បាន ៥ ខែ[២] ។ ភិក្ខុដឹងថា មានសម័យនៃចីវរទាន ហើយគប្បីឆាន់គណៈ ភោជនបាន ។ ដែលហៅថា សម័យដែលធ្វើនូវចីវរ គឺ កាលដែលភិក្ខុ កំពុងធ្វើចីវរ ។ ភិក្ខុដឹងថា មានសម័យជាទីធ្វើនូវចីវរហើយ គប្បីឆាន់គណៈ ភោជនបាន ។ ដែលហៅថា សម័យដែលដើរផ្លូវឆ្ងាយ គឺ ភិក្ខុដឹងថា អញ នឹងដើរផ្លូវឆ្ងាយប្រមាណកន្លះយោជន៍ ហើយគប្បីឆាន់គណៈភោជនបាន ។ កាលភិក្ខុកំពុងដើរទៅ ក៏គប្បីឆាន់គណៈភោជនបាន ។ កាលភិក្ខុមកវិញ ក៏ គប្បីឆាន់គណៈភោជនបាន ។ ដែលហៅថា សម័យឡើងជិះទូក គឺភិក្ខុដឹងថា អញនឹងឡើងជិះទូក ហើយគប្បីឆាន់គណៈភោជនបាន ។ ភិក្ខុឡើងជិះទូក ហើយ គប្បីឆាន់គណៈភោជនបាន ។ កាលភិក្ខុចុះអំពីទូកហើយ គប្បីឆាន់ គណៈភោជនបាន ។ ដែលហៅថា សម័យមានភិក្ខុច្រើនអន្លើ គឺសម័យដែល

---

១- គឺគិតពី ១ រោច ខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មីខែកត្ដិក ។ ២- គឺគិតពី ១ រោច ខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មីខែផល្គុន ។

ភិក្ខុទាំងឡាយពីរ ឬបីអង្គត្រាច់ទៅដើម្បីបិណ្ឌបាត ហើយបានឆាន់ឆ្អែត ក្នុងទីណា ដល់ភិក្ខុមួយអង្គមកទៀត ត្រូវជា ៤ អង្គឆាន់មិនឆ្អែត ។ ភិក្ខុដឹងថាសម័យ មានភិក្ខុច្រើនអង្គជួបច្នេះហើយ គប្បីឆាន់គណៈភោជនបាន ។ ដែលហៅថា សម័យនៃសមណភត្ត គឺអ្នកណាមួយដែលរាប់បញ្ចូលក្នុងពួកអ្នកបួស (ក្រៅព្រះពុទ្ធសាសនា) ធ្វើភត្ត ។ ភិក្ខុដឹងថា សម័យនៃសមណភត្តហើយ គប្បីឆាន់គណៈភោជនបាន ។ ភិក្ខុទទួលគណៈភោជន ដោយគិតថា អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសម័យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ពំនូតដែលលេបចូលក្នុងក ។

[ ១០២ ] គណៈភោជន ភិក្ខុសម្គាល់ថា គណៈភោជនមែន ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងគណៈភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសម្គាល់ក្នុងគណៈភោជនថា មិនមែនគណៈភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនមែនគណៈភោជន ភិក្ខុសម្គាល់ ថាគណៈភោជន ត្រូវអាបត្តិទុក្កដ ។ មិនមែនគណៈភោជន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនគណៈភោជន ភិក្ខុសម្គាល់ថាមិនមែនគណៈភោជន មិនត្រូវអាបត្តិ ។

[ ១០៣ ] អាបត្តិមិនមានដល់ភិក្ខុមានសម័យ ដល់ភិក្ខុទាំងឡាយពីរ ឬបីអង្គដែលឆាន់ជាមួយគ្នា ដល់ភិក្ខុទាំងឡាយដែលត្រាច់ទៅដើម្បីបិណ្ឌបាត ហើយប្រជុំគ្នាឆាន់ក្នុងទីជាមួយគ្នា ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត

បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

## សិក្ខាបទទី ២ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# គណភោជនសិក្ខាបទ

[៩៣] សិក្ខាបទទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **បរិ-ហីនលាភសក្ការោ** សេចក្តីថា បានឮថា ទេវទត្តនោះដឹកនាំឲ្យព្រះបាទ-អជាតសត្រូវផ្តាច់ព្រះជន្មព្រះរាជាក្តី ប្រើខ្មាន់ធ្នូទៅ ( ដើម្បីផ្តាច់ព្រះជន្មព្រះតថាគត ) ក្តី ធ្វើលោហិតុប្បាទក្តី បានជាអ្នកកំបាំងបិទបាំង តែក្នុងវេលាលែងដំរីធនបាលកៈទៅទាំងកណ្តាលថ្ងៃស្រស់ៗ នោះឯង ក៏ប្រាកដច្បាស់ឡើង ។

សេចក្តីនេះដូចម្តេច សេចក្តីថា ព្រោះកើតពាក្យនិយាយឡើងថា ទេវទត្តភិក្ខុលែងដំរីទៅ ( ដើម្បីផ្តាច់ព្រះជន្មព្រះតថាគត ) ក៏បានជាអ្នកប្រាកដច្បាស់ថា មិនមែនតែលែងដំរីតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីព្រះរាជា ទេវទត្តក៏ឲ្យផ្តាច់ព្រះជន្ម សូម្បីពួកខ្មាន់ធ្នូក៏បញ្ជូនទៅ សូម្បីថ្មក៏ប្រមៀល ទេវទត្តភិក្ខុជាបុគ្គលលាមក ។ កាលមានអ្នកសួរថា ទេវទត្តបានធ្វើកម្មនោះរួមជាមួយនរណា អ្នកស្រុកពោលថា ជាមួយព្រះបាទអជាតសត្តុ ។ ក្នុងលំដាប់នោះ អ្នកស្រុកក៏ភ្ញាក់ផ្អើលឡើង ពោលថា ហេតុអ្វីហ្ន៎ ទើបព្រះរាជាសេពគប់ចោរ ដែលជាចម្រូងចម្រាសចំពោះព្រះសាសនាបែបនេះទៅវិញ ព្រះរាជាទ្រង់ជ្រាបការបះបោររបស់អ្នកស្រុក ទើបទ្រង់បណ្តេញទេវទត្តភិក្ខុចេញទៅ តាំងអំពីនោះមកទ្រង់ក៏កាត់កត្ត ៥០០ សម្រាប់នៃទេវទត្តនោះចេញ សូម្បីទីទំនុកបម្រុងទេវ-

ទត្តភិក្ខុនោះ ក៏ទ្រង់មិនបានទៅ សូម្បីពួកអ្នកស្រុកដទៃ ក៏មិនសម្គាល់របស់ណាមួយដែលនឹងគប្បីប្រគេន ឬគប្បីធ្វើដល់ទេវទត្តភិក្ខុនោះ ។ ដោយហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា មានលាភ និងសក្ការៈ វិនាសអន្តរធានហើយ ។

បទថា **កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជតិ** សេចក្តីថា ទេវទត្តនោះត្រិះរិះថា គណៈរបស់អាត្មាអញ កុំបានបែកបាក់គ្នាឡើយ ដើម្បីនឹងចិញ្ចឹមបរិស័ទ ទើបបាននាំបរិស័ទត្រាច់សូមអាហារចាន់ក្នុងត្រកូលទាំងឡាយយ៉ាងនេះថា អ្នកចូរឲ្យភត្តដល់ភិក្ខុមួយរូប អ្នកចូរឲ្យដល់ភិក្ខុ ២ រូបដូច្នេះ ។

[៩៥] បទថា **ចីវរំ បរិត្តំ ឧប្បជ្ជតិ** សេចក្តីថា អ្នកស្រុកទាំងឡាយមិនឲ្យចីវរដល់ភិក្ខុដែលមិនទទួលភត្តាហារ ព្រោះហេតុនោះ ទើបចីវរកើតឡើងតិចតួច ។

[៩៦] បទថា **ចីវរការកេ ភិក្ខូ ភត្តេន ឆិមន្តេន្តិ** សេចក្តីថា ពួកអ្នកស្រុកឃើញភិក្ខុទាំងឡាយ ដែលត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ហើយធ្វើចីវរឲ្យសម្រេចយឺតយូរ ទើបនិមន្តដោយបំណងបុណ្យថា ភិក្ខុទាំងឡាយ នឹងញុំាងចីវរឲ្យសម្រេច ហើយប្រើប្រាស់ដោយអាការយ៉ាងនេះ ។

[៩៩] បទថា **នានាវេរជ្ជកេ** បានដល់ ដែលមកអំពីរដ្ឋផ្សេងៗ គឺពីរាជអាណាចក្រដទៃ ។ បាឋៈថា **នានាវេរញ្ជកេ** ក៏មាន ឯសេចក្តីក៏ដូចគ្នា ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃគណភោជនសិក្ខាបទ

[១០១] បទថា **គណភោជនេ** គឺព្រោះការឆាន់របស់គណៈ ។ ក្នុងសិក្ខាបទនេះ ទ្រង់បំណងយកភិក្ខុចាប់ពី ៤ រូបឡើងទៅ ឈ្មោះថា គណៈ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងកំណត់ដោយពាក្យនោះឯង ទើបត្រាស់ថា **យត្ថ ចត្តារោ ភិក្ខូ ។បេ។ ឯតំ គណភោជនំ នាម** ដូច្នេះ ។

គណៈភោជននេះ រមែងប្រព្រឹត្តទៅដោយអាការ ២ យ៉ាង គឺដោយការនិមន្ត ១ ដោយវិញ្ញត្តិ ១ ។ រមែងប្រព្រឹត្តទៅដោយការនិមន្តដូចម្ដេច គឺ ទាយកចូលទៅរកភិក្ខុ ៤ រូប ហើយនិមន្តប្រារព្ធឈ្មោះភោជនទាំង ៥ ដោយវេវចនៈឯណានីមួយ ឬដោយភាសាដទៃយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំនិមន្តលោកម្ចាស់ដោយបាយ សូមលោកម្ចាស់កាន់យកបាយរបស់ខ្ញុំ សូមសង្ឃឹម សូមពិនិត្យមើល សូមទទួលយកនូវបាយរបស់ខ្ញុំ ដូច្នេះ ភិក្ខុតាំងពី ៤ រូបឡើងទៅទទួលនិមន្តន៍រួមគ្នាយ៉ាងនេះ ទៅព្រមគ្នា ដើម្បីឆាន់ក្នុងថ្ងៃនេះក្ដី ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះក្ដី ដោយអំណាចនៃវេលាដែលគេកំណត់ទុក ទទួលរួមគ្នា ឆាន់រួមគ្នា ចាត់ជាគណៈភោជន ជាអាបត្តិដល់ភិក្ខុទាំងអស់ ។

ភិក្ខុទាំងឡាយទទួលនិមន្តន៍រួមគ្នា ឆាន់ផ្សេងគ្នា ក៏ជាអាបត្តិដូចគ្នា ពិតហើយ ការទទួលប្រគេននោះឯង ជាប្រមាណក្នុងសិក្ខាបទនេះ ។ ភិក្ខុទាំង-ឡាយទទួលនិមន្តន៍រួមគ្នា ទោះទៅព្រមគ្នាក្ដី ទៅផ្សេងគ្នាក្ដី ទទួលប្រគេនផ្សេងគ្នា ឆាន់រួមគ្នាក្ដី ឆាន់ផ្សេងគ្នាក្ដី ជាអនាបត្តិ ។

ភិក្ខុទាំងឡាយទៅកាន់បរិវេណក្តី វិហារ ៤ កន្លែងក្តី ទទួលនិមន្តន៍ផ្សេង គ្នាក្តី បណ្តាភិក្ខុដែលឈរក្នុងទីកន្លែងជាមួយគ្នានោះឯង ទទួលនិមន្តន៍ផ្សេង គ្នា យ៉ាងនេះ គឺកូនប្រុសនិមន្តមួយរូប ឪពុកនិមន្តមួយរូប ទោះទៅព្រមគ្នាក្តី ទៅផ្សេងគ្នាក្តី ទោះឆាន់ព្រមគ្នាក្តី ឆាន់ផ្សេងគ្នាក្តី បើទទួលប្រគេនរួមគ្នា រាប់ ជាគណៈភោជន ត្រូវអាបត្តិដល់ភិក្ខុទាំងអស់ ។ រមែងប្រព្រឹត្តទៅដោយការ និមន្តយ៉ាងនេះប៉ុណ្ណោះ ។

រមែងប្រព្រឹត្តទៅដោយវិញ្ញត្តិដូចម្តេច គឺភិក្ខុ ៤ រូប ឈរ ឬអង្គុយ ជាមួយគ្នា ឃើញឧបាសកហើយ ចេញវាចាសូមថា ចូរអ្នកឲ្យភត្តដល់ពួក អាត្មាទាំង ៤ រូបដូច្នេះក្តី ឃើញផ្សេងៗគ្នា ហើយហាមាត់សូមរួមគ្នាក្តី សូមផ្សេងៗគ្នា យ៉ាងនេះថា អ្នកចូរឲ្យដល់អាត្មា អ្នកចូរឲ្យដល់អាត្មា ដូច្នេះ ក្តី ទោះបីទៅព្រមគ្នាក្តី ទៅផ្សេងគ្នាក្តី ទទួលប្រគេនភត្តហើយ ទោះឆាន់រួម គ្នាក្តី ឆាន់ផ្សេងគ្នាក្តី បើទទួលប្រគេនរួមគ្នា រាប់ថាជាគណៈភោជន ប្រព្រឹត្ត ជាអាបត្តិដល់ភិក្ខុទាំងអស់ ។ រមែងប្រព្រឹត្តទៅដោយវិញ្ញត្តិយ៉ាងនេះ ។

ពីរបទថា **ផាលេត្វា** សេចក្តីថា ( ជើងទាំង ២ ) បែកដោយ អាការត្រង់សាច់ ប្រាកដឲ្យឃើញខាងមុខស្បែកដ៏ធំ ត្រឹមតែត្រូវខ្សាច់ ឬ ក្រួសប៉ះខ្ទប់ ក៏ញុំាងឲ្យកើតទុក្ខឡើង មិនអាចត្រាច់ទៅបិណ្ឌបាតខាងក្នុងស្រុក បាន អាពាធដូច្នោះ គួរឆាន់បាន ដោយគិតថា ជាសម័យអាពាធ ( តែ ) មិនគួរធ្វើឲ្យជាកប្បិយដោយលេស ។

ពីរបទថា **ចីវរេ កយិរមានេ** សេចក្តីថា ក្នុងសម័យដែលពួកភិក្ខុបាន សំពត់ និងអំបោះ ហើយធ្វើចីវរ ។ ពិតហើយ ឈ្មោះថា ចីវរការសម័យ មួយផ្នែកមិនមាន ព្រោះហេតុនោះ ភិក្ខុណាធ្វើការឯណាមួយ ដែលគួរធ្វើក្នុង ចីវរនោះ សមដូចលោកពោលទុកក្នុងមហាបច្ចរីថា ដោយហោចសូម្បីភិក្ខុដែល ដោតម្ជុល ដូច្នេះក៏មាន ជាចីវរកាលសម័យ ។

ចំណែកក្នុងកុរុន្ទី ពោលទុកដោយពិស្តារនោះឯងថា ភិក្ខុណា ធ្វើចីវរ កាត់ចីវរ តម្កល់ទុកនូវអំបោះ ដេរដាន ផ្គុបសំពត់ថ្មី ដេរសង្កត់ថ្នេរ ភ្ជាប់ សំពត់ផ្គុប កាត់អនុវាត តអំបោះ ដេរជាយក្នុងចីវរនោះ ខារអំបោះ រុំអំបោះ សំលៀងកាំបិតតូច ធ្វើអក្សរអំបោះ ភិក្ខុទាំងអស់នេះ លោកហៅថា ធ្វើចីវរ ទាំងអស់ តែភិក្ខុណាអង្គុយក្បែរៗ ពោលជាតកក្តី ធម្មបទក្តី ភិក្ខុនេះ មិន មែនអ្នកធ្វើចីវរ វៀរភិក្ខុនេះចេញ ត្រូវអាបត្តិដល់ភិក្ខុដ៏សេស ព្រោះគណៈ ភោជន ។

បទថា **អឌ្ឍយោជនំ** បានដល់ បំណងនឹងធ្វើដំណើរផ្លូវឆ្ងាយប្រមាណ ប៉ុណ្ណេះ ។ ភិក្ខុណាបំណងនឹងដើរផ្លូវឆ្ងាយ ភិក្ខុនោះ មិនមានពាក្យដែលនឹង ត្រូវពោលឡើយ ។

បទថា **គច្ឆន្តេន** សេចក្តីថា ភិក្ខុដែលដើរផ្លូវឆ្ងាយ ទោះឆាន់ក្នុងទីមួយ គាវុតខាងក្នុងកន្លះយោជន៍ ក៏គួរ ។

ពីរបទថា **អាគតេន ភុញ្ជិតព្វំ** គឺដែលទៅហើយ គប្បីឆាន់បានមួយ ថ្ងៃ សូម្បីក្នុងវេលាដោយសារទូកទៅ ក៏មានន័យដូច្នេះឯង ។ ឯសេចក្តីប្លែក

គ្នា ដូចតទៅនេះថា ក្នុងមហាបច្ចរីពោលថា ភិក្ខុដោយសារទូកទៅសូម្បីដល់ទីដែលខ្លួនប្រាថ្នាហើយ គប្បីធាន់បានអស់កាលដែលខ្លួនមិនទាន់ឡើង ( អំពីទូក ) ។

កំណត់ថា **ចតុត្ថេ អាគតេ** នេះ ជាកំណត់យ៉ាងទាបបំផុត ។ កាលភិក្ខុអង្គទី ៤ មក ភិក្ខុទាំងឡាយ មិនល្មមគ្រប់គ្រាន់ចិញ្ចឹមគ្នាក្នុងសម័យណា សម័យនោះ ចាត់ជាគ្រាប្រជុំធំបាន ។ ក្នុងគ្រាដែលភិក្ខុប្រជុំគ្នារាប់រយអង្គក្តី ពាន់អង្គក្តី មិនមានពាក្យដែលពោលឡើយ ព្រោះហេតុនោះ ក្នុងសម័យដូច្នោះ ភិក្ខុគប្បីអធិដ្ឋានថា ជាគ្រាប្រជុំធំ ហើយធាន់ចុះ ។

បទថា **យោ កោចិ បរិព្វាជកសមាបន្នោ** បានដល់ បណ្តាពួកសហធម្មិកក្តី ពួកតិរ្ថិយក្តី អ្នកបួសពួកណាមួយក្តី កាលអ្នកបួស មានសហធម្មិកជាដើមនោះ អង្គណាមួយធ្វើភត្តាហារហើយ ភិក្ខុគប្បីអធិដ្ឋានថា ជាសម័យភត្តរបស់សមណៈ ហើយធាន់ចុះ ។

## អនាបត្តិនៃគណភោជនសិក្ខាបទ

[ ១០៣ ] ពីរបទថា **អនាបត្តិ សមយេ** បានដល់ ជាអនាបត្តិក្នុងសម័យទាំង ៧ សម័យណាមួយ ។

បទថា **ទ្វេ តយោ ឯកតោ** សេចក្តីថា ភិក្ខុពួកណាត្រេកអរក្នុងការនិមន្តដែលមិនសមគួរ ទទួលរួមគ្នា ២ រូបក្តី ៣ រូបក្តី ហើយធាន់ ជាអនាបត្តិដល់ភិក្ខុពួកនោះ ។

ក្នុងបទថា **ចត្ដារោ គយោ ឯកតោ** នោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដោយចតុក្កៈ ៥ ពួក គឺ **អនិមន្តិតចតុត្ថ** ( មានភិក្ខុមិនបាននិមន្តជាគម្រប់ ៤ ) ១ **បិណ្ឌបាតិកចតុត្ថ** ( មានភិក្ខុសមាទានបិណ្ឌបាតជាវត្តជាគម្រប់ ៤ ) ១ **អនុបសម្បន្នចតុត្ថ** ( មានអនុបសម្បន្នជាគម្រប់ ៤ ) ១ **បត្តចតុត្ថ** ( មានបាត្រជាគម្រប់ ៤ ) ១ **គិលានចតុត្ថ** ( មានភិក្ខុអាពាធជាគម្រប់ ៤ ) ១ ។

សេចក្ដីនេះដូចម្ដេច សេចក្ដីថា បុគ្គលខ្លះក្នុងលោកនេះ និមន្តភិក្ខុ ៤ អង្គថា និមន្តលោកម្ចាស់ទទួលភត្ត ( បាយ ) ។ ក្នុងភិក្ខុ ៤ អង្គនោះ ទៅ ៣ រូប មិនទៅ ១ រូប ឧបាសកសួរថា បពិត្រលោកម្ចាស់ ព្រះថេរៈមួយអង្គទៅឯណា ភិក្ខុឆ្លើយថា មិនបានមកទេឧបាសកៗ នោះ និមន្តភិក្ខុដទៃអង្គខ្លះ ដែលមកដល់ក្នុងខណៈនោះ ឲ្យចូលអង្គុយជាមួយថា បពិត្រលោកម្ចាស់សូមនិមន្តមកចុះ ហើយប្រគេនភត្តដល់ភិក្ខុទាំង ៤ អង្គ ជាអនាបត្តិដល់ភិក្ខុទាំងអស់ ។ ព្រោះហេតុអ្វី ព្រោះគណៈបូរកភិក្ខុ ( ភិក្ខុដែលគម្រប់គណៈ ) គេមិនបាននិមន្ត ។ ពិតហើយ ក្នុងភិក្ខុ ៤ រូបនោះ ភិក្ខុ ៣ រូបប៉ុណ្ណោះ គេនិមន្តបានទទួលប្រគេនហើយ គណៈមិនទាន់គ្រប់ដោយភិក្ខុ ៣ រូបនោះ ឯរូបដែលគ្រប់គណៈ គេមិនបាននិមន្ត ទើបគណៈបែកព្រោះភិក្ខុនោះ ភិក្ខុចតុត្ថដូចពោលមកនេះ ឈ្មោះថា អនិមន្តិតចតុត្ថ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបិណ្ឌបាតិកចតុត្ថថា ក្នុងវេលានិមន្ត មានភិក្ខុសមាទានបិណ្ឌបាតជាវត្តមួយអង្គ ទើបលោកមិនទទួល តែក្នុងវេលានឹងទៅកាលភិក្ខុទទួលនិមន្តន៍ពោលថា បពិត្រលោកម្ចាស់សូមនិមន្តមកចុះ ហើយ

នាំយកភិក្ខុនោះដែលជាអ្នកមិនទៅ ព្រោះមិនបានទទួលនិមន្តទៅ ដោយពោលថា សូមនិមន្តមកចុះ លោកម្ចាស់នឹងបានភត្ត ។ ភិក្ខុនោះធ្វើគណៈឲ្យបែកគ្នា ព្រោះដូច្នោះ ទើបមិនជាអាបត្តិដល់ភិក្ខុទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអនុបសម្បន្នចតុត្ថជា ពួកភិក្ខុទទួលនិមន្តន៍ព្រមគ្នា ជាមួយសាមណេរ សូម្បីសាមណេរនោះក៏ធ្វើគណៈឲ្យដាច់គ្នាបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបត្តចតុត្ថជា ភិក្ខុមួយអង្គមិនទៅឯង បញ្ជូនបាត្រទៅដោយអាការយ៉ាងនេះ គណៈក៏បែក ព្រោះដូច្នោះ ទើបមិនជាអាបត្តិដល់ភិក្ខុគ្រប់អង្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគិលានចតុត្ថជា ពួកភិក្ខុទទួលនិមន្តន៍ មួយអន្ទើដោយភិក្ខុអាពាធ ក្នុងភិក្ខុ ៤ រូបនោះ ភិក្ខុអាពាធប៉ុណ្ណោះ ជាអនាបត្តិ តែលោកជាគណៈបូរកៈរបស់ភិក្ខុក្រៅអំពីនេះបាន ទើបគណៈមិនបែក ( ដាច់ពីគ្នា ) ព្រោះភិក្ខុអាពាធឡើយ ព្រោះដូច្នោះ ទើបជាអាបត្តិដល់ភិក្ខុទាំងនោះពិត ។ តែក្នុងមហាបច្ចរីពោលទុកដោយមិនប្លែកគ្នាថា ភិក្ខុអាពាធបានសម័យ ( គ្រាអាពាធ ) ទើបផុតទៅដោយខ្លួនឯងប៉ុណ្ណោះ ធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុដ៏សេស ព្រោះជាគណៈបូរកៈ ។ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបចតុក្កៈដោយអំណាចនៃភិក្ខុដែលបានចីវរទានសម័យជាដើម ។

បើភិក្ខុអ្នកឈ្លាសមួយអង្គ ក្នុងភិក្ខុ ៤ អង្គនោះ សូម្បីទទួលនិមន្តន៍ហើយទៅ ពោលថា ខ្ញុំនឹងបែកគណៈរបស់ពួកលោក សូមពួកលោកទទួលការនិមន្តដើម្បីពួកអ្នកស្រុក និងទទួលបាត្រដើម្បីប្រយោជន៍ដល់ភត្ត ក្នុងទី

បំផុតនៃបបរ និងរបស់គួរទំពា មិនឲ្យ ( បាត្រ ) ពោលថា ពួកអ្នកឲ្យភិក្ខុទាំងនេះឆាន់ ហើយបញ្ជូនត្រឡប់ទៅមុន អាត្មាធ្វើអនុមោទនាហើយ នឹងទៅតាមក្រោយ ហើយនៅអង្គុយ កាលភិក្ខុទាំងនោះឆាន់ស្រេចហើយទៅ កាលឧបាសកពោលថា លោកម្ចាស់ សូមឲ្យបាត្រមកចុះ ហើយទទួលបាត្រទៅប្រគេនភត្តឆាន់ស្រេច ធ្វើអនុមោទនា ហើយសឹមទៅ ជាអនាបត្តិដល់ភិក្ខុគ្រប់រូប ។

ពិតហើយ ការខុសសង្កេតក្នុងគណៈភោជន រមែងមិនមាន ដោយអំណាចនៃភោជន ៥ យ៉ាងឡើយ។ ពួកភិក្ខុទទួលនិមន្តន៍ដោយបាយ សូម្បីទទួលទំកុម្ភាស ក៏ត្រូវអាបត្តិ ហើយភោជនទាំងនោះ ភិក្ខុទាំងនោះ មិនបានទទួលរួមគ្នា ។ តែមានការខុសសង្កេតដោយអាហារវត្ថុ មានបបរជាដើម ។ បបរជាដើមនោះ ភិក្ខុទាំងនោះទទួលរួមគ្នាបាន ដូច្នេះ ។ ភិក្ខុអ្នកឈ្លាសមួយអង្គ រមែងធ្វើមិនឲ្យត្រូវអាបត្តិដល់ភិក្ខុពួកដទៃ ដោយប្រការយ៉ាងនេះ ។

ព្រោះដូច្នោះ បើបុគ្គលខ្លះដែលអ្នកមានបំណងធ្វើសង្ឃភត្ត ពឹងឲ្យទៅដើម្បីនិមន្ត ( ភិក្ខុ ) មកកាន់វិហារ មិនពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ និមន្តទទួលភិក្ខាក្នុងផ្ទះរបស់ពួកខ្ញុំ តែពោលថា និមន្តលោកម្ចាស់ទទួលភត្តក្តី និមន្តលោកម្ចាស់ទទួលសង្ឃភត្តក្តី សូមសង្ឃទទួលភត្តក្តី ភត្តុទ្ទេសកៈគប្បីជាអ្នកឈ្លាស គប្បីដោះពួកភិក្ខុដែលទទួលនិមន្តន៍អំពីគណៈភោជន គប្បីដោះភិក្ខុអ្នកសមាទានបិណ្ឌិបាតិកង្គធុតង្គ អំពីការបែកធ្លាយនៃធុតង្គ ។

សេចក្តីនេះដោះដូចម្តេច សេចក្តីថា ភត្តុទ្ទេសកភិក្ខុគប្បីពោលយ៉ាង

នេះថា ស្អែកនេះមិនអាច ( ទទួល ) ទេឧបាសក កាលឧបាសកពោលថា ខានស្អែកនេះ លោកម្ចាស់ គប្បីពោលថា ខានស្អែកក៏មិនអាច ( ទទួលបាន ) ឧបាសកបន្ថិតទៅយ៉ាងនេះ រហូតដល់កន្ទះខែ កត្តុទ្ទេសកភិក្ខុគប្បីពោលទៀតថា អ្នកនិយាយអ្វី បើឧបាសកពោលដដែលទៀតថា និមន្តលោកម្ចាស់ទទួលសង្ឃភត្ត លំដាប់នោះ កត្តុទ្ទេសកគប្បីធ្វើមធ្យោបាយយ៉ាងនេះថា ឧបាសក ចូរធ្វើផ្កានេះ ចូរធ្វើស្មៅនេះ ឲ្យជាកប្បិយជាមុន ហើយសួរទៀតថា អ្នកនិយាយអ្វី បើឧបាសកនៅតែពោលយ៉ាងនោះឯងទៀត គប្បីពោលថា ឧបាសក អ្នកមិនបានព្រះមហាថេរៈដែលសមាទានបិណ្ឌបាតជាវត្ត អ្នកនឹងបានតែពួកសាមណេរ ។ តែកាលឧបាសកសួរថា បពិត្រលោកម្ចាស់ ពួកមនុស្សក្នុងស្រុកនោះ និងស្រុកនោះ និមន្តឲ្យលោកម្ចាស់ឆាន់ មិនមែនឬ ខ្ញុំមិនបាន ព្រោះហេតុអ្វី គប្បីពោលថា ពួកគេចេះនិមន្ត ( ចំណែក ) អ្នកមិនចេះនិមន្ត ។ ឧបាសកសួរថា បពិត្រលោកម្ចាស់ ពួកគេនិមន្តដូចម្តេច គប្បីពោលថា ពួកគេពោលយ៉ាងនេះថា និមន្តទទួលភិក្ខារបស់ពួកខ្ញុំ លោកម្ចាស់ បើគេពោលដូចដែលពោលនោះឯង ការនិមន្តនោះសមគួរ ។

បើបុរសនោះនៅពោលដដែលទៀតថា និមន្តទទួលភត្ត គប្បីពោលថា ឧបាសក គ្រានេះ អ្នកមិនបានភិក្ខុច្រើនទេ បានត្រឹម ៣ អង្គប៉ុណ្ណោះ ។ បើបុរសនោះសួរថា បពិត្រលោកម្ចាស់ ពួកអ្នកស្រុកក្នុងស្រុកនោះ និងស្រុកនោះ និមន្តភិក្ខុសង្ឃទាំងអស់ឲ្យឆាន់មិនមែនឬ ហើយខ្ញុំមិនបានព្រោះហេតុអ្វី គប្បីពោលថា អ្នកមិនចេះនិមន្ត ។ បើបុរសនោះសួរថា បពិត្រលោកម្ចាស់

ពួកគេនិមន្តដូចម្តេច គប្បីពោលថា ពួកគេពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ និមន្តទទួលភិក្ខារបស់ពួកខ្ញុំ ។ បើឧបាសកនោះពោលដូចប្រាប់នោះឯងការនិមន្តនោះសមគួរ ។

បើបុរសនោះពោលថា កត្តប៉ុណ្ណោះទៀត ពេលនោះ កត្តុទ្ទេសកគប្បីពោលថា អញ្ជើញចុះឧបាសក ពួកអាត្មាមិនត្រូវការដោយកត្តរបស់អ្នកស្រុកនេះជាទីត្រាច់ទៅបិណ្ឌបាតជាប្រក្រតីរបស់ពួកអាត្មាៗនឹងត្រាច់ទៅបិណ្ឌ-បាតក្នុងស្រុកនេះ ។ បុរសពោលថា និមន្តលោកម្ចាស់ត្រាច់ទៅកាន់ស្រុកនោះចុះ ហើយត្រឡប់មក អ្នកស្រុកសួរថា អ្នកដ៏ចម្រើន អ្នកបានភិក្ខុហើយឬ បុរសនោះពោលថា ក្នុងរឿងនិមន្តនេះ មានពាក្យដែលត្រូវពោលច្រើនមានប្រយោជន៍អ្វីដោយពាក្យពោលដែលគប្បីពោលឲ្យច្រើននេះ ព្រះថេរៈទាំងឡាយពោលថា ពួកអាត្មានឹងត្រាច់ទៅបិណ្ឌបាតស្អែកនេះ គ្រានេះ ពួកអ្នកកុំប្រមាទ ។

ក្នុងថ្ងៃស្អែកឡើង ព្រះសង្ឃត្ថេរគប្បីប្រាប់ភិក្ខុទាំងឡាយ ដែលធ្វើចេតិយវត្ត ហើយកំពុងឈរថា លោកម្ចាស់ ឯស្រុកជិតមានសង្ឃកត្ត តែមនុស្សមិនឈ្លាសបានទៅហើយ ណ្ហើយចុះ ពួកយើងនឹងត្រាច់ទៅបិណ្ឌបាតក្នុងស្រុកជិតនោះ ពួកភិក្ខុគប្បីធ្វើតាមពាក្យរបស់ព្រះថេរៈ មិនគប្បីជាអ្នកប្រដៅក្រ គប្បីត្រាច់ទៅបិណ្ឌបាត កុំឈរត្រង់ទ្វារស្រុកឡើយ ។ កាលអ្នកស្រុកទាំងនោះទទួលបាត្រ និមន្តឲ្យអង្គុយឆាន់ គប្បីឆាន់ចុះ ។ បើគេរៀបចំកត្តទុកត្រង់រោងឆាន់ ហើយត្រាច់ទៅប្រាប់ត្រង់ផ្លូវថា និមន្តទទួលកត្តត្រង់

រោងឆាន់ លោកម្ចាស់ មិនគួរ ។ តែបើគេកាន់យកភត្តទៅក្នុងទីនោះៗ ប្រាប់ថា និមន្តទទួលភត្តចុះក្តី ប្រញាប់នាំទៅកាន់វិហារនោះឯង ទុកក្នុងទីដ៏សមគួរ ហើយប្រគេនដល់ពួកភិក្ខុដែលមកដល់ ហើយភិក្ខុនេះ ឈ្មោះថា ភិក្ខាដែលគេនាំមកចំពោះ រមែងគួរ ។

បើគេរៀបចំទានទុកត្រង់រោងសម្រាប់ចម្អិនអាហារ ហើយត្រាច់ទៅកាន់បរិវេណនោះៗ ប្រាប់ថា និមន្តទទួលភត្តត្រង់រោងចម្អិនអាហារ មិនគួរ ។ តែពួកអ្នកស្រុកណា កាលឃើញពួកភិក្ខុចូលទៅបិណ្ឌបាត ក៏ជួយគ្នាបោសរោងឆាន់ និមន្តឲ្យអង្គុយឆាន់ត្រង់រោងឆាន់នោះ ។ មិនគប្បីបដិសេធជនទាំងនោះឡើយ ។ តែជនពួកណា ឃើញពួកភិក្ខុដែលមិនបានភិក្ខាក្នុងស្រុក កំពុងចេញអំពីស្រុកទៅ ប្រាប់ថា បពិត្រលោកម្ចាស់ និមន្តទទួលភត្តចុះ មិនគប្បីបដិសេធជនទាំងនោះឡើយ ។ មិនគប្បីត្រឡប់ បើពួកអ្នកស្រុកពោលថា បពិត្រលោកម្ចាស់ និមន្តត្រឡប់ចុះ សូមនិមន្តទទួលភត្ត នឹងត្រឡប់ទៅក្នុងបទដែលអ្នកស្រុកពោលថា និមន្តត្រឡប់ចុះក៏បាន ។

អ្នកស្រុកពោលថា និមន្តត្រឡប់ចុះលោកម្ចាស់ ភត្តក្នុងផ្ទះសម្រេចហើយ ភត្តក្នុងស្រុកសម្រេចហើយ ។ នឹងត្រឡប់ទៅដោយគិតថា ភត្តក្នុងផ្ទះ និងក្នុងស្រុក រមែងមានដើម្បីបុគ្គលណាមួយក៏បាន រមែងគួរ ។ អ្នកស្រុកពោលឲ្យសម្ពន្ធគ្នាដោយពាក្យថា និមន្តត្រឡប់ទៅទទួលភត្តចុះ ដូច្នេះ បើត្រឡប់ទៅមិនគួរ ។ ក្នុងពាក្យដែលអ្នកស្រុកឃើញពួកភិក្ខុដែលកំពុងចេញអំពីរោងឆាន់ទៅដើម្បីត្រាច់បិណ្ឌបាត ហើយពោលថា បពិត្រលោកម្ចាស់

និមន្តអង្គុយចុះ សូមនិមន្តទទួលភត្ត ដូច្នេះ ក៏មានន័យនោះឯង ។

ភត្តប្រចាំ ហៅថា **និច្ចភត្ត** ។ អ្នកស្រុកពោលថា និមន្តទទួលនិច្ចភត្ត ទោះបីទទួលរួមគ្នាច្រើនអង្គ ក៏គួរ ។ ក្នុងសលាកភត្តជាដើម ក៏មានន័យដូច្នេះឯង ។ បទដ៏សេសក្នុងសិក្ខាបទនេះ រាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

គណភោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[ ១០៤ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅកូដាគារសាលា ក្នុងមហាវ័ន ក្បែរក្រុងវេសាលី ។ សម័យនោះឯង ក្រុងវេសាលី គេបានចាត់ចែងភត្តដ៏ឧត្តមទាំងឡាយ តាំងនៅជានិច្ច ។ គ្រានោះ អ្នកធ្វើការម្នាក់ ជាមនុស្សទ័លក្រ មានសេចក្ដីត្រិះរិះដូច្នេះថា មនុស្សទាំងឡាយនេះ ធ្វើភត្តដោយគោរព តាមទំនងយ៉ាងណា ( ទំនង ) នេះ មិនមែនជាថោកទាបឡើយ បើដូច្នោះ មានតែអញត្រូវធ្វើភត្តនឹងគេដែរ ។ ឯអ្នកធ្វើការងារ ដែលជាមនុស្សទ័លក្រនោះ ចូលទៅរកបុរសឈ្មោះកិរបតិកៈ លុះចូលទៅហើយ ក៏បាននិយាយពាក្យនេះ នឹងបុរសឈ្មោះកិរបតិកៈនោះថា បពិត្រអយ្យបុត្រ ខ្ញុំប្រាថ្នាដើម្បីធ្វើភត្តដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សូមអ្នកឲ្យថ្លៃឈ្នួលមកខ្ញុំចុះ ។ បុរសឈ្មោះកិរបតិកៈនោះឯង ក៏ជាមនុស្សមានសទ្ធាជ្រះថ្លាដែរ ។ ឯបុរសឈ្មោះកិរបតិកៈនោះ បានឲ្យថ្លៃឈ្នួលច្រើនគ្រាន់បើ ដល់អ្នកធ្វើការងារដែលជាមនុស្សទ័លក្រនោះ ។ គ្រានោះ អ្នកធ្វើការងារដែលជាមនុស្សទ័លក្រនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ។ បុរសអ្នកធ្វើការងារ ដែលជាមនុស្សទ័លក្រនោះ លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគសូមទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក

មួយអន្ទើដោយភិក្ខុសង្ឃ ។ ព្រះអង្គត្រាស់សួរថា ម្នាលអាវុសោ ភិក្ខុសង្ឃ ច្រើនណាស់ អ្នកចូរដឹងចុះ ។ បុរសកម្សត់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃច្រើនក៏ច្រើនចុះ ( ព្រោះ ) ផ្លែពុទ្រាមានប្រមាណច្រើន ខ្ញុំព្រះអង្គបានចាត់ចែងហើយ គ្រឿងផឹកទាំងឡាយ នឹងបរិបូណ៌ដោយបបរលាយដោយផ្លែពុទ្រា។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព។ គ្រានោះ បុរសអ្នកធ្វើការងារដ៏កម្សត់នោះដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ភិក្ខុទាំងឡាយបានដំណឹងថា ឮថា ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អ្នកធ្វើការងារដ៏កម្សត់បាននិមន្តហើយ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក គ្រឿងផឹកទាំងឡាយ និងបរិបូណ៌ដោយបបរលាយដោយផ្លែពុទ្រា ។ ភិក្ខុទាំងនោះត្រាច់ទៅដើម្បីបិណ្ឌបាត ហើយឆាន់តាំងអំពីព្រឹក ។ មនុស្សទាំងឡាយបានដំណឹងថា ឮថា ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អ្នកធ្វើការងារដ៏កម្សត់បាននិមន្តហើយ ។ មនុស្សទាំងនោះនាំយកខាទនីយ ភោជនីយ មានប្រមាណច្រើនទៅដើម្បីអ្នកធ្វើការងារដ៏កម្សត់ ( នោះ ) ។ លុះព្រឹកឡើង ទើបអ្នកធ្វើការងារដ៏កម្សត់នោះឲ្យមនុស្សតាក់តែង ខាទនីយភោជនីយដ៏ឧត្តម ហើយឲ្យគេក្រាបទូលនូវភត្តកាលចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹករួចហើយយាងចូលទៅកាន់លំនៅ អ្នកធ្វើការងារដ៏កម្សត់នោះ លុះចូលទៅ

ដល់ហើយ ក៏គង់លើអាសនៈដែលគេតាក់តែងថ្វាយ មួយអន្លើដោយភិក្ខុសង្ឃ ។ ទើបអ្នកធ្វើការងារដ៏កម្សត់នោះ ក៏អង្គាសភិក្ខុទាំងឡាយក្នុងរោងភត្ត ។ ពួកភិក្ខុពោលយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ ។ អ្នកធ្វើការងារដ៏កម្សត់នោះ ឆ្លើយថា បពិត្រលោកទាំងឡាយដ៏ចម្រើន លោកទាំងឡាយសូមកុំទទួលនូវវត្ថុបន្តិចៗ ដោយគិតថា អ្នកធ្វើការងារនេះ ជាមនុស្សកម្សត់ឡើយ ( ព្រោះ ) ខាទនីយភោជនីយមានប្រមាណច្រើន ខ្ញុំព្រះករុណាឲ្យគេតាក់តែងហើយ បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកទាំងឡាយទទួល ( ឆាន់ ) ត្រាតែឆ្អែត ។ ពួកភិក្ខុឆ្លើយថា ម្នាលអាវុសោ យើងទាំងឡាយទទួលវត្ថុបន្តិចៗ ព្រោះតែហេតុនេះក៏មិនមែនទេ មកពីយើងទាំងឡាយត្រាច់ទៅដើម្បីបិណ្ឌបាត ឆាន់តាំងអំពីព្រឹកហើយ ហេតុនោះ បានជាយើងទាំងឡាយទទួលតែបន្តិចៗ ម្នាក់ ។ លំដាប់នោះ អ្នកធ្វើការងារដ៏កម្សត់នោះពោលទោសតិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកទាំងឡាយដ៏ចម្រើន ខ្ញុំបាននិមន្តហើយ មិនគួរនឹងឆាន់ក្នុងទីដទៃសោះ ឬខ្ញុំមិនអាចដើម្បីប្រគេនឲ្យឆាន់ឆ្អែតទេដឹង ។ ភិក្ខុទាំង-ឡាយឮអ្នកធ្វើការងារដ៏កម្សត់នោះពោលទោសតិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុដែលគេបាននិមន្តក្នុងទីដទៃ ហើយ មិនគួរនឹងឆាន់ក្នុងទីដទៃសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុ ជនគេបាននិមន្តក្នុងទីដទៃហើយ ត្រឡប់ឆាន់ក្នុង

ទីដទៃវិញ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ គេបាននិមន្តក្នុងទីដទៃហើយ មិនគួរនឹងឆាន់ក្នុងទីដទៃ ម្នាលភិក្ខុទាំងឡាយ ការនេះនឹងនាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែល មិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ព្រោះឆាន់បរម្បរភោជន[១] ( គឺភោជនដែលគេនិមន្តខាងក្រោយ ) សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ១០៥ ] សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុមួយរូបទៀត កាន់យកបង្អាន់បិណ្ឌបាតចូលទៅរកភិក្ខុនោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរឆាន់ ។ ភិក្ខុមានជំងឺឆ្លើយថា ម្នាលអាវុសោ កុំឡើយ បង្អាន់ដែលគេបម្រុងឲ្យខ្ញុំមានហើយ ។ បិណ្ឌបាតដែលគេនាំយកមកប្រគេនភិក្ខុនោះក្នុងពេលថ្ងៃពេក ។ ភិក្ខុមានជំងឺនោះ ឆាន់មិនបានដោយស្រួលសោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំង

---

១- ព្រោះភិក្ខុនោះទទួលនិមន្តន៍ឆាន់ភោជន ៥ យ៉ាង ភោជនណាមួយក្នុងទីឯណោះ ហើយត្រឡប់ទៅឆាន់ក្នុងទីឯណោះវិញ ឬទទួលនិមន្តន៍ឆាន់ក្នុងទីឯណោះ ហើយត្រឡប់មកឆាន់ក្នុងទីឯណោះវិញ។

ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជំងឺឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលភិក្ខុមានជំងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៦] សម័យនោះឯង មនុស្សទាំងឡាយតាក់តែងកត្ត ព្រមទាំងចីវរក្នុងសម័យនៃចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា ពួកយើងនឹងនិមន្តលោកម្ចាស់ទាំងឡាយឆាន់រួច ( នឹងប្រគេន ) ចីវរឲ្យស្លៀកដណ្តប់ ។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា បរម្បរភោជន ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ ។ ចីវរក៏កើតឡើងដល់ភិក្ខុដោយស្តួចស្តើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជនក្នុងសម័យនៃចីវរទានបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលភិក្ខុមានជំងឺ ១ សម័យនៃចីវរទាន ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគ បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៧] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកភិក្ខុជាអ្នកធ្វើចីវរឲ្យឆាន់បច្ឆាន់ ។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា បរម្បរភោជន

ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជន ក្នុងសម័យជាទីធ្វើនូវចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលភិក្ខុមានជំងឺ ១ សម័យនៃចីវរទាន ១ សម័យជាទីធ្វើនូវចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៨] គ្រានោះ ពេលបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគទ្រង់ស្បៀកស្បង់ហើយប្រដាប់ដោយបាត្រ និងចីវរ មានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ព្រះអង្គទ្រង់យាងចូលទៅកាន់ត្រកូលមួយ លុះចូលទៅហើយ ក៏ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយ ។ ទើបមនុស្សទាំងឡាយនោះបានថ្វាយភោជនដល់ព្រះដ៏មានព្រះភាគផង ដល់ព្រះអានន្ទដ៏មានអាយុផង ។ ព្រះអានន្ទដ៏មានអាយុសង្ស័យមិនហ៊ានទទួល ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកទទួលចុះ ។ ព្រះអានន្ទក្រាបទូលថា សូមទ្រង់មេត្ដាប្រោសក្រែងមិនគួរ ព្រោះខ្ញុំព្រះអង្គមានចង្ហាន់គេបម្រុងនឹងប្រគេនហើយ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរកំណត់ ( ចង្ហាន់នោះដល់ភិក្ខុឯទៀត ) ហើយទទួលយក ( ចង្ហាន់នេះ ) ចុះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកំណត់នូវបច្ឆាន់ដែលគេបម្រុង ដើម្បីខ្លួនដល់ភិក្ខុឯទៀត ហើយឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីកំណត់ដោយពាក្យយ៉ាងនេះថា ខ្ញុំឲ្យនូវភត្តដែលគេបម្រុងទុកដើម្បីខ្ញុំដល់ភិក្ខុឈ្មោះនេះ ។

[១០៩] ដែលហៅថា បរម្បរភោជន គឺ ( ភិក្ខុ ) ដែលគេនិមន្តដោយភោជន ៥ យ៉ាង ភោជនណាមួយ ហើយវៀរភោជននោះ បែរទៅឆាន់ភោជន ៥ យ៉ាង ភោជនណាមួយនៅទីដទៃ ភោជននោះហៅថា បរម្បរភោជន ។ ពាក្យថា វៀរតែមានសម័យ គឺ លើកទុកតែមានសម័យ ( គឺ ហេតុដែលគួរនឹងឆាន់បាន ) ។ ដែលហៅថា សម័យដែលភិក្ខុមានជំងឺ គឺ ភិក្ខុមិនអាចនឹងអង្គុយឆាន់ជាបទាល់ផ្អែតលើអាសនៈមួយ ។ ភិក្ខុដឹងថា ខ្លួនមានសម័យឈឺថ្កាត់ហើយ គប្បីឆាន់ ( បរម្បរភោជនបាន ) ។ ដែលហៅថា សម័យនៃចីវរទាន គឺបើភិក្ខុមិនបានក្រាលកឋិនទេ សម័យចីវរទានមាន តែមួយខែ គឺខែជាទីបំផុតនៃវស្សានរដូវ បើភិក្ខុបានក្រាលកឋិន សម័យនៃចីវរទានមាន ៥ ខែ ។ ភិក្ខុដឹងថាសម័យនៃចីវរទាន គប្បីឆាន់ ( បរម្បរភោជនបាន ) ។ ដែលហៅថា សម័យជាទីធ្វើនូវចីវរ គឺ កាលដែលភិក្ខុកំពុងធ្វើចីវរ ។ ភិក្ខុដឹងថាសម័យជាទីធ្វើនូវចីវរ គប្បីឆាន់ ( បរម្បរភោជនបាន ) ។ ភិក្ខុទទួល ( បរម្បរភោជន ) ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសម័យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វារៈដែលលេប ។

[១១០] ភិក្ខុសម្គាល់ក្នុងបរម្បរភោជនថា បរម្បរភោជនមែន ហើយ

ឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសម្គាល់ក្នុងបរម្បរភោជនថា មិនមែនបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនមែនបរម្បរភោជន ភិក្ខុសម្គាល់ថា បរម្បរភោជន ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្បរភោជន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្បរភោជន ភិក្ខុសម្គាល់ថា មិនមែនជាបរម្បរភោជន មិនត្រូវអាបត្តិឡើយ ។

[ ១១១ ] អាបត្តិមិនមានដល់ ( ភិក្ខុដែលឆាន់បរម្បរភោជន ) ក្នុងសម័យ ដល់ភិក្ខុដែលបានកំណត់ ( បរម្បរភោជនដល់ភិក្ខុឯទៀត ) ហើយឆាន់ ដល់ភិក្ខុពីរបីអង្គឆាន់ជាមួយគ្នា ក្នុងទីដែលគេនិមន្ត ដល់ភិក្ខុឆាន់តាមលំដាប់លំដោយដែលគេនិមន្ត ដល់ភិក្ខុដែលអ្នកស្រុកទាំងអស់និមន្ត ហើយឆាន់ក្នុងទីណាមួយក្នុងស្រុកនោះ ដល់ភិក្ខុដែលប្រជុំជនទាំងអស់និមន្ត ហើយឆាន់ក្នុងទីណាមួយ ក្នុងប្រជុំជននោះ ដល់ភិក្ខុដែលគេនិមន្ត ហើយពោលថា អាត្មានឹងទទួលតែចង្ហាន់ ( ដែលបានមកដោយត្រាច់បិណ្ឌបាត ) ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា

## ភោជនវគ្គទី ៣

## បរម្បរភោជនសិក្ខាបទ

[ ១០៤ ] ក្នុងសិក្ខាបទទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ន ខោ ឥទំ ឱរកំ ភវិស្សតិ យថយិមេ មនុស្សា សក្កច្ចំ ភត្តំ ករោន្តិ** សេចក្តីថា មនុស្សពួកនេះ ធ្វើភត្តាហារដោយគោរព ដោយទំនងដែលជាហេតុក្នុងព្រះសាសនានេះ ឬទានក្នុងព្រះសង្ឃ មានព្រះពុទ្ធជាប្រធាននេះ ប្រាកដច្បាស់ មិនមែនជាទានថោកថយឡើយ គឺមិនរាប់ជាកុសលតិចតួចថោកទាបឡើយ ។

បទថា **កិរ** ក្នុងបទថា **កិរបតិកោ** នេះ ជាឈ្មោះរបស់កុលបុត្រនោះ ។ ឯកុលបុត្រនោះ គេហៅថា **កិរបតិក** ព្រោះអត្ថថា ជាអធិបតី ( ជាធំ ) ។ បានឮថា បុរសនោះជាធំ ជាអធិបតីឲ្យថ្លៃឈ្នួល ប្រើកម្មករធ្វើការងារដោយកំណត់ជាខែ រដូវ និងឆ្នាំ ។ កម្មករទុគ៌តនោះពោលពាក្យថា **ពទរា បដិយត្តា** នេះ ដោយអំណាចវោហាររបស់សត្វលោក ។

បទថា **ពទរមិស្សកេន** គឺផ្សំដោយផ្លែពុទ្រា ។

[ ១០៥ ] ពីរបទថា **ឧស្សូរេ អាហរិយិត្ថ** គឺទាយកនាំបិណ្ឌបាតមកប្រគេនយូរពេក ។ ការវិកប្បនេះថា ខ្ញុំឲ្យភត្តាហារដែលសង្ឃឹមនឹងបានរបស់ខ្ញុំដល់លោកមានឈ្មោះនេះ ឈ្មោះថា ការវិកប្បភត្តាហារ ។ ការវិកប្បភត្តាហារ គួរទាំងចំពោះមុខ និងកំបាំងមុខ ។ ឃើញ ( ភិក្ខុ ) ចំពោះមុខគប្បីពោលថា ខ្ញុំវិកប្បដល់លោកម្ចាស់ ហើយឆាន់ចុះ ។ បើមិនឃើញគប្បី

ពោលថា ខ្ញុំវិកប្បដល់សហធម្មិក ៥ ដែលមានឈ្មោះនេះ ហើយឆាន់ចុះ ។ តែក្នុងអដ្ឋកថាទាំងឡាយ មានមហាបច្ចរីជាដើមពោលទុក តែវិកប្បកំបាំងមុខប៉ុណ្ណោះ ។ ព្រោះការវិកប្បភត្តាហារនេះ ទ្រង់សង្គ្រោះដោយវិនយកម្ម ដូច្នោះទើបមិនគួរវិកប្បដល់ព្រះមានព្រះភាគ ។ ពិតហើយ កាលព្រះមានព្រះភាគប្រថាប់គង់ក្នុងព្រះគន្ធកុដិក្តី ប្រថាប់គង់ក្នុងជំនុំសង្ឃក្តី កម្មនោះៗ ដែលសង្ឃរួមនឹងភិក្ខុគ្រប់គណៈធ្វើហើយ ឈ្មោះថា ធ្វើល្អហើយនោះឯង ។ ព្រះមានព្រះភាគទ្រង់មិនធ្វើឲ្យខូចកម្ម ទ្រង់មិនធ្វើឲ្យកម្មសម្បូរ ទ្រង់មិនធ្វើឲ្យខូចកម្ម ព្រោះព្រះអង្គជាធម្មិស្សរៈ ទ្រង់មិនធ្វើឲ្យកម្មសម្បូរ ព្រោះព្រះអង្គមិនបានជាគណៈបូរកៈ ( អ្នកធ្វើគណៈឲ្យគ្រប់ចំនួន ) ។

## អនាបត្តិនៃបរម្បរសិក្ខាបទ

[១១១] បទថា **ទ្វេ តយោ និមន្តេន ឯកតោ ភុញ្ជតិ** សេចក្តីថា ដាក់ចុះ គឺសរុបនិមន្តកភត្ត ២-៣ ក្នុងបាត្រតែមួយ គឺធ្វើឲ្យរួមគ្នាតែមួយ ហើយឆាន់ ។ លោកពោលទុកក្នុងមហាបច្ចរីថា ត្រកូល ២-៣ និមន្តភិក្ខុឲ្យអង្គុយក្នុងទីកន្លែងមួយ ហើយនាំ ( ភត្តាហារ ) មកពីទីនេះ និងទីនោះ ហើយផ្ទេរបាយសម្ល និងម្ហូបចុះទៅ ភត្តជារបស់សម្រួមជាមួយគ្នា មិនជាអាបត្តិក្នុងភត្តសម្រួមនេះ ។

បើនិមន្តកភត្តដំបូងនៅខាងក្រោម និមន្តកភត្តក្រោយនៅខាងលើ ជាអនាបត្តិដល់ភិក្ខុដែលឆាន់និមន្តកភត្តក្រោយនោះ តាំងអំពីខាងលើចុះទៅ ។ តែជាអនាបត្តិដល់ភិក្ខុដែលឆាន់ដោយអាការឯណានីមួយ ចាប់តាំងអំពីពេលដែល

លោកយកដៃលូកចូលទៅខាងក្នុង ហើយចាប់ពំនូតបាយមួយដុំ អំពីនិមន្តនកត្ត ដំបូងឡើងមកឆាន់ ហើយលោកពោលទុកក្នុងមហាបច្ចរីថា បើត្រកូលទាំងឡាយចាក់ទឹកដោះក្តី ទឹកទន្លេក្តី ចូលទៅក្នុងភត្តនោះ ភត្តដែលត្រូវទឹកដោះ និងរសណាស្រោចលិចទៅ មានរសតែមួយដូចគ្នានឹងទឹកដោះ និងរសនោះជាអនាបត្តិដល់ភិក្ខុដែលឆាន់តាំងពីកំពូលចុះទៅ ។

តែក្នុងមហាអដ្ឋកថាពោលថា ភិក្ខុបានទឹរកត្ត ( ភត្តលាយទឹកដោះស្រស់ ) ក្តី រសភត្ត ( ភត្តមានរសសម្ល ) ក្តី អង្គុយហើយ សូម្បីពួកអ្នកស្រុកដទៃចាក់ទឹរកត្ត ឬរសភត្តចុះទៅលើទឹរកត្ត និងរសភត្តនោះថែមទៀត ជាអនាបត្តិដល់ភិក្ខុដែលហុតទឹកដោះ ឬរសនោះ តែភិក្ខុកំពុងឆាន់ និងចុកដុំសាច់ ឬដុំបាយ ដែលបានមុនចូលមាត់ ហើយឆាន់តាំងពីកំពូលចុះទៅ គួរ សូម្បីក្នុងបាយាសលាយសប្បិ ក៏មានន័យដូចគ្នា ។

លោកពោលទុកក្នុងមហាអដ្ឋកថាថា ឧបាសកដែលជាជំនិមន្តភិក្ខុទុកកាលភិក្ខុទៅកាន់ត្រកូល ហើយឧបាសកក្តី អន្តោជន មានកូនប្រពន្ធ និងបងប្អូនប្រុស បងប្អូនស្រីរបស់ឧបាសកនោះក្តី នាំយកភត្តចំណែករៀងៗ ខ្លួនមកដាក់ក្នុងបាត្រ ជាអាបត្តិ[១] ដល់ភិក្ខុដែលមិនឆាន់ភត្តចំណែកឧបាសកប្រគេនមុន ឆាន់ចំណែកដែលបានឯក្រោយ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា គួរ ។ ក្នុងមហាបច្ចរីពោលថា បើពួកអ្នកទាំងនោះចែកគ្នាចម្អិន នាំមកប្រគេនអំពីភត្តដែលចម្អិនដើម្បីខ្លួន រៀងៗ ខ្លួន បណ្តាភត្តទាំងនោះ ជាបាចិត្តិយដល់ភិក្ខុ

---

១- បាលីក្នុងអដ្ឋកថាជាអនាបត្តិ ។

ដែលឆាន់កត្ត ដែលគេនាំមកតាមក្រោយ តែបើពួកបុគ្គលទាំងអស់នោះ ចម្អិនរួមគ្នា មិនជាបរម្បរភោជនឡើយ ។

មហាឧបាសក និមន្តភិក្ខុឲ្យអង្គុយចាំ អ្នកស្រុកដទៃទទួលយកបាត្រ ភិក្ខុកុំគប្បីឲ្យ ។ អ្នកស្រុកនោះសួរថា ហេតុអ្វីលោកម្ចាស់ ទើបមិនឲ្យ ខ្ញុំ គប្បីពោលថា ឧបាសក អ្នកនិមន្តពួកអាត្មាទុកមិនមែនឬ អ្នកស្រុកនោះ ពោលថា ណ្ហើយចុះ លោកម្ចាស់ សូមលោកម្ចាស់ឆាន់របស់ដែលលោក ម្ចាស់បានហើយនោះចុះ ។ ទោះឆាន់ក៏គួរ ។ ក្នុងកុរុន្ទីពោលថា កាលអ្នក ដទៃនាំកត្តមកប្រគេន ភិក្ខុសូម្បីប្រាប់ ហើយឆាន់ក៏គួរ ។ ពួកអ្នកស្រុកទាំង ឡាយចង់ស្តាប់ធម៌ ទើបនិមន្តភិក្ខុដែលធ្វើអនុមោទនា ហើយនឹងទៅថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់និមន្តមកទៀត ។ ក្នុងថ្ងៃស្អែក ឡើង ភិក្ខុទោះមកឆាន់កត្តដែលបានហើយទៀត គួរ ។ ព្រោះហេតុអ្វី ព្រោះ អ្នកស្រុកទាំងអស់និមន្តទុក ។

ភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាត បានកត្តាហារមក ។ ឧបាសកដទៃនិមន្ត ភិក្ខុរូបនោះឲ្យអង្គុយចាំនៅក្នុងផ្ទះ ហើយកត្តមិនទាន់សម្រេច ។ បើភិក្ខុនោះ ឆាន់កត្តដែលខ្លួនត្រាច់បិណ្ឌបាតបានមក ជាអាបត្តិពិត ។ បើលោកមិនឆាន់ អង្គុយចាំ ឧបាសកសួរថា ហេតុអ្វី ទើបលោកម្ចាស់មិនឆាន់ លោកពោលថា ព្រោះអ្នកនិមន្តអាត្មាទុក ហើយឧបាសកប្រាប់ថា សូមលោកម្ចាស់ឆាន់កត្ត ដែលលោកម្ចាស់បានហើយចុះ ដូច្នេះ ឆាន់ក៏បាន ។

ពីរបទថា **សកាលេន គាមេន** សេចក្តីថា ជាអនាបត្តិដល់ភិក្ខុដែលអ្នក

ស្រុកទាំងមូលរួមគ្នានិមន្តទុកប៉ុណ្ណោះ ដែលឆាន់នៅក្នុងទីណាមួយ សូម្បីក្នុងពួកគណៈក៏មានន័យដូច្នេះដែរ ។

បទថា **និមន្តិយមានោ ភិក្ខុំ គហេស្សាមីតិ ភណតិ** សេចក្តីថា ភិក្ខុដែលត្រូវគេនិមន្តថា និមន្តលោកម្ចាស់ទទួលភត្ត ពោលថា អាត្មា មិនត្រូវការភត្តរបស់អ្នក អាត្មាទទួលតែភិក្ខា ។ ក្នុងបទថា **ភត្តំ ។បេ។ វទតិ** នេះ ព្រះមហាបទុមត្ថេរពោលថា ភិក្ខុដែលពោលយ៉ាងនេះ អាចដើម្បីធ្វើមិនឲ្យជានិមន្តនភត្តក្នុងសិក្ខាបទនេះបាន តែបានធ្វើឱកាស ដើម្បីប្រយោជន៍ដល់ការឆាន់ ព្រោះដូច្នោះ ទើបភិក្ខុនោះ មិនផុតអំពីគណៈភោជន និងមិនផុតអំពីចារិត្តសិក្ខាបទ ។ ព្រះមហាសុមត្ថេរពោលថា ភិក្ខុអាចនឹងធ្វើឲ្យមិនជានិមន្តនភត្ត ដោយចំណែកណា មិនជាគណៈភោជន មិនជាចារិត្ត ដោយចំណែកនោះ ។ ពាក្យដ៏សេស ដូចដែលពោលហើយនោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមកាយ និងវាចា ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយាផង អកិរិយាផង ពិតហើយ ក្នុងកិរិយា និងអកិរិយានេះ ការឆាន់ជាកិរិយា ការមិនវិកប្បជាអកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បរម្បរភោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[ ១១២ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានេះឯង ឧបាសិកាជាមាតា របស់នាងកាណា ជាស្រីមានសទ្ធាជ្រះថ្លា ។ ( ឧបាសិកានោះ ) បានឲ្យនាង កាណាជាកូនទៅឲ្យបុរសម្នាក់ នៅក្នុងស្រុកតូចមួយ ។ គ្រានោះ នាងកាណា បានទៅផ្ទះមាតាដោយកិច្ចអ្វីនីមួយ ដែលខ្លួនត្រូវធ្វើ ។ ទើបប្តីនាងកាណាប្រើ បម្រើទៅក្នុងសម្នាក់នាងកាណាថា នាងកាណាចូរមក អញនឹងឲ្យនាងកាណា ត្រឡប់មកវិញ ។ កាលនោះឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅ ដោយដៃទទេ ដូចម្តេចនឹងកើត ( គិតដូច្នោះហើយ ) នាងក៏ចម្អិននំ ។ ដល់ នំឆ្អិន មានភិក្ខុអ្នកត្រាច់បិណ្ឌបាតមួយអង្គ ចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតានាងកាណា ។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេន នំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត ។ ( មាតារបស់ នាងកាណា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ ភិក្ខុដទៃ ។ ( មាតារបស់នាងកាណា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយយ៉ាងណា ក៏អស់គ្មានសល់ ។ ស្វាមីរបស់នាងកាណា ប្រើបម្រើទៅក្នុងសម្នាក់នាងកាណាជាគម្រប់ពីរដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ។ ឧបាសិកាជា មាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេ ដូចម្តេចនឹងកើត ( គិត

ដូច្នោះហើយ ) ក៏ចម្អិននំអស់រារៈជាគម្រប់ពីរដង ។ កាលទំផ្អិន មានភិក្ខុមួយអង្គអ្នកត្រាច់ទៅដើម្បីបិណ្ឌបាត ចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា ។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ( ឧបាសិកា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត ។ ( ឧបាសិកា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ នំដែលឧបាសិកាបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់ ។ ស្វាមីរបស់នាងកាណា ក៏ប្រើបម្រើទៅក្នុងសម្នាក់នាងកាណាជាគម្រប់បីដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ថាបើនាងកាណាមិនត្រឡប់មកវិញទេ អញនឹងយកប្រពន្ធឯទៀតហើយ ។ ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេ ដូចម្តេចនឹងកើត ( គិតដូច្នោះហើយ ) ក៏ចម្អិននំអស់រារៈជាគម្រប់បីដង ។ កាលទំផ្អិន មានភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាតមួយអង្គចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតារបស់នាងកាណា ។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ( មាតារបស់នាងកាណា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត ។ ( មាតារបស់នាងកាណា ) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់ ។ កាលនោះស្វាមីរបស់នាងកាណា ក៏យកប្រពន្ធមួយទៀត ។ នាងកាណាបានដឹងច្បាស់ថា ឮថា បុរស

នោះយកប្រពន្ធទៀតហើយ ។ នាងកាណានោះក៏ឈរយំ ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក យាងទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា លុះយាងទៅដល់ហើយក៏គង់លើអាសនៈដែលគេបានចាត់ចែងថ្វាយ ។ ទើបឧបាសិកាជាមាតា របស់នាងកាណាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះនឹងឧបាសិកាជាមាតារបស់នាងកាណា ដែលបានអង្គុយនៅក្នុងទីដ៏សមគួរថា នាងកាណានេះ ហេតុអ្វីបានជាយំ ។ ឧបាសិកាជាមាតារបស់នាងកាណា ក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគក្នុងពេលនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសិកាជាមាតារបស់នាងកាណាឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យឧស្សាហ៍ ឲ្យរីករាយដោយពុទ្ធដីកាដ៏ប្រកបដោយធម៌ ហើយក្រោកចាកអាសនៈយាងទៅវិញ ។

[ ១១៣ ] សម័យនោះឯង មានពួករទេះមួយពួក មានសេចក្តីប្រាថ្នាដើម្បីចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ប្រទេសឈ្មោះបដិយាលោក[១] ។ មានភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាតមួយអង្គ ចូលទៅរកពួករទេះនោះ ដើម្បីបិណ្ឌបាត ។ មានឧបាសកម្នាក់ បានឲ្យគេប្រគេនសដូវដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត ។ ឧបាសកនោះឲ្យគេប្រគេនសដូវដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត ឧបាសកនោះ ។

---

១- គឺប្រទេសនៅទិសខាងលិចចំព្រះអាទិត្យអស្តង្គត ។

ឲ្យគេប្រគេនសជូវដល់ភិក្ខុនោះទៀត ។ ស្បៀងដែលឧបាសកនោះ បានចាត់ចែងហើយទាំងប៉ុន្មានក៏អស់គ្មានសល់ ។ ទើបឧបាសកនោះបាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ សូមអ្នកម្ចាស់រង់ចាំក្នុងថ្ងៃនេះមួយថ្ងៃសិន (ព្រោះ) ស្បៀងដែលខ្ញុំបានចាត់ចែងហើយទាំងប៉ុន្មានខ្ញុំប្រគេនដល់លោកម្ចាស់ទាំងឡាយអស់ទៅហើយ ខ្ញុំនឹងចាត់ចែងស្បៀង ( ថ្មីទៀត ) ។ មនុស្សទាំងនោះឆ្លើយថា បពិត្រអ្នកម្ចាស់ យើងមិនអាចនឹងរង់ចាំបានទេ ( ព្រោះ ) ពួករទេះចេញទៅហើយ ( ថាដូច្នោះហើយ ) ក៏នាំគ្នាទៅ ។ កាលឧបាសក នោះចាត់ចែងស្បៀងហើយ ក៏ទៅក្រោយគេ ចោរទាំងឡាយក៏ដណ្តើមយករបស់ទ្រព្យក្នុងពេលនោះ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាសក្យបុត្រ មិនសមបើនឹងមិនដឹងនូវប្រមាណ ហើយទទួលសោះ ឧបាសកនេះប្រគេនសជូវដល់សមណៈទាំងនេះហើយ ទៅកាលជាខាងក្រោយ ចោរទាំងឡាយក៏ដណ្តើមយក ( របស់ទ្រព្យ ) ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ហើយ ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីការប្រពៃដល់សង្ឃ ដើម្បីនៅសប្បាយដល់សង្ឃ ។បេ។ ដើម្បីសេចក្តី

អនុគ្រោះដល់ព្រះវិន័យ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខានេះយ៉ាងនេះថា ជនបវារណា នូវភិក្ខុដែលចូលទៅកាន់ត្រកូលដោយនំទាំងឡាយក្ដី ដោយសដូវទាំងឡាយក្ដី ដើម្បីនាំទៅបានតាមប្រាថ្នា ។ ភិក្ខុមានសេចក្ដីប្រាថ្នាត្រូវទទួលបានត្រឹមពេញពីរបីបាត្រ ។ បើទទួលឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលបានទទួលនំ ឬសដូវកំណត់ពេញត្រឹមពីរបីបាត្រហើយ ត្រូវនាំចេញអំពីទីនោះ មកចែក មួយអន្លើដោយភិក្ខុទាំងឡាយ ការចែកនំ ឬសដូវនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ ។

[១១៤] ត្រង់ពាក្យថា ភិក្ខុដែលចូលទៅកាន់ត្រកូល សេចក្ដីថា ដែលហៅថាត្រកូល បានដល់ ត្រកូលមាន ៤ យ៉ាង គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលអ្នកជំនួញ ១ ត្រកូលអ្នកគ្រួ ១ ។ ពាក្យថា ចូលទៅ គឺចូលទៅក្នុងត្រកូលទាំងនោះ ។ ដែលហៅថា នំ បានដល់ វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីបញ្ជូនទៅ ។ ដែលហៅថា សដូវ បានដល់ វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីជាស្បៀង ។ ពាក្យថា បវារណាដើម្បីនាំទៅតាមប្រាថ្នា សេចក្ដីថា ( ទាយកនាំមកបវារណា ដោយពាក្យថា ) លោកប្រាថ្នានូវវត្ថុប៉ុន្មាន លោកយកវត្ថុប៉ុណ្ណោះចុះ ។ ពាក្យថា មានសេចក្ដីប្រាថ្នា គឺ មានបំណង ។ ពាក្យថា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ សេចក្ដីថា គប្បីទទួលយកបាន ត្រឹមពេញពីរបីបាត្រ ។ ពាក្យថា បើទទួលឲ្យហួសពីកំណត់នោះ សេចក្ដីថា ភិក្ខុទទួលឲ្យលើសលប់ពីកំណត់នោះទៅ ត្រូវអាបត្តិ

បាចិត្តិយ ។ ( បើ ) ភិក្ខុទទួល ( នំ ឬសដូវ ) កំណត់ពេញពីរបីបាត្រ ហើយចេញពីទីនោះ មកឃើញភិក្ខុ ( ឯទៀត ) ត្រូវប្រាប់ថា ក្នុងទីឯណោះ ខ្ញុំទទួល ( នំ ឬសដូវ ) ពេញពីរបីបាត្រមកហើយ លោកកុំទៅទទួលក្នុងទីនោះឡើយ ។ បើភិក្ខុឃើញហើយមិនប្រាប់ ត្រូវអាបត្តិទុក្កដ ។ បើប្រាប់ហើយ ភិក្ខុនៅតែទៅទទួល ត្រូវអាបត្តិទុក្កដ ។

[ ១១៥ ] ត្រង់ពាក្យថា ត្រូវនាំចេញអំពីទីនោះហើយ ចែកមួយអន្លើដោយភិក្ខុទាំងឡាយ សេចក្តីថា ក្នុងពេលដែលត្រឡប់មក ត្រូវនាំយក ( នំ ឬសដូវ ) នោះមកចែកគ្នា ។ ពាក្យថា ការចែកនំ ឬសដូវនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ សេចក្តីថា ការចែកនំ ឬសដូវនេះ ជាទំនៀមដ៏សមគួរក្នុងសិក្ខាបទនោះ ។ ភិក្ខុសម្គាល់ក្នុងនំ ឬសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រថាច្រើនជាងមែន ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងនំ ឬសដូវ ដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្គាល់ក្នុងនំ ឬសដូវដ៏ច្រើនជាងកំណត់ពេញ ពីរបីបាត្រថាខ្វះទៅវិញ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្គាល់ក្នុងនំ ឬសដូវ ដែលមិនពេញកំណត់ពីរបីបាត្រ ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងនំ ឬសដូវ ដែលមិនពេញពីរបីបាត្រ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងនំ ឬសដូវ ដែលមិនពេញពីរបីបាត្រ ថាមិនពេញមែន មិនត្រូវអាបត្តិ ។

[១១៦] អាបត្តិមិនមានដល់ភិក្ខុដែលទទួលនំ ឬសដូវកំណត់ពេញត្រឹម

តែពីរបីបាត្រ ដល់ភិក្ខុដែលទទួលនំ ឬសដូវមិនពេញពីរបីបាត្រ ដល់ភិក្ខុដែលទទួលវត្ថុ ( ឯណានីមួយ ) ដែលជនមិនតាក់តែងដើម្បីបញ្ជូនទៅ ( ញាតិ ) មិនតាក់តែងដើម្បីជាស្បៀង ដល់ភិក្ខុដែលទទួលវត្ថុដ៏សេសសល់អំពីនំ ឬសដូវ ដែលគេចាត់ចែងដើម្បីបញ្ជូនទៅ ( ញាតិ ) ក្តី ដើម្បីជាស្បៀងក្តី ដល់ភិក្ខុដែលទទួលនំ ឬសដូវអំពីជនដែលគេមានដំណើរប្រុងនឹងទៅហើយខានវិញ ដល់ភិក្ខុដែលទទួលនំ ឬសដូវរបស់ញាតិ ដល់ភិក្ខុដែលទទួលនំ ឬសដូវរបស់ជនដែលបវារណា ដល់ភិក្ខុដែលទទួលនំ ឬសដូវដើម្បីអ្នកដទៃ ដល់ភិក្ខុដែលទទួលនំ ឬសដូវដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# កាណមាតាសិក្ខាបទ

[ ១១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទី ៤ ដូចតទៅនេះ បទថា **កាណមាតា** គឺម្តាយរបស់នាងកាណា ។ បានឮថា នាងកាណានោះ ជាធីតារូបស្អាត គួរសរសើររបស់នាងជាម្តាយនោះ ។ អធិប្បាយថា ជនពួកណាមួយឃើញនាង ជនពួកនោះៗ ក្លាយជាមនុស្សខ្វាក់ ព្រោះតម្រេក គឺជាអ្នកខ្វាក់ព្រោះរាគៈ ព្រោះហេតុនោះ ទើបនាងជាអ្នកប្រាកដ ឈ្មោះថា **កាណា** ព្រោះធ្វើជនទាំងនោះ ឲ្យជាអ្នកខ្វាក់ ។ សូម្បីម្តាយរបស់នាង ក៏អនុលោមប្រាកដឈ្មោះថា **កាណមាតា** ដោយអំណាចនៃនាងដែរ ។

បទថា **អាគតំ** គឺ **អាគមនំ** ប្រែថា ការមក ។

បទថា **កិស្មឹ វិយ** ប្រែថា មើលម្តេចនឹងកើត អធិប្បាយថា មើលទៅដូចជាគួរខ្មាសអៀន ។

ពីរបទថា **រិត្តហត្ថំ គន្តុំ** បានដល់ ក្នុងការទៅគ្រានេះ មានដៃទាំង ២ ទទេ ( ព្រោះហេតុនោះ ) ទើបការទៅលើកនេះ ឈ្មោះថា មានដៃទទេ អធិប្បាយថា ការទៅដៃទទេនោះ ជាការទៅ គួរឲ្យខ្មាសអៀន ។

ពីរបទថា **បរិក្ខយំ អគមាសិ** សេចក្តីថា ឧបាសិកាជាអរិយសាវិកា ឃើញភិក្ខុទាំងឡាយហើយ មិនអាចនឹងមិនប្រគេនរបស់ដែលមានបានទេ ព្រោះហេតុនោះ ទើបឧបាសិកា បានប្រើឲ្យប្រគេន រហូតនំទាំងអស់ ដល់នូវ

ការអស់ទៅ ។

ក្នុងបទថា **ធម្មិយា កថាយ** នេះ មានវិនិច្ឆ័យថា សូម្បីនាងកាណា ស្ដាប់ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងដើម្បីប្រយោជន៍ដល់ម្ដាយនាង ក៏បានជាសោតាបន្នក្នុងវេលាចប់ទេសនា ។

ពីរបទថា **ឧដ្ឋាយាសនា បក្កាមិ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ឧដ្ឋាការចាកសេនាសនៈ ហើយយាងទៅ ។ បុរសនោះបានឮថា ព្រះសាស្ដាទ្រង់យាងទៅផ្ទះរបស់ម្ដាយនាងកាណា ទើបនាំនាងកាណាមក តាំងទុកក្នុងតំណែងតាមប្រក្រតីដើម ។

[ ១១៣ ] តែកាលរឿងនេះកើតឡើងហើយ ព្រះមានព្រះភាគមិនទាន់បញ្ញត្តសិក្ខាបទឡើយ រឿងស្បៀងដើរផ្លូវក៏បានកើតឡើង ព្រោះហេតុនោះដើម្បីសម្ដែងរឿងនេះជាប់តគ្នាទៅ ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលពាក្យថា **តេន ខោ បន សមយេន** ជាដើម ។ ឧបាសកនោះក៏បានប្រើឲ្យប្រគេនរបស់ទាំងអស់ដូចគ្នា ព្រោះខ្លួនជាអរិយសាវក ។ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យបានពោលថា **បរិក្ខយំ អគមាសិ** ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃកាណាមាតាសិក្ខាបទ

[១១៤] ពីរបទថា **យន្តិញ្ចិ បហិណាកត្ថាយ** សេចក្ដីថា អាហារវត្ថុឯណានីមួយ មាននំស្ងោរ និងនំដាក់ស្ករអំពៅជាដើមដែលមានរសល្អក្រៃលែង

ដែលគេ ត្រៀមរៀបចំទុកដើម្បីជារបស់ជំនូន ដល់នូវការរាប់ថា នំទាំងអស់ ក្នុងសិក្ខាបទនេះ ។

ពីរបទថា **យត្ថិញ្ចិ បាថេយ្យត្ថាយ** សេចក្តីថា អាហារវត្ថុឯណានីមួយ មានសដូវជុំ សដូវផង់ ល្ង និងអង្ករទាំងអស់ជាដើម ដែលពួកមនុស្សធ្វើដំណើរត្រៀមរៀបចំទុក ដើម្បីជាស្បៀងតាមផ្លូវ ដល់នូវការរាប់ថា សដូវផង់ទាំងអស់ ក្នុងសិក្ខាបទនេះ ។

ពីរបទថា **តតោ ចេ ឧត្តរឹ** សេចក្តីថា បើភិក្ខុទទួលយកបាត្រទី ៣ ឲ្យកំពុងឡើងមក ( ឲ្យជាកំពូលផុសឡើងដូចស្តូប ) ជាបាចិត្តិយដោយការរាប់ចំនួននំ ។

ពីរបទថា **ទ្វិត្តិបត្តបូរា បដិគ្គហេតព្វា** បានដល់ ទទួលបាត្រពេញស្មើកណ្តាប់ខាងក្រោមនៃមាត់បាត្រ ។

ក្នុងបទថា **អមុត្រ មយា ទ្វិត្តិបត្តបូរា** នេះ មានវិនិច្ឆ័យថា បើភិក្ខុទទួលពេញ ២ បាត្រហើយ គប្បីប្រាប់ថា ក្នុងទីនោះខ្ញុំទទួលពេញ ២ បាត្រហើយ លោកគប្បីទទួលមួយបាត្រ ។ ភិក្ខុដែលមកឯក្រោយ ឃើញភិក្ខុដទៃហើយ ក៏គប្បីប្រាប់ថា ភិក្ខុដែលមកដល់មុនទទួលពេញ ២ បាត្រហើយ ខ្ញុំទទួលពេញមួយបាត្រ លោកកុំទទួលឡើយ ។ សូម្បីក្នុងការដែលភិក្ខុទទួលមុនមួយបាត្រហើយ ប្រាប់គ្នាតៗទៅ ក៏មានន័យដូច្នេះដែរ ។ ឯភិក្ខុដែលទទួលឯងគ្រប់ ៣ បាត្រហើយ ឃើញភិក្ខុដទៃ គប្បីប្រាប់ថា លោកកុំទទួលត្រង់ផ្ទះនេះឡើយ ដូច្នេះ ។

# អធិប្បាយ

## បទភាជនីយនៃកាណមាតាសិក្ខាបទ

[ ១១៥ ] ពីរបទថា **បដិក្កមនំ នីហរិត្វា** គឺនាំទៅកាន់រោងឆាន់ ភិក្ខុដែលទៅកាន់រោងឆាន់ កុំគេចទៅសាលាដែលគេបោះបង់ចោល គប្បីទៅក្នុងទីដែលមានភិក្ខុសង្ឃជាច្រើននៅអង្គុយ ។ តែក្នុងមហាបច្ចរីពោលថា រោងណាមួយនៅជិត និងទីដែលខ្លួនបានបិណ្ឌបាតមក គប្បីទៅត្រង់រោងនោះ និងទៅក្នុងរោងដទៃ ដោយប្រាថ្នាថា អញនឹងប្រគេនដល់ភិក្ខុដែលធ្លាប់ឃើញគ្នាធ្លាប់ជួបគ្នា ឬអ្នករួមនិកាយជាមួយគ្នារបស់ខ្លួន រមែងមិនបាន តែបើរោងនោះជាទីដែលលោកអង្គុយជាប្រចាំ សូម្បីឆ្ងាយក៏គួរទៅ ។

បទថា **សភិកជិតព្វំ** សេចក្តីថា បើភិក្ខុទទួលពេញបាត្រហើយ គប្បីបន្សល់ទុកដើម្បីខ្លួនឯងមួយបាត្រ ហើយប្រគេន ២ បាត្រដល់ភិក្ខុសង្ឃ ។ បើទទួល ២ បាត្រ គប្បីបន្សល់ទុកដើម្បីខ្លួនមួយបាត្រ ហើយប្រគេនមួយបាត្រដល់សង្ឃ តែរមែងមិនបានដើម្បីនឹងឲ្យតាមមិត្តសម្លាញ់ ។ ភិក្ខុដែលទទួលមួយបាត្រ បើមិនបំណាងនឹងឲ្យអ្វីមួយ ក៏មិនគប្បីឲ្យ គឺគប្បីធ្វើតាមការពេញចិត្ត ។

## អនាបត្តិនៃកាណមាតាសិក្ខាបទ

[១១៦] ពីរបទថា **គមនេ បដិប្បស្សទ្ធេ** សេចក្តីថា កាលគេរម្ងាប់ គឺកាត់ការទៅយ៉ាងនេះថា ឥឡូវនេះ អញនឹងមិនបញ្ជូនទៅក្តី អញនឹងមិនទៅក្តី ដូច្នេះ ព្រោះឃើញអន្តរាយក្នុងចន្លោះផ្លូវ ឬព្រោះមិនមានសេចក្តីត្រូវការ ។

ពីរបទថា **ញាតកានំ បវារិតានំ** បានដល់ ជាអនាបត្តិដល់ភិក្ខុដែលទទួលរបស់ពួកញាតិ និងជនបវារណាទាំងនោះ ដែលប្រគេនសូម្បីច្រើន ។ តែក្នុងអដ្ឋកថាទាំងឡាយពោលថា គួរទទួលតែល្មមប្រមាណអំពីរបស់ដែលពួកញាតិ និងជនបវារណាទាំងនោះត្រៀមរៀបចំទុក ដើម្បីជាស្បៀងដើរផ្លូវ និងជារបស់ជំនូន ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កាណមាតាសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទី ៩

[ ១១៧ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ និមន្តភិក្ខុទាំងឡាយឲ្យឆាន់ ។ ពួកភិក្ខុឆាន់ហើយ បានហាមភត្តហើយ ក៏ទៅកាន់ត្រកូលញាតិទាំងឡាយ ភិក្ខុពួកខ្លះក៏ឆាន់ ភិក្ខុពួកខ្លះកាន់យកបិណ្ឌ-បាតទៅ ។ គ្រានោះ ព្រាហ្មណ៍នោះបានពោលពាក្យនេះ នឹងពួកជនជាអ្នកស្និទ្ធស្នាលថា បពិត្រអ្នកម្ចាស់ទាំងឡាយ ភិក្ខុទាំងឡាយ ខ្ញុំបានប្រគេនចង្ហាន់ឆាន់បរិបូណ៌ហើយ សូមអ្នកទាំងឡាយអញ្ជើញមក ខ្ញុំនឹងអង្គាសអ្នករាល់គ្នាទៀត ។ អ្នកស្និទ្ធស្នាលទាំងនោះពោលយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកនឹងអង្គាសយើងទាំងឡាយឲ្យឆ្អែតដូចម្តេចបាន អម្បាលភិក្ខុទាំងឡាយណាដែលអ្នកនិមន្តមកហើយ ភិក្ខុទាំងនោះ មកកាន់ផ្ទះពួកយើង ខ្លះឆាន់ ខ្លះកាន់យកបិណ្ឌបាត ហើយទៅ ។ ទើបព្រាហ្មណ៍នោះ ពោលទោសតិះដៀលបន្តុះបង្អាប់ថា លោកដ៏ចម្រើនទាំងឡាយ មិនសមនឹងឆាន់ក្នុងផ្ទះយើងទាំងឡាយ ហើយទៅឆាន់ក្នុងទីដទៃទៀតសោះ ហាក់ដូចជាខ្ញុំមិនអាចដើម្បីប្រគេនលោក ឆាន់ឲ្យឆ្អែតបាន ។ ពួកភិក្ខុឮព្រាហ្មណ៍នោះពោលទោសតិះដៀលបន្តុះបង្អាប់ ( ដូច្នោះ ) ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយឆាន់ហើយ ហាមភត្តរួចហើយ មិនគួរនឹងទៅឆាន់ក្នុងទីដទៃទៀតសោះ

។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុទាំងឡាយឆាន់ហើយ ហាមភត្តហើយ រូបទៅឆាន់ក្នុងទីដទៃទៀត ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ ឆាន់ហើយ ហាមភត្តរូបហើយ ហេតុអ្វីក៏ទៅឆាន់ក្នុងទីដទៃទៀត ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឆាន់ហើយ ហាមភត្តហើយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១១៨] សម័យនោះឯង ភិក្ខុទាំងឡាយនាំយកនូវបិណ្ឌបាតដ៏ឧត្តមទៅឲ្យពួកភិក្ខុឈឺ ។ ពួកភិក្ខុឈឺឆាន់មិនបានដោយស្រួល ។ ពួកភិក្ខុនាំគ្នាបោលបិណ្ឌបាតដ៏ឧត្តមទាំងនោះ ។ ព្រះដ៏មានព្រះភាគបានឮសំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ច្រៀវនៃក្អែក លុះឮហើយ ទ្រង់ហៅព្រះអានន្ទដ៏មានអាយុ ហើយត្រាស់សួរថា ម្នាលអានន្ទ សំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ច្រៀវ នៃក្អែក សំឡេងនោះជាសំឡេងអ្វីហ្ន៎ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ពួកភិក្ខុឆាន់ភោជនដ៏សល់អំពីភិក្ខុឈឺពិតមែនឬ ។ ព្រះអានន្ទក្រាបទូលថា

បពិត្រព្រះដ៏មានព្រះភាគ ពួកភិក្ខុមិនឆាន់ទេ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ភោជន ដ៏សល់អំពីភិក្ខុឈឺក្តី ភិក្ខុមិនឈឺក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវធ្វើភោជន ដ៏សល់ ( អំពីភិក្ខុឈឺ ) ដោយពាក្យយ៉ាងនេះថា ភោជនទាំងអស់នេះ សមគួរហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើង នូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយឆាន់ហើយ បានហាមភោជនហើយ ទំពាស៊ីក្តី ឆាន់ក្តី នូវខាទនីយាហារ ឬភោជនីយាហារ ដែលជាអនតិរិត្ត គឺ ជា វត្ថុដែលមិនបានធ្វើវិន័យកម្ម និងមិនមែនសល់អំពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយ ។

[១១៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។បេ។ ដែលហៅថា ឆាន់ហើយ គឺ ឆាន់ភោជន ៥ យ៉ាង ភោជនណាមួយ ដោយហោចទៅសូម្បីតែភោជនប្រមាណប៉ុនចុងស្បូវ ។ ដែលហៅថា ហាមភោជន ( គឺហាមប្រកបដោយអង្គ ៥ យ៉ាង ) គឺភិក្ខុ កំពុងឆាន់ ១ គេយកភោជនមកប្រគេនទៀត ១ គេនៅក្នុងហត្ថបាស ១ គេ បង្អោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ ។ ដែលហៅថា អនតិរិត្ត[១]

---

១- អដ្ឋកថា ដែលហៅថា អនតិរិត្តភោជន បានដល់ ភោជនដែលមិនគួរដល់អាការនៃវិនយកម្ម ៧ យ៉ាង និងភោជនដែលមិនមែនសល់អំពីភិក្ខុឈឺ ។ ឯអាការដែលមិនគួរដល់វិនយកម្ម ៧ យ៉ាង នោះ អធិប្បាយថា

១. វត្ថុទាំងឡាយ មានផ្លែ និងមើមជាដើម ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរដល់សមណកប្បក្តី និង

បានដល់ វត្ថុដែលមិនបានធ្វើវិន័យកម្ម ( ដោយអាការ ៧ យ៉ាង ) គឺ របស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ ១ របស់ដែលភិក្ខុមិនបានទទួល ហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើកឡើង ( ឬ ) មិនបានបង្អោនចូលទៅជិតដើម្បីឲ្យភិក្ខុធ្វើឲ្យជារបស់គួរ ១ ភិក្ខុមិនឋិតនៅ ខាងក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ ១ ភិក្ខុឆាន់ហើយ បានហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ និងវត្ថុដែលមិនមែនជារបស់សល់

---

សាច់ដែលមិនគួរក្តី ភោជនដែលមិនគួរក្តី ហៅថា អកប្បិយទាំងអស់ ភិក្ខុអ្នកធ្វើវិនយកម្ម យកអកប្បិយវត្ថុទាំងនេះមកធ្វើជាវិនយកម្មថា វត្ថុទាំងអស់នេះជារបស់គួរហើយ ។

២. វត្ថុដែលភិក្ខុអ្នកធ្វើវិនយកម្មមិនទាន់បានទទួលមកទេ ហើយធ្វើវិនយកម្មថា វត្ថុទាំងអស់នេះគួរហើយ ។

៣. វត្ថុដែលភិក្ខុកាន់មកដើម្បីឲ្យភិក្ខុអ្នកធ្វើវិនយកម្ម ធ្វើឲ្យជារបស់គួរ តែមិនបានលើកឡើង ឬមិនបានបង្អោនទៅ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះ គួរហើយ ។

៤. ភិក្ខុកាន់យកវត្ថុមកដើម្បីឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មឲ្យ តែភិក្ខុអ្នកធ្វើវិនយកម្មនោះ ឋិតនៅខាងក្រៅហត្ថបាស ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៥. ភិក្ខុណាមួយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ តែភិក្ខុអ្នកធ្វើវិនយកម្មនោះឯង មិនទាន់ឆាន់ភោជននៅឡើយ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៦. ភិក្ខុអ្នកធ្វើវិនយកម្មបានឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយ ទៅធ្វើវិនយកម្មឲ្យគេថា របស់ទាំងអស់នេះគួរហើយ ។

៧. ភិក្ខុអ្នកធ្វើវិនយកម្មមិនបានបញ្ចេញវចីភេទថា របស់ទាំងអស់នេះ គួរហើយ ។ និងភោជន ៥ យ៉ាង ភោជនណាមួយដែលមិនមែនសល់អំពីភិក្ខុឈឺ ។ វត្ថុដែលមិនគួរដល់អាការនៃ វិនយកម្មទាំង ៧ យ៉ាងនេះក្តី ភោជនដែលមិនមែនសល់អំពីភិក្ខុឈឺក្តី ទាំងពីរចំណែកនេះ ហៅថា អនតិរិត្ត-ភោជន ។

អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះ ហៅថា អនតិរិត្ត ។ ដែលហៅថា អនតិរិត្ត នោះ បានដល់ វត្ថុដែលបានធ្វើវិន័យកម្ម ( ដោយអាការ ៧ យ៉ាង ) គឺ របស់ដែលគេធ្វើឲ្យជាវត្ថុគួរ ១ របស់ដែលភិក្ខុបានទទួល ហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុលើកឡើង ( ឬ ) បានបង្អោនទៅជិតដើម្បីធ្វើឲ្យជារបស់គួរ ១ ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុបានឆាន់រួចហើយទើបធ្វើ ១ របស់ដែលភិក្ខុឆាន់ហើយ ហាមភោជនហើយ មិនទាន់ក្រោកចាកអាសនៈ ហើយធ្វើ ១ របស់ដែលភិក្ខុពោលថា របស់ទាំងអស់នេះគួរហើយ ១ និងរបស់ដែលសល់ អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះ ហៅថា អនតិរិត្ត ។ ដែលហៅថា ខាទនីយាហារនោះ បានដល់ របស់ទាំងអស់វៀរលែងតែភោជន ៥ យ៉ាង និងរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយាហារ ។ ដែលហៅថា ភោជនីយាហារនោះ បានដល់ ភោជន ៥ យ៉ាង គឺ បាយ នំស្រស់ នំក្រៀម ត្រី សាច់ ។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វារៈដែលលេបចូល ។

[ ១២០ ] ខាទនីយភោជនីយាហារជាអនតិរិត្ត ភិក្ខុសម្គាល់ថា ជាអនតិរិត្តពិតមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងខាទនីយភោជនីយាហារ ជាអនតិរិត្ត ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្គាល់ក្នុងខាទនីយភោជនីយាហារជាអនតិរិត្តថា

ជាអតិរិត្តទៅវិញ ហើយទំពាស៊ីក្តី បរិភោគក្តីនូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ៗ វារៈដែលលេបចូល ។ ភិក្ខុសម្គាល់ក្នុងខាទនីយភោជនីយាហារ ដែលជាអតិរិត្ត ថាជាអនតិរិត្តទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងខាទនីយភោជនីយាហារ ដែលជាអតិរិត្ត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងខាទនីយភោជនីយាហារ ដែលជាអតិរិត្ត ថាជាអតិរិត្តពិតមែន មិនត្រូវអាបត្តិ ។

[ ១២១ ] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យគេធ្វើវិនយកម្ម ហើយឆាន់ ដល់ភិក្ខុដែលទទួលរបស់ដោយគិតថា អញនឹងឲ្យគេធ្វើវិនយកម្ម ហើយឆាន់ ដល់ភិក្ខុដែលនាំយករបស់ទៅដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលឆាន់របស់ដ៏សេសសល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឆាន់របស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកដោយមានហេតុ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# បឋមបវារណាសិក្ខាបទ

[ ១១៧ ] ក្នុងសិក្ខាបទទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ត្រើនបទថា **ភិក្ខូ ភុត្តាវី បវារិតា** សេចក្តីថា ភិក្ខុទាំងឡាយដែលព្រាហ្មណ៍បវារណា ដោយបវារណារហូតល្មមគ្រប់គ្រាន់ដល់សេចក្តីត្រូវការ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ទទួលតាមដែលលោកម្ចាស់ប្រាថ្នាចុះ ហើយហាមដោយខ្លួនឯង ដោយការហាម គឺការបដិសេធយ៉ាងនេះថា ល្មមហើយ អាវុសោ ចូរប្រគេនតិចៗ ចុះ ។

បទថា **បដិវិស្សកេ** គឺពួកមិត្តសម្លាញ់ដែលនៅក្នុងផ្ទះជិតខាង ។

[ ១១៨ ] បទថា **កាកោរវសទ្ទំ** បានដល់ សំឡេងពួកក្អែកស្រែកកញ្ជ្រៀវ គឺសំឡេងសត្វក្អែកចោមរោមគ្នាស្រែកខ្ញៀវខ្ញារ ក្នុងបទថា **អលមេតំ សព្វន្តិ** នេះ នឹងមិនត្រាស់ **តិ** អក្ខរៈឡើយ ត្រាស់ត្រឹមតែ **អលមេតំ សព្វំ** ( ទាំងអស់ក៏គ្រប់គ្រាន់ហើយ ) ប៉ុណ្ណោះក៏សមគួរ ។

បទថា **ភុត្តាវី** ដែលឆាន់ស្រេច ព្រោះភិក្ខុណាទំពាក្តី មិនទំពាក្តីលេបគ្រាប់បាយសូម្បីមួយគ្រាប់ចូលទៅ ភិក្ខុនោះដល់នូវការរាប់ថា អ្នកឆាន់ស្រេច ក្នុងបទថា **ភុត្តាវី** នោះ ។ ព្រោះហេតុនោះ ទើបក្នុងបទភាជនៈនៃបទនោះ ត្រាស់បទថា **ភុត្តាវី នាម បញ្ចន្នំ ភោជនានំ** ដូច្នេះជាដើម ។

បទថា **បវារិតោ** គឺដែលមានការហាម ( កត្ត ) ដែលសម្រេចហើយ

គឺមានការបដិសេធដែលធ្វើហើយ ។ ព្រោះការហាមនោះ មិនមែនធ្វើសម្រេចបាន ដោយហេតុត្រឹមតែការបដិសេធ ដោយពិត រមែងសម្រេចបានដោយអំណាចអង្គ ៥ ។ ដោយហេតុនោះ ក្នុងបទភាជនៈនៃបទនោះ ព្រះមានព្រះភាគត្រាស់បទថា **បវារិតោ នាម អសនំ បញ្ញាយតិ** ជាដើម ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃបឋមប្បវារណាសិក្ខាបទ

[១១៩] ព្រោះបណ្ដាអង្គ ៥ នោះ ដោយអង្គថា **អសនំ បញ្ញាយតិ** នេះ ភិក្ខុដែលឆាន់មិនទាន់ឈប់ ទើបហៅថា អ្នកហាមភត្ត ឯភិក្ខុណាឈ្មោះថា អ្នកឆាន់មិនទាន់ឈប់ ភោជនខ្វះ ភិក្ខុនោះឆាន់ហើយ ភោជនខ្វះមិនទាន់បានឆាន់ និងព្រោះសំដៅយកភោជនដែលលោកឆាន់ហើយ ទើបដល់នូវការរាប់ថា អ្នកឆាន់រួចហើយ ព្រោះដូច្នោះ ពាក្យថា **ភុត្តាវី** ទើបយើងមិនឃើញសេចក្ដី សម្រេចប្រយោជន៍អ្វីមួយផ្សេក ។ ពាក្យថា **ភុត្តាវី** នេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដោយភាពជាបទបរិវារនៃបទថា **បវារិត** និងដោយភាពជាព្យញ្ជនៈពីរោះស្រួលមាត់ ដូចពាក្យថា ពីរយប់ជាដើម ក្នុងពាក្យថា ២-៣ យប់ ... ៥-៦ ម៉ាត់ ... ជាដើម ។

ក្នុងអង្គថា **អសនំ បញ្ញាយតិ** ជាដើម មានវិនិច្ឆ័យដូច្នេះថា ការឆាន់កំពុងប្រាកដ អធិប្បាយថា បើបុគ្គលដែលកំពុងឆាន់នេះនៅឆាន់ ។

ក្នុងអង្គថា **ភោជនំ បញ្ញាយតិ** បានដល់ ភោជនគ្រប់គ្រាន់ដល់ការ

ហាមកំពុងប្រាកដ អធិប្បាយថា ភោជន មានបាយជាដើមឯណាមួយ ដែលគប្បីហាមមាន ។

ក្នុងអង្គថា **ហត្ថបាសេ ឋិតោ** សេចក្ដីថា បើពួកទាយកកាន់យកភោជន គ្រប់គ្រាន់ដល់ការហាមក្នុងឱកាសប្រមាណ ២ ហត្ថ ១ ចំអាម ។

ក្នុងអង្គថា **អភិហរតិ** សេចក្ដីថា បើទាយកនោះបង្អោនកត្តនោះប្រគេនដល់ភិក្ខុនោះដោយកាយ ។

ក្នុងអង្គថា **បដិក្ខេបោ បញ្ញាយតិ** គឺការហាមប្រាកដ ។ អធិប្បាយថា បើភិក្ខុនោះបដិសេធភោជនដែលគេបង្អោនប្រគេននោះ ដោយកាយក្ដី ដោយវាចាក្ដី ។ ភិក្ខុរមែងជាអ្នកឈ្មោះថា ហាមកត្តហើយ ដោយអំណាចនៃអង្គ ៥ ដោយប្រការយ៉ាងនេះឯង ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាលិ ការហាមភោជនប្រាកដដោយអាការ ៥ យ៉ាង ។ អាការ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺការកំពុងឆាន់ប្រាកដ ១ ភោជនប្រាកដ ១ បុគ្គលឋិតនៅក្នុងហត្ថបាស ១ បង្អោនមកប្រគេន ១ ការហាមឃាត់ប្រាកដ ១ ។

ក្នុងបវារណាធិការនោះ មានវិនិច្ឆ័យដូចតទៅនេះថា គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អសនំ** ជាដើមថា ភិក្ខុឆាន់ភោជនណា និងហាមភោជនណា ដែលទាយកនៅក្នុងហត្ថបាសបង្អោនប្រគេន ភោជននោះ បណ្ឌិតគប្បីជ្រាបថា ភោជនទាំងនេះ គឺបាយ នំស្រស់ នំក្រៀម ត្រី សាច់ ឯណាមួយនោះឯង ។

បណ្ដាគោជន មានបាយជាដើមនោះ ដែលឈ្មោះថា បាយ បានដល់បាយដែលកើតពីធញ្ញជាតិ ៧ យ៉ាង គឺស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រងែ ថ្ពៅ ស្កួយ ស្មៅគែលលក ។

បណ្ដាធញ្ញជាតិ ៧ យ៉ាង មានស្រូវសាលីជាដើមនោះ កំណើតស្រូវសាលីគ្រប់ប្រភេទ ដោយហោចសូម្បីស្កួយ ឈ្មោះថា ស្រូវសាលី ។ កំណើតស្រូវខ្សាយទាំងអស់ ឈ្មោះថា **វីហិ** ។ ក្នុងស្រូវដំណើប និងស្រងែ មិនមានការប្លែកផ្សេងគ្នា ។ គ្រាប់ថ្ពៅ ដូចជាថ្ពៅស ថ្ពៅក្រហម ថ្ពៅខ្មៅ គ្រប់ប្រភេទ ឈ្មោះថា **កង្គុ** ។ គ្រាប់ស្កួយ មានពណ៌សគ្រប់ប្រភេទ ដោយហោច សូម្បីថ្ពៅស្រែ ឈ្មោះថា **វរកៈ** ។ ស្មៅគែលលកខ្មៅ តិណធញ្ញជាតិគ្រប់ប្រភេទ មាន **សាមាក** ជាដើម ឈ្មោះ **កុទ្រូសក** ។

អាចារ្យពួកខ្លះពោលថា ក្នុងពពួកស្រូវសាលី និងស្កួយនេះ ស្កួយ និងថ្ពៅស្រែ អនុលោមចូលជាមួយធញ្ញជាតិ ទោះជាធញ្ញជាតិក្ដី ធញ្ញជាតិ-នុលោមក្ដី ពួកអ្នកស្រុកយកអង្ករនៃធញ្ញជាតិទាំង ៧ មានធញ្ញជាតិដូចពោលហើយនេះ ចម្អិនឲ្យជាគោជនណាមួយ ពោលថា អញនឹងដាំបាយក្ដី អញនឹងបបរក្ដី អញនឹងកូរបបរក្ដី អញនឹងកូរតក្កបាយាសជាដើមក្ដី ណាមួយ ។ កាលពួកភិក្ខុឆាន់ភត្តនោះ ក្ដៅក្ដី ត្រជាក់ក្ដី ស្នាមរមែងប្រាកដក្នុងទីដួសយក ឬដួសយកក្នុងវេលាឆាន់ភត្តនោះ ដល់នូវការសង្គ្រោះជាបាយនោះឯង ញុំាងឲ្យកើតការហាម ( ភត្ត ) បើស្នាមមិនប្រាកដ ដល់នូវការសង្គ្រោះជាបបរ មិនញុំាងឲ្យកើតការហាម ( ភត្ត ) ឡើយ ។ បាយាស

ក្តី តក្កយាគូដែលផ្សំដោយស្លឹកឈើ ផ្លែឈើ និងទំពាំងណាមួយ ដាក់ចុះ អំពីជើងក្រានទៅក្តៅនៅឡើយ អាចនឹងផ្សៀងផឹកបាន សូម្បីក្នុងឱកាសដែលមានដៃជួសយក ក៏មិនបង្ហាញស្នាម ( ឲ្យប្រាកដ ) យាគូជាដើមនោះ មិនឲ្យកើតការហាម ( កត្ត ) ទេ ។ បើចំហាយក្តៅអស់ទៅ ត្រជាក់ហើយ ដល់នូវការលូកដៃចូលទៅ សម្តែងស្នាមឲ្យប្រាកដ ត្រឡប់ញុាំងឲ្យកើតការហាម ( កត្ត ) បាន ។ កាពជារបស់រាវៗ ពីមុន ការពារអាបត្តិមិនបាន ។

បើគេបន្ថែមទធិ និងតក្កៈជាដើមចូលទៅហើយ ដាក់ស្លឹកឈើ ផ្លែឈើ និងទំពាំងជាច្រើនចូលទៅ បន្ថែមអង្ករចូលទៅ សូម្បីត្រឹមមួយក្តាប់ ។ បើក្នុងវេលាឆាន់ មានស្នាមប្រាកដ ញុាំងឲ្យកើតការហាមកត្ត ។

ក្នុងនិមន្តនកត្ត មិនមានបបរ អ្នកស្រុកចាក់ទឹកបាយ និងខីរៈចូលទៅក្នុងកត្ត ដោយតាំងចិត្តថា នឹងប្រគេនយាគូ ហើយប្រគេនថា និមន្តទទួលយាគូ សូម្បីយាគូជារបស់រាវក៏ពិត តែក៏ញុាំងឲ្យកើតការហាមកត្តដូចគ្នា បើពួកគេដាក់ ( បាយ ) ចូលក្នុងទឹកដែលក្តៅជាដើម ស្ងោរប្រគេន ភោជននោះ ក៏ដល់នូវការសង្គ្រោះចូលជាបបរដូចគ្នា ។ គេដាក់ត្រី សាច់ ចូលក្នុងកត្តដែលដល់នូវការសង្គ្រោះជាបបរនោះក្តី ក្នុងបបរដទៃណាមួយក្តី បើដុំត្រី និងសាច់ ឬសរសៃប្រាកដ សូម្បីប្រមាណប៉ុនគ្រាប់ស្ពៃ បបរនោះញុាំងឲ្យកើតការហាមកត្តផងដែរ ។ អាហារមានរសសុទ្ធៗ ក្តី យាគូមានរសក្តី មិនឲ្យកើត ( ការហាមកត្តឡើយ ) ។ សូម្បីកត្តដែលជនពួកណាមួយធ្វើដោយវត្ថុ មានផ្លៃ ឬស្សីជាដើមដទៃណាមួយ វៀរលែងតែអង្ករនៃធញ្ញជាតិ ដែល

ពោលហើយចេញក្តី ដោយមើមដំឡូង និងផ្លែឈើក្តី រមែងមិនញុំាងឲ្យកើតការហាម ( កត្ត ) ទេ ។ នឹងពោលទៅថ្មីដល់បបរខាប់ ( នៃផ្លែឫស្សីជាដើម ) ។ បើគេដាក់ត្រី សាច់ ចូលក្នុងយាគូនេះ ធ្វើឲ្យកើតការហាមកត្តបាន ។

ក្នុងមហាបច្ចរីពោលថា សូម្បីកត្តដើម្បីប្រយោជន៍ដល់ខុព្ទី ក៏ធ្វើឲ្យកើតដល់ការហាម ( កត្ត ) ដែរ ។ លោកហៅអង្ករដែលដាក់ចូលក្នុងទឹកក្តៅចំហុយ ( ស្រុះ ) ឲ្យឆ្អិន ដើម្បីប្រយោជន៍ដល់អ្នកស៊ីដោយខុព្ទី ឈ្មោះថា កត្តដើម្បីប្រយោជន៍ដល់ខុព្ទី ( បាយដែលហាលឲ្យក្រៀម ) ។ បើហាលបាយទាំងនោះឲ្យស្ងួតហើយធាន់ គួរ ។ បាយទាំងនោះ មិនដល់នូវការរាប់ថា នំស្ងួត និង មិនដល់នូវការរាប់ថា កត្តឡើយ ។ តែកត្តដែលគេធ្វើដោយបាយក្រៀមទាំងនោះទៀត ហាម ( កត្ត ) នោះដដែល ។ ជនទាំងឡាយ ចាក់អង្ករទាំងនោះក្នុងសប្បិ និងប្រេងជាដើមក្តី ធ្វើជានំក្តី មិនហាម (កត្ត ) ឡើយ អំបុកក្តី នំក្រៀម និងបាយក្តី ដែលធ្វើអំពីអំបុកទាំងនោះក្តី មិនហាម ( កត្ត ) ទេ ។

នំកុម្មាសដែលគេធ្វើអំពីប្រភេទស្រូវដំណើប ឈ្មោះថា នំស្រស់ ។ នំកុម្មាសដែលគេធ្វើអំពីវត្ថុដទៃ មានសណ្តែកបាយជាដើម មិនធ្វើឲ្យកើតការហាម ( កត្ត ) ។ នំក្រៀមដែលគេធ្វើអំពីពពួកស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ឈ្មោះថា សត្តុ ។ ជនទាំងឡាយលីងគ្រាប់ថ្មៅ ស្គួយ និងស្មៅគែលលក ហើយបុកតិចៗ អុំយកសម្បកចេញ ហើយបុកជាថ្មីឲ្យល្អិត

ធ្វើឲ្យជាម្សៅ ។ បើវត្ថុនោះជាប់គ្នា ព្រោះនៅស្រស់ក៏ដល់នូវការសង្គ្រោះចូលជានំក្រៀមនោះឯង ។ គេបុកអង្ករខ្សាយ ដែលលីងឲ្យឆ្អិនស្រួយប្រគេនម្សៅនោះ ក៏ដល់នូវការសង្គ្រោះចូលជាសត្តុ ( នំក្រៀម ) ដូចគ្នា ។

ចំណែកអង្ករនៃស្រូវខ្សាយដែលគេលីងឲ្យឆ្អិនស្មើគ្នា ឬនៃបាយស្រួយ ( ដែលមិនបានលីង ) ឬអង្ករដែលលីងទៅហើយទូទៅ មិនហាម ( កត្ត ) ។ តែម្សៅអង្ករទាំងនោះ ហាមកត្តបាន ។ សូម្បីកន្ទក់ស្រូវខ្សាយដែលគេលីងឲ្យក្រៀមហើយ ក៏ហាម ( កត្ត ) បាន ។ ឯកន្ទក់នៃអង្ករដែលគេលីងឲ្យឆ្អិនស្មើគ្នា ឬឆ្អិនព្រោះកម្តៅថ្ងៃ មិនហាម ( កត្ត ) ទេ ។ លាជ ឬបាយក្រៀមនិងនំក្រៀមជាដើមដែលគេធ្វើអំពីលាជទាំងនោះ រមែងមិនហាម ( កត្ត ) ។ ម្សៅដែលលីងហើយក្តី របស់ទំពាសុទ្ធៗ ប្រភេទណាមួយក្តី មិនហាម ( កត្ត ) ។ តែរបស់ទំពាដែលដាក់ត្រី សាច់ក្តី សដូវឆៅ ឬសដូវដុំ មិនចូលភ្លើង ( ដុំនំក្រៀមមិនទាន់ចម្អិន ) ក្តី រមែងហាម ( កត្ត ) ឯត្រី សាច់ប្រាកដច្បាស់ហើយ តែមានសេចក្តីប្លែកគ្នាដូចតទៅនេះថា បើភិក្ខុកំពុងហុតបបរ គេប្រគេនសាច់ត្រី ឬដុំសាច់ មួយមុខ ២ ដុំ មានទំហំប៉ុនគ្រាប់បបរនោះឯង ក្នុងភាជនៈតែមួយ ឬភាជនៈផ្សេងគ្នា បើភិក្ខុមិនឆាន់ត្រីសាច់ទាំងនោះ ហាមភោជនឯណាមួយដទៃ ដែលគ្រប់គ្រាន់ដល់ការហាមកត្ត មិនឈ្មោះថាហាម ( កត្ត ) ។ បណ្តាដុំទាំង ២ នោះ ដុំណាមួយ លោកឆាន់ហើយមួយដុំនៅក្នុងដៃ ឬក្នុងបាត្រ បើលោកហាមសាច់ដទៃ ឈ្មោះថា ហាមកត្ត ។ ទាំង ២ យ៉ាងនោះ លោកឆាន់អស់ហើយ ក្នុងមាត់សូម្បីប៉ុនគ្រាប់ស្ពៃក៏មិន

សល់ បើលោកហាមសាច់ដទៃ មិនឈ្មោះថា ហាមកត្តទ្បើយ ។

ភិក្ខុកំពុងឆាន់កប្បិយមំសៈ ហាមកប្បិយមំសៈ ឈ្មោះថា ហាមកត្ត កំពុងឆាន់កប្បិយមំសៈ ហាមអកប្បិយមំសៈ មិនឈ្មោះថា ហាមកត្ត ។ ព្រោះហេតុអ្វី ព្រោះមិនមែនវត្ថុ ។ ពិតហើយ មំសៈដែលភិក្ខុគួរឆាន់បាន ប៉ុណ្ណោះ ទើបជាហេតុហាមកត្តដល់ភិក្ខុអ្នកហាម ។ តែបើភិក្ខុស្គាល់អកប្បិយមំសៈនេះ ទើបហាម ព្រោះជារបស់មិនគួរ សូម្បីមិនដឹង ក៏ឈ្មោះថា ហាមរបស់ដែលតាំងនៅក្នុងឋានៈដែលគួរហាមនោះឯង ព្រោះហេតុនោះ ទើបមិនឈ្មោះថា ហាមកត្ត ។

បើភិក្ខុឆាន់អកប្បិយមំសៈ ហាមកប្បិយមំសៈ ឈ្មោះថា ហាមកត្ត ព្រោះហេតុអ្វី ព្រោះជាវត្ថុ ( នៃការហាម ) ។ ពិតហើយ សាច់ដែលភិក្ខុនោះ ហាមនោះឯង ជាវត្ថុនៃការហាមកត្ត ។ ឯអកប្បិយមំសៈដែលភិក្ខុឆាន់ តាំងនៅក្នុងឋានៈដែលគួរហាម ក៏ពិត សូម្បីដូច្នោះ មំសៈដែលកំពុងឆាន់ ក៏នៅមិនទាន់លះភាវៈនៃមំសៈ ព្រោះហេតុនោះ ទើបឈ្មោះថា ហាមកត្ត ។ ភិក្ខុឆាន់អកប្បិយមំសៈ ហាមអកប្បិយមំសៈ មិនឈ្មោះថា ហាមកត្ត តាមន័យមុននោះឯង ។

ភិក្ខុឆាន់កប្បិយមំសៈក្តី អកប្បិយមំសៈក្តី ហាមភោជនទាំង ៥ យ៉ាង ណាមួយ ដែលជាកប្បិយភោជន ឈ្មោះថា ហាមកត្ត ។ ហាមអកប្បិយ-ភោជនដែលកើតអំពីមិច្ឆាជីវៈ មានកុលទូសកកម្ម វេជ្ជកម្ម ការពោលអួតឧត្តរិមនុស្សធម្ម និងការត្រេកអរក្នុងរូបិយជាដើម និងដែលកើតពីការស្វែង

វកមិនសមគួរ ដែលព្រះពុទ្ធទ្រង់វៀរស មិនឈ្មោះថា ហាមកត្តឡើយ ។

ភិក្ខុកំពុងឆាន់កប្បិយភោជនក្តី អកប្បិយភោជនក្តី ហាមកប្បិយភោជន ឈ្មោះថា ហាមកត្ត ។ ហាមអកប្បិយភោជន មិនឈ្មោះថា ហាមកត្តឡើយ បណ្ឌិតគប្បីជ្រាបហេតុក្នុងបទទាំងអស់យ៉ាងនេះ តាមន័យដូចពោលហើយនោះចុះ ។

បណ្ឌិតកាលជ្រាបភោជនដែលភិក្ខុឆាន់ ក្នុងពាក្យថា **អសនំ** ជាដើម និងភោជនដែលទាយកនៅក្នុងហត្ថបាសប្រគេន កាលភិក្ខុហាម ទើបដល់នូវការហាម តាមន័យដូចពោលមកយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីជ្រាបអាការដែលជាហេតុឲ្យដល់ ( នូវការហាមកត្ត ) គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ពាក្យថា **អសនំ ភោជនំ** នេះ ភិក្ខុណាទំពាលេបកត្តចូលទៅ សូម្បីមួយគ្រាប់ ភិក្ខុនោះ កាលបណ្តាភោជន ៥ ភោជនណាមួយ មានក្នុងបាត្រ មាត់ និងដៃណាមួយ ហាមភោជនទាំង ៥ ណាមួយដទៃ ក៏ឈ្មោះថា ហាម ។ មិនមានភោជនក្នុងទីណាមួយ មានបាត្រជាដើម ប្រាកដត្រឹមតែក្លិនអាមិស មិនឈ្មោះថា ហាមកត្តទេ ។ មិនមានភោជនក្នុងមាត់ និងក្នុងដៃ តែមានក្នុងបាត្រ ឯភិក្ខុមិនបំណងនឹងឆាន់ត្រង់អាសនៈនោះ បំណងនឹងចូលទៅកាន់វិហារ ហើយឆាន់ក្តី បំណងនឹងប្រគេនដល់ភិក្ខុដទៃក្តី បើបដិសេធភោជនណាមួយក្នុងចន្លោះនោះ មិនទាន់រាប់ថា ហាមកត្តទេ ព្រោះហេតុអ្វី ព្រោះភាពជាភោជនដែលកំពុងឆាន់ដាច់ទៅ ។

ក្នុងមហាបច្ចរីពោលទុកថា ភិក្ខុណាបំណងនឹងទៅឆាន់ក្នុងទីដទៃ លេប

កត្តនៅក្នុងមាត់ហើយ កាន់យកកត្តដែលសល់ដើរទៅ ហើយហាមភោជនដទៃ ក្នុងចន្លោះផ្លូវ ការហាមកត្តរបស់ភិក្ខុនោះ ក៏មិនមាន ។

បើភិក្ខុមិនបំណងនឹងបរិភោគភោជនដែលមាននៅក្នុងដៃ ឬក្នុងមាត់ ក៏ដូចក្នុងបាត្រ និងហាមភោជនដទៃ ក្នុងខណៈនោះ មិនឈ្មោះថា ហាមកត្តទេ ។ ពិតហើយ លក្ខណៈដែលពោលទុកហើយក្នុងបទមួយ ជាលក្ខណៈដែលបណ្ឌិតគួរជ្រាបក្នុងបទទាំងអស់ ។

ម្យ៉ាងទៀត ក្នុងកុរុន្ទីបានសម្តែងន័យនេះទុកដូចគ្នា ។ សមដូចលោកពោលទុកក្នុងកុរុន្ទីនោះថា ភិក្ខុលេបកត្តក្នុងមាត់ហើយ បំណងនឹងឲ្យកត្តក្នុងដៃដល់អ្នកស៊ីដែល បំណងនឹងឲ្យកត្តក្នុងបាត្រដល់ភិក្ខុ បើហាម ( ភោជនដទៃ ) ក្នុងខណៈនោះ មិនឈ្មោះថា ហាមកត្តទេ ។

ក្នុងពាក្យថា **ហត្ថបាសេ ឋិតោ** នេះ មានវិនិច្ឆ័យដូច្នេះថា ២ ហត្ថ ១ ចំអាម គប្បីជ្រាបថា ហត្ថបាស បើភិក្ខុអង្គុយកំណត់អំពីទីបំផុតក្រោយខ្នងទៅ បើឈរ កំណត់ពីទីបំផុតនៃកែងជើងទៅ បើដេក កំណត់ពីទីបំផុតនៃឆ្អឹងជំនីរខាងក្រៅដែលដេក មកទល់អវយវៈដែលជិតជាង វៀរដៃដែលលាចេញរបស់ទាយក ដែលអង្គុយក្តី ឈរក្តី ដេកក្តី ។ ការហាមកត្តរមែងមានដល់ភិក្ខុអ្នកហាមភោជន ដែលទាយកនៅខាងក្នុងហត្ថបាសនោះបង្អោនប្រគេនប៉ុណ្ណោះ ក្រៅអំពីនោះ មិនជាការហាមឡើយ ។

បទថា **អភិហរតិ** សេចក្តីថា ទាយកនៅខាងក្នុងហត្ថបាសបង្អោន ( ភោជន ) ចូលទៅដើម្បីទទួល ( ប្រគេន ) ។ បើភិក្ខុដែលអង្គុយបន្ទាប់ទៅ

មិននាំបាត្រដែលនៅក្នុងដៃ ឬដែលដាក់នៅលើភ្លៅ ឬជើងទម្រទៅឡើយ ពោលថា និមន្តលោកម្ចាស់ទទួលភត្តាហារ កាលភិក្ខុបដិសេធភត្តនោះ មិនជាការហាមភត្ត ។ សូម្បីក្នុងទាយកដែលនាំល្អិកត្តមកទុកលើផ្ទៃខាងមុខ ហើយពោលថា និមន្តលោកម្ចាស់ទទួលចុះ ក៏មានន័យដូចគ្នា ។

តែកាលគេចាប់លើកឡើង ឬបង្អោនចូលទៅ ពោលថា និមន្តលោកម្ចាស់ទទួលចុះ កាលភិក្ខុបដិសេធ រាប់ជាការហាមភត្ត ។ ព្រះថេរៈអង្គុយលើថេរាសនៈ បញ្ជូនបាត្រទៅឲ្យភិក្ខុកំលោះដែលអង្គុយក្នុងទីឆ្ងាយ ពោលថា លោកចូរទទួលយកបាយអំពីបាត្រនេះ ។ ឯភិក្ខុដែលទទួលបាត្រ ទៅឈរស្ងៀមព្រងើយ ភិក្ខុកំលោះហាមថា ខ្ញុំគ្រប់គ្រាន់ហើយ មិនឈ្មោះថា ហាមភត្ត ។ ព្រោះហេតុអ្វី ព្រោះព្រះថេរៈនៅឆ្ងាយ និងព្រោះទូតមិននាំទៅឲ្យ ។ បើភិក្ខុអ្នកទទួលបាត្រមកពោលថា លោកម្ចាស់ សូមទទួលភត្តនេះ កាលភិក្ខុកំលោះបដិសេធភត្តនោះ រាប់ថា ជាការហាមភត្ត ។

ក្នុងទីអង្គាស ទាយកម្នាក់អង្គាសភិក្ខុច្រើនរូប ដៃម្ខាងកាន់ស្នូកបាយ ដៃម្ខាងកាន់វែក ។ បើក្នុងទីអង្គាសនោះ មានអ្នកដទៃមកពោលថា ខ្ញុំនឹងជួយកាន់ស្នូក អ្នកចូរប្រគេនបាយ ហើយធ្វើកិច្ចត្រឹមតែចាប់ប៉ុណ្ណោះ ឯទាយកដែលអង្គាសឯង លើកស្នូកបាយនោះ ព្រោះដូច្នោះ ស្នូកនោះ រាប់ថាគេនាំមកចំពោះពិត រាប់ជាការហាមភត្តដល់ភិក្ខុដែលហាមអ្នកអង្គាស ដែលកាន់ភត្តអំពីស្នូកនោះ ដោយជាអ្នកមានសេចក្តីត្រូវការនឹងប្រគេន ។ តែបើអ្នកអង្គាសត្រឹមតែចាប់ពាល់ស្នូកប៉ុណ្ណោះ មនុស្សក្រៅពីនេះឯង ជួយលើក

ស្មុគនោះ មិនរាប់ជាការហាមភត្តដល់ភិក្ខុដែលហាមអ្នកអង្គាស ដែលកាន់ភត្តអំពីស្មុគនោះ ដោយជាអ្នកមានសេចក្តីត្រូវការប្រគេន តែកាលទាយកយកវែកដួសភត្ត ( ការហាមភត្ត ) រមែងមានដល់ភិក្ខុអ្នកហាម ។ ពិតហើយ ការបង្អោនចូលមកដោយត្រង់ ដោយវែកនោះឯង រាប់ជាការបង្អោនប្រគេនភត្តនោះ ។ ក្នុងមហាបច្ចរីពោលថា សូម្បីក្នុងភត្តដែលមនុស្សពីរនាក់ជួយគ្នាលើក កាលភិក្ខុបដិសេធ រមែងឈ្មោះថា ហាមភត្តដូចគ្នា ។

កាលទាយកប្រគេនភត្តដល់ភិក្ខុដែលអង្គុយបន្ទាប់ទៅ ភិក្ខុមួយអង្គទៀតយកដៃបិទបាត្រ មិនជាការហាមភត្តឡើយ ព្រោះហេតុអ្វី ព្រោះហាមភត្តដែលគេបង្អោនប្រគេនភិក្ខុអង្គដទៃ ។

ក្នុងពាក្យថា **បដិក្ខេបោ បញ្ញាយតិ** នេះ គប្បីជ្រាបវិនិច្ឆ័យថា ភិក្ខុបដិសេធភត្តដែលគេប្រាប់ ប្រគេនដោយវាចា មិនរាប់ថា ជាការហាមភត្ត តែកាលភិក្ខុបដិសេធដោយកាយ ឬដោយវាចា នូវភត្តដែលគេបង្អោនប្រគេនដោយកាយ ទើបជាការហាមភត្ត ។

ក្នុងការហាមដោយកាយ និងវាចានោះ ដែលឈ្មោះថា ការហាមដោយកាយ គឺភិក្ខុរាដៃក្តី ដែបក់ដេញរុយក្តី ដាយចីវរក្តី ធ្វើអាការដោយចិញ្ចើម ឬខឹងសម្លឹងមើល ។ ដែលឈ្មោះថា ហាមដោយវាចា គឺភិក្ខុពោលថា ល្មមហើយក្តី អាត្មាមិនទទួលទេក្តី កុំចាក់ក្តី ចូរថយទៅក្តី ។ កាលភិក្ខុហាមភត្តដោយកាយ ឬដោយវាចា ដោយអាការណាមួយយ៉ាងនេះ ឈ្មោះថា ការហាមភត្ត ។

ភិក្ខុមួយរូប កាលទាយកប្រគេនភត្ត ខ្វាចអំពីការហាមភត្ត ទាញដៃចេញ និយាយនឹងជនដែលចាក់បាយចូលក្នុងបាត្រហើយ ម្តងហើយ ម្តងទៀតថា អ្នកចូរចាក់ទៅ អ្នកចូរចាក់ទៅចុះ ចូរសង្កត់ដាក់ឲ្យពេញចុះ សួរថា ក្នុងពាក្យនេះ មានសេចក្តីដូចម្តេច ។ ព្រះមហាសុមត្ថេរពោលទុកមុនថា រាប់ថា ជាការហាមភត្ត ព្រោះភិក្ខុពោលដើម្បីមិនឲ្យចាក់ចូល តែព្រះមហា-បទុមត្ថេរពោលថា ធម្មតាភិក្ខុដែលពោលថា ចូរចាក់ ចូរដាក់ឲ្យពេញ ដូច្នេះ អន្លង់ខ្វះជាការហាមភត្ត ហើយទើបពោលថា មិនឈ្មោះថា ជាការហាមភត្ត ។ ភិក្ខុមួយរូបទៀត សង្កេតឃើញភិក្ខុកំពុងនាំភត្តទៅ ពោលថា លោកដ៏មានអាយុ លោកនឹងទទួលអ្វីមួយអំពីបាត្ររបស់ខ្ញុំនេះឬ ខ្ញុំនឹងប្រគេនអ្វីមួយដល់លោក ក្នុងពាក្យនោះ ព្រះមហាសុមត្ថេរក៏ពោលថា រាប់ជាការហាមភត្ត ព្រោះភិក្ខុនោះពោលដោយតាំងចិត្តថា ភិក្ខុនេះនឹងមិនមក ( កាន់សម្នាក់របស់អញ ) ដោយការពោលយ៉ាងនេះ ។

ឯព្រះមហាបទុមត្ថេរពោលថា ធម្មតាភិក្ខុដែលពោលថា លោកនឹងទទួលឬទេ អន្លង់ខ្វះជាការហាមភត្ត ទើបពោលថា មិនទាន់ឈ្មោះថាហាមភត្ត ។

ទាយកម្នាក់បង្អោនប្រគេនរស មានសាច់ ពោលថា និមន្តលោកម្ចាស់ទទួលរសចុះ ។ កាលភិក្ខុបានស្តាប់ពាក្យនោះ ហើយបដិសេធ មិនចាត់ជាការហាម កាលទាយកពោលថា រសត្រី រសសាច់ ជាការហាមភត្តដល់ភិក្ខុដែលបដិសេធ ។ បើទាយកពោលថា សូមនិមន្តលោកម្ចាស់ទទួលរសត្រីសាច់នេះ ក៏ជាការហាមភត្តដល់ភិក្ខុដែលបដិសេធដូចគ្នា ។ ទាយកបែងចែក

សាច់ ទុកដោយឡែក ពោលថា និមន្តលោកម្ចាស់ទទួលរសមានសាច់ បើក្នុងរស នោះមានដុំសាច់ សូម្បីប៉ុនគ្រាប់ស្ពៃ ជាការហាមកត្ត ដល់ភិក្ខុដែលបដិសេធរសនោះ ។ តែបើជារសដែលគេត្រងហើយ គួរ ដូច្នេះឯង ។

ព្រះអភយត្ថេរពោលថា ព្រះមហាថេរៈពោលថា ចូរផងចាំមួយភ្លែតជាមួយអ្នកសួរដោយអើពើ ដោយរសសាច់ ហើយពោលថា នាំថាសមកចុះអ្នក ពាក្យនេះ វិនិច្ឆ័យដូចម្ដេច ។

ព្រះមហាសុមត្ថេរពោលទុកមុនថា ការទៅរបស់អ្នកបង្អោនប្រគេន ( ភត្ត ) ដាច់ទៅហើយមុន ព្រោះដូច្នោះ ទើបឈ្មោះថា ហាមកត្ត ។ តែព្រះមហាបទុមត្ថេរពោលថា ព្រះមហាថេរៈនេះ នឹងទៅទីណា ការទៅរបស់អ្នកបង្អោនប្រគេនភត្តនោះដូចម្ដេច ការហាមកត្តរមែងមានដល់អ្នកទទួល ហើយពោលតទៅថា មិនទាន់ឈ្មោះថា ហាមកត្តទេ ។

ពួកទាយកស្ងោត្រី និងសាច់ ផ្សំដោយទំពាំង និងខ្នុរជាដើម ទាយកកាន់យកសម្លនោះមកពោលថា និមន្តលោកម្ចាស់ទទួលសម្លទំពាំង និមន្តលោកម្ចាស់ទទួលសម្លខ្នុរ សូម្បីសម្លនោះ ក៏មិនហាមកត្ត ។ ព្រោះហេតុអ្វី ព្រោះទាយកពោលដល់ឈ្មោះនៃសូបព្យញ្ជនៈ ដែលគួរដល់ការមិនហាមកត្ត តែបើពួកទាយកពោលថា សម្លត្រី សម្លសាច់ក្ដី ហើយពោលថា និមន្តលោកម្ចាស់ទទួលសម្លត្រី និងសាច់នេះក្ដី ពាក្យនោះរមែងហាមកត្ត ។ មានអាហារមួយបែបឈ្មោះថា មំសករម្ពកៈ ( ញាំសាច់ ) សូម្បីដែលបំណងនឹងប្រគេនមំសករម្ពកៈនោះ ពោលថា សូមនិមន្តលោកម្ចាស់ទទួលករម្ពកៈ សម

គួរទទួល មិនឈ្មោះថា ហាមភត្ត ។ តែកាលទាយកពោលថា ញុំាំសាច់ក្ដី ញុំាំសាច់នេះក្ដី ពាក្យនោះ រមែងហាមភត្ត ។ សូម្បីក្នុងភោជនដែលផ្សំដោយត្រី និងសាច់សព្វបែបយ៉ាង ក៏មានន័យនេះដូចគ្នា ។

ក្នុងមហាបច្ចរីពោលថា ភិក្ខុណាឆាន់ក្នុងស្ថានទីនិមន្ត យល់សាច់ដែលគេបង្អោនប្រគេនថា ជាសាច់ដែលគេឧទ្ទិសចំពោះ ទើបហាម ភិក្ខុនោះ រាប់ថា ជាការហាមភត្តដូចគ្នា ។

ចំណែកមិស្សកកថា លោកពោលទុកដោយល្អិតល្អន់ក្នុងកុរុន្ទី ។ សមដូចដែលលោកពោលទុកក្នុងកុរុន្ទីនោះ យ៉ាងនេះថា ភិក្ខុដែលសមាទាន បិណ្ឌ-បាតជាវត្ត នាំបបរលាយដោយបាយមក ហើយពោលថា និមន្តលោកម្ចាស់ទទួលបបរ មិនឈ្មោះថា ហាមភត្ត ។ បើលោកពោលថា សូមនិមន្តលោកម្ចាស់ទទួលភត្ត ទើបឈ្មោះថា ហាមភត្ត ។ ព្រោះហេតុអ្វី ព្រោះភត្តដែលភិក្ខុត្រាច់បិណ្ឌបាត សួរដោយអើពើ ( ប្រាប់ប្រគេន ) មាន ។

ក្នុងពាក្យថា សូមនិមន្តលោកម្ចាស់ទទួលភត្តនេះ មានអធិប្បាយដូចតទៅនេះថា ភិក្ខុត្រាច់បិណ្ឌបាតជាវត្តពោលថា សូមនិមន្តលោកម្ចាស់ទទួលភត្តលាយដោយបបរ ។ ក្នុងភត្តលាយដោយបបរនោះ បើបបរមានច្រើនជាងក្តី ឬស្មើគ្នាក្តី មិនឈ្មោះថា ហាមភត្តឡើយ ។ បើបបរមានតិច ភត្តមានច្រើនជាង ឈ្មោះថា ហាម ហើយពាក្យនេះ បុគ្គលណាមួយ មិនអាចជំទាស់បាន ព្រោះលោកពោលទុកគ្រប់ៗអដ្ឋកថា តែហេតុក្នុងពាក្យនេះលំបាកយល់ ។

អ្នកប្រគេនពោលថា និមន្តលោកម្ចាស់ទទួលបបរលាយដោយភត្ត ។

កត្តមានច្រើនជាងក្តី មានស្មើគ្នាក្តី មានតិចជាងក្តី រមែងឈ្មោះថា ហាមភត្ត ដូចគ្នា ។ អ្នកប្រគេនមិនប្រាវព្វដល់ភត្ត ឬយាគូ ពោលថា និមន្តលោកម្ចាស់ ទទួលភោជនលាយគ្នា ។ ក្នុងភោជនលាយគ្នានោះ បើភត្តមានច្រើនជាងក្តី មានស្មើគ្នាក្តី រាប់ថា ហាមភត្ត ។ មានតិចជាង មិនរាប់ថា ហាមភត្តទេ ។ ឯភោជនលាយគ្នានេះ មិនដូចគ្នានឹងញាំឡើយ ព្រោះថា ញាំជាសាច់ក៏មាន ញាំមិនមែនសាច់ក៏មាន ដូច្នោះ កាលទាយកពោលពាក្យថា ញាំ មិនរាប់ថា ជាការហាមភត្តឡើយ ។ តែភោជនដែលលាយគ្នានេះ ក្លាយជាបបរផ្សំភត្ត ទៅ រមែងជាការហាមភត្ត ដោយន័យដូចពោលហើយនោះឯង ក្នុងភោជន លាយគ្នានេះ ។

ទាយកពោលញែកប្រគេន ក្នុងភត្តដែលមានរសច្រើនថា និមន្តលោក ម្ចាស់ទទួលរសក្នុងភត្តដែលមានខីរៈច្រើនថា និមន្តលោកម្ចាស់ទទួលខីរៈ និង ក្នុងបាយាសដែលមានសប្បិច្រើនថា និមន្តលោកម្ចាស់ទទួលសប្បិ កាលភិក្ខុ ហាមភត្តនោះ មិនរាប់ថា ជាការហាមភត្ត ។

ឯភិក្ខុណាដើរហាមភត្ត ភិក្ខុនោះ រមែងបានដើម្បីនឹងឆាន់ទាំងដើរនោះ ឯង ។ ដើរទៅដល់ទីមានភក់ ឬទឹក ឈប់ឈរ ហើយគប្បីឲ្យធ្វើជារបស់ សល់ ។ បើទឹកស៊ឹងក្នុងចន្លោះឡើងពេញប្រាំង គប្បីដើរវិលជុំវិញគុម្ពឈើ ត្រង់ឆ្នេរប្រាំង ឆាន់ចុះ ។ បើមានទូក ឬស្ពានហើយ គប្បីដើរទៅមកឆាន់ចុះ មិនគប្បីកាត់ការដើរឲ្យដាច់រយៈ ។ ភិក្ខុអង្គុយហាមភត្ត លើយានក្តី លើខ្នង ដំរី និងខ្នងសេះក្តី លើព្រះចន្ទក្តី លើព្រះអាទិត្យក្តី គប្បីឆាន់ទាំងដែលអង្គុយ

នៅលើយានជាដើមទាំងនោះ សូម្បីកំពុងវិកិលទៅ រហូតដល់វេលាថ្ងៃត្រង់ ។

ភិក្ខុណាឈរហាមកត្ត ភិក្ខុនោះ គប្បីឆាន់ទាំងឈរដូចគ្នា ភិក្ខុណាអង្គុយហាមកត្ត ភិក្ខុនោះ គប្បីឆាន់ក្នុងឥរិយាបថអង្គុយនោះឯង ។ កាលធ្វើឥរិយាបថនោះឲ្យកម្រើក គប្បីធ្វើឲ្យជារបស់សំណល់ ។

ភិក្ខុណា អង្គុយប្រហោងហាមកត្ត ភិក្ខុនោះ គប្បីឆាន់ទាំងដែលអង្គុយប្រហោងនោះឯង តែគប្បីឲ្យជុំចំបើង ឬកំណល់អង្គុយឯណាមួយដល់ភិក្ខុដែលអង្គុយប្រហោងនោះ ភិក្ខុដែលអង្គុយលើតាំងតូចហាមកត្ត រមែងបានដើម្បីវិលទៅគ្រប់ទិសទាំង ៤ មិនធ្វើឲ្យអាសនៈឃ្លាតចាកទី ។ ភិក្ខុអង្គុយលើគ្រែហាមកត្ត រមែងមិនបានដើម្បីរំកិលទៅខាងនោះ ឬខាងនេះ តែបើជនទាំងឡាយសែងលោកឡើង មួយអន្ទើដោយគ្រែ ហាមទៅក្នុងទីដទៃ គួរ ។ ភិក្ខុដេកហាមកត្ត គប្បីឆាន់ក្នុងឥរិយាបថដែលដេកនោះឯង ។ បើប្រែខ្លួន កុំគប្បីឲ្យហួសឋានទៃខ្លួនដែលខ្លួនដេកនោះ ។

បទថា **អនតិរិត្តំ** គឺមិនជារបស់សល់ សេចក្តីថា មិនសេសសល់ ។ តែរបស់មិនជាសំណល់នោះ កើតព្រោះមិនធ្វើឲ្យជារបស់សល់ ដោយអាការនៃវិនយកម្ម ៧ យ៉ាង មានរបស់មិនបានធ្វើឲ្យជាកប្បិយជាដើម ឬមិនជារបស់សល់នៃភិក្ខុអាពាធ ព្រោះហេតុនោះ ទើបក្នុងបទភាជនៈត្រាស់ពាក្យថា **អកប្បិយកតំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អកប្បិយកតំ** សេចក្តីថា ក្នុងផ្លែឈើជាដើម ផ្លែឈើក្តី ឬមើមជំឡូងជាដើមក្តី ដែលមិនទាន់បានធ្វើឲ្យជាកប្បិយ

ដោយសមណវោហារទាំង ៥ និងអកប្បិយមំសៈក្តី អកប្បិយភោជនឯណា មួយ មានផ្លែឈើជាដើមក្តី ដែលមិនទាន់បានធ្វើកប្បិយ និងអកប្បិយមំសៈ អកប្បិយភោជននេះ ឈ្មោះថា របស់ជាអកប្បិយ របស់ជាអកប្បិយនោះ ភិក្ខុធ្វើឲ្យជារបស់សល់យ៉ាងនេះថា ទាំងអស់នោះគ្រប់គ្រាន់ហើយ គប្បីជ្រាប ថា **អកប្បិយកតំ** ( របស់ដែលមិនទាន់បានធ្វើឲ្យជាកប្បិយ ) ។

បទថា **អប្បដិគ្គហិតកតំ** បានដល់ របស់ដែលភិក្ខុមិនទាន់បានទទួល ប្រគេន ធ្វើឲ្យជារបស់សល់ ដោយន័យមុននោះឯង ។

បទថា **អនុច្ចារិតកតំ** បានដល់ របស់ដែលភិក្ខុមកដើម្បីឲ្យធ្វើកប្បិយ មិនទាន់បានចាប់លើកឲ្យក្តី បង្អោនប្រគេនសូម្បីតែបន្តិចបន្តួចក្តី ។

ពីរបទថា **អហត្ថបាសេ កតំ** បានដល់ ឈរធ្វើក្រៅហត្ថបាសរបស់ ភិក្ខុ ដែលមកដើម្បីឲ្យធ្វើកប្បិយ ។

ពីរបទថា **អភុត្តាវិនា កតំ** បានដល់ ភិក្ខុដែលធ្វើឲ្យជារបស់សំណល់ ថា ទាំងអស់នោះគ្រប់គ្រាន់ហើយ មិនទាន់បានឆាន់ភោជនដែលគ្រប់គ្រាន់ ដល់ការហាម ធ្វើហើយ ។

បទថា **ភុត្តាវិនា បវារិតេន អាសនា វុដ្ឋិតេន កតំ** នេះ រាក់ទាំង អស់ហើយ ។

បទថា **អលមេតំ សព្វន្តិ អវុត្តំ** បានដល់ មិនបន្លឺវាចាពោលយ៉ាង នោះ ( ពោលយ៉ាងនេះថា ទាំងអស់នោះគ្រប់គ្រាន់ហើយ ) ។ របស់ដែល ជាសំណល់ឯណា មិនទាន់ធ្វើឲ្យជាកប្បិយ ដោយអាការនៃវិនយកម្មទាំង ៧

យ៉ាងនេះ និងរបស់ណាមិនជាសំណល់នៃភិក្ខុអាពាធ ។ របស់ទាំង ២ យ៉ាង នោះ គប្បីជ្រាបថា របស់មិនជាសំណល់ ដោយប្រការដូច្នេះ ចំណែករបស់ សល់ ក៏គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងរបស់ដែលមិនជាសំណល់នោះឯង ។

ម្យ៉ាងទៀត នៅមានពាក្យដទៃដែលគប្បីពោលក្នុងរបស់សល់នេះ ។ បទថា **ភុត្តាវិនា កតំ ហោតិ** សេចក្តីថា ដល់ភោជនដែលភិក្ខុឆាន់បាយ សូម្បីមួយគ្រាប់ក្តី ទំពាសាច់សូម្បីមួយដុំក្តី អំពីបាត្ររបស់ភិក្ខុដែលជាសភាគ គ្នា ដែលអង្គុយបន្ទាប់ទៅ ធ្វើហើយ បណ្ឌិតក៏គប្បីជ្រាបថា គឺភិក្ខុអ្នកឆាន់ ស្រេចនោះឯងធ្វើ ។

ចំណែកក្នុងបទថា **អាសនា អវុដ្ឋិតេន** នេះ ដើម្បីយល់បានងាយ មានវិនិច្ឆ័យដូចតទៅថា ភិក្ខុ ២ រូប ឆាន់អំពីព្រលឹម ជាអ្នកហាមភត្តហើយ ភិក្ខុមួយរូបគប្បីអង្គុយក្នុងទីហាមភត្តនោះឯង ។ មួយរូបទៀត នាំនិច្ចភត្តក្តី សលាកភត្តក្តី មកហើយ ចាក់ក្នុងបាត្ររបស់ភិក្ខុនោះពាក់កណ្តាល លាងដៃ ហើយ ឲ្យភិក្ខុនោះធ្វើចំណែកដ៏សេស ឲ្យជាកប្បិយហើយ ឆាន់ចុះ ព្រោះ ហេតុអ្វី ព្រោះថា ភត្តដែលជាប់នៅក្នុងដៃរបស់ភិក្ខុដែលនាំភត្តមកនោះជា អកប្បិយ តែបើភិក្ខុដែលនៅអង្គុយពីដំបូង យកដៃទទួលយកបាត្ររបស់ភិក្ខុ ដែលនាំភត្តមកនោះ ដោយខ្លួនឯងនោះឯង មិនមានកិច្ចចាំបាច់លាងដៃ ។ តែ បើភិក្ខុធ្វើឲ្យជាកប្បិយយ៉ាងនោះ ហើយឆាន់ ពួកទាយកដាក់សម្ល ឬរបស់ ទំពាណាមួយចូលក្នុងបាត្រទៀត ភិក្ខុដែលធ្វើឲ្យជាកប្បិយគ្រាមុន រមែងមិន បានដើម្បីនឹងធ្វើទៀត ។ ភិក្ខុដែលមិនទាន់បានធ្វើ ( ឲ្យជាកប្បិយ ) គប្បី

ធ្វើ ។ ហើយគប្បីធ្វើវត្ថុដែលមិនទាន់បានធ្វើប៉ុណ្ណោះ ( ឲ្យជាកប្បិយ ) ។

ពីរបទថា **យំ ច អកតំ យេន អកតំ** សេចក្តីថា របស់ដែលមិនទាន់បានធ្វើ ( ឲ្យជាកប្បិយ ) សូម្បីភិក្ខុដែលបានធ្វើកប្បិយពីមុន ក៏គួរធ្វើ ( ឲ្យជាកប្បិយ ) ។ តែរមែងមិនបានដើម្បីនឹងធ្វើក្នុងភាជនៈដំបូង ។ អធិប្បាយថា ព្រោះថា របស់ដែលភិក្ខុកំពុងធ្វើក្នុងភាជនៈដំបូងនោះ គឺជាការធ្វើរួមគ្នាជាមួយរបស់ដែលធ្វើទុកគ្រាដំបូង ព្រោះដូច្នោះ ទើបគួរធ្វើក្នុងភាជនៈដទៃ ។ តែរបស់ដែលធ្វើហើយយ៉ាងនេះ ភិក្ខុនោះ ទោះឆាន់រួមជាមួយរបស់ធ្វើទុកពីដំបូងនោះ គួរ ។ និងកាលធ្វើកប្បិយ គប្បីធ្វើក្នុងបាត្រតែម្យ៉ាងប៉ុណ្ណោះក៏ទេ គប្បីដាក់ក្នុងថ្នាំងខ្លះ ក្នុងល្អិខ្លះ ក្នុងទីឯណាមួយ ហើយគប្បីធ្វើក្នុងភាជនៈដែលគេបង្អោនចូលមកចុះ ។ បើភិក្ខុរាប់រយរូបហាមភត្ត គ្រប់រូបនឹងឆាន់ភត្តដែលធ្វើកប្បិយហើយនោះ ក៏គួរ ។ សូម្បីពួកភិក្ខុដែលមិនហាមភត្ត ក៏គួរឆាន់ ។ តែមិនគួរដល់ភិក្ខុដែលធ្វើឲ្យជាកប្បិយ ។

បើអ្នកស្រុកឃើញភិក្ខុដែលហាមភត្តចូលទៅបិណ្ឌបាត គប្បីទទួលបាត្រហើយ ឲ្យអង្គុយក្នុងទីដែលនិមន្ត ដើម្បីមង្គលដែលត្រូវមានការឆាន់ពិតប្រាកដ គប្បីឲ្យធ្វើឲ្យជារបស់សល់ជាមុន ហើយឆាន់ចុះ ។ បើក្នុងទីដែលនិមន្តនោះ មិនមានភិក្ខុដទៃ គប្បីបញ្ជូនបាត្រទៅកាន់រោងឆាន់ ឬវិហារហើយឲ្យធ្វើ ( ឲ្យជារបស់សល់ ) ។ តែកាលធ្វើកប្បិយ មិនគួរធ្វើរបស់ដែលនៅក្នុងដៃអនុបសម្បន្ន បើក្នុងរោងឆាន់ មានភិក្ខុមិនឈ្លាស គប្បីទៅឲ្យធ្វើកប្បិយឯង ហើយនាំមកឆាន់ចុះ ។

ក្នុងបទថា **គិលានាតិរិត្តំ** នេះ ភត្តដែលភិក្ខុអាពាធ ឆាន់សល់តែម្យ៉ាង ទើបឈ្មោះថា ភត្តជាសំណល់របស់ភិក្ខុអាពាធ ក៏ទេ ដោយពិត វត្ថុឯណាមួយដែលគេនាំមកចំពោះភិក្ខុអាពាធ ដោយដាក់ចិត្តថា លោកនឹងឆាន់ក្នុងថ្ងៃនេះក្តី ក្នុងថ្ងៃស្អែកនេះក្តី ឬក្នុងវេលាដែលលោកត្រូវការ វត្ថុទាំងអស់នោះ បណ្ឌិតគប្បីជ្រាបថា សំណល់របស់ភិក្ខុអាពាធ ។

ទុក្កដដែលត្រូវគ្រប់ៗ ពំនូត ក្នុងកាលិកទាំងឡាយ មានយាមកាលិកជាដើម លោកកាត់អាបត្តិ ដោយអំណាចកាលិកមិនលាយគ្នា ។ តែបើជាកាលិកលាយគ្នានឹងអាមិស ជាបាចិត្តិយទាំងអស់ ដល់ភិក្ខុដែលទទួលប្រគេនដើម្បីប្រយោជន៍ដល់អាហារក្តី ដើម្បីប្រយោជន៍មិនមែនអាហារក្តី ហើយបរិភោគ ។

## អនាបត្តិនៃបឋមប្បវារណាសិក្ខាបទ

[ ១២១ ] បទថា **សតិ បច្ចយេ** សេចក្តីថា ភិក្ខុឆាន់យាមកាលិកដើម្បីកម្ចាត់សេចក្តីស្រេកឃ្លាន ក្នុងកាលមានសេចក្តីឃ្លាន ឆាន់សត្តាហកាលិក និងយាវជីវិក ដើម្បីរម្ងាប់អាពាធនោះ ក្នុងកាលមានអាពាធ ដែលនឹងគប្បីឲ្យរម្ងាប់បាន ដោយកាលិកនោះៗ ជាអនាបត្តិ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមកាយ និងវាចា ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយាផង ជាអកិរិយាផង ជា

នោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មាន ចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បឋមប្បវារណាសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៦

[១២២] កាលណោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុពីររូប ដើរផ្លូវឆ្ងាយ ទៅក្រុងសាវត្ថី ក្នុងកោសលជនបទ ។ ភិក្ខុមួយរូបប្រព្រឹត្ត អនាចារ ។ ភិក្ខុជាគម្រប់ពីរបាននិយាយពាក្យនេះ ( ឃាត់ ) ភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកកុំធ្វើអំពើយ៉ាងនេះ អំពើដែលលោកធ្វើនេះ មិនគួរទេ ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះ ក៏ចងពៀរនឹងភិក្ខុអ្នកឃាត់នោះ ។ គ្រានោះ ភិក្ខុទាំងនោះបានទៅកាន់ក្រុងសាវត្ថី ។ សម័យនោះឯង ក្នុងក្រុង សាវត្ថី មានប្រជុំជនមួយពួក ( ធ្វើ ) សង្ឃភត្ត ។ ភិក្ខុជាគម្រប់ពីរបានឆាន់ សង្ឃភត្តរួចហើយ ហាមភត្តហើយ ។ ភិក្ខុដែលចងពៀរ ទៅកាន់ត្រកូល ជាញាតិហើយទទួលបិណ្ឌបាត រួចហើយ ក៏ចូលទៅរកភិក្ខុដែលហាមភត្តនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះ ថា ម្នាលលោកដ៏មានអាយុ លោកចូរឆាន់ ( ចង្ហាន់នេះ ) ចុះ ។ ភិក្ខុអ្នកហាមភត្ត ក៏ប្រកែកថា កុំអាវុសោ ខ្ញុំឆាន់បរិបូណ៌ហើយ ។ ភិក្ខុដែលចងពៀរ ក៏អង្វរថា ម្នាលអាវុសោ បិណ្ឌបាត ( នេះ ) ល្អ លោកចូរឆាន់ទៅ ។ កាលបើភិក្ខុ អ្នកចងពៀរនោះជម្រុលខ្លាំងពេក ភិក្ខុអ្នកហាមភត្តនោះ ( ទ្រាំមិនបាន ) ក៏ ឆាន់បិណ្ឌបាតនោះទៅ ។ ភិក្ខុដែលចងពៀរក៏ពោលពាក្យនេះ នឹងភិក្ខុអ្នក ហាមភត្តនោះថា ម្នាលអាវុសោ លោកសម្គាល់មកខ្ញុំថាជាបុគ្គលដែលគេត្រូវ

តែស្តីថាឬអ្វី ក៏រូបលោកឆាន់រួចហើយ ហាមភត្តហើយ ម្តេចឡើយក៏នៅតែឆាន់អនតិរិត្តភោជន ។ ភិក្ខុអ្នកហាមភត្តនោះតបថា ម្នាលអាវុសោ ហេតុម្តេចលោកមិនប្រាប់ ( ខ្ញុំ ) ផង ។ ភិក្ខុអ្នកចងពៀរក៏ឆ្លើយថា ហេតុម្តេច លោកមិនសួរ ( ខ្ញុំជាមុន ) ។ ភិក្ខុអ្នកហាមភត្តនោះក៏តំណាល រឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយក្នុងខណៈនោះ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នា តិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា ភិក្ខុមិនគួរនឹងនាំភត្តទៅហើយ បវារណាបង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យឆាន់នូវអនតិរិត្តភោជន ( ដូច្នេះ ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុពួថា អ្នកឯងបាននាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់ហើយ ហាមភោជនហើយ ឲ្យឆាន់អនតិរិត្តភោជនពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងនាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់ហើយហាមភត្តហើយ ឲ្យឆាន់អនតិរិត្តភោជនទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខានេះ យ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយ រំពៃរកទោស នាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យទំពាស៊ីក្តី បរិភោគក្តី នូវអនតិរិត្តភោជនដោយពាក្យថា នែភិក្ខុ អ្នកចូរទំពាស៊ីក្តី បរិភោគក្តី ដូច្នេះ និមិត្តតែភិក្ខុនោះ

ឆាន់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[១២៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ដែលហៅថា ឆាន់ហើយ គឺភិក្ខុបានឆាន់នូវភោជនទាំង ៥ យ៉ាង ភោជនណាមួយ ដោយហោចទៅ សូម្បី តែប៉ុនចុងស្បូវភ្លាំង ។ ដែលហៅថា ហាមភត្ត ( គឺហាមប្រកប ដោយអង្គ ៥ យ៉ាង ) គឺភិក្ខុកំពុងឆាន់ ១ គេយកភោជនមកប្រគេនទៀត ១ គេឋិតនៅក្នុងហត្ថបាស ១ គេបង្អោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ ។ ដែលហៅថា អនតិរិត្ត បានដល់ វត្ថុដែលមិនបានធ្វើវិនយកម្ម ដោយ ( អាការ ៧ យ៉ាង ) គឺរបស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ ១ របស់ដែល ភិក្ខុមិនបានទទួល ហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើក ឡើង ( ឬមិនបានបង្អោនចូលទៅជិតដើម្បីធ្វើឲ្យជារបស់គួរ ) ១ ភិក្ខុមិន ឋិតនៅខាងក្នុងហត្ថបាស ហើយធ្វើ ១ ភិក្ខុមិនទាន់ឆាន់ ហើយធ្វើ ១ ភិក្ខុ ឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈ ហើយធ្វើ ១ របស់ ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ និងវត្ថុដែលមិនមែនជា របស់សល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះ ហៅថា អនតិរិត្ត ។ ដែលហៅថា ខាទនីយ ( នោះ ) បានដល់វត្ថុទាំងអស់ លើកលែងតែភោជន ៥ យ៉ាង និង វត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិកចេញ ហៅថា ខាទនីយ ។ ដែលហៅថា ភោជនីយ បានដល់ភោជន ៥ យ៉ាង គឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា នាំភត្តទៅបវារណា ( នោះ ) គឺ

ភិក្ខុនិយាយថា លោកចង់បានប៉ុន្មាន និមន្តយកប៉ុណ្ណោះចុះ ។ ដែលហៅថា ដឹង ( នោះ ) គឺភិក្ខុដឹងខ្លួនឯង ឬពួកជនដទៃប្រាប់ដល់ភិក្ខុអ្នកចោទនោះ ឬក៏ភិក្ខុអ្នកហាមភោជននោះប្រាប់ ។ ពាក្យថា រំពៃរកទោស ( នោះ ) គឺភិក្ខុនាំយក ( ខាទនីយ ឬភោជនីយ ) ទៅដោយគិតថា អញនឹងចោទ នឹងរំឭកភិក្ខុនេះ ដោយវត្ថុនេះ អញនឹងចោទចំពោះ និងរំឭកចំពោះភិក្ខុនេះ ដោយវត្ថុនេះ អញនឹងធ្វើភិក្ខុនេះឲ្យអាប់មុខដោយវត្ថុនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួលដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់តាមពាក្យរបស់លោកអ្នកចោទ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗខណៈដែលលេប ។ លុះភិក្ខុនោះឆាន់រួចស្រេចហើយ ភិក្ខុអ្នកបង្ខំ ត្រូវអាបត្តិបាចិត្តិយ ។

[១២៤] ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសម្គាល់ថា ហាមហើយ ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំ ( ភិក្ខុនោះ ) ឲ្យឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទមានសេចក្តីសង្ស័យ ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំឲ្យឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសម្គាល់ថា មិនទាន់ហាម ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំឲ្យឆាន់ មិនត្រូវអាបត្តិ ។ ភិក្ខុអ្នកចោទបង្អោនរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់ តាមពាក្យរបស់លោកអ្នកចោទនោះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុនោះត្រូវអាបត្តិទុក្កដរាល់ៗ ខណៈដែលលេប ។ ភិក្ខុមិនហាមភោជនទេ តែភិក្ខុអ្នកចោទសម្គាល់ថា ហាម ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនហាមភោជនទេ ភិក្ខុអ្នកចោទសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទាន់ហាមភោជន ភិក្ខុអ្នកចោទក៏សម្គាល់ថា មិនទាន់ហាមមែន មិនត្រូវអាបត្តិ ។

[១២៥] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មហើយឲ្យ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរឲ្យគេធ្វើឲ្យជាវិនយកម្ម ហើយនិមន្ត ឆាន់ចុះ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរនាំ ( ខាទនីយភោជនីយាហារនេះ ) ទៅដើម្បីប្រយោជន៍ដល់អ្នកដទៃចុះ ដល់ភិក្ខុដែលឲ្យរបស់ដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឲ្យរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដោយពាក្យថា កាលបើមានហេតុ ចូរលោកឆាន់ចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# ទុតិយបវារណា

[ ១២២ ] ក្នុងសិក្ខាបទទី ៦ មានវិនិច្ឆ័យដូច្នេះ ពីរបទថា **អញ្ញាចារំ អាចរតិ** បានដល់ ធ្វើឲ្យកន្លងល្មើសព្រះបញ្ញត្តិ ។

បទថា **ឧបនន្ធិ** សេចក្តីថា កាលឲ្យការចងក្រោធកើតឡើង ឈ្មោះថា បានចងសេចក្តីក្រោធរបស់ខ្លួនទុកក្នុងបុគ្គលនោះ អធិប្បាយថា ឲ្យអាឃាតកើតឡើងរឿយៗ ។

ពីរបទថា **ឧបនទ្ធោ ភិក្ខុ** បានដល់ ភិក្ខុដែលកើតមានសេចក្តីក្រោធនោះ ។

ពីរបទថា **អភិហដ្ឋុំ បវារេយ្យ** សេចក្តីថា គប្បីនាំទៅបវារណាយ៉ាងនេះ និមន្តចុះភិក្ខុ ទំពាក្តី ឆាន់ក្តី ។ តែក្នុងបទភាជនៈ ព្រះឧបាលីមិនលើកពាក្យថា **ហន្ទ ភិក្ខុ** ជាដើមឡើង ដើម្បីសម្តែងអត្ថនៃការនាំទៅបវារណាដែលទូទៅតែម្យ៉ាង ទើបពោលថា និមន្តទទួលរបស់តាមដែលម្ចាស់ត្រូវការចុះ ។

បទថា **ជានំ** គឺដឹងថា ភិក្ខុនោះជាអ្នកហាមកត្តហើយ ។ ក៏ព្រោះការដឹងនោះរបស់ភិក្ខុនោះ រមែងមានដោយអាការ ៣ យ៉ាង ដូច្នោះ ទើបព្រះ-ឧបាលីពោលបទភាជនៈ ដោយន័យថា **ជានាតិ ញាម សាមំ វា ជានាតិ** ដូច្នេះជាដើម ។

បទថា **អាសាទនាបេក្ខោ** បានដល់ សម្លឹងការរុករាន គឺការចោទ

បានដល់ ការៈដែលធ្វើឲ្យជាអ្នកអប្បយស ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃទុតិយបវារណាសិក្ខាបទ

[១២៣] បទថា **បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស** សេចក្ដីថា កាលភិក្ខុដែលខ្វនបង្អោនប្រគេនភត្ត ទទួលយក ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលបង្អោនប្រគេន ឯសេចក្ដីផ្សេងគ្នានៃអាបត្តិគ្រប់យ៉ាង របស់ភិក្ខុដែលទទួលក្រៅពីនេះ ពោលទុកហើយក្នុងបឋមប្បវារណាសិក្ខាបទ ។ តែក្នុងសិក្ខាបទនេះ ព្រះ-វិនយធរគប្បីកាត់អាបត្តិទាំងអស់ ដល់ភិក្ខុដែលបង្អោនប្រគេនភត្តប៉ុណ្ណោះ ។ បទដ៏សេសប្រាកដជាក់ច្បាស់ហើយ ព្រោះមានន័យដូចពោលហើយ ក្នុងសិក្ខាបទមុន ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះ ។

ទុតិយបវារណាសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[១២៦] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ក្រុងរាជគ្រឹះលេងមហោស្រពលើកំពូលភ្នំ ។ ពួកសត្តរសវគ្គិយភិក្ខុ ក៏បានទៅដើម្បីមើលមហោស្រពដែលគេលេងលើកំពូលភ្នំ ( នោះ ) ។ មនុស្សទាំងឡាយបានឃើញពួកសត្តរសវគ្គិយភិក្ខុហើយ និមន្តឲ្យស្រង់ទឹក ឲ្យលាប ឲ្យឆាន់ស្រេចហើយក៏ប្រគេននូវខាទនីយ ។ ពួកសត្តរសវគ្គិយភិក្ខុកាន់យកខាទនីយ ទៅអារាម ហើយនិយាយពាក្យនេះប្រាប់ពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយចូរទទួលយកខាទនីយទៅឆាន់ចុះ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះសួរថា ម្នាលអាវុសោទាំងឡាយ ពួកលោកបានខាទនីយមកពីណា ។ ពួកសត្តរសវគ្គិយភិក្ខុ បានប្រាប់រឿងនុ៎ះដល់ឆព្វគ្គិយភិក្ខុទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយបានឆាន់ភោជនក្នុងពេលដែលមិនគួរមែនឬ ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា មែនអាវុសោទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុ មិនគួរនឹងឆាន់ភោជនក្នុងពេលវិកាល ( ដូច្នេះ ) សោះ ។ ខណៈនោះឯង ពួកឆព្វគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុមិនគួរឆាន់ភោជនក្នុងពេលវិកាល

( ដូច្នេះ ) ទេ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បាន ឮថា អ្នកទាំងឡាយឆាន់ភោជនក្នុងពេលវិកាល ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មាន ព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរ នឹងឆាន់ភោជនក្នុងពេលវិកាលទេ នែមោឃបុរសទាំងឡាយ អំពើដែល ពួកអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និង មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលជ្រះថ្លា ស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លា តទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើង នូវសិក្ខាបទនេះ ដូច្នេះថា ភិក្ខុណាមួយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ ។

[១២៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងបឋមបារា-ជិកសិក្ខាបទ ។ វេលាដែលព្រះអាទិត្យជ្រេពីត្រង់ ទៅទល់នឹងអរុណរះឡើង ហៅថា ពេលវិកាល ។ ដែលហៅថា ខាទនីយ ( នោះ ) បានដល់ របស់ ទាំងអស់ វៀរលែងភោជន ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយ ។ ដែលហៅថា ភោជនីយ បានដល់ ភោជន ៥ យ៉ាង គឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវ អាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វារៈដែលលេបចូលទៅ ។

[១២៨] ពេលវិកាល ភិក្ខុក៏សម្គាល់ថា ពេលវិកាល ហើយទំពាស៊ីក្តី

បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ ពេលវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ ពេលវិកាល ភិក្ខុសម្គាល់ថា កាលគួរ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិក ទុកសម្រាប់ជាប្រយោជន៍ដល់អាហារត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ ខណៈដែលលេបចូលទៅ ។ ពេលជាកាលគួរ ភិក្ខុសម្គាល់ថា ពេលវិកាល ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសម្គាល់ថា កាលគួរមែន មិនត្រូវអាបត្តិឡើយ ។

[១២៩] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់តែវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិក ដោយមានហេតុដែលគួរឆាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# វិកាលភោជនសិក្ខាបទ

[១២៦] ក្នុងសិក្ខាបទទី ៧ មានវិនិច្ឆ័យដូចតទៅនេះ បទថា **គិរគ្គ-សមជ្ជោ** គឺមហោស្រពលើកំពូលភ្នំ ។ ម្យ៉ាងទៀត បានដល់ មហោស្រពដែលសម្តែងលើកំពូលនៃភ្នំ ។ អ្នកនគរធ្វើការឃោសនា ក្នុងនគរថា បានឮថា មហោស្រពនោះជាប់គ្នារហូត ៧ ថ្ងៃ ។ ពួកមហាជនដ៏ច្រើនបានប្រជុំគ្នាត្រង់មួប់នៃបពិត លើភូមិភាគដែលរាបស្មើខាងក្រៅនគរ ការច្រៀងរាំរបស់តន្ត្រីករ មានប្រការប្លែកៗ ច្រើនយ៉ាងប្រព្រឹត្តទៅ ។ ជនទាំងឡាយបានចងគ្រែត្រួតគ្នា ដើម្បីមើលការរាំច្រៀងរបស់ពួកអ្នករាំច្រៀងទាំងនោះ ។ ពួកសត្តរសវគ្គិយភិក្ខុបួសតាំងពីនៅក្មេងៗ ក្នុងកាលសិក្ខាបទ មិនទាន់បានបញ្ញត្តិ ភិក្ខុទាំងនោះបបួលគ្នាថា អ្នកមានអាយុ ពួកយើងនឹងទៅមើលការច្រៀងរាំជាមួយគ្នា ហើយបានទៅក្នុងទីនោះ ។ គ្រានោះ ពួកញាតិរបស់លោក មានចិត្តត្រេកអរថា លោកម្ចាស់របស់ពួកយើងមកដែរហ្ន៎ ទើបឲ្យងូតទឹក លាបស្រឡាប ឲ្យឆាន់ហើយ បានប្រគេនរបស់ដទៃ មាននំ និងរបស់ទំពាជាដើម ហើយឲ្យកាន់យកទៅផង ។ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សំដៅដល់ញាតិទាំងនោះ ទើបបានពោលថា ពួកមនុស្សបានឃើញ សត្តរសវគ្គិយភិក្ខុទាំងនោះជាដើម ។

បទថា **វិកាលេ** គឺក្នុងកាលដែលហួសទៅហើយ ។ កាលនៃភោជន

របស់ភិក្ខុទាំងឡាយ លោកហៅថា កាល ឯកាលនៃភោជននោះ ដោយកំណត់យ៉ាងទាបជាងគេទាំងអស់ត្រឹមថ្ងៃត្រង់ អធិប្បាយថា បើកាលថ្ងៃត្រង់នោះកន្លងហួសទៅហើយ ។ ដោយហេតុនោះឯង ក្នុងបទភាជនៈនៃបទថា **វិកាលេ** នោះ ទើបព្រះឧបាលីពោលថា បើកាល គឺថ្ងៃត្រង់កន្លងទៅហើយ រហូតដល់ថ្ងៃរះឡើង ឈ្មោះថា **វិកាល** សូម្បីវេលាថ្ងៃត្រង់ ក៏ដល់នូវការសង្គ្រោះថា ជាកាល ។ ចាប់ពីវេលាថ្ងៃត្រង់ទៅ ភិក្ខុមិនអាចដើម្បីទំពា ឬឆាន់បានឡើយ តែអាចដើម្បីប្រញាប់ប្រញាល់ផឹកបាន ឯភិក្ខុដែលមានការរង្កៀស មិនគប្បីធ្វើ ។ និងដើម្បីដឹងកំណត់កាលវេលា គួរបោះសសរជាគ្រឿងចំណាំកាលវេលាទុក ។ ម្យ៉ាងទៀត គប្បីធ្វើភត្តកិច្ចខាងក្នុងកាល ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃវិកាលភោជនសិក្ខាបទ

[១២៧] ក្នុងបទថា **អវសេសំ ខាទនីយំ នាម** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ក្នុងអាហារវត្ថុ មានទំនំជាដើម ដែលសម្រេចពីបុព្វណ្ណជាតិ និងអបរន្នជាតិ មានពាក្យដែលគួរពោលជាមុនយ៉ាងនេះថា វត្ថុណាមានប្រភេទដូចជាស្លឹក និងមើមជាដើម ជារបស់មានគតិដូចអាមិស សេចក្តីនេះដូចម្តេច សេចក្តីថា វត្ថុនេះ មានឫសគួរទំពា មើមគួរទំពា ក្រអៅគួរទំពា ត្រួយគួរទំពា ដើមគួរទំពា សម្បកគួរទំពា ស្លឹកគួរទំពា ផ្កាគួរទំពា ផ្លែគួរទំពា គ្រាប់គួរទំពា ម្សៅគួរទំពា ជ័រគួរទំពា រមែងដល់នូវការសង្គ្រោះចូលក្នុងខាទនីយ

ទាំងអស់ ក្នុងមូលខាទនីយជាដើមនោះ គប្បីកំណត់ដឹងរបស់ដែលគួរទំពា មានគតិដូចអាមិស មានរបស់គួរទំពា ដែលនឹងចផ្អុលឲ្យឃើញល្មមជា លំអានដូចតទៅនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមូលខាទនីយជាមុនថា ស៊ីក និងឫស ដែលគួរជាសូបៈ ( ម្ហូប ) បាន មានជាដើមយ៉ាងនេះ គឺមូលកមូល ខារកមូល បុច្ចុមូល តម្ពកមូល តណ្ឌុលេយ្យកមូល វត្ថុលេយ្យកមូល វជ្ជកលិមូល ជជ្ឈរិមូល មានគតិដូចអាមិស ។ បណ្តាខាទនីយ មានមូលកមូលជាដើមនេះ ជនទាំងឡាយកាត់មើមខ្ទិ ក្នុងវជ្ជកលិមូល ( មើមដំឡូងធំ ) ចោលមើមខ្ទិនោះជាយាវជីវិក ។ ឫសដទៃបែបនេះ ក៏គប្បីជ្រាបដោយន័យនេះឯង ។ លោកពោលទុកថា ចំណែកក្បាលរបស់មូលកខារកៈ និងជជ្ឈរិ ( ត្រាវថ្លៅ និងដំឡូងជ្រូក ) សូម្បីនៅខ្ទិ ក៏មានគតិដូចអាមិសដូចគ្នា ។

ចំណែកភេសជ្ជៈណា ដែលត្រាស់ទុកក្នុងព្រះបាលីថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតនូវឫស ឬមើមជាភេសជ្ជៈ គឺមើមរមៀត មើមខ្ញីមើមលំពាន់ មើមប្រោះ មើមអាចម៍ត្អឺះ មើមរំដេង មើមស្បូវក្លាំង មើមស្មៅក្រវាញជ្រូក ម្យ៉ាងទៀត មើមដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយក្នុងខាទនីយ មិនផ្សាយទៅដើម្បីភោជនីយក្នុងភោជនីយ ឲ្យភិក្ខុទទួលមើមទាំងឡាយនោះហើយ រក្សាទុកដរាបទាល់អស់បាន ដូច្នេះ ។ ភេសជ្ជៈទាំងនោះជាយាវជីវិក ។ ភេសជ្ជៈជាយាវជីវិកនោះ កាលគណនាពាក់ដោយន័យជាដើមថា ចូឡបញ្ចមូល មហាបញ្ចមូល ( ឫសទាំង ៥ តូច ឫសទាំង

៥ ធំ ) មិនមានទីបំផុតដោយការរាប់ ។ ឯភាវៈ គឺការមិនសម្រេចប្រយោជន៍ដល់ខាទនីយ និងប្រយោជន៍ភោជនីយនោះឯង ជាលក្ខណៈនៃមូលភេសជ្ជៈដែលជាយាវជីវិកទាំងអស់ ។

ព្រោះដូច្នោះ ឫសប្រភេទណានីមួយ សម្រេចប្រយោជន៍ដល់ខាទនីយ និងប្រយោជន៍ដល់ភោជនីយរបស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតីក្នុងជនបទនោះៗ ឫស ឬមើមនោះ គប្បីជ្រាបថា ជាយាវកាលិក ។ មូលក្រៅអំពីនេះ គប្បីជ្រាបថា ជាយាវជីវិក សូម្បីពួកយើងពោលឲ្យល្អិតពេកទៅ ក៏ចាំបាច់បញ្ជាក់អះអាងក្នុងលក្ខណៈនេះឯង ។ តែកាលនឹងពោលនាមសញ្ញា ( គ្រឿងចំណាំឈ្មោះ ) ទាំងឡាយទុក ក៏នឹងជាការរាយមាយខ្លាំងឡើងដល់សាធុជន ដែលមិនស្គាល់ឈ្មោះនោះៗ ព្រោះដូច្នោះ ទើបខ្ញុំមិនធ្វើការអើពើក្នុងនាមសញ្ញា សម្តែងតែក្នុងលក្ខណៈប៉ុណ្ណោះ ។ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យដោយអំណាចនៃលក្ខណៈ ដែលសម្តែងទុកក្នុងមើមជំឡូងជាដើមនោះឯង ដូចក្នុងឫស ឬក្រអៅ ដូច្នោះ ។ ម្យ៉ាងទៀត សូម្បីដើមសម្បក ផ្កា និងផ្លែនៃមើម ៨ ប្រភេទ មានរមៀតជាដើម ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីទាំងអស់ លោកក៏ពោលថា ជាយាវជីវិក ។

ក្នុងមើមគួរទំពាមានវិនិច្ឆ័យដូច្នេះថា ជំឡូង ( មើមក្រោមដី ) មាន ២ ប្រភេទ គឺមើមដែលវែង ១ មើមដែលមូល ១ ក្រអៅឈូក និងមើមចារជាដើម មានទាំងវែង និងខ្លី មើមឈូក និងមើមក្រចាប់ជាដើម ដែលអាចារ្យពួកខ្លះ ហៅថា គណ្ឌីក៏មាន ជាមើមប្រភេទមូល ។ បណ្តាមើមទាំងនោះ

មើមដែលចាស់ និងមើមដែលខ្ចី ក្រមី និងឫសរយាងនៃមើមគ្រប់យ៉ាង ចាត់ជាយាវជីវិក ឯពពួកមើមដែលសម្រេចប្រយោជន៍ដល់ខាទនីយ និងប្រយោជន៍ដល់ភោជនីយរបស់ពួកមនុស្ស ដោយអំណាចអាហារតាមប្រក្រតីតាមជនបទនោះៗ មានជាដើមយ៉ាងនេះ គឺពន្លកនៃមើមក្ដៅនាងដែលនៅខ្ចី ស្រួលទំពា ពន្លកនៃដើមចារ មើមនៃដើមម្នាក់ មើមនៃរំពេក ឫសជ្រៃ មើមឈូកក្រហម និងឈូកស ដែលគេហៅថា ក្រអៅឈូក វល្លិ៍ក្ដួង និងវល្លិ៍ត្រចៀកប្រើស ជាដើម មើមជំឡូងបារាំង មើមម្រុំ មើមត្នោត ឫសឈូកខៀវ ឈូកក្រហម មើមកោមុទ និងចង្កុលណី ( ស្គន់ ) ក្ដិលចេក ទំពាំង មើមក្រចាប់ដែលនៅខ្ចី ទំពាងាយ រាប់ជាយាវកាលិក ។ មើមក្ដួចដែលមិនទាន់ត្រាំទឹក ជាយាវជីវិក ដែលត្រាំសាបហើយ ជាយាវកាលិក ។

ឯមើមក្បៀស ខ្ទាយ ខ្ញី និងខ្ទឹមជាដើម ជាយាវជីវិក ។ មើមទាំងនោះ លោកសង្គ្រោះចូលជាមូលភេសជ្ជៈនោះឯង ក្នុងព្រះបាលីយ៉ាងនេះថា ម្យ៉ាងទៀត មើមដទៃជាភេសជ្ជៈ ។

ក្នុងមូឡាលខាទនីយ មានវិនិច្ឆ័យដូច្នេះថា ក្រអៅឈូកក្រហម ដូចគ្នានឹងក្រអៅឈូកសនោះឯង ។ ក្រអៅដែលសម្រេចយោជន៍ដល់ខាទនីយ និងប្រយោជន៍ដល់ភោជនីយរបស់ពួកនោះ ដោយអំណាចអាហារតាមប្រក្រតីក្នុងជនបទនោះៗ ជាដើមយ៉ាងនេះ គឺស្ពៃទឹក និងកណ្ឌមូល ជាយាវកាលិក ។

ឯមើមរបស់រមៀត ខ្ញី ប្រោះ រំពេក ត្នោត ទន្សែ ដើមស្ទីករិត ដូងស្វាជាដើម ចាត់ជាយាវជីវិក ។ មើមរមៀតជាដើមទាំងអស់នោះ លោក

សង្គ្រោះចូលជាមូលភេសជ្ជៈដូចគ្នា ក្នុងព្រះបាលីយ៉ាងនេះថា ម្យ៉ាងទៀត មើមជាទៃជាភេសជ្ជៈ ។

ក្នុងមត្ថកខាទនីយ មានវិនិច្ឆ័យដូច្នេះថា បណ្ដូល ឬពន្លកនៃដើមឈើ និងវល្លិ៍ជាដើម ដែលសម្រេចប្រយោជន៍ដល់ខាទនីយ និងប្រយោជន៍ដល់ភោជនីយនៃពួកមនុស្ស ដោយអំណាចអាហារតាមប្រក្រតី ក្នុងជនបទនោះៗ មានជាដើមយ៉ាងនេះ គឺត្រួយដែលហៅថា ពន្លករបស់ត្នោត ទន្សែ ដើមស្ទឹក រឹត រំពេក ដូង ស្លា ឥន្ទលាំ ( ខ្លះថាល្មើ ) ផ្ដៅ ស្ដៃទឹក ពេក ទំពាំង ពន្លកបបុស ពន្លកអំពៅ ពន្លកត្រាវ ពន្លកស្ពៃ ពន្លកសាមសិប និង ពន្លកនៃធញ្ញជាតិ ៧ ប្រការ ចាត់ជាយាវកាលិក ។ គល់ ឬឫសខ្ចី ( ត្រួយខ្ចី ) នៃពន្លករមៀត ខ្ញី លំពាន់ ផ្ទៃ ខ្ទឹម និងពន្លកត្នោត ទ្រាំង ជ្រៃ ដូង ដែលគេកាត់ឲ្យដាច់ទៅ ជាយាវជីវិក ។

ក្នុងខន្ធខាទនីយ មានវិនិច្ឆ័យដូច្នេះថា ដើម មានជាដើមយ៉ាងនេះ គឺ ដើមក្លោនាង ដើមអំពៅ ឈូកខៀវ ឈូកក្រហម កោមុទ និងចង្កុលណី ដែលនៅខាងក្នុងដី សម្រេចប្រយោជន៍ដល់ខាទនីយ និងប្រយោជន៍ដល់ភោជនីយរបស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតី ក្នុងជនបទនោះៗ រាប់ជា យាវកាលិក ។ ទងនៃឈូក ប្រភេទឧប្បលជាតិក្ដី ទងទាំងអស់នៃឈូកប្រភេទបទុមជាតិក្ដី និងទងឈូកដ៏សេសគ្រប់ៗយ៉ាង មាន ឈូកក្រហមជាដើម ចាត់ជាយាវជីវិក ។

ក្នុងតចខាទនីយ មានវិនិច្ឆ័យដូច្នេះថា សម្បកអំពៅតែម្យ៉ាងប៉ុណ្ណោះ

លោកចាត់ជាយាវកាលិក ។ សម្បកអំពៅនោះ នៅជារបស់មានរស ( ផ្អែម ) ។ សម្បកដ៏សេសគ្រប់យ៉ាង ជាយាវជីវិក ។ ត្រួយ ដើម និង សម្បកទាំង ៣ នោះ គប្បីជ្រាបថា សង្គ្រោះចូលជាមួយកសាវភេសជ្ជៈក្នុង ព្រះបាលី ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់ជាភេសជ្ជៈ គឺទឹកចត់ដែលកើតអំពីដើមស្ដៅ ទឹកចត់ កើតអំពីខ្ទឹងគន់ ទឹកចត់កើតអំពីដើមអំបែងថ្ងៃ ទឹកចត់កើតអំពីវល្លិ៍បណ្ដូល ពេជ្រ ទឹកចត់ដែលកើតអំពីដើមទន្លា ឬថ្នាំ់ ម្យ៉ាងទៀត ទឹកចត់ដទៃណាជា ភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយក្នុងខាទនីយ មិនផ្សាយទៅដើម្បី ភោជនីយក្នុងភោជនីយ ។ ឬកសាវភេសជ្ជៈដទៃណាមួយ ដែលមិនសម្រេច ប្រយោជន៍ដល់របស់គួរទំពាក្នុងរបស់គួរទំពា ដែលមិនសម្រេចប្រយោជន៍ ដល់របស់គួរបរិភោគក្នុងរបស់គួរបរិភោគ ។ ការសង្គ្រោះដើម សម្បកទាំង នោះចូលក្នុងពុទ្ធានុញ្ញាតនេះ រមែងសម្រេច ( រមែងប្រើបាន ) ។ ពួកទឹក ចត់ដែលពោលហើយ បណ្ឌិតគប្បីជ្រាបថា ជារបស់គួរ ដោយប្រការគ្រប់ យ៉ាង ។

ក្នុងបត្តខាទនីយ មានវិនិច្ឆ័យដូច្នេះថា ស្លឹកទាំងឡាយនៃរុក្ខជាតិទាំង នេះ គឺត្រាវ ស្ពួយ ជំឡូងខ្ទី និងជំឡូងក្រហម ទន្សាប់ បុន្នាគ ជំឡូងជ្រៅ ជំឡូងធំ ម្អាក់ ប្រោះ សណ្ដែកបាយ សណ្ដែកសៀង សណ្ដែករាជមាស ញព្រៃដ៏សេស វៀរញធំ ( គឺញស្រុកចេញ ) ដើមបាយម៉ាត កន្ទី-ស បន្តិ ដើមប្រាំខែ ដើមថ្នាំ់ ដូង លោណា ( អំបិលកើតពីដី ) និងស្លឹកឈើពួក

ដទៃ ដែលមានសភាពបែបនេះ សម្រេចប្រយោជន៍ដល់របស់គួរទំពា និង សម្រេចប្រយោជន៍ដល់របស់គួរបរិភោគនៃពួកមនុស្ស ដោយអំណាចអាហារ តាមប្រក្រតី ក្នុងជនបទនោះៗ រាប់ជា យាវកាលិកតែម្យ៉ាង ។

តែលោណាមានស្លឹកទំហំប៉ុនខ្នងក្រចកដទៃណា វារឡើងលើដើមឈើ ឬគុម្ពោតឈើ ពួកអាចារ្យអ្នកកោះ ( អ្នកជម្ពូទ្វីប ឬលង្កាទ្វីប ) ពោលស្លឹក លោណានោះថា ជាយាវជីវិក និងស្លឹកព្រហ្មីថាជាយាវជីវិក ។ ស្លឹកស្វាយទ្វី ជាយាវកាលិក ។ ឯស្លឹកអសោកទ្វីជាយាវជីវិក ។

ក្នុងស្លឹកដទៃណា ដែលព្រះមានព្រះភាគត្រាស់ក្នុងបាលីថា ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតស្លឹកឈើជាភេសជ្ជៈ គឺស្លឹកស្ដៅ ស្លឹកខ្ញែងគន់ ស្លឹកអំបែងថ្ងៃ ស្លឹកម្រះព្រៅ ឬជីរលីងលាក់ ស្លឹកកប្បាស ម្យ៉ាងទៀត ស្លឹក ដទៃណា ជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយក្នុងខាទនីយ មិនផ្សាយ ទៅដើម្បីភោជនីយក្នុងភោជនីយ ដូច្នេះ ។ ស្លឹកទាំងនោះ ជាយាវជីវិក ។ ម្យ៉ាងទៀត មិនមែនស្លឹកតែម្យ៉ាងទេ សូម្បីផ្លែ និងផ្ការបស់ស្ដៅជាដើមនោះ ក៏ជាយាវជីវិកដូចគ្នា ។ ស្លឹកដែលជាយាវជីវិក នឹងមិនមានទីបំផុតដោយការ រាប់យ៉ាងនេះថា ស្លឹកខ្ញែងគន់ ស្លឹកស្ដៅ ស្លឹកបណ្ដូលពេជ្រ ស្លឹកអំបែងថ្ងៃ ស្លឹកជីរលីងលាក់ ស្លឹកពោន ស្លឹកស្ពៃ ស្លឹកម្ជូ ស្លឹកឈូកជាដើម ។

ក្នុងបុប្ផខាទនីយ មានវិនិច្ឆ័យដូច្នេះថា ផ្កាដែលសម្រេចប្រយោជន៍ដល់ របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់ដែលគួរបរិភោគរបស់ ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតី ក្នុងជនបទនោះៗ មានជា

ដើមយ៉ាងនេះ គឺផ្កាត្រាវ ផ្កាស្ពួយ ផ្កាជំឡូងដូង ផ្កាជំឡូងក្រហម ផ្កាជំឡូងធំ ផ្កាញស្បាត ផ្កាញស្រុក ផ្កាក្រចាប់ ផ្កាខ្ទឹមរបស់ដូង ផ្កាត្នោត និងផ្ការំចេក ផ្កាថ្វាន់ ផ្កាម្រុំ ផ្កាឈូកប្រភេទឧប្បល ឈូកក្រហម ផ្កាកណិការ ផ្កាមិនមានក្លិន ( កន្ទឹ-ស ) ផ្កាច្បា ផ្កាទៀនស ជាយាវកាលិក ។

ឯផ្ការបស់រុក្ខជាតិ ដូចជាអសោក ពកុល ក្រពៅ បុន្នាគ ចម្ប៉ា អង្កាបុស្ស ច្បា កណិការ ម្ទះលា ម្ទះរួតជាដើម ជាយាវជីវិក ។ ផ្កាដែលជាយាវជីវិកនោះ មិនមានទីបំផុតដោយការរាប់ តែអ្នកសិក្សាគប្បីជ្រាបថា សង្គ្រោះផ្កាដែលជាយាវជីវិកនោះចូលជាមួយកសាវភេសជ្ជៈ ក្នុងព្រះបាលីនោះឯង ។

ក្នុងផ្លែដែលជាខាទនីយ មានវិនិច្ឆ័យដូច្នេះ គឺផ្លែឈើទាំងឡាយ មានខ្នុរណាំង ខ្នុរបាយស្រោ ត្នោត ដូង ស្វាយ ជម្ពូ ម្កាក់ អំពិល ក្របព្រៃ ខ្វិតឃ្លោក ត្រឡាច ត្រសក់ ទន្លាប់ ឪឡឹក ត្រប់ ចេកមានគ្រាប់ ចេកមិនមានគ្រាប់ ស្រគំជាដើម និងប្រភេទផ្លែឈើដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់គួរបរិភោគនៃពួកមនុស្ស ដោយអាហារតាមប្រក្រតី ក្នុងជនបទនោះៗ ក្នុងលោក គ្រប់ៗ យ៉ាង ជាយាវ-កាលិក ។ និងដោយអំណាចការរាប់ឈ្មោះ បុគ្គលណាក៏មិនអាចរាប់ផ្លែឈើដែលជាយាវកាលិកទាំងនោះឲ្យដល់ទីបំផុតបានឡើយ ។

ឯផ្លែពួកណា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាភេសជ្ជៈ គឺផ្លែពិលង្គ ផ្លែជីប្លី ផ្លែ

ម្រេច ផ្លែសម៉ ផ្លែសម៉ពិភេទក៍ ផ្លែកន្ទួតព្រៃ ផ្លែក្រវាញ ម្យ៉ាងទៀត ផ្លែឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយក្នុងខាទនីយ មិនផ្សាយទៅដើម្បីភោជនីយក្នុងភោជនីយ ដូច្នេះ ។ ផ្លែទាំងនោះជាយាវជីវិក ។ សូម្បីផ្លែឈើដែលជាយាវជីវិកទាំងនោះ បុគ្គលណាក៏មិនអាចនឹងសម្ដែងឲ្យអស់បាន ដោយអំណាចនៃឈ្មោះយ៉ាងនេះ គឺផ្លែស្វាក្មេង ផ្លែជ្រៃ ផ្លែបាស ផ្លែរំចេក ផ្លែញាជាដើម ដែលមិនទាន់ទុំ ផ្លែចាន់ ផ្លែម្រេច ផ្លែក្រវាញធំ ផ្លែក្រវាញតូច ជាដើម ។

ក្នុងអដ្ឋិខាទនីយ មានវិនិច្ឆ័យដូច្នេះថា គ្រាប់ទាំងឡាយ មានជាដើមយ៉ាងនេះ គឺគ្រាប់ខ្នុរសម្ល គ្រាប់ខ្នុរណាំង គ្រាប់ម្កាក់ គ្រាប់ត្រចៀកប្រើសគ្រាប់របស់ផ្លែដែលនៅខ្ចីនៃប្រភេទផ្លែឥន្ទូលាំ រំចេក ទន្លាប់ គ្រាប់អំពិល គ្រាប់បាស គ្រាប់ពន្រៃ គ្រាប់ឈូក ប្រភេទឧប្បល និងបទុម ដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់គួរបរិភោគដោយអំណាចនៃអាហារតាមប្រក្រតីរបស់ពួកមនុស្ស ក្នុងជនបទនោះរាប់ជាយាវកាលិក ។ គ្រាប់មានជាដើមយ៉ាងនេះ គឺគ្រាប់ស្រគំ គ្រាប់បុន្នាគ គ្រាប់សម៉ជាដើម គ្រាប់ស្ពៃ គ្រាប់ជីរវ៉ាន់ស៊ុយ ចាត់ជាយាវជីវិក ។ គ្រាប់ដែលជាយាវជីវិកទាំងនោះ អ្នកសិក្សាគប្បីជ្រាបថា សង្គ្រោះចូលជាមួយផលភេសជ្ជៈក្នុងព្រះបាលីនោះឯង ។

ក្នុងបិដ្ឋខាទនីយ មានវិនិច្ឆ័យដូច្នេះថា ម្សៅទាំងឡាយ មានយ៉ាងនេះជាដើម គឺម្សៅនៃធញ្ញជាតិ ៧ ប្រការ ធញ្ញជាតិអនុលោម និងអបរន្នជាតិ

ម្សៅខ្នុរ ម្សៅខ្នុរសម្ល ម្សៅម្កាក់ ម្សៅត្រចៀកប្រើស ម្សៅត្នោត ដែលលាង ជម្រះហើយ ម្សៅល្ហុទឹកដោះ ដែលសម្រេចប្រយោជន៍ដល់របស់គួរទំពា និងដែលសម្រេចប្រយោជន៍ដល់របស់គួរបរិភោគនៃពួកមនុស្ស ដោយអំណាច នៃអាហារតាមប្រក្រតីក្នុងជនបទនោះ ចាត់ជាយាវកាលិក ។ ម្សៅត្នោតដែល មិនទាន់បានសម្អាត ម្សៅល្ហុទឹកដោះ ម្សៅអស្សគន្ធជាដើម ( ដែលមិនទាន់ បានលាងជម្រះ ) ចាត់ជាយាវជីវិក ។ ម្សៅដែលជាយាវជីវិកទាំងនោះ អ្នក សិក្សាគប្បីជ្រាបថា សង្គ្រោះចូលជាមួយទឹកចត់ និងរុក្ខជាតិប្រភេទឫស និង ផ្លែ ។

ក្នុងនិយ្យាសខាទនីយ មានវិនិច្ឆ័យដូច្នេះថា ជ័រអំពៅ ( តាំងម៉ែ ) តែម្យ៉ាង ជាសត្តាហកាលិក ។ ជ័រដ៏សេសត្រាស់ទុកក្នុងបាលីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើជាភេសជ្ជៈ គឺជ័រដែលហូរចេញ អំពីដើមហិង្គុ ១ ជ័រដែលគេយកស្លឹក និងមែកហិង្គុមករម្ងាស់ ១ ជ័រដែល គេយកតែស្លឹកហិង្គុតែម្យ៉ាងមករម្ងាស់ ១ ( ជ័រទាំង ៣ យ៉ាងនេះជាជាតិហិង្គុ ទាំងអស់ ) ជ័រដែលហូរចេញអំពីត្រួយឈើ ១ ជ័រដែលហូរចេញអំពីស្លឹក ឈើ ១ ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ ១ កំញាន ១ ម្យ៉ាងទៀត ជ័រ ឈើដទៃណាដែលជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយក្នុងខាទនីយ មិន ផ្សាយទៅដើម្បីភោជនីយក្នុងភោជនីយ ដូច្នេះ ។ ចាត់ជាយាវជីវិក បុគ្គល ណាមួយក៏មិនអាចនឹងសម្តែងជ័រភេសជ្ជៈ ដែលលោកសង្គ្រោះ ដោយ យេវាបនកន័យក្នុងព្រះបាលីនោះ ឲ្យអស់ដោយអំណាចនៃឈ្មោះយ៉ាងនេះ

គឺជ័រកណិការ ជ័រស្វាយជាដើម ។ បណ្ដាខាទនីយ មានមូលខាទនីយជាដើមនេះ ដូចពោលមកនេះ យាវកាលិកប្រភេទណាមួយ សូម្បីទាំងអស់ លោកសង្គ្រោះចូលក្នុងអត្ថនេះថា ដ៏សេស ឈ្មោះថា ខាទនីយ ( របស់គួរទំពា ) ។ ឯពាក្យដែលគួរពោល ក្នុងពាក្យថា ភោជន ៥ យ៉ាង ឈ្មោះថា ភោជនីយ ( របស់គួរបរិភោគ ) ជាដើម ខ្ញុំបានពោលទុកហើយដូច្នេះ ។

បទថា **ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិទុក្កដស្ស** សេចក្ដីថា ភិក្ខុណាទទួលប្រគេនខាទនីយ និងភោជនីយនោះ ក្នុងវេលាវិកាល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួល ។ បទដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វិកាលភោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ១៣០ ] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះវេឡដ្ឋ-សីសៈដ៏មានអាយុជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងព្រៃ ។ ព្រះថេរៈនោះត្រាច់ទៅបិណ្ឌបាត លុះបានអាហារបិណ្ឌបាតជាច្រើនហើយ ក៏នាំយកបាយសុទ្ធ[១] មកកាន់អារាម រួចហាលបាយនោះឲ្យស្ងួត ក្រៀមហើយទុកដាក់ កាលណាមានសេចក្តីត្រូវការដោយអាហារ ទើបយកបាយក្រៀមនោះមកត្រាំទឹក ហើយក៏ឆាន់ក្នុងកាលនោះ យូរៗ បានលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង ។ ភិក្ខុទាំងឡាយ បាននិយាយពាក្យនេះនឹងព្រះវេឡដ្ឋសីសៈ ដ៏មានអាយុថា ម្នាលអាវុសោ ចុះហេតុអ្វី បានជាយូរៗ ទើបលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង ។ ទើបព្រះវេឡដ្ឋសីសៈដ៏មានអាយុក៏តំណាល រឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះក៏សួរថា ម្នាលអាវុសោ បើដូច្នោះ មានតែលោកឆាន់ភោជនដែលខ្ទនទុកដាក់ឲ្យកន្លងរាត្រីឬអ្វី ។ ព្រះវេឡដ្ឋសីសៈឆ្លើយថា យ៉ាងហ្នឹងហើយអាវុសោ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ព្រះវេឡដ្ឋសីសៈដ៏មានអាយុ មិនសមបើនឹងឆាន់ភោជនដែលខ្ទនទុកដាក់ឲ្យកន្លងរាត្រី ( ដូច្នេះ ) ទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា

---

១- អដ្ឋកថា គឺបាយតែម្យ៉ាង មិនមានសម្ល និងម្ហូបក្រៀមលាយជាមួយផងទេ ។

ម្នាលវេឡដ្ឋសីសៈឮថា អ្នកឯងបានឆាន់ភោជនដែលខ្ជួនទុកដាក់ឲ្យកន្លងរាត្រី ពិតមែនឬ ។ ព្រះវេឡដ្ឋសីសៈក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលវេឡដ្ឋសីសៈ អ្នកឯង មិនសមបើនឹងឆាន់ភោជនដែលខ្ជួនទុកដាក់ឲ្យកន្លងរាត្រី (ដូច្នេះ) ទេ ម្នាល វេឡដ្ឋសីសៈ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែល មិនទាន់ជ្រះថ្លា និងមិនមែននាំពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែ ជ្រះថ្លាតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែង ឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវ ខាទនីយ ឬភោជនីយ ជាសន្និធិការកៈ គឺ វត្ថុដែលខ្ជួនទុកដាក់ឲ្យកន្លងរាត្រី ត្រូវអាបត្តិបាចិត្តិយ ។

[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ខ្ជួនទុកដាក់ឲ្យកន្លងរាត្រី (បានដល់ ខាទនីយ ឬភោជនីយ) ដែលខ្ជួនទទួលទុកក្នុងថ្ងៃនេះ ហើយឆាន់ក្នុងថ្ងៃខាង ក្រោយ ។ ដែលហៅថា ខាទនីយ (នោះ) បានដល់ វត្ថុទាំងអស់សម្រាប់ ទំពាស៊ី វៀរលែងតែភោជនទាំង ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តា- ហកាលិក យាវជីវិកចេញ ហៅថា ខាទនីយ ។ ដែលហៅថា ភោជនីយ បានដល់ ភោជនទាំង ៥ យ៉ាង គឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវ អាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗវារៈដែលលេបចូលទៅ ។

[១៣២] របស់ដែលជាសន្និធិការកៈ ភិក្ខុក៏សម្គាល់ថា ជាសន្និធិការកៈមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុក៏សម្គាល់ថា មិនមែនជាសន្និធិការកៈ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ៗ ខណៈដែលលេបចូលទៅ ។ របស់ដែលមិនមែនជាសន្និធិការកៈ ភិក្ខុសម្គាល់ថា ជាសន្និធិការកៈ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុក៏សម្គាល់ថា មិនមែនជាសន្និធិការកៈ មិនត្រូវអាបត្តិឡើយ ។

[ ១៣៣ ] អាបត្តិមិនមានដល់ភិក្ខុ ដែលទុកដាក់វត្ថុជាយាវកាលិក[១] ហើយឆាន់ត្រូវតាមកំណត់កាល ដល់ភិក្ខុដែលទុកដាក់វត្ថុជាយាមកាលិក[២] ហើយឆាន់ត្រូវតាមកំណត់យាម ( គឺថ្ងៃមួយ យប់មួយ ) ដល់ភិក្ខុដែលទុកដាក់វត្ថុជាសត្តាហកាលិក[៣] ហើយឆាន់អស់ត្រឹម ៧ ថ្ងៃ ដល់ភិក្ខុដែលឆាន់

---

១- អដ្ឋកថា អាហារមានបាយជាដើម ដែលអ្នកបួសគប្បីឆាន់បានតាំងពីព្រឹកទៅដល់ថ្ងៃត្រង់ ហៅថា យាវកាលិក ។ ២- ទឹក ៨ យ៉ាង មានទឹកស្វាយជាដើម ដែលអ្នកបួសគប្បីឆាន់បានត្រឹមថ្ងៃ ១ យប់ ១ ហៅថា យាមកាលិក ។ ៣- ភេសជ្ជៈ ៥ យ៉ាង មានទឹកដោះថ្លាជាដើម ដែលអ្នកបួសគប្បីទុកឆាន់បានក្នុងរវាង ៧ ថ្ងៃ ហៅថា សត្តាហកាលិក ។

វត្ថុជាយាវជីវិក[១] ព្រោះមានហេតុដែលគួរឆាន់បានដល់ភិក្ខុធ្វត ដល់ភិក្ខុដើមបញ្ញត្តិ ។

## សិក្ខាបទទី ៨ ចប់

១- វត្ថុឯទៀតក្រៅពីកាលិកទាំង ៣ ខាងដើម ដែលអ្នកបួសគប្បីរក្សាទុក ឆាន់បានដរាបទាល់អស់មួយជីវិត ហៅថា យាវជីវិក ។

# អដ្ឋកថា
# ភោជនវគ្គទី ៤
# សន្និធិការកសិក្ខាបទ

[១៣០] ក្នុងសិក្ខាបទទី ៨ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះថេរៈជាធំដែលរួមនៅក្នុងជដិលភិក្ខុទាំង ១០០០ រូប ឈ្មោះថា វេឡដ្ឋសីសៈ ។

ពីរបទថា **អរញ្ញេ វិហរតិ** បានដល់ នៅក្នុងអាវាសមួយ ដែលជាកុដិជាទីបំពេញព្យាយាម ជិតជេតវនវិហារ ។

បទថា **សុក្ខក្ខូរំ** បានដល់ បាយមិនមានសម្ល និងម្ហូប ។ បានឮថា ព្រះថេរៈនោះ ធាន់ខាងក្នុងស្រុកហើយ ខាងក្រោយត្រាច់បិណ្ឌបាត នាំយកបាយដូច្នោះមក ។ ឯព្រះថេរៈនាំយកបាយនោះមក ព្រោះជាអ្នកប្រាថ្នាតិច មិនមែនព្រោះជាអ្នកជាប់ក្នុងបច្ច័យ ។ បានឮថា ព្រះថេរៈសម្រាកសម្រាន្តនៅដោយនិរោធសមាបត្តិអស់ ៧ ថ្ងៃ ចេញអំពីនិរោធសមាបត្តិ យកបិណ្ឌ-បាតនោះស្រួបទឹកធាន់ អង្គុយចូលសមាបត្តិតអំពី ៧ ថ្ងៃនោះទៅ ៧ ថ្ងៃទៀត លោកសម្រាកសម្រាន្តនៅអស់ ២ សប្តាហ៍ ៣ សប្តាហ៍ ៤ សប្តាហ៍ ខ្លះ ដោយប្រការយ៉ាងនេះ ទើបចូលកាន់ស្រុកដើម្បីបិណ្ឌបាត ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលថា យូរៗ ទើបលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។

បទថា **កា ការណា កិរិយា** ( ទាំង ៣ នេះ ) ដោយអត្ថ ដូចគ្នានោះឯង ។ ការធ្វើការសន្សំមានដល់ខាទនីយ និងភោជនីយនោះ ដូច្នោះ ទើប

*ឈ្មោះថា សន្និធិការ ។ សន្និធិការនោះឯង ឈ្មោះថា សន្និធិការកៈ ។ សេចក្ដីថា សន្និធិកិរិយា ( ការធ្វើការសន្សំ ) ។ ពាក្យថា សន្និធិការកៈនោះ ជាឈ្មោះ ( នៃខាទនីយភោជនីយ ) ដែលភិក្ខុទទួលប្រគេនទុកឲ្យកន្លងរាត្រី ១ ដោយហេតុនោះឯង ទើបព្រះឧបាលីពោលទុកក្នុងបទភាជនៈនៃបទថា* **សន្និធិការកំ** *នោះថា ដែលភិក្ខុទទួលប្រគេនក្នុងថ្ងៃនេះ ទំពាស៊ីក្នុងថ្ងៃដទៃ ឈ្មោះថា* **សន្និធិការក** ។

## អធិប្បាយ
## បទភាជនីយនៃសន្និធិការកសិក្ខាបទ

[១៣២] *បទថា* **បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស** *សេចក្ដីថា កាលភិក្ខុទទួលយាវកាលិក ឬយាមកាលិកឯណាមួយ ដែលធ្វើសន្និធិយ៉ាងនេះ ដោយបំណងនឹងទំពាស៊ី ត្រូវទុក្កដ ព្រោះទទួលប្រគេន ។ តែកាលទំពាស៊ី ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ម៉ាត់ ។ បើបាត្រលាងមិនស្អាត កាលស្ទាបដោយម្រាមដៃ ស្នាមប្រាកដ រំអៀអាហារជ្រាបចូលទៅក្នុងចន្លោះថ្នេរនៃបាត្រដែលមានថ្នេរ រំអៀអាហារនោះ កាលរោលលើភ្លើងក្ដៅឲ្យក្ដៅ រមែងជ្រាបចេញក្ដី ទទួលបបរក្ដៅ នឹងប្រាកដក្ដី ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលឆាន់ក្នុងបាត្រដូច្នោះ ក្នុងថ្ងៃរះឡើង ព្រោះដូច្នោះ ភិក្ខុគប្បីលាងបាត្រ ចាក់ទឹកចូលទៅក្នុងបាត្រនោះក្ដី ស្ទាបដោយដៃក្ដី ទើបដឹងបានថា មិនមានរំអិលអាហារ បើមានរំអិលអាហារលើទឹកក្ដី ស្នាមម្រាមដៃប្រាកដក្នុងបាត្រក្ដី បាត្រឈ្មោះ*

ថា លាងមិនស្អាត ។ តែក្នុងបាត្រ មានពណ៌ប្រេង ស្នាមប្រាមដៃរមែង ប្រាកដ ស្នាមប្រាមដៃនោះ ជាអព្វោហារិក ។ ភិក្ខុទាំងឡាយមិនសោកស្តាយ លះបង់ភោជនណា ឲ្យដល់សាមណេរ បើសាមណេរទុកភោជននោះប្រគេន ដល់ភិក្ខុ គួរគ្រប់អន្ទើ ។ តែដែលខ្លួនឯងទទួលប្រគេនហើយ មិនលះបង់ជា មុន រមែងមិនគួរក្នុងថ្ងៃស្អែក ។ ពិតហើយ កាលភិក្ខុនោះទំពាស៊ីបាយ មួយគ្រាប់អំពីភោជនដែលមិនលះបង់នោះ ត្រូវអាបត្តិបាចិត្តិយដូចគ្នា ។

បណ្តាសាច់ដែលជាអកប្បិយ ក្នុងសាច់មនុស្ស ជាបាចិត្តិយ និង ថុល្លច្ច័យ ក្នុងសាច់ដ៏សេស ជាបាចិត្តិយ និងទុក្កដ ។ កាលទំពាស៊ីយាម-កាលិក ក្នុងកាលមានហេតុ ត្រូវអាបត្តិបាចិត្តិយ ។ កាលទំពាស៊ីដើម្បី ប្រយោជន៍ជាអាហារ ត្រូវអាបត្តិបាចិត្តិយ និងទុក្កដ ។ បើភិក្ខុជាអ្នកហាម ភត្ត ទំពាស៊ីភោជនដែលមិនបានធ្វើឲ្យជាសំណល់ ក្នុងអាមិសតាមប្រក្រតី ត្រូវអាបត្តិបាចិត្តិយ ២ ។ ក្នុងសាច់មនុស្សត្រូវបាចិត្តិយ ២ និងថុល្លច្ច័យ ១ ក្នុងអកប្បិយមំសៈដ៏សេស ជាអាបត្តិបាចិត្តិយ និងទុក្កដ ។ កាលទំពាស៊ី យាមកាលិកតាមមាត់ ដែលមានអាមិស កាលមានហេតុ ត្រូវអាបត្តិបាចិត្តិយ ២ ។ ក្នុងមាត់មិនមានអាមិស ត្រូវបាចិត្តិយ ១ ប៉ុណ្ណោះ ។ កាលទំពាស៊ី ដើម្បីប្រយោជន៍ជាអាហារ ទុក្កដបន្ថែមឡើងសូម្បីក្នុងវិកប្បទាំង ២ ។ បើ ភិក្ខុទំពាស៊ីក្នុងវេលាវិកាល ក្នុងភោជនតាមប្រក្រតី ត្រូវអាបត្តិបាចិត្តិយ ២ ព្រោះសន្និធិជាបច្ច័យ ១ ព្រោះវិកាលជាបច្ច័យ ១ ។ ក្នុងអកប្បិយមំសៈ ថុល្លច្ច័យ និងទុក្កដបន្ថែមឡើង ។ ក្នុងពួកយាមកាលិក មិនត្រូវអាបត្តិ ព្រោះ

*ឆាន់ក្នុងវិកាលជាបច្ច័យ ។ តែមិនជាអាបត្តិក្នុងវិកប្បគ្រប់អន្ទើក្នុងវិកាល ព្រោះការមិនជារបស់សល់ ក្នុងយាមកាលិកជាបច្ច័យ ។*

*បទថា* **សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ** *សេចក្តីថា កាលភិក្ខុទទួលប្រគេនដើម្បីប្រយោជន៍ជាអាហារ ត្រូវទុក្កដ ព្រោះការទទួលប្រគេនជាបច្ច័យ ក្នុងដំណាក់កាលទី ១ ។ តែកាលទំពាស៊ី បើជារបស់មិនមានអាមិស ត្រូវទុក្កដគ្រប់ៗ ម៉ាត់ ។ បើសត្តាហកាលិក យាវជីវិក លាយដោយអាមិស ជារបស់ដែលភិក្ខុទទួលប្រគេនរក្សាទុក ត្រូវអាបត្តិបាចិត្តិយតាមវត្ថុពិត ។*

## អនាបត្តិនៃសន្និធិការកសិក្ខាបទ

*[ ១៣៣ ] ក្នុងបទថា* **អនាបត្តិ យាវកាលិកំ** *ជាដើម មានវិនិច្ឆ័យថា ខាទនីយ ភោជនីយ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងពង្រីកសេចក្តីទុកហើយ ក្នុងវិកាលភោជនសិក្ខាបទ ហៅថា យាវកាលិក ព្រោះជារបស់ដែលភិក្ខុគប្បីឆាន់បានមួយរយៈ គឺត្រឹមថ្ងៃត្រង់ ។ ទឹកបានៈ ៨ យ៉ាង និងពួកអនុលោមបានៈ ហៅថា* **យាមកាលិក** *ដោយអត្ថថា មានវេលាមួយរយៈក្នុងយាម ព្រោះជារបស់ដែលភិក្ខុគប្បីឆាន់បាន រហូតអស់យាម គឺបច្ឆិមយាមនៃរាត្រី ។ ភេសជ្ជៈ ៥ យ៉ាង មានសប្បិជាដើម ហៅថា* **សត្តាហកាលិក** *ដោយអត្ថថា មានរយៈពេល ៧ ថ្ងៃ ព្រោះជារបស់ដែលភិក្ខុរក្សាទុកបានដល់ទៅ ៧ ថ្ងៃ កាលិកទាំងអស់ដ៏សេស វៀរទឹកចេញ ហៅថា* **យាវជីវិក** *ព្រោះជារបស់ដែលភិក្ខុគប្បីរក្សាទុកឆាន់បានរហូតអស់ជីវិត*

កាលមានហេតុ ។

បណ្តាកាលិកទាំងនោះ ភិក្ខុទុកយាវកាលិកដែលទទួលប្រគេនក្នុងវេលាអរុណរះ ទុកឆាន់បានរហូតដល់ ដរាបកាលវេលាមិនទាន់កន្លងហួសទៅ ឆាន់យាមកាលិកបាន រហូតថ្ងៃមួយ យប់មួយ ឆាន់សត្តាហកាលិកបាន ៧ រាត្រី ឆាន់យាវជីវិកក្រៅពីនេះបាន រហូតអស់ជីវិត កាលមានហេតុ ជាអនាបត្តិ ។ បទដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

តែក្នុងឋានៈនេះ ក្នុងអដ្ឋកថាទាំងឡាយ លោកពោលបានកថា កប្បិយានុលោមកថា កថាមានជាដើមថា យាមកាលិក និងយាវកាលិកលាយគ្នា គួរ ឬមិនគួរ និងកប្បិយភូមិកថាទុកពិស្តារហើយ ។ ខ្ញុំនឹងពោលកថានោះ ក្នុងអាគតដ្ឋាននោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតឡើងតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សន្និធិការកសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ១៣៤ ] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ពួក ឆព្វគ្គិយភិក្ខុសូមភោជនដ៏ឧត្តមទាំងឡាយ មកដើម្បីប្រយោជន៍ដល់ខ្លួន ហើយ ឆាន់ ។ ពួកមនុស្សពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូន ចៅព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយ ដើម្បី ប្រយោជន៍ដល់ខ្លួន ហើយឆាន់សោះ អ្នកណាមួយមិនគាប់ចិត្ត នឹងភោជន ដែលសម្បូរ អ្នកណាមួយមិនចូលចិត្តនឹងភោជនដែលមានរសឆ្ងាញ់ ។ ភិក្ខុ ទាំងឡាយបានឮពួកមនុស្សទាំងនោះ កំពុងពោលទោសតិះដៀល បន្តុះបង្អាប់ ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមនឹងសូម ភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ដូច្នោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយសូម ភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយក៏នាំគ្នាឆាន់ ពិត មែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលពួកបុរសសោះសូន្យ អ្នក ទាំងឡាយមិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ ខ្លួន ហើយឆាន់ដូច្នេះទេ នែពួកបុរសសោះសូន្យ អំពើនេះមិនមែននាំឲ្យជ្រះ

ថ្វាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះដូចម្តេច ភោជនដ៏ឧត្តមទាំងនោះ គឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយ សូមភោជនដ៏ឧត្តមទាំងឡាយ មានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ១៣៥ ] សម័យនោះឯង ភិក្ខុទាំងឡាយមានជំងឺ ។ ពួកភិក្ខុអ្នកសួរជំងឺបាននិយាយពាក្យនេះនឹងភិក្ខុឈឺទាំងឡាយថា ម្នាលអាវុសោ លោកអាចអត់ទ្រាំបានឬទេ អាចប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុឈឺឆ្លើយថា ម្នាលអាវុសោ ក្នុងកាលមុន យើងទាំងឡាយបានសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ព្រោះហេតុនោះ ទើបយើងទាំងឡាយមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ យើងទាំងឡាយខ្លាចក្រែង មិនហ៊ានសូមទៀត ទើបសេចក្តីមិនសប្បាយមានដល់យើងទាំងឡាយដោយហេតុនោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺ សូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បី

ប្រយោជន៍ដល់ខ្លួន ហើយឆាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ ដូចម្តេច ភោជនដ៏ឧត្តមទាំងនោះ គឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយគ្មានជំងឺសូមភោជនដ៏ឧត្តមទាំងឡាយ មានសភាពយ៉ាងនេះដើម្បី ប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។

[ ១៣៦ ] ត្រង់ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ ឧត្តមទាំងនោះ គឺ ទឹកដោះថ្លារបស់គោក្តី ទឹកដោះថ្លារបស់ពពែក្តី ទឹកដោះថ្លា របស់ក្របីក្តី ហៅថា ទឹកដោះថ្លា ឬសប្បិ និងសាច់របស់ពួកសត្វណាដ៏គួរ ( ដល់វិនយប្បញ្ញត្ត ) ទឹកដោះថ្លារបស់ពួកសត្វនោះ ហៅថា ទឹកដោះថ្លា ឬសប្បិ ។ ទឹកដោះខាប់របស់សត្វអម្បាលនោះឯង ហៅថា ទឹកដោះខាប់ ឬ នវនីត ។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វង និងប្រេង គឺ ខ្លាញ់រាវ ហៅថា ប្រេង ។ ទឹកផ្អែមរបស់មេឃ្មុំ ហៅថា ទឹកឃ្មុំ ។ ទឹកផ្អែម ដែលកើតអំពីអំពៅ ហៅថា ទឹកអំពៅ ឬស្ករអំពៅ ។ សត្វដែលត្រាច់ទៅ ក្នុងទឹក ហៅថា ត្រី ឬមច្ឆជាតិ ។ សាច់នៃពួកសត្វណា ក៏គួរ ( ដល់ វិនយប្បញ្ញត្ត ) សាច់នៃពួកសត្វទាំងនោះ ហៅថា សាច់ ឬមំសៈ ។ ទឹកដោះ ស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់ក្របីក្តី ហៅថា ទឹកដោះស្រស់ ឬខីរៈ សាច់របស់ពួកសត្វណាដ៏គួរ ( ដល់វិនយ- ប្បញ្ញត្ត ) ទឹកដោះស្រស់របស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះស្រស់

ឬទិរៈ ។ ទឹកដោះជូររបស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះជូរ ឬទធិ ។

[១៣៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក សិក្ខាបទ ។ ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយ មានសភាពយ៉ាងនេះ គឺ ភោជនដ៏ថ្លៃថ្លាទាំងឡាយ មានសភាពដូច្នោះ ។ ភិក្ខុណាវៀរភោជនដ៏ឧត្តម ទាំងឡាយ ហើយនៅជាសប្បាយបាន ភិក្ខុនោះ ហៅថា គ្មានជំងឺ ។ ភិក្ខុ ណា វៀរចាកភោជនដ៏ឧត្តមទាំងឡាយហើយ នៅសប្បាយមិនបាន ភិក្ខុនោះ ហៅថា មានជំងឺ ។ ភិក្ខុគ្មានជំងឺសូមភោជនទាំងនោះ ដើម្បីប្រយោជន៍ដល់ ខ្លួន ត្រូវអាបត្តិទុក្កដពេលប្រយោគ ។ ភិក្ខុទទួលដោយតាំងចិត្តថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វារៈដែលលេបចូលទៅ ។

[ ១៣៨ ] ខ្លួនមិនឈឺ ភិក្ខុសម្គាល់ថា ខ្លួនមិនឈឺ ហើយសូម ភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិ បាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយសូមភោជនដ៏ឧត្តម ទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុសម្គាល់ថា ខ្លួនឈឺ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនឈឺ ភិក្ខុ សម្គាល់ថា ខ្លួនមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុសម្គាល់ថា ខ្លួនឈឺ មិនត្រូវអាបត្តិ ។

[១៣៩] អាបត្តិមិនមានដល់ភិក្ខុឈឺ ដល់ភិក្ខុដែលមានជំងឺ ហើយសូម

លុះសូមបានមកក៏បាត់ជំងឺនោះ ហើយឆាន់ ដល់ភិក្ខុដែលឆាន់ភោជនដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកញាតិ ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកជនដែលបានបវារណា ដល់ភិក្ខុដែលសូមដើម្បីប្រយោជន៍ដល់អ្នកឯទៀត ដល់ភិក្ខុដែលឆាន់ភោជនដែលកើតដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា
# ភោជនវគ្គទី ៤
# បណីតភោជនសិក្ខាបទ

[ ១៣៤ ] ក្នុងសិក្ខាបទទី ៩ មានវិនិច្ឆ័យដូច្នេះ បទថា **បណីត-ភោជនានិ** បានដល់ ភោជនដែលល្អប្រណីត ។

បទថា **កស្ស សម្បន្នំ ន មនាបំ** បានដល់ ភោជនដែលប្រកបដោយគុណសម្បត្តិ បុគ្គលណានឹងមិនពេញចិត្ត ។

បទថា **សាទុំ** ប្រែថា មានរសឆ្ងាញ់ ។

[ ១៣៥ ] ក្នុងបទថា **យោ បន ភិក្ខុ ឯវរូបានិ បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ** នេះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុសូមភោជនដែលល្អសុទ្ធៗ មានសប្បិជាដើមមកឆាន់ មិនត្រូវបាចិត្តិយ ។ ត្រូវទុក្កដ ព្រោះសូមសម្ល និងសូមបាយ ក្នុងពួកសេក្ខិយវត្ត ។ តែភិក្ខុដែលសូមភោជនល្អ ដែលលាយជាមួយបាយមកឆាន់ បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិបាចិត្តិយ ។

ក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះថា ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគមិនត្រាស់ថា **បណីតានិ** ត្រាស់ក្នុងសូត្រថា **បណីត-ភោជនានិ** ។ ពិតហើយ កាលទ្រង់ត្រាស់ថា **បណីតានិ** រមែងសង្គ្រោះយកសប្បិជាដើមចូលផង តែបើត្រាស់ថា **បណីតភោជនានិ** អត្ថរមែងប្រាកដដូច្នេះថា ភោជនដែលកើតអំពីធញ្ញជាតិ ៧ ប្រការ លាយដោយរបស់

ប្រណីត ឈ្មោះថា បណីតភោជន ។

[១៣៧] ឥឡូវនេះ ក្នុងបទថា **វិញ្ញាបេតិ បយោគេ ទុក្កដំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា កាលភិក្ខុសូមថា អ្នកចូរឲ្យភត្ត និងសប្បិ ចូររោយសប្បិឲ្យ ចូរធ្វើឲ្យលាយជាមួយសប្បិ ហើយឲ្យ ចូរឲ្យសប្បិ ចូរឲ្យសប្បិនិងភត្ត ដូច្នេះ ត្រូវអាបត្តិទុក្កដ ព្រោះការហាមាត់សូម ត្រូវអាបត្តិទុក្កដព្រោះទទួលប្រគេន ត្រូវអាបត្តិបាចិត្តិយ ព្រោះទំពាស៊ី ។ តែកាលភិក្ខុពោលថា ចូរឲ្យសប្បិភត្ត ព្រោះធម្មតា សប្បិភត្ត ដូចសាលីភត្តមិនមាន ដូច្នោះបណ្ឌិត គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដ ព្រោះហាមាត់សូមសម្ល និងបាយតែម្យ៉ាង ។

បើភិក្ខុពោលថា ចូរឲ្យភត្ត និងសប្បិ តែទាយកប្រគេនភត្ត ហើយប្រគេននវនីត ខីរៈ ឬទធិ ដោយពោលថា និមន្តលោកម្ចាស់ធ្វើសប្បិឆាន់ចុះក្តី ប្រគេនមូលតម្លៃ ពោលថា និមន្តលោកម្ចាស់ទទួលសប្បិ ដោយមូលតម្លៃនេះឆាន់ចុះ ( ត្រូវអាបត្តិបាចិត្តិយ ) តាមវត្ថុនោះឯង ។

តែកាលភិក្ខុពោលថា ចូរឲ្យភត្ត និងសប្បិគោក្តី ចូរឲ្យសប្បិគោក្តី កាលសប្បិគោមិនមាន ចូរឲ្យនវនីតគោក្តី ចូរឲ្យមេគោនោះឯងក្តី ដោយន័យមុននោះឯង ទាយកពោលថា និមន្តលោកម្ចាស់ឆាន់ សប្បិអំពីមេគោនេះ ( ត្រូវអាបត្តិបាចិត្តិយ ) តាមវត្ថុដូចគ្នា ។

តែបើទាយកត្រូវភិក្ខុសូមដោយសប្បិគោ ប្រគេនដោយសប្បិពពែជាដើម ជាការខុសសង្កេត ។ ពិតហើយ កាលមានការប្រគេនយ៉ាងនេះ ទើប

ជាការដែលទាយកត្រូវភិក្ខុសូមវត្ថុមួយ បែរជាប្រគេនវត្ថុមួយទៀត ព្រោះដូច្នោះ ទើបជាអនាបត្តិ ។ សូម្បីក្នុងពាក្យថា ចូរឲ្យសប្បិពពែជាដើមក៏មានន័យដូច្នេះ ។

កាលភិក្ខុពោលថា ចូរឲ្យដោយកប្បិយសប្បិ ទាយកប្រគេនដោយអកប្បិយសប្បិ ក៏ជាការខុសសង្កេតដូចគ្នា កាលភិក្ខុពោលថា ចូរឲ្យដោយអកប្បិយសប្បិ ទាយកប្រគេនដោយកប្បិយសប្បិ ត្រូវអាបត្តិទុក្កដដូចគ្នា ទាំងក្នុងការទទួល ទាំងក្នុងការបរិភោគ ។ កាលអកប្បិយសប្បិមិនមាន ទាយក ប្រគេនដោយអកប្បិយនវនីតជាដើម តាមន័យមុននោះឯង ដោយពោលថា និមន្តលោកម្ចាស់ធ្វើសប្បិឆាន់ចុះ ឈ្មោះថា គេប្រគេនដោយអកប្បិយសប្បិដោយពិត ។

កាលភិក្ខុពោលថា ចូរឲ្យអកប្បិយសប្បិ ទាយកប្រគេនដោយកប្បិយសប្បិ ជាការខុសសង្កេតដូចគ្នា កាលពោលថា ដោយសប្បិ ទាយកប្រគេនដោយរបស់ឯណានីមួយ មាននវនីតជាដើមដ៏សេស ជាការខុសសង្កេតដូចគ្នា សូម្បីក្នុងពាក្យថា ចូរឲ្យនវនីតជាដើម ក៏មានន័យដូច្នេះដូចគ្នា ។

ពិតហើយ មានការហាមាត់សូមដោយវត្ថុណាមួយ កាលភិក្ខុបានវត្ថុនោះក្តី មូលតម្លៃនៃវត្ថុនោះក្តី រាប់ថា ជាការបានវត្ថុនោះៗ ដូចគ្នា ។ តែបើទាយកប្រគេនរបស់ដទៃដែលមកក្នុងព្រះបាលីក្តី មិនបានមកក្តី ជាការខុសសង្កេត ។ កាលភិក្ខុហាមាត់សូមដោយនវនីតជាដើមដទៃ វៀរនវនីតដែលមកក្នុងព្រះបាលីជាដើម ត្រូវអាបត្តិទុក្កដ ដូចលោកពោលទុកថា កាលភិក្ខុ

ពោលថា ចូរឲ្យសប្បិកត្ត ការហាមាត់សូមសម្ង និងបាយ ត្រូវអាបត្តិទុក្កដ ប៉ុណ្ណោះ ព្រោះសប្បិកត្ត មិនមានដូចសាលីកត្តឡើយ យ៉ាងណា សូម្បីក្នុង ពាក្យថា ចូរឲ្យនវនីតកត្តជាដើម ក៏យ៉ាងនោះ ( គឺត្រូវអាបត្តិទុក្កដប៉ុណ្ណោះ ) ដូចគ្នា ។

ពិតហើយ កាលនឹងពោលនវនីតជាដើមតែម្យ៉ាងឲ្យពិស្តារតាមលំដាប់ ( នៃនវនីត ) ក៏នឹងត្រូវពោលអត្ថនេះឯង ។ ហើយអត្ថពិស្តារនោះ បណ្ឌិត អាចដឹងបានដោយសេចក្តីសង្ខេប នឹងមានប្រយោជន៍អ្វីដោយសេចក្តីពិស្តារ ក្នុងនវនីតតែម្យ៉ាងជាដើមនោះ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា សូម្បី ក្នុងពាក្យថា ចូរឲ្យនវនីតជាដើម ក៏មានន័យនេះដូចគ្នា ។

បើភិក្ខុហាមាត់សូមក្នុងទីជាមួយគ្នាក្តី ផ្សេងគ្នាក្តី ដោយវត្ថុ មានសប្បិ ជាដើមទាំងអស់ ចាក់របស់ដែលបានហើយ ចូលក្នុងភាជនជាមួយគ្នា ធ្វើឲ្យ ជារសដូចគ្នា សូម្បីយកចុងស្បូវក្ងាំងជ្រលក់ត្រង់ចុង យកមកលិទ្ធអំពីរស នោះ ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ ៩ សមដូចព្រះមានព្រះភាគត្រាស់ ទុកក្នុងគម្ពីរបរិវារថា ភិក្ខុត្រូវអាបត្តិបាចិត្តិយទាំងអស់ ៩ ដែលមានវត្ថុផ្សេងៗ គ្នា ក្នុងខណៈមួយ មិនមុន មិនក្រោយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

[ ១៣៨ ] ក្នុងបទថា **អគិលានោ គិលានសញ្ញី** នេះ មានវិនិច្ឆ័យ ដូច្នេះថា បើភិក្ខុជាអ្នកមានសេចក្តីសម្គាល់ថា អាពាធ ហាមាត់សូមភេសជ្ជៈ ៥ ដើម្បីប្រយោជន៍ដល់ភេសជ្ជៈ ព្រះវិនយធរគប្បីកាត់អាបត្តិលោក ដោយ

មហានាមសិក្ខាបទ ។ តែកាលហាមាត់សូមបណីតភោជន ៩ យ៉ាង គប្បីកាត់អាបត្តិដោយសិក្ខាបទនេះ តែបណីតភោជន ៩ យ៉ាងនេះ ជាបាដិទេសនីយវត្ថុ សម្រាប់ពួកភិក្ខុនី ។ ព្រោះការហាមាត់សូមសម្ល និងបាយ ត្រូវអាបត្តិទុក្កដ ដែលត្រាស់ទុកក្នុងសេខិយបញ្ញត្តិប៉ុណ្ណោះដល់ភិក្ខុ និងភិក្ខុនីទាំងពីរពួក ។ បទដ៏សេសក្នុងសិក្ខាបទនេះរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៤ កើតអំពីកាយ ១ អំពីកាយ និងវាចា ១ អំពីកាយ និងចិត្ត ១ អំពីកាយវាចា និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

បណីតភោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[ ១៤០ ] កាលនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅកូដាគារសាលា ក្នុងមហាវន ក្បែរក្រុងវេសាលី ។ សម័យនោះឯង មានភិក្ខុមួយរូប ជាអ្នកប្រព្រឹត្តបង្សុកូលនូវរបស់គ្រប់យ៉ាង[១] នៅក្នុងព្រៃស្មសាន ។ ភិក្ខុនោះមិនប្រាថ្នានឹងទទួលយកវត្ថុដែលមនុស្សទាំងឡាយឲ្យឡើយ ។ ភិក្ខុនោះកាន់យកនូវសំណែនក្នុងព្រៃស្មសានខ្លះ ទៀបគល់ឈើខ្លះ ទៀបធរណីទ្វារខ្លះ ដោយខ្លួនឯង ហើយឆាន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនេះ មិនគួរបើនឹងកាន់យកសំណែនរបស់យើងទាំងឡាយដោយខ្លួនឯង ហើយឆាន់ទេ ។ ភិក្ខុជាថេរៈនេះ មានកាយធាត់ ទំនងជាស៊ីសាច់មនុស្សទេដឹង ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេនសោះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារ

---

១ - អដ្ឋកថា ភិក្ខុនោះប្រព្រឹត្តបង្សុកូលគ្រប់ជំពូក ដោយហោចទៅសូម្បីឈើស្ទន់ក៏បង្សុកូលយកដែរ ។

មាត់ ជាអាហារដែលគេមិនបានប្រគេន ( ដូច្នេះ ) ទេ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ លេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំង-ឡាយយ៉ាងនេះ ។

[ ១៨១ ] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងទឹក និងឈើស្ទន់ ។ ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកទឹក និងឈើស្ទន់ឆាន់ដោយខ្លួនឯងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ លេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់ ។

[ ១៨២ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា គេមិនបានប្រគេន គឺសំដៅយកវត្ថុដែលភិក្ខុមិនបានទទួលប្រគេន ។ ដែលហៅថា របស់ដែលគេប្រគេន គឺកាលបើទាយកឲ្យរបស់ណាដោយកាយក្តី ដោយរបស់ដែលជាប់នឹងកាយក្តី ដោយបោះឲ្យក្តី ភិក្ខុក៏ស្ថិតនៅក្នុងហត្ថបាស បានទទួល[១]ដោយកាយ ឬដោយរបស់

---

១- អដ្ឋកថា កិរិយាទទួលប្រគេន ប្រកបដោយអង្គ ៥ គឺ ១. វត្ថុដែលបុរសមានកម្លាំងយ៉ាង-

ដែលជាប់នឹងកាយ របស់នេះ ហៅថា គេប្រគេន ។ ដែលហៅថា អាហារ គឺរបស់ណាមួយ ដែលគួរលេបចូលទៅបាន វៀរលែងតែទឹក និងឈើស្ទន់ របស់នេះ ហៅថា អាហារ ។ ពាក្យថា វៀរលែងតែទឹក និងឈើស្ទន់ គឺ លើកលែងតែទឹក និងឈើស្ទន់ ។ ភិក្ខុទទួលយកដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិ បាចិត្តិយគ្រប់ៗ វារៈដែលលេបចូលទៅ ។

[១៤៣] វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុក៏សម្គាល់ថា មិនបានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសង្ស័យ ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសម្គាល់ថា បានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់ ។ វត្ថុដែលភិក្ខុបានទទួលប្រគេន ភិក្ខុសម្គាល់ថា មិនទាន់បានទទួលប្រគេន ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ ភិក្ខុសម្គាល់ថា បានទទួលប្រគេនហើយ មិនត្រូវអាបត្តិឡើយ ។

---

ល្មមលើកឡើងបាន ។ ២. អ្នកប្រគេនស្ថិតនៅក្នុងហត្ថបាស ៣. អ្នកប្រគេន បានបង្អោនខ្លួនចូលមក ។ ៤. ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តី ប្រគេន ។ ៥. ភិក្ខុទទួល វត្ថុនោះដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ។

[ ១៤៤ ] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ទឹក និងឈើស្ទន់ ដល់ភិក្ខុដែលកាន់យកថ្នាំមហាវិកត ៤ យ៉ាង[1] ដោយខ្លួនឯង ហើយឆាន់ ព្រោះមានហេតុ ហើយគ្មានកប្បិយការក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

ភោជនវគ្គទី ៤ ចប់

**ចំនួនសិក្ខាបទក្នុងភោជនវគ្គនោះមាន ១០ យ៉ាងគឺ**

| | | | |
|---|---|---|---|
| បិណ្ឌ ( សិក្ខាបទ ) | ១ | គណៈ ( សិក្ខាបទ ) | ១ |
| បរៈ ( សិក្ខាបទ ) | ១ | បូវៈ ( សិក្ខាបទ ) | ១ |
| បវារណា ( សិក្ខាបទ ) | ២ | ព្រះដ៏មានព្រះភាគពោលហើយ | |
| វិកាល ( សិក្ខាបទ ) | ១ | សន្និធិការ ( សិក្ខាបទ ) | ១ |
| បណីត ( សិក្ខាបទ ) | ១ | ទ្វារក ( សិក្ខាបទ ) | ១ |

១- មហាវិកត ៤ គឺមូត្រ ១ គូថ ១ ផេះ ១ ដី ១ ។

# អដ្ឋកថា
# ភោជនវគ្គទី ៤
# ទន្តបោណសិក្ខាបទ

[ ១៤០ ] ក្នុងសិក្ខាបទទី ១០ មានវិនិច្ឆ័យដូច្នេះ ភិក្ខុនោះ ឈ្មោះថា **សព្វបំសុកូលិក**( ជាអ្នកមានប្រក្រតីសមាទាន បង្សុកូលគ្រប់យ៉ាង ) ព្រោះអត្ថថា ភិក្ខុនោះ មានបណ្តាបច្ច័យ ៤ គ្រប់យ៉ាង ដោយហោចសូម្បីឈើស្ទន់ ក៏ជាបង្សុកូលទាំងអស់ ។ បានឮថា ភិក្ខុនោះធ្វើភាជនៈដែលគេចោលក្នុងព្រៃស្មសាននោះឯងឲ្យជាបាត្រ ធ្វើចីវរដោយចម្រៀក សំពត់ដែលគេចោលក្នុងព្រៃស្មសាននោះឯង កាន់យកគ្រែ និងតាំងដែលគេចោលក្នុងព្រៃស្មសាននោះដូចគ្នា ដើម្បីប្រើប្រាស់ ។

ជីដូន និងជីតារបស់បិតាដែលស្លាប់ទៅហើយ ហៅថា **អយ្យ** ក្នុងពាក្យថា **អយ្យវោសាដិតកានិ** នេះ ។ ខាទនីយ និងភោជនីយ ដែលគេទុកចោលក្នុងព្រៃស្មសានជាដើម មានប្រយោជន៍ដល់បុព្វបុរសទាំងនោះ ហៅថា **វោសាដិតក** ( គ្រឿងសំណែន ) បានឮថា ពួកមនុស្សបានធ្វើរបស់ដែលជាទីស្រឡាញ់នៃពួកញាតិទាំងនោះ ក្នុងវេលាដែលនៅមានជីវិតនៅឡើយ ឲ្យជាពំនូតបាយ ឧទ្ទិសដល់ពួកញាតិដែលស្លាប់ទៅហើយ សែនទុកក្នុងទីទាំងឡាយ មានឈាបនដ្ឋានជាដើមនោះ ដោយតាំងចិត្តថា សូមពួកញាតិរបស់ពួកយើងបរិភោគចុះ ។

ភិក្ខុនោះយកដុំបាយនោះមកឆាន់ មិនប្រាថ្នារបស់ដទៃ សូម្បីប្រណីត

ដែលគេប្រគេន ។ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យទាំងឡាយបាន ពោលថា កាន់យកអាហារជាគ្រឿងសែនខ្មោចអំពីឈាបនដ្ឋានខ្លះ ត្រង់គល់ ឈើខ្លះ ត្រង់ធរណីទ្វារខ្លះ មកឆាន់ឯងដូច្នេះ ។

បទថា **ថេរោ** ប្រែថា រឹងមាំ គឺរឹងប៉ឹង ។

បទថា **វណ្ណវា** ប្រែថា ធាត់ មានពាក្យអធិប្បាយថា ភិក្ខុនោះធាត់ មានរាងកាយមាំមួន ។

បីបទថា **មនុស្សមំសំ មញ្ញេ ខាទតិ** សេចក្តីថា ពួកយើងយល់ថា ភិក្ខុនោះ ជួនកាលឆាន់សាច់មនុស្ស ។ មហាជនទាំងនោះ មានការយល់ ដូច្នេះថា សេចក្តីពិត ពួកអ្នកស៊ីសាច់មនុស្ស រមែងជាបុគ្គលដូច្នេះ ។

[ ១៤១ ] ក្នុងបទថា **ឧទកទន្តបោណោ កុក្កុច្ចាយន្តិ** នេះ មានវិនិច្ឆ័យ ដូច្នេះថា ពួកភិក្ខុទាំងនោះ មិនបានសង្កេតអត្ថនៃបទថា គប្បីទំពាស៊ីអាហារ ដែលគេមិនបានឲ្យកន្លងទ្វារមាត់ចូលទៅឲ្យត្រឹមត្រូវ ទើបបាននាំគ្នារង្កៀស ។ ឯព្រះមានព្រះភាគ កាលទ្រង់ញុំាងភិក្ខុទាំងនោះឲ្យយល់ព្រមដោយអំណាច នៃរឿងតាមដែលកើតឡើងហើយ ដូចបិតាចង្អុលឲ្យពួកកូនៗ យល់ព្រម ដូច្នោះ ទើបទ្រង់តាំងអនុប្បញ្ញត្តិទុក ។

បទថា **អទិន្នំ** សេចក្តីថា គេមិនបានឲ្យដោយកាយ របស់ជាប់នឹង កាយ និងការបង្អោនឲ្យឯណាមួយ ដល់ភិក្ខុដែលទទួលដោយកាយ ឬដោយ របស់ជាប់កាយ ។ ពិតហើយ ព្រះឧបាលីសំដៅយករបស់ដែលគេមិនបានឲ្យ នេះឯង ទើបពោលទុកក្នុងបទភាជនៈថា ឈ្មោះថា របស់ដែលគេមិនបានឲ្យ

លោកហៅថា របស់មិនទាន់ទទួលប្រគេន ។ តែក្នុងទុតិយបារាជិកត្រាស់ថា ឈ្មោះថា របស់ដែលគេមិនបានឲ្យ លោកហៅទ្រព្យដែលអ្នកដទៃហួងហែង ។ ឯបទថា របស់ដែលគេឲ្យនេះ លោកលើកឡើងទុកដើម្បីសម្ដែងលក្ខណៈនៃរបស់ដែលគេមិនបានឲ្យនោះឯង ដោយអំណាចនៃន័យដែលផ្ទុយគ្នា ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃឧទកទន្តបោណសិក្ខាបទ

[ ១៤២ ] ក្នុងនិទ្ទេសនៃបទថា **ទិន្នំ** នោះ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា **កាយេន វា កាយប្បដិពទ្ធេន វា និស្សគ្គិយេន វា ទេន្តេ** បានដល់កាលអ្នកដទៃគេឲ្យយ៉ាងនេះ ( គឺឲ្យដោយកាយក្តី ដោយរបស់ជាប់កាយក្តី ដោយការបោះឲ្យក្តី ) ។

បទថា **ហត្ថបាសេ ឋិតោ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ** សេចក្តីថា បើភិក្ខុនៅក្នុងហត្ថបាស មានលក្ខណៈដូចពោលហើយខាងដើម ទទួលប្រគេនរបស់នោះ ដែលគេឲ្យយ៉ាងនោះ ដោយហោចសូម្បីធូលីរថ ដោយកាយ ឬដោយរបស់ជាប់ដោយកាយ ។ វត្ថុនោះដែលទទួលប្រគេនហើយយ៉ាងនេះ លោកហៅថា របស់ដែលគេឲ្យ ។ របស់ដែលគេលះបង់ឲ្យដោយពាក្យថា សូមលោកម្ចាស់កាន់យករបស់នេះ របស់នេះ សូមជារបស់លោកម្ចាស់ជាដើម លោកមិនហៅថា របស់ដែលគេឲ្យទេ ។

បណ្តានិទ្ទេសទាំងនោះ បទថា **កាយេន** សេចក្តីថា ដែលគេឲ្យដោយ

បណ្ដាសរីរាវយវៈ មានដៃជាដើមណាមួយ ដោយហោចសូម្បីដោយម្រាមជើង ក៏ឈ្មោះថា គេឲ្យហើយដោយកាយ ។ ក្នុងការទទួលប្រគេន ក៏មានន័យដូច្នេះឯង ។ ពិតហើយ របស់ដែលភិក្ខុទទួលប្រគេនដោយសរីរាវយវៈចំណែកណាមួយ រាប់ថា ទទួលប្រគេនហើយ ដោយកាយដូចគ្នា ។ បើគេឲ្យរបស់ដែលត្រូវធ្វើនត្ថុ ភិក្ខុអាពាធមិនអាចនត្ថុចូលក្នុងច្រមុះបានឡើយ ទទួលយកតាមមាត់បាន ( ប្រគេនតាមមាត់បាន ) ។ សេចក្ដីពិត ដោយគ្រាន់តែការដាក់ចិត្តប៉ុណ្ណោះ ជាប្រមាណក្នុងការទទួលប្រគេននេះ ។ ន័យនេះលោកពោលទុកក្នុងមហាបច្ចរី ។

បទថា **កាយប្បដិពទ្ធេន** សេចក្ដីថា របស់ដែលគេឲ្យដោយឧបករណ៍ណាមួយ បណ្ដាឧបករណ៍ មានវែកជាដើម ឈ្មោះថា គេឲ្យដោយរបស់ជាប់កាយ សូម្បីក្នុងការទទួលប្រគេន ក៏មានន័យដូច្នេះដូចគ្នា ។ របស់ដែលភិក្ខុទទួលដោយវត្ថុណាមួយ ដែលជាប់ដោយរាងកាយ មានបាត្រ និងថាសជាដើម រាប់ថា ទទួលប្រគេនដោយរបស់ជាប់ដោយកាយដូចគ្នា ។

បទថា **និស្សគ្គិយេន** សេចក្ដីថា របស់ដែលគេបោះប្រគេនឲ្យផុតអំពីកាយ និងអំពីរបស់ជាប់ដោយកាយដល់ភិក្ខុដែលនៅក្នុងហត្ថបាស ដោយកាយ ឬរបស់ជាប់ដោយកាយ ឈ្មោះថា គេប្រគេនដោយប្រយោគដែលបោះឲ្យ នេះជាការពណ៌នាតាមព្រះបាលីជាបឋម ។

## បាលីមុត្តកវិនិច្ឆ័យ

ក្នុងសិក្ខាបទនេះ គប្បីជ្រាបវិនិច្ឆ័យបាលីមុត្តកវិនិច្ឆ័យដូចតទៅនេះថា

# អង្គនៃការប្រគេន ៥ យ៉ាង

ការទទួលប្រគេន រមែងឡើងដោយអង្គ ៥ គឺរបស់ដែលត្រូវប្រគេន ល្មមបុរសមានកម្លាំងឱ្យគតកណ្តាលលើករួច ១ ហត្ថបាសប្រាកដ ( នៅក្នុងហត្ថបាស ) ១ ការបង្អោនប្រគេនប្រាកដ ( គេបង្អោនប្រគេន ) ១ ទេវតាក្តី មនុស្សក្តី តិរច្ឆានក្តី ប្រគេន ១ ភិក្ខុទទួលប្រគេនដោយកាយ ឬដោយរបស់ជាប់កាយ ១ ការទទួលប្រគេនរមែងឡើងដោយអង្គ ៥ ដោយប្រការយ៉ាងនេះ ។ ក្នុងអង្គ ៥ នោះ ហត្ថបាសនៃភិក្ខុឈរ អង្គុយ និងដេក បណ្ឌិតគប្បីជ្រាបតាមន័យដូចពោលហើយ ក្នុងបវារណាសិក្ខាបទ ។

បណ្តាអ្នកឲ្យ និងអ្នកទទួលប្រគេន មួយនៅលើអាកាស មួយទៀតនៅលើផែនដី គប្បីកំណត់ប្រមាណហត្ថបាស ត្រង់ក្បាលរបស់អ្នកនៅលើផែនដី និងអវយវៈដែលជិតជាងរបស់អ្នកឈរនៅលើអាកាស វៀរដៃដែលលាចេញដើម្បីឲ្យ ឬដើម្បីទទួល ។ បើមួយចំណែកនៅក្នុងរណ្តៅ ( អណ្តូង ) មួយចំណែកនៅមាត់រណ្តៅ ឬមួយចំណែកនៅលើដើមឈើ មួយចំណែកនៅលើផែនដី ក៏គប្បីកំណត់ប្រមាណហត្ថបាសតាមន័យ ដូចពោលហើយនោះឯង ។

បើបក្សីយកចំពុះពាំផ្កា ឬផ្លែឈើប្រគេនក្តី ដំរីយកប្រមោយចាប់ផ្កា ឬផ្លែឈើប្រគេនក្តី នៅក្នុងហត្ថបាសបែបនេះ ការទទួលប្រគេន រមែងឡើងបាន ។ បើភិក្ខុអង្គុយលើ កដំរី សូម្បីកម្ពស់ ៧ ហត្ថ ១ ចំអាម នឹងទទួលរបស់ដែលដំរីនោះប្រគេនដោយប្រមោយ ក៏គួរដូចគ្នា ។ ទាយកម្នាក់ទូលភាជនៈបាយ និងម្ហូបជាច្រើនលើក្បាល មកកាន់សម្នាក់របស់ភិក្ខុ ពោលទាំង

ឈរថា និមន្តលោកម្ចាស់ទទួលចុះ ជាបឋមការបង្អោនប្រគេនមិនប្រាកដទេ ព្រោះដូច្នោះ មិនគួរទទួល ។ បើគេបង្អោនចុះមកត្រឹមបន្តិចបន្តួច ភិក្ខុគប្បីលាដៃទទួលភាជនៈខាងក្រោម សូម្បីដោយឯកទេស ។ ដោយការទទួលត្រឹមប៉ុណ្ណេះ ភាជនៈទាំងអស់ ឈ្មោះថា ទទួលប្រគេនហើយ ។ តាំងអំពីទទួលប្រគេននោះទៅ ទោះលើកចុះក្តី រុញចេញក្តី ហើយចាប់យករបស់ដែលខ្លួនត្រូវការ គួរ ។ ឯក្នុងភាជនៈតែមួយ មានល្អី ដែលមានបាយជាដើម មិនមានពាក្យដែលគប្បីពោលឡើយ ។

សូម្បីទាយកវែកកត្តាហារទៅ បើបង្អោនអំវែកចុះប្រគេន គួរ ។ បើមានឫស្សីវែងប្រមាណ ៣០ ហត្ថ ត្រង់ចុងម្ខាងចងក្អមទឹកអំពៅព្យួរទុក ត្រង់ចុងម្ខាងចងក្អមសប្បិព្យួរទុក បើភិក្ខុទទួលប្រគេនឫស្សីនោះ ឈ្មោះថា ទទួលប្រគេនរបស់ទាំងអស់ដូចគ្នា ។ បើទាយកពោលថា និមន្តលោកម្ចាស់ទទួលទឹកអំពៅស្រស់ដែលកំពុងហូរចេញអំពីឃ្នាប ការបង្អោនចូលមកប្រគេនមិនប្រាកដ ព្រោះដូច្នោះ ទើបមិនគួរទទួល ។ តែបើគេស្រង់យកកាកចោល ហើយយកដៃជូសឡើងប្រគេន គួរ ។

បាត្រជាច្រើន គេទុកលើគ្រែក្តី លើតាំងក្តី លើកន្ទេលផែងក្តី លើស្នូកឈើក្តី លើបន្ទះក្ដារក្តី ។ ទាយកនៅក្នុងហត្ថបាសនៃភិក្ខុដែលនៅក្នុងទីណាមួយ របស់ដែលគេឲ្យក្នុងបាត្រទាំងនោះ ដែលភិក្ខុនៅក្នុងទីនោះ សូម្បីយកដៃប៉ះគ្រែជាដើម ដោយអត្ថថា ទទួលប្រគេនឈរក្តី អង្គុយក្តី ដេកក្តី ជាការទទួលប្រគេនហើយទាំងអស់ ។ បើភិក្ខុឡើងអង្គុយលើគ្រែជាដើម ដោយ

តាំងចិត្តថា អញនឹងទទួលប្រគេន ក៏គួរដូចគ្នា ។

បើទាយកដាក់បាត្រទាំងឡាយលើផែនដី យកទីប៉ោង និងទីប៉ោងនៃបាត្រទល់គ្នា របស់ដែលគេប្រគេនក្នុងបាត្រ ដែលភិក្ខុអង្គុយយកដៃ ឬម្ដូលប៉ះប៉ុណ្ណោះ ជាការទទួលប្រគេនហើយ ។ លោកពោលទុកក្នុងទីកន្ទែងខ្លះថា ការទទួលប្រគេនក្នុងបាត្រដែលគេតាំងទុកលើកន្ទេលផែងដែលធំ និងកម្រាលលើខ្នងដីជាដើម រមែងមិនឡើង ពាក្យនោះគប្បីជ្រាបថា លោកពោលសំដៅយកការកន្ទេងហួសហត្ថបាសទៅ ។ តែកាលមានហត្ថបាស ក្នុងទីណាមួយក៏គួរ ក្រៅអំពីរបស់ដែលកើតនៅជាមួយទីនោះ ។

ការទទួលប្រគេនលើស្លឹកឈូក ឬលើស្លឹកចារជាដើម ដែលកើតនៅត្រង់ទីនោះ រមែងមិនគួរ ។ ស្លឹកឈូកជាដើមនោះ មិនដល់នូវការរាប់ថា ជារបស់ជាប់កាយ ដូចក្នុងរបស់កើតជាមួយទីនោះ ការទទួលប្រគេនមិនឡើងយ៉ាងណា ក្នុងគ្រែដែលគេភ្ជាប់នៅត្រង់ជន្ទត់ឈើជាដើមក្នុងបន្ទះក្តារ ឬក្នុងថ្មដែលជាអសង្ហារិម ការទទួលប្រគេន ក៏មិនឡើងដូចគ្នា ដូច្នោះ ។ ពិតហើយគ្រែតាំងដែលភ្ជាប់នឹងគល់ជន្ទត់ជាដើមនោះ ជារបស់គួរសង្គ្រោះចូលនឹងរបស់ដែលកើតនៅទីនោះ ។

សូម្បីលើស្លឹកអំពិលជាដើម ដែលជាស្លឹកតូចៗ រាយពេញនៅលើផែនដី ការទទួលប្រគេន ក៏មិនឡើង ។ ព្រោះថា ស្លឹកអំពិលជាដើម មិនអាចនឹងតាំងទុកបានដោយល្អ ។ តែលើស្លឹកដែលធំ មានស្លឹកឈូកជាដើម ( ទទួលប្រគេន ) ឡើង ។

បើទាយកឈរហួសហត្ថបាសក្នុងទីនោះ យកវែកត្រឡោកជងវែងជួស ប្រគេន ភិក្ខុគប្បីប្រាប់ទាយកនោះថា ចូរចូលឲ្យជិត ។ ទាយកនោះមិនបាន ឮក្តី មិនអើពើក្តី ដាក់ចុះទៅក្នុងបាត្រនោះឯង ភិក្ខុគប្បីទទួលប្រគេនជាថ្មី ។ ទោះក្នុងបុគ្គលដែលឈរនៅឆ្ងាយ បោះដុំបាយទៅប្រគេន ក៏មានន័យដូច្នេះ ដូចគ្នា បើក្នុងបាត្រដែលនាំចេញមកអំពីស្រោមបាត្រ មានកម្ទេចល័ខ បើមាន ទឹក គប្បីលាងជាមុន ។ បើមិនមាន គប្បីជូតកម្ទេចល័ខក្តី ឬទទួលប្រគេន ហើយក្តី សឹមទៅបិណ្ឌបាត ។ បើត្រាច់ទៅបិណ្ឌបាត លម្អងធូលីធ្លាក់ ( ក្នុង បាត្រ ) គប្បីទទួលប្រគេនជាមុន សឹមទទួលភិក្ខា ។ តែបើមិនបានទទួល ប្រគេន ទទួល ( ភិក្ខា ) ជាវិនយទុក្កដ ។ តែជាអនាបត្តិដល់ភិក្ខុដែលទទួល ប្រគេនធូលីនោះជាថ្មី ហើយឆាន់ ។ បើភិក្ខុពោលថា ទទួលប្រគេនមុន ចូរ ប្រគេន ពួកទាយកមិនបានឮពាក្យក្តី មិនអើពើ ប្រគេនភិក្ខុជ្រុលទៅនោះឯង មិនជាវិនយទុក្កដ ។ ភិក្ខុទទួលប្រគេនជាថ្មី ហើយគប្បីទទួលភិក្ខាដទៃចុះ ។

បើខ្យល់ខ្លាំង បក់ធូលីឲ្យអណ្តែតទៅធ្លាក់អំពីទីនោះៗ ភិក្ខុមិនអាច ទទួលភិក្ខាបាន នឹងចងចិត្តទទួលដោយចិត្តបរិសុទ្ធថា អញនឹងឲ្យដល់អនុ-បសម្បន្ន គួរ ។ ត្រាច់ទៅបិណ្ឌបាតយ៉ាងនេះ ហើយត្រឡប់ទៅកាន់វិហារក្តី អាសនៈសាលាក្តី ឲ្យភិក្ខានោះដល់អនុបសម្បន្នហើយ ទោះទទួលយកភិក្ខា ដែលអនុបសម្បន្ននោះប្រគេនជាថ្មីក្តី ទោះកាន់យករបស់អនុបសម្បន្ននោះ ដោយវិស្សាសៈឆាន់ក្តីក៏បាន ។

បើភិក្ខុឲ្យបាត្រដែលមានធូលីដល់ភិក្ខុ ក្នុងវេលាត្រាច់បិណ្ឌបាត គប្បី

ប្រាប់ភិក្ខុម្ចាស់បាត្រនោះថា លោកទទួលប្រគេនបាត្រនោះ ហើយគប្បីទទួលភិក្ខា ឬគប្បីឆាន់ ។ ភិក្ខុម្ចាស់នៃបាត្រនោះគប្បីធ្វើយ៉ាងនោះ ។ បើធូលីអណ្តែតនៅខាងលើ គប្បីសិតទឹកបាយចេញ ហើយឆាន់ចំណែកដែលសល់ចុះ ។ បើធូលីលិចកប់ចូលទៅខាងក្នុង គប្បីប្រគេនជាថ្មី ។ បើមិនមានអនុបសម្បន្ន កុំលែង ( បាត្រ ) អំពីដៃឡើយ គប្បីនាំទៅក្នុងទីដែលមានអនុបសម្បន្ន ហើយទទួលប្រគេនជាថ្មី ។ ទោះយកធូលីដែលធ្លាក់ចូលក្នុងបាយដែលស្ងួតចេញ ហើយឆាន់ក៏គួរ ។ តែបើជាធូលីល្អិតច្រើន គប្បីនាំចេញមួយអន្ទើដោយបាយខាងលើក្តី គប្បីទទួលប្រគេនជាថ្មីក្តី ហើយឆាន់ចុះ ។

បើអ្នកស្រុកដាក់បបរ ឬសម្លទុកខាងមុខ ហើយកូរ តំណក់សម្លខ្លាយអំពីភាជនៈ ធ្លាក់ចូលក្នុងបាត្រ ភិក្ខុគប្បីទទួលប្រគេនបាត្រជាថ្មី ។ កាលពួកទាយកយកត្រឡោកដួសមកប្រគេន តំណក់ស្ងបៈជាដើមស្រក់អំពីត្រឡោកចូលទៅក្នុងបាត្រមុន ឈ្មោះថា ធ្លាក់ទៅដោយល្អ មិនមានទោស ព្រោះគេបង្អោនចូលមកប្រគេន ។

បើទាយកកំពុងយកពែងទឹកក្បៀរបាយចុះ ម្រេងភ្លើង ឬផេះធ្លាក់ចុះទៅអំពីពែងទឹក មិនមានទោសដូចគ្នា ព្រោះគេបង្អោនប្រគេន របស់ដែលគេកំពុងប្រគេនដល់ភិក្ខុអង្គបន្ទាប់ទៅ ខ្ទាតចេញអំពីបាត្រ ធ្លាក់ចូលក្នុងបាត្រភិក្ខុមួយរូបទៀត ជាការធ្លាក់ទៅដោយល្អ រាប់ថា ទទួលប្រគេនហើយដូចគ្នា ។

កាលទាយកគេចាត់ចែងជ្រក់ជាដើមប្រគេនដល់ភិក្ខុមួយរូប តំណក់ទឹក ( ជ្រក់ ) ខ្ទាតអំពីបន្ទៃជ្រក់ ធ្លាក់ចូលទៅក្នុងបាត្ររបស់ភិក្ខុដទៃ លោកគប្បី

ទទួលប្រគេនបាត្រជាថ្មី ។ ពួកទាយកកំពុងចាប់ខាងលើបាត្ររបស់ភិក្ខុណា កាលតំណក់ទឹកជ្រក់ធ្លាក់ចូលទៅក្នុងបាត្ររបស់ភិក្ខុនោះ មិនមានទោស ព្រោះគេបង្អោនចូលមក ដោយភាពជាអ្នកបំណងនឹងប្រគេន ។

ពួកអ្នកស្រុកប្រគេនបាត្រពេញដោយបាយាស ភិក្ខុមិនអាចចាប់ខាងក្រោមបាន ព្រោះក្តៅ ទោះចាប់ត្រង់កណ្តាប់មាត់ ក៏គួរដូចគ្នា ។ បើចាប់ហើយ នៅតែមិនអាចទ្រាំបាន គប្បីទទួលដោយជើងបាត្រ ( រង្វេលបាត្រ ) ។

ភិក្ខុដែលអង្គុយកាន់បាត្រ ដេកលក់នៅត្រង់រោងឆាន់ លោកមិនដឹងថាទាយកកំពុងនាំភោជនមកឡើយ គេប្រគេនក៏មិនដឹង ភោជនរាប់ថា មិនទាន់បានប្រគេន ។ តែបើលោកជាអ្នកអង្គុយតាំងចិត្តទុក ( អំពីខាងដើម ) គួរ ។ បើលោកដកដៃអំពីជើងបាត្រ ហើយយកជើងត្បៀតទុក ដេកលក់ទៅ សមគួរដូចគ្នា ។ តែកាលលោកយកជើងជាន់ជើងបាត្រទុក ទទួលប្រគេន បើមិនទាន់លក់ ក៏ជាការទទួលប្រគេនដោយមិនអើពើ ព្រោះដូច្នោះ ទើបមិនគួរធ្វើ ។

អាចារ្យពួកខ្លះពោលថា ការទទួលប្រគេនដោយជើងបាត្រយ៉ាងនេះឈ្មោះថា ជាការទទួលប្រគេនដោយរបស់ដែលជាប់នឹងបាត្រ ដែលជាប់ដោយកាយ ព្រោះដូច្នោះ ទើបមិនគួរ ។ ពាក្យនោះ គ្រាន់តែជាពាក្យប៉ុណ្ណោះ តែដោយអត្ថទាំងអស់នោះ ក៏ជារបស់ជាប់ដោយកាយទាំងអស់ សូម្បីក្នុងកាយសំសគ្គសិក្ខាបទ ក៏បានសម្តែងន័យនេះទុកហើយ ។ តែបើច្បាមយករបស់ដែលធ្លាក់ដែលគេកំពុងប្រគេនដល់ភិក្ខុ យកមកឆាន់ឯងក៏គួរ ។

ក្នុងការចាប់យករបស់ដែលធ្លាក់ឆាន់នោះ មានសូត្រដែលជាគ្រឿង

សាធកៈដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ គ្រាប់បាយណាដែលគេកំពុងឲ្យ ហើយធ្លាក់ចុះ តថាគតអនុញ្ញាតឲ្យភិក្ខុរើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា គ្រាប់បាយនោះទាយកគេលះ គឺប្រគេនរួចស្រេចហើយ ។ ឯសូត្រនេះមានអត្ថគួរអធិប្បាយ ព្រោះដូច្នោះ ក្នុងសូត្រនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា របស់ណាដែលទាយកកំពុងប្រគេនជ្រុះអំពីដៃរបស់អ្នកប្រគេន ធ្លាក់ទៅលើផែនដីដែលស្អាតក្តី លើស្លឹកឈូក សំពត់ កន្ទេលផែងជាដើមក្តី របស់នោះទោះរើសឡើងមកឆាន់ឯងក៏គួរ ។ តែរបស់ណាធ្លាក់ទៅលើផែនដីដែលមានលម្អងធូលី របស់នោះគប្បីជូត ឬលាងធូលីចេញហើយ ឬទទួលប្រគេនហើយឆាន់ចុះ ។ បើរបស់រមៀលទៅកាន់សម្នាក់របស់ភិក្ខុដទៃ បើភិក្ខុម្ចាស់របស់នោះឲ្យនាំយកមកវិញ ក៏គួរ បើលោកពោលនឹងភិក្ខុនោះថា សូមលោកម្ចាស់ឆាន់ចុះ ទោះភិក្ខុនោះឆាន់ ក៏គួរ ។ តែបើភិក្ខុនោះ ម្ចាស់របស់លោកមិនបានប្រាប់ មិនគួរទទួល ។

ក្នុងកុរុន្ទីពោលថា ទោះមិនបានទទួលពាក្យប្រាប់ ភិក្ខុទទួលដោយតាំងចិត្តថា នឹងប្រគេនភិក្ខុម្ចាស់របស់ក៏គួរ ។

សួរថា ព្រោះហេតុអ្វី ទើបរបស់នោះមិនគួរដល់ភិក្ខុក្រៅពីនេះទទួល ឆ្លើយថា ព្រោះព្រះមានព្រះភាគទ្រង់មិនបានអនុញ្ញាតទុក ។

ពិតហើយ ព្រះមានព្រះភាគកាលត្រាស់ថា តថាគតអនុញ្ញាតឲ្យភិក្ខុរើសរបស់ឆាន់ឯងបាន ដូច្នេះ ក៏ទ្រង់អនុញ្ញាតដល់ភិក្ខុដែលគេកំពុងប្រគេន

របស់ដែលភ្លាត់ធ្លាក់ទៅនោះប៉ុណ្ណោះ ឲ្យរើសយករបស់នោះ សូម្បីមិនបាន ទទួលប្រគេនក៏ឆាន់បាន ។ តែដោយពាក្យថា ម្នាលភិក្ខុទាំងឡាយ ព្រោះវត្ថុ នោះ ពួកទាយកលះបង់ គឺឲ្យហើយ ទើបឈ្មោះថា ទ្រង់សម្ដែងភាពមិន មែនជារបស់អ្នកដទៃក្នុងព្រះតម្រាស់នេះ ព្រោះដូច្នោះ ភិក្ខុដទៃរើសឆាន់ឯង ទើបមិនគួរ តែសមគួរ ព្រោះការប្រើរបស់ភិក្ខុដែលជាម្ចាស់នៃរបស់នោះ ។ សេចក្ដីថា នេះជាអធិប្បាយក្នុងបទថា **អនុជានាមិ ភិក្ខវេ** ជាដើមនេះ ។

ព្រោះរបស់ដែលរអិលធ្លាក់នោះ ទ្រង់អនុញ្ញាតទុក ព្រោះជារបស់មិន ទាន់បានទទួលប្រគេន ដូច្នោះ ភិក្ខុមិនចាប់ពាល់របស់តាមដែលតាំងនៅនោះ ឯង យករបស់ណាមួយបិទទុក ហើយឆាន់ក្នុងថ្ងៃស្អែកឡើង ក៏គួរ មិនជា អាបត្តិ ព្រោះសន្និធិជាបច្ច័យ តែគួរទទួលប្រគេនសិន សឹមឆាន់ ។ ពិត ហើយ ព្រះមានព្រះភាគទ្រង់អនុញ្ញាតការរើសឆាន់នោះឯងដល់ភិក្ខុនោះ ចំពោះ ក្នុងថ្ងៃនោះ ក្រៅពីថ្ងៃនោះទៅ ទ្រង់មិនអនុញ្ញាត បានឮថា អត្ថនេះក៏ជា អធិប្បាយក្នុងព្រះតម្រាស់ថា **អនុជានាមិ ភិក្ខវេ** ជាដើមនេះ ។

ឥឡូវនេះ ខ្ញុំនឹងពោលអញ្ញោហារិកន័យតទៅថា ពិតហើយ កាលភិក្ខុ ទាំងឡាយកំពុងឆាន់ ធ្មេញទាំងឡាយ រមែងសឹករេចរិល ក្រចកទាំងឡាយ រមែងសឹក ពណ៌ ( សម្បុរ ) របស់បាត្ររមែងសាក ទាំងអស់ជាអញ្ញោ- ហារិក ។ កាលភិក្ខុសកអំពៅជាដើមដោយកាំបិត ប្រេះរមែងប្រាកដ ប្រេះនោះ ធម្មតាជារបស់កើតឡើងថ្មី គួរទទួលប្រគេនមុន សឹមឆាន់ បើភិក្ខុលាង កាំបិតមុន ហើយសឹមសក ប្រេះមិនប្រាកដ មានត្រឹមតែក្លិនលោហៈ ក្លិន

លោហៈនោះជាអព្ពោហារិក ។ សូម្បីក្នុងប្រភេទរបស់ដែលពុះ ដោយកាំបិតតូច ដែលពួកភិក្ខុរក្សាទុក ក៏មានន័យដូច្នេះឯង ។ ពិតហើយ ភិក្ខុទាំង-ឡាយ ទោះទុកកាំបិតនោះ ដើម្បីប្រើប្រាស់ ក៏ទេ ដូច្នេះ ។

កាលភិក្ខុទាំងឡាយបុក ឬកិនទូវថ្នាំ មានថ្នាំឫសឈើជាដើម ត្បូងត្បាល់ខាងក្រោម និងត្បូងត្បាល់ខាងលើ ត្បាល់ និងអង្រែជាដើម រមែងមានការសឹកទៅ ។ ភិក្ខុទាំងឡាយនឹងដុតកាំបិតដែលរក្សាទុក ហើយដាក់ចុះក្នុងតក្កៈក្តី ខីរៈក្តី ដើមប្រយោជន៍ជាថ្នាំ ពណ៌ខៀវរមែងប្រាកដក្នុងតក្កៈ ឬខីរៈនោះ ។ មានវិនិច្ឆ័យដូចដែលពោលហើយ ក្នុងកាំបិតតូចនោះឯង ។ ឯក្នុងតក្កៈជៅជាដើម មិនគួរពន្លិចកាំបិតដែលរក្សាទុកចូលទៅក្នុងដោយខ្លួនឯង ។ បើភិក្ខុពន្លិចចូលទៅ រមែងមិនផុតពីសាមបក្ក ( ចម្អិនឯង ) ។

កាលភិក្ខុត្រាច់បិណ្ឌបាត ក្នុងកាលភ្លៀងធ្លាក់ ទឹកកខ្វក់ស្រក់អំពីខ្លួន ឬអំពីចីវរចូលក្នុងបាត្រ គប្បីទទួលប្រគេនបាត្រនោះជាថ្មី ។ សូម្បីតំណក់ទឹកដែលធ្លាក់ចូល កាលភិក្ខុកំពុងឆាន់ ត្រង់គល់ឈើជាដើម ក៏មានន័យនេះដូចគ្នា ។ បើភ្លៀងធ្លាក់រហូត ៧ ថ្ងៃ ជាទឹកបរិសុទ្ធ ឬទឹកភ្លៀងដែលធ្លាក់ក្នុងទីវាល គួរ ។

ភិក្ខុកាលឲ្យបាយដល់សាមណេរ គប្បីឲ្យកុំពាល់ត្រូវបាយដែលនៅក្នុងបាត្ររបស់សាមណេរនោះឡើយ គប្បីទទួលប្រគេនបាត្ររបស់សាមណេរនោះ ។ កាលភិក្ខុពាល់ត្រូវបាយក្នុងបាត្រដែលមិនបានទទួលប្រគេន ហើយចាប់បាយក្នុងបាត្ររបស់ខ្លួនទៀត បាយជាឧគ្គហិត ( ប៉ះពាល់របស់មិនទាន់

ប្រគេន ) ។ តែបើភិក្ខុជាអ្នកមានបំណងនឹងឲ្យ ពោលថា នែសាមណេរ អ្នកចូរនាំបាត្រមក ចូរទទួលយកបាយ ដូច្នេះ តែសាមណេរនោះបដិសេធថា ខ្ញុំគ្រប់គ្រាន់ហើយ ភិក្ខុពោលទៀតថា បាយរបស់ខ្ញុំលះដល់លោកហើយ សាមណេរនៅតែពោលថា ខ្ញុំមិនត្រូវការបាយនោះទេ ដូច្នេះ សូម្បីលះរាប់រយដងក៏ដោយ ដរាបណាបាយនៅក្នុងដៃរបស់ខ្លួន រាប់ថា ជារបស់ទទួលប្រគេនហើយ ដូច្នេះ ។

បើបាយតាំងនៅលើរង្វេលបាត្រ ភិក្ខុមិនមានការសោកស្តាយ ពោលថា លោកចូរទទួលយកទៅ ត្រូវទទួលប្រគេនជាថ្មី បើភិក្ខុមិនទាន់ដាច់អាល័យ ដាក់បាត្រទុកលើជើងទ្របាត្រ ហើយពោលនឹងសាមណេរថា ចូរលោកទទួលយកនំក្តី បាយក្តីអំពីបាត្រនេះ ដូច្នេះ សាមណេរលាងដៃហើយ សូម្បីកាន់យកទៅរាប់រយដង មិនប៉ះពាល់របស់ដែលនៅក្នុងបាត្ររបស់ខ្លួនឡើយ ដាក់ចូលក្នុងបាត្ររបស់ខ្លួនឯង មិនមានកិច្ចដែលនឹងត្រូវប្រគេនជាថ្មី តែបើសាមណេរប៉ះពាល់របស់ដែលនៅក្នុងបាត្ររបស់ខ្លួន ចាប់យកចេញអំពីបាត្រនោះ របស់នោះរមែងលាយជាមួយរបស់សាមណេរ គប្បីប្រគេនជាថ្មី ។

តែកេចិអាចារ្យទាំងឡាយពោលថា របស់ដែលសាមណេរចាប់យកដាច់ធ្លាក់ចូលក្នុងបាត្រនោះ គប្បីទទួលប្រគេនជាថ្មី ។ ពាក្យនោះបណ្ឌិតគប្បីជ្រាបក្នុងដុំបាយជាដើម ដែលភិក្ខុកំណត់ទុកយ៉ាងនេះថា លោកចូរចាប់យកដុំបាយមួយដុំ ចូរចាប់យកនំមួយដុំ ចូរចាប់យកចំណែកប៉ុណ្ណោះនៃស្ករអំពៅ ។ ឯក្នុងពាក្យនេះថា លោកចូរចាប់យកនំក្តី បាយក្តីអំពីបាត្រនេះ មិនមានការ

កំណត់ ព្រោះដូច្នោះ របស់ដែលធ្លាក់ចូលក្នុងបាត្ររបស់សាមណេរប៉ុណ្ណោះ ទើបដាច់ប្រគេន ។ ឯបាយដែលនៅក្នុងដៃ ( របស់សាមណេរ ) នៅជារបស់ភិក្ខុនោះឯង ដរាបណាសាមណេរមិនទាន់ប្រាប់ក្តី ភិក្ខុនៅមិនទាន់ហាមថា បានហើយក្តី ព្រោះដូច្នោះ ទើបមិនទាន់ដាច់ប្រគេន ។

បើភិក្ខុដាក់បាយចុះក្នុងភាជនៈសម្រាប់ស្ងោរបបររបស់ខ្លួនក្តី របស់ភិក្ខុទាំងឡាយក្តី ដើម្បីប្រយោជន៍ដល់ភិក្ខុសាមណេរពួកខ្លះ គប្បីពោលថា នែសាមណេរ លោកចូរដាក់ដៃទុកខាងលើភាជនៈ ហើយដួសដាក់លើដៃសាមណេរនោះ ។ របស់ដែលធ្លាក់អំពីដៃសាមណេរចូលទៅក្នុងភាជនៈ វត្ថុដែលធ្លាក់នោះ រមែងមិនធ្វើភាជនៈជាអកប្បិយក្នុងថ្ងៃស្អែក ព្រោះបាយនោះភិក្ខុលះហើយ បើភិក្ខុមិនធ្វើយ៉ាងនេះ ដួសដាក់ចូលទៅ គប្បីធ្វើភាជនៈឲ្យប្រាសចាកអាមិសដូចបាត្រ ហើយឆាន់ចុះ ។

ពួកទាយកដាក់ថ្នាំងបបរទុកហើយទៅ ។ សាមណេរតូចក៏មិនអាចឲ្យភិក្ខុទទួលប្រគេនថ្នាំងបបរនោះបាន ភិក្ខុផ្អៀងបាត្រចូលទៅ សាមណេរដាក់កថ្នាំងលើមាត់បាត្រ ហើយផ្អៀងចុះ ។ បបរដែលហូរទៅក្នុងបាត្រ ឈ្មោះថាប្រគេនហើយ ដូច្នេះ ។ ម្យ៉ាងទៀត ភិក្ខុដាក់ដៃចុះលើដី សាមណេរប្រមៀលទៅទុកលើដៃរបស់ភិក្ខុនោះ គួរ ។ ទោះក្នុងកំប្រោងនំ និងល្អិបាយ និងបាច់អំពៅជាដើម ក៏មានន័យនេះដូចគ្នា ។ បើសាមណេរ ២-៣ រូប ជួយគ្នាប្រគេនភារៈ ( របស់ធ្ងន់ ) ដែលគួរប្រគេនបានក្តី ភិក្ខុ ២-៣ រូបជួយគ្នាទទួលរបស់ដែលមនុស្សមានកម្លាំងរឹងមាំម្នាក់លើកឡើងប្រគេន គួរ ។

# អធិប្បាយ ឧគ្គហិតវគ្គ

ជនទាំងឡាយ ព្យួរក្អមប្រេងក្តី ថ្នាំងទឹកអំពៅក្តី ទុកត្រង់ជើងគ្រែ ឬតាំងភិក្ខុអង្គុយលើគ្រែក្តី លើតាំងក្តី គួរ ។ ប្រេងជាដើមនោះ មិនឈ្មោះថាជាឧគ្គហិតឡើយ ។ ថ្នាំងប្រេងពីរថ្នាំង ជារបស់ដែលគេព្យួរទុកលើដៃកែវ ឬលើតម្កក់ ថ្នាំងលើទទួលប្រគេន ថ្នាំងក្រោមមិនទាន់ទទួលប្រគេន ភិក្ខុចាប់ថ្នាំងលើ គួរ ថ្នាំងក្រោមទទួលប្រគេនហើយ ថ្នាំងលើមិនទាន់ទទួលប្រគេន បើភិក្ខុចាប់ថ្នាំងលើ ហើយចាប់ថ្នាំងក្រោម ថ្នាំងលើជាឧគ្គហិត ។ ខាងក្រោមគ្រែ មានកែវប្រេងមិនទាន់ទទួលប្រគេន បើភិក្ខុបោស យកអំបោសប៉ះកែវប្រេង ប្រេងនោះមិនជាឧគ្គហិត ។

ភិក្ខុតាំងចិត្តថា អញនឹងលើកយករបស់ដែលទទួលប្រគេនទុកហើយ ប្រឡាំទៅចាប់របស់ដែលមិនទាន់បានប្រគេន ដឹងហើយ ទុកវិញ ក្នុងទីដែលខ្លួនលើកមក របស់នោះមិនជាឧគ្គហិត ។ នាំចេញមកខាងក្រៅហើយ ទើបដឹង កុំទុកខាងក្រៅ គប្បីនាំត្រឡប់ចូលទៅទុកក្នុងទីដើមវិញ មិនមានទោស បើកែវប្រេងនោះ ក្នុងកាលមុនបើកទុក មិនគួរបិទ គប្បីទុកតាមប្រក្រតីពីមុន ។ បើទុកខាងក្រៅ កុំប៉ះពាល់ទៀត ។ បើភិក្ខុកំពុងចុះមកកាន់ប្រាសាទជាន់ខាងក្រោម ដឹងថាខ្លួនកំពុងកាន់ប្រេងជាដើមត្រង់កណ្តាលជណ្តើរ ព្រោះមិនមានឱកាស គប្បីនាំទៅទុកខាងលើ ឬខាងក្រោមក៏បាន ។

ផ្សិតកើតឡើងក្នុងប្រេងដែលខ្លួនទទួលប្រគេនហើយ ផង់ផ្សិតកើតឡើងលើខ្ទេះខ្ចីជាដើម ផ្សិត ឬផង់ផ្សិតនោះ ជម្មតាកើតក្នុងប្រេង និងខ្ចីនោះឯងមិនមានកិច្ចដែលត្រូវប្រគេនជាថ្មី ។ មនុស្សឡើងដើមត្នោតក្តី ដូងក្តី យក

ខ្សែសម្រូតធ្លាយត្នោតចុះមកអំពីខាងលើ ស្រែកថា និមន្តលោកម្ចាស់ទទួលចុះ កុំគប្បីទទួល ។ បើមនុស្សដៃទៃឈរលើផែនដី ចាប់ត្រង់កន្ទុយខ្សែលើកប្រគេន ទទួល គួរ ភិក្ខុឲ្យធ្វើមែកឈើធំ ដែលមានផ្លែឲ្យជាកប្បិយ ហើយទទួលប្រគេនផ្លែទាំងឡាយ ឈ្មោះថា ភិក្ខុទទួលប្រគេនហើយដូចគ្នា ។ គួរបរិភោគបានតាមសប្បាយ ។

ជនទាំងឡាយឈរខាងក្នុងរបង ហែករបងប្រគេនដើមអំពៅក្តី ផ្លែទន្លាប់ក្តី កាលបានហត្ថបាស គួរទទួល ។ បើភិក្ខុទទួលដើមអំពៅ ឬផ្លែទន្លាប់ត្រង់ប្រហោងចេញមក មិនប៉ះ ( គងលើ ) របង ទើបគួរ ។ ក្នុងដើមអំពៅ និងផ្លែទន្លាប់ដែលហុចចេញមក ត្រូវ ( គងលើរបង ) លោកមិនបានសម្តែងទោសទុកក្នុងអដ្ឋកថាទាំងឡាយ ។ តែពួកយើងយល់ថា ចាកឋានដែលដើមអំពៅជាដើមពាល់ត្រូវ ហាក់ដូចជាលើករបស់ដែលធ្លាក់ឡើងឯង ។ សូម្បីពាក្យនោះ រមែងប្រើបានក្នុងកាលរបស់ចេញទៅមិនឈប់ ដូចកណ្ឌៈដែលបោះឲ្យរមៀលទៅខាងក្រៅដែនគយ ដូច្នោះ ។

ពួកជនបោះរំលងរបងក្តី កំពែងក្តី ។ តែកំពែងមិនក្រាស់ ហត្ថបាសរមែងគ្រប់គ្រាន់ដល់បុគ្គលដែលឈរក្នុងកំពែង និងខាងក្រៅកំពែង ភិក្ខុនោះទទួលរបស់ដែលបោះឡើងកម្ពស់សូម្បីរាប់រយហត្ថ ហើយធ្លាក់ចុះមកដល់ គួរ ។

ភិក្ខុយកកបញ្ចិះសាមណេរអាពាធទៅ ។ សាមណេរឃើញផ្លែឈើតូចធំ បេះប្រគេនទាំងដែលនៅលើ-កនោះឯង ភិក្ខុគួរទទួល ។ បុគ្គលដទៃឲ្យភិក្ខុជិះកទៅ ប្រគេនផ្លែឈើដល់ភិក្ខុដែលអង្គុយនៅលើ-ក សមគួរទទួល

ដូចគ្នា ភិក្ខុកាន់មែកឈើមានផ្លែ ដើម្បីជាមួយដើរទៅ កាលកើតគំនិតបង់ឆាន់ផ្លែឈើ ទោះឲ្យអនុបសម្បន្នប្រគេនហើយ គួរ ។ ភិក្ខុឲ្យធ្វើកប្បិយមែកឈើ ដើម្បីដេញរុយ ហើយទទួលប្រគេនទុក បើមានបំណងនឹងឆាន់ ការទទួលប្រគេនខាងដើមនោះឯង អាចប្រើបាន មិនមានទោសដល់ភិក្ខុដែលទំពាស៊ី ។

ភិក្ខុដាក់កណ្ឌៈដែលគួរទទួលប្រគេនទុកលើយាន របស់ពួកអ្នកស្រុកដែលធ្វើដំណើរទៅ យានជាប់កក់ ភិក្ខុកំលោះចាប់កង់លើកឡើង គួរ របស់របរមិនឈ្មោះថា ជាឧគ្គហិត ។ ភិក្ខុដាក់របស់ដែលគួរប្រគេនទុកក្នុងទូកចែវទូកទៅក្តី ឬយកដៃកាយទៅ គួរ ។ សូម្បីក្នុងក្បូន ក៏មានន័យដូចគ្នា ។ ភិក្ខុដាក់កណ្ឌៈទុកក្នុងថាសក្តី ក្នុងកន្ទោរក្តី ក្នុងក្អមក្តី ហើយប្រើឲ្យអនុបសម្បន្នកាន់កណ្ឌៈនោះ ចាប់ដើមដៃអនុបសម្បន្នឆ្លងទឹកទៅ គួរ ។ បើថាសជាដើមមិនមាន ឲ្យអនុបសម្បន្នកាន់ហើយ ចាប់អនុបសម្បន្ននោះ ត្រង់ដើមដៃឆ្លងទៅ ក៏គួរ ។

ពួកឧបាសកប្រគេនអង្ករជាស្បៀងដើរផ្លូវដល់ពួកភិក្ខុ ដែលត្រៀមខ្លួនដើរផ្លូវ ពួកសាមណេរជួយកាន់អង្ករភិក្ខុទាំងឡាយ ហើយមិនអាចដើម្បីកាន់អង្ករចំណែកខ្លួនឯងបាន ទើបពួកភិក្ខុជួយកាន់អង្កររបស់សាមណេរទាំងនោះ សាមណេរទាំងឡាយ កាលអង្ករដែលខ្លួនកាន់អស់ហើយ យកអង្ករក្រៅពីនេះដាំបបរ រៀបចំបាត្ររបស់ភិក្ខុសាមណេរទាំងអស់ទុកតាមលំដាប់ ហើយចាក់បបរចូល សាមណេរអ្នកឈ្លាស យកបាត្ររបស់ខ្លួនប្រគេនដល់ព្រះថេរៈ បាត្ររបស់ព្រះថេរៈប្រគេនដល់ព្រះថេរៈអង្គទី ២ ផ្លាស់បាត្រគ្នាទាំងអស់

យ៉ាងនេះជាដើមរហូតគ្រប់គ្នា ។ ឈ្មោះថា ភិក្ខុទាំងអស់ឆាន់បបររបស់សាមណេរ គួរ ។ បើសាមណេរជាអ្នកមិនឈ្លាស ផ្ដើមនឹងហុតបបរក្នុងបាត្ររបស់ខ្លួនដោយខ្លួនឯងប៉ុណ្ណោះ ពួកព្រះថេរៈ គួរសូមហុតទៅតាមលំដាប់យ៉ាងនេះថា អ្នកមានអាយុ ចូរឲ្យបបររបស់លោកដល់ខ្ញុំ ដូច្នេះ ឈ្មោះថា ភិក្ខុទាំងអស់ មិនត្រូវទោស ព្រោះឧគ្គហិតជាបច្ច័យ មិនត្រូវទោស ព្រោះសន្និធិជាបច្ច័យ ។

តែក្នុងការជូរបាត្រគ្នានេះ សេចក្ដីប្លែកគ្នានៃភិក្ខុទាំងឡាយ ដែលនាំប្រេងជាដើមទៅ ដើម្បីញោមប្រុសស្រី និងនាំមែកឈើជាដើមទៅ ដើម្បីជាម្ជប់ជាដើម និងភិក្ខុដែលផ្លាស់ប្ដូរបាត្រគ្នាទាំងនេះ មិនប្រាកដ ព្រោះដូច្នោះបណ្ឌិតគប្បីពិចារណារកហេតុ ។

សាមណេរបំណាងនឹងដាំបាយ មិនអាចស្ទួយអង្ករឲ្យអស់ក្រួសខ្សាច់បាន ភិក្ខុគប្បីទទួលប្រគេនអង្ករ និងភាជនៈ ស្ទួយអង្ករឲ្យអស់ក្រួសខ្សាច់ ហើយលើកភាជនៈឡើងកាន់ជើងក្រានចុះ កុំគប្បីបង្កាត់ភ្លើង ។ ក្នុងវេលាចម្អិនត្រូវបើកមើល ទើបដឹងភាពដែលបាយជារបស់ឆ្អិនបាន ។ បើបាយឆ្អិនមិនល្អ នឹងបិទដើម្បីឲ្យឆ្អិន មិនគួរ នឹងបិទដើម្បីមិនឲ្យធូលី ឬផេះធ្លាក់ចូលទៅ គួរ ។ កាលបាយឆ្អិនហើយ នឹងលើកចុះក្ដី ឆាន់ក្ដី គួរ ។ ចាប់ពីពេលនោះទៅមិនមានកិច្ចដែលត្រូវទទួលប្រគេនជាថ្មី ។

សាមណេរអាចចម្អិនបាន តែលោកមិនមានពេល លោកបំណាងនឹងទៅទីណាមួយ ភិក្ខុទទួលប្រគេនភាជនៈ មួយអន្ទើដោយអង្ករ និងទឹកហើយ

លើកឡើងកាន់ជើងក្រាន គប្បីពោលថា លោកចូរបង្កាត់ភ្លើងឲ្យឆេះល្អ ហើយទៅចុះ ។ បន្ទាប់ពីភ្លើងឆេះល្អនោះហើយ ទោះធ្វើកិច្ចគ្រប់យ៉ាងសមគួរដោយន័យមុនដូចគ្នា ។ ភិក្ខុតាំងភាជនៈស្អាត ដាំទឹកកម្ដៅទុក ដើម្បីប្រយោជន៍ដល់បបរ គួរ ។ កាលទឹកក្ដៅហើយ សាមណេរច្រកអង្ករចូល ។ ចាប់ពីពេលនេះទៅ ភិក្ខុកុំគប្បីរុកភ្លើង ។ និងទទួលប្រគេនបបរដែលឆ្អិន ហើយហុត គួរ ។

សាមណេរដាំបបរ ភិក្ខុរពិសដៃ ចាប់ភាជនៈ ចាប់គ្របឆ្នាំង ដួសពពុះដែលផុរឡើងចោលទៅ ។ ចំពោះភិក្ខុនោះមិនគួរហុត ត្រូវអាបត្តិទុក្កដឈ្មោះទុរុបចិណ្ណ ។ បើភិក្ខុចាប់វែក ឬត្រឡោក ហើយមិនលើកឡើង ។ បបរនោះ រមែងមិនគួរដល់ភិក្ខុទាំងអស់ រមែងជាសាមបក្កផង ទុរុបចិណ្ណផង បើលើកឡើងជាឧគ្គហិតផងដែរ ។

ភិក្ខុត្រាច់បិណ្ឌបាត ដាក់បាត្រទុកលើជើងបាត្រ ។ បើភិក្ខុឡេះឡោះអង្គុយដទៃលេងនៅក្នុងទីនោះ ចាប់ប៉ះពាល់បាត្រ ចាប់ប៉ះពាល់គម្របបាត្រ ។ ភត្តដែលបានអំពីបាត្រនោះ មិនគួរចំពោះភិក្ខុឡេះឡោះនោះ ។ បើលោកលើកបាត្រឡើង ហើយទុកវិញ មិនគួរដល់ភិក្ខុទាំងអស់ ។ ភិក្ខុចាប់មែកឈើ ឬវល្លិ៍អង្រួនផ្លែដែលកើតនៅលើដើមជាដើមនោះ ផ្លែដែលបានអំពីមែកឈើ ឬវល្លិ៍នោះ មិនគួរដល់ភិក្ខុដែលអង្រួននោះដូចគ្នា ហើយលោករមែងត្រូវទុរុបចិណ្ណទុក្កដផងដែរ ។ លោកពោលទុកក្នុងមហាបច្ចរីថា ភិក្ខុទល់ដើមឈើដែលមានផ្លែ ឬចងបន្ទាទុកត្រង់ដើមឈើនោះ គួរ មិនជាទុរុបចិណ្ណទុក្កដ ។

ចំណែកភិក្ខុឃើញផ្លែឈើ មានផ្លែស្វាយជាដើមដែលជ្រុះក្នុងព្រៃ តាំង

ចិត្តថា អញនឹងឲ្យដល់សាមណេរ ហើយនាំមកឲ្យ គួរ ។ ភិក្ខុឃើញវំពានៃសីហៈជាដើម គិតថា អញនឹងឲ្យដល់សាមណេរ ទទួលប្រគេនក្តី មិនបានទទួលប្រគេនក្តី នាំមកឲ្យគួរ ។ បើអាចជម្រះវិតក្កឲ្យបរិសុទ្ធបាន សូម្បីទំពាស៊ីអាហារដែលបានមកពីវំពានៃសីហៈជាដើមនោះ ក៏គួរ មិនត្រូវទោស ព្រោះទទួលប្រគេនសាច់នៅជាបច្ច័យ និងមិនត្រូវទោស ព្រោះឧគ្គហិតជាបច្ច័យឡើយ ។

បើភិក្ខុកាន់ប្រេងជាដើមដើរទៅ ដើម្បីប្រយោជន៍ដល់មាតា និងបិតា កើតព្យាធិឡើងក្នុងកណ្តាលផ្លូវ ទោះទទួលប្រគេនវត្ថុដែលខ្លួនប្រាថ្នាអំពីប្រេងជាដើមនោះ ហើយឆាន់ គួរ ។ តែបើជារបស់ភិក្ខុទទួលប្រគេនទុកក្នុងគ្រាមុន មិនមានកិច្ចនឹងត្រូវទទួលប្រគេនជាថ្មីឡើយ ។

ភិក្ខុនាំអង្ករមកឲ្យ ដើម្បីប្រយោជន៍ដល់មាតាបិតាៗ នោះ រៀបចំចម្អិនបបរជាដើមអំពីអង្ករនោះឯងប្រគេនដល់ភិក្ខុនោះ គួរ ។ មិនមានទោស ព្រោះសន្និធិជាបច្ច័យ ឬព្រោះឧគ្គហិតជាបច្ច័យ ។ ភិក្ខុបិទគម្របដាំទឹកឲ្យក្តៅ គួរបរិភោគបានដរាបដល់អស់ ។ តែបើផេះធ្លាក់ចូលក្នុងទឹកក្តៅនេះ គួរទទួលប្រគេន ។ កាលភិក្ខុយកដង្កៀបដងវែង ចាប់កែវស្ងួប្រេង ផេះធ្លាក់ចូលទៅ កុំលែងដៃ រម្ងាស់ហើយដាក់ចុះ គប្បីទទួលប្រគេនជាថ្មី ។ បើធ្យូងក្តី ឧសក្តី ភិក្ខុទទួលប្រគេនទុកហើយ ការទទួលខាងដើមនោះឯងនៅប្រើបាន ។

ភិក្ខុទំពាអំពៅ សាមណេរពោលថា លោកម្ចាស់ឲ្យខ្ញុំខ្លះ ភិក្ខុប្រាប់ថា ចូរកាត់យកអំពីចំណែកនេះទៅ ហើយកាន់យក ក្នុងចំណែកដែលនៅសល់

មិនមានកិច្ចដែលត្រូវទទួលប្រគេនជាថ្មីឡើយ ។ សម្រាប់ភិក្ខុដែលឆាន់ស្ករអំពៅ ក៏មានន័យដូច្នេះដូចគ្នា ។ ពិតហើយ អំពៅចំណែកដែលសល់អំពីសាមណេរកាត់យកពីឱកាសដែលភិក្ខុប្រាប់ ឈ្មោះថា មិនទាន់លះ ( គឺមិនដាច់ ) ការប្រគេនឡើយ ។ ភិក្ខុកាលចែកស្ករអំពៅ ទទួលប្រគេនហើយ រៀបចំជាចំណែកៗ ។ ពួកភិក្ខុក្តី ពួកសាមណេរក្តី មកហើយ កាន់យកម្នាក់មួយចំណែកៗ ដោយការលើកយកម្តងប៉ុណ្ណោះ ចំណែកដ៏សេសអំពីភិក្ខុសាមណេរចាប់យកទៅហើយ នៅជារបស់ប្រគេនដូចដើម ( មិនទាន់ដាច់ប្រគេន ) ។ បើសាមណេរលើកឡើងហើយដាក់ចុះៗ ចំណែកដ៏សេសអំពីសាមណេរនោះ ជារបស់មិនបានទទួលប្រគេន ។

ភិក្ខុទទួលខ្សៀរ ហើយជក់ ។ មាត់ និងក ហាក់ដូចជាលាបដោយមនោសិលា ។ ទោះឆាន់យាវកាលិក បាន ។ មិនមានទោស ទាក់ទងដោយយាវជីវិក និងយាវកាលិកលាយគ្នា ។ កាលភិក្ខុអប់បាត្រ ឬស្បោរម្រ័ក្សណ៍ ផ្សែងចូលទៅតាមត្រចៀក ច្រមុះ និងមាត់ ទោះហិតផ្កាឈើ ឬផ្លែឈើ ព្រោះមានជំងឺជាបច្ច័យ គួរ ព្រោះជាអព្ពោហារិក ។

ការរើអៀងអាហារដែលឆាន់ហើយចេញមកប៉ះពិតាន ត្រឡប់ចូលទៅខាងក្នុងវិញ គួរ ព្រោះជាហេតុផុតវិស័យ ។ បើរើអៀងចេញមកដល់មាត់ ហើយលេបចូលទៅវិញ ប្រព្រឹត្តជាអាបត្តិ ព្រោះវិកាលភោជនសិក្ខាបទ ។ រសរបស់អាមិសដែលកើតនៅក្នុងចន្លោះធ្មេញចូលទៅ ( ក្នុងបំពង់ក ) ត្រូវអាបត្តិដូចគ្នា ។ បើអាមិសល្អិត រសមិនប្រាកដ ចាត់ចូលក្នុងចំណែកនៃ

អព្វោហារិក ។

ក្នុងវេលាថៃជន្យ ភិក្ខុឆាន់អាហារក្នុងទីមិនមានទឹក ខាកស្តោះទឹកមាត់ បោលទៅ ២-៣ ចំ្ងាយ (ដុំ) ហើយគប្បីទៅកាន់ទីមានទឹក ខ្ពុរមាត់ចុះ ។ មើម ទ្បីដែលទទួលប្រគេនរក្សាទុក ជារបស់ជុះ មិនមានកិច្ចដែលត្រូវទទួលប្រគេន ជាថ្មី បើមិនមានអំបិល ភិក្ខុធ្វើអំបិលដោយទឹកសមុទ្រ គួរ ។ ទឹកប្រៃដែល ភិក្ខុទទួលប្រគេន រក្សាទុក ក្លាយជាអំបិល ឬអំបិលក្លាយជាទឹក ទឹកអំពៅ ស្រស់ក្លាយជាទឹកអំពៅខាប់ក្តី ឬទឹកអំពៅខាប់ ក្លាយជាទឹកអំពៅរាវក្តី ការ ទទួលប្រគេនដើមនោះឯង នៅប្រើបាន ( គឺនៅរក្សានៅឡើយ ) ។ ទឹក សន្សើម និងព្រិល មានគតិដូចទឹកនោះឯង ។

ពួកភិក្ខុកូរទឹកឲ្យថ្លា ដោយគ្រាប់ផ្លែឈើដែលធ្វើឲ្យទឹកថ្លា ( គ្រាប់ ល្មៀង ) នៅរក្សានៅឡើយ ទឹក មានទឹកដែលកូរឲ្យថ្លាជាដើមនោះ ជា អព្វោហារិក លាយជាមួយអាមិសក៏គួរ ។ ទឹកដែលកូរឲ្យថ្លាដោយផ្លែខ្វិត ជាដើម មានគតិដូចអាមិស គួរតែក្នុងវេលាកត្តកាលប៉ុណ្ណោះ ។ ទឹកក្នុងស្រះ បោក្ខរណីជាដើម ទោះបីល្អក់ក៏គួរ តែបើកករនោះ ជាប់មាត់ ឬដៃ មិនគួរ ។ ទឹកនោះ គួរទទួលប្រគេន ហើយសឹមបរិភោគ ។ ទឹកល្អក់ក្នុងទីដែលត្រូវភ្ជួរ ក្នុងស្រែទាំងឡាយ គប្បីទទួលប្រគេន ។ បើទឹកហូរចុះអំពីជ្រោះជាដើម ហើយពេញស្ទឹង គួរ ។

ជលាល័យ មានបឹង ដែលមានដើមថ្ងាន់ជាដើម មានទឹកដែលដេរជាស ទៅដោយផ្កាឈើដែលជ្រុះអំពីដើម ។ បើរសផ្កាឈើមិនប្រាកដ មិនមានកិច្ច

ដែលចាំបាច់ប្រគេន ។ បើទឹកតិច មានរសប្រាកដ គប្បីទទួលប្រគេន ។ សូម្បីក្នុងទឹកដែលគ្របដណ្ដប់ដោយស្លឹកឈើពណ៌ខ្មៅ ក្នុងជ្រលងថ្មទាំង-ឡាយ មានញកភ្នំជាដើម ក៏ន័យនេះដូចគ្នា ។ ផ្កាទាំងឡាយ មានកេសរក្តី មានទឹកដម ( ទឹកដោះ ) ត្រង់ទងក្តី គេដាក់ចូលក្នុងក្អមទឹកផឹក គប្បីទទួលប្រគេន ។ ឬផ្កាទាំងឡាយ ភិក្ខុទទួលប្រគេនហើយ គប្បីដាក់ចូលចុះ ។ ផ្កាប្រទៀង និងផ្កាម្ទេះជារបស់ដែលគេដាក់ត្រាំទុក ទឹកគង់នៅត្រឹមតែអប់ក្លិនទឹកនោះ ជាអព្ពោហារិក គួរជាមួយនឹងអាមិស សូម្បីក្នុងថ្ងៃស្អែក ។

សាមណេរដងទឹកផឹកអំពីទឹកដែលអប់ផ្កា ដែលភិក្ខុរក្សាទុក ហើយចាក់ទឹកដ៏សេសអំពីទីដែលខ្លួនផឹកហើយចូលទៅក្នុងទឹកនោះវិញគប្បីទទួលប្រគេនជាថ្មី ។ ភិក្ខុទោះយកក្អមវែកកេសរផ្កាដែលអណ្តែតលើទឹក ក្នុងស្រះឈូកជាដើមចេញហើយ ដួសយកតែទឹក គួរ ។

ឈើស្ទន់ដែលភិក្ខុធ្វើឲ្យជាកប្បិយ ហើយទទួលប្រគេនរក្សាទុក ។ បើភិក្ខុបំណងនឹងហិតរសនៃឈើជម្រះធ្មេញនោះ ការទទួលប្រគេនខាងដើមនោះឯង សមគួរ ។ បើមិនបានទទួលប្រគេនទុក ត្រូវទទួលប្រគេន ។ កាលរសចូលទៅក្នុងបំពង់ក ក៏ជាអាបត្តិដល់ភិក្ខុដែលមិនដឹងដូចគ្នា ។ ពិតហើយសិក្ខាបទនេះ ជាអចិត្តកៈ ។

សួរថា បណ្តាមហាភូតរូប អ្វីគួរ អ្វីមិនគួរ ឆ្លើយថា ទឹកៈ គួរ ។ ទោះជាទឹកដោះស្រស់នៃសត្វ ដែលមានសាច់ជាកប្បិយក្តី ទឹកដោះស្រស់នៃសត្វដែលមានមំសៈជាអកប្បិយក្តី ភិក្ខុផឹកមិនជាអាបត្តិ ។ វត្ថុទាំងនេះ គឺ

ទឹកភ្នែក ទឹកមាត់ ទឹកសម្បោរ ទឹកមូត្រ លាមក ស្លេស្ម អាចម៍ធ្មេញ អាចម៍ភ្នែក អាចម៍ត្រចៀក ផ្កាអំបិល ( កំណកញើស ) កើតក្នុងរាងកាយ គួរគ្រប់យ៉ាង ។ បណ្ដាវត្ថុទាំងនេះ វត្ថុណាឃ្លាតចាកក្រពេញ ( របស់វា ) ហើយធ្លាក់ចូលក្នុងបាត្រក្ដី ត្រង់ដៃក្ដី វត្ថុនោះត្រូវទទួលប្រគេន ។ វត្ថុដែលនៅជាប់ក្នុងអវយវៈ ជាការទទួលប្រគេនស្រាប់ហើយពិត ។ ភិក្ខុឆាន់មធុបាយាសក្ដៅ ញើសដែលជាប់តាមម្រាមដៃ ហើយជាប់នៅត្រង់មធុបាយាសក្ដី ភិក្ខុកាលបិណ្ឌបាត ញើសហូរចេញពីដៃដល់កណ្ដាប់មាត់បាត្រ ចូលកាន់បាត្រ ។ ក្នុងបាត្រនេះ មិនមានកិច្ចដែលត្រូវទទួលប្រគេន ។ ក្នុងមហាភូតរូបដែលដុតហើយ មិនមានពាក្យពោលថា ចំណែកនេះមិនគួរ ។ តែដែលដុតមិនល្អ ( ឆេះមិនសព្វ ) មិនគួរ ។ ភិក្ខុទោះបុកឆ្អឹងមនុស្សដែលដុតល្អហើយឲ្យជាលម្អិត ហើយរោយចុះក្នុងរបស់ស៊ី គួរ ។

កាលមិនមានកប្បិយការកៈ ទោះកាន់យកថ្នាំមហាវិកតិ ៤ គឺថ្នាំពស់ចឹកឆាន់ឯងក៏គួរ ។ ក្នុងអធិការនៃថ្នាំមហាវិកតិនេះ កប្បិយការកៈ ជាមនុស្សប្រដៅក្រក្ដី ជាមនុស្សមិនអាចក្ដី រមែងតាំងនៅក្នុងចំណែកមិនមានដូចគ្នា ។ បើផេះមិនមាន ភិក្ខុគប្បីដុតឈើស្ងួតយកផេះ បើឧសមិនមាន សូម្បីកាត់ឧសស្រស់អំពីដើមឈើធ្វើផេះ ក៏គួរ ។ ថ្នាំមហាវិកតិទាំង ៤ យ៉ាងនេះ ឈ្មោះថា អនុញ្ញាតចំពោះកាល គួរតែក្នុងពេលត្រូវពស់ចឹកប៉ុណ្ណោះ ។ បទដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ កើតតាមកាយ ១ តាមកាយ និងចិត្ត ១ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ទន្តបោណសិក្ខាបទ ចប់

ភោជនវគ្គទី ៤ ចប់បរិបូណ៌

តាមវណ្ណនានុក្រម

# វិនយបិដក

## អាចេលកវគ្គ សិក្ខាបទទី ១

[១៤៥] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ គង់នៅកូដាគារសាលា ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ។ សម័យនោះឯង របស់ដែលបុគ្គលគប្បីទំពាស៊ីកើតឡើងដល់សង្ឃ ។ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរឲ្យនំដល់ពួកមនុស្សអ្នកស៊ីដែលចុះ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយៗ ក៏ឲ្យពួកមនុស្សដែលជាអ្នកស៊ីដែលអង្គុយជាជួរ ហើយក៏ឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល ) រួចឲ្យនំពីរទៅនាងបរិព្វាជិកាម្នាក់ ដោយសម្គាល់ថាឲ្យនំមួយដូចគេទាំងពួងដែរ ។ ពួកនាងបរិព្វាជិកា ( ដែលនៅ ) ជុំវិញ បាននិយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណៈនោះ ជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសម្គាល់ថា ឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ វារៈជាគម្រប់ពីរដង ព្រះអានន្ទដ៏មានអាយុឲ្យនំមួយៗ ( ដល់មនុស្សដែលជាអ្នកស៊ីដែល ) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសម្គាល់ថាឲ្យនំមួយដូចគេទាំងពួងដែរ ។ ពួកនាងបរិព្វាជិកា ( ដែលនៅ ) ជុំវិញ ក៏និយាយពាក្យនេះ នឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនជាសហាយរបស់ខ្ញុំទេ

គឺលោកសម្គាល់ថា ឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ វារៈជាគម្រប់បីជងទៀត ព្រះអានន្ទដ៏មានអាយុឲ្យនំមួយៗ ( ដល់មនុស្សដែលជាអ្នកស៊ីដែល ) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសម្គាល់ថា ឲ្យនំមួយដូចគេទាំងពួងដែរ ។ ពួកនាងបរិព្វាជិកា ( ដែលនៅ ) ជុំវិញ ក៏និយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនជាសហាយរបស់ខ្ញុំទេ គឺលោកសម្គាល់ថា ឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ពួកនាងបរិព្វាជិកាទាំងនោះ ក៏នាំគ្នានិយាយចំអកថា ( សមណៈនុ៎ះ ) សហាយឬមិនមែនសហាយ ។ ( វេលានោះ ) មានអាជីវកម្នាក់ ដើរទៅកាន់ទីដែលគេអង្គាស ឬចែក ( នំ ) ។ ( ពេលនោះ ) មានភិក្ខុមួយរូបកំពុងប្របាច់បាយលាយដោយទឹកដោះថ្លាដ៏ច្រើន ហើយក៏ឲ្យដុំបាយមួយដុំធំដល់អាជីវកនោះ ។ លំដាប់នោះ អាជីវកនោះក៏កាន់យកដុំបាយនោះ ហើយដើរទៅ ។ ( ពេលនោះ ) មានអាជីវកម្នាក់ទៀត បានពោលពាក្យនេះនឹងអាជីវកនោះថា ម្នាលអាវុសោ អ្នកឯងបានដុំបាយមកពីណា ។ អាជីវកដែលបានដុំបាយនោះ ឆ្លើយតបថា ម្នាលអាវុសោ ដុំបាយ ខ្ញុំបានមកអំពីទីដែលគេអង្គាសនៃមុណ្ឌកគហបតី ( គហបតីត្រងោល ) របស់ព្រះសមណគោតមនោះ ពួកឧបាសកបានឮពាក្យចរចានេះ នៃពួកអាជីវកនោះច្បាស់លាស់ហើយ ។ ទើបពួកឧបាសកទាំងនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះដ៏មានបុណ្យហើយ ក៏អង្គុយក្នុងទីមួយដ៏សមគួរ ។ ឧបាសក

ទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយអម្បាលនេះ ប្រាថ្នានឹងពោលទោសដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន សូមកុំឲ្យលោកម្ចាស់ទាំងឡាយឲ្យ ( វត្ថុអ្វីៗ ) ដល់ពួកតិរ្ថិយដោយដៃរបស់ខ្លួនឡើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសកទាំងនោះ ឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ។ ឯពួកឧបាសកទាំងនោះ កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់លាស់ ទ្រង់ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ទ្រង់ធ្វើធម្មីកថាដ៏ល្មមសមគួរតាមហេតុនោះដល់ពួកភិក្ខុ ហើយទ្រង់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា នៃភិក្ខុទាំង-ឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យ អំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្ដីល្អដល់សង្ឃ ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ ១ ។បេ។ ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឲ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគ ដល់អាចេលកក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

[១៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា អចេលក គឺបុគ្គលដែលបួសជាបរិព្វាជក មានកាយអាក្រាតទាំងអស់ ។ ដែលហៅថា បរិព្វាជក គឺបុរសដែលបួសជាបរិព្វាជកទាំងអស់ វៀរលែងតែភិក្ខុ និងសាមណេរចេញ ។ ដែលហៅថា បរិព្វាជិកា គឺស្រីដែលបួសជាបរិព្វាជិកាទាំងអស់ វៀរលែងតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ី គឺលើកទុកតែភោជន ៥ យ៉ាង ព្រមទាំងទឹក និងឈើស្ទន់ចេញ ក្រៅពីនេះ ហៅថា វត្ថុ ដែលបុគ្គលគួរទំពាស៊ីទាំងអស់ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរបរិភោគ បានដល់ ភោជន ៥ យ៉ាង គឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា ឲ្យ គឺភិក្ខុឲ្យដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ដោយបោះឲ្យក្តី ត្រូវអាបត្តិបាចិត្តិយ ។

[១៤៧] ជនជាតិរ្ថិយ ភិក្ខុក៏សម្គាល់ថា ជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ថិយ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ថិយ ភិក្ខុសម្គាល់ថា មិនមែនជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុឲ្យទឹក និងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។ បុគ្គលមិនមែនជាតិរ្ថិយ ភិក្ខុសម្គាល់ថា ជាតិរ្ថិយ ត្រូវ

អាបត្តិទុក្កដ ។ ជនមិនមែនជាតិរ្ថិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ជនមិនមែន ជាតិរ្ថិយ ភិក្ខុសម្គាល់ថា មិនមែនជាតិរ្ថិយ មិនត្រូវអាបត្តិឡើយ ។

[១៤៨] អាបត្តិមិនមានដល់ភិក្ខុដែលប្រើគេឲ្យឲ្យ មិនឲ្យដោយខ្លួនឯង ដល់ភិក្ខុដែលដាក់[១]វត្ថុទុកឲ្យ ដល់ភិក្ខុដែលឲ្យរបស់ជាគ្រឿងលាបខាងក្រៅ ( មានម្សៅជាដើម ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់

១- ភិក្ខុដាក់របស់ក្នុងភាជន៍ ហើយលើកយកភាជន៍នោះទៅតម្កល់ទុកលើដី ជិតតិរ្ថិយទាំងនោះ ហើយឲ្យដោយវាចា ។

# អដ្ឋកថា

# អចេលកវគ្គទី ៥

# អចេលកសិក្ខាបទ

[១៤៥] ក្នុងសិក្ខាបទទី ១ នៃអចេលកវគ្គ មានវិនិច្ឆ័យដូច្នេះ បទថា **បរិវេសនំ** ប្រែថា ទីកន្លែងអង្គាស ។ បទថា **បរិព្វាជកសមាបន្នោ** គឺចូលដល់ការបួស ។

[១៤៦] បីបទថា **ទេតិ អាបត្តិ បាចិត្តិយស្ស** សេចក្តីថា ភិក្ខុឲ្យបបរ និងបាយល្មមហុតដោយប្រយោគមួយ ត្រូវអាបត្តិបាចិត្តិយ ១ ឲ្យដាច់ជារយៈៗ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ប្រយោគ ។ សូម្បីក្នុងនំ និងបាយជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។

[១៤៧] ពីរបទថា **តិត្ថិយេ តិត្ថិយសញ្ញី** សេចក្តីថា ម្តាយក្តី ឪពុកក្តី ( របស់ភិក្ខុ ) បួសក្នុងពួកតិរ្ថិយ ។ សូម្បីភិក្ខុជាកូន កាលឲ្យដល់តិរ្ថិយទាំងនោះ ដោយសម្គាល់ថា មាតា និងបិតា ត្រូវអាបត្តិបាចិត្តិយដូចគ្នា ។

[១៤៨] បទថា **ទាបេតិ** គឺប្រើឲ្យអនុបសម្បន្នឲ្យ ។

បទថា **ឧបនិក្ខិបិត្វា ទេតិ** សេចក្តីថា ដាក់លើភាជនៈដែលមានសភាពបែបនោះហើយ ដាក់ភាជនៈនោះឲ្យលើផែនដី ជិតតិរ្ថិយទាំងនោះក្តី ប្រើឲ្យដាក់ភាជនៈរបស់តិរ្ថិយទាំងនោះចុះហើយ ឲ្យលើភាជនៈនោះ សូម្បីដាក់បាត្រទុកលើរង្វេលក្តី លើផែនដីក្តី ពោលថា អ្នកទាំងឡាយចូរកាន់យកបាត្រនេះ

ក៏គួរ ។ បើតិរ្ថិយពោលថា របស់នេះជារបស់ផ្ទាល់ខ្លួនរបស់ខ្ញុំពិត សូមលោកម្ចាស់ដាក់អាមិសនោះក្នុងភាជនៈនេះ គប្បីដាក់ចូលទៅ ព្រោះជារបស់ផ្ទាល់ខ្លួននៃតិរ្ថិយនោះ ទើបមិនឈ្មោះថា ជាការឲ្យដោយដៃខ្លួនឯង ។ បទដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ដូចឯឡកលោមសិក្ខាបទ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អចេលកសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ២

[ ១៤៩ ] គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ កាលគង់នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះនឹងភិក្ខុជាសទ្ធិវិហារិក របស់ព្រះថេរៈជាបងប្អូនថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយ នឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ថាដូច្នេះហើយ ក៏មិនឲ្យគេប្រគេន ( អ្វីៗ ) ដល់ភិក្ខុនោះឡើយ ( បែរជា ) ប្រើឲ្យត្រឡប់ទៅវិញថា ម្នាលអាវុសោ លោកចូរទៅចុះ ខ្ញុំនឹងនិយាយ ឬនឹងអង្គុយជាមួយនឹងលោក មិនសប្បាយទេ ខ្ញុំនឹងនិយាយ ឬនឹងអង្គុយតែម្នាក់ឯងស្រួលជាង ។ គ្រានោះ កាលបើពេលដែលត្រូវឆាន់កាន់តែចូលមកជិតហើយ ភិក្ខុនោះ មិនអាចនឹងត្រាច់ទៅបិណ្ឌបាតបាន សូម្បីគ្រាន់តែត្រឡប់មកធ្វើភត្តកិច្ចវិញ ក៏មិនទាន់ជាអ្នកអត់ចង្ហាន់ ( មួយពេលនោះឯង ) ។ ទើបភិក្ខុនោះទៅកាន់អារាម ហើយតំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យដ៏មានអាយុ មិនសមបើមកបបួលភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ហើយមិនឲ្យគេប្រគេនអ្វីៗ ដល់ភិក្ខុនោះ ស្រាប់តែបញ្ជូនឲ្យត្រឡប់ទៅវិញ ( ដូច្នេះ ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ បានឮថា អ្នកឯងបបួលភិក្ខុថា ម្នាល

អាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ហើយមិនឲ្យគេ ( ឲ្យអ្វីៗ ) ដល់ភិក្ខុនោះ ( បែរជា ) បញ្ជូនឲ្យត្រឡប់ទៅវិញ មែនពិតឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនេះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងបបួលភិក្ខុផងគ្នាថា ម្នាលអាវុសោ លោកចូរមក យើងទាំង-ឡាយនឹងទៅកាន់ស្រុកដើម្បីបិណ្ឌបាត ហើយមិនឲ្យគេ ( ឲ្យអ្វីៗ ) ដល់ភិក្ខុនោះ ( បែរជា ) បញ្ជូនឲ្យត្រឡប់ទៅវិញ ដូច្នេះឡើយ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយនិយាយនឹងភិក្ខុយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ហើយឲ្យគេឲ្យ ឬមិនឲ្យគេឲ្យ ( អ្វីៗ ) ដល់ភិក្ខុនោះ ហើយបញ្ជូនឲ្យត្រឡប់ទៅវិញ ដោយពាក្យថា នែអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយ ឬអង្គុយជាមួយនឹងលោកមិនសប្បាយទេ ខ្ញុំនិយាយ ឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ។ ព្រោះធ្វើនូវហេតុនោះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃឡើយ ។

[១៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ ។ ពាក្យថា ម្នាលអាវុសោ លោកចូរមក ( យើងនឹងទៅ ) កាន់ស្រុក ឬនិគម ( ដើម្បីបិណ្ឌ-

បាត ) គឺស្រុកក្តី និគមក្តី នគរក្តី ក៏ហៅថា ស្រុក និងនិគម ( ក្នុងសិក្ខាបទនេះ ) ។ ពាក្យថា ឲ្យគេឲ្យ ( អ្វីៗ ) ដល់ភិក្ខុនោះ គឺប្រើគេឲ្យឲ្យយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី ( ដល់ភិក្ខុនោះ ) ។ ពាក្យថា មិនឲ្យគេឲ្យ គឺមិនឲ្យនរណាឲ្យ ( អ្វីៗ ) សោះ ។ ពាក្យថា បញ្ជូនឲ្យត្រឡប់ទៅវិញ សេចក្តីថា ភិក្ខុប្រាថ្នាដើម្បីសើច ប្រាថ្នាដើម្បីលេង ប្រាថ្នាដើម្បីអង្គុយក្នុងទីស្ងាត់ ប្រាថ្នាដើម្បីប្រព្រឹត្តអនាចារជាមួយនឹងមាតុគ្រាម ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយ ឬអង្គុយជាមួយលោកមិនស្រួលទេ ខ្ញុំនិយាយ ឬអង្គុយតែម្នាក់ឯងស្រួលជាង ថាហើយក៏បញ្ជូនឲ្យត្រឡប់ទៅវិញ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះកំពុងលះបង់ទីល្មមមើលគ្នាឃើញ ឬទីល្មមស្តាប់ឮ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះលះបង់ផុត ( នៅទីល្មមមើលឃើញ ឬទីល្មមស្តាប់ឮ ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ សេចក្តីថា មិនមានហេតុនីមួយដទៃជាបច្ច័យ ក្រៅអំពីហេតុដែលបញ្ជូនទៅនោះឡើយ ។

[ ១៥១ ] ឧបសម្បន្ន ភិក្ខុសម្គាល់ថា ឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសម្គាល់ថា មិនមែនជាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលើកឡើងនូវពាក្យបញ្ឈឺចិត្ត ចំពោះឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបញ្ជូនអនុបសម្បន្នទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលើកនូវពាក្យបញ្ឈឺចិត្ត ( ចំពោះអនុបសម្បន្ន ) ត្រូវអាបត្តិ

ទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសម្គាល់ថា ជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុក៏សម្គាល់ថា មិនមែនជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[ ១៥២ ] អាបត្តិមិនមានដល់ភិក្ខុ ដែលបញ្ជូនភិក្ខុផងគ្នាឲ្យត្រឡប់ទៅ ដោយគិតថា យើងទាំងពីររូបនឹងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងទីជាមួយគ្នាមិនបាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុផងគ្នាឲ្យទៅ ដោយគិតថា ក្រែងភិក្ខុនោះបានឃើញរបស់មានតម្លៃច្រើន ហើយនឹងញុំាងលោភធម៌ឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយគិតថា ក្រែងភិក្ខុនោះបានឃើញមាតុគ្រាមហើយនឹងញុំាងសេចក្តីអផ្សុកឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅ ដោយពាក្យថា លោកចូរនាំយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី ទៅឲ្យដល់ភិក្ខុមានជំងឺ ឬភិក្ខុដែលនៅក្នុងវត្ត ឬអ្នកដែលរក្សាវត្ត ដល់ភិក្ខុមិនប្រាថ្នានឹងប្រព្រឹត្តអនាចារទេ ( តែ ) កាលបើមានកិច្ចហើយ ក៏បញ្ជូនភិក្ខុផងគ្នាទៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់

# អដ្ឋកថា
# អចេលកវគ្គទី ៥
# ឧយ្យោជនសិក្ខាបទ

[ ១៤៩ ] ក្នុងសិក្ខាបទទី ២ មានវិនិច្ឆ័យដូច្នេះ បទថា **បដិក្កមនេបិ** ប្រែថា ក្នុងរោងឆាន់ ។ បទថា **ភត្តវិស្សគ្គំ** ប្រែថា ភត្តកិច្ច ។ បទថា **ន សម្ភាវេសិ** ប្រែថា មិនទាន់ពេលវេលា ។

[ ១៥០ ] បទថា **អនាចារំ** បានដល់ ការកន្លងល្មើសតាមកាយទ្វារ និងវចីទ្វារ ដ៏សេសអំពីអនាចារដែលពោលហើយ ។

ក្នុងបទថា **ទស្សនូបចារំ វា សវនូបចារំ វា វិជហន្តស្ស** នេះ មានវិនិច្ឆ័យថា បើភិក្ខុឈរក្តី អង្គុយក្តី បណ្តេញ ភិក្ខុណាត្រូវបណ្តេញ ភិក្ខុនោះកំពុងលះឧបចារៈទៅ និងឈ្មោះថា អាបត្តិមិនមានដល់ភិក្ខុនោះ តែកាលភិក្ខុដែលត្រូវបណ្តេញទៅនោះ សូម្បីកំពុងលះ ( ឧបចារៈ ) ទៅ ដោយអត្ថក៏ឈ្មោះថា ភិក្ខុដែលបណ្តេញក្រៅអំពីនេះ លះទៅហើយនោះឯង ព្រោះដូច្នោះ ភិក្ខុអ្នកបណ្តេញប៉ុណ្ណោះត្រូវអាបត្តិនេះ ។ បណ្តាអាបត្តិទាំងនោះ បើជើងម្ខាងនៅក្នុងឧបចារៈនៅឡើយ ត្រូវអាបត្តិទុក្កដ ក្នុងខណៈរំលងខេត្តទៅត្រូវអាបត្តិបាចិត្តិយ ។

បណ្តាឧបចារៈ ទស្សនូបចារៈ និងសវនូបចារៈនេះ ប្រមាណ ១២ ហត្ថ ក្នុងឱកាសទីវាលជាប្រមាណនៃឧបចារៈឃើញ ឧបចារៈការបានឮ ក៏មានប្រមាណស្មើគ្នា ។ បើមានសន្ទះទ្វារ និងកំពែងជាដើមខណ្ឌត្រង់កណ្តាលការៈនៃសន្ទឹកទ្វារ និងកំពែងជាដើមនោះ ខណ្ឌទុកនោះឯង ជាការកន្លង

ទស្សនូបចារៈ ។ បណ្ឌិតគប្បីជ្រាបអាបត្តិ ដោយការកន្លងទស្សនូបចារៈ ( ឧបចារៈនៃការឃើញ ) នោះ ។

បទថា **ន អញ្ញោ កោចិ បច្ចយោ ហោតិ** សេចក្ដីថា វៀរអនាចារមានប្រការដូចពោលហើយ មិនមានហេតុចាំបាច់ណាមួយដទៃ ។

[ ១៥១ ] ពីរបទថា **កលិសាសនំ អារោបេតិ** សេចក្ដីថា ការក្រោធឈ្មោះថា កលិ ។ លើករឿងនៃការក្រោធនោះឡើង គឺលើកអាជ្ញានៃសេចក្ដីក្រោធឡើង អធិប្បាយថា សម្ដែងទោសក្នុងការឈរ និងការអង្គុយជាដើមដោយអំណាចនៃការខឹងក្រោធ ពោលពាក្យសម្ដីដែលមិនជាទីស្ដាប់យ៉ាងនេះថា អាវុសោ ចូរមើលការឈរ ការអង្គុយ ការក្រឡេកធ្វេងស្ដាំរបស់ភិក្ខុនេះ លោកឈរដូចដង្គត់ឈើ អង្គុយដូចឆ្កែ ក្រឡេកធ្វេងស្ដាំ ក្រឡឹតក្រឡាប់ដូចស្វា ដោយតាំងចិត្តថា ធ្វើយ៉ាងណា បុគ្គលនេះត្រូវអញបៀតបៀនដោយពាក្យដែលមិនជាទីត្រេកអរយ៉ាងនេះហើយ គប្បីចៀសចេញទៅ ។ បទដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ឧយ្យោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៣

[១៥៣] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុបានដើរទៅផ្ទះរបស់សម្លាញ់ ហើយក៏អង្គុយនៅក្នុងផ្ទះ សម្រាប់ដេកជាមួយនឹងប្រពន្ធរបស់សម្លាញ់នោះ ។ ឯបុរសនោះ ក៏ចូលសំដៅទៅត្រង់ទីដែលព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអង្គុយនោះ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះអង្គុយក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងប្រពន្ធថា នាងចូរប្រគេនចង្ហាន់ដល់លោកម្ចាស់ចុះ ។ ស្រីនោះក៏ប្រគេនចង្ហាន់ដល់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុក្នុងគ្រានោះ ។ លំដាប់នោះ បុរសនោះក៏និយាយពាក្យនេះ នឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តទៅចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ ។ ឯស្ត្រីនោះកំណត់ដឹងថា បុរសនេះមានរាគៈគ្របសង្កត់ហើយ ក៏និយាយពាក្យនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅ បុរសនោះ ( បាននិយាយ ) ជាគម្រប់ពីរដង ។បេ។ បុរសនោះបាននិយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុជាគម្រប់បីដងថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោក

ម្ចាស់និមន្តទៅវិញចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ។ ឯស្ត្រីនោះសោត ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុជាគម្រប់បីដងថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅឡើយ ។ ឯបុរសនោះក៏ដើរចេញអំពីផ្ទះទៅ ហើយពោលទោសនឹងភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន លោកម្ចាស់ឧបនន្ទនេះ ទៅអង្គុយក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់ខ្ញុំ ព្រះឧបនន្ទនោះ កាលខ្ញុំបញ្ជូនឲ្យទៅវិញ ក៏មិនចង់ទៅ យើងខ្ញុំទាំងឡាយជាអ្នកមានកិច្ចច្រើន មានរវល់ច្រើន ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុអម្បាលនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ( គឺតែប្រុសនឹងស្រី ) ( ដូច្នោះ ) សោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដំណើរនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ( ដូច្នោះ ) ទេ នៃមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយ គប្បីសម្ដែងឡើងនូវសិក្ខាបទនេះ

យ៉ាងនេះថា ភិក្ខុណាមួយ ចូលទៅសម្រេចការអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ត្រកូលដែលមានជនតែពីរនាក់ គឺមានតែស្រី និងប្រុសប៉ុណ្ណោះ ។ ជនទាំងពីរនាក់មិនទាន់ចេញទៅ ហើយជនទាំងពីរនាក់នោះ ជាមនុស្សមានរាគៈនៅឡើយ ។ ពាក្យថា ចូលទៅ គឺដើរចូលទៅ ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា ភិក្ខុលះហត្ថបាសនៃមេទ្វារ ឬធរណីក្នុងផ្ទះធំ ហើយអង្គុយនៅ ត្រូវអាបត្តិបាចិត្តិយ ។ ( បើ ) ក្នុងផ្ទះតូច ភិក្ខុចូលហួសមេដំបូល[១] ទៅ ហើយអង្គុយ ត្រូវអាបត្តិបាចិត្តិយ ។

[១៥៥] ផ្ទះសម្រាប់ដេក ភិក្ខុក៏សម្គាល់ថាផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ហើយចូលទៅ សម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេក ភិក្ខុសម្គាល់ថាផ្ទះសម្រាប់ដេក ហើយចូលទៅ សម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសម្គាល់ថា ផ្ទះសម្រាប់ដេក ត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុក៏សម្គាល់ថា មិនមែនផ្ទះសម្រាប់ដេក មិនត្រូវអាបត្តិ ។

---

១- អដ្ឋកថា អធិប្បាយថា ភិក្ខុចូលទៅហួសពាក់កណ្តាលផ្ទះ គឺហួសមេដំបូលផ្ទះ ។

[១៥៦] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយក្នុងផ្ទះធំ មិនលះហត្ថបាសនៃមេទ្វារ ឬធរណី ដល់ភិក្ខុអង្គុយក្នុងផ្ទះតូច មិនហួសមេដំបូល ដល់ភិក្ខុដែលមានភិក្ខុជាគម្រប់ពីរអង្គុយនៅផង ដល់ភិក្ខុដែលអង្គុយនៅ តែជនទាំងពីរនាក់គេចេញទៅហើយ ដល់ភិក្ខុដែលអង្គុយនៅជាមួយនឹងជនទាំងពីរនាក់ជាបុគ្គលមិនមានរាគៈ ដល់ភិក្ខុអង្គុយនៅក្នុងផ្ទះដែលមិនមែនជាផ្ទះសម្រាប់ដេក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់

# អដ្ឋកថា

## អចេលកវគ្គទី ៥

## សភោជនសិក្ខាបទ

[ ១៥៣ ] ក្នុងសិក្ខាបទទី ៣ មានវិនិច្ឆ័យដូច្នេះ បទថា **សយនីយឃរេ** ប្រែថា ក្នុងផ្ទះសម្រាប់ដេក ។ បទថា **យតោ អយ្យស្ស ភិក្ខា ទិន្នា** ប្រែថា ខ្ញុំបានប្រគេនភិក្ខាហើយ អធិប្បាយថា របស់ណាដែលបុគ្គលមកហើយគប្បីបាន លោកម្ចាស់បានរបស់នោះហើយ និមន្តលោកម្ចាស់ត្រឡប់ទៅចុះ ។ បទថា **បរិយុដ្ឋិតោ** គឺជាបុគ្គលដែលរាគៈរួបរឹតហើយ សេចក្តីថា មានបំណងក្នុងមេថុន ។ បទថា **សភោជនេ** បានដល់ ត្រកូលដែលប្រព្រឹត្តទៅជាមួយមនុស្ស ២ នាក់ ឈ្មោះថា **សភោជន** ។ ក្នុងត្រកូលមានមនុស្ស ២ នាក់នោះ ។ម្យ៉ាងទៀត បទថា **សភោជនេ** គឺក្នុងត្រកូលមានភោគៈ ។ ព្រោះថា ស្ត្រីជាភោគៈរបស់បុរស ដែលរាគៈរួបរឹតហើយ និងបុរសដែលជាភោគៈរបស់ស្ត្រី ( ដែលរួបរឹតដោយរាគៈ ) ដោយហេតុនោះឯង ក្នុងបទភាជនៈនៃបទថា **សភោជនេ** នោះ ទើបព្រះមានព្រះភាគត្រាស់ថា មានស្ត្រី និងបុរសជាដើម ។

[១៥៤] ពីរបទថា **មហល្លកេ ឃរេ** គឺក្នុងផ្ទះដេកដែលធំទូលាយ ។

បីបទថា **បិដ្ឋិសង្ឃាដស្ស ហត្ថបាសំ វិជហិត្វា** សេចក្តីថា លះហត្ថបាសនៃទ្វារបន្ទប់ ក្នុងផ្ទះដេកនោះ ហើយអង្គុយក្នុងទីជិតខាងក្នុងទីដេក ។ ឯ

ផ្ទះដេកដូច្នេះ មានក្នុងសាលាមុខ ៤ ជាដើម ។ ព្រះមានព្រះភាគទ្រង់រមែងសម្ដែងការកន្ទេលហួសទីកណ្ដាល ដោយពាក្យនេះថា **បិដ្ឋិវំសំ អតិក្កមិត្វា ។** ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអាបត្តិ ព្រោះកន្ទេលត្រង់កណ្ដាលនៃផ្ទះដេកដែលតូច ដែលគេសាងទុកឯណានីមួយ ។ បទដ៏សេសក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិក ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

សភោជនសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៤

[១៥៧] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថ នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ បានទៅកាន់ផ្ទះរបស់បុរសជាសម្លាញ់ ហើយក៏សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់សម្លាញ់នោះ ។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនគួរបើនឹងហ៊ាន មកសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំងជាមួយនឹងប្រពន្ធរបស់ខ្ញុំ ( ដូច្នេះ ) សោះ ។ ភិក្ខុទាំងឡាយបានឮសម្តីនៃបុរសនោះ និយាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម ( ដូច្នោះ ) ទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងទៅសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម ( ដូច្នោះ ) ទេ នៃមោឃបុរស

អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

[១៥៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺស្រីមនុស្ស មិនមែនជាយក្ខស្រី មិនមែនជាប្រេតស្រី មិនមែនតិរច្ឆានញី ដោយហោចទៅសូម្បីតែក្មេងស្រីដែលទើបនឹងកើតបានមួយថ្ងៃ មិនបាច់និយាយទៅថ្វីដល់ស្រីធំទេ ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ដែលហៅថា ទីស្ងាត់ គឺទីដែលស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលដទៃមិនអាចឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលដទៃ មិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ដែលហៅថា អាសនៈជាទីកំបាំង គឺអាសនៈដែលគេបិទបាំងដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលផែងក្តី ដោយរនាំង ឬវាំងននក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ឬដោយវត្ថុណាមួយ ។ ពាក្យថា សម្រេចការអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីរអង្គុយក្តី ជនទាំងពីរដេកក្តី ( ឯភិក្ខុ ) ត្រូវអាបត្តិ

បាចិត្តិយ ។

[ ១៥៩ ] មាតុគ្រាម ភិក្ខុក៏សម្គាល់ថា មាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំង ជាមួយនឹងយក្ខស្រីក្តី ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានញី ដែលមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ ។

[ ១៦០ ] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយនៅ មានបុរសណាមួយដែលជាមនុស្សដឹងក្តី ( នៅ ) ជាគម្រប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុបានក្រឡេកគយគន់ រកទីមិនស្ងាត់ ហើយអង្គុយ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ហើយអង្គុយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់

# វិនយបិដក

## សិក្ខាបទទី ៥

[១៦១] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ដើរទៅកាន់ផ្ទះរបស់សម្លាញ់ ហើយក៏សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់សម្លាញ់នោះ តែម្នាក់និងម្នាក់ ។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនសមបើនឹងហ៊ានមកសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធខ្ញុំ តែម្នាក់នឹងម្នាក់ ( ដូច្នេះ ) សោះ ។ ភិក្ខុទាំងឡាយបានឮពាក្យសម្ដីនៃបុរសនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ហើយ ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាម តែម្នាក់នឹងម្នាក់ទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងទៅសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម តែម្នាក់នឹងម្នាក់ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្ដីនុ៎ះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាម តែម្នាក់នឹងម្នាក់ ( ដូច្នេះ ) ទេ នៃមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ

មិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ល។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ មួយអន្លើដោយមាតុគ្រាម តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺចំពោះតែស្រីមនុស្ស មិនមែនជាយក្ខស្រី មិនមែនជាប្រេតស្រី មិនមែនជាតិរច្ឆានញី ជាអ្នកដឹងក្តី ជាអ្នកអាចដើម្បីស្គាល់ពាក្យសម្តីដែលបុគ្គលនិយាយល្អ ឬអាក្រក់ ពាក្យអាសគ្រាម ឬមិនមែនអាសគ្រាម ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែភិក្ខុ និងមាតុគ្រាមប៉ុណ្ណោះ ។ ដែលហៅថា ទីស្ងាត់ គឺទីស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ជនដទៃមិនអាចឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយ គឺកាលដែលមាតុគ្រាមអង្គុយហើយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬដេកជិត ( ភិក្ខុ ) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុ និងស្រីទាំងពីរនាក់ អង្គុយក្តី ដេកក្តី ( ភិក្ខុ ) ត្រូវអាបត្តិបាចិត្តិយ ។

[១៦៣] មាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាម ហើយសម្រេចការ

អង្គុយក្នុងទីស្ងាត់ តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយក្នុងទីស្ងាត់ តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់ តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងយក្ខស្រីក្តី ជាមួយនឹងប្រេតក្តី ជាមួយនឹងខ្ទើយ តិរច្ឆានញីដែលមានរាងកាយដូចមនុស្សក្តី តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសម្គាល់ថា មិនមែនមាតុគ្រាម មិនមានអាបត្តិ ។

[ ១៦៤ ] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយនៅ មានបុរសណាម្នាក់ជាអ្នកដឹងសេចក្តីនៅជាគម្រប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុបានក្រឡេកគយគន់ រកទីមិនស្ងាត់ហើយអង្គុយនៅ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់

# អដ្ឋកថា
# អចេលកវគ្គទី ៥
# បឋម និងទុតិយ អនិយតសិក្ខាបទ

*ពាក្យដែលគប្បីពោលក្នុងសិក្ខាបទទី ៤-៥ ទាំងអស់ មានវិនិច្ឆ័យដូចពោលហើយ ក្នុងអនិយតសិក្ខាបទទាំង ២ នោះឯង ។ សភោជនសិក្ខាបទមានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ យ៉ាងណា សូម្បីសិក្ខាបទទី ៤ និងទី ៥ នេះ ក៏មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ ដូចគ្នាដូច្នោះឯង ។*

*បឋម និងទុតិយ អនិយតសិក្ខាបទ ចប់*

# វិនយបិដក

## សិក្ខាបទទី ៦

[១៦៥] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថនៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ត្រកូលជាឧបដ្ឋាករបស់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ និមន្តព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុដោយភត្ត ហើយក៏និមន្តពួកភិក្ខុឯទៀតដោយភត្តដែរ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអាល័យតែចូលទៅរកត្រកូលទាំងឡាយក្នុងពេលមុនឆាន់ ។ ឯភិក្ខុទាំងឡាយនោះ ក៏បាននិយាយពាក្យនេះនឹងមនុស្សអម្បាលនោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់ ( មក ) ។ ពួកមនុស្សអម្បាលនោះក៏និយាយឃាត់ថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយរង់ចាំសិន ទម្រាំព្រះឧបនន្ទជាម្ចាស់ លោកនិមន្តមក ភិក្ខុទាំងឡាយនោះបាននិយាយពាក្យនេះនឹងមនុស្សជាអម្បាលនោះជាគម្រប់ពីរដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក ពួកមនុស្សអម្បាលនោះក៏និយាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមព្រះករុណាទាំងឡាយរង់ចាំសិនចុះ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមក ។ ពួកភិក្ខុអម្បាលនោះ ក៏និយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះជាគម្រប់បីដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក ( នឹងបង្អង់នៅ ) ក្រែងហួសពេលឆាន់ ។ មនុស្សទាំងឡាយក៏និយាយថា បពិត្រព្រះ

ករុណាទាំងឡាយដ៏ចម្រើន យើងខ្ញុំទាំងឡាយបានធ្វើភត្តទាំងប៉ុន្មាន ព្រោះតែព្រះឧបនន្ទជាម្ចាស់ ( ទេតើ ) បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមព្រះករុណាទាំងឡាយរង់ចាំ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមកសិន ។ លំដាប់នោះ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ អាល័យតែចូលទៅគួរសមនឹងត្រកូលទាំងឡាយក្នុងពេលមុនឆាន់ ហើយក៏មកក្នុងវេលាថ្ងៃពេក ។ ភិក្ខុទាំងឡាយក៏ឆាន់ចង្អាន់មិនល្មមដល់ចិត្ត ។ ភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានទទួលនិមន្តន៍គេ ជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ ( ដទៃ ) ក្នុងពេលមុនឆាន់ ( ដូច្នេះ ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានទទួលនិមន្តន៍គេ ជាអ្នកមានភត្តហើយៗ ត្រាច់ទៅក្នុងត្រកូលទាំងឡាយ ( ដទៃ ) ក្នុងពេលមុនឆាន់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងបានទទួលនិមន្តន៍គេ ជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ ( ដទៃ ) ក្នុងពេលមុនឆាន់ ( ដូច្នេះ ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយបានទទួលនិមន្តន៍គេ ជាអ្នកមានភត្ត

ហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៦] កាលនោះ ត្រកូលឧបដ្ឋាករបស់ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ បានបញ្ជូនខាទនីយាហារទៅដើម្បីប្រគេនដល់សង្ឃ ដោយពាក្យថា ខាទនីយនេះ អ្នកឯងត្រូវបង្ហាញដល់ព្រះឧបនន្ទជាម្ចាស់ ហើយសឹមប្រគេនដល់សង្ឃចុះ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ឯពួកមនុស្សអម្បាលនោះ ទៅកាន់អារាមហើយ សួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ព្រះឧបនន្ទជាម្ចាស់និមន្តទៅឯណា ។ ពួកភិក្ខុអម្បាលនោះប្រាប់ថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុនុ៎ះ និមន្តទៅកាន់ស្រុកដើម្បីបិណ្ឌបាតហើយ ។ មនុស្សទាំងឡាយក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខាទនីយាហារនេះ សូមលោកម្ចាស់ទាំងឡាយបង្ហាញដល់ព្រះឧបនន្ទដ៏មានអាយុ ហើយសឹមប្រគេនដល់សង្ឃចុះ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយត្រូវទទួល ហើយតម្កល់ទុក ទម្រាំឧបនន្ទត្រឡប់មកវិញ ។ គ្រានោះ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុគិតថា ព្រះដ៏មានព្រះភាគ ទ្រង់ហាមឃាត់មិនឲ្យត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាមុនភត្ត ( គិតដូច្នោះហើយ ) ក៏ចូលទៅរកត្រកូលទាំងឡាយក្នុង

វេលាក្រោយភត្ត ហើយត្រឡប់មកក្នុងវេលាហួសពេល ។ ខាទនីយាហារ គេក៏ផ្ញើត្រឡប់ទៅវិញ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្ទះបន្ទាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនគួរបើនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាក្រោយភត្ត ( ដូច្នោះ ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាក្រោយភត្ត ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនុ៎ះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលក្រោយភត្ត ( ដូច្នេះ ) ទេ ម្នាលមោឃ-បុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តន៍គេ ជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៧] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងសម័យនៃចីវរទាន ហើយមិនបានចូលទៅរកត្រកូលទាំងឡាយ ។ ចីវរក៏កើតឡើងតិចស្តួចស្តើង ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះ

ភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុតាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយក្នុងសម័យនៃចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេ ជាអ្នកមានភត្ត ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំង-ឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ឯសម័យក្នុងសិក្ខាបទនោះ គឺកាលដែលទាយកប្រគេនចីវរ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ១៦៨ ] សម័យនោះឯង ភិក្ខុទាំងឡាយធ្វើចីវរកម្ម គឺការដេរចីវរ ក៏មានសេចក្តីត្រូវការដោយម្ជុលខ្លះ ដោយចេសខ្លះ ដោយកាំបិតខ្លះ ។ ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យ មិនបានចូលទៅរកត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយក្នុងសម័យធ្វើចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តន៍គេ ជាអ្នកមានភត្ត ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺកាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់

បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៩] សម័យនោះឯង ភិក្ខុទាំងឡាយមានជំងឺ ក៏មានសេចក្តីត្រូវការដោយភេសជ្ជៈទាំងឡាយ ភិក្ខុទាំងឡាយក៏សង្ស័យមិនបានចូលទៅរកត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយសឹមចូលទៅរកត្រកូលទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តន៍គេ ជាអ្នកមានភត្ត ហើយមិនបានលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺកាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា គេនិមន្ត គឺជននិមន្តដោយភោជនទាំង ៥ យ៉ាង ភោជនណាមួយ ។ ដែលហៅថា ជាអ្នកមានភត្ត គឺភិក្ខុដែលគេនិមន្តដោយភត្តណា ឈ្មោះថា ជាអ្នកមានភត្ត ព្រោះភត្តនោះឯង ។ ដែលហៅថា ភិក្ខុមាននៅនោះ គឺភិក្ខុអាចនឹងលាភិក្ខុផងគ្នា ហើយចូលទៅកាន់ ( ត្រកូល ) បាន ។ ភិក្ខុដែលមិនមាននៅនោះ គឺភិក្ខុមិនអាចលាភិក្ខុផងគ្នា ហើយចូលទៅកាន់ ( ត្រកូល ) ឡើយ ។ ដែលហៅថា ក្នុងពេលមុនភត្ត

គឺជនទិមន្តដោយភត្តណា ហើយភិក្ខុមិនទាន់បានឆាន់ភត្តនោះ ។ ដែលហៅថា ក្នុងពេលក្រោយភត្ត គឺជនទិមន្តដោយភត្តណា ភិក្ខុបានឆាន់ភត្តនោះហើយ ដោយហោចទៅសូម្បីប៉ុនចុងនៃស្បូវ ។ ដែលហៅថា ត្រកូល គឺត្រកូលទាំងឡាយ ៤ គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលវេស្សៈ ( អ្នករកស៊ីជួញប្រែ ធ្វើស្រែចម្ការ ) ១ ត្រកូលសុទ្ទៈ ( អ្នកធ្វើការស៊ីឈ្នួល ) ១ ។ ពាក្យថា ដល់នូវកិរិយាត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ គឺកាលដែលភិក្ខុឈានចូលទៅដល់ឧបចារៈផ្ទះរបស់បុគ្គលដទៃទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងជាដំបូងឲ្យកន្លងហួសធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងជាគម្រប់ពីរឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកទុកតែមានសម័យ ។ ដែលហៅថា កាលដែលទាយកប្រគេនចីវរនោះ គឺថា បើភិក្ខុមិនបានក្រាលកឋិនកំណត់កាលត្រឹមមួយខែជាទីបំផុតនៃវស្សានរដូវ ( គឺតាំងពី ១ រោច ខែអស្សុជ ទៅដល់ ១៥ កើត ខែ កត្តិក ) បើភិក្ខុបានក្រាលកឋិនកំណត់កាលត្រឹម ៥ ខែ ( តាំងតែពី ១ រោច ខែអស្សុជ ទៅដល់ ១៥ កើត ខែផល្គុណ ) ។ ដែលហៅថា កាលដែលភិក្ខុធ្វើចីវរនោះ គឺភិក្ខុកំពុងធ្វើចីវរ ។

[ ១៧១ ] មានគេនិមន្តហើយ ភិក្ខុសម្គាល់ថា គេនិមន្តហើយ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសង្ស័យ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយ

ត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសម្គាល់ថាមិនទាន់និមន្ត ហើយមិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ គេមិនបាននិមន្ត ភិក្ខុសម្គាល់ថា និមន្តហើយ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសម្គាល់ថា មិនបាននិមន្ត មិនមានអាបត្តិ ។

[ ១៧២ ] អាបត្តិមិនមានដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលបានលាភិក្ខុផងគ្នា ដែលមាននៅ ហើយចូលទៅ ដល់ភិក្ខុដែលមិនបានលាភិក្ខុផងគ្នា ព្រោះមិនមានភិក្ខុផងគ្នា ហើយចូលទៅ ដល់ភិក្ខុដែលដើរទៅតាមផ្លូវក្បែរផ្ទះនៃបុគ្គលដទៃ ដល់ភិក្ខុដែលដើរទៅដោយផ្លូវតាមឧបចារៈនៃផ្ទះ ដល់ភិក្ខុដែលទៅកាន់អារាម ដែលមានក្នុងចន្លោះស្រុក ដល់ភិក្ខុដែលទៅកាន់លំនៅនៃនាងភិក្ខុនី ដល់ភិក្ខុដែលទៅកាន់លំនៅនៃតិរ្ថិយ ដល់ភិក្ខុដែលដើរត្រឡប់មកវិញ ដល់ភិក្ខុទៅកាន់ផ្ទះនៃទាយកជាម្ចាស់ភត្ត ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់

# អដ្ឋកថា

# អចេលកវគ្គទី ៤

# ចារិត្តសិក្ខាបទ

[១៦៥] ក្នុងសិក្ខាបទទី ៦ មានវិនិច្ឆ័យដូច្នេះ ក្នុងបទថា **ធេជាវុសោ ភត្តំ** នេះ មានវិនិច្ឆ័យថា បានឮថា ភត្តនោះ ជារបស់ដែលពួកអ្នកស្រុកបង្អោននាំមក ព្រោះហេតុនោះ ទើបពួកភិក្ខុបាន ពោលយ៉ាងនោះ ។ តែក្នុងភត្តាហារដែលពួកអ្នកស្រុកមិនបាននាំមក ភិក្ខុរមែងមិនបានពោលយ៉ាងនោះ ( ពោលថា ឲ្យភត្តាហារចុះ អាវុសោ ) ជាបយុត្តវាចា ( ការហាមាត់សូម ) ។

ព្រះមានព្រះភាគត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកអ្នកចូរទទួលប្រគេន ហើយរក្សាទុកដូច្នេះ ដើម្បីរក្សាសទ្ធារបស់ត្រកូល ។ ពាក្យថា បើព្រះមានព្រះភាគគប្បីត្រាស់ថា ពួកអ្នកចែកគ្នាឆាន់ចុះ ពួកអ្នកស្រុកនឹងគប្បីប្រាសចាកការជ្រះថ្លា ។

[ ១៦៦ ] បទថា **ឧស្សារិយិត្ថ** ប្រែថា បាននាំត្រឡប់ទៅវិញ អធិប្បាយថា ពួកអ្នកស្រុកបាននាំខាទនីយនោះត្រឡប់ទៅកាន់ផ្ទះដូចដើម ។

[១៦៩] ក្នុងបទថា **សន្តំ ភិក្ខុំ** នេះ មានវិនិច្ឆ័យថា ភិក្ខុឈ្មោះថា មានដោយហេតុ មានប្រមាណប៉ុនណា ឈ្មោះថា មិនមាន ដោយហេតុមានប្រមាណប៉ុនណា សេចក្តីថា ភិក្ខុដែលនៅក្នុងទីណាមួយ ខាងក្នុងវិហារកើតមានគំនិតថា អាត្មាអញនឹងចូលទៅសួរសុខទុក្ខត្រកូល ចាប់ពីពេលនោះឃើញ

ភិក្ខុក្បែរៗ គឺ ចំពោះមុខគឺ ភិក្ខុណាដែលខ្លួនអាចនឹងប្រាប់ដោយពាក្យពោល តាមប្រក្រតីបាន ភិក្ខុនេះឈ្មោះថា មានភិក្ខុ ។ តែមិនមានកិច្ចដែលត្រូវត្រាច់ទៅលាខាងនោះ និងខាងនេះ ។ ពិតហើយ ភិក្ខុដែលខ្លួនត្រូវត្រាច់រកពោលលាយ៉ាងនេះ ឈ្មោះថា មិនមាននោះឯង ។ម្យ៉ាងទៀត ភិក្ខុទៅដោយធ្វើទុកក្នុងចិត្តថា បើអាត្មាអញជួបភិក្ខុខាងក្នុងឧបចារសីមាហើយ នឹងលា គប្បីលាភិក្ខុដែលខ្លួនឃើញក្នុងឧបចារសីមានោះ បើមិនជួបភិក្ខុ ឈ្មោះថា ជាអ្នកចូលទៅមិនលាភិក្ខុដែលមិនមាន ។

[ ១៧២ ] បទថា **អន្តរារាមំ** បានដល់ ទៅកាន់វិហារដែលមាននៅក្នុងស្រុក ។

បទថា **ភត្តិយឃរំ** បានដល់ ផ្ទះដែលគេនិមន្តគឺ ផ្ទះរបស់ពួកអ្នកស្រុកដែលប្រគេនសលាកភត្តជាដើមគឺ ។

បទថា **អាបទាសុ** សេចក្ដីថា កាលមានអន្តរាយនៃជីវិត និងព្រហ្មចរិយៈ ទោះទៅក៏គួរ ។ បទដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ កើតឡើងតាមកាយនិងវាចា ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយាផង អកិរិយាផង ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ចារិត្តសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៧

[ ១៧៣ ] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្ដុ ក្នុងដែនសក្កៈ ។ សម័យនោះឯង មហានាមសក្យៈ[១] មានថ្នាំសម្រាប់កែរោគដ៏បរិបូណ៌ ។ លំដាប់នោះ មហានាមសក្យៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយថ្នាំសម្រាប់កែរោគ កំណត់ ៤ ខែ ។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃពេកហើយ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឃដោយថ្នាំសម្រាប់កែរោគ កំណត់ ៤ ខែចុះ ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះការបវារណា ដោយបច្ច័យកំណត់ត្រឹម ៤ ខែ ។ សម័យនោះឯង ភិក្ខុទាំងឡាយទៅសូមភេសជ្ជទីងមហានាមសក្យៈតែបន្តិចៗ ។ ភេសជ្ជៈរបស់មហានាមសក្យៈ ក៏ជារបស់នៅតែបរិបូណ៌ដដែល ។ ឯមហា-

---

១- អដ្ឋកថាថា មហានាមសក្យៈនេះ ជាបុត្រនៃចុល្លបិតារបស់ព្រះដ៏មានព្រះភាគ ចាស់ជាងព្រះដ៏មានព្រះភាគប្រមាណ ១ ខែ ជាអរិយសាវ័ក បានតម្កល់នៅក្នុងផលទាំងពីរ គឺសោតាបត្តិផល និងសកទាគាមិផល ។

នាមសក្យៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគម្រប់ពីរដងទៀត លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃ ដោយភេសជ្ជៈកំណត់ ៤ ខែតទៅទៀត ។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃហើយៗ មហានាម បើដូច្នោះ ចូរព្រះអង្គបវា-រណាសង្ឃ ដោយភេសជ្ជ កំណត់ ៤ ខែ តទៅទៀតចុះ ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណាថែមម្ដងទៀត ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយ ទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិចៗ ។ ដោយហេតុនោះឯង ភេសជ្ជៈរបស់មហានាមសក្យៈក៏នៅតែបរិបូណ៌ដដែល ។ មហានាមសក្យៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគម្រប់បីដងទៀត លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយភេសជ្ជៈដរាបដល់អស់ជីវិត ។ ព្រះអង្គត្រាស់តបថា មហានាម ការនោះប្រពៃហើយៗ មហានាម បើដូច្នោះ ចូរមហារាជបវារណាសង្ឃដោយភេសជ្ជៈដរាបដល់អស់ជីវិតចុះ ។ ពួកភិក្ខុមាន

សេចក្តីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណាអស់កាលជានិច្ចបាន ។

[ ១៧៤ ] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកដណ្តប់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ មហានាមសក្យៈក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដូចម្តេច បានជាលោកម្ចាស់ទាំងឡាយ ស្លៀកដណ្តប់សំពត់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ ( ដូច្នេះ ) ធម្មតា អ្នកបួស គេត្រូវស្លៀកដណ្តប់សំពត់ឲ្យត្រឹមត្រូវល្អ ហើយមានអាកប្បកិរិយាដ៏សមគួរទេតើ ។ ពួកឆព្វគ្គិយភិក្ខុក៏ចងទោសនឹងមហានាមសក្យៈ ។ សេចក្តីត្រិះរិះកើតមានដល់ពួកឆព្វគ្គិយភិក្ខុក្នុងវេលានោះថា យើងទាំងឡាយគួរធ្វើមហានាមសក្យៈឲ្យអាប់ឱនដោយឧបាយដូចម្តេច អេះ ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុក៏បានប្រឹក្សាគ្នាដូច្នេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ មហានាមសក្យៈបានបវារណាសង្ឃដោយភេសជ្ជៈហើយ ណ្ហើយចុះ ម្នាលលោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយទៅសូមសប្បិអំពីមហានាមសក្យៈចុះ។ ទើបពួកឆព្វគ្គិយភិក្ខុចូលទៅរកមហានាមសក្យៈ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមហានាមសក្យៈថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បិមួយទោណ ។ ឯមហានាមសក្យៈឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះមួយថ្ងៃសិន មនុស្សទាំងឡាយគេទៅឯក្រោលគោ ដើម្បីនាំសប្បិមក លោកម្ចាស់ទាំងឡាយ នឹងយក

សប្បិនោះទៅក្នុងកាលដ៏គួរ ។ ពួកឆព្វគ្គិយភិក្ខុនិយាយសូមជាគម្រប់ពីរដង ។បេ។ ឆព្វគ្គិយភិក្ខុនិយាយពាក្យនេះ នឹងមហានាមសក្យៈជាគម្រប់បីដងថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បិមួយទោណ ។ មហានាមសក្យៈ ឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ មួយថ្ងៃសិន មនុស្សទាំងឡាយគេទៅឯក្រោលគោ ដើម្បីនាំសប្បិមក លោកម្ចាស់នឹងយកសប្បិនោះទៅក្នុងកាលដ៏គួរ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ អ្នកបវារណាដោយភេសជ្ជៈណាហើយ មិនឲ្យវិញ ប្រយោជន៍អ្វីដោយភេសជ្ជៈដែលអ្នកបវារណា តែមិនចង់ឲ្យនោះ ។ គ្រានោះ មហានាមសក្យៈ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចម្រើនទាំងឡាយ ខ្ញុំបានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ មួយថ្ងៃសិន ចុះហេតុដូចម្តេច បានជាមិនរង់ចាំ ។ ភិក្ខុទាំងឡាយបានឮមហានាមសក្យៈពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ មួយថ្ងៃសិន មិនគួរនឹងមិនរង់ចាំសោះ ។បេ។ ព្រះពុទ្ធជាម្ចាស់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះមួយថ្ងៃសិន ដូច្នេះ ហើយមិនរង់ចាំ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិត

មែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលពួកមោឃ-បុរស អ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចម្រើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះមួយថ្ងៃសិន ហើយមិនសមនឹងមិនរង់ចាំ ( ដូច្នោះ ) សោះ នៃមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ពួកជន ដែលជ្រះថ្លាស្រាប់ហើយនោះទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុដែលគ្មានជំងឺ ត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ បើភិក្ខុត្រេកអរក្រៃលែងជាងនោះទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែគេបានបវារណាថែមទៀត វៀរលែងតែគេបានបវារណាជានិច្ច ។

[១៧៥] ត្រង់ពាក្យថា ភិក្ខុដែលគ្មានជំងឺ ត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ សេចក្តីថា ភិក្ខុគួរត្រេកអរនឹងការបវារណាដោយគិលានប្បច្ច័យ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាថែមទៀតដោយគិតថា អញជាអ្នកមានជំងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាជាប់ជានិច្ច ដោយគិតថា អញជាអ្នកមានជំងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ ។

[ ១៧៦ ] ត្រង់ពាក្យថា បើភិក្ខុត្រេកអរក្រៃលែងជាងនោះ សេចក្តីថា បវារណាកំណត់ភេសជ្ជៈ មិនកំណត់រាត្រី បវារណាកំណត់រាត្រី មិនកំណត់ភេសជ្ជៈ បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រី បវារណាមិនកំណត់

ទាំងភេសជ្ជ មិនកំណត់ទាំងរាត្រី ។ ដែលហៅថា បវារណាកំណត់ភេសជ្ជ (នោះ) គឺភេសជ្ជដែលគេកំណត់ ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាកំណត់រាត្រី គឺរាត្រីដែលគេកំណត់ ដោយពាក្យថា ខ្ញុំព្រះករុណាបវារណាអស់រាត្រីទាំងឡាយប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាកំណត់ទាំងភេសជ្ជ កំណត់ទាំងរាត្រីនោះ គឺគេកំណត់ភេសជ្ជទាំងឡាយផង កំណត់រាត្រីទាំងឡាយផង ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណាដោយភេសជ្ជទាំងឡាយ មានប្រមាណប៉ុណ្ណេះ អស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាមិនកំណត់ភេសជ្ជ មិនកំណត់រាត្រី ( នោះ ) គឺគេមិនកំណត់ភេសជ្ជទាំងឡាយ និងមិនកំណត់រាត្រីទាំងឡាយ ដោយពាក្យថា ខ្ញុំព្រះករុណា សូមបវារណាដោយភេសជ្ជទាំងឡាយ មានប្រមាណប៉ុណ្ណេះ និងអស់រាត្រី ទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

[១៧៧] ឯពាក្យដែលថា កំណត់ភេសជ្ជនោះ អធិប្បាយថា គេបវារណាភិក្ខុដោយភេសជ្ជណា ភិក្ខុត្រឡប់ទៅសូមភេសជ្ជទាំងឡាយដទៃវិញ ក្រៅពីភេសជ្ជដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់រាត្រីនោះ គឺគេបវារណាភិក្ខុក្នុងរាត្រីទាំងឡាយណា ភិក្ខុត្រឡប់សូមក្នុងរាត្រីទាំងឡាយឯទៀតវិញ ក្រៅពីរាត្រីដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់ទាំងភេសជ្ជ កំណត់ទាំងរាត្រីនោះ គឺគេបវារណាភិក្ខុដោយភេសជ្ជទាំងឡាយណា ភិក្ខុវៀរលែងភេសជ្ជទាំងនោះ គេបវារណាភិក្ខុក្នុងរាត្រីណា

ភិក្ខុវៀរលែងរាត្រីទាំងនោះ ហើយត្រឡប់ទៅសូមភេសជ្ជទាំងឡាយដទៃ ក្នុងរាត្រីទាំងឡាយឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ឯមិនកំណត់ភេសជ្ជ និងមិនកំណត់រាត្រី មិនមានអាបត្តិឡើយ ។

[ ១៧៨ ] កាលបើមិនមានកិច្ចដោយភេសជ្ជ ហើយភិក្ខុទៅសូមភេសជ្ជ ត្រូវអាបត្តិបាចិត្តិយ ។ កាលបើមានកិច្ចដោយភេសជ្ជឯទៀត ហើយភិក្ខុទៅសូមភេសជ្ជឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសម្គាល់ថា ហួសកំណត់ដែលគេបវារណាមែន ហើយទៅសូមភេសជ្ជ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសង្ស័យ ហើយទៅសូមភេសជ្ជ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសម្គាល់ថា មិនហួសកំណត់បវារណាទេ ហើយទៅសូមភេសជ្ជ ត្រូវអាបត្តិបាចិត្តិយ ។ មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសម្គាល់ថា ហួសកំណត់ដែលគេបវារណាហើយ ត្រូវអាបត្តិទុក្កដ ។ មិនទាន់ហួសកំណត់បវារណាទេ ភិក្ខុមានការសង្ស័យត្រូវអាបត្តិទុក្កដ ។ មិនទាន់ហួសកំណត់បវារណាទេ ភិក្ខុសម្គាល់ថា មិនហួសកំណត់បវារណា មិនមានអាបត្តិ ។

[ ១៧៩ ] អាបត្តិមិនមានដល់ភិក្ខុ ដែលគេបវារណាដោយភេសជ្ជទាំង-ឡាយណា ភិក្ខុសូមភេសជ្ជទាំងឡាយនោះ ដល់ភិក្ខុដែលគេបវារណាក្នុងរាត្រីទាំងឡាយណា ភិក្ខុសូមក្នុងរាត្រីទាំងឡាយនោះ ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយ គឺអ្នកបានបវារណាហើយ ដោយភេសជ្ជទាំង-

ឡាយនេះ ( ឥឡូវនេះ ) យើងទាំងឡាយត្រូវការដោយភេសជ្ជនេះ នេះផង ហើយសូម ដល់ភិក្ខុដែលបរិយាយប្រាប់គេថា យើងទាំងឡាយ គឺអ្នកបាន បវារណាហើយ ក្នុងរាត្រីទាំងឡាយណា ឯរាត្រីទាំងឡាយនោះ កន្លងហួស ទៅហើយ ( ឥឡូវនេះ ) យើងទាំងឡាយ ត្រូវការដោយភេសជ្ជ ហើយ សូម ដល់ភិក្ខុដែលសូមអំពីពួកញាតិ ដល់ភិក្ខុដែលសូមអំពីពួកទាយកដែល គេបានបវារណា ដល់ភិក្ខុដែលសូមដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ ភិក្ខុដែលបានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់

# អដ្ឋកថា

# អចេលកវគ្គទី ៥

# មហានាមសិក្ខាបទ

[ ១៧៣ ] ក្នុងសិក្ខាបទទី ៧ មានវិនិច្ឆ័យដូច្នេះថា ព្រះឱរសនៃព្រះបិតុលា ( ឪពុកមា ) នៃព្រះមានព្រះភាគ ចាស់ជាងព្រះមានព្រះភាគត្រឹមតែមួយខែ ជាព្រះអរិយសាវក តាំងនៅក្នុងផលទាំង ២ ព្រះនាមថា មហានាមរាជ ។

បីបទថា **ភេសជ្ជំ ឧស្សន្នំ ហោតិ** សេចក្តីថា សប្បិដែលគេនាំមកអំពីក្រោល រក្សាទុកមានប្រមាណច្រើន ។

[ ១៧៥ ] បទថា **សាទិតព្វា** សេចក្តីថា ភិក្ខុមិនគប្បីបដិសេធក្នុងសម័យនោះថា មិនមានរោគ គប្បីទទួលដោយបំណងថា អញនឹងសូមក្នុងកាលមានរោគ ។

[ ១៧៦ ] បីបទថា **ឯត្តកេហិ ភេសជ្ជេហិ បវារេមិ** សេចក្តីថា ទាយកបវារណា ដោយអំណាចឈ្មោះ គឺដោយភេសជ្ជៈ ២-៣ យ៉ាង មានសប្បិ និងប្រេងជាដើមក្តី ដោយអំណាចចំនួន គឺដោយមួយកម្បង់ មួយនាឡិ មួយអាឡ្ហកជាដើម ។

[ ១៧៨ ] បីបទថា **អញ្ញំ ភេសជ្ជំ វិញ្ញាបេតិ** សេចក្តីថា ទាយកបវា-រណាដោយសប្បិ សូមប្រេង ទាយកបវារណាដោយអាឡ្ហក សូមទោណ ។

ពីរបទថា **ឆ ភេសជ្ជេន ករណីយេ** សេចក្តីថា បើភិក្ខុអាចញ៉ាំងអត្ត-ភាពបានដោយភត្តដែលលាយគ្នា ឈ្មោះថា កិច្ចគប្បីធ្វើដោយភេសជ្ជៈមិនមាន ។

[ ១៧៩ ] បទថា **បវារិតានំ** សេចក្តីថា ជាអនាបត្តិដល់ពួកភិក្ខុដែលមនុស្សរបស់ខ្លួនបវារណាទុក ដោយការបវារណាជាចំណែកបុគ្គល ព្រោះការហាមាត់សូម តាមសមគួរដល់ភេសជ្ជៈដែលបវារណាទុក ។ តែក្នុងភេសជ្ជៈ ដែលគេបវារណាដោយអំណាចនៃសង្ឃ គួរកំណត់ដឹងប្រមាណនោះឯង ពាក្យដ៏សេសរាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

មហានាមសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៨

[ ១៨០ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបាទបសេនទិកោសលរាជ ទ្រង់លើកកងទ័ពចេញទៅ ។ ពួកឆព្វគ្គិយភិក្ខុក៏បានទៅមើលកងទ័ពដែលស្តេចលើកចេញទៅហើយ ។ ព្រះបាទបសេនទិកោសលរាជបានទតឃើញពួកឆព្វគ្គិយដើរមកពីចម្ងាយ លុះទ្រង់ឃើញហើយ ក៏មានបន្ទូលឲ្យនិមន្តមក ហើយទ្រង់ត្រាស់សួរដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកលោកនាំគ្នាមកធ្វើអ្វី ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា ពួកអាត្មាមានប្រាថ្នាដើម្បីនឹងមើលមហាបពិត្រ ។ ស្តេចក៏ទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ ការមើលខ្ញុំព្រះករុណា ជាអ្នកត្រេកអរក្នុងការច្បាំងនឹងមានប្រយោជន៍អ្វី ពួកលោកត្រូវតែរមិលមើលព្រះដ៏មានព្រះភាគទេតើ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រ មិនគួរនឹងមកមើលកងទ័ពដែលស្តេចលើកចេញទៅសោះ ពួកយើងឯណាមកក្នុងកងទ័ព ព្រោះហេតុតែការចិញ្ចឹមជីវិត និងបុត្រភរិយា យើងនោះ ឈ្មោះថាគ្មានលាភផង ឈ្មោះថា បានរបស់អាក្រក់ផង ។ ភិក្ខុទាំងឡាយ បានឮពួកមនុស្សនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនាំគ្នាទៅមើលកងទ័ពដែល

ស្តេចលើកចេញទៅសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ នាំគ្នាទៅមើលកងទ័ពដែលស្តេចលើកទៅពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងទៅមើលកងទ័ពដែលស្តេចលើកចេញទៅទេ នែមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខានេះ យ៉ាងនេះថា ភិក្ខុណាមួយទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ១៨១ ] សម័យនោះឯង ឪពុកធំរបស់ភិក្ខុមួយរូប មានជំងឺក្នុងកងទ័ព ។ អ្នកនោះក៏បញ្ជូនទូតទៅកាន់សម្នាក់ភិក្ខុនោះថា ខ្ញុំព្រះករុណាមានជំងឺក្នុងកងទ័ព សូមលោកម្ចាស់និមន្តមក ខ្ញុំព្រះករុណាចង់ឲ្យលោកម្ចាស់និមន្តមកណាស់ ។ លំដាប់នោះ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយថា ភិក្ខុមិនត្រូវទៅមើលកងទ័ពដែលគេលើកចេញទៅទេ តែឥឡូវឪពុកធំអញនេះ មានជំងឺនៅក្នុងកងទ័ពអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ទើបភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាល

ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យទៅកាន់កងទ័ពបាន ព្រោះហេតុមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។

[១៨២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា កងទ័ពដែលគេលើកចេញទៅ គឺ កងទ័ពលើកចេញពីស្រុកទៅតាំងសំចតនៅក្តី ចេញទៅហើយចេះតែដើរទៅទៀតក្តី ។ ដែលហៅថា កងទ័ព គឺ ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ។ ពលដំរី ( មួយៗ ) មានបុរស ១២ នាក់ ។ ពលសេះ ( មួយៗ ) មានបុរស ៣ នាក់ ។ ពលរថ ( មួយៗ ) មានបុរស ៤ នាក់ ។ ពលថ្មើរជើង ( មួយៗ ) មានបុរស ៤ នាក់កាន់ធ្នូសរ ។ ភិក្ខុដើរទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើល ( កងទ័ពនោះ ) នៅទីណា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ( ក្នុងទីនោះ ) ។ ភិក្ខុលះបង់ឧបចារៈសម្រាប់មើលឃើញ ហើយមើលរឿយៗ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ គឺលើកលែងនូវហេតុមានសភាពយ៉ាងហ្នឹង ។

[១៨៣] កងទ័ពលើកចេញទៅហើយ ភិក្ខុសម្គាល់ថា កងទ័ពលើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុមាន

សេចក្តីសង្ស័យ ហើយនៅតែដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុសម្គាល់ថា លើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។ ភិក្ខុដើរទៅដើម្បីមើលកងទ័ពមួយៗ ( ក្នុងកងទ័ពទាំង ៤ ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលកងទ័ពនៅទីណា ត្រូវអាបត្តិទុក្កដនៅ ( ទីនោះ ) ។ ភិក្ខុលះបង់នូវឧបចារៈសម្រាប់មើលឃើញ ហើយមើលរឿយៗ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសម្គាល់ថា លើកចេញទៅហើយ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសម្គាល់ថា មិនទាន់លើកចេញទៅមែន មិនត្រូវអាបត្តិ ។

[ ១៨៤ ] អាបត្តិមិនមានដល់ភិក្ខុដែលឈរនៅក្នុងអារាមហើយមើលឃើញ ដល់ភិក្ខុដែលកងទ័ពនោះលើកមកកាន់ទីដែលភិក្ខុឈរនៅ ( ក្តី ) អង្គុយនៅ ( ក្តី ) ដេកនៅ ( ក្តី ) ដល់ភិក្ខុដែលដើរទៅជួបផ្លូវគ្នា បានឃើញកងទ័ព ដល់ភិក្ខុដែលមានហេតុ មានសភាពយ៉ាងនោះ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយកើតឡើង[១] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់

---

១- បើមានសេចក្តីអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយធម៌ ភិក្ខុគិតថា អញទៅក្នុងកងទ័ពនឹងបានរួចសេចក្តីអន្តរាយ ហើយដើរចូលទៅក្នុងកងទ័ព មិនត្រូវអាបត្តិ ។

# អដ្ឋកថា

## អចេលកវគ្គទី ៥

## ឧយ្យុត្តសិក្ខាបទ

[ ១៨០ ] ក្នុងសិក្ខាបទទី ៨ មានវិនិច្ឆ័យដូចតទៅនេះបទថា **អព្ភុ-យ្យាតោ** គឺទ្រង់លើកកងទ័ពចេញទៅ សេចក្តីថា កែនកងទ័ពចេញទៅអំពីព្រះនគរ ដោយតាំងចិត្តថា អញនឹងប្រឈមមុខជាមួយសត្រូវ ។

បទថា **ឧយ្យុត្តំ** បានដល់ កងទ័ពដែលធ្វើការលើកចេញទៅហើយ ដោយអត្ថថា កងទ័ពដែលរំកិលខ្លួនចេញអំពីភូមិស្រុកទៅហើយ ។

[ ១៨២ ] ពីរបទថា **ទ្វាទសបុរិសោ ហត្ថី** សេចក្តីថា ដំរីមួយក្បាលមានទាហាន ១២ នាក់ យ៉ាងនេះ គឺជិះខាងលើ ៤ នាក់ អ្នករក្សាប្រចាំជើងដំរី ជើងមួយ ២ នាក់ ។

ពីរបទថា **តិបុរិសោ អស្សោ** សេចក្តីថា សេះមួយ មានទាហានប្រចាំ ៣ នាក់ គឺអ្នកជិះម្នាក់ អ្នករក្សាប្រចាំជើង ២ នាក់ ។

ពីរបទថា **ចតុប្បុរិសោ រថោ** សេចក្តីថា រថមួយគ្រឿង មានទាហានប្រចាំ ៤ នាក់ យ៉ាងនេះ គឺសារថី ១ អ្នកចម្បាំង ១ អ្នករក្សាត្រង់កង់ ២ នាក់ ។

បទថា **ចត្តារោ បុរិសា សរហត្ថា** បានដល់ ពលថ្មើរជើង មានយ៉ាងនេះ គឺទាហានកាន់អាវុធគ្រប់ដៃ ៤ នាក់ កងទ័ពប្រកបដោយអង្គ ៤ នេះ ដោយកំណត់យ៉ាងទាប ឈ្មោះថា សេនា ។ កាលទៅមើលសេនានេះ

ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។

ពីរបទថា **ឧស្សន្នបចារំ វិជហិត្វា** សេចក្តីថា កងទ័ពត្រូវអ្វីមួយបិទបាំងទុកក្តី ចុះកាន់រណ្តៅ មើលមិនឃើញក្តី គឺកិក្ខុឈរក្នុងទីនេះហើយ មិនអាចមើលឃើញ ព្រោះហេតុនោះ កាលភិក្ខុទៅកាន់ទីដទៃមើល ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ប្រយោគ ។

[ ១៨៣ ] បទថា **ឯកមេកំ** សេចក្តីថា បណ្តាអង្គ ៤ មានដំរីជាដើម អង្គនីមួយៗ ដោយហោច ដំរីមួយ មានហ្មមួយក្តី ពលថ្មើរជើងកាន់អាវុធម្នាក់ក្តី ។ ព្រះរាជា ឈ្មោះថា ទ្រង់មិនបានយាត្រានាំទ័ព ទ្រង់ទៅប្រពាតព្រះរាជឧទ្យានក្តី ស្ងឹងក្តី យ៉ាងនេះ ឈ្មោះថា ទ្រង់មិនបានលើកទ័ព ។

[ ១៨៤ ] បទថា **អាបទាសុ** សេចក្តីថា កាលមានអន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈ ជាអនាបត្តិដល់ភិក្ខុដែលទៅដោយគិតថា អញទៅក្នុងកងទ័ពនេះ នឹងរួចផុតអន្តរាយបាន ។ បទដ៏សេសក្នុងសិក្ខាបទនេះ រាក់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា ជានោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ឧយ្យុត្តសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ៩

[ ១៨៥ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយ-ភិក្ខុមានកិច្ចធុរៈ ក៏នាំគ្នាទៅកាន់កងទ័ព ហើយឈប់នៅក្នុងកងទ័ពច្រើនជាង បីរាត្រីឡើងទៅ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនគួរនឹងនៅក្នុងកងទ័ពទេ ពួកយើងឯណា មក អាស្រ័យនៅក្នុងកងទ័ព ក៏ព្រោះតែការចិញ្ចឹមជីវិតខ្លួន និងបុត្រភរិយា យើង ទាំងនោះឈ្មោះថា គ្មានលាភផង ឈ្មោះថា បានរបស់អាក្រក់ផង ។ ពួក ភិក្ខុបានឮពួកមនុស្សនោះពោលទោសតិះដៀល បន្តុះបង្អាប់ដូច្នោះហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនៅក្នុងកងទ័ពឲ្យច្រើនជាង បីរាត្រីទៅសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកឯងទៅនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏ មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរ នឹងនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះ ថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-

ឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ( បើ ) ភិក្ខុនោះមានហេតុអ្វីៗ គួរនឹងទៅកាន់កងទ័ពនោះ ភិក្ខុនោះត្រូវនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី ។ បើនៅឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

[១៨៦] ត្រង់ពាក្យថា បើភិក្ខុនោះមានហេតុអ្វីៗ គួរនឹងទៅកាន់កងទ័ព គឺថា ភិក្ខុមានហេតុ មានកិច្ចធុរៈ ( ដែលគួរខានមិនបាន ) ។ ពាក្យថា ភិក្ខុនោះគប្បីនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី គឺភិក្ខុត្រូវនៅបានត្រឹមពីរបីយប់ ។ ពាក្យថា បើនៅឲ្យហួសពីកំណត់នោះទៅ សេចក្ដីថា កាលព្រះអាទិត្យអស្ដង្គតក្នុងថ្ងៃជាគម្រប់ ៤ ភិក្ខុចេះតែនៅក្នុងកងទ័ពនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១៨៧] កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសម្គាល់ថា ហួសមែនហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុមានសេចក្ដីសង្ស័យ ហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសម្គាល់ថា នៅខ្វះ ហើយប្រឹងតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលមិនទាន់ដល់បីរាត្រីភិក្ខុសម្គាល់ថា ហួសហើយ ត្រូវអាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុក៏សម្គាល់ថា មិនទាន់ដល់ មិនត្រូវអាបត្តិ ។

[១៨៨] អាបត្តិមិនមានដល់ភិក្ខុដែលនៅត្រឹមពីរបីរាត្រី ដល់ភិក្ខុដែលនៅមិនទាន់ដល់ពីរបីរាត្រី ដល់ភិក្ខុដែលនៅត្រឹមពីររាត្រី ហើយក្នុងរាត្រីជា

គម្រប់បី បានចេញទៅមុនអរុណរះ ហើយត្រឡប់ទៅនៅវិញទៀត ដល់ភិក្ខុដែលមានជំងឺទៅ ( ក្នុងកងទ័ព ) ដល់ភិក្ខុដែលទៅដោយកិច្ចរបស់ភិក្ខុមានជំងឺ ដល់ភិក្ខុដែលនៅក្នុងកងទ័ព ហើយមានកងទ័ពជាសត្រូវមកចោមព័ទ្ធកងទ័ព ( នោះឯង ) ដល់ភិក្ខុដែលជាប់ជំពាក់ ( ដោយបុគ្គលមានពៀរ ឬឥស្សរជន ) ណាមួយ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់

# អដ្ឋកថា

## អចេលកវគ្គទី ៥

## សេនាវាសសិក្ខាបទ

[ ១៨៦ ] ក្នុងសិក្ខាបទទី ៩ មានវិនិច្ឆ័យដូច្នេះ បទថា **អត្ថង្គតេ សុរិយេ សេនាយ វសតិ** សេចក្ដីថា បើភិក្ខុសម្រេចឥរិយាបថៗ ណាមួយ លើអាកាសដោយឫទ្ធិ ទោះឈរក្ដី អង្គុយក្ដី ដេកក្ដី ត្រូវអាបត្តិបាចិត្តិយ ទាំងអស់ ។

[ ១៨៨ ] បទថា **សេនា វា បដិសេនាយ រុទ្ធា ហោតិ** សេចក្ដីថា កងទ័ព ត្រូវទ័ពសត្រូវឡោមព័ទ្ធ ធ្វើផ្លូវសញ្ចរទៅមកឲ្យដាច់ ។

បទថា **បលិពុទ្ធោ** គឺត្រូវបច្ចាមិត្រក្ដី ឥស្សរជនរារាំងក្ដី ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា ជា នោសញ្ញាវិមោក្ខ ជាអចិត្តកៈ ជាបណ្ណត្តិវជ្ជៈ ជាកាយកម្ម មានចិត្ត ៣ មាន វេទនា ៣ ដូច្នេះឯង ។

សេនាវាសកសិក្ខាបទ ចប់

# វិនយបិដក

## សិក្ខាបទទី ១០

[ ១៨៩ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលនៅក្នុងកងទ័ពអស់ពីរបីរាត្រី បាននាំគ្នាទៅកាន់ទីដែលគេច្បាំងគ្នាខ្លះ ទីគេត្រួតពលខ្លះ ទីតាំងនៅនៃកងទ័ពខ្លះ ទីសម្រាប់មើលគេចាត់ក្បួនកងទ័ពខ្លះ ។ មានឆព្វគ្គិយភិក្ខុមួយរូបទៅកាន់ទីដែលគេច្បាំង ហើយភិក្ខុនោះត្រូវសរ ។ មនុស្សទាំងឡាយក៏ឡកឡឺយឲ្យភិក្ខុនោះថា លោកម្ចាស់ លោកម្ចាស់ច្បាំងស្រួលឬទេ លោកបានខ្ទាច់ប៉ុន្មានហើយ កាលមនុស្សទាំងឡាយនោះ ចំអកចំអន់ឲ្យ ភិក្ខុនោះក៏អៀនអន់ មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រ មិនគួរនឹងនាំគ្នាមកមើលចម្បាំងសោះ ឯពួកយើងមកកាន់ចម្បាំង ក៏ព្រោះតែការចិញ្ចឹមជីវិត និងបុត្រភរិយា អំពើនេះមិនមែនជាលាភរបស់យើងទេ គឺទ្រព្យដែលពួកយើងបានមកឈ្មោះថា បានហើយដោយអាក្រក់ទេតើ ។ ភិក្ខុទាំងឡាយ បានឮពួកមនុស្សទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងទៅមើលចម្បាំងសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយទៅមើលចម្បាំង ពិតមែនឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស

ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំង-ឡាយ អ្នកពាល់គ្នាមិនគួរនឹងទៅមើលចម្បាំងទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា កាលបើភិក្ខុនៅក្នុងកងទ័ពកំណត់ពីរបីរាត្រីហើយ ទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៅនៃកងទ័ពក្តី ទីសម្រាប់គេចាត់ក្បួនទ័ពក្តី ត្រូវអាបត្តិបាចិត្តិយ ។

[ ១៩០ ] ត្រង់ពាក្យថា បើភិក្ខុនៅក្នុងកងទ័ពកំណត់ពីរបីរាត្រីហើយ សេចក្តីថា ភិក្ខុនៅក្នុងកងទ័ពបានត្រឹមពីរបីយប់ ។ ដែលហៅថា ទីដែលគេច្បាំងគ្នានោះ គឺទីដែលគេប្រហារគ្នា ។ ដែលហៅថា ទីដែលគេត្រួតពលនោះ គឺទីដែលគេរាប់ពលថា ពលដំរីមានប៉ុណ្ណេះ ពលសេះមានប៉ុណ្ណេះ ពលរថមានប៉ុណ្ណេះ ពលថ្មើរជើងមានប៉ុណ្ណេះ ។ ដែលហៅថា ទីតាំងនៅនៃកងទ័ពនោះ គឺពលដំរីនៅត្រង់កន្លែងនេះ ពលសេះនៅត្រង់កន្លែងនេះ ពលរថនៅត្រង់កន្លែងនេះ ពលថ្មើរជើងនៅត្រង់កន្លែងនេះ ។ ដែលហៅថា ក្បួនទ័ពនោះ គឺពួកសេនាដំរី ១ ពួកសេនាសេះ ១ ពួកសេនារថ ១ ពួកសេនាថ្មើរជើង ១ ។ ដំរីបី ហៅថា សេនាដំរីយ៉ាងតិចបំផុត ។ សេះបី ហៅថា ពួកសេនាសេះយ៉ាងតិចបំផុត ។ រថបី ហៅថា ពួកសេនារថយ៉ាងតិចបំផុត ។ បុរសបួននាក់ កាន់សរគ្រប់ដៃហៅថា ពួកសេនាថ្មើរជើងយ៉ាងតិចបំផុត ។

[១៩១] ភិក្ខុទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលះបង់ឧបចារៈនៃទីមើល ហើយក៏នៅមើលឃើញរឿយៗ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទៅដើម្បីមើលកងទ័ពមួយៗ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលះបង់ឧបចារៈនៃទីមើល ហើយក៏នៅមើលឃើញរឿយៗ ត្រូវអាបត្តិទុក្កដ ។

[១៩២] អាបត្តិមិនមានដល់ភិក្ខុដែលឈរមើលនៅក្នុងអារាម ដល់ភិក្ខុដែលឃើញចម្បាំងជាដើមដែលគេមកកាន់ទីដែលខ្លួនឈរក្តី អង្គុយក្តី ដេកក្តី ដល់ភិក្ខុដែលដើរទៅប្រទះឃើញតាមផ្លូវ ដល់ភិក្ខុដែលមានកិច្ច ( ត្រូវទៅ ) ហើយប្រទះឃើញ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់

អចេលកវគ្គជាគម្រប់ ៥ ចប់

### ឧទ្ទាននៃអចេលកវគ្គនោះមាន ១០ សិក្ខាបទ គឺ

| | | | |
|---|---|---|---|
| បូវសិក្ខាបទ | ១ | កថាសិក្ខាបទ | ១ |
| ឧបនន្ទ ៣ សិក្ខាបទ | | ឧបដ្ឋាកសិក្ខាបទ | ១ |
| មហានាមសិក្ខាបទ | ១ | បសេនទិសិក្ខាបទ | ១ |
| សេនាសិក្ខាបទ | ១ | វិទ្ធសិក្ខាបទ | ១ |

# អដ្ឋកថា
# អចេលកវគ្គទី ៥
# ឧយ្យោធិកសិក្ខាបទ

[ ១៨៩ ] ក្នុងសិក្ខាបទទី ១០ មានវិនិច្ឆ័យដូច្នេះថា ជនទាំងឡាយលើកគ្នាទៅច្បាំងគ្នា ក្នុងទីនេះ ព្រោះដូច្នោះ ទើបទីនោះ ឈ្មោះថា ទីលានចម្បាំង ។ ពាក្យថា **ឧយ្យោធិក** នេះ ជាឈ្មោះនៃទីប្រហារគ្នា ( យុទ្ធភូមិ ឬសមរភូមិ ) ។

ពួកជនរមែងស្គាល់ទីស្នាក់នៅរបស់ពលចម្បាំងក្នុងទីនេះ ដូច្នោះ ទើបទីនោះ ឈ្មោះថា ទីស្នាក់នៅនៃកងទ័ព សេចក្តីថា ទីកន្លែងត្រួតពល ។

ការរៀបចំក្បួនទ័ព ឈ្មោះថា សេនាព្យូហៈ ។ ពាក្យថា សេនាព្យូហៈ នេះជាឈ្មោះនៃការរៀបចំក្បួនទ័ព ។

ពាក្យថា កងទ័ពដំរីយ៉ាងតិច មានដំរី ៣ នោះ បានដល់ ដំរី ៣ មួយអន្លើនឹងទាហាន ១២ នាក់ ដូចពោលហើយខាងដើម ។ ក្នុងបទដ៏សេស ក៏មានន័យដូចគ្នានោះឯង ។ ពាក្យដ៏សេស មួយអន្លើដោយសមុដ្ឋានជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងឧយ្យុត្តសិក្ខាបទនោះឯង ។

ឧយ្យោធិកសិក្ខាបទ ចប់

អចេលកវគ្គទី ៥ ចប់បរិបូណ៌

តាមវណ្ណនានុក្រម

# ក្បាលទី ៣

## វិនយបិដក ចាលីប្រែ -២

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

**អនិយតកណ្ឌ សិក្ខាបទទី ១** .......... ........... ........ ........... ......... ២

អដ្ឋកថា

អលំកម្មនិយសិក្ខាបទ ...... ...... ...... ...... ...... ...... ......... ១១

សិក្ខាបទវិភង្គនៃអលំកម្មនិយសិក្ខាបទ ...... ...... ...... ...... ..... ១៣

បទភាជនីយនៃអលំកម្មនិយសិក្ខាបទ ...... ...... ...... ...... ...... ១៧

វិនយបិដក

**សិក្ខាបទទី ២** ......... ...... ...... ...... ...... ...... ...... ១៩

អដ្ឋកថា

នាលំកម្មនិយសិក្ខាបទ ...... ...... ...... ...... ...... ...... ......... ២៧

## វិនយបិដក ចាលីប្រែ -៣

**ចីវរវគ្គ សិក្ខាបទទី ១** ..... ......... .......... .......... ........ ............ ២៩

អដ្ឋកថា

បឋមកឋិនសិក្ខាបទ ...... ...... ...... ...... ...... ...... ......... ៣៦

សិក្ខាបទវិភង្គនៃបឋមកឋិនសិក្ខាបទ ...... ...... ...... ...... ..... ៣៩

អធិប្បាយកំណើតចីវរ ៦ ប្រភេទ ..... ...... ...... ...... ...... ......... ៤២

បទភាជនីយនៃបឋមកឋិនសិក្ខាបទ ...... ...... ...... ...... ..... ៤៩

វិនយបិដក

**សិក្ខាបទទី ២** ...... ...... ...... ...... ...... ...... ...... ៦៧

អដ្ឋកថា

ឧទោសិតសិក្ខាបទ ...... ...... ...... ...... ...... ...... ......... ៧៨

សិក្ខាបទវិភង្គនៃឧទ្ទោសិតសិក្ខាបទ ...... ...... ...... ...... ..... ៨០
បទភាជនីយនៃឧទ្ទោសិតសិក្ខាបទ ...... ...... ...... ...... ..... ៨១

វិនយបិដក

**សិក្ខាបទទី ៣** ......... ............... ............. ............ .............. ....... ៩២

អដ្ឋកថា

**ចីវរវគ្គទី១ សិក្ខាបទទី ៣** ............. ............... .............. .................. ៩៩
តតិយកឋិនសិក្ខាបទ

វិនយបិដក

**សិក្ខាបទទី ៤** ...... ...... ...... ...... ...... ...... ...... ១០៣

អដ្ឋកថា

បុរាណចីវរធោវាបនសិក្ខាបទ ..... ...... ...... ...... ...... ......... ១០៨
សិក្ខាបទវិភង្គនៃបុរាណចីវរធោវាបនសិក្ខាបទ ...... ...... ......... ១០៨
បទភាជនីយនៃបុរាណចីវរធោវាបនសិក្ខាបទ ...... ...... ......... ១១១

វិនយបិដក

**សិក្ខាបទទី ៥** ...... ...... ...... ...... ...... ...... ...... ១១៥

អដ្ឋកថា

ចីវរបដិគ្គហណសិក្ខាបទ ..... ...... ...... ...... ...... ......... ១២១
សិក្ខាបទវិភង្គនៃចីវរបដិគ្គហណសិក្ខាបទ ...... ...... ......... ១២៣
បទភាជនីយនៃចីវរបដិគ្គហណសិក្ខាបទ ...... ...... ......... ១២៤

វិនយបិដក

**សិក្ខាបទទី ៦** ...... ...... ...... ...... ...... ...... ...... ១២៦

អដ្ឋកថា

អញ្ញាតកវិញ្ញត្តិសិក្ខាបទ ..... ...... ...... ...... ...... ......... ១៣៣

វិនយបិដក

**សិក្ខាបទទី ៧** ...... ...... ...... ...... ...... ...... ...... ១៤១

អដ្ឋកថា

តទុត្តរិសិក្ខាបទ ...... ...... ...... ...... ...... ...... ...... ១៤៥

វិនយបិដក

**សិក្ខាបទទី ៨** ...... ...... ...... ...... ...... ...... ...... ១៤៩

អដ្ឋកថា

បឋមឧបក្ខដសិក្ខាបទ .... ...... ...... ...... ...... ...... ១៥៤

វិនយបិដក

**សិក្ខាបទទី ៩** ...... ...... ...... ...... ...... ...... ...... ១៦០

អដ្ឋកថា

ទុតិយឧបក្ខដសិក្ខាបទ .... ...... ...... ...... ...... ...... ១៦៥

វិនយបិដក

**សិក្ខាបទទី ១០** .... ...... ...... ...... ...... ...... ១៦៦

អដ្ឋកថា

រាជសិក្ខាបទ ....... ...... ...... ...... ...... ...... ...... ១៧៥

វិនយបិដក

**កោសិយវគ្គ សិក្ខាបទទី ១** ........... ........... ............ ....... ....... ១៩៩

អដ្ឋកថា

កោសិយសិក្ខាបទ ...... ...... ...... ...... ...... ...... ២០២

វិនយបិដក

**សិក្ខាបទទី ២** ....... ..... ...... ...... ...... ...... ២០៣

អដ្ឋកថា

សុទ្ធកាឡកសិក្ខាបទ ...... ...... ...... ...... ...... ...... ២០៦

វិនយបិដក

**សិក្ខាបទទី ៣** ....... ..... ...... ...... ...... ...... ២០៧

អដ្ឋកថា

ទេ្វភាគសិក្ខាបទ ...... ...... ...... ...... ...... ...... ២១០

វិនយបិដក

**សិក្ខាបទទី ៤** ....... ..... ...... ...... ...... ...... ២១១

អដ្ឋកថា

ធព្វស្សសិក្ខាបទ ...... ...... ...... ...... ...... ...... ២១៧

វិនយបិដក

**សិក្ខាបទទី ៥** ....... ..... ...... ...... ...... ...... ២១៩

អដ្ឋកថា

និសីទនសន្ថតសិក្ខាបទ ...... ...... ...... ...... ...... ...... ២២៧

វិនយបិដក

**សិក្ខាបទទី ៦** ....... ..... ...... ...... ...... ...... ២៣២

អដ្ឋកថា

ឯឡកលោមសិក្ខាបទ ...... ...... ...... ...... ...... ...... ២៣៦

វិនយបិដក

**សិក្ខាបទទី ៧** ....... ..... ...... ...... ...... ...... ២៤០

អដ្ឋកថា

ឯឡកលោមធោវាបនសិក្ខាបទ ...... ...... ...... ...... ...... ...... ២៤៥

វិនយបិដក

**សិក្ខាបទទី ៨** ....... ..... ...... ...... ...... ...... ២៤៦

អដ្ឋកថា

រូបិយសិក្ខាបទ ...... ...... ...... ...... ...... ...... ២៥១

សិក្ខាបទវិភង្គនៃរូបិយសិក្ខាបទ ...... ...... ...... ...... ...... ...... ២៥១

បទភាជនីយនៃរូបិយសិក្ខាបទ ...... ...... ...... ...... ...... ...... ២៦៤

វិនយបិដក

សិក្ខាបទទី ៩ ....... ..... ...... ...... ...... ...... ២៦៦

អដ្ឋកថា

រូបិយសំវោហារសិក្ខាបទ ...... ...... ...... ...... ...... ...... ២៧១

សិក្ខាបទវិភង្គនៃរូបិយសំវោហារសិក្ខាបទ ... ...... ...... ...... ...... ២៧១

បទភាជនីយនៃរូបិយសំវោហារសិក្ខាបទ .... ...... ...... ...... ...... ២៧២

វិនយបិដក

សិក្ខាបទទី ១០ .. ..... ...... ...... ...... ...... ២៧៨

អដ្ឋកថា

កយវិក្កយសិក្ខាបទ ...... ...... ...... ...... ...... ...... ២៨៣

សិក្ខាបទវិភង្គនៃកយវិក្កយសិក្ខាបទ ... ...... ...... ...... ...... ២៨៣

បទភាជនីយនៃកយវិក្កយសិក្ខាបទ .... ...... ...... ...... ...... ២៨៧

វិនយបិដក

**បត្តវគ្គ** សិក្ខាបទទី ១ .......... ............ .......... ......... ......... ២៩០

អដ្ឋកថា

បត្តសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ២៩៧

វិនយបិដក

សិក្ខាបទទី ២ ...... ...... ..... ...... ...... ...... ...... ៣០៨

អដ្ឋកថា

ឩនបញ្ចពន្ធនសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៣២០

វិនយបិដក

សិក្ខាបទទី ៣ ...... ...... ..... ...... ...... ...... ...... ៣២៥

អដ្ឋកថា

ភេសជ្ជសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៣៣៥

សិក្ខាបទវិភង្គនៃភេសជ្ជសិក្ខាបទ ...... ...... ...... ..... ...... ........ ៣៣៦

បទភាជនីយនៃភេសជ្ជសិក្ខាបទ ...... ...... ...... ..... ...... ........ ៣៥២

វិនយបិដក

សិក្ខាបទទី ៤ ...... ...... ..... ...... ...... ...... ...... ៣៥៦

អដ្ឋកថា

វស្សិកសាដិកសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៣៦១

សិក្ខាបទវិភង្គនៃវស្សិកសាដិកសិក្ខាបទ .... ...... ..... ...... ........ ៣៦១

បទភាជនីយនៃវស្សិកសាដិកសិក្ខាបទ ..... ...... ..... ...... ........ ៣៦៥

វិនយបិដក

សិក្ខាបទទី ៥ ...... ...... ..... ...... ...... ...... ...... ៣៦៩

អដ្ឋកថា

ចីវរអច្ឆិន្ទនសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៣៧៣

សិក្ខាបទវិភង្គនៃចីវរអច្ឆិន្ទនសិក្ខាបទ ....... . ...... ..... ...... ........ ៣៧៣

បទភាជនីយនៃចីវរអច្ឆិន្ទនសិក្ខាបទ ..... ...... ..... ...... ........ ៣៧៤

វិនយបិដក

សិក្ខាបទទី ៦ ...... ...... ..... ...... ...... ...... ...... ៣៧៧

អដ្ឋកថា

សុត្តវិញ្ញត្តិសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៣៨១

វិនយបិដក

សិក្ខាបទទី ៧ ...... ...... ..... ...... ...... ...... ...... ៣៨៨

អដ្ឋកថា

មហាបេសការសិក្ខាបទ ...... ...... ...... ...... ...... ...... ៣៩៥

វិនយបិដក

សិក្ខាបទទី ៨ ...... ...... ..... ...... ...... ...... ...... ៣៩៧

អដ្ឋកថា

អច្ចេកចីវរសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤០២

វិនយបិដក

សិក្ខាបទទី ៩ ...... ...... ..... ...... ...... ...... ...... ៤០៦

អដ្ឋកថា

សាសង្កសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤១១

វិនយបិដក

សិក្ខាបទទី ១០ ...... ...... ..... ...... ...... ...... ...... ៤១៦

អដ្ឋកថា

បរិណតសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤២១

វិនយបិដក

មុសាវាទវគ្គ សិក្ខាបទទី ១ ... ......... ......... ........ ........ ៤២៦

អដ្ឋកថា

មុសាវាទសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤៣៨

សិក្ខាបទវិភង្គនៃមុសាវាទសិក្ខាបទ .......... ...... ...... ......... ៤៤០

បទភាជនីយនៃមុសាវាទសិក្ខាបទ .......... ...... ...... ......... ៤៤១

វិនយបិដក

សិក្ខាបទទី ២ ...... ...... ...... ...... ...... ...... ...... ... ៤៤៦

អដ្ឋកថា

ឱមសវាទសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤៧៥

សិក្ខាបទវិភង្គនៃឱមសវាទសិក្ខាបទ .......... ...... ...... ......... ៤៧៦

បទភាជនីយនៃឱមសវាទសិក្ខាបទ .......... ...... ...... ......... ៤៧៧

វិនយបិដក

សិក្ខាបទទី ៣ ...... ...... ...... ...... ...... ...... .......... ៤៨១

អដ្ឋកថា

បេសុញ្ញវាទសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤៩១

វិនយបិដក

សិក្ខាបទទី ៤ ...... ..... ...... ...... ...... ...... ......... ៤៩៤

អដ្ឋកថា

បទសោធម្មសិក្ខាបទ ..... ...... ...... ...... ...... ...... ...... ៤៩៧

វិនយបិដក

សិក្ខាបទទី ៥ ...... ..... ...... ...... ...... ...... ......... ៥០៥

អដ្ឋកថា

សហសេយ្យកសិក្ខាបទ ........ ...... ...... ...... ...... ...... ៥០៩

វិនយបិដក

សិក្ខាបទទី ៦ ...... ..... ...... ...... ...... ...... ......... ៥២១

អដ្ឋកថា

ទុតិយសហសេយ្យកសិក្ខាបទ .... ...... ...... ...... ...... ...... ៥២៨

វិនយបិដក

សិក្ខាបទទី ៧ ...... ..... ...... ...... ...... ...... ......... ៥៣០

អដ្ឋកថា

ធម្មទេសនាសិក្ខាបទ .... ...... ...... ...... ...... ...... .......... ៥៣៦

វិនយបិដក

សិក្ខាបទទី ៨ ...... ..... ...... ...... ...... ......... ......... ៥៣៩

អដ្ឋកថា

ភូតារោចនសិក្ខាបទ .... ...... ...... ...... ...... ...... .......... ៥៥៩

វិនយបិដក

សិក្ខាបទទី ៩ ...... ..... ...... ...... ...... ...... ......... ៥៦២

អដ្ឋកថា

ទុដ្ឋុល្លារោចនសិក្ខាបទ .... ...... ...... ...... ...... ...... .......... ៥៦៧

សិក្ខាបទវិភង្គនៃទុដ្ឋុល្លារោចនសិក្ខាបទ .......... ...... ...... ......... ៥៦៧

បទភាជនីយនៃទុជ្ជល្លាភេចនសិក្ខាបទ .......... ...... ...... ......... ៥៦៩

វិនយបិដក

សិក្ខាបទទី ១០ ...... ..... ...... ...... ...... ...... ......... ៥៧១

អដ្ឋកថា

បឋវីខណនសិក្ខាបទ .... ...... ...... ...... ...... ...... .......... ៥៧៥

សិក្ខាបទវិភង្គនៃបឋវីខណនសិក្ខាបទ .......... ...... ...... ......... ៥៧៥

បទភាជនីយនៃបឋវីខណនសិក្ខាបទ .......... ...... ...... ......... ៥៨០

វិនយបិដក

ភូតគាមវគ្គ សិក្ខាបទទី ១ ...... ......... .......... .......... ....... ........ ៥៨៤

អដ្ឋកថា

ភូតគាមសិក្ខាបទ ...... ...... ...... ...... ...... .......... ៥៨៨

សិក្ខាបទវិភង្គនៃភូតគាមសិក្ខាបទ .......... ...... ...... ......... ៥៩១

បទភាជនីយនៃភូតគាមសិក្ខាបទ .......... ...... ...... ......... ៥៩៤

វិនយបិដក

សិក្ខាបទទី ២ ... ..... ...... ...... ...... ...... ......... ៦០៨

អដ្ឋកថា

អញ្ញវាទសិក្ខាបទ .... ...... ...... ...... ...... ...... .......... ៦១៥

វិនយបិដក

សិក្ខាបទទី ៣ ... ..... ...... ...... ...... ...... ......... ៦១៩

អដ្ឋកថា

ឧជ្ឈាបនកសិក្ខាបទ ...... ...... ...... ...... ...... .......... ៦២៤

សិក្ខាបទវិភង្គនៃឧជ្ឈាបនកសិក្ខាបទ .......... ...... ...... ......... ៦២៥

បទភាជនីយនៃឧជ្ឈាបនកសិក្ខាបទ .......... ...... ...... ......... ៦២៦

វិនយបិដក

សិក្ខាបទទី ៤ ... ..... ...... ...... ...... ...... ......... ៦២៨

### អដ្ឋកថា

*ភូតគាមវគ្គ*

*បឋមសេនាសនសិក្ខាបទ* ......... ...... ...... ...... .......... ៦៣៤

*សិក្ខាបទវិភង្គនៃបឋមសេនាសនសិក្ខាបទ* . ...... ...... ......... ៦៣៧

*បទភាជនីយនៃបឋមសេនាសនសិក្ខាបទ* ..... ...... ...... ......... ៦៤២

### វិនយបិដក

**សិក្ខាបទទី ៥** ... ..... ...... ...... ...... ...... ......... ៦៤៥

### អដ្ឋកថា

*ទុតិយសេនាសនសិក្ខាបទ* ...... ...... ...... ...... .......... ៦៥០

*សិក្ខាបទវិភង្គនៃទុតិយសេនាសនសិក្ខាបទ* ......... ...... ...... ......... ៦៥០

*បទភាជនីយនៃទុតិយសេនាសនសិក្ខាបទ* ......... ...... ...... ......... ៦៥១

# វិនយបិដក បាលីប្រែ -៤

**សិក្ខាបទទី ៦** ... ..... ...... ...... ...... ...... ......... ៦៥៧

### អដ្ឋកថា

*អនុប្បខជ្ជសិក្ខាបទ* ...... ...... ...... ...... ...... .......... ៦៦០

*សិក្ខាបទវិភង្គនៃអនុប្បខជ្ជសិក្ខាបទ* ......... ...... ...... ......... ៦៦០

*បទភាជនីយនៃអនុប្បខជ្ជសិក្ខាបទ* ......... ...... ...... ......... ៦៦១

### វិនយបិដក

**សិក្ខាបទទី ៧** ... ..... ...... ...... ...... ...... ......... ៦៦៤

### អដ្ឋកថា

*និក្កឌ្ឍនសិក្ខាបទ* ...... ...... ...... ...... ...... .......... ៦៦៩

*សិក្ខាបទវិភង្គនៃនិក្កឌ្ឍនសិក្ខាបទ* ......... ...... ...... ......... ៦៦៩

*បទភាជនីយនៃនិក្កឌ្ឍនសិក្ខាបទ* ......... ...... ...... ......... ៦៧០

### វិនយបិដក

**សិក្ខាបទទី ៨** ... ..... ...... ...... ...... ...... ......... ៦៧២

អដ្ឋកថា

វេហាសកុដិសិក្ខាបទ ...... ...... ...... ...... ...... .......... ៦៧៥

វិនយបិដក

**សិក្ខាបទទី ៩** ... ..... ...... ...... ...... ...... ......... ៦៧៨

អដ្ឋកថា

មហល្លកវិហារសិក្ខាបទ ...... ...... ...... ...... ...... .......... ៦៨២

វិនយបិដក

**សិក្ខាបទទី ១០** ... ..... ...... ...... ...... ...... ......... ៦៨៨

អដ្ឋកថា

សប្បាណកសិក្ខាបទ ...... ...... ...... ...... ...... .......... ៦៩១

វិនយបិដក

**ឱវាទវគ្គ សិក្ខាបទទី ១** .......... ........ ........... ........... ៦៩៣

អដ្ឋកថា

ឱវាទសិក្ខាបទ ...... ...... ...... ...... ...... .......... ៧០៥

សិក្ខាបទវិភង្គនៃឱវាទសិក្ខាបទ ......... ......... ...... ...... ......... ៧១៥

បទភាជនីយនៃឱវាទសិក្ខាបទ .......... ........ ...... ...... ......... ៧១៦

វិនយបិដក

**សិក្ខាបទទី ២** .......... ...... ...... ...... ...... ......... ៧៣៧

អដ្ឋកថា

អត្ថង្គតសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៤១

វិនយបិដក

**សិក្ខាបទទី ៣** .......... ...... ...... ...... ...... ......... ៧៤៥

អដ្ឋកថា

កិក្ខុនីឧបស្សយសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៥០

វិនយបិដក

**សិក្ខាបទទី ៤** .......... ...... ...... ...... ...... ......... ៧៥៣

អដ្ឋកថា

អាមិសសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៥៧

វិនយបិដក

**សិក្ខាបទទី ៥** .......... ...... ...... ...... ...... ......... ៧៥៩

អដ្ឋកថា

ចីវរទានសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៦៣

វិនយបិដក

**សិក្ខាបទទី ៦** .......... ...... ...... ...... ...... ......... ៧៦៤

អដ្ឋកថា

ចីវរសិព្វនសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៦៨

វិនយបិដក

**សិក្ខាបទទី ៧** .......... ...... ...... ...... ...... ......... ៧៧១

អដ្ឋកថា

សំវិធានសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៧៦

សិក្ខាបទវិភង្គនៃសំវិធានសិក្ខាបទ ......... ......... ...... ...... ......... ៧៧៦

បទភាជនីយនៃសំវិធានសិក្ខាបទ .......... ........ ...... ...... ......... ៧៧៩

វិនយបិដក

**សិក្ខាបទទី ៨** .......... ...... ...... ...... ...... ......... ៧៨២

អដ្ឋកថា

នាវាភិរុហនសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៨៦

វិនយបិដក

**សិក្ខាបទទី ៩** .......... ...... ...... ...... ...... ......... ៧៨៩

អដ្ឋកថា

បារិបាចនសិក្ខាបទ ...... ...... ...... ...... ...... .......... ៧៩៤

វិនយបិដក

**សិក្ខាបទទី ១០** .......... ...... ...... ...... ...... ......... ៧៩៧

អដ្ឋកថា

រហោនិសជ្ជសិក្ខាបទ ...... ...... ...... ...... ...... .......... ៨០០

វិនយបិដក

**ភោជនវគ្គ សិក្ខាបទទី ១** ....... .......... .......... ........ ......... ៨០១

អដ្ឋកថា

អាវសថបិណ្ឌសិក្ខាបទ ...... ...... ...... ...... ...... .......... ៨០៦

វិនយបិដក

**សិក្ខាបទទី ២** .......... ...... ...... ...... ...... ......... ៨១០

អដ្ឋកថា

គណភោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៨២០

វិនយបិដក

**សិក្ខាបទទី ៣** .......... ...... ...... ...... ...... ......... ៨៣៣

អដ្ឋកថា

បរម្បរភោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៨៤១

វិនយបិដក

**សិក្ខាបទទី ៤** .......... ...... ...... ...... ...... ......... ៨៤៦

អដ្ឋកថា

កាណមាតាសិក្ខាបទ ...... ... ...... ...... ...... .......... ៨៥៣

សិក្ខាបទវិភង្គនៃកាណមាតាសិក្ខាបទ ......... ......... ...... ...... ......... ៨៥៤

បទភាជនីយនៃភាណមាតាសិក្ខាបទ ...... ........ ...... ...... ......... ៨៥៦

**វិនយបិដក**

**សិក្ខាបទទី ៥** .......... ...... ...... ...... ...... ......... ៨៥៨

**អដ្ឋកថា**

បឋមបវារណាសិក្ខាបទ ...... ...... ...... ...... ...... .......... ៨៦៤

**វិនយបិដក**

**សិក្ខាបទទី ៦** .......... ...... ...... ...... ...... ......... ៨៨៦

**អដ្ឋកថា**

ទុតិយបវារណាសិក្ខាបទ ...... ...... ...... ...... ...... .......... ៨៩១

**វិនយបិដក**

**សិក្ខាបទទី ៧** .......... ...... ...... ...... ...... ......... ៨៩៣

**អដ្ឋកថា**

វិកាលភោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៨៩៦

**វិនយបិដក**

**សិក្ខាបទទី ៨** .......... ...... ...... ...... ...... ......... ៩០៨

**អដ្ឋកថា**

សន្និធិការកសិក្ខាបទ ...... ...... ...... ...... ...... .......... ៩១២

**វិនយបិដក**

**សិក្ខាបទទី ៩** .......... ...... ...... ...... ...... ......... ៩១៧

**អដ្ឋកថា**

បណីតភោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៩២២

**វិនយបិដក**

**សិក្ខាបទទី ១០** .......... ...... ...... ...... ...... ......... ៩២៧

**អដ្ឋកថា**

ទន្តបោណសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៣១

សិក្ខាបទវិភង្គនៃឧទកទន្តបោណសិក្ខាបទ ....... ........ ........ .......... ........ ៩៣៣
ឧគ្គហិតវត្ថុ ...... ...... ...... ...... ...... .......... ៩៤៦

វិនយបិដក

**អចេលកវគ្គ សិក្ខាបទទី ១**.......... ........ .............. ...... ......... ៩៥៧

អដ្ឋកថា

អចេលកសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៦២

វិនយបិដក

**សិក្ខាបទទី ២** ...... ...... .... ...... ...... ...... ...... ......... ៩៦៤

អដ្ឋកថា

ឧយ្យោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៦៨

វិនយបិដក

**សិក្ខាបទទី ៣** ...... ...... .... ...... ...... ...... ...... ......... ៩៧០

អដ្ឋកថា

សភោជនសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៧៤

វិនយបិដក

**សិក្ខាបទទី ៤** ...... ...... .... ...... ...... ...... ...... ......... ៩៧៦
**សិក្ខាបទទី ៥** ...... ...... .... ...... ...... ...... ...... ......... ៩៧៩

អដ្ឋកថា

បឋម និងទុតិយ អនិយតសិក្ខាបទ ...... ...... ...... ...... ......... ៩៨២

វិនយបិដក

**សិក្ខាបទទី ៦** ...... ...... .... ...... ...... ...... ...... ........ ៩៨៣

អដ្ឋកថា

ចារិត្តសិក្ខាបទ ...... ...... ..... ...... ...... ...... ...... ......... ៩៩១

វិនយបិដក

**សិក្ខាបទទី ៧** ...... ...... .... ...... ...... ...... ...... ........ ៩៩៣

អដ្ឋកថា

មហានាមសិក្ខាបទ ... ..... ...... ...... ...... ...... .......... ១០០១

វិនយបិដក

**សិក្ខាបទទី ៨** ... ...... .... ...... ...... ...... ...... .. ១០០៣

អដ្ឋកថា

ឧយ្យុត្តសិក្ខាបទ ... ..... ...... ...... ...... ...... .......... ១០០៧

វិនយបិដក

**សិក្ខាបទទី ៩** ... ...... .... ...... ...... ...... ...... .. ១០០៩

អដ្ឋកថា

សេនាវាសសិក្ខាបទ ... ..... ...... ...... ...... ...... .......... ១០១២

វិនយបិដក

**សិក្ខាបទទី ១០** ... ...... .... ...... ...... ...... ...... .. ១០១៣

អដ្ឋកថា

ឧយ្យោធិកសិក្ខាបទ ... ..... ...... ...... ...... ...... .......... ១០១៦